# អដ្ឋកថា បដិសម្ភិទាមគ្គ

## ឈ្មោះ សទ្ធម្មប្បកាសិនី

## នៃព្រះសុត្តន្តបិដក ខុទ្ទកនិកាយ

## ទុតិយភាគ_តតិយភាគ

# ៧០_៧១

ពុទ្ធសករាជ ២៥៥១

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

***សុត្ត*** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

***គេយ្យ*** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

***វេយ្យាករណ*** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

***គាថា*** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

***ឧទាន*** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

***ឥតិវុត្តក*** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

***ជាតក*** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។



***អព្ភូតធម៌*** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

***វេទល្ល*** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងរីករាយ ព្រមទាំងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

***ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម***
***ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត***
***មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល***
***បណ្ឌិតគប្បីដឹងបាន ។***

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នារបស់មនុស្សផ្សេងគ្នាក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

**២ ទ្រង់សម្តែងធម៌មានហេតុផល** ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

**៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍ សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះដោយព្រះញាណទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទតែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិ បញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌-វិន័យតាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិ ផ្សេង ៗ គ្នា រហូតមាននិកាយ ដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

**១ ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

**២ សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ



សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថា មិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកយល់ចំពោះអ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុសនោះឯង ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបានយ៉ាងណា ការអធិប្បាយធម៌ ជំទាស់នឹងព្រះត្រៃបិដកក៏មិនបានដូចគ្នា ដូច្នោះ ។

**សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ**

**របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ**

សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

**ក្រុមរៀបរៀងព្រះអដ្ឋកថា**

---



## និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះ ធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្ញាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬមិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុស-ត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ឈ្មោះថា **កាកណ្ឌកៈ** បានស្ដាប់ វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរស របស់ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០

អង្គ ក្នុងចំណោមភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញ៉ាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌-វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូល អាចារ្យសង្ឃិកនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយ គោកុ-លិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទកើតឡើងហើយ ក្នុងវវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធ-សករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហា-សង្ឃិកៈ ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តចរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយ កស្សបិកៈ



ទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈ ផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈដែលជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីព្រះអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )



## ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យបានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះពុទ្ធឃោសៈតែងព្រះគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការរកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យ ជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ពានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។

តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍និងបណ្ឌិតសួរបាន ដូច្នេះព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ

គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវមកដល់វត្តមួយ ដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះបានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថាពុទ្ធមន្ត ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជា ឧបសម្បទាក្នុងព្រះពុទ្ធ-សាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ក៏បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ ញាណោទ័យទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយតែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត ( ឈ្មោះដូចអគ្គសាវក )



ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីបត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅ រហូតដល់កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុថៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ក្នុងពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈនៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាជាមុនសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធ-ឃោសៈ បានរចនាបករណ៍ឈ្មោះវិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ

រហូតដល់ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធ-ឃោសៈ ក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀត គម្រប់ ៣ ដង បន្ទាប់មកទេវតាក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើមបទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយ ក្នុងកន្លែងណានីមួយឡើយ គឺ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ និងសោមនស្សសាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសា-មគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។



អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា ជាអដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនាដែលព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈ ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផុះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈ បានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ: និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែងចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោក ។



# ប្រវត្តិព្រះធម្មសេនាបតី

ព្រះសារីបុត្តត្ថេរ មុននឹងចូលមកបួសក្នុងព្រះពុទ្ធសាសនា មានឈ្មោះថា ឧបតិស្ស: ជាបុត្តរបស់ព្រាហ្មណ៍ឈ្មោះ វង្គន្ត: ដែលជាមេស្រុកក្នុងស្រុកមួយឈ្មោះ ឧបតិស្សគ្រាម ជួនកាលហៅថា “ នាលក: ” ឬ “ នាលន្ទា ” តាំងនៅមិនឆ្ងាយពីក្រុងរាជគ្រឹះ , មានមាតាឈ្មោះ សារី ហើយត្រកូលរបស់លោក មានទ្រព្យប្រមាណ ៥៦០ កោដិកហាបណ: , ព្រះសារីបុត្តដែលមានឈ្មោះថា សារីបុត្ត ព្រោះហៅតាមឈ្មោះរបស់មាតា ឬន័យម្យ៉ាងទៀត ពាក្យថា សារីបុត្ត ប្រែថា បុត្ររបស់អ្នកលេងបាស្កា តែកាលលោកឧបសម្បទាហើយ មិត្តសព្រហ្មចារីនិយមហៅលោកថា “ សារីបុត្ត ” ឯឈ្មោះដើម ឧបតិស្ស: ក៏បាត់ទៅ ។

ព្រះសារីបុត្តមានប្អូនប្រុស ៣ នាក់ គឺ ១. ចុន្ទ: ២. ឧបសេន ៣ . រេវត: និងមានប្អូនស្រី ៣ នាក់ គឺ ១ . ចាលា ២ . ឧបចាលា ៣ . សីសុបចាលា រួមទាំងខ្លួនលោកជា ៧ នាក់ និងសុទ្ធតែជាព្រះអរហន្ត បានបរិនិព្វានហើយ ក្នុងសម័យព្រះពុទ្ធបរមគ្រូនៃយើងនេះ ។

កាលលោកនៅជាបរិព្វាជក ជាអ្នកបួសក្រៅព្រះពុទ្ធសាសនា ដើរស្វែងរកមោក្ខធម៌ជាមួយសម្លាញ់ កោលិត: “ ព្រះមហាមោគ្គល្លាន ” ក៏បានជួបនឹងព្រះអស្សជិត្ថេរ និមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ កាលបានចង្ហាន់ហើយ ក៏ត្រឡប់ដើម្បីរកកន្លែងឆាន់ លុះជ្រាបថា លោកប្រាថ្នានឹងគង់ឆាន់ ក៏ក្រាលអាសនៈរបស់ខ្លួនប្រគេន ក្រោយវេលាដែលព្រះថេរៈឆាន់ហើយ ក៏

ប្រគេនទឹកកំសៀវរបស់ខ្លួនទៀត កាលធ្វើអាចរិយវត្តដូច្នេះហើយ ទើបប្រាស្រ័យដោយពាក្យពេចន៍យ៉ាងពីរោះនឹងព្រះអស្សជិត្ថេរ បានសួរថា លោកម្ចាស់ឥន្ទ្រីយ៍របស់លោកផូរផង់ក្រៃលែង ពណ៌សម្បុរក៏បរិសុទ្ធ លោកតាំងចិត្តបួសចំពោះអ្នកណា អ្នកណាជាសាស្តារបស់លោក លោកពេញចិត្តក្នុងធម៌របស់អ្នកណា ? ព្រះអស្សជិត្ថេរឆ្លើយថា មានព្រះសមណៈជាបុត្រសក្យរាជ ចេញបួសពីសក្យៈត្រកូល យើងតាំងចិត្តបួសចំពោះព្រះមានព្រះភាគនោះ ព្រះមាន-ព្រះភាគអង្គនោះ ជាសាស្តារបស់យើង យើងពេញចិត្តក្នុងធម៌របស់ព្រះមាន-ព្រះភាគអង្គនោះ ។

ឧបតិស្សបរិព្វាជក សួរដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំងថា សាស្តារបស់លោកប្រៀនប្រដៅយ៉ាងណា ? , អស្សជិត្ថេរពិចារណាថា ជាប្រក្រតីពួកបរិព្វាជក រមែងជាបដិបក្ខចំពោះព្រះពុទ្ធសាសនា យើងនឹងសម្តែងជម្រៅព្រះពុទ្ធសាសនាដល់បរិព្វាជកនេះ គិតដូច្នេះហើយ ក៏បានប្រកាសខ្លួនថា យើងជាអ្នកបួសថ្មី ទើបនឹងមកកាន់ធម្មវិន័យនេះ យើងមិនអាចសម្តែងធម៌ឲ្យពិស្តារបានទេ តែយើងនឹងសម្តែងបានចំពោះតែខ្លឹមសារប៉ុណ្ណោះ ។ ឧបតិស្សៈគិតថា យើងឈ្មោះថា ឧបតិស្សៈ ជាអ្នកអាចដឹងច្បាស់នូវធម៌តិច ឬច្រើន បានដោយន័យទាំងរយទាំងពាន់ គិតដូច្នេះហើយ ទើបពោលថា លោកម្ចាស់សម្តែងច្រើនឬតិចក៏ដោយចុះ សូមសម្តែងតែវត្ថុដែលមានប្រយោជន៍ប៉ុណ្ណោះ ខ្ញុំត្រូវការខ្លឹមសារជាសំខាន់ ការសម្តែងព្យញ្ជនៈច្រើន ឬពាក្យនិយាយច្រើន មានប្រយោជន៍អ្វីទៅ ។

កាលឧបតិស្សបរិព្វាជកពោលយ៉ាងនេះ ព្រះអស្សជិត្ថេរទើបបានពោលគាថាថា ៖



**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ**

**តេសញ្ច យោ និរោធោ ច ឯវំ វាទីមហាសមណោតិ**

ធម៌ទាំងឡាយកើតអំពីហេតុ ព្រះតថាគតទ្រង់សម្តែងនូវហេតុនៃធម៌នោះ និងការរលត់នៃធម៌នោះ ព្រះមហាសមណៈទ្រង់ទូន្មានយ៉ាងនេះ ។

ឧបតិស្សៈបានស្តាប់ធម្មកថានេះ ត្រឹមតែ ២ បាទដំបូង ក៏តាំងនៅក្នុងសោតាបត្តិមគ្គប្រកបដោយពាន់ន័យ លុះបានស្តាប់ពីរបាទចុងក្រោយ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ល។

ក្នុងតំណែងជាអគ្គសាវកទី ១ និងជាកំពូលលើសភិក្ខុទាំងឡាយ ផ្នែកខាងបញ្ញា ព្រះសារីបុត្តបានតាំងសេចក្តីប្រាថ្នាអស់កាលដ៏យូរ ប្រមាណ ១ អសង្ខេយ្យនិង ១ សែនកប្ប ក្នុងសម័យព្រះអនោមទស្សីសម្មាសម្ពុទ្ធជាម្ចាស់បានប្រារព្ធនូវបុណ្យធំមួយកាលដែលលោកនៅជាតាបស ឈ្មោះថា សរទតាបសដោយឈរបាំងស្វេតឆត្រផ្កាឈើធំ ថ្វាយចំពោះព្រះអនោមទស្សីសម្មាសម្ពុទ្ធក្នុងពេលព្រះអង្គចូលនិរោធសមាបត្តិរហូត ៧ ថ្ងៃ មិនបរិភោគអាហារអ្វីឡើយ ។

ព្រះសារីបុត្តត្ថេរ ជាអ្នកមានបដិភាណ គឺ បញ្ញា ដោះស្រាយរាល់បញ្ហាចំពោះមុខបានយ៉ាងល្អ និងឆាប់រហ័ស ដែលមានចារឹកទុកក្នុងបាលី គម្ពីរសំយុត្តនិកាយខន្ធវគ្គ ក្នុងរឿងសូចិបរិព្វាជិកាសួរអំពីការបរិភោគ ឱន ងើយផាកច្វេង.ស្តាំ មើលទៅទិសតូច ទិសធំ ។ល។

ចំណែករឿងទាក់ទងនឹងកតញ្ញូកតវេទី គឺ អ្នកដឹងឧបការគុណដល់អ្នកដទៃធ្វើហើយ មានចារឹកទុកថា ព្រះសារីបុត្តប្រាកដកិត្តិគុណថា ជាអ្នកមានកតញ្ញូកតវេទីរកអ្នកស្មើគ្មាន ដូចមានដំណាលទុកក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃព្រាហ្មណវគ្គ បញ្ជាក់ថា ចាប់តាំងពីលោកបានស្តាប់ធម៌អំពីព្រះអស្សជិត្ថេរបាន

បានទូវធម្មចក្ខុ និងបានបួសជាភិក្ខុហើយ លុះបានជ្រាបដំណឹងថា ព្រះអស្សជិ-ត្ថេរជាអាចារ្យនៅក្នុងទិសណា មុននឹងសឹង លោកថ្វាយបង្គំទៅទិសនោះ ទើបសឹងព្រមទាំងងាកសិរសាទៅទិសនោះ ។ល។

ការរំលត់ខន្ធបរិនិព្វានរបស់ព្រះសារីបុត្ត ការចាត់ចែងពិធីបុណ្យ មានទេវតា និងមនុស្សទាំងឡាយរៀបចំឡើងដ៏ធំ មានរឿងដំណាលក្នុងអដ្ឋកថាសារត្ថប្បកាសិនី ដែលជាគម្ពីរអធិប្បាយបាលីគម្ពីរសំយុត្តនិកាយ មហាវារវគ្គបញ្ជាក់ថា លុះព្រះសារីបុត្តពោលសុំខមាទោសចំពោះសង្ឃ និងសង្ឃសូមខមាទោសចំពោះលោកហើយ លោកក៏យកចីវរផ្ទាំងធំមកដណ្តប់ និងគ្របមុខហើយសឹងផ្អៀងទៅខាងស្តាំ និងចូលអនុបុព្វសមាបត្តិ ( ការចូលសមាបត្តិក្នុងធម៌ជាគ្រឿងនៅដោយលំដាប់ ៤ យ៉ាង គឺ រូបឈាន ៤ អរូបឈាន ៤ និងសញ្ញាវេទយិតនិរោធដូចព្រះមានព្រះភាគ ដោយលោកចូលជាអនុលោម និងបដិលោម ហើយក៏បរិនិព្វាន ដោយអនុបាទិសេសនិព្វាន ។

ពន្លឺនៃអារុណោទ័យប្រាកដឡើងនៅលើផ្ទៃមេឃ នាថ្ងៃ ១៥ កើត ខែកត្តិក , ព្រះសារីបុត្តដែលជាធម្មសេនាបតី ក៏បានរំលត់ខន្ធបរិនិព្វាន ដំណាលគ្នា ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ តថាគតបានប្រាប់អ្នកទាំងឡាយជាមុនហើយមិនមែនឬថា ការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ជាទីពេញចិត្តទាំងអស់ រមែងមានជាធម្មតា តើអ្នកណានឹងបានជាទីពឹងក្នុងរបស់ដែលជាទីស្រឡាញ់ពេញចិត្ត ព្រោះវត្ថុណាកើតឡើងហើយ មានបច្ច័យតាក់តែងហើយ មានការបែកធ្លាយជាធម្មតា ការប្រាថ្នាថា សូមវត្ថុទាំងនោះកុំបែកធ្លាយទៅឡើយ មិនជាឋានៈដែលអាចប្រព្រឹត្តទៅបានឡើយ យ៉ាងណាមិញ សារីបុត្តដែលដូចជាដើមឈើធំ ជាទីពឹងពំនាក់របស់ភិក្ខុសង្ឃជាច្រើន



ក៏ត្រូវបរិនិព្វាន ។ ព្រោះដូច្នោះឯង អានន្ទ អ្នកទាំងឡាយចូរមានខ្លួនជាកោះមានខ្លួនជាទីពឹង មិនគប្បីមានវត្ថុដទៃជាទីពឹងឡើយ គឺ ចូរមានធម៌ជាកោះមានធម៌ជាទីពឹង មិនគប្បីមានវត្ថុដទៃជាទីពឹងឡើយ ម្នាលអានន្ទ យ៉ាងណាហៅថា ភិក្ខុមានខ្លួនជាកោះ មានខ្លួនជាទីពឹង ? យ៉ាងនេះគឺ ភិក្ខុក្នុងធម្មវិន័យនេះរមែងជាអ្នកឃើញកាយក្នុងកាយ ឃើញវេទនាក្នុងវេទនា ឃើញចិត្តក្នុងចិត្តឃើញធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកប្រារព្ធសេចក្តីព្យាយាម មានសតិ មានសម្បជញ្ញៈ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ម្នាលអានន្ទ នេះឯងហៅថា ភិក្ខុមានខ្លួនជាកោះ មានខ្លួនជាទីពឹង មិនមែនមានវត្ថុដទៃជាកោះ មិនមែនមានវត្ថុដទៃជាទីពឹងឡើយ ។ល។

ម្នាលភិក្ខុទាំងឡាយ សារីបុត្តនោះ បានបំពេញបារមីអស់មួយអសង្ខេយ្យនិងមួយសែនកប្ប បានប្រកាសធម្មចក្រឲ្យប្រព្រឹត្តទៅដូចជាតថាគត សារីបុត្តនោះ បានជាអ្នកប្រៀនប្រដៅសាសនាចាត់ជាទី ២ បន្ទាប់ពីតថាគត សារីបុត្តនោះ ក្នុងបណ្តាសាវកសន្និបាត វៀរតែតថាគតចេញហើយ គ្មាននរណាផ្ទឹមឡើយដោយបញ្ញាក្នុងម៉ឺនចក្រវាឡ សារីបុត្តជាអ្នកមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាធំទូលាយ មានបញ្ញារហ័ស មានបញ្ញាមុតស្រួច មានបញ្ញាជាគ្រឿងកម្ចាត់កិលេស ។

សារីបុត្តជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស ពេញចិត្តនឹងទីស្ងប់ស្ងាត់ មិនច្រឡូកច្រឡំដោយពួកគណៈ ប្រារព្ធសេចក្តីព្យាយាម ជាអ្នកចូលចិត្តដាស់តឿនអ្នកដទៃ ជាអ្នកតិះដៀលអំពើអាក្រក់ ភិក្ខុរូបនោះជាអ្នកមានខន្តីធម៌ជានិច្ចដូចជាផែនដី សារីបុត្តប្រព្រឹត្តខ្លួនដូចជា គោឧសភរាជបាក់ស្នែងប្រព្រឹត្តខ្លួនមានចិត្តទាប ដូចកូនរបស់មនុស្សអ្នកស្រុកចណ្ឌាល អ្នកទាំងឡាយ

ចូរមើលអដ្ឋិធាតុទាំងឡាយរបស់ភិក្ខុដែលមានបញ្ញាច្រើន ។ល។ មានបញ្ញាជាគ្រឿងកម្ចាត់កិលេសបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរគុណរបស់ព្រះសារីបុត្ត ដោយព្រះគាថា ៥០០ គាថា ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ទទួលអដ្ឋិធាតុរបស់ព្រះសារីបុត្តត្ថេរទុកហើយ ទើបប្រោសឲ្យសាងស្តូបបញ្ចុះអដ្ឋិធាតុរបស់លោកទុក ក្នុងទីជិតទ្វារវត្តជេតពនមហាវិហារ ក្រុងសាវត្ថី ដើម្បីបានជា “ **អគ្គសាវកានុស្សរណដ្ឋាន** ” ជាការលើកឡើងនូវកិត្តិគុណរបស់ព្រះធម្មសេនាបតីសារីបុត្ត និងដើម្បីជាទីសក្ការបូជារបស់ពុទ្ធបរិស័ទតទៅក្នុងអនាគតកាល ។



# រាយនាមលោកអ្នកមានឧបការ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ភ្លាត ហ៊ន ឧបាសក នាក់ ម៉ៅ

ឧបាសក ឌុំ ឆួន ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត ឧបាសក កើត ឌិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម រ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់ ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ ឧបាសិកា ពូ ហ៊ាង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

## រាយនាមអ្នកប្រែសម្រួល

**ព្រះសង្ឃអាស្រមព្រះគន្ធកុដិ**

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានសង្ឃអាស្រម ព្រះគន្ធកុដិ

ព្រះភិក្ខុឧាហមុត្តោ ប៉ូច សុផល ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុចន្ទរក្ខិតោ ម៉ឺន សុច័ន្ទ ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសរញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យ៉ាត កល្យាណ ធម្មាចារ្យ

សាមណេរ អ៊ឹម សុជាន សាមណេរ ម៉ៅ អៀប

សាមណេរ ម៉ុន បូរ៉ា សាមណេរ រិន សុវ៉ាន

**ផ្នែកឧបាសក**

ឧបាសក ក្អាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទួន ឧបាសក ហុក សឹងហួត



## បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី បូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន :**

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **២–អដ្ឋកថា ទិដ្ឋិកថា (ពោលដោយទិដ្ឋិ)** | |
| អដ្ឋកថា អស្សាទទិដ្ឋិនិទ្ទេស | ១ |
| អដ្ឋកថា អត្តានុទិដ្ឋិនិទ្ទេស | ២៦ |
| អដ្ឋកថា មិច្ឆាទិដ្ឋិនិទ្ទេស | ៤២ |
| អដ្ឋកថា សក្កាយទិដ្ឋិនិទ្ទេស | ៤៤ |
| អដ្ឋកថា សស្សតទិដ្ឋិនិទ្ទេស | ៤៥ |
| អដ្ឋកថា ឧច្ឆេទទិដ្ឋិនិទ្ទេស | ៤៦ |
| អដ្ឋកថា អន្តគាហិកទិដ្ឋិនិទ្ទេស | ៤៧ |
| អដ្ឋកថា បុព្វន្តានុទិដ្ឋិនិទ្ទេស | ៥២ |
| អដ្ឋកថា អបរន្តានុទិដ្ឋិនិទ្ទេស | ៥៤ |
| អដ្ឋកថា សញ្ញោជនិកទិដ្ឋិនិទ្ទេស | ៥៥ |
| អដ្ឋកថា មានវិនិពន្ធទិដ្ឋិនិទ្ទេស | ៥៦ |
| អដ្ឋកថា អត្តវាទបដិសំយុត្តទិដ្ឋិនិទ្ទេស | ៥៧ |
| អដ្ឋកថា លោកវាទបដិសំយុត្តទិដ្ឋិនិទ្ទេស | ៥៨ |
| អដ្ឋកថា ភវវិភវទិដ្ឋិនិទ្ទេស | ៥៩ |
| ពោលអំពី ប្រភេទព្រះអរិយបុគ្គល | ៧៦ |
| **៣–អដ្ឋកថា អនាចានស្សតិ** | |
| អដ្ឋកថា គណនវារៈ | ៨១ |
| អដ្ឋកថា សោឡសញ្ញាណនិទ្ទេស | ៨៦ |





| | |
|---|---|
| អដ្ឋកថា ឧបក្កិលេសញ្ញាណនិទ្ទេស | ៨៩ |
| អដ្ឋកថា វោទានញ្ញាណនិទ្ទេស | ៩៧ |
| អដ្ឋកថា សតោការិញ្ញាណនិទ្ទេស ចតុក្កៈទី ១ | ១៣៤ |
| អដ្ឋកថា សតោការិញ្ញាណនិទ្ទេស ចតុក្កៈទី ២ | ២០៣ |
| អដ្ឋកថា សតោការិញ្ញាណនិទ្ទេស ចតុក្កៈទី ៣ | ២០៧ |
| អដ្ឋកថា សតោការិញ្ញាណនិទ្ទេស ចតុក្កៈទី ៤ | ២១៤ |
| អដ្ឋកថា ញាណរាសិឆក្កនិទ្ទេស | ២២១ |
| **៤–អដ្ឋកថា ឥន្ទ្រិយកថា** | |
| អដ្ឋកថា បឋមសុត្តន្តនិទ្ទេស | ២២៧ |
| អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស | ២៥៣ |
| អដ្ឋកថា អស្សាទនិទ្ទេស | ២៥៧ |
| អដ្ឋកថា អាទីនវនិទ្ទេស | ២៥៩ |
| អដ្ឋកថា និស្សរណនិទ្ទេស | ២៥៩ |
| អដ្ឋកថា តតិយសុត្តន្តនិទ្ទេស | ២៦៤ |
| អដ្ឋកថា ចរិយាវារៈ | ២៨៦ |
| អដ្ឋកថា ចារវិហារនិទ្ទេស | ២៦៩ |
| អដ្ឋកថា ចតុត្ថសុត្តន្តនិទ្ទេស | ២៧៨ |
| អដ្ឋកថា អធិបតេយ្យត្ថនិទ្ទេស | ២៧៩ |
| អដ្ឋកថា អាទិវិសោធនត្ថនិទ្ទេស | ២៨០ |
| អដ្ឋកថា អធិមត្តដ្ឋនិទ្ទេស | ២៨០ |
| អដ្ឋកថា អធិដ្ឋានត្ថនិទ្ទេស | ២៨៥ |
| អដ្ឋកថា បរិយាទានត្ថបតិដ្ឋាបកត្ថនិទ្ទេស | ២៨៥ |

អដ្ឋកថា ឥន្ទ្រិយសមោធាន ២៦៧

៥–អដ្ឋកថា វិមោក្ខកថា

អដ្ឋកថា វិមោក្ខុទ្ទេស ២៩៦

អដ្ឋកថា វិមោក្ខនិទ្ទេស ៣០៦

៦–អដ្ឋកថា គតិកថា

អដ្ឋកថា គតិកថា ៣៥៨

៧–អដ្ឋកថា កម្មកថា

អដ្ឋកថា កម្មកថា ៣៧១

៨–អដ្ឋកថា វិបល្លាសកថា

អដ្ឋកថា វិបល្លាសកថា ៣៧៩

៩–អដ្ឋកថា មគ្គកថា

អដ្ឋកថា មគ្គកថា ៣៨៥

១០–អដ្ឋកថា មណ្ឌបេយ្យកថា

អដ្ឋកថា មណ្ឌបេយ្យកថា ៣៨៩

( យុគនទ្ធវគ្គ )

១–អដ្ឋកថា យុគនទ្ធកថា

អដ្ឋកដា យុគនទ្ធកថា ៣៩៨

អដ្ឋកថា សុត្តន្តនិទ្ទេស ៤០៦

អដ្ឋកថា ធម្មុទ្ធច្ចវារនិទ្ទេស ៤១៤

២–អដ្ឋកថា សច្ចកថា

អដ្ឋកថា សច្ចកថា ៤៣០

អដ្ឋកថា បឋមសុត្តន្តនិទ្ទេស ៤៣២





អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស ៤៤២-៤៤៥

៣–អដ្ឋកថា ពោជ្ឈង្គកថា

អដ្ឋកថា ពោជ្ឈង្គកថា ៤៥០

អដ្ឋកថា មូលមូលកាទិទសកកថា ៤៥៤

អដ្ឋកថា សុត្តន្តនិទ្ទេស ៤៦០

៤–អដ្ឋកថា មេត្តាកថា

អដ្ឋកថា មេត្តាកថា ៤៦៤

អដ្ឋកថា ឥន្ទ្រិយវារៈ ៤៧១

អដ្ឋកថា ពលាទិវារត្តយៈ ៤៧៥

៥–វិរាគកថា

អដ្ឋកថា វិរាគកថា ៤៧៦

៦–បដិសម្ភិទាមគ្គកថា

អដ្ឋកថា ធម្មចក្កប្បវត្តនវារៈ ៤៨២

អដ្ឋកថា សតិប្បដ្ឋានវារៈជាដើម ៤៩៧

អដ្ឋកថា សត្តពោធិសត្តវារៈជាដើម ៤៩៨

អដ្ឋកថា ធតុទ្ធធម្មវារៈ ៤៩៩

៧–ធម្មចក្កកថា

អដ្ឋកថា សច្ចវារៈ ៥០១

អដ្ឋកថា សតិប្បដ្ឋានវារៈ ៥០៧

៨–លោកុត្តរកថា

អដ្ឋកថា លោកុត្តរកថា ៥០៨

៩–ពលកថា

អដ្ឋកថា ពលកថា ៥១៩

១០-សុញ្ញកថា

អដ្ឋកថា សុញ្ញកថា ៥៤៥

(បញ្ញាវគ្គ)

១-មហាបញ្ញាកថា

អដ្ឋកថា មហាបញ្ញាកថា ៥៦៧

អដ្ឋកថា សោឡសបញ្ញានិទ្ទេស ៥៧៦

អដ្ឋកថា បុគ្គលវិសេសនិទ្ទេស ៦១៣

២-ឥទ្ធិកថា

អដ្ឋកថា ឥទ្ធិកថា ៦១៦

អដ្ឋកថា ទសឥទ្ធិកថា ៦២២

៣-អភិសមយកថា

អដ្ឋកថា អភិសមយកថា ៧០១

៤-វិវេកកថា

អដ្ឋកថា វិវេកកថា ៧១០

អដ្ឋកថា មគ្គង្គនិទ្ទេស ៧១៣

៥-ចរិយាកថា

អដ្ឋកថា ចរិយាកថា ៧១៧

៦-បាដិហារិយកថា

អដ្ឋកថា បាដិហារិយកថា ៧១៨

៧-សមសីសកថា

អដ្ឋកថា សមសីសកថា ៧២៦



៨-សតិប្បដ្ឋានកថា

អដ្ឋកថា សតិប្បដ្ឋានកថា ៧២៧

៩-វិបស្សនាកថា

អដ្ឋកថា វិបស្សនាកថា ៧៣៤

១០-មាតិកាកថា

អដ្ឋកថា មាតិកាកថា ៧៤៥

និគមកថា ៧៥៤

ប្រជុំកងធម៌ ៧៥៧

# អដ្ឋកថា បដិសម្ភិទាមគ្គ

## ឈ្មោះសទ្ធម្មប្បកាសិនី ក្នុងខុទ្ទកនិកាយ

## ទុតិយភាគ

## ២-ទិដ្ឋិកថា ក្នុងមហាវគ្គ

### អដ្ឋកថា អស្សាទទិដ្ឋិនិទ្ទេស

ពេលនេះ ដល់វេលាដែលពណ៌នាតាមលំដាប់នៃទិដ្ឋិកថា ដែលលោកពោលហើយក្នុងលំដាប់នៃញាណកថា ។ ពិតណាស់ ទិដ្ឋិកថានេះជម្រះមន្ទិល គឺ មិច្ឆាទិដ្ឋិរបស់អ្នកចាក់ធ្លុះសម្មាទិដ្ឋិ ដែលសន្សំនូវញាណបានធ្វើទុកហើយ ដោយញាណកថាដែលជាការធ្វើទុកដោយល្អ ។ ម្យ៉ាងទៀត សម្មាទិដ្ឋិលោក ពោលទុកក្នុងលំដាប់នៃញាណកថាជាសេចក្តីបរិសុទ្ធដោយល្អ ។ ក្នុងទិដ្ឋិកថា នោះមាន ៤ បរិច្ឆេទ គឺ ពាក្យសួរមានជាអាទិ៍ថា **ទិដ្ឋិ** គឺអ្វី ១ ។ ការឆ្លើយតបនូវពាក្យសួរមានជាអាទិ៍ថា ពាក្យថា **ទិដ្ឋិ** គឺអ្វី គឺការស្ទាបអង្អែលដោយការប្រកាន់ខុស ១ សម្តែងដល់សេចក្តីពិស្តានៃការឆ្លើយ ដែលឆ្លើយមានជាអាទិ៍ថា **ទិដ្ឋិ** គឺ ការស្ទាបអង្អែលដោយការប្រកាន់ខុសតើដូចម្តេច ១ ការប្រៀបធៀបជាមួយទិដ្ឋិសូត្រមានជាអាទិ៍ថា **ទិដ្ឋិ** ទាំងអស់



នោះជាអស្សាទទិដ្ឋិ ( ការឃើញដោយសេចក្តីពេញចិត្ត ) ១ ។ ក្នុង ៤ បរិច្ឆេទនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងបុច្ឆាបរិច្ឆេទមុន ។ សួរថា **ទិដ្ឋិ** តើដូចម្តេច ជាធម្មបុច្ឆា ( សួរធម្មតា ) ជាសភាវៈបុច្ឆា ( សួរតាមសភាវៈ ) ។

សួរថា ហេតុនៃទិដ្ឋិប៉ុន្មានយ៉ាង ជាហេតុបុច្ឆា ( សួរតាមហេតុ ) ជា បច្ចយបុច្ឆា ( សួរតាមបច្ច័យ ) ។ អធិប្បាយថា ហេតុនៃទិដ្ឋិទាំងឡាយមានប៉ុន្មាន ។

សួរថា ការរួបរិតនៃទិដ្ឋិប៉ុន្មាន ជាសមុទាចារបុច្ឆា ( សួរតាមសេចក្តីប្រាកដ ) ជាវិការបុច្ឆា ( សួរធ្វើឲ្យប្លែកទៅ ) ។ ពិតណាស់ ទិដ្ឋិទាំងឡាយនោះឯង ឈ្មោះថា **ទិដ្ឋិបរិយុដ្ឋាន** ( ការរួបរឹតនៃទិដ្ឋិ ) ព្រោះតាំងឡើងរុំព័ទ្ធចិត្តដោយអំណាចនៃការប្រាកដ ។

សួរថា ទិដ្ឋិប៉ុន្មាន ជាសំខ្យាបុច្ឆា ( សួរតាមចំនួន ) ជាគណនាបុច្ឆា ( សួរតាមការរាប់ ) នៃទិដ្ឋិទាំងឡាយ ។

សួរថា ការប្រកាន់ខុសនៃទិដ្ឋិប៉ុន្មាន ជាទិដ្ឋិបភេទបុច្ឆា ( សួរតាមប្រភេទនៃទិដ្ឋិ ) ដោយប្រភេទនៃវត្ថុ ដោយសេចក្តីផ្សេងគ្នានៃអារម្មណ៍ ។ ព្រោះថា ទិដ្ឋិទាំងឡាយនោះឯងរមែងប្រកាន់ រមែងស្ទាបអង្អែលវត្ថុនោះ ៗ អារម្មណ៍នោះ ៗ ព្រោះហេតុនោះ ទើបលោកពោល

ថា **ទិដ្ឋិបរាមាស** ( ការស្ទាបអង្អែល គឺ ទិដ្ឋិ ) ។

ស្ទួរថា ការដកឡើងនូវហេតុនៃទិដ្ឋិតើដូចម្តេច ជាបដិបក្ខបុច្ឆា ( ពាក្យសួរបដិបក្ខគ្នា ) ជាបហានូបាយបុច្ឆា ( ពាក្យសួររកឧបាយដើម្បីលះ ) នៃទិដ្ឋិទាំងឡាយ ពិតណាស់ ហេតុនៃទិដ្ឋិទាំងនោះមានខន្ធជាដើម ជាហេតុនៃទិដ្ឋិ ទើបប្រព្រឹត្តទៅមិនបានដោយការដកទិដ្ឋិ ព្រោះហេតុនោះ ទើបឈ្មោះថា ត្រូវដកហេតុទាំងនោះ ដូច្នោះទើបលោកពោលថា **ទិដ្ឋិដ្ឋានសមុគ្ឃាត** ( ដកទីតាំងនៃទិដ្ឋិ ) ព្រោះទីតាំងនៃទិដ្ឋិ ជាហេតុបៀតបៀនយ៉ាងកាចសាហាវ ។

ពេលនេះគប្បីជ្រាបពាក្យឆ្លើយ ៦ ប្រការ មានជាអាទិ៍ថា ទិដ្ឋិតើដូចម្តេច នៃពាក្យសួរទាំង ៦ ប្រការនោះ ។ ក្នុងពាក្យសួរទាំងនោះគប្បីជ្រាបពាក្យសួរដែលគួឆ្លើយថា **ទិដ្ឋិ** តើដូចម្តេច ដូចតទៅនេះ ។

ពាក្យឆ្លើយថា **ទិដ្ឋិ** គឺ ការស្ទាបអង្អែលដោយការឃើញខុស ។ ក៏ទិដ្ឋិនោះឈ្មោះថា **អភិនិវេស** ព្រោះប្រកាន់មាំ តាំងមាំ ប្រកាន់ស្អិតដោយអំណាចនៃការទៀងជាដើម ក្នុងវត្ថុដែលមិនទៀងជាដើម ឈ្មោះថា **បរាមាស** ព្រោះឈានកន្លងអាការមិនទៀងជាដើម ហើយស្ទាបអង្អែលចាប់ប្រកាន់តទៅ ប្រព្រឹត្តទៅដោយអំណាចនៃសភាពជារបស់ទៀងជាដើម ។



ម្យ៉ាងវិញទៀត ឈ្មោះថា **បរាមាស** ព្រោះស្ទាបអង្អែលប្រកាន់វត្ថុដទៃមានជាអាទិ៍ថា ជារបស់ទៀង ថាជារបស់ពិតយ៉ាងខ្ពង់ខ្ពស់ ។ ការប្រកាន់ និងការស្ទាបអង្អែលនោះ ឈ្មោះថា **អភិនិវេសបរាមាស** ។ ព្រះសារីបុត្តត្ថេរ រមែងឆ្លើយសភាវៈរបស់ទិដ្ឋិដោយកិច្ចថា ទិដ្ឋិ មានប្រការយ៉ាងនេះ ដូច្នេះ ។

បទថា **តីណិ សតំ** គឺ ៣០០[1] ជាសេចក្តីប្រែប្រួលរបស់វចនៈ ។

ស្ទួរថា ការដកទីតាំងនៃទិដ្ឋិដូចម្តេច ជាការតាំងពាក្យសួរឡើង ឆ្លើយថា សោតាបត្តិមគ្គ ជាគ្រឿងដកទីតាំងនៃទិដ្ឋិ ។

ពេលនេះ គប្បីជ្រាបការសម្តែងដោយពិស្តាររបស់បទ មានជាអាទិ៍ថា **កថំ អភិនិវេសបរាមាសោ** ការស្ទាបអង្អែលដោយការប្រកាន់ស្អិត តើដូចម្តេច ។

ក្នុងបទទាំងនោះ បទថា **រូបំ** ជាទុតិយាវិភត្តិ ។ ភ្ជាប់សេចក្តីថា ការស្ទាបអង្អែលដោយការប្រកាន់ស្អិតក្នុងរូប ។ ម្យ៉ាងទៀត បទថា **រូបំ**

[1] ក្នុងព្រះសូត្រជា **តីសសតំ** ( ១៣០ ) តែអដ្ឋកថាប្រើពាក្យថា **តីណិសតំ** ( ៣០០ ) ជាវចនវិបល្លាស រាប់ចំនួនដូច្នេះ គឺ ខន្ធ ៥ , អាយតនៈ ១២ , វិញ្ញាណ ៦ , ផស្សៈ ៦ , ចក្ខុសម្ផស្សជាវេទនា ៦ , សញ្ញា ៦ , សញ្ចេតនា ៦ , តណ្ហា ៦ , វិតក្កៈ ៦ , វិចារៈ ៦ , ធាតុ ៦ , កសិណ ១០ , កោដ្ឋាសៈ ៣២ , អាយតនៈ ១២ , ធាតុ ១៦ , ឥន្ទ្រិយ៍ ១៥ , ធាតុ ២៣ , បដិច្ចៈ ១២ , រួម ១៩៣ រាប់ទីតាំងនៃទិដ្ឋិ ៨ ការរួបរិតជាទិដ្ឋិ ១៨ , ទិដ្ឋិ ១៦ , ទិដ្ឋិ ៣ ទៀត ( គឺ នុ៎ះជាយើង នុ៎ះជារបស់យើង នុ៎ះជាខ្លួនយើង ) និងទិដ្ឋិ ៦២ រួមទាំងអស់ មានចំនួន ៣០០ ។

នេះ បានដល់ រូបូបាទានក្ខន្ធ និងកសិណរូប ។ ទិដ្ឋិ គឺ ការស្ទាប អង្អែលដោយការប្រកាន់ខុសថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួន របស់អញ គប្បីប្រកបមួយ ៗ ។

បទថា **ឯតំ** ជាសាមញ្ញវចនៈ ។ ដោយបទនោះ លោកធ្វើឲ្យជា នបុំសកវចនៈ និងឯកវចនៈថា នុ៎ះវេទនារបស់អញ នុ៎ះសង្ខាររបស់ អញ ។ តែបទថា **ឯសោ** លោកសម្ងឹងដល់វត្ថុដែលគួរពោលដល់ ទើបធ្វើឲ្យជាបុំលិង្គវចនៈ ។

បទថា **ឯតំ មម** ( នុ៎ះរបស់អញ ) ជាការសម្គាល់របស់ទិដ្ឋិ ព្រោះមានតណ្ហាជាមូល ។

បទថា **ឯសោហមស្មិ** ( នុ៎ះជាអញ ) ជាការសម្គាល់ដោយទិដ្ឋិ ព្រោះមានមានះជាមូល ។

បទថា **ឯសោ មេ អត្តា** ( នុ៎ះជាខ្លួនរបស់អញ ) ជាការសម្គាល់ ព្រោះទិដ្ឋិនោះឯង ។

ចំណែកអាចារ្យពួកខ្លះពណ៌នាសេចក្ដីនៃពាក្យទាំង ៣ នេះថា ការត្រិះរិះដោយ **មមង្ការ** ( ការប្រកាន់ថាជារបស់អញ ) ថានុ៎ះជារបស់ អញ ការត្រិះរិះដោយ **អហង្ការ** ( ការប្រកាន់ថាជាអញ ) ថានុ៎ះជា អញ និងការប្រកាន់ថា នុ៎ះជាតួខ្លួនអញ ដែលត្រិះរិះដោយអហង្ការៈ



មមង្ការៈថា នុ៎ះជាតួខ្លួនអញ ។ មយ៉ាងទៀត ការសរសើរដោយមានះ អាស្រ័យតណ្ហាជាមូលតាមលំដាប់ ដែលមានះលើកសរសើរហើយ អាស្រ័យតណ្ហាជាមូល និងការប្រកាន់តួខ្លួន ។ ការមិនឃើញលក្ខណៈ ដែលជាទុក្ខនៃសង្ខារទាំងឡាយ ការមិនឃើញលក្ខណៈមិនទៀងនៃ សង្ខារទាំងឡាយ និងការប្រកាន់តួខ្លួនដែលជាហេតុមិនឃើញត្រៃ-លក្ខណ៍នៃសង្ខារទាំងឡាយ ការប្រកាន់តួខ្លួនរបស់អ្នកដែលដល់ការ វិបល្លាសក្នុងសេចក្ដីទុក្ខ ថាជាសុខ ក្នុងរបស់មិនស្អាត ថាស្អាត ក្នុង របស់មិនទៀង ថាទៀង និងអ្នកដល់នូវភាពវិបល្លាស ៤ យ៉ាង ។ ការត្រិះរិះដោយអាការនៃបុព្វេនិវាសញ្ញាណ ការត្រិះរិះដើម្បីបានក្នុង អនាគតនៃទិព្វចក្ខុញ្ញាណ និងការប្រកាន់តួខ្លួនរបស់អ្នកអាស្រ័យការ ត្រិះរិះក្នុងធម៌ទាំងឡាយ ដែលជាឥទប្បច្ចយតា ( វត្ថុនេះជាបច្ច័យដល់ វត្ថុនេះ ) និងបដិច្ចសមុប្បាទ ទាំងចំណែកខាងដើម និងចំណែកខាង ចុង ការនឹកដល់អតីតដោយសេចក្ដីពេញចិត្ត ប្រាថ្នាអនាគតដោយ សេចក្ដីពេញចិត្ត ជាប់ជំពាក់នៅក្នុងបច្ចុប្បន្ន ឈ្មោះថា ប្រកាន់តួ ខ្លួន ។ **ទិដ្ឋិ** មានការមិនដឹងជាហេតុក្នុងចំណែកខាងដើម ក្នុងចំណែក ខាងចុង និងការប្រកាន់តួខ្លួន ព្រោះមានការមិនដឹងជាហេតុ ក្នុងធម៌ ទាំងឡាយដែលជាឥទប្បច្ចយតា និងបដិច្ចសមុប្បាទក្នុងចំណែកខាង

ដើមនិងចំណែកខាងចុង ។

ម្យ៉ាងទៀត ទិដ្ឋិទាំងឡាយ ក្នុងទិដ្ឋិកថានេះ មានខន្ធ ៥ ជាវត្ថុជាទីមួយ ។ ប៉ុន្តែលោកពោលទិដ្ឋិទាំងឡាយ មានអាយតនៈក្នុង ៦ ខាងក្រៅ ៦ វិញ្ញាណ កាយសម្ផស្ស កាយវេទនា កាយសញ្ញា កាយ-ចេតនា កាយតណ្ហា កាយវិតក្កវិចារធាតុ កសិណ ១០ អាការ ៣២ ជាវត្ថុ ។

ម្យ៉ាងទៀត ក្នុងអាការ ៣២ គប្បីជ្រាបថា មិនគួរប្រកាន់មាំទុកដោយផ្សេងគ្នា ធ្វើការប្រកាន់ដូចការប្រកាន់ទុកដោយផ្សេងគ្នា ដោយការប្រកាន់មាំសរីរៈទាំងអស់ អំពីនោះក៏ប្រកបដោយអាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ១៩ មិនប្រកបឥន្ទ្រិយដែលជាលោកុត្តរៈដោយឯកន្តៈ ៣ ព្រោះទិដ្ឋិទាំងឡាយរមែងមិនមានលោកុត្តរៈជាវត្ថុ ។ ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយដែលលាយដោយលោកិយៈ និងលោកុត្តរៈ សូម្បីទាំងពួង គប្បីកាន់យកលោកិយៈតែម្យ៉ាង វៀរលោកុត្តរៈចេញ និងមិនគួរកាន់រូបដែលទាក់ទងដោយអនិន្ទ្រិយប៉ុណ្ណោះ បន្ទាប់ពីនោះក៏ប្រកបដោយធាតុ ៣ ភព ៩ ឈាន ព្រហ្មវិហារសមាបត្តិ និងអង្គនៃបដិច្ចសមុប្បាទ ។ ការបរិហារក្នុងការប្រកាន់យកជាតិ ជរា និងមរណៈទុកផ្សេង មានន័យដូចបានពោលហើយ ។ បទទាំងឡាយ មានរូបជា



ដើមប៉ុណ្ណោះទាំងអស់ ដែលមានជរា និងមរណៈជាខាងចុង មាន ១៩៨ បទ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទីតាំងនៃទិដ្ឋិទាំងឡាយ ដូចតទៅនេះ :-

បទថា **ខន្ធាបិ ទិដ្ឋិដ្ឋានំ** សូម្បីខន្ធទាំងឡាយ ក៏ជាទីតាំងនៃទិដ្ឋិ សេចក្តីថា ឧបាទានក្ខន្ធ ៥ ឈ្មោះថា ជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះសក្កាយទិដ្ឋិ សូម្បីមានវត្ថុ ២០ យ៉ាង ក៏ជាវត្ថុនៃខន្ធ ៥ ព្រោះព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ពួកណាមួយ កាលពិចារណារឿយ ៗ រមែងពិចារណាឃើញខ្លួនឯងជានិច្ច សមណៈ ឬព្រាហ្មណ៍ទាំងឡាយនោះ រមែងពិចារណាឃើញរឿយ ៗ ក្នុងឧបាទានក្ខន្ធ ៥ នោះឯង ឬខន្ធឯណាមួយក្នុងខន្ធទាំង ៥ ប៉ុណ្ណោះ ។

បទថា **អវិជ្ជាបិ ទិដ្ឋិដ្ឋានំ** ( សូម្បីអវិជ្ជាក៏ជាទីតាំងនៃទិដ្ឋិ ) សេចក្តីថា អវិជ្ជាជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះអវិជ្ជាជាការកើតឡើងនៃទិដ្ឋិរបស់បុគ្គលខ្វាក់ភ្នែកទាំងឡាយ និងព្រោះព្រះបាលីថា បពិត្រព្រះអង្គដ៏ចម្រើន ការយល់ថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយរមែងប្រាកដក្នុងបុគ្គលដែលមិនបានត្រាស់ដឹងឯងដោយប្រពៃ ដូច្នេះ ទិដ្ឋិនេះ រមែងប្រាកដព្រោះអាស្រ័យអ្វី ព្រះអង្គ ។ ម្នាលកច្ចានៈ ធាតុនេះធំណាស់ គឺ អវិជ្ជាធាតុ ម្នាលកច្ចានៈ សញ្ញាថោកទាប ទិដ្ឋិថោក-

ទាប រមែងកើតឡើងព្រោះអាស្រ័យធាតុថោកទាប ។

បទថា **ផស្សោបិ ទិដ្ឋិដ្ឋានំ** ( សូម្បីផស្សៈក៏ជាទីតាំងនៃទិដ្ឋិ ) សេចក្ដីថា ផស្សៈជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះការប៉ះខ្ទប់ដោយផស្សៈនោះ ជាការកើតឡើងនៃទិដ្ឋិ និងព្រោះបាលីថា ម្នាលភិក្ខុទាំង-ឡាយ សមណព្រាហ្មណ៍ទាំងឡាយណា ត្រិះរិះចំណែកខាងដើម មានការឃើញតាមចំណែកខាងដើម រមែងពោលដល់បទដែលពេញចិត្តច្រើនយ៉ាង ប្រារព្ធចំណែកខាងដើម សូម្បីប្រការនោះ ក៏ជាបច្ច័យនៃផស្សៈ ។

បទថា **សញ្ញាបិ ទិដ្ឋិដ្ឋានំ** ( សូម្បីសញ្ញាក៏ជាទីតាំងនៃទិដ្ឋិ ) សេចក្ដីថា សញ្ញាជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះសញ្ញាជាហេតុកាន់យកតាមសភាពមិនពិត ដោយកាន់យកត្រឹមអាការ ព្រោះពាក្យដែលសភិយបរិព្វាជក ទូលសួរព្រះមានព្រះភាគដោយគាថា ថា :-

**បពិត្រព្រះមានព្រះភាគ ជាអ្នកមានបញ្ញា**
**ស្មើដោយផែនដី ព្រះអង្គទ្រង់កម្ចាត់ទិដ្ឋិ ៣ និង**
**៦០ ដែលអាស្រ័យគម្ពីរ ដែលជាវាទៈ ជាប្រធាន**
**របស់សមណៈអ្នកមានលទ្ធិដទៃ ដែលអាស្រ័យ**
**អក្ខរៈ គឺ ការកំណត់ដឹង ( ជាស្ត្រី ជាបុរស ) និង**



**សញ្ញាដែលវិបរិត ទ្រង់ឈានកន្លងសេចក្ដីងងឹត**
**គឺ ឱឃៈបានហើយ ។**

និងព្រោះព្រះបាលីថា ធម៌ជាចំណែកនៃសេចក្ដីយឺតយូរ មានសញ្ញាជាហេតុ ដូច្នេះ ។

បទថា **វិតក្កោបិ ទិដ្ឋិដ្ឋានំ** ( សូម្បីវិតក្កៈក៏ជាទីតាំងនៃទិដ្ឋិ ) សេចក្ដីថា វិតក្កៈជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះការកើតនៃទិដ្ឋិដោយវិតក្កៈដល់អាការ និងព្រោះបាលីថា ព្រះមានព្រះភាគត្រាស់ថា :-

**សច្ចៈច្រើនយ៉ាងផ្សេង ៗ គ្នា វៀរចាកសញ្ញា**
**ថាទៀងចេញហើយ រមែងមិនមានក្នុងលោក ។ ក៏**
**សមណព្រាហ្មណ៍ទាំងឡាយ មកកំណត់ការដាច់ចេញ**
**នៃទិដ្ឋិទាំងឡាយហើយ ទើបពោលទិដ្ឋិដែលជាគូគ្នា**
**ថា ពិត ៗ កុហក ៗ ។**

បទថា **អយោនិសោមនសិការោបិ ទិដ្ឋិដ្ឋានំ** ( សូម្បីអយោនិ-សោមនសិការ ក៏ជាទីតាំងនៃទិដ្ឋិ ) សេចក្ដីថា អយោនិសោមនសិការជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះអយោនិសោមនសិការជាហេតុទូទៅនៃអកុសលទាំងឡាយ និងព្រោះបាលីថា កាលព្រះយោគាវចរនោះធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ ទិដ្ឋិ ៦ យ៉ាង ណាមួយរមែងកើត

ឡើង ។

បទថា **បាបមិត្តោបិ ទិដ្ឋិដ្ឋានំ** ( សូម្បីមិត្តអាក្រក់ក៏ជាទីតាំងនៃទិដ្ឋិ ) សេចក្តីថា មិត្តអាក្រក់ជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះមិត្តអាក្រក់ ជាការកើតនៃទិដ្ឋិ ដោយបណ្តោយទៅតាមជាមួយការឃើញ និងព្រោះបាលីថា ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណារកមើលមិនឃើញអង្គដទៃក្នុងខាងក្រៅសូម្បីហេតុតែមួយ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសដ៏ធំយ៉ាងនោះ ដូចការមានមិត្តអាក្រក់នេះឡើយ ។

បទថា **បរតោឃោសោបិ ទិដ្ឋិដ្ឋានំ** ( សូម្បីសំឡេងពីទីដទៃក៏ជាទីតាំង នៃទិដ្ឋិ ) សេចក្តីថា សំឡេងធ្វើឲ្យជាមិច្ឆាទិដ្ឋិពីទីដទៃ កថាប្រកបដោយមិច្ឆាទិដ្ឋិ ជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះការកើតនៃទិដ្ឋិដោយការស្តាប់ធម៌ដែលពោលមិនល្អ និងព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ហេតុ ២ យ៉ាង បច្ច័យ ២ យ៉ាង ទាំងនេះគឺ បរតោ-ឃោសៈ និងអយោនិសោមនសិការ រមែងប្រព្រឹត្តទៅដើម្បីឲ្យកើតមិច្ឆាទិដ្ឋិ ។

ពេលនេះ ព្រះសារីបុត្តត្ថេរកាលនឹងអធិប្បាយសេចក្តីនៃពាក្យថា **ទិដ្ឋិដ្ឋានំ** ទីតាំងនៃទិដ្ឋិ ទើបពោលពាក្យមានជាអាទិ៍ថា ខន្ធទាំងឡាយជាហេតុ ជាបច្ច័យ ដូច្នេះ ។ អធិប្បាយថា ខន្ធទាំងឡាយប៉ុណ្ណោះ ជា



ហេតុកើត និងជាបច្ច័យឧបត្ថម្ភ ព្រោះអាស្រ័យទិដ្ឋិទាំងឡាយ ។

បទថា **សមុដ្ឋានដ្ឋេន** ( ព្រោះអត្ថថាតាំងឡើង ) សេចក្តីថា ឈ្មោះថា **សមុដ្ឋាន** ព្រោះជាហេតុតាំងឡើង គឺ កើតឡើង ។ អធិប្បាយថា ជាហេតុ ព្រោះអត្ថថា តាំងឡើងនោះ គឺ ព្រោះភាពជាហេតុនៃទិដ្ឋិ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងដល់ប្រភេទរបស់ទិដ្ឋិ ដោយប្រភេទនៃកិច្ច ទើបពោលពាក្យមានជាអាទិ៍ថា **កតមានិ អដ្ឋារស ទិដ្ឋិបរិយុដ្ឋានានិ** ការរួបរឹតនៃទិដ្ឋិ ១៨ ដូចម្តេច ។

ក្នុងបទទាំងនោះ បទថា **យា ទិដ្ឋិ** ជាបទដើមហេតុ ដែលទូទៅដល់បទទាំងឡាយ ១៨ បទ ដែលនឹងពោលក្នុងពេលឥឡូវនេះ ។ គប្បីធ្វើការភ្ជាប់សេចក្តីដោយបទទាំងពួងថា ទិដ្ឋិ គឺ ទិដ្ឋិគតៈ ទិដ្ឋិគ-ហនៈ ជាដើម ។ ឈ្មោះថា ទិដ្ឋិ ព្រោះអត្ថថា មិនឃើញតាមសេចក្តីពិត ។ ការឃើញទៅតាមទិដ្ឋិទាំងឡាយនោះ ៗ ឯង ឈ្មោះថា ទិដ្ឋិ-គតៈ ព្រោះចុះកាន់ក្នុងចំណែកទិដ្ឋិ ៦២ ។ លោកពោលសេចក្តីនៃទិដ្ឋិគតៈនោះហើយសូម្បីក្នុងខាងក្រោយ សូម្បីព្រោះទីបំផុត ២ យ៉ាងដោយចំណែកតែមួយ ក៏ជាទិដ្ឋិគតៈ ។

ទិដ្ឋិនោះឈ្មោះថា **ទិដ្ឋិគហន** ព្រោះអត្ថថា ឈានកន្លងទៅបានលំបាក ដូចស្បាតដោយស្មៅ ព្រៃ និងភ្នំ ។ ឈ្មោះថា **ទិដ្ឋិកន្តារ**

ព្រោះអត្ថថា មានសេចក្តីរង្កៀស និងមានភ័យចំពោះមុខ ដូចកន្តារព្រោះចោរ ព្រោះសត្វកាច ព្រោះមិនមានទឹក ព្រោះរកភិក្ខាបានលំបាក ។ ក្នុងធម្មសង្គណី មកហើយដោយលិង្គថា **ទិដ្ឋិកន្តារោ** (កន្តារ គឺ ទិដ្ឋិ) ឈ្មោះថា ទិដ្ឋិជាបន្ទាស្រួច ព្រោះអត្ថថា ចាក់ដោត និងផ្ទុយគ្នានឹងសម្មាទិដ្ឋិ ។

ពិតណាស់ ការឃើញខុស រមែងចោះទម្លុះ និងផ្ទុយគ្នានឹងការឃើញត្រូវ ។ ក្នុងធម្មសង្គណីដែលមានមកហើយថា ជាសត្រូវរបស់ទិដ្ឋិ ។ ឈ្មោះថា **ទិដ្ឋិវិបត្តិ** ព្រោះជាទិដ្ឋិប្រែប្រួលខុសអំពីរូប ដោយគ្រាខ្លះប្រកាន់ជាសស្សតទិដ្ឋិ គ្រាខ្លះប្រកាន់ជាឧច្ឆេទទិដ្ឋិ ។

ពិតណាស់ អ្នកមានទិដ្ឋិ មិនអាចតាំងនៅក្នុងទិដ្ឋិតែម្យ៉ាង គ្រាខ្លះរលឹកដល់សស្សតទិដ្ឋិ គ្រាខ្លះរលឹកដល់ឧច្ឆេទទិដ្ឋិ ។ ឈ្មោះថា ទិដ្ឋិជាសំយោជនៈ ព្រោះទិដ្ឋិនោះឯង ប្រកបក្នុងវត្ថុមិនជាប្រយោជន៍ ។

ឈ្មោះថា ទិដ្ឋិជាកូនសរ ព្រោះទិដ្ឋិនោះឯង ឈ្មោះថា ជាកូនសរ ព្រោះអត្ថថា ចោះទម្លុះមុតចូលទៅខាងក្នុង និងព្រោះអត្ថថា នាំចេញបានលំបាក ។

ឈ្មោះថា ទិដ្ឋិជាគ្រឿងចង្អៀតចង្អល់ ព្រោះទិដ្ឋិនោះឯង ឈ្មោះថា ចង្អៀតចង្អល់ ព្រោះធ្វើការបៀតបៀន ។



ឈ្មោះថា ទិដ្ឋិជាគ្រឿងកង្វល់ ព្រោះទិដ្ឋិនោះឯង ឈ្មោះថា ជាគ្រឿងកង្វល់ ព្រោះរារាំងការរួចផុត ។

ឈ្មោះថា ទិដ្ឋិជាគ្រឿងចង ព្រោះទិដ្ឋិនោះឯង ឈ្មោះថា ជាគ្រឿងចង ព្រោះស្រាយបានលំបាក ។

ឈ្មោះថា ទិដ្ឋិជាអន្លង់ ព្រោះទិដ្ឋិនោះឯង ឈ្មោះថា អន្លង់ព្រោះឡើងបានលំបាក ។

ឈ្មោះថា ទិដ្ឋិជាអនុស័យ ព្រោះទិដ្ឋិនោះឯង ឈ្មោះថាជាអនុស័យ ព្រោះទៅដោយកម្លាំងដ៏ខ្លាំង ។

ឈ្មោះថា ទិដ្ឋិជាហេតុឲ្យកើតសេចក្តីក្តៅក្រហាយ ព្រោះទិដ្ឋិនោះឯង ធ្វើខ្លួនឲ្យក្តៅក្រហាយ ។

ឈ្មោះថា ទិដ្ឋិជាហេតុឲ្យកើតសេចក្តីក្រហល់ក្រហាយ ព្រោះទិដ្ឋិនោះឯង តាមដុតរោលខ្លួន ។

ឈ្មោះថា ទិដ្ឋិជាគ្រឿងចាក់ស្រេះ ព្រោះទិដ្ឋិនោះឯង ចាក់ស្រេះកាយដោយកិលេស ។

ឈ្មោះថា ទិដ្ឋិជាគ្រឿងប្រកាន់មាំ ព្រោះទិដ្ឋិនោះឯង ប្រកាន់ទុកយ៉ាងមាំ ។

ឈ្មោះថា ទិដ្ឋិជាហេតុឲ្យប្រកាន់ស្អិត ព្រោះការប្រកាន់ស្អិត

ដោយការប្រកាន់ថា មានពិតជាដើម ។

ឈ្មោះថា ទិដ្ឋិជាហេតុឲ្យស្ទាបអង្អែល ព្រោះទិដ្ឋិនោះឯងរមែងស្ទាបអង្អែលថា នេះគឺដទៃ ឬស្ទាបអង្អែលវត្ថុដទៃ ។

ពេលនេះ ព្រះសារីបុត្តត្ថេរកាលនឹងចង្អុលបង្ហាញដល់ទិដ្ឋិ ១៦ ដោយអំណាចនៃក្រុម ទើបពោលពាក្យមានជាអាទិ៍ថា ទិដ្ឋិ ១៦ ដូចម្តេច ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទិដ្ឋិ ១៦ នោះ ដូចតទៅនេះ ។ ទិដ្ឋិក្នុងសេចក្តីពេញចិត្ត គឺ សុខ និងសោមនស្ស ឈ្មោះថា **អស្សាទទិដ្ឋិ** ទិដ្ឋិដែលប្រព្រឹត្តទៅតាមខ្លួន ឈ្មោះថា **អត្តានុទិដ្ឋិ** ។ ទិដ្ឋិដែលវិបរិតព្រោះប្រព្រឹត្តទៅថា មិនមាន ឈ្មោះថា **មិច្ឆាទិដ្ឋិ** ។ ទិដ្ឋិក្នុងកាយដែលមានហើយ ឬទិដ្ឋិដែលមានក្នុងកាយ ឈ្មោះថា **សក្កាយទិដ្ឋិ** ។ ម្យ៉ាងទៀត ក្នុងបទថា **កាយោ** នេះ គឺ **ខន្ធបញ្ចក** ។ ទិដ្ឋិឈ្មោះថា **សក្កា-យវត្ថុកា** ព្រោះមានសក្កាយៈ គឺ ខន្ធបញ្ចកៈជាវត្ថុ គឺ ជាទីតាំង ។ ទិដ្ឋិដែលប្រព្រឹត្តទៅថាទៀង ឈ្មោះថា **សស្សតទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅថាសូន្យ ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ។ ឈ្មោះថា **អន្តគ្គាហិកទិដ្ឋិ** ព្រោះកាន់យកទីបំផុត មានសស្សតទិដ្ឋិជាដើម ឬព្រោះមានការកាន់យកទីបំផុត ។ ទិដ្ឋិដែលប្រព្រឹត្តទៅតាមទីបំផុតខាងដើម គឺ អតីត ឈ្មោះថា **បុព្វន្តានុទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅក្នុងទីបំផុតខាងចុង គឺ



អនាគត ឈ្មោះថា **អបរន្តានុទិដ្ឋិ** ។ ឈ្មោះថា **សំយោជនិកាទិដ្ឋិ** ព្រោះប្រកបក្នុងវត្ថុមិនមានប្រយោជន៍ ។ ទិដ្ឋិដែលជាគ្រឿងចង បន្តឲ្យកើតឡើងដោយមានៈដែលកើតឡើងថា ជាអញ ដោយការប្រកាន់ខ្លួនដែលជាមូលនៃទិដ្ឋិ ឈ្មោះថា ទិដ្ឋិប្រកាន់ស្អិតដោយមានៈថា ជាអញ ។ ម្យ៉ាងទៀត ទិដ្ឋិដែលជាប់ដោយមានៈ ហើយកើតឡើងថា របស់អញ ដោយការប្រកាន់ថា របស់អញ ឈ្មោះថា ទិដ្ឋិជាប់ដោយមានៈថា របស់អញ ។ ការនិយាយ ការពោលរបស់ខ្លួន ឈ្មោះថា **អត្តវាទ** , ការនិយាយ ការពោលថា លោករបស់ខ្លួន ឈ្មោះថា **លោកវាទ** ។ ទិដ្ឋិសម្បយុត្តដោយលោកវាទៈនោះ ឈ្មោះថា ទិដ្ឋិសម្បយុត្តដោយលោកវាទៈ សភាពទៀង លោកពោលថា ភព ។ ទិដ្ឋិដែលកើតឡើងដោយអំណាចនៃការទៀង ឈ្មោះថា **ភវទិដ្ឋិ** ។ ការដាច់សូន្យ លោកពោលថា **វិភវ** ។ ទិដ្ឋិដែលកើតឡើងដោយអំណាចនៃការដាច់សូន្យ ឈ្មោះថា **វិភវទិដ្ឋិ** ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងការប្រកាន់ស្អិតដោយទិដ្ឋិ ៣០០ ទើបសួរថា ការប្រកាន់ស្អិតដោយទិដ្ឋិ ៣០០ ដូចម្តេច ។ មិនដោះស្រាយការប្រកាន់ស្អិតទាំងនោះ បំណងនឹងឆ្លើយដោយដោះស្រាយការប្រកាន់ស្អិតទុកផ្សេង ៗ គ្នា ទើបសួរដល់អាការ

ប្រកាន់ស្អិតនៃទិដ្ឋិ ១៦ យ៉ាង ដោយន័យមានជាអាទិ៍ថា អស្សាទទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការប៉ុន្មាន ហើយដោះស្រាយការរាប់អាការប្រកាន់ស្អិតនៃទិដ្ឋិ ១៦ យ៉ាងប៉ុណ្ណោះ មានជាអាទិ៍ថា សស្សតទិដ្ឋិមានការប្រកាន់ស្អិតដោយអាការ ៣៥ តទៅ កាលនឹងដោះស្រាយការរាប់ទាំងនោះទៀត ទើបពោលពាក្យមានជាអាទិ៍ថា **អស្សាទទិដ្ឋិ** មានការប្រកាន់ស្អិតដោយអាការ ៣៥ ដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **រូបំ បដិច្ច** គឺ អាស្រ័យរូបក្ខន្ធ ។ បទថា **ឧប្បជ្ជតិ សុខំ សោមនស្សំ** ( សុខ សោមនស្សកើតឡើង ) សេចក្ដីថា សុខ សោមនស្សសម្បយុត្តដោយរាគៈ អាស្រ័យផ្ទះ រមែងកើតឡើង ព្រោះអាស្រ័យរូបសម្បត្តិថា កាយរបស់យើងនេះជាយ៉ាងនេះ ដូច្នេះ ។ សុខ និងសោមនស្ស ដោយអត្ថបានពោលទុកហើយក្នុងខាងក្រោយ ។

បទថា **រូបស្ស អស្សាទោ** (អស្សាទៈនៃរូប) គឺ សេចក្ដីត្រេកអរអាស្រ័យរូប ។ ឈ្មោះថា **អស្សាទ** ព្រោះត្រេកអរសោយសុខនោះដោយអំណាចនៃតណ្ហា ។

បទថា **អភិនិវេសបរាមាសោ ទិដ្ឋិ** ( ទិដ្ឋិ គឺ ការស្ទាបអង្អែលដោយការប្រកាន់ស្អិត ) សេចក្ដីថា សេចក្ដីត្រេកអរនោះ ជាការស្ទាបអង្អែលដោយការប្រកាន់ស្អិតកើតឡើងថា ទៀងក្ដី សូន្យក្ដី រមែងធ្វើ



ខ្លួនដែលទៀង ឬសូន្យឲ្យមានសេចក្ដីសុខក្ដី ។ ព្រោះដូច្នោះ បទថា **យា ច ទិដ្ឋិ យោ ច អស្សាទោ** ( ទិដ្ឋិ និងអស្សាទៈ ) គឺ ទិដ្ឋិនោះ វៀរអស្សាទៈនឹងមានមិនបាន សូម្បីអស្សាទៈនឹងមាន ឬមិនមានទិដ្ឋិ ព្រោះហេតុនោះ ទាំងពីរយ៉ាងទើបធ្វើរួមគ្នាតែមួយ ។

បទថា **អស្សាទទិដ្ឋិ** លោកអធិប្បាយថា បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅក្នុងសេចក្ដីត្រេកអរ ។

ពេលនេះ ព្រះសារីបុត្តត្ថេរលុះបានប្រៀបធៀបជាមួយសូត្រដទៃផ្សេង ៗ ហើយបំណងតិះដៀលមិច្ឆាទិដ្ឋិ និងបុគ្គលជាមិច្ឆាទិដ្ឋិ ទើបពោលពាក្យមានជាអាទិ៍ថា អស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។

បណ្ដាបទទាំងនោះ បទថា **ទិដ្ឋិវិបត្តិ** បានដល់ វិបត្តិដោយទិដ្ឋិ គឺ មិច្ឆាទិដ្ឋិដែលញ៉ាំងសម្មាទិដ្ឋិឲ្យវិនាស ។ បទថា **ទិដ្ឋិវិប្បន្នោ** បុគ្គលដែលមានទិដ្ឋិវិបត្តិ អធិប្បាយថា ឈ្មោះថា **ទិដ្ឋិវិប្បន្នោ** ព្រោះមានសម្មាទិដ្ឋិវិបត្តិ គឺ វិនាស ឬវិបត្តិវិនាសដោយទិដ្ឋិ ។ បុគ្គលដែលមានទិដ្ឋិវិបត្តិនោះ មិនគួរសេពដោយការចូលទៅរក មិនគួរគប់ដោយចិត្ត មិនគួរអង្គុយជិត ដោយការចូលទៅរកហើយអង្គុយចុះនោះឡើយ ។

បទថា **តំ កិស្ស ហេតុ** ( ប្រការនោះព្រោះហេតុអ្វី ) ជាការណបុច្ឆា ( សួរដល់ហេតុ ) របស់បុគ្គលនោះថា ព្រោះហេតុអ្វី ទើប

មិនគួរធ្វើការសេពជាដើមនោះ ។ ឆ្លើយដល់ហេតុថា ព្រោះបុគ្គលនោះមានទិដ្ឋិលាមក ដូច្នោះ ទើបមិនគួរធ្វើការសេពជាដើម ។

បទថា **ទិដ្ឋិ យោ ភគោ** ( ទិដ្ឋិភគៈណា ) សេចក្ដីថា ភគៈកើតឡើងជាមួយទិដ្ឋិ ព្រោះប្រារព្ធទិដ្ឋិថា ទិដ្ឋិរបស់អញល្អ ដូច្នេះ ។ បទថា **ទិដ្ឋិភគរតោ** ( ជាអ្នកត្រេកអរក្នុងទិដ្ឋិភគៈ ) សេចក្ដីថា ជាអ្នកត្រេកអរដោយទិដ្ឋិភគៈនោះ ដូចសំពត់ជ្រលក់ដោយពណ៌ ។ បទថា **ន មហប្ផលំ** ( ជាទានមិនមានផលច្រើន ) គឺ ដោយផលដែលជាវិបាក ។ បទថា **មហានិសំសំ** ( ជាទានមិនមានអានិសង្សច្រើន ) គឺ ដោយផលដែលហូរចុះមក ឬផលគុណ ។ បទថា **បុរិសបុគ្គលស្ស** នៃបុគ្គល គឺ បុរស ។ ព្រោះដោយវោហាររបស់មនុស្សលោក សរីរៈ លោកហៅថា **បុំ** ។ ឈ្មោះ **បុរិស** ព្រោះដេក គឺ ប្រព្រឹត្តទៅក្នុងសរីរៈនោះ ។ **នរក** លោកហៅថា **បុំ** ។ ឈ្មោះ **បុគ្គល** ព្រោះទៅកាន់នរកនោះ ។ ពិតណាស់ ដោយច្រើនសត្វទាំងឡាយ ចុតិចាកសុគតិហើយ រមែងទៅកើតក្នុងទុគ្គតិនោះ ។

បទថា **តំ កិស្ស ហេតុ** គឺ ការមិនមានផលច្រើននោះជាហេតុព្រោះអ្វី ។ បទថា **ទិដ្ឋិ ហិស្ស បាបិកា** សេចក្ដីថា ព្រោះបុគ្គលនោះមានទិដ្ឋិលាមកដូច្នោះ ទើបមិនមានផលច្រើន ។ បទថា **ទ្វេ គតិយោ**



មានគតិជា ២ គឺ មានគតិ ២ ក្នុងគតិ ៥ ជានរកព្រោះទិដ្ឋិវិបត្តិ ជាកំណើតតិរច្ឆានព្រោះទិដ្ឋិដែលដល់ព្រម ។

បទថា **យញ្ចេវ កាយកម្មំ** គឺ កាយកម្ម មានការតាំងភេទរបស់ខ្លួនប្រកបការបដិបត្តិ អភិវាទ រក្សា និងធ្វើអញ្ជលីជាដើម ។

បទថា **យញ្ច វចីកម្មំ** គឺ វចីកម្ម មានការសូត្ររៀន គិតសម្ដែង ដឹកនាំ ក្នុងលទ្ធិរបស់ខ្លួនជាដើម ។

បទថា **យញ្ច មនោកម្មំ** គឺ មនោកម្មប្រកបដោយការគិតនឹកដល់លោកនេះ លោកខាងមុខ និងវត្ថុដែលធ្វើហើយ និងមិនទាន់បានធ្វើ ។ កាយកម្ម វចីកម្ម មនោកម្ម ក្នុងស្មៅ កំណាត់ឈើ ស្រូវពូជទាំងឡាយ និងក្នុងការបង្អោនឲ្យទទួលបរិភោគទាន របស់សត្វអ្នកមានទិដ្ឋិ ។ បទថា **យថាទិដ្ឋិ** ( តាមទិដ្ឋិ ) គឺ សមគួរដល់ទិដ្ឋិនោះ ។ បទថា **សមត្តំ** គឺ ឲ្យបរិបូរណ៍ ។ បទថា **សមាទិន្នំ** (សមាទាន) គឺ កាន់យក ។

ប៉ុន្តែក្នុងអដ្ឋកថា លោកពោលទុកថា កាយកម្មនោះ មាន ៣ យ៉ាង គឺ កាយកម្មតាំងទុកតាមទិដ្ឋិ ១ , កាយកម្មកើតរួមជាមួយទិដ្ឋិ ១ , កាយកម្មអនុលោមតាមទិដ្ឋិ ១ ។ ក្នុងកាយទ្វារ ៣ យ៉ាងនោះ កាយកម្ម ពោលគឺ បាណាតិបាត អទិន្នាទាន និងមិច្ឆាចារ របស់អ្នកមានទិដ្ឋិយ៉ាងនេះថា អ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុង

កាម មិនមានបាប ដែលមានកាយកម្មនោះជាហេតុ បាបមិនមកដល់ខ្លួន នេះឈ្មោះថា កាយកម្មតាំងទុកតាមទិដ្ឋិ ។ កាយកម្មកើតរួមគ្នាជាមួយការឃើញតាមទិដ្ឋិថា អ្នកសម្លាប់សត្វ អ្នកលួចទ្រព្យ អ្នកប្រព្រឹត្តខុសក្នុងកាម មិនមានបាប ដែលមានកាយកម្មនោះជាហេតុ បាបមិនមកកាន់ខ្លួន នេះឈ្មោះថា កាយកម្មកើតរួមជាមួយទិដ្ឋិ ។ កាយកម្មនោះឯង ដែលប្រកបដោយមិច្ឆាទិដ្ឋិចំពោះអ្នកសមាទានហើយ កាន់យកហើយ ស្ទាបអង្អែលហើយឲ្យបរិបូរណ៍ ឈ្មោះថា កាយកម្មអនុលោមតាមទិដ្ឋិ ។ សូម្បីក្នុងវចីកម្ម មនោកម្ម ក៏មានន័យដូចគ្នា ។ មយ៉ាងទៀត ក្នុងវចីកម្ម មនោកម្មនេះ គប្បីប្រកបថា អ្នកនិយាយកុហក និយាយស៊កសៀត និយាយពាក្យគ្រោតគ្រាត និយាយរោយរាយឥតប្រយោជន៍ មានសេចក្ដីលោភ មានចិត្តព្យាបាទ មានការឃើញខុស មិនមានបាប ដែលមានវចីកម្ម មនោកម្មនោះជាហេតុ បាបមិនមកដល់ខ្លួន ដូច្នេះ ។ មយ៉ាងទៀត ន័យដែលពោលដោយការរក្សាភេទ ការរៀនសូត្រ និងការគិតរបស់មនុស្សលោកជាដើម ជាន័យដែលល្អក្នុងប្រការនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចេតនាជាដើម ដូចតទៅនេះ ។ ការគិតដែលកើតរួមជាមួយទិដ្ឋិ ឈ្មោះថា **ចេតនា** ។ សេចក្ដីត្រូវការដែល



កើតរួមជាមួយទិដ្ឋិ ឈ្មោះថា សេចក្ដីប្រាថ្នា ។ ការតាំងចិត្តដោយអំណាចនៃសេចក្ដីប្រាថ្នាដោយការតាំងចិត្ត ឈ្មោះថា ការតាំងចិត្ត ។ ធម៌ទាំងឡាយ ដែលទាក់ទងនឹងសង្ខារក្ខន្ធ មានផស្សៈជាដើម សម្បយុត្តដោយចេតនាជាដើមទាំងនោះ ឈ្មោះថា សង្ខារ ។

ដោយបទមានជាអាទិ៍ថា **អនិដ្ឋាយ** ( ដើម្បីផលមិនគួរប្រាថ្នា ) លោកពោលដល់ទុក្ខទាំងនោះ ។ ព្រោះទុក្ខដែលសត្វទាំងឡាយអ្នកប្រាថ្នាសេចក្ដីសុខ ឈ្មោះថា មិនប្រាថ្នា ព្រោះមិនស្វែងរក ឈ្មោះថា មិនគួរប្រាថ្នា ព្រោះមិនជាទីស្រឡាញ់ ឈ្មោះថា មិនគួរពេញចិត្ត ព្រោះមិនធ្វើឲ្យចម្រើនចិត្ត និងព្រោះមិនជាទីពេញចិត្ត ឈ្មោះថា មិនជាប្រយោជន៍ ព្រោះមិនចម្រើនតទៅ ឈ្មោះថា ជាទុក្ខ ព្រោះបៀតបៀន ។

បទថា **តំ កិស្ស ហេតុ** សេចក្ដីថា ការប្រព្រឹត្តទៅយ៉ាងនោះព្រោះហេតុអ្វី ។ សម្ដែងដល់ហេតុនោះថា ព្រោះបុគ្គលនោះ មានទិដ្ឋលាមក ។ អធិប្បាយថា ព្រោះទិដ្ឋិរបស់បុគ្គលនោះថោកទាប លាមក ដូច្នោះទើបប្រព្រឹត្តទៅយ៉ាងនោះ ។

បទថា **អល្លាយ បឋវិយា និក្ខិត្តំ** ( ដាក់ចុះក្នុងដីសើម ) គឺ ដែលគេដាំចុះទៅក្នុងដីដែលសើមដោយទឹក ។ បទថា **បឋវីរសំ អាបោរសំ** ( រសដី រសទឹក ) សេចក្ដីថា ក្នុងទីនោះ ៗ សម្បូរណ៍ដោយផែនដី និង

ទឹក ។ ព្រោះក្នុងទីដែលមានពូជខូច ផែនដីទាំងអស់ និងទឹកទាំងអស់ មិនអាចញុាំងពូជ និងផលឲ្យកើតបាន ។ ចំណែកពូជ ដែលដី និងទឹកទាំងនោះប៉ុណ្ណោះ សម្ផស្សពូជ រមែងឲ្យពូជ និងផលកើតបាន ។ ព្រោះដូច្នោះ ទឹកនិ្ទងនោះ ទើបជាបច្ច័យដើម្បីចិញ្ចឹមពូជ គប្បីជ្រាបថា ជារសផែន ដី ជារសទឹក ។ ព្រោះ **រស** សព្ទ មានសេចក្តីសម្បូរណ៍ ដូចលោកពោលទុកថា ឈ្មោះថា **រស** លោកពោលដោយសេចក្តីសម្បូរណ៍ ដោយកិច្ច មា្យ៉ាងទៀត កាលមនុស្សលោកពោលថា គន្ធព្វមានសំឡេងល្អ រមែងដឹងសេចក្តីថា គន្ធព្វសម្បូរណ៍ល្អហើយ ។

បទថា **ឧបាទិយតិ** គឺ កាន់យក ។ ព្រោះពូជបានផែនដីដែលជាបច្ច័យ រមែងបង្កើតផលបាន ។ បទថា **សព្វន្តំ** គឺ រសទាំងពួងនោះ ។ បទថា **តិត្តកត្តាយ** ( ដើម្បីភាពជារបស់មានរសល្វីង ) សេចក្តីថា រសផែនដី និងរសទឹកនោះ សូម្បីមិនមានរសល្វីង អាស្រ័យពូជល្វីង រមែងប្រព្រឹត្តទៅជារបស់ល្វីងនៃដើមស្តៅ និងផ្លែជាដើមប៉ុណ្ណោះ ។ បទថា **កដុកត្តាយ** ( មានរសប្រហាត ) នេះជាវេវចនៈរបស់បទមុននោះឯង ។ គប្បីជ្រាបថា រសល្វីងក្នុងទីនេះ ឈ្មោះថា រសប្រហាត ព្រោះមិនជាទីពេញចិត្ត ដូចក្នុងអាគតស្ថានថា :-

**ផ្លែស្វាយនេះ កាលមុនបានទទួលការនិយម មានពណ៌ ក្លិន**



**រស ព្រោះហេតុអ្វី ផ្លែស្វាយទើបមានរសប្រហាតទៅវិញ ។**

បទថា **អសារតាយ** ដើម្បីភាពមិនមានសារៈ គឺ មិនមានរសផ្អែម ។ បាឋៈថា **អសាទុត្តាយ** ខ្លះ សេចក្តីថា មានរសមិនឆ្ងាញ់ ។ ព្រោះបទថា **សាទុ** ប្រែថា ឆ្ងាញ់ ។ បទថា **ពីជំ ហិស្ស** បានដល់ ពូជរបស់ស្តៅជាដើមនោះ ។ បទថា **ឯវមេវំ** កាត់បទជា **ឯវំ ឯវំ** ។ ព្រោះសុខវេទនា ជាសេចក្តីត្រេកអរយ៉ាងក្រៃលែង ។ ដូច្នោះ លោកទើបសម្តែងដល់ទោសនៃមិច្ឆាទិដ្ឋិ ដោយអំណាចនៃទុក្ខវេទនា ។ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងដល់ទោសនៃមិច្ឆាទិដ្ឋិដោយប្រភេទ ១៨ យ៉ាង ទើបពោលពាក្យមានជាអាទិ៍ថា អស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។ បទនោះមានសេចក្តីដូចបានពោលទុកហើយ ។

បទថា **ឥមេហិ អដ្ឋារសហិ អាការេហិ បរិយុដ្ឋិតចិត្តស្ស សំយោគោ** ( ទំនាក់ទំនងនៃចិត្ត ដែលទិដ្ឋិរួបរឹតដោយអាការ ១៨ យ៉ាងទាំងនេះ ) លោកសម្តែងដល់ការចងព័ទ្ធក្នុងសង្សារ ដោយទិដ្ឋិនោះឯង ។

ក៏ព្រោះសំយោជនៈ សូម្បីជាទិដ្ឋិក៏មាន មិនមែនជាទិដ្ឋិក៏មាន ដូច្នោះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងប្រភេទនោះ ទើបលោកពោលពាក្យមានជាអាទិ៍ថា **អត្ថិ សំយោជនានិ ចេវ** សំយោជន៍មានហើយ

ដូច្នេះ ។

ក្នុងបទទាំងនោះ ព្រោះកាមរាគសំយោជន៍ មានមកថា **អនុនយសំយោជនំ** គឺ សំយោជន៍ដែលមានន័យតាមគ្នា ។ ដូច្នោះ លោកទើបពោលថា **អនុនយសំយោជនំ** គប្បីជ្រាបថា អនុនយសំយោជន៍នេះ លោកពោលសំដៅដល់សេចក្ដីលោភដែលប្រព្រឹត្តទៅ ដែលមិនទាន់ដល់ភាពជាកាមរាគសំយោជន៍ ។ ក្នុងវារៈសូម្បីជាមូលហេតុមានខន្ធ និងអាយតនៈដ៏សេសជាដើម ក៏គប្បីជ្រាបសេចក្ដីដោយន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ព្រោះអស្សាទៈមានវេទនាដ៏ក្រៃលែង លោកទើបធ្វើទេសនា មានវេទនាជាទីបំផុត មិនកាន់យកសញ្ញាជាដើម ។

បទថា **ឥមេហិ បញ្ចត្តឹសាយ អាការេហិ** ( ដោយអាការ ៣៥ ទាំងនេះ ) គឺ ដោយអាការ ៣៥ ដោយអំណាចនៃអារម្មណ៍ គឺ អស្សាទៈដែលកើតឡើងព្រោះអាស្រ័យវត្ថុ ៣៥ ទាំងនេះ គឺ បញ្ចក្ខន្ធ ៥ និងអាយតនៈខាងក្នុង ៦ ពួកជាដើម ។

(ចប់ អដ្ឋកថាអស្សាទទិដ្ឋិនិទ្ទេស)



## អដ្ឋកថា អត្តានុទិដ្ឋិនិទ្ទេស

### ( សម្ដែងដល់អត្តានុទិដ្ឋិ )

គប្បីជ្រាបវិនិច្ឆ័យក្នុងអត្តានុទិដ្ឋិ ដូចតទៅនេះ ។ បទថា **អស្សុតវា បុថុជ្ជនោ** ( បុថុជ្ជនអ្នកមិនបានស្ដាប់ ) គឺ អ្នកគួរដឹង មិនបានស្ដាប់ ព្រោះមិនមានការសិក្សារៀនសូត្រ និងការចាក់ធ្លុះ ។ អ្នកដែលឈ្មោះថា មិនមានការសិក្សា ធ្វើការបដិសេធអត្តានុទិដ្ឋិ ព្រោះប្រាសចាកការរៀនសូត្រ ការសាកសួរ និងវិនិច្ឆ័យ ក្នុងខន្ធ អាយតនៈ ធាតុ សច្ចៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម ។ និងអ្នកដែលឈ្មោះថាមិនចាក់ធ្លុះ ព្រោះមិនចាក់ធ្លុះដល់ការបដិបត្តិដែលគួរចាក់ធ្លុះ ។ ឈ្មោះថា ជាញេយ្យបុគ្គលអ្នកមិនបានស្ដាប់ ព្រោះមិនមានការសិក្សា និងការចាក់ធ្លុះ ។

ពិតណាស់ បទថា **សុតំ** ( ស្ដាប់ហើយ ) គឺ មានការសិក្សាព្រះពុទ្ធវចនៈ និងចាក់ធ្លុះដោយការពោលដល់ហេតុ ព្រោះមានសុតៈជាផល ឈ្មោះថា **សុតវា** អ្នកស្ដាប់ ព្រោះមានសុតៈនោះ អ្នកមិនមានសុតៈ ឈ្មោះថា អ្នកមិនបានស្ដាប់ ។ បុគ្គលអ្នកមិនបានស្ដាប់នោះ

**ជាបុថុជ្ជន ដោយហេតុញ៉ាំងកិលេសដ៏ក្រាស់ឲ្យកើតជាដើម**

**ជននេះមានឈ្មោះថា មានកិលេសក្រាស់ ព្រោះជាអ្នកញ៉ាំង កិលេសដ៏ក្រាស់ឲ្យកើតឡើងឈានចុះដល់ចំណែកខាងក្នុង ។**

ពិតណាស់ ជននោះជាបុថុជ្ជនដោយហេតុញ៉ាំងកិលេសជាដើមដ៏ក្រាស់មានប្រការផ្សេង ៗ ឲ្យកើតឡើង ។ សមដូចដែលលោកពោលទុកថា ឈ្មោះថា បុថុជ្ជន ព្រោះញ៉ាំងកិលេសដ៏ក្រាស់ឲ្យកើតឡើង , ព្រោះកម្ចាត់សក្កាយទិដ្ឋិដ៏ក្រាស់មិនបាន , ព្រោះឃើញមុខនៃសាស្ដាជាច្រើន , ព្រោះដោតក្រងដោយគតិផ្សេង ៗ ដ៏ច្រើន ព្រោះតាក់តែងអភិសង្ខារផ្សេង ៗ ដ៏ច្រើន , ព្រោះត្រូវអន្ទង់ គឺ កិលេសផ្សេង ៗ ដ៏ច្រើនបន្សាត់ទៅ ព្រោះក្ដៅដោយសេចក្ដីក្ដៅផ្សេង ៗ ជាច្រើន , ព្រោះត្រូវសេចក្ដីដុតរោលផ្សេង ៗ ដ៏ច្រើនដុតបំផ្លាញ , ព្រោះចំណង់ ប្រាថ្នា ត្រេកអរ ជ្រប់ ជាប់ជំពាក់ ជាប់ ពាក់ព័ន្ធ ក្នុងកាមគុណ ៥ ដោយចំណែកច្រើន ព្រោះខ្ទប់ រារាំង បិទ បិទបាំង គ្របទុក ដោយនីវរណៈ ៥ ដោយចំណែកច្រើន ។

ម្យ៉ាងវិញទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះជាជនមានការប្រព្រឹត្តធម៌ដែលធ្លាក់ចុះក្នុងខាងក្នុង មានការងាកមុខចេញពីអរិយធម៌ នឹងដោយការរាប់មិនអស់ ឬព្រោះជននេះច្រើនបែកចេញជាពួក មិនសមាគមជាមួយព្រះអរិយៈដែលប្រកបដោយគុណ មានសីលគុណ និងសុតៈជាដើម ។



ដោយ ២ បទទាំងនេះថា **អស្សុតវា បុថុជ្ជនោ** លោកពោលបុថុជ្ជន ២ ជំពូកថា :-

**ព្រះសម្ពុទ្ធជាម្ចាស់ ជាផៅពង្សព្រះអាទិត្យ ត្រាស់ដល់ បុថុជ្ជនទុក ២ ជំពូក គឺ អន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១**

ក្នុងបុថុជ្ជន ២ ជំពូកនោះ គប្បីជ្រាបថា លោកពោលដល់អន្ធបុថុជ្ជន ។ បទថា **អរិយា** ក្នុងបទមានជាអាទិ៍ថា **អរិយានំ អទស្សាវី** មិនបានឃើញព្រះអរិយជាម្ចាស់ ព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ និងព្រះពុទ្ធសាវកទាំងឡាយ លោកពោលថា ជាអរិយៈ ក្នុងទីនេះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះជាអរិយៈ ព្រោះជាអ្នកឆ្ងាយចាកកិលេស ព្រោះទ្រង់មិននាំទៅកាន់ផ្លូវវិនាស ព្រោះទ្រង់នាំទៅកាន់ផ្លូវចម្រើន ព្រោះញ៉ាំងលោក ព្រមទាំងទេវលោកឲ្យផុតទុក្ខ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក្នុងលោកព្រមទាំងទេវលោក ។ល។ តថាគតពោលថា តថាគតជាអរិយៈ ។

ម្យ៉ាងទៀត ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវករបស់ព្រះតថាគត គប្បីជ្រាបថា ជាសប្បុរស ក្នុងបទថា **សប្បុរិសា** នេះ ។ ពិតណាស់ លោកទាំងនោះឈ្មោះថា ជាសប្បុរស ព្រោះជាសប្បុរសដ៏ប្រសើរ ដោយការប្រកបលោកុត្តរគុណ ។ ម្យ៉ាងវិញទៀត លោកទាំង

អស់នោះ លោកក៏ពោលទុកទាំងពីរយ៉ាង សូម្បីព្រះពុទ្ធជាម្ចាស់ទាំងឡាយ ព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ សូម្បីព្រះពុទ្ធសាវកទាំងឡាយ ទាំងជាព្រះអរិយៈ និងទាំងជាសប្បុរស ។ សមដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា :-

**អ្នកណាដែលជាបុគ្គលកតញ្ញូកតវេទី ជាអ្នកប្រាជ្ញ ជាកល្យាណមិត្ត និងជាអ្នកមានភក្តីមាំមួន រមែងធ្វើកិច្ចរបស់អ្នកបានទទួលទុក្ខដោយគោរព អ្នកប្រាជ្ញទាំងឡាយ រមែងពោលដល់អ្នកនោះថា ជាសប្បុរស ។**

ក្នុងបទនេះ លោកពោលព្រះបច្ចេកពុទ្ធថា ជាអ្នកកតញ្ញូកតវេទី ជាអ្នកប្រាជ្ញ លោកពោលព្រះពុទ្ធសាវកថា ជាកល្យាណមិត្ត និងជាអ្នកមានភក្តីមាំមួន ពោលចំពោះព្រះសម្ពុទ្ធជាម្ចាស់ថា រមែងធ្វើកិច្ចរបស់អ្នកដែលទទួលទុក្ខដោយសេចក្តីគោរព ។

ឥឡូវនេះ គប្បីជ្រាបថា អ្នកមានប្រក្រតីមិនឃើញព្រះអរិយៈទាំងនោះ និងមិនធ្វើសេចក្តីល្អក្នុងការឃើញថា ជាអ្នកមិនឃើញព្រះអរិយៈទាំងឡាយ ។ ម្យ៉ាងទៀត អ្នកនោះមាន ២ យ៉ាង គឺមិនឃើញដោយចក្ខុ ១ មិនឃើញដោយញាណ ១ ។ ក្នុង ២ យ៉ាងនោះ ក្នុងទីនេះ លោកបំណងយកមិនឃើញដោយញាណ ។ ពិតណាស់ ព្រះអរិយៈ



ទាំងឡាយ សូម្បីឃើញដោយមំសចក្ខុ ឬដោយទិព្វចក្ខុ ក៏ឈ្មោះថាមិនឃើញ ព្រោះចក្ខុទាំងនោះកាន់យកត្រឹមតែពណ៌ ព្រោះមិនមែនជាអារម្មណ៍នៃភាពជាអរិយៈ ។ ព្រោះថា សូម្បីឆ្កែស្រុក ឆ្កែព្រៃជាដើម ក៏ឃើញព្រះអរិយៈដោយចក្ខុបាន ។ ជនទាំងនោះទើបឈ្មោះថា មិនឃើញព្រះអរិយៈ ។ ព្រោះដូច្នោះ ការឃើញដោយចក្ខុ ទើបមិនជាការឃើញ ការឃើញដោយញាណប៉ុណ្ណោះ ទើបជាការឃើញ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលវក្កលិ ប្រយោជន៍អ្វីដោយការដែលអ្នកឃើញកាយស្អុយនេះ ម្នាលវក្កលិ អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថា ឃើញតថាគត ។ ព្រោះដូច្នោះ សូម្បីឃើញដោយចក្ខុ ក៏មិនបានឃើញដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ដែលព្រះអរិយៈឃើញហើយដោយញាណ និងមិនបានចាក់ធ្លុះធម៌ដែលព្រះអរិយៈសម្រេចហើយ គប្បីជ្រាបថា ឈ្មោះថា មិនឃើញព្រះអរិយៈទាំងឡាយ ព្រោះមិនឃើញភាពជាអរិយៈនៃធម៌ដែលធ្វើឲ្យជាអរិយៈ ។

បទថា **អរិយធម្មស្ស អកោវិទោ** បានដល់ មិនឆ្លាតក្នុងធម៌របស់ព្រះអរិយៈ គឺ មិនឆ្លាតក្នុងអរិយធម៌ មានសតិប្បដ្ឋានជាដើម ។ ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អរិយធម្មេ អវិនីតោ** មិនបានទទួលការណែនាំក្នុងធម៌របស់ព្រះអរិយៈនេះ ដូចតទៅ :-

**ឈ្មោះថា វិន័យមាន ២ យ៉ាង ក្នុងវិន័យ ២ យ៉ាងនេះ**
**វិន័យមួយ ៗ មាន ៥ យ៉ាង ព្រោះមិនមានវិន័យនោះ**
**លោកទើបពោលថា អ្នកមិនបានទទួលការណែនាំ ។**

ពិតណាស់ វិន័យនេះមាន ២ យ៉ាង គឺ **សំវរវិន័យ** ១ **បហានវិន័យ** ១ ។ ក្នុងវិន័យសូម្បី ២ យ៉ាងនេះ វិន័យប្រការមួយ ៗ ចែកជា ៥ យ៉ាង ។

សូម្បីសំវរវិន័យ ក៏មាន ៥ យ៉ាង គឺ សីលសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។

សូម្បីបហានវិន័យ ក៏មាន ៥ យ៉ាង គឺ តទង្គប្បហាន ១ វិក្ខម្ភនប្បហាន ១ សមុច្ឆេទប្បហាន ១ បដិបស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ។

ក្នុងសំវរវិន័យនោះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ។ ភិក្ខុចូលដល់ ចូលដល់ព្រម ដោយបាតិមោក្ខសំវរៈ នេះឈ្មោះថា សីលសំវរៈ ។ ភិក្ខុរក្សាចក្ខុន្ទ្រិយ ដល់នូវភាពសង្រួមក្នុងចក្ខុន្ទ្រិយ នេះឈ្មោះថា សតិសំវរៈ ។

**សតិជាគ្រឿងរាំងក្រសែក្នុងលោក តថាគតពោលសតិថា**
**ជាគ្រឿងរាំងក្រសែទាំងឡាយ ក្រសែទាំងនោះ រមែងបិទ**



**បានដោយបញ្ញា ។**

នេះឈ្មោះថា ញាណសំវរៈ ។ ភាពជាអ្នកអត់ទ្រាំចំពោះក្តៅ និងត្រជាក់ នេះឈ្មោះថា ខន្តិសំវរៈ ។ មិនឲ្យកាមវិតក្កៈដែលកើតឡើងហើយ គ្របសង្កត់បាន នេះឈ្មោះថា វីរិយសំវរៈ ។

សំវរៈសូម្បីទាំងអស់ លោកពោលថា **សំវរ** ព្រោះសង្រួមកាយទុច្ចរិតជាដើម ដែលគួរសង្រួម និងដែលគួរកម្ចាត់ចេញតាមមុខនាទីរបស់ខ្លួន ។ លោកពោលថា **វិន័យ** ព្រោះកម្ចាត់ចេញ ។ គប្បីជ្រាបសំវរវិន័យចែកចេញជា ៥ ចំណែក ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ការលះបង់វត្ថុមិនជាប្រយោជន៍នោះ ៗ ដោយវិបស្សនាញាណនោះ ៗ ព្រោះជាបដិបក្ខក្នុងវិបស្សនាញាណ មានការកំណត់នាមរូបជាដើម ដូចលះភាពងងឹតដោយពន្លឺប្រទីបដូច្នោះ ដូចជាការលះសក្កាយទិដ្ឋិ ដោយការកំណត់នាមរូប លះការឃើញថា មិនមានហេតុ និងជាហេតុមិនស្មើ ដោយការកំណត់បច្ច័យ លះបង់សេចក្តីសង្ស័យដោយឆ្លងផុតសេចក្តីសង្ស័យ លះបង់ការប្រកាន់ថាជាយើងជារបស់យើង ដោយពិចារណាជាកង ៗ លះសេចក្តីសម្គាល់ក្នុងវត្ថុមិនមែនមគ្គ ថាជាមគ្គ ដោយកំណត់មគ្គ និងមិនមែនមគ្គ លះឧច្ឆេទទិដ្ឋិដោយឃើញការកើត លះសស្សតទិដ្ឋិដោយឃើញការវិនាស លះ

ការសម្គាល់ក្នុងវត្ថុមានភ័យថា មិនមានភ័យ ដោយការឃើញភ័យ លះការសម្គាល់ក្នុងវត្ថុដែលគួរពេញចិត្ត ដោយការឃើញទោស លះការសម្គាល់ក្នុងវត្ថុដែលគួររីករាយ ដោយការពិចារណាឃើញសេចក្តីនឿយណាយ លះសេចក្តីប្រាថ្នាក្នុងទីមិនរួចផុត ដោយញាណ គឺសេចក្តីប្រាថ្នាក្នុងទីដែលត្រូវរួចផុត លះការមិនព្រងើយ ដោយឧបេក្ខាញាណ លះសេចក្តីហួងហែងក្នុងការរស់នៅដោយធម៌ និងហួងហែងនិព្វានដោយអនុលោមញ្ញាណ ( កំណត់ដឹងដោយការព្រមតាម ) លះសេចក្តីប្រកាន់ក្នុងសង្ខារនិមិត្តដោយគោត្រភូញាណ ( ញាណឆ្លងផុតគោត្របុថុជ្ជន ) នេះឈ្មោះថា **តទង្គប្បហាន** ។

ការលះបង់ធម៌ មាននីវរណៈជាដើមទាំងនោះ ៗ ព្រោះការពារសេចក្តីប្រព្រឹត្តទៅដោយសមាធិ ដែលជាឧបចារសមាធិ និងអប្បនាសមាធិ ដូចការវែកសារាយក្នុងទឹកឲ្យស្រឡះទៅដោយឆ្នាំង ឈ្មោះថា **វិក្ខម្ភនប្បហាន** ។

ការលះសេចក្តីប្រកាន់ ដោយកិលេសដែលជាចំណែកនៃសមុទ័យ ដែលលោកពោលទុកដោយន័យមានជាអាទិ៍ថា ដើម្បីលះទិដ្ឋិទាំងឡាយក្នុងសន្តានរបស់ខ្លួន ដោយមគ្គនោះ ៗ ព្រោះចម្រើនអរិយមគ្គ ៤ ដោយមិនឲ្យប្រព្រឹត្តតទៅទៀត នេះឈ្មោះថា **សមុច្ឆេទប្បហាន** ។



កិលេសទាំងឡាយដែលស្ងប់រំងាប់ ក្នុងខណៈនៃផល ឈ្មោះថា **បដិបស្សទ្ធិប្បហាន** ។

ការរំលត់ ដែលជាការលះគ្រឿងតាក់តែងទាំងអស់ ព្រោះរលាស់ចេញអំពីគ្រឿងតាក់តែងទាំងអស់បានហើយ នេះឈ្មោះថា **និស្សរណប្បហាន** ។

ក៏បហានទាំងអស់នេះ ឈ្មោះថា **បហាន** ព្រោះអត្ថថា **លះបង់** ឈ្មោះថា **វិន័យ** ព្រោះអត្ថថា ណែនាំឲ្យវិសេស ដូច្នោះលោកទើបពោលថា **បហានវិន័យ** ។ ម្យ៉ាងវិញទៀត បហាននេះ ហៅថា **បហាវិន័យ** ព្រោះលះអកុសលនោះ ៗ ព្រោះមានវិន័យនោះ ៗ ។ សូម្បីបហានវិន័យគប្បីជ្រាបថា ចែកចេញជា ៥ យ៉ាង ដោយប្រការដូច្នេះ ។

**វិន័យនេះ** ដោយសង្ខេបមាន ២ យ៉ាងនេះ និងដោយប្រភេទមាន ១០ យ៉ាង មិនមានដល់បុថុជ្ជនអ្នកមិនបានស្តាប់ ព្រោះខ្វះសំវរៈ និងព្រោះមិនលះវត្ថុដែលគួរលះ ដូច្នោះ បុថុជ្ជននេះ លោកទើបពោលថា មិនបានទទួលការណែនាំ ព្រោះមិនមានវិន័យនោះ ។ សូម្បីក្នុងបទថា **សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ** បុថុជ្ជនអ្នកមិនបានស្តាប់ មិនបានឃើញសប្បុរស មិនឆ្លាតក្នុងធម៌របស់សប្បុរស មិនបានទទួលពាក្យណែនាំក្នុងធម៌របស់

សប្បុរស នេះក៏មានន័យនេះ ។ ដោយសេចក្តីបទនេះ មិនមានហេតុផ្សេងគ្នាឡើយ ។

សមដូចលោកពោលទុកថា អ្នកណាជាអរិយៈ អ្នកនោះជាសប្បុរស ។ អ្នកណាជាសប្បុរស អ្នកនោះជាអរិយៈ ។ ធម៌ណារបស់ព្រះអរិយៈ ធម៌នោះជារបស់សប្បុរស ។ ធម៌ណារបស់សប្បុរស ធម៌នោះជារបស់ព្រះអរិយៈ ។ វិន័យណាជាវិន័យរបស់ព្រះអរិយៈ វិន័យនោះជាវិន័យរបស់សប្បុរស ។ វិន័យណាជាវិន័យរបស់សប្បុរស វិន័យនោះ ជាវិន័យរបស់ព្រះអរិយៈ ។ រួមសេចក្តីថា អរិយៈក្តី សប្បុរសក្តី ធម៌របស់អរិយៈក្តី ធម៌របស់សប្បុរសក្តី វិន័យរបស់អរិយៈក្តី វិន័យរបស់សប្បុរសក្តីទាំងនោះ គឺ ដូចគ្នា តាំងនៅក្នុងទីតែមួយ ស្មើគ្នាដោយភាគស្មើគ្នា កើតក្នុងទីនោះដូចគ្នា ដោយប្រការដូច្នេះ ។

ក៏ព្រោះហេតុអ្វី ព្រះថេរៈទើបសួរថា អត្តានុទិដ្ឋិមានការឃើញខុសដោយអាការ ២០ ដូចម្តេច ហើយមិនដោះស្រាយពាក្យសួរនោះ ត្រឡប់ជាពោលអាងដល់បុថុជ្ជនយ៉ាងនេះថា បុថុជ្ជនក្នុងលោកនេះមិនបានស្តាប់ ដូច្នេះ ។ គប្បីជ្រាបថា ព្រះថេរៈដើម្បីធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ដោយទេសនាជាបុគ្គលាធិដ្ឋាន ទើបពោលអាងដល់បុថុជ្ជនមុន ។



ព្រះថេរៈលុះពោលអាងដល់បុថុជ្ជនយ៉ាងនេះហើយ ឥឡូវនេះកាលនឹងសម្តែងដល់ឧទ្ទេសនៃការប្រកាន់ខុស ទើបពោលពាក្យមានជាអាទិ៍ថា **រូបំ អត្តតោ សមនុបស្សតិ** បុថុជ្ជនរមែងឃើញរូបថាជាខ្លួនដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនោះ ដូចតទៅនេះ ។ បទថា **រូបំ អត្តតោ សមនុបស្សតិ** សេចក្តីថា រមែងឃើញរូបក្ខន្ធ និងកសិណរូបដោយទិដ្ឋិថាជាតួខ្លួន ។ តែនិទ្ទេសគប្បីជ្រាបថា លោកមិនបានពោលដល់រូបនោះថា ការប្រកាន់ក្នុងរូបក្ខន្ធរបស់បុថុជ្ជននោះប្រាកដ ព្រោះអធិការនៃបញ្ចក្ខន្ធ ហើយពោលដល់កសិណរូបជាសាមញ្ញថា **រូប** ។

បទថា **រូបវន្តំ វា អត្តានំ** ( ឃើញខ្លួនថាមានរូប ) គឺ ប្រកាន់វត្ថុមិនមានរូបថាខ្លួន ហើយឃើញខ្លួននោះថាមានរូប ។

បទថា **អត្តនិ វា រូបំ** ( ឃើញរូបក្នុងខ្លួន ) គឺ ប្រកាន់វត្ថុមិនមានរូបនោះថាជាតួខ្លួន ហើយឃើញរូបក្នុងខ្លួននោះ ។

បទថា **រូបស្មឹ វា អត្តានំ** ( ឃើញខ្លួនក្នុងរូប ) គឺ ប្រកាន់វត្ថុមិនមានរូបនោះឯងថាតួខ្លួន ហើយឃើញខ្លួននោះក្នុងរូប ។

ក្នុងបទទាំងនោះ បទថា **រូបំ អត្តតោ សមនុបស្សតិ** ជារូបតែម្យ៉ាង លោកពោលថាជាតួខ្លួន ។ វត្ថុមិនមែនរូបក្នុងឋានៈ ៧ ទាំងនេះ គឺ ឃើញខ្លួនថាមានរូប ១ , ឃើញរូបក្នុងខ្លួន ១ , ឃើញខ្លួន

ក្នុងរូប ១ , ឃើញវេទនា ១ , សញ្ញា ១ , សង្ខារ ១ , វិញ្ញាណ ១ ថាជាខ្លួន លោកពោលថា ជាតួខ្លួន ។

លោកពោលដល់តួខ្លួន លាយដោយរូប និងអរូបក្នុងឋានៈ ១២ យ៉ាងដោយអំណាចនៃវេទនា ៣ ក្នុងខន្ធ ៤ យ៉ាងនេះថា ឃើញខ្លួនថាមានវេទនា , ឃើញវេទនាក្នុងខ្លួន , ឃើញខ្លួនក្នុងវេទនា ម្យ៉ាងទៀត ទិដ្ឋិ ២០ ទាំងនោះ ហាមមគ្គ មិនហាមសួគ៌ កម្ចាត់បានដោយសោត-បត្តិមគ្គ ។

ឥឡូវនេះ ព្រះថេរៈកាលនឹងចង្អុលបង្ហាញដល់រូបនោះ ទើបពោលពាក្យមានជាអាទិ៍ថា **កថំ រូបំ** ឃើញរូបថាជាខ្លួនដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **បឋវីកសិណំ** បានដល់ បឋវីកសិណ ដែលជាបដិភាគនិមិត្តឲ្យកើតឡើង ព្រោះអាស្រ័យបឋវីមណ្ឌល ដោយការផ្សាយទូទៅ ។ បទថា **អហំ** លោកសំដៅដល់ខ្លួននោះឯង ។ បទថា **អត្តំ** គឺ ខ្លួន ។ បទថា **អទ្វយំ** មិនមែនពីរ គឺ តែមួយ ។ បទថា **តេលប្បទីបស្ស** គឺ ប្រទីបដែលមានប្រេង ។ បទថា **ឈាយតោ** គឺ ឆេះឡើងហើយ ។ បទមានជាអាទិ៍ថា **យា អច្ចិ សោ វណ្ណោ** អណ្ដាតភ្លើងណា ពន្លឺក៏ដូច្នោះ លោកពោល ព្រោះប្រាសចាកអណ្ដាតភ្លើងហើយ ក៏មិនមានពន្លឺ ។



បទថា **យា ច ទិដ្ឋិ យញ្ច វត្ថុ** ទិដ្ឋិ និងវត្ថុ អធិប្បាយថា លោកធ្វើទាំងពីរយ៉ាងនោះរួមគ្នា ហើយពោលថា អត្តានុទិដ្ឋិ មានរូបជាវត្ថុ ។

អាបោកសិណជាដើម ជាកសិណនិមិត្តកើតឡើង ព្រោះអាស្រ័យទឹកជាដើម ។ ម្យ៉ាងទៀត អាកាសកសិណដែលកំណត់ទុកសូម្បីជាអារម្មណ៍នៃរូបជ្ឈាន កាលលោកពោលថា ជាអាកាសកសិណ ក៏ជាការពោលលាយគ្នាដោយអារម្មណ៍នៃអរូបជ្ឈាន ដែលជាកសិ-ណុគ្ឃាដិមាកាស ព្រោះហេតុនោះ គប្បីជ្រាបថា លោកទើបមិនកាន់យក ។ ព្រោះអធិការនៃរូប ទើបមិនគួរកាន់យកវិញ្ញាណកសិណដោយពិតដូច្នេះឯង ។

បទថា **ឥធេកច្ចោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ** បុគ្គលពួកខ្លះក្នុងលោកនេះ រមែងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន លោកមិនចែកខន្ធ ៤ ហើយពោលដោយអំណាចការប្រកាន់រួមគ្នា ។ ពិតណាស់ ព្រោះមិនអាចញែកចិត្ត និងចេតសិកទុកឲ្យផ្សេងគ្នាបាន ទើបធ្វើខន្ធទាំងអស់រួមគ្នា ហើយកាន់យកថាជាតួខ្លួន ។

ក្នុងបទថា **ឥមិនា រូបេន រូបវា** មានរូបដោយរូបនេះ រមែងបាន

សរីរៈរូបខ្លះ កសិណរូបខ្លះ ។ បទថា **ឆាយាសម្បន្នោ** ( ដើមឈើមានស្រមោល ) គឺ ដើមឈើមិនលូតលាស់ដល់ព្រមដោយស្រមោល ។ សព្ទថា **ឯន** ក្នុងបទនេះថា **តមេន** ត្រឹមតែនិបាត ជា **តមេតំ** ខ្លះ ។ បទថា **ឆាយាវា** គឺ មានស្រមោល ។ លោកពោលថា អត្តានុទិដ្ឋិមានរូបជាវត្ថុ ។ ព្រោះសូម្បីមិនប្រកាន់ថា រូបជាតួខ្លួន ក៏មិនព្រលែងរូបទើបកើតទិដ្ឋិឡើង ។

បទថា **អត្តនិ រូបំ សមនុបស្សតិ** គឺ ឃើញរូបនោះក្នុងខ្លួន គឺដែលជាកងនៃអរូបនោះ ព្រោះសរីររូប និងកសិណរូបអាស្រ័យចិត្ត ។ បទថា **អយំ គន្ធោ** នេះ ក្លិនក្រអូប ពោលដល់ក្លិនដែលហិតស្រូបចូលទៅ ។ បទថា **ឥមស្មឹ បុប្ផេ** ក្នុងផ្កាឈើនេះ ពោលយ៉ាងនេះ ព្រោះក្លិនក្រអូបអាស្រ័យផ្កាឈើ ។

បទថា **រូបស្មឹ អត្តានំ សមនុបស្សតិ** ឃើញខ្លួនក្នុងរូប គឺ រូបទៅទីណា ចិត្តរមែងទៅកាន់ទីនោះ ។ ព្រោះដូច្នោះ ប្រកាន់ចិត្តអាស្រ័យរូបហើយ ឃើញខ្លួនដែលជាកងអរូបនោះ ក្នុងរូបនោះ ។ លោកពោលដល់ហិបសម្រាប់ទុកដាក់វត្ថុគ្រោតគ្រាត ព្រោះរូបជារបស់គ្រោតគ្រាត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **ឥធេកច្ចោ ចក្ខុសម្ផ-ស្សជំ វេទនំ** ( បុគ្គលខ្លះក្នុងលោកនេះ រមែងឃើញចក្ខុសម្ផស្សជា



វេទនា ) សេចក្ដីថា សូម្បីមិនមានការប្រកាន់ដោយទិដ្ឋិក្នុងវេទនាផ្សេងអំពីគ្នា ក៏ចាប់យកដោយការប្រកាន់ដូចគ្នាថា **វេទនា** ព្រោះវេទនាទាំងពួងធ្លាក់ចុះក្នុងខាងក្នុង ទើបជាការប្រកាន់យកផ្សេងគ្នា ព្រោះហេតុនោះ គប្បីជ្រាបថា លោកប្រកបទុកឲ្យផ្សេងគ្នា ។ ព្រោះបុថុជ្ជននោះរមែងប្រកាន់វេទនានោះឯងថា ជាតួខ្លួន ព្រោះវេទនាជារបស់គ្រោតគ្រាតដោយអំណាចការសោយ ។

បទថា **សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ** បុថុជ្ជនរមែងឃើញ សញ្ញា សង្ខារ វិញ្ញាណ រូប ថាជាខ្លួន សេចក្ដីថា ធ្វើអរូបធម៌ មានសញ្ញាជាដើម និងរូប រួមគ្នា ហើយឃើញថាជាខ្លួន ព្រោះបុថុជ្ជនរមែងប្រកាន់តាមដែលប្រាកដ ដូចមនុស្សឆ្កួតដូច្នោះ ។

ក្នុងបទមានជាអាទិ៍ថា **ចក្ខុសម្ផស្សជំ សញ្ញំ** មានអធិប្បាយថា បុថុជ្ជនរមែងប្រកាន់សញ្ញាថា ជាតួខ្លួន ព្រោះសញ្ញាប្រាកដ ដោយអំណាចនៃការដឹងព្រម ។ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយក្នុងវេទនា ។

ក្នុងបទមានជាអាទិ៍ថា **ចក្ខុសម្ផស្សជំ ចេតនំ** មានអធិប្បាយថា លោកសម្ដែងដល់ចេតនាប៉ុណ្ណោះ ព្រោះចេតនាជាប្រធាន និងប្រាកដក្នុងធម៌ទាំងឡាយ ដែលទាក់ទងជាមួយសង្ខារក្ខន្ធ ។ សូម្បីខន្ធក្រៅ

អំពីនេះ ក៏លោកសម្តែងដោយចេតនានោះ ។ ចំណែកបុថុជ្ជននោះ រមែងប្រកាន់ចេតនាថា ជាតួខ្លួន ព្រោះប្រាកដដោយភាពជាចេតសិក ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

ក្នុងបទមានជាអាទិ៍ថា **ចក្ខុវិញ្ញាណំ** មានអធិប្បាយថា បុថុជ្ជន រមែងប្រកាន់ចិត្តថា ជាតួខ្លួន ព្រោះចិត្តប្រាកដ ដោយអំណាចនៃការដឹងច្បាស់ ។ បទដ៏សេសសូម្បីក្នុងទីនេះ ក៏មានន័យដូចពោលហើយនោះឯង ។

(ចប់ អដ្ឋកថាអត្តានុទិដ្ឋិនិទ្ទេស)



## អដ្ឋកថា មិច្ឆាទិដ្ឋិនិទ្ទេស

មិច្ឆាទិដ្ឋិ មានសេចក្តីដូចបានពោលទុកហើយក្នុងខាងក្រោយ តែគប្បីជ្រាបន័យដទៃ ដូចតទៅនេះ ។

បទថា **នត្ថិ ទិន្នំ** ទានដែលឲ្យហើយមិនមានផល គឺ បដិសេធផលរបស់ទាន ព្រោះជាឧច្ឆេទទិដ្ឋិ ។ បទថា **យិដ្ឋំ** ការបូជាយ័ញ្ញ ក្នុងបទថា **នត្ថិ យិដ្ឋំ** យ័ញ្ញដែលបូជាហើយ មិនមានផលនេះជាយ័ញ្ញបន្តិចបន្តួច ។ បទថា **ហុតំ** សែនបន់ស្រន់ជាមហាយ័ញ្ញ ។ បដិសេធផលរបស់យ័ញ្ញទាំងពីរ ។

បទថា **នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ** ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អធ្វើអាក្រក់មិនមាន គឺ បដិសេធផលនៃបុញ្ញកម្ម មានសីលជាដើម ព្រោះបដិសេធផលនៃទាន បដិសេធផលនៃបាបកម្ម មានបាណាតិបាតជាដើម ។ បទថា **នត្ថិ អយំ លោកោ** លោកនេះមិនមាន គឺ ដោយកម្មដែលធ្វើទុកក្នុងកាលមុន ។ បទថា **នត្ថិ បរោ លោកោ** លោកខាងមុខមិនមាន គឺ ដោយកម្មដែលធ្វើទុកក្នុងលោកនេះ ។ បទថា **នត្ថិ មាតា នត្ថិ បិតា** មាតាមិនមាន បិតាមិនមាន គឺ បដិសេធផលរបស់កម្ម ដែលធ្វើទុកក្នុងមាតាបិតាទាំងនោះ ។ បទថា

**នត្ថិ សត្តា ឱបបាតិកា** សត្វដែលកើតឡើងឯងក៏មិនមាន គឺ បដិសេធការកើតឡើងឯង ដែលមានកម្មជាហេតុ ។ បទថា **នត្ថិ លោកេ សមណព្រាហ្មណា ។បេ។ បវេទេន្តិ** សមណព្រាហ្មណ៍អ្នកបដិបត្តិល្អ បដិបត្តិប្រពៃ អ្នកធ្វើលោកនេះ និងលោកខាងមុខឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ក្រៃលែងហើយ និងប្រៀនប្រដៅប្រជុំជនឲ្យដឹងតាម មិនមានក្នុងលោក គឺ បដិសេធបដិបទាក្នុងការបានអភិញ្ញា ដើម្បីឃើញក្នុងលោកនេះ និងលោកខាងមុខ ។

ប៉ុន្តែក្នុងបាលីនេះ បទថា **នត្ថិ ទិន្នំ** បានដល់វត្ថុ គឺ ទានដែលលោកពោលថា ទានដែលឲ្យហើយមិនមានផល ។ អធិប្បាយថា វត្ថុនៃទិដ្ឋិនោះ ។

បទថា **ឯវំវាទោ មិច្ឆា** វាទៈយ៉ាងនេះខុស គឺ វាទៈនិយាយថាទានដែលឲ្យហើយមិនមានផលយ៉ាងនេះខុស គឺ វិបរិត ។

(ចប់ អដ្ឋកថាមិច្ឆាទិដ្ឋិនិទ្ទេស)



## អដ្ឋកថា សក្កាយទិដ្ឋិនិទ្ទេស

បទថា **សក្កាយទិដ្ឋិ** គឺ អត្តានុទិដ្ឋិនោះឯង គប្បីជ្រាបថា លោកពោលទុកដើម្បីសម្ដែងពាក្យដោយបរិយាយដែលមកហើយក្នុងទីដទៃ ។

(ចប់ អដ្ឋកថាសក្កាយទិដ្ឋិនិទ្ទេស)

## អដ្ឋកថា សស្សតទិដ្ឋិនិទ្ទេស

បទថា **សក្កាយវត្ថុកាយ សស្សតទិដ្ឋិយា** សស្សតទិដ្ឋិមានសក្កាយៈជាវត្ថុ ជាកម្មធារយសមាស ។

គប្បីភ្ជាប់បទថា **សមនុបស្សតិ** រមែងឃើញក្នុងពាក្យខាងចុង ១៥ ពាក្យ មានជាអាទិ៍ថា **រូបវន្តំ វា អត្តានំ** ។ ព្រោះមិនបានក្ដោបខ្លួនដោយយ៉ាងដទៃ ទិដ្ឋិដ៏សេស ១៤ យ៉ាង សម្ដែងសង្ខេបសេចក្ដីទុកដូចគ្នាថា **រូបវន្តំ វា អត្តានំ សមនុបស្សតិ** ឃើញខ្លួនថាមានរូបដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថាសស្សតទិដ្ឋិនិទ្ទេស)



## អដ្ឋកថា ឧច្ឆេទទិដ្ឋិនិទ្ទេស

បទថា **សក្កាយវត្ថុកាយ ឧច្ឆេទទិដ្ឋិយា** ឧច្ឆេទទិដ្ឋិមានសក្កាយៈជាវត្ថុ គឺ ទិដ្ឋិដ៏សេស ៤ យ៉ាង សម្ដែងសង្ខេបសេចក្ដីទុកដូចគ្នាថា ឃើញរូបថាជាខ្លួន ដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថាឧច្ឆេទទិដ្ឋិនិទ្ទេស)

# អដ្ឋកថា អន្តគ្គាហិកទិដ្ឋិនិទ្ទេស

បទថា **អន្តគ្គាហិកាយ ទិដ្ឋិយា** ទិដ្ឋិដែលកាន់យកទីបំផុត ជាការសួរតាមអាការក្នុងវារៈទីមួយ កាន់យកតាមអាការក្នុងវារៈទីពីរ ពោលដោះស្រាយអាការក្នុងវារៈទីបី ។

ក្នុងបទទាំងនោះ បទថា **លោកោ** គឺ តួខ្លួន ។ បទថា **សោ អន្តោ** លោកនោះមានទីបំផុត គឺ ក្នុងទីបំផុតនៃសភាពទៀង និងសភាពសូន្យដែលជាបដិបក្ខចំពោះគ្នា ទីបំផុតនៃសភាពទៀង ក្នុងការប្រកាន់ថាទៀង ទីបំផុតនៃសភាពសូន្យក្នុងការប្រកាន់ថា មិនទៀង ។ បទថា **បរិត្តំ ឱកាសំ** កាន់យកឱកាសបន្តិចបន្តួច គឺ កាន់យកទីតិចតួចត្រឹមតែចង្អេ ឬចានក្រឡូម ។ បទថា **នីលកតោ ផរតិ** ធ្វើពណ៌ខៀវផ្សាយទៅ គឺ ជាអារម្មណ៍ថាពណ៌ខៀវ ។ បទថា **អយំ លោកោ** លោកនេះ លោកពោលសំដៅដល់ខ្លួន ។ បទថា **បរិវដុមោ** លោកមូល គឺ មានកំណត់ទុកដោយជុំវិញ ។ បទថា **អន្តសញ្ញី** មានការសម្គាល់ថា មានទីបំផុត ។

បទថា **យំ ផរតិ** គឺ កសិណរូបផ្សាយទៅ ។ បទថា **តំ វត្ថុ ចេវ លោកោ ច** វត្ថុ និងលោក គឺ កសិណរូបនោះជាអារម្មណ៍ និងលោក



ដោយអត្ថថា គប្បីសម្លឹង ។ បទថា **យេន ផរតិ** គឺ ផ្សាយទៅដោយចិត្ត ។ បទថា **សោ អត្តា ចេវ លោកោ ច** បានដល់ ខ្លួន និងលោក ធ្វើឲ្យជាបុំលិង្គព្រោះសំឡឹងដល់ខ្លួន ។ លោកអធិប្បាយថា ខ្លួននោះឯង គឺ ចិត្តនោះឯងឈ្មោះថា លោក ព្រោះអត្ថថា គប្បីសម្លឹងមើល ។

បទថា **អន្តវា** គឺ មានទីបំផុត ។ បទថា **ឱភាសកតោ ផរតិ** ធ្វើពន្លឺផ្សាយទៅ គឺ ពន្លឺភ្លឺស្វាងដោយអាលោកកសិណ តេជោកសិណ ឬឱទាតកសិណផ្សាយទៅ ។ ព្រោះយកកសិណ មានពន្លឺ ៥ ប្រភេទមាននីលកសិណជាដើម ទើបគួរកាន់យកថា មិនមានការប្រកាន់ខ្លួនដោយអំណាចបឋវីកសិណ អាបោកសិណនិងវាយោកសិណ ។ បទថា **វិបុលំ ឱកាសំ** កាន់ឱកាសដែលទូលាយ គឺ កាន់យកទីធំ ដោយប្រមាណបរិវេណលានជាដើម ។ បទថា **អនន្តវា** មិនមានទីបំផុត គឺ មិនមានទីបំផុត ទូលំទូលាយ ។ បទថា **អបរិយន្តោ** រកទីបំផុតមិនបាន គឺ រកទីបំផុតដែលទូលំទូលាយមិនបាន ។ បទថា **អនន្តសញ្ញី** គឺ មានសេចក្តីសម្គាល់ថា លោកមិនមានទីបំផុត ។

បទថា **តំជីវំ** គឺ ជីវៈនោះ លោកធ្វើឲ្យជាលិង្គវិបល្លាស ។ មយ៉ាងទៀត បទថា **ជីវោ** គឺ តួខ្លួននោះឯង ។ សូម្បីខន្ធ ៥ មានរូបក្ខន្ធជាដើម ក៏ឈ្មោះថាសរីរៈ ព្រោះអត្ថថា មានការវិលទៅ ។

បទថា **ជីវំ ន សរីរំ** ជីវៈមិនមែន សរីរៈ គឺ ជីវៈ បានដល់ ខ្លួន មិន មែនសរីរៈ បានដល់ រូប ។ ក្នុងវេទនាជាដើម ក៏មានន័យនេះ ។

បទថា **តថាគតោ** គឺ សត្វ ។ អាចារ្យពួកមួយពោលថា ព្រះអរហន្ត ។ បទថា **បរម្មរណា** ខាងមុខពីស្លាប់ គឺ ក្នុងលោកដទៃ ។ បទថា **រូបំ ឥធេវ មរណធម្មំ** រូបមានសេចក្តីស្លាប់ជាធម្មតា ក្នុងលោកនេះឯង គឺ ការប្រកាន់បញ្ចក្ខន្ធដោយមាតិកានៃខន្ធដែលប្រាកដដល់ខ្លួន ។ អធិប្បាយថា រូបនោះប្រក្រតីសូន្យបាត់ទៅក្នុងលោកនេះឯង សូម្បីក្នុងខន្ធដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **កាយស្ស ភេទា** អំពីកាយបែកធ្លាយ គឺ ខាងមុខពីកាយ គឺ ខន្ធ ៥ បែកធ្លាយ ។ លោកពោលសេចក្តីនៃឧទ្ទេសនេះថា **បរម្មរណា** ខាងមុខពីស្លាប់ដោយពាក្យនេះ ។

បទថា **ហោតិ** ក្នុងបទមានជាអាទិ៍ថា **ហោតិបិ** យ៉ាងនេះខ្លះ ជាបទគោល ។ **អបិ** សព្ទ សូម្បីក្នុងបទទាំង ៤ ជាសមុច្ចយត្ថៈ មានសេចក្តីរួម ។ បទថា **តិដ្ឋតិ** គឺ ឋិតនៅ ព្រោះជារបស់ដែលទៀង ។ អធិប្បាយថា មិនចុតិ ។ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលបទថា **តិដ្ឋតិ** ដើម្បីភាពផ្សេងគ្នានៃសេចក្តីរបស់បទថា **ហោតិ** ។

បទថា **ឧប្បជ្ជតិ** ឧបត្តិឡើង គឺ ឧបត្តិឡើងដោយចូលទៅកាន់



កំណើតដែលជាអណ្ឌជៈ (កើតពីស៊ុត) និងជលាពុជៈ (កើតពីទឹក)។

បទថា **និព្វត្តតិ** កើត គឺ កើតដោយចូលទៅកាន់កំណើតដែលជាសំសេទជៈ ( កើតពីញើសក្អែល ) ឱបបាតិកៈ ( កើតឡើងឯង ) ។

គប្បីជ្រាប ការប្រកបសេចក្តីដូច្នេះឯង ។ បទថា **ឧច្ឆិជ្ជតិ** រមែងដាច់សូន្យ គឺ ដោយមិនមានការទាក់ទងគ្នា ។ បទថា **វិនស្សតិ** រមែងវិនាសទៅ គឺ ដោយការបែកធ្លាយទៅ ។ បទថា **ន ហោតិ បរម្មរណា** ខាងមុខពីស្លាប់ហើយ រមែងមិនកើតទៀត ជាការពង្រីកសេចក្តីនៃបទមុន ។ អធិប្បាយថា ខាងមុខពីចុតិហើយ រមែងមិនកើតទៀត ។

បទថា **ហោតិ ច ន ច ហោតិ** សត្វខាងមុខអំពីស្លាប់ហើយ រមែងកើតទៀតក៏មាន មិនកើតទៀតក៏មាន ជាទិដ្ឋិរបស់អ្នកប្រកាន់ថាទៀងខ្លះ រមែងមានដោយបរិយាយមួយ មិនមានដោយបរិយាយមួយ ។ លោកអធិប្បាយថា រមែងកើតព្រោះភាពជាជីវៈ មិនកើតព្រោះមិនមានជីវៈ ។

បទថា **នេវ ហោតិ ន ន ហោតិ** សត្វខាងមុខពីស្លាប់ហើយ រមែងកើតទៀតក៏មិនមែន រមែងមិនកើតទៀតក៏មិនមែន ជាទិដ្ឋិរបស់ពួក **អមរាវិក្ខេបិកា** ( ទិដ្ឋិផ្សាយទៅមិនស្លាប់ខ្លួន ) ។ អធិប្បាយថា

មានក៏មិនមែន មិនមានក៏មិនមែន រមែងធ្វើត្រឹមតែបដិសេធន័យដែលលោកពោលទុកមុន ព្រោះខ្លាចត្រូវតិះដៀល និងព្រោះខ្លាចនិយាយកុហក ព្រោះមានបញ្ញាទន់ខ្សោយ និងព្រោះភាពវង្វេង ។

បទថា ***ឥមេហិ បញ្ញាសាយ អាការេហិ*** ដោយអាការ ៥០ ទាំងនេះ គឺ ដោយអាការ ៥០ ដោយអំណាចនៃពួក ៥ ពួកមួយ ៗ មាន ១០ តាមដែលពោលហើយ ។

(ចប់ អដ្ឋកថាអន្តានន្តិកទិដ្ឋិនិទ្ទេស)



## អដ្ឋកថា បុព្វន្តានុទិដ្ឋិនិទ្ទេស

អ្នកមានទិដ្ឋិឈ្មោះថា ***សស្សតវាទ*** ព្រោះពោលដល់សភាពទៀងក្នុងបុព្វន្តានុទិដ្ឋិ ( ការតាមឃើញខន្ធក្នុងចំណែកអតីត ) និងអបរន្តានុទិដ្ឋិ ( ការតាមឃើញខន្ធចំណែកអនាគត ) ។ ម្យ៉ាងទៀត ឈ្មោះថា ***វាទ*** ជាហេតុពោល ។ បទនេះ ជាឈ្មោះនៃអ្នកមានទិដ្ឋិ ។ សូម្បីវាទៈថាទៀង ក៏ឈ្មោះថា ***សស្សត*** ព្រោះប្រកបដោយ ***សស្សតទិដ្ឋិ*** ។ ឈ្មោះថា ***សស្សតវាទ*** ព្រោះមានវាទៈថាទៀង ។ ម្យ៉ាងទៀត វាទៈថាទៀងជាចំណែកខ្លះ ឈ្មោះថា ***ឯកច្ចសស្សត*** ឈ្មោះថា ***ឯកច្ចសស្សតិកា*** ព្រោះមានទិដ្ឋិថា ទៀងជាចំណែកខ្លះនោះ ។ ម្យ៉ាងទៀត វាទៈប្រព្រឹត្តទៅថា លោកមានទីបំផុត មិនមានទីបំផុត មានទីបំផុតខ្លះ មិនមានទីផុតខ្លះ មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ឈ្មោះថា ***អន្តានន្ត*** ឈ្មោះថា ***អន្តានន្តិកា*** ព្រោះមានទិដ្ឋិថា លោកមានទីបំផុត និងមិនមានទីបំផុត ។ ឈ្មោះថា ***អមរា*** ព្រោះមិនស្លាប់ ។ អ្វីមិនស្លាប់ ។ ទិដ្ឋិ និងវាចារបស់អ្នកមានទិដ្ឋិដែលប្រាសចាកទីបំផុត ដោយន័យមានជាអាទិ៍ថា សូម្បីយ៉ាងនេះក៏មិនមានដល់យើង ។ ការបោះពាក្យសម្តីមាន ២ យ៉ាង គឺ ពោលបោះពាក្យសម្តី

ដោយទិដ្ឋិ ឬវាចាដែលពោលមិនឲ្យស្លាប់ខ្លួន ឈ្មោះថា **អមរាវិក្ខេប** ។ ឈ្មោះថា **អមរាវិក្ខេបិកា** ព្រោះមានទិដ្ឋិពោលបោះពាក្យសម្តីទៅមិនស្លាប់ខ្លួន ។

បទថា **អធិច្ចសមុប្បន្នោ** កើតលើងរឿយ ៗ គឺ ការឃើញថាខ្លួន និងលោកកើតឡើង ដោយមិនមានហេតុ ឈ្មោះថា **អធិច្ច-សមុប្បន្ន** ឈ្មោះថា **អធិច្ចសមុប្បន្និកា** ព្រោះមានទិដ្ឋិថា ខ្លួននិង លោកកើតឡើងឯង ៗ ។

(ចប់ អដ្ឋកថាបុព្វន្តានុទិដ្ឋិនិទ្ទេស)



## អដ្ឋកថា អបរន្តានុទិដ្ឋិនិទ្ទេស

អ្នកមានទិដ្ឋិឈ្មោះថា **សញ្ញីវាទ** ព្រោះពោលថា ខ្លួនកាលស្លាប់ហើយមានសញ្ញា ។ ឈ្មោះថា **អសញ្ញីវាទ** ព្រោះពោលថា ខ្លួនកាលស្លាប់ហើយមិនមានសញ្ញា ។ ឈ្មោះថា **នេវសញ្ញីនាសញ្ញីវាទ** ព្រោះពោលថា ខ្លួនកាលស្លាប់ហើយ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ម្យ៉ាងទៀត វាទៈដែលប្រព្រឹត្តទៅថា មានសញ្ញា ឈ្មោះថា **សញ្ញីវាទ** អ្នកមានទិដ្ឋិប៉ុណ្ណោះឈ្មោះថា **សញ្ញីវាទ** ព្រោះមានវាទៈថា មានសញ្ញា ។ អសញ្ញីវាទៈ និងនេវសញ្ញីនាសញ្ញីវាទៈ ក៏ដូចយ៉ាងនោះ ។

អ្នកមានទិដ្ឋិឈ្មោះថា **ឧច្ឆេទវាទ** ព្រោះពោលថាសូន្យ ។ បទថា **ទិដ្ឋធម្មោ** គឺ ធម៌ឃើញប្រចក្ស សំដៅដល់ធម៌ជាបច្ចុប្បន្ន ។ បទនេះជាឈ្មោះនៃអត្តភាពដែលបានក្នុងបច្ចុប្បន្ននោះ ៗ ។ និព្វានក្នុងបច្ចុប្បន្នឈ្មោះថា ទិដ្ឋធម្មនិព្វាន ។ សេចក្តីថា ការចូលទៅស្ងប់ទុក្ខក្នុងអត្តភាពនេះឯង ។ ឈ្មោះថា **ទិដ្ឋធម្មនិព្វានវាទ** ព្រោះពោលដល់និព្វានជាបច្ចុប្បន្នធម៌នោះ ។

ម្យ៉ាងទៀត បទនេះពិស្តារក្នុងនិទ្ទេសនេះ ទើបគួរពោលដល់ព្រហ្មជាលសូត្រទាំងអស់ដោយអដ្ឋកថា ។ ក៏កាលបើយ៉ាងនេះ រមែងយឺតយូរ ព្រោះដូច្នោះទើបមិនឲ្យពិស្តារ ។ អ្នកមានសេចក្តីត្រូវការសូត្រនោះ គួរស្រាវជ្រាវរកមើលខ្លួនឯង ។

(ចប់ អដ្ឋកថាអបរន្តានុទិដ្ឋិនិទ្ទេស)

## អដ្ឋកថា សញ្ញោជនិកទិដ្ឋិនិទ្ទេស

ព្រោះសំយោជនិកទិដ្ឋិ ( ទិដ្ឋិជាគ្រឿងប្រកបសត្វទុកក្នុងភព ) ជាទិដ្ឋិទូទៅដល់ទិដ្ឋិទាំងអស់ ។ ដូច្នោះ លោកទើបសម្តែងសេចក្តីទូទៅដល់ទិដ្ឋិទាំងអស់ ព្រោះសំយោជនិកទិដ្ឋិនោះ ជាគ្រឿងប្រកបទិដ្ឋិទុកទាំងអស់ ។ គប្បីជ្រាបសេចក្តីនោះ ដោយការគ្របសង្កត់ទិដ្ឋិ ដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។

(ចប់ អដ្ឋកថាសញ្ញោជនិកទិដ្ឋិនិទ្ទេស)



## អដ្ឋកថា មានវិនិពន្ធទិដ្ឋិនិទ្ទេស

ក្នុងមានវិនិពន្ធទិដ្ឋិ ( ទិដ្ឋិដែលជាប់ទាក់ទងដោយមានះថាអញ ) ទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ ការស្ទាបអង្អែលដោយការប្រកាន់ខុសថា ភ្នែកជារបស់អញ ឈ្មោះថា ស្ទាបអង្អែលដោយការប្រកាន់ស្អិត មានមានះជាខាងដើម ។ ព្រោះទិដ្ឋិមិនបានសម្បយុត្តដោយមានះ ។ ដោយហេតុនោះ លោកទើបពោលថា **មានវិនិពន្ធា** ទិដ្ឋិជាប់ទាក់ទងដោយមានះ សេចក្តីថា ទិដ្ឋិជាប់ទាក់ទងដោយមានះ មានមានះជាមូល ។

សូម្បីក្នុងបទនេះថា **ចក្ខុំ មមន្តិ អភិនិវេសបរាមាសោ** ការស្ទាបអង្អែលដោយការប្រកាន់ស្អិតថា ភ្នែករបស់យើង ក៏មានន័យនេះ ។ ម្យ៉ាងទៀត ក្នុងបទ **ចក្ខុំ មមន្តិ** នេះគួរពោលថា **មមាតិ** គប្បីជ្រាបថាចុះនិគ្គហិតអាគមជា **មមន្តិ** ។ គប្បីជ្រាបអាយតនៈខាងក្នុងមានរូបជាដើម ដោយទិដ្ឋិដែលជាប់ដោយមានះថា ជាយើង រមែងមិនប្រកាន់អាយតនៈខាងក្រៅថា ជាយើង វៀរកសិណរូប ។ សូម្បីអាយតនៈខាងក្រៅក៏រមែងមានដោយទិដ្ឋិ ដែលជាប់ដោយមានះថា របស់យើង ព្រោះរមែងប្រកាន់សូម្បីអាយតនៈខាងក្រៅថា របស់យើង ។

ក៏ព្រោះទុក្ខវេទនាមិនមែនជាវត្ថុរបស់មានះ ព្រោះជាវត្ថុមិនគួរប្រាថ្នា ដូច្នោះ វេទនា ៦ និងផស្សៈ ៦ ទើបមិនកាន់យកជាមូលបច្ច័យ របស់វេទនាទាំងនោះ ។ ប៉ុន្តែសញ្ញាជាដើម គប្បីជ្រាបថា លោកមិនប្រកាន់យកក្នុងទីនេះ ព្រោះកាត់ចេញហើយ ។

(ចប់ អដ្ឋកថាមានវិនិពន្ធទិដ្ឋិនិទ្ទេស)

## អដ្ឋកថា អត្តវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស

អត្តវាទប្បដិសំយុត្តទិដ្ឋិ ( ទិដ្ឋិដែលបដិសំយុត្តដោយការប្រារព្ធខ្លួន ) បានដល់ អត្តានុទិដ្ឋិនោះឯង ។ លោកពោលដល់ទិដ្ឋិយ៉ាងនេះទៀត ព្រោះបដិសំយុត្តដោយវាទៈថាតួខ្លួន ដូច្នេះ ។

(ចប់ អដ្ឋកថាអត្តវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស)



## អដ្ឋកថា លោកវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស

### ( ទិដ្ឋិបដិសំយុត្តដោយការប្រារព្ធលោក )

បទថា **អត្តា ច លោកោ ច** ខ្លួន និងលោក សេចក្តីថា ខ្លួននោះឯង និងឈ្មោះថា លោក ព្រោះអត្ថថា គប្បីសម្លឹង ។ បទថា **សស្សតោ** គឺ ទិដ្ឋិរបស់អ្នកមានវាទៈថាទៀង ។ បទថា **អសស្សតោ** គឺ ទិដ្ឋិរបស់អ្នកមានវាទៈថាសូន្យ ។ បទថា **សស្សតោ ច អសស្សតោ ច** គឺ ទិដ្ឋិរបស់អ្នកឃើញថាទៀងចំណែកខ្លះ ។ បទថា **នេវ សស្សតោ នាសស្សតោ** ខ្លួន និងលោកទៀងក៏មិនមែន មិនទៀងក៏មិនមែន គឺ ទិដ្ឋិរបស់អ្នកពោលមិនឲ្យស្លាប់ខ្លួន ។ បទថា **អន្តវា** មានទីបំផុត គឺ ទិដ្ឋិរបស់អ្នកបោកប្រាស់ និងរបស់និគ្រន្ថ អាជីវក អ្នកបានកសិណបន្តិចបន្តួច ។ម្យ៉ាងទៀត ពួកឧច្ឆេទទិដ្ឋិរមែងពោលថា សត្វមានខន្ធចំណែកអតីតដោយកំណើត មានខន្ធចំណែកអនាគត ដោយការស្លាប់ ។ ពួកឃើញថាខ្លួន និងលោកកើតឡើងឯង ៗ ពោលថា សត្វមានខន្ធចំណែកអតីតដោយកំណើត ។ បទថា **អនន្តវា** មិនមានទីបំផុត គឺ ទិដ្ឋិរបស់អ្នកបានកសិណរកប្រមាណមិនបាន ។ ប៉ុន្តែពួកអ្នកមានវាទៈថាទៀង រមែងពោលថា សត្វមិនមានខន្ធចំណែកអតីត និងចំណែក

អនាគត ដោយហេតុនោះ ទើបមិនមានទីបំផុត ។ ពួកអ្នកឃើញថា ខ្លួន និងលោកកើតឡើងឯង ៗ ពោលថា មិនមានទីបំផុតដោយខន្ធចំណែកអនាគត ។ បទថា **អន្តវា ច អនន្តវា ច** មានទីបំផុតក៏មាន មិនមានទីបំផុតក៏មាន គឺ ទិដ្ឋិរបស់អ្នកមានកសិណឡើងចុះ ៗ មិនចម្រើន ចម្រើនទៅខាងទទឹង ៗ ។ បទថា **នេវ អន្តវា ន អនន្តវា** មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន គឺ ទិដ្ឋិរបស់អ្នកមានការបោះពាក្យសំដីទៅមិនស្ងាប់ខ្លួន ។

(ចប់ អដ្ឋកថាលោកវាទបដិសំយុត្តទិដ្ឋិនិទ្ទេស)

## អដ្ឋកថា ភវវិភវទិដ្ឋិនិទ្ទេស

ព្រះសារីបុត្តត្ថេរ មិនធ្វើនិទ្ទេស ភវទិដ្ឋិ និងវិភវទិដ្ឋិទុកឲ្យផ្សេងគ្នា ព្រោះមិនមានការប្រកាន់ផ្សេងគ្នាពីទិដ្ឋិ តាមដែលបានពោលហើយ និងមិនធ្វើការសួរដើម្បីសម្តែងអាការមួយ ៗ គឺ ការជាប់នៅ ការសូន្យទៅ ដោយអំណាចនៃទិដ្ឋិតាមដែលពោលហើយនោះឯង ទើបពោលថា ការប្រកាន់ខុសដោយការជាប់នៅ ជាភវទិដ្ឋិ ។ ការប្រកាន់



ខុសដោយការសូន្យទៅ ជាវិភវទិដ្ឋិ ដូច្នេះ ។

គប្បីជ្រាបសេចក្តីក្នុងបទនោះ ដូចតទៅនេះ ។ ការប្រកាន់ខុសដោយការជាប់នៅ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា កាលតថាគតសម្តែងធម៌ដើម្បីការរំលត់កព ចិត្តរបស់ទេវតា និងមនុស្សទាំងនោះរមែងមិនស្ទុះទៅ សេចក្តីថា ការប្រកាន់ខុសដោយការធុញទ្រាន់ចាកព្រះនិព្វាន ដោយការសម្គាល់ថាទៀង ។ ការប្រកាន់ខុសដោយការស្ទុះស្ទា ដូចព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ទេវតា និងមនុស្សពួកខ្លះ នឿយណាយ ធុញទ្រាន់ ជិនឆ្អន់ ដោយកពនោះឯងរមែងភ្ញើតភ្ញើន ការដាច់សូន្យ សេចក្តីថា ការប្រកាន់ខុស ដោយការលះបង់បដិបទាដែលនាំទៅកាន់ការរំលត់ទុក្ខ ដោយសម្គាល់ថាសូន្យ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងការប្រកបភវទិដ្ឋិ និងវិភវទិដ្ឋិទុកក្នុងទិដ្ឋិទាំងពួង ទើបពោលពាក្យមានជាអាទិ៍ថា **អស្សាទ-ទិដ្ឋិយា** ដូច្នេះ ។ ក្នុងបទនោះ ព្រោះអ្នកមានអស្សាទទិដ្ឋិអាស្រ័យការទៀង ឬការសូន្យ រមែងប្រកាន់ថា ទោសក្នុងកាមទាំងឡាយរមែងមិនមាន ដូច្នេះ ។ ដូច្នោះ សូម្បីអស្សាទទិដ្ឋិមានអាការ ៣៥ លោកពោលថា ជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ។

ក្នុងបទនោះ ទិដ្ឋិសូម្បីមួយ ៗ ក៏ជាភវទិដ្ឋិដោយការប្រកាន់

ថាទៀង ។ ជាវិកវទិដ្ឋិដោយការប្រកាន់ថា សូន្យ ។ ដោយអត្តានុទិដ្ឋិ រមែងឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ព្រោះហេតុនោះ លោកទើបពោលថា ជាវិកវទិដ្ឋិ ៥ ព្រោះប្រកាន់ថា កាលខន្ធ ៥ ទាំងនោះសូន្យ ព្រោះភាវៈនៃខ្លួនមិនដទៃអំពីរូបជាដើម ខ្លួនទើបសូន្យ ។ កាលឋានៈ ១៥ ដ៏សេស ព្រោះភាវៈនៃខ្លួនដទៃអំពីរូបជាដើម លោកទើបពោលថា ជាកវទិដ្ឋិ ១៥ ព្រោះប្រកាន់ថាខ្លួនទៀង ។

អ្នកបានទិព្វចក្ខុ បានឈានដែលជាបរិត្តារម្មណ៍ និងអប្បមាណារម្មណ៍ ក្នុងទិដ្ឋិមានទីបំផុត និងមិនមានទីបំផុត ព្រោះមិច្ឆាទិដ្ឋិប្រព្រឹត្តទៅហើយដោយអំណាចនៃការដាច់សូន្យថា ទាំងអស់នោះជាវិកវទិដ្ឋិ លុះចុតិចាករូបធាតុ ហើយឃើញសត្វទាំងឡាយកើតក្នុងទីដទៃ មិនឃើញនូវវិកវទិដ្ឋិ រមែងប្រកាន់យកវិកវទិដ្ឋិ ។ ព្រោះដូច្នោះ ក្នុងបទនោះ លោកទើបពោលថា ជាកវទិដ្ឋិក៏មាន ជាវិកវទិដ្ឋិក៏មាន ដូច្នេះ ។

បទថា ***ហោតិ ច*** ក្នុងបទនេះថា ***ហោតិ ច ន ច ហោតិ*** មាន និងមិនមាន ជាកវទិដ្ឋិ ។ បទថា ***ន ច ហោតិ*** មិនមាន ជាវិកវទិដ្ឋិ ។

បទថា ***នេវ ហោតិ*** ក្នុងបទនេះថា ***នេវ ហោតិ ន ន ហោតិ*** មានក៏មិនមែន មិនមានក៏មិនមែន ជាវិកវទិដ្ឋិ ។ បទថា ***ន ន ហោតិ***



មិនមានក៏មិនមែន ជាកវទិដ្ឋិ ។ ព្រោះដូច្នោះ ក្នុងបទនោះលោកទើបពោលថា ***សិយា*** គប្បីមាន ។

ពួកអ្នកដែលឃើញថា ទៀងជាចំណែកខ្លះនៃការតាមឃើញខន្ធជាអតីត រមែងបញ្ញត្តិថាទៀង និងបញ្ញត្តិថាមិនទៀង ។ ព្រោះដូច្នោះ ទិដ្ឋិនោះទើបជាកវទិដ្ឋិ និងវិកវទិដ្ឋិ ។ ពួកអ្នកដែលឃើញថា មានទីបំផុត និងមិនមានទីបំផុត ៤ ពួក រមែងបញ្ញត្តិខ្លួនថា មានទីបំផុត និងមិនមានទីបំផុត ។ ព្រោះដូច្នោះ ទិដ្ឋិនោះទើបជាកវទិដ្ឋិ និងវិកវ-ទិដ្ឋិ ដូចគ្នានឹងអត្តានុទិដ្ឋិ ។ ពួកអ្នកមានការឃើញដោយការបោះពាក្យសំដីមិនឲ្យស្លាប់ខ្លួន ៤ ពួក អាស្រ័យកវទិដ្ឋិ ឬវិកវទិដ្ឋិ រមែងដល់សេចក្តីរាយមាយតាមវាចា ចំណែកដ៏សេសជាកវទិដ្ឋិ ។ ព្រោះដូច្នោះ លោកទើបពោលថា ***សិយា*** សំដៅដល់ទិដ្ឋិនោះ ៗ ។ ពួកអ្នកដែលពោលថាសូន្យ ៧ ពួក នៃការតាមឃើញខន្ធជាអនាគត ជាវិកវទិដ្ឋិ ដ៏សេសជាកវទិដ្ឋិ ។ ព្រោះដូច្នោះ លោកទើបពោលថា ***សិយា*** ព្រោះសំដៅដល់ទិដ្ឋិនោះ ៗ លោកពោលថា ***សិយា*** នៃសញ្ញោជនិកទិដ្ឋិដោយអំណាចនៃទិដ្ឋិទាំងពួង ។ តួខ្លួនមានការវិនាសទៅ ព្រោះការវិនាសនៃទិដ្ឋិទាំងនោះ ព្រោះប្រកាន់ចក្ខុជាដើមថា ជាអញ ដោយទិដ្ឋិដែលប្រកាន់ស្អិតនោះដោយមានះថា ជាអញ ព្រោះហេតុនោះ លោក

ទើបពោលថា ទាំងអស់នោះជាវិភវទិដ្ឋិ ។

ខ្លួនរមែងមិនវិនាសទៅ សូម្បីការវិនាសនៃទិដ្ឋិទាំងនោះ ព្រោះទិដ្ឋិដែលជាប់ទាក់ទងដោយមានះថា ជាយើង ដូចអត្តានុទិដ្ឋិដទៃពីចក្ខុជាដើមរបស់ខ្លួន ព្រោះដូច្នោះ លោកទើបពោលថា ទាំងអស់ជាទិដ្ឋិ ។

ភវទិដ្ឋិ និងវិភវទិដ្ឋិ នៃទិដ្ឋិបដិសំយុត្តដោយវាទៈ ប្រាវព្ធលោកប្រាកដហើយ ព្រោះលោកពោលទុកដោយន័យមានជាអាទិ៍ថា ខ្លួន និងលោកទៀង ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ គឺ លោកសម្ដែងដល់ការប្រកាន់ខុសនៃទិដ្ឋិ ១៦ និង ៣០០ មានអស្សាទទិដ្ឋិជាខាងដើម មានវិភវទិដ្ឋិជាទីបំផុត ។ អត្តានុទិដ្ឋិ សក្កាយទិដ្ឋិ និងទិដ្ឋិបដិសំយុត្តដោយអត្តវាទៈ លោកពោលទុកដោយភាវៈជាចំណែកដូចគ្នា ដោយបរិយាយមាន ៣ យ៉ាង ។ ប៉ុន្តែទិដ្ឋិសូម្បីទាំងអស់ ដោយមានប្រភេទមិនពិតប្រាកដ ជាសញ្ញោជនិកទិដ្ឋិ ។

ឥឡូវនេះ បទមានជាអាទិ៍ថា **សព្វាវ តា ទិដ្ឋិយោ អស្សាទទិដ្ឋិយោ** ទិដ្ឋិទាំងអស់នោះ ជាអស្សាទទិដ្ឋិ ជាការប្រៀបធៀបទិដ្ឋិតាមដែលប្រកបទុកដោយបរិយាយដទៃ ។

ក្នុងបទទាំងនោះ បទថា **សព្វាវ តា ទិដ្ឋិយោ** ទិដ្ឋិទាំងអស់នោះ បានដល់ ទិដ្ឋិដែលមិនមានសល់តាមដែលពោលហើយ ។ ទិដ្ឋិ



ដែលសង្គ្រោះចូលក្នុងទិដ្ឋិទាំងអស់ ៧ ទាំងនេះ គឺ ឈ្មោះថា **អស្សាទទិដ្ឋិ** ព្រោះត្រេកអរដោយទិដ្ឋិរាគៈ និងព្រោះអាស្រ័យសេចក្ដីពេញចិត្តដោយតណ្ហា ឈ្មោះថា **អត្តានុទិដ្ឋិ** ព្រោះទៅតាមការជាប់ជំពាក់ក្នុងខ្លួន ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះការឃើញវិបរិត ឈ្មោះថា **សក្កាយទិដ្ឋិ** ព្រោះជាទីតាំងនៃខន្ធ ឈ្មោះថា **អន្តគ្គាហិកទិដ្ឋិ** ព្រោះកាន់យកទីបំផុតមួយ ៗ ឈ្មោះថា **សញ្ញោជនិកទិដ្ឋិ** ព្រោះប្រកបដោយវត្ថុមិន មានប្រយោជន៍ ឈ្មោះថា **អត្តវាទប្បដិសំយុត្តទិដ្ឋិ** ព្រោះប្រកបដោយ អត្តវាទៈ ចំណែកទិដ្ឋិ ៩ ដ៏សេស មិនសង្គ្រោះចូលក្នុងទិដ្ឋិទាំអស់ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរសង្ខេបទិដ្ឋិទាំងអស់នោះ ដែលពោលទុកហើយដោយពិស្ដារ ចុះក្នុងទិដ្ឋិ ២ យ៉ាង កាលនឹងសម្ដែងដល់ធម៌ជាទីអាស្រ័យនៃទិដ្ឋិ ២ ពួក ដល់សត្វទាំងឡាយ ទើបពោលគាថាមានជាអាទិ៍ថា **ភវញ្ច ទិដ្ឋី** ។ ពិតណាស់ ទិដ្ឋិទាំងនោះ សូម្បីទាំងអស់ជាភវទិដ្ឋិ ឬវិភវទិដ្ឋិ ។

**ច** សព្ទក្នុងបទនេះថា **ភវញ្ច ទិដ្ឋី វិភវញ្ច ទិដ្ឋី** រួមទិដ្ឋិ ប៉ុណ្ណោះ មិនរួមធម៌ដែលអាស្រ័យ ។ ព្រោះធម៌ឯណាមួយ មិនបានអាស្រ័យភវទិដ្ឋិ និងវិភវទិដ្ឋិ ។ ដូចដែលលោកពោលទុកថា សត្វទាំងឡាយជា

អ្នកអាស្រ័យភវទិដ្ឋិក្តី ជាអ្នកអាស្រ័យវិភវទិដ្ឋិក្តី ដូច្នេះ ។

បទថា **តក្កិកា** ឈ្មោះថា **តិក្កិកា** ព្រោះពោលដោយការត្រិះរិះ ។ ព្រោះម្ចាស់ទិដ្ឋិទាំងនោះ រមែងប្រព្រឹត្តទៅដោយការត្រិះរិះតែម្យ៉ាង ព្រោះមិនមានបញ្ញាចាក់ធ្លុះសេចក្តីពិត ម្យ៉ាងទៀត ជនពួកណាបាន ឈានក្តី បានអភិញ្ញាក្តី រមែងប្រកាន់ទិដ្ឋិ សូម្បីជនទាំងនោះក៏ជា **តក្កិកា** ព្រោះត្រិះរិះហើយកាន់យក ។ បទថា **និស្សិតា សេ** សេចក្តីថា អាស្រ័យហើយ ។ បទថា **សេ** បទមួយប៉ុណ្ណោះត្រឹមតែជានិបាត ។ បទថា **តេសំ និរោធម្ហិ ន ហត្ថិ ញាណំ** ញាណក្នុងនិរោធ រមែងមិន មានដល់ជនទាំងនោះ នេះជាបទពោលដល់ហេតុនៃទិដ្ឋិនិស្ស័យ ។ សេចក្តីថា ព្រោះញាណក្នុងការរំលត់សក្កាយទិដ្ឋិ គឺ និព្វានមិនមាន ដល់ជនទាំងនោះ ដូច្នោះជនទាំងឡាយទើបប្រកាន់ទិដ្ឋិ ២ យ៉ាងនេះ ។ **ហិ** អក្សរក្នុងបទថា **ន ហិ អត្ថិ ញាណំ** នេះជានិបាតចុះក្នុងការសម្តែង ដល់ហេតុ ។

បទថា **យត្ថាយំ លោកោ វិបរិតសញ្ញី** សត្វលោកនេះប្រកាន់ ដោយទិដ្ឋិណាក៏ជាអ្នកមានសញ្ញាវិបរិត ព្រោះទិដ្ឋិនោះ សេចក្តីថា លោកព្រមទាំងទេវលោកនេះ ជាអ្នកមានសញ្ញាវិបរិត្តក្នុងនិរោធដែល ជាសុខណា ថាជាទុក្ខ គប្បីភ្ជាប់សេចក្តីថា ញាណក្នុងនិរោធនោះ



រមែងមិនមាន ។ ព្រោះជាអ្នកមានសញ្ញាវិបរិតថាជាទុក្ខ ព្រះមានព្រះ-ភាគជាម្ចាស់ទើបត្រាស់គាថាព័ន្ធនេះថា :-

**រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍សុទ្ធតែគួរ**
**ប្រាថ្នា គួររីករាយ គួរពេញចិត្ត មានប្រមាណប៉ុណ្ណា**
**លោកពោលថា មានពិត ។ អារម្មណ៍ ៦ យ៉ាងទាំងនេះ**
**លោកព្រមទាំងទេវលោក សម្មតិគ្នាថាជាសុខ តែជាធម៌**
**ជាទីរំលត់អារម្មណ៍ ៦ ទាំងនេះ ជនទាំងនោះសម្មតិគ្នា**
**ថាជាទុក្ខ ។ ការរំលត់នៃបញ្ចក្ខន្ធ ព្រះអរិយទាំងឡាយ**
**ឃើញថាជាសេចក្តីសុខ ការឃើញជំទាស់គ្នាជាមួយ**
**លោកទាំងពួងនេះ រមែងមានដល់បណ្ឌិតទាំងឡាយអ្នក**
**ឃើញពិត ។ ជនពួកដទៃ ពោលវត្ថុកាមណា ដោយភាព**
**ជាសុខ ព្រះអរិយទាំងឡាយពោល វត្ថុកាមនោះ ដោយ**
**ភាពជាទុក្ខ ជនពួកដទៃពោលនិព្វានណា ដោយភាពជា**
**ទុក្ខ ព្រះអរិយទាំងឡាយអ្នកដឹងច្បាស់និព្វាននោះ ដោយ**
**ភាពជាសុខ ។ លោកចូរពិចារណាធម៌ដែលដឹងបានលំបាក**
**ជនពាលទាំងឡាយ អ្នកមិនដឹងច្បាស់នាំគ្នាឈ្លក់វង្វេងនៅ**
**ក្នុងលោកនេះ សេចក្តីងងឹតសូន្យសុងរមែងមានដល់ជន**

ពាលទាំងឡាយ អ្នកត្រូវអវិជ្ជាគ្របសង្កត់ហើយអ្នកមិនឃើញ ។ ចំណែកនិព្វានជាធម្មជាតិ បើកបង្ហាញដល់សប្បុរសអ្នកឃើញពិត ដូចពន្លឺ ដូច្នោះ ជនទាំងឡាយជាអ្នកត្រិះរិះ មិនឆ្លាតចំពោះធម៌ រមែងមិនដឹងច្បាស់និព្វានដែលមានពិតក្នុងទីជិត ។ ជនទាំងឡាយជាអ្នកត្រូវភវរាគៈគ្របសង្កត់ហើយ ស្ទុះទៅតាមក្រសែភវតណ្ហា អ្នកចូលដល់វដ្តៈដែលជាអន្ទាក់នៃមាររឿយ ៗ មិនត្រាស់ដឹងធម៌នេះបានដោយងាយ ។ ក្រៅពីព្រះអរិយទាំងឡាយ នរណាហ្ន៎រមែងគួរនឹងដឹងបទ គឺនិព្វានដែលព្រះអរិយទាំងឡាយត្រាស់ដឹងល្អហើយ ព្រះអរិយជាម្ចាស់ទាំងឡាយជាអ្នកមិនមានអាសវៈ ព្រោះដឹងដោយប្រពៃ រមែងបរិនិព្វាន ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្ដែងទិដ្ឋិទាំងអស់ជា ២ យ៉ាង និងការដកទិដ្ឋិដោយព្រះសូត្រ ទើបនាំព្រះសូត្រមកថា **ទ្វីហិ ភិក្ខវេ** ដូច្នេះជាអាទិ៍ ។

ក្នុងបទទាំងនោះ សូម្បីព្រហ្មទាំងឡាយលោកក៏ហៅថា **ទេវ** ។ បទថា **ឱលិយន្តិ** រមែងក្រាញ គឺ ក្ដាប់ទុក្ខ ។ បទថា **អតិធាវន្តិ** គឺ ស្ទុះស្ទា ។ បទថា **ចក្ខុមន្តោ** គឺ មានបញ្ញា ។ **ច** សព្ទមានអត្ថជា



**អតិរេក** ។

បទថា **ភវារាមា** មានភពជាទីត្រេកអរ គឺ មានភពជាទីអភិរម្យ ។ បទថា **ភវរតា** គឺ ត្រេកអរក្នុងភព ។ បទថា **ភវសម្មុទិតា** គឺ ពេញចិត្តក្នុងភព ។ បទថា **ទេសិយមានេ** គឺ កាលធម៌ដែលព្រះតថាគតឬព្រះសាវករបស់ព្រះតថាគតសម្ដែង ។ បទថា **នបក្ខន្ទតិ** មិនស្ទុះទៅ គឺ មិនចូលដល់ព្រះធម្មទេសនា ឬការរំលត់ភព ។ បទថា **ន បសីទតិ** មិនជ្រះថ្លា គឺ មិនដល់ការជ្រះថ្លាក្នុងធម៌នោះ ។ បទថា **ន សន្តិដ្ឋតិ** មិនតាំងនៅ គឺ មិនតាំងនៅក្នុងធម៌នោះ ។ បទថា **នាធិមុច្ចតិ** មិនបង្អោនទៅ គឺ មិនដល់ការនែបនិត្យក្នុងធម៌នោះ ។ លោកពោលដល់សស្សតទិដ្ឋិដោយហេតុត្រឹមតែប៉ុណ្ណេះ ។

បទថា **អដ្ដិយមានា** នឿយនាយ គឺ ដល់ភាពជាទុក្ខ ។ បទថា **ហរាយមានា** ធុញទ្រាន់ គឺ ដល់ភាពខ្មាស់ ។ បទថា **ជិគុច្ឆមានា** គឺ ដល់ភាពជិនឆ្អិន ។ បទថា **វិភវំ អភិនន្ទន្តិ** ត្រេកអរការប្រាសចាក ភព គឺ ត្រេកអរអាស្រ័យការសូន្យ ឬប្រាថ្នាការសូន្យ ។ បទថា **កិរ** ( បានឮថា ) ជានិបាតចុះក្នុងអត្ថអនុស្សវនៈ ( ការបានឮមក ) ។ បទថា **ភោ** ជាពាក្យហៅ ។ បទថា **សន្តំ** គឺ រំលត់ហើយ ។ បទថា **បណិតំ** សេចក្ដីថា ឈ្មោះថា **ប្រណីត** ព្រោះមិនមានទុក្ខ ឬព្រោះនាំទៅកាន់

កាពជាប្រធាន ។ បទថា **យថាភវំ** គឺ តាមសេចក្តីពិត ។ លោកសម្តែងឧច្ឆេទទិដ្ឋិដោយហេតុត្រឹមតែប៉ុណ្ណោះ ។ បទថា **ឥធ** គឺ ក្នុងសាសនានេះ ។ បទថា **ភូតំ** សេចក្តីពិត គឺ ទុក្ខ បានដល់ ខន្ធ ៥ ដែលកើតពីហេតុ ។ បទថា **ភូតតោ បស្សតិ** ឃើញដោយសេចក្តីពិត គឺ ឃើញសេចក្តីពិតនេះថាជាទុក្ខ ។ បទថា **និព្វិទាយ** ដើម្បីសេចក្តីនឿយណាយ គឺ ដើម្បីការឃើញច្បាស់ ។ បទថា **វិរាគាយ** ដើម្បីប្រាសចាកតម្រេក គឺ ដើម្បីអរិយមគ្គ ។ បទថា **និរោធាយ** ដើម្បីរំលត់ គឺ ដើម្បីព្រះនិព្វាន ។

បទថា **បដិបន្នោ ហោតិ** គឺ ជាអ្នកបដិបត្តិបដិបទាដែលសមគួរដល់និព្វាននោះ ។ បទថា **ឯវំ បស្សន្តិ** អ្នកមានចក្ខុឃើញហើយយ៉ាងនេះ គឺ ឃើញដោយលោកិយញាណក្នុងចំណែកខាងដើម ដោយលោកុត្តរញ្ញាណក្នុងកាលចាក់ធ្លុះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរសម្តែងអានិសង្សនៃសម្មាទិដ្ឋិនោះដោយគាថា ២ គាថា ។

ក្នុងបទទាំងនោះ បទថា **យោ ភូតំ ភូតតោ ទិស្វា** ឃើញភាពជាសត្វដោយសេចក្តីពិត សេចក្តីថា ត្រាស់ដឹងទុក្ខ ដោយត្រាស់ដឹងព្រោះការកំណត់ដឹង ។ បទថា **ភូតស្ស ច អតិក្កមំ** ឈានកន្លង



ភាពជាសត្វ សេចក្តីថា ត្រាស់ដឹងការរំលត់ទុក្ខ ដោយត្រាស់ដឹងដោយការធ្វើឲ្យជាក់ច្បាស់ ។ បទថា **យថាភូតេធិមុច្ចតិ** រមែងបង្អោនចិត្តទៅក្នុងធម៌តាមពិត គឺ បង្អោនចិត្តទៅក្នុងការរំលត់ទុក្ខតាមសេចក្តីពិត ដោយអំណាចនៃការត្រាស់ដឹងដោយមគ្គភាវនាថា នេះស្ងប់ នេះប្រណីត ។ បទថា **ភវតណ្ហា បរិក្ខយា** ដើម្បីការអស់ទៅនៃភវតណ្ហា សេចក្តីថា ដោយការលះហេតុឲ្យកើតទុក្ខ ។

ម្យ៉ាងទៀត កាលមិនមានការត្រាស់ដឹងផ្សេង ៗ នៃសច្ចធម៌ គប្បីជ្រាបថា លោកពោលពាក្យក្នុងខាងដើមថា **ទិស្វា** ដោយវោហារព្រមជាមួយបដិបទាដែលជាចំណែកខាងដើម ព្រោះឃើញមុនហើយខាងក្រោយមិនបង្អោនចិត្តទៅ ។ ការត្រាស់ដឹងអរិយសច្ច ៤ រមែងមានរហូតកាលជានិច្ចតែម្យ៉ាង ។ ម្យ៉ាងវិញទៀត បទទាំងឡាយដែលពោលទុកក្នុងខាងដើម រមែងមានសូម្បីក្នុងកាលជានិច្ច ព្រោះហេតុនោះទើបមិនជាទោស ។

បទថា **ស វេ** គឺ ព្រះអរហន្តនោះតែម្យ៉ាង ។ បទថា **ភូតបរិញ្ញាតោ** កំណត់ដឹងភាពជាសត្វហើយ គឺ កំណត់ដឹងទុក្ខ ។ បទថា **វីតតណ្ហោ** គឺ មានតណ្ហាទៅប្រាសហើយ ។ បទថា **ភវាភវេ** គឺ ក្នុងភពតូចភពធំ ។ បទថា **អភវោ** គឺ ភពធំ ព្រោះមាន **អ** អក្សរ

ប្រព្រឹត្តទៅក្នុងអត្ថថា ចម្រើន ។ គប្បីជ្រាបភពតូចភពធំនោះ ព្រោះការប្រៀបធៀបគ្នា ។

ម្យ៉ាងវិញទៀត បទថា **ភវេ** បានដល់ សស្សតទិដ្ឋិ ។ បទថា **វិភវេ** បានដល់ ឧច្ឆេទទិដ្ឋិ ។ ឈ្មោះថា ប្រាសចាកតណ្ហា ព្រោះមិនមានទិដ្ឋិរាគៈសូម្បីក្នុង ២ យ៉ាងនោះ ។ បទថា **ភូតស្ស វិភវា** ព្រោះការមិនមាននៃភាពជាសត្វ គឺ ព្រោះសូន្យវដ្តទុក្ខ ។ បទថា **នាធិគច្ឆតិ បុនព្ភវំ** រមែងមិនមកកាន់កាន់ភពថ្មី លោកពោលដល់ការបរិនិព្វាននៃព្រះអរហន្ត ។

បទមានជាអាទិ៍ថា **តយោ បុគ្គលា** បុគ្គល ៣ ពួក លោកពោលដើម្បីតិះដៀលអ្នកដែលជាមិច្ឆាទិដ្ឋិ និងដើម្បីសរសើរអ្នកដែលជាសម្មាទិដ្ឋិ ។ ឈ្មោះថា មានទិដ្ឋិវិបត្តិ ព្រោះមានទិដ្ឋិដល់ គឺ ទៅកាន់សេចក្តីគួរខ្ពើម ។ ឈ្មោះថា មានទិដ្ឋិសម្បត្តិ ព្រោះមានទិដ្ឋិដល់ព្រម គឺ ទៅកាន់សេចក្តីល្អ ។

បទថា **តិត្ថិយោ** ទិដ្ឋិ លោកពោលលទ្ធិ ព្រោះបដិបត្តិទិដ្ឋិនោះជាសេចក្តីល្អក្នុងលទ្ធិ ឬឈ្មោះថា **តិត្ថិយ** ព្រោះមានលទ្ធិចូលដល់ការបព្វជ្ជាខាងក្រៅលទ្ធិនោះ ។ បទថា **តិត្ថិយសាវកោ** សាវកតិរ្ថិយ គឺ គ្រហស្ថអ្នកដល់ទិដ្ឋានុគតិរបស់សាវកតិរ្ថិយទាំងនោះ ។ បទថា **យោ ច**



**មិច្ឆាទិដ្ឋិកោ** បុគ្គលអ្នកមានទិដ្ឋិខុស គឺ ចូលដល់ទិដ្ឋិទាំង ២ យ៉ាងនោះជាមិច្ឆាទិដ្ឋិណាមួយ ។

បទថា **តថាគតោ** គឺ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ សូម្បីព្រះបច្ចេកពុទ្ធជាម្ចាស់ក៏សង្គ្រោះចូលក្នុងបទនេះដូចគ្នា ។ បទថា **តថាគតសាវកោ** គឺ អ្នកបានសម្រេចមគ្គ និងផល ។ បទថា **យោ ច សម្មាទិដ្ឋិកោ** អ្នកមានសម្មាទិដ្ឋិ គឺ អ្នកផុតចាកទិដ្ឋិ ២ យ៉ាងនោះ ជាសម្មាទិដ្ឋិ ដោយសម្មាទិដ្ឋិរបស់មនុស្សលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយ ដូចតទៅនេះ ។ បទថា **កោធនោ** ជាមនុស្សក្រោធ គឺ មនុស្សដែលក្រោធរឿយ ៗ ។ បទថា **ឧបនាហី** អ្នកចងសេចក្តីក្រោធ គឺ មានប្រក្រតីផ្តើមសេចក្តីក្រោធនោះហើយចងទុក ។ បទថា **បាបមក្ខី** មានការលុបគុណដ៏លាមក គឺ មានការលុបគុណដែលជាសេចក្តីលាមក ។ បទថា **វសលោ** ជាមនុស្សអាក្រក់ គឺ មានជាតិនៃខ្ជួនលាមក ។ បទថា **មាយាវី** មានមាយា គឺ មានការបិទបាំងសេចក្តីអាក្រក់ដែលមានហើយ ។ បទថា **វិសុទ្ធោ** ជាអ្នកប្រសើរ គឺ ជាអ្នកបរិសុទ្ធដោយញាណទស្សនវិសុទ្ធិ ។ បទថា **សុទ្ធតំ គតោ** ដល់ភាពជាអ្នកបរិសុទ្ធ គឺ ដល់ភាពជាអ្នកបរិសុទ្ធដែលបានដល់ មគ្គផល ។ បទថា **មេធាវី** គឺ អ្នកមានបញ្ញា ។

ដោយគាថានេះ លោកសរសើរចំពោះអ្នកដល់ព្រមដោយសម្មាទិដ្ឋិដែលជាលោកុត្តរៈ ។

បទថា **វិបន្នទិដ្ឋិយោ សម្បន្នទិដ្ឋិយោ** ទិដ្ឋិវិបត្តិ ទិដ្ឋិសម្បត្តិ ព្រះសារីបុត្តលះវោហារថាបុគ្គល ពោលតិះដៀល និងសរសើរធម៌ ។ បទថា **ឯតំ មម** នោះរបស់យើង គឺ ទិដ្ឋិដោយអំណាចនៃការសម្គាល់ដោយតណ្ហា ។ បទថា **ឯសោ ហមស្មិ** នោះជាយើង គឺ ទិដ្ឋិមានការសម្គាល់ដោយមានះជាមូល ។ បទថា **ឯសោ មេ អត្តា** នោះជាខ្លួនរបស់យើង គឺ មានការសម្គាល់ដោយទិដ្ឋិនោះឯង ។

លោកសួរការចែក ការរាប់ និងការសង្គ្រោះកាលនៃទិដ្ឋិវិបត្តិ ៣ ដោយបទមានជាអាទិ៍ថា **ឯតំ មមន្តិ កា ទិដ្ឋិ** ទិដ្ឋិអ្វី ថានោះជារបស់យើង ហើយឆ្លើយ ។ ក្នុងបទទាំងនោះ បទថា **កា ទិដ្ឋិ** សេចក្តីថា បណ្តាទិដ្ឋិដ៏ច្រើន ទិដ្ឋិអ្វី ។ បទថា **កតមន្តានុគ្គហិតា** តាមប្រកាន់ចំណែកទីបំផុតអ្វី សេចក្តីថា ក្នុងពីរកាល គឺ កាលមានខន្ធជាអតីត និងកាលមានខន្ធជាអនាគត តាមប្រកាន់ដោយកាលណា ។ អធិប្បាយថា ជាប់តាម ។

ព្រោះកាលបើស្ទាបអង្អែលថា នោះជាយើង អាងដល់វត្ថុក្នុងអតីតថា នោះបានជារបស់យើងហើយ បានជារបស់យើងហើយយ៉ាង



នេះ បានជារបស់យើងហើយប្រមាណប៉ុណ្ណេះ ហើយស្ទាបអង្អែល ដូច្នោះ ទើបជាបុព្វន្តានុទិដ្ឋិ ( ការតាមឃើញខន្ធចំណែកអតីត ) ។ ហើយទិដ្ឋិទាំងនោះ ទើបជាទិដ្ឋិតាមប្រកាន់ខន្ធចំណែកអតីត ។

ព្រោះកាលបើស្ទាបអង្អែលថា នោះជាយើង រមែងស្ទាបអង្អែលអាស្រ័យផលក្នុងអនាគតថា យើងនឹងបរិសុទ្ធបានដោយសីល វត្តតបៈ ព្រហ្មចរិយៈនេះ ។ ដូច្នោះ ទើបជាអបរន្តានុទិដ្ឋិ តាមឃើញខន្ធចំណែកអនាគត ។ និងទិដ្ឋិទាំងនោះ ទើបជាទិដ្ឋិតាមប្រកាន់ខន្ធចំណែកអនាគត ។

ព្រោះកាលបើស្ទាបអង្អែលថា នោះជាខ្លួនរបស់យើង អាស្រ័យការជាប់បន្តដែលកើតឡើងក្នុងអតីត និងអនាគត រមែងស្ទាបអង្អែលថានោះជាខ្លួនរបស់យើង ហើយរមែងស្ទាបអង្អែលដោយសក្កាយទិដ្ឋិ ដូច្នោះទើបជាសក្កាយទិដ្ឋិ ។ ហើយទិដ្ឋិទាំងនោះជា **បុព្វន្តាបរន្តានុគ្គហិតា** តាមប្រកាន់ខន្ធទាំងអតីត និងអនាគត ។

ម្យ៉ាងទៀត ព្រោះទិដ្ឋិ ៦២ មានសក្កាយទិដ្ឋិជាប្រធាន ហើយទិដ្ឋិ ៦២ រមែងដល់ការដក ដោយការដកសក្កាយទិដ្ឋិនោះឯង ដូច្នោះ លោកទើបពោលថា ទិដ្ឋិ ៦២ ដោយមានសក្កាយទិដ្ឋិជាប្រធាន សេចក្តីថាទិដ្ឋិ ៦២ រមែងមានដោយទ្វារនៃសក្កាយទិដ្ឋិ ដែលមានសក្កាយទិដ្ឋិ

ជាប្រធាន ។ បាឋៈថា **សក្កាយទិដ្ឋិប្បមុខានិ** ដូច្នេះ ល្អជាង ។ ឈ្មោះថា **សក្កាយទិដ្ឋិប្បមុខានិ** ព្រោះមានសក្កាយទិដ្ឋិជាប្រធាន គឺ ជាខាងដើម ។ សក្កាយទិដ្ឋិទាំងនោះ គឺអ្វី ? គឺទិដ្ឋិ ៦២ ។

អត្តានុទិដ្ឋិមានវត្ថុ ២០ ដោយពាក្យសួរថា ទិដ្ឋិអ្វី ? ឆ្លើយថា គឺសក្កាយទិដ្ឋិមានវត្ថុ ២០ ។ ដោយពាក្យសួរថា ទិដ្ឋិប៉ុន្មាន ឆ្លើយថា ទិដ្ឋិ ៦២ មានសក្កាយទិដ្ឋិជាប្រធាន ។ម្យ៉ាងទៀត សក្កាយទិដ្ឋិនោះឯង លោកពោលថា អត្តានុទិដ្ឋិដោយពាក្យសម្គាល់ថា នោះជាតួខ្លួនរបស់យើង ។ កាលពោលដល់អត្តានុទិដ្ឋិនោះ ក៏ជាការពោលដល់សូម្បីទិដ្ឋិដែលបដិសំយុត្តដោយអត្តវាទ ។

ដើម្បីសម្តែងការចំណែកបុគ្គលអ្នកដល់ព្រមដោយទិដ្ឋិ ដោយសម្ព័ន្ធនឹងបុគ្គលអ្នកដល់ព្រមដោយទិដ្ឋិ លោកទើបនាំព្រះសូត្រមកមានជាអាទិ៍ថា **យេ កេចិ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ជនពួកណា មួយដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **និដ្ឋំ គតា** គឺ ដល់ការជឿ គឺជឿថា ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង ដោយអំណាចនៃមគ្គញាណ សេចក្តីថា អស់សេចក្តីសង្ស័យ ។ បាឋៈថា **និដ្ឋាគតា** ជាបទសមាសសេចក្តីដូចគ្នា ។ បទថា **ទិដ្ឋិសម្បន្នា** គឺ ដល់ការស្អាតដោយទិដ្ឋិ ។ បទថា **ឥធ និដ្ឋា** ជឿពិតក្នុងធម៌នេះ គឺ



ការរំលត់ដោយកាមធាតុនេះ ។ បទថា **ឥធ វិហាយ និដ្ឋា** ជឿពិតក្នុងសុទ្ធាវាស ក្នុងធម៌នេះ គឺ លះកាមភពនេះហើយ បរិនិព្វានក្នុងព្រហ្មជាន់សុទ្ធាវាស ។

បទថា **សត្តក្ខត្តុបរមស្ស** គឺ គប្បីកាន់យកអត្តភាពក្នុងភព ៧ ដង គឺ ៧ ដងជាយ៉ាងក្រៃលែង ឈ្មោះថា **សត្តក្ខត្តុបរមោ** គឺ មិនកាន់យកភពទី ៨ ដទៃអំពីភពដែលឧបត្តិកាន់យកអត្តភាពនោះ ។ បានដល់ព្រះសត្តក្ខត្តុបរមសោតាបន្ននោះ ។ បទថា **កោលំកោលស្ស** ឈ្មោះថា **កោលំកោល** ព្រោះទៅកាន់ត្រកូលអំពីត្រកូល ។ សេចក្តីថា ព្រោះមិនកើតក្នុងត្រកូលថោកទាប ចាប់ផ្តើមតាំងអំពីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល រមែងកើតក្នុងត្រកូលមានភោគសម្បត្តិច្រើនប៉ុណ្ណោះ ។ បានដល់ ព្រះកោលំកោលសោតាបន្ន ។ បទថា **ឯកពីជិស្ស** លោកពោលពីជ គឺ ខន្ធ ។ ព្រះសោតាបន្នមានពីជ គឺ ខន្ធមួយប៉ុណ្ណោះកាន់យកអត្តភាពមួយឈ្មោះថា **ឯកពីជី** ។ បានដល់ ព្រះឯកពីជីសោតាបន្ន ។ ឈ្មោះរបស់បុគ្គលទាំងនេះ ជាឈ្មោះដែលព្រះមានព្រះភាគទ្រង់តាំងទុក ។ ព្រោះបុគ្គលអ្នកដល់ឋានៈប្រមាណទាំងនេះ ឈ្មោះថា **សត្តក្ខត្តុបរម** ប្រមាណត្រឹមប៉ុណ្ណោះឈ្មោះថា **កោលំកោល** ប្រមាណប៉ុណ្ណោះឈ្មោះថា **ឯកពីជី** ព្រោះហេតុនោះ ទើបជាឈ្មោះ

ដែលព្រះមានព្រះភាគទ្រង់តាំងទុកឲ្យដល់បុគ្គលទាំងនេះ ។ ពិតណាស់ ព្រះមានព្រះភាគទ្រង់ដឹងថា បុគ្គលនេះនឹងដល់ឋានៈប្រមាណប៉ុណ្ណេះ បុគ្គលនេះនឹងដល់ឋានៈប្រមាណប៉ុណ្ណេះ ហើយទើបទ្រង់តាំងឈ្មោះនោះ ៗ ដល់បុគ្គលទាំងនោះ ។

ពិតណាស់ ព្រះសោតាបន្នមានបញ្ញាទន់ កើត ៧ ដង ទើបឈ្មោះថា **សត្តក្ខត្តុបរមៈ** មានបញ្ញាបែបកណ្តាល កើតទៀតមិនលើសភពទី ៦ ទើបឈ្មោះថា **កោលំកោលៈ** មានបញ្ញាខ្លាំងក្លាកើតត្រឹមតែភពមួយ ទើបឈ្មោះថា **ឯកពីជី** ។ ព្រះសោតាបន្នទាំងនោះ មានបញ្ញាទន់ កណ្តាល និងខ្លាំងក្លានោះ រមែងកំណត់ព្រោះបុព្វហេតុ ។ ព្រះសោតាបន្នសូម្បីទាំង ៣ នេះ លោកពោលដោយអំណាចនៃកាមភពតែក្នុងរូបភព និងអរូបភពរមែងមានបដិសន្ធិសូម្បីច្រើន ។

បទថា **សកទាគាមិស្ស** ឈ្មោះថា **សកទាគាមី** ព្រោះមកកាន់កាមភពមួយដងទៀត ដោយអំណាចនៃបដិសន្ធិ ។ បានដល់ ព្រះសកទាគាមីនោះ ។ បទថា **ទិដ្ឋេវ ធម្មេ អរហា** ព្រះអរហន្តក្នុងបច្ចុប្បន្ន គឺ ព្រះអរហន្តក្នុងអត្តភាពនេះឯង ។ បាឋៈថា **អរហំ** ដូច្នេះខ្លះ ។ បទថា **ឥធ និដ្ឋា** ជៀក្នុងធម៌នេះ លោកពោលសំដៅដល់អ្នកត្រាច់ទៅកាន់កាមភព ។ ចំណែកព្រះអរិយៈទាំងឡាយ កើតក្នុង



រូបភព និងអរូបភព រមែងមិនកើតក្នុងកាមភព រមែងបរិនិព្វានក្នុងភពនោះឯង ។

បទថា **អន្តរាបរិនិព្វាយិស្ស** ឈ្មោះថា **អន្តរាបរិនិព្វាយី** ព្រោះនឹងបរិនិព្វានដោយការរំលត់កិលេស ក្នុងរវាងពាក់កណ្តាលអាយុ ។ ម្យ៉ាងទៀត អនាគាមីនោះមាន ៣ ពួក គឺ លោកនឹងបរិនិព្វានក្នុងរវាងជិតកើត ១ លោកនឹងបរិនិព្វានក្នុងរវាងអាយុនៅមិនទាន់ដល់ពាក់កណ្តាល ១ លោកនឹងបរិនិព្វានក្នុងរវាងអាយុដល់ពាក់កណ្តាល ១ ។ បានដល់ **ព្រះអន្តរាបរិនិព្វាយីអនាគាមី** នោះ ។

បទថា **ឧបហច្ចបរិនិព្វាយិស្ស** បានដល់ ព្រះអនាគាមីអ្នកផុតអាយុពាក់កណ្តាល ឬជិតនឹងដល់កាលកិរិយា ហើយបរិនិព្វានដោយការរំលត់កិលេស ។

បទថា **អសង្ខារបរិនិព្វាយិស្ស** បានដល់ ព្រះអនាគាមីអ្នកមិនធ្វើសេចក្តីព្យាយាមច្រើន ហើយបរិនិព្វានដោយការរំលត់កិលេស ដោយប្រើសេចក្តីព្យាយាមច្រើន ។

បទថា **សសង្ខារបរិនិព្វាយិស្ស** បានដល់ ព្រះអនាគាមីអ្នកត្រូវញុំាងសេចក្តីព្យាយាមច្រើន ហើយបរិនិព្វានដោយការរំលត់កិលេសត្រូវញុំាងសេចក្តីព្យាយាមយ៉ាងលំបាក ។

បទថា **ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ** បានដល់ ព្រះអនាគាមីអ្នកមានក្រសែខាងលើ គឺ ក្រសែតណ្ហា ក្រសែវដ្ដៈក្នុងខាងលើ ព្រោះនាំទៅក្នុងខាងលើ ឬមានក្រសែក្នុងខាងលើ គឺ ក្រសែមគ្គក្នុងខាងលើ ព្រោះទៅក្នុងខាងលើហើយគប្បីបាន ។ ឈ្មោះថា **អកនិដ្ឋ-គាមី** ព្រោះទៅកាន់អកនិដ្ឋា ។ បានដល់ **ព្រះអនាគាមីឧទ្ធំសោត-អកនិដ្ឋគាមី** នោះ ។ នេះគឺ ព្រះអនាគាមីមាន ៤ ប្រភេទ ។

លោកអ្នកធ្វើព្រហ្មលោក ៤ តាំងអំពីអវិហា ឲ្យបរិសុទ្ធហើយទៅកាន់អកនិដ្ឋា ទើបបរិនិព្វាន ឈ្មោះថា **ឧទ្ធំសោតោអកនិដ្ឋគាមី** ។

លោកអ្នកធ្វើព្រហ្មលោក ៣ ខាងក្រោមឲ្យបរិសុទ្ធ ហើយតាំងនៅក្នុងសុទស្សីព្រហ្មលោក ទើបបរិនិព្វាន ឈ្មោះថា **ឧទ្ធំសោតោ** មិនឈ្មោះថា អកនិដ្ឋគាមី ។

លោកអ្នកទៅកាន់អកនិដ្ឋា អំពីនេះហើយបរិនិព្វាន មិនឈ្មោះថា ឧទ្ធំសោតោ ឈ្មោះថា **អកនិដ្ឋាគាមី** ។

លោកអ្នកបរិនិព្វានក្នុងទីនោះ ៗ ក្នុងព្រហ្មលោក ៤ ខាងក្រោម មិនឈ្មោះថា ឧទ្ធំសោតោ មិនឈ្មោះថា អកនិដ្ឋគាមី ។

ព្រះអនាគាមី ៥ ទាំងនេះ លោកពោលយកសុទ្ធាវាស ។ ចំណែកព្រះអនាគាមីទាំងឡាយ ព្រោះនៅលះរូបរាគៈ អរូបរាគៈមិន



បាន នៅប្រាថ្នា រមែងកើតក្នុងរូបភព និងអរូបភពដ៏សេស តែព្រះ-អនាគាមីទាំងឡាយកើតក្នុងសុទ្ធាវាសតែម្យ៉ាង មិនកើតក្នុងទីដទៃ ។

បទថា **អវេច្ចប្បសន្នា** ជ្រះថ្លាដ៏មុតមាំ គឺ ត្រាស់ដឹងដោយអរិយមគ្គហើយ ជ្រះថ្លាដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ។ បទថា **សោតាបន្នា** គឺ លោកអ្នកដល់ក្រសែអរិយមគ្គ ។ សូម្បីបុគ្គលអ្នកតាំងនៅក្នុងអរិយផលទាំងពួង លោកក៏កាន់យកដោយបទនេះ ។

ចប់ អដ្ឋកថាភវវិភវនិទ្ទេស

នៃអដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះថា សទ្ធម្មបកាសិនី

# អានាចានស្សតិកថា ក្នុងមហាវគ្គ

## ៣–អដ្ឋកថា គណនវារ

ឥឡូវនេះ ដល់លំដាប់នឹងពណ៌នានូវកថាដែលមិនធ្លាប់ពណ៌នា នៃអានាបានស្សតិកថាដែលលោកពោលទុកក្នុងលំដាប់នៃទិដ្ឋិកថា ។

ពិតណាស់ អានាបានស្សតិកថានេះ ជាសមាធិភាវនាដែលធ្វើបានឆាយដើម្បីត្រាស់ដឹងតាមសេចក្តីពិតនៃទោសរបស់ទិដ្ឋិ ដែលពោលទុកល្អហើយក្នុងទិដ្ឋិកថា នៃចិត្តបរិសុទ្ធដោយល្អ ដោយការជម្រះមន្ទិលនៃមិច្ឆាទិដ្ឋិ ។ ម្យ៉ាងទៀត ក្នុងសមាធិភាវនាទាំងពួង អានាបានស្សតិកថានេះ លោកពោលទុកក្នុងលំដាប់នៃទិដ្ឋិកថា ថាជាសមាធិភាវនានិងជាប្រធាន ព្រោះត្រាស់ដឹងតាមសេចក្តីពិតនៃចិត្តតាំងមាំហើយដោយសមាធិនេះ ត្រង់ពោធិមូល នៃព្រះសព្វញ្ញូពោធិសត្វទាំងពួង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអានាបានស្សតិកថានោះ ដូចតទៅនេះ ។ បទថា **សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ សមាធិកានិ ទ្វេ ញាណសតានិ ឧប្បជ្ជន្តិ** កាលព្រះយោគាវចរចម្រើនសមាធិដែលបដិសំយុត្តដោយអានាបានស្សតិ មានវត្ថុ ១៦ , ញាណ ២០០ ដែលភ្ជាប់មកអំពីសមាធិ រមែងកើតឡើង ជាការលើកឡើង



សម្តែងចំនួនញាណ ។ បទមានអាទិ៍ថា **អដ្ឋ បរិបន្ថេ ញាណានិ** ញាណក្នុងធម៌ដែលជាអន្តរាយ ៨ ជាការសម្តែងចំនួនញាណ ។ បទដើមថា **កតមានិ អដ្ឋ បរិបន្ថេ ញាណានិ** ញាណក្នុងធម៌ដែលជាអន្តរាយ ៨ តើដូចម្តេច ។ បទចុងក្រោយថា **ឥមានិ ឯកវីសតិ វិមុត្តិសុខេ ញាណានិ** ញាណក្នុងវិមុត្តិសុខ ២១ ទាំងនេះ ជាការសម្តែងសេចក្តីពិស្តារនៃញាណទាំងពួង ។ គប្បីជ្រាបការកំណត់បាលីមុនយ៉ាងនេះថា បទមានជាអាទិ៍ថា **សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ** កាលព្រះយោគាវចរចម្រើនសមាធិដែលបដិសំយុត្តដោយអានាបានស្សតិ មានវត្ថុ ១៦ ជាបទសរុបក្នុងទីបំផុត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការលើកសម្តែងចំនួន ក្នុងការរាប់ចំនួនថា អានាបានស្សតិសមាធិ មានវត្ថុ ១៦ មុន ដូចតទៅនេះ ។ ឈ្មោះថា **សោឡសវត្ថុកោ** ព្រោះមានវត្ថុជាទីតាំង គឺ មានអារម្មណ៍ ១៦ ដោយអំណាចនៃចតុកៈមួយ ៗ ៤ ទាំងនេះ គឺ ខ្យល់ដកដង្ហើមវែង ខ្លី កំណត់ដឹងកងខ្យល់ទាំងពួង រម្ងាប់កាយសង្ខារ ឈ្មោះថា កាយានុបស្សនាចតុកៈ ១ , កំណត់ដឹងបីតិ សុខ ចិត្តសង្ខារ រម្ងាប់ចិត្តសង្ខារ ឈ្មោះថា វេទនានុបស្សនាចតុកៈ ១ , កំណត់ដឹងចិត្ត ចិត្តត្រេកអរក្រៃលែង ចិត្តតាំងមាំ ចិត្តរួចផុត ឈ្មោះថា ចិត្តានុបស្ស-

នាចតុកៈ ១ , ពិចារណាឃើញការមិនទៀង ការប្រាសចាកតម្រេក ការរលត់ទុក្ខ ការលះបង់ ឈ្មោះថា ធម្មានុបស្សនាចតុកៈ ១ ។ អានាបានស្សតិសមាធិ មាន វត្ថុ ១៦ នោះ ។ ក៏ក្នុងបទនេះ លុបវិភត្តិដោយវិធីនៃសមាស ។

បទថា **អានំ** បានដល់ ខ្យល់ដកដង្ហើមចូលក្នុងខាងក្នុង ។

បទថា **អបានំ** បានដល់ ខ្យល់ដកដង្ហើមចេញក្នុងខាងក្រៅ ។ តែអាចារ្យពួកខ្លះពោលដោយការផ្ទុយគ្នា ព្រោះខ្យល់ដកដង្ហើមចេញ លោកពោលថា **អបាន** ព្រោះប្រាសចាកការដកដង្ហើមចូល ។ តែក្នុងនិទ្ទេសលោកពោលថា **អាបាន** ព្រោះសម្ងឹងដល់ទីឃៈ **ន** អក្សរ ។ កាលមាន **អានាបាន** នោះ ឈ្មោះថា អានាបានស្សតិ ។ អានាបានស្សតិនេះ ជាឈ្មោះរបស់សតិកំណត់អស្សាសបស្សាសៈ ( ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញ ) សមាធិប្រកបដោយអានាបានស្សតិ ឬសមាធិក្នុងអានាបានស្សតិ ឈ្មោះថា អានាបានស្សតិសមាធិ ។

បទថា **ភាវយតោ** គឺ ចម្រើននិព្វេធភាគី ( ធម៌ជាចំណែកនៃការចាក់ធ្លុះ ) ។ បទថា **សមាធិកានិ** ដែលភ្ជាប់មកអំពីសមាធិ គឺ ប្រព្រឹត្តទៅជាមួយដោយសេចក្តីក្រៃលែង សេចក្តីថា មានសេចក្តីដ៏ក្រៃលែង ។ ក្នុងបទថា **សមាធិកានិ** នេះ **ម** អក្សរ ជាបទសន្ធិ ។



តែអាចារ្យពួកខ្លះពោលថា **សំ អធិកានិ** ។ បើជាយ៉ាងនោះ ក៏បាន សេចក្តីថា ញាណ ២០០ ផង ក្រៃលែងផង ។ សេចក្តីនោះមិនត្រូវ ព្រោះញាណ ២០០ ទាំងនេះ ក៏នឹងច្រើនជាង ២០ ។

បទថា **បរិបន្ថេ ញាណានិ** ញាណក្នុងធម៌ជាអន្តរាយ គឺ ញាណដែលប្រព្រឹត្តទៅ ព្រោះធ្វើអន្តរាយឲ្យជាអារម្មណ៍ ។ ម្យ៉ាងទៀត ញាណក្នុងធម៌ជាឧបការៈក្នុងឧបក្កិលេស ។ បទថា **វោទានេ ញាណានិ** ញាណក្នុងវោទាន ( សេចក្តីផូរផង់ ) គឺឈ្មោះថា វោទាន ព្រោះចិត្តផូរផង់បរិសុទ្ធដោយញាណនោះ ។ គួរពោលថា **វោទានញាណានិ** លោកពោលថា **វោទានេ ញាណានិ** ញាណក្នុងវោទាន ដូចក្នុងបទមានជាអាទិ៍ថា **សុតមយេ ញាណំ** ញាណក្នុងសុតមយបញ្ញា ។ ឈ្មោះថា **សតោការី** ព្រោះមានសតិសម្បជញ្ញៈធ្វើ ញាណរបស់អ្នកមានសតិធ្វើនោះ ។

បទថា **និព្វិទាញាណានិ** គឺ ញាណដែលជានិព្វិទា ( នឿយណាយ ) ។ បទថា **និព្វិទានុលោមេ ញាណានិ** គឺ ញាណអនុលោមដល់និព្វិទា ។ បាឋៈថា **និព្វិទានុលោមិញាណានិ** ខ្លះ ។ សេចក្តីថា ឈ្មោះថា **និព្វិទានុលោមី** ព្រោះមានញាណអនុលោមដល់និព្វិទា ។ បទថា **និព្វិទាបដិប្បស្សទ្ធិញ្ញាណានិ** គឺ ញាណក្នុងសេចក្តីស្ងប់និព្វិទា ។

បទថា **វិមុត្តិសុខេ ញាណានិ** គឺ ញាណសម្បយុត្តដោយវិមុត្តិសុខ ។

ដោយបទមានជាអាទិ៍ថា **កតមានិ អដ្ឋ** ( ៨ ) តើដូចម្តេច លោកសម្តែងដល់ញាណរួមគ្នាក្នុងធម៌ជាអន្តរាយ និងក្នុងធម៌ជាឧបការៈទាំងនោះ ព្រោះញាណក្នុងធម៌ជាអន្តរាយ និងក្នុងធម៌ជាឧបការៈ ជាគូ ផ្ទុយគ្នា និងជាសត្រូវដល់គ្នា ។ បទមានជាអាទិ៍ថា **កាមច្ឆន្ទនេក្ខម្មា** មានសេចក្តីដូចបានពោលហើយក្នុងខាងក្រោយ ។ ម្យ៉ាងទៀត បទថា **ឧបការំ** ជានបុំសកលិង្គដោយជាលិង្គវិបល្លាស ។

បទថា **សព្វេបិ អកុសលា ធម្មា** អកុសលធម៌សូម្បីទាំងពួង គឺ អកុសលធម៌ណាមួយដ៏សេស ដូចពោលហើយ ។ ម្យ៉ាងទៀត កុសលធម៌ទាំងពួងជាចំណែកនៃការចាក់ធ្លុះ ។ បទថា **បរិបន្ថោ** និង **ឧបការំ** ជាឯកវចនៈ ព្រោះសម្ពឹងដល់បទនោះ ៗ ឯង ។

ព្រះសារីបុត្តត្ថេរ លុះសួរដល់ញាណក្នុងធម៌ជាអន្តរាយ និងញាណក្នុងធម៌ជាឧបការៈនេះហើយ ដោះស្រាយអារម្មណ៍នៃញាណទាំងនោះ ហើយសម្តែងសរុបញាណ ដែលមានញាណនោះជាអារម្មណ៍ថា ជាការដោះស្រាយញាណទាំងនោះ ដោយធម៌ជាបរិបន្ថៈ និងឧបការៈទាំងនោះហើយ ។ សូម្បីក្នុងបទមានជាអាទិ៍ថា ញាណក្នុង



ឧបក្កិលេសក៏មានន័យនេះដូចគ្នា ។

( ចប់ អដ្ឋកថាគណនវារ )

## អដ្ឋកថាសោឡសញ្ញាណនិទ្ទេស

បទថា **សោឡសហិ អាការេហិ** ដោយអាការ ១៦ ទាំងនេះ គឺ ដោយចំណែកនៃញាណ ១៦ ដូចបានពោលហើយ ដោយមានចំណែកទាំងពីរ ។ បទថា **ឧទុបិតចិត្តំ សមុទុបិតចិត្តំ** ចិត្តដែលរាយមាយ និងចិត្តដែលស្ងប់ម្ងាប់ សេចក្តីថា ក្នុងឧបចារភូមិ ចិត្តសន្សំទុកខាងលើ សន្សំទុកខាងលើដោយប្រពៃ ធ្វើការសន្សំខ្ពស់ឡើង ៗ ធ្វើការសន្សំខ្ពស់ឡើង ៗ ដោយប្រពៃ ។ បាឋៈថា **ឧទុជិតំ ចិត្តំ សមុជិតំ** ខ្វះ ។ សេចក្តីថា ចិត្តឈ្មោះ ព្រោះភាពខ្ពង់ខ្ពស់ ឬឈ្មោះ ដោយញាណដែលធ្វើឲ្យខ្ពង់ខ្ពស់ ។

បទថា **សមុទុជិតំ** គឺ ឈ្មោះព្រោះសេចក្តីខ្ពស់ស្មើ ឬឈ្មោះ ដោយញាណដែលធ្វើភាពខ្ពង់ខ្ពស់ ជាការបដិសេធភាពមិនស្មើគ្នា ក្នុងបទនេះថា **សមា** ស្មើ ។ ក្នុងបាឋៈមានឧបសគ្គ ២ គឺ ឧ , ទុ ,

បាឋៈថា **ឧរូជិតំ ចិត្តំ សម្មារូជិតំ** ខ្លះ ។ សូម្បីក្នុងបាឋៈនេះ ក៏មានសេចក្តីថា **ឈ្នះហើយ** ដូចគ្នា ។ អាចារ្យពួកមួយពោលថា បទថា **ឧរូ អរូ** នេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។

ក្នុងអដ្ឋកថាវីណោបមសូត្រ លោកពោលថា **តជ្ជិតំ** និង **សុតជ្ជិតំ** គឺ គំរាមកំហែងហើយ គំរាមកំហែងល្អហើយ ។ សេចក្តីនោះមិនសមគួរក្នុងទីនេះ ។ បទថា **ឯកត្តេ សន្តិដ្ឋតិ** រមែងតាំងនៅក្នុងភាវៈជាធម៌តែមួយ គឺ រមែងតាំងនៅក្នុងភាវៈជាធម៌តែមួយក្នុងឧបចារភូមិ ដោយមិនមានភាពរាយមាយក្នុងអារម្មណ៍ផ្សេង ៗ ។

ក្នុងបទនេះថា **និយ្យានាវរណដ្ឋេន នីវរណា** ឈ្មោះថា នីវរណ ព្រោះអត្ថថា ជាគ្រឿងរារាំងនូវធម៌គ្រឿងនាំចេញ លោកពោលថា សូម្បីការមិនត្រេកអរ សូម្បីអកុលសទាំងពួង ក៏ឈ្មោះថា **នីវរណ** ព្រោះអត្ថថា ជាគ្រឿងរារាំង ។ បទថា **និយ្យានាវរណដ្ឋេន** ឈ្មោះថា **នីវរណ** ព្រោះអត្ថថា ជាគ្រឿងបិទផ្លូវមកនៃធម៌ជាគ្រឿងនាំចេញ ។ បាឋៈថា **និយ្យានាវារណដ្ឋេន** ខ្លះ ។ សេចក្តីថា ឈ្មោះថា **នីវរណ** ព្រោះអត្ថថា ជាគ្រឿងហាមនូវធម៌ជាគ្រឿងនាំចេញ ។

បទថា **នេក្ខម្មំ អរិយានំ និយ្យានំ** នេក្ខម្មៈជាធម៌នាំចេញរបស់ព្រះអរិយៈជាម្ចាស់ទាំងឡាយ គឺ ជាទីតាំងនៃមគ្គ ឈ្មោះថា



ជាធម៌នាំចេញរបស់ព្រះអរិយទាំងឡាយ ដោយផលូបចារៈ ព្រោះជាហេតុនៃអរិយមគ្គ ពោលគឺ ជាធម៌នាំចេញនៃព្រះអរិយៈទាំងឡាយ ។ ព្រះអរិយជាម្ចាស់ទាំងឡាយ រមែងនាំចេញ គឺ ចូលដល់ក្នុងខណៈនៃមគ្គ ដោយផលូបចារនោះជាហេតុ ។ ចំណែកអាចារ្យពួកខ្លះពោលថា បទថា **និយ្យានំ** គឺ **មគ្គ** ។ សេចក្តីនោះ មិនត្រូវ ព្រោះក្នុងទីនេះ លោកបំណងយកឧបចារៈ និងព្រោះមិនមានអាលោកសញ្ញា និងកុលសធម៌ទាំងពួងក្នុងខណៈនៃមគ្គ ។ បទថា **និវុតត្តា** ព្រោះត្រូវអកុលសធម៌រារាំងទុក គឺ បិទបាំងទុក ។

បទថា **នប្បជានាតិ** រមែងមិនដឹង លោកពោលដោយអំណាចនៃបុគ្គល ។ បទថា **វិសុទ្ធិចិត្តស្ស** អ្នកមានចិត្តបរិសុទ្ធ បានដល់ក្នុងឧបចារភូមិនោះឯង ។

បទថា **ខណិកសមោធានា** ការដែលចិត្តតាំងមាំ ប្រព្រឹត្តទៅជាខណៈ សេចក្តីថា ឈ្មោះថា **ខណិកា** ព្រោះមានខណៈ ព្រោះកើតឡើងក្នុងខណៈចិត្ត ក្នុងខណៈចិត្ត បានដល់ ឧបក្កិលេស ការតាំងមាំ ការប្រជុំ ការរួបរួមចិត្ត ប្រព្រឹត្តទៅជាខណៈ ឈ្មោះថា **ខណិកស-មោធាន** ដូច្នោះ ទើបចិត្តមានសភាពតាំងមាំ ប្រព្រឹត្តទៅជាខណៈ ។ លោកអធិប្បាយទុកថា ឧបក្កិលេសទាំងឡាយ កាលកើត រមែងកើត

ដោយការជាប់តគ្នាជាខណៈ ដោយការជាប់បន្តគ្នាមកជាខណៈ គឺ មិនកើតដោយអំណាចនៃខណៈចិត្ត មួយដួង ។

( ចប់ អដ្ឋកថាសោឡសញ្ញាណនិទ្ទេស )

## អដ្ឋកថា ឧបក្កិលេសញ្ញាណនិទ្ទេស

### **បឋមឆក្កៈ ( ឆក្កៈទី ១ )**

គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមឆក្កៈ ដូចតទៅនេះ ។ បទថា **អស្សាសាទិមជ្ឈបរិយោសានំ** ខាងដើមកណ្តាល និងខាងចុង នៃខ្យល់ដកដង្ហើមចូល គឺ ចុងច្រមុះ ឬនិមិត្តមាត់ ជាខាងដើមនៃខ្យល់ចូលក្នុងខាងក្នុង បេះដូងជាកណ្តាល មាននាភីជាខាងចុង ។ កាលព្រះយោគាវចរញុំាងសតិទៅតាមខាងដើម កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចូលនោះ ចិត្តដល់ភាពរាយមាយក្នុងខាងក្នុងទៅតាមសភាពផ្សេងគ្នានៃទីតាំង ចិត្តដល់សភាពរាយមាយក្នុងខាងក្នុងនោះ ជាអន្តរាយដល់សមាធិ ព្រោះមិនតាំងនៅក្នុងអារម្មណ៍តែមួយ ។



បទថា **បស្សាសាទិមជ្ឈបរិយោសានំ** ខាងដើម កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចេញ គឺ ផ្ចិតជាខាងដើមនៃខ្យល់ចេញទៅក្នុងខាងក្រៅ បេះដូងជាកណ្តាល ចុងច្រមុះ និមិត្តមាត់ ឬអាកាសខាងក្រៅ ជាខាងចុង ។ ក្នុងទីនេះគប្បីជ្រាប ការប្រកបដោយន័យដូចពោលហើយនោះឯង ។

បទថា **អស្សាសបដិកន្ខណា និកន្តិ តណ្ហាចរិយា** សភាពក្នុងចិត្ត គឺ សេចក្តីប្រាថ្នាខ្យល់ដកដង្ហើមចូល ការត្រាច់ទៅដោយតណ្ហា សេចក្តីថា ការកំណត់ថា កម្មដ្ឋាននេះជាប់ដោយចុងច្រមុះ ហើយពេញចិត្ត គឺ ប្រាថ្នាខ្យល់ដកដង្ហើមចូលដែលគ្រោតគ្រាត និងគ្រោតគ្រាត ការប្រព្រឹត្តទៅដោយតណ្ហា ។ កាលមានការប្រព្រឹត្តទៅនៃតណ្ហា ឈ្មោះថា ជាអន្តរាយដល់សមាធិ ព្រោះមិននៅក្នុងអារម្មណ៍តែមួយ ។

បទថា **បស្សាសបដិកន្ខណា និកន្តិ** សេចក្តីប្រាថ្នា សេចក្តីពេញចិត្តក្នុងខ្យល់ដកដង្ហើមចេញ សេចក្តីថា សេចក្តីពេញចិត្ត គឺ ការប្រាថ្នាដកដង្ហើមចេញដែលប្រព្រឹត្តទៅមុនខ្យល់ដកដង្ហើមចូល ។ បទដ៏សេស គប្បីប្រកបតាមន័យដូចពោលហើយនោះឯង ។

បទថា **អស្សាសេនាភិតុន្នស្ស** នៃបុគ្គលអ្នកត្រូវខ្យល់ដកង្ហើម

ចូលគ្របសង្កត់ សេចក្តីថា កាលខ្យល់ដកដង្ហើមចូលវែងពេកទៅ ឬខ្លីពេកទៅ ត្រូវដកដង្ហើមចូលទម្លាយបៀតបៀន ព្រោះមានការលំបាកនៃកាយ និងចិត្ត ដែលមានខ្យល់ដកដង្ហើមចូលជាមូល ។

បទថា **បស្សាសបដិលាភេ មុច្ឆនា** សេចក្តីវង្វេងក្នុងការបានខ្យល់ដកដង្ហើមចេញ គឺ ព្រោះត្រូវខ្យល់ដកង្ហើមចូលបៀតបៀនអ្នកមានការសម្គាល់ក្នុងការពេញចិត្តក្នុងខ្យល់ដកដង្ហើមចេញ ប្រាថ្នាខ្យល់ដកដង្ហើមចេញ ត្រេកអរក្នុងការបានខ្យល់ដកដង្ហើមចេញនោះ ។ សូម្បីក្នុងខ្យល់ដកដង្ហើមចេញជាមូល ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាព័ន្ធដែលលោកពោល ដើម្បីពណ៌នាតាមសេចក្តីដែលបានពោលទុកហើយ ដូចតទៅនេះ ។

បទថា **អនុគច្ឆនា** គឺ ទៅតាម ។ បទថា **សតិ** គឺ សតិ ដែលជាហេតុរាយមាយក្នុងខាងក្នុង និងខាងក្រៅ ឈ្មោះថា **វិក្ខេបោ** ព្រោះចិត្តរាយមាយដោយខ្យល់ដកដង្ហើមនោះ សេចក្តីរាយមាយក្នុងខាងក្នុង ឈ្មោះថា **អជ្ឈត្តវិក្ខេបោ** ។ សេចក្តីប្រាថ្នា សេចក្តីរាយមាយក្នុងខាងក្នុងនោះ ឈ្មោះថា **អជ្ឈត្តវិក្ខេបាកង្ខណា** លោកអធិប្បាយថា សេចក្តីប្រាថ្នាខ្យល់ដកដង្ហើមចូលដែលរាយមាយក្នុងខាងក្នុង ដោយការមិនមានចិត្តប្រពៃ ។ គប្បីជ្រាបសេចក្តីប្រាថ្នា សេចក្តីរាយមាយ



ក្នុងខាងក្រៅ ដោយន័យនេះដូចគ្នា ។ បទថា **យេហិ** គឺ ដោយឧបក្កិលេសពួកណា ។ បទថា **វិកម្បមានស្ស** អ្នកញាប់ញ័រ គឺ អ្នករាយមាយ ដល់ភាពរាយមាយ ។

បទថា **នោ ចេ ចិត្តំ វិមុច្ចតិ** បើចិត្តមិនទាន់រួចផុត គឺ ចិត្តមិនបង្អោនទៅក្នុងអារម្មណ៍ដែលជាអស្សាសបស្សាសៈ និងមិនទាន់រួចផុតចាកធម៌ជាសត្រូវ ។ គប្បីជ្រាបការភ្ជាប់ថា ចិត្តមិនទាន់រួចផុត និងឲ្យដល់ការជឿចំពោះអ្នកដទៃ ។ បទថា **វិមោក្ខំ អប្បជានន្តា** មិនដឹងច្បាស់នូវវិមោក្ខ គឺ អ្នកនោះ ឬអ្នកដទៃ មិនដឹងច្បាស់នូវវិមោក្ខដែលជាការពេញនៃអារម្មណ៍ និងនូវវិមោក្ខដែលជាការរួចផុតចាកធម៌ជាសត្រូវ យ៉ាងនេះ ។ បទថា **បរបត្តិយា** គឺ មានមនុស្សដទៃជាបច្ច័យ ជឿមនុស្សដទៃ មិនមានញាណដែលប្រចក្សដល់ខ្លួន កាលគួរពោលថា **បរបច្ចយិកា** លោកពោល **បរបត្តិយា** ។ សេចក្តីដូចគ្នា ។

( ចប់បឋមឆក្កៈ )

## ទុតិយឆក្កៈ ( ឆក្កៈទី ២ )

គប្បីជ្រាបវិនិច្ឆ័យ ក្នុងទុតិយឆក្កៈដូចតទៅនេះ ។ បទថា

**និមិត្តំ** ដែលសម្ផស្សនៃខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ។ ព្រោះអស្សាសបស្សាសៈ ប៉ះខ្ទប់ក្ដោងច្រមុះរបស់អ្នកមានច្រមុះវែង ប៉ះខ្ទប់បបូរមាត់ខាងលើរបស់អ្នកមានច្រមុះខ្លី ។ បើព្រះយោគាវចរនេះនឹកដល់និមិត្តនោះ ចិត្តរបស់ព្រះយោគាវចរអ្នកនឹកដល់និមិត្តនោះ រមែងរវើរវាយ នៅត្រង់ខ្យល់ដកដង្ហើមចូល គឺ មិនតាំងនៅបាន ។ កាលចិត្តរបស់ព្រះយោគាវចរនោះ មិនតាំងនៅ ការរវើរវាយនោះជាអន្តរាយរបស់សមាធិ ព្រោះមិនមានសមាធិ ។ ប្រសិនថានឹកដល់អស្សាសៈតែម្យ៉ាង ចិត្តរបស់ព្រះយោគាវចរនោះ រមែងនាំមកនូវការរាយមាយ ដោយការចូលទៅក្នុងខាងក្នុង ចិត្តមិនតាំងនៅក្នុងនិមិត្ត ។ ព្រោះដូច្នោះ ចិត្តរមែងរវើរវាយក្នុងនិមិត្ត ដោយន័យនេះ គប្បីធ្វើការប្រកបសូម្បីក្នុងបទដ៏សេស ។ បទថា **វិកម្បតិ** ក្នុងគាថាទាំងឡាយ បានដល់ សេចក្ដីរាយមាយ គឺ ដល់ភាពរាយមាយ ។

**( ចប់ ទុតិយឆក្កៈ )**

## តតិយឆក្កៈ ( ឆក្កៈទី ៣ )

គប្បីជ្រាបវិនិច្ឆ័យ ក្នុងតតិយឆក្កៈដូចតទៅនេះ ។ បទថា **អតីតានុធាវនំ ចិត្តំ** ចិត្តស្ទុះទៅតាមអតីតារម្មណ៍ គឺ ចិត្តដែល



ទៅតាមអស្សាសៈ ឬបស្សាសៈ ដែលកន្លងត្រង់សម្ផស្សទៅ ។

បទថា **វិក្ខេបានុបតិតំ** ធ្លាក់ទៅខាងចំណែករាយមាយ គឺ ទៅតាមដោយការរាយមាយ ឬធ្លាក់ទៅ គឺ ទៅតាមការរាយមាយឯង ។ បទថា **អនាគតបដិកង្ខណំ ចិត្តំ** ចិត្តដែលប្រាថ្នាអនាគតារម្មណ៍ គឺ ចិត្តដែលប្រាថ្នា គឺ រំពឹងដល់អស្សាសៈ ឬបស្សាសៈ ដែលនៅមិនទាន់ដល់ត្រង់សម្ផស្ស ។ បទថា **វិកម្បិតំ** ញាប់ញ័រ គឺ ញាប់ញ័រ ដោយសេចក្ដីរាយមាយដែលមិនតាំងនៅក្នុងអស្សាសៈនិងបស្សាសៈនោះ ។ បទថា **លីនំ** ចិត្តរួញរា គឺ ចិត្តស្ទាក់ស្ទើរដោយសេចក្ដីព្យាយាមដែលថោកថយពេកទៅជាដើម ។ បទថា **កោសជ្ជានុបតិតំ** ចិត្តធ្លាក់ទៅខាងចំណែកខ្ជិលច្រអូស គឺ ទៅតាមសេចក្ដីខ្ជិលច្រអូស ។ បទថា **អតិប្បគ្គហិតំ** ចិត្តដែលផ្គងទុកហួសពេក គឺ ចិត្តដែលមានសេចក្ដីឧស្សាហៈហួសពេក ដោយប្រារព្ធការព្យាយាមហួសពេក ។ បទថា **ឧទ្ធច្ចានុបតិតំ** ចិត្តធ្លាក់ទៅខាងចំណែករាយមាយ គឺ ទៅតាមសេចក្ដីរាយមាយ ។ បទថា **អភិនតំ** ចិត្តដែលបង្អោនទៅ គឺ ចិត្តដែលបង្អោនទៅក្រៃលែង គឺ ជាប់នៅក្នុងវត្ថុនៃអស្សាសៈទាំងឡាយ ។ បទថា **អបនតំ** ចិត្តដែលមិនបង្អោនទៅ គឺ ចិត្តប៉ះខ្ទប់ក្នុងវត្ថុនៃការមិនត្រេកអរ ឬចិត្តប្រាសចាកវត្ថុនៃសេចក្ដី

ត្រេកអរនោះ ឬនៅមិនទាន់ប្រាសចាកទៅ សេចក្តីថា មិនប្រាសចាកទៅពីវត្ថុនោះ ។ បទថា **រាគានុបតិតំ** ចិត្តដែលធ្លាក់ទៅខាងចំណែកនៃតម្រេក គឺ កាលព្រះយោគាវចរកំណត់ទុកក្នុងចិត្តដល់អស្សាស-បស្សាសនិមិត្ត សេចក្តីត្រេកត្រអាលធ្លាក់ទៅក្នុងបីតិ និងសុខ ឬក្នុងវត្ថុដែលរីករាយ ពណ៌នា និងការលេងក្នុងកាលមុន ។ បទថា **ព្យាបាទានុបតិតំ** ចិត្តធ្លាក់ទៅខាងចំណែកព្យាបាទ គឺ កាលព្រះយោគាវចរមានចិត្តមិនត្រេកអរ ក្នុងការកំណត់ទុកក្នុងចិត្ត ការព្យាបាទរមែងធ្លាក់ទៅតាមអំណាចនៃទោមនស្ស ដែលកើតឡើងហើយ ឬក្នុងអាឃាតវត្ថុ ( វត្ថុនៃអាឃាត ) ដែលប្រព្រឹត្តមកក្នុងកាលមុន ។

បទថា **ន សមាធិយតិ** ក្នុងគាថាទាំងឡាយ បានដល់ ចិត្តមិនតាំងមាំ ។ បទថា **អធិចិត្តំ** អធិចិត្ត គឺ សមាធិដ៏ក្រៃលែង លោកសម្តែងដោយចិត្តជាប្រធាន ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះសារីបុត្តត្ថេរ គ្រាសម្តែងឧបកិលេស ១៨ ដោយឆក្កៈ ៣ ហើយ ឥឡូវនេះកាលនឹងសម្តែងដល់ទោសនៃឧបកិលេសទាំងនោះ ដោយឲ្យសម្រេចសេចក្តីជាអន្តរាយដល់សមាធិ ទើបពោលគាថាមានជាអាទិ៍ថា **អស្សាសាទិមជ្ឈបរិ**



**យោសានំ** ដូច្នេះទៀត សេចក្តីថា ខាងដើម , កណ្តាល និងខាងចុងនៃខ្យល់ដកដង្ហើមចូល ។

ក្នុងបទទាំងនោះ បទថា **កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ** កាយ និងចិត្ត រមែងមានសេចក្តីប្រារព្ធ សេចក្តីថា សូម្បីរូបកាយ ដោយអំណាចនៃរូបដែលមានការរាយមាយជាសមុដ្ឋាន សូម្បីចិត្តដោយអំណាចនៃការរាយមាយជាការជាប់តគ្នា រមែងជាការស្មុគ-ស្មាញដោយសេចក្តីលំបាក និងមានសេចក្តីខ្វល់ខ្វាយ ដោយភាពខ្សោយជាងនោះ ក៏រញ្ជួយញាប់ញ័រ ដោយភាពខ្សោយជាងនោះ ក៏ជ្រួលច្របល់ រមែងមានការស្មុគស្មាញ មានកម្លាំងខ្លាំងខ្លះ កណ្តាលខ្លះ ខ្សោយខ្លះ ។ លោកអធិប្បាយថា មិនអាចនឹងមិនឲ្យស្មុគស្មាញបាន ។

បទថា **ចិត្តំ វិកម្បិតត្តាបិ** គឺព្រោះចិត្តញាប់ញ័រ ។ បទថា **បរិបុណ្ណា អភាវិតា** ក្នុងគាថាទាំងឡាយ គឺ មិនចម្រើនដូចដែលបំពេញទុក ។ បទថា **ឥញ្ជិតោ** គឺ ញាប់ញ័រ ។ បទថា **ផន្ទិតោ** រើបម្រះ គឺ ញាប់ញ័របន្តិច ។ ព្រោះការដែលនីវរណៈទាំងឡាយក្នុងខាងក្រោមមិនមានលំដាប់ លោកទើបសម្តែងដោយអច្ចន្តសមីប (ជិតបំផុត ) ដោយបទមានជាអាទិ៍ថា ក៏ឯនីវរណៈទាំងឡាយទាំង

នេះ ។ ប៉ុន្តែក្នុងទីនេះ ព្រោះនីវរណៈទាំងឡាយមានលំដាប់ក្នុងបទសរុប លោកទើបសម្តែងជាបរម្មុខា ( ត្រឡប់ក្រោយ ) ដោយបទមានជាអាទិ៍ថា ក៏ឯនីវរណៈទាំងឡាយទាំងនោះ ។

( ចប់ អដ្ឋកថាឧបក្កិលេសនិទ្ទេស )

## អដ្ឋកថា វោទានញ្ញាណនិទ្ទេស

បទថា **វោទានេ ញាណានិ** ញាណក្នុងវោទានៈ គឺ ញាណបរិសុទ្ធិ ។ បទថា **តំ វិវជ្ជយិត្វា** វៀរចិត្តនោះចេញ គប្បីភ្ជាប់សេចក្តីថា វៀរចិត្តដែលស្ទុះទៅរកអតីតារម្មណ៍ ធ្លាក់ទៅខាងចំណែកភាយមាយ ដូចពោលហើយក្នុងកាលមុន ។ បទថា **ឯកដ្ឋានេ សមាទហតិ** រមែងតាំងចិត្តមាំទុកក្នុងឋានៈមួយ គឺ តាំងមាំទុកស្មើត្រង់សម្ផស្សនៃអស្សាសៈ និងបស្សាសៈ ។ បទថា **តត្ថេវ អធិមោក្ខេតិ** បង្អោនចិត្តទៅក្នុងឋានៈនោះឯង កាលលោកពោលថា **ឯកដ្ឋានេ** ក្នុងឋានៈមួយ ព្រះយោគាវចររមែងធ្វើសេចក្តីព្រមព្រៀងត្រង់សម្ផស្សនៃអស្សាសៈ និងបស្សាសៈ ។



បទថា **បគ្គណ្ហិត្វា** ផ្គងចិត្តទុកហើយ គឺ ផ្គងចិត្តទុកដោយចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈ ។ បទថា **វិនិគ្គណ្ហិត្វា** គ្របសង្កត់ចិត្តនោះ គឺ សង្កត់ចិត្តដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ។ អាចារ្យពួកមួយពោលថា ផ្គងចិត្តទុកដោយសតិន្ទ្រិយ និងវីរិយិន្ទ្រិយ គ្របសង្កត់ចិត្តទុកដោយសតិន្ទ្រិយនិងសមាធិន្ទ្រិយ ។

បទថា **សម្បជានោ ហុត្វា** ព្រះយោគាវចរដឹងទាន់ចិត្តនោះ គឺ ដឹងទាន់ដោយអសុភភាវនាជាដើម ម្យ៉ាងទៀត ដឹងទាន់ដោយមេត្តាភាវនាជាដើម គប្បីជ្រាបការភ្ជាប់សេចក្តីថា ព្រះយោគាវចររមែងលះភាគៈព្យាបាទៈដែលចិត្តធ្លាក់ទៅតាម ។ សេចក្តីថា កាលដឹងទាន់ថា ចិត្តជាដូច្នេះ រមែងលះភាគៈ ព្យាបាទៈ ដោយការបដិបក្ខចំពោះចិត្តនោះ ។ បទថា **បរិសុទ្ធំ** បរិសុទ្ធ គឺ មិនមានឧបក្កិលេស ។ បទថា **បរិយោទាតំ** ផូរផង់ គឺ បរិសុទ្ធស្អាត ។ បទថា **ឯកត្តគតំ ហោតិ** ចិត្តដល់ភាវៈជាធម៌តែមួយ គឺ កាលព្រះយោគាវចរដល់សេចក្តីវិសេសនោះ ៗ ចិត្តនោះ ៗ ក៏រមែងដល់ភាវៈជាធម៌តែមួយ ។

បទថា **កតមេ តេ ឯកត្តា** ភាពជាធម៌តែមួយនោះ តើដូចម្តេច ។ ព្រះសារីបុត្តត្ថេរ កាលសួរភាវៈជាធម៌តែមួយ សូម្បីប្រកប និងនៅមិន

ទាន់ប្រកប រមែងសួររួមគ្នា ។ បទថា **ទានវោស្សគ្គុបដ្ឋានេកត្តំ** ភាវៈជាធម៌តែមួយក្នុងការប្រាកដនៃការបរិច្ចាគទាន គឺ ការបរិច្ចាគ ការលះបង់ទានដែលជាទានវត្ថុ ឈ្មោះថា **ទានូបសគ្គោ** បានដល់ ចេតនាបរិច្ចាគទានវត្ថុ ។ ការចូលទៅតាំងសេចក្ដីប្រាកដនៃទាននោះ ដោយធ្វើឲ្យជាអារម្មណ៍ ឈ្មោះថា **ទានូបសគ្គុបដ្ឋានំ** ការប្រាកដនៃការបរិច្ចាគទាន ។ ម្យ៉ាងទៀត ភាពជាធម៌តែមួយ ក្នុងការប្រាកដនៃការបរិច្ចាគទាន ឈ្មោះថា **ទានុបសគ្គុបដ្ឋានេកត្តំ** ។ បាឋៈថា **ទានវោស្សគ្គុបដ្ឋានេកត្តំ** ល្អជាងសេចក្ដីតែមួយដូចគ្នា ។

ដោយបទនេះ លោកពោលចាគានុស្សតិសមាធិ ដោយការលើកបទឡើង ។ ម្យ៉ាងទៀត សូម្បីលោកពោល ចាគានុស្សតិសមាធិនោះ ដោយការលើកបទ ក៏ជាឧបនិស្សយប្បច្ច័យនៃភាពជាធម៌តែមួយដូចគ្នា សូម្បី ៣ យ៉ាងក្រៅពីនេះ ព្រោះដូច្នោះ អាចារ្យពួកមួយទើបពោលទុកក្នុងទីនេះថា លោកបង្ហាញទុកហើយដូច្នេះ ។ មែនពិត សូម្បីនាងវិសាខាមហាឧបាសិកា ក៏នៅក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយដែលនៅចាំវស្សាក្នុងទិសទាំងឡាយក្នុងសាសនានេះ នឹងមកកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគជាម្ចាស់ លុះចូលគាល់ព្រះដ៏មានព្រះភាគហើយ នឹងទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះ



នេះមរណភាពហើយ ភិក្ខុនោះនឹងមានគតិដូចម្ដេច អភិសម្បរាយភពតើដូចម្ដេច ដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ព្យាករណ៍ដល់គតិ និងសម្បរាយភពនោះ ក្នុងសោតាបត្តិផលក្ដី ក្នុងសកទាគាមិផលក្ដី ក្នុងអនាគាមិផលក្ដី ក្នុងអរហត្តផលក្ដី ។ ខ្ញុំម្ចាស់ ចូលទៅរកភិក្ខុទាំងនោះហើយនឹងសួរថា បពិត្រលោកម្ចាស់ទាំងឡាយ លោកម្ចាស់អង្គនោះធ្លាប់មកក្រុងសាវត្ថីឬទេ ។ ប្រសិនបើភិក្ខុទាំងឡាយនឹងពោលដល់ខ្ញុំម្ចាស់ថា ភិក្ខុអង្គនោះធ្លាប់មកក្រុងសាវត្ថី ។ ខ្ញុំម្ចាស់នឹងដល់សេចក្ដីចូលចិត្ត ថ្វាយវស្សិកសាដក អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុបដ្ឋាកភត្ត គិលានភេសជ្ជ ឬធុវយាគូ (បបរជាប្រចាំ) ឲ្យលោកម្ចាស់អង្គនោះធ្លាប់បានបរិភោគវស្សកសាដកក្ដី ។បេ។ នូវយាគូក្ដី កាលខ្ញុំម្ចាស់រលឹកដល់ដូច្នោះ នឹងកើតបាមោជ្ជៈ កាលបាមោជ្ជៈមានហើយ នឹងមានបីតិ កាលបីតិមានហើយ កាយនឹងស្ងប់រម្ងាប់ កាលកាយស្ងប់រម្ងាប់ នឹងសោយសុខ កាលមានសុខ ចិត្តនឹងតាំងមាំ ឥន្ទ្រិយភាវនា ពលភាវនា ពោជ្ឈង្គភាវនានោះ នឹងមានដល់ខ្ញុំម្ចាស់ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ក្នុងភាពជាធម៌តែមួយ លោកពោលដល់ធម៌ទីមួយ ដោយឧបចារសមាធិ , ធម៌ទីពីរ ដោយអប្បនា , ធម៌ទី ៣ វិបស្សនាសមាធិ , ធម៌ទី ៤ ដោយមគ្គ និងផល ។ និមិត្តនៃសមថៈ ឈ្មោះថា **សមថនិមិត្ត** ។

លក្ខណៈដែលអស់ទៅ បែកធ្លាយទៅ ឈ្មោះថា **វយលក្ខណ** ។ បទថា **និរោធោ** គឺ ព្រះនិព្វាន ។ បទដ៏សេស គប្បីប្រកបតាមន័យដែលពោលហើយក្នុង ៣ បទទាំងនេះ ។ បទថា **ចាគាធិមុត្តានំ** របស់បុគ្គលអ្នកបង្អោនចិត្តទៅក្នុងចាគៈ គឺ បង្អោនទៅក្នុងទាន ។ បទថា **អធិចិត្តំ** បានដល់ សមាធិដែលជាបាទនៃវិបស្សនា ។ បទថា **វិបស្សកានំ** របស់អ្នកចម្រើនវិបស្សនាទាំងឡាយ គឺ របស់អ្នកឃើញច្បាស់នូវសង្ខារដោយអនុបស្សនា ៣ តាំងពីភង្គានុបស្សនា ( ពិចារណាឃើញការរលត់សង្ខារ ) ។ បទថា **អរិយបុគ្គលានំ** គឺ អរិយបុគ្គល ៨ ។ ភាពជាធម៌តែមួយ ៣ មានធម៌ទី ២ ជាដើម រមែងប្រកបដោយអានាបានស្សតិ និងកម្មដ្ឋានដ៏សេស ។ បទថា **ចតូហិ ឋានេហិ** គឺ ដោយហេតុទាំងឡាយ ៤ ។ បទដែលលើកឡើងថា ចិត្តដល់ភាពជាធម៌តែមួយជាចិត្តស្ទុះទៅកាន់បដិបទាវិសុទ្ធិ ជាចិត្តចម្រើនលូតលាស់ដោយឧបេក្ខានិងជាចិត្តរីករាយដោយញាណដូច្នេះ ដោយអំណាចនៃសមាធិ វិបស្សនាមគ្គ និងផល ។ បទអធិប្បាយសេចក្តីខាងដើមនៃពាក្យសួរ ព្រោះប្រាថ្នានឹងធ្វើឲ្យពិស្តារនៃបទដែលលើកឡើងទាំងនោះមានជាអាទិ៍ថា អ្វីជាខាងដើមនៃបឋមជ្ឈាន ។

ក្នុងបទទាំងនោះ បទថា **បដិបទាវិសុទ្ធិប្បសន្នញ្ចេវ** រមែងជាចិត្ត



ដែលមានបដិបទាវិសុទ្ធិផូរផង់ គឺ បដិបទានោះឯង ឈ្មោះថា វិសុទ្ធិ ព្រោះជម្រះមន្ទិល គឺ នីវរណៈ , ចិត្តស្ទុះទៅ គឺ ចូលទៅកាន់បដិបទាវិសុទ្ធិនោះ ។ បទថា **ឧបេក្ខានុព្រូហិតញ្ច** គឺ ចម្រើនលូតលាស់ដោយឧបេក្ខា គឺ ភាពជាកណ្តាលនោះ ។ បទថា **ញាណេន ច សម្បហំសិតំ** រីករាយដោយញាណ គឺ រីករាយផូរផង់ បរិសុទ្ធិដោយញាណដែលផូរផង់ ។ អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះថា ឧបចារៈព្រមដោយការសន្សំ ឈ្មោះថា បដិបទាវិសុទ្ធិ អប្បនាឈ្មោះថា ការចម្រើនលូតលាស់ដោយឧបេក្ខា បច្ចវេក្ខណៈ ឈ្មោះថា ការរីករាយ ។

ម្យ៉ាងទៀត ព្រោះលោកពោលបទមានជាអាទិ៍ថា ចិត្តដល់ភាវៈជាធម៌តែមួយ ជាចិត្តស្ទុះទៅកាន់បដិបទាវិសុទ្ធិ ដូច្នោះ គប្បីជ្រាបបដិបទាវិសុទ្ធិដោយការមកនៃអប្បនាជាខាងក្នុង ការចម្រើនលូតលាស់ដោយឧបេក្ខា ដោយកិច្ចនៃឧបេក្ខា គឺ ភាពជាកណ្តាលនោះ ការរីករាយ ដោយការសម្រេចកិច្ចនៃញាណដ៏ផូរផង់ដោយ សម្រេចការមិនកន្លងទៅនៃធម៌ទាំងឡាយ ។ តើដូចម្តេច ព្រោះចិត្ត រមែងបរិសុទ្ធចាកពួកកិលេស គឺ នីវរណៈ ដែលធ្វើអន្តរាយដល់ឈាននោះក្នុងវារៈដែលអប្បនាកើត ។ ព្រោះចិត្តបរិសុទ្ធ ចិត្តប្រាសចាកគ្រឿងរារាំង រមែងដំណើរទៅកាន់សមថនិមិត្តដែលជាកណ្តាល សមាធិ គឺ អប្បនាប្រព្រឹត្ត

ទៅស្មើឈ្មោះថា សមថនិមិត្តដែលជាកណ្តាល ។

ប៉ុន្តែបុរិមចិត្ត (ចិត្តដួងដំបូង) ក្នុងលំដាប់នៃអប្បនាសមាធិនោះ ចូលដល់ភាពជារបស់ពិត ដោយន័យនៃការប្រែប្រួលព្រោះសន្តតិតែម្យ៉ាង ឈ្មោះថា រមែងដំណើរទៅកាន់សមថនិមិត្តដែលជាកណ្តាល ព្រោះដំណើរទៅយ៉ាងនេះ ចិត្តទើបឈ្មោះថា ស្ទុះទៅក្នុងសមថនិមិត្តនោះ ដោយចូលដល់ភាពជារបស់ពិត ។

គប្បីជ្រាបបដិបទាវិសុទ្ធិ ដែលសម្រេចអាការមាននៅក្នុងបុរិមចិត្តយ៉ាងនេះមុន ដោយអំណាចនៃការមកក្នុងខណៈបឋមជ្ឈានកើតឡើងនោះឯង ។ ម្យ៉ាងទៀត កាលចិត្តបរិសុទ្ធហើយ មិនធ្វើសេចក្តីខ្វល់-ខ្វាយក្នុងការជម្រះចិត្ត ព្រោះមិនមានវត្ថុដែលគួរជម្រះទៀត ឈ្មោះថា ចិត្តបរិសុទ្ធដោយភាពព្រងើយ ។ កាលដំណើរទៅកាន់សមថៈ ដោយការចូលដល់សភាពជាសមថៈហើយ មិនធ្វើសេចក្តីខ្វល់ខ្វាយក្នុងការសមាទានទៀត ឈ្មោះថា ចិត្តដំណើរទៅកាន់សមថៈដោយភាពស្មើព្រងើយហើយ ។ ព្រោះដំណើរទៅកាន់សមថៈ កាលចិត្តលះបង់សេចក្តីខ្ជិលច្រអូសដោយកិលេសហើយ ប្រាកដដោយសភាពជាធម៌តែមួយ មិនធ្វើសេចក្តីខ្វល់ខ្វាយក្នុងការប្រាកដនៃភាពជាធម៌តែមួយទៀត ឈ្មោះថា ចិត្ត មានការប្រាកដក្នុងសភាពជាធម៌តែមួយក្នុងភាពព្រងើយហើយ ។



គប្បីជ្រាបការកពូនឡើងនៃឧបេក្ខា ដោយអំណាចកិច្ចនៃភាពព្រងើយជាកណ្តាលនោះ ។

ធម៌ជាគូ គឺ សមាធិ និងបញ្ញា ពួកណាកើតឡើងហើយក្នុងចិត្តនោះ ដែលកពូនឡើងដោយឧបេក្ខាយ៉ាងនេះ កាលនៅមិនទាន់កន្លងហួសគ្នានឹងគ្នា បានប្រព្រឹត្តទៅហើយ ។ ឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមពួកណា មានរសដូចគ្នាដោយរស គឺ វិមុត្តិ ព្រោះផុតចាកកិលេសផ្សេង ៗ ប្រព្រឹត្តទៅហើយ ព្រះយោគាវចរនោះនាំសេចក្តីព្យាយាមណាដែលចូលដល់វិមុត្តិនោះ សមគួរដល់ធម៌មានរសតែមួយ ដោយការមិនប្រព្រឹត្តទៅនៃឥន្ទ្រិយទាំងនោះ ។ ការសេពណា ប្រព្រឹត្តទៅហើយក្នុងខណៈរបស់ព្រះយោគាវចរនោះ អាការទាំងនោះសូម្បីទាំងអស់ ព្រោះឃើញទោស និងអានិសង្សនោះ ៗ ក្នុងសេចក្តីសៅហ្មង និងសេចក្តីផូរផង់ដោយញាណហើយសម្រេច ព្រោះជាចិត្តរីករាយ ជាចិត្តផូរផង់ ដូច្នោះគប្បីជ្រាបថា សេចក្តីរីករាយដោយអំណាចនៃការសម្រេចកិច្ចនៃញាណដែលផូរផង់ ដោយសម្រេចការមិនកន្លងហួសគ្នាជាដើម នៃធម៌ទាំងឡាយ លោកអធិប្បាយទុកដូច្នេះឯង ។

ក្នុងបទនោះមានសេចក្តីដូច្នេះ ព្រោះញាណប្រាកដដោយអំណាចនៃឧបេក្ខា ដូចដែលព្រះសារីបុត្តត្ថេរពោលទុកថា ចិត្តផ្គងទុកហើយយ៉ាង

នោះ រមែងព្រងើយដោយល្អ បញ្ញិន្ទ្រិយមានប្រមាណក្រៃលែងដោយអំណាចនៃបញ្ញា ដោយអំណាចនៃឧបេក្ខា ចិត្តរមែងរួចផុតចាកកិលេសផ្សេង ៗ ដោយអំណាចនៃឧបេក្ខា បញ្ញិន្ទ្រិយមានប្រមាណក្រៃលែងដោយអំណាចនៃបញ្ញា ដោយអំណាចនៃការរួចផុត ធម៌ទាំងនោះ រមែងមានកិច្ចជាចំណែកដូចគ្នា ព្រោះភាពដែលចិត្តជាធម្មជាតរួចផុតហើយ បញ្ញិន្ទ្រិយមានប្រមាណក្រៃលែង ដោយអំណាចនៃបញ្ញា ដោយអំណាចនៃភាវនា ព្រោះអត្ថថា ជាធម៌មានកិច្ចដូចគ្នា ដូច្នោះ លោកទើបពោលថា ការរីករាយដែលជាកិច្ចនៃញាណជាទីបំផុត ។

បទមានជាអាទិ៍ថា **ឯវំតិវត្តគតំ** ចិត្តដែលដល់ការប្រព្រឹត្តទៅ ៣ ប្រការ ជាពាក្យសរសើរចិត្តនោះ ។ ក្នុងបទទាំងនោះ បទថា **ឯវំតិវត្តគតំ** បានដល់ ចិត្តដល់ការប្រព្រឹត្តទៅ ៣ យ៉ាង ដោយអំណាចនៃការស៊ុះទៅកាន់បដិបទាវិសុទ្ធិ ការលូតលាស់ឡើងនូវឧបេក្ខា និងការរីករាយដោយញាណ ។ បទថា **វិតក្កសម្បន្នំ** ជាចិត្តដល់ព្រមដោយវិតក្កៈ គឺ ដល់ភាពជាចិត្តស្អាតដោយវិតក្កៈ ព្រោះប្រាសចាកការកម្រើកនៃកិលេស ។

បទថា **ចិត្តស្ស អធិដ្ឋានសម្បន្នំ** ដល់ព្រមដោយការអធិដ្ឋាននៃចិត្ត គឺ ចិត្តសម្បូរណ៍មិនមានចំនួនតិចដោយការអធិដ្ឋាន ពោលគឺប្រព្រឹត្តទៅតាមលំដាប់នៃចិត្តក្នុងអារម្មណ៍នោះឯង ការប្រព្រឹត្តទៅនៃ



ឈានឈ្មោះថា អធិដ្ឋានព្រោះក្នុងភាពជំនាញនៃអធិដ្ឋាន យ៉ាងណា សូម្បីក្នុងទីនេះសភាពដែលចិត្តមានអារម្មណ៍តែមួយ ក៏ឈ្មោះថា អធិដ្ឋានចិត្តរមែងសមគួរ ដូច្នោះ ដោយហេតុនោះ ចិត្តរមែងតាំងនៅក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ តែលោកពោលថា **សមាធិសម្បន្នំ** ដល់ព្រមដោយសមាធិទុកផ្សេង ទើបគួរកាន់យកតាមន័យដែលពោលហើយនោះឯង ។

ម្យ៉ាងវិញទៀត ព្រោះសង្គ្រោះសមាធិចូលទុកក្នុងអង្គឈាន ទើបពោលថា **ចិត្តស្ស អធិដ្ឋានសម្បន្នំ** ដោយអំណាចនៃពួក ៥ របស់អង្គឈាន ។ បទថា **សមាធិសម្បន្នំ** លោកពោលដោយអំណាចពួក ៥ នៃឥន្ទ្រិយ ព្រោះសង្គ្រោះសមាធិ ចូលទុកក្នុងឥន្ទ្រិយ ។

ប៉ុន្តែក្នុងទុតិយជ្ឈានជាដើម លោកលះបទដែលនៅមិនទាន់បានពោលថា **បីតិសម្បន្នំ** ដល់ព្រមដោយបីតិ ដោយអំណាចនៃការបាន ។

ក្នុងមហាវិបស្សនា ១៨ មានអនិច្ចានុបស្សនាជាដើម វិតក្កៈជាដើមបរិបូណ៌ហើយ ព្រោះមហាវិបស្សនាទាំងនោះជាកាមាវចរ ។

ម្យ៉ាងទៀត ព្រោះក្នុងមហាវិបស្សនាទាំងនោះមិនមានអប្បនា ទើបគួរប្រកបបដិបទាវិសុទ្ធិជាដើម ដោយអំណាចខណិកសមាធិ ។ លោកពោលវិតក្កៈជាដើមបរិបូណ៌ ដោយអំណាចការបាន ព្រោះបានវិតក្កៈជាដើម ដោយបឋមជ្ឈានិក ( អ្នកបានបឋមជ្ឈាន ) ក្នុងមគ្គ ៤ ព្រោះ

វិតក្កៈជាដើមក្នុងមគ្គ មានអ្នកបានទុតិយជ្ឈានជាដើម រមែងសាបសូន្យដូចក្នុងឈានទាំងឡាយ ។

ដោយហេតុត្រឹមតែប៉ុណ្ណោះ ជាចំណែកដែលលោកសម្ដែងវោទា-នញ្ញាណ ( ញាណបរិសុទ្ធិ ) ១៣ ដោយពិស្ដារ ។ សម្ដែងយ៉ាងណា លោកសម្ដែងញាណ ១៣ ទាំងនេះ ក៏គឺញាណទាំងឡាយ ៦ សម្បយុត្តដោយការតាំងមាំក្នុងទីជាមួយគ្នា ដោយការបង្អោនទៅក្នុងការតាំងមាំនោះឯង ដោយការលះសេចក្ដីខ្ជិលច្រអូស ដោយការលះសេចក្ដីរាយមាយ ដោយការលះរាគៈ ដោយការលះព្យាបាទ ញាណ ៤ សម្បយុត្តដោយភាពជាធម៌តែមួយ ៤ , ញាណ ៣ សម្បយុត្តដោយបដិបទាវិសុទ្ធិ ការចម្រើនឡើងនៃឧបេក្ខា និងភាពរីករាយ ។

សូម្បីយ៉ាងនេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្ដែងសេចក្ដីសម្រេចនៃញាណទាំងនោះ ដោយអំណាចនៃការចម្រើនអានាបានស្សតិសមាធិ មិនសរុបញាណទាំងនោះ ហើយសម្ដែងវិធីចម្រើនអានាបាន-ស្សតិ ដែលជាខាងដើមនៃការរំលឹក ដោយន័យមានជាអាទិ៍ **និមិត្តំ អស្សាសបស្សាសា** និមិត្តខ្យល់អស្សាសបស្សាសៈ ហើយសម្ដែងសរុបញាណក្នុងទីបំផុត ។ និមិត្តក្នុងញាណនោះ លោកពោលទុកហើយ ។

បទថា **អនារម្មណាមេកចិត្តស្ស** គឺ មិនជាអារម្មណ៍នៃចិត្តដួង



មួយ ។ ក្នុងបទនេះ **ម** អក្សរជាបទសន្ធិ ។ បាឋៈថា **អនារម្មណមេ-កចិត្តស្ស** ខ្លះ សេចក្ដីថា មិនជាអារម្មណ៍នៃចិត្តដួងមួយ ។ បទថា **តយោ ធម្មា** ធម៌ ៣ ប្រការ គឺ ធម៌ ៣ ប្រការមាននិមិត្តជាដើម ។ បទថា **ភាវនា** បានដល់ អានាបានស្សតិសមាធិភាវនា ។ បទថា **កថំ** តើដូចម្ដេច ជាពាក្យសួរប្រាថ្នានឹងពោលសេចក្ដីនៃគាថាឆ្លើយ ដូចពោលហើយក្នុងលំដាប់នៃគាថាសួរ ដូចពោលហើយក្នុងគ្រាដំបូង ។ បទថា **ន ចិមេ** កាត់បទថា **ន ច ឥមេ** បាឋៈថា **ន ច មេ** ដូច្នេះខ្លះ ។ បាឋៈនោះ ជាបាឋៈកំណត់បទ ។

គប្បីប្រកប **កថំ** សព្ទដោយបទសូម្បីដ៏សេស ៥ យ៉ាងនេះថា **កថំ ន ច អវិទិតា ហោន្តិ កថំ ន ច ចិត្តំ វិក្ខេបំ គច្ឆតិ** ជាធម៌មិនប្រាកដក៏មិនមែនតើដូចម្ដេច ហើយចិត្តមិនចូលដល់សេចក្ដីរាយមាយតើដូចម្ដេច ។ បទថា **បធានញ្ច បញ្ញាយតិ** ចិត្តប្រាកដជាប្រធាន គឺការព្យាយាមប្រារព្ធការចម្រើនអានាបានស្សតិសមាធិប្រាកដ ព្រោះថាវីរិយៈ លោកពោលថាជា **បធាន** ព្រោះជាហេតុចាប់ផ្ដើម ។ បទថា **បយោគញ្ច សាធេតិ** ចិត្តឲ្យប្រយោជន៍សម្រេច គឺ ព្រះយោគាវចរញុំាងឈានគ្របសង្កត់នីវរណៈឲ្យសម្រេច ព្រោះថា ឈាន លោកពោលថា **បយោគ** ព្រោះប្រកបដោយការគ្របសង្កត់នីវរណៈ ។ បទថា

**វិសេសមធិគច្ឆតិ** សម្រេចផលវិសេស គឺ បានមគ្គ ដែលធ្វើការលះសំយោជនៈ ព្រោះថា មគ្គ លោកពោលថា **វិសេស** ព្រោះជាអានិសង្សនៃសមថៈ និងវិបស្សនា ។ ម្យ៉ាងទៀត ព្រោះមគ្គជាប្រធាននៃសេចក្តីវិសេស ទើបមិនធ្វើការសន្សំ ដោយការធ្វើ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរញុំាងសេចក្តីដែលសួរនោះឲ្យសម្រេចដោយឧបមា ទើបពោលពាក្យមានជាអាទិ៍ថា **សេយ្យថាបិ រុក្ខោ** ប្រៀបដូចដើមឈើ ដូច្នេះ ។

បទនោះមានសេចក្តីដូចតទៅនេះ ។ ប្រៀបដូចដើមឈើដែលគេតម្កល់ទុកលើភូមិភាគរាបស្មើ ប្រយោជន៍ដើម្បីមិនឲ្យរមៀលទៅមកក្នុងវេលាយកកាំបិតចាំង និងពុះ ។ បទថា **កកចេន** គឺ អារដោយដៃ ។ បទថា **អាគតេ** គឺ ធ្មេញរណារដែលអារដើមឈើមកជិតខ្លួន ។ បទថា **គតេ** គឺ ធ្មេញរណារដែលអារដើមឈើរុញចេញទៅចំណែកម្ខាង ។ **វា** សព្ទជាសមុច្ចយត្ថ ចុះក្នុងអត្ថបង្រួបបង្រួម ។ បទថា **ន អវិទិតា ហោន្តិ** មិនប្រាកដក៏មិនមែន គឺ ធ្មេញរណារ សូម្បីទាំងអស់ដែលបុរសអារដើមឈើ សូម្បីមិនដល់ទីសម្លឹងមើលក៏រមែងប្រាកដ ព្រោះមិនធ្វើទុកក្នុងចិត្តដល់ធ្មេញរណារដែលមក ឬដែលទៅ ។ បទថា **បធានំ** ជាប្រធាន គឺ សេចក្តីព្យាយាមក្នុងការកាត់ដើមឈើ ។ បទថា **បយោគំ** ប្រយោគ



គឺ កិរិយាដែលកាត់ដើមឈើ ។ បទថា **វិសេសមធិគច្ឆតិ** ដល់សេចក្តីវិសេសមិនមានដោយឧបមា ។

បទថា**ឧបនិពន្ធនា និមិត្តំ** ការទាក់ទងគ្នាជានិមិត្ត គឺ ចុងច្រមុះក្តី បបូរមាត់ក្តី ជានិមិត្ត គឺ ជាហេតុនៃសតិដែលទាក់ទងគ្នា ។

សតិ ឈ្មោះថា **ឧបនិពន្ធនា** ព្រោះជាគ្រឿងចងចិត្តទុកក្នុងអារម្មណ៍ ។ បទថា **នាសិកគ្គេវា** គឺ អ្នកមានច្រមុះវែង តាំងសតិទុកត្រង់ចុងច្រមុះ ។ បទថា **មុខនិមិត្តេ វា** គឺ អ្នកមានច្រមុះខ្លី តាំងសតិទុកត្រង់បបូរមាត់ខាងលើ ព្រោះបបូរមាត់លើជានិមិត្តនៃសតិត្រង់មាត់ ព្រោះដូច្នោះ លោកទើបពោលថា **មុខនិមិត្តឹ** បបូរមាត់ ។ បទថា **អាគតេ** គឺ ខ្យល់ អស្សាសបស្សាសៈដែលមកក្នុងខាងក្នុង ចាកត្រង់សម្ផស្ស ។ បទថា **គតេ** គឺ ខ្យល់អស្សាសបស្សាសៈដែលទៅខាងក្រៅ ចាកត្រង់សម្ផស្ស ។ បទថា **ន អវិទិតា ហោន្តិ** ខ្យល់អស្សាសបស្សាសៈមិនប្រាកដក៏មិនមែន គឺ ខ្យល់អស្សាសបស្សាសៈសូម្បីទាំងអស់នោះ នៅមិនដល់ត្រង់សម្ផស្ស ក៏រមែងប្រាកដ ។ ព្រោះមិនធ្វើទុកក្នុងចិត្តដល់ការមក ការទៅ របស់ខ្យល់អស្សាសបស្សាសៈ ។ បទថា **កម្មនីយំ ហោតិ** រមែងគួរដល់ការងារ គឺ ទាំងកាយ ទាំងចិត្ត រមែងគួរដល់ការងារ សមគួរដល់ភាវនាកម្ម ។ សេចក្តីព្យាយាមនេះ ឈ្មោះថា

**បធាន** ព្រោះហេតុនោះលោកទើបពោលដល់ហេតុ ដោយផល ។

បទថា **ឧបក្កិលេសា បហីយន្តិ** ភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម រមែងលះឧបក្កិលេសបាន គឺ លះនីវរណៈបានដោយការគ្របសង្កត់ទុក ។ បទថា **វិតក្កា វូបសមន្តិ** វិតក្កៈរមែងស្ងប់ទៅ គឺ វិតក្កៈមិនតាំងមាំ ហើយត្រាច់ទៅក្នុងអារម្មណ៍ផ្សេង ៗ រមែងដល់ការស្ងប់ ភិក្ខុប្រារព្ធសេចក្ដីព្យាយាមលះឧបក្កិលេសបានដោយឈានណា វិតក្កៈទាំងឡាយរមែងស្ងប់ដោយឈាននោះ ។ បទថា **អយំ បយោគោ** លោកធ្វើជាបុំលិង្គ ព្រោះសំឡឹងដល់ប្រយោគ ។ បទថា **សញ្ញោជនានិ បហីយន្តិ** ភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម រមែងលះសំយោជនៈបាន គឺ លះបង់សំយោជនៈដែលមគ្គនោះ ៗ លះដោយសមុច្ឆេទប្បហាន ។ បទថា **អនុសយា ព្យាសន្តិ** អនុស័យរមែងដល់ការវិនាស គឺ ព្រោះអនុស័យដែលលះបានហើយមិនកើតឡើងទៀត ទើបឈ្មោះថា **ព្យន្តា** ព្រោះកើតឬវិនាស ប្រាសចាកទៅហើយ ។ ឈ្មោះថា **ព្យន្តិ ហោន្តិ** ព្រោះមិនវិនាសមកអំពីមុន ក្រោយមកទើបវិនាស មានន័យថា វិនាស ។ ដើម្បីសម្ដែងថា ការលះសំយោជនៈរមែងមានបាន ដោយការលះអនុស័យ មិនមែនដោយប្រការដទៃ លោកទើបពោលដល់ការលះអនុស័យ ។ សេចក្ដីថា លះសំយោជនៈបានដោយមគ្គណា អនុស័យរមែងវិនាសទៅ



ដោយមគ្គនោះ នេះជាសេចក្ដីវិសេស ។

ក្នុងចតុក្កៈទី ៤ លោកពោលដល់អរិយមគ្គទុកក្នុងទីនេះ ព្រោះសូម្បីអរិយមគ្គ លោកក៏បានបង្ហាញទុកហើយ សូម្បីកាលមិនពោលដល់ការមិនមានអារម្មណ៍ពីរនៃចិត្តដួងមួយ ព្រោះសម្រេចហើយ លោកទើបមិនពោលដល់ចិត្តដួងនោះដោយសរុបថា ធម៌ ៣ យ៉ាងទាំងនេះ មិនជាអារម្មណ៍នៃចិត្តដួងមួយ យ៉ាងនេះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលនឹងសរសើរព្រះយោគាវចរអ្នកសម្រេចភាវនានោះ ទើបពោលគាថាថា **អានាបានស្សតិ យស្ស** ហើយពោលនិទ្ទេសនៃគាថានោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទនោះដូចតទៅនេះ ភិក្ខុណាចម្រើនអានាបានស្សតិឲ្យបរិបូរណ៍ល្អហើយ អប់រំហើយតាមលំដាប់ តាមដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងហើយ ភិក្ខុនោះរមែងធ្វើលោកនេះឲ្យភ្លឺស្វាង ដូចអ្វី ដូចព្រះចន្ទផុតហើយចាកពពកដូច្នោះ ។ គប្បីជ្រាបសេចក្ដីភ្ជាប់ដោយគាថាថា ព្រះយោគាវចរនោះ ញុំាងលោក មានខន្ធលោកជាដើមនេះឲ្យភ្លឺស្វាង ដូចព្រះចន្ទផុតហើយចាកពពកជាដើម ញុំាងឱកាសលោកនេះឲ្យភ្លឺស្វាងដូច្នោះ ។ គប្បីជ្រាបថាក្នុងបទនេះ លោកធ្វើការលុបអាទិសព្ទ ព្រោះលោកពោលដល់ សូម្បីទឹកសន្សើមជាដើមក្នុង

និទ្ទេសនៃបទថា **អព្ភា មុត្តោវ ចន្ទិមា** ដូចព្រះចន្ទផុតហើយចាកពពក ដូច្នោះ ។

ក្នុងគាថានិទ្ទេស លោកពោលឲ្យប្លែកចេញទៅដោយបដិសេធសេចក្តីនោះថា **នោ បស្សាសោ នោ អស្សាសោ** មិនមែនខ្យល់បស្សាសៈ មិនមែនខ្យល់អស្សាសៈ ។ បទថា **ឧបដ្ឋានំ សតិ** សតិចូលទៅតាំងទុក សេចក្តីថា ឈ្មោះថា សតិចូលទៅតាំងខ្យល់អស្សាសៈនោះ ព្រោះការមិនវង្វេង ។ ខ្យល់បស្សាសៈក៏ដូចគ្នា ដោយហេតុត្រឹមប៉ុណ្ណោះជាការដែលលោកពោលសេចក្តីថា សតិក្នុងខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញ ឈ្មោះថា **អានាបានស្សតិ** ។ ឥឡូវនេះបំណងនឹងបង្ហាញដល់បុគ្គលដែលលោកពោលថា **យស្ស** ដោយអំណាចនៃសតិប៉ុណ្ណោះទើបពោលថា សតិរមែងប្រាកដដល់បុគ្គលអ្នកដកដង្ហើមចូល និងអ្នកដកដង្ហើមចេញ ។ សេចក្តីថា អ្នកណាដកដង្ហើមចូល សតិរបស់អ្នកនោះរមែងកំណត់ខ្យល់អស្សាសៈ ។ អ្នកណាដកដង្ហើមចេញ សតិរបស់អ្នកនោះរមែងកំណត់ខ្យល់បស្សាសៈ ។

បទថា **បរិបុណ្ណា** គឺ បរិបូរណ៍ដោយការសម្រេចអរហត្តមគ្គដែលបន្តមកពីមគ្គក្នុងឈាន និងវិបស្សនា ។ ព្រះសារីបុត្តត្ថេរពោលពាក្យមានជាអាទិ៍ថា **បរិគ្គហដ្ឋេន** ដោយអត្ថថា កាន់យកជុំវិញ សំដៅដល់ធម៌ គឺ មគ្គ ឈាន និងវិបស្សនាញាណ ។ ព្រោះធម៌ទាំងនោះឈ្មោះថា **បរិគ្គហា** ព្រោះព្រះយោគាវចរនេះកាន់យកដោយជុំវិញ ។ ឈ្មោះថា **បរិបុណ្ណា** ដោយអត្ថថា កាន់យកជុំវិញនោះ ។ ឈ្មោះថា **បរិបុណ្ណា** ដោយអត្ថថា ជាបរិវារ ព្រោះចិត្ត និងចេតសិកទាំងពួងជាបរិវារនៃគ្នានិងគ្នា ។ ឈ្មោះថា **បរិបុណ្ណា** ដោយអត្ថថា បរិបូរណ៍ ដោយការបរិបូរណ៍នៃភាវនា ។



បទមានជាអាទិ៍ថា **ចតស្សោ ភាវនា** ភាវនា ៤ លោកពោលដោយអំណាចនៃបទដែលពោលហើយថា **សុភាវិតា** ចម្រើនហើយ ។ ភាវនា ៤ លោកពោលទុកហើយក្នុងខាងក្រោយ ។ បទថា **យានីកតា** ធ្វើឲ្យដូចជាយាន គឺ ធ្វើដូចជាយានដែលទឹមហើយ ។ បទថា **វត្ថុកតា** ធ្វើឲ្យជាទីតាំង គឺ ធ្វើដូចជាវត្ថុ ដោយអត្ថថា ជាទីតាំង ។ បទថា **អនុដ្ឋិតា** បណ្តោនទៅ គឺ ប្រាកដហើយ ។ បទថា **បរិចិតា** អប់រំ គឺ សន្សំទុកដោយជុំវិញ ។ បទថា **សុសមារទ្ធា** ប្រារព្ធល្អហើយ គឺ ប្រារព្ធដោយល្អ ធ្វើដោយល្អ ។

បទថា **យត្ថ យត្ថ អាកង្ខតិ** ភិក្ខុបំណងក្នុងទីណា ៗ គឺ ប្រសិនបើភិក្ខុប្រាថ្នាក្នុងឈានណា ៗ ក្នុងវិបស្សនាណា ៗ ។ បទថា **តត្ថ តត្ថ** គឺ ក្នុងឈាននោះ ៗ ក្នុងវិបស្សនានោះ ៗ ។ បទថា **វសិប្បត្តោ** ជា

អ្នកដល់ភាពជំនាញ បានដល់ ដល់ភាពជាអ្នកជំនាញ គឺ ភាពជាអ្នកមានវសីច្រើន ។ បទថា **ពលប្បត្តោ** ដល់កម្លាំង គឺ ដល់កម្លាំងសមថៈ និងវិបស្សនា ។ បទថា **វេសារជ្ជប្បត្តោ** ដល់សេចក្តីក្លាហាន គឺ ដល់ភាពជាអ្នកក្លាហាន ភាពជាអ្នកឆ្លាត ។ បទថា **តេ ធម្មា** បានដល់ធម៌ គឺ សមថវិបស្សនា ។ បទថា **អាវជ្ជនប្បដិពទ្ធា** ជាធម៌ជាប់ដោយការរំពឹង គឺ ព្រោះជាប់ដោយការនឹកគិត សេចក្តីថា ត្រឹមតែភិក្ខុនោះនឹកគិតប៉ុណ្ណោះ ធម៌ទាំងឡាយរមែងដល់ការប្រកបព្រមដោយសន្តានឬដោយញាណ ។ បទថា **អាកង្ខណប្បដិពទ្ធា** ជាប់ដោយការសង្ឃឹម គឺ ព្រោះជាប់ដោយការពេញចិត្ត សេចក្តីថា ត្រឹមតែភិក្ខុពេញចិត្តប៉ុណ្ណោះ ធម៌ទាំងឡាយ រមែងដល់ការប្រកបព្រមដោយន័យដូចពោលហើយ ។ មួយ៉ាងទៀត មនសិការក្នុងបទថា **មនសិការប្បដិពទ្ធា** នេះ ជាចិត្តុប្បាទនៃការនឹករំពឹង ។ លោកពោលដើម្បីពង្រីកសេចក្តីដោយអំណាចនៃវេវចនៈនៃការសង្ឃឹម ។ បទថា **តេន វុច្ចតិ យានីកតា** ព្រោះហេតុនោះលោកទើបពោលថា ធ្វើឲ្យដូចជាយាន អធិប្បាយថា ធម៌ទាំងនោះធ្វើឲ្យដូចគ្នានឹងយាន ព្រោះធ្វើហើយយ៉ាងនោះ ។

បទថា **យស្មឹ យស្មឹ វត្ថុស្មឹ** ក្នុងវត្ថុណា ៗ គឺ ក្នុងវត្ថុមួយ ៗ ក្នុងវត្ថុ ១៦ ។ បទថា **ស្វាធិដ្ឋិតំ** មាំទាំល្អហើយ គឺ តាំងទុកល្អហើយ ។



បទថា **សុប្បតិដ្ឋិតា** ប្រាកដល្អហើយ គឺ ចូលទៅតាំងទុកដោយល្អ ។ លោកសម្តែងធម៌ ២ យ៉ាងទាំងនោះ ប្រកបដោយអនុលោមបដិលោម ព្រោះធ្វើកិច្ចរបស់ខ្លួន ៗ រួមគ្នានៃសតិដែលមានចិត្តសម្បយុត្តហើយ ។ បទថា **តេន វុច្ចតិ វត្ថុកតា** ដោយហេតុនោះ លោកទើបពោលថា ធ្វើឲ្យជាទីតាំង អធិប្បាយថា ព្រោះភាពជាយ៉ាងនេះ ធម៌ទាំងឡាយទើបធ្វើជាទីតាំង ។

បទថា **យេន យេន ចិត្តំ អភិនីហរតិ** ចិត្តបង្អោនទៅដោយអាការណា ៗ គឺ ចិត្តនាំចេញចាកការប្រព្រឹត្តទៅក្នុងកាលមុន ហើយបង្អោនទៅក្នុងភាវនាវិសេសណា ៗ ។ បទថា **តេន តេន សតិ អនុ-បរិវត្តតិ** សតិក៏ប្រព្រឹត្តទៅតាមដោយអាការនោះ ៗ គឺ សតិជួយជ្រើសរើសក្នុងភាវនាវិសេសនោះៗ ឲ្យប្រព្រឹត្តទៅតាម ព្រោះប្រព្រឹត្តទៅក្នុងកាលមុន ។ ក្នុងបទថា **យេន តេន** នេះ គប្បីជ្រាបថាជាសត្តមីវិភត្តិ ដូចក្នុងប្រយោគមានជាអាទិ៍ថា **យេន ភគវា តេនុបសង្កមិ** ព្រះមាន-ព្រះភាគជាម្ចាស់ ទ្រង់ប្រថាប់នៅក្នុងទីណា ចូលទៅក្នុងទីនោះ ដូច្នេះ ។ បទថា **តេន វុច្ចតិ អនុដ្ឋិតា** ដោយហេតុនោះ ទើបលោកពោលថា បង្អោនទៅ គឺ ព្រោះធ្វើយ៉ាងនោះឯង លោកអធិប្បាយថា ធម៌ទាំងឡាយទៅតាមភាវនានោះ ៗ តាំងនៅ ព្រោះអានាបានស្សតិជាប្រធានរបស់សតិ

គប្បីជ្រាបថា លោកធ្វើការប្រកបព្រមនឹងសតិក្នុងបទថា **វត្ថុកតា និង អនុដ្ឋិតា** ។

ម្យ៉ាងទៀត ព្រោះសតិដែលភិក្ខុអប់រំឲ្យបរិបូរណ៍ហើយ លូតលាស់ហើយ បានអាសេវនៈហើយ ដូច្នោះ អត្ថទាំង ៣ ដែលលោកពោលទុកក្នុងបទថា **បរិបុណ្ណា** ជាការពោលសូម្បីក្នុងបទថា **បរិចិតា** ផង ។ លោកពោលអត្ថទី ៤ ជាអត្ថវិសេស ។

ក្នុងបទទាំងនោះ បទថា **សតិយា បរិគ្គណ្ហន្តោ** ភិក្ខុកំណត់កាន់យកដោយសតិ គឺ ព្រះយោគាវចរកំណត់កាន់យកវត្ថុ ដែលគួរកាន់យកដោយសតិដែលសម្បយុត្តហើយ ឬជាបុព្វភាគ ។ បទថា **ជិនាតិ បាបកេ អកុសលេ ធម្មេ** ភិក្ខុរមែងឈ្នះអកុសលធម៌ដ៏លាមកបាន គឺរមែងឈ្នះ រមែងគ្របសង្កត់កិលេសដ៏លាមកដោយដាច់ជាសមុច្ឆេទ ។ ធម្មទេសនានេះជាបុគ្គលាធិដ្ឋាន ព្រោះកាលធម៌ទាំងឡាយឈ្នះ សូម្បីបុគ្គលអ្នកព្រមព្រៀងដោយធម៌នោះ ក៏ឈ្មោះថា រមែងឈ្នះផង ។ ម្យ៉ាងទៀត ធម៌ទាំងនោះមិនលះសតិ ប្រារព្ធដើម្បីនឹងឈ្នះក្នុងខណៈដែលនៅប្រព្រឹត្តទៅរបស់ខ្លួន លោកពោលថា ឈ្នះហើយ ដូចដែលលោកពោលថា បុគ្គលប្រារព្ធដើម្បីបរិភោគ ក៏ជាការបរិភោគហើយ ។ ម្យ៉ាងទៀត គប្បីជ្រាបលក្ខណៈក្នុងបទនេះដោយអត្ថនៃសព្ទ ។



សូម្បីកាលជាយ៉ាងនេះ កាលគួរនឹងពោលថា **បរិជិតា** លោកផ្លាស់ **ជ** អក្សរជា **ច** អក្សរ ពោលថា **បរិចិតា** ។ លោកធ្វើដោយលក្ខណៈរបស់ភាសា ផ្លាស់ **ទ** អក្សរជា **ត** ក្នុងអត្ថវិកប្បថា **សម្មា គទោ អស្សាតិ សុគតោ** ឈ្មោះថា **សុគត** ព្រោះមានព្រះវាចាប្រពៃ យ៉ាងណា សូម្បីក្នុងបទនេះក៏គប្បីជ្រាបយ៉ាងនោះ ។ បទថា **បរិចិតា** ក្នុងអត្ថវិកប្បនេះ ជាកត្តុសាធនៈ ៣ បទមុនជាកម្មសាធនៈ ។

បទថា **ចត្តារោ សុសមារទ្ធា** ធម៌ ៤ យ៉ាង ភិក្ខុប្រារព្ធល្អហើយ លោកអធិប្បាយថា ធម៌ ៤ យ៉ាង មានអត្ថដែលភិក្ខុប្រារព្ធល្អហើយ ។ គប្បីឃើញថាលុប **អត្ថ** សព្ទ ។ សូម្បីអត្ថនៃបទថា **សុសមារទ្ធា** គប្បីជ្រាបថា លោកពោលថា **សុសមារទ្ធា** ក្នុងទីនេះ ឬ **សុសមារទ្ធធម្មា** មានធម៌ដែលភិក្ខុប្រារព្ធល្អហើយ ។ គប្បីជ្រាបថា លោកពោលថា **ចត្តារោ** ដោយប្រភេទនៃអត្ថ មិនមែនដោយប្រភេទនៃធម៌ ។ ម្យ៉ាងទៀត ព្រោះធម៌ទាំងឡាយដែលភិក្ខុចម្រើនហើយ ឈ្មោះថា ប្រារព្ធល្អហើយ មិនមែនធម៌ពួកដទៃ ដូច្នោះ លោកពោលអត្ថនៃការចម្រើន ៣ យ៉ាងទុក សូម្បីក្នុងទីនេះ ។ សូម្បីអត្ថនៃអាសេវនៈ (ការសេព) លោកក៏ពោលក្នុងអត្ថនៃការចម្រើន ៣ យ៉ាង ដែលពោលហើយ ព្រោះដូច្នោះ លោកមិនពោលអត្ថនៃធម៌នោះ ជាការពោលដល់អត្ថនៃកិលេសដែលជា

សត្រូវដល់ធម៌នោះ ដែលដកចេញហើយ ព្រោះទីបំផុតនៃការប្រារព្ធរមែងប្រាកដ ដោយការដកកិលេសដែលជាសត្រូវ ដោយហេតុនោះ ជាការពោលដល់អត្ថដ៏កំពូលនៃធម៌ដែលប្រារព្ធល្អហើយ ។

ក្នុងបទទាំងនោះ បទថា **តប្បច្ចនីកានំ** កិលេសដែលជាសត្រូវដល់ធម៌នោះ គឺ កិលេសជាសត្រូវដល់ឈាន វិបស្សនា និងមគ្គទាំងនោះ ។ បទថា **កិលេសានំ** នៃកិលេសទាំងឡាយ គឺ នៃកិលេសទាំងឡាយ មានកាមច្ឆន្ទៈជាដើម និងសក្កាយទិដ្ឋិ ដែលសម្បយុត្តដោយនិច្ចសញ្ញាជាដើម ។ បទថា **សុសមូហតត្តា** ព្រោះដកហូតដោយល្អ ព្រោះវិនាសទៅដោយអំណាចនៃវិក្ខម្ភនៈ តទង្គៈ និងសមុច្ឆេទៈ ។ ប៉ុន្តែក្នុងគម្ពីរទាំងឡាយ ពួកអាចារ្យសរសេរទុកថា **សុសមុគ្ឃាតត្តា** បទនោះមិនល្អ ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងអត្ថវិកប្បសូម្បីដទៃ នៃបទនោះទៀត ទើបពោលពាក្យមានជាអាទិ៍ថា **សុសមំ** ភាពស្មើល្អ ។ ក្នុងបទទាំងនោះ បទថា **តត្ថ ជាតា** កុសលធម៌ទាំងឡាយកើតក្នុងធម៌នោះ គឺកើតក្នុងភាវនាវិសេស ដែលដល់កំពូលនោះ ។ បទថា **អនវជ្ជា** មិនមានទោស គឺ ប្រាសចាកទោស ពោលគឺ កិលេស ដោយការមិនចូលដល់ភាពជាអារម្មណ៍នៃកិលេសទាំងឡាយ ។ បទថា **កុសលា**



បានដល់ កុសលដោយកំណើត ។ បទថា **ពោធិបក្ខិយា** ជាចំណែកនៃការត្រាស់ដឹង គឺឈ្មោះថា **ពោធិបក្ខិយា** ព្រោះជាចំណែកនៃព្រះអរិយជាម្ចាស់ ដែលបានឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹង ។ បទថា **បក្ខេ ភវត្តា** ព្រោះមានក្នុងចំណែក គឺ ព្រោះតាំងនៅក្នុងភាពជាឧបការៈ ។ ម្យ៉ាងទៀត ធម៌ ៣៧ ទាំងនោះ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤

ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ ។ បទថា **ឥទំ សមំ** នេះជាភាពស្មើគ្នា គឺ ឈ្មោះថា **ស្មើ** ព្រោះធម្មជាតិក្នុងខណៈមគ្គនេះ រមែងញុំាងកិលេសទាំងឡាយឲ្យស្ងប់ គឺ ឲ្យវិនាសទៅដោយការដាច់ជាសមុច្ឆេទ ។ បទថា **និរោធោ និព្វានំ** ការរលត់ជានិព្វាន គឺ ឈ្មោះថា **និរោធ** ព្រោះរលត់ទុក្ខ ឈ្មោះថា **និព្វាន** ព្រោះមិនមានតណ្ហា ពោលគឺ គ្រឿងចាក់ស្រែះ ។ បទថា **ឥទំ សុសមំ** នេះជាភាពស្មើល្អ គឺ និព្វាននេះ ឈ្មោះថា ស្មើល្អ ព្រោះស្មើដោយល្អ ព្រោះប្រាសចាកភាពមិនស្មើ គឺ សង្ខតធម៌ទាំងពួង ។ បទថា **ញាតំ** ដឹងហើយ គឺ ដឹងស្មើ ពោលគឺ ពោធិបក្ខិយធម៌ ដោយញាណ ព្រោះមិនវង្វេង ដឹងស្មើល្អ ពោលគឺ និព្វាន ដោយញាណ ដោយភាពជាអារម្មណ៍ ឃើញទាំងពីរនោះ ដូចឃើញដោយភ្នែកនោះឯង ។ បទថា **វិទិតំ**

ជ្រាបហើយ គឺ បានទាំងពីរយ៉ាងនោះ ដោយកើតក្នុងសន្តាន និង ដោយធ្វើឲ្យជាអារម្មណ៍ ធ្វើឲ្យច្បាស់ហើយ និងពាល់ត្រូវហើយដោយ បញ្ញាដូចដឹងហើយ ប្រកាសអត្ថនៃបទមុន ៗ ថាមិនថោកថយ មិន វង្វេងភ្លេច មិនច្រចូកច្របល់ មានអារម្មណ៍តែមួយ ។

ក្នុងបទទាំងនោះ បទថា **អារទ្ធំ** ប្រារព្ធហើយ គឺ ប្រាថ្នាហើយ ។ បទថា **អសល្លីនំ** មិនថោកថយ ។ បទថា **ឧបដ្ឋិតា** តាំងមាំហើយ គឺ ចូលទៅតាំងទុកហើយ ។ បទថា **អសម្មុដ្ឋា** មិនវង្វេង គឺ មិនបាត់ទៅ ។ បទថា **បស្សទ្ធោ** ស្ងប់ហើយ គឺ រលត់ហើយ ។ បទថា **អសារទ្ធោ** មិនច្របូកច្របល់ គឺ មិនខ្វល់ខ្វាយ ។ បទថា **សមាហិតំ** តាំងមាំហើយ គឺ តាំងទុកស្មើ ។ បទថា **ឯកគ្គំ** មានអារម្មណ៍តែមួយ គឺ មិនរាយ-មាយ ។

បទមានជាអាទិ៍ថា **ចត្តារោ សុសមារទ្ធា** ធម៌ ៤ យ៉ាង ភិក្ខុ ប្រារព្ធល្អហើយ មានអត្ថជាមូលរបស់ពាក្យ **សុសមារទ្ធ** ទាំងអស់ ។ ចំណែកបទមានជាអាទិ៍ថា **អត្ថិ សមំ** សេចក្តីស្មើក៏មាន មានអត្ថជា មូលរបស់ **សុសម** ។ បទមានជាអាទិ៍ថា **ញាតំ** មានអត្ថជាវិកប្ប របស់ពាក្យ **អារទ្ធ** ។

តពីនេះទៅជាការប្រៀបធៀបអត្ថនៃបទ កាលគួរនឹងពោលថា



**សមា ច សុសមា ច សមសុសមា** ស្មើ និងស្មើដោយល្អ ឈ្មោះថា **សមសុសមា** លោកធ្វើជាឯកសេសសមាសមានរូបជាឯកទ្ទេស ហើយ ពោលថា **សុសមា** ដូចពោលថា **នាមញ្ច រូបញ្ច នាមរូបញ្ច នាមរូបំ** នាម រូប និងនាមរូប ឈ្មោះថា **នាមរូបំ** ។ បទថា **ឥទំ សមំ ឥទំ សុសមំ** នេះស្មើ នេះស្មើល្អ លោកធ្វើជាពាក្យនបុំសកលិង្គ ព្រោះមិន សម្ងឹងជាយ៉ាងដទៃ ។ម្យ៉ាងទៀត ព្រោះសូម្បី **ញាតំ** ដឹងហើយ លោកពោលថា **ទិដ្ឋំ** ឃើញហើយ ។ ឃើញហើយ និងប្រារព្ធហើយ ដោយអត្ថជាដូចគ្នា ។ ចំណែកបទថា **វិទិត** ដឹងហើយ **សច្ឆិកត** ធ្វើឲ្យច្បាស់ហើយ **ផស្សិត** ពាល់ត្រូវហើយ ជាវេវចនៈរបស់បទថា **ញាត** ដឹងហើយ ។ ដូច្នោះ ទើបលោកពោលអត្ថនៃ **អារទ្ធ** ប្រារព្ធ ហើយថា **ញាតំ** ដឹងហើយ ។ បទថា **អារទ្ធំ ហោតិ វីរិយំ អសល្លីនំ** ការព្យាយាមភិក្ខុនោះប្រារព្ធហើយ មិនថោកថយ មានអត្ថត្រូវគ្នា និង ពាក្យថា **អារទ្ធ** តែបទមានជាអាទិ៍ថា **ឧបដ្ឋិតា សតិ** សតិតាំងមាំ លោកពោលដើម្បីសម្តែងធម៌ដែលជាឧបការៈ ដល់ការព្យាយាមដែល សម្បយុត្តហើយ មិនបានពោលដើម្បីសម្តែងអត្ថនៃពាក្យថា **អារទ្ធ** ឈ្មោះថា **សុសមារទ្ធា** ព្រោះប្រារព្ធស្មើហើយដោយល្អ ដោយអត្ថមុន ហើយឈ្មោះថា **សុសមារទ្ធា** ព្រោះផ្តើមស្មើដោយល្អ ដោយអត្ថនេះ

កាលលោកធ្វើជាឯកសេសសមាស ទើបពោលថា **សុសមារទ្ធា** ។ លោកកំណត់កាន់យកអត្ថនេះ ហើយពោលថា ដោយហេតុនោះ លោកទើបពោលថា **សុសមារទ្ធា** ប្រារព្ធសេចក្តីស្ងប់ប្រពៃ ។

បទថា **អនុបុព្វំ** គឺ តាមលំដាប់ ។ អធិប្បាយថា ដំបូង ៗ ។ បទថា **ទីឃំ អស្សាសវសេន** ដោយអំណាចខ្យល់ដកដង្ហើមចូលវែង គឺ ដោយអំណាចខ្យល់ដកដង្ហើមចូល ដែលលោកពោលថា **ទីឃំ** វែង ។ បទថា **បុរិមា បុរិមា** ខាងដើម ៗ គឺ សតិសមាធិ ខាងដើម ៗ ។ លោកពោលអត្ថនៃបទថា **បុព្វំ** ដោយបទនេះ ។ បទថា **បច្ឆិមា បច្ឆិមា** ខាងក្រោយ ៗ គឺ សតិនោះឯង ។ លោកពោលអត្ថនៃបទថា **អនុ** ដោយបទនោះ ។ ដោយបទទាំងពីរនោះ បានសេចក្តីថា អប់រំអានាបានស្សតិមុន និងក្រោយ ។ ព្រោះពោលធ្វើវត្ថុ ១៦ យ៉ាង ខាងលើឲ្យពិស្តារ ក្នុងទីនេះ លោកទើបសង្ខេបហើយសម្តែងបទទីបំផុតថា **បដិនិស្សគ្គានុបស្សី** ពិចារណាឃើញការលះបង់ ដូច្នេះ ។

**ព្រោះអានាបានស្សតិ** សូម្បីទាំងពួងភិក្ខុអប់រំតាមលំដាប់ ព្រោះប្រព្រឹត្តទៅតាមការពេញចិត្តរឿយ ៗ នៃការចម្រើនដល់កំពូល ។ ហេតុនោះលោកទើបពោលថា **អញ្ញមញ្ញំ បរិចិតា ចេវ ហោន្តិ អនុបរិចិតា ច** អាស្រ័យគ្នា ភិក្ខុនោះអប់រំហើយ និងអប់រំតាមលំដាប់ហើយ ដូច្នេះ ។



បទថា **យថត្ថា** អត្ថនៃ **យថា** សព្ទ គឺ អត្ថតាមសភាវៈ ។ បទថា **អត្តទមថដ្ឋោ** ការទូន្មាននូវខ្លួន គឺ ការអស់ការចចេសរបស់ខ្លួនក្នុងខណៈអរហត្តមគ្គ ។ បទថា **សមថដ្ឋោ** ការរម្ងាប់នូវខ្លួន គឺ ភាពជាអ្នកត្រជាក់ត្រជុំ ។ បទថា **បរិនិព្វាបនដ្ឋោ** ការរំលត់ គឺ ដោយការរំលត់កិលេស ។ បទថា **អភិញ្ញដ្ឋោ** ការដឹងច្បាស់ គឺ ដោយអំណាចនៃធម៌ទាំងពួង ។ បទថា **បរិញ្ញដ្ឋោ** ការកំណត់ដឹងជាដើម គឺ ដោយអំណាចនៃកិច្ច គឺ មគ្គញ្ញាណ ។ បទថា **សច្ចាភិសមយដ្ឋោ** ការត្រាស់ដឹងសច្ចៈ គឺ ដោយអំណាចនៃការឃើញច្បាស់ ចាក់ធ្លុះអរិយសច្ចៈ ៤ ។ បទថា **និរោធេ បតិដ្ឋាបកដ្ឋោ** ការតម្កល់ខ្លួនស៊ប់ក្នុងនិរោធ គឺ ដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ ។ លោកបំណងនឹងបង្ហាញថា **ពុទ្ធោ** ក្នុងបទថា **ពុទ្ធេន** សូម្បីមិនមាន បទថា **ពុទ្ធស្ស** ទើបពោលថា **ពុទ្ធោ** ។ បទថា **សយម្ភូ** ព្រះអង្គឯង គឺ ព្រះអង្គឯងប្រាសចាកការណែនាំ ។ បទថា **អនាចរិយកោ** មិនមានអាចារ្យ គឺ ពង្រីកអត្ថនៃបទថា **សយម្ភូ** ។ ព្រោះថា អ្នកណាចាក់ធ្លុះអរិយសច្ចៈប្រាសចាកអាចារ្យ អ្នកនោះជា **សយម្ភូ** ។ សូម្បីបទមាន ជាអាទិ៍ថា **បុព្វេ អននុស្សុតេសុ** ក្នុងធម៌ដែលមិនធ្លាប់ស្តាប់មកពីកាលមុន ជាការប្រកាសអត្ថនៃភាពមិនមានអាចារ្យ ។ បទថា **អននុស្សុតេសុ** គឺ មិន

ផ្ចាប់ស្តាប់មកពីអាចារ្យ ។ បទថា **សាមំ** គឺ ខ្លួនឯង ។ បទថា **អភិសម្ពុជ្ឈិ** ត្រាស់ដឹង គឺ ចាក់ធ្លុះដោយប្រពៃយ៉ាងក្រៃលែង ។ បទថា **តត្ថ ច សព្វញ្ញុតំ បាបុណិ** គឺ សម្រេចភាពជាព្រះសព្វញ្ញុក្នុងសច្ចៈនោះ ។ លោកពោលយ៉ាងនោះ ព្រោះចាក់ធ្លុះសច្ចៈដោយពិត ព្រះសព្វញ្ញុទាំងឡាយជាអ្នកចាក់ធ្លុះសច្ចៈ ។ បាឋៈថា **សព្វញ្ញុតំ បត្តោ** សម្រេចភាពជាព្រះសព្វញ្ញុខ្លះ ។ បទថា **ពលេសុ ច វសីភាវំ** ជាអ្នកមានភាពជំនាញក្នុងពលធម៌ទាំងឡាយ គឺ សម្រេចភាពជាឥស្សរៈក្នុងកម្លាំងរបស់ព្រះតថាគត ១០ ។ អ្នកណាជាយ៉ាងនោះ លោកពោលអ្នកនោះថាជា **ពុទ្ធ** ក្នុងបទថា **ពុទ្ធោ** នោះ ជាបញ្ញត្តិ សំដៅដល់ខន្ធសន្តានដែលអប់រំសម្រេចភាពរួចផុតដ៏កំពូល ជានិមិត្តនៃញាណដែលអ្វី ៗ មិនអាចរារាំងបានក្នុងធម៌ទាំងពួង ឬព្រះពុទ្ធជាម្ចាស់វិសេសជាងសត្វ ជាបញ្ញត្តិ សំដៅដល់ការត្រាស់ដឹងសច្ចៈដែលជាបទដ្ឋាននៃសព្វញ្ញុតញ្ញាណ ។ ដោយហេតុត្រឹមប៉ុណ្ណេះ លោកពោលដល់ការបង្ហាញបទថា **ពុទ្ធ** ដោយអត្ថ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលនឹងបង្ហាញដោយព្យញ្ជនៈ ទើបពោលពាក្យមានជាអាទិ៍ថា **ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ** បទថា **ពុទ្ធោ** ព្រះមានព្រះភាគជាម្ចាស់ទ្រង់ព្រះនាមថា **ពុទ្ធ** ដោយអត្ថថាដូចម្តេច ក្នុងបទ



នោះលោកពោលថា **អវគតោ** ព្រោះត្រាស់ដឹងក្នុងលោកតាមសេចក្តីពិត ឈ្មោះថា **ពុទ្ធោ** ព្រោះត្រាស់ដឹងសច្ចធម៌ ឈ្មោះថា **ពុទ្ធោ** ទ្រង់ប្រៀនប្រដៅពួកសត្វឲ្យត្រាស់ដឹង ដូចលោកពោលថា ស្លឹកឈើស្ងួតព្រោះខ្យល់ប៉ះខ្លួន ។ បទថា **សព្វញ្ញុតាយ ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ព្រោះភាពជាសព្វញ្ញុ ។ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះមានបញ្ញាអាចត្រាស់ដឹងធម៌ទាំងពួង ។ បទថា **សព្វទស្សាវិតាយ ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ទ្រង់ឃើញធម៌ទាំងពួង ។ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ឃើញធម៌ទាំងពួងដោយញាណចក្ខុ ។ បទថា **អនញ្ញនេយ្យតាយ ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ព្រោះមិនមានអ្នកដទៃណែនាំ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះអត្ថថា ត្រាស់ដឹងដោយព្រះអង្គឯង ដោយមិនត្រាស់ដឹងពីអ្នកដទៃ ។ បទថា **វិសវិតាយ ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ព្រោះមានសតិដោយវិសេស លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះអត្ថថា **រីក** ដូចផ្កាឈូករីក ដោយទ្រង់រីកដោយគុណផ្សេង ៗ ។ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះជាអ្នកច្លាតក្នុងការអស់ទៅនៃការដេកលក់ ដោយកិលេសទាំងពួង ដោយលះធម៌ដែលធ្វើចិត្តឲ្យរួញរា ដោយបរិយាយ ៦ មានជាអាទិ៍ថា **ខីណាសវសង្ខាតេន ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ព្រោះរាប់ថាព្រះអង្គអស់អាសវៈ

ដូចបុរសអ្នកច្នាត ក្នុងការអស់ទៅនៃការដេកលក់ ។ ព្រោះបទថា **សន្ធា សន្ធាតំ** ដោយអត្ថដូចគ្នា សេចក្តីថា ដោយចំណែកនៃពាក្យថា **សន្ធាតេន** ។ ឈ្មោះថា **ពុទ្ធោ** ព្រោះរាប់ថា មិនមានគ្រឿងលាបបាន ព្រោះមិនមានគ្រឿងលាបបាន គឺ តណ្ហា និងគ្រឿងលាប គឺ ទិដ្ឋិ ។ លោកអធិប្បាយបទមានជាអាទិ៍ថា **ឯកន្តវីតរាគោ** ទ្រង់ប្រាសចាករាគៈ ដោយចំណែកមួយឲ្យប្លែកដោយពាក្យថា ដោយចំណែកមួយ ព្រោះលះកិលេសទាំងពួងព្រមដោយវាសនាបានហើយ ។ បទថា **ឯកន្តនិក្កិ-លេសោ** ព្រះអង្គមិនមានកិលេសដោយចំណែកមួយ គឺ មិនមានកិលេសដោយកិលេសទាំងពួងដ៏សេសចាក រាគៈ ទោសៈ និងមោហៈ ។ ឈ្មោះថា **ពុទ្ធោ** ព្រោះស្តេចទៅហើយ កាន់ផ្លូវដែលទៅនៃបុគ្គលតែម្នាក់ឯង សូម្បីអត្ថនៃការត្រាស់ដឹង ក៏ឈ្មោះថា ជាអត្ថនៃការទៅកាន់ធាតុទាំងឡាយ ព្រោះអត្ថនៃការត្រាស់ដឹង ដែលជាអត្ថនៃការទៅដល់ ព្រោះដូច្នោះ លោកទើបពោលថា ឈ្មោះថា **ពុទ្ធោ** ព្រោះស្តេចទៅកាន់ផ្លូវដែលទៅនៃបុគ្គលតែម្នាក់ ។

ម្យ៉ាងទៀត ក្នុងបទថា **ឯកាយនមគ្គោ** នេះ លោកពោលឈ្មោះនៃផ្លូវទុក ក្នុងឈ្មោះជាច្រើនថា :-

**មគ្គ បន្ថ បថ បជ្ជ អញ្ជស វដុម អាយតន នាវា ឧត្តរសេតុ**



**( ស្ពានច្លង ) កុល្ល ( ក្បូន ) សង្កម ( ផ្លូវដើរទៅ ) ។**

ព្រោះដូច្នោះ ផ្លូវទើបមានតែមួយ មិនមាន ២ ។ ម្យ៉ាងទៀត ឈ្មោះថា **ឯកាយនមគ្គ** ព្រោះជាផ្លូវដែលបុគ្គលតែម្នាក់គប្បីទៅ ។ បទថា **ឯកេន** តែម្នាក់ គឺ ដោយចិត្តស្ងប់ស្ងាត់ ព្រោះលះការច្រឡូកច្រឡំដោយពួក ។ បទថា **អយិតព្វោ** គប្បីទៅ គឺ គប្បីបដិបត្តិ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **អយនោ** ព្រោះជាហេតុទៅ ។ សេចក្តីថា ចាកសង្សារទៅកាន់និព្វាន ។ ការទៅរបស់អ្នកប្រសើរ ឈ្មោះថា **ឯកា-យន** គឺ អ្នកប្រសើរ ។ បទថា **ឯកេ** គឺ អ្នកដ៏ប្រសើរ ។ ព្រះសម្មា-សម្ពុទ្ធជាម្ចាស់ ជាបុគ្គលប្រសើរជាងសត្វទាំងពួង ។ ព្រោះដូច្នោះ លោកទើបពោលថា ផ្លូវ ដែលជាផ្លូវទៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ឈ្មោះថា **ឯកាយនមគ្គ** ឬឈ្មោះថា **អយនោ** ព្រោះទៅ សេចក្តីថា រមែងទៅ រមែងប្រព្រឹត្តទៅ ។ ឈ្មោះថា **ឯកាយនមគ្គ** ព្រោះជាផ្លូវទៅក្នុងផ្លូវតែមួយ ។ លោកអធិប្បាយថា ផ្លូវប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនា ផ្លូវតែមួយប៉ុណ្ណោះ មិនមែនក្នុងផ្លូវដទៃ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **ឯកាយនោ** ព្រោះទៅផ្លូវតែមួយ លោកអធិប្បាយថា ក្នុងខាងដើម សូម្បីប្រព្រឹត្តទៅដោយមុខផ្សេង ៗ និងដោយន័យផ្សេង ៗ ក្នុងខាងក្រោយ ក៏ទៅនិព្វានតែម្យ៉ាង ប៉ុណ្ណោះ

ព្រោះដូច្នោះ បទថា **ឯកាយនមគ្គោ** សេចក្តីថា ផ្លូវទៅនិព្វាន ជាផ្លូវតែមួយ ។ ឈ្មោះថា **ពុទ្ធោ** ព្រោះព្រះអង្គតែម្នាក់ឯង អ្នកត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ មិនមែន **ពុទ្ធោ** ព្រោះត្រាស់ដឹងតាមអ្នកដទៃ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណដ៏ប្រសើរក្រៃលែង ដោយព្រះអង្គឯងប៉ុណ្ណោះ ។

បទថា **អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភា ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់កម្ចាត់ចេញនូវការមិនមានបញ្ញា ព្រោះទ្រង់បាននូវព្រះបញ្ញាជាគ្រឿងត្រាស់ដឹង ។ បទនេះថា **ពុទ្ធិ ពុទ្ធំ ពោធោ** ជាពាក្យបរិយាយ ។ ក្នុងបទនោះ លោកពោលទុកដើម្បីឲ្យដឹងថា ឈ្មោះថា **ពុទ្ធោ** ព្រោះប្រកបដោយពុទ្ធគុណ ដូចពោលថា ពណ៌ខៀវ ពណ៌ក្រហម ព្រោះប្រកបដោយប្រភេទនៃពណ៌ខៀវ ពណ៌ក្រហម ។

តពីនោះទៅ បទមានជាអាទិ៍ថា **ពុទ្ធោតិ នេតំ នាមំ** បទថា **ពុទ្ធោ** នេះ មិនមែនជាឈ្មោះដែលមាតាជាដើមដាក់ឲ្យ លោកពោលដើម្បីឲ្យដឹងថា នេះជាបញ្ញត្តិទៅតាមអត្ថ ។

ក្នុងបទទាំងនោះ បទថា **មិត្តា** គឺ សម្លាញ់ ។ បទថា **អមច្ចា** គឺ អាមាត្យ ។ បទថា **ញាតី** គឺ ញាតិចំណែកខាងបិតា ។ បទថា **សាលោហិតា** គឺ ញាតិចំណែកខាងមាតា ។ បទថា **សមណា** គឺ អ្នកជា



បព្វជិត ។ បទថា **ព្រាហ្មណា** គឺ អ្នកមានវាទៈថាជាអ្នកចម្រើន ឬអ្នកមានបាបបន្សាត់បង់ហើយ ។ បទថា **ទេវតា** គឺ សក្កទេវរាជជាដើមនិងព្រហ្ម ។ បទថា **វិមោក្ខន្តិកំ** ព្រះនាមដែលកើត ក្នុងទីបំផុតនៃព្រះ-អរហត្តផល គឺ វិមោក្ខ បានដល់ អរហត្តមគ្គ , ទីបំផុតនៃវិមោក្ខ គឺ អរហត្តផល ការកើតក្នុងទីបំផុតនៃវិមោក្ខនោះ ឈ្មោះថា **វិមោក្ខន្តិក** ។

មែនពិត ភាពជាព្រះសព្វញ្ញូ រមែងសម្រេចដោយអរហត្តមគ្គ ជាការសម្រេចក្នុងការកើតអរហត្តផល ។ ព្រោះដូច្នោះ ភាពជាព្រះសព្វញ្ញូ ទើបជាការកើតក្នុងទីបំផុតនៃអរហត្តផល សូម្បីនេមិត្តកនាមនេះឈ្មោះថា ជាការកើតក្នុងទីបំផុតនៃអរហត្តផល ដោយហេតុនោះ លោកទើបពោលថា នេះជាវិមោក្ខន្តិកនាម ព្រះនាមដែលកើតក្នុងទីបំផុតនៃអរហ-ត្តផលនៃព្រះមានព្រះភាគជាម្ចាស់ត្រាស់ដឹងហើយ ។

បទថា **ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា** កើតឡើងព្រមនឹងការបានព្រះសព្វញ្ញុតញ្ញាណ នាក្រោមដើមពោធិព្រឹក្ស គឺ ព្រមជាមួយការបានព្រះសព្វញ្ញុតញ្ញាណក្នុងខណៈតាមដែលបានពោលហើយក្រោមដើមមហាពោធិ ។ បទថា **សច្ឆិកា បញ្ញត្តិ** សច្ឆិកាបញ្ញត្តិ គឺ ដោយធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ឬបញ្ញត្តិកើតដោយការធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងពួង ។ បទថា **យទិទំ ពុទ្ធោ** បញ្ញត្តិថា **ពុទ្ធោ**

នេះ ជាការប្រកាសភាពជាពុទ្ធៈ ដោយព្យញ្ជនៈ ។

ការប្រៀបធៀបគ្នានេះ ដោយអត្ថដូចដែលបានពោលហើយ ក្នុងបទភាជនីយ៍នេះនៃបាទគាថាថា **យថា ពុទ្ធេន ទេសិតា** ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងហើយ ។

ដោយប្រការដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងអានាបានស្សតិហើយ ដោយប្រការដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែង **យថា** សទ្ទជាអត្ថ ១០ យ៉ាង សង្គ្រោះដោយ **យថា** សទ្ទ ដោយហេតុនោះ គប្បីជ្រាបថា លោកធ្វើឲ្យជាឯកសេសសមាសផង ដោយអំណាចនៃឯក-សេសសមាសសរុប **យថា** សទ្ទ មាន **បការ** សទ្ទ និង **យថា** សទ្ទមាន **សការ** សទ្ទ ជាអត្ថ ហើយពោលថា **យថា** ។ ប៉ុន្តែក្នុងបទភាជនីយ៍ លោកធ្វើឲ្យជាឯកវចនៈថា **ទេសិតោ** ដោយការប្រកបសទ្ទនីមួយ ៗ ក្នុង **យថា** សទ្ទនោះ ។ សូម្បីក្នុងបទដើម លោកពោលថា **ហោតិ គហដ្ឋោ វា ហោតិ បព្វជិតោ វា** ដូចបុគ្គល ជាគ្រហស្ថក្តី ជាបព្វជិតក្តី លោកពោលថា **យស្ស គហដ្ឋស្ស វា បព្វជិតស្ស វា** នៃគ្រហស្ថក្តី នៃបព្វជិតក្តី លោកពោលដល់អត្ថនៃលោក ។ បទថា **បភាសេតិ** រមែងឲ្យភ្លឺស្វាង សេចក្តីថា ធ្វើឲ្យប្រាកដដល់ញាណរបស់ខ្លួន ។ បទថា **អភិសម្ពុទ្ធត្ថា** ព្រោះជាអ្នកត្រាស់ដឹងព្រមចំពោះ គឺ ព្រោះ



ចាក់ធ្លុះដោយសាវកបារមីញាណ ។ បទថា **ឱភាសេតិ** រមែងញុំាងលោកនេះឲ្យភ្លឺស្វាង គឺ លោកដែលជាកាមាវចរៈ ។ បទថា **ភាសេតិ** ញុំាងលោកឲ្យភ្លឺស្វាង គឺ លោកជារូបាវចរ ។ បទថា **បភាសេតិ** ញុំាងលោកនេះឲ្យភ្លឺស្វាង គឺ លោកជាអរូបាវចរ ។ បទថា **អរិយញ្ញាណំ** គឺ អរហត្តមគ្គញ្ញាណ ។ បទថា **មហិក មុត្តោ** គឺ ផុតចាកទឹកសន្សើម ។ ទឹកសន្សើម លោកហៅថា **មហិក** ។ បាឋៈថា **មហិយា មុត្តោ** ខ្លះ ។ បទថា **ធូមរជា មុត្តោ** គឺ ផុតចាកផ្សែង និងធូលី ។ បទថា **រាហុគហណា វិប្បមុត្តោ** គឺ ផុតចាកការចាប់របស់រាហូ លោកពោលឲ្យប្លែកដោយឧបសគ្គ ២ យ៉ាង ព្រោះរាហូធ្វើឲ្យព្រះចន្ទសៅហ្មង ព្រោះនៅជិតគ្នា ។ បទថា **ភាសតេ** គឺ ឲ្យភ្លឺស្វាង ដោយមានពន្លឺ ។ បទថា **តបតេ** បានដល់ ឲ្យស្រស់បំព្រងដោយមានតេជៈ ។ បទថា **វិរោចតេ** គឺ ឲ្យភ្លឺថ្លាដោយភាពរុងរោជន៍ ។ បទថា **ឯវមេវំ** កាត់បទជា **ឯវំ ឯវំ** ។ម្យ៉ាងទៀត សូម្បីព្រះចន្ទកាលភ្លឺរុងរោជន៍ រមែងញុំាងឱកាសលោកនេះឲ្យភ្លឺស្វាង យ៉ាងណា ភិក្ខុកាលភ្លឺស្វាង ស្រស់បំព្រង រុងរោជន៍ដោយបញ្ញា រមែងញុំាងលោក មានខន្ធលោកជាដើមឲ្យភ្លឺស្វាង ដោយបញ្ញាដូច្នោះ សូម្បីក្នុងបទទាំងពីរ លោកមិនពោលថា **ភាសេតិ** តែពោលថា **ភាសតេ** ដូច្នេះ ព្រោះកាលពោលយ៉ាងនោះ ក៏ជាការពោល

ហើយសូម្បីអត្ថនៃហេតុផង ។ ប្រសិនបើសួរថា ព្រោះហេតុអ្វី ទើបមិនឧបមាដោយព្រះអាទិត្យដែលមានភ្លឺខ្លាំងក្រៃលែងជាង ត្រឡប់ទៅឧបមាដោយព្រះចន្ទ ។ ឆ្លើយថា គប្បីជ្រាបថា ដែលកាន់យកយ៉ាងនោះ ព្រោះការឧបមាដោយព្រះចន្ទ ដែលប្រកបដោយគុណសម្បត្តិ ត្រជាក់ជាការសមគួរដល់ភិក្ខុអ្នកស្ងប់ដោយការស្ងប់សេចក្តីក្តៅក្រហាយ ព្រោះកិលេសទាំងពួង ។

ព្រះសារីបុត្តត្ថេរ គ្រាសរសើរព្រះយោគាវចរអ្នកញុំាងសិទ្ធិក្នុងការចម្រើនអានាបានស្សតិឲ្យសម្រេច ហើយសម្តែងសរុបញាណទាំងនោះថា **ឥមានិ តេរស វោទានេ ញាណានិ** ញាណក្នុងវោទាន ១៣ ទាំងនេះឯង ។

**( ចប់ អដ្ឋកថាវោទានញ្ញាណនិទ្ទេស )**



## អដ្ឋកថា សតោការិញ្ញាណនិទ្ទេស

### ចតុក្កៈទី ១

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសតោការិញ្ញាណនិទ្ទេស ( ញាណក្នុងការតាំងសតិ ) ដូចតទៅនេះ ។ ក្នុងមាតិកាបទថា **ឥធ ភិក្ខុ** គឺ ភិក្ខុក្នុងសាសនានេះ ។ មែនពិត **ឥធ** សព្ទ ក្នុងបទនេះ នេះសម្តែងដល់ពាក្យប្រៀនប្រដៅ ដែលជានិស្ស័យនៃបុគ្គលអ្នកញុំាងអានាបានស្សតិ-សមាធិមានប្រការទាំងពួងឲ្យកើតឡើង និងបដិសេធភាពជាយ៉ាងនោះរបស់សាសនាដទៃ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សមណៈមានក្នុងសាសនានេះប៉ុណ្ណោះ ។ បេ ។ លទ្ធិនៃសាសនាដទៃនោះ ទទេចាកសមណៈដែលដឹងទូទៅ ។ បទថា **អរញ្ញ-គតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា** នៅក្នុងព្រៃក្តី នៅត្រង់គល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី នេះសម្តែងដល់ការកំណត់កាន់យកសេនាសនៈដែលសមគួរដល់ការចម្រើនអានាបានស្សតិសមាធិ របស់ភិក្ខុនោះ ។ ចិត្តរបស់ភិក្ខុនោះស្វែងរកក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមរហូតអស់កាលយូរ មិនប្រាថ្នាអារម្មណ៍បន្ថែមទៀត ដែលជាអានាបានស្សតិសមាធិ ចិត្តរមែងស្ទុះទៅក្រៅផ្លូវតែម្យ៉ាង ដូចរថទឹមដោយគោកាច ព្រោះដូច្នោះ ប្រៀបដូចជាមនុស្សចិញ្ចឹមគោ បំណងនឹង

ហ្វឹកហ្វាត់កូនគោកាច ដែលផឹកទឹកដោះរបស់មេគោកាច ឲ្យចម្រើន ទើបនាំចេញចាកមេគោ បោះបង្គោលសរសរធំទុកម្ខាង យកខ្សែចងទុកត្រង់សរសរនោះ ពេលនោះ កូនគោរបស់គេមិនអាចកន្ត្រាងចាកទីនោះ ៗ គេចចេញទៅបាន ទើបក្រាបដេកស្ងៀមនៅត្រង់សរសរនោះឯង យ៉ាងណា សូម្បីភិក្ខុនោះក៏ដូច្នោះដូចគ្នា បំណងនឹងហ្វឹកហាត់ចិត្តដែលប្រទូសរាយ ឲ្យចម្រើន ដោយការផឹកនូវរស មានរូបារម្មណ៍ជាដើម រហូតអស់កាលយូរ ទើបនាំចេញចាកអារម្មណ៍ មានរូបជាដើម ហើយចូលទៅកាន់ព្រៃក្តី គល់ឈើក្តី ផ្ទះស្ងាត់ក្តី ចងដោយខ្សែ គឺ សតិ ត្រង់សរសរ គឺ ខ្យល់អស្សាសៈ និងបស្សាសៈនោះ ចិត្តរបស់ភិក្ខុនោះ សូម្បីរើបម្រះទៅខាងនេះខាងនោះ កាលមិនបានអារម្មណ៍ដែលសន្សំទុកក្នុងកាលមុន ក៏មិនអាចនឹងកាត់ខ្សែ គឺ សតិគេចទៅបាន ទើបអង្គុយស្ងៀម ដេកស្ងៀមនៅក្នុងអារម្មណ៍នោះឯង ដោយអំណាចនៃឧបចារៈ និងអប្បនា ។ ដោយហេតុនោះ បោរាណាចារ្យទាំងឡាយទើបពោលទុកថា :

**នរជនគប្បីចងកូនគោដែលគួរហ្វឹកហ្វាត់ទុកត្រង់សរសរនេះ**
**យ៉ាងណា ភិក្ខុគប្បីចងចិត្តរបស់ខ្លួនទុកក្នុងអារម្មណ៍ដោយ**
**សតិឲ្យមាំមួន ដូច្នេះ ។**

សេនាសនៈនោះ របស់ភិក្ខុនោះសមគួរដល់ភាវនា ដោយប្រការ



ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះអានាបានស្សតិដែលជាបទដ្ឋាននៃសុខវិហារធម៌ក្នុងបច្ចុប្បន្ននៃការសម្រេចគុណវិសេសរបស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវករបស់ព្រះពុទ្ធជាម្ចាស់ទាំងពួង ជាកំពូលប្រភេទនៃកម្មដ្ឋាននេះ ដែលព្រះយោគាវចរមិនលះចុងស្រុក ដែលពោរពេញទៅដោយសំលេងស្ត្រី បុរស ដំរី និងសេះជាដើម ដែលលំបាកក្នុងការចម្រើន ព្រោះឈានមានសំឡេងជាគ្រឿងរំខាន ចំណែកព្រះយោគាវចរកំណត់យកកម្មដ្ឋាននេះក្នុងព្រៃមិនមែនស្រុក ញ៉ាំងអានាបានស្សតិចតុក្កជ្ឈានឲ្យកើតឡើង ធ្វើឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយជាការធ្វើបានងាយ ដើម្បីសម្រេចព្រះអរហត្ត ដែលជាផលដ៏ប្រសើ ដូច្នេះ ព្រះមានព្រះភាគ កាលនឹងទ្រង់អាងដល់សេនាសនៈ ដែលសមគួរដល់ព្រះយោគាវចរនោះ ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា **អរញ្ញគតោ វា** ដូច្នេះ ។ ព្រះថេរៈក៏ដូច្នោះ ព្រោះព្រះមានព្រះភាគជាម្ចាស់ ដូចជាអាចារ្យអ្នកមានវិជ្ជាមើលទីដី ។ មែនពិត អាចារ្យអ្នកមានវិជ្ជាចេះមើលទីដីនោះ ឃើញទីដីដែលសាងនគរហើយ កំណត់ទុកដោយល្អ ណែនាំថា ពួកលោកចូរសាងនគរត្រង់ផ្ទៃដីនេះចុះ កាលនគរសម្រេចទៅដោយល្អ រមែងបានសក្ការៈធំ យ៉ាងណា ព្រះដ៏មាន-

ព្រះភាគជាម្ចាស់ក៏ដូច្នោះ ដូចគ្នា ទ្រង់កំណត់សេនាសនៈដែលសមគួរដល់ព្រះយោគាវចរ ហើយទ្រង់ណែនាំថា គួរប្រកបកម្មដ្ឋានក្នុងទីនេះ បន្ទាប់ពីនោះ ព្រះយោគាវចរប្រកបកម្មដ្ឋានក្នុងទីនោះ សម្រេចព្រះ-អរហត្តដោយលំដាប់ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់រមែងបានទទួលសក្ការៈធំថា ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ហ្ន៎ ដូច្នេះ ។

ម្យ៉ាងទៀត ភិក្ខុនេះលោកពោលថា ដូចជាខ្លាដំបង ។ គប្បីជ្រាបថា ដូចស្ដេចខ្លាដំបងពួនអាស្រ័យកម្ពោតស្មៅ កម្ពោតព្រៃញកភ្នំ ក្នុងព្រៃចាប់ម្រឹគ មានក្របីព្រៃ ឈ្លូស ជ្រូកជាដើម យ៉ាងណា ភិក្ខុនេះក៏ដូច្នោះដូចគ្នា ប្រកបកម្មដ្ឋានក្នុងព្រៃជាដើម កាន់យកសោតា-បត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ និងអរិយផលទាំងឡាយតាមលំដាប់ ដូចព្រះបោរាណាចារ្យទាំងឡាយពោលទុកថា :-

**ខ្លាដំបងពួនចាប់ម្រឹគទាំងឡាយ យ៉ាងណា ព្រះពុទ្ធបុត្តនេះ**
**ក៏ដូច្នោះដូចគ្នា ។ ប្រកបសេចក្ដីព្យាយាម ចម្រើនវិបស្សនា**
**ចូលទៅកាន់ព្រៃ រមែងកាន់យកផលដ៏ខ្ពស់ខ្ពស់ ។**

ដោយហេតុនេះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្ដែងសេនាសនៈក្នុងព្រៃ ដែលជាទីកន្លែងប្រកបសេចក្ដីព្យាយាមយ៉ាងរហ័ស



ទើបត្រាស់ព្រះតម្រាស់ មានជាអាទិ៍ថា **អរញ្ញគតោ វា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អរញ្ញគតោ** នៅព្រៃ គឺ ព្រៃដែលជាសេចក្ដីសុខកើតពីសេចក្ដីស្ងាត់ណាមួយ មានលក្ខណៈដូចពោលហើយក្នុងពេលមុន ។ បទថា **រុក្ខមូលគតោ** នៅត្រង់គល់ឈើ គឺ នៅជិតដើមឈើ ។ បទថា **សុញ្ញាគារគតោ** នៅក្នុងផ្ទះស្ងាត់ គឺ នៅក្នុងឱកាសស្ងាត់សូន្យទទេ ។

ម្យ៉ាងទៀត ក្នុងបទនេះសូម្បីនៅក្នុងសេនាសនៈ ៧ យ៉ាង ដ៏សេសវៀរព្រៃ និងគល់ឈើ ក៏គួរពោលថា **សុញ្ញាគារគតោ** នៅផ្ទះស្ងាត់បាន ។ ពិតមែន សេនាសនៈមាន ៩ យ៉ាង ដូចដែលលោកពោលទុកថា ភិក្ខុនោះសេពសេនាសនៈដែលស្ងាត់ គឺ ព្រៃ គល់ឈើ ភ្នំញកភ្នំ ល្អាងភ្នំ ព្រៃខ្មោច ដងព្រៃ ទីវាល ពំនូកចំបើង ។ ព្រះមានព្រះភាគ កាលទ្រង់ណែនាំសេនាសនៈ ដែលសមគួរដល់ការចម្រើនអានា-បានស្សតិកម្មដ្ឋាន ដែលឧបត្ថម្ភដោយ ៣ រដូវ និងឧបត្ថម្ភដោយធាតុ-ចរិយាដល់ភិក្ខុនោះ ហើយកាលទ្រង់ណែនាំដល់ឥរិយាបថដ៏ស្ងប់ដែលជាចំណែកនៃការមិនរួញរា និងមិនរាយមាយ ទើបត្រាស់ថា **និសីទតិ** អង្គុយស្រេចហើយ កាលទ្រង់សម្ដែងដល់ការអង្គុយរបស់ភិក្ខុនោះបានមាំមួន កាលខ្យល់អស្សាសៈ និងបស្សាសៈប្រព្រឹត្តទៅជាប្រក្រតី

និងឧបាយកំណត់កាន់យកអារម្មណ៍ ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា **បល្លង្កំ អាភុជិត្វា** អង្គុយពែនភ្នែន ( ចម្រើនសមាធិ ) ។

ក្នុងបទទាំងនោះ បទថា **បល្លង្កំ** គឺ អង្គុយពែនភ្នែន ។ បទថា **អាភុជិត្វា** ពែន គឺ ភ្នែន ។ បទថា **ឧជុំ កាយំ បណិធាយ** តាំងកាយឲ្យត្រង់ គឺ តាំងសរីរៈខាងលើឲ្យត្រង់ ឲ្យឆ្អឹងកងក្រោយ ១៨ កំណាត់ចុះគ្នា ព្រោះកាលអង្គុយយ៉ាងនេះ ស្បែក សាច់ សសៃ នឹងមិនកោងចុះ វេទនាដែលកើតឡើងគ្រប់ ៗ ខណៈ ព្រោះស្បែក សាច់ និងសសៃកោងចុះជាហេតុមិនឲ្យកើតឡើងដល់ភិក្ខុនោះ កាលវេទនាមិនកើត ចិត្តក៏មានអារម្មណ៍តែមួយ កម្មដ្ឋានមិនវិនាស រមែងចូលដល់ភាពចម្រើនលូតលាស់ ។ បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** តម្រង់សតិទុកចំពោះមុខ គឺ តម្រង់សតិចំពោះកម្មដ្ឋាន ។ បទថា **សោ សតោវ អស្សសតិ សតោ បស្សសតិ** ភិក្ខុនោះជាអ្នកមានសតិ ដកដង្ហើមចូល ជាអ្នកមានសតិ ដកដង្ហើមចេញ គឺ ភិក្ខុនោះ កាលអង្គុយយ៉ាងនេះ និងតាំងសតិទុកយ៉ាងនេះ កាលមិនលះសតិនោះ ឈ្មោះថា ជាអ្នកមានសតិដកដង្ហើមចូល មានសតិដកដង្ហើមចេញ ។ លោកអធិប្បាយថា ជាអ្នកតាំងសតិ ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងដល់



ប្រការដែលភិក្ខុតាំងសតិ ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា **ទីឃំ វា អស្សសន្តោ** កាលដកដង្ហើមចូលវែង ។

ក្នុងបទទាំងនោះ បទថា **ទីឃំ វា អស្សសន្តោ** កាលដកដង្ហើមចូលវែង គឺ ខ្យល់ដកដង្ហើមចូលប្រព្រឹត្តទៅវែង ។ ដកដង្ហើមចូលខ្លីក៏ដូច្នោះ ។ ម្យ៉ាងទៀត គប្បីជ្រាបការដែលខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញវែង និងខ្លីដោយកាល ។

ពិតណាស់ មនុស្សទាំងឡាយ គ្រាខ្លះដកដង្ហើមចូល និងដកដង្ហើមចេញវែង ដូចដំរី និងពស់ជាដើម គ្រាខ្លះដកដង្ហើមចូល-ចេញខ្លី ដូចសុនខ និងទន្សាយជាដើម ។ ដោយប្រការដទៃ ក្នុងកាលនឿយហត់ , ស្មុគស្មាញ ខ្យល់អស្សាសបស្សាសៈមិនមានវែង និងខ្លី ។ ព្រោះដូច្នោះ ខ្យល់អស្សាសបស្សាសៈ កាលចូល និងចេញ អស់កាលយូរ គប្បីជ្រាបថា វែង , កាលចូល និងចេញក្នុងវេលាខ្លី គប្បីជ្រាបថាខ្លី ។ ក្នុងរឿងនេះ ភិក្ខុនេះ កាលដកដង្ហើមចូល និងដកដង្ហើមចេញវែងដោយអាការ ៩ យ៉ាង ដូចពោលហើយក្នុងពេលមុន រមែងដឹងថា យើងដកដង្ហើមចូល ដកដង្ហើមចេញវែង ។ ខ្លីក៏ដូចគ្នា ។ ម្យ៉ាងទៀត :-

**វណ្ណៈ ៤ គឺ វែង ខ្លី ខ្យល់អស្សាសៈ និងបស្សាសៈ ដូច្នោះ**
**រមែងប្រព្រឹត្តទៅ លើចុងច្រមុះរបស់ភិក្ខុអ្នកដឹង យ៉ាងនោះ ។**

គប្បីជ្រាបថា ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាន រមែងសម្បូរណ៌ដល់ភិក្ខុនោះ ដោយអាការមួយ នៃអាការ ៩ យ៉ាង ។

បទថា **សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុរមែងសិក្សាថា ជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួង ហើយដកដង្ហើមចូល រមែងសិក្សាថា នឹងជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួង ហើយដកដង្ហើមចេញ គឺ ភិក្ខុរមែងសិក្សាថា យើងនឹងធ្វើខាងដើម កណ្តាល និងទីបំផុតនៃកងខ្យល់អស្សាសៈទាំងអស់ឲ្យដឹងច្បាស់ ធ្វើឲ្យប្រាកដ ទើបដកដង្ហើមចូល រមែងសិក្សាថា យើងនឹងធ្វើខាងដើម កណ្តាល និងទីបំផុតនៃកងបស្សាសៈទាំងអស់ឲ្យដឹងច្បាស់ ឲ្យប្រាកដ ទើបដកដង្ហើមចេញ ។ ភិក្ខុធ្វើឲ្យដឹងច្បាស់ ឲ្យប្រាកដយ៉ាងនេះ ដកដង្ហើមចូល និងដកដង្ហើមចេញដោយចិត្តសម្បយុត្តដោយញាណ ។ ព្រោះដូច្នោះ លោកទើបពោលថា **អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ** រមែងសិក្សាថា យើងនឹងដកដង្ហើមចូល យើងនឹងដកដង្ហើមចេញ ។ ពិតណាស់ ខាងដើមក្នុងកងខ្យល់អស្សាសៈ ឬក្នុងកងខ្យល់បស្សាសៈ ដែលជារបស់ល្អិត ៗ បក់ទៅរបស់ភិក្ខុនោះ រមែងប្រាកដពីកណ្តាល ទីបំផុតមិនប្រាកដ ។ ភិក្ខុនោះរមែងកំណត់កាន់យកខាងដើមប៉ុណ្ណោះ រមែងលំបាកក្នុងកណ្តាល



និងទីបំផុត ។ ភិក្ខុមួយរូប កណ្តាលប្រាកដ ខាងដើម និងទីបំផុតមិនប្រាកដ ។ ភិក្ខុរូបនោះ អាចកំណត់កាន់យកកណ្តាលប៉ុណ្ណោះ រមែងលំបាកក្នុងខាងដើម និងទីបំផុត ។ ភិក្ខុមួយរូប ទីបំផុតប្រាកដ ខាងដើម និងកណ្តាលមិនប្រាកដ ។ ភិក្ខុរូបនោះ អាចកំណត់កាន់យកទីបំផុតប៉ុណ្ណោះ រមែងលំបាកក្នុងខាងដើម និងកណ្តាល ។ ភិក្ខុមួយរូបប្រាកដទាំងអស់ ភិក្ខុរូបនោះ អាចកំណត់កាន់យកសូម្បីទាំងអស់បាន មិនលំបាកក្នុងទីណា ៗ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលនឹងត្រាស់សម្តែងថា គួរដូច្នោះ ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា **សព្វកាយប្បដិសំវេទី** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សិក្ខតិ** រមែងសិក្សា គឺ ព្យាយាមយ៉ាងនេះ ។ គប្បីជ្រាបសេចក្តីក្នុងបទនេះ យ៉ាងនេះថា ភិក្ខុរមែងសិក្សា រមែងសេព រមែងចម្រើន រមែងធ្វើឲ្យច្រើននូវសិក្ខា ៣ ទាំងនេះ គឺ សេចក្តីសង្រួមរបស់អ្នកយ៉ាងនោះ ឈ្មោះថា អធិសីលសិក្ខា សមាធិរបស់អ្នកយ៉ាងនោះ ឈ្មោះថា អធិចិត្តសិក្ខា បញ្ញារបស់អ្នកយ៉ាងនោះ ឈ្មោះថា អធិប្បញ្ញាសិក្ខា ក្នុងអារម្មណ៍ដោយសតិនោះ ដោយមនសិការនោះ ។

ក្នុងបទនោះ គួរនឹងដកដង្ហើមចូល និងដកដង្ហើមចេញតែម្យ៉ាង

ដោយន័យមុន មិនគួរធ្វើអ្វីៗ យ៉ាងដទៃ ចាប់ផ្តើមពីនោះ គួរធ្វើសេចក្តីព្យាយាមក្នុងការឲ្យញាណកើតឡើងជាដើម ព្រោះដូច្នោះ ដើម្បីសម្តែងអាការដែលញុាំងញាណឲ្យកើតឡើង ដែលលោកពោលដល់បាលីដោយអំណាចនៃបច្ចុប្បន្នកាលថា **អស្សស្សាមីតិ បជានាតិ បស្សស្សាមីតិ បជានាតិ** ភិក្ខុរមែងដឹងថា យើងដកដង្ហើមចូល រមែងដឹងថា យើងដកដង្ហើមចេញ ហើយគួរធ្វើតាំងអំពីនេះទៅ គប្បីជ្រាបថា លោកលើកបាលីឡើងដោយអំណាចនៃអនាគត ដោយន័យមានជាអាទិ៍ថា **សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ** យើងនឹងជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួងទើបដកដង្ហើមចូល ដូច្នេះ ។

បទថា **បស្សម្ភយំ កាយសង្ខារំ ។បេ។ សិក្ខតិ** រមែងសិក្សាថា នឹងរម្ងាប់កាយសង្ខារ ។ បេ ។ គឺ រមែងសិក្សាថា យើងរម្ងាប់ ស្ងប់រំលត់ និងចូលទៅស្ងប់កាយសង្ខារ ពោលគឺ ខ្យល់អស្សាសបស្សាសៈគ្រោតគ្រាតដកដង្ហើមចូល ដកដង្ហើមចេញ ។ ក្នុងបទនោះ គប្បីជ្រាបដល់សភាពគ្រោតគ្រាត ល្អិត និងស្ងប់ ដោយប្រការយ៉ាងនោះ ។

ក្នុងកាលភិក្ខុមិនបានកំណត់កាន់យកមុន កាយ និងចិត្ត រមែងខ្វល់ខ្វាយ និងជារបស់គ្រោតគ្រាត កាលកាយ និងចិត្តគ្រោតគ្រាតមិនស្ងប់ សូម្បីខ្យល់អស្សាសៈ ខ្យល់បស្សាសៈក៏គ្រោតគ្រាតផង ខ្យល់



អស្សាសបស្សាសៈមានកម្លាំងជាងនឹងប្រព្រឹត្តទៅ ច្រមុះមិនល្មម នឹងត្រូវដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះតាមមាត់ ម្យ៉ាងទៀត កាលណាកាយខ្លះ ចិត្តខ្លះ ដែលភិក្ខុនោះកំណត់កាន់យក កាលនោះខ្យល់អស្សាសបស្សាសៈទាំងនោះស្ងប់រម្ងាប់ កាលខ្យល់អស្សាសបស្សាសៈទាំងនោះស្ងប់ ខ្យល់អស្សាសបស្សាសៈល្អិតនឹងប្រព្រឹត្តទៅ រមែងដល់អាការដែលគួរពិចារណាថា ខ្យល់អស្សាសបស្សាសៈមាន ឬមិនមាន ។ ដូចកាលបុរសរត់ចុះពីភ្នំ ឬដាក់របស់ធ្ងន់ចុះពីសីសៈ ហើយឈប់នៅ ខ្យល់អស្សាសបស្សាសៈក៏គ្រោតគ្រាត ច្រមុះក៏មិនល្មម ត្រូវឈរដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះតាមមាត់ ។

ម្យ៉ាងទៀត កាលណាបុរសនោះធូរស្រាលការនឿយហត់ហើយ ងូតទឹក ផឹកទឹក យកសំពត់សាដកសើមគ្របទ្រូង ដេកក្រោមម្លប់ត្រជាក់ កាលនោះខ្យល់អស្សាសបស្សាសៈរបស់បុរសនោះ ល្អិត រមែងដល់អាការដែលគួរពិចារណាថា ខ្យល់អស្សាសបស្សាសៈ មាន ឬមិនមាន យ៉ាងណា គប្បីឲ្យពិស្តារថា ក្នុងកាលដែលភិក្ខុកំណត់កាន់យកយ៉ាងនោះ ក៏ដូច្នោះ ។

ពិតយ៉ាងនោះ ក្នុងកាលដែលភិក្ខុនោះ មិនកំណត់កាន់យកមុន ការចងចិត្ត ការរួបរួម និងការធ្វើទុកក្នុងចិត្ត យើងរមែងស្ងប់កាយ-

សង្ខារគ្រោតគ្រាត ៗ ដូច្នេះ រមែងមិនមាន ។ ក្នុងកាលកំណត់កាន់យកមាន ។ ដោយហេតុនោះ ក្នុងកាលដែលភិក្ខុនោះ កំណត់កាន់យកពីការមិនបានកំណត់កាន់យក កាយសង្ខារជារបស់ល្អិត ដូចព្រះបោរាណាចារ្យទាំងឡាយពោលទុកថា :-

**កាលកាយនិងចិត្តរំជួល កាយសង្ខាររមែងប្រព្រឹត្តទៅគ្រោតគ្រាត ។ កាលកាយមិនរំជួល កាយសង្ខាររមែងប្រព្រឹត្តទៅយ៉ាងសុខុម ។**

សូម្បីក្នុងកាលកំណត់កាន់យកកាយសង្ខារគ្រោតគ្រាត ក្នុងឧបចារៈនៃកម្មដ្ឋានបឋមជ្ឈាន កាយសង្ខារសុខុម ។ សូម្បីឧបចារៈក្នុងបឋមជ្ឈាននោះ កាយសង្ខារក៏នៅគ្រោតគ្រាត ក្នុងបឋមជ្ឈាន ទើបសុខុម ។ ក្នុងបឋមជ្ឈាន និងឧបចារៈនៃទុតិយជ្ឈាន កាយសង្ខារក៏នៅគ្រោតគ្រាត ក្នុងទុតិយជ្ឈានទើបសុខុម ។ ក្នុងទុតិយជ្ឈាន និងឧបចារៈនៃតតិយជ្ឈាន ក៏នៅគ្រោតគ្រាត ក្នុងតតិយជ្ឈានទើបសុខុម ។ ក្នុងតតិយជ្ឈាន និងក្នុងឧបចារៈនៃចតុត្ថជ្ឈានក៏គ្រោតគ្រាត ក្នុងចុតត្ថជ្ឈានទើបសុខុមក្រៃលែង រមែងដល់ការមិនប្រព្រឹត្តទៅទៀតឡើយ ។ នេះជាមតិរបស់លោកអ្នកពោលទីឃភាណកសំយុត្ត ។

ចំណែកលោកមជ្ឈិមកភាណកាចារ្យ រមែងប្រាថ្នាសេចក្តីល្អិតជាង



សូម្បីក្នុងឧបចារៈនៃឈានខ្ពស់ ៗ ចាកឈានទាប ៗ យ៉ាងនេះថា ក្នុងបឋមជ្ឈាននៅគ្រោតគ្រាត ក្នុងឧបចារៈនៃទុតិយជ្ឈានទើបល្អិត ។ តាមមតិរបស់លោកភាណកាចារ្យទាំងពួង កាយសង្ខារដែលប្រព្រឹត្តទៅហើយក្នុងកាលមិនបានកំណត់កាន់យក រមែងស្ងប់ក្នុងកាលដែលកំណត់កាន់យកកាយសង្ខារដែលប្រព្រឹត្តទៅហើយ ក្នុងការកំណត់កាន់យករមែងស្ងប់ក្នុងឧបចារៈនៃបឋមជ្ឈាន ។បេ។ កាយសង្ខារដែលប្រព្រឹត្តទៅហើយក្នុងឧបចារៈនៃចតុត្ថជ្ឈាន រមែងស្ងប់ក្នុងចតុត្ថជ្ឈាន ។ នេះជាន័យក្នុងសមថៈប៉ុណ្ណោះ ។

ចំណែកក្នុងវិបស្សនា កាយសង្ខារដែលប្រព្រឹត្តទៅហើយក្នុងកាលមិនបានកំណត់កាន់យកនៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យកមហាភូតរូប ទើបល្អិត ។ សូម្បីកាយសង្ខារនោះ ក៏នៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យកឧបាទាយរូប ទើបល្អិត ។ សូម្បីដូច្នេះក៏នៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យករូបទាំងអស់ទើបល្អិត ។ សូម្បីដូច្នោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់កាន់យកអរូបទើបល្អិត ។ សូម្បីដូច្នោះ ក៏នៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យករូប និងអរូបទើបល្អិត ។ សូម្បីដូច្នោះ ក៏គ្រោតគ្រាត ក្នុងកាលកំណត់កាន់យកបច្ច័យទើបល្អិត ។ សូម្បីដូច្នោះ ក៏នៅគ្រោតគ្រាត ក្នុងកាកោន់យកនាមរូបព្រមជាមួយ

បច្ច័យទើបល្អិត ។ សូម្បីដូច្នោះ ក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលមានលក្ខណៈជាអារម្មណ៍ ទើបល្អិត ។ សូម្បីដូច្នោះ ក៏ឈ្មោះថា នៅគ្រោតគ្រាត ព្រោះជាវិបស្សនាទន់ខ្សោយ ក្នុងវិបស្សនាមានកម្លាំងទើបល្អិត ។ គប្បីជ្រាបការស្ងប់នៃកាយសង្ខារមុន ៗ ដោយកាយសង្ខារក្រោយ ៗ ដោយន័យដូចពោលហើយក្នុងកាលមុននោះឯង ។ ក្នុងបទនេះ គប្បីជ្រាបសភាពដែលកាយសង្ខារគ្រោតគ្រាត និងល្អិត និងសេចក្ដីស្ងប់យ៉ាងនេះ ។ នេះជាការពណ៌នាបទតាមលំដាប់នៃបឋមចតុក្កៈដែលលោកពោលទុកហើយ ដោយអំណាចនៃកាយានុបស្សនាក្នុងទីនេះ ។

ក៏ព្រោះក្នុងទីនេះ លោកពោលចតុក្កៈនេះ ដោយអំណាចនៃកម្មដ្ឋាននៃអាទិកម្មិកៈ ។ ចំណែកចតុក្កៈ ៣ ក្រៅពីនេះ លោកពោលទុកដោយអំណាចនៃវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនា ។ ដូច្នោះ កុលបុត្តអ្នកជាអាទិកម្មិកៈ បំណងនឹងចម្រើនកម្មដ្ឋាននេះហើយសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា នៃវិបស្សនាដែលជាបទដ្ឋានរបស់ចតុក្កឈាន ។ ធ្វើកិច្ចទាំងពួង មានញុំាងសីលឲ្យបរិសុទ្ធជាដើម ដោយន័យដូចពោលហើយក្នុងវិសុទ្ធមគ្គ ហើយគប្បីរៀនយកកម្មដ្ឋានដែលមានសន្ធិ ( ការជាប់ត ) ៥ ក្នុងសម្នាក់របស់អាចារ្យអ្នកប្រកបដោយអង្គ ៧ ។



សន្ធិ ៥ ទាំងនេះ គឺ ការរៀន ១ សាកសួរ ១ ការប្រាកដ ១ ការនែបនិត្យ ១ លក្ខណៈ ១ ។

ក្នុងសន្ធិទាំងនោះ ការរៀនកម្មដ្ឋាន ឈ្មោះថា **ឧគ្គហ** ។ ការសាកសួរកម្មដ្ឋាន ឈ្មោះថា **បរិបុច្ឆា** ។ ការប្រាកដនៃកម្មដ្ឋាន ឈ្មោះថា **ឧបដ្ឋាន** ។ ការនែបនិត្យនៃកម្មដ្ឋាន ឈ្មោះថា **អប្បនា** ។ លក្ខណៈនៃកម្មដ្ឋាន ឈ្មោះថា **លក្ខណ** ។ លោកអធិប្បាយទុកថា កម្មដ្ឋាននេះជាលក្ខណៈយ៉ាងនេះ បានដល់ ការពិចារណាសភាពរបស់កម្មដ្ឋាន ។

កុលបុត្តអ្នករៀនកម្មដ្ឋាន មានសន្ធិ ៥ យ៉ាងនេះ សូម្បីខ្លួនក៏មិនលំបាក សូម្បីអាចារ្យក៏មិនលំបាក ព្រោះដូច្នោះ ឲ្យអាចារ្យលើកឡើងបន្តិចហើយ ប្រើវេលាទន្ទេញឲ្យច្រើន រៀនកម្មដ្ឋានមានសន្ធិ ៥ យ៉ាងនេះ វៀរទីនៅដែលប្រកបដោយទោស ១៨ យ៉ាង ក្នុងសម្នាក់នៃអាចារ្យ ឬក្នុងទីដទៃ ហើយនៅក្នុងសេនាសនៈប្រកបដោយអង្គ ៥ កាត់បលិពោធបន្តិចបន្តួច បរិភោគស្រេចហើយបន្ទូរការស្រវឹងអាហារ អង្គុយឲ្យសប្បាយ រលឹកដល់គុណព្រះរតនត្រ័យ ធ្វើចិត្តឲ្យរីករាយ មិនឲ្យសាបសូន្យសូម្បីតែបទមួយ ចាកការរៀនពីអាចារ្យ គប្បីធ្វើអានាបានស្សតិកម្មដ្ឋាននេះ ទុកក្នុងចិត្ត ។

តទៅនេះជាវិធីមនសិការកម្មដ្ឋាន គឺ :

**គណនា ( ការរាប់ ) អនុពន្ធនា ( ការជាប់តាម ) ផុសនា ( ការបះពាល់ ) ការតាំងទុក ការឃើញច្បាស់ ការចម្រើន សេចក្តីបរិសុទ្ធិ ការពិចារណាកម្មដ្ឋានទាំងឡាយនោះ ។**

ក្នុងបទទាំងនោះ បទថា **គណនា** គឺ ការរាប់នោះឯង ។ បទថា **អនុពន្ធនា** គឺ ការទៅតាម ។ បទថា **ផុសនា** គឺ ការពាល់ត្រូវ ។ បទថា **ឋបនា** គឺ អប្បនា ។ បទថា **សល្លក្ខណា** គឺ ការឃើញច្បាស់ ។ បទថា **វិវដ្ដនា** គឺ មគ្គ ។ បទថា **បរិសុទ្ធិ** គឺ ផល ។ បទថា **តេសញ្ច បដិបស្សនា** គឺ ការពិចារណាកម្មដ្ឋានទាំងនោះ ។

ក្នុងបទនោះ កុលបុត្តជាអាទិកម្មិកៈនេះ គប្បីដាក់ចិត្តក្នុងកម្មដ្ឋាននេះដោយការរាប់មុន ។ កាលរាប់មិនគួរឲ្យតិចជាង ៥ មិនគួរច្រើនជាង ១០ មិនគួរសម្តែងជាផ្នែកៗ ក្នុងរវាងចន្លោះ , ការរាប់តិចជាង ៥ ចិត្តុប្បាទរមែងរើបម្រះ ក្នុងឱកាសចង្អៀត ដូចហ្វូងគោដែលត្រូវឃាំងទុកក្នុង ក្រោលដែលចង្អៀត , កាលរាប់លើសពី ១០ ចិត្តុប្បាទអាស្រ័យការរាប់ប៉ុណ្ណោះ កាលសម្តែងជាផ្នែក ៗ ក្នុងចន្លោះ , ចិត្តរមែងញាប់ញ័រថា កម្មដ្ឋានរបស់យើងដល់កំពូលហើយឬនៅហ្ន៎ ព្រោះដូច្នោះ គួររាប់វៀរទោសទាំងនេះចេញ ។

ម្យ៉ាងទៀត កាលរាប់ គួររាប់ដូចជាការវាល់ស្រូវរាប់យឺត ៗ មុនសិន ព្រោះវាល់ស្រូវឲ្យពេញនាឡិ ហើយរាប់មួយ ហើយចាក់ចុះ កាលពេញទៀត គ្រាឃើញសម្រាមណាមួយ ៗ ក៏រើសចោល ទើបរាប់ថា មួយ មួយ ។ សូម្បីក្នុងកាលរាប់ថា ពីរ ពីរ ក៏មានន័យនេះ ដូចគ្នា ។



បុគ្គលណាកំណត់ខ្យល់អស្សាសបស្សាសៈ សូម្បីដោយវិធីនេះ យ៉ាងនេះ កំណត់រាប់ថា មួយ មួយ ទៅរហូតដល់ ដប់ ដប់ កាលបុគ្គលនោះរាប់យ៉ាងនេះ ខ្យល់អស្សាសបស្សាសៈទាំងចូល និងចេញ រមែងប្រាកដ ។ បន្ទាប់ពីនោះ កុលបុត្តគួរលះការរាប់ដូចការវាល់ស្រូវដែលរាប់យឺត ៗ នោះចេញ ហើយរាប់ដោយការរាប់របស់មនុស្សចិញ្ចឹមគោ គឺ រាប់លឿន ព្រោះគោបាលអ្នកឆ្លាត យកដុំគ្រួសដាក់ថ្នក់កាន់ខ្សែ និងរំពាត់ទៅកាន់ក្រោលអំពីព្រលឹម វាយគោត្រង់ខ្នងហើយអង្គុយលើចុងសសរ ដាក់ដុំគ្រួស រាប់គោដែលទៅដល់ទ្វារថា មួយ ពីរ ។ គោដែលនៅលំបាកក្នុងទីចង្អៀតមករហូត ៣ យាម ទើបចេញប្រជៀតគ្នានឹងគ្នា ប្រញាប់ចេញជាពួក ៗ ។ គោបាលនោះ ប្រញាប់រាប់ថា បី បួន ប្រាំ ។ល។ ដប់ ។ កាលគោបាលនោះរាប់ដោយន័យមុន ខ្យល់អស្សាសបស្សាសៈប្រាកដសញ្ចរទៅលឿន និងរឿយ ៗ ។

លំដាប់នោះ គោបាលកាលដឹងថា ខ្យល់អស្សាសបស្សាសៈសញ្ចររឿយ ៗ ទើបមិនរាប់ទាំងខាងក្នុងទាំងខាងក្រៅ រាប់ចំពោះដែល

ដល់ទ្វារប៉ុណ្ណោះ ហើយប្រញាប់រាប់យ៉ាងលឿន ៗ ថា ១ ២ ៣ ៤ ៥ , ១ ២ ៣ ៤ ៥ ៦ , ១ ២ ៣ ៤ ៥ ៦ ៧ ។ល។ ៨ ៩ ១០ ។

ពិតណាស់ ក្នុងកម្មដ្ឋានដែលជាប់ដោយការរាប់ចិត្ត រមែងមានអារម្មណ៍តែមួយដោយកម្លាំងនៃការរាប់ ដូចការចតទូកទុកត្រង់ក្រសែទឹកហូរត្របាញ់ ដោយការយកថ្នោលទប់ ដូច្នោះ ។

កាលកុលបុត្តរាប់លឿន ៗ យ៉ាងនេះ កម្មដ្ឋានរមែងប្រាកដដូចប្រព្រឹត្តទៅជាប់តគ្នា កាលដឹងថា កម្មដ្ឋានប្រព្រឹត្តទៅជាប់តគ្នា ហើយមិនកំណត់កាន់យកខ្យល់ខាងក្នុង និងខាងក្រៅប្រញាប់រាប់ដោយន័យមុននោះឯង កាលចិត្តចូលទៅព្រមជាមួយខ្យល់ចូលទៅខាងក្នុង ចិត្តប៉ះខ្ទប់ជាមួយខ្យល់ខាងក្នុង រមែងដូចជាពេញដោយខ្លាញ់ខាប់ កាលនាំចិត្តចេញព្រមជាមួយខ្យល់ចេញខាងក្រៅ ចិត្តរមែងរាយមាយទៅក្នុងអារម្មណ៍ភាពក្រាស់ក្នុងខាងក្រៅ ។ មយ៉ាងទៀត កាលចម្រើនវៀរសតិក្នុងឱកាសបះពាល់ត្រូវហើយ ភាវនារមែងបរិបូរណ៍ ដោយហេតុនោះ លោកទើបពោលថា មិនគប្បីកំណត់ចាប់យកខ្យល់ខាងក្នុង និងខ្យល់ខាងក្រៅហើយប្រញាប់រាប់ដោយន័យមុននោះឯង ។

ក៏ចិត្តនេះគួររាប់យូរត្រឹមណា នៅរហូតកាលអារម្មណ៍នៃអស្សាសបស្សាសៈនៅមាន វៀរការរាប់ចិត្ត រមែងតាំងនៅ កាលអារម្មណ៍នៃ



អស្សាសបស្សាសៈនៅមាន ការរាប់ដើម្បីឲ្យចិត្តតាំងនៅ ធ្វើការកាត់វិតក្កៈដែលផ្សាយទៅក្នុងខាងក្រៅចេញ គួរធ្វើទុកក្នុងចិត្ត ដោយការរាប់យ៉ាងនេះហើយ ធ្វើទុកក្នុងចិត្តដោយការជាប់តាម ។ ការរួបរួមការាប់ ហើយជាប់តាមខ្យល់អស្សាសបស្សាសៈ ក្នុងលំដាប់នៃសតិឈ្មោះថា **អនុពន្ធនា** ( ការជាប់តាម ) ។ ការាប់នោះមិនមែន ដោយអំណាចនៃការជាប់តាមក្នុងខាងដើម កណ្តាល និងខាងចុង ។ ខាងដើម កណ្តាល និងខាងចុង ហើយនិងទោសក្នុងការជាប់តាមការរាប់នោះ ពាក់កណ្តាលពោលទុកហើយក្នុងខាងក្រោយនោះឯង ។

ព្រោះដូច្នោះ កាលមនសិការដោយការជាប់តាម មិនគួរដាក់ចិត្តដោយអំណាចនៃខាងដើម កណ្តាល និងខាងចុង ។ មយ៉ាងវិញទៀត គួរដាក់ចិត្តដោយអំណាចនៃការពាល់ត្រូវ និងដោយអំណាចនៃការនៃបនិត្យ ព្រោះថា មិនមានការដាក់ចិត្តផ្សេងដោយអំណាចនៃការពាល់ត្រូវ និងការនៃបនិត្យ ដូចដោយអំណាចនៃការរាប់ និងការជាប់តាម ។ មយ៉ាងទៀត កាលរាប់ក្នុងទីដែលពាល់ត្រូវហើយ រមែងដាក់ចិត្តដោយការរាប់ និងដោយការពាល់ត្រូវ រួបរួមការរាប់ក្នុងទីដែលពាល់ត្រូវនោះ ហើយជាប់តាមការរាប់ និងការពាល់ត្រូវទាំងនោះ ដោយសតិ និងដម្កល់ចិត្តទុកដោយអំណាចនៃអប្បនា លោកពោលថា រមែងដាក់ចិត្តដោយការ

ជាប់តាម ដោយការពាល់ត្រូវ និងដោយការនែបនិត្យ ។ គប្បីជ្រាបសេចក្តីនោះ ដោយការឧបមាដោយមនុស្សពិការ និងមនុស្សរក្សាទ្វារ ដូចដែលលោកពោលទុកក្នុងអដ្ឋកថាទាំងឡាយ និងដោយឧបមាដោយរណា ដូចដែលលោកពោលទុកហើយក្នុងបាលីនេះឯង ។ តទៅនេះជាឧបមាដោយមនុស្សពិការ ។ ប្រៀបដូចមនុស្សពិការ យោលទោងដល់មាតា និងបុត្តដែលកំពុងលេងទោង អង្គុយនៅត្រង់គល់សសរទោងនោះឯង រមែងឃើញទីបំផុតទាំងពីរ និងកណ្តាលរបស់ក្តារទោង ដែលយោលទៅមកតាមលំដាប់ មិនខ្វល់ខ្វាយដើម្បីនឹងមើលទីបំផុតទាំងពីរ និងកណ្តាល យ៉ាងណា ភិក្ខុក៏ដូច្នោះ ដូចគ្នានឹងការនៅត្រង់គល់សសរ គឺ ការជាប់តាមដោយអំណាចនៃសតិ ហើយអង្គុយយោលទោង គឺ ខ្យល់អស្សាសៈ និងបស្សាសៈដោយសតិក្នុងនិមិត្តនោះ ជាប់តាមខាងដើម កណ្តាល និងខាងចុងរបស់ខ្យល់អស្សាសៈ និងបស្សាសៈ ក្នុងកន្លែងដែលពាល់ត្រូវទាំងទៅនិងមកដោយសតិ ដម្កល់ចិត្តទុកក្នុងកន្លែងនោះ រមែងឃើញ និងមិនខ្វល់ខ្វាយដើម្បីនឹងមើលខ្យល់អស្សាសៈ និងបស្សាសៈទាំងនោះ នេះជាឧបមាដោយមនុស្សពិការ ។

ចំណែកឧបមាដោយមនុស្សរក្សាទ្វារដូច្នេះ ប្រៀបដូចមនុស្សរក្សាទ្វារ រមែងមិនសាកសួរមនុស្សខាងក្នុង និងខាងក្រៅព្រះនគរថា លោក



ជានរណា មកពីណា និងទៅណា អ្វីក្នុងដៃរបស់លោក ព្រោះមនុស្សទាំងនោះមិនមែនជាមុខនាទីរបស់គេ តែគេសាកសួរចំពោះមនុស្សដែលមកដល់ទ្វារហើយប៉ុណ្ណោះ យ៉ាងណា ខ្យល់ចូលទៅខាងក្នុង និងខ្យល់ចេញទៅខាងក្រៅ មិនមែនជាភារៈរបស់ភិក្ខុនោះ ដូច្នោះដូចគ្នា ខ្យល់ដែលដល់ទ្វារប៉ុណ្ណោះ ទើបជាភារៈ នេះជាឧបមាដោយមនុស្សរក្សាទ្វារ ។

ចំណែកឧបមាដោយរណាបានពោលទុកហើយក្នុងអានាបានស្សតិកថា ដោយន័យមានជាអាទិ៍ថា **និមិត្តំ អស្សាសបស្សាសា** និមិត្តខ្យល់អស្សាសៈ និងខ្យល់បស្សាសៈ ។ ប៉ុន្តែក្នុងទីនេះ គប្បីជ្រាបថាជាការប្រកបត្រឹមតែការមិនដាក់ចិត្តដោយអំណាចនៃការមក និងការទៅរបស់រណានោះប៉ុណ្ណោះ ។

កាលនរណា ៗ មនសិការកម្មដ្ឋាននេះមិនយឺត និមិត្តរមែងកើត ។ និងការនែបនិត្យ ពោលគឺ អប្បនាប្រដាប់ដោយអង្គឈានដ៏សេសរមែងសម្បូរណ៍ ។ ចាប់ផ្តើមពីកាលមនសិការ ដោយការរាប់របស់នរណា ៗ ប្រៀបដូចអ្នកមានកាយសោប់សេល់អង្គុយលើគ្រែ ឬតាំង គ្រែ និងតាំងរមែងបន្ទោនចុះ រមែងឃ្មោង គ្រឿងក្រាលរមែងរួញ ចំណែកអ្នកមានកាយមិនសោប់សេល់អង្គុយ គ្រែ និងតាំង រមែងមិនឃ្មោង មិនកោងងគ្រឿងក្រាលមិនរួញ គ្រែ និងតាំង រមែងពេញដោយសំឡី ព្រោះហេតុ

អ្វី ព្រោះអ្នកមានកាយមិនរសាប់រសល់ ស្រាល យ៉ាងណា ចាប់ផ្តើមពីកាលមនសិការ ដោយការរាប់យ៉ាងនោះក៏ដូច្នោះ កាលបើសេចក្តីក្រវល់ក្រវាយ កាយស្ងប់ដោយអំណាចនៃការរលត់ខ្យល់អស្សាសៈ និងបស្សាសៈយ៉ាងគ្រោតគ្រាតតាមលំដាប់ កាយក្តី ចិត្តក្តីជារបស់ស្រាលរាងកាយដូចជាអណ្តែតទៅលើអាកាស ។

កាលខ្យល់អស្សាសៈ និងបស្សាសៈយ៉ាងគ្រោតគ្រាតរបស់ភិក្ខុនោះរលត់ហើយ ចិត្តមានខ្យល់អស្សាសបស្សាសៈល្អិតជានិមិត្ត ជាអារម្មណ៍ រមែងប្រព្រឹត្តទៅ ។ សូម្បីកាលចិត្តនោះរលត់ ខ្យល់អស្សា-សបស្សាសៈដែលជានិមិត្ត ជាអារម្មណ៍ល្អិតជាងនោះនៅប្រព្រឹត្តទៅមក ៗ នោះឯង ។ គប្បីជ្រាបសេចក្តីនេះ ដោយឧបមាដោយថាសលោហៈ ដូចពោលហើយក្នុងពេលមុន ។

កម្មដ្ឋាននេះមិនដូចកម្មដ្ឋានពួកដទៃ ដែលជាក់ច្បាស់ហើយក្រៃ-លែងឡើង ៗ ទៅ ក៏កម្មដ្ឋាននេះ រមែងដល់សភាពល្អិតដល់អ្នកចម្រើនក្រៃលែងឡើង ៗ សូម្បីការប្រាកដក៏មិនដល់ កាលកម្មដ្ឋាននោះមិនប្រាកដយ៉ាងនេះ ភិក្ខុនោះមិនគួរក្រោលចាកអាសនៈទៅ ដោយគិតថាយើងនឹងសួរអាចារ្យ ឬថា ឥឡូវនេះកម្មដ្ឋានរបស់យើងវិនាសហើយដូច្នេះ ព្រោះកាលភិក្ខុញុំាងឥរិយាបថឲ្យកម្រើកហើយទៅ កម្មដ្ឋានរមែង



មានថ្មី ៗ ដោយពិត ព្រោះដូច្នោះ គួរនាំកម្មដានមក ចាកកន្លែងដែលអង្គុយហើយនោះឯង ។

តទៅនេះជាឧបាយនាំកម្មដ្ឋានមក ភិក្ខុនោះដឹងសេចក្តីនៃកម្មដ្ឋានមិនប្រាកដ គប្បីពិចារណាសិក្សាយ៉ាងនេះថា ឈ្មោះថា ខ្យល់អស្សា-សបស្សាសៈទាំងនេះមាននៅត្រង់ណា មិនមានត្រង់ណា មានដល់នរណាឬមិនមានដល់នរណា ។ កាលភិក្ខុពិចារណាយ៉ាងនេះ ដឹងថា ខ្យល់អស្សាសបស្សាសៈទាំងនេះមិនមានដល់មនុស្សនៅក្នុងគភ៌មាតា មិនមានដល់អ្នកមុជទឹក ដល់អសញ្ញីសត្វ មនុស្សស្លាប់ អ្នកចូលចតុត្ថជ្ឈានរួមអ្នកនៅក្នុងរូបភព អរូបភព អ្នកចូលនិរោធ ហើយគប្បីដាស់តឿនដោយខ្លួនឯងយ៉ាងនេះថា ម្នាលបណ្ឌិត លោកមិនបាននៅក្នុងគភ៌មាតាមិនបានមុជទឹក មិនមែនជាអសញ្ញីសត្វ មិនមែនស្លាប់ មិនបានចូលចតុត្ថជ្ឈាន មិនបានរស់នៅក្នុងរូបភព អរូបភព មិនបានចូលនិរោធមិនមែនឬ ។ ខ្យល់អស្សាសបស្សាសៈ របស់លោកនៅមានពិត ៗ តែលោកមិនអាចកំណត់ចាប់យកបាន ព្រោះលោកមានបញ្ញាទន់ខ្សោយ ។

តមកភិក្ខុនោះគួរតាំងចិត្ត ដោយសម្ពស្សជាប្រក្រតីហើយ ញុំាងមនសិការឲ្យប្រព្រឹត្តទៅ ។ ព្រោះថា ខ្យល់អស្សាសបស្សាសៈទាំងនេះប៉ះខ្ទប់ក្តោងច្រមុះរបស់អ្នកមានច្រមុះវែងប្រព្រឹត្តទៅ ប៉ះខ្ទប់រីមបបូរមាត់

ខាងលើរបស់អ្នកមានប្រមុះខ្ពស់ ព្រោះដូច្នោះ ភិក្ខុនោះគួរតាំងនិមិត្តថា ខ្យល់អស្សាសបស្សាសៈប៉ះខ្ទប់ត្រង់នេះ ។ ពិតមែន ព្រះមានព្រះភាគជាម្ចាស់ ត្រាស់អាស្រ័យអំណាចនៃប្រយោជន៍ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលដល់ការចម្រើនអានាបានស្សតិរបស់អ្នកមិនមានសតិ អ្នកមិនមានការដឹងដូច្នេះ ។ ពិតមែន កម្មដ្ឋានយ៉ាងណាមួយរមែងសម្បូរណ៍ដល់អ្នកមានសតិ អ្នកមានសម្បជញ្ញៈដោយពិត ប៉ុន្តែកាលមនសិការដទៃពីនេះ កម្មដ្ឋានក៏នៅប្រាកដ ។

ម្យ៉ាងទៀត អានាបានស្សតិកម្មដ្ឋាននេះ ជាការចម្រើនបានយ៉ាងលំបាក ទាំងជាភូមិនៃមនសិការរបស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះពុទ្ធបុត្តអ្នកជាមហាបុរសនោះឯង មិនបានកើតខាងក្រៅពីនេះ ទាំងសត្វក្រៅនេះមិនបានសេព ។ កម្មដ្ឋានជាចំណែកស្ងប់ និងសុខុម ដោយប្រការដែលធ្វើទុកក្នុងចិត្ត ព្រោះដូច្នោះ ក្នុងទីនេះគប្បីប្រាថ្នាសតិ និងបញ្ញាមានកម្លាំង ។

ដូចជា ក្នុងវេលាត្បាញសំពត់សាជកសាច់ម៉ត់ គប្បីត្រូវការសូម្បីម្ជុលដែលល្អិត សូម្បីអំបោះដោតម្ជុល ក៏ត្រូវតែល្អិតជាងនោះយ៉ាងណា ក្នុងវេលាចម្រើនកម្មដ្ឋាននេះ ដូចនឹងសំពត់សាច់ល្អិត ដូច្នោះដូចគ្នា បញ្ញាដែលសម្បយុត្តដោយសតិនោះ ប្រៀបដោយការដោតម្ជុល



ក៏គប្បីប្រាថ្នាដែលមានកម្លាំង ។ ក៏ឯភិក្ខុអ្នកប្រកបដោយសតិបញ្ញាទាំងនោះ មិនគប្បីស្វែងរកខ្យល់អស្សាសបស្សាសៈទាំងនោះ ក្រៅចាកឱកាសដែលពាល់ត្រូវតាមប្រក្រតី ។

ដូចជាអ្នកស្រែភ្ជួរស្រែហើយប្រលែងគោទៅហើយ អង្គុយសម្រាកបរិភោគអាហារ ។ លំដាប់នោះ គោទាំងនោះរបស់គេរត់ចូលព្រៃទៅ ។ អ្នកស្រែដែលជាមនុស្សឆ្លាតប្រាថ្នានឹងចាប់គោទាំងនោះមកទឹមភ្ជួរ ដើរទៅតាមស្នាមជើងរបស់គោទាំងនោះដែលចូលទៅកាន់ព្រៃ ។ គេយកខ្សែនិងជន្ទួញ ទៅកាន់កំពង់ទឹកដែលគោទាំងនោះចុះដោយត្រង់ អង្គុយខ្លះដេកខ្លះ ។ កាលឃើញគោទាំងនោះត្រាច់ទៅរហូតថ្ងៃ ហើយចុះកាន់កំពង់ដែលធ្លាប់ងូត និងផឹកហើយឡើងមកឈរ ទើបយកខ្សែចង យកជន្ទួញចាក់នាំមកទឹមភ្ជួរធ្វើការតទៅយ៉ាងណា ភិក្ខុនោះក៏ដូច្នោះដូចគ្នា មិនគប្បីស្វែងរកខ្យល់អស្សាសបស្សាសៈទាំងនោះ ក្រៅពីឱកាសដែលពាល់ត្រូវតាមប្រក្រតី គប្បីយកខ្សែ គឺ សតិ និងជន្ទួញ គឺ បញ្ញាតាំងចិត្តទុកក្នុងឱកាសដែលពាល់ត្រូវតាមប្រប្រកតី ហើយញុំាងមនសិការឲ្យប្រព្រឹត្តទៅ ។ ក៏កាលភិក្ខុមនសិការយ៉ាងនេះ មិនយូរឡើយ ខ្យល់អស្សាសបស្សាសៈទាំងនោះក៏ប្រាកដ ដូចគោប្រាកដត្រង់កំពង់ដែលធ្លាប់ចុះ លំដាប់នោះ ភិក្ខុនោះ គប្បីចងដោយខ្សែ គឺ សតិ ប្រកបទុក

ក្នុងទីនោះ ហើយចាក់ដោយជន្លួញ គឺ បញ្ញា គប្បីប្រកបកម្មដ្ឋានរឿយ ៗ កាលប្រកបយ៉ាងនេះមិនយឺតយូរឡើយ និមិត្តរមែងប្រាកដ ក៏និមិត្តនោះមិនបានកើតដូចគ្នាតែមួយ នៃនិមិត្តទាំងពួង ។ ម្យ៉ាងវិញទៀត និមិត្តញុំាងសុខសម្ផស្សឲ្យកើតឡើងដល់នរណា ៗ រមែងប្រាកដ ដូចប៉ុយគរប៉ុយកប្បាស និងខ្សែខ្យល់ អាចារ្យពួកខ្លះពោលទុកដូច្នេះ ។

ចំណែកក្នុងអដ្ឋកថាទាំងឡាយមានវិនិច្ឆ័យដូចតទៅនេះ ។ ពិតណាស់ និមិត្តនេះមានរូបស្រដៀងផ្កាយប្រាកដដល់នរណា ៗ ដូចដុំកែវមណី និងដុំកែវមុក្តា មានសម្ផស្សរឹងប្រាកដដល់នរណា ៗ ដូចគ្រាប់កប្បាស និងដូចបំណែកខ្លឹមឈើ ប្រាកដដល់នរណា ៗ ដូចខ្សែសង្វារវែង ដូចក្លួនផ្កាឈើ និងដូចដុំផ្សែង ប្រាកដដល់នរណា ៗ ដូចសសៃពីងពាងដែលលាតសន្ធឹង ដូចដុំពពក ដូចផ្កាបទុម ដូចកង់រថ ដូចមណ្ឌលព្រះច័ន្ទ និងដូចមណ្ឌលព្រះអាទិត្យ ។ ក៏ឯនិមិត្តនោះ កាលភិក្ខុច្រើនរូបអង្គុយស្វាធ្យាយព្រះសូត្រ ភិក្ខុមួយរូបពោលថា ព្រះសូត្រនេះ ប្រាកដដល់លោកទាំងឡាយបែបណា ភិក្ខុមួយរូបពោលថា ប្រាកដដល់ខ្ញុំ ដូចទឹកស្ទឹងហូរពីភ្នំ ។ ម្យ៉ាងទៀតភិក្ខុមួយរូបពោលថា ប្រាកដដល់ខ្ញុំ ដូចដងព្រៃមួយកន្ទែង ។ ភិក្ខុដទៃពោលថា ប្រាកដដល់ខ្ញុំ ដូចដើមឈើមានម្លប់ត្រជាក់ សម្បូរណ៍ដោយមែក ពោរពេញដោយផ្លែ ។



សូត្រតែមួយប៉ុណ្ណោះប្រាកដដល់ភិក្ខុទាំងនោះ ដោយសេចក្តីផ្សេងគ្នា ព្រោះសញ្ញាផ្សេងគ្នា ។ កម្មដ្ឋានតែមួយប៉ុណ្ណោះ រមែងប្រាកដដោយសេចក្តីផ្សេងគ្នា ព្រោះសញ្ញាផ្សេងគ្នា ដោយអាការយ៉ាងនេះ ព្រោះកម្មដ្ឋាននោះកើតពីសញ្ញា មានសញ្ញាជានិទាន មានសញ្ញាជាដែនកើត ដូច្នោះគប្បីជ្រាបថា រមែងប្រាកដដោយសេចក្តីផ្សេងគ្នា ព្រោះសញ្ញាផ្សេងគ្នា ។

ម្យ៉ាងទៀត កាលនិមិត្តប្រាកដ ភិក្ខុនោះគប្បីទៅរកអាចារ្យ ហើយប្រាប់ឲ្យជ្រាបថា លោកអាចារ្យនិមិត្តប្រាកដបែបនេះ ប្រាកដដល់ខ្ញុំ ។ ចំណែកអាចារ្យគួរពោលថា ម្នាលអាវុសោ នេះជានិមិត្ត ម្នាលសប្បុរស លោកចូលធ្វើកម្មដ្ឋានទុកក្នុងចិត្តឲ្យរឿយ ៗ ចុះ បន្ទាប់ពីនោះ គប្បីតាំងចិត្តទុកក្នុងនិមិត្តប៉ុណ្ណោះ ។

ចាប់ផ្តើមពីនេះទៅ ភិក្ខុនោះរមែងមានភាវនាមុតមាំ ដោយប្រការដូច្នោះ ។ សមដូចបោរាណាចារ្យទាំងឡាយពោលទុកថា :-

**អ្នកមានបញ្ញាញុំាងចិត្តឲ្យតាំងមាំក្នុងនិមិត្ត ចម្រើនអាការផ្សេង ៗ**
**រមែងចងចិត្តរបស់ខ្លួនក្នុងខ្យល់អស្សាសៈ និងបស្សាសៈ ដូច្នេះ ។**

ចាប់ផ្តើមពីការប្រាកដនៃនិមិត្តយ៉ាងនេះ ភិក្ខុនោះក៏គ្របសង្កត់នីវរណ៍ទាំងឡាយបានហើយ ។ កិលេសទាំងឡាយស្ងប់ ។ ចិត្តតាំងមាំ

ដោយឧបចារសមាធិ ភិក្ខុនោះមិនគួរធ្វើទុកក្នុងចិត្តនូវនិមិត្តនោះ ដោយភាពជាពណ៌ មិនគួរពិចារណាដោយភាពជាលក្ខណៈ ។ ភិក្ខុគប្បីវៀរអសប្បាយៈ ៧ មានអាវាសជាដើម ហើយសេពសប្បាយៈ ៧ ទាំងនោះ គួររក្សាទុកឲ្យល្អដូចខត្តិយមហេសី រក្សាគភ៌របស់ព្រះបាទចក្រពត្តិ និងដូចអ្នកស្រែរក្សាស្រូវសាលីផើម និងស្រូវជំណើបដូច្នោះ ។ បន្ទាប់ពីការរក្សានិមិត្តនោះទុកយ៉ាងនេះហើយ កាលចម្រើនលូតលាស់ដោយមនសិការរឿយ ៗ ញ៉ាំងអប្បនាកោសល្យ ១០ យ៉ាង ឲ្យដល់ព្រម គប្បីប្រកបភាវនា ដោយមានសេចក្ដីព្យាយាមស្មើជានិច្ច កាលភិក្ខុព្យាយាមយ៉ាងនេះ ចតុក្កឈាន និងបញ្ចកឈាន រមែងកើតក្នុងនិមិត្តនោះ តាមលំដាប់ ដូចដែលលោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ ម្យ៉ាងទៀត ភិក្ខុអ្នកមានចតុក្កឈានកើត និងបញ្ចក្កឈានហើយ ប្រាថ្នានឹងចម្រើនកម្មដ្ឋានដោយអំណាចនៃវិបស្សនា និងមគ្គ ដើម្បីសម្រេចសេចក្ដីបរិសុទ្ធិ ចូរធ្វើឈាននោះឲ្យដល់ភាពជំនាញ ដោយអាការ ៥ យ៉ាង កំណត់នាមរូប ហើយផ្ដើមវិបស្សនា ។

យ៉ាងណា ព្រោះភិក្ខុនោះចេញចាកសមាបត្តិហើយ រមែងឃើញថា ករជកាយ និងចិត្តជាហេតុកើតខ្យល់អស្សាសបស្សាសៈ ។ ដូចខ្យល់រមែងសញ្ចរ ព្រោះអាស្រ័យស្នប់របស់ជាងមាស និងសេចក្ដីព្យាយាម



ដែលកើតពីការសប់នៃបុរសនោះយ៉ាងណា ខ្យល់អស្សាសៈ បស្សាសៈ រមែងសញ្ចរ ព្រោះកាយ និងចិត្តដូច្នោះដូចគ្នា លំដាប់នោះរមែងកំណត់កាយថា ជារូប គឺ ខ្យល់អស្សាសបស្សាសៈ និងកំណត់ចិត្តថា ជាអរូប ក្នុងធម៌ដែលសម្បយុត្តដោយចិត្តនោះ ។

លុះភិក្ខុកំណត់នាមរូបយ៉ាងនេះហើយ ស្វែងរកបច្ច័យនៃនាមរូបនោះ កាលស្វែងរក ក៏ឃើញបច្ច័យនោះ ប្រារព្ធដល់ការប្រព្រឹត្តទៅនៃនាមរូប ក្នុងកាលទាំង ៣ ហើយ ទើបឆ្លងសេចក្ដីសង្ស័យបាន ឆ្លងសេចក្ដីសង្ស័យបានហើយ ទើបលើកឡើងកាន់ត្រៃលក្ខណៈថា **អនិច្ចំ ទុក្ខំ អនត្តា** ដោយអំណាចនៃការពិចារណាជាកលាបៈ ( សំណុំ ) កាលចំណែកខាងដើមនៃឧទយព្វយានុបស្សនាកើត ទើបលះវិបស្សនូបក្កិលេស ១០ មានឱភាសជាដើម ហើយកំណត់ឧទយព្វយានុបស្សនាញាណ ដែលផុតចាកឧបក្កិលេសថា **មគ្គ** លះការកើតដល់ **ភង្គានុបស្សនា** ( ពិចារណាឃើញការរលត់ ) កាលសង្ខារទាំងពួងប្រាកដ ដោយភាពជាភ័យ ដោយភង្គានុបស្សនាជាលំដាប់ ទើបនឿយណាយ ក៏សម្រេចអរិយមគ្គ ៤ តាមលំដាប់ តាំងនៅក្នុងអរហត្តផល ដល់ទីបំផុតនៃបច្ចវេក្ខណញាណ ១៩ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរនៃលោក ព្រមទាំងទេវលោក ។ ដោយហេតុប្រមាណប៉ុណ្ណេះ ការចម្រើនអានាបានស្សតិ-

*សមាធិ ផ្តើមពីការរាប់ខ្យល់អស្សាសបស្សាសៈនោះ មានវិបស្សនាជាទីបំផុត ក៏គ្រប់ដោយបរិបូរណ៍ ។ នេះជាការពណ៌នាបឋមចតុក្កៈដោយអាការទាំងពួង ដូច្នេះឯង ។*

*ម្យ៉ាងទៀត ក្នុងចតុក្កៈ ៣ ក្រៅនេះ ព្រោះមិនមានន័យនៃកម្ម-ដ្ឋានភាវនាទុកផ្សេង ដូច្នោះ គប្បីជ្រាបសេចក្តីយ៉ាងនេះនៃចតុក្កៈទាំងនោះដោយន័យនៃការពណ៌នាអនុបទនោះឯង ។*

*បទថា* ***បីតិបដិសំវេទី*** *ដឹងច្បាស់បីតិ គឺ រមែងសិក្សាថាយើងធ្វើបីតិឲ្យដឹងច្បាស់ ធ្វើឲ្យប្រាកដ ទើបដកដង្ហើមចូលដកដង្ហើមចេញ ។ ក្នុងបទនោះ ជាការដឹងច្បាស់បីតិដោយអាការ ២ គឺ ដោយអារម្មណ៍ និងដោយការមិនវង្វេង ។*

*ដឹងច្បាស់បីតិដោយអារម្មណ៍ តើដូចម្តេច ។ ភិក្ខុរមែងចូលឈាន ២ យ៉ាង ព្រមដោយបីតិ ភិក្ខុនោះឈ្មោះថា ដឹងច្បាស់បីតិដោយអារម្មណ៍ ដោយការបានឈានក្នុងខណៈសមាបត្តិ ព្រោះដឹងច្បាស់អារម្មណ៍ហើយ ។*

*ដឹងច្បាស់ដោយការមិនវង្វេងតើដូចម្តេច ។ ភិក្ខុចូលឈាន ២ យ៉ាង កាលចេញហើយ រមែងពិចារណាបីតិដែលសម្បយុត្តដោយឈានដោយភាពជារបស់អស់ទៅ ដោយភាពជារបស់វិនាសទៅ ដែលភិក្ខុ*



*នោះដឹងច្បាស់បីតិដោយការមិនវង្វេង ដោយការចាក់ធ្លុះលក្ខណៈ ក្នុងខណៈនៃវិបស្សនា ។ ដោយន័យនេះឯង គប្បីជ្រាបសូម្បីបទដ៏សេសដោយអត្ថ ។ ប៉ុន្តែក្នុងបទនេះ មានសេចក្តីត្រឹមតែផ្សេងគ្នានេះ គប្បីជ្រាបថា ជាការដែលភិក្ខុដឹងច្បាស់សុខដោយអំណាចនៃឈាន ៣ ដឹងច្បាស់ចិត្តសង្ខារដោយអំណាចនៃឈានទាំង ៤ ។*

*បទថា* ***ចិត្តសង្ខារោ*** *ចិត្តសង្ខារ គឺ វេទនាខន្ធ និងសញ្ញាខន្ធ ។ បទថា* ***បស្សម្ភយំ ចិត្តសង្ខារំ*** *រម្ងាប់ចិត្តសង្ខារ សេចក្តីថា រម្ងាប់ចិត្តសង្ខារគ្រោតគ្រាត ៗ គឺ រលត់ ។ គប្បីជ្រាបចិត្តសង្ខារនោះដោយពិស្តារតាមន័យដូចពោលហើយក្នុងកាយសង្ខារ ។*

*ម្យ៉ាងទៀត ក្នុងបទថា* ***បីតិ*** *នេះ លោកពោលវេទនាដោយមាតិកានៃបីតិ ។ ក្នុងបទថា* ***សុខ*** *លោកពោលវេទនាដោយសរុប ។ ក្នុងបទនៃ* ***ចិត្តសង្ខារ*** *ទាំងពីរ វេទនាសម្បយុត្តដោយសញ្ញា ព្រោះបាលីថា សញ្ញា និងវេទនាជាចេតសិក ធម៌ទាំងនេះជាប់ដោយចិត្តជាចិត្តសង្ខារផង ហេតុនោះគប្បីជ្រាបថា លោកពោលចតុក្កៈនេះដោយន័យនៃវេទនានុបស្សនាយ៉ាងនេះ ។ សូម្បីក្នុងចតុក្កៈទី ៣ ក៏គប្បីជ្រាបសេចក្តីជាអ្នកដឹងច្បាស់ចិត្តដោយអំណាចនៃឈាន ៤ ។*

*បទថា* ***អភិប្បមោទយំ ចិត្តំ*** *ធ្វើចិត្តឲ្យសប្បាយ គឺ ភិក្ខុរមែង*

សិក្សាថា យើងញ៉ាំងចិត្តឲ្យសប្បាយ ឲ្យស្រស់ស្រាយ ឲ្យរីករាយ ឲ្យរុងរឿង នឹងដកដង្ហើមចូល និងដកដង្ហើមចេញ ។ ក្នុងបទនោះ ភិក្ខុជាអ្នករីករាយដោយអាការ ២ យ៉ាង គឺ ដោយអំណាចនៃសមាធិ និងដោយអំណាចនៃវិបស្សនា ។

ដោយអំណាចនៃសមាធិ តើដូចម្តេច ។ ភិក្ខុចូលដល់ឈានពីរយ៉ាងព្រមទាំងបីតិ គ្រាចេញហើយ រមែងពិចារណាបីតិសម្បយុត្ត ដោយឈានដោយការអស់ទៅ ដោយការវិនាសទៅ ។ ភិក្ខុញ៉ាំងបីតិសម្បយុត្តដោយឈានក្នុងខណៈនៃវិបស្សនាយ៉ាងនេះ ឲ្យជាអារម្មណ៍ ញ៉ាំងចិត្តឲ្យរីករាយសប្បាយ បដិបត្តិយ៉ាងនេះ លោកពោលថា ភិក្ខុរមែងសិក្សាថា យើងនឹងញ៉ាំងចិត្តឲ្យសប្បាយ សឹមដកដង្ហើមចូល ដកដង្ហើមចេញ ។

បទថា **សមាទហំ ចិត្តំ** តាំងចិត្តទុក គឺ តម្កល់ចិត្តទុកស្មើក្នុងអារម្មណ៍ ដោយអំណាចនៃបឋមជ្ឈានជាដើម ឬចូលឈានទាំងនោះគ្រាចេញហើយ ចិត្តសម្បយុត្តដោយឈានរមែងកើតឡើង ដោយការអស់ទៅ ដោយការវិនាសទៅ ដោយការចាក់ធ្លុះលក្ខណៈក្នុងខណៈនៃវិបស្សនា ព្រោះចិត្តមានអារម្មណ៍តែមួយខណៈ កាលចិត្តមានអារម្មណ៍តែមួយខណៈកើតឡើងហើយយ៉ាងនេះ ភិក្ខុតម្កល់ចិត្តទុកស្មើក្នុងអារម្មណ៍ សូម្បីដោយអំណាចដកដង្ហើមចូល ដកដង្ហើមចេញ ក៏ពោលថា ភិក្ខុរមែងសិក្សាថា



យើងនឹងតម្កល់ចិត្តទុកក្នុងការដកដង្ហើមចូល ដកដង្ហើមចេញ ។

បទថា **វិមោចយំ ចិត្តំ** ញ៉ាំងចិត្តឲ្យរួច គឺ ញ៉ាំងចិត្តឲ្យរួចចាកនីវរណៈទាំងឡាយដោយបឋមជ្ឈាន ញ៉ាំងចិត្តឲ្យផុតចាកវិតក្កវិចារៈដោយទុតិយជ្ឈាន ចាកបីតិដោយតតិយជ្ឈាន ចាកសុខទុក្ខដោយចតុ-ត្ថជ្ឈាន ឬចូលឈានទាំងឡាយនោះ កាលចេញហើយ រមែងពិចារណាចិត្តសម្បយុត្តដោយឈាន ដោយការអស់ទៅ ដោយការវិនាសទៅ ភិក្ខុនោះ ញ៉ាំងចិត្តឲ្យរួចផុតចាកនិច្ចសញ្ញាដោយអនិច្ចានុបស្សនា ក្នុងខណៈនៃវិបស្សនា ញ៉ាំងចិត្តឲ្យរួចចាកសុខសញ្ញាដោយទុក្ខានុបស្សនា ចាកអត្តសញ្ញាដោយអនត្តានុបស្សនា ចាកតម្រេកដោយនិព្វិទានុបស្សនា ចាករាគៈដោយវិរាគានុបស្សនា ចាកសមុទយដោយនិរោធានុបស្សនា ចាកការប្រកាន់មាំដោយបដិនិស្សគ្គានុបស្សនា រមែងដកដង្ហើមចូល និងដកដង្ហើមចេញ ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា **វិមោចយំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ** ភិក្ខុរមែងសិក្សាថា យើងនឹងជម្រះចិត្ត ដកដង្ហើមចូល ដកដង្ហើមចេញ ។ គប្បីជ្រាបថាចតុក្កៈនេះលោកពោលដោយអំណាចនៃចិត្តានុបស្សនា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទី ៤ ដូចតទៅនេះ ។ គប្បីជ្រាប

**អនិច្ចំ** ក្នុងបទថា **អនិច្ចានុបស្សី** ពិចារណាឃើញការមិនទៀងនេះមុន ។ គប្បីជ្រាបអនិច្ចតា គប្បីជ្រាបអនិច្ចានុបស្សនា គប្បីជ្រាបអនិច្ចានុបស្សី ។

ក្នុងបទទាំងនោះ បទថា **អនិច្ចំ** ការមិនទៀង បានដល់ខន្ធ ៥ ។ ព្រោះហេតុអ្វី ? ព្រោះបញ្ចក្ខន្ធមានការកើត រលត់ និងជាយ៉ាងដទៃ ។

បទថា **អនិច្ចតា** ភាពជារបស់មិនទៀង គឺ ការដែលបញ្ចក្ខន្ធទាំងនោះ កើត រលត់ និងជាយ៉ាងដទៃ ឬមានហើយមិនមាន សេចក្តីថា ការមិនតាំងនៅដោយអាការនោះរបស់សត្វទាំងឡាយ ដែលកើតហើយបែកធ្លាយទៅ ដោយការទម្លាយនៃខណៈ ។

បទថា **អនិច្ចានុបស្សនា** ពិចារណាឃើញការមិនទៀង គឺ ពិចារណាឃើញការមិនទៀង ក្នុងរូបជាដើម ដោយអំណាចនៃការមិនទៀងនោះ ។

បទថា **អនិច្ចានុបស្សី** ពិចារណាឃើញការមិនទៀង គឺ ប្រកបដោយអនុបស្សនានោះ ព្រោះដូច្នោះ គប្បីជ្រាបថា ភិក្ខុនោះដកដង្ហើមចូល និងដកដង្ហើមចេញ រមែងសិក្សាក្នុងទីនេះថា យើងនឹងពិចារណាឃើញការមិនទៀង ដកង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។

ក្នុងបទថា **វិរាគានុបស្សី** ពិចារណាឃើញការប្រាសចាកតម្រេកនេះ ការប្រាសចាកតម្រេកមាន ២ យ៉ាង គឺ ការប្រាសចាកតម្រេកព្រោះអស់ទៅ និងការប្រាសចាកតម្រេក ព្រោះធ្វេងផុត ។ ក្នុង ២ បទនោះ



បទថា **ខយវិរាគោ** ការប្រាសចាកតម្រេកព្រោះអស់ទៅ បានដល់ការទម្លាយខណៈនៃសង្ខារទាំងឡាយ ។ បទថា **អច្ចន្តវិរាគោ** ការប្រាសចាកតម្រេក ព្រោះការធ្វេងផុត បានដល់ និព្វាន ។

បទថា **វិរាគានុបស្សនា** ពិចារណាឃើញការប្រាសចាកតម្រេក បានដល់ វិបស្សនា និងមគ្គដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការឃើញទាំងពីរយ៉ាងនោះ ។ គប្បីជ្រាបថា ភិក្ខុជាអ្នកប្រកបដោយអនុបស្សនាសូម្បីពីរយ៉ាង ទើបដកដង្ហើមចូល ដកដង្ហើមចេញ រមែងសិក្សាថា យើងនឹងពិចារណាការប្រាសចាកតម្រេក ដូច្នេះ ។ សូម្បីក្នុងបទថា **និរោធានុបស្សី** ក៏មានន័យនេះដូចគ្នា ។

ការលះបង់ ក្នុងបទថា **បដិនិស្សគ្គានុបស្សី** ពិចារណាឃើញការលះបង់នេះ មាន ២ យ៉ាង គឺ លះបង់ព្រោះបរិច្ចាគ និងលះបង់ព្រោះការស្ទុះទៅ ។ ការពិចារណាឃើញការលះបង់ ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។ បទនេះ ជាឈ្មោះនៃវិបស្សនា មគ្គ ព្រោះវិបស្សនា រមែងលះបង់កិលេសទាំងឡាយព្រមដោយខន្ធាភិសង្ខារ ដោយអំណាចនៃតទង្គៈ រមែងស្ទុះទៅព្រោះឃើញទោសនៃសង្ខតធម៌ និងព្រោះបង្អោនទៅក្នុងព្រះនិព្វានដែលផ្ទុយគ្នា និងទោសនៃសង្ខតធម៌នោះ ព្រោះហេតុនោះ លោកទើបពោលថា លះបង់ព្រោះបរិច្ចាគ និងលះបង់ព្រោះការស្ទុះទៅ ។ **មគ្គ** រមែងលះកិលេសទាំងឡាយព្រមដោយខន្ធាភិសង្ខារ

ដាច់ជាសមុច្ឆេទ រមែងស្ទុះទៅក្នុងព្រះនិព្វាន ដោយការធ្វើឲ្យជាអារម្មណ៍ ព្រោះហេតុនោះ លោកទើបពោលថា លះបង់ព្រោះបរិច្ចាគ លះបង់ព្រោះស្ទុះទៅ ។ សូម្បីទាំងពីរបទនោះ លោកក៏ពោលថាជា **អនុបស្សនា** ព្រោះឃើញញាណមុន ៗ គប្បីជ្រាបថា ភិក្ខុប្រកបដោយបដិនិស្សគ្គានុបស្សនា ( ពិចារណាឃើញការលះបង់ ) សូម្បីពីរយ៉ាងនោះ ទើបដកដង្ហើមចូល និងដកដង្ហើមចេញ រមែងសិក្សាថា យើងនឹងជាអ្នកពិចារណាឃើញការលះបង់ ទើបដកដង្ហើមចូល ដកដង្ហើមចេញ ។

ម្យ៉ាងវិញទៀត គប្បីជ្រាបថា ក្នុងបទថា **អនិច្ចានុបស្សី** នេះ លោកពោលដោយអំណាចនៃវិបស្សនាទន់ខ្សោយ ។ បទថា **វិរាគានុបស្សី** លោកពោលដោយអំណាចនៃវិបស្សនា ដែលអាចប្រាសចាកតម្រេកក្នុងសង្ខារទាំងឡាយបាន ព្រោះមានកម្លាំងខ្លាំងនោះ ។ បទថា **បដិនិស្សគ្គានុបស្សី** លោកពោលដោយអំណាចនៃវិបស្សនាដែលខ្លាំងក្លាជិតចូលដល់មគ្គហើយ ។

សូម្បីមគ្គ ក៏មិនបានទម្លាយវិបស្សនាដែលបាន លោកពោលចតុក្កៈនេះ ដោយអំណាចនៃវិបស្សនាសុទ្ធ ប៉ុន្តែ ៣ យ៉ាង ខាងដើម លោកពោលដោយអំណាចនៃសមថៈ និងវិបស្សនា ។

**( ចប់ អដ្ឋកថាអានាបានស្សតិមាតិកា )**



ឥឡូវនេះ ដើម្បីសម្តែងចំណែកមាតិកា តាមដែលតម្កល់ទុកដោយលំដាប់ ទើបផ្តើមបទមានជាអាទិ៍ថា **ឥធាតិ ឥមិស្សា ទិដ្ឋិយា** ។ បទថា **ឥធ** គឺ ក្នុងទិដ្ឋិនេះ ។ ក្នុងបទទាំងនោះ លោកពោលដល់ពាក្យប្រៀនប្រដៅរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ទាំងនោះ ដែលបានដល់ត្រៃសិក្ខាដោយបទ ១០ បទ មានជាអាទិ៍ថា **ឥមិស្សា ទិដ្ឋិយា** ក្នុងទិដ្ឋិនេះ ព្រោះពាក្យប្រៀនប្រដៅនោះ លោកពោលថា **ទិដ្ឋិ** ព្រោះព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់ឃើញហើយ លោកពោលថា **ខន្តិ** ដោយអំណាចសេចក្តីអត់ធន់ ពោលថា **រុចិ** ដោយអំណាចសេចក្តីពេញចិត្ត ពោលថា **ខេត** ដោយអំណាចកាន់យក ពោលថា **ធម្ម** ដោយអត្ថថា ជាសភាវធម៌ ពោលថា **វិន័យ** ដោយអត្ថថា គួរសិក្សា ពោលថា **ធម្មវិន័យ** សូម្បីដោយអត្ថទាំងពីរនោះ ពោលថា **បាវចន** ដោយអំណាចធម៌ដែលត្រាស់សម្តែង ពោលថា **ព្រហ្មចរិយ** ដោយអត្ថថា ជាការប្រព្រឹត្តដ៏ប្រសើរ ពោលថា **សត្ថុសាសន៍** ដោយអំណាចឲ្យពាក្យប្រៀនប្រដៅ ។

ព្រោះដូច្នោះ ក្នុងបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម គប្បីជ្រាបសេចក្តីថា ក្នុងការឃើញរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងសេចក្តីអត់ធន់របស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងសេចក្តីពេញចិត្តរបស់ព្រះពុទ្ធជាម្ចាស់ក្នុងខេត្តរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងធម៌របស់ព្រះពុទ្ធជាម្ចាស់នេះ

ក្នុងវិន័យរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងធម៌ និងវិន័យរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងបាវចនៈរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងព្រហ្មចរិយៈរបស់ព្រះពុទ្ធជាម្ចាស់នេះ ក្នុងសត្ថុសាសន៍របស់ព្រះពុទ្ធជាម្ចាស់នេះ ។

ម្យ៉ាងវិញទៀត បាវចនៈទាំងអស់ បានដល់ ត្រៃសិក្ខា នេះឈ្មោះថា **ទិដ្ឋិ** ព្រោះព្រះមានព្រះភាគជាម្ចាស់ទ្រង់ឃើញហើយ ព្រោះជាបច្ច័យនៃសម្មាទិដ្ឋិ និងព្រោះមានសម្មាទិដ្ឋិជាធម៌ដល់មុន ឈ្មោះថា **ខន្តិ** ដោយអំណាចសេចក្ដីអត់ធន់របស់ព្រះមានព្រះភាគជាម្ចាស់ ឈ្មោះថា **រុចិ** ដោយអំណាចការពេញចិត្ត ឈ្មោះថា **អាទាយ** ដោយអំណាចការកាន់យក ឈ្មោះថា **ធម្ម** ព្រោះទ្រទ្រង់ទុកនូវអ្នកបដិបត្តិ មិនឲ្យធ្លាក់ទៅក្នុងអបាយ ឈ្មោះថា **វិន័យ** ព្រោះដុសខាត់ចំណែកសៅហ្មងចេញទៅ ធម្ម និងវិន័យនោះ ឈ្មោះថា ធម្មវិន័យ ឬឈ្មោះថា ធម្មវិន័យ ព្រោះកម្ចាត់អកុសលធម៌ទាំងឡាយដោយកុសលធម៌ ដោយហេតុនោះឯង ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលគោតមី នាងគប្បីដឹងធម៌ពួកណា ធម៌ទាំងនេះរមែងប្រព្រឹត្តទៅដើម្បីប្រាសចាកសេចក្ដីតម្រេក មិនប្រព្រឹត្តទៅដើម្បីមានសេចក្ដីតម្រេក ។បេ។ ម្នាលគោតមី នាងគប្បីទ្រទ្រង់ទុកដោយចំណែកតែមួយថា នេះជាធម៌ នេះជាវិន័យ នេះជាសត្ថុសាសន៍ ឬឈ្មោះថា ធម្មវិន័យ ព្រោះជាការបង្គាប់



បញ្ញាដោយធម៌ មិនមែនបង្គាប់បញ្ញាដោយអាជ្ញាជាដើម ។ សមដូចព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកថា:

**ជនពួកខ្លះទូន្មានដោយអាជ្ញា ដោយសំណូមពរ និងដោយការវាយ ព្រះដ៏មានព្រះភាគជាម្ចាស់អ្នកស្វែងរកគុណដ៏ធំ មិនប្រើអាជ្ញា មិនប្រើសស្ត្រា ទូន្មានដ៏ប្រសើរ ។**

ម្យ៉ាងទៀត ឈ្មោះថា ធម្មវិន័យ ព្រោះណែនាំដោយធម៌ ថាអ្វីជាសេចក្ដីប្រណែនរបស់អ្នក ឬបដិបត្តិដោយធម៌ ។ ពិតមែន វិន័យនោះ ដើម្បីធម៌មិនមានទោស មិនមែនដើម្បីអានិសង្សនៃភោគសម្បត្តិក្នុងភព ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយនេះ មិនមែននៅដើម្បីបោកបញ្ឆោតមនុស្ស ។ សូម្បីព្រះបុណ្ណត្ថេរក៏ពោលថា នែអាវុសោ ការប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគជាម្ចាស់ ដើម្បីអនុបាទាបរិនិព្វាន ។ ម្យ៉ាងវិញទៀត ឈ្មោះថា **វិន័យ** ព្រោះនាំទៅឲ្យបរិសុទ្ធ ការនាំទៅដោយធម៌ ឈ្មោះថា ធម្មវិន័យ ។ វិន័យនោះ រមែងនាំទៅចាកធម៌ គឺ សង្សារ ឬចាកធម៌មានសេចក្ដីសោកជាដើម ទៅកាន់និព្វានដ៏បរិសុទ្ធ ឬការនាំទៅកាន់ធម៌ មិនមែននាំទៅកាន់ពួកម្ចាស់លទ្ធិ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មវិន័យ** ។ ពិតមែន ព្រះមានព្រះភាគ

ជាម្ចាស់ជាអ្នកទ្រទ្រង់ធម៌ , វិន័យនោះ របស់ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនោះឯង ។ ម្យ៉ាងវិញទៀត ព្រោះធម៌ទាំងឡាយនោះឯង គួរដឹងដ៏ក្រៃលែង គួរកំណត់ដឹង គួរលះ គួរចម្រើន និងគួរធ្វើឲ្យជាក់ច្បាស់ ដូច្នោះ វិន័យនោះជាការនាំទៅក្នុងធម៌ទាំងឡាយ មិនមែននាំទៅក្នុងសត្វ និងក្នុងវត្ថុមានជីវិតទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មវិន័យ** ។

ពាក្យជាប្រធាន ព្រោះពាក្យរបស់មនុស្សដទៃ ដល់ព្រមដោយអត្ថនិងដល់ព្រមដោយព្យញ្ជនៈ ឈ្មោះថា ពាក្យជាប្រធាន ពាក្យជាប្រធាននោះឯង ឈ្មោះថា **បាវចន** ។ ឈ្មោះថា **ព្រហ្មចរិយ** ព្រោះមានការប្រព្រឹត្តដ៏ប្រសើរដោយចរិយាទាំងពួង ។ ឈ្មោះថា **សត្ថុសាសន៍** ព្រោះជាពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគជាម្ចាស់ ជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ឬពាក្យប្រៀនប្រដៅដែលជារបស់ព្រះ-សាស្ដា ឈ្មោះថា **សត្ថុសាសន៍** ។ ព្រោះព្រះធម្មវិន័យនោះឯងព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ជាសាស្ដា ក្នុងព្រះបាលីថា ម្នាលអានន្ទ ធម៌ និងវិន័យណាដែលតថាគតសម្ដែងហើយ បញ្ញត្តិហើយ ធម៌និងវិន័យនោះ ជាសាស្ដារបស់អ្នកទាំងឡាយ អំណើះអត់ពីតថាគតទៅដោយកន្លងសាស្ដាទៅ ។ គប្បីជ្រាបសេចក្ដីនៃបទទាំងឡាយនោះ ដោយ



ប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រោះភិក្ខុអ្នកញ៉ាំងអានាបានស្សតិសមាធិឲ្យកើត ដោយអាការទាំងពួង មាននៅក្នុងសាសនានេះប៉ុណ្ណោះ មិនមានក្នុងសាសនាដទៃ ដូច្នោះ ក្នុងបទនោះ ៗ លោកទើបកំណត់សេចក្ដីពិតប្រាកដថា **ឥមិស្ស** នៃសាសនានេះ និង **ឥមស្មឹ** ក្នុងសាសនានេះ ។ នេះជាអត្ថនៃការបង្ហាញនៃមាតិកាថា **ឥធ** ។

ម្យ៉ាងទៀត លោកមិនពោលអត្ថនៃពាក្យរបស់ **ភិក្ខុ** សព្ទ ដោយពាក្យមានជាអាទិ៍ថា **បុថុជ្ជនកល្យាណកោ** ភិក្ខុអ្នកជាកល្យាណបុថុជ្ជនហើយសម្ដែងដល់ភិក្ខុដែលប្រាថ្នាយកក្នុងទីនេះប៉ុណ្ណោះ ។ ក្នុងបទនោះ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកលះកិលេសមិនបាន និងឈ្មោះថា កល្យាណបុថុជ្ជនជន ព្រោះជាអ្នកប្រកបដោយការបដិបត្តិ មានសីលជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា កល្យាណបុថុជ្ជន កល្យាណបុថុជ្ជននោះឯង ឈ្មោះថា **បុថុជ្ជនកល្យាណកោ** ។

ឈ្មោះថា **សេក្ខោ** ព្រោះនៅសិក្សាអធិសីលជាដើម បានដល់ព្រះសោតាបន្ន ព្រះសកទាគាមី ឬព្រះអនាគាមី ។

ឈ្មោះថា **អកុប្បធម្មោ** ព្រោះមានធម៌ គឺ អរហត្តផលមិនកម្រើក គឺ មិនអាចឲ្យញាប់ញ័របាន ។ ពិតមែន សូម្បីមានធម៌មិនកម្រើកនោះ ក៏នៅចម្រើនសមាធិនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអរញ្ញនិទ្ទេស ដូចតទៅនេះ ។ ដោយបរិយាយនៃវិន័យ ពាក្យថា **ព្រៃ** មកក្នុងបទមានជាអាទិ៍ថា ព្រៃដ៏សេសក្រៅអំពីស្រុក និងឧបចារៈនៃស្រុក ។ ដោយបរិយាយនៃព្រះសូត្រសំដៅដល់ភិក្ខុអ្នកនៅព្រៃ មកហើយក្នុងបទមានជាអាទិ៍ថា សេនាសនៈចុងបំផុត ៥០០ ជួរធ្នូ ឈ្មោះថា ព្រៃ ។ ព្រះវិន័យ និងព្រះសូត្រ សូម្បីទាំងពីរជាបរិយាយទេសនា ( ទេសនាបែបបរិយាយ ) ដើម្បីសម្ដែងព្រៃដោយបរិយាយនៃអភិធម្មថា ព្រះអភិធម្មជានិប្បរិយាយទេសនា ( ទេសនាដោយត្រង់ ) ទើបពោលថា ព្រៃ គឺ ចេញខាងក្រៅសសរខឿនទៅ ។ បាឋៈថា **និក្ខមិត្វា ពហិ ឥន្ទខីលំ** លោកពោលថា ហួសសសរខឿនចេញទៅ ។ ម្យ៉ាងទៀត ក្នុងបទថា **ឥន្ទខីលោ** នេះ គឺ ធរណីទ្វារស្រុក ឬនគរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរុក្ខមូលនិទ្ទេស ដូចតទៅនេះ ។ ព្រោះគល់ឈើប្រាកដហើយ លោកទើបមិនពោលដល់គល់ឈើនោះ ពោលពាក្យមានជាអាទិ៍ថា **យត្ថ** ដូច្នេះ ។

បទថា **យត្ថ** គឺ ត្រង់គល់ឈើណា ។ ឈ្មោះថា **អាសន** ព្រោះជាទីអង្គុយ ។ បទថា **បញ្ញត្តំ** គឺ តាំងទុកហើយ ។ បទថា **មញ្ចោ វា** ជាអាទិ៍ ជាពាក្យពោលដល់ប្រភេទរបស់អាសនៈ ។ ពិតមែន សូម្បី



គ្រែលោកក៏ពោលទុកក្នុងអាសនៈទាំងឡាយ ក្នុងបទនេះ ព្រោះជាឱកាសអង្គុយក៏បាន ។ ម្យ៉ាងទៀត គ្រែនោះយ៉ាងណាមួយ បណ្ដាគ្រែពិសេស គឺ **មសារក** ( គ្រែដែលមានមេស៊កបញ្ចូលទៅក្នុងជំណាប់ជើង ) **ពុន្ទិកាពទ្ធ** ( គ្រែដែលគេបង្ខាំងជើងដោយមេគ្រែ ) **កុឡីរបាទក** ( គ្រែមានជើងដូចជើងក្ដាម) **អាហច្ចបាទក** (គ្រែមានជើងទល់នឹងមេ) ។ បណ្ដាតាំងទាំងនោះ តាំងយ៉ាងណាមួយ ក៏ដូចគ្នា ។

បទថា **ភិសិ** ពូក បានដល់ ពូកណាមួយ បណ្ដាពូកធ្វើដោយរោមកែះ ពូកធ្វើដោយសំពត់ ពូកធ្វើដោយសម្បកឈើ ពូកធ្វើដោយស្មៅ ពូកធ្វើដោយស្លឹកឈើ ។ បទថា **តដ្ដិកា** កន្ទេល គឺ កន្ទេលត្បាញដោយស្លឹកត្នោតជាដើម ។ បទថា **ចម្មខណ្ឌោ** កំណាត់ស្បែក គឺ កំណាត់ស្បែកយ៉ាងណាមួយ ដែលសមគួរជាទីអង្គុយ ។ គ្រឿងក្រាលធ្វើដោយស្មៅជាដើម គឺយកស្មៅជាដើមផ្គុំចូលគ្នា ។ បទថា **តត្ថ** គឺត្រង់គល់ឈើនោះ ។ ដោយបទមានជាអាទិ៍ថា **ចង្កមតិ វា** ដើរ លោកពោលសំដៅដល់ត្រង់គល់ឈើ ដែលជាទីញុំាងឥរិយាបថ ៤ ឲ្យប្រព្រឹត្តទៅបាន ។ ដោយបទទាំងពួងមាន បទថា **យត្ថ** ជាដើម លោកពោលដល់សេចក្ដីត្រង់គល់ឈើមានម្លប់ត្រឈឹងត្រឈៃក្រាស់ខ្មឹក និងព្រោះជាទីស្ងាត់ចាកពួកមនុស្ស ។ បទថា **កេនចិ** ដោយពួកជនណា ៗ ។

លោកចែកពួកជននោះឲ្យពិស្តារចេញទៅ ទើបពោលថា **គហដ្ឋេន វា បព្វជិតេន វា** ជាគ្រហស្ថក៏ដោយ ជាបព្វជិតក៏ដោយ ។ បទថា **អនាកិណ្ណំ** មិនកុះករ គឺ មិនជួបជុំ មិនផ្អៀតចង្អល់ ។ សេនាសនៈណាទីស្បាតដោយភ្នំ , ស្បាតដោយព្រៃ , ស្បាតដោយស្ទឹង មួយគាវុតខ្លះ កន្លះយោជន៍ខ្លះ ដោយជុំវិញ នរណា ៗ មិនអាចចូលទៅបាន ដោយមិនមែនវេលាដែលគួរ សេនាសនៈនេះ ឈ្មោះថា មិនកុះករសូម្បីក្នុងទីជិត ។ ចំណែកសេនាសនៈណានៅកន្លះយោជន៍ ឬមួយយោជន៍ សេនាសនៈឈ្មោះថា មិនកុះកករ ព្រោះនៅឆ្ងាយ ។

បទថា **វិហារោ** វិហារ បានដល់ ទីនៅដ៏សេសផុតចាកអឌ្ឍយោគជាដើម ។

បទថា **អឌ្ឍយោគោ** រោងមានដំបូលពាក់កណ្តាល បានដល់ ផ្ទះដូចស្លាបគ្រុឌ ។

បទថា **បាសាទោ** ប្រាសាទ បានដល់ ប្រាសាទវែងមានជហ្វាពីរ ។

បទថា **ហម្មិយំ** ផ្ទះត្រងិល បានដល់ ប្រាសាទមានផ្ទះកំពូលតាំងនៅក្នុងផ្ទៃអាកាសខាងលើ ។

បទថា **គុហា** ល្អាង លោកពោលទុកក្នុងអដ្ឋកថាខន្ធកៈយ៉ាងនេះ គឺ ល្អាងឥដ្ឋ ល្អាងថ្ម ល្អាងឈើ ល្អាងដី ។ ចំណែកក្នុងអដ្ឋកថាវិភង្គ



លោកពោលដល់សេនាសនៈដែលធ្វើផ្លូវការពារជុំវិញ និងទីសម្រាកពេលយប់ និងពេលថ្ងៃ ទុកខាងក្នុងថា វិហារ ។

បទថា **គុហា** បានដល់ ល្អាងដី គួរសម្រាកអាស្រ័យបានរហូតយប់ និងថ្ងៃ ។ លោកពោលបទទាំងពីរនេះឲ្យផ្សេងគ្នា គឺ ល្អាងភ្នំ ឬល្អាងដី លោកធ្វើឲ្យជាវត្ថុមានាវិកត្តិថា **និសីទតិ** រមែងអង្គុយដោយអំណាចនៃលក្ខណៈទូទៅគ្រប់កាលទាំងពួងនៃមាតិកា តែលោកធ្វើជាការសម្រេចរូបថា **និសិន្នោ** អង្គុយហើយ ដើម្បីសម្តែងការចាប់ផ្តើម និងសេចក្តីចុងក្រោយនៃការអង្គុយ ព្រោះមានការចាប់ផ្តើមភាវនារបស់ភិក្ខុអ្នកអង្គុយក្នុងទីនេះ ។

ម្យ៉ាងទៀត ព្រោះកាលភិក្ខុអង្គុយតាំងកាយ កាយរមែងត្រង់ដូច្នោះ លោកទើបមិនអើពើក្នុងព្យញ្ជនៈ កាលនឹងសម្តែងដល់សេចក្តីបំណងតែម្យ៉ាង ទើបពោលពាក្យមានជាអាទិ៍ថា **ឧជុកោ** ត្រង់ ។

ក្នុងបទទាំងនោះ បទថា **ឋិតោ សុបណិហិតោ** កាយជាកាយដែលភិក្ខុនោះតាំងទុកត្រង់ សេចក្តីថា ជាកាយតាំងទុកត្រង់ ព្រោះតាំងត្រង់ហើយ មិនមែនតាំងទុកត្រង់ដោយខ្លួនឯង ។ បទថា **បរិគ្គហដ្ឋោ** គឺ មានការកំណត់កាន់យកជាអត្ថ ។ កំណត់កាន់យកអ្វី ។ កាន់យកការនាំចេញ ។ នាំអ្វីចេញ ។ នាំអានាបានស្សតិសមាធិ រហូតដល់អរហត្តមគ្គ

ចេញ ដោយហេតុនោះ លោកទើបពោលថា **និយ្យានដ្ឋោ** មានការនាំចេញជាអត្ថ ។ លោកពោលមានការនាំចេញជាអត្ថ ចាកសង្សារដោយអំណាចនៃអត្ថដែលចម្រើននៃ **មុខសតូ** ។

បទថា **ឧបដ្ឋានដ្ឋោ** មានការចូលទៅតាំងទុកជាអត្ថ គឺ មានសភាវធម៌ជាអត្ថ ។ ដោយបទទាំងនេះទាំងអស់ ជាចំណែក លោកអធិប្បាយថា តាំងសតិ មានការនាំចេញ កំណត់កាន់យក ។ តែអាចារ្យពួកខ្លះពណ៌នាថា បទថា **បរិគ្គហដ្ឋោ** គឺ មានការកំណត់កាន់យកជាអត្ថដោយសតិ ។ បទថា **និយ្យានដ្ឋោ** គឺ មានទ្វារចូលចេញនៃខ្យល់អស្សាសបស្សាសៈ ។ លោកអធិប្បាយថា តាំងសតិ មានការនាំខ្យល់អស្សាសបស្សាសៈដែលកំណត់កាន់យកចេញ ។

បទថា **ពត្តឹសាយ អាការេហិ** ដោយអាការ ៣២ លោកពោលដោយអំណាចការកាន់យកដោយមិនមានចំណែកសល់ របស់ភិក្ខុទាំងឡាយអ្នកបានទទួលតាមលំដាប់ ក្នុងវត្ថុដែលមិនពិតប្រាកដនោះ ៗ ។ បទថា **ទីឃំ អស្សាសេន** ដោយអំណាចខ្យល់ដកដង្ហើមចូលវែង គឺ ដោយអំណាចខ្យល់អស្សាសៈដែលពោលហើយថា **វែង** ក្នុងមាតិកា ។ ក្នុងបទដ៏សេសក៏យ៉ាងនេះ ។ បទថា **ឯកគ្គតំ** គឺ ការដែលចិត្តមានអារម្មណ៍តែមួយ ។ បទថា **អវិក្ខេបំ** មិនរាយមាយ គឺ ការដែលចិត្ត



មានអារម្មណ៍តែមួយ លោកពោលថា មិនរាយមាយ ព្រោះចិត្តមិនរាយមាយទៅក្នុងអារម្មណ៍ផ្សេង ៗ ។ បទថា **បជានតោ** ដឹងហើយ គឺ ដឹងច្បាស់ដោយការមិនវង្វេង ឬដឹងដោយធ្វើឲ្យជាអារម្មណ៍ថា យើងបានការមិនរាយមាយហើយ ។ បទថា **តាយ សតិយា** គឺ ដោយសតិដែលចូលទៅតាំងទុកហើយ ។ បទថា **តេន ញាណេន** គឺ ដោយញាណដឹងការមិនរាយមាយនោះ ។ ក្នុងបទថា **សតោការី ហោតិ** ជាអ្នកធ្វើសតិនេះ ព្រោះសតិសម្បយុត្តដោយញាណនោះឯង លោកប្រាថ្នាយកសតិ ។ ដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ភិក្ខុប្រកបដោយសតិ និងបញ្ញាយ៉ាងក្រៃលែង ឈ្មោះថា ជាអ្នកមានសតិ ។ ដូច្នោះសូម្បីញាណ លោកក៏កាន់យកដោយពាក្យថា **សតោ** មានសតិ ។

បទថា **អទ្ធានសង្ខាតេ** គឺ ក្នុងកាលដែលរាប់វែង ។ ផ្លូវវែងលោកក៏ហៅថា **អទ្ធានោ** ។ សូម្បីកាលនេះលោកពោលថា **អទ្ធានោ** ព្រោះវែងដូចផ្លូវវែង សូម្បីពោលខ្យល់អស្សាសៈ និងបស្សាសៈផ្សេងគ្នាថា **អស្សសតិ** ដកដង្ហើមចូលខ្លះ និង **បស្សសតិ** ដកដង្ហើមចេញខ្លះ ដើម្បីសម្ដែងការប្រព្រឹត្តទៅតាមលំដាប់នៃការនា លោកទើបពោលសង្ខេបទៀតថា **អស្សសតិ ខ្លះ បស្សសតិ ខ្លះ** ។ បទថា **ឆន្ទោ ឧប្បជ្ជតិ** ឆន្ទៈរមែងកើតឡើង គឺ ឆន្ទៈរមែងកើត ដើម្បីភាពក្រៃលែង ៗ ឡើង

ទៅនៃការចម្រើនក្រៃលែងនៃភាវនា ។ បទថា **សុខុមតរំ** ល្អិតជាង លោកពោលព្រោះមានការស្ងប់ ។ បទថា **បាមុជ្ជំ ឧប្បជ្ជតិ** ភាពរីករាយ រមែងកើត គឺ បីតិរមែងកើត ព្រោះការបរិបូណ៌នៃភាវនា ។

បទថា **អស្សាសបស្សាសាបិ ចិត្តំ វិវដ្ដតិ** ចិត្តរមែងគេច ចេញចាកខ្យល់អស្សាសបស្សាសៈ គឺ កាលបដិភាគនិមិត្តកើត ព្រោះ អាស្រ័យខ្យល់អស្សាសបស្សាសៈ ចិត្តរមែងត្រឡប់ចាកខ្យល់អស្សាស-បស្សាសៈប្រក្រតី ។ បទថា **ឧបេក្ខា សណ្ឋាតិ** ឧបេក្ខា រមែងតាំងនៅ គឺ ក្នុងបដិភាគនិមិត្តនោះ មជ្ឈត្តុបេក្ខាដែលជាឧបចារៈ និងអប្បនា រមែងតាំងនៅ ព្រោះមិនមានការខ្វល់ខ្វាយក្នុងការតាំងទុក នូវការសម្រេចសមាធិ ។

បទថា **នវហាការេហិ** ដោយអាការ ៩ យ៉ាង បានដល់ អាការ ៩ យ៉ាង គឺ អាការ ៣ លោកពោលថា **អស្សសតិ ខ្វះ បស្សសតិ ខ្វះ** មុនឆន្ទៈកើត តាំងអំពីចាប់ផ្ដើមភាវនា អាការ ៣ មុនសភាពបាមោជ្ជៈកើត តាំងពីឆន្ទៈកើតអាការ ៣ តាំងពីបាមោជ្ជៈកើត ។ បទថា **កាយោ** កាយ ឈ្មោះថា **កាយ** ព្រោះប្រជុំខ្យល់ អស្សាសៈ និងបស្សាសៈដែលជារបស់ល្អិត ៗ ឡើងទៅ ។ សូម្បីនិមិត្ត ដែលកើតព្រោះអាស្រ័យខ្យល់អស្សាសៈប្រក្រតី បស្សាសៈប្រក្រតី ក៏រមែងបានឈ្មោះថា ខ្យល់



អស្សាសៈ បស្សាសៈ ។

បទថា **ឧបដ្ឋានំ សតិ** សតិប្រាកដ ឈ្មោះថា សតិប្រាកដ ព្រោះសតិកំណត់អារម្មណ៍នោះតាំងនៅ ។ បទថា **អនុបស្សនាញាណំ** សតិជាអនុបស្សនាញាណ សេចក្ដីថា កាយានុស្សនាជានិមិត្ត ដោយអំណាចសមថៈ , នាមកាយរូបកាយានុបស្សនា ជាញាណ ដោយអំណាចវិបស្សនា ។

បទថា **កាយោ ឧបដ្ឋានំ** កាយប្រាកដ គឺ ឈ្មោះថា ប្រាកដ ព្រោះកាយមានសតិចូលទៅតាំងទុក ។ បទថា **នោ សតិ** មិនមែនសតិ សេចក្ដីថា កាយនោះមិនមែនសតិ ។ បទថា **តាយ សតិយា** គឺ សតិដែលពោលហើយក្នុងឥឡូវនេះ ។ បទថា **តេន ញាណេន** ដោយញាណនោះ គឺ ដោយញាណដែលពោលក្នុងឥឡូវនេះដូចគ្នា ។ បទថា **តំ កាយំ អនុបស្សតិ** ពិចារណាឃើញកាយនោះ គឺ ទៅតាមកាយដែលពោលដោយអំណាចនៃសមថៈ និងវិបស្សនា ហើយឃើញដោយញាណសម្បយុត្តដោយឈាន ឬដោយវិបស្សនាញាណ ។ សូម្បីក្នុងសេចក្ដីមិនមានបទ **កាយ** ជាដើម ក្នុងមាតិកា ក៏គួរពោលក្នុងឥឡូវនេះ ព្រោះចតុក្កៈនេះ លោកពោលដោយអំណាចកាយានុបស្សនាលោកបង្ហាញបទនៃ **កាយ** សំដៅដល់ពាក្យថា **កាយេ កាយានុបស្សនា សតិប្បដ្ឋាន-**

**ភាវនា** សតិប្បដ្ឋានភាវនា គឺ ការពិចារណាឃើញកាយក្នុងកាយ ។

បទថា **កាយេ កាយានុបស្សនា** គឺ ពិចារណាឃើញកាយនោះ ៗ ក្នុងកាយច្រើនយ៉ាង ។ មួយ៉ាងទៀត លោកអធិប្បាយថា ការពិចារណាឃើញកាយក្នុងកាយ មិនមែនពិចារណាឃើញធម៌ដទៃ មិនមែនពិចារណាឃើញការទៀង ភាពជាសុខ សេចក្ដីស្អាតក្នុងកាយ ដែលជារបស់មិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាត ដោយពិតការពិចារណាឃើញកាយប៉ុណ្ណោះ ដោយភាពមិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាត ។ មួយ៉ាងវិញទៀត លោកអធិប្បាយថា ការពិចារណាឃើញត្រឹមតែកាយ ព្រោះមិនឃើញនរណា ៗ ដែលគួរប្រកាន់ក្នុងកាយថា យើង របស់យើង ស្រី ឬប្រុស ។

សូម្បីក្នុង ៣ បទ មានជាអាទិ៍ថា **វេទនាសុ វេទនានុបស្សនា** ខាងដើម ក៏មានន័យនេះដូចគ្នា ។ សតិនោះឯងប្រាកដ ឈ្មោះថា **សតិប្បដ្ឋាន** សតិប្បដ្ឋានសម្បយុត្តដោយកាយានុបស្សនា ឈ្មោះថា **កាយានុបស្សនាសតិប្បដ្ឋាន** ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាននោះ ឈ្មោះថា **កាយានុបស្សនាសតិប្បដ្ឋានភាវនា** ។

បទថា **តំ កាយំ** លោកពោលធ្វើដូចជា សម្ដែងហើយព្រោះកាយនោះ លោកសង្គ្រោះដោយ **កាយ** សព្ទ ក្នុងនាមកាយ រូបកាយ



សូម្បីមិនបានសម្ដែងទុក ព្រោះអនិច្ចានុបស្សនាជាដើម រមែងបានក្នុងនាមកាយ និងរូបកាយនោះឯង មិនបានក្នុងកាយនិមិត្ត អនុបស្សនា និងភាវនា រមែងបានព្រោះលោកពោលទុកហើយ ។

បទមានជាអាទិ៍ថា **ទីឃំ អស្សាសបស្សាសវសេន** ដោយអំណាចខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញវែង លោកពោលដើម្បីសម្ដែងដល់អានិសង្សនៃអានាបានស្សតិភាវនា ព្រោះសតិបរិបូរណ៍ និងញាណបរិបូរណ៍ ជាអានិសង្សនៃអានាបានស្សតិភាវនានោះ ។ បទថា **ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ** កាលដឹងចិត្តមានអារម្មណ៍តែមួយមិនរាយមាយ លោកពោលសំដៅដល់ កាលចិត្តមានអារម្មណ៍តែមួយក្នុងកាលឃើញច្បាស់ឈានដែលបានហើយ ។ បទថា **វិទិតា វេទនា** គឺ វេទនាដែលប្រាកដ ដោយឃើញការកើតឡើងចាកភាពសាមញ្ញ ។ បទថា **វិទិតា ឧបដ្ឋហន្តិ** ប្រាកដចូលទៅតាំងនៅ គឺ ប្រាកដចូលទៅតាំងនៅដោយការអស់ទៅ ដោយការវិនាសទៅ ដោយភាពសូន្យ ។

បទថា **វិទិតា អព្ភត្ថំ គច្ឆន្តិ** ប្រាកដដល់ការរលត់ទៅ គឺ ប្រាកដដល់ការវិនាស ព្រោះដោយឃើញការវិនាស ដោយភាពសាមញ្ញ អធិប្បាយថា ទម្លាយ ។ សូម្បីក្នុងសញ្ញា និងវិតក្កៈក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងវិញទៀត កាលលោកពោល វេទនា សញ្ញា និងវិតក្កៈ ៣ យ៉ាងទាំងនេះ សូម្បីរូបធម៌ដ៏សេស ក៏ជាការពោលទុកផង ។ ព្រោះហេតុអ្វីទើបពោល ៣ យ៉ាងប៉ុណ្ណោះ ។ ព្រោះកំណត់កាន់យកបានលំបាក សុខទុក្ខប្រាកដក្នុងវេទនាមុន តែឧបេក្ខា ល្អិតសុខុមកំណត់កាន់យកបានលំបាក មិនប្រាកដដោយល្អ សូម្បីឧបេក្ខាក៏នៅប្រាកដដល់ភិក្ខុនោះ ។ សញ្ញាកាន់យកតាមសភាវៈ មិនប្រាកដ ព្រោះកាន់យកត្រឹមតែអាការ ។ ម្យ៉ាងទៀត សញ្ញានោះ សម្បយុត្តដោយវិបស្សនាញាណ កាន់យកលក្ខណៈជាសាមញ្ញតាមសភាវៈមិនប្រាកដយ៉ាងក្រៃលែង សូម្បីសញ្ញានឹងប្រាកដដល់ភិក្ខុនោះ វិតក្កៈធ្វើទុកផ្សេងពីញាណ ព្រោះជាញាណបដិរូប ទើបកំណត់កាន់យកលំបាក ព្រោះញាណបដិរូបជាវិតក្កៈ ។ សមដូចព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលអាវុសោវិសាខៈ ធម៌ គឺ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ សង្គ្រោះចូលក្នុងបញ្ញាខន្ធ ។

សូម្បីវិតក្កៈនោះ ក៏ប្រាកដដល់ភិក្ខុនោះ ព្រោះហេតុនោះ កាលពោលដល់ការកាន់យកលំបាកយ៉ាងនេះ រូបធម៌ដ៏សេស ក៏ជាការពោលហើយផង ។ ក្នុងនិទ្ទេសនៃបទទាំងនេះ លោកសួរថា វេទនាប្រាកដកើតឡើងដូចម្តេច មិនឆ្លើយបទនោះ ឆ្លើយត្រឹមតែការប្រាកដនៃវេទនា



ដែលកើតឡើង ទើបជាការឆ្លើយត្រង់ដែលវេទនាប្រាកដ ព្រោះហេតុនោះ ទើបពោលពាក្យមានអាទិ៍ថា **កថំ វេទនាយ ឧប្បាទោ វិទិតោ ហោតិ** ការកើតនៃវេទនាប្រាកដ តើដូចម្តេច ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទមានជាអាទិ៍ថា **អវិជ្ជាសមុទយា អវិជ្ជានិរោធា** ព្រោះអវិជ្ជាកើត ព្រោះអវិជ្ជារលត់ មានសេចក្តីដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។ សូម្បីសញ្ញា និងវិតក្កៈ ក៏គប្បីជ្រាបដោយន័យនេះឯង ។ ក្នុងវិតក្កវារៈ លោកមិនបានពោលថា ព្រោះផស្សៈរលត់ ហើយពោលក្នុងទីនៃផស្សៈថា ព្រោះសញ្ញាកើត ព្រោះសញ្ញារលត់ ។ ប្រសិនសួរថា ដែលពោលដូច្នោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះវិតក្កៈមានសញ្ញាជាមូល ព្រោះលោកពោលទុកថា សេចក្តីផ្សេងគ្នានៃសង្កប្បៈកើតឡើង ព្រោះអាស្រ័យការផ្សេងគ្នានៃសញ្ញា ។

ម្យ៉ាងទៀត ក្នុងបទមានជាអាទិ៍ថា **អនិច្ចតោ មនសិករោតោ** កាលមនសិការដោយការមិនទៀង គប្បីប្រកបធម៌នោះ ៗ ក្នុងវារៈនោះ ៗ ដោយន័យមានជាអាទិ៍ថា **វេទនំ អនិច្ចតោ មនសិករោតោ** កាលមនសិការវេទនាដោយការមិនទៀង ក៏ព្រោះវេទនាសម្បយុត្តដោយវិបស្សនា ទើបមិនជាឧបការៈដល់វិបស្សនា ព្រោះមិនអាចធ្វើកិច្ចនៃ

វិបស្សនាបាន ដូច្នោះឯង វេទនាទើបមិនមកក្នុងពោធិបក្ខិយធម៌ កិច្ចនៃសញ្ញាសម្បយុត្តដោយវិបស្សនា ទើបមិនឃៀងឃាត ព្រោះដូច្នោះ សញ្ញានោះ ទើបមិនជាឧបការដល់វិបស្សនា តែកិច្ចនៃការឃើញ វៀរវិតក្កៈរមែងមិនមាន ព្រោះវិបស្សនាមានវិតក្កៈជាមិត្ត រមែងធ្វើកិច្ចរបស់ខ្លួន ។ ដូចដែលលោកពោលទុកថា :-

បញ្ញាតាមធម្មតារបស់ខ្លួន រមែងមិនអាចនឹងកាត់ក្តីអារម្មណ៍ថា **អនិច្ចំ ទុក្ខំ អនត្តា** បាន តែកាលវិតក្កៈប៉ះខ្ទប់ហើយ ប៉ះខ្ទប់ហើយឲ្យអារម្មណ៍ ទើបអាចកាត់ក្តីបាន ដូចហិរញ្ញិកដាក់កហាបណៈទុកត្រង់ដៃ សូម្បីបំណងនឹងត្រួតមើលក្នុងចំណែកទាំងអស់ ក៏មិនអាចនឹងត្រឡប់បញ្ច្រាសដោយខែ្សភ្នែកបាន តែកាលយកម្រាមដៃត្រឡប់បង្វិលទៅមកខាងនោះខាងនេះ ក៏អាចត្រួតមើលបានយ៉ាងណា បញ្ញាក៏ដូច្នោះដូចគ្នាតាមធម្មតារបស់ខ្លួនមិនអាចវិនិច្ឆ័យអារម្មណ៍ ដោយអំណាចនៃការមិនទៀងជាដើមបាន តែអាចវិនិច្ឆ័យអារម្មណ៍ដែលមានវិតក្កៈមានការលើកចិត្តឡើងជាលក្ខណៈ មានការប៉ះខ្ទប់ និងការផ្តោតអារម្មណ៍ជាកិច្ចដែលមកហើយបាន ដូចប៉ះខ្ទប់ និងត្រឡប់បង្វិលទៅមក ដូច្នោះ ។

ព្រោះដូច្នោះ ដើម្បីសម្តែងត្រឹមតែលក្ខណៈ ព្រោះវេទនា និងសញ្ញាទាំងឡាយមិនជាឧបការៈដល់វិបស្សនា លោកទើបសម្តែងដោយ



ឯកវចនៈក្នុងបទនោះ ៗ ថា **វេទនាយ សញ្ញាយ** ដូច្នេះ ។

បទថា **ទីឃំ អស្សាសបស្សាសវសេន** ដោយអំណាចខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញវែងជាដើម លោកពោលដើម្បីសម្តែងការដល់ព្រមនៃអានាបានស្សតិភាវនា និងផលនៃភាវនា ។

ក្នុងបទទាំងនោះ បទថា **សមោធានេតិ** ឲ្យប្រជុំចុះ សេចក្តីថា តាំងទុកនូវអារម្មណ៍ ឬញុំាងអារម្មណ៍ឲ្យតាំងទុក ឈ្មោះថា បុគ្គលរមែងតាំងអារម្មណ៍ ដើម្បីសេចក្តីបរិបូរណ៍នៃភាវនា សូម្បីក្នុងការតាំងមាំ និងការខ្វល់ខ្វាយ ។ បទថា **គោចរំ** អារម្មណ៍ គឺ សង្ខារជាអារម្មណ៍ ក្នុងខណៈនៃវិបស្សនា និងនិព្វានជាអារម្មណ៍ ក្នុងខណៈនៃមគ្គ និងខណៈនៃផល ។ បទថា **សមត្ថំ** គឺ សេចក្តីស្ងប់ជាប្រយោជន៍ ឬឈ្មោះថា **សមត្ថោ** ព្រោះប្រយោជន៍នៃសេចក្តីស្ងប់នូវធម៌ មានសេចក្តីស្ងប់ជាប្រយោជន៍នោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **មគ្គំ សមោធានេតិ** ញុំាងមគ្គឲ្យប្រជុំចុះ គឺ និព្វាននោះឯង ជាគោចរក្នុងខណៈមគ្គ និងផល ។ បទថា **អយំ បុគ្គលោ** បុគ្គលនេះ គឺ ព្រះយោគាវចរអ្នកប្រកបរឿយ ៗ នូវអានាបានស្សតិភាវនា ។ ក្នុង បទថា **ឥមស្មឹ អារម្មណេ** ក្នុងអារម្មណ៍នេះ គឺ ក្នុងអារម្មណ៍ដែលជាសង្ខតៈ ពោលគឺ នាមកាយ រូបកាយ ដែលលោកសង្គ្រោះដោយ

បទថា **កាយេ** និងក្នុងនិព្វានជាអារម្មណ៍ត្រង់មគ្គដោយលំដាប់នោះ ។ លោកពោលសព្ទថា **អារម្មណ និង គោចរ** មានសេចក្តីតែមួយដូចគ្នា ដោយបទថា **យន្តស្ស** ជាដើម ។ បទថា **តស្ស** គឺនៃបុគ្គលនោះ ។ បទថា **បជានាតីតិ បុគ្គលោ បជានទា បញ្ញា** លោកអធិប្បាយថា បុគ្គលរមែងដឹងដោយបញ្ញា ។ បទថា **អារម្មណស្ស ឧបដ្ឋានំ** ការប្រាកដនូវអារម្មណ៍ គឺ សតិ ជាការប្រាកដនៃសង្ខារជាអារម្មណ៍ ក្នុងខណៈនៃវិបស្សនា និងនិព្វានជាអារម្មណ៍ក្នុងខណៈនៃមគ្គផល ។ ក្នុងបទដែលជាឆដ្ឋីវិភត្តិចុះក្នុងកម្ម (ទុតិយាវិភត្តិ) ដូចពោលថាទំនុកបម្រុងព្រះរាជា ។ បទថា **អវិក្ខេបោ** ការមិនរាយមាយ គឺ សមាធិ ។ បទថា **អធិដ្ឋានំ** ការតាំងមាំ គឺ មានសង្ខារតាមដែលពោលហើយជាអារម្មណ៍ និងមាននិព្វានជាអារម្មណ៍ ឈ្មោះថា **អធិដ្ឋានំ** ព្រោះអារម្មណ៍មានចិត្តតាំងមាំ ។ បទថា **វោទានំ** ការផូរផង់ គឺ ញាណ ឈ្មោះថា **វោទានំ** ព្រោះអារម្មណ៍ជាហេតុឲ្យចិត្តផូរផង់បរិសុទ្ធ ។

សមាធិជាចំណែកបក្សពួកនៃការរួញរា ឈ្មោះថា ស្ងប់ ព្រោះជាសេចក្តីស្ងប់ ដោយការដល់ការមិនរួញរា ។ ញាណជាចំណែកបក្សពួកនៃការរាយមាយ ឈ្មោះថា ស្ងប់ ព្រោះជាសេចក្តីស្ងប់ដោយភាវៈមិនរាយមាយ ដោយហេតុនោះ ជាចំណែកដែលលោកពោលដល់សមថៈ



និងវិបស្សនា ជាធម៌គូគ្នា ក្នុងខណៈនៃវិបស្សនា មគ្គ និងផល តែសតិឈ្មោះថា ស្ងប់ ព្រោះមានឧបការៈ ដល់សេចក្តីស្ងប់ទាំងពីរនោះ ព្រោះមានទាំងអស់ អារម្មណ៍ឈ្មោះថា ស្ងប់ ព្រោះតាំងមាំដោយសមថៈ ។ បទថា **អនវជ្ជដ្ឋោ** ធម៌ដែលមិនមានទោសជាប្រយោជន៍ គឺ សភាវៈនៃវិបស្សនាមិនមានទោស ។ បទថា **និក្កិលេសដ្ឋោ** ធម៌ដែលមិនមានកិលេសជាប្រយោជន៍ គឺ សភាវៈនៃមគ្គមិនមានកិលេស ។ បទថា **វោទាដ្ឋោ** ធម៌មានភាពផូរផង់ជាប្រយោជន៍ គឺ សភាវៈនៃផលបរិសុទ្ធ ។ បទថា **បរមដ្ឋោ** ធម៌ដ៏ប្រសើរជាប្រយោជន៍ គឺ សភាវៈនៃនិព្វានជាធម៌ខ្ពង់ខ្ពស់បំផុត ជាងធម៌ទាំងពួង ។ បទថា **បដិវិជ្ឈតិ** រមែងចាក់ធ្លុះ គឺ ចាក់ធ្លុះសភាវៈនោះ ៗ ដោយការមិនវង្វេង ។ ក្នុងបទនេះ លោកពោលដល់ការចាក់ធ្លុះដោយប្រពៃដោយបទនេះ មានជាអាទិ៍ថា **អារម្មណស្ស ឧបដ្ឋានំ** ប្រាកដនូវអារម្មណ៍ ។ ម្យ៉ាងទៀត ក្នុងបទនេះនោះឯង ព្រោះលោកពោលដល់ការចាក់ធ្លុះធម៌ ដែលមានសភាពផូរផង់ជាប្រយោជន៍ ទើបជាការពោលដល់ធម៌ដែលមិនមានទោសជាប្រយោជន៍ ធម៌ដែលមិនមានកិលេសជាប្រយោជន៍ និងធម៌ដ៏ប្រសើរជាប្រយោជន៍ មានលក្ខណៈដូចគ្នា ។ ដូចដែលលោកពោលទុកថា :-

**ធម៌ជាគ្រឿងនាំទៅ មានលក្ខណៈដូចដែលលោកពោលថា**

**កាលពោលដល់ធម៌ដូចគ្នា ជាការពោលដល់ធម៌ខ្វះទាំងអស់**
**ដែលមានលក្ខណៈដូចគ្នា ។**

ម្យ៉ាងទៀត ក្នុងបទនេះថា ធម៌ដែលមិនមានទោសជាប្រយោជន៍ ធម៌ដែលមិនសៅហ្មង ឈ្មោះថា ជាធម៌ស្ងប់ជាប្រយោជន៍ ព្រោះជាប្រយោជន៍នៃសេចក្ដីស្ងប់ពោលគឺការមិនរាយមាយ ។ ធម៌ដែលផូរ-ផង់ជាប្រយោជន៍ ឈ្មោះថា ជាធម៌មានសេចក្ដីស្ងប់ជាប្រយោជន៍ ព្រោះសេចក្ដីស្ងប់នោះឯង សំដៅដល់សេចក្ដីផូរផង់នៃវិបស្សនា និងមគ្គ ។ ឈ្មោះថា ជាធម៌មានសេចក្ដីស្ងប់ជាប្រយោជន៍ ព្រោះជាប្រយោជន៍នៃសេចក្ដីស្ងប់ ពោលគឺ សេចក្ដីផូរផង់នៃមគ្គ សំដៅដល់ សេចក្ដីផូរផង់នៃផល ។ ចំណែកធម៌ដ៏ប្រសើរជាប្រយោជន៍ ជាធម៌មានការស្ងប់ជាប្រយោជន៍ ព្រោះមានសេចក្ដីស្ងប់នោះឯង ជាប្រយោជន៍ ឬព្រោះជាប្រយោជន៍នៃសេចក្ដីស្ងប់ទាំងអស់ ព្រោះប្រកបដោយនិព្វាន សេចក្ដីស្ងប់ និងធម៌ដែលមានសេចក្ដីស្ងប់ជាប្រយោជន៍ មានប្រការដូចពោលហើយនោះ លោកធ្វើឲ្យជាឯកសេសមាសសរុបជាឯកទេស ហើយទើបពោលថា **សមត្ថញ្ច បដិវិជ្ឈតិ** ចាក់ធ្លុះធម៌ដែលមានសេចក្ដីស្ងប់ជាប្រយោជន៍ ។ ធម៌ គឺ ឥន្ទ្រិយពល និងពោជ្ឈង្គៈ រមែងមានសូម្បីក្នុងខណៈនៃវិបស្សនា មគ្គ និងផល ។



មគ្គ និងវិសុទ្ធិ ៣ រមែងបានក្នុងខណៈមគ្គផលនោះឯង ។ វិមោក្ខ វិជ្ជា និងការដឹងក្នុងការអស់ទៅ រមែងបានក្នុងខណៈមគ្គនោះឯង ។ វិមុត្តិ និងការដឹងក្នុងការមិនកើត រមែងបានក្នុងខណៈផលនោះឯង ។ ដ៏សេសរមែងបានសូម្បីក្នុងខណៈវិបស្សនា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មវារៈដូចតទៅនេះ បទថា **ឥមេ ធម្មេ ឥមស្មឹ អារម្មណេ សមោធានេតិ** ញ៉ាំងធម៌ទាំងនេះឲ្យប្រជុំចុះក្នុងអារម្មណ៍នេះ គប្បីជ្រាបធម៌ដ៏សេសតាមការប្រកប វៀរនិព្វាន ។ លោកពោលបទនេះ ដោយអំណាចជាយេភុយ្យន័យ (ជាចំណែកច្រើន) ម្យ៉ាងទៀត ក្នុងបទនេះ លោកពោលអត្ថដែលនៅមិនទាន់បានពោលទុកហើយក្នុងខាងក្រោយ ។ សូម្បីកាលលោកសម្ដែងធម៌ជាគ្រឿងនាំចេញដោយចតុក្កៈមួយ ៗ ក៏ជាការសម្ដែងដល់ធម៌ជាគ្រឿងនាំចេញដោយចំណែកមួយ ៗ ព្រោះចំណែកសូម្បីមួយ ៗ មានការឈានចុះទៅក្នុងទីបំផុតនៃចតុក្កៈ ជាឧបនិស្ស័យនៃធម៌ជាគ្រឿងនាំចេញ ព្រោះវៀរចំណែកមួយ ៗ ចេញ មិនជាការនាំចេញ ។

(ចប់អដ្ឋកថា សម្ដែងខ្យល់ដកដង្ហើមចូល និងចេញវែង)

គប្បីជ្រាបវិនិច្ឆ័យក្នុងវេស្សនិទ្ទេសដូចតទៅនេះ ។ បទថា **វិត្ត-វេសង្ខាតេ** ក្នុងខណៈដែលរាប់បានបន្តិចបន្តួច គឺ ក្នុងកាលដែលរាប់បានតិចតួច ។ បទដ៏សេសគប្បីជ្រាបដោយន័យដូចពោលហើយក្នុងនិទ្ទេសនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សព្វកាយបដិសំវេទិនិទ្ទេស** ដូចតទៅនេះ ។ ដើម្បីកាន់យកសេចក្ដីសុខព្រោះវេទនាក្នុងអរូបធម៌គ្រោតគ្រាត លោកទើបពោលដល់វេទនា សោយឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍មុន បន្ទាប់ពីនោះ ពោលដល់សញ្ញាកាន់យកអាការនៃអារម្មណ៍របស់វេទនា យ៉ាងនេះថា បុគ្គលរមែងដឹងព្រមដល់វេទនាដែលសោយ បន្ទាប់ពីនោះ ពោលដល់ចេតនាដែលជាអភិសង្ខារដោយអំណាចនៃសញ្ញា បន្ទាប់ពីនោះពោលដល់ផស្សៈ ព្រោះបាលីថា សម្ផ័ស្សហើយ រមែងសោយអារម្មណ៍ សម្ផ័ស្សហើយ រមែងដឹងវេទនា សម្ផ័ស្សហើយ រមែងនឹកគិតដល់វេទនា បន្ទាប់ពីនោះពោលដល់មនសិការ ដែលមានលក្ខណៈទូទៅនៃវេទនាទាំងពួង ពោលដល់សង្ខារក្ខន្ធដោយចេតនាជាដើម កាលលោកពោលដល់ខន្ធ ៣ យ៉ាង យ៉ាងនេះ ជាការពោលដល់វិញ្ញាណក្ខន្ធអាស្រ័យខន្ធនោះ ។ បទថា **នាមញ្ច** បានដល់ នាមមានប្រការដូចដែលពោលហើយ ។ បទថា **នាមកាយោ ច** នេះ លោកពោលដើម្បី



នាំនាមនោះចេញ ព្រោះលោកសង្គ្រោះនិព្វានចូលដោយនាម និងព្រោះលោកុត្តរធម៌មិនចូលដល់វិបស្សនា គឺ លោកនាំយកនិព្វានចេញ ដោយពាក្យថា **កាយោ** ព្រោះនិព្វានផុតចាកខន្ធ ។ បទថា **យេ ច វុច្ចន្តិ ចិត្តសង្ខារា** លោកពោលចិត្តសង្ខារថា ជានាមកាយ គឺ លោកពោលថា ចិត្តសង្ខារ សូម្បីពោលយ៉ាងនេះថា សញ្ញា និងវេទនាជាចេតសិក ធម៌ទាំងនេះជាប់ទាក់ទងដោយចិត្ត ជាចិត្តសង្ខារ ក៏សង្គ្រោះចូលដោយនាមកាយក្នុងទីនេះ ។

បទថា **មហាភូតា មហាភូតរូប** ឈ្មោះថា **មហាភូតា** ព្រោះជាធំដោយភាពប្រាកដធំ ដោយភាពសាមញ្ញជារបស់ធំ ដោយបរិហារធំ ដោយខុសប្រក្រតីធំ ។ មហាភូតរូបមាន ៤ យ៉ាងគឺ **បឋវី អាបោ តេជោ វាយោ** ។ បទថា **ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ** រូបដែលអាស្រ័យមហាភូតរូប ៤ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ សេចក្ដីថា រូបដែលនៅមិនទាន់លះនៅប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវមហាភូតរូប ៤ ។ ក៏ឧបាទាយរូបនោះមាន ២៤ យ៉ាង គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ រូប សំឡេង ក្លិន រស ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ហទយវត្ថុ ឱជា កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបលហុតា រូបមុទុតា រូបកម្មញ្ញតា ឧបចយរូប សន្តតិរូប ជរតារូប អនិច្ចតារូប ។

បទថា **អស្សាសោ ច បស្សាសោ ច** គឺ ខ្យល់អស្សាសបស្សាសៈតាមប្រក្រតីនោះឯង ។ សូម្បីបដិភាគនិមិត្តកើតឡើង ព្រោះអាស្រ័យខ្យល់អស្សាសបស្សាសៈ ក៏បានឈ្មោះនោះ ដូចបឋវីកសិណជាដើម ។ម្យ៉ាងទៀត ព្រោះឃើញស្រដៀងរូបបដិភាគនិមិត្ត ទើបបានឈ្មោះថា រូប ដូចក្នុងប្រយោគមានជាអាទិ៍ថា ឃើញរូបក្នុងខាងក្រៅ ។

បទថា **និមិត្តញ្ច ឧបនិពន្ធនា** គឺ ដែលសម្ព័ន្ធខ្យល់អស្សាសបស្សាសៈ ជានិមិត្តនៃការជាប់ទាក់ទងគ្នាដោយសតិ ។

បទថា **យេ ច វុច្ចន្តិ កាយសង្ខារា** លោកពោលកាយសង្ខារថាជារូបកាយ គឺ លោកពោលថា កាយសង្ខារសូម្បីពោលយ៉ាងនេះថា ខ្យល់អស្សាសបស្សាសៈប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ទាក់ទងដោយកាយ ជាកាយសង្ខារ ក៏សង្គ្រោះចូលដោយរូបកាយក្នុងទីនេះ ។

បទថា **តេ កាយា បដិវិទិតា ហោន្តិ** កាយទាំងនោះ រមែងប្រាកដ គឺ កាយមានខ្យល់អស្សាសបស្សាសៈជានិមិត្ត ក្នុងខណៈនៃឈាន កាយមានរូប និងមិនមានរូបដ៏សេសក្នុងខណៈនៃវិបស្សនា រមែងប្រាកដជាអារម្មណ៍ ក្នុងខណៈនៃមគ្គ រមែងប្រាកដដោយការមិនវង្វេង ។

លោកពោលបទមានជាអាទិ៍ថា **ទីឃំ អស្សាសបស្សាសវសេន** ដោយអំណាចនៃខ្យល់អស្សាសបស្សាសៈវែង សំដៅដល់ សូម្បីក្នុង



វិបស្សនាមគ្គកើតឡើងហើយដល់ព្រះយោគាវចរ អ្នកបានឈានដោយអំណាចនៃខ្យល់អស្សាសបស្សាសៈ ។

បទមានជាអាទិ៍ថា **អាវជ្ជតោ បជានតោ** កាលនឹកដល់ កាលដឹង មានសេចក្ដីដូចបានពោលហើយក្នុងសីលកថា ។ លោកធ្វើកាយទាំងឡាយមានប្រការដូចពោលហើយទាំងនោះ ទុកក្នុងខាងក្នុងហើយពោលថា **សព្វកាយបដិសំវេទី** ជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួង ។

ក្នុងបទមានជាអាទិ៍ថា **សព្វកាយបដិសំវេទី អស្សាសបសានំ សំវរដ្ឋេន** ដោយអត្ថថា ភាពជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួង ប្រុងប្រយ័ត្នខ្យល់ដកដង្ហើមចេញ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ការសង្រួមក្នុងឈាន វិបស្សនា មគ្គដែលកើតឡើងហើយ ព្រោះខ្យល់អស្សាសបស្សាសៈ ដូចលោកពោលថា **សព្វកាយបដិសំវេទី** ជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួង ជាសីលវិសុទ្ធិដោយអត្ថថា ប្រុងប្រយ័ត្ន ការមិនរាយមាយជាចិត្តវិសុទ្ធិដោយអត្ថថា មិនរាយមាយ បញ្ញានោះឯងជាទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ត្រឹមតែការមិនមានបាប សូម្បីក្នុងការមិនមានវិរតិក្នុងឈាន និងវិបស្សនាក៏គប្បីជ្រាបថា ឈ្មោះថា សង្រួម ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃបទមានជាអាទិ៍ថា **បស្សម្ភយំ** រម្ងាប់ ដូចតទៅនេះ ។ បទថា **កាយិកា** ប្រព្រឹត្តទៅតាមកាយ គឺ មាន

ក្នុងរូបកាយ ។ បទថា **កាយបដិពទ្ធា** គឺ ជាប់ដោយកាយ អាស្រ័យកាយ ។ កាលមានកាយ ខ្យល់អស្សាសបស្សាសៈក៏មាន កាលកាយមិនមាន ខ្យល់អស្សាសបស្សាសៈក៏មិនមាន ព្រោះដូច្នោះ ខ្យល់អស្សា-សបស្សាសៈ ទើបឈ្មោះថា កាយសង្ខារ ព្រោះខ្យល់អស្សាសប-ស្សាសៈទាំងនោះ តាក់តែងឡើងដោយកាយ ។ បទថា **បស្សម្ភេន្តោ** រម្ងាប់ គឺ ឲ្យរំលត់ ឲ្យរម្ងាប់ ។ ការរម្ងាប់កាយសង្ខារយ៉ាងគ្រោតគ្រាត សម្រេចដោយពាក្យថា **បស្សម្ភន** ។ បទថា **និរោធេន្តោ** រំលត់ គឺ រំលត់ដោយមិនឲ្យកាយសង្ខារយ៉ាងគ្រោតគ្រាតកើតឡើង ។ បទថា **វូបសមេន្តោ** ស្ងប់ គឺ នាំសេចក្តីស្ងប់ដោយន័យនៃការប្រែប្រួលសន្តតិឯណាមួយ ក្នុងកាយសង្ខារយ៉ាងគ្រោតគ្រាតនោះឯង ។ បទថា **សិក្ខតិ** រមែងភ្ជាប់សេចក្តីថា រមែងសិក្សាថា យើងនឹងដកដង្ហើមចូល ដោយអំណាចនៃអធិការ ( នាទី ) ឬរមែងសិក្សាត្រៃសិក្ខា ។ ឥឡូវនេះ ដើម្បីសម្តែងដល់ការរម្ងាប់កាយសង្ខារយ៉ាងគ្រោតគ្រាត លោកទើបពោលពាក្យមានជាអាទិ៍ថា **យថារូបេហិ** ព្រោះកាយសង្ខារបែបណា ។

បទថា **អានមនា** ការទន់ទៅ គឺ បង្អោនទៅខាងក្រោយ ។ បទថា **វិនមនា** ការបង្អោនទៅ គឺ បង្អោនទៅទាំងពីរខាង ។ បទថា **សន្នមនា** ការទោរទៅ គឺ ទោរទៅយ៉ាងល្អរបស់កាយសង្ខារ ដែលទោរទៅសូម្បី



ដោយខាងទាំងពួង ។ បទថា **បណាមនា** ការឱនទៅ គឺ ឱនទៅខាងមុខ ។ បទថា **ឥញ្ជនា** ការញាប់ញ័រ គឺ ញ័រទៅ ។ បទថា **ផន្ទនា** ការរើបម្រះ គឺ រើទៅបន្តិចបន្តួច ។ បទថា **បកម្បនា** ការលើក គឺ យោងទៅមកច្រើន ។ គប្បីធ្វើការភ្ជាប់សេចក្តីថា ការទន់ទៅ ។ល។ ការលើកកាយ ដោយកាយសង្ខារបែបណា រម្ងាប់កាយសង្ខារបែបនោះ និងការទន់ទៅ ។ល។ ការលើកណានៃកាយ រម្ងាប់ការទន់ទៅជាដើមនោះ ព្រោះកាលកាយសង្ខាររម្ងាប់ ក៏ជាការរម្ងាប់ការទន់ទៅជាដើមនៃកាយ ។ គប្បីជ្រាបដោយការភ្ជាប់សេចក្តីថា កាយមិនមានការទន់ទៅជាដើម ដោយកាយសង្ខារបែបណា រម្ងាប់កាយសង្ខារ សូម្បីល្អិតសុខុមបែបនោះបាន ។ កាយមិនមានការទន់ទៅជាដើមណា រម្ងាប់កាយសង្ខារដែលល្អិតសុខុមនោះបាន ។ បទថា **សន្តំ សុខុមំ** ល្អិតសុខុមនេះ ជាការវនបុំសកៈ ( ជានបុំសកលិង្គ ) ក្នុងបទថា **ឥតិ កិរ** នេះ បទថា **ឥតិ** មកក្នុងសេចក្តីថា **ឯវំ** យ៉ាងនេះ ។ បទថា **កិរ** មកក្នុងសេចក្តីថា **យទិ** ប្រសិនបើថា គឺ ប្រសិនបើនិយាយត ៗ គ្នាមកថា ភិក្ខុរមែងសិក្សាថា យើងនឹងរម្ងាប់ខ្យល់អស្សាសបស្សាសៈសូម្បីសុខុមយ៉ាងនេះ រមែងដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។

ម្យ៉ាងវិញទៀត បទថា **កិរ** លោកអធិប្បាយថា ព្រោះជាពាក្យ

*និយាយត ៗ គ្នា ទើបគួរចុះក្នុងអត្ថថា មិនគួរជឿ មិនគួរអត់ទ្រាំ និង មនុស្សដទៃគេនិយាយមក យើងទើបមិនជឿ មិនអត់ទ្រាំ មិនប្រចក្ស ដល់យើងថា ភិក្ខុរមែងសិក្សាការរម្ងាប់កាយសង្ខារ សូម្បីសុខុមដោយ ប្រការដូច្នេះ ដូច្នោះ ។*

*បទថា* **ឯវំ សន្តេ** *កាលជាយ៉ាងនេះ គឺ កាលរម្ងាប់កាយសង្ខារ ដែលសុខុមយ៉ាងនេះមានហើយ ។ បទថា* **វាតូបលទ្ធិយា ច បភាវនា ន ហោតិ** *ការបានខ្យល់ក៏មិនប្រាកដ គឺ បានខ្យល់អស្សាសបស្សាសៈ ។ បទថា* **ឧបលទ្ធិ** *ការបាន គឺ ការដឹង សេចក្តីថា ការដឹងក្នុងភាវនា ដែលមានខ្យល់អស្សាសបស្សាសៈនោះជាអារម្មណ៍ ដែលបានទទួល ខ្យល់អស្សាសបស្សាសៈមក រមែងមិនប្រាកដ គឺ មិនកើត អារម្មណ៍ នោះមិនមានភាវនា ។*

*បទថា* **អស្សាសបស្សាសានញ្ច បភាវនា ន ហោតិ** *ខ្យល់ អស្សាសបស្សាសៈក៏មិនប្រាកដ សេចក្តីថា ព្រោះរលត់ខ្យល់អស្សា-សបស្សាសៈ សូម្បីសុខុមដោយភាវនា ខ្យល់អស្សាសបស្សាសៈទាំង នោះក៏មិនកើត មិនប្រាកដ ។*

*បទថា* **អានាបានស្សតិយា ច បភាវនា ន ហោតិ** *អានាបា-នស្សតិក៏មិនប្រាកដ គឺ សតិសម្បយុត្តដោយការដឹងក្នុងភាវនា ដែល*



*មានអានាបានស្សតិនោះជាអារម្មណ៍ ព្រោះមិនមានខ្យល់អស្សាស-បស្សាសៈ ក៏មិនប្រាកដ ព្រោះដូច្នោះ ការចម្រើនអានាបានស្សតិសមាធិ ដែលសម្បយុត្តដោយការដឹងក្នុងភាវនានោះ រមែងមិនមាន ។ បទថា* **ច នំ** *ក្នុងបទនេះថា* **ន ច នំ តំ** *ត្រឹមតែជានិបាតដូចក្នុងបទថា* **ភិក្ខុ ច នំ** *ជាដើម ។ ក្អាប់សេចក្តីថា បណ្ឌិតទាំងឡាយនឹងចូលសមាបត្តិដូច ដែលពោលហើយនោះក៏មិនមែន សូម្បីនឹងចេញចាកសមាបត្តិនោះ ក៏ មិនមែន ។*

*បទថា* **ឥតិ កិរ** *គឺ ដោយប្រការយ៉ាងនេះ ដោយជាពាក្យ របស់ពួកអ្នកនិយាយត ៗ គ្នា ។ គប្បីឃើញថា* **កិរ** *សព្ទក្នុងបទនេះចុះ ក្នុងអត្ថថា ដោយប្រការយ៉ាងនេះ ។ បទថា* **ឯវំ សន្តេ** *គឺ កាលការ រម្ងាប់មានហើយយ៉ាងនេះ ។ បទថា* **យថា កថំ វិយ** *សេចក្តីនោះដូចម្តេច គឺ សួរការប្រៀបធៀបថា សេចក្តីនោះដូចវិធីដែលពោលទុកដូចម្តេច លោកសម្តែងការប្រៀបធៀបនោះ ដោយបទថា* **សេយ្យថាបិ** *ដូចជា ។*

*បទថា* **កំសេ** *រគាំង គឺ ភាជនធ្វើដោយលោហៈ។ បទថា* **និមិត្តំ** *គឺ អាការនៃសំឡេងទាំងនោះ ។ ម្យ៉ាងវិញទៀត បទថា* **និមិត្តំ** *ជា ទុតិយាវិភត្តិចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ សេចក្តីថា នៃនិមិត្ត និមិត្តនៃសំឡេង មិនមែនដទៃពីសំឡេង ។ បទថា* **សុគ្គហិតត្តា** *គឺ ព្រោះកាន់យកដោយ*

ល្អ ។ បទថា **សុមនសិកតត្តា** គឺ ព្រោះនឹកគិតដោយល្អ ។ បទថា **សុបធារិតត្តា** ព្រោះទ្រទ្រង់ចាំទុកដោយល្អ គឺ តាំងទុកក្នុងចិត្តដោយល្អ ។

បទថា **សុខុមនិមិត្តារម្មណត្តាបិ** សូម្បីព្រោះនិមិត្តនៃសំឡេងល្អិតជាអារម្មណ៍ គឺ ព្រោះសំឡេងសូម្បីល្អិតក្នុងកាលនោះរលត់ទៅ ចិត្តសូម្បីមាននិមិត្តនៃសំឡេងជាអារម្មណ៍ល្អិតជាងរមែងមានបាន ព្រោះធ្វើនិមិត្តនៃសំឡេងល្អិតជាង សូម្បីមិនជាអារម្មណ៍នៃនិមិត្តសំឡេង តាមដែលកំណត់ទុក ។ មា៉្យងទៀត សូម្បីព្រោះភាពជានិមិត្តនៃសំឡេងល្អិតជាងជាអារម្មណ៍ ។ គប្បីជ្រាបសេចក្តីសូម្បីក្នុងអប្បនាដោយន័យនេះឯង ។

ក្នុងបទមានជាអាទិ៍ថា **បស្សម្ភយំ** គប្បីជ្រាបការប្រកបថា ខ្យល់អស្សាសបស្សាសៈ លោកពោលថា រម្ងាប់កាយសង្ខារ គឺ **កាយ** ឬខ្យល់អស្សាសបស្សាសៈ ក្នុងបទនេះថា រម្ងាប់កាយសង្ខារ គឺ កាយ ។ កាលព្រះយោគាវចរមានការនឹកគិតថា កាលកាយសង្ខារសូម្បីរម្ងាប់ទៅដោយភាវនាវិសុទ្ធិ ( សេចក្តីបរិសុទ្ធនៃភាវនា ) យើងនឹងរម្ងាប់កាយ-សង្ខារយ៉ាងគ្រោតគ្រាត ដូច្នេះ ឈ្មោះថា រម្ងាប់យ៉ាងក្រៃលែង ដោយការយកចិត្តទុកដាក់នោះ ការដកដង្ហើមយ៉ាងសុខុមក៏នៅមិនទាន់ប្រាកដ ។

បទថា **អដ្ឋអនុបស្សនេ ញាណានិ** ញាណក្នុងការពិចារណា ៨



បានដល់ អនុបស្សនាញាណ ៨ គឺ កាលពោលវត្ថុ ៤ ថា ជាអ្នកដឹងច្បាស់កងខ្យល់ទាំងពួង វែង ខ្លី រម្ងាប់កាយសង្ខារ ដោយអំណាចខ្យល់អស្សាសៈ ៤ ដោយអំណាចខ្យល់បស្សាសៈ ៤ ។

បទថា **អដ្ឋ ច ឧបដ្ឋានានុស្សតិយោ** អនុស្សតិដែលប្រាកដ ៨ បានដល់ ឧបដ្ឋានានុស្សតិ ៨ គឺ កាលលោកពោលដល់វត្ថុ ៤ ដោយន័យមានជាអាទិ៍ថា កាលដឹងសភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃខ្យល់ដកដង្ហើមចូលវែង សតិរមែងតាំងមាំដោយអំណាចនៃខ្យល់អស្សាសៈ ៤ ដោយអំណាចនៃខ្យល់បស្សាសៈ ៤ ។

បទថា **ចត្តារិ សុត្តន្តិកវត្ថូនិ** រឿងដែលមានមកក្នុងព្រះសូត្រ ៤ គឺ សុត្តន្តិកវត្ថុ ៤ ដោយអំណាចនៃចតុក្កៈទី ១ ព្រោះព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ទុកហើយក្នុងអានាបានស្សតិសូត្រ ។

(ចប់អដ្ឋកថាបឋមចតុក្កនិទ្ទេស)

ចប់ភាណវារៈ

## ចតុក្កៈទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុងបីតិបដិសំវេទិនិទ្ទេសនៃចតុកទី ២ ដូចតទៅនេះ ក្នុងបទថា **ឧប្បជ្ជតិ បីតិបាមុជ្ជំ** បីតិ និងបាមោជ្ជៈរមែងកើត ។ បទថា **បីតិ** ជាមូលបទ ។ បទថា **បាមុជ្ជំ** ជាបទពង្រីកសេចក្តី គឺការរីរាយទន់ ។ ក្នុងបទមានជាអាទិ៍ថា **យា បីតិ បាមុជ្ជំ** លោកពោលថា បីតិ រមែងបានឈ្មោះមានជាអាទិ៍យ៉ាងនេះថា បីតិ និងបាមោជ្ជៈ ។ ក្នុងបទទាំងនោះ បទថា **បីតិ** ជាបទសម្តែងសភាវៈ ។ ការកើតនូវការរីករាយទន់ ឈ្មោះថា **បាមុជ្ជំ** ។ អាការនៃភាពរីករាយ ឈ្មោះថា **អាមោទនា** ។ អាការនៃការសប្បាយ ឈ្មោះថា **បមោទនា** ។ម្យ៉ាងទៀត ការធ្វើភេសជ្ជៈ ប្រេង ឬទឹកក្តៅទឹកត្រជាក់ឲ្យរួមជាចំណែកដូចគ្នា លោកហៅថា **មោទនា** យ៉ាងណា សូម្បីដោយការធ្វើធម៌ទាំងឡាយឲ្យរួមជាមួយគ្នា ក៏ហៅថា **មោទនា** ដូច្នោះ ។ លោកពោលថា **អាមោទនា បមោទនា** ព្រោះបន្ថែមបទឧបសគ្គចុះទៅ ។ ឈ្មោះថា **ហាសោ** ព្រោះអត្ថថា ត្រេកអរ ។ ឈ្មោះថា **បហាសោ** ព្រោះអត្ថថា រីករាយ ។ បទនេះ ជាឈ្មោះនៃសេចក្តីត្រេកអររីករាយ ។ ឈ្មោះថា **វិត្តិ** ព្រោះការសប្បាយចិត្ត ។ បទនេះ ជាឈ្មោះរបស់ទ្រព្យ ។ ម្យ៉ាងទៀត ឈ្មោះថា **វិត្តិ** ព្រោះជាបច្ច័យនៃសោមនស្ស ព្រោះធ្វើឲ្យកើតការសប្បាយចិត្ត ។ ដូចជាសោមនស្ស រមែងកើតសូម្បីដល់មនុស្ស



មានទ្រព្យ ព្រោះអាស្រ័យទ្រព្យ យ៉ាងណា សេចក្តីសោមនស្ស រមែងកើតសូម្បីដល់មនុស្សមានបីតិ ព្រោះអាស្រ័យបីតិ ដូច្នោះ ព្រោះដូច្នោះ លោកទើបពោលថា **វិត្តិ** ការសប្បាយចិត្ត ។ ពិតណាស់ បទនេះ ជាឈ្មោះរបស់បីតិ ដែលស្ថិតនៅនៃការត្រេកអរទុក ។ ម្យ៉ាងទៀត បុគ្គលអ្នកមានបីតិ លោកហៅថា **ឧទគ្គោ** អ្នកត្រេកអរ ព្រោះជាអ្នកមានកាយ និងចិត្តខ្ពង់ខ្ពស់ក្រៃលែង ។ ចំណែកភាពជាអ្នកមានចិត្តខ្ពស់ ឈ្មោះថា **ឱទគ្យំ** ។ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា** ការសប្បាយចិត្ត ។ ពិតណាស់ ចិត្តរបស់អ្នកមិនត្រេកអរ ព្រោះទុក្ខជាហេតុ មិនឈ្មោះថា មានចិត្តជារបស់ខ្លួន ។ ចិត្តរបស់អ្នកត្រេកអរ ព្រោះសុខជាហេតុ ឈ្មោះថា មានចិត្តជារបស់ខ្លួន ។ ភាពជាអ្នកមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា** ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រោះភាពជាអ្នកមានចិត្តជារបស់ខ្លួន មិនមែនរបស់នរណាៗដទៃ សភាពនៃចិត្តនោះឯង ឈ្មោះថា ចេតសិកធម៌ ដូច្នោះលោកទើបពោលថា **អត្តមនតា ចិត្តស្ស** សភាពនៃចិត្តជារបស់ខ្លួន ។ បទដ៏សេសគប្បីជ្រាបការប្រកបដោយន័យដូចបានពោលទុកហើយ ក្នុងខាងក្រោយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សុខបដិសំវេទិនិទ្ទេស** ដូចតទៅនេះ ។ បទថា **ទ្វេ សុខានិ** សុខមាន ២ យ៉ាង លោកពោលដើម្បីសម្តែងដល់

ភូមិរបស់សមថៈ និងវិបស្សនា ។ ព្រោះកាយិកសុខ ( សុខផ្លូវកាយ ) ជាភូមិរបស់វិបស្សនា ។ ចេតសិកសុខ ( សុខផ្លូវចិត្ត ) ជាភូមិរបស់សមថៈ និងវិបស្សនា ។

បទថា **កាយិកំ** កាយិកសុខ ឈ្មោះថា **កាយិកំ** ព្រោះប្រកបហើយក្នុងកាយ ដោយកើតឡើងតាមលំដាប់ វៀរបសាទកាយ ។ បទថា **ចេតសិកំ** ចេតសិកសុខ ឈ្មោះថា **ចេតសិក** ព្រោះប្រកបទុកក្នុងចិត្ត ដោយមិនប្រាសទៅ ។ ក្នុងពីរបទនោះ បដិសេធចេតសិកសុខ ដោយបទថា **កាយិក** ។ បដិសេធកាយិកទុក្ខ ដោយបទថា **សុខ** ។ម្យ៉ាងទៀត បដិសេធកាយិកសុខ ដោយបទថា **ចេតសិក** ។ បដិសេធចេតសិកទុក្ខ **សុខ** ។

បទថា **សាតំ** ការឆ្ងាញ់ពិសារ គឺ ការផ្អែម ផ្អែមដោយល្អ ។ បទថា **សុខំ** គឺ សុខនោះឯង មិនមែនទុក្ខ ។

បទថា **កាយសម្ផស្សជំ** គឺ កើតក្នុងកាយសម្ផ័ស្ស ។ បទថា **សាតំ សុខំ វេទយិកំ** សេចក្ដីសុខដែលបានសោយ ជាការឆ្ងាញ់ពិសារ គឺ សេចក្ដីសុខដែលបានសោយ ជាការឆ្ងាញ់ពិសារ ដែលមិនបានសោយមិនជាការឆ្ងាញ់ពិសារ សេចក្ដីសុខដែលបានសោយ មិនមែនសេចក្ដីទុក្ខដែលបានសោយ ។ បីបទតទៅ លោកពោលដោយឥត្ថីលិង្គ ។ សេចក្ដី



ក្នុងបទនេះមានជាអាទិ៍ថា **សាតា វេទនា ន អសាតា សុខ វេទនា នទុក្ខា** សុខវេទនាជា ការឆ្ងាញ់ពិសារ មិនមែនការមិនឆ្ងាញ់ពិសារ វេទនាជាសុខ មិនមែនជាទុក្ខ ។

គប្បីប្រកបចេតសិកសុខនិទ្ទេស ដោយន័យផ្ទុយគ្នា ដែលលោកពោលហើយ ។ បទថា **តេ សុខា** សុខទាំងនោះ ជាលិង្គវិបល្លាស ។ លោកពោលថា **តានិ សុខានិ** ។ បទដ៏សេសក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងបឋមចតុក្កៈ ក្រោយក្នុងចតុក្កៈ គប្បីជ្រាបសុត្តន្តិកវត្ថុ ( រឿងដែលមានក្នុងព្រះសូត្រ ) ដោយអំណាចនៃទុតិយចតុក្កៈ ។

(ចប់អដ្ឋកថាទុតិយចតុក្កនិទ្ទេស)

ចប់ភាណវារៈ

## ចតុក្កៈទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង **តតិយចតុក្កៈនិទ្ទេស** ដូចតទៅនេះ ។ បទថា **ចិត្តំ** ជាមូលបទ ។ បទថា **វិញ្ញាណំ** ជាបទពង្រើកសេចក្តី ។ បទមានជាអាទិ៍ថា **យំ ចិត្តំ** ចិត្តណា គប្បីប្រកបដោយន័យដូចពោល ហើយក្នុងបីតិ ។ ក្នុងបទមានជាអាទិ៍ថា **ចិត្តំ** នោះ ឈ្មោះថា **ចិត្តំ** ព្រោះវិចិត្រដោយចិត្ត ។ ឈ្មោះថា **មនោ** ព្រោះកំណត់ដឹងអារម្មណ៍ ។ បទថា **មានសំ** គឺ ចិត្តនោះឯង ។ លោកពោលធម៌ដែលសម្បយុត្ត ហើយថា **មានសោ** ក្នុងបទនេះថា អន្ទាក់ណា មានចិត្តត្រាច់ទៅក្នុងអាកាស ដូច្នេះជាដើម ព្រះអរហត្ត លោកពោល **មានសំ** ក្នុងបទនេះថា

> **បពិត្រព្រះមានព្រះភាគជាម្ចាស់ អ្នកប្រាកដក្នុងពួកជន**
> **សាវករបស់ព្រះអង្គ ត្រេកអរក្នុងព្រះសាសនានៅមិន**
> **បានសម្រេចព្រះអរហត្ត នៅជាព្រះសេក្ខៈ ដូចម្តេច**
> **នឹងគប្បីធ្វើកាលកិរិយា ។**

បទថា **ហទយំ** គឺ ចិត្ត ។ ឧរៈ លោកពោលថា **ហទ័យ** ក្នុងបទមានជាអាទិ៍ថា យើងនឹងធ្វើចិត្តរបស់លោកឲ្យច្រួលច្រាល ឬនឹងហែកទ្រូងរបស់លោក ។ លោកពោលថា **ចិត្ត** ក្នុងបទមានជាអាទិ៍ថា ឃើញថានឹងស្មោះចិត្តចាកចិត្តដោយការមិនដឹង ។ លោកពោលហទយវត្ថុ ក្នុងបទថា **វក្កំ ហទយំ** ។ តែក្នុងទីនេះ **ចិត្ត** លោកពោលថា **ហទយ**



ព្រោះអត្ថថា នៅខាងក្នុង ។ ចិត្ត នោះឈ្មោះថា **បណ្ឌរំ** ព្រោះអត្ថថា បរិសុទ្ធ លោកពោលសំដៅដល់ **ភវង្គចិត្ត** ។ ដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះបរិសុទ្ធ តែចិត្តនោះត្រូវឧបក្កិលេសទាំងឡាយដែលត្រាច់មក ទើបសៅហ្មង ។ ម្យ៉ាងទៀត សូម្បីចិត្តអកុសល លោកក៏ពោលថា **បណ្ឌរ** ដូចគ្នា ព្រោះអកុសល ចេញចាកចិត្តនោះហើយ ដូចស្ទឹងគង្គាហូរចេញ ពីស្ទឹងគង្គា និងដូចស្ទឹងគោធាវរី ហូរចេញពីស្ទឹងគោធាវរី ដូច្នោះ ។ ម្យ៉ាងទៀត ព្រោះចិត្តមានលក្ខណៈដឹងអារម្មណ៍ ទើបមិនមែនជាកិលេស ដោយការសៅហ្មង ដោយសភាវៈជាចិត្តបរិសុទ្ធិតែម្យ៉ាង តែកាលប្រកបដោយឧបក្កិលេស ចិត្តទើបសៅហ្មង ព្រោះហេតុនោះ ទើបគួរពោលថា **បណ្ឌរ** ( ផូរផង់ ) ។ ម្យ៉ាងទៀត ការកាន់យក **មនោ** ក្នុងបទនេះថា **មនោ មនាយតនំ** ដើម្បីសម្តែងដល់ភាពជា អាយតនៈរបស់ចិត្ត ។ ដោយហេតុនោះ លោកទើបសម្តែងដល់បទថា **មនាយតន** នេះ មិនមែនឈ្មោះថា មនាយតនៈ ព្រោះជាអាយតនៈរបស់ចិត្ត ដូចទេវាយតនៈ ( ទីនៅរបស់ទេវតា ) ដែលពិតចិត្តនោះឯង ជាអាយតនៈ ទើបឈ្មោះថា **មនាយតន** ។ អត្ថនៃអាយតនៈ លោកពោលទុកក្នុងខាងក្រោយហើយ ។ ឈ្មោះថា **មនោ** ព្រោះដឹង សេចក្តីថា ដឹងច្បាស់ ។ ចំណែក

ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា **មនោ** ព្រោះដឹងច្បាស់នូវអារម្មណ៍ ដូចវាល់ដោយនាឡិ និងដូចថ្លឹងដោយគ្រឿងថ្លឹងធំ ។ ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះធ្វើប្រយោជន៍ធំក្នុងលក្ខណៈ ដឹង ។ ចិត្តនោះឯងជាឥន្ទ្រិយ ទើបឈ្មោះថា **មនិន្ទ្រិយ** ។ ឈ្មោះថា **វិញ្ញាណំ** ព្រោះអត្ថថា ដឹងច្បាស់ ។ វិញ្ញាណនោះ ជាខន្ធ ទើបឈ្មោះថា វិញ្ញាណក្ខន្ធ ។ លោកពោលថា ខន្ធកើតឡើង វិញ្ញាណមួយ ជាចំណែកមួយរបស់វិញ្ញាណក្ខន្ធដោយអត្ថថា ជាកង ។

ព្រោះដូច្នោះ លោកពោលថា បុគ្គលកាលកាត់ចំណែកមួយរបស់ដើមឈើ ឈ្មោះថា កាត់ដើមឈើ យ៉ាងណា វិញ្ញាណសូម្បីមួយ ជាចំណែកមួយរបស់វិញ្ញាណក្ខន្ធក៏ដូច្នោះ ដូចគ្នា លោកទើបពោលថា វិញ្ញាណក្ខន្ធកើតឡើង ។ម្យ៉ាងវិញទៀត ព្រោះអត្ថនៃកងមិនមែនជាអត្ថនៃខន្ធ អត្ថនៃចំណែកទើបជាអត្ថនៃខន្ធប៉ុណ្ណោះ ដូច្នោះទើបមានសេចក្តីថា **វិញ្ញាណកោដ្ឋាសោ** ចំណែកនៃវិញ្ញាណដូច្នេះខ្លះព្រោះជាអត្ថនៃចំណែក ។

បទថា **តជ្ជា មនោវិញ្ញាណធាតុ** មនោវិញ្ញាណធាតុដែលសមគួរដល់ចិត្តនោះ គឺ មនោវិញ្ញាណធាតុ ដែលសមគួរដល់សម្បយុត្តធម៌មានផស្សៈជាដើមទាំងនោះ ។ ពិតមែន ក្នុងបទនេះ ចិត្តមួយដូងប៉ុណ្ណោះ



លោកពោលដោយ ៣ ឈ្មោះថា គឺ ឈ្មោះថា **មនោ** ព្រោះអត្ថថា វាប់ ឈ្មោះថា **វិញ្ញាណំ** ព្រោះអត្ថថា ដឹងច្បាស់ ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ជាសភាវៈ ឬព្រោះអត្ថថា មិនមែនសត្វ ។ បទថា **អភិប្បមោ-ទោ** សេចក្តីត្រេកអរ គឺ សេចក្តីរីករាយក្រៃលែង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិនិទ្ទេសដូចតទៅនេះ ។ ឈ្មោះថា **ឋិតិ** ការតាំងនៅ ព្រោះតាំងនៅក្នុងអារម្មណ៍ដោយការមិនញាប់ញ័រ ។ ពីរបទតទៅផ្តើមឧបសគ្គចូល ឈ្មោះថា **សណ្ឋិតិ** ការតាំងនៅល្អ ព្រោះប្រមូលសម្បយុត្តធម៌ទាំងឡាយទុកក្នុងអារម្មណ៍ ហើយតាំងនៅ ឈ្មោះថា **អវដ្ឋិតិ** ការតាំងមាំ ព្រោះចូលទៅតោងអារម្មណ៍ ហើយតាំងនៅ ។

ធម៌ ៤ យ៉ាង ក្នុងចំណែកកុសល គឺ សទ្ធា សតិ សមាធិ បញ្ញា រមែងតោងអារម្មណ៍ទុក ។ ដោយហេតុនោះ **សទ្ធា** លោកទើបពោលថា **ឱកប្បនា** ការជឿមុតមាំ ។ **សតិ** លោកពោលថា **អបិលាបនតា** ការមិនបណ្តោយចិត្ត ។ **សមាធិ** លោកពោលថា **អវដ្ឋិតិ** ការតាំងមាំ ។ **បញ្ញា** លោកពោលថា **បរិយោគាហនា** ការឈានចុះ ។

ចំណែកធម៌ ៣ យ៉ាង ក្នុងអកុសល គឺ តណ្ហា ទិដ្ឋិ អវិជ្ជា រមែងតោងអារម្មណ៍ទុក ដោយហេតុនោះ លោកទើបពោលធម៌ទាំងនោះថា **ឱឃ** អន្លង់ ។ ឈ្មោះថា **អវិសាហារោ** ការមិនឃ្លេងឃ្លោង ព្រោះ

ជាបដិបក្ខចំពោះការឃ្លេងឃ្លោង ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆា ។ ចិត្តទៅដោយអំណាចនៃការរាយមាយ និងសង្ស័យ ឈ្មោះថា រមែងរាយមាយ ។ សមាធិនេះ មិនជាយ៉ាងនោះ ទើបឈ្មោះថា **អវិក្ខេបោ** ការមិនរាយមាយ ។ ចិត្ត ឈ្មោះថា ឃ្លេងឃ្លោងដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆា រមែងអណ្តែតទៅខាងនោះខាងនេះ ។ តែសមាធិនេះ មានចិត្តមិនឃ្លេងឃ្លោង ទើបឈ្មោះថា **អវិសាហដមានសតា** ការមានចិត្តមិនឃ្លេងឃ្លោង ។

បទថា **សមថោ** សេចក្តីស្ងប់ បានដល់ សេចក្តីស្ងប់ ៣ យ៉ាង គឺ **ចិត្តសមថ** ចិត្តស្ងប់ ១ , **អធិករណសមថ** អធិករណ៍ស្ងប់ ១ , **សព្វសង្ខារសមថ** សង្ខារទាំងពួងស្ងប់ ១ ។ ក្នុងសេចក្តី ស្ងប់ ៣ យ៉ាងនោះ ឈ្មោះថា ចិត្តស្ងប់ ព្រោះចិត្តមានអារម្មណ៍ជាតែមួយ ក្នុងសមាបត្តិ ៨ ព្រោះការញាប់ញ័រនៃចិត្ត ការក្តៅនៃចិត្ត រមែងស្ងប់ រមែងចូលទៅស្ងប់ ព្រោះអាស្រ័យចិត្តស្ងប់នោះ ដូច្នោះ លោកទើបពោលសមាធិនោះថា **ចិត្តសមថោ** ចិត្តស្ងប់ ។

ឈ្មោះថា **អធិករណ៍ស្ងប់** អធិករណ៍មាន ៧ យ៉ាង មានសម្មុខាវិន័យជាដើម ព្រោះអធិករណ៍ទាំងនោះស្ងប់ ចូលទៅស្ងប់ ព្រោះអាស្រ័យអធិករណសមថៈនោះ ដូច្នោះ លោកពោលសមាធិនោះថា



**អធិករណសមថោ** អធិករណ៍ស្ងប់ ។

ម្យ៉ាងទៀត ព្រោះសង្ខារទាំងឡាយទាំងពួងស្ងប់ ចូលទៅស្ងប់ ព្រោះអាស្រ័យនិព្វាន ដូច្នោះ លោកទើបពោលសមាធិនោះថា **សព្វ-សង្ខារសមថោ** សង្ខារទាំងពួងស្ងប់ ។ ក្នុងអត្ថនេះលោកប្រាថ្នាយកចិត្តស្ងប់ ។ ឈ្មោះថា **សមាធិន្ទ្រិយំ** ព្រោះធ្វើភាពជាធំក្នុងលក្ខណៈនៃសមាធិ ។ ឈ្មោះថា **សមាធិពលំ** ព្រោះមិនញាប់ញ័រដោយឧទ្ធច្ចៈ ។ បទថា **សម្មាសមាធិ** បានដល់ សមាធិពិតប្រាកដ សមាធិធ្វើឲ្យផុតទុក្ខ កុសលសមាធិ លោកពោលដល់ការរួចផុតរបស់ចិត្តចាកវត្ថុនៃកិលេស ១០ យ៉ាង មានជាអាទិ៍ថា **រាគតោ វិមោចយំ ចិត្តំ** សភាពនៃចិត្តរួចចាករាគៈ ។ ម្យ៉ាងទៀត ក្នុងបទនេះលោករួម **មិទ្ធ** សព្វផង **ថីន** សព្វផង និងរួម **កុក្កុច្ច** សព្វផង **ឧទ្ធច្ច** សព្វផង ដោយហេតុនោះ លោកទើបពោលអធិប្បាយដល់ការចេញចាកនីវរណៈជាដើម ដោយបឋមជ្ឈានជាដើម ដោយពោលដល់ការចេញចាកវត្ថុដែលជាកិលេស ព្រោះមិនរួមគ្នាក្នុងបាឋៈពួកដទៃ និងការចេញចាកនិច្ចសញ្ញាជាដើម ដោយអនិច្ចានុប-ស្សនាជាដើម ។

ម្យ៉ាងទៀត ក្នុងបេយ្យាលនេះថា **កថំ តំ ចិត្តំ អនុបស្សតិ** រមែងពិចារណាចិត្តនោះ តើដូចម្តេច គឺ លោកពោលដល់ការលះនិច្ចសញ្ញា

ជាដើម ដោយអនិច្ចានុបស្សនា ។ គប្បីជ្រាបរឿងមកក្នុងព្រះសូត្រ ៤ ដោយអំណាចនៃតតិយចតុក្កៈដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថា តតិយចតុក្កនិទ្ទេស)



## ចតុក្កៈទី ៤

គប្បីជ្រាបវិនិច្ឆ័យ ក្នុងចតុក្កនិទ្ទេសដូចតទៅនេះ ។ លោកតាំងពាក្យសួរដោយពាក្យជាទំសំកលិគ្គថា **អនិច្ចន្តិ កឹ អនិច្ចំ** បទថា **អនិច្ចំ** តើអ្វីមិនទៀង ។

បទថា **ឧប្បាទវយដ្ឋេន** ព្រោះអត្ថថា កើតឡើង និងវិនាសទៅ សេចក្តីថា ព្រោះសភាវៈ គឺ ការកើត និងការវិនាស ។ ក្នុងបទនេះ បញ្ចក្ខន្ធ ជាសភាវៈលក្ខណៈកើត និងការវិនាសរបស់បញ្ចក្ខន្ធ ជាវិការលក្ខណៈ ( លក្ខណៈផ្លាស់ប្តូរ ) ដោយបទនេះ លោកពោលថា ឈ្មោះថា មិនទៀង ព្រោះមានហើយមិនមាន ចំណែកក្នុងអដ្ឋកថាសូម្បីលោកពោលថា ការមិនទៀងដោយអំណាចនៃសង្ខតលក្ខណៈ និងពោលថា បញ្ចក្ខន្ធទាំងនោះ មានការកើត ការរលត់ និងជាយ៉ាងដទៃ ក៏នៅពោលថា ការមានហើយមិនមានដូច្នេះ ។ ដោយបទនេះ អាការ គឺ មានហើយមិនមាន លោកពោលថាជា អនិច្ចលក្ខណៈ ។ លោកពោលធ្វើបេយ្យាលថា កាលឃើញការកើត និងការវិនាសនៃបញ្ចក្ខន្ធ រមែងឃើញលក្ខណៈ ៥០ ទាំងនេះ ។ បទថា **ធម្មា** គឺ ធម៌តាមដែលលោកពោលហើយ មានរូបក្ខន្ធជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិរាគានុបស្សីនិទ្ទេសដូចតទៅនេះ ។ បទថា **រូបេ អាទីនវំ ទិស្វា** ឃើញទោសក្នុងរូប គឺ ឃើញទោសក្នុងរូបក្ខន្ធ

ដោយការតាំងនៅក្នុងការមិនទៀងជាដើម ដូចដែលលោកពោលហើយខាងមុនចាប់ផ្តើមពីកង្ខានុបស្សនាញាណ ។ បទថា **រូបវិរាគោ** ក្នុងការប្រាសចាកតម្រេកក្នុងរូប គឺ និព្វាន ព្រោះបុគ្គលអាស្រ័យនិព្វានប្រាសចាកតម្រេកក្នុងរូប រមែងរលត់ដោយការដល់ការមិនកើតទៀតជាធម្មតា ដូច្នោះ លោកទើបពោលថា ប្រាសចាកតម្រេកក្នុងរូប ។ បទថា **ឆន្ទជាតោ ហោតិ** ជាអ្នកកើតឆន្ទៈ គឺ មានឆន្ទៈក្នុងធម៌ដែលកើតឡើងដោយអំណាចនៃការស្តាប់ ។ បទថា **សទ្ធាធិមុត្តោ** បង្អោនចិត្តទៅដោយសទ្ធា គឺ បង្អោនទៅ សម្រេចចិត្តទៅក្នុងនិព្វាននោះ ដោយសទ្ធា ។ បទថា **ចិត្តញ្ចស្ស ស្វាធិដ្ឋិតំ** ទីងមានចិត្តតាំងមាំល្អ គប្បីជ្រាបដោយភ្ជាប់សេចក្តីថា ចិត្តរបស់ព្រះយោគាវចរនោះតាំងមាំដោយល្អ ប្រតិស្ឋានទុកដោយល្អ ដោយអំណាចនៃអារម្មណ៍ក្នុងការទម្លាយរូបដែលបានដល់ការប្រាសចាកតម្រេកក្នុងការអស់ទៅ ដោយអំណាចនៃការបានឮ បានស្តាប់និព្វានដែលប្រាសចាកតម្រេកក្នុងរូប ពោលគឺ ការប្រាសចាកតម្រេកទាំងអស់ ។

បទថា **រូបេ វិរាគានុបស្សី** ពិចារណាការប្រាសចាកតម្រេកក្នុងរូប លោកពោលការប្រាសចាកតម្រេកក្នុងការអស់ទៅនៃរូប ដោយសត្តមីវិភត្តិថា **រូបេ វិរាគោ** ការប្រាសចាកតម្រេកក្នុងរូប ។ លោក



ពោលសេចក្តីប្រាសចាកតម្រេកទាំងអស់នៃរូបដោយសត្តមីវិភត្តិ ចុះក្នុងអត្ថនៃនិមិត្តថា **រូបេ វិរាគោ** ការប្រាសចាកតម្រេកក្នុងរូប ។ លោកពោលការប្រាសចាកតម្រេកសូម្បីទាំងពីរយ៉ាងនោះ មានការពិចារណាដោយអារម្មណ៍ និងដោយអធ្យាស្រ័យជាប្រក្រតីថា **រូបេ វិរាគានុបស្សី** ពិចារណាការប្រាសចាកតម្រេកក្នុងរូប ។ ក្នុងវេទនាជាដើម ក៏មានន័យនេះ ។ សូម្បីក្នុងនិទ្ទេសនៃបទថា **និរោធានុបស្សី** ក៏មានន័យដូចគ្នា ។

ក៏ក្នុងបទនេះថា **កតីហាការេហិ** ដោយអាការប៉ុន្មាន មានភាពពិសេសដូចតទៅនេះ ។ លោកសម្តែងដល់ការរលត់ជាទោស សូម្បីក្នុងរូបជាដើម ដោយការឃើញទោស ការរលត់នៃអង្គរបស់បដិច្ចសមុប្បាទមានអវិជ្ជាជាដើម ព្រោះអវិជ្ជាជាដើមទាំងនោះ មិនកន្លងអង្គបដិច្ចសមុប្បាទទៅបាន ដោយពាក្យពិសេសនេះឯង គឺ លោកពោលដល់ភាពវិសេសនៃនិរោធានុបស្សនា ព្រោះពិចារណាឃើញការប្រាសចាកតម្រេក ។ ក្នុងបទទាំងនោះ បទថា **អនិច្ចដ្ឋេន** ដោយអត្ថថា មិនទៀង គឺ ដោយអត្ថថា អស់ទៅ ឬដោយអត្ថថា មានហើយមិនមាន ។ បទថា **ទុក្ខដ្ឋេន** ដោយអត្ថថា មានទុក្ខ គឺ ដោយអត្ថថា គួរខ្លាច ឬដោយអត្ថថា បៀតបៀន ។ បទថា **អនត្តដ្ឋេន** ដោយអត្ថថា ជាអនត្តា គឺ

ដោយអត្ថថា រកសារៈមិនបាន ឬដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។ បទថា **សន្តាបដ្ឋេន** ដោយអត្ថថា ជាហេតុឲ្យក្តៅក្រោហាយ គឺ ដោយអត្ថថា កិលេសជាហេតុឲ្យក្តៅក្រហាយ ។ បទថា **បរិណាមដ្ឋេន** ដោយអត្ថថា ប្រែប្រួល គឺ ដោយអត្ថថា ប្រែប្រួលដោយ ២ ចំណែក ដោយអំណាចនៃជរា និងភង្គៈ (ការរលត់) ។ បទថា **និទាននិរោធេន** ដោយនិទានរលត់ គឺ ដោយមិនមានហេតុបច្ច័យ ។ បទថា **និរុជ្ឈតិ** រមែងរលត់ គឺ មិនមាន ។ បទថា **សមុទយ និរោធេន** ដោយសមុទយរលត់ គឺ ដោយការមិនមានបច្ច័យដែលជិត ។ ព្រោះហេតុបច្ច័យ លោកពោលថា **និទាន** ដូចភោជនមិនជាទីសប្បាយដល់មនុស្សឈឺ បច្ច័យដែលជិត លោកពោល **សមុទយ** ដូចខ្យល់ទឹកប្រមាត់ និងស្លេស្មរបស់មនុស្សឈឺ ។ ព្រោះនិទាន រមែងឲ្យផលដល់ការវិនិច្ឆ័យសមុទ័យ ជាហេតុឲ្យកើតផលដោយល្អ ។ បទថា **ជាតិនិរោធេន** ដោយជាតិរលត់ គឺ ដោយមិនមានការកើតនៃបច្ច័យ ។ បទថា **ភវនិរោធេន** ដោយភពរលត់ គឺ ដោយមិនមានការកើតនៃបច្ច័យដែលជិត ( អាសន្នបច្ច័យ ) គួរពោលថា ឈ្មោះថា **ភព** ព្រោះជាតិជាហេតុឲ្យកើតទុក្ខ ។ បទថា **ហេតុនិរោធេន** ដោយហេតុរលត់ គឺ ដោយមិនមានបច្ច័យឲ្យកើត ជនកបច្ច័យ ។ បទថា **បច្ចយនិរោធេន** ដោយ



បច្ច័យរលត់ គឺ ដោយមិនមានឧបត្ថម្ភកបច្ច័យ សូម្បីហេតុប្បច្ច័យក៏ជាអាសន្នបច្ច័យ ជនកបច្ច័យ និងឧបត្ថម្ភកបច្ច័យ នោះឯង ។ ដោយបច្ច័យទាំងនោះ លោកពោលការរលត់មួយគ្រា ក្នុងខណៈវិបស្សនាខ្លាំងក្លា ។ ការរលត់ដាច់ជាសមុច្ឆេទ ក្នុងខណៈនៃមគ្គ ។ បទថា **ញាណុប្បាទេន** ដោយញាណកើត គឺ ដោយការកើតឡើងនៃវិបស្សនាញាណខ្លាំងក្លា ឬនៃមគ្គញ្ញាណ ។ បទថា **និរោធុបដ្ឋានេន** ដោយនិរោធប្រាកដ គឺ ដោយការប្រាកដនៃនិព្វាន ពោលគឺ **និរោធ** ដោយអំណាចនៃការបានស្តាប់ដល់ការរលត់ ការអស់ទៅដោយប្រចក្សក្នុងខណៈវិបស្សនា និងដោយការប្រាកដនៃនិព្វាន ដោយការប្រចក្សក្នុងខណៈនៃមគ្គ ។ ដោយបទទាំងនេះ ជាការពោលសេចក្តីពិតប្រាកដដោយឥន្ទ្រិយដែលជាវិស័យ និងលោកពោលដល់ការរលត់ជាខណៈ និងរលត់ដាច់ជាសមុច្ឆេទ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា **បដិនិសគ្គនុបស្សី** (ពិចារណាការលះបង់) ដូចតទៅនេះ ។ បទថា **រូបំ បរិច្ចជតិ** លះបង់រូប គឺ លះបង់រូបក្ខន្ធ ព្រោះមិនសម្លឹងដល់ការឃើញទោស ។ បទថា **បរិច្ចាគបដិនិស្សគ្គោ** លះបង់ដោយការបរិច្ចាគ លោកអធិប្បាយថា ឈ្មោះថា **បដិនិស្សគ្គោ** ព្រោះអត្ថថា លះបង់ ។ ដោយបទនេះ ជាការដែល

លោកពោលដល់អត្ថនៃការបរិច្ចាគនៃបទថា **បដិនិស្សគ្គ** ព្រោះដូច្នោះ អធិប្បាយថា បានដល់ ការលះបង់កិលេសទាំងឡាយ ម្យ៉ាងទៀត ក្នុងបទនេះ វិបស្សនាដែលជាវុដ្ឋានគាមិនី ( ញាណជាគ្រឿងនាំចេញទៅ ) រមែងលះបង់កិលេសទាំងឡាយបានដោយខណៈ មគ្គរមែងលះបង់កិលេសបានដោយដាច់ជាសមុច្ឆេទ ។

បទថា **រូបនិរោធេ និព្វានេ ចិត្តំ បក្ខន្ទតិ** ចិត្តរមែងស្ទុះទៅក្នុងនិព្វានដែលជាទីរលត់រូប គឺ វិបស្សនាដែលជាវុដ្ឋានគាមិនី រមែងស្ទុះទៅ ព្រោះបង្អោនទៅក្នុងនិព្វាននោះ មគ្គរមែងស្ទុះទៅដោយការធ្វើឲ្យជាអារម្មណ៍ ។

បទថា **បក្ខន្ទនបដិនិស្សគ្គោ** សេចក្ដីលះបង់ដោយការស្ទុះទៅ លោកអធិប្បាយថា ឈ្មោះថា **បដិនិស្សគ្គ** ព្រោះអត្ថថា ស្ទុះទៅ ។ ដោយបទ ដែលលោកពោលដល់អត្ថនៃការស្ទុះទៅរបស់បទថា **បដិនិស្សគ្គ** ព្រោះដូច្នោះ ទើបមានសេចក្ដីថា បានដល់ ការលះចិត្តចុះក្នុងនិព្វាន ។ គប្បីជ្រាបរឿងដែលមកក្នុងព្រះសូត្រ ៤ រឿង ដោយអំណាចនៃចតុត្ថចតុក្កៈ ។ ក្នុងចតុក្កៈនេះ គប្បីជ្រាបដល់បទដែលគួរពោលដល់ជរា និងមរណៈ ដោយន័យដូចពោលហើយក្នុងខាងក្រោយនោះឯង ។



ម្យ៉ាងវិញទៀត ក្នុងសតិប្បដ្ឋានទាំងឡាយ គប្បីជ្រាបថា លោកធ្វើការបង្ហាញជាឯកវចនៈ ដោយពោលដល់កាយ និងចិត្តតែមួយថា **កាយេ កាយានុបស្សនា** ពិចារណាកាយក្នុងកាយ **ចិត្តេ ចិត្តានុបស្សនា** ពិចារណាចិត្តក្នុងចិត្ត . ធ្វើការបង្ហាញជាពហុវចនៈ ដោយពោលដល់សេចក្ដីផ្សេង ៗ គ្នា របស់វេទនា និងធម៌ថា **វេទនាសុ វេទនានុបស្សនា** ពិចារណាវេទនាក្នុងវេទនាទាំងឡាយ **ធម្មេសុ ធម្មានុបស្សនា** ពិចារណាធម៌ក្នុងធម៌ទាំងឡាយ ដោយប្រការដូច្នេះ ។

ចប់ អដ្ឋកថា ចតុត្ថចតុក្កនិទ្ទេស និង

ចប់ អដ្ឋកថា សតោការិញ្ញាណនិទ្ទេស

# អដ្ឋកថា ញាណរាសិឆក្កនិទ្ទេស

ឥឡូវនេះ ជាសមាធិ ២៤ ក្នុងវត្ថុ ១២ គឺ សមាធិមួយ ៗ មានពីរ គឺ សមាធិមួយដោយអំណាចខ្យល់អស្សាសៈ សមាធិមួយដោយអំណាចខ្យល់បស្សាសៈ ក្នុងវត្ថុមួយៗ នៃវត្ថុ ១២ ដោយអំណាចចតុក្កៈ ៣ មានកាយានុបស្សនាជាដើម ក្នុងសមាធិញ្ញាណនិទ្ទេស ២៤ ក្នុងញាណ ដែលលោកសំដែងទុកហើយ ដោយកងទាំង ៦ កង ។ ញាណសម្បយុត្តដោយសមាធិទាំងនោះ ក្នុងខណៈឈាន ដោយអំណាចនៃសមាធិ ២៤ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិបស្សនាញាណនិទ្ទេស ៧២ ដូចតទៅនេះ បទថា **ទីឃំ អស្សាសា** ព្រោះខ្យល់ អស្សាសៈ ដែលលោកពោលហើយថា **វែង** លោកពោលទុកដូចម្តេច ។ លោកពោលទុកថាឈ្មោះថា **វិបស្សនា** ព្រោះអត្ថថា ពិចារណាឃើញដោយភាពមិនទៀងក្នុងខណៈវិបស្សនាដោយចិត្តតាំងមាំនោះ ព្រោះបានឈាន ព្រោះហេតុខ្យល់ដកដង្ហើមចូលវែង ។ សូម្បីក្នុងអត្ថដទៃក៏មានន័យនេះ ។ ក្នុងវត្ថុ ១២ គឺ អនុបស្សនាមួយ ៗ ៦ អនុបស្សនា ៣ ដោយអំណាចនៃខ្យល់អស្សាសៈ ។ អនុបស្សនា ៣ ដោយអំណាចនៃបស្សាសៈ ក្នុងវត្ថុមួយ ៗ



នៃវត្ថុ ១២ ទាំងនោះ រួមជាអនុបស្សនា ៧២ ។ អនុបស្សនា ៧២ ទាំងនោះឯង ជាញាណ ដោយអំណាចនៃវិបស្សនា ៧២ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិព្វិទាញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **អនិច្ចានុបស្សី អស្សាសំ** ពិចារណាឃើញដោយភាពជារបស់មិនទៀងដកដង្ហើមចូល គឺ ពិចារណាខ្យល់ដកដង្ហើមចូល ដោយភាពជារបស់មិនទៀង សេចក្តីថា ពិចារណាប្រព្រឹត្តទៅដោយភាពជារបស់មិនទៀង ។ ក៏ពាក្យថា **អស្សាសំ** នេះ គប្បីឃើញថាចុះក្នុងអត្ថនៃហេតុ ។ បទថា **យថាភូតំ បជានាតិ បស្សតីតិ និព្វិទាញាណំ** ឈ្មោះថា និព្វិទាញាណ ព្រោះដឹងឃើញតាមសេចក្តីពិត គឺ តាំងពីពិចារណាជាកង ៗ រហូតដល់ពិចារណាឃើញការរលត់ រមែងដឹងតាមសេចក្តីពិតនៃសង្ខារទាំងឡាយ រមែងឃើញដោយញាណចក្ខុនោះ ដូចឃើញដោយចក្ខុ ព្រោះដូច្នោះ ទើបឈ្មោះថា និព្វិទាញាណ ។ លោកអធិប្បាយថាឈ្មោះថា និព្វទាញាណក្នុងសង្ខារទាំងឡាយ ។ គប្បីជ្រាបថា វិបស្សនាញាណ ជានិព្វិទាញាណ តាមដែលបានពោលហើយក្នុងនិទ្ទេសនេះ ព្រោះញាណទាំងឡាយ មានភយតូបដ្ឋានញ្ញាណ ( បញ្ញាឃើញសង្ខារប្រាកដជារបស់គួរខ្លាច ) ជាដើម និងមុញ្ចិតុកម្យតាញាណ ( បញ្ញាដែលប្រាថ្នានឹងរួចផុត ) ជាដើមជាធម៌ផ្សេងគ្នា ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃនិព្វិទានុលោមញាណ ដូចតទៅនេះ ។ បទថា **អនិច្ចានុបស្សី អសព្វាសំ** ពិចារណាឃើញការមិនទៀង ដកដង្ហើមចូល គឺ ពិចារណាខ្យល់ដកដង្ហើមចូល ដោយភាពជារបស់មិនទៀង ។ បទថា **ភយតុបដ្ឋានេ បញ្ញា** បញ្ញាក្នុងការប្រាកដជារបស់គួរខ្លាចដែលលោកពោលដល់ ភយតុបដ្ឋានញាណ អាទីនវា-នុបស្សនាញាណ និងនិព្វិទាញាណ ដោយពាក្យនោះឯង ព្រោះញាណទាំង ៣ មានលក្ខណៈតែមួយដូចគ្នា ។ ញាណ ៣ ទាំងនេះ លោកពោលថា **និព្វិទានុលោមញាណ** ព្រោះអនុលោម ដោយការអនុកូលរបស់និព្វិទាញាណ ដូចដែលពោលហើយដោយលំដាប់ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃនិព្វិទាបដិបស្សទ្ធិញាណ ដូចតទៅនេះ ។ បទថា **អនិច្ចានុបស្សី អសព្វាសំ** ដូចគ្នានឹងការពោលមកតាមលំដាប់នោះឯង ។ បទថា **បដិសង្ខា សន្តិដ្ឋនា បញ្ញា** បញ្ញាពិចារណារកផ្លូវហើយព្រងើយ គឺ លោកពោលដល់មុញ្ចិតុកម្យតា-ញាណ បដិសង្ខានុបស្សនាញាណ (ប្រាជ្ញារំពឹងដល់ការពិចារណារកផ្លូវ) សង្ខារុបេក្ខាញាណ ( ប្រាជ្ញារំពឹងដោយការព្រងើយ ) ដោយពាក្យនោះឯង ព្រោះញាណទាំង ៣ មានលក្ខណៈតែមួយដូចគ្នា ។ សូម្បីអនុលោម-ញាណ និងមគ្គញាណ លោកក៏រួមទុកដោយពាក្យថា **បដិសង្ខា សន្តិដ្ឋនា**



នោះឯង ។ សូម្បីសង្ខារុបេក្ខាញាណ និងអនុលោមញាណ ក៏ឈ្មោះថា និព្វិទាបដិបស្សទ្ធិញាណ ដោយលះសេចក្តីខ្វល់ខ្វាយ ក្នុងការកើតនិព្វិទា ព្រោះនិព្វិទាដល់កំពូលហើយ ។

ចំណែកមគ្គញាណ ឈ្មោះថា និព្វិទាបដិបស្សទ្ធិញាណ ព្រោះកើតក្នុងទីបំផុតនៃនិព្វិទាបដិបស្សទ្ធិញាណ ព្រោះហេតុនោះ ទើបគួរយ៉ាងក្រៃលែង ។ ការមិនកាន់យកមុញ្ចិតុកម្យតាញាណដែលជាខាងដើមដូចក្នុងនិព្វិទានុលោមញាណ ហើយកាន់យកញាណពីរពួក ក្នុងទីបំផុតថា **បដិសង្ខា សន្តិដ្ឋនា** ដើម្បីសង្គ្រោះចូលក្នុងមគ្គញាណ ។ ព្រោះលោកកាលបើពោលថា **មុញ្ចិតុកម្យតា** រមែងសង្គ្រោះយកអនុលោម-ញាណផង មិនបានសង្គ្រោះយកមគ្គញាណ ។ ព្រោះមគ្គញាណមិនបានឈ្មោះថា **មុញ្ចិតុកម្យតា** ។ ម្យ៉ាងទៀត បញ្ញា ឈ្មោះថា **សន្តិដ្ឋនា** ព្រោះព្រងើយហើយនៅក្នុងការសម្រេចចិត្ត ។

ម្យ៉ាងទៀត សូម្បីក្នុងអដ្ឋកថាលោកក៏ពោលថា បទថា **ផុស-នា** ការពាល់ត្រូវ គឺ **អប្បនា** ការនែបនិត្យ ។ បញ្ញា ឈ្មោះថា **សន្តិដ្ឋនា** ការព្រងើយ ព្រោះធ្វើមគ្គញាណនេះ ឲ្យជាអប្បនាក្នុងនិព្វាន ដោយហេតុនោះ លោកទើបសង្គ្រោះ សូម្បីមគ្គញាណ ដោយពាក្យថា **សន្តិដ្ឋនា** សូម្បីនិព្វិទានុលោមញាណដោយអត្ថ ក៏ជានិព្វិទាញាណ

នោះឯង ព្រោះហេតុនោះ លោកទើបសង្គ្រោះនិព្វិទានុលោមញ្ញាណទាំងនោះ ដោយនិព្វិទាញាណហើយប្រើសព្ទ **និព្វិទា** ថា **និព្វិទាបដិ-បស្សទ្ធិញ្ញាណានិ** ដូច្នេះ មិនមែនសព្ទថា **និព្វិទានុលោម** ។ ក្នុងវត្ថុ ៤ គឺ ក្នុងញាណមួយ ៗ មាន ២ គឺ ញាណមួយដោយអំណាចនៃខ្យល់អស្សាសៈ ញាណមួយដោយអំណាចនៃខ្យល់បស្សាសៈ ក្នុងវត្ថុមួយនៃវត្ថុ ៤ ដែលលោកពោលហើយ ដោយអំណាចនៃធម្មានុបស្សនា ចតុក្កៈទី ៤ ក្នុងញាណដ្ឋកនិទ្ទេសទាំង ៣ នេះ ទើបរួមជាញាណ ៨ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិមុត្តិសុខញ្ញាណនិទ្ទេសដូចតទៅនេះ ។ ព្រះសារីបុត្តត្ថេរ លុះសម្តែងការលះដោយបទថា **បហីនត្តា** ព្រោះលះហើយ កាលនឹងសម្តែងការលះនោះដោយសមុច្ឆេទប្បហាន ទើបពោលថា **សមុច្ឆិន្នត្តា** ព្រោះដាច់ជាសមុច្ឆេទ ។

បទថា **វិមុត្តិសុខេ ញាណំ** ញាណក្នុងវិមុត្តិសុខ គឺ ញាណសម្បយុត្តដោយវិមុត្តិសុខដែលជាផល និងញាណ គឺ ការពិចារណាវិមុត្តិសុខដែលជាផល ជាអារម្មណ៍ ។ ដើម្បីសម្តែងថា ការលះវត្ថុទុច្ចរិតដែលរួបរឹត ដោយការលះកិលេស ដែលជាវត្ថុដេកត្រាំក្នុងសន្តាន លោកទើបពោលដល់ការលះកិលេសដែលជាអនុស័យទៀត ។ លោកធ្វើញាណគណនា ដោយការរាប់ចំនួនកិលេសដែលលះបានហើយ សំដៅ



ដល់ ផលញ្ញាណ ២១ ។ និងលោករាប់ចំនួនបច្ចវេក្ខណញ្ញាណ ដែលជាផល ដោយការរាប់ចំនួនដល់ការពិចារណាកិលេស ដែលលះបានហើយ សំដៅដល់ បច្ចវេក្ខណញ្ញាណ ។

អដ្ឋកថា ញាណកថានិទ្ទេស

អដ្ឋកថា អានាបានស្សតិកថា

នៃអដ្ឋកថា បដិសម្ភិទាមគ្គ ឈ្មោះថា សទ្ធម្មប្បកាសិនី

ចប់

# ៤-ឥន្ទ្រិយកថា

## ១- អដ្ឋកថា បឋមសុត្តន្តនិទ្ទេស

ឥឡូវនេះ ដល់កាលពណ៌នាតាមសេចក្តីដែលនៅមិនធ្លាប់ពណ៌នា ក្នុងឥន្ទ្រិយកថា ដែលពោលក្នុងលំដាប់អានាបានស្សតិកថា ។

ពិតណាស់ ឥន្ទ្រិយកថានេះ ពោលក្នុងលំដាប់អានាបានស្សតិកថា ដើម្បីសម្តែងវិធីមានការជម្រះឥន្ទ្រិយ ដែលជាឧបការៈដល់អានាបានស្សតិនោះ ព្រោះមិនមានអានាបានស្សតិភាវនា ព្រោះការមិនមានឥន្ទ្រិយទាំងឡាយដែលជាឧបការៈដល់អានាបានស្សតិភាវនា ព្រោះហេតុនោះ ព្រះសារីបុត្តត្ថេរបំណងនឹងធ្វើឥន្ទ្រិយកថា ដែលគួរពោលនោះ ដែលជាទេសនាដែលមានមកក្នុងព្រះសូត្រដោយ ប្រាថ្នានឹងឲ្យដឹងនូវខ្លួនបានស្តាប់មកចំពោះព្រះភ័ក្ត្ររបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ឲ្យជាខាងដើម ទើបពោលពាក្យជាដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឯវំ** ជាបទនិបាត ។ បទទាំងឡាយមានជាអាទិ៍ថា **មេ** ជាបទនាម ។ បទថា **វិ** ក្នុងបទថា **វិហរតិ** នេះ ជាបទឧបសគ្គ ។ បទថា **ហរតិ** ជាបទអាខ្យាត ។ គប្បីជ្រាប ការចែកបទដោយន័យនេះ ដោយប្រការដូច្នេះ ។

ប៉ុន្តែដោយអត្ថ **ឯវំ** សព្ទ រមែងប្រាកដក្នុងអត្ថនៃនិទស្សនៈ ការ



បង្ហាញ និងក្នុងអត្ថនៃអវធារណៈ ( ការទទួលព្រម ) ក្នុងការកាន់យកពាក្យដែលជាឧបមា ការអាង ការតិះដៀល ការសរសើរ និងអាការ ។ តែ **ឯវំ** សព្ទ ក្នុងទីនេះវិញ្ញូជនបញ្ញត្តិចុះក្នុងអត្ថនៃអាការ និងក្នុងអត្ថនៃនិទស្សនៈ និងក្នុងអត្ថនៃអវធារណៈ ក៏ដូចយ៉ាងនោះ ។

ក្នុងអត្ថទាំងនោះ លោកពោលសេចក្តីនេះដោយ **ឯវំ** សព្ទ ដែលមានអាការជាអត្ថ ប្រែថា ដោយអាការយ៉ាងនេះ ។ នរណា ៗ អាចនឹងដឹងតម្រាស់របស់ព្រះមានព្រះភាគជាម្ចាស់នោះ ដែលមានន័យផ្សេង ៗ ល្អិតល្អន់ មានអធ្យាស្រ័យមិនតិចជាសមុដ្ឋាន សម្បូណ៌ ដោយអត្ថ និងព្យញ្ជនៈ មានបាដិហារិយៈច្រើនយ៉ាងជ្រាលជ្រៅ ដោយហេតុផលទេសនា និងបដិវេធ ដែលមកកាន់គន្លងសោតៈ ដោយសមគួរដល់ភាសារបស់ខ្លួន នៃសត្វទាំងពួងបានដោយគ្រប់ប្រការ សូម្បីញ៉ាំងអ្នកប្រាថ្នានឹងស្តាប់ឲ្យកើតដោយកម្លាំងទាំងពួង ទើបពោលថា **ឯវំ មេ សុតំ** គឺ សូម្បីខ្ញុំក៏ស្តាប់មកហើយដោយ អាការមួយ ដូច្នេះ ។ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងខ្លួនថា យើងមិនមែនព្រះសយម្ភូ វត្ថុនេះ យើងនៅមិនបានធ្វើឲ្យជាក់ច្បាស់ដោយ **ឯវំ** សព្ទ ដែលមាននិទស្សនៈជាអត្ថ ទើបសម្តែងសូត្រទាំងអស់ ដែលគួរពោលក្នុងឥឡូវនេះថា **ឯវំ មេ សុតំ** សូម្បីយើងក៏ស្តាប់មកហើយយ៉ាងនេះ ដូច្នេះ ។ ដោយមានអវធារណៈ

ជាអត្ថ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងកម្លាំង ដែលទ្រទ្រង់របស់ខ្លួន សមគួរដែលព្រះមានព្រះភាគជាម្ចាស់នឹងទ្រង់សរសើរ ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងឡាយជាសាវ័ករបស់តថាគត មានបញ្ញាច្រើន សារីបុត្តជាអ្នកប្រសើរ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណារកមិនឃើញ បុគ្គលដទៃសូម្បីត្រឹមតែម្នាក់ ដែលជាអ្នកញ៉ាំងធម្មចក្កដ៏ប្រសើរ ដែលតថាគតប្រកាសទៅហើយយ៉ាងនេះ ឲ្យប្រព្រឹត្តទៅតាមបានយ៉ាងត្រឹមត្រូវ ដូចសារីបុត្តឡើយ ម្នាលភិក្ខុទាំង-ឡាយ សារីបុត្តញ៉ាំងធម្មចក្កដ៏ប្រសើរ ដែលតថាគតប្រកាសហើយ ឲ្យប្រព្រឹត្តទៅតាមបានយ៉ាងត្រឹមត្រូវ ទើបញ៉ាំងភាវៈជាអ្នកប្រាថ្នានឹងស្ដាប់ឲ្យកើតដល់សត្វទាំងឡាយថា យើងស្ដាប់មកហើយយ៉ាងនេះ ព្រះធម្ម-ចក្កនោះឯង មិនខ្វះចន្លោះ មិនលើសដោយអត្ថ ឬដោយព្យញ្ជនៈ គប្បីយល់ឃើញយ៉ាងនេះប៉ុណ្ណោះ មិនគប្បីយល់ឃើញជាយ៉ាងដទៃ ។

**មេ** សព្ទ រមែងប្រាកដក្នុងអត្ថនៃតតិយាវិភត្តិ ចតុត្ថីវិភត្តិ និងឆដ្ឋីវិភត្តិ ។ តែក្នុងទីនេះ រមែងគួរក្នុងពីរអត្ថថា **មយា សុតំ** ដែលយើងស្ដាប់ហើយ និង **មម សុតំ** ស្ដាប់ហើយដល់យើង ដូច្នេះ ។ សព្ទថា **សុតំ** នេះ ទាំងជាឧបសគ្គ និងមិនមែនឧបសគ្គ រមែងប្រាកដក្នុងការស្ដាប់ច្បាស់ ការទៅ ការរីករាយ ការសន្សំ ការប្រកប ការដឹងច្បាស់



តាមត្រចៀក និងកាលនឹងដឹង រមែងប្រាកដដោយការស្ទុះទៅតាមសោត-ទ្វារ ។ តែក្នុងទីនេះ **សុតំ** សព្ទ នោះ មានសេចក្ដីថា ចូលទៅទ្រទ្រង់ទុក ឬការចូលទៅទ្រទ្រង់ទុក ដោយការស្ទុះទៅតាមសោតទ្វារ ។

កាល **មេ** សព្ទ មានអត្ថថា **មយា** រមែងគួរថា ដែលយើងស្ដាប់ហើយយ៉ាងនេះ គឺ ចូលទៅទ្រទ្រង់ទុក ដោយស្ទុះទៅតាមសោត-ទ្វារ ។ កាលមានអត្ថថា **មម** រមែងគួរ ថាការស្ដាប់ គឺ ការចូលទៅទ្រទ្រង់ដោយស្ទុះទៅតាមសោតទ្វាររបស់យើង យ៉ាងនេះ ។

ម្យ៉ាងទៀត កាលមិនដឹងសេចក្ដីត្រង់ការស្ដាប់ដែលខ្លួនឲ្យកើតហើយថា យើងស្ដាប់មកហើយយ៉ាងនេះ កាលនឹងបើកបង្ហាញការស្ដាប់ដែលមានមកអំពីមុន រមែងញ៉ាំងការមិនជឿក្នុងធម៌ នេះឲ្យវិនាសទៅថា ពាក្យនេះយើងទទួលមកហើយចំពោះព្រះភ័ក្ត្រនៃព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គទ្រង់ក្លាហានដោយវេសារជ្ជធម៌ ៤ ទ្រទ្រង់កម្លាំង ១០ ដែលតាំងនៅក្នុងឋានៈអង់អាច បន្លឺសីហនាទ ខ្ពង់ខ្ពស់ជាងសត្វទាំងពួង អ្នកជាឥស្សរៈក្នុងធម៌ ជាធម្មជាភ ជាធម្មាធិបតី ជាធម្មទីបៈ ជាធម្មសរណៈ ជាចក្រពត្តិនៃសទ្ធម្មដ៏ប្រសើរ ព្រះអង្គជាសម្មាសម្ពុទ្ធជាម្ចាស់មិនគួរធ្វើសេចក្ដីសង្ស័យក្នុងអត្ថ ក្នុងធម៌ ក្នុងបទ ក្នុងព្យញ្ជនៈ នេះឡើយ ញ៉ាំងសទ្ធាសម្បទាឲ្យកើត ។ ដោយហេតុនោះ លោកទើបពោលថា ៖

សាវករបស់ព្រះគោតមពោលយ៉ាងនេះថា យើងស្តាប់មកហើយយ៉ាងនេះ រមែងញុំាងអ្នកមិនជឿឲ្យវិនាសទៅ ញុំាងអ្នកជឿឲ្យចម្រើនក្នុងព្រះសាសនា ដូច្នេះ ។

បទថា **ឯកំ** សម្តែងចំនួន ។ បទថា **សមយំ** សម្តែងកំណត់ ។ **ឯកំ សមយំ** សម្តែងការមិនពិតប្រាកដ ។ **សមយ** សព្ទ ក្នុងបទនោះ រមែងប្រាកដក្នុង **ការប្រជុំ ខណៈ កាល ពួក ហេតុ ទិដ្ឋិ ការបាន ការលះ** និង **ការចាក់ធ្លុះ** ។

តែក្នុងទីនេះ **សមយ** សព្ទ យកសេចក្តីថា **កាល** ។ ដោយហេតុនោះ លោកសម្តែងថា **ឯកំ សមយំ** ក្នុងសម័យមួយ បណ្តាសម័យទាំងឡាយដែលជាប្រភេទនៃកាល មានឆ្នាំ រដូវ ខែ កន្លះខែ យប់ ថ្ងៃ ព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយស្របក់ ជាដើម ។

ក្នុងកាលទាំងឡាយ មានឆ្នាំជាដើមទាំងនេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ព្រះសូត្រណា ៗ ក្នុងឆ្នាំ រដូវ ខែ បក្ខ កណ្តាល យប់ ឬកណ្តាលថ្ងៃណា ៗ ព្រះសូត្រទាំងអស់នោះ ព្រះថេរៈដឹងហើយយ៉ាងល្អ កំណត់ហើយយ៉ាងល្អ ដោយបញ្ញាដោយពិត ។ តែព្រោះកាលពោលយ៉ាងនេះថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ក្នុងឆ្នាំឯនោះ រដូវ



ឯនោះ ខែឯនោះ បក្ខឯនោះ កណ្តាលយប់ថ្ងៃឯនោះ កណ្តាលថ្ងៃថ្ងៃឯនោះ មិនអាចនឹងទ្រទ្រង់ចាំបាន នឹងលើកឡើងសម្តែង ឬឲ្យលើកឡើងសម្តែងបានដោយងាយ គួរនឹងពោលឲ្យច្រើន ដូច្នោះ ព្រះសារីបុត្តត្ថេរប្រមូលសេចក្តីនោះ ចុះដោយបទតែមួយប៉ុណ្ណោះ ហើយពោលថា **ឯកំ សមយំ** ។

បណ្តាសម័យដែលមានប្រភេទច្រើនយ៉ាង តាមការប្រកាសទុកក្នុងទេវតា និងមនុស្សទាំងឡាយរបស់ព្រះមានព្រះភាគជាម្ចាស់ មានជាអាទិ៍យ៉ាងនេះ គឺ សម័យចុះកាន់ព្រះគភ៌ សម័យប្រសូត្រ សម័យកើតសង្វេគ សម័យស្តេចទ្រង់ផ្នួស សម័យទ្រង់បំពេញទុក្ករកិរិយា សម័យឈ្នះមារ សម័យត្រាស់ដឹង សម័យសោយ សុខក្នុងទិដ្ឋធម៌ សម័យទេសនា សម័យបរិនិព្វាន សម្តែងដល់សម័យមួយ គឺ សម័យទេសនា ។ លោកពោលថា **ឯកំ សមយំ** សំដៅដល់ សម័យណាមួយ ក្នុងបណ្តាសម័យ ដែលជាសម័យទ្រង់បំពេញកិច្ចដោយព្រះករុណា ក្នុងសម័យទ្រង់បំពេញព្រះញាណករុណា ដែលជាសម័យទ្រង់បដិបត្តិប្រយោជន៍ដើម្បីអ្នកដទៃ ក្នុងសម័យដែលទ្រង់បដិបត្តិដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍ដើម្បីអ្នកដទៃ ដែលជាសម័យសម្តែងធម្មីកថា ក្នុងសម័យដែលទ្រង់ធ្វើកិច្ចដល់អ្នកមកប្រជុំគ្នា ដែលជាសម័យទ្រង់ប្រកាសព្រះសាសនា ។

ម្យ៉ាងទៀត ព្រោះបទថា **ឯកំ សមយំ** ជាអច្ចន្តសំយោគ គឺជាទុតិយាវិភត្តិចុះក្នុងអត្ថថា អស់ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងព្រះសូត្រនេះ ឬព្រះសូត្រដទៃក្នុងសម័យណា ទ្រង់នៅដោយព្រះករុណាវិហារអស់សម័យនោះ ដូច្នោះ ដើម្បីបំភ្លឺសេចក្តីនោះ លោកទើបធ្វើឲ្យជាទុតិយាវិភត្តិ ដូចដែលលោកពោលថា

**លោកសម្លឹងដល់អត្ថនោះ ៗ ហើយទើបពោល**
**សមយ សព្ទ ក្នុងទីដទៃដោយសត្តមីវិភត្តិ និង**
**តតិយាវិភត្តិ ក្នុងទីនេះពោលដោយទុតិយាវិភត្តិ ។**

ចំណែកព្រះបុរាណាចារ្យទាំងឡាយពណ៌នាថា **សមយ** សព្ទនេះមានសេចក្តីផ្សេងគ្នាត្រឹមតែពាក្យនិយាយថា **តស្មឹ សមយេ** ក្នុងសម័យនោះ **តេន សមយេន** ដោយសម័យនោះ ឬ **តំ សមយំ** អស់សម័យនោះ ក្នុងទីទាំងពួងមានសេចក្តីជាសត្តមីវិភត្តិទាំងអស់ ។ ព្រោះដូច្នោះ សូម្បីកាលពោលថា **ឯកំ សមយំ** ក៏គប្បីជ្រាបសេចក្តីថា **ឯកស្មឹ សមយេ** ក្នុងសម័យមួយ ។

បទថា **ភគវា** គឺ គ្រូ ។ ព្រោះជនទាំងឡាយក្នុងលោក ហៅគ្រូថា **ភគវា** ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគជាម្ចាស់នេះជាគ្រូ របស់សព្វសត្វ ព្រោះជាអ្នកប្រសើរដោយគុណទាំងពួង ព្រោះដូច្នោះ គប្បីជ្រាប



បទថា **ភគវា** តទៅ ។ សូម្បីព្រះបុរាណាចារ្យទាំងឡាយ ក៏នៅពោលទុកថា ៖

*ពាក្យថា ភគវា ជាពាក្យប្រសើរជាទីបំផុត ពាក្យថា*
*ភគវា ជាពាក្យខ្ពង់ខ្ពស់ ជាទីបំផុត ព្រះតថាគតនោះ*
*ទ្រង់ជាអ្នកគួរដល់សេចក្តីគោរព គារវៈ ដោយហេតុ*
*នោះទើបទ្រង់មានព្រះនាមថា ភគវា ។*

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីពិស្តារនៃបទនោះដោយគាថានេះថា

**ព្រោះហេតុដែលព្រះពុទ្ធជាម្ចាស់ទ្រង់មានភាគ្យធម៌ ១**
**ទ្រង់មានភគ្គធម៌ ១ ទ្រង់ប្រកបដោយភគធម៌ ១ ទ្រង់**
**ចំណែកធម៌ ១ ទ្រង់មានភក្តីភាព ១ ទ្រង់មិនមានការ**
**ត្រាច់ទៅក្នុងភពទាំងឡាយ ១ ដូច្នោះ ទើបបានទទួល**
**ព្រះនាមថា ភគវា ។**

ពិតណាស់ ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ លោកពោលទុកក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងវិសុទ្ធិមគ្គហើយ ។

ដោយហេតុត្រឹមតែប៉ុណ្ណោះ ក្នុងនិទ្ទេសនេះ លោកសម្តែងទេស-នាសម្បត្តិ ដោយពាក្យថា **ឯវំ** សម្តែងសាវកសម្បត្តិ ដោយបទថា **មេ សុតំ** សម្តែងកាលសម្បត្តិថា **ឯកំ សមយំ** សម្តែងទេសកសម្បត្តិ ដោយ

បទថា **ភគវា** ។

ម្យ៉ាងទៀត ក្នុងបទថា **សាវត្ថិយំ** នេះ ឈ្មោះថាសាវត្ថី ជានគរដែលជាទីនៅរបស់ឥសី ឈ្មោះថា **សវត្ថ** ។ អ្នកអក្សរសាស្ត្រពោលទុកយ៉ាងនេះថា ដូច **នគរកាកន្ទី មាកន្ទី** ។ តែព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា **សាវត្ថី** ព្រោះមនុស្សទាំងឡាយមានគ្រឿងឧបភោគបរិភោគសព្វគ្រប់ ។ ម្យ៉ាងទៀត កាលពួកអ្នករទេះសួរថា មានទំនិញអ្វីខ្លះ អ្នកស្រុកសាវត្ថីឆ្លើយថា មានគ្រប់យ៉ាង ។

គ្រឿងឧបករណ៍គ្រប់ប្រភេទ រួមនៅក្នុងក្រុងសាវត្ថី មានគ្រប់កាល ព្រោះដូច្នោះ អាស្រ័យគ្រឿងឧបករណ៍ទាំងអស់ ទើបហៅថា **សាវត្ថី** ។

ជិតក្រុងសាវត្ថីនោះ ។ បទថា **សាវត្ថិយំ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា **ជិត** ។ បទថា **វិហរតិ** នេះ សំដែងដល់ការព្រមព្រៀង ដោយការនៅណាមួយ ក្នុងបណ្ដាការនៅដោយឥរិយាបថ និងការនៅដែលជារបស់ទិព្វរបស់ព្រហ្ម របស់ព្រះអរិយៈដោយមិនវិសេស ។ តែក្នុងទីនេះ សំដែងដល់ការប្រកបដោយឥរិយាបថណាមួយ ក្នុងបណ្ដាឥរិយាបថទាំងឡាយដែលមានប្រភេទ ដូចជាឈរ ដើរ អង្គុយ និងដេក ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ សូម្បីប្រថាប់ឈរ សូម្បីទ្រង់



ដំណើរ សូម្បីទ្រង់ ប្រថាប់អង្គុយ សូម្បីទ្រង់ផ្ទុំ ក៏គប្បីជ្រាបថា **វិហរតិ** ប្រថាប់នៅ នោះឯង ។

ក្នុងបទថា **ជេតវនេ** នេះ ឈ្មោះថា **ជេត** ព្រោះទ្រង់ឈ្នះជនជាសត្រូវរបស់ព្រះអង្គ ឬឈ្មោះថា **ជេត** ព្រោះកើតកាលឈ្នះជនជាសត្រូវនៃព្រះរាជារបស់ខ្លួន ឬឈ្មោះថា **ជេត** ព្រោះតាំងឈ្មោះយ៉ាងនេះដល់ព្រះកុមារ ព្រោះធ្វើឲ្យជាមង្គល ។

ឈ្មោះថា **វន** ព្រោះប្រាថ្នា សេចក្ដីថា ព្រោះធ្វើសេចក្ដីត្រេកអរដល់សត្វទាំងឡាយ ដើម្បីអត្តសម្បត្តិ ព្រោះញុំាំងសេចក្ដីស្រឡាញ់ឲ្យកើតក្នុងខ្លួន ។ ឬឈ្មោះថា **វន** ព្រោះ **សំណូមពរ** សេចក្ដីថា ដូចអង្វរសត្វទាំងឡាយថា ចូរមកប្រើប្រាស់ជាមួយនឹងយើងចុះ មានទាំងខ្យល់ជំនោររំភើយ ៗ ដើមឈើ មែកឈើ ប្រគាបឈើ កំណាត់ឈើ ស្លឹកឈើ ដែលធ្វើឲ្យកើតសេចក្ដីក្លើតក្លើនដោយក្លិនក្រអូបនៃផ្ការឈើប្រភេទផ្សេង ៗ គ្រប់ប្រភេទ និងជាទីត្រេកអររបស់បក្សាបក្សី មានសត្វតាវ៉ៅជាដើម ។

សួនរបស់ស្ដេចជេត ឈ្មោះថា **ជេតវ័ន** ព្រោះសួននោះ ព្រះរាជកុមារព្រះនាមថា **ជេត** ទ្រង់ដាំធ្វើឲ្យលូតលាស់ ទ្រង់មើលថែរក្សាយ៉ាងល្អ ។ ក៏ស្ដេចជេតនោះ ជាម្ចាស់របស់សួននោះ ព្រោះដូច្នោះ ទើប

ហៅថា **ជេតវនំ** សួនរបស់ស្តេចជេត ។ ក្នុងជេតវននោះ ឈ្មោះថា **វន** មាន ២ យ៉ាង គឺ សួនដាំ និងកើតឯង ។ ជេតវននេះ និងវេឡុវន ជាដើម ជាសួនដាំ ។ អន្ធវន មហាវនជាដើម កើតឯង ។

បទថា **អនាថបិណ្ឌិកស្ស អារាមេ** អារាមរបស់អនាថបិណ្ឌិក-សេដ្ឋី មាតាបិតាតាំងឈ្មោះថា សុទត្តគហបតី ។ ម្យ៉ាងទៀត ព្រោះជាអ្នកសម្បូរណ៍ដោយសេចក្តីប្រាថ្នាគ្រប់ប្រការ ព្រោះប្រាសចាកសេចក្តីកំណាញ់ និងព្រោះព្រមព្រៀងដោយគុណ មានករុណាជាដើមបានបរិច្ចាគដុំបាយដល់មនុស្សអនាថាអស់កាលជានិច្ច ដោយហេតុនេះ ទើបឈ្មោះថា **អានាថបិណ្ឌិក** ឈ្មោះថា **អារាម** ព្រោះជាទីមកត្រេចអររបស់សត្វ ឬដោយចំពោះបព្វជិត ។ បព្វជិតទាំងឡាយមកអំពីទីនោះ ៗ រមែងត្រេកអរ រមែងត្រេកអរក្រៃលែង ព្រោះអារាមនោះ លម្អដោយផ្ការឈើ និងផ្លែឈើជាដើម និងព្រោះដល់ព្រមដោយអង្គនៃសេនាសនៈ ៥ យ៉ាង មានមិនឆ្ងាយពេក មិនជិតពេកជាដើម សេចក្តីថា ជាអ្នកមិនធុញទ្រាន់ក្នុងការអាស្រ័យនៅ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **អារាម** ព្រោះកាលជនទៅក្នុងទីនោះ ៗ រមែងញ៉ាំងសេចក្តីត្រេកអរឲ្យដល់ខ្លួន ដោយសម្បត្តិ មានប្រការដូចពោលហើយ ព្រោះអារាមនោះ អនាថបិណ្ឌិក-គហបតី ទិញដោយប្រាក់ ១៨ កោដិ អំពីព្រះហត្ថរបស់ព្រះរាជកុមារជេត



ដើម្បីក្រាលផែនដី ហើយឲ្យសាងសេនាសនៈដោយប្រាក់ ១៨ កោដិ សាងផ្លូវទៅកាន់វិហារដោយប្រាក់ ១៨ កោដិ[1] ហើយបង្អោនថ្វាយចំពោះភិក្ខុសង្ឃ មានព្រះដ៏មានព្រះភាគជាម្ចាស់ជាប្រមុខ ដោយបរិច្ចាគប្រាក់ ៥៤ កោដិ ដោយប្រការដូច្នេះ ដូច្នោះទើបហៅថា អារាមរបស់អនាថបិណ្ឌិកៈ អារាមរបស់អនាថបិណ្ឌិកនោះ ។

ម្យ៉ាងទៀត ពាក្យថា **ជេតវនេ** ប្រកាសម្ចាស់ដើម ។ ពាក្យថា **អនាថបិណ្ឌិកស្ស អារាមេ** ប្រកាសម្ចាស់ក្រោយ ។ ប្រយោជន៍អ្វីក្នុងការប្រកាសជនទាំងនោះ ។ ជាការនឹកដល់ទិដ្ឋានុគតិរបស់អ្នកប្រាថ្នាបុណ្យទាំងឡាយ ។ ស្តេចទ្រង់បរិច្ចាគប្រាក់ ១៨ កោដិ ដែលបានអំពីការលក់ដី ហើយបានសាងខ្លោងទ្វារ និងប្រាសាទ និងដើមឈើមានតម្លៃច្រើនកោដិ អនាថបិណ្ឌិកបរិច្ចាគ ៥៤ កោដិ ដោយប្រការដូច្នេះ ដោយការប្រកាសឈ្មោះជនទាំងនោះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងថា អ្នកប្រាថ្នាបុណ្យទាំងឡាយ រមែងធ្វើបុណ្យយ៉ាងនេះ រមែងបបួលអ្នកប្រាថ្នាបុណ្យពួកដទៃ ក្នុងការនឹកដល់ទិដ្ឋានុគតិរបស់លោកទាំងនោះ ។

---

**១ បាលីថា វិហារមហំ បុណ្យឆ្លងវិហារ ។**

ក្នុងសេចក្តីនោះនឹងមានអ្នកនិយាយថា ប្រសិនបើព្រះដ៏មានព្រះភាគជាម្ចាស់ប្រថាប់នៅក្នុងក្រុងសាវត្ថី ក៏មិនគួរពោលថា **ជេតវនេ អានាថបិណ្ឌិកស្ស អារាមេ** ក្នុងវិហារជេតវន អារាម របស់អានាថ-បិណ្ឌិកសេដ្ឋី លុះប្រថាប់នៅក្នុងទីនោះហើយ ក៏មិនគួរពោលថា **សាវត្ថិយំ** ជិតក្រុងសាវត្ថី ព្រោះសម័យមួយមិនអាចនឹងប្រថាប់នៅក្នុងទីកន្លែងពីរបាន ។ មិនគួរឃើញយ៉ាងនោះ យើងបានពោលទុកហើយមិនមែនឬថា បទថា **សាវត្ថិយំ** ជាសត្តមីវិភត្តិចុះក្នុងអត្ថថា **ជិត** គឺ ជិតក្រុងសាវត្ថី ។

ព្រោះដូច្នោះ ដូចហ្វូងគោទាំងឡាយត្រាច់ទៅជិតទន្លេគង្គា និងទន្លេយមុនាជាដើម ក៏ហៅថា ហ្វូងគោត្រាច់ទៅជិតទន្លេគង្គា ត្រាច់ទៅជិតទន្លេយមុនា យ៉ាងណា សូម្បីសេចក្តីនោះ ក៏ដូច្នោះ ជេតវនអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី កាលព្រះសាស្តាប្រថាប់នៅក្នុងទីនោះ ក៏ពោលថា ប្រថាប់នៅក្នុងព្រះវិហារជេតវនអារាមរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ព្រោះពាក្យថា **ក្រុងសាវត្ថី** របស់បទនោះ ដើម្បីសម្តែងដល់គោចរគាម ពាក្យដ៏សេសដើម្បីសម្តែងដល់ទីនៅដ៏សមគួរដល់បព្វជិត ។

ក្នុងបទទាំងនោះ ព្រះសារីបុត្តត្ថេរសម្តែងដល់ការធ្វើសេចក្តី



អនុគ្រោះគ្រហស្ថរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ដោយប្រកាសឈ្មោះក្រុងសាវត្ថី សម្តែងដល់ការធ្វើសេចក្តីអនុគ្រោះបព្វជិតដោយប្រកាសឈ្មោះជេតវនជាដើម ម្យ៉ាងទៀត ដោយបទដើមសម្តែងដល់ឧបាយជាគ្រឿងវៀរការប្រកបអត្តកិលមថានុយោគ ព្រោះបានទទួលបច្ច័យ ដោយបទក្រោយ សម្តែងដល់ឧបាយជាគ្រឿងវៀរការប្រកបកាមសុខ-ល្លិកានុយោគ ព្រោះលះវត្ថុកាម ។

ម្យ៉ាងវិញទៀតដោយបទមុន សម្តែងដល់ការប្រកបធម្មទេសនាដោយ បទក្រោយសម្តែងដល់ការបង្អោនទៅដើម្បីវិវេក ។ ដោយបទដើម សម្តែងដល់ការចូលដល់ដោយព្រះករុណា ដោយបទក្រោយសម្តែងដល់ការចូលដល់ដោយបញ្ញា ។ ដោយបទដើមសម្តែងដល់ភាពជាអ្នកបង្អោនទៅ ដើម្បីញុំាងប្រយោជន៍សុខឲ្យសម្រេចដល់សត្វទាំងឡាយ ដោយបទក្រោយសម្តែងដល់ការមិនចូលទៅជាប់ក្នុងការធ្វើប្រយោជន៍សុខដើម្បីអ្នកដទៃ ។ ដោយបទដើមសម្តែងដល់ការនៅជាសុខ មានការមិនលះបង់សុខដែលប្រកបដោយធម៌ជានិមិត្ត ដោយបទក្រោយ សម្តែងដល់ការនៅជាសុខ មានការប្រកបធម៌ដ៏កំពូលរបស់មនុស្ស ។ ដោយបទដើម សម្តែងដល់ភាពជាអ្នកច្រើនដោយឧបការៈដល់មនុស្សទាំងឡាយ ដោយបទក្រោយ សម្តែងដល់ភាពជាអ្នកច្រើន

ដោយឧបការៈពពួកទេព ។ ដោយបទដើម សម្តែងដល់សេចក្តីដែលព្រះអង្គឧប្បត្តិ ឡើងក្នុងលោក ជាអ្នកចម្រើនក្នុងលោក ដោយបទក្រោយសម្តែងដល់ភាពជាអ្នកមិនត្រូវលោកលាប ។ ដោយបទដើម សម្តែងដល់ការបង្ហាញដល់ប្រយោជន៍ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ឧប្បត្តិឡើងហើយ ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកកាលកើតឡើងក្នុងលោក រមែងកើតឡើងដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់លោក ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ បុគ្គលឯក គឺ នរណា គឺ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ដោយបទក្រោយ សម្តែងដល់ការនៅដ៏សមគួរ ក្នុងទីដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឧប្បត្តិហើយ ។

ពិតណាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឧប្បត្តិក្នុងព្រៃទាំងនោះ ។ ទាំងលោកិយឧប្បត្តិ និងលោកុត្តរឧប្បត្តិ គឺ គ្រាដំបូងទ្រង់ឧប្បត្តិក្នុងលុម្ពិនីវ័ន គ្រាទីពីរទ្រង់ឧប្បត្តិក្នុងពោធិមណ្ឌល ដោយហេតុនោះ គប្បីជ្រាបការប្រកបសេចក្តីក្នុងបទនេះ ដោយន័យមានជាអាទិ៍យ៉ាងនេះថា ព្រះសារីបុត្តត្ថេរ រមែងសម្តែងដល់ការប្រថាប់នៅរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ក្នុងព្រៃទាំងនោះ ។



បទថា **តត្រ** ក្នុងទីនោះ ជាបទសម្តែងដល់ទេសៈ និងកាលៈ ។ លោកសម្តែងថា ក្នុងសម័យដែលប្រថាប់នៅ និងក្នុងព្រះវិហារជេតវ័នដែលប្រថាប់នៅ ឬសម្តែងដល់ទេសៈ និងកាលៈ ដែលគួរពោល ។ ពិតណាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់មិនសម្តែងធម៌ក្នុងទេសៈ ឬកាលៈ ដែលមិនសមគួរ ដូចក្នុងសេចក្តីនេះថា ម្នាលពាហិយៈ នៅមិនដល់វេលា ។

បទថា **ខោ** ជានិបាតចុះក្នុងអត្ថនៃអវធារណៈ ត្រឹមតែធ្វើបទឲ្យពេញ ឬក្នុងអត្ថនៃកាលដើម ។ បទថា **ភគវា** គឺ សម្តែងភាពជាអ្នកគោរពរបស់លោក ។ បទថា **ភិក្ខុ** ជាពាក្យពោលដល់បុគ្គលដែលគួរស្តាប់ព្រះតម្រាស់ ។ម្យ៉ាងវិញទៀត ក្នុងបទថា **ភិក្ខុ** នេះ គប្បីជ្រាបអត្ថនៃពាក្យដោយន័យមានជាអាទិ៍ថា ឈ្មោះថា **ភិក្ខុ** ព្រោះជាអ្នកសូម ឈ្មោះថា **ភិក្ខុ** ព្រោះជាអ្នកត្រាច់ទៅដើម្បីសូម ។ បទថា **អមន្តេសិ** គឺ ត្រាស់ហៅ បានត្រាស់ឲ្យដឹង នេះជាសេចក្តីក្នុងបទថា **អាមន្តេសិ** នេះ តែក្នុងទីដទៃប្រព្រឹត្តទៅក្នុងសេចក្តីឲ្យដឹងខ្លះ ក្នុងការហៅខ្លះ ។ បទថា **ភិក្ខវោ** សំដែងអាការហៅ ។ ដោយបទនោះ ព្រះដ៏មានព្រះជាម្ចាស់ កាលនឹងទ្រង់ប្រកាសដល់ការប្រព្រឹត្ត ដែលសេពគប់មនុស្សអាក្រក់ និងមនុស្សល្អ ដោយព្រះតម្រាស់ដែលសម្រេច

ដោយការប្រកបគុណ មានសភាពជាអ្នកសូមជាប្រក្រតី មានភាពជាអ្នកសូមជាធម្មតា និងភាពជាធ្វើសេចក្ដីល្អក្នុងការសូមជាដើម របស់ភិក្ខុទាំងនោះ ទើបទ្រង់ធ្វើការគ្របសង្កត់ភាពជាអ្នកវាយមាយ និងការតក់ស្លុត ។ ក៏ដោយបទថា **ភិក្ខវេ** នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើភិក្ខុទាំងនោះ ឲ្យបែរមុខចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គ ដោយព្រះតម្រាស់ដែលពោរពេញទៅដោយព្រះករុណាដ៏ទូលំទូលាយ ព្រះហឫទ័យ និងព្រះនេត្រសុភាព ទ្រង់ញ៉ាំងភិក្ខុទាំងនោះឲ្យកើតសេចក្ដីប្រាថ្នាដើម្បីនឹងស្ដាប់ដោយព្រះតម្រាស់ សម្ដែងភាពជាអ្នកប្រាថ្នាដើម្បីនឹងពោលនោះឯង ។

ម្យ៉ាងទៀត ដោយបទថា **ភិក្ខវេ** នោះ ទ្រង់ដឹកនាំភិក្ខុទាំងនោះឲ្យតាំងចិត្តស្ដាប់ដោយល្អ ដោយព្រះតម្រាស់ដែលជាប្រយោជន៍ ក្នុងការត្រាស់ដឹង ។ ពិតណាស់ ភាពជាអ្នកតាំងចិត្តស្ដាប់ដោយល្អ ជាសម្បត្តិរបស់ព្រះសាសនា ។ ប្រសិនបើមានពាក្យសួរថា បើមានទេវតា និងមនុស្សពួកដទៃនៅជាមួយផង ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ហៅចំពោះភិក្ខុទាំងឡាយប៉ុណ្ណោះ ។ ឆ្លើយថា ព្រោះភិក្ខុទាំងឡាយជាអ្នកចម្រើនជាទីបំផុត ប្រសើរបំផុត ជាអ្នកអង្គុយជិត ជាអ្នកត្រៀមហើយគ្រប់កាល និងដូចជាភាជនៈនៃព្រះធម៌



ទេសនារបស់ព្រះមានព្រះភាគជាម្ចាស់ ទូទៅដល់បរិស័ទទាំងពួង ។ ម្យ៉ាងទៀត ភិក្ខុទាំងឡាយ ឈ្មោះថា ជាអ្នកចម្រើនជាទីបំផុតក្នុងបរិស័ទ ព្រោះចូលដល់មុន ឈ្មោះថា ជាអ្នកប្រសើរបំផុត ព្រោះជាអ្នកធ្វើដំណើរតាមព្រះចរិយារបស់ព្រះសាស្ដា តាំងអំពីជាអ្នកមិនគ្រប់គ្រងផ្ទះជាដើម និងព្រោះជាអ្នកទទួលពាក្យ ប្រៀនប្រដៅទុកទាំងអស់ ឈ្មោះថា ជាអ្នកជិត ព្រោះអង្គុយក្នុងទីនោះ ក៏អង្គុយជិតព្រះសាស្ដា ឈ្មោះថា ជាអ្នកត្រៀមទុកគ្រប់កាល ព្រោះជាអ្នកត្រាច់ទៅក្នុងសំណាក់របស់ព្រះសាស្ដា និងឈ្មោះថា ដូចជាភាជនៈនៃព្រះធម្មទេសនា ព្រោះជាអ្នកព្រមបដិបត្តិតាមបាននូវពាក្យប្រៀនប្រដៅ ។

ក្នុងសេចក្ដីនោះ នឹងមានអ្នកនិយាយថា ក៏ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងធម៌ ត្រាស់ហៅភិក្ខុទាំងឡាយមុន ហេតុអ្វីទ្រង់មិនសម្ដែងធម៌ទៅ ។ ដើម្បីឲ្យតាំងសតិ ព្រោះភិក្ខុទាំងឡាយក្នុងទីប្រជុំ អង្គុយគិតយ៉ាងដទៃខ្លះ ចិត្តវាយមាយខ្លះ ពិចារណាធម៌ខ្លះ មនសិការកម្មដ្ឋានខ្លះ ភិក្ខុទាំងនោះ កាលព្រះដ៏មានព្រះភាគជាម្ចាស់មិនត្រាស់ហៅ ហើយទ្រង់សម្ដែងធម៌ទៅ ក៏មិនអាចនឹងកំណត់បានថា ទេសនានេះ អ្វីជានិទាន មានបច្ច័យ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងដោយមានរឿងកើតឡើង យ៉ាងណា គប្បីដល់

សេចក្តីភាយមាយ ឬគប្បីកាន់យកខុស ដោយហេតុនោះ ដើម្បីឲ្យភិក្ខុទាំងនោះតាំងសតិ ទើបត្រាស់ហៅមុនហើយ ទ្រង់សំដែងធម៌ក្នុងខាងក្រោយ ។

បទថា **ភទន្តេ** នេះជាពាក្យសម្តែងសេចក្តីគោរព ឬជាការឲ្យពាក្យទទួលចំពោះព្រះសាស្តា ។ ម្យ៉ាងទៀត បទថា **ភទន្តេ** នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលត្រាស់ថា **ភិក្ខវោ** ត្រាស់ហៅភិក្ខុទាំងឡាយពួកនោះ ។ ភិក្ខុទាំងនោះទទួលថា **ភទន្តេ** ទូលទទួលព្រះដ៏មានព្រះភាគជាម្ចាស់ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **ភិក្ខវោ** ភិក្ខុទាំងឡាយនោះទទួលថា **ភទន្តេ** ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឲ្យភិក្ខុទាំងឡាយ ឲ្យពាក្យទទួលថា **ភិក្ខវោ** ។ ភិក្ខុទាំងឡាយ ទូលពាក្យថា **ភទន្តេ** ។ បទថា **តេភិក្ខូ** ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ហៅ ។ បទថា **ភគវតោ បច្ចស្សោសុំ** គឺភិក្ខុទាំងឡាយទូលទទួលការត្រាស់ហៅរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ សេចក្តីថា ភិក្ខុទាំងឡាយបែរមុខ ស្តាប់ ទទួល កាន់យក ។ បទថា **ភគវា ឯតទវោច** គឺ ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ព្រះសូត្រទាំងអស់នោះ ដែលគួរត្រាស់ក្នុងឥឡូវនេះ ។

ម្យ៉ាងទៀត ដោយហេតុត្រឹមតែប៉ុណ្ណោះ ព្រះសារីបុត្តត្ថេរទើប



ពោលដល់និទានណា ដែលប្រដាប់ដោយការអាងដល់ កាលៈ ទេសៈ អ្នកសម្តែង និងបរិស័ទ ដើម្បីសេចក្តីងាយនៃព្រះសូត្រនេះ ដែលធ្វើឲ្យ... បញ្ចាំងដល់សេចក្តីជ្រាលជ្រៅនៃទេសនា និងញាណរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដែលសម្បូណ៌ដោយអត្ថ និងព្យញ្ជនៈ ដូចកំពង់ទឹកដែលជាភូមិភាគដ៏ស្អាត ពោរពេញដោយដីខ្សាច់ដែលលាតសន្ធឹងទុកដោយសំណាញ់កែវមុក្តា មានជណ្តើរកែវវិលាសៈ រចនាដោយផ្ទាំងសិលាភបរលោង ដើម្បីចុះទៅស្រួលក្នុងស្រះបោក្ខរណី មានទឹកមានរសឆ្ងាញ់ ថ្លាស្អាតពោរពេញទៅដោយផ្កាឈូក និងគុម្ពឈូក ដូចជណ្តើរដ៏ល្អស្អាតរុងរឿង រំលេចឡើងដោយពន្លឺស្វាងស្វៃនៃមណ្ឌលកែវមណី ដែលចងភ្ជាប់ទុកជាមួយផែនក្តារដែលល្អិតទន់ធ្វើដោយភ្លុកដំរី និងវល្លិ៍មាស ដើម្បីងាយឡើង ញុំាំងប្រាសាទដ៏ប្រសើរតុបតែងទុកយ៉ាងរុងរោចន៍លោមព័ទ្ធដោយជញ្ជាំងដែលរៀបទុកយ៉ាងល្អ និងវេទិការដែលវិចិត្រ ដូចព្រោះប្រាថ្នានឹងពាល់ត្រូវផ្លូវនៃនក្ខត្ត ដូចមហាទ្វារ ដែលមានទ្វារ និងបង្អួចធំទូលាយ រុងរោចន៍ ភ្លឺស្វាង បរិសុទ្ធិដោយមាស ប្រាក់ កែវមណី កែវមុក្តា និងកែវប្រវាលជាដើម ដើម្បីងាយចូលទៅកាន់ផ្ទះធំ ដែលស្រស់ល្អដោយឥស្សរិយសម្បត្តិដែលរុងរឿង ដែលជាគោលការប្រព្រឹត្តរបស់ជន ក្នុងផ្ទះដែលមាន

សម្ដែងពីរោះ ដោយការនិយាយ ការសើច លាយឡំទៅដោយសម្ដែងប៉ះខ្ទប់ មានកងដៃ និងកងជើងថ្នាក់ទីនជាដើម ការពណ៌នាសេចក្ដីនៃនិទាននោះ ពេញលេញហើយ ។

បទថា **បញ្ច** ក្នុងព្រះសូត្រជាការកំណត់ចំនួន ។ បទថា **ឥមានិ ឥន្ទ្រិយានិ** ឥន្ទ្រិយទាំងនេះ ជាបទបង្ហាញធម៌ដែលកំណត់ទុកហើយ ។ អត្ថនៃឥន្ទ្រិយ លោកពោលទុកហើយក្នុងខាងក្រោយ ។ ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ គ្រាទ្រង់សម្ដែងព្រះសូត្រនេះហើយ មានបំណងនឹងសម្ដែងវិធីចម្រើនសេចក្ដីបរិសុទ្ធ នៃឥន្ទ្រិយទាំងឡាយដែលបានត្រាស់ទុកក្នុងព្រះសូត្រនេះ និងការរម្ងាប់ឥន្ទ្រិយដែលចម្រើនហើយ ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា **ឥមានិ បញ្ចិន្ទ្រិយានិ** ឥន្ទ្រិយ ៥ ទាំងនេះ ។

ក្នុងបទទាំងនោះ បទថា **វិសុជ្ឈន្តិ** គឺ រមែងដល់សេចក្ដីបរិសុទ្ធ ។ បទថា **អស្សទ្ធេ** អ្នកមិនមានសទ្ធា គឺ អ្នកប្រាសចាកការជឿក្នុងព្រះរតនត្រ័យ ។ បទថា **សទ្ធេ** អ្នកមានសទ្ធា គឺ អ្នកដល់ព្រមដោយសទ្ធាក្នុងព្រះរតនត្រ័យ ។ បទថា **សេវតោ** សមាគម គឺ សេពគប់ដោយចិត្ត ។ បទថា **ភជតោ** គប់រក គឺ ចូលទៅអង្គុយជិត ។ បទថា **បយិរុបាសតោ** អង្គុយជិត គឺ ចូលទៅអង្គុយដោយការគោរព ។



បទថា **បាសាទនីយេ សុត្តន្តេ** ព្រះសូត្រដែលនាំមកនូវសេចក្ដីជ្រះថ្លា គឺ ព្រះសូត្របដិសំយុត្តដោយ ព្រះរតនត្រ័យដែលកើតសេចក្ដីជ្រះថ្លា ។ បទថា **កុសីតេ** អ្នកខ្ជិលច្រអូស ឈ្មោះថា **កុសីទា** ព្រោះលិចចុះដោយអាការខ្ជិលច្រអូស ។ **កុសីទា** ហ្នឹងឯង គឺ អ្នក ខ្ជិលច្រអូស ។ បុគ្គលអ្នកខ្ជិលច្រអូសទាំងនេះ ។ បទថា **សម្មប្បធានេ** ការព្យាយាមប្រពៃ គឺ ព្រះសូត្របដិសំយុត្តដោយសេចក្ដីព្យាយាមប្រពៃ ដែលឲ្យសម្រេចកិច្ច ៤ យ៉ាង ។ បទថា **មុដ្ឋស្សតិ** អ្នកមិនមានសតិ គឺ អ្នកមានសតិវិនាសទៅ ។ បទថា **សតិប្បដ្ឋានេ** សតិប្បដ្ឋាន គឺ ព្រះសូត្រដែលធ្វើឲ្យក្រៃលែងដោយសតិប្បដ្ឋាន ។ បទថា **ឈានវិ-មោក្ខេ** ឈាន និងវិមោក្ខ គឺ ព្រះសូត្រដែលធ្វើឲ្យក្រៃលែងដោយចតុត្ថជ្ឈាន វិមោក្ខ ៨ និងវិមោក្ខ ៣ យ៉ាង ។ បទថា **ទុប្បញ្ញេ** បុគ្គលបញ្ញាអាក្រក់ គឺ មិនមានបញ្ញា ឬឈ្មោះថា **ទុប្បញ្ញា** ព្រោះជាអ្នកមានបញ្ញាអាក្រក់ ព្រោះមិនមានបញ្ញា នូវបុគ្គលអ្នកមានបញ្ញាអាក្រក់ទាំងនោះ ។

បទថា **គម្ភីរញាណចរិយំ** ញាណចរិយាដែលជ្រាលជ្រៅ គឺ ព្រះសូត្រ បដិសំយុត្តដោយអរិយសច្ចៈ ៤ និងបដិច្ចសមុប្បាទជាដើម ឬដូចជាញាណកថា ។ បទថា **សុត្តន្តក្ខន្ធេ** ចំនួនព្រះសូត្រ គឺ ចំណែក

នៃព្រះសូត្រ ។

បទថា **អស្សទ្ធិយំ** ភាពជាអ្នកមិនមានសទ្ធា ក្នុងបទមានជាអាទិ៍ថា **អស្សទ្ធិយំ** គឺ ភាពជាអ្នកមិនមានសទ្ធា បុគ្គលឃើញទោសក្នុងការមិនមានសទ្ធា លះការមិនមានសទ្ធា រមែងចម្រើនសទ្ធិន្ទ្រិយ បុគ្គលឃើញអានិសង្សក្នុងសទ្ធិន្ទ្រិយ ចម្រើនសទ្ធិន្ទ្រិយ រមែងលះភាពជាអ្នកមិនមានសទ្ធា ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **កោសជ្ជំ** គឺ ភាពជាអ្នកខ្ជិលច្រអូស ។ បទថា **បមាទំ** គឺ ការនៅប្រាសចាកសតិ ។ បទថា **ឧទ្ធច្ចំ** គឺ ភាពជាអ្នករាយមាយបានដល់ ការរាយមាយ ។

បទថា **បហីនត្តា** ព្រោះអ្នកលះហើយ គឺ ព្រោះជាអ្នកលះការបំពេញឈានដោយអំណាចនៃអប្បនា ។ បទថា **សុប្បហីនត្តា** ភាពជាអ្នកលះល្អហើយ គឺ ព្រោះជាអ្នកលះហើយដោយល្អ ដោយការបំពេញវិបស្សនា ដោយអំណាចនៃវុដ្ឋានគាមិនី ។ បទថា **ភាវិតំ ហោតិ សុភាវិតំ** ដែលបុគ្គលចម្រើនហើយ អប់រំល្អហើយ គប្បីប្រកបតាមលំដាប់ដូចដែលពោលហើយនោះឯង ។ ពិតណាស់ ព្រោះលះដោយអំណាចផ្ទុយគ្នានឹងវិបស្សនា ទើបគួរពោលថា **សុប្បហីនត្តា** ព្រោះដូច្នោះ ទើបគួរពោលថា **សុភាវិតំ** មិនមែនដោយឈាន ។



ម្យ៉ាងទៀត ព្រោះការសម្រេចភាវនា ដោយការលះវត្ថុដែលគួរលះជាការសម្រេចការលះវត្ថុដែលគួរលះ ដោយការសម្រេចនៃភាវនាដូច្នោះ លោកសម្តែងធ្វើជាគូគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **បដិបស្សទ្ធិវារ** ដូចតទៅនេះ បទថា **ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច** ជាឥន្ទ្រិយដែលបុគ្គលចម្រើនហើយ អប់រំហើយ ព្រោះឥន្ទ្រិយដែលបុគ្គលចម្រើនហើយនោះឯងជាឥន្ទ្រិយដែលអប់រំហើយ ។ បទថា **បដិប្បស្សទ្ធានិ ច សុប្បដិប-ស្សទ្ធានិ ច** រម្ងាប់ហើយ រម្ងាប់ល្អហើយ លោកពោលដល់សេចក្តីដែលឥន្ទ្រិយរម្ងាប់ហើយនោះឯង ជាឥន្ទ្រិយរម្ងាប់ល្អហើយ ។ គប្បីជ្រាបសេចក្តីដែលឥន្ទ្រិយ ដែលបុគ្គលចម្រើនហើយ និងរម្ងាប់ហើយដោយអំណាចនៃការកើតនូវកិច្ចរបស់មគ្គក្នុងខណៈនៃផល ។ បទថា **សមុច្ឆេទវិសុទ្ធិយោ** សមុច្ឆេទវិសុទ្ធិ បានដល់ មគ្គវិសុទ្ធិនោះឯង ។ បទថា **បដិប្បស្សទ្ធិវិសុទ្ធិយោ** បដិបស្សទ្ធិវិសុទ្ធិ បានដល់ ផលវិសុទ្ធិនោះឯង ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងការប្រកបឥន្ទ្រិយមានវិធីដូចពោលហើយយ៉ាងនោះ ដោយអំណាចនៃការរកបុគ្គល ទើបពោលពាក្យមានជាអាទិ៍ថា **កតីនំ បុគ្គលានំ** បុគ្គលប៉ុន្មាន ។ ក្នុង

បទទាំងនោះ បទថា **ភាវិតិន្ទ្រិយវសេន ពុទ្ធោ** ឈ្មោះថា **ពុទ្ធោ** ដោយអំណាចភាពជាអ្នកចម្រើនឥន្ទ្រិយហើយ សេចក្តីថា អ្នកត្រាស់ដឹង អ្នកដឹងអរិយសច្ចៈ ៤ ដោយការស្តាប់ធម្មកថា អំពីព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ នេះជាពាក្យនិយាយដល់ហេតុនៃភាពជាអ្នកចម្រើនឥន្ទ្រិយហើយ ព្រោះថា អ្នកចម្រើនឥន្ទ្រិយហើយ ក្នុងខណៈនៃផល ព្រោះជាអ្នកត្រាស់ដឹងមគ្គដោយអំណាចការសម្រេចភាវនា ។ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងដល់អ្នកតាំងនៅក្នុងអរហត្តផលប៉ុណ្ណោះ ឲ្យវិសេសឡើងទៅ ព្រោះអរិយបុគ្គលទាំងឡាយសូម្បី ៨ ក៏ជាព្រះសាវករបស់ព្រះតថាគត ទើបពោលថា **ខីណាសវោ** ព្រះខីណាស្រព ព្រោះព្រះខីណាស្រពប៉ុណ្ណោះ លោកពោលថា **ភាវិតិន្ទ្រិយោ** អ្នកចម្រើនហើយ ដោយការសម្រេចកិច្ចទាំងពួង ។ ចំណែកព្រះអរិយបុគ្គលសូម្បីក្រៅអំពីនោះ ក៏ជាអ្នកចម្រើនឥន្ទ្រិយហើយដូចគ្នា ដោយបរិយាយព្រោះសម្រេចកិច្ចដោយមគ្គនោះ ៗ ព្រោះដូច្នោះ ក្នុងខណៈនៃផល ៤ លោកពោលថា ឥន្ទ្រិយ ៥ ជាឥន្ទ្រិយដែលបុគ្គលចម្រើនហើយ អប់រំល្អហើយ ។ មួយវិញទៀត ព្រោះឥន្ទ្រិយភាវនានៅមាននោះឯង ដល់ព្រះអរិយបុគ្គលទាំងនោះ ដើម្បីប្រយោជន៍ដល់ឧបរិមគ្គ ដូច្នោះ ព្រះអរិយបុគ្គលទាំងនោះ ទើបមិនឈ្មោះថា ជាអ្នកចម្រើនឥន្ទ្រិយ



ហើយដោយត្រង់ ។ បទថា **សយម្ភូតដ្ឋេន** ដោយអត្ថថា ត្រាស់ដឹងឯង គឺ ជាអ្នកមិនមានអាចារ្យ ជា **ភគវា** ដោយអត្ថកើតហើយ កើតហើយក្នុងជាតិដែលជាអរិយៈ ។ ពិតណាស់ សូម្បីព្រះបច្ចេកពុទ្ធជាម្ចាស់នោះ ក៏ជាព្រះសយម្ភូក្នុងខណៈផល ដោយអំណាចនៃការសម្រេចភាវនា ។ ឈ្មោះថា **ភាវិតិន្ទ្រិយោ** ដោយអត្ថថា ជាអ្នកដឹងឯង ក្នុងខណៈនៃផលដោយប្រការដូច្នេះ ។ បទថា **អប្បមេយ្យដ្ឋេន** ដោយអត្ថថា មានព្រះគុណប្រមាណមិនបាន គឺ ដោយអត្ថថា មិនអាចប្រមាណបាន ព្រោះទ្រង់ប្រកបដោយអនន្តគុណ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ឈ្មោះថា មានព្រះគុណប្រមាណមិនបាន ព្រោះសម្រេចដោយភាវនាក្នុងខណៈនៃផល ព្រោះដូច្នោះឯង ទើបជាអ្នកចម្រើនឥន្ទ្រិយហើយ ។

(ចប់ អដ្ឋកថា បឋមសុត្តន្តនិទ្ទេស)

# អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស

ព្រះសារីបុត្តត្ថេរបំណងនឹងតាំងព្រះសូត្រដទៃនេះទៀត ហើយបង្ហាញដល់ប្រភេទនៃឥន្ទ្រិយទាំងឡាយ ទើបសម្តែងព្រះសូត្រមានជាអាទិ៍ថា **បញ្ចិមានិ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយឥន្ទ្រិយ ៥ ទាំងនេះ ។ ក្នុងបទទាំងនោះ បទថា **យេ ហិ កេចិ** សមណៈ ឬព្រាហ្មណ៍ពួកណាមួយ ជាបទកាន់យកដោយមិនមានសល់ ។ **ហិ** អក្សរ ជានិបាតចុះក្នុងអត្ថត្រឹមតែឲ្យពេញបទ ( បទសម្បូរណ៍ ) ។

បទថា **សមណា វា ព្រាហ្មណា វា** លោកពោលដោយអំណាចនៃវោហារនៃលោក ។ បទថា **សមុទយំ** ហេតុឲ្យកើត គឺ បច្ច័យ ។ បទថា **អត្ថង្គមំ** ការរលត់ គឺ ដល់ការមិនមាននៃឥន្ទ្រិយដែលកើតហើយ ឬការមិនកើតនៃឥន្ទ្រិយដែលនៅមិនកើត ។ បទថា **អស្សាទំ** គឺ អានិសង្ស ។ បទថា **អាទីនវំ** គឺ ទោស ។ បទថា **និស្សរណំ** ឧបាយគ្រឿងរលាស់ចេញ គឺ ចេញទៅ ។ បទថា **យថាភូតំ** គឺ តាម សេចក្តីពិត ។ បទថា **សមណេសុ** គឺ អ្នកស្ងប់បាប ។ បទថា **សមណសម្មតា** បានទទួលសន្មតិថា ជាសមណៈ គឺ យើងមិនបានទទួលសន្មតិថា ជាសមណៈ ។ កាលពោលថា **សម្មតា** ដោយអំណាចនៃបច្ចុប្បន្នកាល ជាការពោលឆដ្ឋីវិភត្តិក្នុងបទថា **មេ** នេះ ដោយ



អំណាចនៃលក្ខណៈរបស់សត្ថុ ។

បទថា **ព្រាហ្មណេសុ** គឺ អ្នកបន្សាត់បាប ។ បទថា **សាមញ្ញត្ថំ** សាមញ្ញផល គឺ ប្រយោជន៍នៃភាពជាសមណៈ ។ បទ ថា **ព្រហ្មញ្ញត្ថំ** ព្រហ្មញ្ញផល គឺ ប្រយោជន៍នៃភាពជាព្រាហ្មណ៍ ។ សូម្បីដោយបទទាំងពីរ ក៏ជាការពោលដល់អរហត្តផលនោះឯង ។

មយ៉ាងវិញទៀត បទថា **សាមញ្ញត្ថំ** បានដល់ផល ៣ ខាងក្រោម ។ បទថា **ព្រហ្មញ្ញត្ថំ** បានដល់ អរហត្តផល ។ ព្រោះទាំងសាមញ្ញផល និងព្រហ្មញ្ញផល ក៏គឺ អរិយមគ្គនោះឯង ។ បទថា **ទិដ្ឋេវ ធម្មេ** គឺ ក្នុងអត្តភាពដែលប្រចក្សហើយនេះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដែលដឹងក្រៃលែងខ្លួនឯង គឺ ធ្វើឲ្យប្រចក្សដោយបញ្ញាដែលដឹងក្រៃលែងដោយខ្លួនឯង ។ បទថា **ឧបសម្បជ្ជ** ចូលដល់ គឺ ដល់ហើយ ឬឲ្យសម្រេចហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះ ។ ព្រះ-សារីបុត្តត្ថេរ សួរដល់ចំនួនប្រភេទរបស់ហេតុកើតនៃឥន្ទ្រិយជាដើមមុន ហើយឆ្លើយចំនួននៃប្រភេទតទៅ ។ ក្នុងបទទាំងនោះ បទថា **អសីតិសតំ** ១៨០ គឺ ១០០ លើសដោយ ៨០ ។ យោជនាកែថា

ដោយអាការដែលបណ្ឌិតពោលថា ១៨០ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគណនានិទ្ទេស ដែលជាចំណែកខាងដើម
នៃការសួរចំនួនប្រភេទទៀត ដូចតទៅនេះ ។ បទថា **អធិមោក្ខត្ថាយ**
ដើម្បីប្រយោជន៍ដល់ការបង្អោនចិត្តជឿ ។ គឺដើម្បីបង្អោនចិត្តជឿ
ដើម្បីប្រយោជន៍ដល់ការជឿ ។ បទថា **អាវជ្ជនាយ សមុទយោ** ហេតុ
កើតនៃការនឹកដល់ គឺ បច្ច័យនៃសទ្ធិន្ទ្រិយ ការនឹកដល់ចំណែកខាង
ដើមថា យើងនឹងញុំាងសទ្ធាឲ្យកើត ជាឧបនិស្សយប្បច្ច័យនៃសទ្ធិ-
ន្ទ្រិយ ការនឹកដល់ការស្ទុះទៅនៃសទ្ធិន្ទ្រិយ ជាអនន្តរប្បច្ច័យនៃជវន
ចិត្តដួងដំបូង ជាឧបនិស្សយប្បច្ច័យនៃជវនចិត្តដួងទី ២ ជាដើម ។
បទថា **អធិមោក្ខវសេន** ដោយអំណាចការបង្អោនចិត្តជឿ គឺ ដោយ
អំណាចការបង្អោនចិត្តជឿ សម្បយុត្តដោយឆន្ទៈ ។ បទថា **ឆន្ទស្ស
សមុទយោ** ហេតុកើតនៃឆន្ទៈ គឺ ហេតុកើតនៃធម៌ឆន្ទៈជាយេវាបន-
កធម៌ សម្បយុត្តដោយអធិមោក្ខ ដែលកើតឡើង ព្រោះការនឹកដល់
ចំណែកខាងដើមជាបច្ច័យ ។ម្យ៉ាងទៀត ហេតុកើតនោះជាបច្ច័យ
នៃសទ្ធិន្ទ្រិយ ដោយអំណាចនៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ
និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ
នឹងជាអធិបតិប្បច្ច័យ ក្នុងកាលដែលមានឆន្ទៈជាធំ ហេតុកើតនោះជា



បច្ច័យនៃឥន្ទ្រិយទី ២ ដោយអំណាចនៃអនន្តរប្បច្ច័យ សមនន្តរប្ប-
ច្ច័យ អនន្តរូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និង
វិគតប្បច្ច័យ ។ ដោយន័យនេះឯង គប្បីធ្វើការប្រកបសូម្បីមនសិការ ។

សេចក្តីពិត ក្នុងបទថា **មនសិការោ** នេះក៏ដូចគ្នា គឺ មានមនសិការ
ដូចគ្នា ដែលមានការស្ទុះទៅជាលក្ខណៈ ។ មនសិការនោះ មិនជា
អធិបតិប្បច្ច័យក្នុងសម្បយុត្តធម៌ទាំងឡាយ គប្បីជ្រាបថា ការកាន់
យកហេតុកើតទាំងពីរនេះថា ព្រោះជាពលវប្បច្ច័យ ( បច្ច័យដែល
មានកម្លាំង ) ។ បទថា **សទ្ធិន្ទ្រិយស្ស វសេន** ដោយអំណាចនៃ
សទ្ធិន្ទ្រិយ គឺ ដោយអំណាចសទ្ធិន្ទ្រិយ ដែលដល់ភាពជាឥន្ទ្រិយ
ព្រោះការចម្រើនក្រៃលែងនៃការនោ ។ បទថា **ឯកត្តុបដ្ឋានំ** សេចក្តី
ប្រាកដជាធម៌តែមួយ គឺ ឋានៈដែលធំក្រៃលែង ព្រោះមិនញាប់ញ័រ
ក្នុងអារម្មណ៍ រមែងជាបច្ច័យនៃសទ្ធិន្ទ្រិយខ្ពស់ឡើងទៅ ។ គប្បីជ្រាប
សូម្បីឥន្ទ្រិយដ៏សេស ដោយន័យដូចពោលហើយក្នុងសទ្ធិន្ទ្រិយនោះ
ឯង ។ ឥន្ទ្រិយមួយ ៗ មានហេតុកើតក្នុងមួយ ៗ ៤ ព្រោះហេតុនោះ
ឥន្ទ្រិយ ៥ ទើបមានហេតុ ២០ ក្នុងហេតុកើតមួយ ៗ របស់ហេតុកើត
ទាំង ៤ លោកប្រកបចូលជាមួយឥន្ទ្រិយ ៥ ហើយពោលហេតុកើត
សរុប ២០ ។

អាចារ្យទាំងឡាយពោលថា គប្បីឃើញ ២០ ទី ១ ដោយអំណាចនៃមគ្គផ្សេង ៗ , ២០ ទី ២ ដោយអំណាចនៃមគ្គ ១ រួមជាអាការ ៤០ ដោយប្រការដូច្នេះ ។

សូម្បី **អត្ថង្គមវារ** ( ការរលត់ ) ក៏គប្បីជ្រាបដោយន័យនេះឯង ។ ម្យ៉ាងទៀត ការរលត់នោះ ការមិនបានរបស់អ្នកមិនខ្វល់ខ្វាយ ក្នុងការចម្រើនឥន្ទ្រិយ ឈ្មោះថា រលត់ការបាន ។ វិនាសការបានរបស់អ្នកវិនាសចាកការចម្រើនឥន្ទ្រិយ ឈ្មោះថា រលត់ ។ ការស្ងប់រម្ងាប់ របស់អ្នកសម្រេចផល ឈ្មោះថា រលត់ ។ បទថា **ឯកត្តំ អនុបដ្ឋានំ** ការមិនប្រាកដជាធម៌តែមួយ គឺ ការមិនប្រាកដក្នុងធម៌តែមួយ ។

## អដ្ឋកថា អស្សាទនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងអស្សាទនិទ្ទេស ដូចតទៅនេះ ។ បទថា **អស្សទ្ធិយស្ស អនុបដ្ឋានំ** ការមិនប្រាកដនៃភាពជាអ្នកមិនមានសទ្ធា គឺ វៀរបុគ្គលអ្នកមិនមានសទ្ធា សេពគប់បុគ្គលអ្នកមានសទ្ធា ពិចារណាបសាទនីយសូត្រ និងធ្វើយោនិសោមនសិការក្នុងសូត្រនោះឲ្យច្រើន ឈ្មោះថា ការមិនប្រាកដនូវភាពជាអ្នកមិនមានសទ្ធា ។ ក្នុងបទថា



**អស្សទ្ធិយបរិឡាហស្ស អនុបដ្ឋានំ** ការមិនប្រាកដនៃសេចក្ដីក្ដៅក្រហាយព្រោះភាពជាអ្នកមិនមានសទ្ធានេះ កាលនិយាយដល់សទ្ធាប្រព្រឹត្តក្នុងមនុស្សមិនមានសទ្ធា សេចក្ដីទុក្ខ ទោមនស្សរមែងកើត នេះឈ្មោះថា សេចក្ដីក្ដៅក្រហាយ ព្រោះភាពជាអ្នកមិនមានសទ្ធា ។ បទថា **អធិមោក្ខចរិយាយ វេសារជ្ជំ** សេចក្ដីក្លៀវក្លានៃការប្រព្រឹត្តទៅ ដោយការបង្អោនចិត្តជឿ គឺ ភាពជាអ្នកក្លាហានដោយការប្រព្រឹត្តទៅនៃសទ្ធា របស់អ្នកដល់ភាពជំនាញ ដោយអំណាចនៃវត្ថុដែលជាសទ្ធា ឬដោយសការៈ ។ បទថា **សន្តោ ច វិហារាធិគមោ** សេចក្ដីស្ងប់ និងការសម្រេចសុខវិហារធម៌ គឺ ការបានសមថៈ ឬវិបស្សនា ។ ពាក្យថា **សោមនស្ស** ក្នុងបទថា **សុខំ សោមនស្សំ** នេះ ដើម្បីសម្ដែងដល់សេចក្ដីសុខផ្លូវចិត្ត សូម្បីសេចក្ដីសុខតាមផ្លូវកាយ ក៏រមែងបានដល់ កាយដែលសម្ផស្សដោយរូបប្រណីតកើតឡើង ព្រោះសទ្ធិន្ទ្រិយ ព្រោះសេចក្ដីសុខសោមនស្សជាប្រធាន និងជាគុណ លោកទើបពោលឲ្យវិសេសថា សុខ និងសោមនស្សនេះ ជាគុណនៃសទ្ធិន្ទ្រិយ ដោយន័យនេះ គប្បីជ្រាបការប្រកបសូម្បីគុណនៃឥន្ទ្រិយដ៏សេស ។

(ចប់ អដ្ឋកថា អស្សាទនិទ្ទេស)

## អដ្ឋកថា អាទីនវនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងអាទីនវនិទ្ទេស ដូចតទៅនេះ ។ បទថា **អានិច្ចដ្ឋេន** ព្រោះអត្ថថា មិនទៀង គឺ ព្រោះអត្ថថា សទ្ធិន្ទ្រិយមិនទៀង លោកពោលថា សទ្ធិន្ទ្រិយនោះ មានអត្ថថា មិនទៀង ជាទោសរបស់សទ្ធិន្ទ្រិយ ។ សូម្បីក្នុងពីរបទក្រៅនេះ ក៏មានន័យដូចគ្នា ។ គប្បីជ្រាបថា ទោសទាំងនេះ ជាទោសរបស់គុណនៃហេតុកើត និងការរលត់របស់ឥន្ទ្រិយដែលជាលោកិយៈនោះឯង ។

(ចប់ អដ្ឋកថាអាទីនវនិទ្ទេស)

## អដ្ឋកថា និស្សរណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិស្សរណនិទ្ទេស ដូតទៅនេះ ។ ក្នុងបទថា **អធិមោក្ខដ្ឋេន** ដោយអត្ថថា ការបង្អោនចិត្តជឿជាដើម លោកធ្វើមួយ ៗ ៥ ក្នុងឥន្ទ្រិយមួយ ៗ ហើយសំដែងឥន្ទ្រិយ ៥ មានឧបាយជាគ្រឿងរលាស់ចេញ ២៥ ដោយអំណាចមគ្គ និងផល ។ ក្នុង



បទទាំងនោះ បទថា **តតោ បណីតតរសទ្ធិន្ទ្រិយស្ស បដិលាភា** តែការបានសទ្ធិន្ទ្រិយដែលប្រណីតជាងនោះ គឺ ដោយអំណាចការបានសទ្ធិន្ទ្រិយដែលប្រណីតជាងខណៈនៃមគ្គ ចាកសទ្ធិន្ទ្រិយដែលប្រព្រឹត្តទៅហើយក្នុងខណៈនៃវិបស្សនានោះ ។ បទថា **បុរិមតរសទ្ធិន្ទ្រិយា និស្សដំ ហោតិ** រលាស់ចេញចាកសទ្ធិន្ទ្រិយ ដែលមានអំពីមុន គឺ សទ្ធិន្ទ្រិយក្នុងខណៈនៃមគ្គ ចេញចាកសទ្ធិន្ទ្រិយដែលប្រព្រឹត្តទៅហើយក្នុងខណៈនៃវិបស្សនា ដែលមានអំពីមុន ។ ដោយន័យនេះឯង គប្បីប្រកបសូម្បីសទ្ធិន្ទ្រិយក្នុងខណៈនៃផល សូម្បីសទ្ធិន្ទ្រិយដ៏សេសក្នុងខណៈទាំងពីរនោះ ។

បទថា **បុព្វភាគេ បញ្ចហិ ឥន្ទ្រិយេហិ** ដោយឥន្ទ្រិយ ៥ ក្នុងចំណែកខាងដើម គឺ គ្រឿងរលាស់ចេញទៅ ៨ ដោយអំណាចនៃសមាបត្តិ ៨ មានបឋមជ្ឈានជាដើម ដោយឥន្ទ្រិយ ៥ ក្នុងឧបចារៈនៃបឋមជ្ឈាន ជាគ្រឿងរលាស់ចេញ ១៨ ដោយអំណាចនៃវិបស្សនា ១៨ មានអនិច្ចានុបស្សនាជាដើម គ្រឿងរលាស់ចេញទៅជាលោកុត្តរៈ ៨ ដោយអំណាចនៃសោតាបត្តិមគ្គ ជាដើម ។ លោកសម្តែងនិស្សរណៈ ( គ្រឿងរលាស់ចេញ ) ៣៤ ដោយអំណាចឈាន សមាបត្តិ មហាវិបស្សនា មគ្គ និងផល ដោយការឈានកន្លងទៅនៃឥន្ទ្រិយ

មុន ៗ ។ ក៏បទថា **នេក្ខម្មេ បញ្ចិន្ទ្រិយានិ** ឥន្ទ្រិយ ៥ ក្នុងនេក្ខម្មៈ លោកសម្តែងនិស្សរណៈ ៣៧ ជាបដិបក្ខ ដោយអំណាចការលះវត្ថុជាបដិបក្ខ ។ ក្នុងបទនោះ លោកពោលនិស្សរណៈ ៧ ក្នុងនិស្សរណៈ ៧ មាននេក្ខម្មៈជាដើម ដោយអំណាចនៃឧបចារភូមិ តែលោកមិនបានពោលដល់ផល ព្រោះមិនមានការលះធម៌ដែលបដិបក្ខ ។ បទថា **ទិដ្ឋេកដ្ឋេហិ** កិលេសនៅក្នុងទីជាមួយគ្នានឹងទិដ្ឋិ កិលេស ឈ្មោះថា **ទិដ្ឋេកដ្ឋា** ព្រោះតាំងនៅក្នុងបុគ្គលម្នាក់ព្រមជាមួយទិដ្ឋិ រហូតដល់សោតាបត្តិមគ្គចេញចាកកិលេស ដែលនៅក្នុងទីជាមួយគ្នានឹងទិដ្ឋិទាំងនោះ ។ បទថា **ឱឡារិកេហិ** ចេញចាកកិលេសចំណែកគ្រោតគ្រាត គឺចាកកាមរាគៈ និងព្យាបាទៈ ដែលគ្រោតគ្រាត ។ បទថា **អនុសហគតេហិ** ចេញចាកកិលេសចំណែកល្អិត គឺ កាមរាគៈ និងព្យាបាទៈនោះឯង ដែលជាចំណែកល្អិត ។ បទថា **សព្វកិលេសេហិ** ចេញចាកកិលេសទាំងពួង គឺ ចេញចាកកិលេស មានរូបរាគៈជាដើម ។ ព្រោះលះកិលេសទាំងនោះបាន ក៏ជាការលះកិលេសទាំងពួងបាន ព្រោះដូច្នោះទើបលោកពោលថា **សព្វកិលេសេហិ** ។ តែក្នុងនិទ្ទេសនេះ បទទាំងឡាយដែលមានសេចក្តីនៅមិនទាន់បានពោលទុក បានពោលទុកហើយក្នុងខាងក្រោយ ។



បទថា **សព្វេសញ្ញេវ ខីណាសវានំ តត្ថ តត្ថ បញ្ចិន្ទ្រិយានិ** ឥន្ទ្រិយ ៥ ក្នុងធម៌នោះ ៗ ដែលព្រះខីណាស្រពទាំងពួង រលាស់ចេញហើយ គឺ ឥន្ទ្រិយ ៥ ក្នុងឋានៈនោះ ៗ ក្នុងបណ្ដាឋានៈទាំងឡាយ ដែលពោលទុកហើយក្នុងកាលមុន មានជាអាទិ៍ថា **អធិមោក្ខដ្ឋេន** ដែលព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវ័កទាំងឡាយ ដែលជាព្រះខីណាស្រពរលាស់ចេញហើយចាកឋានៈនោះ ៗ តាមដែលប្រកបទុក ។ ក្នុងវារៈនេះ លោកពោលដល់ន័យដែលបានពោលហើយក្នុងគ្រាដំបូង ដោយអំណាចនៃព្រះខីណាស្រព តាមដែលប្រកបទុក ។

ក៏និស្សរណៈទាំងនេះ មាន ១៨០ តើដូចម្តេច ។ លោកអធិប្បាយទុកដូច្នេះ ក្នុងបឋមវារៈ មាននិស្សរណៈទាំងអស់ ៩៦ គឺ លោកពោលទុកដោយអំណាចនៃមគ្គ និងផល ២៥ ដោយការឈានកន្លង ៣៤ ដោយអំណាចជាបដិបក្ខ ៣៧ ។ ក្នុងទុតិយវារៈ កាលនាំនិស្សរណៈចេញ ១២ ដោយអំណាចនៃព្រះខីណាស្រពទាំងឡាយ និស្សរណៈទាំងនេះ ក៏ជា ៨៤ ដោយប្រការដូច្នេះ និស្សរណៈមុន ៩៦ និងនិស្សរណៈទាំងនេះ ៨៤ ទើបរួមជា និស្សរណៈ ១៨០ ។

ក៏និស្សរណៈ ១២ ដែលព្រះខីណាស្រពគប្បីនាំចេញ តើដូច

ម្តេច ។ និស្សរណៈ ដែលព្រះខីណាស្រពគប្បីនាំចេញ ១២ ទាំងនេះ គឺ បណ្តានិស្សរណៈដែលពោលហើយ ដោយការឈានកន្លងនិស្សរណៈ ៨ លោកពោលទុកដោយអំណាចនៃមគ្គ និងផល បណ្តានិស្សរណៈដែលពោលហើយដោយអំណាចបដិបក្ខ និស្សរណៈ ៤ លោកពោលដោយអំណាចនៃមគ្គ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី ព្រះខីណាស្រពគប្បីនាំនិស្សរណៈដែលពោលហើយ ដោយអំណាចនៃអរហត្តផលចេញ ។ ឆ្លើយថា ព្រោះបាននិស្សរណៈ ២៥ ដែលពោលទុកមុនទាំងអស់ ដោយអំណាចនៃអរហត្តផល ទើបពោលនិស្សរណៈ ដោយអំណាចនៃអរហត្តផលនោះឯង ។ ផលសមាបត្តិខាងលើ ៗ នៅមិនទាន់ចូលដល់ផលសមាបត្តិខាងក្រោម ៗ ព្រោះដូច្នោះ ទើបមិនបានផល សូម្បី ៣ ក្នុងខាងក្រោម ។ ម្យ៉ាងទៀត ឈាន សមាបត្តិ វិបស្សនា និងនេក្ខម្មៈជាដើម រមែងបានដោយអំណាចនៃកិរិយា ។ ឥន្ទ្រិយ ៥ ទាំងនេះ រលាស់ចេញចាកធម៌ដែលជាបដិបក្ខ ព្រោះធម៌ដែលជាបដិបក្ខទាំងឡាយស្ងប់មុនហើយ ដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថា និស្សរណនិទ្ទេស )

ចប់ អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស



## អដ្ឋកថា តតិយសុត្តន្តនិទ្ទេស

ព្រះសារីបុត្តត្ថេរបំណងនឹងតាំងព្រះសូត្រដទៃទៀត ហើយបង្ហាញដល់ប្រភេទនៃឥន្ទ្រិយ ទើបពោលពាក្យមានជាអាទិ៍ **បញ្ចិមានិ ភិក្ខវេ** ដូច្នេះ ។

អរិយមគ្គមានអង្គ ៨ ឈ្មោះថា **សោត** ក្នុងបទនេះថា **សោតាបត្តិយង្គេសុ** ការដល់នូវការសម្រេចយ៉ាងសម្បូណ៌ ឈ្មោះថា **សោតាបត្តិ** ( ការដល់ក្រសែនៃធម៌គ្រាដំបូង ) ។ អង្គ គឺ សម្ភារៈនៃ **សោតាបត្តិ** ឈ្មោះថា **សោតាបត្តិយង្គានិ** ( អង្គនៃការដល់ក្រសែនៃធម៌គ្រាដំបូង ) ។ សោតាបត្តិយង្គៈ ៤ យ៉ាង ទាំងនេះ គឺ ការសេពគប់សប្បុរសជាសោតាបត្តិយង្គៈ ១ ការស្តាប់សទ្ធម្មជាសោតាបត្តិយង្គៈ ១ យោនិសោមនការជាសោតាបត្តិយង្គៈ ១ ការបដិបត្តិធម៌សមគួរដល់ធម៌ជាសោតាបត្តិយង្គៈ ១ ជាអង្គនៃការបានចំណែកខាងដើម ព្រោះភាវៈជា **សោតាបន្ន** ។ អាការដ៏សេស បានពោលទុកហើយក្នុងខាងក្រោយ ។

ម្យ៉ាងទៀត បទនេះលោកពោលដើម្បីឲ្យឃើញថា ឥន្ទ្រិយទាំងនេះជាធំក្នុងវិស័យរបស់ខ្លួន ។ ប្រៀបដូចសេដ្ឋីបុត្ត ៤ នាក់

កាលសម្លាញ់មានព្រះរាជាអ្នកកាពធំជាទី ៥ ដើរទៅតាមផ្លូវ ដោយគិតថា នឹងលេងនក្ខត្តឫក្ស គ្រាទៅដល់ផ្ទះរបស់សេដ្ឋីបុត្តទី ១ , ៤ នាក់ទៀតក្រៅពីនោះ អង្គុយស្ងៀម ។ អ្នកជាម្ចាស់ផ្ទះប៉ុណ្ណោះ បង្គាប់ថា ពួកអ្នកចូរឲ្យខាទនីយៈ ភោជនីយៈដល់សម្លាញ់ទាំងនេះ ពួកអ្នកចូរឲ្យរបស់ក្រអូប ផ្កាឈើ និងគ្រឿងប្រដាប់ជាដើម ដល់សម្លាញ់ទាំងនេះ ហើយដើរត្រួតពិនិត្យក្នុងផ្ទះ កាលទៅដល់ផ្ទះមនុស្សទី ២ , ៣ , ៤ មនុស្ស ៤ នាក់ទៀតក្រៅពីនោះ អង្គុយស្ងៀម ។ អ្នកជាម្ចាស់នៃផ្ទះប៉ុណ្ណោះបង្គាប់ថា ពួកអ្នកចូរឲ្យខាទនីយៈ ភោជនីយៈដល់សម្លាញ់ទាំងនេះ ពួកអ្នកចូរឲ្យរបស់ក្រអូប ផ្កាឈើ និងគ្រឿងប្រដាប់ជាដើមដល់សម្លាញ់ ហើយដើរត្រួតពិនិត្យក្នុងផ្ទះ ។ កាលទៅដល់ព្រះរាជដំណាក់របស់ព្រះរាជា ជាខាងក្រោយ ព្រះរាជាជាធំក្នុងទីទាំងពួង ក្នុងកាលនេះ ក៏ទ្រង់ត្រាស់បញ្ជាថា ពួកអ្នកចូរឲ្យខាទនីយៈ ភោជនីយៈដល់សម្លាញ់ទាំងនេះ ចូរឲ្យរបស់ក្រអូប មានផ្កាឈើ និងគ្រឿងប្រដាប់ដល់សម្លាញ់ទាំងនេះ ហើយទ្រង់យាងត្រួតពិនិត្យព្រះរាជដំណាក់របស់ព្រះអង្គយ៉ាងណា កាលឥន្ទ្រិយទាំង ៥ មានសទ្ធាជាដើមក៏ដូច្នោះដូចគ្នា សូម្បីកើតក្នុងអារម្មណ៍ដូចគ្នា ក៏ដូចជាសម្លាញ់ទាំងនោះដើរទៅតាមផ្លូវរួមគ្នា ។ លុះដល់ផ្ទះបុគ្គលទី ១ បុគ្គល ៤ នាក់



ទៀតអង្គុយស្ងៀម ម្ចាស់ផ្ទះប៉ុណ្ណោះ ដើរត្រួតពិនិត្យ យ៉ាងណា សទ្ធិន្ទ្រិយ មានលក្ខណៈបង្អោនចិត្តជឿ ព្រោះសម្រេចភាពសោតាបត្តិយង្គៈ ជាធំ ជាប្រធាន ដូច្នោះ ។ ឥន្ទ្រិយដ៏សេស ក៏បណ្តោយតាមសទ្ធិន្ទ្រិយទៅ ។

កាលដល់ផ្ទះបុគ្គលទី ២ បុគ្គល ៤ នាក់ ទៀតអង្គុយស្ងៀម ។ ម្ចាស់របស់ផ្ទះប៉ុណ្ណោះដើរត្រួតត្រា យ៉ាងណា វីរិយិន្ទ្រិយប៉ុណ្ណោះ មានលក្ខណៈផ្គងទុក ព្រោះសម្រេចភាពជាសម្មប្បធាន ជាធំ ជាប្រធាន ដូច្នោះ ។ ឥន្ទ្រិយដ៏សេសតាម វីរិយិន្ទ្រិយទៅ ។

កាលដល់ផ្ទះបុគ្គលទី ៣ បុគ្គល ៤ នាក់ ទៀតអង្គុយស្ងៀម ។ ម្ចាស់របស់ផ្ទះប៉ុណ្ណោះដើរត្រួតត្រា យ៉ាងណា សតិន្ទ្រិយប៉ុណ្ណោះ មានលក្ខណៈតាំងមាំ ព្រោះសម្រេចភាពជាសតិប្បដ្ឋាន ជាធំ ជាប្រធាន ដូច្នោះ ។ ឥន្ទ្រិយដ៏សេសតាមសតិន្ទ្រិយទៅ ។

កាលដល់ផ្ទះបុគ្គលទី ៤ បុគ្គល ៤ នាក់ទៀតអង្គុយស្ងៀម ។ ម្ចាស់របស់ផ្ទះប៉ុណ្ណោះដើរត្រួតត្រា យ៉ាងណា សមាធិន្ទ្រិយប៉ុណ្ណោះ មានលក្ខណៈមិនរាយមាយ ព្រោះសម្រេចភាពជាឈាន ជាធំ ជាប្រធាន ដូច្នោះ ។ ឥន្ទ្រិយដ៏សេសតាមសមាធិន្ទ្រិយទៅ ។

ប៉ុន្តែកាលទៅដល់ព្រះរាជដំណាក់របស់ព្រះរាជា បុគ្គល ៤ នាក់

ទៀតអង្គុយស្ងៀម ។ ព្រះរាជាប៉ុណ្ណោះ ទ្រង់យាងត្រួតត្រា យ៉ាងណា បញ្ញិន្ទ្រិយប៉ុណ្ណោះមានលក្ខណៈដឹងទូទៅ ព្រោះសម្រេចអរិយសច្ចៈ ជាធំ ជាប្រធាន ដូច្នោះ ។ ឥន្ទ្រិយដ៏សេសតាមបញ្ញិន្ទ្រិយទៅ ដោយប្រការ ដូច្នោះ ។

(ចប់ អដ្ឋកថាតតិយសុត្តន្តនិទ្ទេស)

## អដ្ឋកថា បភេទគណននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងបភេទគណននិទ្ទេស ដែលជាខាងដើមនៃពាក្យសួរចំនួនប្រភេទនៃព្រះសូត្រ ។ បទថា **សប្បុរិសសំសេវេ** គឺ ការសេពគប់សប្បុរស បានដល់ ក្នុងការសេពគប់មនុស្សល្អដោយប្រពៃ ។ បទថា **អធិមោក្ខាធិបតេយ្យដ្ឋេន** ដោយអត្ថថា ជាធំ ក្នុងបង្អោនការចិត្តជឿ គឺ ដោយអត្ថថា ភាពជាធំក្នុងឥន្ទ្រិយដ៏សេសពោលគឺ បង្អោនចិត្តជឿ អធិប្បាយថា ដោយអត្ថ គឺ ជាប្រធាននៃឥន្ទ្រិយដ៏សេស ។ បទថា **សទ្ធម្មស្សវនេ** គឺ ការស្តាប់ព្រះសទ្ធម្ម បានដល់ ធម៌របស់ សប្បុរស ឬឈ្មោះថា **សទ្ធម្ម** ព្រោះជាធម៌ស្អាតក្នុងការស្តាប់ ព្រះសទ្ធម្មនោះ ។ បទថា **យោនិសោមនសិការេ** គឺ ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។ ក្នុងបទថា **ធម្មានុធម្មប្ប-**



**បដិបត្តិយា** ការបដិបត្តិនូវធម៌សមគួរដល់ធម៌នេះ គប្បីជ្រាបសេចក្តីដូច្នេះ ធម៌ដែលជាលោកុត្តរធម៌ ៩ ឈ្មោះថា **ធម្មានុធម្ម** ។ ការបដិបត្តិការដល់ធម្មានុធម្មៈ ដែលបានដល់ សីល សមាធិ បញ្ញា ឈ្មោះថា **ធម្មានុធម្មប្បដិបត្តិ** ។ សូម្បីក្នុង **សម្មប្បធាន** ជាដើម ក៏មានន័យនេះដូចគ្នា ។

(ចប់ អដ្ឋកថា បភេទគណននិទ្ទេស)

## អដ្ឋកថា ចរិយាវារ

សូម្បីក្នុងចរិយាវារ ក៏គប្បីជ្រាបសេចក្តីដោយន័យនេះដូចគ្នា ។ លោកពោលបឋមវារៈ ដោយអំណាចនៃការឲ្យឥន្ទ្រិយកើតឡើង តែម្យ៉ាង ។ លោកពោលចរិយាវារៈ ដោយអំណាចនៃការសេព និងកាលនៃការធ្វើឲ្យបរិបូរណ៍នូវឥន្ទ្រិយទាំងឡាយ ដែលកើតឡើងហើយ ។ ពិតណាស់ ពាក្យថា **ចរិយា បកតិ ឧស្សន្នតា** ចរិយាប្រក្រតី ការចម្រើនឡើង ដោយភាពតែមួយដូចគ្នា ។

(ចប់ អដ្ឋកថា ចរិយាវារៈ)

# អដ្ឋកថា ចារវិហារនិទ្ទេស

ឥឡូវនេះ ព្រះសារីបុត្តត្ថេរប្រាថ្នានឹងសម្ដែងប្រភេទនៃឥន្ទ្រិយ ដោយបរិយាយដទៃទៀត ដោយការសម្ដែងការប្រព្រឹត្ត និងវិហារធម៌ ដែលសម្ព័ន្ធនឹងចរិយា ទើបលើកមាតិកាថា **ចារោ ច វិហារោ ច** ជាដើមហើយ ទើបពោលសម្ដែងមាតិកាវនោះ ។ ក្នុងមាតិកានោះ គប្បីជ្រាបការសម្ព័ន្ធរបស់មាតិកាថា ដូចជា សព្រហ្មចារីអ្នកដឹងច្បាស់ គប្បីកំណត់ទុកក្នុងឋានៈដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តតាមទីអាស្រ័យថា លោកអង្គនេះសម្រេចហើយ ឬថានឹងសម្រេចដោយពិត យ៉ាងណា ការប្រព្រឹត្ត និងវិហារធម៌របស់អ្នកដល់ព្រមដោយឥន្ទ្រិយ ក៏ដូច្នោះ ដែលសព្រហ្មចារីអ្នកដឹងច្បាស់ ត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧទ្ទេសនិទ្ទេស ដូចតទៅនេះ ។ ការប្រព្រឹត្តនោះឯង គឺ **ចរិយា** ។ ព្រោះពាក្យថា **ចារោ ចរិយា** ដោយអត្ថតែមួយដូចគ្នា ។ ព្រោះដូច្នោះក្នុងនិទ្ទេសនៃបទថា **ចារោ** លោកទើបពោលថា **ចរិយា** ។ បទថា **ឥរិយាបថចរិយា** គឺ ការប្រព្រឹត្តរបស់ឥរិយាបថ បានដល់ ការប្រព្រឹត្តទៅ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ចំណែក **អាយតនចរិយា** ការប្រព្រឹត្តក្នុងអាយតនៈ



គឺ ការប្រព្រឹត្តទៅនៃសតិសម្បជញ្ញៈក្នុងអាយតនៈទាំងឡាយ ។ បទថា **បត្តិ** គឺ ផល ។ លោកពោលថា **បត្តិ** ព្រោះដល់ផលទាំងនោះ ជាប្រយោជន៍ក្នុងបច្ចុប្បន្ន និងកពខាងមុខរបស់សត្វលោក នេះជាសេចក្ដីពិសេសរបស់បទថា **លោកត្ថ** ជាប្រយោជន៍ដល់លោក ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងភូមិរបស់ចរិយាទាំងនោះ ទើបលោកពោលពាក្យមានជាអាទិ៍ថា **ចតូសុ ឥរិយាប-ថេសុ** ក្នុងឥរិយាទាំងឡាយ ៤ ។ បទថា **សតិប្បដ្ឋានេសុ** គឺ អារម្មណ៍ដែលជាសតិប្បដ្ឋាន ។ សូម្បីការពោលដល់សតិប្បដ្ឋាន លោកក៏ពោលធ្វើមិនឲ្យជាយ៉ាងដទៃពីសតិ គឺ ដទៃដោយអំណាចនៃវោហារ ។

បទថា **អរិយសច្ចេសុ** ក្នុងអរិយសច្ចៈទាំងឡាយ លោកពោលដោយអំណាចការកំណត់ គឺ យកសច្ចៈទុកផ្សេងពីលោកិយសច្ចញាណដែលជាចំណែកខាងដើម ។ បទថា **អរិយមគ្គេសុ សាមញ្ញផលេសុ ច** ក្នុងអរិយមគ្គ និងសាមញ្ញផល លោកពោលដោយអំណាចនៃវោហារប៉ុណ្ណោះ ។ បទថា **បទេសេ** ចំណែកខ្លះ គឺ ជាឯកទេសក្នុងការប្រព្រឹត្តកិច្ចដែលជាប្រយោជន៍ដល់លោក ។ ពិតណាស់ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងទ្រង់ធ្វើលោកត្ថចរិយា ដោយមិនមានចំណែកខ្លះ ។

ព្រះសារីបុត្តត្ថេរកាលនឹងសម្ដែងចរិយាទាំងនោះទៀត ដោយអំណាចនៃការកបុគ្គល ទើបពោលពាក្យមានជាអាទិ៍ថា **បណិធិសម្បន្នានំ** របស់លោកអ្នក ដល់ព្រមដោយការតាំងចិត្តទុក ក្នុងបទនោះ លោកអ្នកមានឥរិយាបថមិនកម្រើក ដល់ព្រមដោយការឃុំគ្រងឥរិយាបថព្រោះឥរិយាបថស្ងប់ គឺ ដល់លព្រមដោយឥរិយាបថដែលស្ងប់ សមគួរដល់ភាវៈជាភិក្ខុ ឈ្មោះថា **បណិធិសម្បន្នា** អ្នកដល់ព្រមដោយការតាំងចិត្តទុក ។ បទថា **ឥន្ទ្រិយេសុ គុត្តទ្វារានំ** អ្នកមានទ្វារឃុំគ្រងឥន្ទ្រិយ គឺ ឈ្មោះថា **គុត្តទ្វារា** ព្រោះមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ដែលប្រព្រឹត្តទៅហើយក្នុងវិស័យដោយអំណាចនៃទ្វារនីមួយ ៗ របស់អ្នកមានទ្វារគ្រប់គ្រងហើយទាំងនោះ ។ ក៏ក្នុងបទថា **ទ្វារំ** នេះ គឺ ចក្ខុទ្វារ ជាដើម ដោយអំណាចនៃទ្វារដែលកើតឡើង ។ បទថា **អប្បមាទវិហារីនំ** របស់លោកអ្នកនៅដោយការមិនប្រមាទ គឺ អ្នកនៅដោយការមិនប្រមាទក្នុងសីល ជាដើម ។ បទថា **អធិចិត្តមនុយុត្តានំ** របស់អ្នកខ្វល់ខ្វាយក្នុងអធិចិត្ត គឺ អ្នកខ្វល់ខ្វាយក្នុងសមាធិ ដែលបានដល់ អធិចិត្ត ដែលមានវិបស្សនាជាបាទ ។ បទថា **ពុទ្ធិសម្បន្នានំ** របស់អ្នកដល់ព្រមហើយដោយបញ្ញា គឺ អ្នកដល់ព្រមហើយដោយញាណ ដែលប្រព្រឹត្តទៅហើយតាំង



អំពីការកំណត់នាមរូប រហូតដល់គោត្រភូ ។ បទថា **សម្មាបដិបន្នានំ** របស់លោកអ្នកបដិបត្តិ ប្រពៃ គឺ ក្នុងខណៈនៃមគ្គ ៤ ។ បទថា **អធិគតប្ផលានំ** របស់អ្នកសម្រេចផល គឺ ក្នុងខណៈនៃផល ៤ ។ បទថា **អធិមុច្ចន្តោ** អ្នកបង្អោនចិត្តជឿ គឺ អ្នកធ្វើការបង្អោនចិត្តជឿ ។ បទថា **សទ្ធាយ ចរតិ** រមែងប្រព្រឹត្តដោយ សទ្ធា គឺ ប្រព្រឹត្តទៅដោយអំណាចនៃសទ្ធា ។ បទថា **បគ្គណ្ហន្តោ** អ្នកផ្គងទុក គឺ តាំងទុកដោយសេចក្ដីព្យាយាម គឺ សម្មប្បធាន ៤ ។ បទថា **ឧបដ្ឋាបេន្តោ** អ្នកចូលទៅតាំងទុកមាំ គឺ ចូលទៅតាំងអារម្មណ៍ទុកដោយសតិ ។ បទថា **អវិក្ខេបំ ករោន្តោ** អ្នកធ្វើចិត្តមិនឲ្យរាយមាយ គឺ មិនធ្វើសេចក្ដីរាយមាយដោយអំណាចនៃសមាធិ ។ បទថា **បជានន្តោ** អ្នកដឹងច្បាស់ គឺ ដឹងច្បាស់ដោយបញ្ញាជាគ្រឿងដឹងអរិយសច្ចៈ ៤ ។ បទថា **វិជានន្តោ** ដឹងច្បាស់ គឺ ដឹងច្បាស់អារម្មណ៍ដោយវិញ្ញាណ គឺការពិចារណា ដែលជាប្រធាននៃជវនចិត្ត សម្បយុត្តដោយឥន្ទ្រិយ ។ បទថា **វិញ្ញាណចរិយាយ** ដោយវិញ្ញាណចរិយា គឺ ដោយអំណាចនៃការប្រព្រឹត្តដោយវិញ្ញាណ គឺ ការពិចារណា ។ បទថា **ឯវំ បដិបន្នស្ស** របស់អ្នកបដិបត្តិយ៉ាងនេះ គឺ បដិបត្តិដោយឥន្ទ្រិយចរិយាព្រមដោយជវនចិត្ត ។ បទថា **កុសលា ធម្មា អាយាបេន្តិ** កុសលធម៌

ទាំងឡាយ រមែងញុំាងឥដ្ឋផលឲ្យយឺតយូរទៅ គឺ កុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅហើយ ដោយអំណាចនៃសមថៈ និងវិបស្សនា រមែងញុំាងការរុងរឿងឲ្យប្រព្រឹត្តទៅ សេចក្តីថា រមែងប្រព្រឹត្តទៅ ។ បទថា **អាយតនចរិយា** ដោយអាយតនចរិយា គឺ ប្រព្រឹត្តដោយសេចក្តីព្យាយាមដ៏កំពូលនៃកុសលធម៌ទាំងឡាយ ។ លោកពោលអធិប្បាយថា ប្រព្រឹត្តដោយសេចក្តីប្រឹងប្រែង ដោយការឲ្យប្រព្រឹត្តទៅ ។ បទថា **វិសេសមធិគច្ឆតិ** រមែងសម្រេចធម៌វិសេស គឺ សម្រេចធម៌វិសេស ដោយអំណាចនៃវិក្ខម្ភនៈ តទង្គៈ សមុច្ឆេទៈ និងបដិប្បស្សទ្ធិ ។ បទថា **ទស្សនចរិយា** ជាដើម មានសេចក្តីដូចពោលហើយនោះឯង ។

ក្នុងបទមានជាអាទិ៍ថា **សទ្ធាយ វិហរតិ** រមែងនៅដោយសទ្ធា មានវិនិច្ឆ័យដូចតទៅនេះ ។ គប្បីឃើញការនៅដោយឥរិយាបថរបស់អ្នកព្រមព្រៀងដោយសទ្ធាជាដើម ។ បទថា **អនុពុទ្ធោ** ដឹងតាម គឺ ដោយបញ្ញាពិចារណាសេចក្តីពិតហើយ ។ បទថា **បដិវិទ្ធោ** ចាក់ធ្លុះហើយ គឺ ដោយបញ្ញាដឹងប្រចក្សច្បាស់ ។ ព្រោះកាលអ្នកតាំងនៅក្នុងអធិមោក្ខៈជាដើម ដឹងតាមហើយ ចាក់ធ្លុះហើយ ការប្រព្រឹត្តនិងវិហារធម៌ ដែលត្រាស់ដឹងតាម ចាក់ធ្លុះហើយដូច្នោះ លោកទើបសំដែងដល់អ្នកតាំងនៅក្នុងអធិមោក្ខៈជាដើម សូម្បីក្នុងការដឹងតាម



និងចាក់ធ្លុះ ។ បទថា **ឯវំ** ក្នុងបទមានជាអាទិ៍ថា **ឯវំ សទ្ធាយ ចរន្តំ** ប្រព្រឹត្តដោយសទ្ធាយ៉ាងនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងដល់ប្រការដូចពោលហើយ ទើបសម្តែងដល់អត្ថនៃ **យថា** សព្ទ ។ សូម្បីក្នុងបទមានជាអាទិ៍ថា **វិញ្ញូ** គប្បីជ្រាបសេចក្តីដូច្នេះ ។ ឈ្មោះថា **វិញ្ញូ** ព្រោះដឹងតាមសភាវៈ ។ ឈ្មោះថា **វិភាវី** ព្រោះញុំាងសភាវៈដែលដឹងហើយឲ្យជាក់ច្បាស់ គឺ ធ្វើឲ្យប្រាកដ ។ ឈ្មោះថា **មេធា** ព្រោះទម្លាយកិលេស ដូចជារន្ទះទំលាយថ្មដែលគរទុក ឬឈ្មោះថា **មេធា** ព្រោះអត្ថថា រៀនទ្រទ្រង់ចាំទុកបានរហ័ស ។ ឈ្មោះថា **មេធាវី** ព្រោះជាអ្នកមានបញ្ញា ។ ឈ្មោះថា **បណ្ឌិតា** ព្រោះដល់ គឺ ប្រព្រឹត្តទៅដោយញាណគតិ ។ ឈ្មោះថា **ពុទ្ធិសម្បន្នា** ព្រោះជាអ្នកដល់ព្រមដោយ **ពុទ្ធិសម្បទា** ការដល់ព្រមដោយបញ្ញា ។ ឈ្មោះថា **សព្រហ្មចារិនោ** ព្រោះប្រព្រឹត្តបដិបទាដ៏ខ្ពង់ខ្ពស់ ដែលជាព្រហ្មចរិយា ។ ឈ្មោះថា មានកម្មតែមួយ ដោយអំណាចនៃការធ្វើកម្ម ៤ យ៉ាង មាន **អបលោកនកម្ម** ( ការយល់ព្រម ) ជាដើម រួមគ្នា ។ ឈ្មោះថា មានឧទ្ទេសតែមួយ គឺ មានការសូត្របាតិមោក្ខ ៥ យ៉ាងដូចគ្នា ។ ឈ្មោះថា **សមសិក្ខា** ព្រោះមានការសិក្សាស្មើគ្នា ។ ភាពជាអ្នកមានការសិក្សាស្មើគ្នា ឈ្មោះថា **សមសិក្ខតា** អាចារ្យពួកខ្លះ

ពោលថា **សមសិក្ខាតា** ខ្លះ ប្រែថា មានការសិក្សាស្មើគ្នា ។ លោកអធិប្បាយថា អ្នកមានកម្មតែមួយដូចគ្នា មានការសិក្សាស្មើគ្នា ឈ្មោះថា **សព្រហ្មចារី** ។ កាលគួរពោលថា **ឈានានិ** លោកធ្វើលិង្គវិបល្លាសជា **ឈានា** ។ បទថា **វិមោក្ខា** បានដល់ វិមោក្ខ ៣ ឬ ៨ ។ បទថា **សមាធិ** បានដល់ សមាធិ ៣ មានវិតក្កៈមានវិចារៈ មិនមានវិតក្កៈមានត្រឹមតែវិចារៈ មិនមានវិតក្កៈមិនមានវិចារៈ ។ បទថា **សមាបត្តិ-យោ** សមាបត្តិ គឺ មិនតាំងនៅក្នុង **សុញ្ញតានិមិត្ត** ( មិនមាននិមិត្តថាសូន្យ ) ។ បទថា **អភិញ្ញាយោ** គឺ អភិញ្ញា ៦ ។ ឈ្មោះថា **ឯកំសោ** ព្រោះជាចំណែកមួយ មិនមែនជាចំណែក ២ ។ ឈ្មោះថា **ឯកំសវចនំ** ព្រោះពោលដល់ប្រយោជន៍ចំណែកមួយ ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីធ្វើការប្រកបយ៉ាងនេះ ។ តែដោយពិសេស ឈ្មោះថា **សំសយោ** ព្រោះដេកត្រាំ គឺ ប្រព្រឹត្តទៅស្មើ ឬដោយជុំវិញ ។ ឈ្មោះថា **និស្សំសយោ** ព្រោះមិនមានការសង្ស័យ ។ ឈ្មោះថា **កង្ខា** ព្រោះភាពជាអ្នកកាត់ក្តីមិនបានក្នុងរឿងមួយប៉ុណ្ណោះ សូម្បីយ៉ាងដទៃក៏ស្ទាក់ស្ទើរ ។ ឈ្មោះថា **និក្កង្ខោ** ព្រោះមិនមានការស្ទាក់ស្ទើរ ។ ភាពមានចំណែក ២ ឈ្មោះថា **ទ្វេជ្ឈំ** , ការមិនមានចំណែក ២ ឈ្មោះថា **អទ្វេជ្ឈោ** ។ ឈ្មោះថា **ទ្វេឡ្ហកំ** ព្រោះកម្រើកញាប់ញ័រ



ដោយពីរចំណែក ។ ឈ្មោះថា **អទ្វេឡ្ហកោ** ព្រោះមិនមានការញាប់ញ័រជាពីរចំណែក ( និយាយមិនមានពីរ ) ការពោលដោយធម៌ជាគ្រឿងនាំចេញ ឈ្មោះថា **និយ្យានិកវចនំ** អាចារ្យពួកខ្លះពោលថា **និយ្យោគវចនំ** ខ្លះ ប្រែថា ពាក្យពោលក្នុងការនាំចេញ ពាក្យទាំងអស់នោះ ជាវេវចនៈរបស់វិចិកិច្ឆា ។ ឈ្មោះថា **បិយវចនំ** ព្រោះជាពាក្យពោលគួរជាទីស្រឡាញ់ ដោយមានប្រយោជន៍គួរជាទីស្រឡាញ់ ។ មួយយ៉ាងទៀត **គរុវចនំ** ពាក្យពោលដោយការគោរព ឈ្មោះថា **សគារវំ** ព្រោះមានការគោរព ព្រមដោយគារវៈការកោតក្រែង ឈ្មោះថា **បតិស្សយោ** សេចក្តីថា មិនដេក មិនអង្គុយ ព្រោះធ្វើការគោរពអ្នកដទៃ មួយយ៉ាងវិញទៀត ការទទួលពាក្យ ឈ្មោះថា **បតិស្សវោ** សេចក្តីថា ស្តាប់ពាក្យអ្នកដទៃ ព្រោះប្រព្រឹត្តបន្ទាបខ្លួន ។ សូម្បីក្នុង ២ បទនេះ ជាឈ្មោះនៃភាពជាធំរបស់អ្នកដទៃ ឈ្មោះថា **សគារវំ** ព្រោះប្រព្រឹត្តទៅជាមួយដោយការគោរព ឈ្មោះថា **សប្បតិស្សយំ** ព្រោះប្រព្រឹត្តទៅជាមួយនឹងការកោតក្រែង ឬការទទួលពាក្យ ។ ក៏កាលបើនឹងពោលថា **សប្បតិស្សវំ** លោកពោលថា **សប្បតិស្សំ** ព្រោះលុប **យ** អក្សរ ឬ **វ** អក្សរ ។ ពាក្យដែលមានសណ្តាប់ធ្នាប់ល្អយ៉ាងក្រៃលែង ឈ្មោះថា **អធិវចនំ** ។ ឈ្មោះថា **សគារវសប្បតិស្សំ**

ព្រោះមានការគោរព និងការកោតក្រែង ។ ពាក្យពោល មានការគោរពកោតក្រែង ឈ្មោះថា **សគារវសប្បតិស្សាធិវចនំ** សូម្បីក្នុងបទទាំងពីរនេះ លោកពោលថា **ឯតំ** រឿយ ៗ ដោយអំណាចសេចក្តីផ្សេងគ្នានៃការកំណត់វេវចនៈ ។ បទថា **បត្តោ វា បាបុណិស្សតិ វា** សម្រេចហើយ ឬនឹងសម្រេច បានដល់ ឈានជាដើម នោះឯង ។

(ចប់ អដ្ឋកថាចារ វិហារនិទ្ទេស)

ចប់ អដ្ឋកថា តតិយសុត្តន្តនិទ្ទេស



# អដ្ឋកថា ចតុត្ថសុត្តន្តនិទ្ទេស

ព្រះសារីបុត្តត្ថេរ តាំងសូត្រទី ១ ទៀត ហើយសម្តែងឥន្ទ្រិយទាំងឡាយដោយអាការយ៉ាងដទៃទៀត ។ ក្នុងបទទាំងនោះ បទថា **កតីហាការេហិ កេនដ្ឋេន ទដ្ឋព្វានិ** ឥន្ទ្រិយ ៥ ទាំងនេះ គប្បីឃើញដោយអាការប៉ុន្មាន ដោយអត្ថថាដូចម្តេច គឺ គប្បីឃើញដោយអាការប៉ុន្មាន ។ បទថា **កេនដ្ឋេន ទដ្ឋព្វានិ** គប្បីឃើញដោយអត្ថថា ដូចម្តេច ព្រះសារីបុត្តត្ថេរ សួរដល់អាការដែលគប្បីឃើញ និងអត្ថដែលគប្បីឃើញ ។ បទថា **ឆហាការេហិ កេនដ្ឋេន ទដ្ឋព្វានិ** គឺ គប្បីឃើញដោយអាការ ៦ គប្បីឃើញ ដោយអត្ថពោលគឺអាការ ៦ នោះឯង ។ បទថា **អាធិបតេយ្យដ្ឋេន** គឺ ដោយអត្ថថា ភាពជាធំ ។ បទថា **អាទិវិសោធនដ្ឋេន** ជាគ្រឿង ជម្រះក្នុងខាងដើម គឺ ដោយអត្ថថា ជាគ្រឿងជម្រះសីល ដែលជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ បទថា **អធិមត្តដ្ឋេន** ដោយអត្ថថា មានប្រមាណក្រៃលែង លោកពោលថា **អធិមត្តំ** ព្រោះមានកម្លាំងមានប្រមាណក្រៃលែង ។ បទថា **អធិដ្ឋានដ្ឋេន** គឺ ដោយអត្ថថា តាំងមាំ ។ បទថា **បរិយាទានដ្ឋេន** ដោយអត្ថថា គ្របសង្កត់ គឺ ដោយអត្ថថា អស់ទៅ ។ បទថា

**បតិដ្ឋាបកដ្ឋេន** គឺ ដោយអត្ថថា ឲ្យតាំងនៅ ។

## អដ្ឋកថា អធិបតេយ្យដ្ឋនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **អាធិបតេយ្យដ្ឋនិទ្ទេស** ដូចតទៅនេះ ។ បទមានជាអាទិ៍ថា **អស្សទ្ធិយំ បជហតោ** នៃបុគ្គលអ្នកលះភាពជាអ្នកមិនមានសទ្ធា ជាពាក្យពោលដល់ ការលះធម៌ជាបដិបក្ខនៃឥន្ទ្រិយមួយ ៗ លោកពោលដើម្បីសេចក្តីសម្រេចនៃភាពជាធំក្នុងការសម្រេចកិច្ចនៃការលះធម៌ជាបដិបក្ខរបស់ខ្លួន ៗ សូម្បីក្នុងខណៈមួយ ។

លោកពោលដល់ឥន្ទ្រិយ ៤ ដ៏សេស សម្បយុត្តដោយសទ្ធិន្ទ្រិយនោះ ។ គប្បីជ្រាបសូម្បីលោកពោលធ្វើឥន្ទ្រិយមួយ ៗ ឲ្យជានាទីក្នុងខណៈផ្សេង ៗ គ្នា ហើយធ្វើឥន្ទ្រិយនោះ ៗ ឲ្យជាធំជាងឥន្ទ្រិយដែលជាបដិបក្ខនោះ ៗ ហើយនាំឥន្ទ្រិយនោះទៅ ។ ចំណែកបទថា **កាមច្ឆន្ទំ បជហតោ** នៃបុគ្គលអ្នកលះកាមច្ឆន្ទៈជាដើម លោកពោលដោយអំណាចនៃខណៈជាមួយគ្នានោះឯង ។

(ចប់ អដ្ឋកថាអធិបតេយ្យដ្ឋនិទ្ទេស)



## អដ្ឋកថា អាទិវិសោធនដ្ឋនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **អាទិវិសោធនដ្ឋនិទ្ទេស** ដូចតទៅនេះ ។ បទថា **អស្សទ្ធិយសំវរដ្ឋេន សីលវិសុទ្ធិ** ជាសីលវិសុទ្ធិ ព្រោះអត្ថថា សង្រួមនូវភាពជាអ្នកមិនមានសទ្ធា គឺឈ្មោះថា សីលវិសុទ្ធិ ព្រោះអត្ថថា ហាមនូវភាពជាអ្នកមិនមានសទ្ធា ដោយការជម្រះមន្ទិលរបស់សីល ដោយអត្ថថា **វៀរ** ។

បទថា **សទ្ធិន្ទ្រិយស្ស អាទិវិសោធនា** ជាគ្រឿងជម្រះក្នុងខាងដើមនៃសទ្ធិន្ទ្រិយ គឺ ជម្រះសីលដែលជាខាងដើម ដោយអំណាចជាឧបនិស្ស័យនៃសទ្ធិន្ទ្រិយ ។ ដោយន័យនេះឯង គប្បីជ្រាបឥន្ទ្រិយសូម្បីដ៏សេស និងឥន្ទ្រិយដែលជាហេតុនៃការសង្រួមកាមច្ឆន្ទៈជាដើម ។

(ចប់ អដ្ឋកថាអាទិវិសោធនដ្ឋនិទ្ទេស)

## អដ្ឋកថា អធិមត្តដ្ឋនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **អធិមត្តដ្ឋនិទ្ទេស** ដូចតទៅនេះ ។ បទថា **សទ្ធិន្ទ្រិយស្ស ភាវនាយ ឆន្ទោ ឧប្បជ្ជតិ** ឆន្ទៈកើតឡើង

ដើម្បីការចម្រើននៃសទ្ធិន្ទ្រិយ គឺ ឆន្ទៈក្នុងធម៌ដែលឆ្លាត រមែងកើតឡើងក្នុងសទ្ធិន្ទ្រិយ ព្រោះស្តាប់ធម៌បដិសម្បយុត្តដោយសទ្ធារបស់បុគ្គលអ្នកមានសទ្ធា ឬព្រោះឃើញគុណនៃការចម្រើនសទ្ធិន្ទ្រិយ ។ បទថា **បាមោជ្ជំ ឧប្បជ្ជតិ** ការរីករាយរមែងកើតឡើង គឺ សេចក្តីរីករាយរមែងកើត ព្រោះឆន្ទៈកើត ។ បទថា **បីតិ ឧប្បជ្ជតិ** បីតិ រមែងកើតឡើង គឺ បីតិមានកម្លាំងរមែងកើត ព្រោះការរីករាយ ។ បទថា **បស្សទ្ធិ ឧប្បជ្ជតិ** បស្សទ្ធិរមែងកើត គឺ កាយបស្សទ្ធិ និងចិត្ត-បស្សទ្ធិរមែងកើត ព្រោះការឆ្អែតនៃបីតិ ។ បទថា **សុខំ ឧប្បជ្ជតិ** សុខរមែងកើតឡើង គឺ ចេតសិកសុខ រមែងកើតឡើង ព្រោះកាយនិងចិត្តស្ងប់ ។ បទថា **ឱភាសោ ឧប្បជ្ជតិ** ពន្លឺរមែងកើតឡើង គឺ ពន្លឺ គឺ ញាណរមែងកើតឡើង ព្រោះលេចចេញនូវសេចក្តីសុខ ។ បទថា **សំវេគោ ឧប្បជ្ជតិ** សេចក្តីសង្វេគរមែងកើតឡើង គឺ សេចក្តីសង្វេគ ព្រោះសេចក្តីប្រែប្រួលនៃសង្ខារ រមែងកើតឡើង ព្រោះដឹងច្បាស់ទោសនៃសង្ខារ ដោយពន្លឺ គឺ ញាណ ។ បទថា **សំវេជេត្វា ចិត្តំ សមាទិយតិ** ចិត្តសង្វេគហើយ រមែងតាំងមាំ គឺ ចិត្តញុំាងសេចក្តីសង្វេគឲ្យកើតហើយ រមែងតាំងមាំដោយសេចក្តីសង្វេគនោះឯង ។ បទថា **សាធុកំ បគ្គណ្ហាតិ** រមែងផ្គងទុកល្អ គឺ នាំចេញការតក់ស្លុត



និងការរាយមាយចេញបាន ហើយរមែងផ្គង ទុកដោយល្អ ។ បទថា **សាធុកំ អជ្ឈុបេក្ខតិ** រមែងព្រងើយដោយល្អ គឺ ព្រោះសេចក្តីព្យាយាមប្រព្រឹត្តទៅយ៉ាងស្មើ មិនធ្វើសេចក្តីខ្វល់ខ្វាយក្នុងការប្រកបសេចក្តីព្យាយាម ដែលស្មើជានិច្ចទៀត ឈ្មោះថា រមែងព្រងើយដោយល្អ ដោយអំណាចការព្រងើយដោយដាក់ខ្លួនជាកណ្តាល ក្នុងការព្យាយាមនោះ ។ បទថា **ឧបេក្ខាវសេន** ដោយអំណាចនៃឧបេក្ខា គឺ ដោយអំណាចនៃការព្រងើយ ដោយការដាក់ខ្លួនជាកណ្តាលក្នុងការព្យាយាមនោះ ព្រោះមានលក្ខណៈនាំទៅស្មើ ។ បទថា **នានត្តកិលេសេហិ** ចាកកិលេសផ្សេង ៗ គឺ ចាកកិលេសដែលមានសភាពផ្សេងគ្នា ជាបដិបក្ខនៃវិបស្សនា ។ បទថា **វិមោក្ខវសេន** ដោយអំណាចនៃវិមោក្ខ គឺ ដោយអំណាចនៃការរួចផុតចាកកិលេសផ្សេង ៗ តាំងពីភង្គានុបស្សនា ( ការពិចារណាឃើញការរលត់នៃសង្ខារ ) ។ បទថា **វិមុត្តត្តា** ព្រោះការដែលចិត្តជាធម្មជាតិរួចផុត គឺ រួចផុតចាកកិលេសផ្សេងៗ ។ បទថា **តេ ធម្មា** បានដល់ ធម៌ទាំងឡាយមានឆន្ទៈជាដើម ។ បទថា **ឯករសា ហោន្តិ** មានរសតែមួយដូចគ្នា គឺ មានរសតែមួយដូចគ្នា ដោយអំណាចនៃវិមុត្តិ ។ បទថា **ភាវនាវសេន** ដោយអំណាចនៃភាវនា គឺ ដោយអំណាចនៃភាវនាមានរសតែមួយដូចគ្នា ។ បទថា

**តតោ បណីតតរេ វិវដ្ដន្តិ** ធម៌ទាំងនោះ រមែងចេញចាកធម៌នោះ ទៅកាន់ធម៌ដែលប្រណីតជាង គឺ ធម៌ទាំងឡាយ មានឆន្ទៈជាដើម រមែងចេញចាកអារម្មណ៍ គឺ វិបស្សនានោះ ជាហេតុទៅកាន់អារម្មណ៍ គឺ និព្វានដែលប្រណីតជាងដោយគោត្រភូញាណ ពោលគឺ **វិវដ្ដនា-នុបស្សនា** ( ការពិចារណាឃើញការគេចចេញទៅ ) សេចក្ដីថា ធម៌ទាំងឡាយចេញចាកអារម្មណ៍ គឺ សង្ខារ ហើយប្រព្រឹត្តទៅក្នុងអារម្មណ៍ គឺ និព្វាន ។ បទថា **វិវដ្ដនាវសេន** ដោយអំណាចនៃការគេចចេញ គឺ ដោយអំណាចនៃការចេញចាកសង្ខារក្នុងខណៈគោត្រភូ ដោយអារម្មណ៍ គឺ សង្ខារ ។ បទថា **វិវដ្ដិតត្តា តតោ វោស្សជ្ជតិ** ចិត្តរមែងលះបង់ធម៌នោះ ព្រោះជាចិត្តគេចចេញហើយ គឺ បុគ្គលអ្នកព្រមព្រៀងដោយមគ្គ រមែងលះបង់ចោលកិលេស និងខន្ធ ដោយហេតុនោះឯង ព្រោះចិត្តគេចទៅហើយ ដោយអំណាចនៃការប្រាកដទាំងពីរចំណែក ក្នុងខណៈមគ្គកើតនោះឯង ។ បទថា **វោស្សជ្ជិតត្តា តតោ និរុជ្ឈន្តិ** ធម៌ទាំងឡាយរមែងរលត់ទៅពីនោះ ព្រោះចិត្តជាធម្មជាតិលះបង់ចោលហើយ គឺ កិលេស និងខន្ធរមែងរលត់ទៅ ដោយអំណាចនៃការរលត់ គឺ ការមិនកើត ដោយហេតុនោះ ព្រោះចិត្តជាធម្មជាតិលះបង់ចោលកិលេស និងខន្ធ ក្នុងខណៈមគ្គកើតឡើងនោះឯង ។ ម្យ៉ាងទៀត បទ



ថា **វោស្សជ្ជិតត្តា** លោកធ្វើឲ្យជាពាក្យពោលតាម ហេតុផលដែលពិតក្នុងសេចក្ដីប្រាថ្នា ។ កាលមានការរំលត់កិលេស លោកក៏ពោលដល់ការរំលត់ខន្ធ ព្រោះការប្រាកដនៃការរំលត់ខន្ធ ។ បទថា **និរោធវសេន** ដោយអំណាចនៃការរំលត់ គឺ ដោយអំណាចការរំលត់ តាមដែលពោលហើយ ។ ព្រះសារីបុត្តត្ថេរប្រាថ្នានឹងសម្ដែងដល់ការលះបង់ ២ ប្រការ ក្នុងខណៈដែលមគ្គនោះកើតឡើង ទើបពោលបទមានជាអាទិ៍ថា **និរោធវសេន ទ្វេ វោស្សគ្គា** ការលះបង់ដោយអំណាចនៃការរំលត់មាន ២ ប្រការ ។ ការលះបង់សូម្បី ២ ប្រការ ក៏មានអត្ថដូចពោលហើយក្នុងខាងក្រោយ ។

សូម្បីក្នុងបទមានជាអាទិ៍ថា **អស្សទ្ធិយស្ស បហានាយ ឆន្ទោ ឧប្បជ្ជតិ** ឆន្ទៈរមែងកើតឡើង ដើម្បីលះនូវភាពជាអ្នកមិនមានសទ្ធា គប្បីជ្រាបដោយសេចក្ដីពិស្ដារដោយន័យនេះឯង ។ សូម្បីក្នុងវារៈដែលមាន វីរិយិន្ទ្រិយជាដើម ជាមូលហេតុ ក៏មានន័យនេះដូចគ្នា ។

(ចប់ អដ្ឋកថា អធិមត្តដ្ឋនិទ្ទេស)

## អដ្ឋកថា អធិដ្ឋានដ្ឋនិទ្ទេស

សូម្បី **អធិដ្ឋានដ្ឋនិទ្ទេស** គប្បីជ្រាបដោយសេចក្ដីពិស្ដារដោយន័យនេះ ។ មានសេចក្ដីផ្សេងគ្នាតែមួយ នៅក្នុងបទនេះថា **អធិដ្ឋាតិ** រមែងតាំងមាំ សេចក្ដីថា រមែងតាំងនៅ ។

(ចប់ អដ្ឋកថា អធិដ្ឋានដ្ឋមនិទ្ទេស)

## អដ្ឋកថា បរិយាទានដ្ឋប្បតិដ្ឋាប្បកដ្ឋនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **បរិយាទានដ្ឋនិទ្ទេស** ដូចតទៅនេះ ។ បទថា **បរិយាទិយតិ** រមែងគ្របសង្កត់ គឺ រមែងឲ្យអស់ទៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **បតិដ្ឋាបកដ្ឋនិទ្ទេស** ដូចតទៅនេះ ។ បទថា **សទ្ធោ សទ្ធិន្ទ្រិយំ អធិមោក្ខេ បតិដ្ឋាបេតិ** អ្នកមានសទ្ធា រមែងឲ្យសទ្ធិន្ទ្រិយតាំងនៅក្នុងការបង្អោនចិត្តជឿ គឺ អ្នកដល់ព្រមដោយសទ្ធា បង្អោនចិត្តជឿថា សង្ខារទាំងឡាយទាំងពួង មិនទៀង ជាទុក្ខ ជាអនត្តា រមែងឲ្យសទ្ធិន្ទ្រិយតាំងនៅក្នុងការបង្អោនចិត្តជឿ



ដោយបទនេះ លោកសម្ដែងសេចក្ដីវិសេស នៃការចម្រើនឥន្ទ្រិយ ដោយសេចក្ដីវិសេសនៃបុគ្គល ។

បទថា **សទ្ធស្ស សទ្ធិន្ទ្រិយំ អធិមោក្ខេ បតិដ្ឋាបេតិ** សទ្ធិន្ទ្រិយរបស់អ្នកមានសទ្ធា រមែងឲ្យតាំងនៅក្នុងការបង្អោនចិត្តជឿ គឺ សទ្ធិ-ន្ទ្រិយរបស់បុគ្គលអ្នកដល់ព្រមដោយសទ្ធា រមែងញ៉ាំងសទ្ធានោះឲ្យតាំងនៅ ។ម្យ៉ាងទៀត រមែងញ៉ាំងបុគ្គលអ្នកបង្អោនចិត្តជឿ ឲ្យតាំងនៅ ក្នុងការបង្អោនចិត្តជឿ ។ ដោយបទនេះ លោកសម្ដែងសេចក្ដីវិសេសរបស់បុគ្គល ដោយសេចក្ដីវិសេសនៃការចម្រើនឥន្ទ្រិយ ។ កាលផ្គងចិត្តហើយយ៉ាងនេះ រមែងឲ្យវីរិយិន្ទ្រិយតាំងនៅក្នុងសេចក្ដីផ្គងចិត្ត កាលតាំងសតិទុក រមែងឲ្យសតិន្ទ្រិយតាំងនៅក្នុងការតាំងមាំ កាលតាំងចិត្តទុកមាំ រមែងឲ្យសមាធិន្ទ្រិយតាំងនៅក្នុងភាពមិនរាយមាយ កាលឃើញ **អនិច្ចំ ទុក្ខំ អនត្តា** រមែងឲ្យបញ្ញិន្ទ្រិយតាំងនៅក្នុងទស្សនៈ ព្រោះហេតុនោះ គប្បីជ្រាបការប្រកបសូម្បីក្នុងបទដ៏សេស ។

បទថា **យោគាវចរោ** ឈ្មោះថា **យោគាវចរោ** ព្រោះត្រាច់ទៅក្នុងសមថយោគៈ (ការប្រកបសមថៈ) ឬក្នុងវិបស្សនាយោគៈ ( ការប្រកបវិបស្សនា ) ។ បទថា **អវចរតិ** គឺ ត្រាច់ទៅ ។

(ចប់ អដ្ឋកថាបរិយាទានដ្ឋប្បតិដ្ឋាបកដ្ឋនិទ្ទេស)

ចប់ អដ្ឋកថាចតុត្ថសុត្តន្តនិទ្ទេស

# អដ្ឋកថា ឥន្ទ្រិយសមោធាន

ឥឡូវនេះ ព្រះសារីបុត្តត្ថេរប្រាថ្នានឹងសម្ដែង ដល់ការប្រជុំឥន្ទ្រិយរបស់អ្នកចម្រើនសមាធិ និងរបស់អ្នកចម្រើនវិបស្សនា កាលសម្ដែងប្រភេទនៃភាពជាអ្នកឆ្លាតក្នុងការតាំងទុក ជាលំដាប់ដំបូងមុន ទើបពោលពាក្យមានជាអាទិ៍ថា **បុថុជ្ជនោ សមាធឹ ភាវេន្តោ** ចម្រើនសមាធិ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុថុជ្ជនោ សមាធឹ ភាវេន្តោ** គឺ បុថុជ្ជនចម្រើនសមាធិ ដែលជាចំណែកនៃការចាក់ធ្លុះ ។ សូម្បីចំណែកលោកុត្តរសមាធិ ក៏រមែងមានដល់ព្រះសេក្ខៈ និងដល់អ្នកប្រាសចាករាគៈ ។ បទថា **អាវជ្ជិតត្តា** អ្នកមានខ្លួនពិចារណាហើយ គឺ មានខ្លួនពិចារណានិមិត្ត មានកសិណជាដើមហើយ ។ លោកអធិប្បាយថា ព្រោះធ្វើបរិកម្មមានកសិណជាដើម ហើយមានខ្លួន ជានិមិត្តឲ្យកើតក្នុងបរិកម្មនោះ ។ បទថា **អារម្មណូបដ្ឋានកុសលោ** ជាអ្នកឆ្លាតក្នុងការតាំងទុកនូវអារម្មណ៍ គឺ ជាអ្នកឆ្លាតក្នុងការតម្កល់ទុកនូវនិមិត្តដែលឲ្យកើតនោះឯង ។ បទថា **សមថនិមិត្តូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវសមថនិមិត្ត គឺ កាលបើចិត្តរាយមាយដោយ



ភាពជាអ្នកផ្ដើមសេចក្ដីព្យាយាមខ្លាំងពេក ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវអារម្មណ៍ គឺ សេចក្ដីស្ងប់ចិត្តដោយអំណាចនៃការចម្រើនបស្សទ្ធិ-សម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ។

បទថា **បគ្គហនិមិត្តូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវបគ្គហនិមិត្ត គឺ កាលបើចិត្តរួញរាដោយភាពជាអ្នកមានសេចក្ដីព្យាយាមធូរថយពេក ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវនិមិត្ត គឺ ការផ្គងចិត្ត ដោយអំណាចនៃការចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ វីរិយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈ ។ បទថា **អវិក្ខេបូបដ្ឋាន-កុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវការមិនរាយមាយ គឺ ជាអ្នកឈ្លាសក្នុងការតាំងទុកនូវសមាធិ ដែលសម្បយុត្តដោយចិត្តមិនរាយមាយ និងចិត្តមិនរួញរា ។ បទថា **ឱភាសុបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវឱភាស គឺ កាលចិត្តមិនត្រេកអរ ព្រោះជាអ្នកប្រកបដោយបញ្ញាទន់ខ្សោយ ជាអ្នកឈ្លាសក្នុងការតាំងទុកនូវ **ញាណោភាស** ព្រោះញុំាងចិត្តឲ្យសង្វេគ ដោយការពិចារណាសង្វេគវត្ថុ ៨ ។ សង្វេគ វត្ថុ ៨ គឺ ជាតិ ១ ជរា ១ ព្យាធិ ១ មរណៈ ១ អបាយទុក្ខជាទី ៥ វដ្ដមូលកទុក្ខក្នុងអតីត ១ វដ្ដមូលកទុក្ខក្នុងអនាគត១អាហារបរិយេដ្ឋិមូលកទុក្ខ (ទុក្ខពីការស្វែងរកអាហារ ) ១ ។

បទថា **សម្បហំសនូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវភាពរីករាយ គឺ កាលចិត្តមិនត្រេកអរ ព្រោះមិនសម្រេចសេចក្ដីសុខ គឺ សេចក្ដីស្ងប់ ធ្វើចិត្តឲ្យជ្រះថ្លាដោយការនឹករឮកដល់ពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសេចក្ដីរីករាយ ។ បទថា **ឧបេក្ខូបដ្ឋានកុសលោ** ជាអ្នកឈ្លាស ក្នុងការតាំងទុកនូវឧបេក្ខា គឺ កាលចិត្តប្រាសចាកទោស មានការរាយមាយជាដើម ជាអ្នកឆ្លាតក្នុងការតម្កល់ទុកនូវឧបេក្ខា ដោយធ្វើសេចក្ដីមិខ្វល់ខ្វាយក្នុងការគ្រប់សង្កត់ និងការលើកឡើងជាដើម ។

បទថា **សេក្ខោ** ឈ្មោះថា **សេក្ខោ** ព្រោះសិក្សាត្រៃសិក្ខា ។ បទថា **ឯកត្តូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវធម៌តែមួយ គឺ កាលបើចិត្តចេញចាកកាមជាដើម ព្រោះលះសក្កាយទិដ្ឋិជាដើម បានហើយ ។ បទថា **វីតរាគោ** មានរាគៈទៅប្រាសហើយ គឺ ប្រាសចាករាគៈ អស់អាសវៈហើយ ព្រោះលះរាគៈបានហើយ ដោយប្រការទាំងពួង ។ បទថា **ញាណូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវញាណ គឺ ភាពជាអ្នកឈ្លាសក្នុងអសម្មោហញាណក្នុងទីនោះៗ ព្រោះក្នុងធម៌របស់ព្រះអរហន្ត ជាធម៌ប្រាសចាកសេចក្ដីវង្វេង ។ បទថា **វិមុត្តូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវញាណ គឺ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវអរហត្តផល-វិមុត្តិ ។ ពិតណាស់ លោកបំណងយកអរហត្តផលវិមុត្តិ ព្រោះផុតចាកកិលេសទាំងពួង ។



គប្បីជ្រាបបទមាជាអាទិ៍ថា **អនិច្ចតោ** និងបទមានជាអាទិ៍ថា **និច្ចតោ** ក្នុងការតម្កល់ទុក និងការមិនតម្កល់ទុកនូវវិបស្សនាភាវនាដោយន័យដូចពោលហើយក្នុងសីលកថានោះឯង ។ តែដោយបាឋៈលោកកាត់បទសមាសដោយឆដ្ឋីវិភត្តិក្នុងបទទាំងនេះ គឺ ជាអ្នកឆ្លាតក្នុងការតាំងទុកដោយកាប្រមូលមក ជាអ្នកឈ្លាសក្នុងការតាំងទុកដោយសេចក្ដីប្រែប្រួល ជាអ្នកឈ្លាសក្នុងការតាំងទុក ដោយសភាពរកនិមិត្តមិនបាន ជាអ្នកឆ្លាតក្នុងការមិនតាំងទុក ដោយសភាពមាននិមិត្ត ជាអ្នកឈ្លាសក្នុងការតាំងទុកដោយសភាពមិនមានទីតាំង ជាអ្នកឈ្លាសក្នុងការមិនតាំងទុកដោយសភាពមានទីតាំង ជាអ្នកឈ្លាសក្នុងមិនតាំងទុកដោយការប្រកាន់មាំ ។ ក៏ក្នុងបទថា **សុញ្ញតូបដ្ឋានកុសលោ** ជាអ្នកឆ្លាតក្នុងការតាំងទុក ដោយភាពជារបស់សូន្យនេះ លោកកាត់បទថា **សុញ្ញតោ ឧបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ព្រោះភាពជារបស់សូន្យ ឬ **សុញ្ញតាយ ឧបដ្ឋានកុសលោ** ជាអ្នកឆ្លាតក្នុងការតម្កល់ទុក ព្រោះជារបស់សូន្យ ។ មយ៉ាងទៀត ព្រោះមហាវិបស្សនា

៨ ទាំងនេះ គឺ និព្វិទានុបស្សនា ១ វិរាគានុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គានុបស្សនា ១ អធិប្បញ្ញាធម្មវិបស្សនា ១ យថាភូតញាណទស្សន ១ បដិសង្ខានុបស្សនា ១ វិវដ្តនានុបស្សនា ១ ជាមហាវិបស្សនាវិសេស ដោយភាពពិសេសតាមសភាវៈរបស់ខ្លួន មិនមែនពិសេសដោយភាពពិសេសនៃអារម្មណ៍ ដូច្នោះ ពាក្យមានជាអាទិ៍ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយភាពជារបស់ គួរនឿយណាយ ទើបមិនគួរដល់មហាវិបស្សនា ៨ ទាំងនោះ ដូច ពាក្យមានជាអាទិ៍ថា ជាអ្នកឈ្លាសក្នុងការតាំងទុកដោយភាពជារបស់មិនទៀង ព្រោះដូច្នោះ លោកទើបមិនប្រកបមហាវិបស្សនា ៨ ទាំងនេះទុក ។

ចំណែកអាទីនវានុបស្សនា ឈ្មោះថា លោកប្រកបថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយភាពជាទោស ជាអ្នកច្លាតក្នុងការមិនតម្កល់ទុកដោយការប្រកាន់មាំដោយសេចក្តីអាល័យ ដោយពាក្យគូនេះថា ជាអ្នកច្លាតក្នុងកាតាំងទុកដោយសភាពសូន្យ ជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកដោយការប្រកាន់មាំ ព្រោះហេតុនោះលោកទើបមិនប្រកបទុកដោយសរុប ។

ក្នុងមហាវិបស្សនា ១៨ គប្បីជ្រាបថា លោកមិនប្រកបមហាវិបស្សនា ៩ ទាំងនេះ គឺ មហាវិបស្សនាខាងដើម ៨ និងអាទីនវានុបស្សនា ១ ទុកហើយ ប្រកបមហាវិបស្សនា ៩ ទៀត ក្រៅនេះទុក ។



បទថា **ញាណូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកនូវញាណ គឺ ព្រះសេក្ខៈជាអ្នកឈ្លាសក្នុងការតាំងទុកនូវញាណ ដោយការចម្រើនវិបស្សនា ព្រោះមិនមានវិបស្សនូបក្កិលេស ប៉ុន្តែលោកមិនបានពោលថា ជាអ្នកឈ្លាសក្នុងការតាំងទុកនូវញាណ ព្រោះការប្រាកដនៃសេចក្តីប្រាថ្នាដោយការចម្រើនសមាធិ ។ បទថា **វិសញ្ញោគូបដ្ឋានកុសលោ** ជាអ្នកឈ្លាសក្នុងការតាំងទុកដោយមិនទាក់ទង គឺ ជាអ្នកឈ្លាសក្នុងការតាំងទុកនូវការមិនប្រកប ដូចដែលលោកពោលទុក ៤ យ៉ាង គឺ កាមយោគវិសញ្ញោគៈ ( ការមិនប្រកបដោយកាមយោគៈ ) ១ ភវយោគវិសញ្ញោគៈ (ការមិនប្រកបដោយភវយោគៈ ) ១ ទិដ្ឋិយោគវិសញ្ញោគៈ ( ការមិនប្រកបដោយទិដ្ឋិយោគៈ ) ១ អវិជ្ជាយោគវិសញ្ញោគៈ (ការមិនប្រកបដោយអវិជ្ជាយោគៈ ) ១ ។

បទថា **សញ្ញោគានូបដ្ឋានកុសលោ** ជាអ្នកច្លាតក្នុងការមិនតាំងទុកដោយការប្រកប គឺ ជាអ្នកឈ្លាសក្នុងការមិនតាំងទុកនូវការប្រកប ដែលលោកពោលទុក ៤ យ៉ាង គឺ កាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ បទថា **និរោធូប-**

**ដ្ឋានកុសលោ** ជាអ្នកឆ្លាតក្នុងការតាំងទុកដោយការរលត់ គឺ ឈ្មោះថាជាខីណាស្រព ព្រោះមានចិត្តបង្អោនទៅកាន់និព្វាន ដោយអំណាចនៃកម្លាំងរបស់លោកដែលអស់អាសវៈហើយ ដូចព្រះដ៏មានព្រះភាគជា-ម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៀតមានទៀត ចិត្តរបស់ភិក្ខុជាខីណាស្រពបង្អោនទៅកាន់និព្វាន ទោរទៅកាន់និព្វាន ឱនទៅកាន់និព្វាន តាំងនៅក្នុងវិវេក ត្រេកអរក្រៃលែងក្នុងនេក្ខម្មៈ ធ្វើឲ្យស្ងួនស្ងៀមអស់ទៅចាកធម៌ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ជាអ្នកឆ្លាតក្នុងការតាំងទុកនូវនិព្វាន ពោលគឺ ការរលត់ ។

បទថា **កុសលំ** ក្នុងបទមានជាអាទិ៍ថា **អារម្មណូបដ្ឋានកុសលវសេន** ដោយអំណាចជាអ្នកឈ្លាស ក្នុងការតម្កល់ទុកនូវអារម្មណ៍បានដល់ **ញាណ** ។ ពិតណាស់ សូម្បីញាណ ក៏ ឈ្មោះថា **កុសល** ព្រោះប្រកបដោយបុគ្គលអ្នកឈ្លាស ដូចបទថា **បណ្ឌិតា ធម្មា** ធម៌ទាំងឡាយជាបណ្ឌិត ព្រោះប្រកបដោយបុគ្គលជាបណ្ឌិត ព្រោះដូច្នោះទើបមានសេចក្ដីថា ដោយអំណាចនៃភាពជាអ្នកឈ្លាស ។

ឥឡូវនេះ សូម្បីលោកពោលទុកហើយក្នុងញាណកថា មានជាអាទិ៍ថា **ចតុសដ្ឋិយា អាការេហិ** ដោយអាការ ៦៤ លោកក៏នៅនាំមកពោលទុកក្នុងទីនេះ ដោយភ្ជាប់ជាមួយឥន្ទ្រិយកថា ។ គប្បីជ្រាបបទ



នោះ ដោយន័យដែលលោកពោលទុកហើយក្នុងខាងក្រោយនោះឯង ។

ព្រះសារីបុត្តត្ថេរ ប្រាថ្នានឹងពោលប្រភេទរបស់ឥន្ទ្រិយដែលភ្ជាប់ជាមួយសមន្តចក្ខុទៀត ទើបពោលបទមានជាអាទិ៍ថា **ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ** បទធម៌ណា ៗ ដែលព្រះតថាគតទ្រង់មិនឃើញនោះ ក្នុងលោកនេះមិនមាន ។ ក្នុងបទទាំងនោះ បទថា **សមន្តចក្ខុ** បានដល់ ព្រះសព្វញ្ញុតញ្ញាណ ។ លោកសំដែងសេចក្ដីដែលឥន្ទ្រិយទាំងឡាយ ៥ មិនប្រាសចាកគ្នា ដោយបទមានជាអាទិ៍ថា **បញ្ចិន្ទ្រិ-យស្ស វសេន** ដោយអំណាចនៃបញ្ចិន្ទ្រិយ ។ លោកសំដែងសេចក្ដីដែលឥន្ទ្រិយ ៥ មានរសតែមួយ និងជាបច្ច័យដល់គ្នានឹងគ្នា ក្នុងវេលាប្រកបការបង្អោនទៅ ឬក្នុងខណៈនៃមគ្គ ដោយចតុក្កៈ ៥ មានឥន្ទ្រិយមួយ ៗ ជាមូល មានជាអាទិ៍ថា **សទ្ទហន្តោ បគ្គណ្ហាតិ** កាលបើការជឿរមែងផ្គងទុក ។

លោកសំដែងសេចក្ដីដែលឥន្ទ្រិយ ៥ មានរសតែមួយដូចគ្នា និងជាបច្ច័យដល់គ្នានឹងគ្នា ក្នុងវេលាប្រកបការបង្អោនទៅ ឬក្នុងខណៈនៃមគ្គ ដោយចតុក្កៈ ៥ ដែលមានឥន្ទ្រិយមួយៗ ជាមូល មានជាអាទិ៍ថា **សទ្ទហិតត្តា បគ្គហិតំ** ព្រោះភាពជាអ្នកជឿ ទើបផ្គងទុក ។ ព្រះសារីបុត្តត្ថេរ ប្រាថ្នានឹងពោលប្រភេទរបស់ឥន្ទ្រិយដោយភ្ជាប់ជាមួយ

ពុទ្ធចក្ខុ ទើបពោលបទមានជាអាទិ៍ថា **យំ ពុទ្ធចក្ខុំ** ព្រះពុទ្ធញាណជាពុទ្ធចក្ខុ ។ ក្នុងបទទាំងនោះ បទថា **ពុទ្ធចក្ខុំ** បានដល់ **ឥន្ទ្រិយបរោបរិយត្តញ្ញាណ** ( ប្រាជ្ញាកំណត់ដឹងភាពទន់ខ្ចី និងចាស់ក្លានៃឥន្ទ្រិយរបស់សត្វទាំងឡាយ ) និង **អាសយានុសយញ្ញាណ** ( ប្រាជ្ញាកំណត់ដឹងអធ្យាស្រ័យ និងអនុស័យរបស់សត្វទាំងឡាយ ) ។ ក៏បទថា **ពុទ្ធញ្ញាណំ** នេះ ក៏បានដល់ ញាណទាំងពីរនោះដូចគ្នា ។ បទដ៏សេសមានសេចក្តីដូចពោលទុកហើយក្នុងខាងក្រោយនោះឯង ។

(ចប់ អដ្ឋកថាឥន្ទ្រិយសមោធាន)

ចប់ អដ្ឋកថាឥន្ទ្រិយកថា



## ៥-វិមោក្ខកថា

## អដ្ឋកថា វិមោក្ខុទ្ទេស

ឥឡូវនេះ ដល់កាលនឹងពណ៌នាទៅតាមលំដាប់សេចក្តី ដែលមិនធ្លាប់ពណ៌នានៃវិមោក្ខកថា ដែលលោកពោលក្នុងលំដាប់ឥន្ទ្រិយកថា ។ ពិតណាស់ វិមោក្ខកថានេះ លោកពោលក្នុងលំដាប់ ឥន្ទ្រិយកថា ព្រោះអ្នកប្រកបដោយឥន្ទ្រិយភាវនាជាអ្នកបានវិមោក្ខ ។ ក៏ព្រះសារីបុត្តត្ថេរកាលពោលវិមោក្ខកថានោះ ធ្វើសុត្តន្តទេសនាឲ្យជាប្រធានហើយពោលចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគជាម្ចាស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រនោះ ដូចតទៅនេះ ។ ក្នុងបទមានជាអាទិ៍ថា **សុញ្ញតោ វិមោក្ខោ** បានដល់ អរិយមគ្គដែលប្រព្រឹត្តទៅ ព្រោះធ្វើនិព្វានឲ្យជាអារម្មណ៍ ដោយអាការនៃភាពជារបស់សូន្យ ឈ្មោះថា **សុញ្ញតវិមោក្ខ** ។ សុញ្ញតវិមោក្ខនោះ ឈ្មោះថា **សុញ្ញត** ព្រោះជាធាតុសូន្យ ។ ឈ្មោះថា **វិមោក្ខ** ព្រោះរួចផុតចាកកិលេសទាំងឡាយ ។

ដោយន័យនេះឯង គប្បីជ្រាបថា វិមោក្ខប្រព្រឹត្តទៅ ព្រោះធ្វើនិព្វានឲ្យជាអារម្មណ៍ ដោយអាការរកនិមិត្តមិនបាន ឈ្មោះថា **អនិមិត្តវិមោក្ខ** ។ វិមោក្ខប្រព្រឹត្តទៅ ព្រោះធ្វើនិព្វានឲ្យជាអារម្មណ៍

ដោយអាការមិនមានទីតាំង ឈ្មោះថា **អប្បណិហិតវិមោក្ខ** ។

ភិក្ខុមួយរូបពិចារណាសង្ខារទាំងឡាយ ដោយភាពមិនទៀង តាំងពីដើមនោះឯង ម្យ៉ាងទៀត ព្រោះត្រឹមតែពិចារណាមិនទៀង ប៉ុណ្ណោះ នៅមិនជាការចេញទៅនៃមគ្គ គួរពិចារណាដោយភាពជាទុក្ខខ្លះ ដោយភាពជាអនត្តាខ្លះ ។ ប្រសិនបើកាលភិក្ខុនោះបដិបត្តិហើយយ៉ាងនេះ រមែងជាការចេញទៅនៃមគ្គ ក្នុងកាលដែលពិចារណាដោយភាពមិនទៀង ភិក្ខុនេះឈ្មោះថា នៅដោយភាពមិនទៀង ហើយចេញទៅដោយភាពមិនទៀង ។ ម្យ៉ាងទៀត ប្រសិនបើការចេញទៅនៃមគ្គ ក្នុងកាលដែលភិក្ខុនោះពិចារណាដោយភាពជាទុក្ខ ដោយភាពជាអនត្តា ភិក្ខុនេះឈ្មោះថា នៅដោយភាពមិនទៀង ហើយចេញទៅដោយភាពជាទុក្ខ ដោយភាពជាអនត្តា ។ សូម្បីក្នុងការនៅដោយភាពជាទុក្ខ ដោយភាពជាអនត្តាហើយចេញទៅ ក៏មានន័យនេះ ។

ម្យ៉ាងទៀត ក្នុងឧទ្ទេសនេះ សូម្បីភិក្ខុណានៅដោយភាពមិនទៀង ដោយភាពជាទុក្ខ ដោយភាពជាអនត្តា ប្រសិនបើក្នុងវេលាចេញ រមែងចេញដោយភាពមិនទៀង សូម្បីភិក្ខុទាំង ៣ នេះ ក៏ជាអ្នកច្រើនទៅដោយអធិមោក្ខៈ រមែងបានសទ្ធិន្ទ្រិយ រមែងផុតដោយអនិមិត្តវិមោក្ខ ជាសទ្ធានុសារី (អ្នករឭកសទ្ធា) ក្នុងខណៈបឋមមគ្គ ជាអ្នកផុតចាក



ដោយសទ្ធាក្នុងឋានៈ ៧ ។ ម្យ៉ាងទៀត ប្រសិនបើចេញទៅដោយភាពជាទុក្ខ សូម្បីជនទាំង ៣ ក៏ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបានសមាធិន្ទ្រិយ រមែងផុតដោយ អប្បណិហិតវិមោក្ខ ជាកាយសក្ខី (សាក្សីឃើញនឹងភ្នែកផ្លូវកាយ) ក្នុងទីទាំងពួង ។ ម្យ៉ាងទៀត អរូបឈានក្នុងកាយសក្ខីនេះជាបាទរបស់ភិក្ខុណា ភិក្ខុនោះ ជាឧភតោភាគវិមុត្តក្នុងផលដ៏ប្រសើរ បន្ទាប់ពីនោះ ជាការចេញដោយភាពជាអនត្តារបស់ជនទាំងនោះ ។ សូម្បីជនទាំង ៣ ក៏ជាអ្នកច្រើនដោយការដឹង រមែងបានបញ្ញិន្ទ្រិយ រមែងរួចផុត ដោយសុញ្ញតវិមោក្ខ ជាធម្មសារី (អ្នករឭកដល់ធម៌) ក្នុងខណៈបឋមមគ្គ ជាអ្នកដល់ទិដ្ឋិក្នុងឋានៈ ៦ ជាអ្នករួចផុតដោយបញ្ញាក្នុងផលដ៏ប្រសើរ ។

ម្យ៉ាងទៀត ឈ្មោះថា **មគ្គ** រមែងបានឈ្មោះដោយហេតុ ៥ ប្រការ គឺ ដោយប្រព្រឹត្តទៅជាមួយនឹងកិច្ច ១ ដោយភាពជាសត្រូវ ១ ដោយប្រព្រឹត្តទៅជាមួយនឹងគុណ ១ ដោយអារម្មណ៍ ១ ដោយការមក ១ ។ ប្រសិនបើភិក្ខុពិចារណាសង្ខារដោយភាពមិនទៀង ហើយចេញចាកការព្រងើយកន្តើយក្នុងសង្ខារ រមែងផុតដោយអនិមិត្តវិមោក្ខ ប្រសិនបើពិចារណាដោយភាពជាទុក្ខ ហើយចេញ រមែងផុតដោយអប្បណិហិតវិមោក្ខ ប្រសិនបើពិចារណាដោយភាពជាអនត្តា ហើយចេញ រមែង

ផុតដោយ សុញ្ញតវិមោក្ខ នេះឈ្មោះថា ជាឈ្មោះដោយការប្រព្រឹត្ត ទៅជាមួយនឹងកិច្ច (នាទី) ។

ម្យ៉ាងទៀត **វិមោក្ខ** ឈ្មោះថា **អនិមិត្ត** ព្រោះធ្វើការបែក ភាពជាឃនៈ ( ដុំ ) របស់សង្ខារទាំងឡាយដោយអនិច្ចានុបស្សនា ហើយលះនិមិត្តថាទៀង និមិត្តថាយឺនយូរ និមិត្តថាមាំទាំបេញទៅ ។ ឈ្មោះថា **អប្បណិហិត** ព្រោះលះសុខសញ្ញា ដោយទុក្ខានុបស្សនា ហើយញ៉ាំងសេចក្តីប្រាថ្នាដែលតាំងទុកឲ្យស្ងួតទៅ ។ ឈ្មោះថា **សុញ្ញត** ព្រោះលះសេចក្តីសម្គាល់ថាខ្លួន សត្វ បុគ្គល ដោយអនត្តានុបស្សនា ហើយឃើញសង្ខារទាំងឡាយដោយភាពជារបស់សូន្យ នេះឈ្មោះថា ជាឈ្មោះដោយភាពជាសត្រូវ ។

ម្យ៉ាងទៀត ឈ្មោះថា **សុញ្ញត** ព្រោះភាពជារបស់សូន្យចាក រាគៈជាដើម ។ ឈ្មោះថា **អនិមិត្ត** ព្រោះមិនមានរូបនិមិត្តជាដើម ឬ រាគៈនិមិត្តជាដើម ។ ឈ្មោះថា **អប្បណិហិត** ព្រោះមិនមានទីតាំង របស់រាគៈជាដើម នេះឈ្មោះថា ជាឈ្មោះដោយប្រព្រឹត្តទៅជាមួយ នឹងគុណនៃមគ្គនោះ ។

មគ្គនេះនោះ រមែងធ្វើនិព្វានដែលជារបស់សូន្យ មិនមាននិមិត្ត មិនមានទីតាំង ឲ្យជាអារម្មណ៍ ព្រោះហេតុនោះ លោកទើបពោលថា



សុញ្ញតៈ អនិមិត្តៈ អប្បណិហិតៈ នេះឈ្មោះថា ជាឈ្មោះដោយភាព ជាអារម្មណ៍ ។

ម្យ៉ាងទៀត ការមកមាន ២ យ៉ាង គឺ វិបស្សនាគមនៈ ( ការ មកនៃវិបស្សនា ) ១ មគ្គាគមនៈ ( ការមកនៃមគ្គ ) ១ ។

ការមកនៃវិបស្សនា រមែងបានក្នុងមគ្គ ការមកនៃមគ្គ រមែង បានក្នុងផល ។ ព្រោះអនត្តានុបស្សនា ឈ្មោះថា **សុញ្ញត** មគ្គនៃ សុញ្ញតវិបស្សនា ឈ្មោះថា **សុញ្ញត** ។ ផលនៃសុញ្ញតមគ្គ ឈ្មោះថា **សុញ្ញត** ។ អនិច្ចានុបស្សនា ឈ្មោះថា **អនិមិត្ត** មគ្គនៃអនិមិត្ត-វិបស្សនា ឈ្មោះថា **អនិមិត្ត** ។ ក៏ឈ្មោះនេះ រមែងបានដោយអភិ-ធម្មបរិយាយ តែក្នុងសុត្តន្តបរិយាយក៏បានផង ។ ពិតណាស់ អាចារ្យទាំងឡាយ ពោលទុកក្នុងសុត្តន្តបរិយាយនោះថា ព្រះយោ-គាវចរធ្វើនិព្វានដែលជាគោត្រភូញាណ រកនិមិត្តមិនបានឲ្យជាអារម្មណ៍ ជាឈ្មោះដែលមិនមាននិមិត្តតាំងនៅក្នុងអាគមនីយដ្ឋាន ( ទីកន្លែងដែល មកដល់ ) ខ្លួនឯងហើយឲ្យឈ្មោះដល់មគ្គ ដោយហេតុនោះ លោកទើប ពោលថា មគ្គជាអនិមិត្តៈ គួរពោលថា ផលជាអនិមិត្តៈដោយការមកនៃ មគ្គ ។ ទុក្ខានុបស្សនា ឈ្មោះថា **អប្បណិហិត** ព្រោះញ៉ាំងការតាំង ទុកក្នុង សង្ខារទាំងឡាយឲ្យស្ងួតទៅមគ្គនៃអប្បណិហិតវិបស្សនា ឈ្មោះ

ថា **អប្បណិហិត** ។ ផលនៃអប្បណិហិតមគ្គ ឈ្មោះថា **អប្បណិហិត** ព្រោះហេតុនោះ វិបស្សនារមែងឲ្យឈ្មោះនៃមគ្គរបស់ខ្លួនយ៉ាងនេះ ។ មគ្គរមែងឲ្យឈ្មោះនៃផល នេះឈ្មោះថា ជាឈ្មោះដោយការមកដល់ ។ ព្រះយោគាវចររមែងកំណត់គុណវិសេសនៃវិមោក្ខ ចាកការព្រងើយក្នុងសង្ខារដោយប្រការដូច្នេះ ។

ព្រះសារីបុត្តត្ថេរ លុះលើកវិមោក្ខដែលជាមហាវត្ថុ ៣ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងហើយ ដែលសម្តែងយ៉ាងនេះ បំណងនឹងបង្ហាញដល់វិមោក្ខ សូម្បីដទៃទៀតដោយអំណាចការបង្ហាញវិមោក្ខនោះ ទើបពោលពាក្យមានជាអាទិ៍ថា **អបិច អដ្ឋសដ្ឋី វិមោក្ខា**ម្យ៉ាងទៀត វិមោក្ខ ៦៨ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អបិច** ជាបទសម្តែងដល់បរិយាយដទៃ ។ វិមោក្ខទាំងនោះមាន ៦៨ បានដូចម្តេច មាន ៧៥ មិនមែនឬ ។ មាន ៧៥ តាមពាក្យហៅពិតឬ មិនគួររាប់វិមោក្ខ ៣ ទាំងនេះ ព្រោះបង្ហាញវិមោក្ខដទៃ វៀរវិមោក្ខ ៣ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងហើយ និងព្រោះបំបែកវិមោក្ខទាំងនោះ សូម្បីវិមោក្ខ ៣ មានអជ្ឈត្តវិមោក្ខជាដើម ក៏មិនគួររាប់ ព្រោះឈានចុះខាងក្នុងដោយពោលពិស្តារ ៤ ចំណែក អប្បណិហិតវិមោក្ខ ក្នុងបទនេះថា **បណិ-**



**ហិតោ វិមោក្ខោ អប្បណិហិតោ វិមោក្ខោ** បណិហិតវិមោក្ខ អប្បណិហិតវិមោក្ខ ក៏មិនគួររាប់ ព្រោះមានឈ្មោះដូចគ្នា ដោយការលើកឡើងសម្តែងជាគ្រាដំបូង កាលនាំវិមោក្ខ ៧ យ៉ាងទាំងនេះចេញយ៉ាងនេះហើយ ក៏សល់វិមោក្ខ ៦៨ ។ ប្រសិនសួរថា កាលជាយ៉ាងនេះ ព្រោះហេតុអ្វី ទើបលើកវិមោក្ខ ៣ មានសុញ្ញតវិមោក្ខជាដើម លើកឡើងសម្តែង ។ ឆ្លើយថា ដើម្បីលើកឡើងដោយឧទ្ទេស ហើយធ្វើការបង្ហាញវិមោក្ខទាំងនោះ ។ ម្យ៉ាងទៀត វិមោក្ខ ៣ មានអជ្ឈត្តវុដ្ឋានវិមោក្ខ (វិមោក្ខមានការចេញចាកខាងក្នុង) ជាដើម លោកលើកឡើងសម្តែងដោយ អំណាចនៃពួកដែលជាមូលហេតុវៀរប្រភេទចេញ ។ គប្បីជ្រាប សូម្បីអប្បណិហិតវិមោក្ខ លោកក៏លើកឡើងសម្តែងទៀតដោយអំណាចជាបដិបក្ខរបស់បណិហិតវិមោក្ខ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអជ្ឈត្តវុដ្ឋានវិមោក្ខជាដើមដូចតទៅនេះ ។ ឈ្មោះថា **អជ្ឈត្តវុដ្ឋានោ** ព្រោះចេញចាកខាងក្នុង ។ ឈ្មោះថា **អនុលោមា** ព្រោះបណ្តោយតាម ឈ្មោះថា **អជ្ឈត្តវុដ្ឋានបដិប្បស្សទ្ធិ** ព្រោះរម្ងាប់ចេញទៅនៃការចេញចាកខាងក្នុង ។ បទថា **រូបី** គឺ រូបដែលជារូបឈាន ឲ្យកើតឡើងក្នុងអវយវៈ មានសក់ជាដើមក្នុងខាងក្នុង ។ ឈ្មោះថា **រូបី** ព្រោះភិក្ខុមានរូប ។ បទថា **រូបានិ បស្សតិ**

ភិក្ខុឃើញរូប គឺ ឃើញរូបមាននីលកសិណជាដើមក្នុងខាងក្រៅ ដោយញាណចក្ខុ ដោយបទនេះ លោកសម្ដែងដល់ការបានឈានក្នុងកសិណទាំងឡាយ ដែលមានវត្ថុក្នុងខាងក្នុង និងខាងក្រៅ ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** គឺ ភិក្ខុមិនមានការសម្គាល់ថា រូបក្នុងខាងក្នុង សេចក្ដីថា មានរូបាវចរឈាននៅមិនទាន់កើតក្នុងសក់ជាដើមរបស់ខ្លួន ដោយបទនេះ លោកធ្វើបរិកម្មក្នុងខាងក្រៅហើយ ទើបសម្ដែងឈានដែលបានហើយក្នុងខាងក្រៅនោះឯង ។ បទថា **សុភន្តេវ អធិមុត្តោ** បង្អោនចិត្តទៅក្នុងធម៌ចំណែកស្អាតប៉ុណ្ណោះ គឺ បង្អោនទៅក្នុងអារម្មណ៍ថាស្អាតប៉ុណ្ណោះ ។ ក្នុងបទនោះ ការចងចិត្តថាស្អាតមិនមានក្នុងអប្បនាខាងក្នុងសូម្បីដោយពិត តែភិក្ខុណាផ្សាយសត្តារម្មណ៍ទៅដោយអាការជារបស់មិនគួរខ្ពើមហើយ ព្រោះភិក្ខុនោះជាអ្នកបង្អោនចិត្តទៅថា ស្អាតប៉ុណ្ណោះ ដូច្នោះ លោកទើបលើកឡើងសម្ដែងយ៉ាងនេះ ។ ឈ្មោះថា **សមយវិមោក្ខោ** ព្រោះមានវិក្ខម្ភនវិមុត្តិក្នុងសម័យដែលនៅ មិនទាន់ផ្អែតផ្អន់ ។ ឈ្មោះថា **សាមយិកោ** ព្រោះវិមោក្ខនោះប្រកប ហើយក្នុងសម័យដែលនៅមិនទាន់ផ្អែតផ្អន់ ដោយអំណាចកិច្ចរបស់ខ្លួន ។ បាឋៈថា **សាមាយិកោ** ខ្លះ ។ ឈ្មោះថា **កុប្បោ** ព្រោះអាចកម្រើកបាន គឺ ទម្លាយបាន ។ បទថា **លោកិកោ** ព្រោះប្រកបទុកក្នុងលោក



ដោយមិនឈានកន្លងលោក ។ បាឋៈថា **លោកិយោ** ខ្លះ ។ ឈ្មោះថា **លោកុត្តរោ** ព្រោះឆ្លងលោក ឬឆ្លងលោកបានហើយ ។ ឈ្មោះថា **សាសវោ** ព្រោះមានអាសវៈ ដោយការធ្វើឲ្យជាអារម្មណ៍ ។ ឈ្មោះថា **អនាសវោ** ព្រោះមិនមានអាសវៈដោយការធ្វើឲ្យជាអារម្មណ៍ និងដោយការប្រកបរួម ។ ឈ្មោះថា **សាមិសោ** ព្រោះមានអាមិសៈ ពោលគឺរូប ។ ឈ្មោះថា **និរាមិសា និរាមិសតរោ** ព្រោះមិនមានអាមិសៈ ក្រៃលែងជាងមិនមានអាមិសៈ ព្រោះលះរូប និងអរូបបាន ដោយប្រការទាំងពួង ។

បទថា **បណិហិតោ** គឺ តាំងទុកហើយ ប្រាថ្នាហើយដោយអំណាចនៃតណ្ហា ។ ឈ្មោះថា **សញ្ញុត្តោ** ព្រោះប្រកបហើយដោយសំយោជនៈ ដោយការធ្វើឲ្យជាអារម្មណ៍ ។ បទថា **ឯកត្តវិមោក្ខោ** បានដល់ វិមោក្ខមានសភាពដូចគ្នា ព្រោះមិនលូតលាស់ដោយកិលេសទាំងឡាយ ។ បទថា **សញ្ញាវិមោក្ខោ** គឺ វិបស្សនាញាណនោះឯង ឈ្មោះថា សញ្ញាវិមោក្ខ ព្រោះផុតចាកសញ្ញាវិបរិត ។ វិបស្សនា-ញាណនោះឯង ឈ្មោះថា **ញាណវិមោក្ខ** ព្រោះវិមោក្ខ គឺ ញាណនោះឯង ដោយអំណាចផុតចាកការវង្វេង ។ បទថា **សីតិសិយាវិមោក្ខោ** គឺ ការផុតប្រព្រឹត្តទៅហើយថា វិបស្សនាញាណនោះឯងគប្បីជាសេចក្ដី

ត្រជាក់ ឈ្មោះថា **សីតិសិយាវិមោក្ខ** បាឋៈថា **សីតិសិកាវិមោក្ខោ** ខ្លះ ។ អាចារ្យទាំងឡាយពណ៌នាសេចក្តីនៃបទនោះថា ការផុត ព្រោះភាពជារបស់ត្រជាក់ ។ បទថា **ឈានវិមោក្ខោ** បានដល់ វិមោក្ខ គឺឈាននោះឯង ដែលមានប្រភេទជាឧបចារៈ និងអប្បនា និងមានប្រភេទជាលោកិយៈ និងលោកុត្តរៈ ។ បទថា **អនុបាទា ចិត្តស្ស វិមោក្ខោ** បានដល់ ការផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ គឺ មិនធ្វើការប្រកាន់ ។ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

(ចប់ អដ្ឋកថាវិមោក្ខុទ្ទេស)



## អដ្ឋកថា វិមោក្ខនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឧទ្ទេស មានជាអាទិ៍ថា **កតមោ** ដូចតទៅនេះ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** គឺ ពិចារណាឃើញយ៉ាងនេះ ។ បទថា **សុញ្ញមិទំ** នាមរូបនេះទទេ គឺ បញ្ចក្ខន្ធនេះទទេ ។ ទទេចាកអ្វី ទទេចាកភាពជាតួខ្លួន ឬចាកវត្ថុជារបស់ខ្លួន ។

ក្នុងបទទាំងនោះ បទថា **អត្តេន វា** ចាកភាពជាតួខ្លួន គឺ ទទេចាកភាពជាតួខ្លួន ព្រោះមិនមានតួខ្លួនដែលកំណត់ថា ជាមនុស្សពាល ។ បទថា **អត្តនិយេន វា** ចាកវត្ថុជារបស់ខ្លួន គឺ ទទេចាកវត្ថុជារបស់ខ្លួនដែលកំណត់ទុកនោះ ការមិនមានវត្ថុជារបស់ខ្លួន ព្រោះមិនមានខ្លួននោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា វត្ថុជារបស់ខ្លួន នឹងគប្បីជារបស់ទៀង ឬគប្បីជាសេចក្តីសុខ ។ សូម្បីទាំងពីរយ៉ាងនោះ ក៏មិនមាន ។ លោកអធិប្បាយទុកថា អនិច្ចានុបស្សនា ដោយបដិសេធវត្ថុដែលជារបស់ទៀង ទុក្ខានុបស្សនា ដោយបដិសេធសេចក្តីសុខ ។ បទថា **សុញ្ញមិទំ អត្តេន វា** នាមរូបនេះ ទទេចាកភាពជារបស់ខ្លួន លោកពោលដល់អនត្តានុបស្សនានោះឯង ។ បទថា **សោ** គឺ ភិក្ខុនោះ ឃើញច្បាស់ដោយអនុបស្សនា ៣ យ៉ាងនេះ ។ បទថា **អភិនិវេសំ ន**

**ករោតិ** មិនធ្វើការប្រកាន់មាំ គឺ មិនធ្វើការប្រកាន់ខ្លួនដោយអំណាចនៃ **អនត្តានុបស្សនា** ។ បទថា **និមិត្តំ ន ករោតិ** មិនធ្វើគ្រឿងសម្គាល់ គឺ មិនធ្វើគ្រឿងសម្គាល់ថា ទៀងដោយអំណាចនៃ **អនិច្ចានុបស្សនា** ។ បទថា **បណិធឹ ន ករោតិ** មិនធ្វើការប្រាថ្នា គឺ មិនធ្វើសេចក្តីប្រាថ្នាដោយអំណាចនៃ **ទុក្ខានុបស្សនា** ។

វិមោក្ខ ៣ ទាំងនេះ រមែងបានដោយអំណាចនៃតទង្គៈ ក្នុងខណៈនៃវិបស្សនាដោយបរិយាយ តែរមែងបានដោយអំណាចនៃសមុច្ឆេទ ក្នុងខណៈនៃមគ្គដោយនិប្បរិយាយ ។ ឈាន ៤ ជា **អជ្ឈត្តវុដ្ឋានវិមោក្ខ** ព្រោះចេញចាកនីវរណៈជាដើមក្នុងខាងក្នុង ។ អរូបសមាបត្តិ ៤ ឈ្មោះថា **ពហិទ្ធាវុដ្ឋានវិមោក្ខ** ព្រោះចេញចាកអារម្មណ៍ទាំងឡាយ សូម្បីអារម្មណ៍ លោកក៏ពោលថា ខាងក្រៅក្នុងបទនេះ ដូចអាយតនៈ ខាងក្រៅ ។ ទាំងពីរនេះជាវិក្ខម្ភនវិមោក្ខ ។ តែសមុច្ឆេទវិមោក្ខ ជា **ទុភតោវុដ្ឋានវិមោក្ខ** ។

លោកពោលការចេញចាកខាងក្នុងដោយសរុប ដោយបទមានជាអាទិ៍ថា **នីវរណេហិ វុដ្ឋា** ចេញចាកនីវរណៈទាំងឡាយ ។ ដោយបទមានជាអាទិ៍ថា **រូបសញ្ញាយ ចេញ**ចាករូបសញ្ញា លោកមិនពោលដល់សមាបត្តិនោះ ព្រោះការឈានកន្លងអារម្មណ៍ មានកសិណជាដើម



ប្រាកដហើយ ទើបពោលដល់ការឈានកន្លងរូបសញ្ញាជាដើម ដូចដែលពោលហើយក្នុងព្រះសូត្រទាំងឡាយ ។

បទថា **សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស** ជាបទសមាស ។ កាត់បទថា **សក្កាយទិដ្ឋិយា** ( ចាកសក្កាយទិដ្ឋិ ) **វិចិកិច្ឆាយ** ( ចាកវិចិកិច្ឆា ) **សីលព្វតបរាមាសា** ( ចាកសីលព្វតបរាមាស ) នេះឯងជាបាឋៈ ។

ដោយបទថា **វិតក្កោ ច** ជាអាទិ៍ លោកពោលដល់ឧបចារៈភូមិនៃឈាន និងសមាបត្តិ ។ ដោយបទថា **អនិច្ចានុបស្សនា** ជាអាទិ៍ លោកពោលដល់វិបស្សនាដែលជាចំណែកខាងដើមនៃមគ្គ ៤ ។

បទថា **បដិលាភោ វា** ការបាន ឈ្មោះថា **បដិលាភោ** ព្រោះខ្វល់ខ្វាយ ប្រាថ្នា បានដល់ ភាពជំនាញ ៥ យ៉ាង ព្រោះការខ្វល់ខ្វាយក្នុងឈាន និងការខ្វល់ខ្វាយក្នុងសមាបត្តិទាំងពួង ជាការរម្ងាប់ដោយដល់ភាពជំនាញ ដូច្នោះ ការបាន លោកទើបពោលថា វិមោក្ខ ជាការរម្ងាប់ ។ ចំណែកវិបាក ជាការរម្ងាប់ឈាន និងសមាបត្តិ ព្រោះហេតុនោះទើបត្រង់ពិត ។ តែអាចារ្យពួកខ្លះពោលថា ការបានឈាន និងសមាបត្តិ ព្រោះការខ្វល់ខ្វាយក្នុងឧបចារៈស្ងប់ ព្រោះដូច្នោះការបានឈាន និងសមាបត្តិលោកទើបពោលថា **បដិបស្សទ្ធិវិមោក្ខ** ការរួច

ផុតជាការរម្ងាប់ ។

បទថា **អជ្ឈត្តំ** ក្នុងខាងក្នុង គឺប្រព្រឹត្តទៅព្រោះជាប់នឹងខ្លួន ។ បទថា **បច្ចត្តំ** ចំពោះខ្លួន គឺ ប្រព្រឹត្តទៅចំពោះខ្លួន ។ លោកសម្ដែងខាងក្នុងជាប់ដោយខ្លួន សូម្បីដោយបទទាំងពីរនោះ ។ បទថា **នីលនិមិត្តំ** និមិត្តពណ៌ខៀវ គឺ ពណ៌ខៀវនោះឯង ។ បទថា **នីលសញ្ញំ បដិលភតិ** បាននីលសញ្ញា គឺ បានសញ្ញាពណ៌ខៀវក្នុងនីលនិមិត្តនោះ ។ បទថា **សុគ្គហិតំ ករោតិ** ធ្វើនិមិត្តនោះឲ្យជាការកាន់យកល្អហើយ គឺ ធ្វើឲ្យជាការកាន់យកដោយល្អក្នុងបរិកម្មភូមិ ។ បទថា **សូបធារិតំ ឧបធារេតិ** ទ្រទ្រង់ចាំទុកល្អហើយ គឺ ទ្រទ្រង់ចាំធ្វើទុកដោយល្អក្នុងឧបចារភូមិ ។ បទថា **ស្វាវត្ថិតំ អវត្ថាបេតិ** កំណត់ទុកល្អហើយ គឺ កាត់ក្ដីដោយល្អក្នុងអប្បនាភូមិ ។ បាឋៈថា **វវត្ថាបេតិ** ខ្លះ ។ ពិតណាស់ ភិក្ខុកាលធ្វើនីលបរិកម្មក្នុងខាងក្នុង រមែងធ្វើសក់ល្អ ឬដួងភ្នែក ។ បទថា **ពហិទ្ធា នីលនិមិត្តេ** ក្នុងនិមិត្តពណ៌ខៀវខាងក្រៅ គឺ ក្នុងនីលកសិណណាមួយ បណ្ដាផ្កាឈើពណ៌ខៀវ សម្ពត់ពណ៌ខៀវ ធាតុពណ៌ខៀវ ។ បទថា **ចិត្តំ ឧបសំហរតិ** គឺ ប្រមូលចិត្តទៅ ។ សូម្បីក្នុងពណ៌លឿងជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **អាសេវតិ** រមែងសេព គឺ សេពសញ្ញានោះឯងអំពីដើម ។



បទថា **ភាវេតិ** គឺ រមែងចម្រើន ។ បទថា **ពហុលីករោតិ** ធ្វើឲ្យច្រើន ៗ គឺ ធ្វើរឿយ ៗ ។ បទថា **រូបំ** បានដល់ រូបមាននិមិត្តពណ៌ខៀវ ។ បទថា **រូបសញ្ញី** គឺ មានការសម្គាល់ថា ជារូប ការសម្គាល់ ក្នុងរូបនោះ ឈ្មោះថា **រូបសញ្ញា** ឈ្មោះថា **រូបសញ្ញី** ព្រោះមានរូបជាសញ្ញា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា មាននិមិត្តពណ៌លឿងក្នុងខាងក្នុង ភិក្ខុកាលធ្វើបីតបរិកម្ម រមែងធ្វើត្រង់ខ្លាញ់ ឬត្រង់សម្បុរ ឬត្រង់ភ្នែកពណ៌លឿង ។ កាលធ្វើលោហិតបរិកម្ម រមែងធ្វើត្រង់សាច់ ឈាម អណ្ដាត បាតដៃ បាតជើង ឬត្រង់ភ្នែកពណ៌ក្រហម កាលធ្វើឱទាតបរិកម្ម រមែងធ្វើត្រង់ឆ្អឹង ធ្មេញ ក្រចក ឬក្នុងកន្លែងភ្នែកពណ៌ស ។ បទថា **អជ្ឈត្តំ អរូបំ** មិនមានរូបក្នុងខាងក្នុង សេចក្ដីថា មិនមានរូបនិមិត្តក្នុងខាងក្នុង ។

បទថា **មេត្តាសហគតេន** ប្រកបដោយមេត្តា គឺ ប្រកបដោយមេត្តាដោយអំណាចនៃបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន និងចតុ-ត្ថជ្ឈាន ។ បទថា **ចេតសា** គឺ មានចិត្ត ។ បទថា **ឯកំ ទិសំ** រហូតទិសមួយ លោកពោលសំដៅដល់សត្វមួយ ដែលកំណត់គ្រាដំបូងនៃទិសមួយ ដោយអំណាចនៃការផ្សាយទៅ ញុំាងសត្វដែលមិនជាប់ដោយ

ទិសមួយ ៗ បទថា **ផរិត្វា** ផ្សាយទៅហើយ គឺ ពាល់ត្រូវធ្វើឲ្យជាអារម្មណ៍ ៗ បទថា **វិហរតិ** នៅ គឺ ញុំាងការនៅដោយឥរិយាបថដែលតាំងមាំដោយព្រហ្មវិហារឲ្យប្រព្រឹត្តទៅ ៗ បទថា **តថា ទុតិយំ** ទិសទីពីរក៏ដូចគ្នា គឺ ផ្សាយទៅរហូតទិសណាមួយក្នុងបណ្តាទិសទាំងឡាយមានទិសខាងកើតជាដើមយ៉ាងណា ទិសទី ២ ទី ៣ ទី ៤ ដែលជាលំដាប់នោះ ក៏ដូច្នោះដែរ ៗ បទថា **ឥតិ ឧទ្ធំ** ទាំងខាងលើ លោកអធិប្បាយថា ទិសខាងលើដោយន័យនេះដូចគ្នា ៗ បទថា **អធោ តិរិយំ** ទិសខាងក្រោម កណ្តាល ខាងទទឹង គឺ សូម្បីទិខាងក្រោម សូម្បីទិសទទឹង ក៏យ៉ាងនោះដូចគ្នា ៗ

ម្យ៉ាងទៀត ក្នុងបទទាំងនោះ បទថា **អធោ** គឺ ខាងក្រោម ៗ បទថា **តិរិយំ** គឺ តូច សេចក្តីថា ញុំាងចិត្តសហគតៈដោយមេត្តាឲ្យស្ទុះទៅខ្វះ ឲ្យស្ទុះត្រឡប់ខ្វះ ក្នុងទិសទាំងពួង ដូចឲ្យសេះរត់ទៅរត់មកក្នុងបរិវេណរបស់សេះដូច្នោះ ៗ

ដោយហេតុត្រឹមប៉ុណ្ណេះ លោកកំណត់កាន់យកទិសមួយ ៗ ហើយសម្តែងការផ្សាយមេត្តាទៅដោយកំណត់ ៗ ចំណែកបទមានជាអាទិ៍ថា **សព្វធិ** ក្នុងទីគ្រប់ស្ថានលោកពោលដើម្បីសម្តែងដោយមិនកំណត់ ៗ បទថា **សព្វធិ** គឺ ក្នុងទីទាំងពួង ៗ បទថា **សព្វត្តតាយ**



ទូទាំងសត្វគ្រប់ជំពូក គឺ គ្រប់ខ្លួនក្នុងប្រភេទសត្វ មានអាក្រក់ កណ្តាល ប្រសើរ មិត្រ សត្រូវ និងភាពជាកណ្តាលជាដើមទាំងពួង អធិប្បាយថា ព្រោះមិនធ្វើការបែងចែកថា នេះជាសត្វដទៃ ជាអ្នកស្មើនឹងខ្លួន ៗ ម្យ៉ាងវិញទៀត បទថា **សព្វត្តតាយ** គឺ ដោយភាពជាអ្នកមានចិត្តរួមនៅទាំងអស់ អធិប្បាយថា មិនរាយមាយទៅក្នុងខាងក្រៅសូម្បីបន្តិចបន្តួច ៗ បទថា **សព្វាវន្តំ** លោក គឺ សត្វគ្រប់ជំពូក អធិប្បាយថា ប្រកបដោយសត្វទាំងពួង ៗ ចុះថា **សព្វវន្តំ** ខ្វះ ៗ បទថា **លោកំ** បានដល់ សត្វលោក ម្យ៉ាងទៀង ក្នុងនិទ្ទេសនេះ លោកពោលថា **មេត្តាសហគតេន** ដោយចិត្តប្រកបដោយមេត្តាទៀត ព្រោះសម្តែងបរិយាយដោយបទមានជាអាទិ៍យ៉ាងនេះថា **វិបុលេន** ដ៏ធំទូលាយ ឬព្រោះក្នុងបទនេះ លោកមិនពោល **តថា** សព្ទ ឬ **ឥតិ** សព្ទទៀត ដូចក្នុងការផ្សាយទៅដោយកំណត់ ដូច្នោះ លោកទើបពោលបទថា **មេត្តាសហគតេន ចេតសា** ដោយចិត្តប្រកបដោយមេត្តាទៀត ឬលោកពោលបទនេះដោយការសរុប ៗ ក្នុងបទថា **វិបុលេន** នេះ គប្បីឃើញភាពធំទូលាយដោយការផ្សាយទៅ គប្បីឃើញចិត្តនោះដល់ភាពជាធំដោយភូមិ ៗ ពិតណាស់ ចិត្តនោះដល់ភាវៈប្រព្រឹត្តទៅជាធំ ព្រោះអាចគ្របសង្កត់កិលេសបាន ព្រោះមានផលទូលំទូលាយ និង

ព្រោះការជាប់បន្តគ្នាយូរ ។ម្យ៉ាងទៀត ចិត្ត ឈ្មោះថា **មហគ្គតំ** ព្រោះដល់ គឺ ដំណើរទៅដោយឆន្ទៈ វីរិយៈ ចិត្ត និងបញ្ញាដ៏ធំក្រៃលែង ។ ឈ្មោះថា **អប្បមាណំ** រកប្រមាណមិនបាន ដោយអំណាចនៃភាពជំនាញ និងដោយអំណាចនៃសត្តារម្មណ៍ដែលប្រមាណមិនបាន ។ ឈ្មោះថា **អវេរំ** មិនមានពៀរ ព្រោះលះសត្រូវ គឺ ព្យាបាទ ។ ឈ្មោះថា **អព្យាបជ្ឈំ** មិនមានការបៀតបៀន ព្រោះលះទោមនស្សចេញបាន លោកអធិប្បាយថា មិនមានទុក្ខ ។ បទថា **អប្បដិកូលា ហោន្តិ** សត្វទាំងឡាយមិនគួរខ្ពើមរអើម គឺ សត្វទាំងឡាយមិនជាទីខ្ពើមរអើមចិត្តរបស់ភិក្ខុ ហើយរមែងឧបដ្ឋាក សូម្បីក្នុងបទដ៏សេសគប្បីប្រកបដោយករុណា មុទិតា និងឧបេក្ខា ដោយន័យដូចពោលហើយនោះឯង ។ ឈ្មោះថា មិនមានពៀរ ព្រោះលះសត្រូវ គឺ ការបៀតបៀនដោយករុណា ។ ព្រោះលះសត្រូវ គឺ ការច្រណែនដោយមុទិតា ។

បទថា **ឧបេក្ខាសហគតេន** គឺ មានចិត្តប្រកបដោយឧបេក្ខាដោយអំណាចនៃចតុត្ថជ្ឈាន ។ ឈ្មោះថា មិនមានពៀរ ព្រោះលះសត្រូវ គឺ រាគៈ ។ ឈ្មោះថា មិនបៀតបៀន ព្រោះលះសោមនស្សទាក់ទងនឹងគេហសិតៈ (កាមគុណ) អកុសលសូម្បីទាំងអស់ឈ្មោះថា មានការបៀតបៀន ព្រោះប្រកបដោយសេចក្តីក្តៅក្រហាយ គឺ កិលេស



នេះជាសេចក្តីពិសេសរបស់បទនោះ ។

បទថា **សព្វសោ** គឺ ដោយអាការទាំងពួង ឬនៃសញ្ញាទាំងពួង សេចក្តីថា នៃសញ្ញាមិនមានសល់ ។ បទថា **រូបសញ្ញានំ** រូបសញ្ញា គឺ រូបាវចរឈាន ដូចដែលពោលមកហើយដោយមាតិកាថា សញ្ញា និងអារម្មណ៍របស់រូបាវចរឈាននោះ ។ ពិតណាស់ សូម្បីរូបាវចរ-ឈាន លោកពោលថា រូប ក្នុងបទមានជាអាទិ៍ថា **រូបី រូបានិ បស្សតិ** ភិក្ខុមានរូបរមែងឃើញរូបទាំងឡាយ សូម្បីអារម្មណ៍របស់រូបាវចរ-ឈាន លោកក៏ពោលថា រូប ក្នុងបទមានជាអាទិ៍ថា **ពហិទ្ធា រូបានិ បស្សតិ សុវណ្ណទុព្វណ្ណានិ** ភិក្ខុឃើញរូបទាំងឡាយក្នុងខាងក្រៅមានសម្បុរស្អាត និងសម្បុរអាក្រក់ ព្រោះដូច្នោះ ក្នុងទីនេះ បទថា **រូប-សញ្ញានំ** នេះ ជាឈ្មោះរបស់រូបាវចរឈាន ដូចដែលលោកពោលហើយដោយមាតិកាថា **សញ្ញា** យ៉ាងនេះថា **រូបេ សញ្ញា រូបសញ្ញា** ការសម្គាល់ក្នុងរូប ឈ្មោះរូបសញ្ញា ។ ឈ្មោះថា **រូបសញ្ញំ** ព្រោះមានរូបជាសញ្ញា លោកអធិប្បាយថា រូប ជាឈ្មោះរបស់ភិក្ខុនោះ គប្បីជ្រាបថា បទនេះ ជាឈ្មោះរបស់អារម្មណ៍ ដែលជាប្រភេទមានបឋវី-កសិណជាដើម ដោយប្រការដូច្នេះ ។

បទថា **សមតិក្កមា** ព្រោះកន្លង គឺ ព្រោះប្រាសចាកតម្រេក

និងព្រោះរំលត់តណ្ហា លោកអធិប្បាយទុកដូចម្តេច ។ លោកអធិប្បាយទុកថា ភិក្ខុព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះហេតុប្រាសចាកតម្រេក ព្រោះរំលត់ រូបសញ្ញា ពោលគឺ ឈាន ១៥ ដោយអំណាចនៃកុសល វិបាក កិរិយាទាំងនេះ និងរូបសញ្ញា ពោលគឺ អារម្មណ៍ ៩ ដោយអំណាចបឋវីកសិណជាដើមទាំងនេះ ឬរូបសញ្ញាមិនមានចំណែកសល់ ដោយអាការទាំងពួង ចូលដល់អាកាសានញ្ចាយតនៈ ព្រោះមិនអាចចូលដល់រូបសញ្ញានោះ ព្រោះនៅមិនទាន់ឈានកន្លងរូបសញ្ញាបាន ដោយប្រការទាំងពួង ។

ម្យ៉ាងទៀត ព្រោះសមាបត្តិនោះ គប្បីសម្រេចដោយការឈានកន្លងអារម្មណ៍ មិនមែនដូចបឋមជ្ឈានជាដើម ក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ។ ការឈានកន្លងសញ្ញា រមែងមិនមានដល់អ្នកនៅមិនទាន់ប្រាសចាកតម្រេកក្នុងអារម្មណ៍ ដូច្នោះ គប្បីជ្រាបថា លោកធ្វើការពណ៌នាសេចក្តីនេះ សូម្បីដោយអំណាចនៃការឈានកន្លងអារម្មណ៍ ។

បទថា **បដិឃសញ្ញានំ អត្ថង្គមា** ព្រោះរលត់បដិឃសញ្ញា គឺ សញ្ញាកើតការប៉ះខ្ទប់វត្ថុ មានចក្ខុជាដើម ឈ្មោះថា បដិឃសញ្ញា ។ បទនេះជាឈ្មោះរបស់រូបសញ្ញាជាដើម ។ ព្រោះរលត់ ព្រោះលះ ព្រោះមិនឲ្យកើតបដិឃសញ្ញា ១០ ដោយប្រការទាំងពួង គឺ កុសលវិបាក



នៃសញ្ញាទាំងនោះ ៥ អកុសលវិបាក ៥ លោកអធិប្បាយថា ធ្វើមិនឲ្យប្រព្រឹត្តទៅបាន ម្យ៉ាងទៀត សញ្ញាទាំងនេះ រមែងមិនមានសូម្បីដល់អ្នកចូលដល់បឋមជ្ឈានជាដើមដោយពិត ព្រោះក្នុងសម័យនោះ ចិត្តមិនប្រព្រឹត្តទៅដោយអំណាចនៃទ្វារ ៥ សូម្បីដូច្នោះ ដើម្បីឲ្យកើតឧស្សាហៈក្នុងឈាននេះ ដូចក្នុងចតុត្ថជ្ឈាននៃសុខ និងទុក្ខដែលលះបានហើយក្នុងទីដទៃ និងដូចក្នុងតតិយមគ្គនៃសក្កាយទិដ្ឋិជាដើម គប្បីជ្រាបពាក្យនៃសញ្ញាទាំងនោះក្នុងទីនេះ ដោយអំណាចនៃការសរសើរឈាននេះ ។

ម្យ៉ាងទៀត សញ្ញាទាំងនោះ មិនមានដល់អ្នកចូលដល់រូបាវចរក៏ពិតមែនហើយ សូម្បីដូច្នោះ រមែងមិនមាន ព្រោះលះបានហើយក៏មិនមែន ព្រោះការចម្រើនរូបាវចរៈ រមែងមិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកក្នុងរូប ព្រោះនៅជាប់ក្នុងរូប សញ្ញាទាំងនោះ ទើបនៅប្រព្រឹត្តទៅ ចំណែកភាវនានេះ នៅប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកក្នុងរូប ព្រោះដូច្នោះ ទើបគួរពោលថា សញ្ញាទាំងនោះ លះបានហើយក្នុងបទនេះ មិនមែនពោលតែម្យ៉ាង សូម្បីដើម្បីទ្រទ្រង់ទុកយ៉ាងនេះដោយចំណែកមួយផង ព្រោះនៅលះសញ្ញាទាំងនោះមិនបានមកពីមុន ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា អ្នកចូលដល់បឋមជ្ឈានដូចជាបន្លា ។ ម្យ៉ាងទៀត ព្រោះលះបានហើយក្នុងទីនេះ ព្រះដ៏មានព្រះភាគជាម្ចាស់

ទើបត្រាស់ដល់សេចក្តីដែលអរូបសមាបត្តិមិនញាប់ញ័រ និងសេចក្តីដែលផុតទៅយ៉ាងស្ងប់ ។

បទថា **នានត្តសញ្ញានំ អមនសិការា** ព្រោះមិនមនសិការដល់នានត្តសញ្ញា គឺ សញ្ញាប្រព្រឹត្តទៅក្នុងគោចរផ្សេង ៗ គ្នា ឬសញ្ញាមានសេចក្តីផ្សេង ៗ គ្នា ព្រោះសញ្ញាទាំងនោះប្រព្រឹត្តទៅក្នុងគោចរមានសភាពផ្សេង ៗ គ្នា ដែលជាសេចក្តីផ្សេងគ្នា មានរូបសញ្ញាជាដើម និងព្រោះសញ្ញា ៤៤ យ៉ាងនេះ គឺ កាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសល-វិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១ មានសេចក្តីផ្សេងគ្នា មានសភាពផ្សេងគ្នា មិនដូចគ្នា ដូច្នោះលោកទើបពោលថា **នានត្តសញ្ញា** ព្រោះមិនមនសិការ មិននឹកគិត និងមិនឲ្យកើតក្នុងចិត្តនៃនានត្តសញ្ញាទាំងនោះដោយប្រការទាំងពួង ព្រោះមិននឹកគិតដល់សញ្ញាទាំងនោះ មិនឲ្យកើតក្នុងចិត្ត មិនមនសិការ មិនពិចារណា លោកទើបពោលថា **តស្មា**ម្យ៉ាងទៀត ព្រោះរូបសញ្ញា និងបដិឃសញ្ញាមុនមិនមាន សូម្បីក្នុងភពដែលកើតដោយឈាននេះ មិនចាំបាច់ពោលថ្វីក្នុងកាលចូលដល់ឈាននេះ ក្នុងភពនោះ ដូច្នោះ លោកទើបពោល ការមិនមានសូម្បីដោយចំណែកទាំងពីរ គឺ ព្រោះឈានកន្លង ព្រោះរលត់សញ្ញា



ទាំងនោះ ។

ពិតណាស់ សូម្បីក្នុងនិទ្ទេសនោះ ភិក្ខុកាលចូលដល់ឈាននេះហើយរមែងចូលដល់ ព្រោះមនសិការសញ្ញាទាំងនោះ ។ តែកាលមនសិការសញ្ញាទាំងនោះ ក៏នៅជាអ្នកមិនចូលដល់ ។ ម្យ៉ាងទៀតក្នុងនិទ្ទេសនេះ លោកពោលដល់ការលះរូបាវចរធម៌ទាំងពួង ដោយបទនេះថា **រូបសញ្ញានំ សមតិក្កមា** ព្រោះកន្លងរូបសញ្ញា ដូច្នេះដោយសង្ខេប ។ ដោយបទនេះថា **បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា** ព្រោះរលត់បដិឃសញ្ញា ព្រោះមិនមានមនសិការនាន-ត្តសញ្ញា គប្បីជ្រាបថា លោកពោលការលះ និងការមិនមនសិការចិត្តចេតសិកដែលជាកាមាវចរទាំងពួង ។

ក្នុងបទថា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុតនេះ គប្បីជ្រាបសេចក្តីដូច្នេះ ឈ្មោះថា **អនន្តោ** ព្រោះអាកាសនោះមិនប្រាកដថាកើត ឬវិនាសព្រោះត្រឹមតែជាបញ្ញត្តិ ឈ្មោះថា **អនន្តោ** សូម្បីដោយអំណាចការផ្សាយទៅមិនមានទីបំផុត ។ ពិតណាស់ ព្រះយោគាវចរនោះ រមែងមិនផ្សាយទៅដោយឯកទេស រមែងផ្សាយទូទៅ ។ បទថា **អាកាសោ** គឺ អាកាសដែលបើកកសិណឡើង ។ បទមានជាអាទិ៍ថា **អាកាសានញ្ចាយតនំ** មានសេចក្តីដូចបានពោលហើយ ។

បទថា **ឧបសម្បជ្ជ វិហរតិ** ចូលដល់ គឺ ចូលដល់អាយតនៈនោះហើយ ឲ្យសម្រេចនៅដោយឥរិយាបថដែលសមគួរនោះ ។ ឈ្មោះថា **សមាបត្តិ** ព្រោះគួរចូលដល់អាយតនៈនោះឯង ។

បទថា **អាកាសានញ្ចាយតនំ សមតិក្កម្ម** ព្រោះកន្លងអាកាសានញ្ចាយតនៈ សូម្បីឈាន សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ដោយន័យដូចពោលហើយក្នុងកាលមុន ។ ពិតណាស់ សូម្បីអារម្មណ៍ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ដោយន័យដែលពោលហើយក្នុងកាលមុន ព្រោះអាកាសានញ្ចៈ ( ភាវៈទទេនៃអាកាស ) នោះ ជាអាយតនៈដោយអត្ថថា ជាទីតាំង ព្រោះជាអារម្មណ៍របស់អរូបឈានទីមួយ ដូចទីនៅរបស់ទេព ដូច្នោះ ។ ម្យ៉ាងទៀត ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអាកាសានញ្ចៈ ( ភាវៈទទេនៃអាកាស ) នោះ ជាអាយតនៈដោយអត្ថថា ជាកន្លែងកើត ព្រោះជាហេតុកើតរបស់ឈាននោះ ដូចបទមានជាអាទិ៍ថា **កម្ពោជា អស្សានំ អាយតនំ** កម្ពោជនគរ ជាកន្លែងកើតរបស់សេះទាំងឡាយ ។

ព្រះយោគាវចរគួរកន្លងសូម្បីទាំងពីរយ៉ាង គឺ ឈាន និងអារម្មណ៍ ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការហើយ ចូលដល់វិញ្ញាណញ្ចាយតនៈនេះ ដូច្នោះ គប្បីជ្រាបថា លោកធ្វើសូម្បី



ទាំងពីរយ៉ាងនេះរួមគ្នា ហើយពោលបទនេះថា **អាកាសានញ្ចាយតនំ សមតិក្កម្ម** ។ បទថា **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត វិញ្ញាណនោះឯង លោកពោលថា កិក្ខុមនសិការវិញ្ញាណដែលផ្សាយទៅថា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុតថា **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត ឬឈ្មោះថា **អនន្តំ** ដោយអំណាចមនសិការ ។ ពិតណាស់ ព្រះយោគាវចរនោះ កាលមនសិការ អាកាស អារម្មណ៍ និងវិញ្ញាណនោះ ដោយមិនមានចំណែកសល់ រមែងធ្វើការមិនមានទីបំផុតទុកក្នុងចិត្ត ។ បទថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** ព្រោះកន្លងវិញ្ញាណញ្ចាយតនៈ សូម្បីឈាន សូម្បីអារម្មណ៍ ក៏ជាវិញ្ញាណញ្ចាយតនៈ តាមន័យដូចពោលហើយសូម្បីក្នុងបទនេះ និងបទមុន ។ ពិតណាស់ សូម្បីអារម្មណ៍ ក៏ជាវិញ្ញាណញ្ចាយតនៈ តាមន័យដូចពោលហើយក្នុងកាលមុន ព្រោះវិញ្ញាណញ្ចៈ ( វិញ្ញាណទទេ ) នោះ ជាអាយតនៈដោយអត្ថថា ជាទីតាំង ព្រោះជាអារម្មណ៍នៃអរូបឈានទីពីរ ។ ម្យ៉ាងទៀត ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះវិញ្ញាណញ្ចៈនោះ ជាអាយតនៈដោយអត្ថថា ជាកន្លែងកើត ព្រោះជាហេតុកើតរបស់ឈាននោះ ។ ព្រះយោគាវចរគួរកន្លងសូម្បីទាំងពីរ គឺ ឈាន និងអារម្មណ៍ ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងមិនធ្វើទុកក្នុងចិត្តហើយ

គប្បីចូលដល់អាកិញ្ចញ្ញាយតនៈនេះ ។ ព្រោះដូច្នោះ គប្បីជ្រាបថា លោកធ្វើសូម្បីទាំងពីរយ៉ាងនោះ រួមចូលគ្នា ហើយពោលបទនេះថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** ដូច្នេះ ។ បទថា **នត្ថិ កិញ្ចិ** មិនមានអ្វី លោកអធិប្បាយថា ព្រះយោគាវចរធ្វើទុកក្នុងចិត្តយ៉ាងនេះថា **នត្ថិ នត្ថិ** មិនមាន មិនមាន **សុញ្ញំ សុញ្ញំ** ទទេ ទទេ **វិវិត្តំ វិវិត្តំ** ស្ងាត់ ស្ងាត់ ។

បទថា **អាកិញ្ចញ្ញាយតនំ សមតិក្កម្ម** ព្រោះកន្លងអាកិញ្ចញ្ញាយតនៈ ( មិនមានអ្វីតិចតួចជាអារម្មណ៍ ) សូម្បីឈាន សូម្បីអារម្មណ៍ក៏ជាអាកិញ្ចញ្ញាយតនៈតាមន័យដូចពោលហើយសូម្បីក្នុងបទនេះ និងក្នុងមុននោះឯង ។ ពិតណាស់ សូម្បីអារម្មណ៍ក៏ជាអាកិញ្ចញ្ញាយតនៈ ព្រោះអាកិញ្ចញ្ញៈ (មិនមានអ្វីសល់) នោះ ជាអាយតនៈដោយអត្ថថាជាទីតាំង ព្រោះជាអារម្មណ៍នៃអរូបឈានទី ៣ តាមន័យដូចបានហើយក្នុងបទមុន ។ មយ៉ាងទៀត ឈ្មោះថា អាកិញ្ចញ្ញាយតនៈ ព្រោះអាកិញ្ចញ្ញាយតនៈនោះ ជាអាយតនៈដោយអត្ថថា ជាកន្លែងឲ្យកើត ព្រោះជាហេតុកើតនៃឈាននោះឯង ព្រោះឈានកន្លងសូម្បីទាំងពីរយ៉ាងនោះ គឺ ឈាន និងអារម្មណ៍ ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនធ្វើទុកក្នុងចិត្ត ហើយគប្បីចូលដល់នេវសញ្ញានាសញ្ញាយតនៈ ( មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ) នេះ ព្រោះដូច្នោះ គប្បី



ជ្រាបថា លោកធ្វើសូម្បីទាំងពីរយ៉ាងនោះរួមគ្នា ហើយពោលបទនេះថា **អាកិញ្ចញ្ញាយតនំ សមតិក្កម្ម** ដូច្នេះ ។ សញ្ញាវេទយិតនិរោធកថា ( ការរលត់សញ្ញាវេទនា ) លោកពោលទុកហើយក្នុងខាងក្រោយ ។

វិមោក្ខ ៧ មានជាអាទិ៍ថា **រូបី រូបានិ បស្សតិ** ( ភិក្ខុមានរូបរមែងឃើញរូបទាំងឡាយ ) ឈ្មោះថា វិមោក្ខ ព្រោះអត្ថថា រួចផុតដោយល្អចាកធម៌ជាសត្រូវទាំងឡាយ និងព្រោះអត្ថថា រួចផុតដោយល្អ ដោយអំណាចសេចក្ដីត្រេកអរក្នុងអារម្មណ៍ ។ ចំណែកនិរោធសមាបត្តិ ឈ្មោះថា **វិមោក្ខ** ព្រោះអត្ថថា រួចផុតហើយចាកចិត្ត និងចេតសិកទាំងឡាយ ។ ឈ្មោះថា **សមយវិមោក្ខ** ព្រោះរួចផុតក្នុងសម័យចូលដល់សមាបត្តិ មិនមែនរួចផុតក្នុងសម័យចេញឡើយ ។

ឈ្មោះថា **អរិយមគ្គ** ព្រោះរួចផុតតែម្យ៉ាង ដោយអំណាចនៃសមុច្ឆេទវិមុត្តិ ។ ឈ្មោះថា **សាមញ្ញផល** ព្រោះរួចផុតតែម្យ៉ាង ដោយអំណាចនៃបដិប្បស្សទ្ធិវិមុត្តិ ឈ្មោះថា **និព្វាន** ព្រោះរួចផុតតែម្យ៉ាង ដោយអំណាចនៃនិស្សរណវិមុត្តិ នេះជា **អសមយវិមោក្ខ** សាមយិកាសាមយិកវិមោក្ខ (រួចផុតមួយគ្រា និងរួចផុតមិនមួយគ្រា) ក៏ដូច្នោះដែរ ។

ឈ្មោះថា **កុប្បា** ព្រោះអាស្រ័យសេចក្ដីប្រមាទ ទើបវិនាស ។

ឈ្មោះថា **អកុប្បា** ព្រោះមិនវិនាសយ៉ាងនោះ ។ ឈ្មោះថា **លោកិយោ** ព្រោះប្រព្រឹត្តទៅតាមលោក ។ ឈ្មោះថា **លោកុត្តរោ** ព្រោះអរិយមគ្គទាំងឡាយរមែងឆ្លងលោក ឈ្មោះថា **លោកុត្តរោ** ព្រោះសាមញ្ញផលនិងនិព្វានឆ្លងទៅហើយចាកលោក ។ ឈ្មោះថា **អនាសវោ** ព្រោះអាសវៈទាំងឡាយមិនតោងយកលោកុត្តរធម៌ដ៏ខ្ពង់ខ្ពស់ ដោយតេជៈបាន ដូចសត្វរុយមិនទុំលើដុំដែកដែលក្ដៅដូច្នោះ ។

បទថា **រូបប្បដិសញ្ញុត្តោ** វិមោក្ខបដិសំយុត្តដោយរូប គឺ រូបឈាន ។ បទថា **អរូបប្បដិសញ្ញុត្តោ** វិមោក្ខដែលមិនបដិសំយុត្តដោយរូប គឺ អរូបសមាបត្តិ ។ វិមោក្ខដែលត្រូវតណ្ហាតោងយកទុកឈ្មោះថា **បណិហិតវិមោក្ខ** វិមោក្ខដែលមិនត្រូវតណ្ហាតោងយកទុកឈ្មោះថា **អប្បណិហិតវិមោក្ខ** ។ មគ្គផលឈ្មោះថា **ឯកត្តវិមោក្ខ** ព្រោះមានអារម្មណ៍ដូចគ្នា និងព្រោះសម្រេចដូចគ្នា , និព្វាន ឈ្មោះថា **ឯកត្តវិមោក្ខ** ព្រោះមិនមានទីពីរ ឈ្មោះថា **នានត្តវិមោក្ខ** ព្រោះមានអារម្មណ៍ផ្សេងគ្នា និងព្រោះមានវិបាកផ្សេងគ្នា ។

បទថា **សិយា** ប្រែថា គប្បីមាន សេចក្ដីថា គប្បីមាន គឺ មាន ១០ និងមាន ១ ។ ម្យ៉ាងទៀត បទថា **សិយា** ជាពាក្យសម្ដែងវិធីមិនមែនជាពាក្យសួរ ។ បទថា **វត្ថុវសេន** ដោយអំណាចនៃវត្ថុ គឺ



មាន ១០ ដោយអំណាចនៃវត្ថុ ១០ មាននិច្ចសញ្ញាជាដើម ។ បទថា **បរិយាយេន** ដោយបរិយាយ គឺមាន ១ ដោយបរិយាយនៃការរួបផុត ។ បទថា **សិយាតិ កថញ្ច សិយា** បទថា គប្បីមានបាន គឺ គប្បីមានបានដូចម្ដេច បានដល់ សួរថា វត្ថុណាតាំងទុកថា គប្បីមានវត្ថុនោះគប្បីមានបានដូចម្ដេច ។ បទថា **អនិច្ចានុបស្សនញាណំ** ជាបទសមាស ។ បាលីថា **អនិច្ចានុបស្សនាញាណំ** ដូច្នេះខ្លះ ។ សូម្បីក្នុងបទដ៏សេស ក៏ដូចគ្នា ។

បទថា **និច្ចតោ សញ្ញាយ** ចាកនិច្ចសញ្ញា គឺ ចាកសញ្ញាដែលប្រព្រឹត្តទៅហើយដោយភាពជារបស់ទៀង សេចក្ដីថា ចាកសញ្ញាដែលប្រព្រឹត្តទៅហើយថា ជារបស់ទៀង ។ សូម្បីក្នុងបទនេះថា **សុខតោ អត្តតោ និមិត្តតោ សញ្ញាយ** ចាកសុខសញ្ញា អត្តសញ្ញា និមិត្តសញ្ញា ក៏មានន័យនេះ ។ ម្យ៉ាងទៀត បទថា **និមិត្តតោ** គឺ ចាកនិមិត្តថាទៀង ។ បទថា **នន្ទិយា សញ្ញាយ** ចាកនន្ទិសញ្ញា គឺ ចាកសញ្ញាដែលប្រព្រឹត្តទៅហើយដោយការភ្លើតភ្លើន សេចក្ដីថា ចាកសញ្ញាដែលសម្បយុត្តដោយការភ្លើតភ្លើន ។ សូម្បីក្នុងបទនេះថា **រាគតោ សមុទយតោ អាទានតោ បណិធិតោ អភិនិវេសតោ សញ្ញាយ** ចាករាគសញ្ញា សមុទយសញ្ញា អាទានសញ្ញា បណិធិសញ្ញា អភិនិវេសសញ្ញា ក៏មានន័យនេះ ។

ម្យ៉ាងទៀត ព្រោះអនុបស្សនា ៣ យ៉ាង គឺ **ខយានុបស្សនា** ( ពិចារណាឃើញការអស់ទៅ ) **វយានុបស្សនា** ( ពិចារណាឃើញការវិនាស ) **វិបរិណាមានុបស្សនា** ( ពិចារណាឃើញការប្រែប្រួល ) ជាសេចក្ដីវិសេសនៃ **ភង្គានុបស្សនា** ដែលជាពលវប្បច្ច័យ ព្រោះជាកម្លាំងនៃអនិច្ចានុបស្សនាជាដើម ព្រោះអនិច្ចានុបស្សនាមានកម្លាំងដោយឃើញការរលត់ ក៏កាលអនិច្ចានុបស្សនាមានកម្លាំង សូម្បីការពិចារណាឃើញទុក្ខ និងអនត្តាថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ វត្ថុនោះជាអនត្តា ដូច្នេះ ក៏មានកម្លាំង ដូច្នោះកាលពោលអនិច្ចានុបស្សនាជាដើម ក៏ជាការពោលដល់អនុបស្សនាសូម្បីទាំង ៣ នោះផង ។ ម្យ៉ាងទៀត ព្រោះលោកពោលថា សុញ្ញតានុបស្សនាញាណ រួចផុតចាកសញ្ញាដោយការប្រកាន់មាំក្នុងវត្ថុដែលជាសារៈ ប្រកាន់មាំវត្ថុដោយការវង្វេង ប្រកាន់មាំវត្ថុដែលការអាល័យ ប្រកាន់មាំវត្ថុដែលជាកិលេសដែលចងចិត្ត តាមពាក្យនិយាយថា រមែងរួចផុតចាកសញ្ញាដោយការប្រកាន់មាំ លោកអធិប្បាយដូចតទៅថា រួចផុតចាកសញ្ញាដោយមិនពិចារណា ព្រោះមិនមានវត្ថុប្រកាន់មាំ ដូច្នោះគប្បីជ្រាបថា អនុបស្សនាសូម្បី ៥ មាន **អធិបញ្ញាធម្មវិបស្សនា** ជាដើម លោកមិនបានពោលទុកឡើយ ក្នុងមហាវិបស្សនា ១៨ គប្បី



ជ្រាបថា លោកមិនបានពោលដល់អនុបស្សនាទាំង ៨ នោះឡើយ ។ ពោលដល់តែអនុបស្សនា ១០ ប៉ុណ្ណោះ ។

បទថា **អនិច្ចានុបស្សនា យថាភូតំ ញាណំ** អនិច្ចានុបស្សនា-យថាភូតញាណ គឺ ការពិចារណាឃើញការមិនទៀង ជាការដឹងតាមសេចក្ដីពិត ។ សូម្បីទាំងពីរបទជាបឋមាវិភត្តិ ។ បទថា **យថាភូ-តញាណំ** លោកពោលដល់អត្ថនៃញាណ ។ សូម្បីក្នុងបទដ៏សេស ក៏យ៉ាងនេះ ។ បទថា **សម្មោហា អញ្ញាណា** ចាកការវង្វេង ចាកការមិនដឹង គឺ ចាកការមិនដឹងដែលជាការវង្វេង ។ បទថា **មុច្ចតិ** ( រួចផុត ) លោកពោលដល់អត្ថនៃវិមោក្ខ ។

បទថា **អនិច្ចានុបស្សនា អនុត្តរំ សីតិភាវំ ញាណំ** សេចក្ដីថា អនិច្ចានុបស្សនាជាញាណ ដែលមានការត្រជាក់ចិត្តដ៏ប្រសើរ ឈ្មោះថា **អនុត្តរំ** ព្រោះអត្ថថា ខ្ពង់ខ្ពស់ ដោយមាននៅក្នុងព្រះសាសនានេះប៉ុណ្ណោះ ឬឈ្មោះថា **អនុត្តរំ** ព្រោះជាបច្ច័យនៃភាពខ្ពង់ខ្ពស់ ញាណដែលមានសេចក្ដីត្រជាក់ចិត្តនោះឯង ឈ្មោះថា **សីតិភាវញ្ញាណ** ។ សីតិភាវញ្ញាណនោះ ជាញាណខ្ពង់ខ្ពស់ ពោលគឺ ពិចារណាឃើញការមិនទៀង ។ **និព្វាន** ឈ្មោះថា ជាការត្រជាក់យ៉ាងក្រៃលែង ក្នុងព្រះពុទ្ធវចនៈនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦

ប្រការ អ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់ព្រះនិព្វាន ដែលមានភាពត្រជាក់យ៉ាងកំពូល តែក្នុងទីនេះ វិបស្សនាជាការត្រជាក់យ៉ាងក្រៃលែង ។

បទថា **និច្ចតោ សន្តាបបរិឡាហទរថា មុច្ចតិ** រួចផុតចាកការក្តៅក្រហាយ ការពេលពល និងការក្រវល់ក្រវាយ ដោយភាពជាសភាវៈមិនទៀងសូម្បីក្នុងបទនេះ កិលេសដែលប្រព្រឹត្តថា ទៀង លោកពោលថា **សន្តាបោ** ព្រោះអត្ថថា ក្តៅក្រហាយក្នុងលោកនេះ និងលោកខាងមុន ។ លោកពោលថា **បរិឡាហោ** ព្រោះអត្ថថា ដុតបំផ្លាញ ។ លោកពោលថា **ទរថោ** ព្រោះអត្ថថា ក្តៅ ។

បទមានជាអាទិ៍ថា **នេក្ខម្មំ ជាយតិ ឈានំ** មានសេចក្តីដូចពោលហើយក្នុងខាងក្រោយ ។ម្យ៉ាងទៀត បទមានជាអាទិ៍ថា នេក្ខម្មៈ ក្នុងបទនេះ គឺ សមាបត្តិ ៨ ដែលជាចំណែកនៃការចាក់ធ្លុះ ។

បទថា **អនុបាទា ចិត្តស្ស វិមោក្ខោ** ( ការរួចផុតនៃចិត្តព្រោះមិនប្រកាន់មាំ ) ក្នុងទីនេះ គឺ វិបស្សនានោះឯង ។ តែក្នុងបាលីនេះថា ការនិយាយគ្នា មានរឿងនេះជាប្រយោជន៍ ការប្រឹក្សាគ្នាមានរឿងនេះជាប្រយោជន៍ នេះគឺ ការរួចផុតនៃចិត្តព្រោះមិនប្រកាន់មាំ , និព្វាន គឺ **អនុបាទា ចិត្តស្ស វិមោក្ខោ** ។ បទថា **កតិហុបាទានេហិ** គឺ ដោយឧបាទានប៉ុន្មាន ។ បទថា **កតមា ឯកុបាទា** គឺ ចាកឧបាទានមួយ



តើដូចម្តេច ។

បទថា **ឥទំ ឯកុបាទានា** គឺ ចាកឧបាទានមួយនេះ ។ ម្យ៉ាងវិញទៀត បទថា **ឥទំ** សម្ដែងដល់ញាណមុន ។ ក្នុងការរួចផុតឧបាទាននោះ មានសេចក្តីដូចតទៅនេះ ព្រោះព្រះយោគាវចរឃើញហើយ ឃើញហើយនូវការកើត និងការវិនាសរបស់សង្ខារទាំងឡាយអំពីខាងដើម ឃើញដោយអនិច្ចានុបស្សនា ខាងក្រោយឃើញការរលត់នៃសង្ខារទាំងឡាយ ហើយឃើញដោយអនិមិត្តានុបស្សនា ព្រោះអនិមិត្តានុបស្សនា ជាភាពវិសេសនៃអនិច្ចានុបស្សនា ការមិនមានតួខ្លួនជាការប្រាកដ ដោយការឃើញការកើត និងការរលត់ និងដោយកាឃើញការរលត់នៃសង្ខារទាំងឡាយ ដោយហេតុនោះ ទើបជាការលះទិដ្ឋុបាទាន និងអត្តវាទុបាទានបាន ។ ម្យ៉ាងទៀត ព្រោះលះទិដ្ឋិនោះឯង ទើបជាការលះសីលព្វតុបាទាន ព្រោះមិនមានការឃើញថាតួខ្លួនរមែងបរិសុទ្ធបានដោយសីល និងវត្ត ។ ម្យ៉ាងទៀត ព្រោះព្រះយោគាវចរឃើញការមិនមានតួខ្លួនដោយត្រង់ ដោយអនត្តានុប-ស្សនា ។ ម្យ៉ាងវិញទៀត សុញ្ញតានុបស្សនា ជាការឃើញវិសេសនៃអនត្តានុបស្សនានោះឯង ដូច្នោះ ញាណ ៤ ទាំងនេះ រមែងរួចផុតចាកឧបាទានទាំងឡាយ ៣ មានទិដ្ឋុបាទានជាដើម ។ លោកមិន

ពោលដល់ការរួចផុតចាកកាមុបាទាន ព្រោះតណ្ហាជាសត្រូវដោយត្រង់របស់អនុបស្សនា ៤ មានទុក្ខានុបស្សនាជាដើម និងចំពោះអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ព្រោះកាលព្រះយោគាវចរឃើញថា សង្ខារទាំងឡាយជាទុក្ខ ដោយទុក្ខានុបស្សនាអំពីខាងដើម និងកាលខាងជាក្រោយឃើញថា សង្ខារទាំងឡាយជាទុក្ខ ដោយអប្បណិហិតានុបស្សនា រមែងលះការប្រាថ្នាសង្ខារទាំងឡាយចេញបាន ព្រោះអប្បណិហិតានុបស្សនាជាសេចក្ដីវិសេសនៃទុក្ខានុបស្សនានោះឯង ។ មួយវិញទៀត ព្រោះកាលព្រះយោគាវចរនឿយណាយក្នុងសង្ខារទាំងឡាយដោយនិព្វិទានុបស្សនា ការប្រាសចាកតម្រេកដោយវិរាគានុបស្សនារមែងលះការប្រាថ្នាសង្ខារទាំងឡាយចេញបាន ដូច្នោះ ញាណទាំង ៤ នេះ រមែងរួចផុតចាកកាមុបាទាន ព្រោះព្រះយោគាវចររលត់កិលេសទាំងឡាយបានដោយនិរោធានុបស្សនា រមែងលះកិលេសទាំងឡាយបានដោយបដិនិស្សគ្គានុបស្សនា ដូច្នោះ ញាណទាំង ២ នេះ រមែងរួចផុតចាកឧបាទាន ៤ ដោយហេតុនោះ លោកទើបបង្ហាញវិមោក្ខ ៦៨ ដោយសេចក្ដីផ្សេងគ្នាដោយសភាវៈ និងដោយសេចក្ដីផ្សេងគ្នា ដោយអាការ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលសម្ដែងដល់ប្រធាននៃវិមោក្ខ



ទាំងឡាយ ៣ ដែលលើកឡើងសម្ដែងអំពីខាងដើមហើយ ប្រាថ្នានឹងសម្ដែងឥន្ទ្រិយវិសេស និងបុគ្គលវិសេសដែលជាប្រធាន ជាប្រមុខនៃវិមោក្ខ ទើបពោលពាក្យមានជាអាទិ៍ថា **តីណិ ខោ បនិមានិ** វិមោក្ខដែលជាប្រធានទាំង ៣ នេះឯង ។ ក្នុងបទទាំងនោះ បទថា **វិមោក្ខមុខានិ** គឺ ប្រធាននៃវិមោក្ខ ៣ ។ បទថា **លោកនិយ្យានាយ សំវត្តន្តិ** រមែងប្រព្រឹត្តទៅដើម្បីនាំចេញចាកលោក គឺ ចេញទៅចាកលោក ដែលប្រព្រឹត្តទៅក្នុងធាតុទាំង ៣[១] ។

បទថា **សព្វសង្ខារេ បរិច្ឆេទបរិវដ្ដុមតោ សមនុបស្សនតាយ** ដោយការពិចារណាឃើញសង្ខារទាំងពួង ដោយការស្ទុះទៅតាមកំណត់ គឺ ដោយការពិចារណាឃើញដោយការកំណត់ និងដោយកិរិយាស្ទុះទៅដោយអំណាចការកើត និងការវិនាសនៃសង្ខារទាំងឡាយ ។ បាឋៈថាដ៏សេសថា **លោកនិយ្យានំ ហោតិ** ជាការនាំចេញទៅចាកលោក ។

ពិតណាស់ អនិច្ចានុបស្សនាកំណត់ថា មុនការកើត សង្ខារទាំងឡាយមិនមាន ហើយស្វែងរកគតិនៃសង្ខារទាំងនោះ ពិចារណាឃើញដោយកិរិយាស្ទុះទៅ និងដោយទីបំផុតថា ខាងមុខពីការសាបសូន្យ សង្ខារទាំងឡាយ រមែងមិនមានទីទៅ រមែងអន្តរធានទៅក្នុងទីនោះៗ ឯង ។

---

“ ១ ” **អនិមិត្តធាតុ , អប្បណិហិតធាតុ , សុញ្ញតធាតុ**

ព្រោះថា សង្ខារទាំងពួងកំណត់ទីបំផុតខាងដើម ដោយការកើត កំណត់ទីបំផុតខាងចុង ដោយការវិនាស ។

បទថា **អនិមិត្តត្តាយ ច ធាតុយា ចិត្តសម្បក្ខន្ទនតាយ** ដោយកិរិយាស្ទុះទៅនៃចិត្តក្នុងអនិមិត្តធាតុ គឺ ជាការនាំចេញទៅចាកលោក ព្រោះចិត្តបង្អោនទៅក្នុងនិព្វាន សូម្បីក្នុងខណៈវិបស្សនា និងព្រោះនិព្វានធាតុ ពោលគឺ អនិមិត្តចូលទៅកាន់ចិត្ត ដោយប្រាកដដោយអាការនៃអនិមិត្ត ។ បទថា **មនោសមុត្តេជនតាយ** ដោយការអង់អាចនៃចិត្ត គឺ ដោយការតក់ស្លុត ព្រោះចិត្តរមែងតក់ស្លុតក្នុងសង្ខារទាំងឡាយដោយ ទុក្ខានុបស្សនា ។

បទថា **អប្បណិហិតាយ ច ធាតុយា** ក្នុងអប្បណិហិតធាតុ ( ធាតុដែលមិនតាំងនៅ ) គឺ និព្វានធាតុ ដែលបានដល់អប្បណិហិត ដោយប្រាកដ ដោយអាការដែលមិនជាទីតាំង ព្រោះចិត្តបង្អោនទៅក្នុងនិព្វានសូម្បីក្នុងខណៈវិបស្សនា ។ បទថា **សព្វធម្មេ** លោកមិនពោលថា **សព្វសង្ខារេ** ពោលថា **សព្វធម្មេ** ព្រោះព្រះនិព្វាន សូម្បីការមិនចូលដល់វិបស្សនា ក៏មានសភាពជាអនត្តា ។ បទថា **បរតោ សមនុបស្សនតាយ** ដោយពិចារណាឃើញដោយភាពជារបស់ដទៃ គឺ ដោយពិចារណាឃើញដោយភាពជាអនត្តាយ៉ាងនេះថា មិនមែនយើង



មិនមែនរបស់យើង ព្រោះអាស្រ័យបច្ច័យ ព្រោះមិននៅក្នុងអំណាច និងព្រោះមិនស្តាប់បង្គាប់ ។ បទថា **សុញ្ញតាយ ច ធាតុយា** ក្នុងសុញ្ញតធាតុ គឺ ក្នុងនិព្វានធាតុ ពោលគឺ សុញ្ញតា ព្រោះការប្រាកដដោយអាការជារបស់សូន្យ ព្រោះចិត្តបង្អោនទៅក្នុងនិព្វាន សូម្បីក្នុងខណៈនៃវិបស្សនា ។ ពាក្យទាំង ៣ នេះ លោកពោលដោយអំណាចនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដោយប្រការដូច្នេះ ។ ដោយហេតុនោះឯង លោកទើបពោលបទមានជាអាទិ៍ថា **អនិច្ចតោ មនសិករោតោ** កាលមនសិការដោយភាពជារបស់មិនទៀងក្នុងលំដាប់តពីនោះ ។

ក្នុងបទទាំងនោះ បទថា **ខយតោ** គឺដោយការអស់ទៅ ។ បទថា **ភយតោ** ដោយភាពជារបស់គួរភ័យ គឺ ដោយការមានភ័យ ។ បទថា **សុញ្ញតោ** ដោយភាពជារបស់សូន្យ គឺ ដោយការប្រាសចាកខ្លួន ។ បទថា **អធិមោក្ខពហុលំ** ចិត្តច្រើនដោយការបង្អោនទៅ គឺ ចិត្តច្រើនដោយសទ្ធាក្នុងការជឿព្រះដ៏មានព្រះភាគជាម្ចាស់ថា ព្រះ-ព្រះភាគជាម្ចាស់ត្រាស់ដឹងពិតហ្ន៎ ដោយការឃើញការរលត់ក្នុងខណៈដោយប្របក្សរបស់អ្នកបដិបត្តិដោយសទ្ធាថា សង្ខារទាំងឡាយរមែងបែកធ្លាយទៅ ដោយអំណាចនៃការរលត់ក្នុងខណៈ ដោយអនិច្ចានុ-

បស្សនា ។ ម្យ៉ាងវិញទៀត ចិត្តច្រើនដោយការបង្អោនទៅ ព្រោះឃើញការមិនទៀងនៃសង្ខារទាំងឡាយដែលជាបច្ចុប្បន្ន ហើយបង្អោនទៅថា សង្ខារទាំងពួងដែលជាអតីត អនាគត និងបច្ចុប្បន្ន មិនទៀងដោយអាការយ៉ាងនេះ ។ បទថា **បស្សទ្ធិពហុលំ** ច្រើនដោយសេចក្ដីស្ងប់ គឺ ចិត្តច្រើនដោយសេចក្ដីស្ងប់ ព្រោះមិនមានសេចក្ដីក្រវល់-ក្រវាយនៃចិត្ត ព្រោះលះការតាំងចិត្ត ដែលធ្វើឲ្យចិត្តកម្រើក ដោយទុក្ខានុបស្សនា ម្យ៉ាងទៀត ចិត្តច្រើនដោយសេចក្ដីស្ងប់ ព្រោះមិនមានសេចក្ដីរាយមាយ ព្រោះកើតសេចក្ដីសង្វេគ និងព្រោះតាំងសេចក្ដីសង្វេគទុកដោយប្រពៃ ដោយទុក្ខានុបស្សនា ។ បទថា **វេទពហុលំ** ច្រើនដោយការដឹង គឺ ចិត្តច្រើនដោយញាណរបស់អ្នកឃើញអន-ត្តលក្ខណៈដ៏ជ្រាលជ្រៅ ដែលមនុស្សខាងក្រៅមិនឃើញ ដោយអនត្តានុបស្សនា ។ ម្យ៉ាងវិញទៀត ចិត្តច្រើនដោយសេចក្ដីត្រេកអរនៃអ្នកត្រេកអរថា ឃើញអនត្តលក្ខណៈ ដែលលោកព្រមទាំងទេវ-លោកនៅមិនឃើញ ។

បទថា **អធិមោក្ខពហុលោ សទ្ធិន្ទ្រិយំ បដិលភតិ** អ្នកច្រើនដោយការបង្អោនចិត្តទៅ រមែងបានសទ្ធិន្ទ្រិយ គឺ ការបង្អោនចិត្តទៅក្នុងចំណែកខាងដើមប្រព្រឹត្តទៅដោយច្រើន ឈ្មោះថា សទ្ធិន្ទ្រិយ ដោយ



ការបំពេញភាវនា បុគ្គលនោះរមែងបានសទ្ធិន្ទ្រិយនោះ ។ បទថា **បស្សទ្ធិពហុលោ សមាធិន្ទ្រិយំ បដិលភតិ** អ្នកច្រើនដោយបស្សទ្ធិ រមែងបានសមាធិន្ទ្រិយ គឺ បុគ្គលអ្នកច្រើនដោយបស្សទ្ធិ រមែងបានសមាធិន្ទ្រិយនោះ ព្រោះបស្សទ្ធិជាបច្ច័យ ដោយការបំពេញភាវនាដោយបាលីថា អ្នកមានកាយស្ងប់រមែងសោយសុខ ចិត្តរបស់អ្នកមានសេចក្ដីសុខរមែងតាំងមាំ ។ បទថា **វេទពហុលោ បញ្ញិន្ទ្រិយំ បដិ-លភតិ** ការដឹងក្នុងចំណែកខាងដើមប្រព្រឹត្តទៅច្រើន ឈ្មោះថាបញ្ញិន្ទ្រិយ ដោយការបំពេញភាវនា បុគ្គលនោះរមែងបានបញ្ញិន្ទ្រិយនោះ ។ បទថា **អាធិបតេយ្យំ ហោតិ** ឥន្ទ្រិយដែលជាធំ គឺ សូម្បីឆន្ទៈជាដើម ជាធំ ឥន្ទ្រិយរមែងជាធំ ជាប្រធាន ដោយអំណាចញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេចបាន ។ បទថា **ភាវនាយ** ជាសត្តមីវិភត្តិឬដើម្បីប្រយោជន៍ដល់ការចម្រើនឲ្យក្រៃលែង ៗ ឡើងទៅ ។ បទថា **តទន្វយានិ ហោន្តិ** គឺ ទៅតាមឥន្ទ្រិយនោះ ប្រព្រឹត្តទៅតាមឥន្ទ្រិយនោះ ។ បទថា **សហជាតប្បច្ចយា ហោន្តិ** ជាសហជាតប្បច្ច័យ ( បច្ច័យកើតរួមគ្នា ) គឺ កាលកើតរមែងជាឧបការៈ ព្រោះការដែលកើតរួមគ្នា ដូចប្រទីបជាឧបការៈដល់ពន្លឺ ដូច្នោះ ។ បទថា **អញ្ញមញ្ញ-ប្បច្ចយា ហោន្តិ** ជាអញ្ញមញ្ញប្បច្ច័យ ( ជាបច្ច័យដល់គ្នានឹងគ្នា ) គឺ

ជាឧបការៈដល់គ្នានឹងគ្នា ដោយការជួយឲ្យកើត ដូចឈើ ៣ កំណាត់ដែលជួយគ្នានឹងគ្នា ។ បទថា **និស្សយប្បច្ចយា ហោន្តិ** ជានិស្សយប្បច្ច័យ ( បច្ច័យដែលអាស្រ័យគ្នា ) គឺ ជាឧបការៈ ដោយអាការតាំងចិត្ត និងដោយអាការជាទីអាស្រ័យ ដូចផែនដីជាដើម ជាឧបការៈរបស់ការលូតលាស់នៃដើមឈើ ។ បទថា **សម្បយុត្តបច្ចយា ហោន្តិ** ជាសម្បយុត្តប្បច្ច័យ ( បច្ច័យដែលប្រកបគ្នា ) គឺ ជាឧបការៈដោយភាពជាសម្បយុត្តប្បច្ច័យ ពោលគឺ មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នា រលត់ព្រមគ្នា ។

បទថា **បដិវេធកាលេ** ក្នុងកាលចាក់ធ្លុះ គឺ ក្នុងកាលចាក់ធ្លុះសច្ចៈក្នុងខណៈនៃមគ្គ ។ បទថា **បញ្ញិន្ទ្រិយំ អាធិបតេយ្យំ ហោតិ** បញ្ញិន្ទ្រិយជាធំ គឺ បញ្ញិន្ទ្រិយនោះឯង ធ្វើនិព្វានឲ្យជាអារម្មណ៍ក្នុងខណៈនៃមគ្គ រមែងជាធំដោយអំណាចធ្វើកិច្ច គឺ ឃើញសច្ចៈ និងដោយអំណាចធ្វើកិច្ច គឺ លះកិលេស ។ បទថា **បដិវេធាយ** នៃការចាក់ធ្លុះ គឺ ដើម្បីត្រូវការចាក់ធ្លុះសច្ចៈ ។ បទថា **ឯករសា** មានរសដូចគ្នា គឺ ដោយវិមុត្តិរស ។ បទថា **ទស្សនដ្ឋេន** ព្រោះអត្ថថា ឃើញ គឺ ព្រោះអត្ថថា ឃើញសច្ចៈ ។

បទថា **ឯវំ បដិវិជ្ឈន្តោបិ ភាវេតិ ភាវេន្តោបិ បដិវិជ្ឈតិ**



ដោយអាការយ៉ាងនេះ សូម្បីបុគ្គលអ្នកចាក់ធ្លុះ ក៏រមែងចម្រើន សូម្បីបុគ្គលអ្នកចម្រើន ក៏រមែងចាក់ធ្លុះ លោកពោលដើម្បីសម្តែងការប្រព្រឹត្តទៅទាំងពួងនៃការចម្រើន និងការចាក់ធ្លុះដូចគ្នាប៉ុណ្ណោះក្នុងខណៈនៃមគ្គ ។ លោកប្រកប **អបិ** សព្ទ ក្នុងបទថា **បដិវេធកាលេបិ** ព្រោះបញ្ញិន្ទ្រិយនោះឯងជាធំ សូម្បីក្នុងខណៈនៃវិបស្សនា ដោយអនត្តានុបស្សនា ។

បទថា **អនិច្ចតោ មនសិករោតោ កតមិន្ទ្រិយំ អធិមត្តំ ហោតិ** កាលមនសិការដោយភាពជារបស់មិនទៀង ឥន្ទ្រិយអ្វីមានប្រមាណក្រៃលែង លោកពោលដើម្បីសម្តែងគុណវិសេស ដោយអំណាចនៃឥន្ទ្រិយ ។ ក្នុងបទទាំងនោះ បទថា **អធិមត្តំ** គឺ ក្រៃលែង ។ ក្នុងបទនោះ គប្បីជ្រាបសេចក្តីដែលសទ្ធិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយមានប្រមាណក្រៃលែង ដោយអំណាចការព្រងើយកន្តើយក្នុងសង្ខារ ។

ក្នុងបទថា **សទ្ធាវិមុត្តោ** បង្អោនចិត្តជឿនេះ លោកពោលថា ជាសទ្ធាវិមុត្ត ក្នុងឋានៈ ៧ ទាំងនេះ វៀរសោតាបត្តិមគ្គ ព្រោះសូម្បីកាលលោកពោលមិនប្លែកគ្នាក្នុងបទនេះ ក៏ពោលប្លែកគ្នាក្នុងបទតទៅ ។ លោកពោលថា បុគ្គលជាសទ្ធាវិមុត្ត ព្រោះសទ្ធិន្ទ្រិយមានប្រមាណ

ក្រៃលែង មិនមែនជាសទ្ធាវិមុត្ត ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែងក្នុងទីទាំងពួង ។ អាចារ្យទាំងឡាយពោលថា ក្នុងឥន្ទ្រិយដ៏សេសសូម្បីកាលមានសមាធិន្ទ្រិយ បញ្ញិន្ទ្រិយមានប្រមាណក្រៃលែង ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែងក្នុងខណៈនៃសោតាបត្តិមគ្គ បុគ្គលក៏ជាសទ្ធាវិមុត្តិបានដូចគ្នា ។

បទថា **កាយសក្ខី ហោតិ** បុគ្គលជាកាយសក្ខី ( មានកាយជាសាក្សី ) គឺ បុគ្គលឈ្មោះថា ជាកាយសក្ខីក្នុងឋានៈ ៨ យ៉ាង ។ បទថា **ទិដ្ឋិប្បត្តោ ហោតិ** បុគ្គលឈ្មោះថា ជាទិដ្ឋិប្បត្ត ( ដល់ហើយនូវទិដ្ឋិ ) គប្បីជ្រាបតាមន័យដូចពោលហើយក្នុងសទ្ធាវិមុត្តនោះឯង ។

បទថា **សទ្ទហន្តោ វិមុត្តោតិ សទ្ធាវិមុត្តោ** បុគ្គលឈ្មោះថា សទ្ធាវិមុត្ត ព្រោះបង្អោនចិត្តជឿទៅ លោកអធិប្បាយថា ឈ្មោះថា សទ្ធាវិមុត្ត ព្រោះជឿក្នុងខណៈសោតាបត្តិមគ្គ ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែង បង្អោនចិត្តទៅក្នុងខណៈនៃផលសូម្បីទាំង ៤ ។

ឥឡូវនេះ នឹងពោលដល់ភាពជាសទ្ធាវិមុត្តិក្នុងខណៈមគ្គ ៣ ខាងលើ តែនឹងពោលសេចក្ដីដែលជាសទ្ធានុសារី ( ស្ទុះទៅតាមសទ្ធា ) ក្នុងខណៈនៃសោតាបត្តិមគ្គក្នុងខាងក្រោយ ។

បទថា **ផុដ្ឋត្តា សច្ឆិកតោតិ កាយសក្ខី** បុគ្គលឈ្មោះថា ជា



កាយសក្ខី ព្រោះធ្វើឲ្យជាក់ច្បាស់ ព្រោះជាអ្នកពាល់ត្រូវធម៌ កាលភាពនៅជាសុក្ខវិបស្សក កាលមានភាវៈដែលផលនៃឧបចារឈាន បានរូបឈាន និងអរូបឈាន បុគ្គលឈ្មោះថា ជាកាយសក្ខី ព្រោះធ្វើឲ្យជាក់ច្បាស់និព្វាន ព្រោះជាអ្នកពាល់ត្រូវផលរបស់រូបឈាន និងអរូបឈាន ។ លោកអធិប្បាយថា ជាកាយសក្ខីក្នុងការសម្ផស្សឈាន និងក្នុងនិព្វាន មានប្រការដូចពោលហើយដោយនាមកាយ ។

បទថា **ទិដ្ឋត្តា បត្តោតិ ទិដ្ឋិប្បត្តោ** បុគ្គលឈ្មោះថា ជាទិដ្ឋិបត្ត ព្រោះសម្រេចហើយ ព្រោះជាអ្នកឃើញធម៌ គឺ បុគ្គលឈ្មោះថា ជាទិដ្ឋិបត្តៈ ព្រោះសម្រេចនិព្វានដោយអំណាចនៃសោតាបត្តិផលជាដើមក្នុងខាងក្រោយ ព្រោះឃើញនិព្វានមុនដោយបញ្ញិន្ទ្រិយដែលសម្បយុត្តគ្នាក្នុងខណៈនៃសោតាបត្តិមគ្គ ។ លោកអធិប្បាយថា សម្រេចនិព្វានដោយទិដ្ឋិ គឺ បញ្ញិន្ទ្រិយ ។ តែនឹងពោលសេចក្ដីដែលជាធម្មានុសារី ( ស្ទុះទៅតាមធម៌ ) ក្នុងខណៈសោតាបត្តិមគ្គក្នុងខាងក្រោយ ។

បទថា **សទ្ទហន្តោ វិមុច្ចតីតិ សទ្ធាវិមុត្តោ** បុគ្គលឈ្មោះថា ជាសទ្ធាវិមុត្ត ព្រោះរមែងបង្អោនចិត្តជឿទៅ គឺ បុគ្គលឈ្មោះថា ជាសទ្ធាវិមុត្ត ព្រោះបង្អោនចិត្តជឿក្នុងខណៈនៃសកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ ព្រោះសេចក្ដីដែលសទ្ធិន្ទ្រិយមានប្រមាណ

ក្រៃលែង សូម្បីបង្អោនចិត្តទៅក្នុងសទ្ធិន្ទ្រិយនោះ លោកក៏ពោលថា **វិមុត្ត** ដោយអំណាចនៃការពោលតាមពិត ដោយបំណង ។ បទថា **ឈានផស្សំ** ពាល់ត្រូវឈាន គឺ ពាល់ត្រូវឈាន ៣ យ៉ាង ។ លោកពោលបទមានជាអាទិ៍ថា **ឈានផស្សំ** និងបទមានអាទិ៍ថា **ទុក្ខា សង្ខារា** មុន ហើយទើបពោលទាំងពីរបទឲ្យផ្សេងគ្នា ។ បទថា **ញាណំ ហោតិ** ជាអាទិ៍ មានសេចក្តីដូចពោលហើយក្នុងខាងក្រោយ ។ ម្យ៉ាងទៀត ក្នុងបទនេះ អាចារ្យទាំងឡាយអធិប្បាយថា បុគ្គលអ្នកបានឈាន លុះចេញហើយ ដោយទុក្ខានុបស្សនាដែលឧបត្ថម្ភដល់សមាធិន្ទ្រិយ រមែងសម្រេចមគ្គផល ។ បទថា **សិយា** ប្រែថា គប្បីមាន គប្បីកើត ។ បទនេះ ជាឈ្មោះនៃវិធីប៉ុណ្ណោះ ។ បទថា **តយោ បុគ្គលា** បុគ្គល ៣ ពួក គឺ បុគ្គល ៣ ពួក លោកពោលហើយដោយកំណត់នៃវិបស្សនា និងដោយការកំណត់នៃឥន្ទ្រិយ ។ បទថា **វត្ថុវសេន** ដោយអំណាចនៃវត្ថុ គឺ ដោយអំណាចនៃឥន្ទ្រិយវត្ថុមួយ ៗ ក្នុងអនុបស្សនា ៣ ។ បទថា **បរិយាយេន** គឺ ដោយបរិយាយនោះឯង ។ ដោយវារៈនេះ លោកសម្តែងដល់អ្វី ។ លោកសម្តែងថា លោកពោលដល់ភាពជាធំនៃឥន្ទ្រិយមួយ ៗ ដោយអនុបស្សនាមួយ ៗ ដោយយេ-កុយ្យន័យ (ន័យដោយច្រើន) និងគ្រាខ្វះភាពជាធំនៃឥន្ទ្រិយមួយ ៗ ក្នុង



អនុបស្សនាទាំង ៣ ។ ម្យ៉ាងវិញទៀត ឈ្មោះថា មានសទ្ធាវិមុត្តជាដើម រមែងមានក្នុងខណៈនៃមគ្គ និងផល សម្ទឹងដល់ភាពជាធំនៃឥន្ទ្រិយទាំងនោះៗ ក្នុងវិបស្សនា ដែលជាចំណែកខាងដើមទាំងនោះ ព្រោះមានអនុបស្សនាទាំង ៣ ក្នុងខណៈនៃវិបស្សនាដែលជាចំណែកខាងដើម ព្រោះកាលពោលយ៉ាងនេះ ភាពជាធំនៃឥន្ទ្រិយ និងបុគ្គលនិយម លោកធ្វើទុកក្នុងខាងលើនៃវិបស្សនា ដែលជាវុដ្ឋានគាមិនីក្នុងខាងក្រោយ ជាការដែលលោកធ្វើល្អហើយ មិនញាប់ញ័រឡើយ ។ ក្នុងអនន្តរវារៈ បទថា **សិយាតិ អញ្ញោយេវ** គប្បីជាយ៉ាងដទៃ គឺ គប្បីជាយ៉ាងនេះ ។ ក្នុងបទនេះលោកពោលដល់ ការកំណត់ក្នុងបទមុន ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងចំណែកបុគ្គលវិសេស ដោយអំណាចនៃមគ្គ និងផល ទើបពោលពាក្យជាដើមថា **អនិច្ចតោ មនសិករោតោ ។បេ។ សោតាបត្តិមគ្គំ បដិលភតិ** កាលមនសិការដោយភាពជារបស់មិនទៀង សទ្ធិន្ទ្រិយមានប្រមាណក្រៃលែង ព្រោះសទ្ធិ-ន្ទ្រិយមានប្រមាណក្រៃលែង បុគ្គលទើបបានសោតាបត្តិមគ្គ ។

ក្នុងបទទាំងនោះ បុគ្គលឈ្មោះថា **សទ្ធានុសារី** ព្រោះរលឹកដល់ គឺ ទៅតាមសទ្ធា ឬរលឹកដល់ព្រះនិព្វានដោយសទ្ធា ។ បទថា **សច្ឆិកតំ** ធ្វើឲ្យជាក់ច្បាស់ គឺ ធ្វើឲ្យប្រចក្ស ។ បទថា **អរហត្តំ** គឺ

អរហត្តផល ។ ឈ្មោះថា **ធម្មានុសារី** ព្រោះរលឹកដល់ធម៌ ពោលគឺ បញ្ញា ឬរលឹកដល់ព្រះនិព្វានដោយធម៌នោះ ។

ព្រះសារីបុត្តត្ថេរ បំណងនឹងពណ៌នាដល់បុគ្គលវិសេសដោយភាពវិសេសនៃឥន្ទ្រិយ ៣ ដោយបរិយាយដទៃទៀត នឹងពោលពាក្យមានជាអាទិ៍ថា **យេ ហិ កេចិ** បុគ្គលពួកណាមួយដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភាវិតា វា** ចម្រើនហើយ គឺ ចម្រើនហើយក្នុងអតីត ។ បទថា **ភាវេន្តិ វា** រមែងចម្រើន គឺ ចម្រើនក្នុងបច្ចុប្បន្ន ។ បទថា **ភវិស្សន្តិ វា** នឹងចម្រើន គឺ នឹងចម្រើនក្នុងអនាគត ។ បទថា **អធិគតា វា** សម្រេចហើយជាដើម លោកពោលដើម្បីពង្រីកអត្ថនៃបទមុន ៗ ដែលមានទីបំផុតមួយ ៗ ។ បទថា **ផស្សិតា វា** ពាល់ត្រូវហើយ គឺ ពាល់ត្រូវហើយដោយញាណផុសនា ។ បទថា **វសិប្បត្តា** ដល់ភាពជំនាញ គឺ ដល់ភាពជាឥស្សរៈ ។ បទថា **បារមិប្បត្តា** ដល់ភាពសម្រេច គឺ ដល់ទីបំផុត ។ បទថា **វេសារជ្ជប្បត្តា** ដល់ភាពក្លៀវក្លា គឺ ដល់ភាពក្លាហាន ។ សទ្ធាវិមុត្តជាដើមក្នុងទីទាំងពួងដល់ហើយ ក្នុងខណៈដែលលោកពោលទុកហើយក្នុងខាងក្រោយ ។ សតិប្បដ្ឋានជាដើម ដល់ហើយក្នុងខណៈនៃមគ្គនោះឯង ។

បទថា **អដ្ឋ វិមោក្ខេ** វិមោក្ខ ៨ គឺ បុគ្គលពួកណាមួយសម្រេច



ហើយ ដោយការសម្រេចបដិសម្ភិទាមគ្គ មានជាអាទិ៍ថា **រូបី រូបានិ បស្សតិ** ដូច្នេះ ។ បទថា **តិស្សោ សិក្ខា** សិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា សម្រេចមគ្គប៉ុណ្ណោះដេលសិក្សា ។ បទថា **ទុក្ខំ បរិជានន្តិ** កំណត់ដឹងទុក្ខជាដើម កំណត់ដឹងក្នុងខណៈនៃមគ្គនោះឯង ។ បទថា **បរិញ្ញាបដិវេធំ បដិវិជ្ឈតិ** ចាក់ធ្លុះទុក្ខសច្ចៈជាការចាក់ធ្លុះដោយបរិញ្ញា ឈ្មោះថា **បរិញ្ញាបដិវេធ** ព្រោះចាក់ធ្លុះដោយការចាក់ធ្លុះដោយបរិញ្ញា ឬគប្បីចាក់ធ្លុះដោយបរិញ្ញា ។ សូម្បីក្នុងបទដ៏សេសក៏ដូច្នោះ លោកពោលពាក្យមានជាអាទិ៍ថា **អភិញ្ញាបដិវេធ** ចាក់ធ្លុះដោយអភិញ្ញា ព្រោះឲ្យវិសេសចាកធម៌ទាំងពួងជាដើម ។ ចំណែកសច្ឆិកិរិយាបដិវេធ ការចាក់ធ្លុះដោយសច្ឆិកិរិយា គប្បីជ្រាបដោយអំណាចការសម្រេចញាណក្នុងការពិចារណានិព្វាន ក្នុងខណៈនៃមគ្គ នោះឯង ។ ក្នុងទីនេះ ជាការសម្តែងដល់អរិយបុគ្គល ៥ ទុកយ៉ាងនេះ មិនសម្តែងដល់អរិយបុគ្គល ២ ទាំងនេះ គឺ **ឧភតោភាគវិមុត្ត** និង **បញ្ញាវិមុត្ត** ។ តែក្នុងទីដទៃ លោកពោលទុកថា បុគ្គលណាមនសិការដោយភាពជាទុក្ខ ច្រើនដោយបស្សទ្ធិ រមែងបានសមាធិន្ទ្រិយ បុគ្កលនោះឈ្មោះថា កាយសក្ខីក្នុងទីទាំងពួង ចំណែកបុគ្គលសម្រេចអរូបឈានហើយ សម្រេចផលដ៏ប្រសើរ ឈ្មោះថា ឧភតោ-

ភាគវិមុត្ត ។ម្យ៉ាងទៀត បុគ្គលណាមនសិការដោយភាពជាអនត្តា ច្រើនដោយការដឹង រមែងបានបញ្ញិន្ទ្រិយ បុគ្គលនោះឈ្មោះថា **ធម្មានុសារី** ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ទិដ្ឋិបត្តៈ ក្នុងឋានៈ ៦ ឈ្មោះថា បញ្ញាវិមុត្ត ក្នុងផលដ៏ប្រសើរ ។ ក្នុងទីនេះ លោកសង្គ្រោះបុគ្គលទាំងនោះដោយ កាយសក្ខី និងទិដ្ឋិបត្ត តែដោយអត្ថ ឈ្មោះថា ឧភតោភាគវិមុត្ត ព្រោះរួចផុតដោយចំណែកពីរ គឺ ដោយអរូបឈាន និងដោយអរិយមគ្គ , ឈ្មោះថា បញ្ញាវិមុត្ត ព្រោះដឹងច្បាស់ទើបរួចផុតដោយហេតុត្រឹមប៉ុណ្ណេះ ដែលលោកសម្ដែងដល់ភាពវិសេសនៃឥន្ទ្រិយនិងបុគ្គល ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែងដល់វិមោក្ខវិសេស ដែលជាប្រធាននៃវិមោក្ខ និងបុគ្គលវិសេស ទើបពោលពាក្យមានជាអាទិ៍ថា **អនិច្ចតោ មនសិករោតោ** កាលមនសិការដោយភាពជារបស់មិនទៀង ។ ក្នុងបទទាំងនោះ បទថា **ទ្វេ វិមោក្ខា** វិមោក្ខ ២ គឺ អប្បណិហិតវិមោក្ខ និងសុញ្ញាតវិមោក្ខ ។ មគ្គបានឈ្មោះថា អនិមិត្តវិមោក្ខ ដោយអំណាចសម្រេចអនិច្ចានុបស្សនា មគ្គដែលបានឈ្មោះថា អប្បណិហិតវិមោក្ខ ដោយភាពជាគុណ ព្រោះមិនមានរាគៈ ទោសៈ មោហៈ ជាទីតាំង និងដោយអារម្មណ៍ ព្រោះធ្វើនិព្វាន ដែល



បានឈ្មោះថា អប្បណិហិត ព្រោះមិនមានបណិហិតទាំងនោះ ឲ្យជាអារម្មណ៍ ។ ម្យ៉ាងទៀត មគ្គបានឈ្មោះថា សុញ្ញតវិមោក្ខ ដោយភាពជាគុណ ព្រោះថា ទទេចាករាគៈ ទោសៈ និងមោហៈ និងដោយអារម្មណ៍ ព្រោះធ្វើនិព្វានដែលបានឈ្មោះថា សុញ្ញតៈ ព្រោះទទេចាករាគៈជាដើមនោះឯង ឲ្យជាអារម្មណ៍ ព្រោះដូច្នោះ វិមោក្ខទាំង ២ នោះ ទើបឈ្មោះថា ទៅតាមអនិមិត្តវិមោក្ខ ។ ម្យ៉ាងទៀត គប្បីជ្រាបថា បច្ច័យមានសហជាតប្បច្ច័យជាដើម សូម្បីមិនដទៃចាកមគ្គ ដែលជាអនិមិត្តៈ រមែងកើតដោយអំណាចនៃអង្គមគ្គមួយៗ របស់អង្គមគ្គ ៨ ។

បទថា **ទ្វេ វិមោក្ខា** មួយទៀត គឺ សុញ្ញតវិមោក្ខ និងអនិមិត្តវិមោក្ខ ។ ពិតណាស់ មគ្គបានឈ្មោះថា អប្បណិហិតវិមោក្ខ ដោយអំណាចនៃការដល់ទុក្ខានុបស្សនា រមែងបានឈ្មោះថា អនិមិត្តវិមោក្ខ ដោយភាវៈជាគុណ ព្រោះមិនមានរូបនិមិត្ត រាគនិមិត្ត និងនិច្ចនិមិត្តជាដើម និងដោយអារម្មណ៍ ព្រោះធ្វើនិព្វាន ពោលគឺ អនិមិត្ត ព្រោះមិនមាននិមិត្តទាំងនោះជាអារម្មណ៍ ។ គប្បីប្រកបបទដ៏សេសដោយន័យដូចពោលហើយនោះឯង ។

បទថា **ទ្វេ វិមោក្ខា** មួយទៀត គឺ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ។ ការប្រកបមានន័យដូចពោលហើយក្នុងបទនេះឯង ។

បទថា **បដិវេធកាលេ** ក្នុងកាលចាក់ធ្លុះ លោកពោលហើយតាមលំដាប់នៃឥន្ទ្រិយទាំងឡាយ ដូចបានពោលទុកហើយ ។ ម្យ៉ាងទៀត ឈ្មោះថា វិមោក្ខ រមែងមិនមានក្នុងខណៈនៃវិបស្សនា ព្រោះបណ្តាយតាមខណៈនៃមគ្គ តែលោកសម្តែងមគ្គវិមោក្ខ ដែលពោលទុកហើយ គ្រាដំបូងឲ្យប្លែកទៅចាកពាក្យថា **បដិវេធកាលេ** ។ លោកសង្ខេបវារៈម្តង ២ មានជាអាទិ៍ថា បុគ្គលណាជាសទ្ធាវិមុត្ត និងវារៈថា កាលបុគ្គលមនសិការដោយភាពជាសភាវៈមិនទៀង រមែងបានសោតាបត្តិមគ្គ តែគប្បីជ្រាបការប្រកបដោយអំណាចនៃវិមោក្ខ ដោយពិស្តារ ។ គប្បីជ្រាបវារៈមានជាអាទិ៍ថា **យេ ហិ កេចិ នេក្ខម្មំ** តាមន័យដូចពោលហើយនោះឯង ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ដែលលោកសម្តែងដល់សេចក្តីវិសេសនៃវិមោក្ខ និងបុគ្គល ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងប្រធានរបស់វិមោក្ខ និងវិមោក្ខដោយចំណែកមិនច្រើន ទើបពោលពាក្យមានជាអាទិ៍ថា **អនិច្ចតោ មនសិករោន្តោ** កាលបុគ្គលមនសិការដោយភាពមិនទៀង ។ ក្នុងបទទាំងនោះ បទថា **យថាភូតំ** តាមសេចក្តីពិត គឺ តាមសភាវៈ ។ បទថា **បជានាតិ** រមែងដឹង គឺ ដឹងដោយញាណ ។ បទថា **បស្សតិ** រមែងឃើញ គឺ ឃើញដោយញាណនោះឯង ដូចឃើញដោយចក្ខុ ។



បទថា **តទន្វយេន** គឺ ដោយការប្រព្រឹត្តទៅតាមសម្មាទស្សនៈនោះ អធិប្បាយថា ដោយទៅតាមសម្មាទស្សនៈនោះ ដែលបានឃើញហើយដោយញាណដោយប្រចក្ស ។ បទថា **កង្ខា បហីយតិ** រមែងលះបង់សេចក្តីសង្ស័យបាន គឺ សេចក្តីសង្ស័យថា ទៀង ឬមិនទៀង រមែងលះបានដោយអនិច្ចានុបស្សនា សេចក្តីសង្ស័យក្រៅនេះ រមែងលះបានដោយអនុបស្សនាក្រៅនេះ ។ បទថា **និមិត្តំ** និមិត្ត គឺ រមែងដឹងសង្ខារនិមិត្តដែលជាអារម្មណ៍តាមសេចក្តីពិត ព្រោះលះនិច្ចសញ្ញាបាន ដោយការបែកសន្តតិ និងយនៈចេញទៅ ។ បទថា **តេន វុច្ចតិ សម្មាទស្សនំ** ព្រោះហេតុនោះ លោកទើបពោលសម្មាទស្សនៈ ព្រោះដឹងតាមសេចក្តីពិតនោះ លោកទើបពោលញាណនោះថា សម្មាទស្សនៈ ។ បទថា **បវត្តំ** ការប្រព្រឹត្តទៅ គឺ ដឹងការប្រព្រឹត្តទៅ ដែលជាវិបាកសូម្បីដឹងសុខតាមសេចក្តីពិត ព្រោះលះតណ្ហា ពោលគឺ បណិធិបាន ដោយការដកសុខសញ្ញាក្នុងអាការ ដែលដឹងដល់ទុក្ខ ហើយលះសុខសញ្ញា ។ បទថា **និមិត្តញ្ច បវត្តញ្ច** រមែងដឹង រមែងឃើញនិមិត្ត និងការប្រព្រឹត្តទៅ គឺ រមែងដឹងសង្ខារនិមិត្ត និងការប្រព្រឹត្តទៅ ដែលជាវិបាកតាមសេចក្តីពិត ព្រោះលះអត្តសញ្ញា សូម្បីដោយប្រការទាំងពីរ ដោយការដកឃនៈដែលនៅរួមគ្នា ដោយមានមនសិការដល់

ធាតុផ្សេង ៗ ។ ឥឡូវនេះ លោកពោលដល់ ៣ បទប៉ុណ្ណោះ មានជាអាទិ៍ថា **យញ្ច យថាភូតំ ញាណំ** យថាភូតញាណ មិនបានពោលដល់បទដទៃ ។

បទថា **ភយតោ ឧបដ្ឋាតិ** រមែងប្រាកដដោយភាពជារបស់គួរខ្លាច គឺ និមិត្តនោះ រមែងប្រាកដជារបស់គួរខ្លាចតាមលំដាប់ ព្រោះឃើញការមិនមានសុខជានិច្ច និងតួខ្លួន ។ ដោយបទមានជាអាទិ៍ថា **យា ច ភយតូបដ្ឋានេ បញ្ញា** បញ្ញាក្នុងការប្រាកដជារបស់គួរខ្លាច លោកពោលដល់ញាណ ៣ តាំងនៅក្នុងញាណមួយ ដែលប្លែកគ្នាដោយនាទី សម្ព័ន្ធជាមួយភយតូបដ្ឋានញាណ ក្នុងវិបស្សនាញាណ ៩ ពោលគឺ បដិបទាញាណទស្សនវិសុទ្ធិ ( ការបរិសុទ្ធិនៃញាណជាគ្រឿងឃើញផ្លូវបដិបត្តិ ) ដែលលោកពោលទុកហើយ គឺ ឧទយព្វយានុបស្សនាញាណ ( ប្រាជ្ញាឃើញទាំងការកើត និងការរលត់ ) ១ ភង្គានុបស្សនាញាណ (ប្រាជ្ញាឃើញការរលត់) ១ ភយតូបដ្ឋានញាណ ( ប្រាជ្ញាឃើញសង្ខារជារបស់គួរខ្លាច ) ១ អាទីនវានុបស្សនាញាណ ( ប្រាជ្ញាឃើញទោស ) ១ និព្វិទានុបស្សនាញាណ ( ប្រាជ្ញាឃើញដល់ការនឿយណាយ ) ១ មុញ្ចិតុកម្យតាញាណ ( ប្រាជ្ញាឃើញដោយប្រាថ្នានឹងគេចចេញ ) ១ បដិសង្ខានុបស្សនាញាណ ( ប្រាជ្ញា



ឃើញដោយពិចារណារកផ្លូវ ) ១ សង្ខារុបេក្ខានុបស្សនាញាណ ( ប្រាជ្ញាឃើញដោយភាពព្រងើយកន្តើយ ) ១ អនុលោមញាណ ( ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងអរិយសច្ច ) ១ មិនពោលដល់ញាណដ៏សេស ។

ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងសេចក្តីថា សុញ្ញតានុបស្សនាញាណរួមគ្នានោះ តាំងនៅក្នុងទីជាមួយគ្នា ដោយសម្ព័ន្ធនៃអនត្តានុបស្សនាជាលំដាប់ តាំងនៅក្នុងទីបំផុតនៃអនុបស្សនា ៣ ទៀត ទើបពោលបទមានជាអាទិ៍ថា **យា ច អនត្តានុបស្សនា យា ច សុញ្ញតានុបស្សនា** ធម៌ទាំងនេះ គឺ អនត្តានុបស្សនា និងសុញ្ញតានុបស្សនា ។ ព្រោះញាណទាំង ២ នេះ ដោយអត្ថដូចគ្នា តែផ្សេងគ្នាដោយកិច្ច ។ អនិច្ចានុបស្សនា និងអនិមិត្តានុបស្សនាដោយអត្ថ ជាញាណដូចគ្នា ទុក្ខានុបស្សនា និងអប្បណិហិតានុបស្សនា ដោយអត្ថ ជាញាណដូចគ្នា ផ្សេងគ្នាដោយប្រភេទនៃកិច្ចប៉ុណ្ណោះ ដូចញាណទាំងនេះ ។ កាលលោកពោលថា អនត្តានុបស្សនា និងសុញ្ញតានុបស្សនាតាំងនៅជាមួយគ្នា ជាការដែលលោកពោលដល់ញាណ សូម្បីទាំងពីរទាំងនោះតាំងនៅជាមួយគ្នា ព្រោះមានលក្ខណៈដូចគ្នា ។

បទថា **និមិត្តំ បដិសង្ខា ញាណំ ឧប្បជ្ជតិ** ញាណ គឺ ការ

ពិចារណានិមិត្ត រមែងកើត គឺ ញាណរមែងកើត ព្រោះដឹងដោយអំណាចនៃអនិច្ចលក្ខណៈថា សង្ខារនិមិត្តមិនយឺនយូរ ប្រព្រឹត្តទៅត្រឹមជួរខណៈ សូម្បីញាណកើតឡើងខាងក្រោយ ព្រោះដឹងអំពីមុនក៏ពិតតែដូច្នោះ ដោយវោហារលោកពោលយ៉ាងនេះ ដូចបទមានជាអាទិ៍ថា មនោវិញ្ញាណ រមែងកើតព្រោះអាស្រ័យចិត្ត និងធម៌ ។ ម្យ៉ាងទៀត សូម្បី អ្នកដឹងគម្ពីរសទ្ទសាស្ត្រ រមែងប្រាថ្នាបទនេះ សូម្បីក្នុងកាលស្មើគ្នា ដូចក្នុងបទមានជាអាទិ៍ថា ការងងឹតរមែងប្រាសទៅ ព្រោះព្រះអាទិត្យរះឡើង ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា លោកពោលយ៉ាងនេះ ព្រោះធ្វើបទដើម និងបទចុង ឲ្យតែមួយដូចគ្នា ដោយឯកត្តន័យ ។ ដោយន័យនេះ គប្បីជ្រាបអត្ថក្នុងពីរបទក្រៅនេះ ។ សេចក្ដីដែលញាណ ៣ មានមុញ្ចិតុកម្យតាញាណជាដើម តាំងនៅក្នុងឋានៈជាមួយគ្នា មានន័យដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។

បទថា **និមិត្តា ចិត្តំ វុដ្ឋាតិ** ចិត្តរមែងចេញទៅចាកនិមិត្ត គឺ ចិត្តឈ្មោះថា រមែងចេញទៅចាកសង្ខារនិមិត្ត ព្រោះមិនជាប់នៅក្នុងសង្ខារនិមិត្ត ដោយឃើញទោសក្នុងសង្ខារនិមិត្ត ។ បទថា **អនិមិត្តេ ចិត្តំ បក្ខន្ទតិ** ចិត្តរមែងស្ទុះទៅក្នុងនិព្វាន ដែលរកនិមិត្តមិនបាន គឺ ចិត្តរមែងចូលកាន់និព្វានដែលរកនិមិត្តមិនបាន ដោយភាពជាបដិបក្ខ



ចំពោះសង្ខារនិមិត្ត ព្រោះចិត្តបង្អោនទៅក្នុងនិព្វាននោះ ។ សូម្បីក្នុងអនុបស្សនាទាំងពីរដ៏សេស ក៏គប្បីជ្រាបសេចក្ដីដោយន័យនេះ ។ បទថា **និរោធនិព្វានធាតុយា** ក្នុងនិព្វានធាតុដែលជាទីរំលត់ គឺ ក្នុងបទនេះ លោកពោលដល់សូម្បីអនុបស្សនាទាំងពីរគ្រាដំបូង ។ បាឋៈថា **និរោធេ** ខ្វះ ។ បទថា **ពហិទ្ធាវុដ្ឋានវិវដ្តនេ បញ្ញា** បញ្ញាក្នុងការចេញទៅ និងការគេចទៅខាងក្រៅ គឺ លោកពោលដល់គោត្រភូញាណ ដោយការសម្ពន្ធ ដោយការចេញទៅ ។ បទថា **គោត្រភូ ធម្មា** គឺ គោត្រភូញាណនោះឯង ។ ព្រោះការដែលគោត្រភូញាណ តាំងនៅដូចគ្នា ដោយប្រការក្រៅនេះ រមែងមិនគួរ ។ គប្បីជ្រាបថា លោកធ្វើជាពហុវចនៈ ដូចក្នុងបទមានជាអាទិ៍ថា ធម៌ទាំងឡាយដែលជាអសង្ខតៈ ធម៌ទាំងឡាយដែលមិនមានបច្ច័យ ឬដោយអំណាចនៃមគ្គ ៤ ព្រោះវិមោក្ខ ក៏គឺមគ្គ និងមគ្គចេញចាកចំណែកទាំងពីរ ដូច្នោះ ដោយការសម្ពន្ធនោះ លោកទើបពោលបទមានជាអាទិ៍ថា **យា ច ទិភតោវុដ្ឋានវិវដ្តនេ បញ្ញា** បញ្ញាក្នុងការចេញទៅ និងគេចចេញទៅចាកចំណែកទាំងពីរ ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែងបរិយាយក្នុងខណៈតែមួយនៃខណៈផ្សេងគ្នារបស់វិមោក្ខទាំងឡាយទៀត ទើបពោលពាក្យមានជា

អាទិ៍ថា **កតីហាការេហិ** ដោយអាការប៉ុន្មាន ។

ក្នុងបទទាំងនោះ បទថា **អាធិបតេយ្យដ្ឋេន** គឺ ដោយភាពជាធំ ។ បទថា **អធិដ្ឋានដ្ឋេន** គឺ ដោយភាពតាំងមាំ ។ បទថា **អភិនីហារដ្ឋេន** គឺ ដោយការបង្អោនចិត្តទៅដោយវិបស្សនាវីថិ ។ បទថា **និយ្យាន-ដ្ឋេន** ដោយការនាំចេញទៅ គឺ ដោយការចូលទៅដល់និព្វាន ។ បទថា **អនិច្ចតោ មនសិករោតោ** មនសិការដោយភាពមិនទៀង គឺ ក្នុងខណៈ នៃវិបស្សនាដែលជាវុដ្ឋានគាមិនីនោះឯង ។ បទថា **អនិមិត្តោ វិមោក្ខោ** អនិមិត្តវិមោក្ខ គឺ ក្នុងខណៈនៃមគ្គនោះឯង ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។ បទថា **ចិត្តំ អធិដ្ឋាតិ** រមែងតម្កល់ចិត្តទុកមាំ គឺ ធ្វើចិត្តឲ្យក្រៃលែងតាំងមាំទុក ។ អធិប្បាយថា ញុំាងចិត្តឲ្យតាំងមាំ ។ បទថា **ចិត្តំ អភិនីហរតិ** រមែងបង្អោនចិត្តទៅ គឺ បង្អោនចិត្តទៅដោយវិបស្សនាវីថិ ។

បទថា **និរោធំ និព្វានំ និយ្យាតិ** រមែងនាំចិត្តចេញទៅកាន់និព្វានដែលជាទីរំលត់ គឺ លោកសម្ដែងការដែលខណៈផ្សេងគ្នា ៤ ចំណែក ការផ្សេងគ្នាដោយអាការយ៉ាងនេះថា បុគ្គលរមែងចូលដល់និព្វាន ពោលគឺ ការរំលត់ ។

បទថា **សមោធានដ្ឋេន** ដោយការប្រជុំចុះ ព្រោះមានខណៈជា



មួយគ្នា គឺ ដោយការប្រជុំរួមគ្នា ។ បទថា **អធិគមនដ្ឋេន** ដោយការសម្រេច គឺ ដោយការត្រាស់ដឹង ។ បទថា **បដិលាភដ្ឋេន** ដោយការបាន គឺ ដោយការដល់ ។ បទថា **បដិវេធដ្ឋេន** ដោយការចាក់ធ្លុះ គឺ ដោយការចាក់ធ្លុះដោយញាណ ។ បទថា **សច្ឆិករណដ្ឋេន** ដោយការធ្វើឲ្យជាក់ច្បាស់ គឺ ដោយធ្វើឲ្យប្រចក្ស ។ បទថា **ផស្សនដ្ឋេន** ដោយការពាល់ត្រូវ គឺ ការពាល់ត្រូវដោយសម្ផស្សញាណ ។ បទថា **អភិសមយដ្ឋេន** ដោយការត្រាស់ដឹង គឺ ដោយការមកដល់ព្រមចំពោះមុខ ។ ក្នុងបទថា **សមោធានដ្ឋេន** នេះជាមូលបទ ។ បទដ៏សេស ជាវេវចនៈនៃការសម្រេច ព្រោះដូច្នោះឯង លោកទើបធ្វើការឆ្លើយបទទាំងអស់ ជាចំណែកដូចគ្នា ។ បទថា **និមិត្តា មុច្ចតិ** រមែងផុតចាកនិមិត្ត គឺ ផុតចាកនិមិត្តថា ទៀង ដោយបទនេះ លោកពោលដល់អត្ថនៃវិមោក្ខ ។ បទថា **យតោ មុច្ចតិ** រួចផុតចាកអារម្មណ៍ណា គឺ រួចផុតចាកនិមិត្តណា ។ បទថា **តត្ថ ន បណិទហតិ** រមែងមិនតាំងនៅក្នុងអារម្មណ៍នោះ គឺ មិនធ្វើសេចក្ដីប្រាថ្នាក្នុងនិមិត្តនោះ ។ បទថា **យត្ថ ន បណិទហតិ** រមែងមិនតាំងនៅក្នុងអារម្មណ៍ណា គឺ មិនតាំងនៅក្នុងនិមិត្តណា ។ បទថា **តេន សុញ្ញោ** ជាអ្នកទទេចាកអារម្មណ៍នោះ គឺ ទទេចាកនិមិត្តនោះ ។ បទថា **យេន សុញ្ញោ** ជាអ្នកទទេចាក

អារម្មណ៍ណា គឺ ជាអ្នកទទេចាកនិមិត្តណា ដោយបទនេះថា **តេន និមិត្តេន អនិមិត្តោ** មិនមាននិមិត្ត ព្រោះនិមិត្តនោះ លោកពោលដល់ការមិនមាននិមិត្ត ។ បទថា **បណិធិយា មុច្ចតិ** រមែងរួចផុតចាកសេចក្តីប្រាថ្នាជាទីតាំង ។ បាឋៈថា **បណិធិ មុច្ចតិ** មានអត្ថជាបញ្ចមីវិភត្តិ គឺ រួចផុតចាកបណិធិ ដោយបទនេះ លោកពោលដល់វិមោក្ខ ។ បទថា **យត្ថ ន បណិទហតិ** បុគ្គលរមែងមិនតាំងនៅក្នុងអារម្មណ៍ណា គឺ មិនតាំងនៅក្នុងទុក្ខណា ។ បទថា **តេន សុញ្ញោ** ជាអ្នកទទេចាកអារម្មណ៍នោះ គឺ ទទេចាកទុក្ខនោះ ។ បទថា **យេន សុញ្ញោ** ជាអ្នកទទេចាកអារម្មណ៍ណា គឺ ទទេចាកទុក្ខនិមិត្តណា ។ បទថា **យេន និមិត្តេន** ព្រោះនិមិត្តណា គឺ ព្រោះទុក្ខនិមិត្តណា ។ ដោយបទនេះថា **តត្ថ ន បណិទហតិ** បុគ្គលមិនតាំងនៅក្នុងនិមិត្តនោះ លោកពោលដល់ការមិនតាំងទុក ។ ដោយបទនេះថា **អភិនិវេសា មុច្ចតិ** រួចផុតចាកសេចក្តីប្រកាន់មាំ លោកពោលដល់វិមោក្ខ ។ បទថា **យេន សុញ្ញោ** ជាអ្នកទទេចាកអារម្មណ៍ណា គឺ ជាអ្នកទទេនិមិត្ត គឺ ការប្រកាន់មាំណា ។ បទថា **យេន និមិត្តេន** ព្រោះនិមិត្តណា គឺ ព្រោះនិមិត្ត គឺ ការប្រកាន់មាំណា ។ បទថា **យត្ថ ន បណិទហតិ តេន សុញ្ញោ** បុគ្គលមិនតាំងនៅក្នុងអារម្មណ៍ណា ជាអ្នកទទេចាក



អារម្មណ៍នោះ គឺ មិនតាំងនៅក្នុងនិមិត្ត គឺ ការប្រកាន់មាំណា ជាអ្នកទទេចាកនិមិត្ត គឺ ការប្រកាន់មាំនោះ ដោយបទនេះ លោកពោលដល់អត្ថនៃសុញ្ញតៈ ។

ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងវិមោក្ខ ៨ ជាដើមទៀត ទើបពោលពាក្យជាដើមថា **អត្ថិ វិមោក្ខោ** វិមោក្ខមានដូច្នេះ ។ ក្នុងបទទាំងនោះ បទមានជាដើមថា **និច្ចតោ អភិនិវេសា** រួចផុតចាកការប្រកាន់មាំថា ទៀង គប្បីជ្រាបដោយន័យដែលលោកពោលហើយក្នុងសញ្ញាវិមោក្ខ ។ បទថា **សព្វាភិនិវេសេហិ** ចាកការប្រកាន់មាំទាំងពួង គឺ ចាកការប្រកាន់មាំ មានប្រការដូចពោលហើយ ដោយប្រការដូច្នេះ ឈ្មោះថា សុញ្ញតវិមោក្ខ ដោយអំណាចនៃការរួចផុតចាកការប្រកាន់មាំ ។ ឈ្មោះថា អនិមិត្តវិមោក្ខ ដោយអំណាចនៃការរួចផុតចាកនិមិត្តថា ទៀងជាដើម ។ ឈ្មោះថា អប្បណិហិតវិមោក្ខ ដោយអំណាចនៃការរួចផុតចាកសេចក្តីប្រាថ្នា ដែលជាទីតាំងថា ទៀង ជាដើម ។

ម្យ៉ាងទៀត ក្នុងបទនេះថា **បណិធិ មុច្ចតិ** គប្បីជ្រាបថាជាបញ្ចមីវិភត្តិក្នុងទីទាំងពួង ប្រែថា រួចផុតចាកបណិធិ ឬបាឋៈថា **បណិធិយា មុច្ចតិ** ប្រែដូចគ្នាថា រួចផុតចាកបណិធិ ។ មានដូចក្នុង

បទនេះថា **សព្វបណិធីហិ មុច្ចតិ** រួចផុតចាកបណិធិទាំងពួង ។ លោកពោលអនុបស្សនា ៣ យ៉ាងនេះថា វិមោក្ខដោយបរិយាយ ព្រោះសេចក្តីដែលវិមោក្ខជាអង្គរបស់វិបស្សនានោះ និងព្រោះជាបច្ច័យនៃសមុច្ឆេទវិមោក្ខ ។

បទថា **តត្ថ ជាតា** កើតក្នុងមគ្គវិមោក្ខនោះ លោកអធិប្បាយថា កាលវិបស្សនាវិមោក្ខសូម្បីមាននៅក្នុងលំដាប់កុសលធម៌ទាំងឡាយកើតក្នុងមគ្គវិមោក្ខនោះ ព្រោះកថានេះ ជាអធិការនៃមគ្គវិមោក្ខ ។ បទថា **អនវជ្ជកុសលា** កុសលធម៌ដែលមិនមានទោស គឺ កុសលប្រាសចាកទោសមានរាគៈជាដើម ឬធ្វើការកាត់ផ្តាច់ជាសមុច្ឆេទ ។ បទថា **ពោធិបក្ខិយា ធម្មា** ពោធិបក្ខិយធម៌ ( ធម៌ដែលជាចំណែកនៃការត្រាស់ដឹង ) គឺ ពោធិបក្ខិយធម៌ ៣៧ ដែលលោកពោលទុក គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គមានអង្គ ៨ ។ បទថា **ឥទំ មុខំ** នេះ ធម៌ជាប្រធាន លោកអធិប្បាយថា ធម្មជាតិមានប្រការដូចពោលហើយនេះ ឈ្មោះថា ធម៌ជាប្រធាន ព្រោះជាប្រធាននៃការចូលទៅកាន់និព្វាន ដោយជាអារម្មណ៍ ។ បទថា **តេសំ ធម្មានំ** នៃធម៌ទាំងនោះ គឺ នៃពោធិបក្ខិយធម៌ទាំងនោះ ។



បទថា **ឥទំ វិមោក្ខមុខំ** នេះ ជាធម៌ដែលជាប្រធាននៃវិមោក្ខ គឺ និព្វានជានិស្សរណវិមោក្ខ ក្នុងបណ្តាវិក្ខម្ភនវិមោក្ខ តទង្គវិមោក្ខ សមុច្ឆេទវិមោក្ខ បដិបស្សទ្ធិវិមោក្ខ និងនិស្សរណវិមោក្ខ ។ និព្វានឈ្មោះថា **វិមោក្ខមុខំ** ព្រោះជាប្រធាន ដោយអត្ថថា ខ្ពង់ខ្ពស់ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សង្ខតធម៌ ឬអសង្ខតធម៌មានប្រមាណប៉ុនណា វិរាគៈលោកពោលថា ប្រសើរជាងធម៌ទាំងនោះ ។ លោកពោលអត្ថនេះ ដោយអំណាចនៃកម្មធារយ-សមាសថា វិមោក្ខនោះផង ជាប្រធានផង ឈ្មោះថា **វិមោក្ខមុខំ** ។ ក្នុងបទថា **វិមោក្ខញ្ច** នេះជាលិង្គវិបល្លាស ។ បទថា **តីណិ អកុស-លមូលានិ** អកុសលមូល ៣ គឺ រាគៈ ទោសៈ មោហៈ ។ បទថា **តីណិ ទុច្ចរិតានិ** ទុច្ចរិត ៣ គឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ។ បទថា **សព្វេបិ អកុសលា ធម្មា** អកុសលធម៌សូម្បីទាំងអស់ គឺ អកុសលធម៌សម្បយុត្តដោយអកុសលមូល សម្បយុត្ត និងមិនសម្បយុត្តដោយទុច្ចរិត វៀរទោមនស្សដែលគួរសេពជាដើម ។ បទថា **កុសល-មូលសុចរិតានិ** សុចរិតដែលជាកុសលមូល គប្បីជ្រាបដោយភាពជាបដិបក្ខជាមួយនឹងទុច្ចរិត ដែលជាអកុសលដូចពោលហើយ ។

បទថា **សព្វេបិ កុសលា ធម្មា** កុសលធម៌សូម្បីទាំងអស់ គឺ

កុសលធម៌សូម្បីទាំងអស់ ជាឧបនិស្សយនៃវិមោក្ខ សម្បយុត្ត និង មិនសម្បយុត្តដោយកុសលមូល តាមន័យដូចពោលហើយ ។ **វិវដ្ដកថា** (កថាពោលដោយការគេចចេញទៅ) លោកពោលទុកហើយក្នុងខាងក្រោយ ។ តែក្នុងទីនេះ លោកពោលវិវដ្ដៈដ៏សេសដោយសម្ព័ន្ធជាមួយនឹងវិមោក្ខវិវដ្ដៈ ។ បទថា **អាសេវនា** ការសេព គឺ សេពតាំងអំពីខាងដើម ។ បទថា **ភាវនា** ការចម្រើន គឺ ការចម្រើននៃវិមោក្ខនោះឯង ។ បទថា **ពហុលីកម្មំ** ការធ្វើឲ្យច្រើន គឺ ធ្វើរឿយ ៗ ឲ្យដល់ភាពជំនាញនៃវិមោក្ខនោះ ។ ម្យ៉ាងទៀត គប្បីជ្រាបការសេពជាដើម ដោយអំណាចញុំាងកិច្ចឲ្យសម្រេចក្នុងខណៈតែមួយនៃមគ្គនោះឯង ។ បទមានជាដើមថា **បដិលាភោ វា វិបាកោ វា** ការបាន ឬវិបាក មានអត្ថដូចពោលទុកហើយក្នុងខាងក្រោយនោះឯង ដោយប្រការដូច្នេះ ។

ចប់ អដ្ឋកថាវិមោក្ខកថា

នៃសទ្ធម្មបកាសិនី អដ្ឋកថាបដិសម្ភិទាមគ្គ



## ៦-អដ្ឋកថា គតិកថា

ឥឡូវនេះ ការពណ៌នាសេចក្ដីតាមលំដាប់ដែលមិនធ្លាប់ពណ៌នា នៃគតិកថា ដែលព្រះសារីបុត្តត្ថេរសម្ដែងដល់ហេតុសម្បត្តិ ដែលជាហេតុនៃការកើតវិមោក្ខនោះ ពោលទុកហើយ ។ សូម្បីឈាននឹងមិនកើតឡើង សូម្បីដល់អ្នកជាទុហេតុកបដិសន្ធិ ព្រោះព្រះបាលីថា **នត្ថិ ឈានំ អបញ្ញស្ស** ឈានរមែងមិនមានដល់អ្នកមិនមានបញ្ញា ក៏វិមោក្ខនឹងកើតបានដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **គតិសម្បត្តិយា** គតិសម្បត្តិ គឺ គតិសម្បត្តិដែលបានដល់មនុស្ស និងទេព ក្នុងបណ្ដាគតិ ៥ គឺ នរក កំណើតតិរច្ឆាន ប្រេតវិស័យ មនុស្ស និងទេព ។ ដោយបទនេះឯង លោកបដិសេធគតិវិបត្តិ ៣ ខាងដើម ។ សម្បត្តិនៃគតិ ឈ្មោះថា គតិសម្បត្តិ ។ លោកអធិប្បាយថា **សុគតិ** ។ ម្យ៉ាងទៀត ខន្ធទាំង-ឡាយព្រមនឹងឱកាស ឈ្មោះថា គតិ ។ ក៏ក្នុងគតិ ៥ លោកកាន់យកសូម្បីអសុរកាយ ដោយសព្ទថា **បេតវិស័យ** ។ បទថា **ទេវា** បានដល់កាមាវចរទេព ៦ និងព្រហ្មទាំងឡាយ ។ សូម្បីអសុរ លោកក៏សង្គ្រោះសព្ទថា **ទេវ** ។ បទថា **ញាណសម្បយុត្តេ** ក្នុងកម្មដែល

សម្បយុត្តដោយញាណ គឺ ក្នុងខណៈបដិសន្ធិសម្បយុត្តដោយញាណ ។ ពិតណាស់ សូម្បីខណៈ ក៏គប្បីជ្រាបថា លោកពោលដោយវោហារនោះឯង ព្រោះប្រកបដោយញាណសម្បយុត្ត ។ បទថា **កតីនំ ហេតូនំ** នៃហេតុប៉ុន្មាន គឺ នៃហេតុប៉ុន្មាន ក្នុងបណ្តាអលោភហេតុ អទោស-ហេតុ អមោហហេតុ ។ បទថា **ឧបបត្តិ** គឺ ការកើត ។

ម្យ៉ាងទៀត ព្រោះសូម្បីកើតក្នុងត្រកូលសូទ្រៈក៏ជាតិហេតុកៈបាន ដូច្នោះ ពាក្យសួរដំបូង ទើបសំដៅដល់តិហេតុកៈទាំងនោះ និង ព្រោះមនុស្សមានបញ្ញាច្រើន ដោយច្រើនកើតក្នុងត្រកូលមហាសាល ៣ ត្រកូល ដូច្នោះពាក្យសួរទើបមាន ៣ យ៉ាង ដោយអំណាចនៃត្រកូល ៣ ទាំងនោះ តែលោកសង្ខេបបាឋៈទុក ។

ឈ្មោះថា **មហាសាលា** ព្រោះមានសម្បត្តិច្រើន អធិប្បាយថា មានផ្ទះធំ មានសម្បត្តិច្រើន ។ ម្យ៉ាងវិញទៀត គួរពោលថា **មហា-សារា** ព្រោះមានទ្រព្យច្រើន លោកពោលថា **មហាសាលា** ព្រោះប្តូរ **រ** អក្សរជា **ល** អក្សរ ។ ឈ្មោះថា **ខត្តិយមហាសាលា** ព្រោះជាក្សត្រមាហាសាល ឬមហាសាលក្នុងក្សត្រ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងបទនោះ ក្សត្រណារក្សាទ្រព្យយ៉ាងតិច ១០០ កោដិ ទុកក្នុងព្រះរាជវាំង ទ្រង់ប្រើប្រាស់ចាយវាយកហាបណៈ ១



ថ្ងៃ ២០ អម្ពណៈ ក្សត្រអង្គនេះឈ្មោះថា ក្សត្រមហាសាល ។ ព្រាហ្មណ៍ណា រក្សាទ្រព្យយ៉ាងតិច ៨០ កោដិ ទុកក្នុងផ្ទះ ប្រើប្រាស់ចាយវាយ ១ ថ្ងៃ ១០ អម្ពណៈ ព្រាហ្មណ៍នេះឈ្មោះថា ព្រាហ្មណ-មហាសាល ។ គហបតីណារក្សាទ្រព្យយ៉ាងតិច ៤០ កោដិ ទុកក្នុងផ្ទះ ប្រើប្រាស់ចាយវាយ ១ ថ្ងៃ ៥ អម្ពណៈ គហបតីនេះឈ្មោះថា គហ-បតីមហាសាល ។ ព្រោះទេពជាន់រូបាវចរ និងទេពជាន់អរូបាវចរ ជាតិហេតុកៈតែម្យ៉ាង លោកទើបមិនពោលថា **ញាណសម្បយុត្តេ** ក្នុងកម្មដែលសម្បយុត្តដោយញាណ ។ តែក្នុងមនុស្សទាំងឡាយ ព្រោះមានទុហេតុកៈ និងអហេតុកៈ និងក្នុងទេពជាន់កាមាវចរដ៏សេស ព្រោះមានទុហេតុកៈលោកទើបពោល **ញាណសម្បយុត្តេ** ។ ម្យ៉ាងទៀត កាមាវចរទេពទាំងឡាយក្នុងទីនេះ ឈ្មោះថា **ទេវា** ព្រោះរីករាយ ដោយការត្រេកអរក្នុងកាមគុណ ៥ និងរុងរឿងដោយរស្មីនៃរាងកាយ ។ រូបាវចរព្រហ្មទាំងឡាយ ឈ្មោះថា **ទេវា** ព្រោះរីករាយដោយការត្រេកអរក្នុងឈាន និងរុងរឿងដោយរស្មីនៃរាងកាយ ។ អរូបាវចរ-ព្រហ្មទាំងឡាយ ឈ្មោះថា **ទេវា** ព្រោះរីករាយដោយការត្រេកអរក្នុងឈាន និងរុងរឿងដោយរុងរឿងនៃញាណ ។

បទថា **កុសលកម្មស្ស ជវនក្ខណេ** ក្នុងខណៈស្ទុះទៅនៃ

កុសលកម្ម គឺ ក្នុងខណៈស្ទុះទៅនៃកុសលកម្មដែលជា តិហេតុកកា-មាវចរ ដែលញុំាងតិហេតុកបដិសន្ធិឲ្យកើតក្នុងអតីតជាតិ ៧ វារៈ ដោយអំណាចការកើតរឿយ ៗ ក្នុងជវនវីថិចិត្ត សេចក្តីថា ក្នុងកាលដែលប្រព្រឹត្តទៅ ។ បទថា **តយោ ហេតូ កុសលា** ហេតុ ៣ ប្រការជាកុសល គឺ អលោភៈ អទោសៈ អមោហៈ ជាកុសលហេតុ ។ បទថា **តស្មឹ ខណេ ជាតចេតនាយ** នៃចេតនាដែលកើតក្នុងខណៈនោះ គឺ នៃកុសលចេតនាដែលកើតក្នុងខណៈដូចពោលហើយនោះ ។ បទថា **សហជាតប្បច្ចយា ហោន្តិ** ជាសហជាតប្បច្ច័យ គឺ កាលកើតរមែងជាឧបការៈដោយការកើតរួមគ្នា ។ បទថា **តេន វុច្ចតិ** ដោយហេតុនោះលោកទើបពោល គឺ ពោលដោយភាពជាសហជាតប្បច្ច័យនោះឯង ។ បទថា **កុសលមូលប្បច្ចយាបិ សង្ខារា** សូម្បីព្រោះកុសលមូលជាបច្ច័យក៏កើតសង្ខារ លោកពោលដោយន័យនៃបច្ចយាការដែលប្រព្រឹត្តទៅក្នុងខណៈចិត្តមួយដួង ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកសង្គ្រោះចេតសិកទាំងអស់ ដែលសង្គ្រោះដោយសង្ខារក្ខន្ធក្នុងបទនោះ ដោយពហុវចនៈថា **សង្ខារា** សង្ខារទាំងឡាយ ។ លោកពោលថា **កុស-លមូលានិ** ខ្ចុះ សូម្បីព្រោះជាបច្ច័យឲ្យកើតសង្ខារដោយ **អបិ** សព្ទ ។ បទថា **និក្កន្តិក្ខណេ** ក្នុងខណៈការពេញចិត្តនៃសង្ខារ ដែលកើតឡើង



ក្នុងកម្មដែលប្រាកដចំពោះមុខ ដើម្បីឲ្យវិបាករបស់ខ្លួន ក្នុងកម្មនិមិត្ត ឬក្នុងគតិនិមិត្ត ដែលប្រាកដដោយកម្មដែលប្រាកដហើយយ៉ាងនោះ ។ បទថា **និក្កន្តិ** ការពេញចិត្ត គឺ ការស្រឡាញ់ ការប្រាថ្នា ។ ពិតណាស់ ព្រោះជិតនឹងស្លាប់មានចិត្តជ្រួលច្របល់ដោយមោហៈ ការពេញចិត្តរមែងកើតឡើង សូម្បីក្នុងសំណាញ់នៃអវិចិមហានរក ចំណែកក្នុងនិមិត្តដ៏សេសនឹងជាយ៉ាងណា ។ បទថា **ទ្វេ ហេតូ** ហេតុ ២ ប្រការ គឺ លោភៈ មោហៈ ជាអកុសលហេតុ ។ ចំណែកការពេញចិត្តក្នុងភព ប្រារព្ធខន្ធសន្តានរបស់ខ្លួន ត្រឹមតែចេញទៅចាកភវង្គវីថិ ដែលប្រព្រឹត្តទៅហើយក្នុងលំដាប់នៃបដិសន្ធិ រមែងកើតឡើងសូម្បីដល់សង្ខារទាំងពួង ។ បទមានជាអាទិ៍យ៉ាងនេះថា ឬថា អកុសលធម៌ មិនធ្លាប់កើតឡើងដល់បុគ្គលណា ក្នុងភូមិណា កុសល-ធម៌ទាំងឡាយ ក៏មិនធ្លាប់កើតដល់បុគ្គលនោះ ក្នុងភូមិនោះឬ ? មានពាក្យឆ្លើយថា មែន ដូច្នេះលោកពោលសំដៅដល់ការពេញចិត្តនេះឯង ។ បទថា **តស្មឹ ខណេ ជាតចេតនាយ** នៃចេតនាដែលកើតក្នុងខណៈនោះ គឺ អកុសលចេតនា ។ បទថា **បដិសន្ធិក្ខណេ** ក្នុងខណៈនៃបដិសន្ធិ គឺ ក្នុងខណៈនៃបដិសន្ធិដែលកាន់យកហើយ ដោយកម្មនោះ ។ បទថា **តតោ ហេតូ** ហេតុ ៣ ប្រការ គឺ អលោភៈ

អទោសៈ អមោហៈ ជាអព្យាកតហេតុ ។ បទថា **តស្មឹ ខណេ ជាតចេតនាយ** នៃចេតនាដែលកើតក្នុងខណៈនោះ គឺ អព្យាកតចេតនាដែលជាវិបាក ។ ក្នុងបទនេះថា **នាមរូបប្បច្ចយាបិ វិញ្ញាណំ** សូម្បីព្រោះនាមរូបជាបច្ច័យ ក៏មានវិញ្ញាណក្នុងខណៈបដិសន្ធិនោះ វិបាកហេតុ ៣ និងចេតសិកដ៏សេសជានាម ហទយវត្ថុជារូប សូម្បីតែនាមរូបជាបច្ច័យនោះ បដិសន្ធិវិញ្ញាណរមែងប្រព្រឹត្តទៅ ។ នាមសូម្បីក្នុងបទថា **វិញ្ញាណប្បច្ចយាបិ នាមរូបំ** សូម្បីព្រោះវិញ្ញាណជាបច្ច័យ ក៏មាននាមរូបនេះ មានប្រការដូចបានពោលហើយ ។ ចំណែករូបក្នុងបទនេះ បានដល់ រូប ៣០ គឺ វត្ថុទសកៈ កាយទសកៈ ភាវទសកៈ របស់សត្វអ្នកនៅក្នុងគភ៌ ព្រោះលោកប្រាថ្នាយកមនុស្សបដិសន្ធិព្រមដោយហេតុ ។ម្យ៉ាងទៀត បានដល់ រូប ៧០ គឺ ចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ ( និងរូប ៣០ ខាងដើម ) របស់សត្វសំសេទជៈ ឱបបាតិកៈ ដែលមានអាយតនៈគ្រប់នាមរូបមានប្រការដូច្នេះ រមែងប្រព្រឹត្តទៅ ព្រោះបដិសន្ធិវិញ្ញាណជាបច្ច័យក្នុងខណៈបដិសន្ធិ ។

ក្នុងបទនេះថា **បញ្ចក្ខន្ធា** ខន្ធ ៥ គឺ រូបដែលបានក្នុងខណៈបដិសន្ធិដោយបដិសន្ធិចិត្តជារូបក្ខន្ធ វេទនាដែលកើតរួមគ្នាជាវេទនាខន្ធ



សញ្ញាជាសញ្ញាខន្ធ ចេតសិកដ៏សេសជាសង្ខារក្ខន្ធ បដិសន្ធិចិត្តជាវិញ្ញាណក្ខន្ធ ។ បទថា **សហជាតប្បច្ចយា ហោន្តិ** ជាសហជាតប្បច្ច័យ គឺ ខន្ធមិនមានរូប ៤ ជាសហជាតប្បច្ច័យនៃគ្នានឹងគ្នា មហាភូតរូប ៤ ក្នុងរូបក្ខន្ធ ជាសហជាតប្បច្ច័យនៃគ្នានឹងគ្នា ខន្ធមិនមានរូប និងហទយរូប ជាសហជាតប្បច្ច័យនៃគ្នានឹងគ្នា សូម្បីមហាភូតរូប ក៏ជាសហជាតប្បច្ច័យនៃឧបាទារូប ។ បទថា **អញ្ញមញ្ញប្បច្ចយា ហោន្តិ** ជាអញ្ញមញ្ញប្បច្ច័យ គឺ បញ្ចក្ខន្ធ ជាឧបការៈដល់គ្នានឹងគ្នាដោយការឧបត្ថម្ភឲ្យកើត ខន្ធមិនមានរូប ៤ ក៏ជាអញ្ញមញ្ញប្បច្ច័យ មហាភូតរូប ៤ ក៏ជាអញ្ញមញ្ញប្បច្ច័យ ។ បទថា **និស្សយប្បច្ចយា ហោន្តិ** ជានិស្សយប្បច្ច័យ គឺ បញ្ចក្ខន្ធ ជាឧបការៈដោយអាការតាំងមាំ និងដោយអាការជាទីអាស្រ័យ ខន្ធមិនមានរូប ៤ ជានិស្សយប្បច្ច័យនៃគ្នានឹងគ្នា ព្រោះហេតុនោះ គប្បីឲ្យពិស្តារដូចសហជាតប្បច្ច័យ ។ បទថា **វិប្បយុត្តប្បច្ចយា ហោន្តិ** ជាវិប្បយុត្តប្បច្ច័យ គឺ បញ្ចក្ខន្ធ ជាឧបការៈដោយភាពវិប្បយុត្តប្បច្ច័យ ដោយការមិនចូលដល់ភាពដែលមានវត្ថុតែមួយជាមួយគ្នាជាដើម ខន្ធមិនមានរូប ជាវិប្បយុត្តប្បច្ច័យនៃបដិសន្ធិរូប ហទយវត្ថុរូប ជាវិប្បយុត្តប្បច្ច័យនៃខន្ធមិនមានរូប ព្រោះក្នុងបទនេះថា **បញ្ចក្ខន្ធា** លោកពោលដោយអំណាចតាម

ដែលមានបានដោយប្រការដូច្នេះ ។

ក្នុងបទថា **ចត្តារោ មហាភូតា** មហាភូតរូប ៤ នេះ លោកពោលដល់បច្ច័យ ៣ មុន ។ បទថា **តយោ ជីវិតសង្ខារា** គ្រឿងតាក់តែងជីវិត ៣ ប្រការ គឺ អាយុ ឧស្មា និងវិញ្ញាណ ។ បទថា **អាយុ** បានដល់ រូបជីវិតិន្ទ្រិយនិងអរូបជីវិតិន្ទ្រិយ ។ បទថា **ឧស្មា** បានដល់ តេជោធាតុ ។ បទថា **វិញ្ញាណំ** បានដល់ បដិសន្ធិវិញ្ញាណ ។ ពិតណាស់ ឈ្មោះថា **ជីវិតសង្ខារ** ព្រោះអាយុ ឧស្មា និងវិញ្ញាណទាំងនេះ រមែងតាក់តែងជីវិតសង្ខារ គឺ ឲ្យប្រព្រឹត្តទៅក្រៃលែង ៗ ឡើង ។

បទថា **សហជាតប្បច្ចយា ហោន្តិ** ជាសហជាតប្បច្ច័យ គប្បីជ្រាបថា អរូបជីវិតិន្ទ្រិយ និងបដិសន្ធិវិញ្ញាណ ជាអញ្ញមញ្ញប្បច្ច័យ និងសហជាតប្បច្ច័យនៃខន្ធដទៃសម្បយុត្តគ្នានឹងហទយវត្ថុរូប តេជោធាតុជា អញ្ញមញ្ញាប្បច្ច័យ និងសហជាតប្បច្ច័យនៃមហាភូតរូប ៣ និងជា សហជាតប្បច្ច័យនៃឧបាទាយរូប រូបជីវិតិន្ទ្រិយជាសហជាតប្បច្ច័យដោយ បរិយាយនៃសហជាតរូប ។

បទថា **អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ** ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ គឺ អរូបជីវិតិន្ទ្រិយ និងបដិ-



សន្ធិវិញ្ញាណ ទាំង ២ ជាអញ្ញមញ្ញប្បច្ច័យនៃខន្ធដែលសម្បយុត្តគ្នា ។ គប្បីជ្រាបប្រកបដោយន័យដែលលោកពោលទុកថា **អញ្ញមញ្ញនិស្សយប្បច្ចយា ហោន្តិ** ជាអញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ ។

បទថា **វិប្បយុត្តប្បច្ចយា ហោន្តិ** ជាវិប្បយុត្តប្បច្ច័យ គឺ អរូបជីវិតិន្ទ្រិយ និងបដិសន្ធិវិញ្ញាណ រមែងជាវិប្បយុត្តប្បច្ច័យនៃបដិសន្ធិរូប ។ ចំណែករូបជីវិតិន្ទ្រិយមិនសមគួរក្នុងភាពជាអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ ព្រោះដូច្នោះ លោកទើបពោលដោយអំណាចតាមដែលមានបានថា **តយោ ជីវិតសង្ខារា** គ្រឿងតាក់តែងជីវិត ៣ ដូច្នេះ ។ គប្បីប្រកបនាម និងរូប ក្នុងភាពជាបច្ច័យ ៤ ដោយន័យដូចពោលហើយនោះឯង ។

បទថា **ចុទ្ទស ធម្មា** គឺធម៌ ១៤ ប្រការ ដោយចំនួនយ៉ាងនេះ គឺ ខន្ធ ៥ មហាភូតរូប ៤ ជីវិតសង្ខារ ៣ នាម ១ រូប ១ ។ ភាពជាបច្ច័យ មានសហជាតប្បច្ច័យជាដើមនៃធម៌ទាំងនោះ និងធម៌ដទៃខាងដើម មានន័យដូចពោលហើយ ។ បទថា **សម្បយុត្តប្បច្ចយា ហោន្តិ** ជាសមប្បច្ច័យ គឺ ធម៌ទាំងឡាយជាឧបការៈដោយភាពសម្បយុត្តគ្នាពោលគឺ មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នារលត់ព្រមគ្នា ។ បទថា **បញ្ចិន្ទ្រិយា** ឥន្ទ្រិយ ៥ បានដល់ សទ្ធិន្ទ្រិយ

ជាដើម ។ បទថា **នាមញ្ច** ក្នុងទីនេះ បានដល់ ខន្ធ ៣ មានវេទនាខន្ធជាដើម ។ បទថា **វិញ្ញាណញ្ច** បានដល់ បដិសន្ធិវិញ្ញាណ ។ បទថា **ចុទ្ទស ធម្មា** គឺ ធម៌ ១៤ ប្រការម្ដងទៀត ដោយចំនួនយ៉ាងនេះទៀត គឺ ខន្ធ ៤ ឥន្ទ្រិយ ៥ ហេតុ ៣ នាម ១ រូប ១ ។

បទថា **អដ្ឋវីសតិ ធម្មា** ធម៌ ២៨ ប្រការ គឺ ខាងដើម ១៤ និងធម៌ទាំងនេះ ១៤ ។ ព្រោះសូម្បីរូប ក៏រាប់ចូលទៅក្នុងធម៌នេះ លោកទើបនាំសម្បយុត្តប្បច្ច័យចេញ ហើយពោលវិប្បយុត្តច្ច័យ ។

ព្រះសារីបុត្តត្ថេរ គ្រាសម្ដែងដល់ប្រភេទនៃបច្ច័យនោះ ៗ នៃធម៌ដែលកើតឡើងព្រោះបច្ច័យនោះ ៗ ដែលមាននៅក្នុងបដិសន្ធិយ៉ាងនេះហើយ កាលនឹងសម្ដែងសតុបហេតុ ដែលបង្ហាញទុកពីខាងដើម ទើបពោលថា **ឥមេសំ អដ្ឋន្នំ ហេតូនំ បច្ចយា ឧប្បត្តិ ហោតិ** រមែងឧប្បត្តិព្រោះបច្ច័យនៃហេតុ ៨ ប្រការទាំងនេះ ។ ហេតុ ៨ ប្រការនេះ គឺ កុសលហេតុ ៣ ក្នុងខណៈប្រមូលកម្ម អកុសលហេតុ ២ ក្នុងខណៈពេញចិត្ត អព្យាកតហេតុ ៣ ក្នុងខណៈបដិសន្ធិ ។ ក្នុងហេតុទាំងនោះ កុសលហេតុ ៣ និងអកុសលហេតុ ២ ជាឧបនិស្សយប្បច្ច័យ ដោយការប្រព្រឹត្តទៅក្នុងខណៈបដិសន្ធិនេះ អព្យាកតហេតុ ២ ជាបច្ច័យដោយអំណាចហេតុប្បច្ច័យ និងសហជាតប្បច្ច័យ



តាមសមគួរ ។ សូម្បីក្នុងវារៈដ៏សេសក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ព្រោះអរូបាវចរមិនមានរូប លោកទើបពោលថា សូម្បីនាមជាបច្ច័យក៏មានវិញ្ញាណ សូម្បីវិញ្ញាណជាបច្ច័យក៏មាននាម ។ សូម្បីធម៌ ១៤ បញ្ចូលគ្នាជាមួយរូប ក៏ថយចុះទៅ ព្រោះធម៌នោះថយចុះក្នុងវារៈថា **អដ្ឋវីសតិ ធម្មា** ធម៌ ២៨ ប្រការ ទើបមិនបានដូច្នេះ ។ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ គ្រាសម្ដែងគតិហេតុកបដិសន្ធិ ដែលជាបច្ច័យនៃវិមោក្ខហើយ ប្រាថ្នានឹង សម្ដែងគតិហេតុកបដិសន្ធិឲ្យវិសេស ដោយការសម្ព័ន្ធគ្នានោះ ទើប ពោលបទមានជាអាទិ៍ថា **គតិសម្បត្តិយា ញាណវិប្បយុត្តេ** ក្នុងកម្ម ដែលមិនប្រកបដោយញាណ គតិសម្បត្តិរមែងមានហេតុកើត ។

បទថា **កុសលកម្មស្ស ជវនក្ខណេ** ក្នុងខណៈស្ទុះទៅនៃកុសលកម្ម គឺ ក្នុងខណៈស្ទុះទៅនៃកុសលកម្មដែលជាទុហេតុកៈ ដែលឲ្យបដិសន្ធិក្នុងអតីតជាតិ តាមន័យដូចពោលហើយនោះឯង ។ បទថា **ទ្វេ ហេតូ** ហេតុ ២ ប្រការ គឺ អលោភៈ អទោសៈ ជាកុសលហេតុ ព្រោះមិនប្រកបដោយញាណ ។ សូម្បីអព្យាកតហេតុ ក៏មាន ២ គឺ អលោភៈ អទោសៈ ដូចគ្នា ។ បទថា **ចត្តារិ ឥន្ទ្រិយានិ** គឺ ឥន្ទ្រិយ ៤ មានសទ្ធិន្ទ្រិយជាដើម វៀរបញ្ញិន្ទ្រិយ ។ បទថា **ទ្វាទស ធម្មា** ធម៌

១២ ប្រការ គឺ ធម៌ ១២ ប្រការ ព្រោះបញ្ចិន្ទ្រិយ និងអមោហៈហេតុ វៀរចេញទៅ ព្រោះធម៌ ២ ប្រការនោះវៀរចេញ ទើបជាធម៌ ២៦ ។ បទថា **ឆន្នំ ហេតូនំ** គឺ នៃហេតុ ៦ ប្រការ យ៉ាងនេះ គឺ កុសលហេតុ ២ អកុសលហេតុ ២ វិបាកហេតុ ២ ។ តែក្នុងទីនេះមិនកាន់យក រូបាវចរ និងអរូបាវចរ ព្រោះជាតិហេតុកៈតែម្យ៉ាង ។ គប្បីជ្រាបបទដ៏សេស ដោយន័យដូចពោលហើយ ក្នុងបឋមវារៈនោះឯង ។ ក្នុងវារៈនេះលោកពោលទុកថា បដិសន្ធិដែលជាទុហេតុកៈ រមែងមិនមានដោយកម្មដែលជាតិហេតុកៈ ព្រោះកម្មដែលជាទុហេតុកៈ លោកពោលហើយដោយបដិសន្ធិដែលជាទុហេតុកៈ ព្រោះដូច្នោះ ពាក្យណាដែលលោកពោលទុកក្នុងវាទៈរបស់ព្រះមហាធម្មរក្ខិតត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកក្នុងអដ្ឋកថាធម្មសង្គហៈថា បដិសន្ធិជាតិហេតុកៈដោយកម្ម ដែលជាតិហេតុកៈ មិនមែនជាទុហេតុកៈ និងអហេតុក ទុហេតុកៈ និងអ-ហេតុកៈ រមែងកើតដោយកម្មដែលជាទុហេតុកៈ មិនមែនជាតិហេតុកៈ ពាក្យនោះសមតាមបាលីនេះ ។ ចំណែកពាក្យណាដែលលោកពោលទុកក្នុងវាទៈរបស់ព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក និងព្រះមហាទត្តត្ថេរអ្នកនៅក្នុងមោរវាបីថា បដិសន្ធិជាតិហេតុកៈខ្លះ ជាទុហេតុកៈខ្លះ រមែងមានបានដោយកម្មដែលជាតិហេតុកៈ មិនមែនជា



អហេតុកៈ បដិសន្ធិជាទុហេតុកៈខ្លះ ជាអហេតុកៈខ្លះ រមែងមានបានដោយកម្មដែលជាទុហេតុកៈ មិនមែនជាតិហេតុកៈ ពាក្យនោះប្រាកដជាឃៀងឃ្លាត នឹងក្លាត់ទៅចាកបាលីនេះ ព្រោះកថានេះ ជាអធិការនៃហេតុ ទើបមិនពោលដល់អហេតុកៈបដិសន្ធិ ។

(ចប់ អដ្ឋកថាគតិកថា)

## ៧–អដ្ឋកថា កម្មកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្ដីដែលនៅមិនបានពណ៌នាទុកនៃ **កម្មកថា** ដែលព្រះសារីបុត្តត្រេសម្ដែងដល់កម្មដែលជាបច្ច័យនៃហេតុសម្បត្តិនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មកថានោះ ដូចតទៅនេះ ។ ក្នុងបទមានជាដើមថា **អហោសិ កម្មំ អហោសិ កម្មវិបាកោ** កម្មមានរួចហើយ វិបាកនៃកម្មមានរួចហើយ លោកកាន់យកវិបាកដែលជាផលក្នុងភពអតីត នៃកម្មដែលធ្វើហើយក្នុងភពអតីតនោះឯង ទើបពោលថា **អហោសិ កម្មំ អហោសិ កម្មវិបាកោ** ។

លោកកាន់យកវិបាកដែលមិនមែនផលក្នុងភពអតីត ដោយការព្រមព្រៀងរបស់បច្ច័យនៃកម្មអតីត ដែលជាទិដ្ឋធម្មវេទនីយកម្ម (កម្មឲ្យផលក្នុងភពនេះ ) និងជាឧបបជ្ជវេទនីយកម្ម ( កម្មឲ្យផលចំពោះកាលកើតហើយក្នុងភពខាងមុខ ) និងវិបាកដែលមិនមែនជាផលនៃកម្មដែលរលត់ហើយក្នុងអតីតនោះឯង ហើយដែលជាទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម ( កម្មឲ្យផលក្នុងភពបន្តៗទៅ) ទើបពោលថា **អហោសិ កម្មំ នាហោសិ កម្មវិបាកោ** កម្ម



មានរួចហើយ វិបាកនៃកម្មមិនទាន់មាន ។

លោកកាន់យកវិបាកដែលជាផលនៃកម្មអតីត ដោយការដល់ព្រមនៃបច្ច័យក្នុងភពបច្ចុប្បន្ន នៃវិបាកដែលមិនមែនជាផល ហើយទើបពោលថា **អហោសិ កម្មំ អត្ថិ កម្មវិបាកោ** កម្មមានរួចហើយ វិបាកនៃកម្មមាន ។

លោកកាន់យកវិបាកដែលមិនមែនជាផលនៃកម្មអតីត ដែលកន្លងកាលនៃវិបាកហើយ និងរបស់អ្នកបរិនិព្វានក្នុងភពបច្ចុប្បន្ននោះឯង ហើយទើបពោលថា **អហោសិ កម្មំ នត្ថិ កម្មវិបាកោ** កម្មមានរួចហើយ វិបាកនៃកម្មមិនមាន ។

លោកកាន់យកវិបាកដែលជាផល ដោយការដល់ព្រមនៃបច្ច័យក្នុងភពអនាគត នៃកម្មអតីតដែលគួរដល់វិបាក ដែលជាវិបាកនៅមិនទាន់ជាផល ហើយទើបពោលថា **អហោសិ កម្មំ ភវិស្សតិ កម្មវិបាកោ** កម្មមានរួចហើយ វិបាកនៃកម្មនឹងមាន ។

លោកកាន់យកវិបាកដែលមិនគួរឲ្យផល នៃកម្មអតីត ដែលកន្លងនៃកម្មវិបាកហើយ និងរលត់ក្នុងភពអនាគតនោះឯង ទើបពោលថា **អហោសិ កម្មំ ន ភវិស្សតិ កម្មវិបាកោ** កម្មមាន រួចហើយ វិបាកនៃកម្មនឹងមិនមាន ។

លោកសម្តែងកម្មអតីតយ៉ាងនេះទុក ៦ យ៉ាង ដោយអំណាចនៃវិបាក និងមិនមែនវិបាក ក្នុងអតីត បច្ចុប្បន្ន និងអនាគត ។

លោកកាន់យកវិបាកដែលឲ្យផលក្នុងបច្ចុប្បន្ននេះ នៃកម្មដែលជាទិដ្ឋធម្មវេទនីយកម្មដែលធ្វើហើយក្នុងភពនេះ ហើយទើបពោលថា **អត្ថិ កម្មំ អត្ថិ កម្មវិបាកោ** កម្មមាន វិបាកនៃកម្មមាន ។

លោកកាន់យកវិបាកដែលមិនឲ្យផលក្នុងបច្ចុប្បន្ននេះ ដោយសេចក្តីព្រមព្រៀងនៃបច្ច័យរបស់កម្មបច្ចុប្បន្ននោះ និងនៅមិនទាន់ឲ្យផលក្នុងភពនេះ របស់អ្នកបរិនិព្វានក្នុងភពបច្ចុប្បន្នហើយ ទើបពោលថា **អត្ថិ កម្មំ នត្ថិ កម្មវិបាកោ** កម្មមាន វិបាកនៃកម្មមិនមាន ។

លោកកាន់យកវិបាកដែលគួរឲ្យផល ក្នុងភពអនាគតរបស់កម្មបច្ចុប្បន្ន ដែលជាឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម ទើបពោលថា **អត្ថិ កម្មំ ភវិស្សតិ កម្មវិបាកោ** កម្មមាន វិបាកនៃកម្មនឹងមាន ។

លោកកាន់យកវិបាកដែលមិនគួរឲ្យផលក្នុងភពអនាគត ដោយការព្រមព្រៀងនៃបច្ច័យ នៃកម្មបច្ចុប្បន្ន ដែលជាឧបបជ្ជវេទនីយកម្ម និងមិនគួរឲ្យផលដល់អ្នកគួរបរិនិព្វានក្នុងភពអនាគត ដែលជាអបរា-បរិយវេទនីយកម្ម ហើយទើបពោលថា **អត្ថិ កម្មំ ន ភវិស្សតិ កម្មវិបា-**



**កោ** កម្មនឹងមាន វិបាកនៃកម្មនឹងមិនមាន ។

លោកសម្តែងដល់បច្ចុប្បន្នកម្មយ៉ាងនេះទុក ៤ យ៉ាង ដោយអំណាចនៃវិបាក និងមិនមែនវិបាកក្នុងបច្ចុប្បន្ន និងអនាគត ។

លោកកាន់យកវិបាកដែលគួរឲ្យផលក្នុងអនាគត នៃកម្មដែលគួរធ្វើក្នុងភពអនាគត ហើយទើបពោលថា **ភវិស្សតិ កម្មំ ភវិស្សតិ កម្មវិបាកោ** កម្មមាន វិបាកនៃកម្មនឹងមាន ។

លោកកាន់យកវិបាកដែលមិនគួរឲ្យផល ដោយការព្រមព្រៀងនៃបច្ច័យរបស់កម្មអនាគតនោះ និងមិនគួរឲ្យផលរបស់អ្នកបរិនិព្វានក្នុងភពអនាគតហើយ ទើបពោលថា **ភវិស្សតិ កម្មំ ន ភវិស្សតិ កម្មវិបាកោ** កម្មនឹងមាន វិបាកនៃកម្មនឹងមិនមាន ។

លោកសម្តែងកម្មអនាគតយ៉ាងនេះទុក ២ យ៉ាង ដោយអំណាចនៃវិបាក និងមិនមែនវិបាកក្នុងអនាគត ដែលលោកធ្វើកម្មទាំងអស់នោះ ជាចំណែកដូចគ្នា ហើយសម្តែងកម្ម ១២ យ៉ាង ។ លោកតាំងនៅក្នុងឋានៈនេះ ហើយនាំកម្មចតុក្កៈ ៣ មកពោល កាលពោលកម្មចតុក្កៈនោះហើយ សេចក្តីនេះនឹងប្រាកដច្បាស់ថា ព្រោះកម្ម ៤ យ៉ាង គឺ ទិដ្ឋធម្មវេទនីយកម្ម ១ ឧបបជ្ជវេទនីយកម្ម ១ អបរា-បរិយវេទនីយកម្ម ១ អហោសិកម្ម ១ ។

ក្នុងកម្មទាំងនោះ ជវនចេតនាគ្រាដំបូង ជាកុសលក្តី ជាអកុសលក្តី ក្នុង ៧ ខណៈចិត្ត ក្នុងជវនវីថិចិត្ត ១ ឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ។ ទិដ្ឋធម្មវេទនីយកម្មនោះ រមែងឲ្យផលក្នុងអត្តភាពនេះប៉ុណ្ណោះ តែកាលមិនអាចឲ្យផលយ៉ាងនោះ ក៏ជាអហោសិកម្មដោយអំណាចតិកៈនេះថា កម្មមានរួចហើយ វិបាកនៃកម្មមិនទាន់មានហើយ វិបាកនៃកម្មនឹងមិនមាន វិបាកនៃកម្មមិនមានដូច្នេះ ។ ចំណែកជវនចេតនាដួងទី ៧ ឲ្យសម្រេចប្រយោជន៍ ឈ្មោះថា ឧបបជ្ជវេទនីយកម្ម ។

ឧបបជ្ជវេទនីយកម្មនោះ រមែងឲ្យផលក្នុងអត្តភាពជាលំដាប់ កាលមិនអាចឲ្យផលយ៉ាងនោះបាន ក៏ជាអហោសិកម្ម តាមន័យដូចពោលហើយនោះឯង ។ មួយ៉ាងទៀត ជវនចេតនា ៥ ដួង ក្នុងរវាងកម្មទាំងពីរនោះ ឈ្មោះថា អបរាបរិយវេទនីយកម្ម ។ អបរាបរិយវេទនីយកម្មនោះ រមែងបានឱកាសខណៈណាក្នុងអនាគត រមែងឲ្យផលកាលនោះ កាលនៅមានការវិលវល់នៅក្នុងសង្សារ ឈ្មោះថា អហោសិកម្មមិនមាន ។

កម្ម ៤ យ៉ាង សូម្បីដទៃជា គរុកម្ម ពហុលកម្ម អាសន្នកម្ម និងកដត្តាវាបនកម្ម ( កម្មត្រឹមតែធ្វើ ) ។ ក្នុងកម្មនោះ កើតបានទាំងកុសល និងអកុសលក្នុងកម្មធ្ងន់ និងស្រាល កម្មណាធ្ងន់មានសម្លាប់



មាតាជាដើម ឬមហគ្គតកម្ម ( កម្មកើតពីការបានឈាន ) កម្មនោះឯងឲ្យផលមុន ។ មួយ៉ាងទៀត សូម្បីក្នុងកម្មក្រាស់ និងមិនក្រាស់ កម្មណាក្រាស់ មានភាពជាអ្នកមានសីលក្តី ជាអ្នកទ្រុស្តសីលក្តី កម្មនោះរមែងឲ្យផលមុន ។ កម្មដែលរលឹកដល់ក្តី កម្មដែលធ្វើហើយក្តី ក្នុងវេលាជិតស្លាប់ ឈ្មោះថា អាសន្នកម្ម ។ ពិតណាស់ អ្នកជិតនឹងស្លាប់អាចរលឹកដល់ ឬធ្វើកម្មណា ការបានអាសេវនៈរឿយ ៗ ផុតចាកកម្ម ៣ ទាំងនេះ រមែងកើតឡើងដោយកម្មនោះឯង ឈ្មោះថា កដត្តាវាបនកម្ម ។ ក្នុងកាលមិនមានកម្មទាំងនោះ កដត្តាវាបនកម្មនោះរមែងឲ្យបដិសន្ធិ ។

កម្ម ៤ យ៉ាងដទៃទៀត គឺ ជនកកម្ម ( កម្មតាក់តែងឲ្យកើត ) ឧបត្ថម្ភកកម្ម ( កម្មឧបត្ថម្ភ ) ឧបបីឡកកម្ម ( កម្មបៀតបៀន ) ឧបឃាតកកម្ម ( កម្មកាត់ផ្តាច់ ) ។ ក្នុងកម្ម ៤ យ៉ាងនោះ កម្មដែលជាកុសលខ្លះ អកុសលខ្លះ ឈ្មោះថា ជនកកម្ម ។ ជនកកម្មនោះ ញុំាងរូបវិបាក និងអរូបវិបាកឲ្យកើត សូម្បីក្នុងការប្រព្រឹត្តទៅក្នុងបដិសន្ធិ ។

ចំណែកឧបត្ថម្ភកកម្ម មិនអាចឲ្យវិបាកកើតបាន រមែងឧបត្ថម្ភសុខ និងទុក្ខដែលកើតឡើង ក្នុងវិបាកដែលកើតហើយដោយបដិសន្ធិដែលកម្មដទៃឲ្យ រមែងឲ្យប្រព្រឹត្តទៅរហូតកាលឆ្ងាយ ។

ឧបបីឡកកម្ម រមែងបៀតបៀន បៀតបៀនសុខ និងទុក្ខដែលកើតក្នុងវិបាកដែលកើតហើយដោយបដិសន្ធិដែលកម្មដទៃឲ្យ រមែងមិនឲ្យប្រព្រឹត្តទៅរហូតកាលឆ្ងាយបាន ។

ចំណែកឧបឃាតកកម្ម កាត់ផ្តាច់កម្មដែលមានកម្លាំងខ្សោយដទៃ ដែលជាកុសលខ្លះ អកុសលខ្លះ ហើយការពារវិបាកនៃកម្មនោះ ធ្វើឱកាសដល់វិបាករបស់ខ្លួន ក៏កាលឱកាសដែលកម្មនោះធ្វើហើយ លោកពោលថា កម្មនោះឈ្មោះថា កើតវិបាក ។

ដោយប្រការដូច្នេះ វេលាកម្ម និងវេលាវិបាកនៃកម្ម ១២ ទាំងនេះ រមែងប្រាកដដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដោយភាវៈជាវត្ថុដែលពិតប្រាកដនៃកម្មវិបាក ញាណមិនទូទៅដល់សាវកទាំងឡាយ ។ អ្នកអប់រំវិបស្សនាគប្បីដឹងវេលាកម្ម និងវេលាវិបាកដោយឯកទេស ។ ព្រោះដូច្នោះ លោកប្រកាសសេចក្តីវិសេសនៃកម្មនេះ ដោយឃើញត្រឹមតែជាមាតិកា ។ លោកពោលបឋមវារៈ ៣ ដោយអំណាចកម្មសុទ្ធ ៗ យ៉ាងនេះហើយ ចែកកម្មនោះឯងចេញជា ២ ចំណែក ហើយទើបពោលដល់វារៈ ១០ ដទៃទៀតដោយបរិយាយ ១០ ដោយអំណាចនៃគូរបស់កម្មមានកុសលកម្ម និងអកុសលកម្មជាដើម ។

ក្នុងកុសលកម្ម និងអកុសលកម្មនោះ ឈ្មោះថា **កុសលំ** ព្រោះ



អត្ថថា មិនមានរោគ ឈ្មោះថា **អកុសលំ** ព្រោះអត្ថថា មិនមានរោគរកមិនបាន ( មានរោគ ) លោកពោលទុកៈនេះ ដោយអំណាចនៃជាតិ ។

អកុសលនោះឯង ជាសាវជ្ជៈ ( មានទោស ) ព្រោះប្រកបដោយទោស មានរាគៈជាដើម កុសល ជាអនវជ្ជៈ ( មិនមានទោស ) ព្រោះមិនមានទោស មានរាគៈជាដើមនោះ ។ អកុសលឈ្មោះថា កណ្ហធម៌ ( ធម៌ខ្មៅ ) ព្រោះមិនបរិសុទ្ធ ឬព្រោះជាហេតុកើតធម៌ខ្មៅ ។ កុសល ឈ្មោះថា សុកធម៌ ( ធម៌ស ) ព្រោះបរិសុទ្ធ ឬព្រោះជាហេតុកើតធម៌ស កុសលឈ្មោះថា **សុខុទ្រយ** (កម្មមានសុខជាកម្រៃ) ព្រោះចម្រើនដោយសេចក្តីសុខ អកុសលឈ្មោះថា **ទុក្ខុទ្រយ** ( កម្មមានទុក្ខជាកម្រៃ ) ព្រោះចម្រើនដោយទុក្ខ ។ កុសលមានសុខជាវិបាក ព្រោះមានផលជាសុខ ។ អកុសលមានទុក្ខជាវិបាក ព្រោះមានផលជាទុក្ខ ។ គប្បីជ្រាបអាការផ្សេងគ្នានៃកម្មទាំងនោះ ដោយប្រការដូច្នេះឯង ។

(ចប់ អដ្ឋកថាកម្មកថា)

# ៨-អដ្ឋកថាវិបល្លាសកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តីដែលនៅមិនធ្លាប់ពណ៌នា នៃវិបល្លាសកថា ដែលមានព្រះសូត្រជាបទនាំ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកក្នុងវិបល្លាស ដែលជាបច្ច័យនៃកម្មនោះ ពោលហើយ ។ គប្បីជ្រាបសេចក្តីក្នុងព្រះសូត្រសិន ។ បទថា **សញ្ញាវិបល្លាសា** គឺ មានការសម្គាល់ឃ្លៀងឃ្លាតជាសភាវៈ អធិប្បាយថា មានសញ្ញាវិបរិត ។ សូម្បីក្នុងពីរបទដ៏សេសក៏មានន័យដូចគ្នា ។ សញ្ញាវិបល្លាស រមែងប្រាកដក្នុងកាលនៃកិច្ចរបស់ខ្លួន មានកម្លាំងដោយអកុសលសញ្ញា ប្រាសចាកទិដ្ឋិ ក្នុងឋានៈនៃកិច្ចរបស់ចិត្តមានកម្លាំងខ្សោយ ។

ចិត្តវិបល្លាស រមែងប្រព្រឹត្តទៅក្នុងកាលនៃកិច្ចរបស់ខ្លួន ជាអកុសលចិត្តប្រាសចាកទិដ្ឋិមានកម្លាំង ។

ទិដ្ឋិវិបល្លាស រមែងប្រព្រឹត្តទៅក្នុងចិត្តដែលសម្បយុត្តដោយទិដ្ឋិ ។

ព្រោះដូច្នោះ សញ្ញាវិបល្លាស មានកម្លាំងខ្សោយជាងទាំងអស់ ។ ចិត្តវិបល្លាសមានកម្លាំងច្រើនជាង សញ្ញាវិបល្លាសនោះ ។ ទិដ្ឋិវិបល្លាសមានកម្លាំងច្រើនជាងទាំងអស់ ។ ពិតណាស់ ឈ្មោះថា ការសម្គាល់ ព្រោះកាន់យកត្រឹមតែអាការប្រាកដនៃអារម្មណ៍ ដូចការឃើញកហាបណៈរបស់ទារកដែលនៅមិនទាន់ដឹងក្តី ។ ឈ្មោះថា ការគិត ព្រោះសូម្បីដល់ការដឹងច្បាស់លក្ខណៈ ដូចការឃើញកហាបណៈរបស់អ្នកស្រុក ។ ឈ្មោះថា ការឃើញ ព្រោះស្ទាបវត្ថុដែលចាប់កាន់ ដូចការចាប់ដែកដោយដង្កាប់ធំរបស់ជាងដែក ។



បទថា **អនិច្ចេ និច្ចន្តិ សញ្ញាវិបល្លាសោ** ការសម្គាល់ខុសក្នុងសភាវៈដែលមិនទៀង ថាទៀង គឺ ការសម្គាល់ដែលកើតឡើងព្រោះចាប់យកក្នុងវត្ថុមិនទៀងថា នេះទៀង ឈ្មោះថា សញ្ញាវិបល្លាស ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងដោយន័យនេះ ។

បទថា **ន សញ្ញាវិបល្លាសោ ន ចិត្តវិបល្លាសោ ន ទិដ្ឋិវិបល្លាសោ** ការសម្គាល់មិនខុស ការគិតមិនខុស ការឃើញមិនខុស លោកពោលដល់ការកាន់យកតាមសេចក្តីពិត ព្រោះមិនមានការប្រកាន់ខុស ១២ យ៉ាង ក្នុងវត្ថុ ៤ យ៉ាង ។

គប្បីជ្រាបសេចក្តីក្នុងគាថាទាំងឡាយ ដូចតទៅនេះ ។ បទថា **អនត្តនិ ច អត្តា** គឺ មានការសម្គាល់យ៉ាងនេះថា ក្នុងសភាវៈដែលមិនមែនតួខ្លួន ថាតួខ្លួន ។ បទថា **មិច្ឆាទិដ្ឋិហតា** ត្រូវការឃើញខុស

នាំទៅ គឺ មិនត្រឹមតែមានការសម្គាល់តែម្យ៉ាងប៉ុណ្ណោះ ត្រូវញុំាងការឃើញខុសដែលកើតឡើង ដោយសញ្ញានាំទៅ ។ បទថា **ចិត្តចិត្តា** មានចិត្តឃ្លេងឃ្លោង គឺ ប្រកបដោយចិត្តឃ្លេងឃ្លោង វិលទៅដែលកើតឡើងដោយសញ្ញា និងទិដ្ឋិ ។ បទថា **វិសញ្ញិនោ** មានសញ្ញាខុស នេះត្រឹមតែជាទេសនា ។ សេចក្តីថា មានការសម្គាល់ ការគិត និងការឃើញវិបរិត ។

ម្យ៉ាងវិញទៀត ព្រោះសញ្ញាជាតួនាំ លោកទើបពោលសញ្ញាវិបល្លាសដោយ ៤ បទ នៃទិដ្ឋិមុន បន្ទាប់ពីនោះទើបពោលបទថា **មិច្ឆាទិដ្ឋិហតា** ត្រូវមិច្ឆាទិដ្ឋិនាំទៅ ជាទិដ្ឋិវិបល្លាស ។ បទថា **ចិត្ត-ចិត្តា** ចិត្តឃ្លេងឃ្លោង ជាចិត្តវិបល្លាស ។ បទថា **វិសញ្ញិនោ** មានសញ្ញាខុស គឺ ដល់មោហៈប្រាសចាកសញ្ញាប្រក្រតី ដោយការកាន់យកវិបល្លាស ៣ ដូចក្នុងបទនេះថា សន្ទប់ព្រោះកម្លាំងពិសដល់វិសញ្ញី ( អស់ការដឹង ) ។ បទថា **តេ យោគយុត្តា មារស្ស** គឺ សត្វទាំងនោះ ឈ្មោះថា ជាប់នៅក្នុងអន្ទាក់របស់មារ ។ បទថា **អយោគក្ខេមិនោ** ជាសត្វមិនមានការរួចផុតចាកកិលេស គឺ មិនសម្រេចនិព្វានដែលជាទីក្សេមចាកយោគៈ គឺ ចង្រៃ ៤ ។ បទថា **សត្តា គច្ឆន្តិ សំសារំ** សត្វទាំងឡាយត្រូវទៅកាន់សង្សារ គឺ បុគ្គល



ទាំងនោះឯងត្រូវត្រាច់ទៅកាន់សង្សារ ។ តើដូចម្តេច ? ព្រោះសត្វទាំងនោះត្រូវទៅកាន់ជាតិ និងមរណៈ ដូច្នោះទើបត្រូវត្រាច់ទៅ ។ បទថា **ពុទ្ធា** គឺ ព្រះសព្វញ្ញូអ្នកត្រាស់ដឹង អរិយសច្ច ៤ ជាពហុ-វចនៈដោយអំណាចទូទៅក្នុងកាល ៣ ។ បទថា **លោកស្មឹ** គឺ ក្នុងឱកាសលោក ។ បទថា **បភង្ករា** មានពន្លឺភ្លឺស្វាង គឺ ធ្វើលោកឲ្យភ្លឺស្វាងដោយបញ្ញា ។ បទថា **ឥមំ ធម្មំ បកាសេន្តិ** ព្រះពុទ្ធជាម្ចាស់ទាំងឡាយទ្រង់ប្រកាសព្រះធម៌ គឺ ទ្រង់សម្តែងធម៌លះបង់វិបល្លាស ។ បទថា **ទុក្ខូបសមគាមិនំ** ឲ្យដល់ភាពស្ងប់រម្ងាប់ទុក្ខ គឺ ដល់និព្វានដែលជាការស្ងប់រម្ងាប់ទុក្ខ ។ បទថា **តេសំ សុត្វាន** គឺ ស្តាប់ធម៌របស់ព្រះពុទ្ធជាម្ចាស់ទាំងនោះ ។ បទថា **សប្បញ្ញា** អ្នកមានបញ្ញា គឺ មានបញ្ញាដែលជាការសមគួរ ។ បទថា **សចិត្តំ បច្ចលទ្ធុ** ត្រឡប់បានការគិត គឺ ត្រឡប់បានការគិតរបស់ខ្លួនវៀរការវិបល្លាស ។ កាត់បទជា **បដិអលទ្ធុ** ។ ម្យ៉ាងទៀត កាត់បទជា **បដិលភឹសុ បដិអលទ្ធុំ** ។ បទថា **អនិច្ចតោ ទក្ខុំ** បានឃើញដោយភាពជាសភាវៈមិនទៀង គឺ បានឃើញដោយអំណាចនៃភាពជាសភាវៈមិនទៀងនោះឯង ។ បទថា **អត្តនិ អនត្តា** ឃើញសភាពដែលមិនមែនតួខ្លួនដោយភាពជាសភាវៈមិនមែនតួខ្លួន គឺ បានឃើញថា ភាពមិនមែនតួខ្លួនថាជាភាវៈមិនមែន

តួខ្លួននោះឯង ។ ម្យ៉ាងវិញទៀត បានឃើញសភាវៈមិនមែនតួខ្លួនថា តួខ្លួនមិនមានក្នុងវត្ថុ ។ បទថា **សម្មាទិដ្ឋិ សមាទានា** ជាអ្នកកាន់យកសម្មាទិដ្ឋ គឺ ការឃើញប្រពៃ ។ បទថា **សព្វទុក្ខំ អបច្ចគុំ** កន្លងចាកទុក្ខទាំងពួង គឺ ឈានកន្លងវដ្ដទុក្ខទាំងអស់ ។ បទថា **ទិដ្ឋិសម្បន្នស្ស** អ្នកដល់ព្រមដោយទិដ្ឋិនៃពាក្យសួរលះហើយ និងលះទូទៅ គឺ ព្រះ-សោតាបន្ន ។ បទថា **ទុក្ខេ សុខន្តិ សញ្ញា ឧប្បជ្ជតិ ចិត្តំ ឧប្បជ្ជតិ** ការសម្គាល់ ការគិតក្នុងភាពជាទុក្ខថា ជាសេចក្ដីសុខរមែងកើតឡើង គឺ ត្រឹមតែការសម្គាល់ ឬត្រឹមតែការគិត រមែងកើតឡើង ព្រោះនៅលះការសន្សំមោហៈមិនបាន រមែងកើតឡើងសូម្បីដល់ព្រះអនាគាមី មិនចាំបាច់និយាយថ្វីដល់ព្រះសោតាបន្ន ។ វិបល្លាសទាំងពីរនេះ ព្រះអរហន្តប៉ុណ្ណោះ ទើបលះបាន ។

បទថា **អសុភេ សុភន្តិ សញ្ញា ឧប្បជ្ជតិ ចិត្តំ ឧប្បជ្ជតិ** ការសម្គាល់ ការគិតក្នុងសភាវៈដែលមិនស្អាតថា ស្អាតកើតឡើង គឺ កើតឡើងសូម្បីដល់ព្រះសកទាគាមី មិនចាំបាច់និយាយថ្វីដល់ព្រះ-សោតាបន្ន ។ វិបល្លាសទាំងពីរនេះ ព្រះអនាគាមីទើបលះបាន លោកពោលទុកក្នុងអដ្ឋកថាដោយប្រការដូច្នេះ ព្រោះដូច្នោះ គប្បីជ្រាបថា ទាំងពីរនេះ លោកពោលសំដៅដល់ព្រះសោតាបន្ន និងព្រះសកទាគាមី ។



ព្រោះព្រះអនាគាមី លះកាមរាគៈបានហើយ គប្បីជ្រាបថា លោកពោលដល់ការលះការសម្គាល់ខុស ការគិតខុសក្នុងសភាវៈមិនស្អាតថាស្អាត ។ ដោយបទថា **ទ្វីសុ វត្ថូសុ** ជាដើម លោកសម្ដែងសរុបដល់ការលះ និងការលះទូទៅ ។ ក្នុងបទនោះ ជាការលះវិបល្លាស ៦ ក្នុងវត្ថុ ២ ទាំងនេះ គឺ ក្នុងសភាវៈមិនទៀងថាទៀង ក្នុងសភាវៈមិនមែនតួខ្លួនថាតួខ្លួន ជាការលះទិដ្ឋិវិបល្លាស ២ ក្នុងវត្ថុ ២ ទាំងនេះ គឺ ក្នុងសភាវៈជាទុក្ខថាជាសុខ ក្នុងសភាវៈមិនស្អាតថាស្អាត ។ ក្នុងគម្ពីរខ្លះ គម្ពីរលោកសសេរ បទថា **ទ្វេ** មុន ។ សសេរបទថា **ឆ** ក្នុងខាងក្រោយ ។ បទថា **ចតូសុ វត្ថូសុ** លោកពោលដល់វិបល្លាស ៤ រួមជា ១ ។ បទថា **អដ្ឋ** បានដល់ វិបល្លាស ៦ ក្នុងវត្ថុ ២ វិបល្លាស ២ ក្នុងវត្ថុ ២ រួមជាវិបល្លាស ៨ ។ បទថា **ចត្តារោ** គឺ វិបល្លាស ៤ បានដល់ សញ្ញាវិបល្លាស និងចិត្តវិបល្លាសមួយយ៉ាង ២ ក្នុងវត្ថុមួយ ៗ ក្នុងបណ្ដាវត្ថុដែលជាទុក្ខ និងមិនស្អាត ក្នុងគម្ពីរខ្លះ លោកសសេរទុកយ៉ាងនោះដូចគ្នា សូម្បីក្នុងកន្លែងដែលលោកពោលថា **ឆ ទ្វីសុ** វិបល្លាស ៦ ក្នុងវត្ថុ ២ ដូច្នេះឯង ។

(ចប់ អដ្ឋកថាវិបល្លាសកថា)

## ៩–អដ្ឋកថា មគ្គកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តីដែលនៅមិនធ្លាប់ពណ៌នា នៃមគ្គកថា ដែលព្រះសារីបុត្តត្ថេរសម្តែងអរិយមគ្គធ្វើការលះវិបល្លាស ៣ ទាំងនោះពោលហើយ ។

ក្នុងបទទាំងនោះ បទថា **មគ្គោតិ កេនដ្ឋេន មគ្គោ** បទថា **មគ្គោ** ឈ្មោះថា មគ្គដោយអត្ថថាអ្វី គឺ ក្នុងព្រះពុទ្ធសាសនាលោកពោលថា មគ្គដោយអត្ថថាអ្វី ។ ក្នុងបរិយាយ ១០ មានជាអាទិ៍ថា **មិច្ឆាទិដ្ឋិយា បហានាយ** ដើម្បីលះមិច្ឆាទិដ្ឋិ លោកពោលដល់មគ្គមួយ ៗ ដោយអំណាចជាសត្រូវដោយត្រង់នៃអង្គមគ្គនោះ ៗ ។ បទថា **មគ្គោ ចេវ ហេតុ ច** ជាមគ្គ និងជាហេតុ គឺ ឈ្មោះថា **មគ្គ** ដោយអត្ថថា ជាផ្លូវចំពោះ ដើម្បីធ្វើកិច្ចនោះ ៗ ឈ្មោះថា **ហេតុ** ដោយអត្ថថា ជាអ្នកធ្វើឲ្យដល់ ដោយហេតុនោះ លោកទើបពោលដល់មគ្គមានអត្ថថា ជាផ្លូវចំពោះ និងមានអត្ថថា ជាអ្នកនាំឲ្យដល់មគ្គ មគ្គជាផ្លូវចំពោះ ក្នុងបទជាដើមថា នេះជាមគ្គ នេះជាបដិបទា ហេតុជាអ្នកនាំឲ្យដល់ ក្នុងប្រយោគមានជាដើមថា មគ្គមានអត្ថថា នាំចេញទៅ មានអត្ថថា ជាហេតុនៃមគ្គ ដោយបទទាំងពីរនេះ ដែលលោកធ្វើការឆ្លើយនឹងពាក្យសួរថា **មគ្គោតិ កេនដ្ឋេន មគ្គោ** ដូច្នេះ ។



បទថា **សហជាតានំ ធម្មានំ ឧបត្ថម្ភនាយ** ដើម្បីឧបត្ថម្ភសហជាតធម៌ គឺ ដើម្បីជាការឧបត្ថម្ភអរូបធម៌ដែលកើតព្រមនឹងខ្លួន ដោយភាពជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ ជាដើម ។ បទថា **កិលេសានំ បរិយាទាយ** ដើម្បីគ្របសង្កត់កិលេសទាំងឡាយ គឺ ដើម្បីឲ្យកើតកិលេសដ៏សេសដូចពោលហើយ ដែលមគ្គនោះ ៗ ទម្លាយឲ្យអស់ទៅ ។ ក្នុងបទនេះថា **បដិវេធាទិវិ-សោធនាយ** ដើម្បីសេចក្តីបរិសុទ្ធក្នុងខាងដើមនៃបដិវេធ មានសេចក្តីដូច្នេះ ព្រោះសីល និងទិដ្ឋិជាខាងដើមនៃសច្ចបដិវេធ ដោយបាលីថា អ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ សីលបរិសុទ្ធដោយល្អ និងទិដ្ឋិដែលត្រង់ សីល និងទិដ្ឋិនោះ រមែងបរិបូណ៌ដោយមគ្គក្នុងខាងដើម ដូច្នោះលោកទើបពោល **បដិវេធាទិវិសោធនាយ** ដូច្នេះ ។ បទថា **ចិត្តស្ស អធិដ្ឋានាយ** ដើម្បីការតាំងមាំនៃចិត្ត គឺ ដើម្បីការតាំងមាំក្នុងកិច្ចរបស់ខ្លួននៃចិត្តដែលសម្បយុត្តគ្នា ។ បទថា **ចិត្តស្ស វោទានាយ** ដើម្បីការផូរផង់នៃចិត្ត គឺ ដើម្បីបរិសុទ្ធនៃចិត្ត ។ បទថា **វិសេ-សាធិគមាយ** ដើម្បីសម្រេចធម៌វិសេស គឺ ដើម្បីបានចំពោះគុណវិសេសជាធម៌ជាលោកិយៈ ។ បទថា **ឧត្តរិបដិវេធាយ** ដើម្បីចាក់ធ្លុះធម៌ដ៏ក្រៃលែង គឺ ដើម្បីចាក់ធ្លុះធម៌ដែល ក្រៃលែងជាងធម៌ជា

លោកិយៈ ។ បទថា **សច្ចាភិសមយាយ** ដើម្បីត្រាស់ដឹងសច្ចៈ គឺដើម្បីត្រាស់ដឹងធម៌ឯកនៃអរិយសច្ច ៤ គឺ ដើម្បីចាក់ធ្លុះធម៌ឯក ដោយអំណាចញុំាងកិច្ចឲ្យសម្រេច ។ បទថា **និរោធេបតិដ្ឋាបនាយ** ដើម្បីឲ្យចិត្តតាំងនៅក្នុងនិរោធ គឺ ដើម្បីឲ្យចិត្តឬបុគ្គលតាំងនៅក្នុងនិព្វាន ។ លោកធ្វើអង្គនៃមគ្គ ៨ ជាចំណែកដូចគ្នាហើយ លោកពោលដល់ការលះកិលេសដែលមគ្គនោះ ៗ ទម្លាយក្នុងខណៈនៃសកទាគាមិមគ្គជាដើម ហេតុក្នុងចំពោះពោលយ៉ាងនេះ លោកពោលហើយក្នុងខាងក្រោយ ព្រោះការជម្រះក្នុងខាងដើមដោយល្អ និងការផូរផង់នៃចិត្តដោយល្អ រមែងមានបានដោយមគ្គខ្ពស់ ៗ ដូច្នោះលោកទើបពោលបទទាំងឡាយសូម្បីទាំងនោះ ។

ដោយបទមានជាអាទិ៍ថា **ទស្សនមគ្គោ** ជាមគ្គនៃការឃើញ លោកពោលដល់អត្ថនៃមគ្គ ដោយអំណាចនៃលក្ខណៈរបស់ធម៌នោះរហូតដល់ទីបំផុត ។ បទសូម្បីទាំងអស់នោះ មានសេចក្តីដូចដែលលោកពោលទុកហើយក្នុងអភិញ្ញេយ្យនិទ្ទេស ( សម្តែងដល់ធម៌ដែលគួរដឹងក្រៃលែង ) ។ ក្នុងបទនេះ លោកសម្តែងដល់មគ្គដែលជាលោកិយៈ និងលោកុត្តរៈតាមដែលកើតយ៉ាងនេះ ។ លោកសម្តែងដល់មគ្គដោយអត្ថថា ជាហេតុ ។ម្យ៉ាងទៀត ព្រោះមគ្គនោះជាមគ្គ



ដោយត្រង់ លោកទើបមិនពោលថា **មគ្គោ** ។ បទមានជាអាទិ៍ថា **អធិបតេយ្យដ្ឋេន ឥន្ទ្រិយា** ឈ្មោះថា ឥន្ទ្រិយដោយអត្ថថា ជាធំ លោកពោលដោយអំណាចនៃអត្ថរបស់ឥន្ទ្រិយជាដើម ។ ម្យ៉ាងទៀតក្នុងបទថា **សច្ចានិ** នេះ បានដល់ សច្ចញាណ ។ ធម៌ទាំងនោះសូម្បីទាំងអស់ ឈ្មោះថា មគ្គ ដោយអត្ថថា ជាផ្លូវបដិបត្តិដើម្បីនិព្វាន ។ ម្យ៉ាងទៀត និព្វាន លោកពោលទុកក្នុងទីបំផុត គប្បីជ្រាបថា លោកពោលថា មគ្គ ព្រោះសប្បុរសអ្នកត្រូវសង្សារទុក្ខគ្របសង្កត់ អ្នកត្រូវការផុតចាកទុក្ខគប្បីស្វែងរក ។

(ចប់ អដ្ឋកថាមគ្គកថា)

## ១០–អដ្ឋកថា មណ្ឌបេយ្យកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្ដីដែលនៅមិនធ្លាប់ពិចារណានៃមណ្ឌបេយ្យកថា ( របស់ថ្លាដែលគួរផឹក ប្រៀបដោយគុណធម៌ ) ដែលជាខាងដើមចំណែកមួយ របស់ព្រះតម្រាស់នៃព្រះ-ដ៏មានព្រះភាគជាម្ចាស់ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងសេចក្ដីដែលមគ្គនោះជាធម៌ថ្លូវផង់គួរផឹក ត្រាស់ទុកហើយ ។

ក្នុងបទទាំងនោះ បទថា **មណ្ឌបេយ្យំ** ជាព្រហ្មចរិយថ្លាថ្លូវផង់គួរផឹក ឈ្មោះថា **មណ្ឌោ** ដោយអត្ថថា ថ្លាថ្លូវផង់ ដូចទឹកដោះថ្លាដែលសម្បុណ៌ស្អាតថា លោកហៅថា **សប្បិមណ្ឌ** ការថ្លាថ្លូវផង់របស់ទឹកដោះថ្លា ដូច្នោះ ។ ឈ្មោះថា **បេយ្យំ** ដោយអត្ថថា គួរផឹក ។ ជនទាំងឡាយផឹករបស់ណា គួរផឹកហើយចុះទៅក្នុងរវាងថ្ពល់ អស់ការដឹងសូម្បីសំពត់ស្លៀកជាដើមរបស់ខ្លួន ក៏នៅមិនជាប់នឹងខ្លួន របស់គួរផឹកនោះសូម្បីថ្លាក៏មិនគួរផឹក ។ ចំណែកសាសនព្រហ្មចរិយ គឺត្រៃសិក្ខានេះ របស់តថាគត ឈ្មោះថា ព្រោះសម្បូណ៌ ព្រោះមិនមានមន្ទិល ព្រោះថ្លាថ្លូវផង់ និងឈ្មោះថា គួរផឹក ព្រោះនាំប្រយោជន៍សុខមកឲ្យ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបទ្រង់សម្ដែងថា ជាព្រហ្មចរិយៈថ្លាគួរផឹក ។ ឈ្មោះថា **មណ្ឌបេយ្យំ** ព្រោះមាន



សភាពថា គួរផឹក ។ នោះគឺអ្វី ? គឺ សាសនព្រហ្មចរិយៈ ។ ព្រោះហេតុអ្វីត្រៃសិក្ខា ទើបឈ្មោះថា ព្រហ្មចរិយៈ ។ **និព្វាន** ឈ្មោះថា **ព្រហ្ម** ព្រោះអត្ថថា ខ្ពង់ខ្ពស់ ត្រៃសិក្ខាជាការប្រព្រឹត្តដើម្បីប្រយោជន៍ដល់ភាពខ្ពង់ខ្ពស់ ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់និព្វាន ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើប ត្រាស់ថា ជាព្រហ្មចរិយៈសាសនព្រហ្មចរិយៈ ក៏គឺ ត្រៃសិក្ខានោះឯង ។

បទថា **សត្ថា សម្មុខីភូតោ** ព្រះសាស្ដាមាននៅចំពោះមុខ នេះជាពាក្យសម្ដែងដល់ហេតុក្នុងបទនេះ ។ ក៏ព្រោះព្រះសាស្ដាមាននៅចំពោះមុខ ដូច្នោះ លោកទាំងឡាយចូរប្រកបការព្យាយាម ក្រេបផឹកព្រហ្មចរិយៈដ៏ថ្លានេះចុះ ព្រោះកាលក្រេបផឹកថ្នាំថ្លាខាងក្រៅមិនបាននៅចំពោះមុខពេទ្យ រមែងមានការសង្ស័យថា យើងមិនដឹងខ្នាត ឬការយកឡើងយកចុះ តែនៅចំពោះមុខពេទ្យ ក៏អស់សង្ស័យដោយគិតថា ពេទ្យនឹងដឹងការក្រេបផឹក ព្រះសាស្ដាអ្នកជាព្រះធម្មសាមីរបស់ពួកយើងមាននៅចំពោះមុខយ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបបបួលក្នុងការក្រេបផឹក ព្រហ្មចរិយៈដែលថ្លាថា ពួកលោកចូរធ្វើការព្យាយាមហើយក្រេបផឹកចុះ ។ ឈ្មោះថា **សត្ថា** ព្រោះតាមប្រៀន-ប្រដៅតាមសមគួរ នូវទិដ្ឋធម្មិកប្រយោជន៍ សម្បរាយិកប្រយោជន៍

និងបរមត្ថប្រយោជន៍ ។ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទនេះ សូម្បីដោយន័យនៃនិទ្ទេសមានជាដើមថា **សត្ថា ភគវា សត្ថវាហោ** ព្រះដ៏-មានព្រះភាគជាម្ចាស់ អ្នកទ្រទ្រង់នាំពួក ឈ្មោះថា **សត្ថវាហ** ឈ្មោះថា **សម្មុខីភូតោ** ព្រោះមានចំពោះមុខប្រាកដហើយ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងមណ្ឌបេយ្យនិទ្ទេស ដូចតទៅនេះ ។ បទថា **តិធត្តមណ្ឌោ** សេចក្ដីថ្លាមាន ៣ ប្រការ ឈ្មោះថា **តិធត្តំ** សេចក្ដីថ្លាក្នុងព្រះសាស្ដាដែលមាននៅចំពោះមុខមាន ៣ ប្រការ ឈ្មោះថា **តិធត្តមណ្ឌោ** សេចក្ដីថា សភាពថ្លាមាន ៣ យ៉ាង ។ បទថា **សត្ថរិ សម្មុខីភូតេ** ក្នុងព្រះសាស្ដាដែលមាននៅចំពោះមុខនេះ លោកពោលដើម្បីសម្ដែងភាពថ្លា ៣ ប្រការ ដែលបរិបូណ៌ដោយអាការទាំងពួង សូម្បីកាលព្រះសាស្ដាស្ដេចបរិនិព្វាន ភាពថ្លា ៣ ប្រការ នៅប្រព្រឹត្តទៅដោយឯកទ្ទេស ។ ម្យ៉ាងទៀត ក្នុងនិទ្ទេសនៃបទនោះ គប្បីជ្រាបថា លោកមិនបានពោលថា **សត្ថរិ សម្មុខីភូតេ** ហើយពោលថា **កតមោ ទេសនាមណ្ឌោ** សភាពថ្លានៃទេសនាតើដូចម្ដេច ? បទថា **ទេសនាមណ្ឌោ** សភាពថ្លានៃទេសនា គឺ ធម្មទេសនានោះឯងជាសភាពថ្លា ។ បទថា **បដិគ្គហមណ្ឌោ** សភាពថ្លានៃការទទួល គឺ អ្នកទទួលទេសនានោះឯង ជាអ្នកថ្លាផូរផង់ ។ បទថា **ព្រហ្មចរិយ-មណ្ឌោ** សភាពថ្លានៃព្រហ្មចរិយៈ គឺ មគ្គព្រហ្មចរិយៈនោះឯង ជាសភាពថ្លាផូរផង់ ។



បទថា **អាចិក្ខនា** ការប្រាប់ គឺ ដោយឈ្មោះថា ឈ្មោះទាំងឡាយនេះនៃសច្ចៈជាដើម គួរសម្ដែង ។ បទថា **ទេសនា** ការសម្ដែង គឺ ការបង្ហាញ ។ បទថា **បញ្ញបនា** ការបញ្ញត្តិ គឺ ការឲ្យដឹង ឬការតាំងទុកចំពោះមុខ គឺ ញាណ ពិតណាស់ កាលតាំងអាសនៈទុក លោកពោលថា ក្រាលអាសនៈ ។ បទថា **បដ្ឋបនា** ការតែងតាំង គឺ ការបញ្ញត្តិ សេចក្ដីថា ការប្រព្រឹត្តទៅ ឬការតាំងទុកចំពោះមុខ គឺ ញាណ ។ បទថា **វិវរណា** ការបើកបង្ហាញ គឺ ធ្វើការបើកបង្ហាញ សេចក្ដីថា ចង្អុលបង្ហាញ ។ បទថា **វិភជនា** ការចែក គឺ ធ្វើការចែក សេចក្ដីថា បង្ហាញដោយការចែក ។ បទថា **ឧត្តានីកម្មំ** ការធ្វើឲ្យងាយ គឺ ការធ្វើការប្រាកដ ។

ម្យ៉ាងវិញទៀត បទថា **អាចិក្ខនា** ជាបទសម្ដែងហេតុនៃបទ ៦ បទ មានទេសនាជាដើម ។ លោកពោល ៦ បទ មានទេសនាជាដើម ដើម្បីពង្រីកសេចក្ដីនៃបទថា **អាចិក្ខនា** ។ ក្នុង ៦ បទនោះ បទថា **ទេសនា** គឺ ការសម្ដែងដោយលើកមាតិកាឡើងមុនដោយសង្ខេប ដោយអំណាចនៃឧគ្ឃដិតញ្ញូបុគ្គល ព្រោះឧគ្ឃដិតញ្ញូបុគ្គល រមែងដឹងច្បាស់ ចាក់ធ្លុះបទដែលលោកពោលដោយសង្ខេប និងពោលឡើងមុន ។ បទថា **បញ្ញបនា** គឺ ការបញ្ញត្តិដោយការបង្ហាញបទ ដែលលោកសង្ខេបទុកមុនដោយពិស្ដារ ដោយការពេញចិត្តនៃការគិត និងដោយការវាងវៃនៃបញ្ញាក្នុងធម៌ទាំងនោះ ដោយអំណាចនៃវិបច្ចិត-

ញ្ញបុគ្គល ។ បទថា **បដ្ឋបនា** គឺ ការបញ្ញត្តិដោយការធ្វើឲ្យពិស្តារក្រៃលែងឡើង ដោយការបង្ហាញចំពោះនិទ្ទេសដែលលោកបង្ហាញធម៌ទាំងនោះទុកហើយ ។ បទថា **វិវរណា** គឺ ការបើកបង្ហាញបទ សូម្បីដែលលោកបង្ហាញទុកហើយ ដោយការនិយាយរឿយ ៗ ។ បទថា **វិភជនា** គឺ ចំណែក ដោយធ្វើការចែកសូម្បីបទដែលលោកពោលទុកហើយរឿយ ៗ ។ បទថា **ឧត្តានីកម្មំ** គឺ ធ្វើឲ្យងាយ ដោយពោលធ្វើបទដែលលោកបើកបង្ហាញហើយដោយពិស្តារ និងដោយពោលបង្ហាញបទដែលលោកចែកទុកហើយ ។ ទេសនានេះ រមែងមានដើម្បីការចាក់ធ្លុះសូម្បីរបស់នេយ្យបុគ្គលទាំងឡាយ ។

បទថា **យេ វា បនញ្ញេបិ កេចិ** ឬលោកអ្នកដឹងច្បាស់ពួកណាមួយ លោកសំដៅដល់វិនិបាតិកៈ ( ពួកអ្នកធ្លាក់ទៅក្នុងអបាយ ) មានមាតារបស់បិយង្ករៈជាដើម ។ បទថា **វិញ្ញាតារោ** អ្នកដឹងច្បាស់ គឺ អ្នកដឹងច្បាស់លោកុត្តរធម៌ដោយការចាក់ធ្លុះ ។ ពិតណាស់ លោកអ្នកដឹងច្បាស់ទាំងនេះ មានភិក្ខុជាដើម ឈ្មោះថា **បដិគ្គហា** អ្នកទទួល ព្រោះទទួលព្រះធម៌ទេសនាដោយអំណាចការចាក់ធ្លុះ ។ បទថា **អយមេវ** ជាដើម មានសេចក្ដីដូចលោកពោលទុកហើយក្នុងនិទ្ទេសនៃបឋមឈាន ។ អរិយមគ្គ លោកពោលថា ជាព្រហ្មចរិយៈ ព្រោះប្រព្រឹត្តដើម្បីប្រយោជន៍ដល់ធម៌ដែលប្រសើរ ព្រោះហូរទៅនិព្វាន ។



ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងប្រកបឥន្ទ្រិយពលៈ ពោជ្ឈង្គៈ និងអង្គនៃមគ្គ ដែលមាននៅក្នុងខណៈនៃមគ្គ ជាភាពថ្លាក្នុងការបង្អោនចិត្តជឿ ក្នុងនោះដោយបទនេះជាដើមថា **អធិ-មោក្ខមណ្ឌោ** សភាពថ្លានៃការបង្អោនចិត្តជឿ ក្នុងវិធីនៃព្រហ្មចរិយៈមានសភាពថ្លាគួរក្រេបផឹក ។

ក្នុងបទទាំងនោះ បទថា **អធិមោក្ខមណ្ឌោ** គឺ ភាពថ្លាដែលបានដល់ការបង្អោនចិត្តជឿ ។ បទថា **កសដោ** ជាកាកសំណល់ គឺ ល្អក់ប្រាសចាកការជ្រះថ្លា ។ បទថា **ឆឌ្ឌេត្វា** លះបង់ហើយ គឺ លះដាច់ជាសមុច្ឆេទ ។ បទថា **សទ្ធិន្ទ្រិយស្ស អធិមោក្ខមណ្ឌំ បិវតីតិ មណ្ឌ-បេយ្យំ** ក្រេបផឹកភាពថ្លានៃការបង្អោនចិត្តជឿនៃសទ្ធិន្ទ្រិយ ព្រោះហេតុនោះ សទ្ធិន្ទ្រិយ ទើបជាព្រហ្មចរិយៈមានភាពថ្លាគួរផឹក អធិប្បាយថា សូម្បីកាលសភាពថ្លានៃការបង្អោនចិត្តជឿ មិនជាដទៃចាកសទ្ធិន្ទ្រិយ លោកក៏ពោលធ្វើជាយ៉ាងដទៃដោយអំណាចនៃវោហារ ។ កូនថ្មកិន សូម្បីកាលកូនថ្មកិន មិនជាយ៉ាងដទៃមាននៅ លោកក៏ហៅថា សរីរៈនៃកូនថ្មកិនយ៉ាងណា ម្យ៉ាងទៀត ក្នុងបាលីលោកពោលភាវៈមិនជាយ៉ាងដទៃចាកធម្មតាក្នុងបទមានជាអាទិ៍ថា **ផុសិតត្តំ** សភាពជាវត្ថុសម្ផស្សបាន ដូចជាយ៉ាងដទៃយ៉ាងណា ម្យ៉ាងទៀត អដ្ឋកថាលោកពោលដល់លក្ខណៈមិនជាយ៉ាងដទៃចាកធម្មតា ក្នុងបទមានជាដើមថា

**ផុសនលក្ខណោ ផស្សោ** ផស្សៈមានលក្ខណៈពាល់ត្រូវ ដូចជាយ៉ាងដទៃយ៉ាងណា គប្បីជ្រាបសេចក្តីឧបមានេះ ដូច្នោះ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងបទដែលនៅមិនធ្លាប់ពោលដូចតទៅនេះ ។ បទថា **បរិឡាហោ** សេចក្តីក្តៅក្រហាយ គឺ ការក្តៅក្រហាយ ព្រោះកិលេសដែលជាបដិបក្ខចំពោះបីតិ ដែលមានលក្ខណៈរីករាយពេញចិត្ត ។ បទថា **ទុដ្ឋុល្លំ** សេចក្តីអាក្រក់គ្រោតគ្រាត គឺ សភាពគ្រោតគ្រាត ការមិនស្ងប់ដោយអំណាចកិលេសដែលជាបដិបក្ខចំពោះសេចក្តីស្ងប់ ។ បទថា **អប្បដិសង្ខា** សេចក្តីមិនពិចារណា គឺ ការនាំសេចក្តីមិនស្ងប់មកដោយអំណាចកិលេស ដែលជាបដិបក្ខចំពោះការពិចារណា ។

ព្រះដ៏មានព្រះភាគជាម្ចាស់ មានព្រះបំណងនឹងទ្រង់បង្ហាញដល់វិធីនៃព្រហ្មចរិយៈមានភាពថ្លាគួរក្រេបផឹក ដោយបរិយាយដទៃ ទើបត្រាស់ព្រះតម្រាស់ថា **អត្ថិ មណ្ឌោ** សភាពថ្លាមាន ។

ក្នុងបទទាំងនោះ បទថា **តត្ថ** គឺ ក្នុងសទ្ធិន្ទ្រិយនោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាដើមថា **អត្ថរសោ** អត្ថរស គឺ ការបង្អើនទៅនៃសទ្ធិន្ទ្រិយជាអត្ថ សទ្ធិន្ទ្រិយជាធម៌ សទ្ធិន្ទ្រិយនោះឯង ឈ្មោះថា **វិមុត្តិ** ព្រោះរួចចាកកិលេសផ្សេង ៗ ការដល់ព្រមនៃអត្ថនោះ ឈ្មោះថា **អត្ថរសោ អត្ថស** ការដល់ព្រមនៃធម៌នោះ , ឈ្មោះថា



**ធម្មរសោ** ធម្មរស ។ ការដល់ព្រមនៃវិមុត្តិនោះ ឈ្មោះថា **វិមុត្តិរស** ។

ម្យ៉ាងវិញទៀត ការត្រេកអរក្នុងការបានអត្ថ ឈ្មោះថា អត្ថរស ។ ការត្រេកអរក្នុងការបានធម៌ ឈ្មោះថា ធម្មរស ។ ការត្រេកអរក្នុងការបានវិមុត្តិ ឈ្មោះថា វិមុត្តិរស ។ បទថា **រតិ** ការត្រេកអរ គឺ សម្បយុត្តដោយរសនោះ ឬបីតិមានរសនោះជាអារម្មណ៍ ។ គប្បីជ្រាបអត្ថសូម្បីក្នុងបទដ៏សេសដោយន័យនេះ ។

ក្នុងបរិយាយនេះលោកពោលអត្ថថា ព្រហ្មចរិយៈថ្លាគួរក្រេបផឹក ឈ្មោះថា **មណ្ឌបេយ្យំ** ។

ព្រះដ៏មានព្រះភាគជាម្ចាស់ គ្រាទ្រង់សម្តែងព្រហ្មចរិយៈដែលថ្លាគួរក្រេបផឹកដោយអំណាចនៃឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ និងអង្គនៃមគ្គ តាមលំដាប់នៃពោធិបក្ខិយធម៌ មានឥន្ទ្រិយជាដើម យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងភាពថ្លានៃព្រហ្មចរិយៈ ដែលតាំងនៅក្នុងទីបំផុតទៀត ។ នឹងទ្រង់ធ្វើមគ្គឲ្យជាធម៌ដល់មុន ព្រោះមគ្គជាប្រធាន ទើបទ្រង់សម្តែងអង្គនៃមគ្គ ពោជ្ឈង្គៈ ពលៈ និងឥន្ទ្រិយ ។

បទមានជាដើមថា **អាធិបតេយ្យដ្ឋេន ឥន្ទ្រិយា មណ្ឌោ** ឥន្ទ្រិយមានភាពថ្លា ព្រោះអត្ថជាធំ គឺ ឥន្ទ្រិយជាលោកិយៈ និងលោកុត្តរៈមានភាពថ្លាតាមដែលប្រកបទុក ។ គប្បីជ្រាបបទនោះដោយន័យដូចពោលហើយក្នុងខាងក្រោយ ។

ម្យ៉ាងទៀត ក្នុងបទនេះថា **តថដ្ឋេន សច្ចា មណ្ឌោ** សច្ចៈជាភាពថ្លា ព្រោះអត្ថថា ជាសច្ចៈពិត គប្បីជ្រាបថា លោកពោលថា សច្ចញ្ញាណ ជាសច្ចៈ ព្រោះមិនមានទុក្ខសមុទយៈ ជាភាពថ្លាដូចក្នុងមហាហត្ថិបទោបមសូត្រ ។

ចប់ អដ្ឋកថាមណ្ឌបេយ្យកថា

និង

ចប់ អដ្ឋកថាមហាវគ្គ

**រួមកថាដែលមានក្នុងវគ្គនេះ គឺ**

**១-ញាណកថា ២-ទិដ្ឋិកថា ៣-អានាបានកថា ៤-ឥន្ទ្រិយកថា ៥-វិមោក្ខកថា ៦-គតិកថា ៧-កម្មកថា ៨-វិបល្លាសកថា ៩-មគ្គកថា ១០-មណ្ឌបេយ្យកថា និងអដ្ឋកថា ។**

និកាយដែលប្រសើរនេះជាវគ្គដែលប្រសើរមួយ

មិនមានវគ្គដទៃស្មើ លោកតាំងទុកហើយដូច្នេះឯង ។



## ១-អដ្ឋកថា យុគនទ្ធកថា

## អដ្ឋកថា យុគនទ្ធកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់ដែលនៅមិនទាន់ធ្លាប់ពោលនៃយុគនទ្ធកថា ដែលមានសូត្រជាបទប្រធាន ដែលព្រះអានន្ទត្ថេរសម្ដែងដល់គុណយុគនទ្ធធម៌ ( ធម៌ជាប់គ្នាជាគូ ) នៃអរិយមគ្គដែលជាគុណធម៌ផូរផង់ គួរក្រេបផឹក ។

ព្រះធម្មសេនាបតីសារីបុត្តត្ថេរ កាលព្រះមានព្រះភាគជាម្ចាស់ដែលជាព្រះធម្មរាជា ទ្រង់មានព្រះជន្មនៅឡើយ ទ្រង់បានបរិនិព្វានក្នុងវស្សាដែលព្រះអង្គទ្រង់ជាព្រះធម្មរាជា ស្ដេចបរិនិព្វាន ។ ដូច្នេះគប្បីជ្រាបថា កាលព្រះធម្មរាជាទ្រង់មានព្រះជន្មនៅឡើយ ព្រះធម្មសេនាបតីសារីបុត្តបានស្ដាប់សូត្រនេះ ដែលព្រះអានន្ទជាធម្មភណ្ឌាគារិកៈ ( ឃ្លាំងព្រះធម៌ ) សម្ដែងទុកចំពោះមុខព្រះអានន្ទហើយ ទើបពោល ថា **ឯវម្មេ សុតំ** ខ្ញុំម្ចាស់បានស្ដាប់មកយ៉ាងនេះ ។

ក្នុងបទទាំងនោះ បទថា **អាយស្មា** ជាពាក្យពោលគួរស្រឡាញ់ ជាពាក្យសម្ដែងសេចក្ដីគោរព ជាពាក្យសម្ដែងនូវគារវៈ និងការកោតក្រែង អធិប្បាយថា អ្នកមានអាយុ ។ បទថា **អានន្ទោ** ជាឈ្មោះរបស់

ព្រះថេរៈនោះ ។ ព្រោះព្រះថេរៈ កាលកើត បានធ្វើសេចក្តីពេញចិត្ត សេចក្តីរីករាយយ៉ាងច្រើនក្នុងត្រកូលដូច្នេះ ព្រះថេរៈនោះ ទើបបាន ឈ្មោះថា **អានន្ទ** ។ បទថា **កោសម្ពិយំ** ជិតនគរមានឈ្មោះយ៉ាងនោះ ។ ព្រោះនគរនោះ មានដើមសង្កែរ ដុះឡើងណែនដេរដាស់ក្នុងទីនោះ ៗ មានសួន និងស្រះបោក្ខរណីជាដើម ដូច្នេះ ។ នគរនោះទើប ឈ្មោះថា **កោសម្ពី** អាចារ្យមួយពួកពោលថា ព្រោះឥសីកុសម្ពៈសាងទុកមិន ឆ្ងាយពីអាស្រម ។ បទថា **ឃោសិតារាមេ** ក្នុងឃោសិតារាម គឺ ក្នុង អារាមដែលឃោសិតសេដ្ឋីសាងទុក ។ ក្នុងក្រុងកោសម្ពី មានសេដ្ឋី ៣ នាក់ គឺ ឃោសិតសេដ្ឋី កុក្កុដសេដ្ឋី បាវារិកសេដ្ឋី ។ សេដ្ឋីទាំង ៣ នាក់នោះ បានស្តាប់មកថា ព្រះពុទ្ធជាម្ចាស់ទ្រង់ឧបត្តិហើយក្នុងលោក ទើបឲ្យត្រៀមឧបករណ៍ឲ្យទានដោយរទេះ ៥០០ ទៅក្រុងសាវត្ថី ចាត់ទី សម្រាកជិតវត្តជេតពន ហើយទៅគាល់ព្រះសាស្តា បានថ្វាយបង្គំ អង្គុយធ្វើបដិសណ្ឋារៈ ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ហើយ បានតាំងនៅក្នុងសោតាបត្តិផល បាននិមន្តព្រះសាស្តាថ្វាយមហាទាន ចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាម្ចាស់ជាប្រធានអស់កន្លះខែ ហើយថ្វាយ បង្គំព្រះបាទមូលរបស់ព្រះសាស្តា អារាធនាព្រះអង្គ ដើម្បីស្តេចយាង កាន់ជនបទរបស់ខ្លួន កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាល



គហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងរីករាយក្នុងសុញ្ញាគារ លុះដឹងថា ព្រះមានព្រះភាគជាម្ចាស់ឲ្យពាក្យប្តេជ្ញាដល់យើងហើយ ទើប រីករាយយ៉ាងក្រៃលែង ទើបថ្វាយបង្គំព្រះទសពល ចេញទៅសាងវិហារ ដើម្បីជាទីប្រថាប់របស់ព្រះមានព្រះភាគជាម្ចាស់ ក្នុងទី ១ យោជន៍ ៗ ក្នុងរវាងផ្លូវដល់ក្រុងកោសម្ពីដោយលំដាប់ ធ្វើការបរិច្ចាគទ្រព្យជាច្រើន ក្នុងអារាមរបស់ខ្លួន ៗ ហើយសាងវិហារទាំងឡាយ ថ្វាយចំពោះព្រះ មានព្រះភាគ ក្នុងបណ្តាសេដ្ឋីទាំងនោះ ឃោសិតសេដ្ឋីសាងអារាមឈ្មោះ ឃោសិតារាម កុក្កុដសេដ្ឋីសាងអារាមឈ្មោះ កុក្កុដារាម បាវារិកសេដ្ឋី សាងក្នុងសួនអម្ពវ័ន ឈ្មោះ បាវារិកម្ពវ័ន ។ លោកពោលថា **ឃោ-សិតសេដ្ឋិនា ការិតេ អារាមេ** ក្នុងអារាមដែលឃោសិតសេដ្ឋីសាង សំដៅដល់ ឃោសិតារាមនោះ ។

ក្នុងបទថា **អាវុសោ ភិក្ខវោ** ម្នាលភិក្ខុជាអាវុសោទាំងឡាយនេះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលទ្រង់ត្រាស់ហៅសាវកទាំងឡាយ ទ្រង់ រមែងត្រាស់ហៅថា **ភិក្ខវោ** ។ ចំណែកសាវកទាំងឡាយគិតថា យើងចូរ កុំដូចព្រះពុទ្ធជាម្ចាស់ទាំងឡាយឡើយ គប្បីពោលថាអាវុសោមុនហើយ ទើបពោលថា **ភិក្ខវោ** ខាងក្រោយ ។ មយ៉ាងទៀត កាលព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ហៅ ភិក្ខុសង្ឃរមែងទទួលថា **ភទន្តេ** កាលសាវកហៅ ភិក្ខុ

សង្ឃទទួលថា **អាវុសោ** ។

បទថា **យោ ហិ កោចិ** ភិក្ខុណាមួយ ជាពាក្យមិនប្រាកដ ។ ដោយបទនេះ ជាការសំដៅយកភិក្ខុទាំងអស់ដូច្នោះ ។ បទថា **មម សន្តិកេ** ក្នុងសម្នាក់របស់យើង គឺ ក្នុងទីជិតយើង ។ បទថា **អរហត្តប្បត្តំ** គឺ បានសម្រេចព្រះអរហត្តដោយខ្លួនឯង ។ រូបសម្រេចជានបុំសកលិង្គ ឬកាត់បទថា **អរហត្តំ បត្តំ** សម្រេចនូវព្រះអរហត្ត សេចក្តីថា ព្រះអរហត្តដែលខ្លួនបានសម្រេចហើយ ឬបាឋៈដ៏សេសថា ខ្លួនសម្រេចព្រះអរហត្តហើយ ។

បទថា **ចតូហិ មគ្គេហិ** ដោយមគ្គ ៤ គឺ ដោយបដិបទាមគ្គ ៤ ដែលលោកពោលទុកក្នុងខាងដើម មិនមែនដោយអរិយមគ្គ ។ ព្រោះលោកពោលទុកមួយផ្នែក ដោយបទថា **ចតូហិ មគ្គេហិ** ដោយមគ្គ ៤ គប្បីជ្រាបថា បដិបទាមគ្គ មាន ៤ យ៉ាងនេះ គឺ មគ្គមានធម្មុទ្ធច្ចៈជាប្រធាននៃអរិយមគ្គខាងដើម របស់ព្រះអរហន្តណាមួយ ១ , មគ្គមានសមថៈជាប្រធាននៃអរិយមគ្គ ១ , មគ្គមានវិបស្សនាជាខាងដើមនៃអរិយមគ្គ ១ , មគ្គមានយុគនទ្ធធម៌ ( ធម៌ជាប់គ្នាជាគូ ) ជាខាងដើមនៃអរិយមគ្គ ១ , បទថា **ឯតេសំ វា អញ្ញតរេន** ឬដោយមគ្គទាំងនោះមគ្គណាមួយ ឬដោយមគ្គមួយបណ្តាបដិបទាមគ្គទាំង ៤ នោះ សេចក្តីថា



ព្រះអានន្ទត្ថេរ ព្យាករណ៍ការសម្រេចព្រះអរហត្តដោយបដិបទាមគ្គ ។ ពិតណាស់ កាលព្រះអរហន្តជាសុក្ខវិបស្សកៈ សម្រេចសោតាបត្តិមគ្គ ដែលមានធម្មុទ្ធច្ចៈជាខាងដើម ហើយសម្រេចមគ្គ ៣ ដ៏សេស ដោយវិបស្សនាសុទ្ធ ការសម្រេចព្រះអរហត្តរមែងជាមគ្គ មានធម្មុទ្ធច្ចៈជាខាងដើម ការសម្រេចអរហត្តរបស់ព្រះអរហន្តដែលមានមគ្គ ៤ ដែលខ្លួនសម្រេចហើយក្តី មិនសម្រេចក្តី នូវធម៌ត្រូវឧទ្ធច្ចៈរារាំង សម្រេចហើយដោយអំណាចបដិបទាមគ្គ ៣ មានសមថៈជាខាងដើមជាដើម ។ មគ្គមួយ ៗ រមែងជាមគ្គ មានមគ្គមួយ ៗ ក្រៅពីនេះជាខាងដើម ដូច្នេះ ព្រះអានន្ទត្ថេរពោលថា **ឯតេសំ វា អញ្ញតរេន** ។

បទថា **សមថបុព្វង្គមំ វិបស្សនំ ភាវេតិ** រមែងចម្រើនវិបស្សនាដែលមានសមថៈជាខាងដើម គឺ ចម្រើនវិបស្សនា ធ្វើសមថៈឲ្យជាខាងដើម គឺ ឲ្យទៅដល់មុន សេចក្តីថា ញុំាងសមាធិឲ្យកើតមុនហើយ ទើបចម្រើនវិបស្សនាខាងក្រោយ ។ បទថា **មគ្គោ សញ្ជាយតិ** មគ្គរមែងកើត គឺ លោកុត្តរមគ្គរមែងកើតមុន ។ ក្នុងបទជាដើមថា **សោ តំ មគ្គំ** ភិក្ខុនោះ រមែងសេពនូវមគ្គនោះ ឈ្មោះថា ការសេពជាដើមនូវមគ្គ ដែលមានខណៈចិត្តមួយរមែងមិនមាន តែភិក្ខុញុំាងទុតិយមគ្គឲ្យកើត លោកពោលថា ភិក្ខុសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ។

បទថា **សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តិ ហោន្តិ** រមែងលះសញ្ញោជនៈបាន អនុស័យរមែងអស់ទៅ គឺ រមែងលះសំយោជនៈទាំងពួងបានតាមលំដាប់ រហូតដល់អរហត្តមគ្គ អនុស័យរមែងអស់ទៅ ។

ម្យ៉ាងទៀត បទថា **អនុសយា ព្យន្តីហោន្តិ** សេចក្ដីថា អនុស័យប្រាសចាកទៅដោយមិនកើតឡើងទៀត ។ បទថា **បុន ចបរំ** ប្រការមួយទៀត គឺ នៅមានហេតុដទៃទៀត ។ បទថា **វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ** រមែងចម្រើនសមថៈ មានវិបស្សនាជាខាងដើម គឺ ភិក្ខុចម្រើនសមថៈ ធ្វើវិបស្សនាឲ្យជាខាងដើម គឺ ឲ្យដល់មុន សេចក្ដីថា ញុំាងវិបស្សនាឲ្យកើតមុន ទើបចម្រើនសមាធិជាខាងក្រោយ ។ បទថា **យុគនទ្ធំ ភាវេតិ** ចម្រើនជាគូ គឺ ចម្រើនធ្វើឲ្យជាគូ ។ ក្នុងបទនេះ មិនអាចចូលសមាបត្តិដោយចិត្តនោះ ហើយពិចារណាសង្ខារទាំងឡាយដោយចិត្តនោះបាន តែភិក្ខុនោះចូលសមាបត្តិត្រឹមណា រមែងពិចារណាសង្ខារបានត្រឹមនោះ ។ ពិចារណាដល់សង្ខារបានត្រឹមណា រមែងចូលសមាបត្តិបានត្រឹមនោះ យ៉ាងណា ។ ភិក្ខុចូលបឋមជ្ឈាន លុះចេញពីបឋមជ្ឈាននោះហើយ រមែងពិចារណាសង្ខារទាំងឡាយ គ្រាពិចារណាសង្ខារទាំងឡាយហើយ រមែងចូលទុតិយជ្ឈាន គ្រាចេញពីទុតិយជ្ឈាននោះហើយ រមែងពិចារណាសង្ខារទាំងឡាយ គ្រាពិចារណាសង្ខារទាំង



ឡាយហើយ រមែងចូលតតិយជ្ឈាន ។ល។ នេវសញ្ញានាសញ្ញាយតន-សមាបត្តិ គ្រាចេញពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ រមែងពិចារណាដល់សង្ខារទាំងឡាយ ដោយប្រការដូច្នេះ ។ ភិក្ខុឈ្មោះថា ចម្រើនសមថៈ និងវិបស្សនាដែលជាធម៌គូគ្នា ។

ក្នុងបទនេះថា **ធម្មុទ្ធច្ចវិគ្គហិតមានសំ ហោតិ** មានចិត្តនឹកដល់ឱភាស ដែលធម៌ត្រូវឧទ្ធច្ចៈរារាំង គឺ ឧទ្ធច្ចៈ បានដល់ សេចក្ដីរាយមាយដោយការកើតឡើងនៃចិត្តសហគតដោយឧទ្ធច្ចៈ ដោយអំណាចនៃការវិលទៅក្នុងធម៌ ១០ ប្រការ មានឱភាសជាដើម ដែលដឹងបានថា ជាឧបក្កិលេសនៃវិបស្សនា ព្រោះអ្នកចម្រើនវិបស្សនា មានបញ្ញាទន់ខ្សោយឈ្មោះថា **ធម្មុទ្ធច្ច** មានចិត្តដែលធម្មុទ្ធច្ចៈនោះរារាំង គឺ កាន់យកខុសឲ្យដល់នូវសេចក្ដីពិរោធ ឈ្មោះថា មានចិត្តនឹកដល់ឱភាសដែលជាធម៌ត្រូវឧទច្ចៈរារាំង ឬមានចិត្តត្រូវធម្មុទ្ធច្ចៈដែលជាហេតុរារាំង ដោយការកើតនៃតណ្ហា មានះ ទិដ្ឋិ ដែលមានធម្មុទ្ធច្ចៈនោះជាហេតុ ។ ម្យ៉ាងទៀត បាឋៈថា **ធម្មុទ្ធច្ចវិគ្គហិតមានសំ** ក៏មាន ។ ដោយបទនេះថា **ហោតិ សោ អាវុសោ សមយោ** ម្នាលអាវុសោ សម័យនោះ ព្រះអានន្ទត្ថេរហាមធម្មុទ្ធច្ចៈនោះ ដោយកំណត់មគ្គ និងមិនមែនមគ្គ ហើយសម្ដែងដល់វិថីបដិបត្តិនៃវិបស្សនាទៀត ។

បទថា **យំ តំ ចិត្តំ** ចិត្តនោះណា គឺ ក្នុងសម័យណាចិត្តនោះឈានកាន់វីថិនៃវិបស្សនាប្រព្រឹត្តទៅហើយ ។ បទថា **អជ្ឈត្តមេវ សន្តិដ្ឋតិ** ចិត្តរមែងតាំងមាំនៅខាងក្នុង គឺ ចិត្តឈានចុះកាន់វីថិនៃវិបស្សនាហើយ រមែងតាំងមាំនៅក្នុងអារម្មណ៍ ពោលគឺ ខាងក្នុងនៃអារម្មណ៍ក្នុងសម័យនោះ ។ បទថា **សន្និសីទតិ** ចិត្តស្ងប់ គឺ ស្ងប់ដោយប្រពៃ ដោយការប្រព្រឹត្តទៅក្នុងអារម្មណ៍នោះផង ។ បទថា **ឯកោទិ ហោតិ** ជាធម៌ខ្ពស់ឯក គឺ មានអារម្មតែមួយ ។ បទថា **សមាធិយតិ** តាំងមាំ គឺ ចិត្តតាំងមាំដោយប្រពៃ តាំងមាំដោយល្អ ។

នេះជាអដ្ឋកថាព្រះសូត្រ



# អដ្ឋកថា សុត្តន្តនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសកថានៃសូត្រនោះដូចតទៅនេះ :

បទថា **តត្ថ ធម្មា ជាតេ** ធម៌ដែលកើតក្នុងសមាធិនោះ គឺ ចិត្តនិងចេតសិកដែលកើតក្នុងសមាធិនោះ ។ ព្រះអានន្ទត្ថេរ សម្តែងដល់ប្រភេទនៃវិបស្សនា ដោយបទជាដើមថា **អនិច្ចតោ អនុបស្សនដ្ឋេន** ដោយអត្ថថា ពិចារណាឃើញដោយភាពជាសភាវៈមិនទៀង ។ បទថា **សម្មាទិដ្ឋិ មគ្គោ** បានដល់ មគ្គ គឺ សម្មាទិដ្ឋិ ។ ក្នុងអង្គនៃមគ្គ ៨ សូម្បីអង្គនីមួយៗ លោកក៏ហៅមគ្គ ។ បទថា **អាសេវតិ** រមែងសេព គឺ រមែងសេពដោយអំណាចនៃសោតាបត្តិមគ្គ ។ បទថា **ភាវេតិ** រមែងចម្រើន គឺ រមែងចម្រើនដោយអំណាចនៃសកទាគាមិមគ្គ ។ បទថា **ពហុលីក-រោតិ** រមែងធ្វើឲ្យច្រើន គឺ រមែងធ្វើឲ្យច្រើន ដោយញ៉ាំងអនាគាមិមគ្គនិងអរហត្តមគ្គ សូម្បីសេចក្តីមិនផ្សេងគ្នានៃនាទីរបស់មគ្គ ៣ នេះ ព្រោះអាវជ្ជនចិត្តជាដើម ជាចិត្តទូទៅ លោកទើបឆ្លើយដូចគ្នា ។ ក្នុងបេយ្យាលវាងអាលោកសញ្ញា និងបដិនិស្សគ្គានុបស្សនា លោកសង្ខេបសេចក្តីមិនរាយមាយជាដើម ឈានសមាបត្តិ កសិណ អនុស្សតិ និងអសុភៈនិងខ្យល់ដកដង្ហើមចូលវែងជាដើម ព្រោះលោកបានសម្តែងទុកហើយ

ក្នុងសមាធិញ្ញាណនិទ្ទេសក្នុងលំដាប់ ។

ម្យ៉ាងទៀតក្នុងបទទាំងនោះបទថា **អវិក្ខេបវសេន** ដោយអំណាចនៃសេចក្ដីមិនរាយមាយ គប្បីកាន់យកដោយសេចក្ដីមិនរាយមាយ ដែលជាចំណែកខាងដើម ។ ក្នុងបទជាដើមថា **អនិច្ចានុបស្សី អស្សាសវសេន** ដោយអំណាចភាពជាអ្នកពិចារណាឃើញការមិនទៀង ដកដង្ហើមចូល គប្បីជ្រាបវិបស្សនាមានកម្លាំង មានសមាធិដែលសម្បយុត្តដោយវិបស្សនាជាខាងដើម ក្នុងកាលនៃវិបស្សនាទន់ខ្សោយ ក្នុងចតុក្កៈដែលលោកពោលហើយ ដោយអំណាចនៃវិបស្សនាសុទ្ធ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈនៃវិបស្សនាជាខាងដើមដូចតទៅនេះ :

លោកពោលវិបស្សនាមិនកំណត់អារម្មណ៍ ដោយបទជាដើមថា **អនិច្ចតោ** មុន ពោលកំណត់អារម្មណ៍ដោយបទជាដើមថា **រូបំ អនិច្ចតោ** ក្នុងខាងក្រោយ ។ បទថា **តត្ថ ជាតានំ** កើតហើយក្នុងវិបស្សនានោះ គឺ ចិត្ត និងចេតសិកធម៌ កើតហើយក្នុងវិបស្សនានោះ ។ ការលះបង់ក្នុងបទនេះថា **វោស្សគ្គារម្មណតា** សភាពចិត្តមានការលះបង់ជាអារម្មណ៍ គឺ ព្រះនិព្វាន ព្រោះព្រះនិព្វានលោកពោលថា **វោស្សគ្គោ** ព្រោះរលាស់ចោលសង្ខតធម៌ ព្រោះលះបង់ ។ វិបស្សនា និងធម៌ដែលសម្បយុត្តដោយវិបស្សនានោះ មាននិព្វានជាទីតាំង មានព្រះនិព្វានជាអារម្មណ៍ ព្រោះ



បង្អោនទៅកាន់ព្រះនិព្វាន និងតាំងនៅក្នុងព្រះនិព្វាន ដោយអំណាចនៃអធ្យាស្រ័យ ។ សូម្បីការតាំងទុក ក៏ឈ្មោះថា អារម្មណ៍ ព្រោះគោងមាននិព្វានជាអារម្មណ៍ ដោយអត្ថថា តាំងនៅក្នុងព្រះនិព្វាននោះឯង ។ ពិតណាស់ សូម្បីបាលីក្នុងទីដទៃ ការតាំងទុកក៏លោកពោលថា **អារម្មណំ** ដូចលោកពោលបទជាដើមថា ម្នាលអាវុសោ ដូចបុរសយកគប់ភ្លើងស្មៅដុតផ្ទះប្រក់ដោយដើមបបុស ផ្ទះប្រក់ដោយស្បូវ អំពីទិសខាងកើតកន្លងទៅអស់មួយឆ្នាំ ភ្លើងបានឱកាស គប្បីបានអារម្មណ៍ ព្រោះដូច្នោះ ចិត្តមានការលះបង់ធម៌ទាំងឡាយ ដែលកើតក្នុងវិបស្សនានោះ ជាអាម្មណ៍ សេចក្ដីរាយមាយណាដែលមានប្រភេទជាឧបចារៈ និងអប្បនាពោលគឺ ចិត្តដែលមានអារម្មណ៍តែមួយ ឲ្យសមាធិកើត ដោយមាននិព្វានជាទីតាំង ជាហេតុ សេចក្ដីមិនរាយមាយនោះ លោកពោលថា ជាសមាធិ គឺ មានការតាំងមាំ ដែលជាចំណែកនៃការចាក់ធ្លុះ ។ ឲ្យសមាធិកើក្នុងខាងក្រោយ ព្រោះដូច្នោះ លោកពោលថា **ឥតិ បឋមំ វិបស្សនា បច្ឆា សមថោ** ដោយប្រការដូច្នេះ វិបស្សនាមុន សមថៈជាខាងក្រោយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងយុគនទ្ធនិទ្ទេស ដូចតទៅនេះ ។ ព្រោះលំដាប់នៃធម៌ជាគូ លោកពោលទុកហើយក្នុងអដ្ឋកថានៃសូត្រ ក្នុង

ខាងក្រោយ ប្រាកដហើយដោយន័យនៃនិទ្ទេសទាំងពីរមុន ចំណែកលំដាប់នៃនិទ្ទេសធម៌ដែលជាគូក្នុងខណៈនៃមគ្គ ដែលមិនទាន់ប្រាកដ ព្រោះដូច្នោះ ព្រះអានន្ទត្ថេរ មិនពោលដល់ការចម្រើនធម៌ជាគូ ដែលមានមិនតិចក្នុងចំណែកខាងដើម កាលនឹងសម្ដែងដល់ការចម្រើនធម៌ជាគូ ដែលបានដោយចំណែកមួយក្នុងខណៈនៃមគ្គ ទើបពោលពាក្យជាដើមថា **សោឡសហិ អាការេហិ** ដោយអាការ ១៦ ។

ក្នុងបទទាំងនោះ ធម៌ជាគូ ដែលលោកលើកឡើងសម្ដែងទុកក្នុងទីបំផុតក្នុងអាការ ១៧ យ៉ាង ជាដើមថា **អារម្មណដ្ឋេន** ដោយភាពជាអារម្មណ៍លះធម៌ជាគូនោះ ព្រោះតាំងនៅក្នុងទីជាមួយគ្នា ដោយបទជាមូលហេតុហើយពោលថា **សោឡសហិ** ដោយអាការ ១៦ យ៉ាង ដោយអំណាចនៃអាការ ១៦ ដ៏សេស ។

បទថា **អារម្មណដ្ឋេន** គឺ ដោយការតោង អធិប្បាយថា ដោយអំណាចនៃអារម្មណ៍ ។ សូម្បីបទដ៏សេសក្នុងនេះ ។

បទថា **គោចរដ្ឋេន** គឺ ឋានៈគួរអាស្រ័យ ។

បទថា **បហានដ្ឋេន** គឺ ដោយការលះ ។ បទថា **បរិច្ចាគដ្ឋេន** ដោយការលះបង់ គឺ ពេលការលះមានហើយ ក៏ដោយការមិនប្រកាន់ការលះបង់ ។



បទថា **វុដ្ឋានដ្ឋេន** ដោយការចេញ គឺ ដោយការចេញទៅ ។ បទថា **វិវដ្ដនដ្ឋេន** ដោយការគេចចេញទៅ គឺ កាលការចេញទៅមានហើយ ដោយការមិនវិលត្រឡប់មកទៀត ដោយការត្រឡប់ទៅ ។ បទថា **សន្តដ្ឋេន** ដោយភាពជាធម៌ស្ងប់ គឺ ដោយការរលត់ ។ បទថា **បណីតដ្ឋេន** ដោយភាពជាធម៌ប្រណីត គឺ សូម្បីមានការរលត់ហើយ ក៏ដោយភាពជាធម៌ខ្ពង់ខ្ពស់ ឬជាធម៌មិនក្ដៅក្រហាយ ។

បទថា **វិមុត្តដ្ឋេន** ដោយការរួចផុត គឺ ដោយការប្រាសចាកគ្រឿងចង ។ បទថា **អនាសវដ្ឋេន** ភាពមិនមានអាសវៈ គឺ សូម្បីមានការរួចផុតពីគ្រឿងចងហើយ ក៏ដោយការប្រាសចាកអាសវៈ ដែលធ្វើអារម្មណ៍ឲ្យប្រព្រឹត្តទៅ ។ បទថា **តរណដ្ឋេន** ដោយភាពជាគ្រឿងឆ្លងផុត គឺ ដោយការមិនលិច និងអណ្ដែត ។ បទថា **អនិមិត្តដ្ឋេន** ការមិនមាននិមិត្ត គឺ ដោយការប្រាសចាកសង្ខារនិម្មិត្ត ។

បទថា **អប្បណិហិតដ្ឋេន** ដោយការមិនមានទីតាំង គឺ ដោយការប្រាសចាកទីតាំង ។ បទថា **សុញ្ញតដ្ឋេន** ដោយភាពទទេរ គឺ ដោយការប្រាសចាកគ្រឿងប្រកាន់ ។ បទថា **ឯករសដ្ឋេន** ដោយភាពជាធម៌មានកិច្ចជាចំណែកមួយជាមួយគ្នា គឺ ដោយកិច្ចតែម្យ៉ាង ។ បទថា **អនតិវត្តនដ្ឋេន** ដោយការមិនកន្លង គឺ ដោយការមិនកន្លងគ្នានឹងគ្នា ។

បទថា **យុគនទ្ធវេជ្ជន** គឺ ភាពជាគូ ។

បទថា **ឧទ្ធច្ចំ បជហតោ អវិជ្ជំ បជហតោ** កាលកិក្កុលះឧទ្ធច្ចៈ, អវិជ្ជា លោកពោលដោយអំណាចការលះធម៌ជាបដិបក្ខរបស់កម្មនោះ ៗ របស់ព្រះយោគាវចរ ។ ម្យ៉ាងទៀត និរោធក្នុងទីនេះ គឺ និព្វាននោះឯង ។ បទថា **អញ្ញមញ្ញំ នាតិវត្តន្តិ** មិនកន្លងគ្នានឹងគ្នា គឺ ប្រសិនបើសមថៈកន្លងវិបស្សនា ចិត្តគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស ព្រោះសមថៈប្រព្រឹត្តទៅក្នុងចំណែកការរួញរា ។ ប្រសិនបើ វិបស្សនាកន្លងសមថៈចិត្តគប្បីប្រព្រឹត្តទៅដើម្បីការរាយមាយ ព្រោះវិបស្សនាប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីរាយមាយ ព្រោះដូច្នោះ សមថៈកាលមិនកន្លងវិបស្សនារមែងមិនធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស វិបស្សនាមិនកន្លងសមថៈរមែងមិនធ្លាក់ទៅក្នុងសេចក្តីរាយមាយ សមថៈប្រព្រឹត្តទៅស្មើ រមែងរក្សាវិបស្សនាពីការធ្លាក់ទៅកាន់សេចក្តីរាយមាយ វិបស្សនាប្រព្រឹត្តទៅស្មើ រមែងរក្សាសមថៈពីការធ្លាក់ទៅកាន់សេចក្តីខ្ជិលច្រអូស , សមថៈនិងវិបស្សនាទាំងពីរមានកិច្ចដូចគ្នា ដោយកិច្ច គឺ ការមិនកន្លងគ្នានឹងគ្នា ដោយប្រការដូច្នេះ ។ សមថៈ និងវិបស្សនាប្រព្រឹត្តទៅមិនកន្លងគ្នានឹងគ្នា រមែងធ្វើប្រយោជន៍ឲ្យសម្រេច ។ ការដែលសមថៈនិងវិបស្សនានោះជាធម៌គូ ក្នុងខណៈនៃមគ្គរមែងមានបាន ព្រោះជា



ធម៌គូ ក្នុងខណៈនៃវិបស្សនា ដែលជាវុដ្ឋានគាមិនី ។

ដើម្បីជាការយល់កិច្ចរបស់មគ្គទាំងអស់ ព្រោះលោកពោលការលះ ការចេញ និងការចៀសចេញដោយអំណាចនៃកិច្ចរបស់មគ្គ លោកទើបសម្តែងកិលេសសហគតៈដោយឧទ្ធច្ចៈ និងខន្ធ និងកិលេស សហគតៈដោយអវិជ្ជា និងខន្ធ ព្រោះលោកពោលខន្ធដ៏សេសយ៉ាងនោះហើយទើបមិនសម្តែងដល់ឧទ្ធច្ចៈ និងអវិជ្ជាដោយអំណាចនៃការយល់ត្រឹមធម៌ដែលបដិបក្ខ។ បទថា **វិវដ្តតោ** គឺ ចៀសចេញ ។ បទថា **សមាធិ កាមាសវា វិមុត្តោ ហោតិ** សមាធិផុតចាកកាមាសវៈ លោកពោលព្រោះសមាធិជាបដិបក្ខនៃកាមច្ឆន្ទៈ ។ បទថា **រាគវិរាគា** ព្រោះបន្ទោបង់រាគៈ ឈ្មោះថា **រាគវិរាគោ** ព្រោះមានការបន្ទោរបង់ ការឈានកន្លងរាគៈ ឬជាបញ្ចមីវិភត្តថា **រាគវិរាគតោ** ពីការបន្ទោរបង់រាគៈ ។ ម្យ៉ាងទៀត ព្រោះបន្ទោរបង់អវិជ្ជា ។

បទថា **ចេតោវិមុត្តិ** គឺ សមាធិសម្បយុត្តដោយមគ្គ ។ បទថា **បញ្ញាវិមុត្តិ** បញ្ញាសម្បយុត្តដោយមគ្គ ។ បទថា **តរតោ** គឺ អ្នកឆ្លងកាត់ ។ បទថា **សព្វបណីធិហិ** ដោយទីតាំងទាំងពួង គឺ ដោយទីតាំងនៃរាគៈ ទោសៈ មោហៈ ឬដោយការប្រាថ្នាទាំងពួង ។

ព្រះអានន្ទត្ថេរៈ លុះឆ្លើយអាការ ១៤ យ៉ាងនេះហើយ ទើបមិន

ធ្វើយការមានកិច្ចដូចគ្នា និងការមិនឈានកន្លង ហើយពោលថា **ឥមេហិ សោឡហិ អាការេហិ** ដោយអាការ ១៦ យ៉ាងទាំងនេះ ។ ព្រោះហេតុអ្វី ព្រោះក្នុងទីបំផុតរបស់អាការមួយ ៗ នៃអាការ ១៤ ទាំងនោះ លោកសម្តែងទុកថា អាការទាំងឡាយ មានកិច្ចដូចគ្នាជាធម្មិគូ មិនឈានកន្លងគ្នានឹងគ្នាដូច្នេះ ទើបលោកសម្តែងអាការទាំងនោះតែម្យ៉ាង ដូច្នោះលោកទើបពោលថា **សោឡសហិ** ។ ចំណែកអាការមានភាពជាធម្មិគូ លោកមិនបានពោលទុក សូម្បីក្នុងនិទ្ទេសនេះឡើយ ។

ចប់ អដ្ឋកថាសុត្តនិទ្ទេស



# អដ្ឋកថា ធម្មុទ្ធច្ចវារនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មុទ្ធច្ចវារៈដូចតទៅនេះ :

បទថា **អនិច្ចតោ មនសិករោតោ ឱភាសោ ឧប្បជ្ជតិ** កាលភិក្ខុមនសិការៈដោយភាពជាសភាវៈមិនទៀង ឱភាសរមែងកើតឡើង គឺភិក្ខុតាំងនៅក្នុងឧទយព្វយានុបស្សនា ឃើញច្បាស់នូវសង្ខារទាំងឡាយដោយអនុបស្សនា ៣ រឿយ ៗ មានចិត្តបរិសុទ្ធដោយការលះកិលេសដោយតទង្គប្បហានក្នុងវិបស្សនាញាណដែលដល់ភាពចាស់ក្លា ឱភាសរមែងកើតតាមប្រក្រតី ដោយអានុភាពនៃវិបស្សនាញាណក្នុងមនសិការៈដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ ឬដោយភាពមិនមែនតួខ្លួន ព្រោះហេតុនោះ លោកទើបពោលដល់ឱភាសរបស់ភិក្ខុមនសិការៈដោយភាពជាសភាវៈមិនទៀងមុន ។

ភិក្ខុអ្នកចម្រើនវិបស្សនាមិនឆ្លាត កាលឱភាសនោះកើត គិតថា ឱភាសបែបនេះ មិនធ្លាប់កើតដល់យើងពីមុនឡើយ យើងជាអ្នកសម្រេចមគ្គសម្រេចផលជាពិតប្រាកដហើយ ទើបកាន់យកវត្ថុដែលមិនមែនមគ្គនោះឯង ថាជាមគ្គ វត្ថុមិនមែនផលនោះឯង ថាជាផល ។

កាលភិក្ខុនោះកាន់យកវត្ថុដែលមិនមែនមគ្គ ថាជាមគ្គ វត្ថុដែល

មិនមែនផល ថាជាផល ឈានចេញចាកវិបស្សនាវីថិ ។ ភិក្ខុនោះលះវិបស្សនាវីថិរបស់ខ្លួនដល់នូវសេចក្តីរាយមាយ ឬសម្គាល់ឱភាសដោយការសម្គាល់នៃតណ្ហា និងទិដ្ឋិ កំពុងអង្គុយ ។ ឱភាសនេះ ញុាំងពន្លឺត្រឹមទីអង្គុយរបស់ភិក្ខុណាមួយប៉ុណ្ណោះ ខាងក្នុងបន្ទប់របស់ភិក្ខុណាមួយប៉ុណ្ណោះ សូម្បីក្រៅបន្ទប់របស់ភិក្ខុណាមួយ ទូទាំងវិហាររបស់ភិក្ខុណាមួយ ១ គាវុត កន្លះយោជន៍ ២ យោជន៍ ។ល។ ធ្វើពន្លឺជាចំណែកដូចគ្នា តាំងអំពីផែនដីរហូតដល់អកនិដ្ឋកព្រហ្មលោក របស់ភិក្ខុណាមួយតែសម្រាប់ព្រះដ៏មានព្រះភាគជាម្ចាស់ កើតឱភាសមួយម៉ឺនលោកធាតុ ព្រោះឱភាសនេះ ញុាណងទីនោះ ៗ ឲ្យពន្លឺកើតក្នុងទីងងឹត ដែលប្រកបដោយអង្គ ៤ ។

បទថា **ឱភាសោ ធម្មោតិ ឱភាសំ អាវជ្ជតិ** ភិក្ខុនឹកដល់ឱភាសថា ឱភាសជាធម៌ គឺ ភិក្ខុធ្វើទុកក្នុងចិត្តដល់ឱភាសនោះ ៗ ថា ឱភាសនេះជាមគ្គធម៌ ឬជាផលធម៌ដូច្នេះ ។

បទថា **តតោ វិក្ខេបោ ឧទ្ធច្ចំ** ព្រោះនឹកដល់ឱភាសនោះ សេចក្តីរាយមាយទើបជាឧទ្ធច្ចៈ គឺ ព្រោះឱភាសនោះ ឬព្រោះនឹកដល់ថាឱភាសជាធម៌ សេចក្តីរាយមាយទើបកើតឡើង នុ៎ះ គឺ ឧទ្ធច្ចៈ ។ បទថា **តេន ឧទ្ធច្ចេន វិគ្គហិតមានសោ** ភិក្ខុមានចិត្តដែលឧទ្ធច្ចៈនោះរារាំង គឺ ភិក្ខុ



មានចិត្តដែលឧទ្ធច្ចៈកើតឡើងយ៉ាងនោះ រារាំង ឬអ្នកចម្រើនវិបស្សនាមានចិត្ត ដែលឧទ្ធច្ចៈនោះជាហេតុរារាំង ដោយកើតកិលេស ដែលមានឧទ្ធចៈនោះជាមូលហេតុ ព្រោះឈានចុះកាន់វិបស្សនាវីថិ ឬសេចក្តីរាយមាយ ហើយតាំងនៅក្នុងកិលេសដែលមានសេចក្តីរាយមាយនោះជាមូល-ហេតុ រមែងមិនដឹងសេចក្តីប្រាកដដោយភាពជាសភាវៈមិនទៀង ដោយភាពជាទុក្ខ ដោយភាពមិនមែនតួខ្លួន តាមសេចក្តីពិត ។ គប្បីប្រកប **ឥតិ** សព្ទ យ៉ាងនេះថា **តេន វុច្ចតិ ធម្មុទ្ធច្ចវិគ្គហិតមានសោតិ** ដោយហេតុនោះ លោកទើបពោលថា មានចិត្តនឹកដល់ឱភាសដែលជាធម៌ត្រូវឧទ្ធច្ចៈរារាំង ។

បទថា **ហោតិ សោ សមយោ** សម័យនោះ គឺ ប្រសិនបើថាការពិចារណាកើតឡើងដល់ព្រះយោគាវចរ សូម្បីអ្នកមានចិត្តសៅហ្មងដោយសេចក្តីពេញចិត្ត ព្រះយោគាវចរនោះ រមែងដឹងយ៉ាងនេះថា ធម្មតាវិបស្សនាមានសង្ខារជាអារម្មណ៍ មគ្គ និងផលមាននិព្វានជាអារម្មណ៍ សូម្បីចិត្តទាំងនេះមានសង្ខារជាអារម្មណ៍ ព្រោះដូច្នោះ ឱភាសនេះ មិនមែនមគ្គ ឧទយព្វយានុបស្សនាប៉ុណ្ណោះ ជាមគ្គរបស់និព្វាន ។ ព្រះយោគាវចរកំណត់មគ្គ និងមិនមែនមគ្គហើយ វៀរសេចក្តីរាយមាយនោះ តាំងនៅក្នុងឧទយព្វយានុបស្សនាពិចារណាសង្ខារទាំងឡាយដោយ

ល្អ ដោយភាពជាសភាវៈមិនទៀង ដោយភាពជាទុក្ខ ដោយភាពមិនមែនតួខ្លួន ។ កាលព្រះយោគាវចរពិចារណាបែបនោះ ជាសម័យ តែកាលមិនពិចារណាបែបនេះ ជាអ្នកមានអតិមានះថា យើងជាអ្នកសម្រេចមគ្គនិងផលដូច្នេះ ។ បទថា **យំ តំ ចិត្តំ** បានដល់ វិបស្សនាចិត្តនោះ ។ បទថា **អជ្ឈត្តមេវ** ក្នុងខាងក្នុង គឺ ក្នុងខាងក្នុងគោចរដែលជាអារម្មណ៍នៃអនិច្ចានុបស្សនា ។

បទថា **ញាណំ ឧប្បជ្ជតិ** ញាណរមែងកើតឡើង គឺ កាលព្រះយោគាវចរនោះពិចារណាយ៉ាងល្អិតល្អន់ដល់រូបធម៌ និងអរូបធម៌ វិបស្សនាញាណដែលឈ្លាសវៃខ្លាំងក្លាក្រៃលែង មានកម្លាំងមិនត្រូវកម្ចាត់រមែងកើតឡើងដូចវជិរៈរបស់ព្រះឥន្ទដែលចោលចេញទៅ ដូច្នោះ ។

បទថា **បីតិ ឧប្បជ្ជតិ** បីតិរមែងកើតឡើង គឺ ក្នុងសម័យនោះបីតិសម្បយុត្តដោយវិបស្សនា ៥ យ៉ាងនេះ គឺ **ខុទ្ទកាបីតិ** ( បីតិយ៉ាងតិច ) ១ **ខណិកាបីតិ** ( បីតិជាខណៈ ) ១ **ឱក្កន្តិកាបីតិ** ( បីតិជាស្រេបក់ ៗ ) ១ **ឧព្វេង្គាបីតិ** ( បីតិយ៉ាងអណ្តែត ) ១ **ផរណាបីតិ** (បីតិជ្រួតជ្រាប) ១ រមែងកើតឡើងដល់ព្រះយោគាវចរនោះញ៉ាំងសរីរៈទាំងអស់ឲ្យឆ្អែត ។

បទថា **បស្សទ្ធិ ឧប្បជ្ជតិ** សេចក្តីស្ងប់រមែងកើតឡើង គឺ ក្នុង



សម័យនោះ ព្រះយោគាវចរនោះមិនមានសេចក្តីខ្វល់ខ្វាយនៃកាយ និងចិត្ត មិនមានភាពធ្ងន់ មិនមានភាពរឹងត្អឹង មិនមានភាពមិនគួរដល់ការងារ មិនមានការឈឺ មិនមានការកោង ដោយពិតព្រះយោគាវចរនោះ មានកាយ និងចិត្តស្ងប់ស្រាល គួរដល់ការងារ ជំនាញវាងវៃត្រង់ ។ ព្រះយោគាវចរនោះ មានកាយ និងចិត្តដែលបស្សទ្ធិជាដើមទាំងនេះអនុគ្រោះហើយ រមែងសោយនូវសេចក្តីរីករាយដែលមិនមែនរបស់មនុស្សក្នុងសម័យនោះ លោកពោលដល់សេចក្តីត្រេកអរថា

**សេចក្តីត្រេកអរដែលមិនមែនរបស់មនុស្ស រមែង**
**មានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះទទេ អ្នកមាន**
**ចិត្តស្ងប់ អ្នកឃើញច្បាស់នូវធម៌ដោយប្រពៃ**
**តែកាលណា ៗ ភិក្ខុរមែងពិចារណាការកើត និង**
**ការរលត់នៃខន្ធទាំងឡាយ តែកាលណា ៗ ភិក្ខុ**
**រមែងបានបីតិ និងបាមោជ្ជៈ បីតិ និងបាមោជ្ជៈ**
**នោះជាអមតៈរបស់ភិក្ខុអ្នកដឹងច្បាស់ទាំងឡាយ ។**

សេចក្តីស្ងប់នៃកាយ និងចិត្ត សម្បយុត្តដោយវិបស្សនា ព្រមដោយភាពជារបស់ស្រាលជាដើម ញ៉ាំងសេចក្តីរីករាយដែលមិនមែនរបស់មនុស្សនេះឲ្យសម្រេច រមែងកើតដល់ភិក្ខុនោះ ។ បទថា **សុខំ ឧប្ប-**

**ជ្ជតិ** សុខរមែងកើតឡើង គឺ សុខសម្បយុត្តដោយវិបស្សនាដែលញុំាង សរីរៈទាំងអស់ឲ្យស្រស់បស់ រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ បទថា **អធិមោក្ខោ ឧប្បជ្ជតិ** អធិមោក្ខៈ ( ការបង្អោនចិត្តជឿ ) រមែងកើតឡើង គឺ សទ្ធាសម្បយុត្តដោយវិបស្សនាដែលជាសេចក្តីជ្រះថ្លាយ៉ាងខ្លាំងរបស់ចិត្ត និងចេតសិក រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ បទថា **បគ្គាហោ ឧប្បជ្ជតិ មគ្គាហ** ( សេចក្តីព្យាយាម ) រមែងកើតឡើង គឺ សេចក្តីព្យាយាមដែលសម្បយុត្តដោយវិបស្សនា ដែលផ្គងទុកល្អហើយ រមែងមិនធូរពេកមិនតឹងពេក រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ បទថា **ឧបដ្ឋានំ ឧប្បជ្ជតិ** ឧបដ្ឋានៈ ( សេចក្តីតាំងមាំ ) រមែងកើតឡើង គឺ សតិសម្បយុត្តដោយវិបស្សនា តាំងទុកល្អហើយ កប់ណែនមិនញាប់ញ័រ ដូចជាភ្នំធំរមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ ភិក្ខុនោះរមែងនឹកដល់ រូបរួមធ្វើទុកក្នុងចិត្ត ពិចារណាដល់ឋានៈណា ៗ ឋានៈនោះ ៗ ស្ទុះចេញទៅ រមែងប្រាកដដល់ភិក្ខុនោះដោយសតិ ដូចបរលោកប្រាកដដល់អ្នកបានទិព្វចក្ខុ ដូច្នោះ ។ បទថា **ឧបេក្ខា** គឺ ការព្រងើយដោយវិបស្សនា និងព្រងើយដោយការពិចារណា ។ ពិតណាស់ សូម្បីការព្រងើយដោយវិបស្សនាដែលជាកណ្តាល ក្នុងសង្ខារទាំងពួងមានកម្លាំង រមែងកើតឡើងក្នុងសម័យនោះ សូម្បីការព្រងើយ



ដោយការពិចារណា រមែងកើតឡើងក្នុងមនោទ្វារ ។ ពិតណាស់ ការព្រងើយ ដោយការពិចារណានោះ កាលភិក្ខុនោះពិចារណាដល់ឋានៈនោះ សភាពខ្លាំងក្លារមែងនាំទៅ ដូចវជិរៈរបស់ព្រះឥន្ទដែលចោលចេញទៅ និងដូចកូនសរដែកដ៏ក្តៅ ដែលស្ទុះចេញទៅត្រង់កាជនៈស្លឹកឈើ ។ លោកពោលទុកក្នុងវិសុទ្ធិមគ្គយ៉ាងនេះ ។

ម្យ៉ាងទៀត ក្នុងបទនេះថា **វិបស្សនូបេក្ខា** អាចារ្យទាំងឡាយពោលថា បានដល់ ឧបេក្ខា គឺ ដាក់ខ្លួនជាកណ្តាលក្នុងអារម្មណ៍នោះ ៗ សម្បយុត្តដោយវិបស្សនា ។ ពិតណាស់ កាលកាន់យកវិបស្សនាញាណក៏នឹងមានទោសដោយពាក្យនិយាយទៀតថា **ញាណ** រមែងកើត ព្រោះវិបស្សនាមកដល់ហើយ ។ ម្យ៉ាងទៀត ក្នុងការពណ៌នាដល់តតិយជ្ឈានលោកពោលថា សូម្បីសង្ខារុបេក្ខា និងវិបស្សនូបេក្ខា ដោយអត្ថ ក៏ជាចំណែកដូចគ្នា ព្រោះជាបញ្ញាដូចគ្នា ផ្សេងគ្នាជា ២ ចំណែក ដោយអំណាចនៃមុខនាទី ព្រោះដូច្នោះកាលពោលដល់ឧបេក្ខា គឺ ភាពជាកណ្តាលក្នុងអារម្មណ៍នោះ សម្បយុត្តដោយវិបស្សនា ទើបមិនមានទោសក្នុងការនិយាយទៀត និងសមល្មមដោយការពណ៌នាតតិយជ្ឈាន ។ ក៏ព្រោះក្នុងឥន្ទ្រិយ ៥ លោកពោលដល់បញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ និងសតិន្ទ្រិយថា **ញាណ អធិមោក្ខ បគ្គាហ ឧបដ្ឋាន** ចំណែកសមាធិន្ទ្រិយ

លោកមិនសម្ដែងទុក ។ មួយវិញទៀត គប្បីសម្ដែងសមាធិន្ទ្រិយប៉ុណ្ណោះ ដោយអំណាចនៃធម៌ជាគូ ដូច្នោះ គប្បីជ្រាបសមាធិប្រព្រឹត្តទៅស្មើ លោកពោលថា ឧបេក្ខា ព្រោះធ្វើការលះសេចក្ដីខ្វល់ខ្វាយក្នុងការតាំងមាំ ។

បទថា **និកន្តិ ឧប្បជ្ជតិ** និកន្តិ ( សេចក្ដីពេញចិត្ត ) រមែងកើតឡើង គឺ សេចក្ដីពេញចិត្ត មានអាការស្ងប់ សុខុម ធ្វើសេចក្ដីអាល័យក្នុងវិបស្សនាដែលប្រដាប់ដោយឱភាសជាដើមយ៉ាងនេះ រមែងកើតឡើង សេចក្ដីពេញចិត្តណា មិនអាចសូម្បីកំណត់បានថា ជាកិលេស ដូចក្នុងឱភាសឯណានីមួយកើតឡើង ព្រះយោគាវចរគិតថា ញាណបែបនេះមិនធ្លាប់កើតដល់យើងពីមុន បីតិ បស្សទ្ធិ អធិមោក្ខៈ បគ្គហៈ ឧបដ្ឋានៈ ឧបេក្ខា និកន្តិ បែបនេះធ្លាប់កើតឡើងហើយ យើងជាអ្នកបានសម្រេចមគ្គ យើងជាអ្នកសម្រេចផលជាពិតប្រាកដ ហើយកាន់យកវត្ថុមិនមែនជាមគ្គ ថាជាមគ្គ វត្ថុមិនមែនផល ថាជាផល កាលព្រះយោគាវចរនោះកាន់យកវត្ថុមិនមែនជាមគ្គ និងវត្ថុមិនមែនជាផល ថាជាមគ្គផល វិបស្សនាវីថិ រមែងវិនាសបាត់ទៅ ។

ព្រះយោគាវចរនោះលះមូលកម្មដ្ឋានរបស់ខ្លួនហើយ អង្គុយត្រេកអរនឹងសេចក្ដីពេញចិត្តនោះប៉ុណ្ណោះ ។

មួយវិញទៀត ក្នុងបទនេះ លោកពោលឱភាសជាដើមថា ជាឧប-



ក្កិលេស ព្រោះជាទីតាំងនៃសេចក្ដីសៅហ្មង ព្រោះមិនមែនជាអកុសល ចំណែកនិកន្តិ ជាឧបក្កិលេសផង និងជាទីតាំងនៃសេចក្ដីសៅហ្មងផង ។ ឧបក្កិលេសទាំងនេះ មាន ១០ យ៉ាង ដោយអំណាចនៃវត្ថុមាន ៣០ ដោយអំណាចនៃការកាន់យក យ៉ាងណា ។ កាលព្រះយោគាវចរប្រកាន់ថា ឱភាសកើតឡើងហើយដល់យើង រមែងជាការប្រកាន់ដោយទិដ្ឋិ កាលប្រកាន់ថា ឱភាសគួរពេញចិត្តកើតឡើងហើយ រមែងជាការប្រកាន់ដោយមានះ កាលត្រេកអរនឹងឱភាស រមែងជាការប្រកាន់ដោយតណ្ហា ការប្រកាន់ ៣ យ៉ាង ដោយអំណាចនៃទិដ្ឋិ មានះ និងតណ្ហា ក្នុងឱភាសដោយប្រការដូច្នេះ ។ សូម្បីឧបក្កិលេសដ៏សេសក៏ដូច្នោះ ឧបក្កិលេស ៣០ ដោយអំណាចនៃការប្រកាន់ រមែងមានដោយប្រការដូច្នេះ ។

បទថា **ទុក្ខតោ មនសិករោតោ អនត្តតោ មនសិករោតោ** កាលភិក្ខុមនសិការដោយភាពជាទុក្ខ ដោយភាពជាអនត្តា គប្បីជ្រាបអត្ថដោយន័យនេះ សូម្បីក្នុងវារៈទាំងឡាយ ។ ក្នុងបទនេះ គប្បីជ្រាបការកើតនៃវិបស្សនូបកិលេស នៃវិបស្សនានីមួយ ៗ ដោយអំណាចនៃអនុបស្សនាមួយ ៗ មិនមែនមានតែមួយយ៉ាងប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអនុបស្សនា ៣ ដូចតទៅនេះ ។ ព្រះអានន្ទត្ថេរ លុះសម្ដែងឧបក្កិលេសទាំងឡាយដោយអំណាចនៃវិបស្សនា ដោយ

មិនផ្សេងគ្នាយ៉ាងនេះ កាលនឹងសម្តែងដោយអំណាចនៃសេចក្តីផ្សេងគ្នាទៀត ទើបពោលពាក្យជាដើមថា **រូបំ អនិច្ចតោ មនសិករោតោ** កាលភិក្ខុមនសិការរូបថា មិនទៀងដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ជរា មរណំ អនិច្ចតោ ឧបដ្ឋានំ** ជរាមរណៈដែលប្រាកដដោយសភាវៈមិនទៀង គឺ ការប្រាកដរបស់ជរា និងមរណៈ ដោយភាពមិនទៀង ។

ព្រោះព្រះយោគាវចរអ្នកមិនឆ្លាត មិនឈ្លាស ដោយអំណាចនៃឧបក្កិលេស ៣០ ដូចពោលហើយក្នុងបទមុន រមែងញាប់ញ័រក្នុងឱភាសជាដើម រមែងពិចារណាឱភាសមួយ ៗ ថា នុ៎ះជាយើង នុ៎ះជារបស់យើង នុ៎ះជាតួខ្លួនរបស់យើង ដូច្នោះព្រះអានន្ទត្ថេរ កាលនឹងសម្តែងសេចក្តីនោះ ទើបពោលគាថា ២ គាថាជាដើមថា **ឱភាសេ ចេវ ញាណេ ច** ក្នុងឱភាស និងញាណដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **វិកម្បតិ** រមែងកម្រើក គឺ រមែងកម្រើកញាប់ញ័រ ៣ យ៉ាង ដោយអំណាចកិលេសផ្សេង ៗ ក្នុងអារម្មណ៍ មានឱភាសជាដើម ។ បទថា **យេហិ ចិត្តំ បវេធតិ** ចិត្តរមែងញាប់ញ័រ គឺ ចិត្តរមែងកម្រើកញាប់ញ័រដោយបស្សទ្ធិ និងសុខដោយប្រការផ្សេង ៗ ដោយអំណាចកិលេសផ្សេង ៗ ព្រោះដូច្នេះ គប្បីជ្រាបសេចក្តីសម្ពន្ធថា



ព្រះយោគាវចររមែងរសេមរសាមក្នុងបស្សទ្ធិ និងសុខ ។ បទថា **ឧបេក្ខា វជ្ជនាយ ចេវ** ចាកការនឹកដល់ឧបេក្ខា គឺ ចិត្តរមែងកម្រើកចាកការនឹក គឺ ឧបេក្ខា អធិប្បាយថា រមែងកម្រើកចាកសេចក្តីព្រងើយក្នុងការនឹកដល់ ប៉ុន្តែក្នុងវិសុទ្ធិមគ្គ លោកពោលទុកថា **ឧបេក្ខាវជ្ជនាញ្ច** ក្នុងការនឹកដល់ឧបេក្ខា ។ បទថា **ឧបេក្ខាយ ច** សេចកក្តីព្រងើយ គឺ ចិត្តរមែងកម្រើកដោយការព្រងើយ មានប្រការដូចពោលហើយ អធិ-ប្បាយថា រមែងកម្រើកដោយសេចក្តីពេញចិត្ត ។

ម្យ៉ាងទៀត ក្នុងបទនេះ ព្រោះលោកសម្តែងដល់ឧបេក្ខា ២ យ៉ាង ទើបពោលដោយអត្ថទាំង ២ ប្រការ ក្នុងឋានៈដែលលោកពោលហើយថា **ឧបេក្ខាឧប្បជ្ជតិ** ឧបេក្ខារមែងកើត ។ អនុបស្សនាមួយ ៗ ព្រោះសេចក្តីប្រាកដនៃការព្រងើយ ដោយការនឹកដល់នៃអនុបស្សនាមួយ ៗ ក្នុងអនិច្ចានុបស្សនាជាដើម លោកពោលថា ចម្រើនរឿយ ៗ ថា **អនិច្ចំ អនិច្ចំ ទុក្ខំ ទុក្ខំ អនត្តា អនត្តា** ។

ម្យ៉ាងទៀត ព្រះយោគាវចរជាអ្នកឆ្លាត ជាបណ្ឌិត ឈ្លាសវៃ សម្បូណ៌ចំណេះដឹង កាលឱភាសជាដើមកើតឡើង រមែងកំណត់ រមែងពិចារណាឱភាសនោះដោយបញ្ញាថា ឱភាសនេះកើតឡើងហើយដល់យើង ក៏ឱភាសនោះឯងជាសភាវៈមិនទៀង ជាវត្ថុដែលត្រូវតាក់តែង

អាស្រ័យគ្នាកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការបន្ទោបង់រាគៈជាធម្មតា មានការរលត់កិលេសជាធម្មតា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះ ។ ប្រសិនបើឱកាសជាតួខ្លួន គប្បីគួរនឹងប្រកាន់ថាជាតួខ្លួន តែឱកាសនេះមិនមែនតួខ្លួន នូវប្រកាន់ថាជាតួខ្លួន ព្រោះដូច្នោះ ព្រះយោគាវចរកាលឃើញថា ឱកាសនេះមិនមែនតួខ្លួន ព្រោះមិននៅក្នុងអំណាច ទើបដកទិដ្ឋិចេញបាន ។ ប្រសិនបើឱកាសគប្បីជាសភាវៈទៀង គួរដើម្បីប្រកាន់ថាជាសភាវៈទៀង តែឱកាសនេះ ជាសភាវៈមិនទៀង នៅប្រកាន់ថាជាសភាវៈទៀង ព្រោះដូច្នោះ ព្រះយោគាវចរកាលឃើញថាជាសភាវៈមិនទៀង ព្រោះមានហើយមិនមាន រមែងដកមានះចេញ ។ ប្រសិនបើឱកាសជាសុខ គួរគប្បីប្រកាន់ថាជាសុខ តែឱកាសនេះជាទុក្ខ នៅតែប្រកាន់ថាជាសេចក្ដីសុខ ព្រោះដូច្នោះ ព្រះយោគាវចរនេះ កាលឃើញថាជាទុក្ខ ព្រោះកើតឡើងអស់ទៅ និងបៀតបៀន រមែងដកសេចក្ដីពេញចិត្តក្នុងឱកាស សូម្បីក្នុងបទដ៏សេស ក៏ដូច្នោះ ។

ព្រះយោគាវចរ លុះពិចារណាយ៉ាងនេះហើយ រមែងពិចារណាឃើញឱកាសថា នុ៎ះមិនមែនជាយើង នុ៎ះមិនមែនជារបស់យើង នុ៎ះមិនមែន



ជាតួខ្លួនយើង កាលពិចារណាយ៉ាងនេះ រមែងមិនកម្រើក មិនញាប់-ញ័រក្នុងឱកាសជាដើម ព្រោះដូច្នោះ ព្រះអានន្ទត្ថេរសម្ដែងសេចក្ដីនោះ ទើបពោលគាថា ថា **ឥមានិ ទស ឋានានិ** ឋានៈ ១០ ប្រការទាំងនេះ ។

ក្នុងបទទាំងនោះ បទថា **ទស ឋានានិ** គឺ មានឱកាសជាដើម ។ បទថា **បញ្ញាយស្ស បរិច្ចិតា** ភិក្ខុនោះកំណត់ដោយបញ្ញា គឺ កំណត់ត្រឹមត្រូវ អប់រំរឿយ ៗ ដោយបញ្ញា ផុតចាកឧបក្កិលេស ។ បទថា **ធម្មុទ្ធច្ចកុសលោ ហោតិ** ជាអ្នកឆ្លាតក្នុងការនឹកដល់ឱកាសជាដើម ដែលជាធម៌រាយមាយ គឺ ព្រះយោគាវចរជាអ្នកកំណត់ឋានៈ ១០ យ៉ាងដោយបញ្ញា ជាអ្នកឆ្លាតដោយការចាក់ធ្លុះតាមសេចក្ដីពិតនៃធម្មុទ្ធច្ចៈ មានប្រការដូចពោលហើយក្នុងកាលមុន ។

បទថា **ន ច សម្មោហគច្ឆតិ** រមែងមិនដល់សេចក្ដីវង្វេង គឺ មិនដល់សេចក្ដីវង្វេងដោយការដកតណ្ហា មានះ និងទិដ្ឋិ ព្រោះភាពជាអ្នកឆ្លាតក្នុងធម្មុទ្ធច្ចៈ ។

ឥឡូវនេះ ព្រះអានន្ទត្ថេរលុះញុំាំងវិធីដែលពោលទុកហើយ ក្នុងផ្នែកមុនឲ្យជាក់ច្បាស់ ដោយបរិយាយដទៃទៀត កាលនឹងសម្ដែង ទើបពោលគាថាជាដើមថា **វិកម្បតិចេវ កិលិស្សតិ ច** ចិត្តរកម្រើក និងសៅហ្មង ។ ក្នុងបទនោះ ព្រះយោគាវចរមានបញ្ញាទន់ខ្សោយ រមែងដល់

សេចក្តីរាយមាយក្នុងឱកាសជាដើម និងការកើតនៃកិលេសដ៏សេស ។ ព្រះយោគាវចរមានបញ្ញាកណ្តាល រមែងដល់សេចក្តីរាយមាយ មិនដល់ការកើតនៃកិលេសដ៏សេស ព្រះយោគាវចរនោះ រមែងជាអ្នកមានមានះខ្លាំង ។ ព្រះយោគាវចរមានបញ្ញាចាស់ក្លា សូម្បីដល់សេចក្តីរាយមាយ ក៏នៅតែលះមានះខ្លាំងក្លានោះបាន ហើយប្រារព្ធវិបស្សនា ។ ចំណែកឧព្រះយោគាវចរអ្នកមានបញ្ញាក្រៃលែង មិនដល់នូវសេចក្តីរាយមាយ និងមិនដល់ការកើតឡើងនៃកិលេសដ៏សេស ។ បទថា **វិកម្បតិ ចេវ** រមែងញាប់ញ័រ បានដល់ បណ្តាព្រះយោគាវចរទាំងនោះ ព្រះយោគា-វចរមានបញ្ញាទន់ខ្សោយ រមែងដល់ភាពរាយមាយ គឺ ធម្មុទ្ធច្ចៈ ។ បទថា **កិលិស្សតិ ច** រមែងសៅហ្មងដោយកិលេស គឺ តណ្ហា មានះ និងទិដ្ឋិ ។ សេចក្តីថា រមែងក្តៅក្រហាយត្រូវបៀតបៀន ។ បទថា **ចវតិ ចិត្តភាវនា** ចិត្តឃ្លាតចាកចិត្តភាវនា គឺ ឃ្លាតចាកចិត្តភាវនា គឺ វិប-ស្សនារបស់ព្រះយោគាវចរនោះអ្នកមានបញ្ញាទន់ខ្សោយ ព្រោះមិនកម្ចាត់ភាពជាបដិបក្ខពីឋានៈក្នុងកិលេសទាំងឡាយនោះឯង អធិប្បាយថា ធ្លាក់ទៅ ។ បទថា **វិកម្បតិ កិលេស្សតិ** ចិត្តរមែងញាប់ញ័រ សៅហ្មង គឺ ព្រះយោគាវចរមានបញ្ញាថ្នាក់កណ្តាល រមែងញាប់ញ័រដោយសេចក្តីរាយ-មាយ រមែងមិនសៅហ្មងដោយកិលេស ។ បទថា **ភាវនា បរិហាយតិ** ភាវនារមែងវិនាសទៅ គឺ វិបស្សនារមែងវិនាស អធិប្បាយថា ប្រព្រឹត្តទៅមិនបាន ដោយមិនមានការប្រារព្ធវិបស្សនា ព្រោះព្រះយោគាវចរអ្នកមានបញ្ញាកណ្តាលនោះ មានមានះខ្លាំង ។ បទថា **វិកម្បតិ ន កិលិស្សតិ** សូម្បីព្រះយោគាវចរ អ្នកមានបញ្ញាចាស់ក្លា ក៏រមែងញាប់ញ័រដោយសេចក្តីរាយមាយ មិន សៅហ្មងដោយកិលេស ។ បទថា **ភាវនា ន បរិហាយតិ** ភាវនារមែង មិនវិនាស គឺ ព្រះយោគាវចរអ្នកមានបញ្ញាចាស់ក្លានោះ កាលនៅមានសេចក្តីរាយមាយ វិបស្សនាភាវនា រមែងមិនវិនាស គឺ នៅតែប្រព្រឹត្តទៅបាន ព្រោះនៅមានការលះសេចក្តីរាយ-មាយនៃអតិមានះនោះ ហើយប្រារព្ធវិបស្សនា ។

បទថា **ន ច វិក្ខិប្បតេ ចិត្តំ ន កិលិស្សតិ** ចិត្តមិនរាយមាយ មិនសៅហ្មង គឺ ចិត្តរបស់ព្រះយោគាវចរអ្នកមានបញ្ញាចាស់ក្លាក្រៃលែង រមែងមិនរាយមាយ ដោយសេចក្តីរាយមាយ និងសៅហ្មងដោយកិលេសទាំងឡាយ ។ បទថា **ន ចវតិ ចិត្តភាវនា** ចិត្តរមែងមិនឃ្លាតចាកចិត្តភាវនា គឺ មិនឃ្លាតចាកចិត្តភាវនា គឺ វិបស្សនារបស់ព្រះយោគាវចរនោះ អធិប្បាយថា តាំងនៅក្នុងទីដដែល ព្រោះមិនមានកិលេសដែលធ្វើឲ្យរាយមាយ ។

ដោយឋានៈដែលជាហេតុ ឬជាការធ្វើ ៤ ទាំងនេះ ដែលលោក

ពោលទុកក្នុងឥឡូវនេះ ក្នុងបទជាដើមថា **ឥមេហិ ចតូហិ ឋានេហិ** ដោយឋានៈ ៤ យ៉ាងទាំងនេះ ព្រះយោគាវចរទី ៤ ជាអ្នកឆ្លាត មានបញ្ញាច្រើន មានចិត្តដែលសេចក្តីរួញរា និងសេចក្តីរាយមាយនៃចិត្តរារាំងក្នុងឋានៈ ១០ យ៉ាង មានឱភាសជាដើម ជាអ្នកប្រាសចាកការកើតឡើងនៃកិលេសដែលធ្វើឲ្យរាយមាយ រមែងដឹងដោយប្រការផ្សេងៗ ថាព្រះយោគាវចរ ៣ ជំពូក មានព្រះយោគាវចរបញ្ញាទន់ខ្សោយជាដើម រមែងមានចិត្តបែបនេះ និងយ៉ាងនេះ ព្រោះហេតុនោះ គប្បីជ្រាបការពណ៌នាអត្ថដោយការសម្ព័ន្ធ ដោយប្រការដូច្នេះ ។

បទថា **សង្ខេបោ** សេចក្តីរុញរា គប្បីជ្រាបចិត្តដែលរួញរាដោយអំណាចការកើតចិត្តរាយមាយ និងកិលេសទាំងឡាយ ។ បទថា **វិក្ខេបោ** សេចក្តីរាយមាយ គឺ គប្បីជ្រាបសេចក្តីដែលចិត្តរាយមាយដោយអំណាចនៃសេចក្តីរាយមាយ ដូចពោលហើយក្នុងឋានៈ ២ ទាំងឡាយថា **វិកម្បតិ កិលិស្សតិ** ចិត្តរមែងញាប់ញ័រ សៅហ្មងដូច្នេះឯង ។

ចប់អដ្ឋកថា ធម្មុទ្ធច្ចវារៈនិទ្ទេស

ចប់អដ្ឋកថា យុគនទ្ធកថា



## ២–អដ្ឋកថា សច្ចកថា

ឥឡូវនឹងពណ៌នាតាមលំដាប់សេចក្តី ដែលនៅមិនទាន់ពណ៌នានៃ **សច្ចកថា** ដែលមានព្រះសូត្រជាខាងដើម ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងដល់សេចក្តីវិសេសនៃការចាក់ធ្លុះសច្ចៈ ដែលតាំងនៅលើសេចក្តីពិតដោយអំណាចនៃអរិយមគ្គជាគុណនៃធម៌គូគ្នា ទ្រង់ត្រាស់ទុកហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រនោះមុន ដូចតទៅនេះ ។ បទថា **តថានិ** គឺ ជារបស់ពិតដោយសេចក្តីពិត ពិតណាស់ ធម្មជាតិទាំងឡាយដែលជាសេចក្តីពិតនោះឯង ឈ្មោះថា **សច្ច** ដោយអត្ថថា ពិត ។ អត្ថនៃសច្ចៈ លោកពោលទុកហើយក្នុងអដ្ឋកថាបឋមញ្ញាណនិទ្ទេស ។ បទថា **អវិតថានិ** ជារបស់មិនប្រែប្រួល គឺ ប្រាសចាកសេចក្តីផ្ទុយគ្នាក្នុងសភាវៈដែលពោលហើយ ព្រោះសច្ចៈមិនមាន ក៏ឈ្មោះថា មិនមានសច្ចៈ ។ បទថា **អនញ្ញាកានិ** មិនឃៀងឃ្លាត គឺ វៀរចាកសភាពដទៃ ព្រោះមិនមែនមានសច្ចៈ ក៏ឈ្មោះថា មានសច្ចៈ ។

បទថា **ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ** សច្ចៈថា នេះទុក្ខ ជារបស់ពិត គឺ ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលពោលថា នេះជាទុក្ខ វត្ថុនេះឈ្មោះថា ជារបស់ពិត ព្រោះតាមសភាពពិត ។ ពិតណាស់ ទុក្ខហ្នឹងឯង

គឺ ទុក្ខ ឈ្មោះថា ជារបស់មិនប្រែប្រួល ព្រោះមិនមានវត្ថុផ្សេងគ្នាក្នុងសភាវៈដូចពោលហើយ ព្រោះទុក្ខមិនមាន ក៏ឈ្មោះថា មិនមានទុក្ខ ឈ្មោះថា មិនឃ្លៀងឃ្លាត ព្រោះប្រាសចាកសភាវៈដទៃ ។ ពិតណាស់ ទុក្ខមិនមានសភាវៈ ជាសមុទយៈ គឺ ហេតុឲ្យកើតទុក្ខបាន ។ សូម្បីក្នុងសមុទយៈជាដើម ក៏មានន័យនេះដូចគ្នា ។



# អដ្ឋកថា បឋមសុត្តន្តនិទ្ទេស

បទថា **តថដ្ឋេន** ដោយអត្ថថា ជារបស់ពិត គឺ ដោយអត្ថតាមសេចក្ដីពិត ។ បទថា **បីឡនដ្ឋោ** សភាពបៀតបៀនជាដើម មានសេចក្ដីដូចពោលហើយ ក្នុងញាណកថានោះឯង ។

បទថា **ឯកប្បដិវេធានិ** មានការសម្រេចដោយញាណមួយ គឺ សម្រេចដោយមគ្គញ្ញាណមួយ ឬឈ្មោះថា **ឯកប្បដិវេធានិ** ព្រោះមានការចាក់ធ្លុះរួមគ្នា ។ បទថា **អនត្តដ្ឋេន** ដោយភាពជាអនត្តា គឺ ដោយភាពជាអនត្តា ព្រោះភាពដែលសច្ចៈ សូម្បី ៤ ប្រាសចាកខ្លួន ។ ដូចដែលលោកពោលទុកក្នុងវិសុទ្ធិមគ្គថា ដោយបរមត្ថ សច្ចៈទាំងអស់នោះឯងគប្បីជ្រាបថា ទទេរ ព្រោះមិនមានអ្នកសោយ អ្នកធ្វើ អ្នករលត់ និងអ្នកទៅ ដោយហេតុនោះ លោកទើបពោលថា :-

> **សេចក្ដីពិត ទុក្ខប៉ុណ្ណោះមាន នរណា ៗ ជាទុក្ខមិនមាន**
> **មិនមានការធ្វើ នរណា ៗ អ្នកធ្វើមិនមាន សេចក្ដីរលត់**
> **នរណា ៗ អ្នករលត់មិនមាន ផ្លូវមាន តែមនុស្សអ្នកដើរ**
> **មិនមាន ។**

ម្យ៉ាងទៀត :

**សភាពទទេរ ចាកសភាពស្អាត សេចក្តីសុខ ការតាំងនៅ**
**និងតួខ្លួន សភាពទទេរចាក ២ បទ ខាងដើម និងតួខ្លួន ជា**
**អមតៈបទ ក្នុងសច្ចៈទាំងនោះ សភាពទទេរជាមគ្គប្រាស**
**ចាកសេចក្តីសុខ ការតាំងនៅ និងតួខ្លួន ។**

បទថា **សច្ចដ្ឋេន** ដោយភាពជារបស់ពិត គឺ ដោយភាពមិនខុសចាកសេចក្តីពិត ។ បទថា **បដិវេធដ្ឋេន** ដោយភាពជាបដិវេធ គឺ ដោយភាវៈគប្បីចាក់ធ្លុះក្នុងខណៈនៃមគ្គ ។ បទថា **ឯកសង្គហិតានិ** សច្ចៈ ៤ លោកសង្គ្រោះតែមួយ គឺ សង្គ្រោះដោយអត្ថមួយ ៗ សេចក្តីថា ដល់ការរាប់ថា ១ ។ បទថា **យំ ឯកសង្គិតំ តំ ឯកត្តំ** វត្ថុណាលោកសង្គ្រោះតែមួយ វត្ថុនុ៎ះតែមួយ សេចក្តីថា ព្រោះលោកសង្គ្រោះ ដោយអត្ថ ១ ដូច្នោះទើបតែមួយ ។ លោកសំដៅដល់ សច្ចៈទាំងឡាយតែមួយ សូម្បីមានច្រើនហើយ ក៏ធ្វើឲ្យជាឯកវចនៈ ។

បទថា **ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតិ** បុគ្គលរមែងចាក់ធ្លុះសច្ចៈ ១ ដោយញាណមួយ គឺ បុគ្គលកំណត់យ៉ាងល្អដល់ភាវៈនៃសច្ចៈ ៤ ផ្សេងគ្នា និងជាចំណែកដូចគ្នា ក្នុងចំណែកខាងដើម ហើយស្ថិតនៅ រមែងចាក់ធ្លុះសច្ចៈ ១ មានសភាពជារបស់ពិតជាដើម ដោយមគ្គញាណ ១ ក្នុងខណៈនៃមគ្គ ។ ដូចម្តេច ពេលចាក់ធ្លុះសច្ចៈ ១ មានសភាពជា



របស់ពិតជាដើម នៃនិរោធសច្ចៈ រមែងជាការចាក់ធ្លុះសច្ចៈ ១ មានភាពជារបស់ពិតជាដើម សូម្បីសច្ចៈដ៏សេសក៏ដូចគ្នា ។ កាលព្រះយោគាវចរ កំណត់ដោយល្អដល់សេចក្តីផ្សេងគ្នា និងជាចំណែកដូចគ្នានៃខន្ធ ៥ ក្នុងចំណែកខាងដើម ហើយតាំងនៅក្នុងពេលចេញចាកមគ្គ ចេញដោយភាពជាសភាវៈមិនទៀង ជាទុក្ខ ជាអនត្តា , សូម្បីឃើញខន្ធ ១ ដោយសភាពមិនទៀងជាដើម សូម្បីខន្ធដ៏សេស ក៏ជាការឃើញដោយសភាពជាសភាវៈមិនទៀង យ៉ាងណា សូម្បីសេចក្តីនេះក៏គប្បីឃើញមានឧបមាដូច្នោះ ។

បទថា **ទុក្ខស្ស ទុក្ខដ្ឋោ តថដ្ឋោ** សភាពទ្រាំបានលំបាកនៃទុក្ខជាសភាវៈពិត គឺ អត្ថ ៤ យ៉ាង មានសេចក្តីបៀតបៀននៃទុក្ខសច្ចៈ ជាដើម ជាសភាវៈពិត ព្រោះពិត ។ សូម្បីក្នុងសច្ចៈដ៏សេស ក៏មានន័យនេះដូចគ្នា ។ អត្ថ ៤ យ៉ាងនោះឯង ឈ្មោះថា ជាសភាវៈមិនមែនតួខ្លួន ព្រោះមិនមានតួខ្លួន ឈ្មោះថា ជាសភាពពិត ព្រោះមិនខុស ប្រាសចាកសេចក្តីពិត ដោយសភាវៈដូចពោលហើយ ឈ្មោះថា ជាសភាវៈចាក់ធ្លុះ ព្រោះគួរចាក់ធ្លុះក្នុងខណៈនៃមគ្គ ។

បទជាដើមថា **យំ អនិច្ចំ** វត្ថុណាមិនទៀង លោកសម្តែងធ្វើសាមញ្ញលក្ខណៈឲ្យជាខាងដើម ។ ក្នុងបទទាំងនោះ បទថា **យំ អនិច្ចំ**

**តំ ទុក្ខំ យំ ទុក្ខំ តំ អនិច្ចំ** វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ វត្ថុនោះមិនទៀង លោកសំដៅយកទុក្ខ សមុទយៈ និងមគ្គ ព្រោះសច្ចៈ ទាំង ៣ នោះ ជាសភាវៈមិនទៀង និងឈ្មោះថា ជាទុក្ខ ព្រោះមិនទៀង ។ បទថា **យំ អនិច្ចញ្ច ទុក្ខញ្ច តំ អនត្តា** វត្ថុណាមិនទៀងផង ជាទុក្ខផង វត្ថុនោះជាអនត្តា លោកសង្គ្រោះសច្ចៈទាំង ៣ នោះ ដូចគ្នា ។ បទថា **យំ អនិច្ចញ្ច ទុក្ខញ្ច អនត្តា ច** វត្ថុណាមិនទៀងផង ជាទុក្ខផង ជាអនត្តាផង លោកសង្គ្រោះយកនិរោធសច្ចៈព្រមទាំងសច្ចៈ ៣ ទាំងនោះ ។ ពិតណាស់ សូម្បីសច្ចៈ ៤ ក៏ជាអនត្តា ។ បទថា **តំ តថំ** វត្ថុនោះជារបស់ពិត គឺ វត្ថុនោះជារបស់ពិត ជាសច្ចៈចតុក្កៈ ។ បទថា **តំ សច្ចំ** វត្ថុនោះជារបស់ពិត គឺ វត្ថុនោះឯងមិនខុសប្រាសចាកសេចក្តីពិត តាមសភាវៈជាសច្ចចតុក្កៈ ។

ក្នុងបទជាដើមថា **នវហាការេហិ** ដោយអាការ ៩ គប្បីជ្រាបថាលោកសម្តែងដោយការដឹងក្រៃលែង ព្រោះព្រះបាលីថា **សព្វំ ភិក្ខវេ អភិញ្ញេយ្យំ** ម្នាលភិក្ខុទាំងឡាយ វត្ថុគួរដឹងក្រៃលែងទាំងពួងជាដើម ដោយការកំណត់ដឹង ព្រោះសេចក្តីប្រាកដនៃញាតបរិញ្ញាក្នុងសច្ចៈ ៤ ក្នុងសច្ចៈនេះសូម្បីផ្សេងគ្នា ក្នុងការកំណត់ដឹងទុក្ខ ក្នុងការលះសមុទយៈ ក្នុងការចម្រើនមគ្គ ក្នុងការធ្វើឲ្យជាក់ច្បាស់និរោធ ដោយការលះ ព្រោះ



ប្រាកដការលះដោយឃើញអរិយសច្ចៈ ៤ ដោយការចម្រើន ព្រោះប្រាកដការចម្រើនអរិយសច្ចៈ ៤ ដោយធ្វើឲ្យជាក់ច្បាស់ ព្រោះប្រាកដការធ្វើឲ្យជាក់ច្បាស់អរិយសច្ចៈ ៤ ។

ក្នុងបទជាដើមថា **នវហាការេហិ តថដ្ឋេន** ដោយភាពជារបស់ពិត ដោយអាការ ៩ លោកប្រកបតាមន័យដែលពោលហើយគ្រាដំបូងនោះឯង ។ ក្នុងបទជាដើមថា **ទ្វាទសហិ អាការេហិ** ដោយអាការ ១២ ដែលជារបស់ពិតជាដើម មានសេចក្តីដូចពោលហើយក្នុងញាណកថា ។

គប្បីជ្រាបការប្រកបតាមន័យដូចពោលហើយ សូម្បីក្នុងនិទ្ទេសនៃអាការទាំងនោះ ។

ក្នុងបទជាដើមថា **សច្ចានំ កតិ លក្ខណានិ** សច្ចៈមានលក្ខណៈប៉ុន្មាន ព្រះមានព្រះភាគជាម្ចាស់ទ្រង់ចែកលក្ខណៈ ៦ ដែលគួរពោលតទៅជា ២ ចំណែក គឺ សង្ខតៈ និងអសង្ខតៈ ហើយត្រាស់ថា **ទ្វេ លក្ខណានិ** មានលក្ខណសច្ចៈ ២ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សង្ខតលក្ខណញ្ច អសង្ខតលក្ខណញ្ច** សង្ខតលក្ខណៈ និងអសង្ខតលក្ខណៈ គឺ ព្រះមាន-ព្រះភាគត្រាស់សង្ខតលក្ខណៈ និងអសង្ខតលក្ខណៈ ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សង្ខតលក្ខណៈ របស់សង្ខតធម៌ ៣ ទាំងនេះ គឺ ការកើតប្រាកដ ១ ការសាបសូន្យប្រាកដ ១ ការឋិតនៅ មានការប្រែ

ប្រែប្រួលប្រាកដ ១ , ម្នាលភិក្ខុទាំងឡាយ អសង្ខតលក្ខណៈ របស់អសង្ខតធម៌ ៣ ទាំងនេះ គឺ ការកើតមិនប្រាកដ ១ ការមិនសាបសូន្យប្រាកដ ១ ការឋិតនៅមានការប្រែប្រួលជាយ៉ាងដទៃមិនប្រាកដ ១ ដូច្នេះ តែសង្ខតធម៌មិនមែនលក្ខណៈ លក្ខណៈមិនមែនសង្ខតធម៌ ។ មយ៉ាងទៀត វៀរសង្ខតធម៌ចេញហើយ មិនអាចបញ្ញត្តិលក្ខណៈបាន សូម្បីវៀរលក្ខណៈចេញហើយ ក៏មិនអាចបញ្ញត្តិសង្ខតធម៌បាន តែសង្ខតធម៌រមែងប្រាកដបានដោយលក្ខណៈ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងលក្ខណៈទាំង ២ នោះដោយពិស្តារ ទើបត្រាស់ថា **ឆ លក្ខណានិ** លក្ខណៈទាំងឡាយ ៦ ។ បទថា **សង្ខតានំ សច្ចានំ** សច្ចៈដែលតាក់តែង គឺ ទុក្ខសច្ចៈ សមុទយសច្ចៈ និងមគ្គសច្ចៈ ព្រោះសច្ចៈទាំងនោះឈ្មោះថា សង្ខតៈ ព្រោះអាស្រ័យបច្ច័យតាក់តែង ។ បទថា **ឧប្បាទោ** គឺ ជាតិ ។ បទថា **បញ្ញាយតិ** គឺ រមែងឲ្យដឹង ។ បទថា **វយោ** គឺ ការរលត់ ។ បទថា **ឋិតានំ អញ្ញថត្តំ** កាលតាំងនៅការប្រែប្រួលប្រាកដ គឺ កាលតាំងនៅសេចក្តីជាយ៉ាងដទៃ គឺ ជរាប្រាកដ ព្រោះដែលសង្ខតសច្ចៈ ៣ សម្រេចហើយ លោកទើបពោលដល់ការកើត ការវិនាស និងការ ប្រែប្រួល តែមិនគួរពោលដល់ ការកើត ការវិនាស និងការប្រែប្រួល ព្រោះការ



កើត មិនគួរពោលថា ការកើត ការវិនាស និងការប្រែប្រួលមិនប្រាកដ ព្រោះអាស្រ័យវត្ថុតាក់តែង តែគួរពោល ជាសង្ខតៈ ព្រោះការខុសប្រក្រតីរបស់សង្ខតៈ ។ អាចារ្យទាំងឡាយថា ការកើត ការចាស់ និងការរលត់របស់ទុក្ខសច្ចៈ និងសមុទយៈសច្ចៈ រាប់ជាប់ដោយសច្ចៈ , ការកើត ការចាស់ និងការរលត់របស់មគ្គសច្ចៈ មិនរាប់ជាប់ដោយសច្ចៈ ។

ក្នុងបទនោះ លោកពោលទុកក្នុងអដ្ឋកថានៃខន្ធកវគ្គថា ក្នុងខណៈសង្ខតៈទាំងឡាយកើត សង្ខតៈទាំងឡាយក្តី លក្ខណៈនៃការកើតក្តី ខណៈសង្ខតៈកើតនោះ ពោលគឺ កាលក្តី រមែងប្រាកដ កាលការកើតកន្លងទៅ សង្ខតៈក្តី លក្ខណៈជរាក្តី ខណៈនៃការកើត ពោលគឺ កាលក្តី រមែងប្រាកដក្នុងខណៈរលត់ សង្ខតៈក្តី ជរាក្តី លក្ខណៈរលត់ក្តី ខណៈនៃការរលត់នោះ ពោលគឺ កាលក្តី រមែងប្រាកដ ។

បទថា **អសង្ខតស្ស សច្ចស្ស** សច្ចៈដែលមិនតាក់តែង គឺ និរោធសច្ចៈ ព្រោះនិរោធសច្ចៈនោះ ឈ្មោះថា អសង្ខតៈ ព្រោះសម្រេចឯង មិនត្រូវអាស្រ័យបច្ច័យតាក់តែង ។ បទថា **ឋិតស្ស** កាលតាំងនៅ គឺ តាំងនៅ ព្រោះជាសភាវៈទៀង មិនបានតាំងនៅ ព្រោះការដល់ឋានៈ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់សម្ដែងលក្ខណៈទាំង ២ នោះទៀតដោយពិស្ដារ ទើបទ្រង់ត្រាស់ថា **ទ្វាទស លក្ខណានិ** លក្ខណៈទាំងឡាយ ១២ ។

គប្បីវិនិច្ឆ័យក្នុងបទជាដើមថា **ចតុន្នំ សច្ចានំ កតិ កុសលា** សច្ចៈ ៤ ជាកុសលប៉ុន្មាន ដូចតទៅនេះ ។ បទថា **អព្យាកតំ** អព្យាកតៈ (ធ្វើឲ្យជាក់ច្បាស់មិនបាន ) គឺ និព្វានជាអព្យាកតៈ ក្នុងអព្យាកតៈ ៤ គឺ វិបាកជាអព្យាកតៈ កិរិយាជាអព្យាកតៈ រូបជាអព្យាកតៈ និព្វានជាអព្យាកតៈ ព្រោះអព្យាកតៈសូម្បីទាំង ៤ ឈ្មោះថា អព្យាកតៈ ព្រោះធ្វើឲ្យជាក់ច្បាស់មិនបាន ដោយលក្ខណៈជាកុសល និងអកុសល ។

បទថា **សិយា កុសលំ** ជាកុសលក៏មាន គឺ ជាកុសលដោយអំណាចនៃកាមាវចរៈកុសល រូបាវចរៈកុសល និងអរូបាវចរៈកុសល ។

បទថា **សិយា អកុសលំ** ជាអកុសលក៏មាន គឺ ជាអកុសលដោយអំណាចនៃអកុសលដ៏សេស វៀរតណ្ហា ។

បទថា **សិយា អព្យាកតំ** ជាអព្យាកតៈក៏មាន គឺ ជាអព្យាកតៈដោយអំណាចនៃវិបាក កិរិយា ដែលជាកាមាវចរៈ រូបាវចរៈ និងអរូ-បាវចរៈ និងរូបទាំងឡាយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **សិយា តីណិ សច្ចានិ** ជាសច្ចៈ ៣ ដូតទៅនេះ ។ បទថា **សង្គហិតានិ** លោក



សង្គ្រោះ គឺ រាប់ចូល ។ បទថា **វត្ថុវសេន** ដោយអំណាចនៃវត្ថុ គឺ ដោយអំណាចនៃវត្ថុ ពោលគឺ ទុក្ខ សមុទយៈ និរោធ មគ្គ ដែលជាអកុសល កុសល និងអព្យាកតៈ ។ បទថា **យំ ទុក្ខសច្ចំ អកុសលំ** ទុក្ខសច្ចៈជាអកុសល គឺ អកុសលដ៏សេស វៀរតណ្ហា ។ **អកុសលដ្ឋេន ទ្វេ សច្ចានិ ឯកសច្ចេន សង្គហិតានិ** សច្ចៈ ២ លោកសង្គ្រោះ ដោយសច្ចៈ ១ ដោយភាពជាអកុសល គឺ ទុក្ខសច្ចៈ និងសមុទយសច្ចៈ ទាំង ២ នេះ លោកសង្គ្រោះដោយសច្ចៈ ១ ដោយភាពជាអកុសល ។ អធិ-ប្បាយថា ឈ្មោះថា ជាអកុសលសច្ចៈ ។ បទថា **ឯកសច្ចំ ទ្វីហិ សច្ចេហិ សង្គហិតំ** សច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ២ គឺ ទុក្ខ-សច្ចៈ និងសមុទយសច្ចៈ ។ បទថា **យំ ទុក្ខសច្ចំ កុសលំ** ទុក្ខសច្ចៈជាកុសល គឺ ជាកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាទុក្ខសច្ចៈ និងមគ្គសច្ចៈ ទាំង ២ នេះ លោកសង្គ្រោះដោយសច្ចៈ ១ ភាពជាកុសល ឈ្មោះថា កុសលសច្ចៈ , កុសលសច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ២ គឺ ទុក្ខសច្ចៈ និងមគ្គសច្ចៈ ។ បទថា **យំ ទុក្ខសច្ចំ អព្យាកតំ** ទុក្ខសច្ចៈជាអព្យាកតៈ គឺ វិបាក កិរិយាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងរូប ជាទុក្ខសច្ចៈ និងនិរោធសច្ចៈ ទាំង ២ នេះ លោកសង្គ្រោះដោយសច្ចៈ ១ ដោយភាពជាអព្យាកតៈ ឈ្មោះថា អព្យាកតសច្ចៈ ,

អព្យាកតសច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ២ គឺ ទុក្ខសច្ចៈ និង និរោធសច្ចៈ ។

បទថា **តីណិ សច្ចានិ ឯកសច្ចេន សង្គហិតានិ** សច្ចៈ ៣ លោកសង្គ្រោះដោយសច្ចៈ ១ គឺ សមុទយសច្ចៈ មគ្គសច្ចៈ និងនិរោធសច្ចៈ លោកសង្គ្រោះដោយទុក្ខសច្ចៈ ១ ដែលជាអកុសល កុសល និងអព្យាកតៈ ។ បទថា **ឯកំ សច្ចំ តីហិ សច្ចេហិ សង្គហិតំ** សច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ៣ គឺ ទុក្ខសច្ចៈ ១ លោកសង្គ្រោះដោយសមុទយសច្ចៈ មគ្គសច្ចៈ និងនិរោធសច្ចៈ ដែលជាអកុសល កុសល និងអព្យាកតៈដទៃទៀត ។ ចំណែកអាចារ្យពួកខ្លះ ពណ៌នាទុកថា ទុក្ខសច្ចៈ និងសមុទយៈសច្ចៈ លោកសង្គ្រោះដោយសមុទយសច្ចៈ ដោយភាពជាអកុសល ទុក្ខសច្ចៈ និងមគ្គសច្ចៈ លោកសង្គ្រោះដោយមគ្គសច្ចៈ ដោយភាពជាកុសល មិនមែនដោយភាពជាទស្សនៈ ។ ទុក្ខសច្ចៈ និងនិរោធសច្ចៈ លោកសង្គ្រោះដោយនិរោធសច្ចៈ ដោយភាពជាអព្យាកតៈ មិនមែនដោយភាពជាសង្ខតៈ ។

ចប់អដ្ឋកថា បឋមសុត្តន្តនិទ្ទេស



## អដ្ឋកថា ទុតិយសុត្តន្តបាលិនិទ្ទេស

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បំណងសម្តែងការចាក់ធ្លុះសច្ចៈ ដោយអំណាចនៃអត្ថរបស់ព្រះសូត្រដទៃទៀត ទើបទ្រង់នាំព្រះសូត្រមកត្រាស់សម្តែងជាដើមថា **បុព្វេ មេ ភិក្ខវេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុព្វេ មេ ភិក្ខវេ សម្ពោធា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ មុនអំពីត្រាស់ដឹង គឺ តាំងអំពីសព្វញ្ញុតញ្ញាណរបស់តថាគត ។ បទថា **អនភិសម្ពុទ្ធស្ស** នៅមិនទាន់ត្រាស់ដឹង គឺ មិនទាន់ចាក់ធ្លុះធម៌ទាំងពួង ។ បទថា **ពោធិសត្តស្សេវ សតោ** គឺ ពេលតថាគតនៅជាពោធិសត្វ ។ បទថា **ឯតទហោសិ** បានមានការគិតនេះ គឺ ពេលតថាគតប្រថាប់លើពោធិបល្ល័ង្ក មានបរិវិតក្កៈនេះ ។ បទថា **អស្សាទោ** សេចក្តីពេញចិត្ត ឈ្មោះថា **អស្សាទ** ព្រោះសេចក្តីពេញចិត្ត ។ បទថា **អាទីនវោ** គឺ ជាទោស ។ បទថា **និស្សរណំ** ឧបាយជាគ្រឿងរលាស់ចេញ គឺ គេចចេញទៅ ។ បទថា **សុខំ** ឈ្មោះថាសុខ ព្រោះដល់សេចក្តីសប្បាយ អធិប្បាយថា ធ្វើរូបដែលកើតឡើងឲ្យមានសេចក្តីសុខ ។ បទថា **សោមនស្សំ** ឈ្មោះថា **សុមន** ព្រោះមានចិត្តស្អាត ព្រោះប្រកបដោយបីតិ និងសោមនស្ស ភាវៈនៃការមាន

ចិត្តស្អាត ឈ្មោះថា **សោមនស្សំ** សេចក្តីសុខនោះឯងវិសេសជាង ការប្រកបដោយបីតិ ។ បទថា **អនិច្ចំ** គឺ មិនតាំងនៅ ។ បទថា **ទុក្ខំ** ឈ្មោះថា ទុក្ខ ព្រោះជាទីតាំងនៃសេចក្តីទុក្ខ និងជាសង្ខារទុក្ខ ។ បទថា **វិបរិណាមធម្មំ** មានសេចក្តីប្រែប្រួលជាធម្មតា គឺ មិននៅក្នុងអំណាច មានការប្រែប្រួលទៅដោយជរា និងការរលត់ជាប្រក្រតី ដោយបទនេះ លោកពោលដល់ការមិនមានតួខ្លួន ។ បទថា **ឆន្ទរាគវិនយោ** ការកម្ចាត់ឆន្ទរាគៈ គឺ រាគំងរាគៈដែលបានដល់ ឆន្ទៈ មិនមែនរាគំងរាគៈ គឺ ពណ៌សម្បុរ ។ បទថា **ឆន្ទរាគប្បហានំ** ការលះឆន្ទរាគៈ គឺ លះឆន្ទរាគៈនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **យាវកីវញ្ច** ត្រឹមណាដូចតទៅនេះ ។ តថាគតមិនទាន់ដឹងសព្វ គឺ មិនចាក់ធ្លុះដោយញាណដ៏ក្រៃលែងនូវគុណដោយភាពជាគុណ ។ល។ នៃឧបាទានក្ខន្ធ ៥ ទាំងនេះ តាមសេចក្តីពិតត្រឹមណា តថាគតក៏នៅមិនទាន់ប្តេជ្ញា គឺ មិនធ្វើការប្តេជ្ញាថា តថាគតជាអរហន្ត បានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណ គឺ ភាពជាសព្វញ្ញូ មិនមានអ្នកដទៃក្រៃលែងជាងត្រឹមនោះ គប្បីជ្រាបអត្ថដោយការភ្ជាប់ដោយប្រការដូច្នេះ ។ បទថា **កីវញ្ច** ជានិបាត ។ បទថា **យតោ** គឺ ព្រោះហេតុណា ឬក្នុងកាលណា ។ បទថា **អថ** គឺ ក្នុងលំដាប់ ។

បទថា **ញាណញ្ច បនមេ ទស្សនំ ឧទបាទិ** ញាណទស្សនៈ



កើតឡើងដល់តថាគត គឺ បច្ចវេក្ខណញ្ញាណ គឺ ទស្សនៈកើតឡើងដល់តថាគត ដោយធ្វើកិច្ច គឺ ទស្សនៈ ។ បទថា **អកុប្បា** មិនកម្រើក គឺ មិនឲ្យកម្រើក មិនឲ្យញាប់ញ័របាន ។ បទថា **វិមុត្តិ** គឺ អរហត្តផលវិមុត្តិ សូម្បីការពិចារណាមគ្គ និព្វាន ក៏ជាការដែលលោកពោលដោយការពិចារណាផលនោះឯង ។ បទថា **អយមន្តិមា ជាតិ** ជាតិនេះមានក្នុងទីបំផុត គឺ ការប្រព្រឹត្តទៅនៃខន្ធនេះមានក្នុងទីបំផុត ។ បទថា **នត្ថិទានិ បុនព្ភវោ** ឥឡូវនេះការកើតទៀតមិនមាន គឺ ឥឡូវនេះមិនមានការកើតទៀត ដោយបទនេះ លោកពោលដល់ការពិចារណាកិលេសដែលលះបានហើយ ព្រោះការពិចារណាកិលេសដែលនៅសល់ មិនមានដល់ព្រះអរហន្ត ។

ចប់អដ្ឋកថា ទុតិយសុត្តន្តបាលិនិទ្ទេស

## អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស

ការត្រាស់ដឹងថា សុខសោមនស្សសម្បយុត្តដោយតណ្ហានេះ ជាគុណនៃរូប ក្នុងលំដាប់នៃការប្រកបសច្ចៈបដិវេធញ្ញាណ និងក្នុងចំណែកខាងដើមថា **អយំ រូបស្ស អស្សាទោតិ បហានប្បដិវេធោ** ការចាក់ធ្លុះដោយការលះថា សុខសោមនស្សនេះ ជាគុណនៃរូប ហើយចាក់ធ្លុះសមុទយសច្ចៈ ពោលគឺ ការលះសមុទយក្នុងខណៈនៃមគ្គ ។ បទថា **សមុទយសច្ចំ** សមុទយសច្ចៈ គឺ ញាណដែលចាក់ធ្លុះក្នុងសមុទយសច្ចៈ ។ សូម្បីអារម្មណញ្ញាណ ដែលជាអរិយសច្ចៈ លោកក៏ពោលថា **សច្ច** ដូចក្នុងប្រយោគជាដើមថា កុសលធម៌ណាមួយ កុសលធម៌ទាំងអស់នោះ រមែងដល់នូវការសង្គ្រោះចូលក្នុងអរិយសច្ចៈ ៤ ។

ការត្រាស់ដឹងថា រូបមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជា ធម្មតា នេះជាទោសនៃរូបក្នុងចំណែកខាងដើមថា **អយំ រូបស្ស អាទី-នវោតិ បរិញ្ញាបដិវេធោ** ការចាក់ធ្លុះដោយការកំណត់ដឹងថា រូបមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា នេះជាទោសនៃរូប ហើយចាក់ធ្លុះទុក្ខសច្ចៈ ពោលគឺ ការកំណត់ដឹងទុក្ខក្នុងមគ្គញ្ញាណ ។ បទថា **ទុក្ខសច្ចំ** បានដល់ ញាណដែលចាក់ធ្លុះក្នុងទុក្ខសច្ចៈ ។



ការត្រាស់ដឹងថា នេះជាឧបាយជាគ្រឿងរលាស់ចេញនៃរូបក្នុងចំណែកខាងដើមថា **ឥទំ រូបស្ស និស្សរណន្តិ សច្ឆិកិរិយាបដិវេធោ** ការចាក់ធ្លុះដោយធ្វើជាក់ច្បាស់ថា ការកម្ចាត់ឆន្ទរាគៈ ការលះឆន្ទរាគៈ នេះជាឧបាយរលាស់ចេញនៃរូប ហើយចាក់ធ្លុះនិរោធសច្ចៈ ពោលគឺ ការធ្វើឲ្យជាក់ច្បាស់ក្នុងខណៈនៃមគ្គ ។ បទថា **និរោធសច្ចំ** និរោធ-សច្ចៈ គឺ ញាណចាក់ធ្លុះនិរោធសច្ចៈ មាននិរោធសច្ចៈជាអារម្មណ៍ ។ បទថា **យា ឥមេសុ តីសុ ឋានេសុ** ក្នុងឋានៈទាំង ៣ នេះ គប្បីជ្រាបការប្រកបសេចក្ដីថា **ទិដ្ឋិ សង្កប្ប** ប្រព្រឹត្តទៅហើយដោយអំណាចនៃការចាក់ធ្លុះក្នុងសមុទយៈ ទុក្ខ និរោធ ៣ តាមដែលពោលហើយនេះ ។ បទថា **ភាវនា បដិវេធោ** ការចាក់ធ្លុះដោយភាវនា គឺ ចាក់ធ្លុះដោយមគ្គសច្ចៈ ដែលបានដល់ មគ្គភាវនានេះ ។ បទថា **មគ្គសច្ចំ** មគ្គសច្ច គឺ ញាណដែលចាក់ធ្លុះមគ្គសច្ចៈ ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងសច្ចៈ និងការចាក់ធ្លុះសច្ចៈដោយបរិយាយដទៃទៀត ទើបទ្រង់ត្រាស់ ព្រះតម្រាស់ជាដើមថា **សច្ចន្តិ កតិហាការេហិ សច្ចំ** សច្ចៈដោយអាការប៉ុន្មាន ។ ក្នុងបទនោះ ព្រោះព្រះសព្វញ្ញូពោធិសត្វសូម្បីទាំងពួង ប្រថាប់លើពោធិបល្ល័ង្ក ក៏ស្វែងរកសមុទយសច្ចៈ មានជាតិជាដើម របស់ទុក្ខសច្ចៈ មានជរាមរណៈ

ជាដើម ថាអ្វីហ្ន៎ ។ មួយ៉ាងទៀត ការស្វែងរកយ៉ាងនោះ ទើបកំណត់កាន់យកថា សមុទយសច្ចៈ មានជាតិជាដើម ជាបច្ច័យរបស់ទុក្ខសច្ចៈ មានជរាមរណៈជាដើម ដូច្នោះ ការស្វែងរកនោះ និងការកំណត់នោះ លោកធ្វើជាសច្ចៈ ព្រោះស្វែងរក និងកំណត់សច្ចៈទាំងឡាយ ទើបពោលថា **ឯសនដ្ឋេន បរិគ្គហដ្ឋេន** ដោយការស្វែងរក ដោយការកំណត់ ។

មួយ៉ាងទៀត វិធីនេះ រមែងបានក្នុងការកំណត់បច្ច័យ សូម្បីរបស់ព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ តែរមែងបានក្នុងការកំណត់បច្ច័យនៃព្រះសាវកទាំងឡាយ ដោយការស្តាប់ ។ បទថា **បដិវេធដ្ឋេន** ដោយការចាក់ធ្លុះ គឺ ដោយការចាក់ធ្លុះជាចំណែកដូចគ្នា ក្នុងខណៈនៃមគ្គ របស់អ្នកដែលស្វែងរក និងរបស់អ្នកកំណត់យ៉ាងនោះ ក្នុងចំណែកខាងដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **កឹនិទានំ** ដូចតទៅនេះ ។ បទថា **និទាន** ជាដើម ជាវេចនៈរបស់ហេតុទាំងអស់ ព្រោះហេតុរមែងឲ្យនូវផល ដូចប្រាប់ថា អញ្ជើញពួកលោកទទួលរបស់នោះចុះ ដូច្នេះ ហេតុនេះទើបលោកពោលថា **និទាន** ព្រោះផលរមែងតាំងឡើង កើតឡើង ជាដែនកើតឡើងអំពីហេតុនោះ ដូច្នោះលោកទើបពោលថា **សមុ-ទយោ ជាតិ បភវោ** ។ ក្នុងបទនោះ មានអធិប្បាយដូចតទៅនេះ ។ ឈ្មោះថា **កឹនិទានំ** ព្រោះមានអ្វីជាហេតុ ។ ឈ្មោះថា **កឹសមុទយំ**



ព្រោះមានអ្វីជាសមុទយៈ ។ ឈ្មោះថា **កឹជាតិកំ** ព្រោះមានអ្វីជាកំណើត ។ ឈ្មោះថា **កឹបភវំ** ព្រោះមានអ្វីជាដែនកើត ។

មួយ៉ាងទៀត ព្រោះជរាមរណៈនោះ មានជាតិជាហេតុ មានជាតិជាសមុទយៈ មានជាតិជាកំណើត មានជាតិជាដែនកើត ដោយអត្ថតាមដែលពោលហើយ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបទ្រង់ត្រាស់ថា **ជាតិនិទានំ** មានជាតិជាហេតុ ជាដើម ។ បទថា **ជរាមរណំ** ជរាមរណៈ គឺ ទុក្ខសច្ចៈ ។ បទថា **ជរាមរណសមុទយំ** ហេតុកើតនៃជរា និងមរណៈ គឺ សមុទយសច្ចៈជាបច្ច័យនៃជរា និងមរណៈនោះ ។ បទថា **ជរាមរណនិរោធំ** ការរលត់នៃជរា និងមរណៈ គឺ និរោធសច្ចៈ ។ បទថា **ជរាមរណនិរោធគាមិនីបដិបទំ** ការបដិបត្តិឲ្យដល់សេចក្តីរលត់នៃជរា និងមរណៈ គឺ មគ្គសច្ចៈ ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយន័យនេះ ។ បទថា **និរោធប្បជាននា** ការដឹងច្បាស់ដល់សេចក្តីរលត់ គឺ ដឹងការរលត់ដោយធ្វើជាអារម្មណ៍ ។ បទថា **ជាតិ សិយា ទុក្ខសច្ចំ សិយា សមុទយសច្ចំ** ជាតិជាទុក្ខសច្ចៈក៏មាន ជាសមុទយសច្ចៈក៏មាន ឈ្មោះថា **ទុក្ខសច្ច** ដោយសេចក្តីប្រាកដ ព្រោះភពជាបច្ច័យ ឈ្មោះថា **សមុទយ** ព្រោះដោយភាពជាបច្ច័យរបស់ជរា និងមរណៈ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។ បទថា **អវិជ្ជា សិយា ទុក្ខសច្ចំ** អវិជ្ជា

ជាទុក្ខសច្ចៈក៏មាន ក៏ព្រោះមានអាសវៈជាសមុទយៈ អវិជ្ជាជាសមុទយៈ ព្រោះសភាវៈជាដែនកើត ដូច្នេះ ។

ចប់អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស

ចប់អដ្ឋកថា សច្ចកថា



## ៣-អដ្ឋកថា ពោជ្ឈង្គកថា

ឥឡូវនេះ នឹងពណ៌នាសេចក្តីតាមលំដាប់ ដែលមិនទាន់ពណ៌នា នៃ **ពោជ្ឈង្គកថា** មានព្រះសូត្រជាខាងដើម ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងដល់សេចក្តីពិសេសរបស់ពោជ្ឈង្គៈឲ្យសម្រេចនៃការចាក់ធ្លុះសច្ចៈ ទ្រង់ត្រាស់ទុកហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រនោះ ដូចតទៅនេះ ។ បទថា **ពោជ្ឈង្គា** លោកពោលថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់ដឹង ឬនៃបុគ្គលអ្នកត្រាស់ដឹង ។ ព្រះអរិយសាវក រមែងត្រាស់ដឹងដោយធម្មសាមគ្គី បានដល់ សតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គ ជាបដិបក្ខនៃអន្តរាយទាំងឡាយដ៏ច្រើន មានសេចក្តីរួញរា រាយមាយ តាំងនៅ រួបរួម ប្រកបកាមសុខ ធ្វើខ្លួនឲ្យលំបាក ឧច្ឆេទទិដ្ឋិ សស្សតទិដ្ឋិ និងការប្រកាន់មាំជាដើម ព្រោះហេតុនោះ លោកទើបពោលថា **ពោធិ** អ្នកត្រាស់ដឹង ។ បទថា **ពុជ្ឈតិ** រមែងត្រាស់ដឹង លោកអធិប្បាយថា ចេញពីការដេកលក់ ដែលជាសន្តាននៃកិលេស ឬចាក់ធ្លុះអរិយសច្ចៈ ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ដូចព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងថា អ្នកចម្រើនពោជ្ឈង្គៈ ៧ ហើយត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអង្គនៃការត្រាស់ដឹង បានដល់ ធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គជាដើម ។ សូម្បីព្រះអរិយសាវកណា រមែងត្រាស់ដឹងដោយធម្មសាមគ្គីនោះ មានប្រការតាមដែលពោលហើយ លោកហៅព្រះអរិយសាវកនោះថា **ពោធិ** ។ ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃអ្នកត្រាស់ដឹងនោះ ដូចអង្គសេនា និងអង្គរថជាដើម ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ ទើបពោលថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃអ្នកត្រាស់ដឹង ។ លោកពោលអត្ថនៃសតិសម្ពោជ្ឈង្គៈជាដើមទុកក្នុងអភិញ្ញេយ្យនិទ្ទេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គនិទ្ទេស ដូចតទៅនេះ ។ បទថា **ពោធាយ សំវត្តន្តិ** រមែងប្រព្រឹត្តទៅក្នុងការត្រាស់ដឹង គឺ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង ។ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងរបស់អ្នកណា ? ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងរបស់អ្នកមានកិច្ចដែលធ្វើហើយដោយការពិចារណានិព្វាន ដោយមគ្គ និងផល ឬដើម្បីប្រយោជន៍ដល់ការភ្ញាក់ពីការដេកលក់ ព្រោះកិលេស លោកអធិប្បាយថា ដើម្បីភាពជាអ្នកត្រាស់ដឹងដោយផល ។ ពោជ្ឈង្គៈ រមែង



ប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង សូម្បីមានវិបស្សនាជាកម្លាំង ។ នេះជាអធិប្បាយទូទៅរបស់ពោជ្ឈង្គៈដែលជាវិបស្សនាមគ្គ និងផល ។ ពោជ្ឈង្គៈទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹងក្នុងឋានៈ ៣ ដើម្បីចាក់ធ្លុះនិព្វាន ។ ដោយបទនេះ លោកពោលដល់ពាក្យថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់ដឹង ។ ទីកើតរបស់ពោជ្ឈង្គៈ លោកពោលទុកដោយចតុក្កៈ ៥ មានជាដើមថា **ពុជ្ឈន្តីតិ ពោជ្ឈង្គា** ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថា ត្រាស់ដឹង លោកពោលទុកក្នុងអភិញ្ញេយ្យនិទ្ទេស ។ ម្យ៉ាងទៀត បទថា **ពុជ្ឈន្តិ** សម្ដែងដល់អ្នកធ្វើ ដើម្បីឲ្យឃើញនូវភាពជាអ្នកអាចក្នុងការធ្វើកិច្ចរបស់ខ្លួននៃពោជ្ឈង្គៈ ។ បទថា **ពុជ្ឈនដ្ឋេន** ព្រោះអត្ថថា ត្រាស់ដឹង សូម្បីភាពជាអ្នកអាចក្នុងការធ្វើកិច្ចរបស់ខ្លួន ក៏បង្ហាញដល់ភាវៈដើម្បីឲ្យឃើញភាពមិនមានអ្នកធ្វើ ។ បទថា **ពោធេន្តិ** ឲ្យត្រាស់ដឹង ដោយការចម្រើនពោជ្ឈង្គៈ បង្ហាញដល់ហេតុកត្តា ( អ្នកប្រើឲ្យធ្វើ ) ព្រោះជាអ្នកប្រកប ។ បទថា **ពោធដ្ឋេន** ព្រោះអត្ថឲ្យត្រាស់ដឹង គឺ បង្ហាញដល់ភាវៈរបស់អ្នកប្រើឲ្យធ្វើ ព្រោះជាអ្នកប្រកប តាមន័យដូចពោលហើយក្នុងកាលមុននោះឯង ។ បទថា **ពោធិបក្ខិយដ្ឋេន** ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងចំណែក ត្រាស់ដឹង គឺប្រព្រឹត្តទៅក្នុងចំណែករបស់ព្រះយោគាវចរអ្នកបាន ឈ្មោះថា **ពោធិ**

ព្រោះអត្ថថា ឲ្យត្រាស់ដឹង ។ នេះជាការសម្តែងសេចក្តីដែលពោជ្ឈង្គៈទាំងនោះ ជាឧបការៈដល់ព្រះយោគាវចរ ។ ដោយបទទាំងនេះ លោកអធិប្បាយថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃការត្រាស់ដឹង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងលក្ខណៈជាដើមថា **ពុទ្ធិលភនដ្ឋេន** គឺ ព្រោះអត្ថថា ឲ្យបានការត្រាស់ដឹង ។ បទថា **ពុទ្ធិលភនដ្ឋេន** គឺ ព្រោះអត្ថថា ឲ្យយោគាវចរដល់ការត្រាស់ដឹង ។ បទថា **ពោធនដ្ឋេន** ព្រោះអត្ថថា បណ្តុះការត្រាស់ដឹង គឺ ព្រោះអត្ថថា ឲ្យសត្វទាំងឡាយតាំង នៅ ។ បទថា **បាបនដ្ឋេន** ព្រោះអត្ថថា ឲ្យដល់ការត្រាស់ដឹង គឺ ព្រោះអត្ថថា ឲ្យសម្រេចដល់សត្វដែលតាំងនៅ ។

អាចារ្យទាំងឡាយពោលថា ពោជ្ឈង្គៈដែលវិបស្សនាទាំងនេះ គឺ ពោជ្ឈង្គៈជាមគ្គផល ផ្សេងគ្នាដោយឧបសគ្គ ៣ សព្ទ គឺ **បតិ អភិ សំ** ចំពោះ ក្រៃលែង ព្រម គប្បីជ្រាបថា លោកអធិប្បាយទុកថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់ដឹងពោជ្ឈង្គៈទាំងឡាយ លោកសម្តែងទុកដោយធម្មវោហារសូម្បីទាំងអស់ ។



# អដ្ឋកថា មូលមូលកាទិទសកកថា

គប្បីជ្រាបវិនិច្ឆ័យក្នុងមូលមូលកទសកៈ ជាដើមថា **មូលដ្ឋេន** ដូចតទៅនេះ ។ បទថា **មូលដ្ឋេន** ព្រោះអត្ថថា ជាមូល គឺ ក្នុងវិបស្សនាជាដើម ព្រោះអត្ថថា ពោជ្ឈង្គៈមុន ៗ ជាមូលរបស់ពោជ្ឈង្គៈក្រោយ ៗ នៃសហជាតធម៌ និងដល់គ្នានឹងគ្នា ។ បទថា **មូលចរិយដ្ឋេន** ព្រោះអត្ថថា ប្រព្រឹត្តតាមអត្ថដែលជាមូល គឺ ប្រព្រឹត្តទៅជាមូល ឈ្មោះថា **មូលចរិយា** ព្រោះអត្ថថា ប្រព្រឹត្តទៅជាមូលនោះ អធិប្បាយថា ព្រោះអត្ថថា ជាមូល ហើយទើបប្រព្រឹត្តទៅ ។ បទថា **មូលបរិគ្គហដ្ឋេន** ព្រោះអត្ថថា កំណត់ធម៌ដែលជាមូល គឺ ពោជ្ឈង្គៈទាំងនោះ ឈ្មោះថា កំណត់ ព្រោះកំណត់ដើម្បីត្រូវការឲ្យកើតតាំងអំពីដើមកំណត់មូលនោះឯង ឈ្មោះថា **មូលបរិគ្គហា** ព្រោះអត្ថថា កំណត់ធម៌ដែលជាមូលនោះ ។ ឈ្មោះថា **បរិវារដ្ឋេន** ព្រោះអត្ថថា មានធម៌ជាបរិវារ ដោយជាបរិវារដល់គ្នានឹងគ្នា ។ ឈ្មោះថា **មូលបរិបូរដ្ឋេន** ព្រោះអត្ថថា មានធម៌បរិបូណ៌ដោយការបំពេញភាវនា ។ ឈ្មោះថា **មូលបរិបាកដ្ឋេន** ព្រោះអត្ថថា មានធម៌ចាស់ក្លា ដោយឲ្យដល់សេចក្តីសម្រេច ។ ឈ្មោះថា **មូលប្បដិសម្ភិទា** បែកធ្លាយក្នុងធម៌ដែលជាមូល ព្រោះមូល ៦ យ៉ាង

ទាំងនោះ ឈ្មោះថា **បដិសម្ភិទា** ព្រោះបែកធ្លាយក្នុងប្រភេទ ព្រោះអត្ថថា បែកធ្លាយក្នុងធម៌ដែលជាមូល ។ បទថា **មូលប្បដិសម្ភិទាបាបនដ្ឋេន** ព្រោះអត្ថថា ឲ្យដល់ការបែកធ្លាយក្នុងធម៌ដែលជាមូល គឺ ព្រោះអត្ថថា ឲ្យដល់ការបែកធ្លាយក្នុងធម៌ដែលជាមូលរបស់ព្រះយោគាវចរ ដែលខ្វល់ខ្វាយក្នុងការចម្រើនពោជ្ឈង្គ: ព្រោះអត្ថថា ចម្រើនការជំនាញ ដោយការបែកធ្លាយក្នុងធម៌ដែលជាមូលនោះនៃព្រះយោគាវចរនោះឯង ។ ក្នុងវោហាររបស់បុគ្គលដូច្នេះ សូម្បីដ៏សេសគប្បីជ្រាបថា លោកពោលថា ពោជ្ឈង្គ: ព្រោះជាអង្គនៃអ្នកត្រាស់ដឹង ។ គប្បីជ្រាបពោជ្ឈង្គ:ជាផល ក្នុងការមិនពោលដល់សេចក្ដីសម្រេចដូច្នេះ ក្នុងបទថា **មូលប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ** សូម្បីរបស់អ្នកដល់ភាពជំនាញ ក្នុងការបែកធ្លាយនូវធម៌ដែលជាមូល ។ បាឋ:ថា **វសីភាវំ បត្តានំ** របស់អ្នកដល់ភាពជំនាញខ្លះ ។

(ចប់មូលមូលកទសក:)



# អដ្ឋកថា ពោជ្ឈង្គកថា

ក្នុងទសក: ៩ មានហេតុមូលក:ជាដើម សូម្បីដ៏សេសគប្បីជ្រាបអត្ថនៃពាក្យទូទៅដោយន័យនេះឯង ។ ពោជ្ឈង្គ:តាមដែលពោលហើយក្នុងពាក្យមិនទូទៅ ឈ្មោះថា **ហេតុ** ព្រោះឲ្យកើតធម៌តាមដែលពោលហើយ ឈ្មោះថា **បច្ច័យ** ព្រោះឧបត្ថម្ភ ឈ្មោះថា **វិសុទ្ធិ** ព្រោះជាសេចក្ដីបរិសុទ្ធនៃតទង្គ: **សមុច្ឆេទ** និង **បដិបស្សទ្ធិ** ឈ្មោះថា មិនមានទោស ព្រោះប្រាសចាកទោស ឈ្មោះថា **នេក្ខម្ម** ព្រោះបាលីថា **សព្វេបិ កុសលា ធម្មា នេក្ខម្មំ** កុសលធម៌សូម្បីទាំងអស់ជានេក្ខម្ម: ឈ្មោះថា **វិមុត្តិ** ដោយអំណាចនៃតទង្គវិមុត្តិជាដើម ព្រោះរួចផុតចាកកិលេសទាំងឡាយ ។ ពោជ្ឈង្គ:ដែលជាមគ្គ និងផល ឈ្មោះថា **អនាសវា** ព្រោះប្រាសចាកវិស័យរបស់អាសវ: ។ ពោជ្ឈង្គ: សូម្បី ៣ យ៉ាង ឈ្មោះថា **វិវេកា** ដោយអំណាចនៃតទង្គវិវេកជាដើម ព្រោះស្ងាត់ចាកកិលេសទាំងឡាយ ។ ពោជ្ឈង្គ:ដែលជាវិបស្សនា និងមគ្គ ឈ្មោះថា **វោស្សគ្គា** ព្រោះស្ទុះទៅការលះ និងស្ទុះទៅដោយការស្ទុះទៅ ។ ពោជ្ឈង្គ:ជាផល ឈ្មោះថា **វោស្សគ្គា** ព្រោះស្ទុះទៅដោយការស្ទុះទៅ ។ ទសក: ៩ លោកសម្ដែងដោយបទមួយ ៗ ជាដើមថា **មូលដ្ឋំ ពុជ្ឈន្តិ** ត្រាស់

ដឹងសភាវៈដែលជាមូល គប្បីជ្រាបដូចន័យដែលពោលហើយនោះឯង ។ ចំណែកបទថា **វសីភាវប្បត្តានំ** លោកមិនប្រាប់ ព្រោះមិនមានពាក្យជាបច្ចុប្បន្នកាល ការកំណត់ជាដើម មានអត្ថដូចពោលហើយក្នុងអភិ-ញ្ញេយ្យនិទ្ទេស ។

ព្រះថេរៈ គ្រាលើកសូត្រដែលខ្លួនសម្តែងឡើងហើយ បំណងនឹងសម្តែងពោជ្ឈង្គៈ វិធីដោយការបង្ហាញសូត្រនោះ ទើបពោលពាក្យនិទានមានជាអាទិ៍ថា **ឯកំ សមយំ** ហើយលើកឡើងសម្តែង ។ ក៏ក្នុងសូត្រនេះ ព្រោះជាសូត្រដែលខ្លួនឯងសម្តែង លោកទើបមិនពោលថា **ឯវំ មេ សុតំ** ។ មយ៉ាងទៀត ក្នុងបទថា **អាយស្មា សារីបុត្តោ** នេះ លោកពោលធ្វើខ្លួន ដូចជាអ្នកដទៃជាដើម ដើម្បីភាពច្បាស់របស់អ្នកសម្តែង ។ ព្រោះអាចារ្យទាំងឡាយប្រកបពាក្យដូច្នេះ ទុកច្រើនក្នុងគន្ថៈទាំងឡាយក្នុងលោក ។ បទថា **បុព្វណ្ហសមយំ** គឺ អស់វេលាព្រឹកទាំងមូល ។ បទនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃអច្ចន្តសំយោគ សូម្បីក្នុងពីរបទដ៏-សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ អាវុសោ ហោតិ** ម្នាលអាវុសោ ប្រសិនបើសតិសម្ពោជ្ឈង្គៈរបស់យើងមានហើយដូច្នេះ គឺ ប្រសិនបើសតិសម្ពោជ្ឈង្គៈរបស់យើងមានហើយយ៉ាងនេះ ។ **អប្បមាណោតិ មេ ហោតិ** សតិសម្ពោជ្ឈង្គៈរបស់យើង



ក៏មិនមានប្រមាណ គឺ សតិសម្ពោជ្ឈង្គៈរបស់យើងរកប្រមាណមិនបានយ៉ាងនេះ ។ បទថា **សុសមារទ្ធោតិ មេ ហោតិ** ប្រារព្ធហើយដោយល្អ គឺ សតិសម្ពោជ្ឈង្គៈរបស់យើង បរិបូណ៌ដោយល្អយ៉ាងនេះ ។ បទថា **តិដ្ឋន្តំ** តាំងនៅ គឺ តាំងនៅ ដោយប្រព្រឹត្តទៅក្នុងនិព្វានារម្មណ៍ ។ បទថា **ចវតិ** ឃ្លាតទៅ គឺ ប្រាសទៅចាកនិព្វានារម្មណ៍ សូម្បីក្នុងពោជ្ឈង្គៈដ៏សេស ក៏មានន័យនេះ ។ បទថា **រាជមហាមត្តស្ស** គឺ មហាអាមាត្យរបស់ព្រះរាជា ឬអ្នកប្រកប ដោយប្រមាណភោគសម្បត្តិ ព្រោះមានភោគសម្បត្តិច្រើន ។ បទថា **នានារត្តានំ** ពេញដោយសំពត់ពណ៌ផ្សេង ៗ គឺ សំពត់ជ្រលក់ដោយពណ៌ផ្សេង ៗ ។ បទនេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថបរិបូណ៌ អធិប្បាយថា ដោយពណ៌ផ្សេង ៗ ។ បទថា **ទុស្សករណ្ឌកោ** គឺ ប្រៀបបានទូរក្សាសំពត់ ។ បទថា **ទុស្សយុគំ** សំពត់គូ គឺ គូនៃសំពត់ ។ បទថា **បារុបិតុំ** គឺ ដើម្បី បិទបាំង ។ ក្នុងសូត្រនេះលោក ពោលដល់ពោជ្ឈង្គៈដែលជាផលរបស់ ព្រះថេរៈពិតណាស់ ក្នុងកាលណាព្រះថេរៈធ្វើសតិសម្ពោជ្ឈង្គៈឲ្យជាប្រធាន ហើយចូលដល់ផលសមាបត្តិ ក្នុងកាលនោះ ពោជ្ឈង្គៈក្រៅពីនេះ ក៏ប្រព្រឹត្តតាមសតិសម្ពោជ្ឈង្គៈនោះទៅ ក្នុងកាលណាចូលដល់ធម្មវិចយសម្ពោជ្ឈង្គៈជាដើមណាមួយ ក្នុងកាលនោះ ពោជ្ឈង្គៈសូម្បីដ៏សេស ក៏ប្រព្រឹត្តតាម

ធម្មវិចយសម្ពោជ្ឈង្គៈនោះទៅ ព្រោះហេតុនោះ ព្រះថេរៈកាលនឹងសម្ដែងនូវភាពជំនាញរបស់ខ្លួនក្នុងការប្រព្រឹត្តនូវផលសមាបត្តិយ៉ាងនោះ ទើបពោលសូត្រនេះ ។

(ចប់អដ្ឋកថា ពោជ្ឈង្គកថា)



# អដ្ឋកថា សុត្តន្តនិទ្ទេស

ក្នុងបទថា **កថំ សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតិ** ប្រសិនបើសតិសម្ពោជង្គៈរបស់យើងមានដូច្នេះ នោះមានយ៉ាងណា បទថា **ពោជ្ឈង្គោ** សេចក្ដីថា កាលព្រះយោគាវចរចូលផលសមាបត្តិ ធ្វើសតិ-សម្ពោជ្ឈង្គៈឲ្យជាប្រធាន កាលពោជ្ឈង្គៈដទៃមានហើយ សតិសម្ពោជ្ឈង្គៈរមែងមានយ៉ាងនេះ ព្រោះហេតុនេះ ប្រសិនបើកាលសតិសម្ពោជ្ឈង្គៈប្រព្រឹត្តទៅហើយយ៉ាងនេះ សតិសម្ពោជ្ឈង្គៈនោះ មានយ៉ាងណា ។

បទថា **យាវតា និរោធូបដ្ឋាតិ** និរោធ រមែងប្រាកដត្រឹមណា គឺនិរោធរមែងប្រាកដក្នុងកាលណា អធិប្បាយថា និព្វានរមែងប្រាកដជាអារម្មណ៍ក្នុងកាលណា ។ បទថា **យាវតា អច្ចិ** អណ្ដាតភ្លើងមានត្រឹមណា គឺ អណ្ដាតភ្លើងមានប្រមាណត្រឹមណា ។ បទថា **កថំ អប្បមា-ណោ ឥតិ ចេ ហោតីតិ ពោជ្ឈង្គោ** ពោជ្ឈង្គៈក្នុងសេចក្ដីថា សតិ-សម្ពោជ្ឈង្គៈរបស់យើង ក៏ឈ្មោះថា រកប្រមាណមិនបាននោះ មានយ៉ាងណា សេចក្ដីថា កាលសតិសម្ពោជ្ឈង្គៈ សូម្បីរកប្រមាណមិនបានមានហើយ សតិសម្ពោជ្ឈង្គៈនេះ ក៏រមែងរកប្រមាណមិនបាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ប្រសិនបើសតិសម្ពោជ្ឈង្គៈរកប្រមាណ

មិនបាន មានដល់ព្រះយោគាវចរអ្នកប្រព្រឹត្តទៅយ៉ាងណា ។ បទថា **បមាណវន្តោ** មានប្រមាណ គឺ កិលេសទាំងឡាយ បរិយុដ្ឋានកិលេស និងសង្ខារធ្វើឲ្យកើតភពថ្មី ឈ្មោះថា មានប្រមាណ ។ រាគៈ ជាដើម ព្រោះពាក្យថា រាគៈ ទោសៈ មោហៈ ធ្វើប្រមាណ រមែងកើតឡើង ដល់បុគ្គលណា ធ្វើប្រមាណដល់បុគ្គលនោះថា នេះប្រមាណប៉ុណ្ណេះ ឈ្មោះថា ប្រមាណ ។ កិលេសជាដើមជាគ្រឿងចងអាស្រ័យក្នុងប្រមាណនោះ ឈ្មោះថា មានប្រមាណ ។ បទថា **កិលេស** គឺ ជាអនុស័យ ។ បទថា **បរិយុដ្ឋានា** គឺ កិលេសដល់នូវការរាយមាយ ។ បទថា **សង្ខារា បោនោព្ភវិកា** សង្ខារដែលឲ្យកើតភពថ្មី គឺ ការកើតភពរឿយ ៗ ឈ្មោះថា **នព្ភវ** ឈ្មោះថា **បោនព្ភវិកា** ព្រោះមានភពថ្មី ជាប្រក្រតី ការមានភពថ្មីនោះឯង ឈ្មោះថា **បោនោព្ភវិកា** ។ **សង្ខារ** បានដល់ កុសលកម្ម និង អកុសលកម្ម ។ បទថា **អប្បមាណោ** រកប្រមាណមិនបាន គឺ ឈ្មោះថា រកប្រមាណមិនបាន ព្រោះមិនមានប្រមាណ ដែលមានប្រមាណដូចប្រការដែលពោលហើយ ដើម្បីសេចក្តីពិសេសពីនោះ ព្រោះសូម្បីមគ្គ និង ផល ក៏មិនមានប្រមាណ ។ បទថា **អចលដ្ឋេន អសង្ខតដ្ឋេន** ព្រោះអត្ថថា មិនញាប់ញ័រ ព្រោះអត្ថថា ជាអសង្ខតធម៌បានពោលទុកហើយ ឈ្មោះថា មិនញាប់ញ័រ ព្រោះមិនមានការរលត់ ឈ្មោះថា **អសង្ខត**



ព្រោះមិនមានបច្ច័យ ពិតណាស់ ទាំងមិនញាប់ញ័រ ទាំងជាអសង្ខតៈ ប្រាសចាកប្រមាណ យ៉ាងក្រៃលែង ។

បទថា **កថំ សុសមារទ្ធោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ** សតិសម្ពោជ្ឈង្គៈ ឈ្មោះថា យើងប្រារព្ធហើយដោយល្អនោះយ៉ាងណា គឺ គប្បីប្រកបដូចន័យដែលពោលហើយក្នុងលំដាប់ ។ បទថា **វិសមា** មិនស្មើ ឈ្មោះថា **វិសមា** ព្រោះមិនស្មើដោយខ្លួនឯង និងព្រោះជាហេតុនៃការមិនស្មើ ។ បទថា **សមធម្មោ** ឈ្មោះថា ធម៌ស្មើ ព្រោះអត្ថថា ជាធម៌ស្ងប់ ជាធម៌ប្រណីត ឈ្មោះថា **ស្ងប់** ព្រោះមិនមានប្រមាណ ឈ្មោះថា **ប្រណីត** ព្រោះអត្ថថា ជាធម៌ខ្ពង់ខ្ពស់ជាងធម៌ទាំងពួង ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាសង្ខតៈធម៌ក្តី អសង្ខតធម៌ក្តី មានប្រមាណត្រឹមណា តថាគតពោលថា **វិរាគ** ថាជាធម៌ប្រសើរជាងធម៌ទាំងពួង ។ ប្រារព្ធហើយក្នុងធម៌ស្មើដោយល្អ ដូចពោលហើយក្នុងសមធម៌នោះ ឈ្មោះថា **សុសមារទ្ធោ** ប្រារព្ធហើយដោយល្អ ។ បទថា **អាវជ្ជិតត្តា** ព្រោះការនឹកដល់ លោកពោលសំដៅដល់កាលដែលប្រព្រឹត្តទៅហើយដោយផលសមាបត្តិ លោកអធិប្បាយទុកថា ព្រោះមនោទ្វារាវជ្ជនៈកើតឡើងហើយក្នុងនិព្វាន ពោលគឺ **អនុប្បាទាទិ** ( និព្វានដែលមិនមានការកើត ) ជាដើម ។ បទថា **តិដ្ឋតិ** តាំងនៅ គឺ ប្រព្រឹត្តទៅ ។

បទថា **ឧប្បាទា** ( ការកើត ) ជាដើម មានអត្ថដូចដែលលោកពោលទុកហើយក្នុងខាងក្រោយ ។ ក្នុងវារៈសូម្បីដែលជាពោជ្ឈង្គមូលកៈដ៏សេសក៏មានន័យនេះដូចគ្នា ។

(ចប់ អដ្ឋកថាពោជ្ឈង្គកថា)



## ៤-អដ្ឋកថា មេត្តាកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់ដែលនៅមិនទាន់ធ្លាប់ពណ៌នានៃមេត្តាកថា ដែលមានព្រះសូត្រជាខាងដើម ដំណើរតាមពោជ្ឈង្គកថា ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកលំដាប់នៃពោជ្ឈង្គកថា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រនោះដូចតទៅនេះ ។ បទថា **អាសេវិតាយ** ដែលបុគ្គលសេពហើយ គឺ ដោយអើពើ ។ បទថា **ភាវិតាយ** គឺ ចម្រើនហើយ ។ បទថា **ពហុលីកតាយ** ធ្វើឲ្យច្រើនហើយ គឺ ធ្វើហើយរឿយ ៗ ។ បទថា **យានីកតាយ** ធ្វើឲ្យដូចជាយាន គឺ ធ្វើឲ្យដូចជាយានដែលទឹមហើយ ។ បទថា **វត្ថុកតាយ** ធ្វើឲ្យជាទីតាំង គឺ ធ្វើដូចវត្ថុ ព្រោះអត្ថថា ជាទីតាំង ។ បទថា **អនុដ្ឋិតាយ** តាំងទុករឿយ ៗ គឺ ប្រាកដហើយ ។ បទថា **បរិចិតាយ** អប់រំហើយ គឺ សន្សំទុកឲ្យតាំងនៅដោយជុំវិញ ។ បទថា **សុសមារទ្ធាយ** ប្រារព្ធល្អហើយ គឺ ប្រារព្ធហើយដោយល្អ ធ្វើដោយល្អហើយ ។ បទថា **អានិសង្សា** គឺ គុណ ។ បទថា **បាដិកង្ខា** សង្ឃឹម គឺ គប្បីសង្ឃឹម គប្បីប្រាថ្នា ។

បទថា **សុខំ សុបតិ** ដេកលក់ជាសុខ គឺ ដេកលក់ជាសុខ មិនដេកលក់ដូចមនុស្សចំណែកច្រើន ដេកស្រមុ៉ករមៀលទៅមក ដេកលក់

ជាទុក្ខ សូម្បីឈានចុះកាន់ការដេកលក់ ក៏ដូចចូលផលសមាបត្តិ ។ បទថា **សុខំ បដិពុជ្ឈតិ** ភ្ញាក់ជាសុខ គឺ ភ្ញាក់ជាសុខ មិនខុសប្រក្រតី ដូចផ្កាបទុមរីកស្គុះស្គាយ មិនភ្ញាក់ដូចអ្នកដទៃដែលថ្ងូរពត់កាយត្រឡប់ទៅមក ភ្ញាក់ជាទុក្ខ ។ បទថា **ន បាបកំ សុបិនំ បស្សតិ** មិនសុបិនអាក្រក់ គឺ កាលសុបិន រមែងឃើញសុបិនដ៏ចម្រើន ដូចសំពះព្រះចេតិយ៍ ដូចធ្វើការបូជា ដូចការស្តាប់ព្រះធម៌ មិនដែលសុបិនអាក្រក់ដូចអ្នកដទៃដែលសុបិន្តឃើញដូចត្រូវចោរព័ទ្ធចាប់ខ្លួន ដូចត្រូវសត្វកាចបៀតបៀន និងដូចធ្លាក់ចុះក្នុងជ្រោះ ។ បទថា **មនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ គឺ ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ដូចកែវមុក្តាពាក់ទុកត្រង់ទ្រូង និងដូចផ្កាឈើប្រដាប់ទុកលើសីសៈ ។ បទថា **អមនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ គឺ ជាទីស្រឡាញ់សូម្បីរបស់អមនុស្សដូចជាទីស្រឡាញ់របស់មនុស្ស ។ បទថា **ទេវតា រក្ខន្តិ** ទេវតារមែងរក្សា គឺ ទេវតារមែងរក្សា ដូចមាតារក្សាបុត្ត ដូច្នោះ ។

បទថា **នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** ភ្លើង ថ្នាំពិស សស្ត្រា រមែងមិនប៉ះពាល់គេ គឺ ភ្លើង ថ្នាំពិស សស្ត្រា រមែងមិនឈានចូលទៅ ក្នុងកាយរបស់អ្នកនៅដោយមេត្តា អធិប្បាយថា មិន



ញាំងកាយរបស់គេឲ្យកម្រើក ។ បទថា **តុវដំ ចិត្តំ សមាធិយតិ** ចិត្តរមែងតាំងមាំបានរហ័ស គឺ ចិត្តអ្នកនៅដោយមេត្តា រមែងតាំងមាំបានដោយរហ័ស មិនមានការយឺតយូរ ។ បទថា **មុខវណ្ណោ វិប្បសីទតិ** សម្បុរមុខស្រស់បស់ គឺ មុខរបស់គេមានពណ៌ស្រស់ថ្លា ដូចត្នោតទុំផុតចាកទង ។ បទថា **អសម្មូឡ្ហោ កាលំ ករោតិ** មិនវង្វេងពេលធ្វើមរណកាល គឺ អ្នកនៅដោយមេត្តា មិនវង្វេងក្នុងពេលជិតស្លាប់ មិនវង្វេងក្នុងការធ្វើកាលកិរិយា ដូចមនុស្សឈានចុះកាន់ការដេកលក់ ។ បទថា **ឧត្តរឹ អប្បដិវិជ្ឈន្តោ** ពេលមិនទាន់ចាក់ធ្លុះធម៌ដ៏ក្រៃលែង គឺ កាលមិនទាន់អាចសម្រេចអរហត្តដ៏ក្រៃលែងជាងមេត្តាសមាបត្តិ បានឃ្លាតចាកលោកនេះ ដូចដេកលក់ហើយភ្ញាក់ ។ បទថា **ព្រហ្មលោកូបគោ ហោតិ** គឺ រមែងចូលដល់ព្រហ្មលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមេត្តានិទ្ទេស ដូចតទៅនេះ ។ បទថា **អនោធិសោ ផរណា** គឺ ផ្សាយទៅដោយមិនមានចំណែកសល់ ឈ្មោះថា **ឱធិ** មិនមានខេត្តដែន ឈ្មោះថា **អនោធិ** ដោយមិនមានខេត្តដែននោះ សេចក្តីថា ដោយមិនចោះចំពោះ លោកអធិប្បាយថា ផ្សាយទៅដោយមិនមានទីកំណត់ ។ បទថា **ឱធិសោ** ដោយចំណែក គឺ ដោយមានកំណត់ បទថា **ទិសា ផរណា** គឺ ផ្សាយទៅក្នុងទិសទាំងឡាយ ។

បទថា **សព្វេ** ទាំងអស់ គឺ កំណត់ដោយមិនមានសល់ ។ អត្ថនៃបទថា **សត្តា** លោកពោលទុកហើយក្នុងអដ្ឋកថាមាតិកាញាណកថា ។ វោហារនេះ រមែងប្រព្រឹត្តទៅ សូម្បីអ្នកដែលប្រាសចាករាគៈហើយដោយរុឡ្ហិ-សព្ទដូចវោហារថា ផ្ចិតស្លឹកត្នោត រមែងប្រព្រឹត្តទៅក្នុងផ្ចិតវិជនី សូម្បីធ្វើដោយឫស្សី ។ បទថា **អវេរា** មិនមានពៀរ គឺ ប្រាសចាកពៀរ ។ បទថា **អព្យាបជ្ឈា** មិនបៀតបៀន គឺ វៀរចាកការព្យាបាទ ។ បទថា **អនីឃា** គឺ មិនមានទុក្ខ ។ បទថា **សុខី អត្តានំ បរិហរន្តុ** រក្សាខ្លួនទៅជាសុខចុះ គឺ មានសេចក្តីសុខញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ គប្បីជ្រាបសេចក្តីសម្ពន្ធរបស់ពាក្យក្នុងបទយ៉ាងនេះថា សម្តែងការមិនមានពៀរអាស្រ័យសន្តានរបស់ខ្លួន និងអ្នកដទៃ អាស្រ័យសន្តានរបស់អ្នកដទៃ និងមនុស្សក្រៅពីនេះ ក្នុងបទថា **អវេរា** សម្តែងការមិនមានព្យាបាទ ដែលមិនមានពៀរនោះជាមូល ព្រោះការមិនមានពៀរ ក្នុងបទជាដើមថា **អព្យាបជ្ឈា** សម្តែងសេចក្តីមិនមានទុក្ខ ដែលមិនមានការព្យាបាទនោះជាមូល ព្រោះមិនមានការព្យាបាទ ក្នុងបទថា **អនីឃា** សម្តែងការរក្សាអត្តភាពដោយសេចក្តីសុខ ព្រោះមិនមានទុក្ខ ក្នុងបទថា **សុខី អត្តានំ បរិហរន្តុ** ផ្សាយមេត្តាដោយអំណាចនៃពាក្យដែលប្រាកដហើយ ក្នុងពាក្យទាំងឡាយ ៤ ជាដើមថា **អវេរា ហោន្តុ** ចូរកុំមានពៀរ



ឡើយទាំងនេះ ។

ក្នុងបទជាដើមថា **បាណា** មានសេចក្តីដូចតទៅនេះ ។ ឈ្មោះថា **បាណា** ព្រោះមានជីវិត សេចក្តីថា ព្រោះប្រព្រឹត្តទៅអាស្រ័យខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។ ឈ្មោះថា **ភូតា** ព្រោះមានទៅ សេចក្តីថា ព្រោះទៅកើត ។ ឈ្មោះថា **បុគ្គលា** ព្រោះទៅក្នុងនរកដែលលោកហៅថា **បុំ** នោះ ។ សរីរៈ ឬខន្ធបញ្ចកៈ លោកហៅថា អត្តភាព សំដៅដល់អត្តភាព ព្រោះប្រាកដត្រឹមបញ្ញត្តិ ឈ្មោះថា **អត្តភាវបរិយា-បន្នា** អ្នកជាប់ដោយអត្តភាព ព្រោះជាប់ដោយការកំណត់ ឈានចុះក្នុងអត្តភាពនោះ ។ លោកលើកពាក្យដ៏សេសដោយអំណាចនៃរុឡ្ហិសព្ទ ( សព្ទដែលពង្រីកសេចក្តី ) ហើយ គប្បីជ្រាបថា ពាក្យទាំងអស់នោះជាវេវចនៈរបស់សត្វទាំងពួង ដូចពាក្យ **សត្តា** ដូច្នោះ ។

ពាក្យសូម្បីដទៃ ជាវេវចនៈរបស់សត្វទាំងពួងជាដើមថា **សព្វេ ជន្តូ សព្វេ ជីវា** សត្វកើតទាំងពួង សត្វមានជីវិតទាំងពួង ក៏មានដោយពិត តែលោកកាន់យកពាក្យ ៥ ទាំងនេះ ដោយជាពាក្យប្រាកដហើយ ទើបពោលថា **មេត្តាចេតោវិមុត្តិ** ផ្សាយទៅដោយមិនចោះចំពោះ ដោយអាការ ៥ ។ ម្យ៉ាងទៀត មិនមែនដោយពាក្យត្រឹមតែនិយាយតែម្យ៉ាងប៉ុណ្ណោះ នៃបទជាដើមថា **សត្តា បាណា** ពិតណាស់ សត្វណាប្រាថ្នា

សេចក្តីផ្សេងគ្នា សូម្បីដោយអត្ថ ការផ្សាយទៅដោយមិនចោះចំពោះរបស់សត្វទាំងនោះរមែងខុស ព្រោះដូច្នោះមិនកាន់យកអត្ថយ៉ាងនោះ ហើយផ្សាយមេត្តាដោយមិនចោះចំពោះ ដោយអាការណាមួយ ក្នុងអាការ ៥ នោះ ។

ម្យ៉ាងទៀត ក្នុងការផ្សាយទៅដោយចោះចំពោះ គប្បីជ្រាបសេចក្តីដូច្នេះ ។ បទថា **ឥត្ថិយោ បុរិសា** លោកពោលដល់ភេទ ។ បទថា **អរិយា អនរិយា** លោកពោលដល់អរិយៈ និងបុថុជ្ជន ។ បទថា **ទេវា មនុស្សា វិនិបាតិកា** លោកពោលដល់ការកើត ។ សូម្បីក្នុងការផ្សាយទៅក្នុងទិស មិនធ្វើការចែកទិស ហើយផ្សាយទៅដោយមិនចោះចំពោះ ព្រោះផ្សាយទៅ ដោយន័យជាដើមថា **សព្វេ សត្តា** ក្នុងទិសទាំងពួង ផ្សាយទៅដោយចំពោះ ព្រោះផ្សាយទៅដោយន័យជាដើមថា **សព្វា ឥត្ថិយោ** ក្នុងទិសទាំងពួង ។

ម្យ៉ាងទៀត ព្រោះការផ្សាយមេត្តាសូម្បី ៣ យ៉ាងនេះ លោកពោលដោយអំណាចនៃចិត្តមិនដល់អប្បនា ដូច្នោះគប្បីកាន់យកអប្បនាក្នុងវារៈ ៣ ក្នុងការផ្សាយដោយមិនចោះចំពោះ លោកពោលដល់ការផ្សាយទៅ ៤ យ៉ាង ដោយរួបរួមប្រយោជន៍នោះឯង គឺ ម្យ៉ាងថា សត្វទាំងឡាយទាំងពួង ចូរកុំមានពៀរនឹងគ្នាឡើយ ។ ម្យ៉ាងថា ចូរកុំ



បៀតបៀនគ្នា ។ ម្យ៉ាងថា ចូរកុំមានទុក្ខ ។ ម្យ៉ាងថា ចូរមានសេចក្តីសុខរក្សាខ្លួនចុះ ព្រោះមេត្តាមានលក្ខណៈរួបរួមប្រយោជន៍ដោយអំណាចនៃអប្បនាមួយ ៗ មាន ៤ ក្នុងអាការ ៥ ជាដើមថា **សត្តា** រួមជាអប្បនា ២០ ក្នុងការផ្សាយដោយចោះចំពោះ ដោយអំណាចនៃអប្បនាមួយ ៗ មាន ៤ ក្នុងអាការ ៧ ជាដើមថា **សព្វា ឥត្ថិយោ** រួមជាអប្បនា ២៨ ។ ម្យ៉ាងទៀតក្នុងការផ្សាយទៅក្នុងទិស អប្បនា ៤៨០ គឺ អប្បនា ២០០ ធ្វើមួយ ៗ ឲ្យជា ២០ ក្នុងទិសមួយ ៗ ដោយន័យជាដើមថា សត្វទាំងឡាយទាំងពួងក្នុងទិសខាងកើត អប្បនា ២៨០ ធ្វើមួយ ៗ ២៨ នៃទិសមួយ ៗ ដោយន័យជាដើមថា ស្ត្រីទាំងឡាយទាំងពួងក្នុងទិសខាងកើត អប្បនាទាំងអស់ លោកពោលទុកក្នុងទីនេះរួមអប្បនា ៥២៨ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលការផ្សាយសូម្បី ករុណា មុទិតា ឧបេក្ខា ដូចលោកពោលការផ្សាយមេត្តាដោយអាការ ៣ យ៉ាង ដូច្នោះ ។

## អដ្ឋកថា ឥន្ទ្រិយវារៈ

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ ដើម្បីទ្រង់ត្រាស់សម្ដែងអាការប្រមូលមកនូវមេត្តា និងការអប់រំឥន្ទ្រិយជាដើម ទើបទ្រង់ត្រាស់ព្រះតម្រាស់ជាដើមថា **សព្វេសំ សត្តានំ បីឡនំ វជ្ជេត្វា** វៀរការបៀតបៀនសត្វទាំងឡាយទាំងពួង ។

ក្នុងបទទាំងនោះ បទថា **បីឡនំ** ការបៀតបៀន គឺ ការបៀតបៀនសរីរៈខាងក្នុង ។ បទថា **ឧបឃាតំ** ការសម្លាប់ គឺ ការសម្លាប់សរីរៈខាងក្រៅ ។ បទថា **សន្តាបំ** ការធ្វើឲ្យក្ដៅក្រហាយ គឺ ធ្វើឲ្យចិត្តក្ដៅក្រហាយ ដោយប្រការផ្សេង ៗ ។ បទថា **បរិយាទានំ** សេចក្ដីញាំញី គឺ ការអស់ជីវិតជាដើម ដោយប្រក្រតី ។ បទថា **វិហេសំ** បៀតបៀន គឺ បៀតបៀនជីវិតអ្នកដទៃ ។ បទថា **វជ្ជេត្វា** វៀរ គឺ នាំមួយ ៗ ក្នុងការបៀតបៀនជាដើម ចេញទៅអំពីចិត្តរបស់ខ្លួនឯង ។ លោកពោលបទ ៥ មានការបៀតបៀនទាំងនេះជាដើម ដែលវៀរវត្ថុដែលជាបដិបក្ខចំពោះការរួបរួមមេត្តា ។

បទថា **អបីឡនាយ** ដោយការមិនបៀតបៀនជាដើម លោកពោល



ដោយការរួបរួមមេត្តា ។

បទថា **អបីឡនាយ** គប្បីភ្ជាប់សេចក្ដីថា ប្រព្រឹត្តមេត្តាក្នុងសត្វទាំងពួងដោយអាការមិនបៀតបៀន ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទ ៣ សូម្បីទាំងនេះថា **មា វេរិនោ មា ទុក្ខិនោ មា ឧក្ខិតត្តា** ចូរកុំមានពៀរ ចូរកុំមានទុក្ខ ចូរកុំមានខ្លួនជាទុក្ខ ជាពាក្យបដិសេធវត្ថុជាបដិបក្ខនៃការរួបរួមមេត្តា ។ ពាក្យថា **មា** គឺ ចូរកុំមាន ។ ៣ បទថា **អវេរិនោ សុខិនោ សុខិតត្តា** ចូរជាអ្នកមិនមានពៀរ មានសេចក្ដីសុខ មានខ្លួនជាសុខ ជា ពាក្យរួបរួមមេត្តា ។ ២ បទនេះថា **អព្យាបជ្ឈា អនីឃា** ចូរជាអ្នកមិនបៀតបៀន មិនមានទុក្ខ គប្បីជ្រាបថា លោកសង្គ្រោះចូលដោយពាក្យថា **សុខិនោ** ចូរមានសេចក្ដីសុខ ។

បទថា **សុខិតត្តា** ចូរមានខ្លួនជាសុខ សម្ដែងសេចក្ដីសុខនោះប្រព្រឹត្តទៅជានិច្ច ។ ម្យ៉ាងទៀត បទថា **សុខិតត្តា** និងបទថា **សុខី អត្តានំ បរិហរន្តុ** ដោយអត្ថដូចគ្នា ។ ម្យ៉ាងទៀត គប្បីសង្គ្រោះពាក្យថា ការមិនបៀតបៀនគ្នា និងការមិនមានទុក្ខ ដោយបទជាដើមថា **អបី-ឡនាយ** ដោយមិនបៀតបៀន ។ បទថា **អដ្ឋហាការេហិ** ដោយអាការ ៨ ទាំងនេះ គឺ អាការរួបរួមមេត្តា ៥ ជាដើមថា **អបីឡនាយ** អាការ

រួបរួមមេត្តា ៣ ជាដើមថា **អវេរិនោ ហោន្តុ** ។ បទថា **មេត្តាយតិ** ប្រព្រឹត្តដោយសេចក្តីស្រឡាញ់ គឺ សេចក្តីអាល័យ ។ បទថា **តំ ធម្មំ ចេតយតិ** គិតដល់ធម៌នោះ គឺ គិតជាប់តធម៌នោះដែលរួបរួមប្រយោជន៍ អធិប្បាយថា ប្រព្រឹត្ត ។ បទថា **សព្វព្យាបាទបរិយុដ្ឋានេហិ វិមុច្ចតិ** ផុតចាកការព្យាបាទ និងបរិយុដ្ឋានកិលេសទាំងពួង គឺ ផុតចាកការគ្របសង្កត់ដោយសេចក្តីរាយមាយរបស់ព្យាបាទទាំងពួង ដែលជាបដិបក្ខនៃមេត្តា ។ បទថា **មេត្តា ច ចេតោវិមុត្តិ ច** មេត្តា និងចេតោវិមុត្តិ គឺ មេត្តាមយ៉ាងប៉ុណ្ណោះ លោកពណ៌នាទុក ៣ យ៉ាង ។

បទ ៣ ទាំងនេះ គឺ **អវេរិនោ ខេមិនោ សុខិនោ** ជាអ្នកមិនមានពៀរ មានសេចក្តីក្សេម មានសេចក្តីសុខ លោកពោលសង្គ្រោះអាការដូចពោលហើយក្នុងបទមុនដោយសង្ខេប ។ ឥន្ទ្រិយ ៥ សម្បយុត្តដោយមេត្តា លោកពោលហើយ ដោយន័យជាដើមថា **សទ្ធាយ អធិមុច្ចតិ** បង្អោនចិត្តទៅដោយសទ្ធា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈ ៦ ជាដើមថា **អាសេវនា** ដូចទៅនេះ ឈ្មោះថា **អាសេវនា** ព្រោះសេពមេត្តា ។ ភាវនាពហុលីកម្ម ក៏យ៉ាងនោះ ។ បទថា **អលង្ការា** អលង្ការ គឺ គ្រឿងប្រដាប់ ។ បទថា **ស្វាលង្កតា** ប្រដាប់ដោយល្អ គឺ ប្រដាប់តាក់តែងដោយល្អ ។ បទថា **បរិក្ខារា** គឺ សម្ភារៈទាំងឡាយ ។ បទថា **សុបរិក្ខតា** តាក់តែងដោយល្អ



គឺ ប្រមូលរួបរួមទុកដោយល្អ ។ បទថា **បរិវារា** ដោយអត្ថថា **រក្ខា** ។ លោកពោល ២៨ បទ មានអាសេវនៈជាដើមទៀត ដើម្បីពោលដល់គុណរបស់មេត្តា ។ ក្នុងបទទាំងនោះ បទថា **បារិបូរិ** ធ្វើឲ្យពេញ គឺ ការបរិបូណ៌ ។ បទថា **សហគតា** គឺ សហគតដោយបញ្ញា ។ បទថា **សហជាតា** ជាដើម ក៏យ៉ាងនោះ ។ បទថា **បក្ខន្ទនា** ស្ទុះទៅ គឺ ចូលទៅដោយមេត្តា ឈ្មោះថា **បក្ខន្ទនា** ព្រោះជាហេតុស្ទុះទៅនៃមេត្តា ។ បទថា **សំសីទនា** សេចក្តីផូរផង់ជាដើម ក៏យ៉ាងនោះ ។ បទថា **ឯតំ សន្តន្តិ បស្សនា** ឃើញថា នេះស្ងប់ គឺ ឃើញថា មេត្តានេះស្ងប់ ព្រោះហេតុនោះ ការឃើញថានេះស្ងប់ ជានបុំសកលិង្គ ដូចក្នុងពាក្យថា **ឯតទគ្គំ** នេះប្រសើរ ។ បទថា **ស្វាធិដ្ឋិតា** អធិដ្ឋានល្អហើយ គឺ តាំងទុកដោយល្អ ។ បទថា **សុសមុគ្គតា** ដំណើរទៅដោយល្អហើយ គឺ លើកឡើងហើយដោយល្អ ។ បទថា **សុវិមុត្តា** រួចផុតវិសេសហើយ គឺ ផុតដោយល្អហើយចាកសឹកសត្រូវរបស់ខ្លួន ៗ ។ បទថា **និព្វត្តេន្តិ** គឺ ឥន្ទ្រិយ ៥ ប្រការ សម្បយុត្តដោយមេត្តា ញ៉ាំងមេត្តាឲ្យកើត ។ បទថា **ជោតេន្តិ** ឲ្យរុងរឿង គឺ ធ្វើឲ្យប្រាកដ ។ បទថា **បតាបេន្តិ** ឲ្យក្លៀវក្លា គឺ ឲ្យរុងរោចន៍ ។

ចប់ ឥន្ទ្រិយវារៈ

## អដ្ឋកថា ពលាធិវារត្តយ

គប្បីជ្រាបពលវារៈ ដោយន័យដូចពោលហើយក្នុងឥន្ទ្រិយវារៈនោះឯង ។ លោកពោលវារៈអង្គនៃមគ្គក្នុងពោជ្ឈង្គៈទុក ដោយបរិយាយមិនបានពោល ដោយអំណាចតាមលក្ខណៈ ។ ក្នុងវារៈនៃអង្គមគ្គលោកពោលសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ទុកដោយអំណាចនៃចំណែកខាងដើមរបស់មេត្តា មិនមែនដោយអំណាចនៃអប្បនា ព្រោះធម៌ទាំងនោះរមែងមិនកើតរួមដោយមេត្តា ។ គប្បីជ្រាបអត្ថនៃវារៈដ៏សេសជាដើមថា **សព្វេសំ បាណានំ** នៃសត្វទាំងឡាយទាំងពួង ដោយន័យដូចពោលហើយក្នុងវារៈ ៧ នោះឯង ។ ចំណែកវិធីចម្រើនមេត្តាគប្បីកាន់យកពីវិសុទ្ធិមគ្គ ។

ចប់ អដ្ឋកថាពលាធិវារត្តយ

ចប់ អដ្ឋកថាមេត្តាកថា



## ៥–អដ្ឋកថា វិរាគកថា

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តី ដែលមិនធ្លាប់ពណ៌នានៃវិរាគកថា ដែលមានពោល គឺ វិរាគៈជាខាងដើម ដែលព្រះសារីបុត្តត្ថេរពោលទុកហើយ ក្នុងលំដាប់នៃមេត្តាកថាដែលជាទីបំផុតការប្រកបមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិរាគកថានោះសិន ព្រះសារីបុត្តត្ថេរប្រាថ្នាសម្តែងអត្ថនៃបទព្រះសូត្រទាំង ២ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកហើយថា ពេលនឿយណាយ រមែងបន្ទោបង់សេចក្តីត្រេកអរ ព្រោះបន្ទោបង់សេចក្តីត្រេកត្រអាល ចិត្តរមែងផុត ទើបតាំងឧទ្ទេសថា **វិរាគោ មគ្គោ វិមុត្តោ ផលំ** វិរាគជាមគ្គ វិមុត្តិជាផល ។

ព្រះសារីបុត្តត្ថេរសម្តែងអត្ថនៃពាក្យក្នុងវិរាគកថានោះមុន ទើបពោលពាក្យជាដើមថា **កថំ វិរាគោ មគ្គោ** វិរាគៈ ជាមគ្គដូចម្តេច ។ ក្នុងបទទាំងនោះ បទថា **វិរជ្ជតិ** រមែងបន្ទោបង់ គឺ ប្រាសចាកសេចក្តីត្រេកត្រអាល បទដ៏សេសមានអត្ថដូចពោលហើយ ក្នុងមគ្គញ្ញាណនិទ្ទេស ។ បទថា **វិរាគោ** សេចក្តីថា ព្រោះសម្មាទិដ្ឋិ រមែងបន្ទោបង់សេចក្តីត្រេកត្រអាល ដូច្នោះទើបឈ្មោះថា **វិរាគ** ។

ម្យ៉ាងទៀត វិភត្ត: ( មគ្គ ) នោះ ព្រោះមានវិភត្ត: (និព្វាន) ជាអារម្មណ៍ ។ល។ ប្រតិស្ឋានក្នុងវិភត្ត: ដូច្នោះ គប្បីជ្រាបសេចក្តីសម្ព័ន្ធរបស់ពាក្យទាំងឡាយ ៥ ជាដើមថា **វិភត្តារម្មណោ** ( មានវិភត្ត: គឺ និព្វានជាអារម្មណ៍ ) យ៉ាងនេះថា **វិភត្តោ** វិភត្ត: ( មគ្គ ) ។ ក្នុងបទទាំងនោះ បទថា **វិភត្តារម្មណោ** គឺ មាននិព្វានជាអារម្មណ៍ ។ បទថា **វិភត្តគោចរោ** មានវិភត្ត:ជាគោចរ គឺ មាននិព្វានជាវិស័យ ។ បទថា **វិភត្តេ សមុបាគតោ** ចូលមកប្រជុំក្នុងវិភត្ត: គឺ កើតព្រមគ្នាក្នុងនិព្វាន ។ បទថា **វិភត្តេ ឋិតោ** តាំងនៅក្នុងវិភត្ត: គឺ តាំងនៅក្នុងនិព្វាន ដោយអំណាចនៃការប្រព្រឹត្តទៅ ។ បទថា **វិភត្តេ បតិដ្ឋិតោ** ប្រតិស្ឋានក្នុងវិភត្ត: គឺ ប្រតិស្ឋានក្នុងនិព្វាន ដោយអំណាចនៃការមិនត្រឡប់ ។ បទថា **និព្វានញ្ច វិភត្តោ** និព្វានជាវិភត្ត: គឺ និព្វាន ឈ្មោះថា ជាវិភត្ត: ព្រោះមានវិភត្ត:ជាហេតុ ។ បទថា **និព្វានារម្មណតា ជាតា** ធម៌ទាំងពួងកើត ព្រោះសម្មាទិដ្ឋិមាននិព្វានជាអារម្មណ៍ គឺ ធម៌ទាំងពួងកើតក្នុងសម្មាទិដ្ឋិ មាននិព្វានជាអារម្មណ៍ ឬដោយសេចក្តីសម្មាទិដ្ឋិមាននិព្វានជាអារ្មណ៍ ។ ធម៌ទាំងឡាយ មានផស្ស:ជាដើម ទាំងពួងដែលសម្បយុត្តដោយមគ្គទាំងនោះ ឈ្មោះថា **វិភត្ត** ព្រោះអត្ថថា បន្ទោបង់សេចក្តីត្រេកត្រអាល ព្រោះហេតុនេះ ទើបឈ្មោះថា **វិភត្ត** បទថា **សហជាតានិ** ជាសហជាតិ គឺ អង្គនៃមគ្គ ៧ មានសម្មាសង្កប្ប:ជាដើមកើតរួមជាមួយ



សម្មាទិដ្ឋិ ។ បទថា **វិភត្តំ គច្ឆន្តីតិ វិភត្តោ មគ្គោ** អង្គ ៧ ដែលកើតរួមគ្នា រមែងដល់ភាពជាវិភត្ត: ព្រោះហេតុនោះ វិភត្ត:ទើបជាមគ្គ សេចក្តីថា អង្គ ៧ ដែលកើតរួមគ្នារមែងដល់វិភត្ត: ធ្វើនិព្វានឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបឈ្មោះថា **វិភត្ត** ព្រោះមានវិភត្ត: ( និព្វាន ) ជាអារម្មណ៍ ឈ្មោះថា **មគ្គ** ព្រោះអត្ថថា ស្វែងរក អង្គនៃមគ្គ សូម្បីអង្គមួយ ៗ រមែងបានឈ្មោះថា មគ្គ កាលលោកពោលដល់ការ:នៃអង្គមួយ ៗ ជាមគ្គ ជាការពោលដល់សម្មាទិដ្ឋិ ក៏ជាមគ្គដូចគ្នា ព្រោះដូច្នោះឯង លោកទើបកាន់យកអង្គនៃមគ្គ ៨ ទើបពោលថា **ឯតេន មគ្គេន** ដោយមគ្គនេះ ។ បទថា **ពុទ្ធា ច** ព្រះពុទ្ធជាម្ចាស់ទាំងឡាយ លោកសង្គ្រោះចូល សូម្បីព្រះបច្ចេកពុទ្ធទាំងឡាយផង ។ ពិតណាស់ សូម្បីព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងនោះ ក៏ឈ្មោះថា **ពុទ្ធ** ដូចគ្នា ព្រោះព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធជាម្ចាស់ ២ ទាំងនេះ គឺ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះបច្ចេកពុទ្ធជាម្ចាស់ ។ បទថា **អគតំ** មិនធ្លាប់ទៅ គឺ មិនធ្លាប់ទៅក្នុងសង្សារដែលមិនដឹងខាងដើម និងទីបំផុត ។ បទថា **ទិសំ** ឈ្មោះថា **ទិស** ព្រោះឃើញ អាងដល់ ជាប់ត ដោយការបដិបត្តិទាំងអស់ ។ ម្យ៉ាងទៀត ឈ្មោះថា **ទិស** ព្រោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់ឃើញ ទ្រង់អាងដល់ ទ្រង់ពោលថា **បរមំ សុខំ** ជាសុខយ៉ាងក្រៃលែង ។

ម្យ៉ាងទៀត **ទិស** ព្រោះហេតុឃើញ លះបង់ទុក្ខទាំងពួង និព្វានដែលជាទិសនោះ ។

បទថា **អដ្ឋង្គិកោ មគ្គោ** មគ្គមានអង្គ ៨លោកពោលទុកយ៉ាងណា ។ លោកពោលទុកថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ និងព្រះសាវកទាំងឡាយ រមែងដល់និព្វានដោយប្រជុំធម៌មានអង្គ ៨ នោះ ដោយហេតុនោះ ប្រជុំធម៌មានអង្គ ៨ នោះ ទើបឈ្មោះថា មគ្គ ព្រោះអត្ថថាជាគ្រឿងទៅ ។ បទថា **បុថុសមណព្រាហ្មណានំ បរប្បវាទានំ** សមណ-ព្រាហ្មណ៍ជាច្រើននាក់ អ្នកកាន់លទ្ធិដទៃ គឺ សមណៈ និងព្រាហ្មណ៍ផ្សេង ៗ កាន់លទ្ធិដទៃចាកសាសនានេះ ។ បទថា **មគ្គោ** កំពូល គឺ មគ្គមានអង្គ ៨ ប្រសើរជាងមគ្គដ៏សេសទាំងនោះ ។ បទថា **សេដ្ឋោ** ប្រសើរ គឺ គួរឲ្យសរសើរយ៉ាងក្រៃលែងជាងមគ្គដ៏សេស ។ បទថា **វិមោក្ខោ** ជាប្រធាន គឺ ល្អក្នុងភាពជាប្រធាន សេចក្ដីថា សេចក្ដីល្អនេះឯង ព្រោះជាប្រធានរបស់មគ្គដ៏សេស ។ បទថា **ឧត្តមោ** ខ្ពង់ខ្ពស់ គឺ ឆ្លងកាត់មគ្គដ៏សេសទៅបានយ៉ាងវិសេស ។ បទថា **បវរោ** ប្រសើរ គឺ បែកចេញពីមគ្គដ៏សេសដោយប្រការផ្សេង ៗ ។ បទថា **ឥតិ** ជានិបាតចុះក្នុងអត្ថថា ហេតុ ។ ព្រោះដូច្នោះអធិប្បាយថា ព្រះមានព្រះ-ភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងថា **អដ្ឋង្គិកមគ្គ** ប្រសើរជាងមគ្គទាំងឡាយ សមដូចព្រះអង្គទ្រង់ត្រាស់ទុកថា ៈ-



> អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយ បទទាំង ៤
> ប្រសើរជាងសច្ចៈទាំងឡាយ វិរាគៈប្រសើរជាងធម៌
> ទាំងឡាយ ព្រះមានព្រះភាគជាម្ចាស់ប្រសើរជាងសត្វ
> ជើង ២ ទាំងឡាយ ។

ក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់មគ្គនោះ ហើយត្រាស់ថា អដ្ឋង្គិកមគ្គប្រសើរជាងមគ្គទាំងឡាយដូច្នេះ ។ សូម្បីក្នុងវារៈដ៏សេស គប្បីជ្រាបសេចក្ដីដោយន័យនេះ និងដោយន័យដូចពោលហើយក្នុងខាងក្រោយ ។

វិភគៈដែលបានដល់ ការឃើញក្នុងបទជាដើមថា **ទស្សនវិភគោ** ឈ្មោះថា **វិភគ** ព្រោះការឃើញ ។ គប្បីជ្រាបថា លោកពោលដល់ពលៈមុនឥន្ទ្រិយក្នុងទីនេះ ព្រោះពលៈប្រសើរជាងអត្ថនៃភាពជាឥន្ទ្រិយ ។ បទមានពាក្យជាដើមថា **អាធិបតេយ្យដ្ឋេន ឥន្ទ្រិយានិ** ជាឥន្ទ្រិយ ព្រោះអត្ថថាជាធំ ជាការសម្ដែងអត្ថរបស់ឥន្ទ្រិយជាដើម មិនមែនសម្ដែងអត្ថរបស់វិភគៈ ។ បទថា **តតដ្ឋេន សច្ចា** ជាសច្ចៈ ព្រោះអត្ថថាជារបស់ពិត គប្បីជ្រាបថា ជាសច្ចញាណ ។ បទថា **សីលវិសុទ្ធិ** សេចក្ដី បរិសុទ្ធិនៃសីល គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ។ បទថា **ចិត្តវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃចិត្ត គឺ សម្មាសមាធិ ។ បទថា **ទិដ្ឋិវិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃទិដ្ឋិ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ ។ បទ

ថា **វិជ្ជាវិមុត្តដ្ឋេន** ព្រោះអត្ថថា រួចផុតពិសេស គឺ ព្រោះអត្ថថា រួចចាក កិលេសដែលទម្លាយដោយមគ្គនោះ ៗ ។ បទថា **វិជ្ជា** ការដឹងច្បាស់ គឺ សម្មាទិដ្ឋិ ។ បទថា **វិមុត្តិ** ការរួចផុតពិសេស គឺ សមុច្ឆេទវិមុត្តិ ។ បទថា **អមតោគធំ និព្វានំ បរិយោសានដ្ឋេន មគ្គោ** និព្វានដែលធ្លាក់ចុះ ក្នុងអមតៈជាមគ្គ ព្រោះអត្ថថា ជាទីបំផុត ឈ្មោះថា **មគ្គ** ព្រោះស្វែងរក ដោយការពិចារណាមគ្គផល ។ ធម៌ដែលលោកពោលក្នុងវិភគនិទ្ទេសនេះ សូម្បីទាំងអស់ក៏ក្នុងខណៈនៃមគ្គនោះឯង ក្នុងវិមុត្តិនិទ្ទេសក្នុងខណៈនៃផល ព្រោះដូច្នេះ សូម្បីមនសិការដល់ឆន្ទៈ ក៏សម្បយុត្តដោយមគ្គផល ។ គប្បីជ្រាបអត្ថសូម្បីក្នុងវិមុត្តិនិទ្ទេស ដោយន័យដូចពោល ហើយក្នុងវិភគនិទ្ទេសនោះឯង ។ ម្យ៉ាងទៀត ផលក្នុងនិទ្ទេសនេះ ឈ្មោះថា **វិមុត្តិ** ព្រោះផុតដោយការស្ងប់ ។ និព្វានឈ្មោះថា **វិមុត្តិ** ព្រោះផុតដោយការនាំចេញទៅ ។ ពាក្យជាដើមថា **សហជាតានិ សត្តដ្ឋានិ** អដ្ឋ ៧ ជាសហជាតិ រមែងមិនបានក្នុងទីនេះ ព្រោះហេតុនេះលោក ទើបមិនបានពោលទុក ព្រោះការរួចផុតជាផលដោយខ្លួនឯង លោកទើបពោលត្រឹមតែប៉ុណ្ណេះថា **បរិច្ចាគដ្ឋេន វិមុត្តិ** ឈ្មោះថា **វិមុត្តិ** ព្រោះអត្ថថា **លះ** បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

(ចប់អដ្ឋកថាវិភគកថា)



# ៦-បដិសម្ភិទាមគ្គកថា

## អដ្ឋកថា ធម្មចក្កប្បវត្តនវារៈ

ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តីដែលនៅមិនទាន់ពណ៌នាមកពីមុននៃបដិសម្ភិទាកថា ដែលមានធម្មចក្កប្បវត្តនសូត្រជាខាងដើម ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងដល់ប្រភេទនៃបដិសម្ភិទាមគ្គ សម្រេចដោយអំណាចនៃមគ្គ ដែលបានដល់ **វិភគ** ត្រាស់ទុកហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រដូចតទៅនេះ ។ បទថា **ពារាណសិយំ** គឺ មានស្ទឹងឈ្មោះថា **ពារាណសា** ។ ក្រុងពារាណសី ជានគរនៅមិនឆ្ងាយពីស្ទឹងពារាណសា ។ ជិតក្រុងពារាណសីនោះ ។ បទថា **ឥសិបតនេ មិគទាយេ** ព្រៃឥសិបតនមិគទាយវ័ន គឺ ឈ្មោះថា សួនមិគទាយវ័ន ព្រោះជាទីឲ្យអភ័យដល់ម្រឹគទាំងឡាយ ទើបបានឈ្មោះយ៉ាងនោះ និងដោយអំណាចនៃការចុះ និងការហោះឡើងនៃពួកឥសី ។ ព្រោះពួកឥសី មានសព្វញ្ញូកើតឡើងហើយ ៗ ក៏ចុះទៅក្នុងព្រៃឥសិបតនមិគទាយវ័ននោះ អធិប្បាយថា អង្គុយប្រជុំគ្នា ដើម្បីញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ សូម្បីពួកឥសីព្រះបច្ចេកពុទ្ធ ចេញពីនិរោធសមាបត្តិពេលកន្លងទៅ ៧ ថ្ងៃ ពីញកភ្នំនន្ទមូលកៈ លាងមុខនៅស្រះអនោត្ត-

ស្រះ ហោះមកតាមអាកាស ក៏ចុះទៅប្រជុំគ្នានៅទីនោះ ប្រជុំគ្នាដើម្បីជាសុខ ដើម្បីជាឧបោសថធំ និងដើម្បីឧបោសថតូច ពេលត្រឡប់ទៅកាន់ភ្នំគន្ធមាទន៍ ក៏ហោះទៅអំពីទីនោះ ព្រោះហេតុនោះ ដោយបទនេះ ទីនោះលោកទើបពោលថា **ឥសិបតន** ព្រោះជាទីចុះ និងហោះចុះឡើងរបស់ឥសី ។ បាលីថា **ឥសិបតនំ** ដូច្នេះខ្លះ ។

បទថា **បញ្ចវគ្គិយេ** ភិក្ខុបញ្ចវគ្គីយ៍ ( មានពួក ៥ ) គឺ ពួករបស់ភិក្ខុ ៥ ដូចដែលពោលទុកយ៉ាងនេះថា ៖

**ព្រះមហាថេរៈ ៥ ទាំងនេះ គឺ ព្រះកោណ្ឌញ្ញៈ ១**

**ព្រះភទ្ទិយៈ ១ ព្រះវប្បៈ ១ ព្រះមហានាម ១**

**ព្រះអស្សជិ ១ ដែលហៅថា ភិក្ខុមានពួក ៥ ។**

ឈ្មោះថា **បញ្ចវគ្គ** ឈ្មោះថា **បញ្ចវគ្គីយ៍** ព្រោះរាប់បញ្ចូលក្នុងពួក ៥ នោះ ។ បទថា **ភិក្ខូ អាមន្តេសិ** ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ សេចក្ដីថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់បំពេញបារមីខាងដើមចាប់ផ្ដើមតាំងអំពីសន្សំអភិនីហារទៀបបាទមូល របស់ព្រះទសពលជាម្ចាស់ព្រះនាមថា **ទីបង្ករ** រហូតសម្រេចភពចុងក្រោយដោយលំដាប់ ក្នុងភពចុងក្រោយ ស្ដេចយាងចេញសាងមហាភិនេស្រ្កមណ៍ ទ្រង់ដល់ពោធិមណ្ឌលដោយលំដាប់ ប្រថាប់លើអបរាជិតបល្ល័ង្ក ក្រោមពោធិមណ្ឌល



នោះ ទ្រង់កម្ចាត់មារ និងពលមារ ទ្រង់រឭកដល់បុព្វេនិវាសញ្ញាណក្នុងបឋមយាម ក្នុងមជ្ឈិមយាម ទ្រង់ញុំាងទិព្វចក្ខុឲ្យបរិសុទ្ធ , ក្នុងទីបំផុតនៃបច្ឆិមយាម ទ្រង់ញុំាងម៉ឺនលោកធាតុឲ្យភ្លឺស្វាង ឲ្យញាប់ញ័រ ទ្រង់បានសម្រេចសព្វញ្ញុតញ្ញាណកន្លងទៅ ៧ សប្តាហ៍ ត្រង់ពោធិមណ្ឌល មហាព្រហ្មចូលអារាធនាឲ្យទ្រង់សម្ដែងធម៌ ទ្រង់ប្រមើលមើលសត្វលោកដោយទិព្វចក្ខុ ស្ដេចយាងទៅកាន់ក្រុងពារាណសី ដើម្បីទ្រង់អនុគ្រោះសត្វលោក ទ្រង់មានព្រះបំណងនឹងឲ្យភិក្ខុបញ្ចវគ្គីយ៍ ព្រមទទួលហើយទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ទើបទ្រង់ត្រាស់ហៅ ។

បទថា **ទ្វេ មេ ភិក្ខវេ អន្តា** ម្នាលភិក្ខុទាំងឡាយ ចំណែកនៃទីបំផុត ២ យ៉ាងនេះ ព្រះសូរសៀងដែលបន្លឺចេញដោយទ្រង់បន្លឺព្រះតម្រាស់នេះ ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវីចិ ហើយផ្សាយទៅរហូតម៉ឺនលោកធាតុក្នុងសម័យនោះ ព្រហ្ម ១៨ កោដិមកប្រជុំគ្នា ព្រះអាទិត្យអស្តង្គត ព្រះចន្ទ័ពេញវង់ ប្រកបដោយអាសាឡ្ហនក្ខត្តក្សរះឡើងនៅទិសខាងកើត ក្នុងសម័យនោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ចាប់ផ្ដើមត្រាស់ សម្ដែងធម្មចក្កប្បវត្តនសូត្រ មានព្រះតម្រាស់ជាដើមថា **ទ្វេ មេ ភិក្ខវេ អន្តា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បព្វជិតេន** បព្វជិត គឺ អ្នកកាត់វត្ថុកាម

ដែលទាក់ទងដោយគ្រហស្ថចេញបួស ។ បទថា **ន សេវិតព្វា** មិនគួរសេព គឺ មិនគួរប្រើប្រាស់ ។ ព្រះមានព្រះភាគត្រាស់ថា **ន សេវិតព្វា** ដែលបព្វជិតគួរសេព ព្រោះការបដិបត្តិយ៉ាងពិសេសជាគ្រឿងទ្រទ្រង់របស់បព្វជិតទាំងឡាយ ។ បទថា **យោ ចាយំ កាមេសុ កាមសុខល្លិកានុ-យោគោ** ការប្រកបខ្លួនទុកក្នុងកាមសុខ ក្នុងកាមទាំងឡាយ គឺ ការប្រកបកាមសុខ គឺ កិលេសក្នុងវត្ថុកាម ឬការប្រកបអាស្រ័យកាមសុខ គឺ កិលេស ។ បទថា **ហីនោ** ជារបស់ថោកទាប គឺ លាមក ។ បទថា **គាម្មោ** គឺ របស់អ្នកស្រុក ។ បទថា **បោថុជ្ជនិកោ** ជារបស់បុថុជ្ជន គឺ បុថុជ្ជន បានដល់ អន្ធពាលបុថុជ្ជន ប្រព្រឹត្តរឿយ ៗ ។ បទថា **អនរិយោ** គឺ មិនមែនរបស់ព្រះអរិយជាម្ចាស់ ។ ម្យ៉ាងទៀត មិនមែនជារបស់សម្រាប់ព្រះអរិយជាម្ចាស់អ្នកបរិសុទ្ធិខ្ពង់ខ្ពស់ ។ បទថា **អន-ត្ថសញ្ហិតោ** មិនប្រកបដោយប្រយោជន៍ សេចក្ដីថា មិនអាស្រ័យហេតុដែលនាំសេចក្ដីសុខមកឲ្យ ។

បទថា **អត្តកិលមថានុយោគោ** ការធ្វើខ្លួនឲ្យលំបាក សេចក្ដីថា ធ្វើទុក្ខឲ្យដល់ខ្លួន ។ បទថា **ទុក្ខោ** គឺ នាំសេចក្ដីទុក្ខមកឲ្យ ដោយធ្វើខ្លួនឲ្យលំបាក មានដេកលើទីធ្វើដោយបន្លាជាដើម ។ ក្នុងបទនេះ លោកមិនពោលថា **ហីនោ** ដើម្បីរក្សាចិត្តរបស់អ្នកបំពេញតបៈទាំងនោះ ព្រោះ



អ្នកបំពេញតបៈទាំងនោះ ប្រកាន់ថា ជាតបៈដ៏ខ្ពង់ខ្ពស់ ។ មិនពោលថា **គាម្មោ** ព្រោះជាធម្មតារបស់បព្វជិតទាំងឡាយ មិនពោលថា **បោថុជ្ជ-និកោ** ព្រោះមិនទូទៅដល់គហស្ថទាំងឡាយ ។ ម្យ៉ាងទៀត ក្នុងបទថា **កាមសុខល្លិកានុយោគោ** នោះ លោកមិនពោលថា **ទុក្ខោ** ព្រោះពួកអ្នកប្ដេជ្ញាថា ជាបព្វជិតពួកណាមួយមានវាទៈថា និព្វានក្នុងបច្ចុប្បន្នប្រកាន់យកថា ព្រោះតួខ្លួននេះពេញប្រៀប ដល់ព្រមដោយការបម្រើកាមគុណ ៥ ដោយហេតុនេះ តួខ្លួននេះ ទើបជាការបានសម្រេចព្រះ-និព្វានក្នុងបច្ចុប្បន្ន ដើម្បីរក្សាចិត្តរបស់អ្នកបំពេញតបៈធម៌ទាំងនោះ និងព្រោះការសមាទានធម៌នោះ ជាសេចក្ដីសុខក្នុងបច្ចុប្បន្ន មិនគួរសេពកាម-សុខល្លិកានុយោគ ព្រោះជាសេចក្ដីសុខ សៅហ្មងដោយតណ្ហា និងទិដ្ឋិក្នុងបច្ចុប្បន្ន ព្រោះមានទុក្ខជាផលតទៅ និងព្រោះជាអ្នកខ្វល់ខ្វាយក្នុងកាមសុខល្លិកានុយោគនោះ ពាក់ព័ន្ធដោយតណ្ហា និងទិដ្ឋិ មិនគួរសេពអត្តកិលមថានុយោគ ព្រោះជាទុក្ខសៅហ្មង ដោយទិដ្ឋិក្នុងបច្ចុប្បន្ន ព្រោះមានទុក្ខជាផលតទៅ និងព្រោះជាអ្នកខ្វល់ខ្វាយក្នុងអត្តកិលមថានុយោគនោះពាក់ព័ន្ធដោយទិដ្ឋិ ។ បទថា **ឯតេ តេ** គឺ ទាំងនោះ ។ បទថា **អនុបគម្ម** មិនទាក់ទង គឺ មិនចូលទៅជិត ។ បទថា **មជ្ឈិមា** ផ្លូវកណ្ដាល ឈ្មោះថា **មជ្ឈិមា** ព្រោះជាផ្លូវកណ្ដាលមិនមានសុខ និងទុក្ខ

សៅហ្មង ឈ្មោះថា **បដិបទា** ព្រោះជាហេតុដល់និព្វាន ។ បទថា **អភិសម្ពុទ្ធា** ត្រាស់ដឹងហើយ គឺ ចាក់ធ្លុះហើយ ។

ក្នុងបទជាដើមថា **ចក្ខុករណី** ធ្វើចក្ខុ មានសេចក្ដីដូចតទៅនេះ ។ ឈ្មោះថា **ចក្ខុករណី** ព្រោះធ្វើបញ្ញាចក្ខុ ។ បទថា **ញាណករណី** ធ្វើញាណជាវេវចនៈរបស់បទថា **ចក្ខុករណី** នោះឯង ។ បទថា **ឧបសមាយ** ដើម្បីសេចក្ដីស្ងប់ គឺ ដើម្បីស្ងប់កិលេស ។ បទថា **អភិញ្ញាយ** ដើម្បីការដឹងដ៏ក្រៃលែង គឺ ដើម្បីប្រយោជន៍ដល់ការដឹងដ៏ក្រៃលែងនូវសច្ចៈ ៤ ។ បទថា **សម្ពោធាយ** ដើម្បីត្រាស់ដឹង គឺ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងសច្ចៈ ៤ ទាំងនោះ ។ បទថា **និព្វានាយ** ដើម្បីនិព្វាន គឺ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ។

ម្យ៉ាងទៀត ឈ្មោះថា **ចក្ខុករណី** ព្រោះធ្វើមគ្គញ្ញាណ គឺ ទស្សនៈ ។ ឈ្មោះថា **ញាណករណី** ព្រោះធ្វើមគ្គញ្ញាណ គឺ ភាវនា ដើម្បីស្ងប់កិលេសទាំងពួង ដើម្បីដឹងដ៏ក្រៃលែងនូវធម៌ទាំងពួង ដើម្បីត្រាស់ដឹងអរហត្តផល ដើម្បីរំលត់កិលេស និងខន្ធ ។ លោកពោលសច្ចៈកថាទុកក្នុងអភិញ្ញេយ្យនិទ្ទេសហើយ ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រកាសសច្ចៈយ៉ាងនេះហើយ បានស្ដាប់លំដាប់ការចាក់ធ្លុះរបស់ព្រះអង្គ របស់បញ្ចវគ្គីយ៍ទាំងនោះ



អ្នកនៅមានអតិមានៈក្នុងព្រះអង្គហើយ ទ្រង់ញ៉ាំងការបដិបត្តិឲ្យបរិសុទ្ធដោយការដកអតិមានៈ កាលទ្រង់ឃើញការចាក់ធ្លុះសច្ចៈ ទើបទ្រង់សម្ដែងលំដាប់នៃការចាក់ធ្លុះរបស់ព្រះអង្គ ដោយបទជាដើមថា **ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ តថាគតមិនធ្លាប់ស្ដាប់មកពីមុនថា នេះទុក្ខអរិយសច្ច គឺ ទ្រង់សម្ដែងលំដាប់បដិវេធរបស់ព្រះអង្គ ។

ក្នុងបទទាំងនោះ បទថា **អននុស្សុតេសុ** មិនធ្លាប់បានស្ដាប់សេចក្ដីថា មិនធ្លាប់ប្រព្រឹត្តទៅតាមអ្នកដទៃ ។ អត្ថនៃបទជាដើមថា **ចក្ខុំ** មានជាក់ច្បាស់ខាងមុខ ។ ការចាក់ធ្លុះ ការឃើញសច្ចៈ ៤ គឺ នេះទុក្ខអរិយសច្ចៈ ១ នេះទុក្ខសមុទយៈ ១ នេះទុក្ខនិរោធ ១ នេះទុក្ខនិរោធគាមិនីបដិបទា ១ រមែងប្រព្រឹត្តទៅក្នុងសេក្ខភូមិ ។ ការពិចារណាសច្ចៈ ៤ គឺ កំណត់ដឹងហើយ ១ , លះហើយ ១ , ធ្វើឲ្យជាក់ច្បាស់ហើយ ១ , ចម្រើនហើយ ១ , រមែងប្រព្រឹត្តទៅក្នុងអសេក្ខភូមិ ។

បទថា **តិបរិវដ្ដំ** មានការវិលជុំវិញ ៣ គឺ ព្រោះមានការវិល ៣ ជុំវិញដោយអំណាចនៃការវិលជុំវិញ ៣ គឺ **សច្ចញាណ** ( ញាណកំណត់ដឹងអរិយសច្ចៈ ) , **កិច្ចញាណ** ( ញាណកំណត់ដឹងកិច្ចដែល

គួរធ្វើ ) , **កតញ្ញាណ** ( ញាណកំណត់ដឹងកិច្ចដែលធ្វើហើយ ) ។ ក្នុងបទថា **តិបរិវដ្ដំ** នេះ ការដឹងតាមសភាពពិតក្នុងសច្ចៈ ៤ យ៉ាងនេះថា នេះទុក្ខអរិយសច្ចៈ នេះទុក្ខសមុទយអរិយសច្ចៈ នេះទុក្ខនិរោធអរិយសច្ចៈ នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ឈ្មោះថា **សច្ចញ្ញាណ** ។ ក្នុងសច្ចៈទាំងនេះ ញាណ គឺ ការដឹងកិច្ចដែលគួរធ្វើយ៉ាងនេះថា ទុក្ខគួរកំណត់ដឹង សមុទយៈគួរលះ និរោធគួរធ្វើឲ្យជាក់ច្បាស់ មគ្គគួរចម្រើន ឈ្មោះថា **កិច្ចញ្ញាណ** ។ ញាណ គឺ ការដឹងដល់ភាពដែលកិច្ចនោះបានធ្វើហើយយ៉ាងនេះថា ទុក្ខកំណត់ដឹងហើយ សមុទយៈលះបានហើយ និរោធធ្វើឲ្យ ជាក់ច្បាស់ហើយ មគ្គចម្រើនហើយ ឈ្មោះថា **កតញ្ញាណ** ។

បទថា **ទ្វាទសាការំ** មានអាការ ១២ គឺ មានអាការ ១២ ដោយអំណាចនៃអាការមួយ ៗ ៣ ក្នុងសច្ចៈនីមួយ ៗ នោះ ។ បទថា **ញាណទស្សនំ** គឺ ទស្សនៈ បានដល់ ញាណដែលកើតឡើងដោយអំណាចនៃសច្ចៈទាំងនោះ មានការវិលជុំវិញ ៣ មានអាការ ១២ ។ បទថា **អត្តមនា** រីករាយត្រេកអរ គឺ មានចិត្តជារបស់ខ្លួន ។ ពិតណាស់ អ្នកមានចិត្តប្រកបដោយបីតិសោមនស្ស ឈ្មោះថា មានចិត្តជារបស់ខ្លួន ។ ព្រោះសត្វទាំងឡាយប្រាថ្នាសេចក្ដីសុខ ស្អប់ទុក្ខ អធិប្បាយថា មានចិត្តជារបស់ខ្លួន មានចិត្តកាន់យកហើយ មានចិត្តឆ្អែតហើយ ដោយបីតិ



និងសោមនស្ស ។ បទថា **អភិនន្ទុំ** ពេញចិត្ត គឺ បែរមុខចូលទៅរកព្រះមានព្រះភាគជាម្ចាស់ហើយ ធ្វើការពេញចិត្ត ។ បទថា **វេយ្យាករណស្មឹ** វេយ្យាករណ៍ ភាសិត ព្រះសូត្រដែលមិនមានគាថា ឈ្មោះថា **វេយ្យាករណំ** ព្រោះធ្វើឲ្យជាក់ច្បាស់ក្នុងអត្ថតែម្យ៉ាង ។ បទថា **ភញ្ញមានេ** គឺ ត្រាស់ធ្វើឲ្យបច្ចុប្បន្នជិតបច្ចុប្បន្ន គឺ កំពុងត្រាស់ ។ បទថា **វិរជំ** ប្រាសចាកធូលី គឺ ប្រាសចាកធូលី មានរាគៈជាដើម ។ បទថា **វិតមលំ** ប្រាសចាកមន្ទិលមានរាគៈជាដើម ព្រោះរាគៈជាដើម ឈ្មោះថា ធូលី ព្រោះអត្ថថា គ្របសង្កត់ ឈ្មោះថា មន្ទិល ព្រោះអត្ថថា ប្រទូសរ៉ាយ ។ បទថា **ធម្មចក្ខុំ** ធម្មចក្ខុ ក្នុងកន្លែងខ្លះ បានដល់ ញាណក្នុងបឋមមគ្គ ក្នុងកន្លែងខ្លះ បានដល់ មគ្គញ្ញាណ ៣ ជាដើម ក្នុងកន្លែងខ្លះ បានដល់ មគ្គញ្ញាណទី ៤ តែក្នុងទីនេះ បានដល់ ញាណក្នុងបឋមមគ្គ ប៉ុណ្ណោះ ។

បទថា **យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** វត្ថុណាមួយមានការកើតឡើងជាធម្មតា វត្ថុនោះទាំងអស់សុទ្ធតែមានការរលត់ជាធម្មតា អធិប្បាយថា ធម្មចក្ខុកើតឡើងដល់ព្រះកោណ្ឌញ្ញៈ ប្រព្រឹត្តទៅហើយយ៉ាងនេះ ដោយអំណាចនៃវិបស្សនា ។ បទថា **ធម្មចក្កេ** បានដល់ បដិវេធញ្ញាណ និងទេសនាញ្ញាណ ។ ពិតណាស់ កាលព្រះមានព្រះភាគ

ជាម្ចាស់ទ្រង់ប្រថាប់នៅលើពោធិបល្ល័ង្ក សូម្បីបដិវេធញ្ញាណមានអាការ ១២ ប្រព្រឹត្តក្នុងសច្ចៈ ៤ កាលប្រថាប់ គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន សូម្បីទេសនាប្រព្រឹត្តទៅហើយ ដោយសច្ចទេសនា មានអាការ ១២ ឈ្មោះថា **ធម្មចក្ក** សូម្បីទាំងពីរយ៉ាងនោះ ក៏ជាញាណរបស់ព្រះទសពល ធម្មចក្កនោះ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងដោយទេសនានេះ ឈ្មោះថា ប្រព្រឹត្តទៅហើយ ព្រះភាគជាម្ចាស់ទ្រង់ប្រកាសធម្មចក្កនោះ រហូតដល់វេលាដែលព្រះអញ្ញាកោណ្ឌញ្ញត្ថេរមិនទាន់តាំងនៅក្នុងសោតាបត្តិផល ព្រមទាំងព្រហ្ម ១៨ កោដិ លុះពេលព្រះអញ្ញាកោណ្ឌញ្ញៈតាំងនៅហើយ ធម្មចក្ក ទើបឈ្មោះថា ប្រកាសហើយ ។ លោកសំដៅដល់រឿងនោះ ទើបពោលថា **បវត្តិតេ ច ភគវតា ធម្មចក្កេ** ពេលព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រកាសព្រះធម្មចក្កហើយ ។

បទថា **កុម្មា ទេវា** គឺ ទេវតាដែលនៅលើផែនដី ។ បទថា **សទ្ទមនុស្សាវេសុំ** ប្រកាសឲ្យលាន់ឮឡើង គឺ កុម្មទេវតាឲ្យសាធុការជាសំឡេងតែមួយដូចគ្នា ហើយប្រកាសលាន់ឮឡើងជាដើមថា **ឯតំ ភគវតា** ។ បទថា **អប្បដិវត្តិយំ** ដែលនរណាឲ្យប្រព្រឹត្តទៅមិនបាន គឺ មិនអាចជំទាស់បានថា នេះមិនជាយ៉ាងនោះ ។ ម្យ៉ាងទៀត ក្នុងបទនេះគប្បីជ្រាបថា ទេវតា និងព្រហ្មទាំងឡាយមកប្រជុំគ្នា ពេលចប់ទេសនា



បានឲ្យសាធុការ មានសំឡេងដូចគ្នា តែកុម្មទេវតាជាដើម មិនទាន់មកប្រជុំ លុះបានស្តាប់សំឡេងទេវតា និងព្រហ្មនោះ ៗ ទើបបានឲ្យសាធុការ ។ ក៏កុម្មទេវតាដែលនៅតាមភ្នំ និងដើមឈើជាដើមទាំងនោះ សូម្បីកុម្មទេវតាទាំងនោះ នឹងរាប់បញ្ចូលទៅក្នុងពួកទេវតាជាន់ចាតុម្មហារាជិកា លោកក៏ពោលផ្ញើឲ្យផ្សេងគ្នាក្នុងបទនេះ ។ បទថា **ចាតុម្មហារាជិកា** ព្រោះមានទេវតា មហារាជា ៤ បានដល់ ស្តេចធតរដ្ឋៈ វិរុឡ្ហកៈ វិរូបក្ខៈ និងកុវេរៈ ។ ទេវតាទាំងនោះ ស្ថិតនៅក្នុងកណ្តាលភ្នំសិនេរុ ទេវតាទាំងនោះ នៅលើភ្នំក៏មាន នៅលើអាកាសក៏មាន តអំពីទេវតាទាំងនោះទៅដល់ចក្រវាឡបរពិត ទេវតាសូម្បីទាំងអស់នេះ គឺ ខិឌ្ឌាបទោសិកា មនោបទោសិកា សីតវលាហកា ឧណ្ហវលាហកា ចន្ទិមទេវបុត្ត សុរិយទេវបុត្ត ក៏ជាទេវតាប្រតិស្ថាននៅក្នុងទេវលោកជាន់ចាតុម្មហារាជិកានោះឯង ។ ឈ្មោះថា **តាវត្តឹង្សា** ព្រោះមានជន ៣៣ នាក់ កើតក្នុងទេវលោកនោះ ។ ម្យ៉ាងទៀត លោកពោលថា ឈ្មោះថា **តាវត្តឹង្សា** ជាឈ្មោះរបស់ទេវតាទាំងនោះ សូម្បីទេវតាទាំងនោះ ប្រតិស្ថានលើភ្នំក៏មាន លើអាកាសក៏មាន ជាប់តគ្នាមកនៃទេវតាទាំងនោះដល់ចក្កវាឡបពិត ជាន់យាមាជាដើមក៏យ៉ាងនោះ ។ សូម្បីក្នុងទេវលោកមួយ ទេវតាទាំងឡាយសុទ្ធតែតជាប់គ្នារហូតដល់ចក្រវាឡបពិត ។

ឈ្មោះថា **យាមា** ព្រោះទៅ ដល់ព្រមនូវសុខដែលជាទិព្វ ។ ឈ្មោះថា **តុសិត** ព្រោះត្រេកអរ រីករាយ ។ ឈ្មោះថា **និម្មានរតី** ព្រោះនិម្មិត-សម្បត្តិតាមសេចក្តីពេញចិត្តក្នុងវេលាប្រាថ្នា និងត្រេកអរដោយចំណែកពិសេសពីទីតាក់តែងទុកតាមប្រក្រតី ។ ឈ្មោះថា **បរនិម្មិតវសវត្តី** ព្រោះពេលអ្នកដទៃដឹងវារៈចិត្ត ហើយនិម្មិតសម្បត្តិឲ្យ រមែងប្រព្រឹត្តទៅកាន់អំណាច ។ ឈ្មោះថា ព្រហ្មកាយិកា ព្រោះរាប់បញ្ចូលក្នុងព្រហ្មកាយ ។ សូម្បីព្រហ្មកាយិកាទាំងអស់ លោកសំដៅដល់ព្រហ្មដែលមានខន្ធ ៥ ផង ។

លោកពោលថា **តេន បុហុត្តេន** ដោយមួយស្របក់ លោកពោលឲ្យប្លែក នឹងពាក្យថា **តេន ខណេន** ដោយខណៈនោះ ដោយខណៈ ក៏បានដល់មួយស្របក់ លោកអធិប្បាយថា មិនមែនដោយខណៈផ្លូវបរមត្ថ ។ បទថា **យាវ ព្រហ្មលោកា** រហូតដល់ព្រហ្មលោក គឺធ្វើព្រហ្មលោកឲ្យមានទីបំផុត ។ បទថា **សទ្ទោ** គឺ សំឡេងសាធុការ ។ បទថា **ទសសហស្សី** គឺ មានម៉ឺនចក្រវាឡ ។ បទថា **សង្កម្បិ** ញាប់ញ័រ គឺ កក្រើកញាប់ញ័រឡើងទៅខាងលើដោយល្អ ។ បទថា **សម្បកម្បិ** ញាប់ញ័រដោយល្អ គឺ រំពើកញាប់ញ័រឡើងទៅខាងលើ ចុះមកក្រោមដោយល្អ ។ បទថា **សម្បវេធិ** ញាប់ញ័រ គឺ ញ័រទៅកាន់ទិសទាំង ៤



ដោយល្អ ។

កាលព្រះពោធិសត្វទ្រង់យាងចុះកាន់ព្រះគភ៌នៃព្រះមាតា ដើម្បីភាពជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងកាលប្រសូតិចាកព្រះគភ៌ព្រះមាតានោះ មហាប្រឹថពីបានញាប់ញ័រដោយតេជៈនៃបុណ្យ ក្នុងការត្រាស់ដឹងបានញាប់ញ័រដោយតេជៈនៃញាណ គឺ ការចាក់ធ្លុះ , ក្នុងគ្រាប្រកាសព្រះធម្មចក្ក ផែនដីបានញាប់ញ័រដូចឲ្យសាធុការ ដោយតេជៈនៃញាណ គឺ ទេសនា បានញាប់ញ័រដោយទេវានុភាព ក្នុងគ្រាទ្រង់ដាក់អាយុសង្ខារ និងក្នុងគ្រាមហាបរិនិព្វាន ផែនដីដូចអត់ទ្រាំការភ្ញាក់ផ្អើលមិនបាន ដោយសេចក្តីករុណា បានញាប់ញ័រ ដោយទេវានុភាព ។ បទថា **អប្បមាណោ** រកប្រមាណមិនបាន គឺ មានប្រមាណច្រើន ។ បទថា **ឧឡារោ** យ៉ាងក្រៃលែងនេះ លោកពោលថា **មធុរំ ឧឡារំ** មានរសផ្អែមយ៉ាងក្រៃលែង ក្នុងបទជាដើមថា **ឧឡារានិ ឧឡារានិ ខាទនីយានិ ខាទន្តិ** ទំពាររបស់ទំពារមានរសផ្អែមយ៉ាងក្រៃលែង ។ លោកពោលថា **បណីតំ ឧឡារំ** ប្រណីតយ៉ាងក្រៃលែង ក្នុងប្រយោគជាដើមថា **ឧឡារាយ វត្ថុ-ភោគាយ ចិត្តំ នមតិ** ចិត្តរមែងបង្អោនទៅក្នុងសំពត់ និងសម្បត្តិយ៉ាងក្រៃលែង ។ លោកពោលថា **សេដ្ឋំ ឧឡារំ** ប្រសើរយ៉ាងក្រៃលែងក្នុងប្រយោគជាដើមថា **ឧឡារាយ ខលុ ភវំ វច្ឆាយនោ សមណំ**

**គោតមំ បសំសាយ បសំសតិ** បានឮថា លោកវច្ឆាយនៈដ៏ចម្រើន សរសើរព្រះសមណគោតម ដោយការសរសើរយ៉ាងក្រៃលែង ។ តែក្នុងទីនេះ លោកពោលថា **វិបុលោ ឧឡារោ** ធំទូលាយយ៉ាងក្រៃលែង ។ បទថា **ឱភាសោ** ពន្លឺភ្លឺ គឺ ពន្លឺកើតដោយអានុភាពនៃទេសនាញាណ និងទេវានុភាព ។ បទថា **លោកេ** គឺ ក្នុងម៉ឺនចក្រវាឡនោះឯង ។

បទថា **អតិក្កម្មេវ ទេវានំ ទេវានុភាវំ** កន្លងនូវទេវានុភាពរបស់ទេវតាទាំងឡាយ គឺ អានុភាពរបស់ទេវតាទាំងឡាយប្រាកដ ដូច្នេះ រស្មីសំពត់ដែលស្លៀក ផ្សាយទៅ ១២ យោជន៍ អានុភាពរបស់សរីរៈ គ្រឿងប្រដាប់ និងវិមានក៏ដូចយ៉ាងនោះ ពន្លឺភ្លឺឈានកន្លងទេវានុភាពរបស់ទេវតាទាំងឡាយ ។ បទថា **ឧទានំ** ឧទាន គឺ ព្រះតម្រាស់ដែលបន្លឺចេញមកសម្រេចដោយសោមនស្សញ្ញាណ ។ បទថា **ឧទានេសិ** គឺ ទ្រង់ បន្លឺ ។ បទថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** កោណ្ឌញ្ញៈដ៏ចម្រើនបានត្រាស់ដឹងហើយហ្ន៎ ព្រះសូរសៀងដែលបន្លឺឧទាននេះ ផ្សាយទៅរហូតម៉ឺនលោកធាតុ ។ បទថា **អញ្ញាកោណ្ឌញ្ញោ** សេចក្តីថា កោណ្ឌញ្ញៈ ត្រាស់ដឹងហើយយ៉ាងប្រសើរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **ទស្សនដ្ឋេន** ព្រោះអត្ថថាឃើញ ក្នុងនិទ្ទេសនៃចក្ខុជាដើមដូចតទៅនេះ ។ ញាណមួយនោះឯង



ឈ្មោះថា **ចក្ខុ** ព្រោះធ្វើកិច្ចដោយការឃើញ ដូចចក្ខុរបស់សត្វដែលគប្បីណែនាំតាមដូចពោលហើយ ។ ឈ្មោះថា **ញាណ** ព្រោះធ្វើកិច្ចដោយញាណ ។ ឈ្មោះថា **បញ្ញា** ព្រោះធ្វើកិច្ចដឹង ដោយប្រការផ្សេង ៗ ។ ឈ្មោះថា **វិជ្ជា** ព្រោះធ្វើការចាក់ធ្លុះដោយមិនមានចំណែកសល់ ។ ឈ្មោះថា **អាលោកោ** ព្រោះធ្វើកិច្ចដោយពន្លឺ ក្នុងកាលទាំងពួង ។

សូម្បីក្នុងបទជាដើមថា **ចក្ខុំ ធម្មោ** ចក្ខុជាធម៌ មានសេចក្តីដូចតទៅនេះ ។ ញាណមួយនោះឯង លោកពណ៌នាទុកដោយ ៥ ចំណែក ដោយសេចក្តីផ្សេងគ្នានៃកិច្ច ។

បទថា **អារម្មណា** ដោយអត្ថថា ឧបត្ថម្ភ ។ បទថា **គោចរា** ដោយអត្ថថា ជាអារម្មណ៍ ។ ក្នុងបទជាដើមថា **ទស្សនដ្ឋេន** លោកពោលដល់ញាណកិច្ច ទុកដោយ ៥ ចំណែក ។

ដោយន័យនេះ គប្បីជ្រាបញាណ ៦០ គឺ ធម៌ ១៥ , អត្ថ ១៥ ធ្វើក្នុងវារៈមួយ ៗ ក្នុង ៣ វារៈ មួយ ៗ ៥ ជានិរុត្តិ ៣០ ក្នុង និរុត្តិ ៣០ បណ្ណរសកៈ ២ ក្នុងធម៌ ១៥ ក្នុងអត្ថ ១៥ ។ សូម្បីក្នុងអរិយសច្ចៈដ៏សេស ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបញាណ ២៤០ យ៉ាងនេះ គឺ ធម៌ ៦០ អត្ថ ៦០

ជានិរុត្តិ ១២០ ក្នុងធម៌ ៦០ ក្នុងអត្ថ ៦០ , ក្នុងនិរុត្តិ ១២០ ក្នុងធម៌ ៦០ ក្នុងអត្ថ ៦០ ដោយអំណាចនៃធម៌ និងអត្ថមួយ ៗ ១៥ ក្នុងអរិយសច្ចៈមួយ ៗ ក្នុងអរិយសច្ចៈ ៤ ។

(ចប់អដ្ឋកថា ធម្មចក្កប្បវត្តនវារៈ)

## អដ្ឋកថា សតិប្បដ្ឋានវារជាដើម

គប្បីជ្រាបអត្ថ និងការរាប់នៅក្នុងបដិសម្ភិទានិទ្ទេស ដែលមានសតិប្បដ្ឋានសូត្រជាខាងដើម និងមានឥទ្ធិបាទសូត្រជាខាងដើម ។



## អដ្ឋកថា សត្តពោធិសត្តវារជាដើម

ក្នុងសូត្រមួយ ៗ ក្នុងសូត្រ ៧ របស់ព្រះពោធិសត្វ ៧ មានធម៌ ១០ គឺ ក្នុងសមុទយៈ ៥ មានចក្ខុជាដើម ក្នុងនិរោធ ៥ មានអត្ថ ១០ ដោយក្នុងសមុទយៈ ៥ មានអត្ថថា ការឃើញជាដើម ។ ក្នុងនិរោធ ៥ មាននិរុត្តិ ២០ ដោយអំណាចនៃធម៌ និងអត្ថទាំងនោះ មានញាណ ៤០ ការរាប់ធ្វើវេយ្យាករណ៍ កាសិតរួមគ្នាពោលងាយយល់ដោយល្អ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបដិសម្ភិទានិទ្ទេស ដែលលោកពោលហើយដោយអំណាចនៃព្រះសព្វញ្ញុតញ្ញាណ ដូចតទៅនេះ ក្នុងមូលកៈមួយ ៗ មានធម៌ ២៥ ដោយអំណាចបញ្ចកៈមួយ ៗ ៥ គឺ ក្នុងពាក្យមួយ ៗ ក្នុង ៥ ពាក្យនេះ គឺ ឃើញដឹងហើយ ១ ឃើញហើយ ១ ដឹងច្បាស់ហើយ ១ ធ្វើឲ្យជាក់ច្បាស់ហើយ ១ ពាល់ត្រូវហើយ ១ ដោយបញ្ញាធម៌ ៥ មានចក្ខុជាដើម ធម៌ ៥ មានអត្ថថា ការឃើញជាដើម មានអត្ថ ២៥ ជានិរុត្តិ គុណនឹង ២ ( ៥០ ) ជាញាណគុណនឹង ២ ( ១០០ ) ធ្វើ ៥ យ៉ាងរួមគ្នា ហើយធ្វើជា ៥ ប្រាំដង សូម្បីក្នុងវារៈដែលពោលធ្វើ ៥

រួមគ្នាជា ២៥ ទើបជាធម៌ ១២៥ មានអត្ថ ១២៥ មាននិរុត្តិគុណនឹង ២ ( ២៥០ ) មានញាណគុណនឹង ២ ( ៥០០ ) ។

បទថា **អឌ្ឍតេយ្យានិ** គឺ មាននិរុត្តិ ២៥០ ។ សូម្បីខន្ធជាដើម ក៏មានន័យនេះដូចគ្នា ។

# អដ្ឋកថា ឆតុទ្ទធម្មវារ

គប្បីជ្រាបវិនិច្ឆ័យក្នុងឆតុទ្ទធម្មវារៈដូចតទៅនេះ ។ បទថា **ទិយឌ្ឍសតំ** មានធម៌ ១៥០ គឺ ២៥ រូប ៦ ដង ជាធម៌ ១៥០ មាននិរុត្តិគុណនឹង ២ ( ៣០០ ) មានញាណគុណនឹង ២ ( ៦០០ ) ។ បទថា **បដិសម្ភិទាធិករណេ** គឺ ក្នុងគម្ពីរបដិសម្ភិទា ។ បទថា **អឌ្ឍនវធម្មសតានិ** នេះ គឺ មានធម៌ ៨៥០ យ៉ាងនេះ គឺ ក្នុងសច្ចៈ ៤ ដែលពោលហើយជាដំបូង ៦០ ក្នុងសតិប្បដ្ឋាន ៤ រូប ៦០ ក្នុងសម្មប្បធាន ៤ រូប ៦០ ក្នុងវេយ្យាករណភាសិតរបស់ព្រះពោធិសត្វ ៧ ក្នុងធម៌ ៥ មានតាំង



នៅក្នុងអភិញ្ញា ជាដើម ១២៥ ក្នុងធម៌ ៥ មានខន្ធជាដើម ១២៥ ក្នុងអរិយសច្ចៈ ៤ ទៀត ១០០ ក្នុងបដិសម្ភិទា ៤ រូប ១០០ ក្នុងពុទ្ធធម៌ ៦ រូប ១៥០ ។

សូម្បីអត្ថក៏ដូច្នោះដូចគ្នា មាននិរុត្តិ ១២០ ក្នុងឋានៈ ៣ មានសច្ចៈជាដើម មាននិរុត្តិ ១៤០ ក្នុងវេយ្យាករណភាសិត ៧ មាននិរុត្តិក្នុងអភិញ្ញាជាដើម និងក្នុងខន្ធជាដើម មួយ ៗ ១៥០ មាននិរុត្តិមួយ ៗ ២០០ ក្នុងអរិយសច្ចៈ ៤ និងក្នុងបដិសម្ភិទា មាននិរុត្តិ ៣០០ ក្នុងពុទ្ធធម៌រូប មាននិរុត្តិ ១.៧០០ មានញាណ ៣.៤០០ យ៉ាងនេះគឺ មានញាណមួយ ៗ ២០០ ក្នុងឋានៈ ៣ មានសច្ចៈជាដើម មានញាណ ២៨០ ក្នុងវេយ្យាករណភាសិត ៧ មានញាណមួយ ៗ ៥០០ ក្នុងអភិញ្ញាជាដើម និងក្នុងខន្ធជាដើម មានញាណមួយ ៗ ៤០០ ក្នុងបដិសម្ភិទា ៤ មានញាណ ៦០០ ក្នុងពុទ្ធធម៌ ។

(ចប់អដ្ឋកថា បដិសម្ភិទាកថា)

# ៧-ធម្មចក្កកថា

## *អដ្ឋកថា សច្ចវារៈ ៤*

នឹងពណ៌នាតាមលំដាប់សេចក្តីដែលមិនទាន់បានពណ៌នាទុក នៃ **ធម្មចក្កកថា** ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ធ្វើព្រះធម្មចក្កប្បវត្ត-នសូត្រឲ្យជាខាងដើមទៀត ទ្រង់ត្រាស់ហើយ ។

ក្នុងបទទាំងនោះ បទថា **ទុក្ខវត្ថុកា** ជាទីតាំងនៃទុក្ខ គឺ ព្រោះមានទុក្ខជាទីតាំង ដោយអំណាចនៃការត្រាស់ដឹងតែម្យ៉ាង ។ ព្រះសារី-បុត្តត្ថេរ ញ៉ាំងទុក្ខនោះឲ្យពិសេសថែមទៀត ទើបពោលពាក្យជាដើមថា **សច្ចវត្ថុកា** ជាទីតាំងនៃសច្ចៈ ។ ឈ្មោះថា **សច្ចារម្មណា** ព្រោះមានសច្ចៈជាអារម្មណ៍ ជាតួឧបត្ថម្ភ ។ ឈ្មោះថា **សច្ចគោចរា** ព្រោះមានសច្ចៈជាគោចរ ជាវិស័យ ។ បទថា **សច្ចសង្គហិតា** សង្គ្រោះចូលក្នុងសច្ចៈ គឺ សង្គ្រោះដោយមគ្គសច្ច ។ បទថា **សច្ចបរិយាបន្នា** រាប់ចូលក្នុងមគ្គសច្ចៈ ។ បទថា **សច្ចេ សមុទាគតា** ចូលមកប្រជុំក្នុងសច្ចៈ គឺ កើតរួមគ្នាក្នុងទុក្ខសច្ចៈ ដោយកំណត់ដឹងទុក្ខ ។ បទថា **ឋិតា បតិដ្ឋិតា** គឺ តាំងនៅក្នុងសច្ចៈ ប្រតិស្ឋាននៅក្នុងសច្ចៈនោះឯងដូចគ្នា ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ប្រាថ្នានឹងសម្តែងធម្មចក្ក ដែលព្រះ



មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងថា **បវត្តិតេ ច ភគវតា ធម្មចក្កេ** គ្រាព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកាសព្រះធម្មចក្កហើយដូច្នេះ ទើបពោលពាក្យជាដើមថា **ធម្មចក្កំ** ។ ក្នុងបទថា **ធម្មចក្កំ** នោះ ធម្មចក្កមាន ២ យ៉ាង គឺ បដិវេធធម្មចក្ក និងទេសនាធម្មចក្ក ។ បដិវេធធម្មចក្កនៅឯពោធិបល្ល័ង្ក , ទេសនាធម្មចក្ក នៅឯព្រៃឥសិបតនមិគទាយវ័ន ។

បទថា **ធម្មញ្ច បវត្តេតិ ចក្កញ្ច** ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ញ៉ាំងធម៌ និងចក្កឲ្យប្រព្រឹត្តទៅ លោកពោលដល់ **បដិវេធធម្មចក្ក** ។ បទថា **ចក្កញ្ច បវត្តេតិ ធម្មញ្ច** ទ្រង់ញ៉ាំងចក្ក និងធម៌ឲ្យប្រព្រឹត្តទៅ លោកពោលដល់ ទេសនាធម្មចក្ក ។ សេចក្តីនេះតើដូចម្តេច ក៏ព្រោះព្រះមានព្រះភាគជាម្ចាស់ ប្រថាប់នៅលើពោធិបល្ល័ង្ក ញ៉ាំងធម៌មានប្រភេទជាដើមថា ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ និងអង្គនៃមគ្គ ឲ្យប្រព្រឹត្តទៅក្នុងខណៈនៃមគ្គ ធម៌នោះឯង ឈ្មោះថា **ចក្ក** ព្រោះប្រព្រឹត្តទៅដើម្បីកម្ចាប់សត្រូវ គឺ កិលេស ដូចចក្កសម្រាប់ប្រហារ ។ ព្រះមាន-ព្រះភាគជាម្ចាស់ទ្រង់ញ៉ាំងចក្ក គឺ ធម៌ឲ្យប្រប្រឹត្តទៅ ឈ្មោះថា ទ្រង់ញ៉ាំងចក្កឲ្យប្រព្រឹត្តទៅ ដោយបទនោះ លោកពោលជាកម្មធារយសមាសថា **ចក្ក** គឺ **ធម៌** ។ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រថាប់ក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ញ៉ាំងចក្ក គឺ ទេសនា ឲ្យប្រព្រឹត្តទៅ ព្រោះ

ប្រព្រឹត្តទៅដើម្បីកម្ចាប់សត្រូវ គឺ កិលេស ក្នុងសន្តានវេនេយ្យសត្វ ក្នុងខណៈសម្តែងធម៌ ដូចជាចក្កសម្រាប់ប្រើប្រហារ និងញ៉ាំងធម្មចក្ក ដែលមានប្រភេទជាដើមថា ឥន្ទ្រិយ៍ ពលៈ ពោជ្ឈង្គៈ អង្គនៃមគ្គ ឲ្យប្រព្រឹត្តទៅក្នុងសន្តានរបស់វេនេយ្យសត្វ ។ ដោយបទនេះ លោកពោលដល់ទ្វន្ទសមាសថា ធម៌ផង ចក្កផង ឈ្មោះថា ធម៌ និងចក្ក ក៏ព្រោះការប្រព្រឹត្តទៅមាន ក៏ឈ្មោះថា នៅប្រព្រឹត្តទៅដូច្នោះ សូម្បីក្នុងទីទាំងពួងលោកពោលថា **បវត្តេតិ** ឲ្យប្រព្រឹត្តទៅ តែគប្បីជ្រាបថា លោកពោលថា **ចក្កំ** ព្រោះអត្ថថា ប្រព្រឹត្តទៅ ។

បទជាដើមថា **ធម្មេន បវត្តេន្តីតិ ធម្មចក្កំ** ឈ្មោះថា ធម្មចក្ក ព្រោះទ្រង់ឲ្យចក្កប្រព្រឹត្តទៅដោយធម៌ គប្បីជ្រាបថា លោកពោលសំដៅដល់ **ទេសនាធម្មចក្កំ** នោះឯង ។ ក្នុងបទទាំងនោះ បទថា **ធម្មេន បវត្តេតិ** លោកពោលថា ធម្មចក្ក ព្រោះចក្កប្រព្រឹត្តទៅហើយ ដោយធម៌តាមសភាវៈយ៉ាងណា ។ បទថា **ធម្មចរិយាយ បវត្តេតិ** លោកពោលថា **ធម្មចក្ក** ព្រោះចក្កប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ធម៌ ក្នុងសន្តានរបស់វេនេ-យ្យសត្វ ។ ដោយបទជាដើមថា **ធម្មេ ឋិតោ** តាំងនៅក្នុងធម៌ លោកពោលដល់សេចក្តីដែលព្រះមានព្រះភាគជាម្ចាស់ ជាអ្នកមានធម៌ ជាម្ចាស់នៃធម៌ ។ សមដូចដែលព្រះមហាកច្ចាយនៈពោលថា ម្នាលអាវុសោទាំងឡាយ ព្រះមាន



ព្រះភាគជាម្ចាស់ព្រះអង្គនោះ ទ្រង់ដឹង ទ្រង់ឃើញ ជាអ្នកមានព្រះចក្ខុ ជាអ្នកមានព្រះញាណ ជាអ្នកមានធម៌ ជាម្ចាស់នៃធម៌ ជាព្រហ្ម ជាអ្នកផ្សព្វផ្សាយ ជាអ្នកប្រកាស ជាអ្នកពន្រឹកសេចក្តី ជាអ្នកឲ្យអមតធម៌ ជាអ្នកម្ចាស់នៃធម៌ ជាព្រះតថាគត ព្រោះដូច្នោះ ដោយបទនោះ លោកទើបពោលថា **ធម្មចក្កំ** ព្រោះចក្កនៃធម៌ ។ បទថា **ឋិតោ** តាំងនៅហើយ គឺ តាំងនៅដោយភាពជាអារម្មណ៍ ។ បទថា **បតិដ្ឋិតោ** ប្រតិស្ឋានហើយ គឺ ប្រតិស្ឋានដោយការមិនញាប់ញ័រ ។ បទថា **វសិប្បត្តោ** ទ្រង់បានសម្រេចដល់ការជំនាញ គឺ ដល់ភាពមានឥស្សរភាព ។ បទថា **បារមិប្បត្តោ** ទ្រង់សម្រេចដល់ភាពខ្ពង់ខ្ពស់ គឺ បានសម្រេចទីបំផុត ។ បទថា **វេសារជ្ជប្បត្តោ** ទ្រង់បានសម្រេចដល់ភាពក្លៀវក្លា គឺ បានសម្រេចដល់ភាពជាអ្នកក្លៀវក្លា ។ ដោយបទជាដើមថា **ធម្មេ បតិដ្ឋាបេន្តោ** ទ្រង់ឲ្យមហាជនតាំងនៅក្នុងធម៌ ទ្រង់សម្ទឹងដល់សន្តានរបស់វេនេយ្យសត្វ ហើយពោលថា **ចក្កំ** ដើម្បីប្រយោជន៍ដល់ធម៌ ព្រោះព្រះអង្គជាម្ចាស់នៃធម៌ ដោយពាក្យដូចពោលហើយ ។ ដោយបទជាដើមថា **ធម្មំ សក្ករោន្តោ** ទ្រង់ធ្វើសក្ការៈបូជាធម៌ លោកពោលថា **ចក្កំ** ដើម្បីប្រយោជន៍ដល់ធម៌ ព្រោះបុគ្គលណាប្រព្រឹត្តធម៌ដោយសក្ការៈជាដើម បុគ្គលឈ្មោះថា ប្រព្រឹត្តដើម្បីធម៌ ។ បទថា **ធម្មំ គរុករោន្តោ**

ទ្រង់គោរពធម៌ គឺ ធ្វើសេចក្តីគោរពនោះ ដោយឲ្យកើតគារវៈក្នុងធម៌នោះ ។ បទថា **ធម្មំ មានេន្តោ** ទ្រង់រាប់អានធម៌ គឺ ទ្រង់រាប់អានធម៌ គឺ ទ្រង់ធ្វើធម៌ឲ្យជាទីស្រឡាញ់ ជាទីលើកសរសើរ ។ បទថា **ធម្មំ បូជេន្តោ** ទ្រង់បូជាធម៌ គឺ អាងដល់ធម៌នោះ ហើយធ្វើការបូជា ដោយបដិបត្តិបូជាក្នុងទេសនា ។ បទថា **ធម្មំ អបចាយមានោ** ទ្រង់ឱនលំទោនក្នុងធម៌ គឺ ធ្វើសេចក្តីប្រព្រឹត្តបន្ទាប ដោយការធ្វើសក្ការៈ និងគោរពធម៌នោះឯង ។ បទថា **ធម្មទ្ធជោ ធម្មកេតុំ** មានធម៌ជាទង់ មានធម៌ជាកំពូល សេចក្តីថា មានធម៌ជាទង់ និងមានធម៌ជាកំពូល ដោយការនាំធម៌ទុកក្នុងខាងមុខដូចទង់ និងលើកឡើងដូចជាកំពូល ហើយឲ្យប្រព្រឹត្តទៅ ។ បទថា **ធម្មាធិបតេយ្យោ** មានធម៌ជាធំ គឺ មកអំពីការមានធម៌ជាធំជាអ្នកមានធម៌ជាធំ ដោយការធ្វើកិរិយាទាំងពួង ដោយអំណាចនៃធម៌ គឺ ការតាំងការនោ ។

បទថា **តំ ខោ បន ធម្មចក្កំ អប្បដិវត្តិយំ** ដែលនរណា ៗ ញុំាងធម្មចក្កនោះឲ្យប្រព្រឹត្តទៅមិនបាន លោកពោលដល់ភាពជាធម៌ដែលមិនត្រូវកម្ចាត់ ព្រោះនរណា ៗ មិនអាចនឹងឲ្យត្រឡប់បាន ព្រោះដូច្នោះធម៌នោះ លោកទើបពោលថា **ចក្កំ** ព្រោះអត្ថថា ប្រព្រឹត្តទៅបាន ។

បទថា **សទ្ធិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតិ** សទ្ធិន្ទ្រីយ៍ជាធម៌



ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ សេចក្តីថា ញុំាងសទ្ធិន្ទ្រីយ៍ជាធម៌នោះឲ្យប្រព្រឹត្តទៅ ដោយញុំាងសទ្ធិន្ទ្រីយ៍សម្បយុត្តដោយមគ្គឲ្យកើតក្នុងសន្តានរបស់វេនេយ្យសត្វ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនោះដូចគ្នា ។ បទថា **សច្ចា** គឺ សច្ចញាណ វិបស្សនា វិជ្ជា និងមគ្គញ្ញាណ ។ បទថា **អនុប្បាទេ ញាណំ** ញាណក្នុងការមិនកើត គឺ ញាណក្នុងអរហត្តផលញុំាងញាណឲ្យប្រព្រឹត្តទៅក្នុងសន្តានវេនេយ្យសត្វ កាលធ្វើការចាក់ធ្លុះ គឺ និព្វាន ក៏ឈ្មោះថា ញុំាងញាណឲ្យប្រព្រឹត្តទៅ ។ ក្នុងសមុទយវារៈជាដើម លោកសម្តែងសង្ខេបបទដែលប្លែកថា **សមុទយវត្ថុកា និរោធវត្ថុកា មគ្គវត្ថុកា** មានសមុទយជាទីតាំង មាននិរោធជាទីតាំង មានមគ្គជាទីតាំង ។ បទជាដើម ដូចពោលហើយក្នុងវារៈនេះ គប្បីជ្រាបដោយន័យដូចពោលហើយនេះឯង ។

# អដ្ឋកថា សតិប្បដ្ឋានវារៈ

*សុម្បីវារៈ សតិប្បដ្ឋាន ឥទ្ធិបាទជាខាងដើម លោកក៏ពោលទុក ហើយដោយអំណាចនៃខណៈរបស់មគ្គ សុម្បីវារៈទាំងនោះ ក៏សម្តែងសង្ខេបបទដែលប្លែកក្នុងវារៈនោះ ៗ ដោយប្រការដូច្នេះ ។*

(ចប់ អដ្ឋកថាធម្មចក្កកថា)



# ៨–អដ្ឋកថា លោកុត្តរកថា

*ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តីដែលមិនធ្លាប់ពណ៌នានៃលោកុត្តរកថា ដែលព្រះសារីបុត្តត្ថេរពោលទុកក្នុងលំដាប់នៃធម្មចក្កកថា ដែលប្រព្រឹត្តទៅក្នុងលោកុត្តរធម៌ ។ សេចក្តីនៃបទលោកុត្តរកថានោះ និងមានជាក់ច្បាស់ក្នុងនិទ្ទេសវារៈ ។ ពោធិបក្ខយធម៌ ៣៧ ជាដើមថា **ចត្តារោ សតិប្បដ្ឋានា** សម្បយុត្តដោយមគ្គ និងផលតាមដែលប្រកបធម៌ទាំងនោះ ឈ្មោះថា **ពោធិបក្ខិយធម៌** ព្រោះប្រព្រឹត្តទៅក្នុងចំណែកនៃអរិយៈ ដែលបានឈ្មោះយ៉ាងនេះថា **ពោធិ** ព្រោះអត្ថថាត្រាស់ដឹង ។ បទថា **បក្ខេ ភវត្តា** ព្រោះប្រព្រឹត្តទៅក្នុងចំណែក គឺតាំងនៅក្នុងភាពជាឧបការៈ ។ ឈ្មោះថា **ឧបដ្ឋានំ** ព្រោះឈានចុះ គឺស្ទុះទៅក្នុងអារម្មណ៍ទាំងនោះហើយប្រាកដ សតិនោះឯងប្រាកដឈ្មោះថា សតិប្បដ្ឋាន ប្រភេទរបស់សតិប្បដ្ឋាននោះ ៤ យ៉ាង ប្រព្រឹត្តទៅដោយអំណាចការកាន់យកអាការមិនស្អាត មិនទៀង ជាទុក្ខ មិនមែនខ្លួន និងដោយអំណាចការញុាំងកិច្ចឲ្យសម្រេច ដោយការលះសេចក្តីស្អាត សុខ ការទៀង និងការសម្គាល់ថាជាតួខ្លួន ក្នុងកាយ វេទនា ចិត្ត និងធម៌ ព្រោះដូច្នោះ លោកទើបហៅថា សតិប្បដ្ឋាន ៤ ។*

ឈ្មោះថា **បធានំ** ព្រោះជាហេតុតាំងទុក ។ ការតាំងទុកដោយល្អ ឈ្មោះថា **សម្មប្បធាន** ។ ម្យ៉ាងទៀត ឈ្មោះថា **សម្មប្បធានំ** ព្រោះជាហេតុតាំងទុកប្រពៃ ឬការតាំងទុកដោយល្អនោះ ឈ្មោះថា **បធាន** ព្រោះប្រាសចាកការប្រព្រឹត្តខុស គឺ កិលេស ព្រោះនាំសេចក្តីប្រសើរមកឲ្យ ដោយអត្ថថា ឲ្យសម្រេចប្រយោជន៍សុខ ឬធ្វើភាពជាប្រធាន **សម្ម-ប្បធាន** នេះ ជាឈ្មោះនៃសេចក្តីព្យាយាម ។ សម្មប្បធាននោះ មាននាទីលះអកុសលដែលកើតហើយ មិនឲ្យអកុសលកើតឡើង ឲ្យសម្រេចកិច្ចក្នុងការកើតឡើងនៃកុសលដែលមិនទាន់កើត ឲ្យសម្រេចកិច្ចក្នុងការតាំងនៅនៃកុសលដែលកើតឡើងហើយ ព្រោះហេតុនោះ សម្មប្បធាន ទើបមាន ៤ យ៉ាងដោយប្រការដូច្នេះ លោកទើបពោលថា **សម្មប្បធាន ៤** ។

ឈ្មោះថា **ឥទ្ធិបាទ** ព្រោះការសម្រេច ដោយបរិយាយនេះថា សត្វទាំងឡាយជាអ្នកសម្បូណ៌ទៅដោយការសម្រេចនោះ ជាអ្នកចម្រើនដល់ថ្នាក់ឧក្រិដ្ឋ ឈ្មោះថា រមែងសម្រេច ព្រោះអត្ថថា សម្រេចដោយបរិយាយនៃសេចក្តីសម្រេច ជាធម៌ឲ្យដល់សេចក្តីសម្រេច ដោយអត្ថថាជាខាងដើម ដែលសម្បយុត្តចូលជាមួយគ្នានៃសេចក្តីសម្រេចនោះ និងព្រោះអត្ថថា ជាហេតុនៃចំណែកខាងដើមដែលជាផល ព្រោះដូច្នោះ លោកទើបពោលថា **ឥទ្ធិបាទ ៤** ។



ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាធំ ពោលគឺ គ្របសង្កត់ ព្រោះគ្របសង្កត់ការមិនមានសទ្ធា សេចក្តីខ្ជិលច្រអូស សេចក្តីប្រមាទ សេចក្តីរាយមាយ និងសេចក្តីវង្វេង ។ ឈ្មោះថា **ពល** ព្រោះអត្ថថា មិនញាប់ញ័រ ព្រោះមិនត្រូវការមិនមានសទ្ធាជាដើម ហើយគ្របសង្កត់ ។ សូម្បីឥន្ទ្រីយ៍ និងពលៈ ទាំងពីរយ៉ាងនោះ ក៏មាន ៥ យ៉ាង ដូចគ្នា គឺ សទ្ធា វីរិយ សតិ សមាធិ បញ្ញា ព្រោះដូច្នោះ លោកទើបពោលថា ឥន្ទ្រិយ ៥ ពល ៥ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយ ៧ មានសតិជាដើម ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃសត្វអ្នកត្រាស់ដឹង និងធម៌ទាំងឡាយ ៨ មានសម្មាទិដ្ឋិជាដើម ជាអង្គនៃមគ្គ ព្រោះអត្ថថា នាំចេញ ដោយហេតុនោះ លោកទើបពោលថា ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ។

**ពោធិបក្ខិយធម៌** ៣៧ ប្រការ ទាំងនេះ ពេលវិបស្សនាដែលជាលោកិយៈក្នុងចំណែកខាងដើមនៅប្រព្រឹត្តទៅ ឈ្មោះថា កាយានុបស្ស-នាសតិប្បដ្ឋាន ព្រោះកំណត់កាន់យកកាយដោយអាការ ១៤ យ៉ាង , ឈ្មោះថា វេទនានុបស្សនាសតិប្បដ្ឋាន ព្រោះកាន់យកវេទនាដោយអាការ ៩ យ៉ាង , ឈ្មោះថា ចិត្តានុបស្សនាសតិប្បដ្ឋាន ព្រោះការកាន់យកចិត្តដោយអាការ ១៦ យ៉ាង , ឈ្មោះថា ធម្មានុបស្សនាសតិប្បដ្ឋាន ព្រោះកំណត់កាន់យកធម៌ដោយអាការ ៥ យ៉ាង ដោយប្រការដូច្នេះ ។

ក្នុងកាលព្យាយាមដើម្បីឃើញអកុសល ដែលកើតឡើងហើយដល់អ្នកដទៃ ដែលមិនទាន់ធ្លាប់កើតក្នុងអត្តភាពនេះ ហើយមិនឲ្យអកុសលនោះកើត ដោយគិតថា យើងនឹងមិនបដិបត្តិដូចដែលអកុសលនោះកើតដល់អ្នកបដិបត្តិ អកុសលនោះ នឹងមិនកើតដល់យើង យ៉ាងនេះ , ជាសម្មប្បធានប្រការទី ១ ក្នុងការព្យាយាមដើម្បីឃើញអកុសលដែលកើតព្រោះការប្រព្រឹត្តរបស់ខ្លួន ហើយលះអកុសល ជាសម្មប្បធានប្រការទី ២ , ពេលព្យាយាមដើម្បីឲ្យកើតឈាន ឬវិបស្សនាដែលមិនធ្លាប់កើតក្នុងអត្តភាពនេះឲ្យកើតឡើង ជាសម្មប្បធានប្រការទី ៣ , ពេលព្យាយាមឲ្យវិបស្សនា ឬឈានកើតរឿយ ៗ ដោយប្រការដែលមិនឲ្យវិនាស ជាសម្មប្បធានប្រការទី ៤ ។

ក្នុងកាលធ្វើឆន្ទៈឲ្យជាធុរៈ ហើយឲ្យកុសលកើតឡើងជា **ឆន្ទិទ្ធិ-បាទ** ក្នុងកាលធ្វើវីរិយ ចិត្ត វិមំសា ឲ្យជាធុរៈ ហើយឲ្យកុសលកើតឡើងជា **វិមំសិទ្ធិបាទ** ក្នុងការវៀរចាកការនិយាយកុហក ជាសម្មាវាចា ក្នុងកាលវៀរចាកការងារខុស ចិញ្ចឹមជីវិតខុស ជាសម្មាអាជីវៈ ពោធិ-បក្ខិយធម៌ទាំងឡាយ រមែងបានក្នុងចិត្តផ្សេង ៗ យ៉ាងនេះ ដោយប្រការដូច្នេះ ។ តែក្នុងខណៈនៃមគ្គ ៤ រមែងបានក្នុងចិត្តរួមគ្នា ក្នុងខណៈនៃផល រមែងបានពោធិបក្ខយធម៌ដ៏សេស វៀរសម្មប្បធាន ៤ ។



មយ៉ាងទៀត ពេលលោកុត្តរធម៌ទាំងនោះ បានក្នុងចិត្តមួយដួងជាមួយគ្នាយ៉ាងនេះ សតិ មាននិព្វានជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ លោកពោលថា សតិប្បដ្ឋាន ៤ ដោយអំណាចការសម្រេចកិច្ច ក្នុងការលះសេចក្តីសម្គាល់ថាស្អាត ក្នុងកាយជាដើម វីរិយៈតែម្យ៉ាងប៉ុណ្ណោះ លោកពោលថា សម្មប្បធាន ៤ ដោយអំណាចសម្រេចកិច្ច មិនឲ្យអកុសលកើតឡើង លះអកុសលដែលកើតជាដើម ។ ក្នុងពោធិបក្ខិយធម៌ដ៏សេស មិនមានការដក និងការបន្ថែម ។

មយ៉ាងទៀត ក្នុងពោធិបក្ខិយធម៌ទាំងនោះ គប្បីជ្រាបគាថា ដូចតទៅនេះ ។ ធម៌ទាំងឡាយនោះ មាន ៦ ពួក ដូច្នេះ គឺ ៈ-

**ធម៌ទាំងឡាយ ៩ ប្រការ ជាធម៌មានដោយពួកមួយ**
**ធម៌ ១ ប្រការ មានដោយពួក ២ មយ៉ាងទៀត ធម៌មួយ**
**មានដោយពួក ៤ និងដោយពួក ៥ ដោយពួក ៨ និង**
**ដោយពួក ៩ ។**

បទថា **នវ ឯកវិធា** ធម៌ទាំងឡាយ ៩ ប្រការ មានដោយពួកមួយ គឺ ធម៌ ៩ ប្រការទាំងនេះ គឺ ឆន្ទៈ ១ ចិត្ត ១ បីតិ ១ បស្សទ្ធិ ១ ឧបេក្ខា១ សង្កប្បៈ ១ វាចា ១ កម្មន្តៈ ១ អាជីវៈ ១ មានដោយពួក ១ ប៉ុណ្ណោះ ដោយអំណាចឆន្ទិទ្ធិបាទជាដើម មិនរួមបញ្ចូលក្នុងចំណែក

ដទៃ ។ បទថា **ឯកោ ទ្វេធា** ធម៌ ១ ប្រការ មានពួក ២ គឺ សទ្ធា តាំងនៅដោយពួក ២ ដោយអំណាចនៃឥន្ទ្រិយ និងពលៈ ។ បទថា **អថ ចតុបញ្ចធា** ម្យ៉ាងទៀត ធម៌មួយ មានដោយពួក ៤ និងដោយពួក ៥ គឺ ធម៌ដទៃ ធម៌មួយមានដោយពួក ៤ធម៌ដទៃតាំងនៅដោយពួក ៥ ។

ក្នុងធម៌ទាំងនេះ សមាធិមួយ តាំងនៅដោយពួក ៤ គឺ ឥន្ទ្រីយ៍ ១ ពលៈ ១ ពោជ្ឈង្គៈ ១ អង្គមគ្គ ១ ។ បញ្ញាតាំងនៅដោយពួក ៥ ដោយពួកនៃធម៌ ៤ ទាំងនោះឯង ដោយមួយចំណែករបស់ឥទ្ធិបាទ ។ បទថា **អដ្ឋធា នវធា ចេវ** ដោយ ៨ និង ៩ ពួក គឺ ម្យ៉ាងមួយទៀត តាំងនៅដោយពួក ៨ ធម៌ប្រការមួយទៀតតាំងនៅពួក ៩ អធិប្បាយថា សតិតាំងនៅពួក ៨ គឺ សតិប្បដ្ឋាន ៤ ឥន្ទ្រីយ៍ ១ ពលៈ ១ ពោជ្ឈង្គៈ ១ អង្គមគ្គ ១ ។ វីរិយៈតាំងនៅពួក ៩ គឺ សម្មប្បធាន ៤ ឥទ្ធិបាទ ១ ឥន្ទ្រិយ ១ ពលៈ ១ ពោជ្ឈង្គៈ ១ អង្គមគ្គ ១ ដោយប្រការដូច្នេះ គប្បីជ្រាបសេចក្តីក្នុងគាថាតទៅនេះ ។

**ពោធិបក្ខយធម៌ទាំងឡាយនោះ ដែលមិនលាយគ្នាក៏មាន**
**១៤ ប៉ុណ្ណោះ ដោយពួក មាន ៧ ពួក ដោយប្រភេទមាន**
**៣៧ ពេលអរិយមគ្គកើតឡើង ពោធិបក្ខិយធម៌ទាំងនោះ**
**ក៏កើតឡើង ព្រមគ្នាទាំងអស់តែម្យ៉ាង ដោយការធ្វើកិច្ច**



**របស់ខ្លួន ៗ ឲ្យសម្រេច និងដោយដំណើរទៅតាមរូប**
**របស់ខ្លួន ។**

ព្រះសារីបុត្តត្ថេរ គ្រាសម្តែងពោធិបក្ខិយធម៌ ៣៧ ប្រការ សម្បយុត្តដោយមគ្គ និងផលយ៉ាងនេះហើយ ទើបសង្ខេបពោធិបក្ខិយ-ធម៌ទាំងនោះ ចុះក្នុងមគ្គ និងផលទៀត ហើយពោលថា អរិយមគ្គ ៤ និងសាមញ្ញផល ៤ ភាពជាសមថៈ ឈ្មោះថា **សាមញ្ញ** ។ សាម័ញ្ញនេះ ជាឈ្មោះនៃអរិយមគ្គ ៤ ផលនៃសាម័ញ្ញទាំងឡាយ ឈ្មោះថា **សាមញ្ញ-ផល** ។ ចំណែកនិព្វាន មិនលាយឡំគ្នាឡើយ ។ លោកុត្តរធម៌ទាំងឡាយ ៤៦ ដោយអំណាចនៃពោធិបក្ខិយធម៌ ៣៧ មគ្គ ៤ ផល ៤ និងនិព្វាន ១ ដោយពិស្តារ បន្ទាប់អំពីនោះដោយសង្ខេប លោកុត្តរធម៌ ៩ ដោយអំណាចនៃមគ្គ ៤ ផល ៤ និព្វាន ១ សូម្បីបន្ទាប់ពីនោះ ដោយសង្ខេប គប្បីជ្រាបថា លោកុត្តរធម៌ ៣ ដោយអំណាចមគ្គ ១ ផល ១ និព្វាន ១ ។ ម្យ៉ាងទៀត កាលពោលដល់សេចក្តីដែលមគ្គផល មានសតិប្បដ្ឋានជាដើមជាលោកុត្តរៈ ក៏ជាការដែលលោកពោលដល់សេចក្តីនៃផស្សៈជាដើម សម្បយុត្តដោយមគ្គផលនោះ ក៏ជាលោកុត្តរៈដូចគ្នា ។ លោកពោលដល់សតិប្បដ្ឋានជាដើម ដោយមានធម៌ជាប្រធាន ។ ម្យ៉ាងទៀត ក្នុងលោកុត្តរធម៌និទ្ទេសក្នុងអភិធម្ម លោកពោលដល់ផស្សៈជាដើម ដែល

សម្បយុត្តដោយមគ្គ និងផល ជាលោកុត្តរធម៌ ។

បទថា **លោកំ តរន្តិ** ឆ្លងផុតលោក គឺ ឈានកន្លងលោក ។ ក្នុងបទនេះ ពាក្យជាបច្ចុប្បន្នកាលដូច្នេះទាំងអស់ លោកសំដៅដល់អរិយមគ្គ ៤ ព្រោះសោតាបត្តិមគ្គ ឆ្លងកាត់អបាយលោកបាន សកទាគាមិមគ្គ ឆ្លងកាមាវចរលោកជាឯកទេសបាន អនាគាមិមគ្គ ឆ្លងកាមាវចរលោកបាន អរហត្តមគ្គ ឆ្លងរូបាវចរលោក និងអរូបាវចរលោកបាន ។ បទថា **លោកា ឧត្តរន្តិ** ឆ្លងចាកលោក គឺ ចេញចាកលោក ។ បទថា **លោកតោតិ ច លោកម្ហាតិ ច** ពាក្យថា ចាកលោក និងអំពីលោក គឺ លោកសម្តែងដល់សេចក្តីពិសេសរបស់បញ្ចមីវិភត្តិ ។ បទថា **លោកំ សមតិក្កមន្តិ** កន្លងផុតលោក មានសេចក្តីដូចបានពោលទុកហើយគ្រាដំបូង ។ ក្នុងបទនោះ លោកពោលមិនសម្លឹងដល់សេចក្តីនៃឧបសគ្គ ។ ក្នុងបទនេះ លោកពោលព្រមដោយសេចក្តីរបស់ឧបសគ្គ ។ បទថា **លោកំ សមតិក្កន្តា** កន្លងផុតលោកហើយ គឺ ឈានកន្លងលោក តាមដែលពោលហើយដោយល្អ ។ ពាក្យដែលជាអតីតកាល ដូច្នេះទាំងអស់ ក្នុងបទនេះ លោកពោលសំដៅដល់និព្វានជាផល ។ ព្រោះសោតាបត្តិផលជាដើម ឈានកន្លងលោកតាមដែលពោលហើយ និព្វាន ឈានកន្លងលោកទាំងអស់គ្រប់ពេល ។ បទថា **លោកេន អតិរេកា** គឺ



ក្រៃលែងជាងលោក ។ បទនេះ លោកពោលសំដៅដល់លោកុត្តរធម៌សូម្បីទាំងអស់ ។ បទថា **និស្សរន្តិ** គឺ ប្រាសទៅ ។ បទថា **និទ្ទស្សដ្ឋា** គឺ ចេញទៅ ។ ពាក្យ ១៨ មានជាដើមថា **លោកេ ន តិដ្ឋតិ** មិនតាំងនៅក្នុងលោក រមែងគួរ សូម្បីក្នុងលោកុត្តរធម៌ទាំអស់ ។ បទថា **ន តិដ្ឋន្តិ** លោកពោលព្រោះមិនរាប់ជាប់នៅក្នុងលោក ។ បទថា **លោកេ ន លិម្បន្តិ** មិនជាប់ក្នុងលោក គឺ សូម្បីប្រព្រឹត្តទៅក្នុងសន្តានក៏មិនជាប់ក្នុងលោកនោះ ។ បទថា **លោកេន ន លិម្បន្តិ** មិនជាប់ដោយលោក សេចក្តីថា មិនជាប់ដោយចិត្តណា ៗ របស់អ្នកនៅមិនទាន់ចាក់ធ្លុះ ដោយចិត្តជាអកុសល និងមិនអាចរបស់អ្នកចាក់ធ្លុះហើយ ។ បទថា **អសំលិត្តា អនុបលិត្តា** មិនជាប់ មិនលាប គប្បីជ្រាបដោយឧបសគ្គ ។ បទថា **វិប្បមុត្តា** រួចផុតហើយ គឺ ការមិនជាប់នៅនោះឯងប្លែកត្រង់ព្យញ្ជនៈផ្សេងគ្នា ព្រោះអ្នកណាមិនជាប់ក្នុងវត្ថុណា ដោយវត្ថុណា អ្នកនោះជាអ្នករួចផុតក្នុងវត្ថុនោះ ដោយវត្ថុនោះ ។ ៣ បទជាដើមថា **លោកា វិប្បមុត្តា** រួចផុតចាកលោក លោកពោលជាបញ្ចមីវិភត្តិ ។ បទថា **វិសញ្ញុត្តា** មិនប្រកបជាមួយភាពខ្ពង់ខ្ពស់នៃការផុតទៅ ព្រោះអ្នកណារួចផុតក្នុងវត្ថុណា ដោយវត្ថុណា ចាកវត្ថុណា អ្នកនោះមិនជាប់ជំពាក់ក្នុងវត្ថុនោះ ដោយវត្ថុនោះ ចាកវត្ថុនោះ ។ បទថា **លោក វិសុជ្ឈន្តិ**

ស្អាត ប្លែកគ្នាត្រង់ឧបសគ្គ ។ បទថា **វុដ្ឋហន្តិ** ចេញ គឺ ភ្ញាក់ឡើង ។ បទថា **វិវដ្ដន្តិ** គឺមិនត្រឡប់ ។ បទថា **ន សជ្ជន្តិ** មិនជាប់ គឺ មិនប្រកប ។ បទថា **ន គយ្ហន្តិ** មិនប្រកាន់ គឺ មិនចាប់កាន់ ។ បទថា **ន ពជ្ឈន្តិ** មិនពាក់ព័ន្ធ គឺ មិនជំពាក់ ។ បទថា **សមុច្ឆិន្ទន្តិ** កម្ចាត់ គឺ ធ្វើមិនឲ្យប្រព្រឹត្តទៅបាន ។ លោកពោលដល់ពាក្យជាដើមថា ព្រោះមិនបរិសុទ្ធចាកលោក ដូចបទថា **លោកំ សមុច្ឆិន្ទត្តា** ព្រោះកាត់ផ្ដាច់ពីលោក ។ បទថា **បដិប្បស្សម្ភេន្តិ** ធ្វើលោកឲ្យរម្ងាប់ហើយ គឺ ឲ្យលោករលត់ ។ ៤ បទ មានជាអាទិ៍ថា បទថា **អបច្ចគា** រមែងគួរក្នុងលោកុត្តរៈសូម្បីទាំងពួង ។ បទថា **អបច្ចគា** មិនត្រឡប់មក គឺ មិនមានផ្លូវ ។ បទថា **អគតិ** មិនមានគតិ គឺ មិនជាទីពឹង ។

បទថា **អវិសយា** មិនជាវិស័យ គឺ ជាទីអាស្រ័យ ។ បទថា **អសាធារណា** មិនជាសាធារណៈ គឺ មិនទូទៅ ។ បទថា **វមន្តិ** គឺ ខ្ជាក់ចេញ ។ បទថា **ន បច្ចាគមន្តិ** មិនវិលមក លោកពោលដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ សេចក្ដីថា មិនលេបរបស់ដែលខ្ជាក់ហើយម្ដងទៀត ដោយបទនេះ លោកពោលដល់របស់ខ្ជាក់ចេញហើយ ។ សូម្បីក្នុងពួក ៣ នៃទុកៈក្នុងលំដាប់ ក៏មានន័យនេះដូចគ្នា ។

បទថា **វិសិនេន្តិ** មិនចង គឺ ខ្ចាត់ខ្ចាយទៅ រួចផុតទៅ សេចក្ដីថា



មិនចងទុក ។ បទថា **ន ឧស្សិនេន្តិ** ចង គឺ មិនខ្ចាត់ខ្ចាយ មិនរួចផុត ។ បទថា **វិសិនេន្តិ** បាឋៈធ្វើឲ្យសំឡេងខ្វីថា **ន ឧស្សិនេន្តិ** ល្អជាង ។ បទថា **វិធូបេន្តិ** កម្ចាត់ គឺ ឲ្យរលត់ ។ បទថា **ន សុធូបេន្តិ** មិនឱបក្រសោបលោក គឺ មិនរុងរឿង ។ បទថា **លោកំ សមតិកម្ម អភិកុយ្យ តិដ្ឋន្តិ** កន្លងលោក គ្រប់សង្កត់លោកតាំងនៅ គឺ លោកុត្តរធម៌ សូម្បីទាំងអស់ ឈានកន្លង និងគ្របសង្កត់លោក ហើយតាំងនៅដោយល្អ ព្រោះហេតុនោះ ទើបឈ្មោះថា **លោកុត្តរ** លោកពោលដល់សភាពលោកុត្តរៈទាំងឡាយ ប្រសើរជាងលោក និងក្រៃលែងជាងលោក ដោយប្រការដូចពោលមកនេះ សូម្បីទាំងអស់ ។

(ចប់អដ្ឋកថាលោកុត្តរកថា)

# ៩-អដ្ឋកថា ពលកថា

ឥឡូវនេះនឹងពណ៌នាតាមលំដាប់ ដែលមិនធ្លាប់ពណ៌នានៃពលកថា ដែលមានព្រះសូត្រជាខាងដើម ជាលោកុត្តរកថា ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកក្នុងលំដាប់នៃលោកុត្តរកថា ។ ក្នុងពលកថានោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងពលៈ ៥ ដោយព្រះសូត្រអំពីខាងដើម ហើយទ្រង់មានព្រះបំណងនឹងត្រាស់សម្តែងពលៈ សូម្បីដទៃពីពលៈ ៥ នោះ ទើបត្រាស់ព្រះតម្រាស់ជាដើមថា **អបិច អដ្ឋសដ្ឋី ពលានិ**ម្យ៉ាងទៀត ពលៈ ៦៨ ប្រការ ដូច្នេះ ។ សូម្បីពលៈ ៦៨ ទាំងអស់ ក៏ឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ដោយការៈផ្តុយគ្នាជាមួយនឹងពលៈ ៥ នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **ហិរិពលំ** ហិរិពលៈដូចតទៅនេះ ឈ្មោះថា **ហិរិ** ព្រោះជាហេតុខ្មាស់ចំពោះបាប ។ បទនោះជាឈ្មោះរបស់សេចក្តីខ្មាស់ ។ ឈ្មោះថា **ឱត្តប្ប** ព្រោះជាហេតុខ្លាចចំពោះបាប ។ បទនោះជាឈ្មោះរបស់សេចក្តីតក់ស្លុត ។ ហិរិមានវត្ថុខាងក្នុងជាសមុដ្ឋាន ឱត្តប្បៈមានវត្ថុខាងក្រៅជាសមុដ្ឋាន ។ ហិរិមានខ្លួនជាធំ ឱត្តប្បៈមានលោកជាធំ ។ ហិរិតាំងនៅក្នុងសភាពដែលខ្មាស់ ឱត្តប្បៈ



តាំងនៅក្នុងសភាពដែលខ្លាច ។ ហិរិមានសេចក្តីគោរពជាលក្ខណៈ ឱត្តប្បៈមានការឃើញភ័យ ពីការខ្លាចទោស ។ ឈ្មោះថា **ហិរិពល** ព្រោះហិរិនោះឯង រមែងមិនញាប់ញ័រដោយការមិនមានហិរិ ។ ឈ្មោះថា **ឱត្តប្បពល** ព្រោះឱត្តប្បៈនោះឯង រមែងមិនញាប់ញ័រ ដោយការមិនមានឱត្តប្បៈ ។ ឈ្មោះថា **បដិសង្ខានពល** ព្រោះមិនញាប់ញ័រដោយការពិចារណា ។ បទនេះ ជាឈ្មោះរបស់បញ្ញា ចូលទៅពិចារណាកំពុងកើតឡើងដល់ព្រះយោគាវចរអ្នកចម្រើនពោជ្ឈង្គៈ ៧ ដោយសេចក្តីព្យាយាមជាគោល ឈ្មោះថា **ភាវនាពល** ។ បទនេះជាឈ្មោះរបស់ខន្ធ ៤ ដែលប្រព្រឹត្តទៅយ៉ាងនោះ ។ សីលជាដើមដែលបរិសុទ្ធ ឈ្មោះថា **អនវជ្ជពល** ។ សង្គហវត្ថុ ៤ ឈ្មោះថា **សង្គាហពល** ។ បាឋៈថា **សង្គហេពលំ** កម្លាំងក្នុងការសង្គ្រោះខ្លះ ។ ការអត់ទ្រាំចំពោះទុក្ខ ឈ្មោះថា **ខន្តិពល** សេចក្តីត្រេកអរក្នុងធម្មកថារបស់អ្នកដទៃ ឈ្មោះថា **បញ្ញត្តិពល** ។ ការសម្លឹងដល់ប្រយោជន៍ដ៏ក្រៃលែង ឈ្មោះថា **និជ្ឈត្តិពល** ។

ភាពជាអ្នកច្រើនក្នុងកុសលទាំងឡាយ ឈ្មោះថា **ឥស្សរិយពល** ។ ការតម្កល់តាមសេចក្តីពេញចិត្តក្នុងកុសលទាំងឡាយ ឈ្មោះថា **អធិដ្ឋានពល** ។ ប្រយោជន៍របស់ហិរិពលៈជាដើម លោកពោលកាន់យកការ

ប្រកបដោយសេចក្តីពិសេស ដោយព្យញ្ជនៈក្នុងបទមាតិកាទាំងឡាយ ។

បទថា **សមថពលំ វិបស្សនាពលំ** គឺ សមថៈ និងវិបស្សនា ដែលមានកម្លាំងនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមាតិកានិទ្ទេស ដូចតទៅនេះ ។ បទថា **អស្សទ្ធិយេ ន កម្បតីតិ សទ្ធាពលំ** ឈ្មោះថា សទ្ធាពលៈ ព្រោះអត្ថថា មិនញាប់ញ័រក្នុងការមិនមានសទ្ធា ព្រះសារីបុត្តត្ថេរពោលដល់អត្ថ របស់ពលៈដែលជាមូល ហើយសម្តែងសទ្ធាពលៈនោះ ឲ្យពិសេស ដោយបរិយាយ ៩ ដទៃទៀត ។ ពិតណាស់ ធម៌ណាមិនញាប់ញ័រ ជាធម៌មានកម្លាំង ធម៌នោះរមែងឧបត្ថម្ភធម៌ដែលកើតរួមគ្នា ព្រះយោគាវចរ គ្របសង្កត់កិលេស ដែលបដិបក្ខរបស់ខ្លួនទុកបាន ជម្រះសីល និងទិដ្ឋិជាខាងដើមនៃការបាក់ធ្លុះបាន ញ៉ាំងចិត្តឲ្យតាំងមាំក្នុងអារម្មណ៍ ធ្វើចិត្តឲ្យផូរផង់ ដល់នូវភាពជំនាញ រមែងសម្រេចគុណវិសេស ពេលសម្រេចក្រៃលែងជាងនោះ រមែងធ្វើឲ្យការបាក់ធ្លុះក្រៃលែងឡើង គ្រាសម្រេចមគ្គតាមលំដាប់ហើយ រមែងធ្វើការសម្រេចសច្ចៈបាន រមែងឲ្យតាំងនៅក្នុងនិរោធដោយការសម្រេចផលបាន ព្រោះដូច្នោះ លោកទើបធ្វើអត្ថនៃពលៈឲ្យពិសេសដោយអាការ ៩ យ៉ាង ។ ក្នុងពលៈ ៤ មានវីរិយពលៈជាដើម ក៏មានន័យនេះ ។



បទថា **កាមច្ឆន្ទំ ហិរិយតិ** ខ្មាស់កាមច្ឆន្ទៈ គឺ ព្រះយោគាវចរ ប្រកបដោយនេក្ខម្មៈ ខ្មាស់កាមច្ឆន្ទៈដោយនេក្ខម្មៈ ។ សូម្បីឱត្តប្បៈ ក៏ន័យនេះដូចគ្នា ។ សូម្បីអកុសលទាំងពួងនេះ ក៏ជាចំណែកដែលលោកពោលដល់សេចក្តីខ្មាចផង ។ គប្បីជ្រាបអត្ថសូម្បីនៃបទថា **ព្យាបាទំ** ជាដើម ក៏ដោយន័យនេះឯង ។ បទថា **បដិសង្ខាតិ** រមែងពិចារណា គឺ ពិចារណាដោយភាពជាទោសដោយការមិនវង្វេង ។ បទថា **ភាវេតិ** គឺ រមែងចម្រើន ។ បទថា **វជ្ជំ** ទោស គឺ ទោសមានរាគៈជាដើម ។ បទថា **សង្គណ្ហាតិ** រមែងសង្គ្រោះ គឺ រមែងចង ។ បទថា **ខមតិ** រមែងអត់ធន់ គឺ ព្រះយោគាវចរនោះ រមែងអត់ធន់ រមែងពេញចិត្ត ។ បទថា **បញ្ញាបេតិ** រមែងតាំងទុក គឺ ពេញចិត្ត ។

បទថា **និជ្ឈាបេតិ** រមែងសម្លឹង គឺ រមែងគិត ។ បទថា **វសំ វត្តេតិ** ឲ្យប្រព្រឹត្តទៅក្នុងអំណាច គឺ ធ្វើចិត្តច្រើនក្នុងការគិតឲ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ។ បទថា **អធិដ្ឋាតិ** រមែងអធិដ្ឋាន គឺ រមែងចាត់ចែង ។ សូម្បីពលៈទាំងអស់ មានភាវនាពលៈជាដើម ក៏ជានេក្ខម្មៈជាដើមនោះឯង ។ ក្នុងអដ្ឋកថានៃមាតិកា លោកពោលទុកដោយប្រការដទៃ តែគប្បីជ្រាបថា លោកមិនពោលដល់អត្ថទុកក្នុងទីនេះ ព្រោះប្រាកដដោយព្យញ្ជនៈស្រាប់ហើយ ។ ព្រះសារីបុត្តត្ថេរ សម្តែងដល់

សមថពលៈ និងវិបស្សនាពលៈដោយពិស្តារ ក្នុងទីបំផុតពោលបទជាដើមថា **ឧទ្ធច្ចសហគតកិលេសេ ច ខន្ធេ ច ន កម្បតិ** ចិត្តមិនញាប់ញ័រក្នុងកិលេស ដែលសហគតដោយឧទ្ធច្ចៈ និងក្នុងខន្ធ និងបទជាដើមថា **អវិជ្ជាសហគតក្កិលេសេ ច ខន្ធេ ច ន កម្បតិ** ចិត្តមិនញាប់ញ័រក្នុងកិលេសដែលសហគតដោយអវិជ្ជា និងខន្ធ គប្បីឲ្យឃើញដល់លក្ខណៈ របស់សមថពលៈ និងវិបស្សនាពលៈ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសេក្ខពលៈ និងអសេក្ខពលៈ ដូចតទៅនេះ ។

បទថា **សម្មាទិដ្ឋឹ សិក្ខតីតិ សេក្ខពលំ** ឈ្មោះថា សេក្ខពលៈ ព្រោះព្រះសេក្ខៈត្រូវនៅសិក្សាសម្មាទិដ្ឋិ សេចក្តីថា ឈ្មោះថា ព្រះសេក្ខៈ ព្រោះព្រះសេក្ខៈបុគ្គល ត្រូវសិក្សានូវសម្មាទិដ្ឋិ ឈ្មោះថា សេក្ខពលៈ ព្រោះសម្មាទិដ្ឋិនោះឯង ជាកម្លាំងរបស់ព្រះសេក្ខៈនោះ ។ បទថា **តត្ថ សិក្ខិតត្តា អសេក្ខពលំ** ឈ្មោះថា អសេក្ខពលៈ ព្រោះព្រះអសេក្ខៈសិក្សាក្នុងសម្មាទិដ្ឋិជាដើមនោះ ស្រេចហើយ សេចក្តីថា ឈ្មោះថា ព្រះអសេក្ខៈ ព្រោះអសេក្ខបុគ្គលមិនត្រូវសិក្សា ព្រោះសម្មាទិដ្ឋិនោះព្រះអសេក្ខបុគ្គលសិក្សាហើយ ឈ្មោះថា **អសេក្ខពល** ព្រោះសម្មាទិដ្ឋិនោះឯង ជាកម្លាំងរបស់ព្រះអសេក្ខៈនោះ ។ ក្នុងសម្មាសង្កប្បៈជាដើម



ក៏ន័យនេះដូចគ្នា ។

បទថា **សម្មាញាណំ** សម្មាញាណ គឺ បច្ចវេក្ខណញ្ញាណ ( ញាណជាគ្រឿងពិចារណា ) ។ ពិតណាស់ សូម្បីញាណនោះ ជាលោកិយៈ ក៏ជាសេក្ខពលៈ ព្រោះសេក្ខៈនៅប្រព្រឹត្ត ។ លោកពោលថា អសេក្ខពលៈ ព្រោះព្រះអសេក្ខៈមិនត្រូវប្រព្រឹត្តទៀត ។ បទថា **សម្មា-វិមុត្តឹ** សម្មាវិមុត្តិ គឺ ធម៌សម្បយុត្តដោយផលដ៏សេស វៀរអង្គនៃមគ្គ ៨ តែអាចារ្យពួកខ្លះពោលថា វិមុត្តិដ៏សេស វៀរលោកុត្តរវិមុត្តិ ជាសម្មាវិមុត្តិ សេចក្តីថា សម្មាវិមុត្តិនោះ ជាសេក្ខពលៈ និងអសេក្ខពលៈ មានន័យដូចពោលហើយនោះឯង ។ ញាណពលៈ សូម្បីទាំងអស់មានក្នុងព្រះខីណាសវពលៈ ។ បទថា **ខីណាសវស្ស ភិក្ខុនោ** ដែលភិក្ខុខីណាស្រព ជាធម្មីវិកត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ជា **ខីណាសវេន ភិក្ខុនា** ។ បទថា **អនិច្ចតោ** ដោយភាពជាសភាវៈមិនទៀង គឺ ដោយភាពមិនទៀងដោយអាការមានហើយមិនមាន ។ បទថា **យថាភូតំ** គឺ តាមសេចក្តីពិត ។ បទថា **បញ្ញាយ** ដោយបញ្ញា គឺ ដោយមគ្គប្បញ្ញាជាមួយនឹងវិបស្សនា ភិក្ខុជាខីណាស្រពឃើញដោយល្អ ដោយភាពជាសភាវៈមិនទៀង ដោយភាពជាទុក្ខ ដោយមិនមែនខ្លួន ព្រោះមានបញ្ញានោះជាមូល ។ បទថា **យំ** ជាការវេនបុំសក ឬមានសេចក្តីថា ដោយ

ហេតុណា ។ បទថា **អាគម្ម** គឺ អាស្រ័យ ។ បទថា **បដិជានាតិ** ប្តេជ្ញា គឺ ទទួលធ្វើតាមប្តេជ្ញា ។ បទថា **អង្គារកាសូបមា** ប្រៀបដោយរណ្តៅរងើកភ្លើង គឺ ប្រៀបដោយរណ្តៅរងើកភ្លើង ដោយអត្ថថា គួរឲ្យខ្លាចណាស់ ។ បទថា **កាមា** គឺ វត្ថុកាម និងកិលេសកាម ។ បទថា **វិវេកនិន្នំ** បង្អោនទៅក្នុងវិវេក គឺ បង្អោនទៅក្នុងនិព្វាន ពោលគឺ ការស្ងាត់ចាកឧបធិដោយផលសមាបត្តិ ។ ពិតណាស់ វិវេកមាន ៣ គឺ **កាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក** ( ស្ងាត់ចាកកិលេស ១ ) ។

អ្នកមានកាយតាំងនៅក្នុងសេចក្តីស្ងាត់ ត្រេកអរក្នុងនេក្ខម្មៈ ឈ្មោះថា **កាយវិវេក** អ្នកខ្វល់ខ្វាយក្នុងអធិចិត្ត ឈ្មោះថា **ចិត្តវិវេក** ។ បុគ្គលអ្នកមិនមានឧបធិ ប្រាសចាកគ្រឿងតាក់តែង ឬបង្អោនទៅក្នុងនិព្វាន ពោលគឺ វិវេកដែលជាគ្រឿងនាំចេញទៅ ឈ្មោះថា **ឧបធិ-វិវេក** ។ សេចក្តីពិត **វិវេក** មាន ៥ យ៉ាង គឺ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិបស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ម្យ៉ាងទៀត បទថា **វិវេកនិន្នំ** គឺ បង្អោនទៅក្នុងវិវេក ។ បទថា **វិវេកបោណំ** គឺ ទោរទៅក្នុងវិវេក ។ បទថា **វិវេកបព្ភារំ** គឺ ឈមទៅក្នុងវិវេក ។ សូម្បីបទទាំងពីរ ក៏ជាវេវចនៈរបស់បទនោះឯង ។ បទថា **វិវេកដ្ឋំ** តាំងនៅក្នុងវិវេក គឺ វៀរចាកកិលេសទាំងឡាយ ឬ



ទៅឆ្ងាយ ។ បទថា **នេក្ខម្មាភិរតំ** ត្រេកអរក្នុងនេក្ខម្មៈ គឺ ត្រេកអរក្នុងនិព្វាន ឬត្រេកអរក្នុងបព្វជ្ជា ។ បទថា **ព្យន្តីភូតំ** អស់សូន្យទៅ គឺ ប្រាសចាកទៅ សូម្បីការសម្តែងមួយដងក៏មិនខុស ផុតទៅមិនអាស្រ័យនៅ គឺ ប្រាសចាកទៅ ។ បទថា **សព្វសោ** គឺ ដោយប្រការទាំងពួង ។ បទថា **អាសវដ្ឋានិយេហិ ធម្មេហិ** ចាកធម៌ដែលជាទីតាំងនៃអាសវៈ សេចក្តីថា ចាកកិលេសដែលជាហេតុរបស់អាសវៈទាំងឡាយ ដោយការអាស្រ័យ ។

ម្យ៉ាងទៀត បទថា **ព្យន្តីភូតំ** ការអស់សូន្យទៅ គឺ ប្រាសចាកសេចក្តីប្រាថ្នា អធិប្បាយថា អស់តណ្ហា ។ អំពីណា ចាកធម៌ដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង គឺ ពីធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងពួង ។ ក្នុងទីនេះ លោកពោលដល់លោកិយមគ្គ និងលោកុត្តរមគ្គរបស់ព្រះខីណាស្រព ដោយខីណាសវពលៈ ១០ អាចារ្យទាំងឡាយពោលថា **ពល** កំណត់ដឹងទុក្ខថា សង្ខារទាំងឡាយទាំងពួងមានសភាវៈមិនទៀង **ពល** លះសមុទយៈថា កាមទាំងឡាយប្រៀបដូចរណ្តៅរងើកភ្លើង **ពល** ធ្វើឲ្យជាក់ច្បាស់និរោធថា ចិត្តបង្អោនទៅក្នុងវិវេក **ពល** ក្នុងការចម្រើនមគ្គ ៧ យ៉ាង មានជាដើមថា សតិប្បដ្ឋាន ៤ ។ ឥន្ទ្រិយពលៈ ១០ យ៉ាង មានជាក់ច្បាស់ក្នុងឥទ្ធិកថា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងតថាគតពលនិទ្ទេស ដូចតទៅនេះ ។ បទថា **តថាគតពលានិ** គឺ កម្លាំងរបស់ព្រះតថាគតប៉ុណ្ណោះ មិនទូទៅដោយជនដទៃ ឬថា ពលៈដែលមកហើយ ដូចពលៈរបស់ព្រះពុទ្ធជាម្ចាស់អំពីមុនហើយ ដោយការសន្សំបុណ្យ ។ ក្នុងបទនោះ តថាគតពលៈមាន ២ យ៉ាង គឺ **កាយពល ១ ញាណពល ១** ក្នុងពលៈ ២ យ៉ាងនោះ គប្បីជ្រាបកាយពលៈ ដោយរាប់តាមត្រកូលដំរី ។ សមដូចដែលបោរាណាចារ្យទាំងឡាយពោលទុកថា :

**ត្រកូលដំរីទាំង ១០ នេះ គឺ កាឡាវកៈ ១ គង្គេយ្យៈ ១**
**បណ្ឌរៈ ១ តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១**
**ហេមៈ ១ ឧបោសថ ១ ឆទ្ទន្ត ១ ។**

ទាំងនេះ គឺ ត្រកូលដំរី ១០ ។ ក្នុងបទទាំងនោះ បទថា **កាឡាវកំ** គប្បីឃើញត្រកូលដំរីតាមប្រក្រតី ។ កម្លាំងកាយរបស់បុរស ១០ ស្មើនឹងកម្លាំងរបស់ដំរីត្រកូលកាឡាវកៈ ១ ។ កម្លាំងរបស់ត្រកូលកាឡាវកៈ ១០ ស្មើដោយកម្លាំងរបស់ត្រកូលគង្គេយ្យៈ ១ ។ កម្លាំងរបស់គង្គេយ្យៈ ១០ ស្មើដោយកម្លាំងរបស់ត្រកូលបណ្ឌរៈ ១ ។ កម្លាំងរបស់បណ្ឌរៈ ១០ ស្មើដោយកម្លាំងរបស់ត្រកូលតម្ពៈ ១ ។ កម្លាំងរបស់តម្ពៈ ១០ ស្មើដោយកម្លាំងរបស់ត្រកូលបិង្គលៈ ១ ។ កម្លាំងរបស់បិង្គលៈ ១០



ស្មើដោយកម្លាំងរបស់ត្រកូលគន្ធៈ ១ ។ កម្លាំងរបស់គន្ធៈ ១០ ស្មើដោយកម្លាំងរបស់ត្រកូលមង្គលៈ ១ ។ កម្លាំងរបស់មង្គលៈ ១០ ស្មើដោយត្រកូលរបស់ហេមវតៈ ១ ។ កម្លាំងរបស់ហេមវតៈ ១០ ស្មើដោយកម្លាំងរបស់ត្រកូលឧបោសថ ១ ។ កម្លាំងរបស់ឧបោសថ ១០ ស្មើដោយត្រកូលរបស់ឆទ្ទន្ត ១ ។ កម្លាំងរបស់ឆទ្ទន្ត ១០ ស្មើនឹងកម្លាំងរបស់ព្រះតថាគតមួយព្រះអង្គ ។

បទនេះ លោកពោលដល់ សូម្បីបទថា **នារាយនសង្ឃាតពលំ** គឺ កម្លាំងរបស់នារាយនៈ ។ តថាគតពលៈ ស្មើនឹងកម្លាំងធម្មតា ១.០០០ កោដិ ស្មើនឹងកម្លាំងបុរស ១០.០០០ កោដិ នេះគឺ កាយពលៈរបស់ព្រះតថាគត ។

ចំណែក **ញាណពល** មកហើយក្នុងបាលីនេះផងក្នុងទីដទៃ ។ ញាណ ១.០០០ មិនតិច សូម្បីដទៃយ៉ាងនេះ គឺ **ទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ អកម្បនញ្ញាណ** ( ញាណមិនញាប់ញ័រ ) ក្នុងបរិស័ទ ៨ **ចតុយោនិបរិច្ឆេទកញ្ញាណ** ( ញាណកំណត់កំណើត ៤ ) **បញ្ចគតិបរិច្ឆេទកញ្ញាណ** ( ញាណកំណត់គតិ៥ ) មកហើយក្នុងមជ្ឈិមនិកាយ ញាណ ៧៣ , ញាណ ៧៧ មកហើយក្នុងសំយុត្តនិកាយនេះឈ្មោះថា **ញាណពល** ។ ក្នុងទីនេះ លោកប្រាថ្នាយកញាណពលៈ

នោះឯង ព្រោះញាណនេះ លោកពោលថា ជាពលៈ ដោយអត្ថថា មិនញាប់ញ័រ និងដោយអត្ថថា ឧបត្ថម្ភ ។

បទថា **ឋានញ្ច ឋានតោ** ហេតុគួរថាជាហេតុគួរ គឺ ហេតុដោយជាហេតុ ។ ព្រោះហេតុផល រមែងតាំងនៅក្នុងញាណនោះ គឺ រមែងកើតឡើង និងរមែងប្រព្រឹត្តទៅ ព្រោះប្រព្រឹត្តទៅជាប់ដោយញាណនោះ ដូច្នេះ លោកទើបពោលថា **ឋានំ** ។ ព្រះមានព្រះភាគជាម្ចាស់ គ្រាទ្រង់ជ្រាបធម៌ដែលជាហេតុជាបច្ច័យ ដើម្បីកើតធម៌ថាជាឋានៈ ធម៌ដែលមិនជាហេតុជាបច្ច័យ ដើម្បីកើតធម៌ដែលមិនជាឋានៈ ឈ្មោះថា ទ្រង់រមែងជ្រាបឋានៈថាជាឋានៈ និងអឋានៈ ថាជាអឋានៈ តាមសេចក្តីពិត ។ បទថា **យម្បិ** គឺ ដោយញាណណា ។ បទថា **ឥទម្បិ** គឺ សូម្បីញាណនេះ ក៏ជាឋានញ្ញាណ អធិប្បាយថា ជាតថាគតពលៈ របស់តថាគត ។ សូម្បីបទដ៏សេស ក៏គប្បីជ្រាបការប្រកបយ៉ាងនេះ ។

បទថា **អាសភណ្ឋានំ** ឋានៈដ៏ខ្ពង់ខ្ពស់ គឺ ឋានៈដ៏ប្រសើរ ឋានៈដែលខ្ពង់ខ្ពស់ អធិប្បាយថា ជាឋានៈរបស់ព្រះពុទ្ធជាម្ចាស់អំពីមុន ទាំងឡាយដ៏អង់អាច ។ ម្យ៉ាងទៀត **គោឧសភ** ជាប្រធាននៃគោ ១០០ ក្បាល , **គោវសភ** ជាប្រធាននៃគោ ១.០០០ ក្បាល គោឧសភៈជាប្រធាននៃគោ ១០០ ក្រោល , គោវសភៈជាប្រធាននៃគោ ១.០០០



ក្រោល , **គោនិសភ** ប្រសើរជាងគោទាំងអស់ អត់ទ្រាំចំពោះអន្តរាយទាំងពួងបាន ពណ៌សគួរខ្ពាច នាំភារៈទៅបានច្រើន មិនតក់ស្លុត សូម្បីសំឡេងរន្ទះបាញ់ តាំងឡើង ១០០ ដង ក្នុងទីនេះលោកប្រាថ្នាយក **គោឧសភ** ព្រោះបទថា **អាសភណ្ឋានំ** សូម្បីនេះ ក៏ជាពាក្យពោលដោយបរិយាយរបស់ឧសភៈនោះ ឈ្មោះថា អាសភៈ ព្រោះឋានៈនេះ ជារបស់ឧសភៈ ។

បទថា **ឋានំ** គឺ យកជើងទាំង ៤ ជាន់លើផែនដីឲ្យមាំ ។ ម្យ៉ាងទៀត ឋានៈនេះ ឈ្មោះថា **អាសភ** ព្រោះដូចអ្នកអង់អាច ដូចជាគោឧសភៈ គឺ គោដែលប្រកបដោយឧសភពលៈ យកជើងទាំង ៤ ជាន់ផែនដី តាំងទុកដោយមិនញាប់ញ័រយ៉ាងណា សូម្បីព្រះតថាគតក៏ដូច្នេះ ទ្រង់ប្រកបដោយតថាគតពលៈ ១០ យកជើង គឺ វេសារជ្ជៈ ៤ ជាន់ផែនដី គឺ បរិស័ទ ៨ មិនញាប់ញ័រដោយសឹកសត្រូវណា ៗ ក្នុងលោកព្រមទាំងទេវលោក តាំងនៅដោយឋានៈដែលមិនញាប់ញ័រ ។ ម្យ៉ាងទៀត ពេលតាំងនៅយ៉ាងនេះ រមែងប្តេជ្ញាចូលទៅជិត មិនប្រែត្រឡប់ឲ្យកើតឡើងក្នុងខ្លួននូវឋានៈដែលអង់អាចនោះ ដោយហេតុនោះលោកទើបពោលថា **អាសភណ្ឋានំ បដិជានាតិ** ប្តេជ្ញាឋានៈដែលអង់អាច ។

បទថា **បរិសាសុ** គឺ ក្នុងបរិស័ទ ៨ មានក្សត្រ ព្រាហ្មណ៍ គហបតី សមណៈ ទេពជាន់ចាតុម្មហារាជិកៈ ទេពជាន់តាវត្តឹង្ស មារ និងព្រហ្ម ។ បទថា **សីហនាទំ នទតិ** បន្លឺសីហនាទ គឺ បន្លឺសំឡេងប្រសើរ សំឡេងមិនតក់ស្លុត ឬបន្លឺសំឡេងគឹកកង ដូចសំឡេងសីហៈ ។ គប្បីសម្តែងអត្ថនេះ ដោយសីហនាទសូត្រ ។ រាជសីហ៍លោកហៅថា **សីហ** ព្រោះអត់ធន់ ព្រោះសម្លាប់សត្វជាអាហារ យ៉ាងណា ព្រះតថាគតក៏ដូច្នោះ ។ លោកពោលថា **សីហ** ព្រោះអត់ធន់ចំពោះលោកធម៌ និងកម្ចាត់បរប្បវាទ ( អ្នកពោលជំទាស់ ) ការបន្លឺរបស់សីហៈ ដូចពោលហើយយ៉ាងនោះ ឈ្មោះថា **សីហនាទ** ។ សីហៈ ប្រកបដោយសីហពលៈ ក្លៀវក្លា ប្រាសចាកការព្រឺរោម បន្លឺសីហនាទក្នុងទីទាំងពួងយ៉ាងណា សូម្បីព្រះតថាគត ដូចសីហ៍ដូច្នោះ ទ្រង់ប្រកបដោយតថាគតពលៈ ទ្រង់ក្លៀវក្លាក្នុងបរិស័ទ ៨ ប្រាសចាកសេចក្តីតក់ស្លុត ទ្រង់បន្លឺសីហនាទ ដល់ព្រមដោយបទបាទ ការសម្តែងជាច្រើនយ៉ាង ដោយន័យជាដើមថា **ឥតិ រូបំ** រូបដូច្នេះ ដោយហេតុនោះ លោកទើបពោលថា **បរិសាសុ សីហនាទំ នទតិ** ទ្រង់បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ។

បទថា **ព្រហ្មំ** ក្នុងបទនោះថា **ព្រហ្មចក្កំ បវត្តេតិ** ប្រកាសព្រហ្មចក្ក



ជាចក្កដ៏ប្រសើរខ្ពង់ខ្ពស់បរិសុទ្ធ ។ គប្បីជ្រាបចក្កសព្ទ ដូចតទៅនេះ ។

**ចក្កស័ព្ទប្រាកដក្នុង សម្បត្តិ លក្ខណៈ គ្រឿងប្រកបរថ**
**ឥរិយាបថ ទាន រតនចក្ក ធម្មចក្ក ឧរចក្កជាដើម ក្នុង**
**ទីនេះ ប្រាកដក្នុងធម្មចក្ក ព្រះយោគាវចរ គប្បីប្រកាស**
**ធម្មចក្ក សូម្បីនោះ ដោយអាការ ២ យ៉ាង ។**

**ចក្ក** សព្ទ ប្រាកដក្នុងសម្បត្តិ ក្នុងបទជាដើមថា ម្នាលភិក្ខុទាំងឡាយ សម្បត្តិរបស់ទេវតា និងមនុស្សទាំងឡាយអ្នកប្រកបដោយចក្ក ៤ ទាំងនេះ ។ ប្រាកដក្នុង **លក្ខណៈ** ក្នុងប្រយោគនេះថា ចក្កកើតត្រង់ផ្ទៃព្រះបាទខាងក្រោម ។ ប្រាកដក្នុងចំណែកនៃរថ ក្នុងប្រយោគនេះថា ដូចកង់រទេះវិលទៅតាមស្នាមជើងគោ ដូច្នេះ ។ ប្រាកដក្នុង **ឥរិយាបថ** ក្នុងបទនេះថា មានចក្ក ៤ មានទ្វារ ៩ ។ ប្រាកដក្នុងទាន ក្នុងប្រយោគនេះថា លោកចូរឲ្យបរិភោគចុះ នឹងកុំជាអ្នកប្រមាទ បពិត្រព្រះអង្គជាធំក្នុងដែនកោសល សូមព្រះអង្គញ៉ាំងចក្កឲ្យប្រព្រឹត្តទៅចុះ ។ ប្រព្រឹត្តទៅ **រតនចក្ក** ក្នុងបទនេះថា ចក្ករតន៍ ដែលជាទិព្វ បានប្រាកដហើយ ។ ប្រព្រឹត្តទៅ **ធម្មចក្ក** ក្នុងបទនេះថា ចក្កដែលតថាគតប្រកាសហើយ ។ ប្រព្រឹត្តទៅក្នុង **ឧរចក្ក** រមែងវិលទៅ លើក្បាលរបស់សត្វអ្នកត្រូវសេចក្តីប្រណែនគ្របសង្កត់ហើយ ។ ប្រព្រឹត្តទៅក្នុង **បហរ-**

**ណចក្ក** ក្នុងបទនេះថា ដោយចក្កមានមុខមុត ។ ក្នុង **អសនិមណ្ឌល** ក្នុងបទនេះថា ផ្ទេកបន្ទោរ ។ តែក្នុងទីនេះ **ចក្ក** សព្ទនេះ ប្រាកដក្នុង ធម្មចក្ក ។

ម្យ៉ាងទៀត ធម្មចក្កនោះមាន ២ យ៉ាង គឺ **បដិវេធញ្ញាណ** និង **ទេសនាញាណ** ។ ក្នុងញាណទាំងពីរនោះ ការនាំមកនូវអរិយផលរបស់ខ្លួន ដែលចម្រើនហើយដោយបញ្ញា ឈ្មោះថា បដិវេធញ្ញាណ ។ ការនាំមកនូវអរិយផលរបស់សាវ័កទាំងឡាយដែលចម្រើនដោយករុណា ឈ្មោះថា ទេសនាញាណ ។ ក្នុងញាណទាំងពីរនោះ បដិវេធញ្ញាណមាន ២ យ៉ាង គឺ **កំពុងកើត ១ កើតហើយ ១** ។ ញាណនោះឈ្មោះថា កំពុងកើត តាំងអំពីចេញមហាអភិនេស្រ្កមន៍ រហូតដល់អរហត្តមគ្គ ឈ្មោះថា កើតហើយក្នុងអរហត្តផល ។ ម្យ៉ាងទៀត ឈ្មោះថា កំពុងកើត តាំងអំពីប្រតិស្ឋាន ក្នុងភពតុសិត រហូតបានសម្រេចអរហត្តមគ្គនៅក្រោមពោធិបល្ល័ង្ក ឈ្មោះថា កើតហើយ ក្នុងខណៈនៃផល ឬកំពុងកើតតាំងអំពីសាសនាព្រះទីបង្ករទេសពល រហូតបានសម្រេចអរហត្តមគ្គ ឈ្មោះថា កើតហើយក្នុងខណៈនៃផល ។ សូម្បីទេសនាញាណ ក៏មាន ២ យ៉ាង គឺ **កំពុងប្រព្រឹត្តទៅ ១ ប្រព្រឹត្តទៅហើយ ១** ។ ទេសនាញាណនោះ ឈ្មោះថា កំពុងប្រព្រឹត្តទៅ ដរាបការកើតអរហត្តមគ្គរបស់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ , ឈ្មោះថា ប្រព្រឹត្តទៅហើយ ក្នុងខណៈនៃផល ។



បដិវេធញ្ញាណជាលោកុត្តរៈ ទេសនាញាណជា លោកិយៈ ។ សូម្បីទាំង ២ នោះ មិនទូទៅដល់អ្នកដទៃ ជាឱរសញ្ញាណ ( ញាណកើតអំពីទ្រូង ) របស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ ដោយហេតុនោះ លោកទើបពោលថា **ព្រហ្មចក្កំ បវត្តេតិ** ប្រកាសព្រហ្មចក្ក ។

បទថា **កម្មសមាទនានំ** កម្មសមាទាន គឺ កុសលកម្ម និងអកុសលកម្ម ដែលសមាទានហើយ ឬកម្មនោះឯងឈ្មោះថា កម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ** ដោយឋានៈ ដោយហេតុ គឺ ដោយបច្ច័យ និងដោយហេតុ ក្នុងបទនោះ ឋានៈនៃវិបាក ព្រោះគតិ ឧបធិ កាល ប្រយោគ កម្មជាហេតុ ។ បទថា **សព្វត្ថគាមិនី** បដិបទាជាគ្រឿងឲ្យដល់ប្រយោជន៍ទាំងពួង ។ គឺ បដិបទាជាគ្រឿងឱ្យដល់គតិទាំងពួង និងបដិបទាជាគ្រឿងឲ្យដល់អគតិ ។ បទថា **បដិបទំ** បដិបទា គឺ មគ្គ ។ បទថា **យថាភូតំ បជានាតិ** ដឹងតាមសេចក្តីពិត គឺ តថាគតរមែងដឹងសភាពពិត ដោយ មិនវិបរិតនៃការបដិបត្តិ ពោលគឺ កុសលចេតនា និងអកុសលចេតនា សូម្បីក្នុងវត្ថុមួយ ដោយន័យនេះថា សូម្បីកាលមនុស្សច្រើនសម្លាប់សត្វមួយក្បាលប៉ុណ្ណោះ ចេតនានៃការសម្លាប់នោះ ក៏ជាចេតនាទៅកាន់នរក និងជាចេតនាទៅកាន់កំណើតតិរច្ឆាន ។ បទថា **អនេកធាតុំ** អនេកធាតុ គឺ ធាតុច្រើន មានចក្ខុធាតុជាដើម ឬមានកាមធាតុ

ជាដើម ។ បទថា **នានាធាតុំ** ធាតុផ្សេង ៗ គឺ ធាតុមានប្រការផ្សេង ៗ ព្រោះធាតុទាំងនោះ មានលក្ខណៈខុសគ្នា ។ បទថា **លោកំ** បានដល់ លោក គឺ ខន្ធ អាយតនៈ ធាតុ ។ បទថា **យថាភូតំ បជានាតិ** ដឹង តាមសេចក្ដីពិត គឺ ចាក់ធ្លុះសភាវៈនៃធាតុនោះ ៗ ដោយមិនវិបរិត ។ បទថា **នានាធិមុត្តិកតំ** គឺ សត្វទាំងឡាយមានអធ្យាស្រ័យផ្សេងគ្នា ដោយ អធ្យាស្រ័យអាក្រក់ ប្រណីតជាដើម ។ បទថា **បរសត្តានំ** របស់សត្វ ដទៃ គឺ របស់សត្វជាប្រធាន ។ បទថា **បរបុគ្គលានំ** របស់សត្វដទៃ គឺ របស់សត្វអាក្រក់ដទៃពីសត្វដែលជាប្រធាននោះ ទាំង ២ បទនេះ មាន អត្ថដូចគ្នា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ដោយអាការ ២ យ៉ាង ដោយអំណាចវេនេយ្យសត្វ សូម្បីក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្ដែងដោយន័យដូចពោលហើយ ។

បទថា **ឥន្ទ្រិយបរោបរិយត្តំ** ការចាស់ក្លា និងទន់ខ្សីនៃឥន្ទ្រិយ គឺ ភាពចាស់ក្លា និងភាពទន់ខ្សីនៃឥន្ទ្រិយ មានសទ្ធិន្ទ្រិយ៍ជាដើម អធិប្បាយ ថា សេចក្ដីចម្រើន និងសេចក្ដីវិនាស ។

បទថា **ឈានវិមោក្ខសមាធិសមាបត្តីនំ** ឈានវិមោក្ខ សមាធិ និងសមាបត្តិ គឺ នៃឈាន ៤ មានបឋមជ្ឈានជាដើម នៃវិមោក្ខ ៨ ជាដើមថា អ្នកមានរូប រមែងឃើញរូបទាំងឡាយ របស់សមាធិ ៣ មាន



វិតក្កៈ វិចារៈ ជាដើម នៃអនុបុព្វសមាបត្តិ ៩ មានបឋមជ្ឈានសមាបត្តិ ជាដើម ។ បទថា **សង្កិលេសំ** សេចក្ដីសៅហ្មង គឺ ធម៌ដែលប្រព្រឹត្តទៅ ក្នុងចំណែកវិនាស ។ បទថា **វោទានំ** សេចក្ដីផូរផង់ គឺ ធម៌ដែល ប្រព្រឹត្តទៅក្នុងចំណែកពិសេស ។ បទថា **វុដ្ឋានំ** ការចេញ គឺ ហេតុ ដែលចេញពីឈាន ។ ម្យ៉ាងទៀត ការចេញនោះ លោកពោលទុក យ៉ាងនេះថា សូម្បីសេចក្ដីផូរផង់ ក៏ជាការចេញ សូម្បីការចេញពីសមាធិ នោះ ៗ ក៏ជាការចេញ បានដល់ ឈានដែលស្ទាត់ជំនាញ និងសមាត្តិ ដែលជាផលនៃភវង្គ ។

ព្រោះឈានដែលស្ទាត់ជំនាញថ្នាក់ទាប ៗ ជាបទដ្ឋាននៃឈាន ថ្នាក់ខ្ពស់ ៗ ដូច្នេះទើបលោកពោលថា សូម្បីសេចក្ដីផូរផង់ ក៏ជាការ ចេញ ការចេញចាកឈានទាំងពួង រមែងមានបានដោយភវង្គ ការចេញ ពីនិរោធសមាបត្តិ រមែងមានបានដោយផលសមាបត្តិ ។ លោកសំដៅ ដល់ការចេញនោះ ទើបលោកពោលថា សូម្បីការចេញពីសមាធិនោះ ៗ ក៏ជាការចេញ ។

បុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ និងអាសវក្ខយញ្ញាណ លោក ប្រកាសទុកហើយក្នុងកាលមុននោះឯង ។ បទទាំងនោះ បទថា **អាសវានំ ខយា** ព្រោះអាសវៈអស់ទៅ គឺ កិលេសទាំងអស់ អស់ទៅដោយ

អរហត្តមគ្គ ។ បទថា **អនាសវំ** មិនមានអាសវៈ គឺ ប្រាសចាកអាសវៈ បទថា **ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ** នេះ លោកពោលសមាធិសម្បយុត្តដោយអរហត្តផល ដោយពាក្យថា **ចេតោ** ពោលបញ្ញាសម្បយុត្តដោយអរហត្តផលនោះ ដោយពាក្យថា **បញ្ញា** ។ ម្យ៉ាងទៀត គប្បីជ្រាបថា សមាធិ ឈ្មោះថា ចេតោវិមុត្តិ ព្រោះផុតចាករាគៈ បញ្ញាឈ្មោះថា បញ្ញាវិមុត្តិ ព្រោះផុតចាកអវិជ្ជា ។ សមដូចដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ **សមាធិ** គប្បីជាសមាធិន្ទ្រីយ៍ **បញ្ញា** គប្បីជាបញ្ញិន្ទ្រីយ៍ ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូច្នេះឯង ឈ្មោះថា **ចេតោវិមុត្តិ** ព្រោះបន្ទោបង់រាគៈ ឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះបន្ទោបង់អវិជ្ជា ។ ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបថា សមថពលៈ ជាចេតោវិមុត្តិ វិបស្សនាពលៈ ជាបញ្ញាវិមុត្តិ ។ បទថា **ទិដ្ឋេវ ធម្មេ** គឺ ក្នុងអត្តភាពនេះ ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ប្រពៃខ្លួនឯង គឺ ធ្វើឲ្យប្រចក្សច្បាស់ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង អធិប្បាយថា ដឹងដោយបច្ច័យដទៃទៀត ។ បទថា **ឧបសម្បជ្ជ** ចូលដល់ គឺ បានសម្រេច ឬស្រេចហើយ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីពិស្តាររបស់ទសពលញ្ញាណ ១០ នេះ ដោយន័យដូចពោលហើយក្នុងអភិធម្ម ។



ក្នុងបទនោះ ចំណែកពាក្យបរវាទីមានថា ឈ្មោះថា ទសពលញ្ញាណ ជាញាណចំពោះមិនមាន ។ នេះជាប្រភេទរបស់សព្វញ្ញុតញ្ញាណនោះឯង សេចក្តីនេះមិនគប្បីឃើញយ៉ាងនោះ ។ ព្រោះទសពលញ្ញាណជាយ៉ាងដទៃ សព្វញ្ញុតញ្ញាណជាយ៉ាងដទៃ ទសពលញ្ញាណរមែងដឹងកិច្ចរបស់ខ្លួនប៉ុណ្ណោះ សព្វញ្ញុតញ្ញាណរមែងដឹងកិច្ចនោះខ្លះ កិច្ចដ៏សេសពីនោះខ្លះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ទសពលញ្ញាណ** ដូចតទៅនេះ :-

ទសពលញ្ញាណទី ១ រមែងដឹងហេតុ និងមិនមែនហេតុ ។

ទសពលញ្ញាណទី ២ រមែងដឹងកម្ម និងវិបាក ។

ទសពលញ្ញាណទី ៣ រមែងដឹងការកំណត់របស់កម្ម ។

ទសពលញ្ញាណទី ៤ រមែងដឹងហេតុនៃការផ្សេងរបស់ធាតុ ។

ទសពលញ្ញាណទី ៥ រមែងដឹងអធ្យាស្រ័យរបស់សត្វទាំងឡាយ ។

ទសពលញ្ញាណទី ៦ រមែងដឹងភាពចាស់ក្លា និងភាពទន់ខ្ចីនៃឥន្ទ្រីយ៍ទាំងឡាយ ។

ទសពលញ្ញាណទី ៧ រមែងដឹងសេចក្តីសៅហ្មងជាដើម នៃញាណទាំងនោះ ព្រមទាំងឈានជាដើម ។

ទសពលញ្ញាណទី ៨ រមែងដឹងការជាប់តគ្នារបស់ខន្ធដែលនៅ

អាស្រ័យក្នុងកាលមុន ។

ទសពលញ្ញាណទី ៩ រមែងដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ។

ទសពលញ្ញាណទី ១០ រមែងកំណត់ដឹងនូវសច្ចៈប៉ុណ្ណោះ ។

**ចំណែកសព្វញ្ញុតញ្ញាណ**

រមែងដឹងវត្ថុដែលទសពលញ្ញាណទាំងនោះគួរដឹង ដែលក្រៃលែងជាងនោះ តែមិនធ្វើកិច្ចទាំងអស់របស់ញាណទាំងនោះ ព្រោះទសពលញ្ញាណនោះ មានឈាន ក៏មិនអាចឲ្យនៃបនិត្យបាន មានឫទ្ធិមិនអាចធ្វើឲ្យអស្ចារ្យបាន មានមគ្គមិនអាចញ៉ាំងកិលេសឲ្យអស់បាន ។

ម្យ៉ាងទៀត គួរសួរបរវាទីយ៉ាងនេះថា ឈ្មោះថា ទសពលញ្ញាណនេះ មានវិតក្កៈ មានវិចារៈ ឬមិនមានវិតក្កៈ មានតែវិចារៈ ឬមិនមានទាំងវិតក្កៈ និងវិចារៈ ជាកាមាវចរៈ ឬរូបាវចរៈ ឬអរូបាវចរៈ ជាលោកិយៈ និងលោកុត្តរៈ ។ ពេលដឹងក៏នឹងឆ្លើយថា ឈាន ៧ មានវិតក្កៈ មានវិចារៈតាមលំដាប់ និងឆ្លើយថា ឈាន ២ ក្រៅពីនោះមិនមានវិតក្កៈ មិនវិចារៈ និងឆ្លើយថា អាសវក្ខយញ្ញាណមានទាំងវិតក្កៈមានទាំងវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមវិចារៈក៏មាន មិនមានវិតក្កៈ និងមិនមានទាំងវិចារៈក៏មាន ។ ម្យ៉ាងទៀត នឹងឆ្លើយថា ឈាន



ទី ៧ ជាកាមាវចរៈតាមលំដាប់ ឈាន ២ ក្រៅពីនេះ ជារូបាវចរៈ ក្នុងទីបំផុតពីនោះ ជាលោកុត្តរៈតែម្យ៉ាង នឹងឆ្លើយថា ចំណែកសព្វញ្ញុតញ្ញាណ មានទាំងវិតក្កៈ មានទាំងកាមាវចរៈ ជាលោកិយៈ ។

ឥឡូវនេះ ព្រះតថាគតទ្រង់ជ្រាបការពណ៌នាតាមសេចក្ដី ដែលនៅមិនធ្លាប់ពណ៌នាទុកបទយ៉ាងនេះ ហើយទ្រង់ឃើញការមិនមានគ្រឿងរាំងនៃកិលេស ដែលជាឋានៈ និងអឋានៈនៃការសម្រេច ការអស់ទៅនៃអាសវៈ និងការមិនសម្រេចនៃវេនេយ្យសត្វទាំងឡាយ ដោយឋានាឋានញ្ញាណជាគ្រាដំបូង ព្រោះទ្រង់ឃើញឋានៈរបស់សម្មាទិដ្ឋិ ដែលជាលោកិយៈ ព្រោះទ្រង់ឃើញការមិនមានឋានៈរបស់និយតមិច្ឆាទិដ្ឋិ កាលទ្រង់ឃើញការមិនមានគ្រឿងរាំងវិបាក ដោយកម្មវិបាកញ្ញាណ ព្រោះទ្រង់ឃើញបដិសន្ធិដែលជាតិហេតុកៈ ទ្រង់ឃើញការមិនមានគ្រឿងរាំងកម្មដោយសព្វត្ថគាមិនីបដិបទាញាណ ( ញាណកំណត់ដឹងផ្លូវទៅកាន់ភូមិទាំងពួង ) ព្រោះទ្រង់ឃើញការមិនមានអនន្តរិយកម្ម ទ្រង់ឃើញចរិយាពិសេស ដើម្បីទ្រង់សម្ដែងធម៌ អនុគ្រោះដល់អនាវរណញ្ញាណ ( ញាណដែលមិនមានគ្រឿងរាំង ) ដោយនានាធាតុញ្ញាណ ( ញាណកំណត់ដឹងធាតុផ្សេង ៗ ) នៃធាតុដ៏ច្រើន ព្រោះទ្រង់សម្ដែងសេចក្ដីផ្សេងគ្នានៃធាតុដោយប្រការដូច្នេះ ។

គ្រាទ្រង់សម្តែងអធ្យាស្រ័យ ដោយនានាធិមុត្តិកតាញាណ (ញាណកំណត់ដឹងអធ្យាស្រ័យផ្សេង ៗ) របស់វេនេយ្យសត្វទាំងនោះ ដើម្បីមិនកាន់យកការប្រកប ក៏ទ្រង់សម្តែងធម៌ដោយអំណាចអធ្យាស្រ័យ បន្ទាប់ពីនោះ ដើម្បីទ្រង់សម្តែងធម៌តាមសមត្ថភាព តាមកម្លាំងរបស់អ្នកបង្អោនទៅក្នុងទិដ្ឋិយ៉ាងនេះ ទើបទ្រង់ឃើញសភាពទន់ខ្ចី និងចាស់ក្លារបស់ឥន្ទ្រីយ៍ ដោយឥន្ទ្រិយបរោបរិយត្តញ្ញាណ ព្រោះទ្រង់ឃើញភាពចាស់ក្លា និងភាពទន់ខ្ចីរបស់ឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើម ។

ម្យ៉ាងទៀត ប្រសិនបើវេនេយ្យសត្វទាំងឡាយនោះ កំណត់ដឹងសភាពទន់ខ្ចី និងចាស់ក្លារបស់ឥន្ទ្រីយ៍យ៉ាងនេះ មិនមាននៅឆ្ងាយ ពេលនោះព្រះតថាគតរមែងចូលដល់ ដោយឫទ្ធិ៍ពិសេសឆាប់រហ័ស ព្រោះទ្រង់ជំនាញក្នុងឈានជាដើម ដោយញាណមានឈានជាដើម គ្រាចូលដល់ហើយ ទ្រង់ឃើញជាក់ច្បាស់នូវជាតិមុន ដោយបុព្វេនិវាសានុស្សតិញ្ញាណ សេចក្តីពិសេសរបស់ចិត្តខណៈនោះ ដោយចេតោបរិយញ្ញាណ ដែលគួរបានសម្រេច ព្រោះអនុភាពនៃទិព្វចក្ខុញ្ញាណ ទ្រង់សម្តែងធម៌ដើម្បីការអស់អាសវៈ ព្រោះប្រាសចាកការវង្វេង ដោយបដិបទាដែលនាំទៅកាន់ការអស់អាសវៈ ដោយអនុភាពនៃអាសវក្ខយញ្ញាណ ព្រោះដូច្នោះគប្បីជ្រាបថា លោកពោលដល់កម្លាំង ១០ ដោយបទនេះតាមលំដាប់ ។



ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ប្រាថ្នានឹងសម្តែងកម្លាំងទាំងអស់ ដោយភាពជាលក្ខណៈ ទើបតាំងពាក្យសួរដោយន័យជាដើមថា **កេន-ដ្ឋេន សទ្ធាពលំ** ឈ្មោះថា សទ្ធាពលៈ ព្រោះអត្ថថាដូចម្តេច ហើយឆ្លើយដោយន័យជាដើមថា **អស្សទ្ធិយេ អកម្បិយដ្ឋេន** ព្រោះអត្ថថា មិនញាប់ញ័រក្នុងភាពជាអ្នកមិនមានសទ្ធា ។

ក្នុងបទទាំងនោះ បទជាដើមថា **ហិរិយតិ** រមែងខ្មាស់ ជាការសម្តែងដល់បុគ្គលាធិដ្ឋាន ។ ក្នុងទីបំផុតអធិដ្ឋានពលៈ មានភាវនា-ពលៈជាដើម គប្បីជ្រាបថា លោកពោលសំដៅដល់នេក្ខម្មៈជាដើមប៉ុណ្ណោះ ដោយបទថា **តត្ថ តេន** និង **តំ** ក្នុងនេក្ខម្មៈនោះ ដោយនេក្ខម្មៈនោះ នូវនេក្ខម្មៈនោះ ។

បទថា **តេន ចិត្តំ ឯកគ្គំ** ចិត្តមានអារម្មណ៍តែមួយ ដោយនេក្ខម្មៈនោះ លោកអធិប្បាយថា ចិត្តមានអារម្មណ៍តែមួយដោយសមាធិនោះ ។ បទថា **តត្ថ ជាតេ** ធម៌ដែលកើតក្នុងភាវនានោះ គឺ ធម៌ដែលកើតក្នុងសមថៈនោះ ដោយការប្រកប ឬមានវិបស្សនាជាអារម្មណ៍ កើតក្នុងសមថៈនោះ ។ បទថា **តត្ថ សិក្ខតិ** ព្រះសេក្ខៈនៅសិក្សាក្នុងសម្មាទិដ្ឋិនោះ សេចក្តីថា ឈ្មោះថា សេក្ខពលៈ ព្រោះព្រះសេក្ខៈនៅសិក្សាក្នុងសេក្ខពលៈនោះ ។ បទថា **តត្ថ សិក្ខិតត្តា** ព្រោះសេចក្តីដែលអសេក្ខៈ

សិក្សាក្នុងសម្មាទិដ្ឋិនោះស្រេចហើយ សេចក្ដីថា ឈ្មោះថា អសេក្ខពលៈ ព្រោះអសេក្ខៈសិក្សាហើយក្នុងអសេក្ខពលៈនោះ ។ បទថា **តេន អសាវា ខីណា** អាសវៈទាំងឡាយអស់ទៅ ដោយសម្មាទិដ្ឋិនោះ សេចក្ដីថា ញាណនោះឈ្មោះថា ខីណាសវពលៈ ព្រោះអាសវៈទាំងឡាយអស់ទៅហើយ ដោយលោកិយញ្ញាណ និងលោកុត្តរញ្ញាណនោះ ។ ពិតណាស់ អាសវៈទាំងឡាយ ឈ្មោះថា អស់ទៅដោយលោកិយញ្ញាណ ព្រោះការមិនមានលោកុត្តរធម៌ ព្រោះការមិនមានវិបស្សនា ។ ឈ្មោះថា **ខីណាសវពល** ព្រោះកម្លាំងរបស់ព្រះខីណាស្រពយ៉ាងនេះ ។ បទថា **តំ តស្ស ឥជ្ឈតីតិ ឥទ្ធិពលំ** ឈ្មោះថា **ឥទ្ធិពល** ព្រោះឫទ្ធិ៍រមែងសម្រេចដោយការអធិដ្ឋាន សេចក្ដីថា ឫទ្ធិ៍នោះឯងជាកម្លាំង ទើបឈ្មោះថា ឥទ្ធិពលៈ ព្រោះឥទ្ធិរមែងសម្រេច ដល់អ្នកមានឫទ្ធិ៍នោះ ។ បទថា **អប្បមេយ្យដ្ឋេន** ព្រោះអត្ថថា ជាកម្លាំងរកប្រមាណមិនបាន គឺ សាវកទាំងឡាយរមែងដឹងឋានៈ និងអឋានៈជាដើម ដោយឯកទេស ។ លោកពោលថា **យថាភូតំ បជានាតិ** រមែងដឹងច្បាស់តាមសេចក្ដីពិត សំដៅដល់ការដឹងនោះឯង ដោយអាការទាំងពួង សូម្បីលោកមិនពោលថា **យថាភូតំ បជានាតិ** ទុកក្នុងវិជ្ជា ៣ ក៏ពិត តែព្រោះលោកពោលទុកក្នុងទីដទៃទើបជាការពោល សូម្បីក្នុងវិជ្ជា ទាំងនោះផង ។



បទថា **អញ្ញត្ថ** គឺ ក្នុងញាណពលៈ ៧ ដ៏សេស និងក្នុងពលៈ ១០ ក្នុងអភិធម្ម ។ មួ៉ាងទៀត ឥន្ទ្រិយបរោបរិយត្តិញ្ញាណ មិនទូទៅដល់សាវកទាំងឡាយ សូម្បីដោយប្រការទាំងពួង ព្រោះដូច្នោះ សូម្បីពលៈ ១០ ក៏មិនទូទៅដល់សាវកទាំងឡាយ ពលៈ ១០ ឈ្មោះថារកប្រមាណមិនបាន ព្រោះអត្ថថា មានប្រមាណយ៉ាងក្រៃលែង ព្រោះអត្ថថា ថ្លឹងមិនបាន ព្រោះដូច្នោះលោកទើបពោលថា **អប្បមេយ្យដ្ឋេន តថាគតពលំ** ឈ្មោះថា តថាគតពលៈ ព្រោះអត្ថថា ជាកម្លាំងរកប្រមាណមិនបាន ដោយប្រការដូច្នេះ ។

(ចប់អដ្ឋកថា ពលកថា)

## ១០–អដ្ឋកថា សុញ្ញកថា

ឥឡូវនេះ ពណ៌នាតាមលំដាប់សេចក្តីដែលមិនធ្លាប់ពិចារណានៃសុញ្ញកថាដែលមានព្រះសូត្រជាខាងដើម មានលោកុត្តរសុញ្ញតាជាទីបំផុត ដែលព្រះអានន្ទត្ថេរ ពោលហើយក្នុងលំដាប់នៃពលកថា ដែលមានលោកុត្តរពលៈ ជាទីបំផុត។

គប្បីជ្រាបវិនិច្ឆ័យ នៅក្នុងព្រះសូត្រ ដូចតទៅនេះមុន ។ បទថា **អថ** ជានិបាត ចុះក្នុងការប្រកាន់មាំនៃពាក្យ ។ ដោយបទនោះ លោកធ្វើការប្រកាន់ដោយពាក្យជាដើមថា **អាយស្មា** ។ បទថា **ខោ** ជានិបាត ចុះក្នុងអត្ថនៃបទបរិបូណ៌ ( ធ្វើបទឲ្យពេញ ) ។ បទថា **យេន ភគវា តេនុបសង្កមិ** ព្រះអានន្ទត្ថេរចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ដល់ទីប្រថាប់ ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ព្រោះដូច្នោះគប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា **យត្ថ ភគវា តត្ថ ឧបសង្កមិ** ព្រះមានព្រះភាគប្រថាប់នៅទីណា ចូលទៅគាល់ហើយក្នុងទីនោះ ។ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា ព្រះមានព្រះភាគជាម្ចាស់ដែលមនុស្ស និងទេវតាគប្បីចូលទៅគាល់ ដោយហេតុណា ចូលទៅគាល់ហើយដោយហេតុណា ក៏គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា ព្រះមាន-



ព្រះភាគ ដែលទេវតា និងមនុស្សចូលទៅគាល់ដោយហេតុអ្វី ដោយប្រាថ្នាសម្រេចគុណវិសេស មានប្រការផ្សេង ៗ ដូចដើមឈើធំមានផ្លែជានិច្ចដែលពួកបក្សាបក្សី ទាំងឡាយចូលទៅដោយប្រាថ្នាស៊ីផ្លែឈើមានរសឆ្ងាញ់ដូច្នោះ ចូលទៅរកហើយដោយហេតុនោះ ។ ក៏បទថា **ឧបសង្កមិ** លោកអធិប្បាយថា ចូលទៅហើយ ។ បទថា **ឧបសង្កមិត្វា** គ្រាចូលទៅគាល់ហើយ ជាបទសម្តែងដល់ទីបំផុតនៃការចូលគាល់ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ទៅហើយយ៉ាងនេះ គឺ ទៅកាន់ទីវាងសេនាសនៈពីទីនោះបានដល់ ជិតព្រះមានព្រះភាគ ។ បទថា **អភិវាទេត្វា** គឺ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។

ឥឡូវនេះ ព្រះអានន្ទត្ថេរប្រាថ្នានឹងចូលសួរសេចក្តីដែលខ្លួនមកឧបដ្ឋាកព្រះមានព្រះភាគជាម្ចាស់ ជាបុគ្គលប្រសើរក្នុងលោក ទើបលើកដៃឡើងថ្វាយបង្គំលើសិរសាហើយ អង្គុយក្នុងទីសមគួរ ។ បទថា **ឯកមន្តំ** សម្តែងដល់ភាពជាសភាវៈនបុំសកៈ ដូចក្នុងប្រយោគជាដើមថា ព្រះច័ន្ទ និងព្រះអាទិត្យ ដើរមិនស្មើគ្នា ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទនេះថា យ៉ាងនេះ ព្រះអានន្ទត្ថេរអង្គុយដោយអាការអង្គុយដ៏សមគួរ បទនេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ បទថា **និសីទិ** គឺ សម្រេចដោយការអង្គុយ ។ ពិតណាស់ ទេវតា និងមនុស្ស

ដែលឆ្ងាត គ្រាចូលទៅរកបុគ្គលគួរគោរព រមែងអង្គុយក្នុងទីដ៏សមគួរ ព្រោះជាអ្នកឆ្លាតក្នុងអាសនៈ ព្រះថេរៈក៏ជាអ្នកឆ្លាតក្នុងបណ្តាមនុស្ស ឆ្លាតទាំងនោះ ព្រោះដូច្នោះ ទើបអង្គុយក្នុងទីសមគួរ អង្គុយយ៉ាងណា ទើបឈ្មោះថា អង្គុយក្នុងទីសមគួរ ។ គឺ វៀរទោសនៃការអង្គុយ ៦ ប្រការ គឺ ឆ្ងាយពេក ១ , ជិតពេក ១ , លើខ្យល់ ១ , ទីមិនមានរវាងចន្លោះ ១ , ចំពោះមុខពេក ១ , ក្រោយឆ្ងាយពេក ១ ។ ព្រោះអង្គុយឆ្ងាយពេក បើប្រាថ្នានឹងនិយាយ ក៏ត្រូវនិយាយសំឡេងខ្លាំង ។ អង្គុយជិតពេក ក៏រមែងប្រជ្រៀត ។ អង្គុយលើខ្យល់ ក៏រំខានដល់ក្លិនខ្លួន ។ អង្គុយមិនមានរវាងចន្លោះ ប្រកាសសេចក្តីមិនគោរព ។ អង្គុយចំពោះមុខពេក ប្រសិនបើប្រាថ្នានឹងឃើញមុខ រមែងញ៉ាំងភ្នែកនឹងភ្នែកឲ្យប៉ះគ្នា ។ អង្គុយក្រោយឆ្ងាយពេក បើប្រាថ្នានឹងឃើញ ក៏ត្រូវអើតកមើល ។ ព្រោះដូច្នោះ ព្រះអានន្ទត្ថេរទើបអង្គុយវៀរទោសនៃការអង្គុយ ៦ ប្រការទាំងនេះ ដោយហេតុនោះ លោកទើបពោលថា **ឯកមន្តំ និសីទិ** អង្គុយក្នុងទីដ៏សមគួរ ។ បទថា **ឯតទវោច** គឺ បានទូលសួរព្រះមានព្រះភាគជាម្ចាស់ ។

បទថា **សុញ្ញោ លោកោ សុញ្ញោ លោកោតិ ភន្តេ វុច្ចតិ** បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ថា លោកសូន្យ លោកសូន្យ ដូច្នោះ



សេចក្តីថា ភិក្ខុអ្នកបដិបត្តិក្នុងសាសនានេះ រមែងពោលថា **លោកសូន្យ លោកសូន្យ** ដូច្នេះ ព្រោះពាក្យដូច្នោះ និយាយគ្នាច្រើនក្នុងទីនោះ ៗ ដើម្បីសង្គ្រោះភិក្ខុទាំងអស់នោះ ទើបនិយាយដដែល ៗ កាលពោលយ៉ាងនេះហើយ ក៏ជាការរួមពាក្យទាំងអស់នោះ ។ បទថា **កិត្តាវតា** គឺដោយប្រមាណប៉ុនណា ។ សព្ទថា **នុ ហ្ន៎** ជានិបាតចុះក្នុងអត្ថនៃសេចក្តីសង្ស័យ ។ បទថា **សុញ្ញំ អត្តេន វា អត្តនិយេន វា** សូន្យចាកខ្លួន ឬសូន្យចាកវត្ថុជារបស់ខ្លួន គឺ សូន្យចាកខ្លួន ដែលលោកកំណត់ទុកយ៉ាងនេះថា អ្នកធ្វើ អ្នកសោយ អ្នកមានអំណាច និងចាកបរិក្ខារដែលជារបស់ខ្លួន ព្រោះការមិនមានខ្លួននោះឯង ចក្ខុជាដើមទាំងអស់ ជាធម្មជាតិរបស់លោក ចក្ខុជាដើមនោះឯង ឈ្មោះថា **លោក** ព្រោះអត្ថថាបែកធ្លាយ ។ ក៏ព្រោះខ្លួនមិនមានក្នុងលោកនេះ និងវត្ថុដែលជារបស់ខ្លួនក៏មិនមានក្នុងលោកនេះ ព្រោះដូច្នោះ លោកទើបពោលថា **សុញ្ញោ លោកោ** លោកសូន្យ ។ សូម្បីលោកុត្តរធម៌ ក៏សូន្យដូចគ្នា ព្រោះជាវត្ថុរបស់ខ្លួន តែលោកពោលដល់លោកិយធម៌ប៉ុណ្ណោះ ដោយសមគួរដល់ពាក្យសួរ ។

មយ៉ាងទៀត បទថា **សុញ្ញោ** លោកមិនពោលថា ធម៌មិនមានលោកពោលដល់ការមិនមានខ្លួន និងសារៈដែលជារបស់ខ្លួន ក្នុងធម៌

នោះ ។ ក៏កាលសត្វលោកនិយាយថា ផ្ទះសូន្យ ឆ្នាំងសូន្យ ក៏មិនមែនពោលដល់ការមិនមានផ្ទះ និងឆ្នាំង លោកពោលដល់ការមិនមានវត្ថុដទៃក្នុងផ្ទះ និងក្នុងឆ្នាំងនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ត្រាស់សេចក្ដីនេះទុកថា ក៏វត្ថុណាមិនមានក្នុងវត្ថុនោះ ភិក្ខុរមែងពិចារណាវត្ថុនោះថាសូន្យដោយហេតុនោះ តែវត្ថុណាមានសល់នៅក្នុងវត្ថុនោះ វត្ថុនោះមានហើយ ភិក្ខុរមែងដឹងថា មានហើយដូច្នោះ ។ ក្នុងញេយ្យ-គន្ថៈ ( គម្ពីរដើម្បីការត្រាស់ដឹង ) និងក្នុងសទ្ទគន្ថៈ ( គម្ពីរស័ព្ទ ) ក៏មានសេចក្ដីយ៉ាងនោះដូចគ្នា ។ ក្នុងព្រះសូត្រនេះ លោកពោលដល់អនត្តលក្ខណសូត្រ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេសដូចទៅនេះ ។ លោកលើកបទមាតិកា ២៥ បទជាដើមថា **សុញ្ញំ សុញ្ញំ** ឡើងដោយភ្ជាប់ពាក្យថាសូន្យ ហើយសម្ដែងមានបទមាតិកាទាំងនោះ ។

គប្បីជ្រាបសេចក្ដីក្នុងមាតិកានោះ ដូចតទៅនេះ ។ ឈ្មោះថា **សុញ្ញំ សុញ្ញំ** ព្រោះសូន្យ គឺ ទទេ មិនប្លែកពីបទដទៃ ។ ក៏ក្នុងបទនេះ ព្រោះមិនសម្ដែងថា **អសុកំ** ឯណោះ លោកមិនសម្លឹងដល់សភាពសូន្យ ហើយទើបធ្វើឲ្យជាពាក្យនបុំសកលិង្គ ។ បទដ៏សេសក៏យ៉ាងនោះ ។ ឈ្មោះថា **សង្ខារសូន្យ** ព្រោះសង្ខារនោះឯង សូន្យចាកសង្ខារដ៏សេស ។



ឈ្មោះថា **វិបរិណាម សុញ្ញ** ព្រោះសូន្យខុសធម្មតា ផ្លាស់ប្ដូរ ប្រែប្រួលទៅដោយជរា និងការរលត់ សូន្យព្រោះវិបរិណាមធម៌នោះ ។ ឈ្មោះថា **អគ្គសុញ្ញ** ព្រោះអគ្គបទនោះ ប្រសើរចាកខ្លួន និងចាកវត្ថុដែលជារបស់ខ្លួន ឬសូន្យចាកសង្ខារទាំងពួង ។ ឈ្មោះថា **លក្ខណសុញ្ញ** ព្រោះលក្ខណៈនោះឯង សូន្យចាកលក្ខណៈដ៏សេស ។ ឈ្មោះថា **វិក្ខម្ភនសុញ្ញ** ព្រោះសូន្យ ព្រោះការគ្របសង្កត់ មាននេក្ខម្មៈជាដើម ។ សូម្បីក្នុងសុញ្ញៈ ៤ មាន តទង្គសុញ្ញៈ ( សូន្យព្រោះអង្គនោះ ៗ ) ជាដើម មានន័យនេះដូចគ្នា ។ ឈ្មោះថា **អជ្ឈត្តសុញ្ញ** ( ខាងក្នុងសូន្យ ) ព្រោះខាងក្នុងនោះ សូន្យចាកខ្លួន និងចាកវត្ថុដែលជារបស់ខ្លួនជាដើម ។ ឈ្មោះថា **ពហិទ្ធាសុញ្ញ** ( ខាងក្រៅសូន្យ ) ព្រោះខាងក្រៅនោះសូន្យចាកខ្លួន និងចាកវត្ថុដែលជារបស់ខ្លួនជាដើម ។ ឈ្មោះថា **ទុភតោសុញ្ញ** ទាំងខាងក្នុង និងខាងក្រៅសូន្យ ព្រោះទាំងពីរនោះសូន្យចាកខ្លួន និងចាកវត្ថុដែលជារបស់ខ្លួនជាដើម ។ ឈ្មោះថា **សភាគសុញ្ញ** ( ចំណែកស្មើគ្នាសូន្យ ) ព្រោះសភាគមានចំណែកស្មើគ្នា សភាគនោះ សូន្យចាកខ្លួន និងចាកវត្ថុជារបស់ខ្លួនជាដើម សេចក្ដីថា សូន្យដូចគ្នា ។ ឈ្មោះថា **វិសភាគសុញ្ញ** ( ចំណែកដែលមិនស្មើគ្នាសូន្យ ) ព្រោះវិសភាគនោះ ប្រាសចាកចំណែកស្មើគ្នា វិសភាគៈនោះ សូន្យចាកខ្លួន និងចាកវត្ថុជា

របស់ខ្លួន សេចក្ដីថា សូន្យមិនដូចគ្នា ។ ក្នុងគម្ពីរខ្លះសរសេរទុកថា **សភាគសុញ្ញំ វិសភាគសុញ្ញំ** នៅក្នុងលំដាប់ **និស្សរណសុញ្ញំ** ( សូន្យព្រោះរលាស់ចេញ ) ។ ឈ្មោះថា **ឯសនាសុញ្ញ** ( ការស្វែងរកសូន្យ ) ព្រោះការស្វែងរកនេក្ខម្មៈជាដើម សូន្យចាកកាមច្ឆន្ទៈជាដើម ។ សូម្បីក្នុងសុញ្ញៈ ៣ មាន **បរិគ្គហសុញ្ញ** ( ការកំណត់សូន្យ ) ជាដើម ក៏មានន័យនេះដូចគ្នា ឈ្មោះថា **ឯកត្តសុញ្ញ** ( ការប្រាកដតែមួយសូន្យ ) ព្រោះភាពតែមួយនោះ សូន្យចាកសភាពផ្សេងគ្នា ព្រោះតាំងនៅក្នុងអារម្មណ៍តែមួយ ព្រោះមិនមានការរាយមាយក្នុងអារម្មណ៍ផ្សេង ៗ គ្នា ។ ឈ្មោះថា **នានត្តសុញ្ញ** ( ភាពផ្សេង ៗ សូន្យ ) ព្រោះសភាពផ្សេង ៗ នោះ សូន្យចាកភាពតែមួយ ព្រោះផ្ទុយគ្នានឹងភាពតែមួយនោះ ។ ឈ្មោះថា **ខន្តិសុញ្ញ** ព្រោះសេចក្ដីអត់ធន់ក្នុង នេក្ខម្មៈជាដើម សូន្យចាកកាមច្ឆន្ទៈជាដើម **អធិដ្ឋានសុញ្ញ** និង **បរិយោគាហនសុញ្ញ** មានន័យដូចគ្នា ។ បទថា **សម្បជានស្ស** អ្នកមានសម្បជញ្ញៈ គឺ ព្រះអរហន្តដែលបរិនិព្វានប្រកបដោយសម្បជញ្ញៈ ។ បទថា **បវត្តបរិយាទានំ** គ្របសង្កត់ការប្រព្រឹត្តទៅ គឺ អនុបាទាបរិនិព្វាន ( បរិនិព្វានព្រោះមិនកើតទៀត ) ។ បទថា **សព្វសុញ្ញតានំ** គឺ ក្រៃលែងជាងការសូន្យទាំងពួង ។ បទថា **បរមត្ថសុញ្ញំ** គឺ ការសូន្យដែលជាប្រយោជន៍ខ្ពង់ខ្ពស់ ព្រោះមិនមាន



សង្ខារទាំងពួង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមាតិកានិទ្ទេស ដូចតទៅនេះ ។ បទថា **និច្ចេន វា** ចាកការទៀង គឺ សូន្យចាកការទៀង ព្រោះមិនមានការទៀងណា ៗ ដែលឈានកន្លងការរលត់ ហើយប្រព្រឹត្តទៅបាន ។ បទថា **ធុវេន វា** ចាកការយូរអង្វែង គឺ សូន្យការយឺតយូរ ព្រោះមិនមានការស្ថិតស្ថេរណា ៗ ដែលប្រព្រឹត្តទៅជាប់ដោយបច្ច័យ សូម្បីកាលដែលមានហើយ ។ បទថា **សស្សតេន វា** ចាកសេចក្ដីស្ថិតស្ថេរ គឺ សូន្យចាកការទៀង ព្រោះមិនមានអ្វី ៗ ដែលមានហើយក្នុងកាលទាំងពួង ដែលកាត់ផ្ដាច់ទៅហើយ ។ បទថា **អវិបរិណាមធម្មេន វា** ចាកការមិនប្រែប្រួលជាធម្មតា គឺ សូន្យចាក ការមិនប្រែប្រួលជាធម្មតា ព្រោះមិនមានអ្វី ៗ ដែលប្រក្រតី និងមិនប្រែប្រួលទៅដោយ ការរលត់ កាលពោលដល់ការសូន្យចាកខ្លួន ដោយព្រះសូត្រហើយ ដើម្បីសម្ដែងការសូន្យចាកភាពជារបស់ទៀង និងសូន្យចាកសេចក្ដីសុខ លោកពោលដល់បទជាដើមថា **និច្ចេន វា** ទុកក្នុងទីនេះ ។ កាលពោលដល់សេចក្ដីសូន្យចាកភាពជារបស់ទៀង ព្រោះភាពជារបស់មិនទៀង ជាទុក្ខ ដោយត្រូវបៀតបៀន លោកពោលដល់សេចក្ដីសូន្យចាកសេចក្ដីសុខផង ។ ក៏គប្បីជ្រាបថា លោកសង្ខេបវិស័យ ៦ មានរូបជាដើម វិញ្ញាណ ៦ មាន

ចក្ខុវិញ្ញាណជាដើម ផស្សៈ ៦ មាន ចក្ខុសម្ផស្សៈជាដើម និងវេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម ទុកក្នុងទីនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **បុញ្ញាភិសង្ខារោ** ដូចតទៅនេះ ឈ្មោះថា **បុញ្ញ** ព្រោះជម្រះការធ្វើរបស់ខ្លួន ព្រោះញុំាងអជ្ឈាស្រ័យរបស់បុគ្គលនោះឲ្យពេញ និងញុំាងសេចក្ដីចម្រើនដែលគួរបូជាឲ្យកើត ។ ឈ្មោះថា **អភិសង្ខារ** ព្រោះតាក់តែងវិបាក និងកដត្តារូប ។ ការតាក់តែងបុណ្យ ឈ្មោះថា **បុញ្ញាភិសង្ខារ** ការតាក់តែងបាបដោយផ្ទុយនឹងបុញ្ញាភិសង្ខារ ឈ្មោះថា **អបុញ្ញាភិសង្ខារ** ។ ឈ្មោះថា **អនេញ្ជាភិសង្ខារ** ព្រោះតាក់តែងការមិនញាប់ញ័រ ។

បុញ្ញាភិសង្ខារមានចេតនា ១៣ គឺ កាមាវចរកុសលចេតនា ៨ ប្រព្រឹត្តទៅដោយអំណាចនៃទាន សីល ភាវនាជាដើម និងរូបាវចរកុសលចេតនា ៥ ប្រព្រឹត្តទៅដោយអំណាចនៃភាវនា ។ អបុញ្ញាភិសង្ខារ មានអកុសលចេតនា ១២ ប្រព្រឹត្តទៅដោយអំណាចនៃបាណាតិបាតជាដើម ។ អនេញ្ជាភិសង្ខារ មានអរូបាវចរចេតនា ៤ ប្រព្រឹត្តទៅដោយអំណាចនៃភាវនាប៉ុណ្ណោះ ព្រោះហេតុនោះ សង្ខារ ៣ មានចេតនា ២៩ ។

ក្នុងកាយសង្ខារជាដើម មានសេចក្ដីដូច្នេះ ។ ឈ្មោះថា **កាយសង្ខារ** ព្រោះប្រព្រឹត្តទៅតាមផ្លូវកាយ ឬតាក់តែងកាយ ។ សូម្បីក្នុង



**វចីសង្ខារ** និង **ចិត្តសង្ខារ** ក៏មានន័យនេះដូចគ្នា ។ លោកពោលតិកៈនេះ ដើម្បីឲ្យឃើញការប្រព្រឹត្តទៅ តាមផ្លូវទ្វារនៃបុញ្ញាភិសង្ខារជាដើម ក្នុងខណៈប្រមូលកម្មទុក ។

ចេតនា ២១ គឺ កាមាវចរកុសលចេតនា ៨ អកុសលចេតនា ១២ អភិញ្ញាចេតនា ១ ញុំាងកាយវិញ្ញត្តិ ( ឲ្យដឹងតាមផ្លូវកាយ ) ឲ្យតាំងឡើង ហើយប្រព្រឹត្តទៅតាមទ្វារកាយ ឈ្មោះថា កាយសង្ខារ ។ ចេតនានោះឯងញុំាង វចីវិញ្ញត្តិ ( ឲ្យដឹងតាមផ្លូវវាចា ) ឲ្យតាំងឡើង ឲ្យប្រព្រឹត្តទៅតាមវចីទ្វារ ឈ្មោះថា វចីសង្ខារ ។ ចំណែកចេតនា ២៩ សូម្បីទាំងអស់ប្រព្រឹត្តទៅក្នុងមនោទ្វារ ឈ្មោះថា ចិត្តសង្ខារ ។

ក្នុងបទជាដើមថា **អតីតា សង្ខារា** សង្ខារចំណែកអតីតៈ មានសេចក្ដីដូចតទៅនេះ ។ សង្ខតធម៌សូម្បីទាំងអស់ លុះកាលខ្លួនរលត់ទៅ ឈ្មោះថា សង្ខារចំណែកអតីតៈ ។ សង្ខតធម៌មិនទាន់មកដល់ខ្លួន ឈ្មោះថា សង្ខារចំណែកអនាគត ។ សង្ខតធម៌ដល់កាលរបស់ខ្លួន ឈ្មោះថា សង្ខារចំណែកបច្ចុប្បន្ន ។ ព្រះមានព្រះភាគជាម្ចាស់ គ្រាទ្រង់សម្ដែងដល់សង្ខារចំណែកបច្ចុប្បន្នក្នុងការសូន្យ ព្រោះការប្រែប្រួលហើយ ទើបទ្រង់សម្ដែងបច្ចុប្បន្នធម៌មុនថា ការប្រែប្រួលរបស់សង្ខារចំណែក បច្ចុប្បន្ននោះ ៗ អាចពោលបានងាយ ។

ក្នុងបទទាំងនោះ បទថា **ជាតំ រូបំ** រូបកើតហើយ គឺ រូបចំណែកបច្ចុប្បន្ន ។ គប្បីជ្រាបសេចក្ដីក្នុងបទនេះ **សភាវេន សុញ្ញំ** សូន្យចាកសភាវៈដូចតទៅនេះ ។ ការកើតឯងឈ្មោះថា **សភាវ** អធិប្បាយថា កើតឯង ឬសភាពរបស់ខ្លួន ឈ្មោះថា **សភាវ** អធិប្បាយថា ការកើតរបស់ខ្លួនឯង ។ ឈ្មោះថា សូន្យចាកសភាវៈ ព្រោះការកើតឯងវៀរបច្ច័យមិនបាន ព្រោះប្រព្រឹត្តទៅជាប់ដោយបច្ច័យ ឬភាពជារបស់ខ្លួនមិនមានក្នុងសភាវៈនេះ លោកអធិប្បាយថា សូន្យចាកការកើតឯងឬចាកភាពជាខ្លួន ។ ម្យ៉ាងទៀត ភាពជារបស់ខ្លួន ឈ្មោះថា សភាវៈព្រោះជាធម៌នីមួយ ៗ ក្នុងរូបធម៌មួយ ៗ និងអរូបធម៌ច្រើន មានបឋវីធាតុជាដើម ឈ្មោះថា ខ្លួន ប្រាថ្នាយកអ្នកដទៃផង ។ ក៏បទថា **ភាវោ** នេះជាពាក្យពោលដោយធម្មបរិយាយ ។ ធម៌ គឺ សភាវៈដទៃមិនមានដល់ធម៌មួយ ព្រោះដូច្នោះ ឈ្មោះថា សូន្យចាកសភាវៈដទៃរបស់ខ្លួនដោយហេតុនោះ លោកទើបពោលសេចក្ដីនៃធម៌នោះ ជាសភាវៈតែមួយដូចគ្នា ។

ម្យ៉ាងទៀត បទថា **សភាវេន សុញ្ញំ** សូន្យចាកសភាវៈ គឺ សូន្យចាកសភាពដែលសូន្យ ។ លោកអធិប្បាយទុកយ៉ាងណា លោកអធិប្បាយទុកថា សូន្យព្រោះជាសភាវៈសូន្យ សូន្យមិនមែនសូន្យព្រោះ



ជាសភាវៈសូន្យដោយបរិយាយយ៉ាងដទៃ ។

បើអាចារ្យពួកខ្លះគប្បីពោលថា ភាពជាខ្លួន ឈ្មោះថា សភាវៈសូន្យចាកសភាវៈនោះ ។ អធិប្បាយទុកយ៉ាងណា ។ ធម៌ឈ្មោះថា **ភាវ** ភាវៈនោះបន្ថែមបទ **ស** ចូលទៅបំណងយកអ្នកដទៃ ទើបជាសភាវៈ ។ ព្រោះធម៌មិនមានដល់នរណា លោកទើបពោលការមិនមាននៃរូបថា រូបកើតហើយ សូន្យចាកសភាវៈ ដូច្នេះ ។ កាលបើដូច្នោះ រមែងខុសដោយពាក្យថា **ជាតំ រូបំ** រូបកើតហើយ ។ ព្រោះរូបប្រាសចាកការកើតនឹងឈ្មោះថា រូបកើតហើយមិនបាន ។ និព្វាន ប្រាសចាកការកើត និព្វាននោះ ទើបមិនឈ្មោះថា កើតហើយ ។ ម្យ៉ាងទៀត ជាតិ ជរា និងមរណៈ ប្រាសចាកការកើត ក៏មិនឈ្មោះថា កើតហើយ ។ ដោយហេតុនោះឯង ក្នុងបទនេះ លោកទើបមិនលើកឡើងយ៉ាងនេះថា ជាតិកើតហើយ សូន្យចាកសភាវៈ ជរាមរណៈកើតហើយ សូន្យចាកសភាវៈ ហើយទើបសម្ដែងភពនោះឯងឲ្យជាទីបំផុត ។

ប្រសិនបើមានពាក្យថា **ជាតំ** កើតហើយ គប្បីគួរដល់អ្នកប្រាសចាកការកើត ក៏គួរពោលបានថា **ជាតា ជាតិ ជាតំ ជរាមរណំ** ជាតិកើតហើយ ជរា និងមរណៈកើតហើយ ព្រោះបើ ជាតិ ជរា និងមរណៈប្រាសចាកការកើត លោកក៏មិនពោលពាក្យថា **ជាតិ** ដូច្នោះ ពាក្យថា

**សុញ្ញំ** គឺ មិនមានសភាវៈ ទើបខុសដោយពាក្យ **ជាតំ** ព្រោះប្រាសចាកការកើតនៃការមិនមាន ។ មយ៉ាងទៀត បើមិនមានពាក្យថា **សុញ្ញំ** ក៏ខុសជាមួយពាក្យរបស់សត្វលោក ដែលពោលហើយក្នុងខាងក្រោយដោយព្រះតម្រាស់របស់ព្រះមានព្រះភាគជាម្ចាស់ និងដោយពាក្យញេយ្យ-គន្ថៈ និងសទ្ទគន្ថៈ និងខុសជាមួយយុត្តិយ៉ាងច្រើន ព្រោះដូច្នោះ គប្បីលះបង់ពាក្យនោះ ដូចចោលសំរាម ។ ក្នុងបទនេះ ជាការត្រឹមត្រូវថា ធម៌ទាំងឡាយមាននៅក្នុងខណៈរបស់ខ្លួន ដោយប្រមាណនូវព្រះពុទ្ធ-វចនៈដ៏ច្រើន និងដោយត្រឹមត្រូវច្រើនជាដើមថា ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលបណ្ឌិតទាំងឡាយក្នុងលោកសន្មតថា មានហើយ សូម្បីតថាគតក៏ពោលថាវត្ថុនោះមានហើយ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលបណ្ឌិតទាំងឡាយក្នុងលោកសន្មតថា មិនមាន តថាគតក៏ពោលថា វត្ថុនោះមិនមាន ។ ម្នាលភិក្ខុទាំងឡាយ វត្ថុណាមួយដែលបណ្ឌិតទាំងឡាយក្នុងលោកសន្មត់ថាមាន តថាគតក៏ពោលថា វត្ថុនោះមាន ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា ដែលបណ្ឌិតទាំងឡាយក្នុងលោកសន្មតថាមាន សូម្បីតថាគតក៏ពោលថា វត្ថុនោះមាន ។

បទថា **វិគតំ រូបំ** រូបប្រាសទៅ គឺ រូបចំណែកអតីតៈរលត់



ព្រោះកើតហើយដល់នូវការបែកធ្លាយ ។ បទថា **វិបរិណតញ្ចេវ សុញ្ញញ្ច** រូបប្រែប្រួលទៅ និងសូន្យទៅ គឺ រូបដល់ការខុសប្លែក ការប្រែប្រួលដោយជរា និងការរលត់ និងសូន្យចាកការប្រែប្រួលនោះ ព្រោះប្រាកដការប្រែប្រួលនៃរូបដែលកំពុងប្រព្រឹត្តទៅ ព្រោះមិនមានការប្រែប្រួលនៃរូបចំណែកអតីតៈ ។

សូម្បីក្នុងបទថា **ជាតា វេទនា** វេទនាកើតហើយជាដើម ក៏មានន័យនោះដូចគ្នា ។ មយ៉ាងទៀត ជាតិ ជរា និងមរណៈ មិនគួរក្នុងទីនេះ ដោយមិនបាននូវសភាវៈរបស់ខ្លួន ព្រោះមិនទាន់សម្រេច ព្រោះដូច្នោះ លោកទើបលះបង់ន័យទាំងពីរ មានជាអាទិ៍ថា ជាតិកើតឡើងហើយ ជរា និងមរណៈកើតហើយ ហើយធ្វើន័យមានភពជាដើមនោះឯង ឲ្យជាទីបំផុតទុក ។

បទថា **អគ្គំ** គឺ ជាអ្នកនៅក្នុងភាពដ៏ប្រសើរ ។ បទថា **សេដ្ឋំ** គឺ គួរសរសើរយ៉ាងក្រៃលែង ។ បទថា **វិសិដ្ឋំ** គឺ វិសេសយ៉ាងក្រៃលែង អាការ ៣ យ៉ាងនោះ គឺ **អគ្គំ សេដ្ឋំ វិសិដ្ឋំ** បានដល់ និព្វានដ៏ប្រសើរ ឈ្មោះថា **បទំ** ព្រោះការបដិបត្តិដោយសម្មាបដិបទា ។ បទថា **យទិទំ** កាត់បទជា **យំ ឥទំ** ។ ឥឡូវនេះ ព្រះអានន្ទត្ថេរសម្តែងដល់និព្វាន ដែលគួរពោលទុក ព្រោះការស្ងប់សង្ខារទាំងពួង រមែងមានបាន ព្រោះ

អាស្រ័យនិព្វាន ការលះឧបធិទាំងឡាយ ដែលបានដល់ ខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ កាមគុណូបធិ រមែងមានបាន ការអស់តណ្ហា ការប្រាសចាកកិលេស និងការរលត់ រមែងមានបាន ដូច្នោះ លោកទើបពោលថា **សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ** ការស្ងប់សង្ខារទាំងពួង ការលះឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកកិលេស ការរលត់ ។ បទថា **និព្វានំ** គឺ ចេញចាកសភាវលក្ខណៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងលក្ខណៈទាំងឡាយដូចតទៅនេះ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ ពាលនិមិត្ត ពាលបទាន ( រឿងរ៉ាវរបស់បុគ្គលពាល ) របស់បុគ្គលពាលមាន ៣ យ៉ាង ។ ៣ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលក្នុងលោកនេះ មានការគិតអាក្រក់ និយាយអាក្រក់ និងធ្វើកម្មអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ៣ យ៉ាងទាំងនោះឯង ជាពាលលក្ខណៈ ពាលនិមិត្ត ពាលបទាន របស់បុគ្គលពាល ។

ពាលលក្ខណៈ ៣ យ៉ាង របស់បុគ្គលពាល បណ្ឌិតទាំងឡាយ ហៅថា **ពាល** ព្រោះលក្ខណៈរបស់ខ្លួន ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ



បណ្ឌិតលក្ខណៈ បណ្ឌិតនិមិត្ត បណ្ឌិតបទាន ( រឿងរ៉ាវរបស់បណ្ឌិត ) របស់បណ្ឌិតមាន ៣ យ៉ាង ទាំងនេះ ។ ៣ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតក្នុងលោកនេះ គិតល្អ និយាយល្អ និងធ្វើកម្មល្អ ។ ម្នាលភិក្ខុទាំងឡាយ ៣ យ៉ាង ទាំងនេះឯង ជាបណ្ឌិតលក្ខណៈ បណ្ឌិតនិមិត្ត និងបណ្ឌិតបទាន របស់បណ្ឌិត ។ បណ្ឌិតលក្ខណៈ ៣ យ៉ាង របស់បណ្ឌិត បណ្ឌិតទាំងឡាយ ហៅថា **បណ្ឌិត** ព្រោះលក្ខណៈរបស់ខ្លួន ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សង្ខតលក្ខណៈនៃសង្ខតធម៌ ៣ ទាំងនេះ ៣ យ៉ាងទាំងនេះ ដូចម្តេច ។ ការកើតប្រាកដ ១ ការវិនាសប្រាកដ ១ ការប្រែប្រួលចាកការតាំងនៅប្រាកដ ១ ។ ម្នាលភិក្ខុទាំងឡាយ ៣ យ៉ាង ទាំងនោះឯង ជាសង្ខតលក្ខណៈនៃសង្ខតធម៌ ។

ដោយបទនេះ លោកសម្តែងដល់ការមិនមានលក្ខណៈ ២ ដ៏សេសក្នុងខណៈកើត , លក្ខណៈ ២ ដ៏សេសក្នុងខណៈតាំងនៅ , លក្ខណៈ ២ ដ៏សេសក្នុងខណៈរលត់ ។ ម្យ៉ាងទៀត ក្នុងបទនេះ លោកពោលដល់លក្ខណៈមានការកើតជាដើម នៃជាតិ និងជរាមរណៈ ដោយបេយ្យាលមុខ ។ លក្ខណៈនោះ លះជាតិ ជរា និងមរណៈចេញ ព្រោះសូន្យ

ចាកការប្រែប្រួល ទើបឃ្លៀងឃ្លាតជាមួយអត្ថន័យ នៃការមានភពជាទីបំផុត និងដោយលទ្ធិដែលមិននិយាយដល់ការកើតជាដើម នៃការកើតជាដើម ។ តែព្រោះធ្លាក់ទៅក្នុងក្រសែលក្ខណៈ គប្បីជ្រាបថា លោកសរសេរធ្វើឲ្យធ្លាក់ទៅក្នុងក្រសែ ។ ម្យ៉ាងទៀត លោកពោលថា ក្នុងអភិធម្មមិនបានលើកឡើងថា អង្គនៃឈាន សូម្បីបានក្នុងសង្គហវារៈនៃមនោធាតុ និងមនោវិញ្ញាណធាតុ ដែលជាអហេតុកវិបាក ក៏ធ្លាក់ទៅក្នុងក្រសែនៃវិញ្ញាណ ៥ យ៉ាងណា សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបសេចក្ដីដែលជាលក្ខណៈធ្លាក់ទៅក្នុងក្រសែដូច្នោះ ។

ម្យ៉ាងទៀត ការកើតជាដើមនៃសង្ខារទាំងឡាយ ដែលមានជាតិ ជរា និងមរណៈ គប្បីជ្រាបលោកពោលធ្វើសង្ខារទាំងនោះ ដូចក្នុងបទថា ឃើញជាតិ ជរា និងមរណៈ ដោយសភាពមិនទៀង ។

បទថា **នេក្ខម្មេន កាមច្ឆន្ទោ វិក្ខម្ភិតោ ចេវ សុញ្ញោ ច** កាមច្ឆន្ទៈ ដែលនេក្ខម្មៈគ្របសង្កត់ហើយនិងសូន្យទៅ គឺ កាមច្ឆន្ទៈដែលនេក្ខម្មៈគ្របសង្កត់ហើយ និងសូន្យទៅ ព្រោះនេក្ខម្មៈ ពោលគឺការដែលនេក្ខម្មៈនោះឯងគ្របសង្កត់ ព្រោះមិនមាននេក្ខម្មៈក្នុងកាមច្ឆន្ទៈនោះ ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីធ្វើការប្រកបយ៉ាងនោះ ។ ម្យ៉ាងទៀត សូម្បីក្នុងតទង្គប្បហាន និងសមុច្ឆេទប្បហាន លោកក៏



ពោលដោយការគ្របសង្កត់ ដោយអត្ថថា ធ្វើឲ្យឆ្ងាយ ដោយបទនេះថា លះដោយតទង្គៈ និងសមុច្ឆេទ ដែលធ្វើឲ្យឆ្ងាយហើយនោះឯង ។

បទថា **នេក្ខម្មេន កាមច្ឆន្ទោ តទង្គសុញ្ញោ** កាមច្ឆន្ទៈ ជាតទង្គសុញ្ញៈ ( សូន្យព្រោះអង្គនោះ ៗ ) ព្រោះនេក្ខម្មៈ គឺ កាមច្ឆន្ទៈលះបានដោយនេក្ខម្មៈ សូន្យដោយអង្គ គឺ នេក្ខម្មៈនោះ ។ ម្យ៉ាងទៀត កាមច្ឆន្ទៈណាមួយ សូន្យទៅដោយអង្គនោះដែលជានេក្ខម្មៈ ព្រោះមិនមាននេក្ខម្មៈជាកាមច្ឆន្ទៈនោះ ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីជ្រាបការប្រកបយ៉ាងនោះ ។ ក៏ក្នុងបទនេះ លោកសម្ដែងភាពសូន្យដោយអង្គនោះ ៗ ដោយឧបចារៈឈាន និងអប្បនាឈាន និងដោយ វិបស្សនាត្រឹមតែការមិនមានអង្គនោះ ៗ ក្នុងកាមច្ឆន្ទៈនោះ ៗ ប៉ុន្តែលោកសម្ដែងវិបស្សនា ធ្វើវិវដ្ដានុបស្សនា ( ការឃើញនិព្វាន ) ឲ្យជាទីបំផុត ព្រោះមិនមានពាក្យសម្ដែងដល់ការលះ លោកមិនសម្ដែងដល់មគ្គ ៤ ។

ក្នុងបទជាដើមថា **នេក្ខម្មេន កាមច្ឆន្ទោ សមុច្ឆិន្នោ ចេវ សុញ្ញោ ច** កាមច្ឆន្ទៈ ដែលនេក្ខម្មៈកាត់ផ្ដាច់ហើយ និងសូន្យទៅ គប្បីជ្រាបអត្ថក្នុងបទនេះដោយន័យដូចពោលហើយក្នុងវិក្ខម្ភនៈ ( ការគ្របសង្កត់ ) នោះឯង ។ លោកពោលដល់សមុច្ឆេទ ( ការកាត់ផ្ដាច់ ) ដោយបរិយាយនេះថា នីវរណៈទាំងឡាយ សូម្បីលះហើយដោយតទង្គៈ និងវិក្ខម្ភនៈ

ក៏ឈ្មោះថា កាត់ផ្តាច់ហើយ ព្រោះមិនមានការប្រាកដឡើង គប្បីជ្រាបថា លោកពោលដោយអំណាចឲ្យសម្រេចក្នុងការកាត់ផ្តាច់កាមច្ឆន្ទៈនោះ ៗ ឬ ដោយអំណាចនេក្ខម្មៈ ដែលសម្បយុត្តដោយមគ្គជាដើម ។

ម្យ៉ាងទៀត **ក្នុងបដិប្បស្សទ្ធិសុញ្ញ** ( សូន្យព្រោះរម្ងាប់ ) និង **និស្សរណសុញ្ញ** ( សូន្យព្រោះរលាស់ចេញ ) គប្បីជ្រាបអត្ថតាមន័យ ដូចពោលហើយក្នុងបទនេះនោះឯង ។ ចំណែកក្នុងតទង្គប្បហាន វិក្ខម្ភនប្បហាន និងសមុច្ឆេទប្បហាន លោកពោលកាន់យកត្រឹមតែការរលាស់ចេញ ព្រោះត្រឹមតែរម្ងាប់ក្នុងបទនេះ ។ ក្នុងសុញ្ញៈ ៥ ទាំងនេះ នេក្ខម្មៈជាដើម លោកពោលដោយឈ្មោះថា វិក្ខម្ភនសុញ្ញៈ តទង្គសុញ្ញៈ សមុច្ឆេទសុញ្ញៈ បដិប្បស្សទ្ធិសុញ្ញៈ និងនិស្សរណសុញ្ញៈ ។ បទថា **អជ្ឈត្តំ** គឺ មានក្នុងខាងក្នុង ។ បទថា **ពហិទ្ធា** គឺ មានក្នុងខាងក្រៅ ។ បទថា **ទុភតោសុញ្ញំ** គឺ សូន្យទាំងខាងក្នុង និងខាងក្រៅ ។ ពាក្យថា **តោ** រមែងមានសូម្បីក្នុងបច្ចត្តៈ (បឋមាវិភត្តិ ) ជាដើម ។

អាយតនៈខាងក្នុង ៦ ជាដើម ជាចំណែកស្មើគ្នា ដោយភាពជាអាយតនៈខាងក្នុង ៦ ជាដើម ជាចំណែកមិនស្មើគ្នាដោយអាយតនៈទាំងឡាយដទៃ ។ ម្យ៉ាងទៀត បទជាដើមថា **វិញ្ញាណកាយា** ដោយពួកវិញ្ញាណ ក្នុងទីនេះលោកពោលដល់វិញ្ញាណជាដើម ដោយពាក្យថា **កាយ** ។ ក្នុង **នេក្ខម្មេសនា** ( ការស្វែងរកនេក្ខម្មៈ ) ជាដើម គប្បីជ្រាប



សេចក្តីដូចតទៅនេះ ។ ឈ្មោះថា **ឯសនា** ព្រោះវិញ្ញូជនទាំងឡាយអ្នកមានសេចក្តីត្រូវការនេក្ខម្មៈនោះ រមែងស្វែងរកនេក្ខម្មៈនោះឯង ។

ម្យ៉ាងទៀត សូម្បីការស្វែងរកនេក្ខម្មៈជាដើម ក្នុងចំណែកខាងដើម ក៏សូន្យចាកកាមច្ឆន្ទៈជាដើម ។ លោកអធិប្បាយថា សូម្បីនេក្ខម្មៈជាដើម ក៏មិនចាំបាច់ពោល ។ ក្នុង **បរិគ្គហ** ( ការកំណត់ ) ជាដើម គប្បីជ្រាបសេចក្តីដូចតទៅនេះ ។ លោកពោលថា ឈ្មោះថា **បរិគ្គហ** ព្រោះវិញ្ញូជនស្វែងរកនេក្ខម្មៈជាដើមក្នុងចំណែកខាងដើម កំណត់យកក្នុងចំណែកខាងចុង ឈ្មោះថា **បដិលាភ** ( ការបាន ) ព្រោះវិញ្ញូជនកំណត់យកនេក្ខម្មៈ រមែងបានដោយការសម្រេច និងឈ្មោះថា **បដិវេធ** ( ការចាក់ធ្លុះ ) ព្រោះវិញ្ញូជនបាននេក្ខម្មៈ ហើយរមែងចាក់ធ្លុះដោយញាណ ។

ព្រះអានន្ទត្ថេរ សួរដល់សភាវៈតែមួយសូន្យ និងសភាវៈផ្សេង ៗ សូន្យក្នុងគ្រាតែមួយ ហើយដោះស្រាយសភាវៈតែមួយសូន្យ មិនដោះស្រាយសភាវៈផ្សេង ៗ សូន្យ ហើយធ្វើការសរុបក្នុងគ្រាតែមួយជាមួយគ្នា ។ ប្រសិនបើសួរថា ព្រោះហេតុអ្វីទើបមិនដោះស្រាយ ។ ឆ្លើយថា គប្បីជ្រាបថា មិនដោះស្រាយ ព្រោះលោកសម្លឹងដល់ការប្រកបក្នុងបទនេះ ដោយបរិយាយដូចពោលហើយ ។ ម្យ៉ាងទៀត ក្នុងបទនេះគប្បីជ្រាបការប្រកបដូច្នេះ នេក្ខម្មៈដូចគ្នា កាមច្ឆន្ទៈមានសភាពផ្សេងគ្នា

កាមច្ឆន្ទៈមានសភាពផ្សេងគ្នា សូន្យចាកសភាវៈដូចគ្នា គឺ នេក្ខម្មៈ ។ សូម្បីក្នុងបទដ៏សេស គប្បីជ្រាបការប្រកបយ៉ាងនេះ ។

ក្នុងបទជាដើមថា **ខន្តិ** គប្បីជ្រាបសេចក្ដីដូចតទៅនេះ ។ នេក្ខម្មៈជាដើម លោកពោលថា **ខន្តិ** ព្រោះអត់ធន់ ពេញចិត្ត ពោលថា **អធិដ្ឋាន** ព្រោះចូលទៅតាំងទុកនូវសេចក្ដីពេញចិត្ត និងពោលថា **បរិយោគាហន** ( សេចក្ដីមាំទាំ ) ព្រោះចូលទៅតាំងទុកហើយ សេពតាមសេចក្ដីពេញចិត្ត ។ បរមត្ថសុញ្ញនិទ្ទេសមានជាដើមថា **ឥធ សម្បជានោ** ( ដឹងខ្លួន ) លោកពោល ហើយ ក្នុងបរិនិព្វានញាណនិទ្ទេសនោះឯង ។

ម្យ៉ាងទៀត ក្នុងសុញ្ញៈទាំងអស់នេះ **សង្ខារសុញ្ញ** (សង្ខារសុញ្ញៈ) **វិបរិណាមសុញ្ញ** ( ការប្រែប្រួលសូន្យ ) និង **លក្ខណសុញ្ញ** ( លក្ខណៈសូន្យ ) លោកពោលឲ្យឃើញដល់ការមិនលាយច្រឡំគ្នានឹងគ្នា នៃធម៌ទាំងឡាយ តាមដែលបានពោលទុកហើយ ។

ម្យ៉ាងទៀត លោកពោលដល់ការសូន្យចាកធម៌ចំណែកកុសល នៃធម៌ចំណែកអកុសលក្នុងឋានៈណា ដើម្បីឲ្យឃើញទោសក្នុងអកុសលដោយឋានៈនោះ ។ លោកពោលដល់ការសូន្យចាកធម៌ ចំណែកអកុសល នៃធម៌ចំណែកកុសល ដោយឋានៈណា ដើម្បីឲ្យឃើញអានិសង្សក្នុងកុសលដោយឋានៈនោះ លោកពោលដល់ការសូន្យចាកខ្លួន និងចាកវត្ថុជារបស់ខ្លួនក្នុងឋានៈណា ដើម្បីឲ្យកើតសេចក្ដីនឿយណាយដល់ឋានៈ



នោះ ក្នុងសង្ខារទាំងពួង ។ គប្បីជ្រាបថា លោកពោលដល់ **អគ្គសុញ្ញ** និង **បរមត្ថសុញ្ញ** ដើម្បីឲ្យកើតឧស្សាហៈក្នុងនិព្វាន ។

ក្នុងការសូន្យទាំងនោះ ការសូន្យ ២ យ៉ាង គឺ អគ្គសុញ្ញៈ និងបរមត្ថសុញ្ញៈ ដោយអត្ថ បានដល់ និព្វាននោះឯង លោកពោលធ្វើជា ២ យ៉ាង ដោយអំណាចនៃការប្រសើរ និងមានប្រយោជន៍យ៉ាងក្រៃលែង និងដោយអំណាចនៃសឧបាទិសេស និងអនុបាទិសេស ។ ការសូន្យ ២ យ៉ាងនោះ មានចំណែកស្មើគ្នា ព្រោះសូន្យចាកខ្លួន និងសូន្យចាកវត្ថុជារបស់ខ្លួន និងសូន្យចាកសង្ខារ ។ ការសូន្យ ៦ យ៉ាងទាំងនេះ គឺ សុញ្ញសុន្យ ១ ខាងក្នុងសូន្យ ១ ខាងក្រៅសូន្យ ១ ទាំងខាងក្នុង និងខាងក្រៅសូន្យ ១ ចំណែកស្មើគ្នាសូន្យ ១ និងចំណែកមិនស្មើគ្នាសូន្យ ១ ជាសុញ្ញសុញ្ញៈទាំងអស់ ។ ម្យ៉ាងទៀត លោកពោលការសូន្យ ៦ យ៉ាងដោយប្រភេទ មានខាងក្នុងសូន្យជាដើម ។ ម្យ៉ាងទៀត ការសូន្យ ៦ យ៉ាង ឈ្មោះថា ចំណែកមិនស្មើគ្នា ព្រោះសូន្យចាកខ្លួន និងវត្ថុដែលជារបស់ខ្លួនជាដើម ។

ការសូន្យ ១៧ យ៉ាង គឺ សង្ខារសុញ្ញៈ ១ វិបរិណាមសុញ្ញៈ ១ លក្ខណសុញ្ញៈ ១ វិក្ខម្ភនសុញ្ញៈ ១ តទង្គសុញ្ញៈ ១ សមុច្ឆេទសុញ្ញៈ ១ បដិប្បស្សទ្ធិសុញ្ញៈ ១ និស្សរណសុញ្ញៈ ១ ឯសនាសុញ្ញៈ ១ បរិគ្គហសុញ្ញៈ ១ បដិលាភសុញាៈ ១ បដិវេធសុញ្ញៈ ១ ឯកត្តសុញ្ញៈ ១

នានត្តសុញ្ញៈ ១ ខន្តិសុញ្ញៈ ១ អធិដ្ឋានសុញ្ញៈ ១ បរិយោគាហនសុញ្ញៈ ១ លោកពោលទុកផ្សេងគ្នា ដោយអំណាចនៃការមិនមាន ព្រោះសូន្យធម៌នោះ ៗ ដែលមិនមានខ្លួន ។

ម្យ៉ាងទៀត សង្ខារសុញ្ញៈ វិបរិណាមសុញ្ញៈ លក្ខណៈសុញ្ញៈ មានចំណែកស្មើគ្នាដោយការមិនលាយគ្នា នឹងការសូន្យក្រៅអំពីនោះ ។ ការសូន្យ ៥ យ៉ាង មានវិក្ខម្ភនសុញ្ញៈជាដើម ឈ្មោះថា មានចំណែកស្មើគ្នា ព្រោះការសូន្យដោយធម៌ចំណែកកុសល ។ ការសូន្យ ៤ មានឯសនាសុញ្ញៈ ជាដើម និងការសូន្យ ៣ មានខន្តិសុញ្ញជាដើម ឈ្មោះថា មានចំណែកស្មើគ្នា ព្រោះសូន្យចាកធម៌ចំណែកអកុសល ឯកត្តសុញ្ញៈ និងនានត្តសុញ្ញៈ មានចំណែកស្មើគ្នាដោយផ្ទុយគ្នានឹងគ្នា ។

**បុគ្គលអ្នកដឹងអត្ថនៃការសូន្យ រមែងពណ៌នាទុក**
**ក្នុងសាសនានោះថា ធម៌ទាំងឡាយទាំងពួង**
**ដោយសង្ខេបជាការសូន្យ ៣ ចំណែក ២**
**ចំណែក និង ១ ចំណែក ។**

យ៉ាងណា ធម៌ទាំងពួងដែលជាលោកិយធម៌ ឈ្មោះថា សូន្យចាកការតាំងនៅ ការស្អាត សេចក្ដីសុខ និងតួខ្លួន ព្រោះប្រាសចាកការតាំងនៅ ការស្អាត សេចក្ដីសុខ និងតួខ្លួន ។ ធម៌ដែលជាមគ្គ និងផល ឈ្មោះថា សូន្យចាកការតាំងនៅ សេចក្ដីសុខ និងតួខ្លួន ព្រោះប្រាស



ចាកការតាំងនៅ សេចក្ដីសុខ និងតួខ្លួន សភាវៈមិនទៀងនោះឯង សូន្យចាកសេចក្ដីសុខការមិនមានអាសវៈ សូន្យចាកសេចក្ដីស្អាត ។ និព្វានធម៌ ឈ្មោះថា សូន្យចាកតួខ្លួន ព្រោះមិនមានតួខ្លួន ។ សង្ខតធម៌សូម្បីទាំងអស់ ទាំងលោកិយធម៌ និងលោកុត្តរធម៌ ឈ្មោះថា សូន្យចាកសត្វ ព្រោះមិនមានសត្វណា ៗ ។ និព្វានធម៌ជាអសង្ខតធម៌ ឈ្មោះថា សូន្យចាកសង្ខារធម៌ ព្រោះមិនមានសូម្បីសង្ខារទាំងឡាយនោះ ។ ចំណែកធម៌ទាំងអស់ ទាំងសង្ខតធម៌ និងអសង្ខតធម៌ ឈ្មោះថា សូន្យចាកតួខ្លួន ព្រោះមិនមានបុគ្គល ពោលគឺ តួខ្លួន ដោយប្រការដូច្នេះ ។

**ចប់អដ្ឋកថា សុញ្ញកថា នៃអដ្ឋកថា បដិសម្ភិទាមគ្គ**
**ឈ្មោះថា សទ្ធម្មបកាសិនី និងចប់ការពណ៌នាតាមលំដាប់សេចក្ដី**
**ដែលមិនធ្លាប់វណ្ណនា រួមកថាមានក្នុងវគ្គនេះគឺ ៖**
**១-យុគនទ្ធកថា ២-សច្ចកថា ៣-ពោជ្ឈង្គកថា ៤-មេត្តាកថា**
**៥-វិរាគកថា ៦-បដិសម្ភិទាកថា ៧-ធម្មចក្កកថា ៨-លោកុត្តរកថា**
**៩-ពលកថា ១០-សុញ្ញៈ និងអដ្ឋកថានិកាយដ៏ប្រសើរ**
លោកតាំងទុកហើយជាវរមគ្គដែលប្រសើរទី ២
មិនមានវគ្គដទៃស្មើ ដូច្នេះឯង ។

## ១–អដ្ឋកថា មហាបញ្ញាកថា

## ក្នុងបញ្ញាវគ្គ

ឥឡូវនេះ នឹងពណ៌នាតាមសេចក្តីដែលនៅមិនទាន់បានពណ៌នា នៃបញ្ញាកថា ដែលព្រះសារីបុត្តត្ថេរពោលទុកក្នុងលំដាប់នៃសុញ្ញកថា ដែលជាបទដ្ឋាននៃបញ្ញាដោយពិសេស ។

ខាងដើមក្នុងបញ្ញាកថានោះ បញ្ញា ៧ ប្រការ មានអនុបស្សនាមួយ ៗ ជាមូលក្នុងអនុបស្សនា ៧ ព្រះសារីបុត្តត្ថេរសម្តែង ធ្វើពាក្យសួរឲ្យជាខាងដើមមុន ។ បញ្ញា ៣ មានអនុបស្សនា ៧ ជាមូល និងមានអនុបស្សនាដ៏ក្រៃលែងមួយ ៗ ជាមូល ព្រះសារីបុត្តត្ថេរសម្តែងឡើង ដោយមិនមានពាក្យសួរ ។ ព្រះថេរៈសម្តែងសេចក្តីបរិបូររបស់បញ្ញា ១០ អំពីខាងដើមដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអនុបស្សនាទាំងនោះ ដូចតទៅនេះ ។ ព្រោះ **អនិច្ចានុបស្សនា** ( ការពិចារណាឃើញថាមិនទៀង ) ស្ទុះទៅក្នុងសង្ខារដែលបានឃើញហើយ ដោយភាពមិនទៀង ដោយភាពជាទុក្ខថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ និងដោយភាពជាអនត្តាថា វត្ថុណាជាទុក្ខ វត្ថុនោះជាអនត្តា ដូច្នោះ អនិច្ចានុបស្សនានោះ ដែល



បុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងញុំាង **ជវនបញ្ញា** ( បញ្ញាស្ទុះទៅ ) ឲ្យបរិបូរណ៍ ។ ពិតណាស់ បញ្ញានោះ ឈ្មោះថា **ជវនា** ព្រោះស្ទុះទៅក្នុងវិស័យរបស់ខ្លួន ឈ្មោះថា **ជវនបញ្ញា** ព្រោះបញ្ញានោះស្ទុះទៅ ។

**ទុក្ខានុបស្សនា** ( ការពិចារណាឃើញជាទុក្ខ ) មានកម្លាំងព្រោះអាស្រ័យសមាធិន្ទ្រិយ រមែងជ្រែក រមែងទម្លាយបណិធិ ព្រោះដូច្នោះ ទុក្ខានុបស្សនា រមែងញុំាងនិព្វេធិកបញ្ញា ( បញ្ញាទម្លាយកិលេស ) ឲ្យបរិបូរណ៍ ។ ពិតណាស់ បញ្ញានោះ ឈ្មោះថា **និព្វេធិកា** ព្រោះទម្លាយកិលេស ឈ្មោះថា **និព្វេធិកបញ្ញា** ព្រោះបញ្ញានោះ ទម្លាយកិលេស ។

**អនត្តានុបស្សនា** ( ការពិចារណាឃើញថាជាអនត្តា ) រមែងញុំាងមហាបញ្ញាឲ្យបរិបូរណ៍ ព្រោះការដល់នូវភាពចម្រើន ដោយឃើញសភាពជារបស់សូន្យ ជាការដល់នូវភាពជាធំ ។ ពិតណាស់ បញ្ញានោះ ឈ្មោះថា **មហាបញ្ញា** បញ្ញាធំ ព្រោះដល់នូវសេចក្តីចម្រើន ។

ព្រោះ **និព្វិទានុបស្សនា** ( ការពិចារណាឃើញ ហើយនឿយណាយ ) ជាបញ្ញាដែលចាស់ក្លា អាចនឿយណាយក្នុងសង្ខារទាំងពួង

ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងនៃការមានកម្លាំងដោយអាសេវនៈសូម្បីពីខាងដើម ដូច្នោះ **និព្វិទានុបស្សនា** រមែងញុំាង **តិក្ខប្បញ្ញា** ( បញ្ញាចាស់ក្លា ) ឲ្យបរិបូរណ៍ ។

ព្រោះសូម្បី **វិរាគានុបស្សនា** ( ការពិចារឃើញនូវការប្រាសចាកតម្រេក ) ក៏ទូលំទូលាយ អាចប្រាសចាកតម្រេកពីសង្ខារទាំងពួង ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងដែលចម្រើន ជាងការមានកម្លាំងដោយអាសេវនៈសូម្បីពីខាងដើម ដូច្នោះ វិរាគានុបស្សនា រមែងញុំាង **វិបុលប្បញ្ញា** ( បញ្ញាទូលំទូលាយ ) ឲ្យបរិបូរណ៍ ។

ព្រោះ **និរោធានុបស្សនា** ( ការពិចារណាឃើញការរលត់ ) ក៏ជ្រាលជ្រៅ អាចឃើញការរលត់ទាំងពួង ដោយលក្ខណៈនៃការសូន្យទៅ ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងដែលចម្រើនជាង មានកម្លាំង ដោយអាសេវនៈសូម្បីពីខាងដើម ដូច្នោះ **និរោធានុបស្សនា** រមែងញុំាង **គម្ភីរប្បញ្ញា** ( បញ្ញាដ៏ជ្រាលជ្រៅ ) ឲ្យបរិបូរណ៍ ។ ពិតណាស់ **និរោធ** ឈ្មោះថា **គម្ភីរោ** ព្រោះមិនបានតាំងនៅដោយបញ្ញារាក់ ៗ សូម្បីបញ្ញាដល់ការធ្លាក់ចុះក្នុងសេចក្ដីជ្រាលជ្រៅនោះ ក៏ឈ្មោះថា **គម្ភីរា** ។

សូម្បីព្រោះ **បដិនិស្សគ្គានុបស្សនា** ( ការពិចារណាឃើញការ



លះបង់ ) ជាបញ្ញាមិនជិត អាចលះបង់សង្ខារទាំងពួងដោយលក្ខណៈនៃការសូន្យ ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងដែលចម្រើនជាងការមានកម្លាំង ដោយអាសេវនៈសូម្បីអំពីខាងដើម ព្រោះ **ពុទ្ធិ** រមែង តាំងនៅឆ្ងាយជាងបញ្ញា ៦ ព្រោះនៅមិនទាន់ដល់កំពូល ដូច្នោះ បដិនិស្សគ្គានុបស្សនា រមែងញុំាង **អសាមន្តប្បញ្ញា** ( បញ្ញាមិនជិត ) ឲ្យបរិបូរណ៍ ព្រោះមិនជិតនោះឯង ។ ពិតណាស់ អសាមន្តបញ្ញានោះ ឈ្មោះថា **អសាមន្តា** ព្រោះឆ្ងាយចាកបញ្ញាខាងក្រោម ឈ្មោះថា **អសាមន្តប្បបញ្ញា** ព្រោះបញ្ញាមិនជិត ។

បទថា **បណ្ឌិច្ចំ បូរេន្តិ** គឺ រមែងញុំាងភាវៈជាបណ្ឌិតឲ្យបរិបូរណ៍ ។ ព្រោះបញ្ញា ៧ តាមដែលពោលហើយ ឲ្យចម្រើនបរិបូរណ៍ហើយ ដល់លក្ខណៈរបស់បណ្ឌិត ជាបណ្ឌិតដោយសង្ខារុបេក្ខាញាណ អនុលោមញាណ និងគោត្រកូញាណ ពោលគឺ វុដ្ឋានគាមិនីវិបស្សនា ដែលដល់កំពូល ជាអ្នកប្រកបដោយភាវៈជាបណ្ឌិត ដូច្នោះ លោកទើបពោលថា **បណ្ឌិច្ចំ បូរេន្តិ** រមែងញុំាងភាវៈជាបណ្ឌិតឲ្យបរិបូរណ៍ ។

បទថា **អដ្ឋប្បញ្ញា** គឺ បញ្ញា ៨ ប្រការ ព្រមទាំងបញ្ញា គឺ ភាវៈជាបណ្ឌិត ។ បទថា **បុថុប្បញ្ញំ បរិបូរេន្តិ** រមែងញុំាងបុថុប្បញ្ញា ( បញ្ញាក្រាស់ ) ឲ្យបរិបូរណ៍ គឺ ព្រោះបណ្ឌិតនោះ ជាអ្នកប្រកប

ដោយភាពជាបណ្ឌិតនោះ ធ្វើនិព្វានក្នុងលំដាប់គោត្រភូញាណឲ្យជាអារម្មណ៍ រមែងសម្រេចបញ្ញា គឺ មគ្គផល ដែលពោលថា **បុថុប្បញ្ញា** ព្រោះបញ្ញា សម្រេចភាពជាលោកុត្តរៈហើយ តាំងមាំជាងលោកិយៈ ដូច្នោះ លោកទើបពោលថា បញ្ញា ៨ ប្រការ រមែងញុំាង **បុថុប្បញ្ញា** ឲ្យបរិបូរណ៍ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទមានជាអាទិ៍ថា **ឥមា នវ បញ្ញា** បញ្ញា ៩ ប្រការនេះ ដូចតទៅនេះ ។ ការពិចារណាមគ្គរបស់ព្រះអរិយ-បុគ្គលនោះ ដែលសម្រេចមគ្គ និងផលតាមលំដាប់ អ្នកមានចិត្តសន្តានប្រព្រឹត្តទៅដោយអាការរីករាយ ព្រោះមានចិត្តសន្តានប្រណីត ដោយការប្រកបលោកុត្តរធម៌ដ៏ប្រណីត អ្នកចេញចាកភវគ្គ ក៏ធ្លាក់ចុះជាលំដាប់នៃផល ការពិចារណាផលរបស់ព្រះអរិយបុគ្គល អ្នកធ្លាក់ចុះកាន់ភវង្គ ហើយចេញចាកភវង្គនោះ ការពិចារណាកិលេសដែលបានលះហើយ ដោយន័យនេះឯង ការពិចារណាកិលេសដ៏សេស ការពិចារណានិព្វាន ការពិចារណា ៥ ប្រការ រមែងប្រព្រឹត្តទៅដោយប្រការដូច្នេះឯង ។ ក្នុងការពិចារណាទាំងនោះ ការពិចារណាមគ្គ និងការពិចារណាផល ជាបដិភាណប្បដិសម្ភិទា ដូចម្ដេច ។ លោកគិតតាមបាលិក្នុងអភិធម្ម ហើយពោលទុកក្នុងអដ្ឋកថានោះថា ធម៌ ៥



ប្រការនេះ គឺ ធម៌ដែលកើតព្រោះបច្ច័យឯណានីមួយ ១ និព្វាន ១ អត្ថនៃភាសិត ១ វិបាក ១ កិរិយា ១ ជាអត្ថ ។ មគ្គញ្ញាណ និងផល-ញ្ញាណ ដែលមាននិព្វាននោះជាអារម្មណ៍ ព្រោះព្រះនិព្វានជាអត្ថ ទើបជាអត្ថប្បដិសម្ភិទា ព្រោះពាក្យថា ញាណ ក្នុងអត្ថទាំងឡាយជា **អត្ថប្បដិសម្ភិទា** ។ បច្ចវេក្ខណញ្ញាណ នៃមគ្គញ្ញាណ និងផលញ្ញាណ ដែលជាអត្ថប្បដិសម្ភិទានោះ ជា **បដិភាណប្បដិសម្ភិទា** ព្រោះពាក្យថា ញាណ ក្នុងញាណទាំងឡាយ ជាបដិភាណប្បដិសម្ភិទា បច្ចវេក្ខណ-ញ្ញាណនោះ ឈ្មោះថា **ហាសប្បញ្ញា** ( បញ្ញាដែលរីករាយ ) នៃចិត្តសន្តាន ដែលប្រព្រឹត្តទៅដោយអាការរីករាយ ព្រោះដូច្នោះ លោកទើបពោលថា បញ្ញា ៩ រមែងញុំាង **ហាសប្បញ្ញា** ឲ្យបរិបូរណ៍ ហើយហាសប្បញ្ញា ជាបដិភាណប្បដិសម្ភិទា បញ្ញាសូម្បីមានប្រការទាំងពួងឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ឲ្យដឹង ពោលគឺ ធ្វើខ្ញីមសារនោះ ៗ ឲ្យប្រាកដ ឈ្មោះថា **បញ្ញា** ព្រោះដឹងធម៌ទាំងឡាយ ដោយប្រការនោះ ៗ ។

បទថា **តស្ស** គឺ ព្រះអរិយបុគ្គលមានប្រការដូចពោលហើយនោះ ។ បទនោះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ បទថា **អត្ថវវត្ថានតោ** ដោយការកំណត់អត្ថ គឺ ដោយការកំណត់អត្ថ ៥ យ៉ាង

ដែលបានពោលហើយ ។ ម្យ៉ាងទៀត សូម្បីពេលនេះ លោកក៏ពោលទុកក្នុង **សមណករណិយកថា** ( កថាដែលសមណៈគប្បីធ្វើ ) ថា ញាណដែលមានប្រភេទជាចំណែកទី ១ ក្នុង ៥ ប្រភេទ ក្នុងអត្ថគឺ ហេតុផល ១ និព្វាន ១ អត្ថនៃពាក្យ ១ វិបាក ១ កិរិយា ១ ។ បទថា **អធិគតា ហោតិ** ដែលបុគ្គលសម្រេចហើយ គឺ បានហើយ បដិសម្ភិទានោះឯង ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវការបានចំពោះ ត្រឹមត្រូវហើយដោយបញ្ញា ដោយផស្សៈដែលបានចំពោះនោះឯង ។ បទថា **ធម្មវវត្ថានតោ** ដោយការកំណត់ធម៌ គឺ ដោយការកំណត់ធម៌ ៥ យ៉ាង ដែលលោកពោលដោយលំដាប់នៃបាលីក្នុងអភិធម្មថា ធម៌ ៥ យ៉ាងទាំងនេះ គឺ ហេតុដែលញាំងផលឲ្យកើតឯណាមួយ ១ អរិយមគ្គ ១ ភាសិត ១ កុសល ១ អកុសល ១ ឈ្មោះថា **ធម៌** ។ សូម្បីបទនេះ លោកក៏ពោលទុកក្នុងសមណករណិយកថា ថា ញាណដែលមានប្រភេទជាចំណែកទី ២ ក្នុង ៥ ប្រភេទក្នុងធម៌ គឺ ហេតុ ១ អរិយមគ្គ ១ ពាក្យនិយាយ ១ កុសល ១ អកុសល ១ ។

បទថា **និរុត្តិវវត្ថានតោ** ដោយការកំណត់និរុត្តិ គឺ ដោយការកំណត់និរុត្តិដែលសមគួរដល់អត្ថនោះ ៗ ។ បទថា **បដិភាណវវត្ថានតោ** ដោយការកំណត់បដិភាណ គឺ ដោយការកំណត់បដិសម្ភិទាញាណ ៣ បានដល់ បដិភាណ ។ បទថា **តស្សិមា** កាត់បទជា **តស្ស ឥមា** នេះជាពាក្យសរុប ។



ព្រះសារីបុត្តត្ថេរ កាលសម្ដែងគុណវិសេសរបស់អនុបស្សនាទាំងឡាយ ដោយការសង្គ្រោះចូលជាមួយគ្នាទាំងអស់យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្ដែងដោយប្រភេទនៃវត្ថុ ទើបពោលពាក្យមានជាអាទិ៍ថា **រូបេ អនិច្ចានុបស្សនា** ពិចារណាឃើញការមិនទៀងក្នុងរូប ។ បទនោះ មានសេចក្ដីដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែង **ជវនបញ្ញា** ដោយអំណាចនៃអតីត អនាគត និងបច្ចុប្បន្នក្នុងរូបជាដើម ទើបផ្ដើមពាក្យសួរដោយអំណាចរូបជាដើមតែម្យ៉ាង និងដោយអំណាចរូបក្នុងអតីត អនាគតនិងបច្ចុប្បន្ន ហើយបានដោះស្រាយទៅតាមលំដាប់របស់ពាក្យសួរ ។ ក្នុងជវនបញ្ញានោះ បញ្ញាដែលលោកសម្ដែងទុកមុនក្នុងការដោះស្រាយរូបសុទ្ធ ៗ ជាដើម ជាជវនបញ្ញាដោយអំណាចនៃការស្ទុះទៅក្នុងអតីតជាដើម ក្នុងការដោះស្រាយទាំងអស់ ដែលមានរូបក្នុងអតីត អនាគតនិងបច្ចុប្បន្ន ជាមូល ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែងប្រភេទនៃបញ្ញា ដែលមានព្រះសូត្រយ៉ាងច្រើនជាខាងដើមទៀត ទើបសម្ដែងព្រះសូត្រទាំងឡាយមុន ។

ក្នុងបទទាំងនោះ បទថា **សប្បុរិសសំសេវោ** ការសេពគប់សប្បុរស គឺ ការសេពគប់សប្បុរសទាំងឡាយ មានប្រការដូចពោលហើយក្នុងខាងក្រោយ ។ បទថា **សទ្ធម្មស្សវនំ** ការស្តាប់ព្រះសទ្ធម្ម គឺ ស្តាប់ពាក្យទូន្មានដែលសម្តែងពីការបដិបត្តិ មានសីលជាដើមក្នុងសម្នាក់របស់សប្បុរសទាំងឡាយនោះ ។ បទថា **យោនិសោមនសិការោ** ការធ្វើទុកក្នុងចិត្តដោយប្រពៃ គឺ ធ្វើទុកក្នុងចិត្តដោយឧបាយដោយការពិចារណាអត្ថនៃធម៌ដែលបានស្តាប់ហើយ ។ បទថា **ធម្មានុធម្មប្បដិបត្តិ** បដិបត្តិធម៌សមគួរដល់ធម៌ គឺ បដិបត្តិធម៌ដែលជា“១” បដិបត្តិមានសីលជាដើម ដែលទាក់ទងក្នុងលោកុត្តរធម៌ ។

ពាក្យ ៤ ទាំងនេះ គឺ **បញ្ញាបដិលាភាយ** ( ដើម្បីបានបញ្ញា ) ១ **បញ្ញាវុឌ្ឍិយា** ( ដើម្បីសេចក្តីចម្រើននៃបញ្ញា ) ១ **បញ្ញាវេបុល្លាយ** ( ដើម្បីសេចក្តីទូលំទូលាយបែបញ្ញា ) ១ **បញ្ញាពាហុល្លាយ** ( ដើម្បីភាពជាអ្នកមានបញ្ញាច្រើន ) ១ ជាពាក្យសម្តែងភាវៈ ដោយអំណាចនៃបញ្ញា ។ ពាក្យ ១២ ដ៏សេស ជាពាក្យសម្តែងភាវៈ ដោយអំណាចនៃបុគ្គល ។

(ចប់ អដ្ឋកថាមហាបញ្ញាកថា)



# អដ្ឋកថា សោឡសបញ្ញានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះ ។ បទថា **ឆន្នំ អភិញ្ញានំ** អភិញ្ញា ៦ គឺ ឥទ្ធិវិធ ( សម្តែងឫទ្ធិបាន ) , ១ ទិព្វសោត ( ត្រចៀកទិព្វ ) ១ , ចេតោបរិយញ្ញាណ ( កំណត់ដឹងចិត្តអ្នកដទៃ ) ១ , បុព្វេនិវាសញ្ញាណ ( រលឹកជាតិបាន ) ១ , ទិព្វចក្ខុ ( ភ្នែកទិព្វ ) ១ , អាសវក្ខយញ្ញាណ ( ការដឹងនូវការអស់អាសវៈ ) ១ ។ បទថា **តេសត្តតីនំ ញាណានំ** ញាណ ៧៣ គឺ ញាណទូទៅដល់សាវក ដែលលោកសម្តែងទុកក្នុងញាណកថា ។

ក្នុងបទថា **សុត្តសត្តតីនំ ញាណានំ** ញាណ ៧៧ នេះ មានព្រះបាលីថាដូច្នេះ ៖-

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងញាណវត្ថុ ៧៧ យ៉ាង ដល់អ្នកទាំងឡាយ ចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសម្តែង ។ ម្នាលភិក្ខុទាំងឡាយ ញាណវត្ថុ ៧៧ ដូចម្តេច ? ញាណថា ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ , ញាណថា បើមិនមានជាតិ ជរា និងមរណៈក៏មិនមាន ។ ញាណថា ព្រោះជាតិជាបច្ច័យសូម្បីក្នុងអតីតកាល ក៏មានជរា និងមរណៈ , ញាណថា បើមិនមានជាតិ ជរា និង

មរណៈក៏មិនមាន , ញាណថា ព្រោះជាតិជាបច្ច័យសូម្បីក្នុងកាលអនាគត ក៏មានជរា និងមរណៈ , ញាណថា កាលបើមិនមានជាតិ ជរា និងមរណៈក៏មិនមាន ។ ញាណថា ធម្មដ្ឋិតិញ្ញាណ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការប្រាសចាកកិលេសជាធម្មតា មានការរលត់ជាធម្មតា ។ ញាណថា ព្រោះភពជាបច្ច័យ ទើបមានជាតិ ។ល។ ញាណថា ព្រោះឧបាទានជាបច្ច័យ ទើបមានភព ។ ញាណថា ព្រោះតណ្ហាជាបច្ច័យ ទើបមានឧបាទាន ។ ញាណថា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ។ ញាណថា ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ។ ញាណថា ព្រោះសឡាយតនៈជាបច្ច័យ ទើបមានផស្សៈ ។ ញាណថា ព្រោះនាមរូបជាបច្ច័យ ទើបមានសឡា-យតនៈ ។ ញាណថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ។ ញាណថា ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ ។ ញាណថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។ ញាណថា កាលបើមិនមានអវិជ្ជា សង្ខារក៏មិនមាន ។ ញាណថា ព្រោះអវិជ្ជាជាបច្ច័យសូម្បីក្នុងកាលជាអតីត ក៏មានសង្ខារ , ញាណថា បើមិនមានអវិជ្ជា សង្ខារក៏មិនមាន ។ ញាណថា ព្រោះអវិជ្ជាជាបច្ច័យ សូម្បីក្នុងកាលអនាគតក៏មានសង្ខារ ញាណថា បើមិនមានអវិជ្ជា សង្ខារក៏មិនមាន ។ ញាណថា ធម្មដ្ឋិតិ-



ញ្ញាណមានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការប្រាសចាកកិលេសជាធម្មតា មានការរលត់ទៅជាធម្មតា ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលញាណវត្ថុ ៧៧ យ៉ាងនេះ ។ ញាណ ៧៧ យ៉ាង ព្រះមានព្រះភាគត្រាស់ទុកហើយក្នុង **និទានវគ្គ** ដោយប្រការដូច្នេះ ។ មួយ៉ាងទៀត ញាណវត្ថុ ៤៤ យ៉ាង លោកពោលក្នុងមួយយ៉ាង ៗ ៤ ក្នុងអង្គ ១១ ដោយន័យថា ញាណក្នុងជរា និងមរណៈ ញាណក្នុងហេតុកើតជារា និងមរណៈ ញាណក្នុងការរលត់ជរា និងមរណៈ ញាណក្នុងបដិបទាឲ្យដល់ការរលត់ជរា និងមរណៈ លោកមិនបានកាន់មកក្នុងទីនេះ ។ មួយ៉ាងទៀត ញាណក្នុងទាំងពីរកន្លែងនោះ ជាវត្ថុនៃប្រយោជន៍ទូលំទូលាយ និងសេចក្តីសុខ ទើបឈ្មោះថា ញាណវត្ថុ ។

ការបាន ក្នុងបទមានជាអាទិ៍ថា **លាភោ** លោកពោលថា **បដិលាភោ** ការបានចំពោះ ព្រោះបន្ថែមឧបសគ្គធ្វើឲ្យវិសេស ។ ដើម្បីអធិប្បាយសេចក្តីនៃបទនោះទៀត លោកទើបពោលថា **បត្តិ សម្បត្តិ** ការដល់ ការដល់ព្រម ។ បទថា **ផស្សនា** ការពាល់ត្រូវ គឺ ការពាល់ត្រូវដោយការចាក់ធ្លុះ ។ បទថា **សច្ឆិកិរិយា** ការធ្វើឲ្យជាក់ច្បាស់ គឺ ការធ្វើឲ្យជាក់ច្បាស់ដោយការបានចំពោះ ។ បទថា **ឧបសម្បទា** ការ

ចូលដល់ព្រម គឺ ការឲ្យសម្រេច ។ បទថា **សត្តន្នញ្ច សេក្ខានំ** ព្រះសេក្ខៈ ៧ ពួក គឺ របស់ព្រះសេក្ខៈ ៧ ពួក មានលោកដែលតាំងនៅក្នុងសោតាបត្តិមគ្គ ដែលបានដឹងថា ជាព្រះសេក្ខៈ ព្រោះនៅសិក្សាសិក្ខា ៣ ។ បទថា **បុថុជ្ជនកល្យាណកស្ស** របស់កល្យាណបុថុជ្ជន គឺរបស់បុថុជ្ជន ដែលបានដឹងថា ជាបុគ្គលល្អ ដោយអត្ថថា ជាអ្នកល្អ ព្រោះប្រកបដោយបដិបទាដែលញ៉ាំងសត្វឲ្យដល់និព្វាន ។ បទថា **វឌ្ឍិតវឌ្ឍនា** គឺ ជាហេតុចម្រើនដោយបញ្ញា រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើននៃបញ្ញា ដោយអំណាចនៃបញ្ញា ៨ តាមដែលពោលហើយ និងដោយអំណាចនៃបញ្ញារបស់ព្រះអរហន្ត រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិបូណ៌នៃបញ្ញា ក៏ដូចគ្នា ។

ក្នុងបទមានជាអាទិ៍ថា **មហន្តេ អត្ថេ បរិគ្គណ្ហាតិ** រមែងកំណត់អត្ថធំ មានសេចក្តីដូចតទៅនេះ ។ ព្រះអរិយសាវកដែលចាក់ធ្លុះបដិសម្ភិទា រមែងកំណត់អត្ថជាដើម ដោយធ្វើឲ្យជាអារម្មណ៍ ។ មហាបញ្ញាសូម្បីទាំងអស់ ក៏ជារបស់ព្រះអរិយសាវកទាំងឡាយនោះឯង ។ម្យ៉ាងទៀត មហាបញ្ញា ជាវិស័យនៃបញ្ញានោះ មានសេចក្តីដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។

**នានា** សព្ទ ក្នុងបទមានជាអាទិ៍ថា **បុថុនានាខន្ធេសុ** ក្នុងខន្ធ



ផ្សេង ៗ ជាច្រើន ជាពាក្យពោលដល់អត្ថនៃ **បុថុ** សព្ទ ។ បទថា **ញាណំ បវត្តតីតិ បុថុបញ្ញា** ឈ្មោះថា បុថុបញ្ញា ព្រោះញាណប្រព្រឹត្តទៅ សេចក្តីថា ញាណនោះឈ្មោះថា បុថុបញ្ញា ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធជាដើម តាមដែលពោលហើយនោះ ។ បទថា **នានាបដិច្ចសមុប្បាទេសុ** ក្នុងបដិច្ចសមុប្បាទផ្សេង ៗ លោកពោលព្រោះជាបច្ច័យច្រើន ដោយអំណាចនៃធម៌អាស្រ័យគ្នាកើតឡើង ។ បទថា **នានាសុញ្ញតមនុបលព្ភេសុ** ក្នុងការបានរឿយ ៗ នូវសេចក្តីសូន្យផ្សេង ៗ គឺការចូលទៅបាន ឈ្មោះថា **ឧបលព្ភ** អធិប្បាយថា ការកាន់យក ការមិនចូលទៅបាន ឈ្មោះថា **អនុបលព្ភ** ព្រោះការមិនចូលទៅបានពាក្យច្រើន ឈ្មោះថា **អនុបលព្ភា** ជាពហុវចនៈ ។ ម្យ៉ាងវិញទៀត ការមិនចូលទៅបាននូវខ្លួន និងវត្ថុដែលជាប់ដោយខ្លួន ក្នុងសេចក្តីសូន្យផ្សេង ៗ ដោយសុញ្ញតា ២៥ ឈ្មោះថា **នានាសុញ្ញតានុបលព្ភា** ។ ក្នុងនានាសុញ្ញតានុបលព្ភានោះ បើគួរនឹងពោលថា **នានាសុញ្ញតមនុបលព្ភេសុ** លោកពោល **ន** អក្សរ ដោយបទសន្ធិ ដូចក្នុងបទថា **អទុក្ខមសុខា** មិនទុក្ខមិនសុខ ។ បញ្ញា ៥ យ៉ាងនេះ ទូទៅដល់កល្យាណបុថុជ្ជន ។

បញ្ញាក្នុងបទមានជាអាទិ៍ថា **នានាអត្ថា** មានអត្ថផ្សេង ៗ របស់

ព្រះអរិយៈជាម្ចាស់មែនពិត ។ បទថា **បុថុជ្ជនសាធារណេ ធម្មេ** ក្នុងធម៌ទូទៅដល់បុថុជ្ជន គឺ លោកិយធម៌ ។ លោកពោលថា ឈ្មោះថា **បុថុ-ជនបញ្ញា** ព្រោះបញ្ញាក្រាស់ បញ្ញាមួយផ្នែក ព្រោះមាននិព្វានដែលជារបស់ធំ ជាអារម្មណ៍ចាកលោកិយៈដោយបរិយាយក្នុងទីបំផុតនេះ ។ បទថា **វិបុលបញ្ញា** គប្បីជ្រាបតាមន័យនៃមហាបញ្ញា ។ កាលបើកំណត់ ធម៌តាមដែលពោលហើយ គប្បីជ្រាបការបរិបូណ៌នៃបញ្ញាកំណត់ធម៌ទាំងនោះ ព្រោះមានគុណធំ និងបញ្ញាកំណត់ធម៌ទាំងនោះ ព្រោះភាវៈជាធំ និងកំណត់ធម៌ ព្រោះមានភាវៈធំ ព្រោះភាវៈជាធំក្រៃលែងដោយខ្លួនឯង ប៉ុណ្ណោះ ។ **គម្ភីរបញ្ញា** គប្បីជ្រាបដោយន័យនៃបុថុបញ្ញា ។ ធម៌ទាំងនោះ ដែលមិនគប្បីបាន និងបញ្ញានោះ ឈ្មោះថា **គម្ភីរា** ព្រោះប្រក្រតីជន មិនគប្បីបាន ។

បទថា **យស្ស បុគ្គលស្ស** គឺ នៃព្រះអរិយបុគ្គលនោះឯង ។ បទថា **អញ្ញោ កោចិ** អ្នកណាមួយ គឺ បុថុជ្ជន ។ បទថា **អភិសម្ភវិតុំ** ដើម្បីគ្របសង្កត់បាន គឺ ដើម្បីដល់ព្រមបាន ។ បទថា **អនភិសម្ភវនីយោ** ដែលនរណា ៗ គ្របសង្កត់មិនបាន គឺ ដែលនរណា ៗ មិនអាចសម្រេចបាន ។ បទថា **អញ្ញេហិ** គឺ បុថុជ្ជននោះឯង ។ បទថា **អដ្ឋមកស្ស** របស់បុគ្គលទី ៨ គឺ របស់លោកអ្នកតាំងនៅក្នុងសោតបត្តិមគ្គ ជាបុគ្គល



ទី ៨ រាប់តាំងអំពីលោកដែលតាំងនៅក្នុងអរហត្តផល ។ បទថា **ទូរេ** គឺ នៅក្នុងទីឆ្ងាយ ។ បទថា **វិទូរេ** គឺ ឆ្ងាយជាពិសេស ។ បទថា **សុវិទូរេ** គឺ ឆ្ងាយសែនឆ្ងាយ ។ បទថា **ន សន្តិកេ** គឺ មិនជិត ។ បទថា **ន សាមន្តា** គឺ ក្នុងចំណែកមិនជិត ។ ពាក្យប្រកប ពាក្យបដិសេធទាំងពីរនេះ កំណត់ដល់សភាពឆ្ងាយនោះឯង ។ បទថា **ឧបាទាយ** គឺ អាស្រ័យ ។ បទថា **សោតាបន្នស្ស** គឺ លោកអ្នកតាំងនៅក្នុងសោតាបត្តិផល ។ ដោយបទនេះ លោកពោលថា មគ្គបញ្ញានោះ ៗ ឆ្ងាយចាកផលបញ្ញានោះ ៗ ។ បទថា **បច្ចេកសម្ពុទ្ធោ** ប្លែកគ្នាដោយឧបសគ្គ ។ ទាំងពីរបទនេះ បរិសុទ្ធិដូចគ្នា ។

ព្រះសារីបុត្តត្ថេរ កាលពោលពាក្យមានជាអាទិ៍ថា បញ្ញារបស់ព្រះបច្ចេកពុទ្ធ និងសត្វលោក ព្រមទាំងទេវលោក ឆ្ងាយអំពីបញ្ញារបស់ព្រះតថាគត ហើយបំណងនឹងសម្តែងបញ្ញាដែលតាំងនៅឆ្ងាយនោះ ដោយប្រការយ៉ាងច្រើន ទើបពោលបទមានជាអាទិ៍ថា **បញ្ញា-បភេទកុសលោ** ព្រះតថាគតទ្រង់ជាអ្នកឆ្លាតក្នុងប្រភេទនៃបញ្ញាដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បញ្ញាបភេទកុសលោ** គឺ ទ្រង់ឆ្លាតក្នុងប្រភេទនៃបញ្ញាដែលមានការកំណត់ដ៏ច្រើនរបស់ព្រះអង្គ ។ បទថា **បភិន្នញាណោ** ទ្រង់មានញាណបែកធ្លាយ គឺ មានព្រះញាណដល់ប្រភេទ

រកទីបំផុតមិនបាន ។ ដោយបទនេះ សូម្បីមានសេចក្តីថ្ងាតក្នុងប្រភេទនៃបញ្ញា ព្រះសារីបុត្តត្ថេរ ក៏សម្តែងសភាពដែលបញ្ញាទាំងនោះ មានប្រភេទរកទីបំផុតមិនបាន ។ បទថា **អធិគតប្បដិសម្ភិទោ** ទ្រង់សម្រេចបដិសម្ភិទា គឺ ទ្រង់បានបដិសម្ភិទាញាណ ៤ ដ៏ប្រសើរ ។ បទថា **ចតុវេសារជ្ជប្បត្តោ** ទ្រង់ដល់វេសារជ្ជញ្ញាណ ៤ គឺ ទ្រង់ដល់ញាណពោលគឺ សេចក្តីក្លាហាន ៤ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា

ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ពិចារណានិមិត្តនោះថា បើព្រះសម្មាសម្ពុទ្ធត្រាស់ដឹងធម៌ទាំងនោះ សមណៈ ព្រាហ្មណ៍ ទេវតា មារ ព្រហ្ម ឬនរណា ៗ ក្នុងលោកនេះនឹងសង្ស័យលើតថាគត ក្នុងប្រការនោះ ព្រមជាមួយធម៌ថា ធម៌ទាំងនេះ ព្រះសម្មាសម្ពុទ្ធមិនទាន់បានត្រាស់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនបានពិចារណាដល់និមិត្តនោះ ជាអ្នកដល់នូវសេចក្តីក្សេម ដល់នូវការមិនមានភ័យដល់សេចក្តីក្លាហាន ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ពិចារណាឃើញនិមិត្តនោះថា កាលព្រះខីណាស្រពត្រាស់ដឹងធម៌ទាំងនោះ សមណៈ ព្រាហ្មណ៍ ។ល។ ឬនរណា ៗ ក្នុងលោក នឹងសង្ស័យលើតថាគតក្នុងប្រការនោះ ព្រមជាមួយធម៌ថា អាសវៈទាំងនេះមិនទាន់អស់ទៅកាលព្រះខីណាស្រពសេពអន្តរាយិកធម៌នោះដែលថា មិនគួរអន្តរាយបាន



មយ៉ាងទៀត ធម៌ដែលលោកសម្តែងហើយ ដើម្បីប្រយោជន៍ដល់បុគ្គលណា ធម៌នោះរមែងមិននាំចេញ ដើម្បីការអស់សេចក្តីទុក្ខដោយប្រពៃដល់បុគ្គលអ្នកធ្វើនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនិមិត្តនោះ ។ល។ ។

បទថា **ទសពលធារី** ទ្រទ្រង់ពលៈ ១០ ឈ្មោះថា **ទសពលា** ព្រោះមានពលៈ ១០ ។ ពលៈរបស់អ្នកមានពលៈ ១០ ឈ្មោះថា **ទសពលពលានិ** ឈ្មោះថា **ទសពលពលធារី** ព្រោះទ្រទ្រង់ពលៈរបស់អ្នកមានពលៈ ១០ អធិប្បាយថា ទ្រទ្រង់កម្លាំង គឺ ទសពលញ្ញាណ ។ ដោយពាក្យទាំង ៣ នេះ លោកសម្តែងត្រឹមតែមាតិកាប្រភេទរបស់វេនេយ្យសត្វ ដែលមានប្រភេទដ៏ច្រើនសន្ធឹកសន្ធាប់ ។ ព្រះតថាគតទ្រង់ជាបុរសអង់អាចដោយបានសម្មតិ ជាមង្គលក្រៃលែង ដោយអំណាចប្រកបដោយបញ្ញា ទ្រង់ជាបុរសសីហៈ ដោយអត្ថថា មិនមានសេចក្តីតក់ស្លុត ទ្រង់ជាបុរសនាគ ដោយអត្ថថា ជាធំ ទ្រង់ជាបុរសអាជានេយ្យ ដោយអត្ថថា ជាអ្នកដឹងទូទៅ ទ្រង់ជាបុរសនាំធុរៈទៅ ដោយអត្ថថា នាំធុរៈកិច្ចរបស់លោកទៅ ។

គ្រានោះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងគុណវិសេសដែលបានពីអនន្តញ្ញាណ មានតេជៈជាដើម ដើម្បីសម្តែងនូវភាវៈនៃតេជៈ

ជាដើមទាំងនោះ ជាឫសគល់នៃអនន្តញ្ញាណ ទើបពោល **អនន្ត-ញ្ញាណោ** ទ្រង់មានព្រះញាណរកទីបំផុតមិនបាន ហើយពោលបទមានជាអាទិ៍ថា **អនន្តតេជោ** ទ្រង់មានតេជៈរកទីបំផុតមិនបាន ។

ក្នុងបទទាំងនោះ បទថា **អនន្តញ្ញាណោ** គឺ ទ្រង់មានញាណប្រាសចាកទីបំផុត ដោយការកំណត់ចំនួន និងដោយភាពជាអ្នកមានអំណាច ។ បទថា **អនន្តតេជោ** គឺ ទ្រង់មានតេជៈដោយព្រះញាណរកទីបំផុតមិនបាន ដោយការកម្ចាត់ងងឹត គឺ មោហៈក្នុងសន្តានរបស់វេ-នេយ្យសត្វ ។ បទថា **អនន្តយសោ** ទ្រង់មានព្រះយសរកទីបំផុតមិនបាន គឺ ទ្រង់មានការប្រកាសកិត្តិគុណរកទីបំផុតមិនបាន ផ្សាយទៅក្នុងលោកទាំង ៣ ដោយព្រះបញ្ញាគុណ ។ បទថា **អឌ្ឍោ** ទ្រង់ជាអ្នកស្តុកស្តម្ភ គឺ ដល់ព្រមដោយទ្រព្យ គឺ បញ្ញា ។ បទថា **មហទ្ធនោ** ទ្រង់មានទ្រព្យច្រើន ឈ្មោះថា **មហទ្ធនោ** ពោះមានទ្រព្យ គឺ បញ្ញាច្រើន ដោយភាពជាអ្នកច្រើនដោយអំណាច សូម្បីក្នុងសេចក្តីជាអ្នកចម្រើនដោយទ្រព្យ គឺ បញ្ញា ។ បទថា **ធនវា** ទ្រង់មានអរិយទ្រព្យ ឈ្មោះថា **ធនវា** ព្រោះមានទ្រព្យ គឺ បញ្ញាដ៏គួរសរសើរ ព្រោះមានទ្រព្យ គឺ បញ្ញាដែលប្រកបជាមួយជានិច្ច ព្រោះមានទ្រព្យ គឺ បញ្ញាដែលដល់កំពូល ។ ក្នុងអត្ថទាំង ៣ នេះ អ្នកដឹងសព្ទទាំងឡាយរមែងប្រាថ្នាពាក្យ



នេះ ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងការសម្រេចក្នុងអត្តសម្បត្តិរបស់ព្រះមានព្រះភាគ ដោយព្រះបញ្ញាគុណយ៉ាងនេះហើយ កាលនឹងសម្តែង សេចក្តីសម្រេចសម្បត្តិដែលជាប្រយោជន៍ដល់លោក ដោយព្រះបញ្ញាគុណទៀត ទើបពោលបទមានជាអាទិ៍ថា **នេតា** ទ្រង់ជាអ្នកនាំ ។

គប្បីជ្រាបសេចក្តីក្នុងបទទាំងនោះ ដូចតទៅនេះ ។ ទ្រង់ជាអ្នកនាំវេនេយ្យសត្វទាំងឡាយទៅកាន់ឋានដ៏ក្សេម ពោលគឺ និព្វាន ចាកឋានដែលគួរភ័យខ្លាច គឺ សង្សារវដ្ត ទ្រង់ជាអ្នកនាំទៅដោយវិសេសនូវវេនេយ្យសត្វទាំងឡាយ ដោយសំវរវិន័យ និងបហានវិន័យ ក្នុងវេលាទ្រង់ណែនាំ ទ្រង់នាំទៅរឿយ ៗ ដោយការកាត់សេចក្តីសង្ស័យក្នុងខណៈទ្រង់សម្តែងធម៌ ទ្រង់កាត់សេចក្តីសង្ស័យហើយ ទ្រង់បញ្ញត្តិអត្ថដែលគួរឲ្យដឹង ទ្រង់ពិនិត្យដោយធ្វើការកាត់សម្រេចសេចក្តីដែលបញ្ញត្តិទុកយ៉ាងនេះ ទ្រង់បង្ហាញអត្ថដែលទ្រង់ពិនិត្យហើយយ៉ាងនោះដោយការប្រកបក្នុងការបដិបត្តិ ទ្រង់ឲ្យពួកសត្វអ្នកបដិបត្តិហើយនោះឲ្យជ្រះថ្លាដោយផលរបស់ការបដិបត្តិ ។ **ហិ** អក្សរ ក្នុងបទនេះថា **សោ ហិ ភគវា** ជានិបាតចុះក្នុងការសម្តែងអាងដល់ហេតុនៃអត្ថដែលពោលទុកហើយក្នុងលំដាប់ ។ បទថា **អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា**

ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឲ្យកើតឡើង គឺ ញ៉ាំងអរិយមគ្គដែលជាហេតុនៃអសាធារណញ្ញាណ ៦ ដែលមិនធ្លាប់កើតក្នុងសន្តានរបស់ខ្លួនឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួន ដើម្បីប្រយោជន៍ដល់លោក ទៀបគល់ពោធិព្រឹក្ស ។ បទថា **អសញ្ជាតស្ស មគ្គស្ស សញ្ជានេតា** ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតព្រម ឲ្យកើតព្រម គឺ ញ៉ាំងអរិយមគ្គដែលជាហេតុនៃសាវកបារមីញាណ ដែលមិនធ្លាប់កើតព្រមក្នុងសន្តានរបស់វេនេយ្យសត្វ ឲ្យកើតព្រមក្នុងសន្តាននៃវេនេយ្យសត្វ តាំងអំពីទ្រង់ប្រកាស់ព្រះធម្មចក្កជរាបដល់សព្វថ្ងៃនេះ ។ ពិតណាស់ ព្រះមានព្រះភាគជាម្ចាស់ ឈ្មោះថា **សញ្ជានេតា** ព្រោះទ្រង់ញ៉ាំងអរិយមគ្គឲ្យកើតព្រមក្នុងសន្តានរបស់វេនេយ្យសត្វដែលជាសាវក ដោយព្រះតម្រាស់ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកនោះឯង ។ បទថា **អនក្ខា-តស្ស មគ្គស្ស អក្ខាតា** ត្រាស់ប្រាប់មគ្គដែលមិនទាន់មានអ្នកណាប្រាប់ គឺ ទ្រង់ព្យាករណ៍ដើម្បីភាពជាព្រះពុទ្ធរបស់ព្រះពោធិសត្វទាំងឡាយជាអ្នកសន្សំបុណ្យកុសលទុក ដើម្បីភាពជាព្រះពុទ្ធអ្នកប្រកបដោយធម៌ ៨ ប្រការ ហើយទ្រង់ប្រាប់មគ្គ គឺ បារមី ដែលមិនធ្លាប់បានប្រាប់ គឺ អរិយមគ្គដែលគួរឲ្យកើតឡើង នៅទៀបគល់មហាពោធិព្រឹក ដោយត្រឹមតែព្យាករណ៍ថា នឹងជាព្រះពុទ្ធជាម្ចាស់ ។ ន័យនេះរមែងបានសូម្បី



ក្នុងការព្យាករណ៍ព្រះបច្ចេកពោធិសត្វ ដូចគ្នា ។

បទថា **មគ្គញ្ញូ** ទ្រង់ដឹងមគ្គ គឺ ទ្រង់ដឹងអរិយមគ្គដែលខ្លួនឲ្យកើតឡើងដោយការពិចារណា ។ បទថា **មគ្គវិទូ** ទ្រង់ជ្រាបមគ្គ គឺ ទ្រង់ឆ្លាតក្នុងអរិយមគ្គ ដែលគប្បីឲ្យកើតឡើងក្នុងសន្តានរបស់វេនេយ្យសត្វ ។ បទថា **មគ្គកោវិទោ** ទ្រង់ឆ្លាតក្នុងមគ្គ គឺ ទ្រង់ឃើញច្បាស់នូវមគ្គដែលគួរប្រាប់ដល់ព្រះពោធិសត្វទាំងឡាយ ។ មួយ៉ាងវិញទៀត ទ្រង់ដឹងមគ្គដែលជាការបដិបត្តិដើម្បីអភិសម្ពោធិ ទ្រង់ជ្រាបមគ្គដែលជាការបដិបត្តិដើម្បីបច្ចេកពោធិ ទ្រង់ឆ្លាតក្នុងមគ្គ ដែលជាការបដិបត្តិដើម្បីសាវកពោធិ ។

មួយ៉ាងវិញទៀត អាចារ្យទាំងឡាយ រមែងធ្វើការប្រកបអត្ថតាមលំដាប់ ដោយអំណាចនៃមគ្គរបស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវកក្នុងអតីត អនាគត និងបច្ចុប្បន្ន ដោយអំណាចនៃអប្បណិហិតមគ្គ ដែលមានសុញ្ញតៈជានិមិត្ត និងដោយអំណាចនៃមគ្គរបស់ឧគ្ឃដិតញ្ញូបុគ្គល វិបចិតញ្ញូបុគ្គល និងនេយ្យបុគ្គល តាមសមគួរ ព្រោះបាលីថា ដោយមគ្គនេះ សាវកទាំងឡាយឆ្លងហើយក្នុងកាលមុន នឹងឆ្លង រមែងឆ្លងនូវឱឃៈ ដូច្នេះ ។

បទថា **មគ្គានុគាមី ច បន** ក៏ព្រះសាវកជាអ្នកប្រព្រឹត្តទៅតាម

មគ្គ គឺ ជាអ្នកប្រព្រឹត្តទៅតាមមគ្គដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រព្រឹត្តទៅហើយ ។ **ច** សព្ទ ក្នុងបទនេះជានិបាតចុះក្នុងអត្ថនៃហេតុ ។ ដោយបទនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ដល់ហេតុនៃការសម្រេចគុណ មានការញុំាងមគ្គឲ្យកើតជាដើម ។ **បន** សព្ទ ជានិបាតចុះក្នុងអត្ថថា ធ្វើហើយ ។ ដោយបទនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ដល់ហេតុនៃមគ្គដែលធ្វើហើយ ។ បទថា **បច្ឆា សមន្នាគតា** ព្រះសាវកដែលនឹងមកក្នុងខាងក្រោយ គឺ កាលព្រះមានព្រះភាគស្តេចយាងទៅមុន ព្រះសាវកប្រកបដោយគុណ ដល់ព្រមដោយសីលជាដើម មកក្នុងខាងក្រោយ ។ ដោយហេតុនេះ ព្រោះគុណមានសីលជាដើម សូម្បីទាំងអស់របស់ព្រះមានព្រះភាគ អាស្រ័យអរហត្តមគ្គនោះឯង នឹងមកហើយ ដោយបទមានជាអាទិ៍ថា ដោយញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើងដូច្នេះ ដូច្នោះ ព្រះថេរៈពោលដល់គុណ ព្រោះអាស្រ័យអរហត្តមគ្គនោះឯង ។ បទថា **ជានំ ជានាតិ** ព្រះមានព្រះភាគកាលទ្រង់ជ្រាប ក៏រមែងទ្រង់ជ្រាប គឺ រមែងទ្រង់ជ្រាបវត្ថុដែលគួរទ្រង់ជ្រាប អធិប្បាយថា ធម្មតាវត្ថុដែលគួរជ្រាបដោយបញ្ញាយ៉ាងណាមួយ ដើម្បីព្រះសព្វញ្ញុតញ្ញាណ រមែងទ្រង់ជ្រាបវត្ថុដែលគួរជ្រាបទាំងអស់នោះដែលជាផ្លូវនៃចំណុចគួរណែនាំ ៥ ប្រការ ដោយបញ្ញា ។ បទថា



**បស្សំ បស្សតិ** ព្រះមានព្រះភាគ កាលទ្រង់ឃើញ ក៏រមែងទ្រង់ឃើញ គឺ ទ្រង់ឃើញវត្ថុដែលគួរឃើញ អធិប្បាយថា ទ្រង់ធ្វើផ្លូវដែលគួរណែនាំនោះឯង ដូចឃើញដោយចក្ខុ ព្រោះឃើញទាំងអស់ ឈ្មោះថា រមែងឃើញដោយបញ្ញាចក្ខុ ឬថា ព្រះមានព្រះភាគជាម្ចាស់ មិនមែនដូចមនុស្សពួកខ្លះ សូម្បីកាន់យកវត្ថុវិបរិត កាលដឹង ក៏រមែងមិនដឹង សូម្បីកាលឃើញក៏រមែងមិនឃើញ តែព្រះមានព្រះភាគ ទ្រង់កាន់យកតាមសភាពពិត ទ្រង់ជ្រាប ក៏រមែងទ្រង់ជ្រាប ទ្រង់ឃើញក៏រមែងទ្រង់ឃើញ ព្រះមានព្រះភាគព្រះអង្គនោះ ឈ្មោះថា មានចក្ខុ ព្រោះអត្ថថា ទ្រង់ជាអ្នកនាំក្នុងការឃើញ ឈ្មោះថា ទ្រង់មានញាណ ព្រោះអត្ថថា មានភាពជាអ្នកទ្រង់ដឹងច្បាស់ជាដើម ឈ្មោះថា ទ្រង់មានធម៌ ព្រោះអត្ថថា មានសភាពមិនវិបរិត ឬសម្រេចដោយធម៌ដែលព្រះអង្គទ្រង់គិតដោយព្រះទ័យ ហើយទ្រង់ថ្លែងដោយព្រះវាចា ព្រោះទ្រង់ស្ទាត់ក្នុងបរិយត្តិធម៌ ឈ្មោះថា ទ្រង់មានព្រហ្ម ព្រោះអត្ថថា ទ្រង់ជាអ្នកប្រសើរបំផុត ។ម្យ៉ាងទៀត ឈ្មោះថា ទ្រង់មានចក្ខុ ព្រោះទ្រង់ដូចជាចក្ខុ ឈ្មោះថា ទ្រង់មានញាណ ព្រោះទ្រង់ដូចជាញាណ ឈ្មោះថា ទ្រង់មានធម៌ ព្រោះទ្រង់ដូចជាធម៌ ឈ្មោះថា ទ្រង់មានព្រហ្ម ព្រោះទ្រង់ដូចជាព្រហ្ម ។

ព្រះមានព្រះភាគព្រះអង្គនោះ ត្រាស់ប្រាប់ ព្រោះត្រាស់ប្រាប់ព្រះធម៌ ឬព្រោះញុាំងព្រះធម៌ឲ្យប្រព្រឹត្តទៅ ត្រាស់ប្រាប់ទូទៅ ព្រោះត្រាស់ប្រាប់ដោយប្រការផ្សេងៗ ឬឲ្យប្រព្រឹត្តទៅដោយប្រការផ្សេងៗ ទ្រង់នាំអត្ថចេញ ព្រោះទ្រង់នាំអត្ថចេញហើយ ទើបទ្រង់ណែនាំ ទ្រង់ប្រទានអមតធម៌ ព្រោះទ្រង់សម្តែងផ្លូវបដិបត្តិដើម្បីសម្រេចអមតធម៌ ឬព្រោះទ្រង់ឲ្យសម្រេចអមតធម៌ដោយការសម្តែងធម៌ ប្រកាសអមត-ធម៌ ទ្រង់ជាធម្មសាមី ព្រោះទ្រង់ឲ្យកើតលោកុត្តរធម៌ដោយការប្រទានលោកុត្តរធម៌ តាមសេចក្តីសុខដោយសមគួរដល់វេនេយ្យសត្វ និងទ្រង់ជាឥស្សរៈក្នុងធម៌ទាំងឡាយ ។ បទថា **តថាគត** មានអត្ថដូចបានពោលហើយក្នុងខាងក្រោយ ។

ឥឡូវនេះ ព្រះសារីបុត្តត្រូវប្រាថ្នានឹងសម្តែងគុណ ដូចដែលពោលហើយដោយបទមានជាអាទិ៍ថា **ជានំ ជានាតិ** កាលទ្រង់ជ្រាបក៏រមែងទ្រង់ថ្វាយឲ្យវិសេសក្រៃលែងឡើង ព្រោះព្រះសព្វញ្ញុតញ្ញាណកាលនឹងញុាំងព្រះសព្វញ្ញុតញ្ញាណឲ្យសម្រេច ទើបពោលបទមានជាអាទិ៍ថា **នត្ថិ** មិនមានដូច្នេះ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ត្រាស់ដូច្នោះ មិនបានធ្វើឲ្យជាក់ច្បាស់មិនមាន ព្រោះកម្ចាត់សេចក្តីវង្វេង ព្រមទាំងវាសនាក្នុងធម៌ទាំងពួង ដោយអរហត្ត-



មគ្គញ្ញាណ ដែលសម្រេចដោយកម្លាំងបុណ្យ ដែលទ្រង់បំពេញមកហើយ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគទ្រង់មិនជ្រាប មិនមាន ព្រោះទ្រង់ជ្រាបធម៌ទាំងពួងដោយសេចក្តីមិនវង្វេង ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគទ្រង់មិនបានឃើញមិនមាន ព្រោះធម៌ទាំងពួងព្រះអង្គទ្រង់ឃើញដោយញាណចក្ខុ ដោយចក្ខុ ក៏ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគទ្រង់មិនបានជ្រាបមិនមាន ព្រោះព្រះអង្គទ្រង់សម្រេចហើយដោយញាណ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគទ្រង់ធ្វើមិនឲ្យជាក់ច្បាស់មិនមាន ព្រោះព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយការធ្វើឲ្យជាក់ច្បាស់ ដោយការមិនវង្វេង ឈ្មោះថា បទធម៌ដែលព្រះអង្គមិនពាល់ត្រូវដោយបញ្ញាមិនមាន ព្រោះព្រះអង្គពាល់ត្រូវដោយបញ្ញាដែលមិនវង្វេង ។ បទថា **បច្ចុប្បន្នំ** បានដល់ កាល ឬធម៌ជាបច្ចុប្បន្ន ។ បទថា **ឧបាទាយ** គឺ កាន់យកហើយ សេចក្តីថា ធ្វើទុកក្នុងខាងក្នុង សូម្បីនិព្វានផុតចាកកាល លោកក៏កាន់យកដោយពាក្យថា **ឧបាទាយ** នោះឯង ។ ម្យ៉ាងទៀត ពាក្យមាន **អតីត** កន្លងទៅហើយជាដើម រមែងតភ្ជាប់ជាមួយពាក្យថា **នត្ថិ** ឬជាមួយពាក្យមានជាអាទិ៍ថា **សព្វេ** ។ បទថា **សព្វេ ធម្មា** ធម៌ទាំងឡាយទាំងពួង ពោលគឺសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់ ។ បទថា **សព្វាការេន** ដោយ

អាការទាំងពួង គឺ រួមអាការទាំងពួង មានអាការមិនទៀងជាដើមនៃធម៌មួយ ៗ ក្នុងបណ្តាធម៌ទាំងអស់ ។ បទថា **ញាណមុខេ** ក្នុងមុខ គឺ ព្រះញាណ បានដល់ ចំពោះមុខ គឺ ព្រះញាណ ។ បទថា **អាបាថំ អាគច្ឆតិ** រមែងមកកាន់គន្លង គឺ រមែងដល់ការរួមគ្នា ។ បទថា **ជានិតព្វំ** គួរដឹង លោកពោលដើម្បីអធិប្បាយសេចក្តីនៃបទថា **នេយ្យំ** គួរណែនាំ **វា** សព្ទ ក្នុងបទមានជាអាទិ៍ថា **អត្តត្ថោ វា** និងប្រយោជន៍ខ្លួន ជាសមុច្ចយត្ថ ( ការរួមគ្នា ) ។ បទថា **អត្តត្ថោ** គឺ ប្រយោជន៍របស់ខ្លួន ។ បទថា **បរត្ថោ** ប្រយោជន៍របស់អ្នកដទៃ គឺ ប្រយោជន៍របស់លោក ៣ ដទៃ ។ បទថា **ឧភយត្ថោ** ប្រយោជន៍ទាំងពីរចំណែក បានដល់ ប្រយោជន៍របស់ទាំងពីរ ចំណែកដូចគ្នា គឺ របស់ខ្លួន និងរបស់អ្នកដទៃ ។ បទថា **ទិដ្ឋធម្មិកោ** ប្រយោជន៍ភពនេះ គឺ ប្រយោជន៍ប្រកបក្នុងភពនេះ ឬប្រយោជន៍បច្ចុប្បន្ន ប្រយោជន៍ប្រកបហើយក្នុងភពខាងមុខ ឬប្រយោជន៍ក្នុងសម្បរាយភព ឈ្មោះថា **សម្បរាយិកោ** ។

គប្បីជ្រាបក្នុងបទមានជាអាទិ៍ថា **ឧត្តានោ** ដូចតទៅនេះ ប្រយោជន៍ដែលពោលដោយវោហារ ឈ្មោះថា **ឧត្តានោ** ប្រយោជន៍ដែលរាក់ ព្រោះយល់ងាយ ប្រយោជន៍ដែលគប្បីពោលកន្លងនូវវោហារបដិសំយុត្តដោយសុញ្ញតា ឈ្មោះ **គម្ភីរោ** ប្រយោជន៍ដែលជ្រៅ ព្រោះ



យល់លំបាក ប្រយោជដែលជាលោកុត្តរៈ ឈ្មោះថា **គុឡ្ហោ** ប្រយោជន៍កំបាំង ព្រោះនិយាយច្រើនក្នុងរឿងខាងក្រៅ ប្រយោជន៍មានការមិនទៀងជាដើម ឈ្មោះថា **បដិច្ឆន្នោ** ប្រយោជន៍បិទបាំង ព្រោះបិទបាំងដោយឃនៈ ( ដុំ ) ជាដើម ប្រយោជន៍ដែលនិយាយដោយមិនប្រើវោហារច្រើន ឈ្មោះថា **នេយ្យោ** ប្រយោជន៍ដែលគួរនាំទៅ ព្រោះមិនកាន់យកតាមសេចក្តីពេញចិត្ត គួរនាំទៅតាមសេចក្តីបំណង ប្រយោជន៍ដែលនិយាយដោយប្រើវោហារ ឈ្មោះថា **នីតោ** ប្រយោជន៍ដែលនាំទៅហើយ ព្រោះនាំសេចក្តីបំណងទៅដោយត្រឹមតែពាក្យនិយាយអំពីប្រយោជន៍ គឺ សីល សមាធិ និងវិបស្សនា ដែលបរិសុទ្ធិ៍ដោយល្អ ឈ្មោះថា **អនវជ្ជោ** ប្រយោជន៍មិនមានទោស ព្រោះប្រាសចាកទោសដោយតទង្គៈ និងវិក្ខម្ភនៈ ប្រយោជន៍ គឺ អរិយមគ្គ ឈ្មោះថា **និក្កិលេសោ** ប្រយោជន៍មិនមានកិលេស ព្រោះកាត់ផ្តាច់កិលេសហើយ ប្រយោជន៍ គឺ អរិយផល ឈ្មោះថា **វោទានោ** ប្រយោជន៍ដ៏ផូរផង់ ព្រោះស្ងប់កិលេស និព្វាន ឈ្មោះថា **បរមត្ថោ** ប្រយោជន៍ដ៏ក្រៃលែង ព្រោះនិព្វាន ជាធម៌ដ៏ខ្ពង់ខ្ពស់ជាងសង្ខតធម៌ និងអសង្ខតធម៌ទាំងឡាយ ។

បទថា **បរិវត្តតិ** រមែងប្រព្រឹត្តទៅ គឺ ជ្រាបចូលពិចារណាដោយ

ជុំវិញ រមែងប្រព្រឹត្តទៅដោយវិសេសក្នុងខាងក្នុងពុទ្ធញ្ញាណ ព្រោះមិនមែនជាចំណែកខាងក្រៅចាកវិស័យនៃពុទ្ធញ្ញាណ ព្រះសារីបុត្តត្ថេររមែងសម្ដែងសេចក្ដី ដែលព្រះមានព្រះភាគទ្រង់សម្រេចព្រះញាណដោយបទមានជាអាទិ៍ថា **សព្វំ កាយកម្មំ** រហូតកាយកម្មទាំងពួង ។ បទថា **ញាណានុបរិវត្តតិ** ព្រះញាណរមែងប្រព្រឹត្តទៅរហូត សេចក្ដីថា មិនប្រាសចាកព្រះញាណ ។ បទថា **អប្បដិហតំ** មិនបានរាំងលោកសម្ដែងដល់សេចក្ដីដែលមិនមានអ្វីបិទបាំងទុក ព្រះសារីបុត្តត្ថេរបំណងនឹងញុំាងព្រះសព្វញ្ញុតញ្ញាណឲ្យសម្រេចដោយឧបមា ទើបពោលបទមានជាអាទិ៍ថា **យាវតកំ** នេយ្យបទមានប៉ុន្មាន ។ ក្នុងបទទាំងនោះឈ្មោះថា **នេយ្យំ** ព្រោះគួរដឹង ឈ្មោះថា **នេយ្យបរិយន្តិកំ** ព្រោះព្រះញាណ មាននេយ្យបទជាទីបំផុត ក៏អ្នកមិនមែនសព្វញ្ញូ មិនមាននេយ្យ-បទជាទីបំផុត សូម្បីក្នុងនេយ្យបទមានព្រះញាណជាទីបំផុតក៏មានដូច្នេះដូចគ្នា ព្រះសារីបុត្តត្ថេរសម្ដែងសេចក្ដីដែលបានពោលទុកហើយក្នុងគូដើមឲ្យវិសេស ទៅដោយគូនេះ សម្ដែងកំណត់ដោយការបដិសេធដោយគូទី ៣ ម្យ៉ាងទៀត នេយ្យៈក្នុងបទនេះ ឈ្មោះថា **នេយ្យបថ** ព្រោះជាគន្លងនៃញាណ ។ បទថា **អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ** ធម៌ទាំងនោះតាំងនៅក្នុងទីបំផុតដោយជុំវិញដល់គ្នានឹងគ្នា គឺ មានប្រក្រតី



ញុំាងនេយ្យៈ និងញាណឲ្យអស់ទៅហើយ តាំងនៅក្នុងទីបំផុតដោយជុំវិញដល់គ្នានឹងគ្នាចាកឋានៈ ។ បទថា **អាវជ្ជនបដិពទ្ធា** ជាប់ដោយការពិចារណា គឺ ជាប់ជាមួយមនោទ្វារាវជ្ជនៈ សេចក្ដីថា រមែងដឹងលំដាប់នៃសេចក្ដីនឹករលឹកនោះឯង ។ បទថា **អាកង្ខបដិពទ្ធា** ជាប់ដោយព្រះបំណង គឺ ជាប់ដោយសេចក្ដីពេញចិត្ត សេចក្ដីថា រមែងដឹងលំដាប់នៃអាវជ្ជនចិត្ត ដោយជវនញាណ លោកពោលបទទាំងពីរក្រៅអំពីនេះ ដើម្បីប្រកាសសេចក្ដីតាមលំដាប់បទទាំងពីរនេះ ។

បទថា **ពុទ្ធោ អាសយំ ជានាតិ** ព្រះពុទ្ធជាម្ចាស់ រមែងទ្រង់ជ្រាបអធ្យាស្រ័យជដើម លោកពណ៌នាទុកក្នុងញាណកថាហើយ តែមកក្នុងមហានិទ្ទេសថា ព្រះមានព្រះភាគរមែងទ្រង់ជ្រាបអធ្យាស្រ័យ ។ ក្នុងបទនោះ មកក្នុងអនាគតស្ថានថា **ពុទ្ធស្ស ភគវតោ** ក្នុងទីនេះទីកន្លែងខ្លះថា **ពុទ្ធស្ស** ។ បទថា **អន្តមសោ** គឺ ដោយទីបំផុត ។

ក្នុងបទថា **តិមិតិមិង្គលំ** នេះ គប្បីជ្រាបដូចតទៅនេះ ត្រីមួយប្រភេទឈ្មោះថា **តិមិ** ត្រីមួយប្រភេទឈ្មោះថា **តិមិង្គលៈ** ព្រោះមានខ្លួនធំជាងត្រីតិមិនោះ អាចលេបត្រីតិមិបាន ត្រីមួយប្រភេទឈ្មោះថា តិមិតិមិង្គលៈ មានបណ្ដោយ ៥០០ យោជន៍ អាចលេបត្រីតិមិង្គលៈបាន ។ ក្នុងបទនេះ គប្បីជ្រាបថាជាឯកវចនៈ ដោយកាន់យកកំណើត ។

ក្នុងបទថា **គរុឡំ វេនតេយ្យំ** គ្រុឌត្រកូលវេនតេយ្យៈនេះ គប្បីជ្រាបថា ឈ្មោះថា **គរុឡ** ជាឈ្មោះដោយកំណើត ឈ្មោះថា **វេនតេយ្យ** ជាឈ្មោះដោយគោត្រ ។ បទថា **បទេសោ** គឺ ក្នុងឯកទេស ។ បទថា **សារីបុត្តសមា** មានបញ្ញាស្មើដោយព្រះសារីបុត្ត គប្បីជ្រាបថា លោកពោលសំដៅដល់ព្រះថេរៈដែលជាធម្មសេនាបតីរបស់ព្រះពុទ្ធជាម្ចាស់ទាំងពួង ព្រោះព្រះសាវកដ៏សេស មិនមានអ្នកណាស្មើដល់ព្រះធម្មសេនាបតីថេរៈខាងបញ្ញា សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តជាកំពូលលើភិក្ខុទាំងឡាយដែលជាសាវករបស់តថាគតផ្នែកខាងមានបញ្ញាច្រើន ក៏លោកពោលទុកក្នុងអដ្ឋកថាថា :

*សត្វទាំងឡាយណា វៀរចាកព្រះលោកនាថ*
*សត្វទាំងនោះ រមែងមិនដល់នូវចំណែកទី ១៦*
*នៃបញ្ញារបស់ព្រះសារីបុត្ត ។*

បទថា **ផរិត្វា** ផ្សាយទៅ គឺ ពុទ្ធញាណសម្រេចដល់បញ្ញាសូម្បីរបស់ទេវតា និងមនុស្សទាំងពួង ហើយផ្សាយទៅ ជ្រាបចូលទៅកាន់បញ្ញារបស់ទេវតា និងមនុស្សទាំងនោះ ដោយឋានៈ ហើយតាំងនៅ ។ បទថា **អតិយំសិត្វា** កម្ចាត់ហើយ គឺ ពុទ្ធញាណឈាន



កន្លងបញ្ញា សូម្បីរបស់ទេវតា និងមនុស្សទាំងពួង ផ្សាយទៅ កម្ចាត់ទម្លាយនេយ្យៈទាំងពួង សូម្បីមិនមែនវិស័យរបស់ទេវតា និងមនុស្សទាំងនោះ ហើយតាំងនៅ បាឋៈក្នុងមហានិទ្ទេសថា **អភិភវិត្វា** គ្របសង្កត់ហើយ គឺ ញាំញីហើយ ដោយបទថា **យេបិតេ** ជាដើម ។ ព្រះសារីបុត្តត្រូវផ្សាយទៅ កម្ចាត់ដោយប្រការនេះ ហើយសម្តែងហេតុឲ្យប្រច័ក្សនៃឋានៈ ។ ក្នុងបទទាំងនោះ បទថា **បណ្ឌិតា** គឺ ប្រកបដោយភាពជាបណ្ឌិត ។ បទថា **និបុណា** ល្អិត គឺ មានបញ្ញាល្អិតសុខុមអាចចាកធ្លុះរហូតបញ្ញាសុខុមក្នុងចន្លោះអត្ថបាន ។ បទថា **កតបរប្បវាទា** ធ្វើនូវវាទៈដេញដោល និងធ្វើវាទៈតស៊ូជាមួយជនដទៃ ។ បទថា **វាលវេធិរូបា** គឺ មានបញ្ញាប្រៀបដូចនាយខ្មាន់ធ្នូ ដែលអាចបាញ់រោមទ្រាយ ។ បទថា **តេ ភិន្ទន្តា បញ្ញា ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ** ត្រាច់ទៅកម្ចាត់បញ្ញា និងទិដ្ឋិ ដោយបញ្ញា សេចក្តីថា ត្រាច់ទៅដូច ទម្លាយទិដ្ឋិរបស់អ្នកដទៃសូម្បីសុខុម ដោយបញ្ញារបស់ខ្លួន ដូចនាយខ្មាន់ធ្នូបាញ់រោមទ្រាយដូច្នោះ ។

ម្យ៉ាងទៀត បញ្ញានោះឯង គឺ **បញ្ញាគត** ទិដ្ឋិនោះឯង គឺ **ទិដ្ឋិគត** ដូចក្នុងពាក្យថា **គូថគតំ មុត្តគតំ** គូថ មូត្រ ជាដើម ។ បទថា **បញ្ហំ អភិសង្ខរិត្វា** តាក់តែងបញ្ហា គឺ តែងពាក្យសួរ ២ បទខ្លះ ៣

បទខ្ទះ ៤ បទខ្ទះ លោកពោលអស់វារៈ ២ ដង ដើម្បីសង្គ្រោះចូលជាមួយគ្នា ព្រោះធ្វើបញ្ហាប៉ុណ្ណោះ ឲ្យច្រើនក្រៃលែងឡើង ។ បទថា **គុឡ្ហានិ ច បដិច្ឆន្នានិ ច** បញ្ហាទាំងកំបាំង និងចំហ មានបាឋៈដ៏សេសថា **អត្ថជាតានិ** កើតប្រយោជន៍ បណ្ឌិតទាំងឡាយសួរបញ្ហា ព្រោះបណ្ឌិតទាំងនោះ ឃើញប្រការដែលណែនាំយ៉ាងនោះ ដែលព្រះដ៏មានព្រះភាគទ្រង់ព្រះ បំណងយ៉ាងនេះថា ចូរសួរបញ្ហាដែលខ្លួនតែងមក ក៏ព្រះមានព្រះភាគ ទ្រង់មិនប្រទានឱកាសដើម្បីឲ្យអ្នកដទៃសួរ ទ្រង់សម្តែងធម៌ដល់អ្នក ចូលទៅគាល់ព្រះអង្គប៉ុណ្ណោះ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

បណ្ឌិតទាំងនោះ នាំគ្នាតែងបញ្ហាដោយសម្គាល់ថា នឹងចូលទៅរកព្រះសមណគោតមទូលសួរបញ្ហានេះ ប្រសិនបើព្រះសមណគោតមនោះ ត្រូវពួកយើងសួរហើយយ៉ាងនេះ នឹងព្យាករណ៍យ៉ាងនេះ ពួកយើងនឹងលើកវាទៈនោះចំពោះព្រះអង្គ សូម្បីប្រសិនបើព្រះសមណ-គោតមនោះ ត្រូវពួកយើងសួរហើយយ៉ាងនេះ នឹងព្យាករណ៍យ៉ាងនេះ ពួកយើងនឹងលើកវាទៈនោះ សូម្បីយ៉ាងនេះដល់ព្រះអង្គ ដូច្នេះ ។ បណ្ឌិតទាំងនោះ នាំគ្នាចូលទៅគាល់ព្រះសមណគោតមដល់ទីប្រថាប់ ។ ព្រះសមណគោតម ក៏ទ្រង់សម្តែង ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយ



ដោយធម្មីកថា ។ បណ្ឌិតទាំងនោះ ត្រូវព្រះសមណគោតមទ្រង់សម្តែង ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ក៏មិនសួរបញ្ហានឹងព្រះសមណគោតម បណ្ឌិតទាំងនោះនឹងលើកវាទៈដល់ព្រះសមណគោតមដូចម្តេចបាន រមែងក្លាយជាសាវករបស់ព្រះសមណគោតម ដោយពិត ។

បើសួរថា ព្រោះហេតុអ្វី បណ្ឌិតទាំងឡាយទើបមិនចូលសួរបញ្ហា ។ ឆ្លើយថា ន័យថា ព្រះមានព្រះភាគកាលទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ទ្រង់ពិចារណាមើលអធ្យាស្រ័យរបស់បរិស័ទ តែសេចក្តីនោះទ្រង់ឃើញថា បណ្ឌិតទាំងនេះនាំគ្នាមកធ្វើបញ្ហាលាក់កំបាំងសម្ងាត់ ឲ្យមានសារៈតាមបំណង លុះបណ្ឌិតទាំងនោះមិនបានសួរព្រះអង្គឡើយ ព្រះអង្គទ្រង់ពិចារណាឃើញថា ទោសទាំងឡាយមានប្រមាណប៉ុណ្ណោះ ក្នុងការសួរបញ្ហាប្រមាណប៉ុណ្ណោះ ក្នុងការឆ្លើយបញ្ហាប្រមាណប៉ុណ្ណោះ ក្នុងអត្ថ ក្នុងបទ ក្នុងអក្ខរៈ ដូច្នេះ កាលនឹងសួរបញ្ហាទាំងនេះគប្បីសួរយ៉ាងនេះ កាលនឹងដោះស្រាយបញ្ហា គួរដោះស្រាយយ៉ាងនេះដូច្នោះ ទើបព្រះអង្គទ្រង់ដាក់បញ្ហាដែលបណ្ឌិតទាំងនោះនាំមក ធ្វើឲ្យមានសារៈដោយល្អ ទុកក្នុងរវាងធម្មកថាហើយ ទើបទ្រង់សម្តែង ។ បណ្ឌិតទាំងនោះរមែងពេញចិត្តថា យើងមិនសួរបញ្ហាទាំងនេះ ជាការប្រសើររបស់យើង ប្រសិនបើយើងគប្បីសួរព្រះសមណគោតម ទ្រង់គប្បីធ្វើឲ្យពួក

យើងតាំងនៅតិចតួចបានឡើយ ។ ប្រការមួយទៀត ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលទ្រង់សម្តែងធម៌ ទ្រង់រមែងផ្សាយមេត្តាទៅកាន់បរិស័ទ ដោយការផ្សាយមេត្តា មហាជនរមែងមានចិត្តជ្រះថ្លាក្នុងព្រះទសពល ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់មានព្រះរូបឆោមល្អស្អាត គួរទស្សនា មានព្រះសូរសៀងពីរោះ មានព្រះជិវ្ហាទន់ មានព្រះទន្តស្និទ្ធ ទ្រង់ពោលធម៌ដូចស្រោចហឫទយដោយទឹកអម្រិត ក្នុងពេលទ្រង់ពោលធម៌នោះ អ្នកមានចិត្តជ្រះថ្លាដោយទ្រង់ផ្សាយមេត្តារមែង មានការគិតយ៉ាងនេះថា យើងមិនអាចនឹងចាប់វត្ថុផ្ទុយគ្នាជាមួយព្រះមានព្រះភាគ ទ្រង់ពោលកថាមិនមានពីរ កថាមិនមែនជាមោឃៈ កថានាំសត្វចេញទៅ មានសភាពបែបនេះឡើយ បណ្ឌិតទាំងឡាយរមែងមិនសួរបញ្ហា ព្រោះសភាពនៃខ្លួនជ្រះថ្លានោះឯង ។

បទថា **កថិតា វិសជ្ជិតា ច** បញ្ហាទាំងនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែង ទ្រង់ដោះស្រាយហើយ សេចក្តីថា បញ្ហាទាំងនោះព្រះមានព្រះភាគទ្រង់ពោល ដោយការត្រាស់បញ្ហាដែលបណ្ឌិតទាំងឡាយសួរថា ពួកលោកចូរសួរយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ដោះស្រាយដោយប្រការដែលគួរដោះស្រាយនោះឯង ។ បទថា **និទ្ទិដ្ឋការណា** មានហេតុដែលទ្រង់សម្តែងឲ្យឃើញច្បាស់ សេចក្តីថា បញ្ហាទាំងនោះ



មានហេតុដែលព្រះមានព្រះភាគទ្រង់សម្តែងឲ្យឃើញច្បាស់ ដោយការដោះស្រាយធ្វើឲ្យមានហេតុយ៉ាងនេះថា ការដោះស្រាយរមែងមានដោយហេតុការណ៍យ៉ាងនេះ ។បទថា **ឧបក្ខិត្តកា ច តេ ភគវតោ សម្បជ្ជន្តិ** បណ្ឌិតទាំងនោះចូលទៅបង្គំគាល់ រមែងប្រាកដដល់ព្រះមានព្រះភាគ សេចក្តីថា បណ្ឌិតទាំងនោះ មានខត្តិយបណ្ឌិតជាដើម ចូលគាល់ទៀបព្រះបាទ រមែងប្រាកដដល់ព្រះមានព្រះភាគ ដោយការដោះស្រាយបញ្ហារបស់ព្រះមានព្រះភាគជាម្ចាស់ ទាំងសាវក ទាំងឧបាសក រមែងប្រាកដ អធិប្បាយថា បណ្ឌិតទាំងនោះរមែងដល់សាវកសម្បត្តិ ឬឧបាសកសម្បត្តិ ។ បទថា **អថ** ជានិបាតចុះក្នុងអត្ថថា លំដាប់ អធិប្បាយថា ក្នុងលំដាប់ព្រមដោយសម្បត្តិដែលបណ្ឌិតទាំងនោះចូលទៅគាល់ ។ បទថា **តត្ថ** គឺ ក្នុងទីនោះ ឬក្នុងអធិការនោះ ។ បទថា **អតិរោចតិ** រមែងរុងរឿង គឺ ភ្លឺច្បាស់យ៉ាងក្រៃលែង ។ បទថា **យទិទំ បញ្ញាយ** គឺ ដោយបញ្ញា សេចក្តីថា ព្រះមានព្រះភាគរមែងរុងរឿងដោយបញ្ញារបស់ព្រះអង្គ ។ **ឥតិ** សព្ទ ចុះក្នុងអត្ថនៃហេតុ សេចក្តីថា ព្រះមានព្រះភាគជាបុគ្គលដ៏កំពូល មានព្រះបញ្ញាទូលំទូលាយ ដោយហេតុនេះ ។

បទថា **ភាគំ អភិកុយ្យតីតិ ភូរិបញ្ញោ** ឈ្មោះថា **ភូរិបញ្ញោ** មាន

បញ្ញាប្រៀបដូចផែនដី ព្រោះអត្ថថា គ្របសង្កត់រាគៈ សេចក្តីថា ឈ្មោះថា **ភូរិបញ្ញា** ព្រោះមគ្គប្បញ្ញានោះ ៗ គ្របសង្កត់ ញាំញីរាគៈដែលជាទោសជាប់ខ្លួន ។ បទថា **ភូរិ** មានអត្ថថា ធ្លាត ឈ្លាសវៃ សេចក្តីធ្លាតរមែងគ្របសង្កត់វត្ថុដែលជាបដិបក្ខ សេចក្តីមិនធ្លាតគ្របសង្កត់មិនបាន ព្រោះដូច្នោះលោកទើបពោលថា អត្ថនៃការគ្របសង្កត់ដោយភូរិប្បញ្ញា ។ បទថា **អភិភវិតា** គ្របសង្កត់ហើយ គឺ ផលប្បញ្ញានោះ ៗ គ្របសង្កត់ ញាំញីរាគៈនោះ ៗ ។ បាឋៈថា **អភិភវិតា** ខ្វះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

ក្នុងបទ មានរាគៈជាដើម គប្បីជ្រាបសេចក្តីដូចតទៅនេះ ។ **រាគ** មានលក្ខណៈត្រេកអរ ។ **ទោស** មានលក្ខណៈប្រទូសរ៉ាយ ។ **មោហ** មានលក្ខណៈវង្វេង ។ **កោធ** មានលក្ខណៈក្រោធ ។ **ឧបនាហ** មានលក្ខណៈចងសេចក្តីក្រោធទុក ។ កោធៈកើតមុន ឧបនាហៈកើតជាខាងក្រោយ ។ **មក្ខ** មានលក្ខណៈលុបគុណអ្នកដទៃ ។ **បលាស** មានលក្ខណៈវាយឫកស្មើ ។ **ឥស្សា** មានលក្ខណៈធ្វើសម្បត្តិអ្នកដទៃឲ្យវិនាស ។ **មច្ឆរិយ** មានលក្ខណៈបិទបាំងក្នុងសម្បត្តិរបស់ខ្លួន ។ **មាយា** មានលក្ខណៈបិទបាំងសេចក្តីអាក្រក់ដែលខ្លួនធ្វើ ។ **សាឋេយ្យ** មានលក្ខណៈប្រកាសគុណដែលមិនមានរបស់ខ្លួន ។ **ថម្ភ** មានលក្ខណៈ



តឹងនៃចិត្ត ។ **សារម្ភ** មានលក្ខណៈអួតអាងខ្លួន ។ **មានះ** មានលក្ខណៈប្រកាន់ខ្លួន ។ **អតិមានះ** មានលក្ខណៈប្រកាន់ខ្លួនខ្លាំង ។ **មទ** មានលក្ខណៈស្រវឹង ។ **បមាទ** មានលក្ខណៈបណ្តែតបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ។

ដោយបទថា **រាគោ អរិ តំ អរឹ មទ្ទនិបញ្ញា** ជាបញ្ញា ញាំញីរាគៈដែលជាសត្រូវជាដើម លោកអធិប្បាយទុកយ៉ាងណា កិលេសមានរាគៈជាដើម ឈ្មោះថា **ភូអរិ** ព្រោះអត្ថថា ជាសត្រូវក្នុងចិត្ត-សន្តាន ។ លោកពោលថា **ភូរិ** ព្រោះលុប **អ** អក្សរដោយបទសន្ធិ ។ គប្បីជ្រាបថា កាលគួរនឹងពោលថា បញ្ញាញាំញី **ភូរិ** នោះឈ្មោះថា **ភូរិមទ្ទនិបញ្ញា** លោកពោលថា **ភូរិបញ្ញា** ព្រោះលុប **មទ្ទនិ** សព្ទចេញ ។ ក៏បទថា **តំ អរឹ មទ្ទនី** លោកកំណត់បទថា **តេសំ អរីនំ មទ្ទនី** ការញាំញីសត្រូវទាំងនោះ ។ បទថា **បឋវីសមាយ** ស្មើដោយផែនដី គឺ ឈ្មោះថា ស្មើដោយផែនដី ព្រោះអត្ថថា ធំទូលាយនោះឯង ។ បទថា **វិត្ថតាយ** ទូលំទូលាយ គឺ ផ្សាយទៅក្នុងវិស័យដែលគួរដឹងបាន មិនប្រព្រឹត្តទៅក្នុងឯកទេស ។ បទថា **វិបុលាយ** ធំទូលាយ គឺ ឱឡារ ។ តែមកក្នុងមហានិទ្ទេសថា **វិបុលាយ វិត្ថតាយ** បរិបូរណ៍ទូលំទូលាយ ។ បទថា **សមន្នាគតោ** គឺ បុគ្គលអ្នកប្រកបហើយ ។

**ឥតិ** សព្ទ ចុះក្នុងអត្ថថា **ហេតុ** សេចក្តីថា ដោយហេតុនេះ បញ្ញារបស់បុគ្គលនោះ ឈ្មោះថា **ភូរិបញ្ញា** ព្រោះបុគ្គលជាអ្នកប្រកបដោយភូរិ-ប្បញ្ញា ព្រោះហេតុនោះ បុគ្គលរមែងត្រេកអរក្នុងអត្ថដែលចម្រើនហើយ កាលគួរនឹងពោលថា **ភូរិបញ្ញស្ស បញ្ញា ភូរិបញ្ញបញ្ញា** បញ្ញារបស់បុគ្គលអ្នកប្រកបដោភូរិប្បញ្ញា ឈ្មោះថា **ភូរិបញ្ញបញ្ញា** លោកពោល **ភូរិបញ្ញា** ព្រោះលុប **បញ្ញា** សព្ទមួយចេញ ។ ម្យ៉ាងទៀត ឈ្មោះថា **ភូរិបញ្ញា** ព្រោះមានបញ្ញាស្មើដោយផែនដី ។ បទថា **អបិច** លោកពោលដើម្បីឲ្យឃើញបរិយាយដទៃ ។ បទថា **បញ្ញាយមេតំ** គឺ ពាក្យថា **ភូរិ** នេះ ជាឈ្មោះរបស់បញ្ញា ។ បទថា **អធិវចនំ** ជាពាក្យពោលយ៉ាងក្រៃលែង ។ បទថា **ភូរិ** ឈ្មោះថា **ភូរិ** ព្រោះអត្ថថា រមែងត្រេកអរក្នុងអត្ថដែលចម្រើនហើយ ។ បទថា **មេធា** បញ្ញា ឈ្មោះថា **មេធា** ព្រោះអត្ថថា ទម្លាយកិលេសទាំងឡាយ ដូចរន្ទះទម្លាយវត្ថុដែលផ្តុំដោយថ្មដូច្នោះ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **មេធា** ព្រោះអត្ថថា កាន់យកទុកដោយរហ័ស ។ បទថា **បរិណាយកា** បញ្ញាជាបរិនាយក ។ ឈ្មោះថា **បរិណាយិកា** ព្រោះអត្ថថា បញ្ញារមែងកើតឡើងដល់សត្វណា រមែងនាំសត្វនោះទៅក្នុងធម៌ដែលសម្បយុត្ត ក្នុងការបដិបត្តិនូវប្រយោជន៍ និងក្នុងបដិវេធដែលមានលក្ខណៈពិតប្រាកដ ដោយបទ



ទាំងនេះ គឺ លោកពោលដល់ពាក្យដែលបរិយាយនៃបញ្ញាសូម្បីយ៉ាងដទៃផង ។

បទថា **បញ្ញាពាហុល្លំ** ភាពជាអ្នកមានបញ្ញាច្រើន ឈ្មោះថា **បញ្ញាពហុលោ** ព្រោះមានបញ្ញាច្រើន ភាពនៃបុគ្គលអ្នកមានបញ្ញាច្រើននោះ ឈ្មោះថា **បញ្ញាពាហុល្លៈ** បញ្ញានោះឯងប្រព្រឹត្តទៅច្រើន ។

ក្នុងបទមានជាអាទិ៍ថា **ឥធេកច្ចោ** បុគ្គលខ្លះក្នុងលោកនេះ បានដល់ កល្យាណបុថុជ្ជន ឬអរិយបុគ្គល ។ ឈ្មោះថា **បញ្ញាគរុកោ** ព្រោះជាអ្នកមានបញ្ញាធ្ងន់ ។ ឈ្មោះថា **បញ្ញាចរិតោ** ព្រោះជាអ្នកមានបញ្ញាជាចរិត ។ ឈ្មោះថា **បញ្ញាសយោ** ព្រោះមានបញ្ញាជាទីអាស្រ័យ ។ ឈ្មោះថា **បញ្ញាធិមុត្តោ** ព្រោះបង្អោនចិត្តជឿដោយបញ្ញា ។ ឈ្មោះថា **បញ្ញាធជោ** ព្រោះមានបញ្ញាជាទង់ជ័យ ។ ឈ្មោះថា **បញ្ញាកេតុ** ព្រោះមានបញ្ញាជាកំពូល ។ ឈ្មោះថា **បញ្ញាធិបតិ** ព្រោះមានបញ្ញាជាធំ ។ ឈ្មោះថា **បញ្ញាធិបតេយ្យោ** ព្រោះមកពីភាពជាអ្នកមានបញ្ញាជាធំ ។ ឈ្មោះថា **វិចយពហុលោ** ព្រោះមានការពិចារណាសភាវធម៌ច្រើន ។ ឈ្មោះថា **បវិចយពហុលោ** ព្រោះមានការស្រាវជ្រាវសភាវធម៌ដោយប្រការផ្សេង ៗ ច្រើន ។ ការធ្លាក់ចុះដោយបញ្ញាហើយ ប្រាកដធម៌នោះ ៗ គឺ ធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា

**ឱក្ខាយន** ឈ្មោះថា **ឱក្ខាយនពហុលោ** ព្រោះមានការពិចារណាច្រើន ។ ការសម្លឹងពិចារណាធម៌នោះ ៗ ដោយបញ្ញាដ៏ប្រពៃ ឈ្មោះថា **សមេក្ខា** ។ ដំណើរទៅ ការប្រព្រឹត្តទៅ ដោយសម្លឹងពិចារណាដោយប្រពៃ ឈ្មោះថា **សមេក្ខាយនំ** ។ ឈ្មោះថា **សមេក្ខាយនធម្មោ** ព្រោះមានការសម្លឹងពិចារណាដោយប្រពៃនូវធម៌ជាប្រក្រតី ។ ឈ្មោះថា **វិភូតវិហារី** ព្រោះធ្វើធម៌នោះឲ្យជាក់ច្បាស់ ឲ្យប្រាកដហើយ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **វិភូតវិហារី** ព្រោះមានធម៌ជាគ្រឿងនៅដ៏ជាក់ច្បាស់ ។ ឈ្មោះថា **តច្ចរិតោ** ព្រោះមានបញ្ញាជាចរិត ។ ឈ្មោះថា **តគ្គរុកោ** ព្រោះមានបញ្ញាធ្ងន់ ។ ឈ្មោះថា **តព្ពហុលោ** ព្រោះមានបញ្ញាច្រើន ។ ការបង្អោនទៅក្នុងបញ្ញានោះ ឈ្មោះថា **តន្និន្នោ** ។ ការបង្អោនទៅក្នុងបញ្ញានោះ ឈ្មោះថា **តប្បោណោ** ។ វត្ថុដែលបង្ហាញទៅក្នុងបញ្ញា ឈ្មោះថា **តប្បព្ភារោ** ។ បង្អោនចិត្តទៅក្នុងបញ្ញានោះ ឈ្មោះថា **តទធិមុត្តោ** ។ បញ្ញានោះជាធំ ឈ្មោះថា **តទធិបតិ** ។ អ្នកមកចាកបញ្ញាជាធំនោះ ឈ្មោះថា **តទធិបតេយ្យោ** ។ បទមានជាអាទិ៍ថា **បញ្ញាគរុកោ** មានបញ្ញាធ្ងន់ លោកពោលចាប់ផ្តើមអំពីការកើតក្នុងជាតិមុន ដូចក្នុងប្រយោគមានជាអាទិ៍ថា បុគ្គលនេះជាអ្នកធ្ងន់ក្នុងកាម រមែងដឹងក្នុងការសេពកាម ។ បទមានជាអាទិ៍ថា



**តច្ចរិតោ** លោកពោលដល់ក្នុងជាតិនេះ ។

**សីឃបញ្ញា** ( បញ្ញារហ័ស ) **លហុបញ្ញា** ( បញ្ញាស្រាល ) **ហាសបញ្ញា** ( បញ្ញារីករាយ ) និង **ជវនបញ្ញា** ( បញ្ញាស្ទុះទៅ ) ជាបញ្ញាលាយដោយលោកិយៈ និងលោកុត្តរៈ ។

ឈ្មោះថា **សីឃបញ្ញា** ដោអត្ថថា រហ័ស ។ ឈ្មោះថា **លហុបញ្ញា** ដោយអត្ថថា ស្រាល ។ ឈ្មោះថា **ហាសបបញ្ញា** ដោយអត្ថថា រីករាយ ។ ឈ្មោះថា **ជវនបញ្ញា** ដោយអត្ថថា ស្ទុះទៅក្នុងសង្ខារចូលដល់វិបស្សនា និងវិសង្ខារ ។ បទថា **សីឃំ សីឃំ** ក្លាម ៗ លោកពោលពីរដង ដើម្បីសង្គ្រោះសីលជាដើមច្រើន ។ បទថា **សីលានិ** គឺ បាតិមោក្ខសំវរៈសីល ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុក ដោយអំណាចនៃចារិតសីល និងវារិតសីល ។ បទថា **ឥន្ទ្រិយសំវរំ** ឥន្ទ្រិយសំវរៈ គឺ ការមិនធ្វើឲ្យរាគៈ បដិឃៈ ចូលទៅកាន់ឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ការពារដោយមុខផ្សេងគ្នា គឺ សតិ ។ បទថា **ភោជនេ មត្តញ្ញុតំ** គឺ ភាពជាអ្នកដឹងប្រមាណក្នុងការបរិភោគដោយពិចារណាហើយ ទើបបរិភោគ ។ បទថា **ជាគរិយានុយោគំ** ប្រកបដោយសេចក្តីព្យាយាម ព្រោះជាអ្នកភ្ញាក់រឭក គឺ ឈ្មោះថា **ជាគរោ** ជាអ្នកភ្ញាក់រឭក ព្រោះក្នុង ៣ ចំណែក នៃថ្ងៃរមែងភ្ញាក់ គឺ មិនដេក

លក់ក្នុងចំណែកបឋមយាម និងមជ្ឈិមយាមនៃរាត្រី បំពេញសមណធម៌តែម្យ៉ាង ។ ភាពជាអ្នកភ្ញាក់ កម្ម គឺ ភាពជាអ្នកភ្ញាក់ ការប្រកបរឿយ ៗ របស់អ្នកភ្ញាក់ ឈ្មោះថា **ជាគរិយានុយោគ** ញ៉ាំងជាគរិយានុយោគនោះឲ្យបរិបូរ ។ បទថា **សីលក្ខន្ធំ** គឺ សីលក្ខន្ធដែលជារបស់ព្រះសេក្ខៈ ឬព្រះអសេក្ខៈ ។ ខន្ធ សូម្បីក្រៅអំពីនេះ ក៏គប្បីជ្រាបយ៉ាងនេះ ។ បទថា **បញ្ញាក្ខន្ធំ** គឺ មគ្គប្បញ្ញា និងលោកិយប្បញ្ញារបស់ព្រះសេក្ខៈ និងព្រះអសេក្ខៈ ។ បទថា **វិមុត្តិក្ខន្ធំ** គឺ ផលវិមុត្តិ ។ បទថា **វិមុត្តិញ្ញាណទស្សនក្ខន្ធំ** គឺ បច្ចវេក្ខណញ្ញាណ ។ បទថា **ហាសពហុលោ** ជាអ្នកមានសេចក្ដីរីករាយ ជាមូលបទ ។ បទថា **វេទពហុលោ** ជាអ្នកមានសេចក្ដីពេញចិត្តច្រើន ជាបទសម្ដែងដោយការសោយសោមនស្សវេទនាដែលសម្បយុត្តដោយបីតិនោះឯង ។ បទថា **តុដ្ឋិពហុលោ** ជាអ្នកមានសេចក្ដីត្រេកអរច្រើន ជាបទសម្ដែងដោយការត្រេកអរនៃបីតិមានកម្លាំងតិច ។ បទថា **បាមុជ្ជពហុលោ** ភាពជាអ្នកមានបាមោជ្ជៈច្រើន ជាបទសម្ដែងដល់បាមោជ្ជៈមានកម្លាំង គឺ បីតិ ។ បទថា **យំកិញ្ចិ រូបំ** ជាអាទិ៍ មានសេចក្ដីដូចបានពោលហើយ ក្នុងសមសនញ្ញាណនិទ្ទេស ។ បទថា **តុលយិត្វា** គឺ ថ្លឹងថ្លែងដោយកលាបសម្មសនៈ ( ការពិចារណាឃើញជាដុំ ជាកង ) ។ បទថា



**តីរយិត្វា** គឺ ពិចារណាដោយឧទយព្វយានុបស្សនាជាដើម ។ បទថា **វិភាវយិត្វា** ពិចារណា គឺ ធ្វើឲ្យប្រាកដដោយភង្គានុបស្សនាជាដើម ។ បទថា **វិភូតំ កត្វា** ធ្វើឲ្យជាក់ច្បាស់ គឺ ធ្វើឲ្យច្បាស់ដោយសង្ខារុបេក្ខាញាណ ។

**តិក្ខប្បញ្ញា** ( បញ្ញាក្លៀវក្លា ) ជាលោកុត្តរៈតែម្យ៉ាង ។ បទថា **ឧប្បន្នំ** កើតឡើងហើយ គឺ វិតក្កៈសូម្បីលះបានដោយសមថៈ និងវិបស្សនា ដោយវិក្ខម្ភនៈ និងតទង្គៈ លោកក៏ពោលថា កើតឡើងនឹងដកចេញមិនបាន ព្រោះមិនកន្លងភាពធម្មតាដែលកើតឡើង ព្រោះដកចេញមិនបានដោយអរិយមគ្គ ។ ក្នុងទីនេះ លោកបំណងយកវិតក្កៈដែលកើតឡើងហើយដកចេញមិនបាននោះ ។ បទថា **នាធិវាសេតិ** មិនទទួលទុក គឺ មិនលើកឡើងកាន់សត្វទាំងឡាយ បទថា **បជហតិ** រមែងលះ គឺ លះដោយដាច់ខាត ។ បទថា **វិនោទេតិ** រមែងបន្ទោបង់ គឺ រមែងបន្សាត់ចេញទៅ ។ បទថា **ព្យន្តីករោតិ** រមែងធ្វើឲ្យអស់ដល់ទីបំផុត គឺ ធ្វើឲ្យប្រាសចាកទីបំផុត ។ បទថា **អនភាវំ គមេតិ** ឲ្យដល់ការមិនមានតទៅ សេចក្ដីថា ដល់អរិយមគ្គតាមលំដាប់វិបស្សនាហើយ ឲ្យដល់ការមិនមានដោយអំណាចនៃសមុច្ឆេទ ។

វិតក្កៈប្រកបដោយកាម ឈ្មោះថា **កាមវិតក្ក** វិតក្កៈប្រកបដោយ

សេចក្តីស្លាប់របស់អ្នកដទៃ ឈ្មោះថា **ព្យាបាទវិតក្ក** ។ វិតក្កៈប្រកប ដោយការបៀតបៀនអ្នកដទៃ ឈ្មោះថា **វិហិង្សាវិតក្ក** ។ បទថា **បាបកេ** គឺ លាមក ។ បទថា **អកុសលេ ធម្មេ** គឺ ធម៌ដែលមិនមានសេចក្តីឆ្លាត ។ បទថា **និព្វេធិកបញ្ញា** បញ្ញាជាគ្រឿងទម្លាយកិលេស គឺ មគ្គបញ្ញា ដែលកើតឡើងដល់បុគ្គលអ្នកច្រើនដោយសេចក្តីនឿយណាយ ។ បទថា **ឧព្វេគពហុលោ** ជាអ្នកច្រើនដោយអំណាចភយញ្ញាណ ភ័យព្រោះញាណ ។ បទ ថា **ឧត្តាសពហុលោ** ជាអ្នកច្រើនទៅដោយសេចក្តីញញើតញញើម គឺ ច្រើនទៅដោយសេចក្តីភ័យខ្លាចដ៏ខ្លាំងក្លា ។ បទនេះ ជាការអធិប្បាយ បទមុននោះឯង ។ បទថា **ឧក្កណ្ឋនពហុលោ** គឺ ជាអ្នកច្រើនទៅដោយ សេចក្តីនឿយណាយ ព្រោះបែរមុខឆ្ពោះវិសង្ខារ ក្រៅអំពីសង្ខារ ។ បទ ថា **អនភិរតិពហុលោ** ជាអ្នកច្រើនទៅដោយសេចក្តីមិនពេញចិត្ត លោក សម្តែងដល់ការមិនមានសេចក្តីត្រេកអរ ដោយសេចក្តីនឿយណាយ ។ សូម្បីបទនេះ ព្រះសារីបុត្តត្ថេរអធិប្បាយសេចក្តីនោះដោយពាក្យទាំងពីរ ។

ក្នុងបទទាំងនោះ បទថា **ពហិមុខោ** បែរមុខចេញ គឺ ឆ្ពោះមុខ ចំពោះព្រះនិព្វានដែលជាចំណែកក្រៅពីសង្ខារ ។ បទថា **ន រមតិ** មិន ត្រេកអរ គឺ មិនត្រេកអរខ្លាំង ។ បទថា **អនិព្វិទ្ធបុព្វំ** មិនធ្លាប់នឿយ-ណាយ គឺ មិនធ្លាប់ដល់ទីបំផុតក្នុងសង្សារ ដែលមិនដឹងខាងដើម និង



ទីបំផុត ហើយនឿយណាយ ។ បទថា **អប្បទាលិតបុព្វំ** មិនធ្លាប់ទម្លាយ ជាពាក្យពោលដល់អត្ថរបស់បទនោះ សេចក្តីថា មិនធ្លាប់ទម្លាយដោយ ការធ្វើទីបំផុតនោះឯង ។ បទថា **លោភក្ខន្ធំ** គំនរលោភៈ គឺ គំនរ លោភៈ ឬមានចំណែកនៃលោភៈ ។

បទថា **ឥមាហិ សោឡសហិ បញ្ញាហិ សមន្នាគតោ** បុគ្គលអ្នក ប្រកបដោយបញ្ញា ១៦ ប្រការទាំងនេះ លោកពោលដល់ព្រះអរហន្ត ដោយកំណត់យ៉ាងឧក្រិដ្ឋ សូម្បីព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះ អនាគាមី ក៏រមែងបានដូចគ្នា ព្រោះលោកពោលទុកក្នុងខាងក្រោយថា **ឯកោ សេក្ខបដិសម្ភិទប្បត្តោ** បុគ្គលម្នាក់ ជាព្រះសេក្ខៈបានសម្រេច បដិសម្ភិទា ។

(ចប់ អដ្ឋកថាសោឡសបញ្ញានិទ្ទេស)

# អដ្ឋកថា បុគ្គលវិសេសនិទ្ទេស

ព្រះសារីបុត្តត្ថេរ សម្តែងដល់លំដាប់របស់បុគ្គលវិសេសដែលសម្រេចបដិសម្ភិទា ដោយបទមានជាអាទិ៍ថា **ទ្វេ បុគ្គលា** បុគ្គល ២ ប្រភេទ ។ ក្នុងបទទាំងនោះ បទថា **បុព្វយោគោ** អ្នកមានសេចក្តីព្យាយាមខាងដើម គឺ ប្រកបដោយបុណ្យដែលជាហេតុសម្រេចបដិសម្ភិទាក្នុងអតីតជាតិ ។ បទថា **តេន** គឺ ហេតុដែលមានសេចក្តីព្យាយាមមកអំពីខាងដើមនោះ ។ សូម្បីបទដ៏សេសក៏យ៉ាងនោះ ។ បទថា **អតិរេកោ ហោតិ** ជាអ្នកដ៏ប្រសើរ គឺ ព្យាយាមច្រើនឡើង ឬព្រោះមានសេចក្តីព្យាយាមច្រើនក្រៃលែង លោកទើបថា **អតិរេកោ** ។ បទថា **អធិកោ ហោតិ** ជាអ្នកប្រសើរ គឺ ជាអ្នកខ្ពង់ខ្ពស់ ។ បទថា **វិសេសោ ហោតិ** ជាអ្នកវិសេស គឺ វិសេសជាទីបំផុត ឬព្រោះមានសេចក្តី ព្យាយាមវិសេស ទើបលោកពោលថា **វិសេសោ** ។ បទថា **ញាណំ បភិជ្ជតិ** ញាណដែលបែកធ្លាយ គឺ ការបែកធ្លាយក្នុងបដិសម្ភិទាញាណ ។ បទថា **ពហុស្សុតោ** ជាពហុសូត គឺ ជាពហុសូតដោយអំណាចនៃព្រះពុទ្ធវចនៈ ។ បទថា **ទេសនាពហុលោ** ជាអ្នកច្រើនដោយទេសនា គឺ ដោយអំណាចនៃធម្មទេសនា ។ បទថា **គរូបនិស្សិតោ**



ជាអ្នកអាស្រ័យគ្រូ គឺ ចូលទៅអាស្រ័យគ្រូដែលក្រៃលែងដោយបញ្ញា ។ បទថា **វិហាពហុលោ** ជាអ្នកច្រើនទៅដោយវិហារធម៌ បានដល់ ជាអ្នកមានវិហារធម៌ គឺ ច្រើនដោយវិបស្សនា ជាអ្នកមានវិហារធម៌ គឺ ច្រើនដោយផលសមាបត្តិ ។ បទថា **បច្ចវេក្ខណាពហុលោ** ជាអ្នកច្រើនដោយការពិចារណា បានដល់ បើមានវិហារធម៌ គឺ វិបស្សនា រមែងជាអ្នកមានការពិចារណាវិបស្សនា កាលបើមានវិហារធម៌ គឺ ផលសមាបត្តិ រមែងជាអ្នកច្រើនដោយការពិចារណាផលសមាបត្តិ ។ បទថា **សេក្ខប្បដិសម្ភិទប្បត្តោ** គឺ ជាព្រះសេក្ខៈសម្រេចបដិសម្ភិទា ជាព្រះអសេក្ខៈសម្រេចបដិសម្ភិទា ក៏យ៉ាងនោះ ។

ក្នុងបទថា **សាវកបារមិប្បត្តោ** ជាអ្នកសម្រេចសាវកបារមីនេះ មានវិនិច្ឆ័យដូចតទៅនេះ ។ ការដល់ត្រើយនៃសាវកញ្ញាណ ៦៧ របស់ព្រះមហាសាវកអ្នកប្រសើរជាងសាវក អ្នកមានបញ្ញាច្រើនទាំងឡាយ ឈ្មោះថា **បារមី** ។ បារមីរបស់ព្រះសាវក ឈ្មោះថា សាវកបារមី ។ អ្នកដល់សាវកបារមីនោះ ឈ្មោះថា **សាវកបារមិប្បត្តោ** ។ បាឋៈថា **សាវកបារមិតាប្បត្តោ** ខ្លះ ។ មហាសាវកនោះ ជាអ្នករក្សា និង ជាអ្នកបំពេញសាវកញ្ញាណ ៦៧ ឈ្មោះថា **បរមោ** ។ ការកើត ឬកម្មនៃបរមៈនោះ ដោយញាណកិរិយា ៦៧ យ៉ាងនេះ របស់បរមៈនោះ

ឈ្មោះថា **បារមី** ។ បារមីរបស់ព្រះសាវកនោះ ឈ្មោះថា **សាវក-បារមី** ។ អ្នកដល់សាវកបារមីនោះ ឈ្មោះថា **សាវកបារមិប្បត្តោ** ។ បទថា **សាវកបារមិប្បត្តោ** បានដល់ ព្រះសាវកអង្គណាមួយ មានព្រះមហាមោគ្គល្លានត្ថេរជាដើម ។

ព្រះសារីបុត្តត្ថេរពោលថា **ឯកោ បច្ចេកសម្ពុទ្ធោ** អ្នកដែលជាព្រះបច្ចេកពុទ្ធ ព្រោះមិនមានព្រះសាវកដទៃ ដូចជាព្រះសាវកដែលបានសម្រេចជាសាវកបារមី ។ ព្រះសារិបុត្តត្ថេរ សម្តែងសេចក្តីសរុបដែលបានពោលហើយ ដោយបទមានជាអាទិ៍ថា **បញ្ញាបភេទកុសលោ** ទ្រង់ជាអ្នកឆ្លាតក្នុងប្រភេទនៃបញ្ញា ។ លោកសម្តែងញាណច្រើនយ៉ាង នៃញាណកថាដោយច្រើន ។ លោកពោលដល់បញ្ញាសូម្បីតែមួយ នៃបញ្ញាកថាដោយច្រើនឲ្យផ្សេង ៗ គ្នា ដោយអាការផ្សេង ៗ គ្នានេះ ជាសេចក្តីពិសេសដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថាបុគ្គលវិសេសនិទ្ទេស)



## ២–អដ្ឋកថា ឥទ្ធិកថា

ពេលនេះ នឹងពណ៌នាតាមសេចក្តីដែលមិនទាន់បានពណ៌នាទុក នៃឥទ្ធិកថា ដែលព្រះសារីបុត្តត្ថេរសម្តែងដល់បុញ្ញានុភាពក្នុងលំដាប់នៃបញ្ញាកថា គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យសួរទាំងនោះ ដូចតទៅនេះ មុន បទថា **កា ឥទ្ធិ** ឫទ្ធិដូចម្តេច ជា **សភាវបុច្ឆា** ( សួរដល់សភាវៈ ) ។ បទថា **កតិឥទ្ធិយោ** ឫទ្ធិប៉ុន្មាន ជា **បភេទបុច្ឆា** ( សួរដល់ប្រភេទ ) ។ បទថា **កតិភូមិយោ** ភូមិនៃឫទ្ធិមានប៉ុន្មាន ជា **សម្ភារបុច្ឆា** ( សួរដល់ការសន្សំ ) ។ បទថា **កតិបាទា** បាទនៃឫទ្ធិមានប៉ុន្មាន ជា **បតិដ្ឋបុច្ឆា** ( សួរដល់ទីតាំង ) ។ បទថា **កតិបទានិ** បទនៃឫទ្ធិមានប៉ុន្មាន ជា **អាសន្នការណបុច្ឆា** ( សួរដល់ហេតុដែលជិតបំផុត ) ។ បទថា **កតិមូលានិ** មូលនៃឫទ្ធិមានប៉ុន្មាន ជា **អាទិ-ការណបុច្ឆា** ( សួរហេតុជាខាងដើម ) ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យឆ្លើយដូចតទៅនេះ បទថា **ឥជ្ឈ-នដ្ឋេន ឥទ្ធិ** ឈ្មោះថាឫទ្ធិ ដោយអត្ថថា សម្រេច អធិប្បាយថា ដោយអត្ថថា សម្រេច និងដោយអត្ថថា បានចំពោះ ព្រោះវត្ថុណាសម្រេច និងបានចំពោះ លោកពោលវត្ថុនោះថា រមែងសម្រេច សមដូចព្រះដ៏

មានព្រះភាគត្រាស់ទុកថា ប្រសិនបើវត្ថុកាមនោះសម្រេចដល់សត្វអ្នកប្រាថ្នាកាមហើយ ដូច្នេះ ។ គប្បីជ្រាបបទមានជាអាទិ៍ថា ឈ្មោះថា **ឥទ្ធិ** ព្រោះនេក្ខម្មៈរមែងសម្រេច ឈ្មោះថា **បាដិហារិយំ** ព្រោះនេក្ខម្មៈរមែងកម្ចាត់កាមច្ឆន្ទៈ គប្បីជ្រាបន័យដទៃដូចតទៅ ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច បទដែលជាឈ្មោះរបស់ឧបាយសម្បទា ( ការដល់ព្រមដោយឧបាយ ) ពិតណាស់ ឧបាយសម្បទា រមែងសម្រេច ព្រោះប្រសព្វនូវផលតាមបំណង សមដូចព្រះមានព្រះភាគត្រាស់ទុកថា ចិត្តគហិបតីនេះឯង ជាអ្នកមានសីល មានកល្យាណធម៌ ប្រសិនបើចិត្តគហិបតីនឹងប្រាថ្នាថា យើងគប្បីជាស្តេចចក្រពត្តិដូច្នេះ សេចក្តីតាំងចិត្តរបស់អ្នកមានសីលនឹងសម្រេច ព្រោះជាអ្នកបរិសុទ្ធិ គប្បីជ្រាបន័យដទៃតទៅទៀត ឈ្មោះថា **ឥទ្ធិ** ព្រោះជាហេតុសម្រេចរបស់សត្វ ។ បទថា **ឥជ្ឈន្តិ** រមែងសម្រេច លោកអធិប្បាយថា ជាសេចក្តីចម្រើនលូតលាស់ដល់ភាពឧក្រិដ្ឋ ។

ឈ្មោះថា ឫទ្ធិ ដែលអធិដ្ឋាន ព្រោះសម្រេចដោយការអធិដ្ឋានក្នុងឫទ្ធិ ១០ ។ ឈ្មោះថា ឫទ្ធិ ដែលនិម្មិតបានផ្សេង ៗ ព្រោះប្រព្រឹត្តទៅដោយការធ្វើឲ្យប្លែក ដោយលះបង់វណ្ណៈប្រក្រតី , ឈ្មោះថា ឫទ្ធិ សម្រេចដោយចិត្ត ព្រោះប្រព្រឹត្តទៅដោយការសម្រេចនៃសរីរៈដែល



សម្រេចអំពីចិត្តយ៉ាងដទៃ , ឈ្មោះថា ឫទ្ធិដែលផ្សាយទៅដោយញាណជាសេចក្តីពិសេស កើតដោយអានុភាពរបស់ញាណក្នុងខាងដើម ក្នុងខាងក្រោយ ឬក្នុងខណៈនោះ , ឈ្មោះថា ឫទ្ធិ ផ្សាយទៅដោយសមាធិជាសេចក្តីពិសេសកើតដោយអានុភាពរបស់សមថៈក្នុងខាងដើម ក្នុងខាងក្រោយ ឬក្នុងខណៈនោះ , ឈ្មោះថា ឫទ្ធិរបស់ព្រះអរិយៈ ព្រោះកើតដល់ព្រះអរិយៈដែលដល់នូវភាពជំនាញផ្លូវចិត្ត , ឈ្មោះថា ឫទ្ធិកើតអំពីផលកម្ម ជាសេចក្តីពិសេសកើតដោយផលកម្ម , ឈ្មោះថា ឫទ្ធិ របស់អ្នកមានបុណ្យ ព្រោះជាសេចក្តីពិសេសកើតដល់អ្នកដែលមានបុណ្យបានធ្វើទុកក្នុងកាលមុន , ឈ្មោះថា ឫទ្ធិ សម្រេចដោយវិជ្ជា ជាសេចក្តីពិសេសកើតអំពីវិជ្ជា , សេចក្តីសម្រេចដោយកម្មនោះ ៗ ដោយការប្រកបត្រូវនោះ ឈ្មោះថា **ឥទ្ធិ** ដោយអត្ថថា **សម្រេច** ព្រោះហេតុនៃការប្រកបត្រូវក្នុងចំណែកនោះ ៗ ។

បទថា **ឥទ្ធិយា ចតស្សោ ភូមិយោ** ភូមិ ៤ នៃឫទ្ធិ សូម្បីកាលលោកពោលមិនឲ្យប្លែកគ្នា លោកក៏ពោលដល់ភូមិនៃឫទ្ធិដែលអធិដ្ឋានដែលនិម្មិតបានផ្សេង ៗ និងដែលសម្រេចដល់ចិត្តតាមការចង់បាន មិនមែនរបស់ឫទ្ធិដ៏សេស ។ បទថា **វិវេកជា ភូមិ** ជាភូមិកើតពីវិវេក គឺជាភូមិកើតពីវិវេក ឬក្នុងវិវេក ឈ្មោះថា **វិវេកជាភូមិ** ។ បទថា **បីតិ-**

**សុខភូមិ** ជាភូមិនៃបីតិ និងសុខ គឺ ជាភូមិប្រកបដោយបីតិ និងសុខ ។ បទថា **ឧបេក្ខាសុខភូមិ** ជាភូមិនៃឧបេក្ខា និងសុខ គឺ ឈ្មោះថា **ភូមិ** ព្រោះប្រកបដោយឧបេក្ខា គឺ ដាក់ខ្លួនជាកណ្តាលក្នុងអារម្មណ៍នោះ ៗ និងដោយសុខ ។ បទថា **អទុក្ខមសុខភូមិ** ជាភូមិនៃការមិនមានទុក្ខ មិនមានសុខ ជាភូមិប្រកបដោយអទុក្ខមសុខវេទនាក្នុងឈានទាំងនោះ បឋមជ្ឈាន និងទុតិយជ្ឈាន មានការផ្សាយទៅនៃបីតិ តតិយជ្ឈានមានការផ្សាយទៅនៃសុខ ចតុត្ថជ្ឈានមានការផ្សាយទៅនៃចិត្ត ក៏ក្នុងបទនេះ ព្រោះអ្នកមានកាយស្រាលទន់គួរដល់ការងារ ឈានកន្លងសុខ-សញ្ញា និងលហុសញ្ញាដោយសញ្ញា ដោយការផ្សាយទៅនៃសុខដែលបានអំពីឫទ្ធិ ដូច្នោះ ឈាន ៣ ខាងដើម គប្បីជ្រាបថាជាសម្ភារភូមិ ព្រោះប្រព្រឹត្តទៅដើម្បីបានឫទ្ធិដោយបរិយាយនេះ ចំណែកចតុត្ថជ្ឈានជាភូមិប្រក្រតីដើម្បីបានឫទ្ធិប៉ុណ្ណោះ ។ បទថា **ឥទ្ធិលាភាយ** ដើម្បីបានឫទ្ធិ គឺ ដើម្បីបានឫទ្ធិទាំងឡាយដោយការប្រោកដក្នុងសន្តានរបស់ខ្លួន ។ បទថា **ឥទ្ធិបដិលាភាយ** ដើម្បីបានចំពោះនូវឫទ្ធិ គឺ ដើម្បីបានឫទ្ធិដែលវិនាសហើយ បានមកដោយប្រារព្ធសេចក្តីព្យាយាម បន្ថែមបទឧបសគ្គចុះទៅ ។ បទថា **ឥទ្ធិវិកុព្វនាយ** ដើម្បីសម្តែងឫទ្ធិបានផ្សេង ៗ គឺ ដើម្បីសម្តែងឫទ្ធិបានច្រើនយ៉ាង ។ បទថា **ឥទ្ធិវិសវិតាយ**



ដើម្បីការហូរទៅនៃឫទ្ធិ ឈ្មោះថា **វិសវី** ព្រោះហូរទៅកាន់ភាពវិសេសផ្សេងៗ គឺ ឲ្យកើត ឲ្យប្រព្រឹត្តទៅ ម្យ៉ាងវិញទៀត ឈ្មោះថា **វិសវី** ព្រោះមានការហូរទៅច្រើនយ៉ាង សភាពនៃអ្នកមានការហូរទៅ ឈ្មោះថា **វិសវិតា** ដើម្បីភាពជាអ្នកមានការហូរទៅនៃឫទ្ធិនោះ អធិប្បាយថា ដើម្បីសម្តែងភាពពិសេស របស់ឫទ្ធិបានច្រើនយ៉ាង ។ បទថា **ឥទ្ធិវសីភាវាយ** ដើម្បីភាពជាអ្នក ជំនាញក្នុងឫទ្ធិ គឺ ដើម្បីភាពជាឥស្សរៈក្នុងឫទ្ធិ ។ បទថា **ឥទ្ធិវេសារជ្ជាយ** គឺ ដើម្បីភាពជាអ្នកក្លៀវក្លាដោយ ឫទ្ធិ ។

ឥទ្ធិបាទមានអត្ថដូចបានពោលទុកហើយក្នុងញាណកថា បទថា **ឆន្ទំ ចេ ភិក្ខុ និស្សាយ** ប្រសិនបើភិក្ខុអាស្រ័យឆន្ទៈ ហើយធ្វើឆន្ទៈឲ្យជាធំ ។ បទថា **លភតិ សមាធឹ** រមែងបានសមាធិ គឺ រមែងបានចំពោះធ្វើឲ្យសមាធិកើត សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នាក្នុងបទទាំងនោះ គប្បីជ្រាបបទ ៤ គឺ ឆន្ទៈ វិរិយៈ ចិត្តៈ វិមំសា គប្បីជ្រាបបទ ៣ យ៉ាងនេះ គឺ សមាធិ ៤ សម្បយុត្តដោយបទនោះ បទទាំងឡាយ ៤ ទៀត ព្រោះឆន្ទៈ គឺ សេចក្តីប្រាថ្នាដើម្បីឲ្យឫទ្ធិកើតប្រកបដោយភាពតែមួយជាមួយសមាធិ រមែងប្រព្រឹត្តទៅដើម្បីបានសមាធិ វិរិយៈជាដើមក៏ដូច្នោះ ឆន្ទៈគប្បីជ្រាបថា លោកពោលដល់បទ ៨ នេះ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងដល់យោគវិធីដែលព្រះយោគាវចរប្រាថ្នានឹងញុំាងអភិញ្ញាឲ្យកើត ទើបត្រាស់ដល់ការមិនញាប់ញ័រនៃចិត្តថា ព្រះយោគាវចរនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានកិលេសជាទីទួល ប្រាសចាកឧបកិលេស ជាចិត្តទន់គួរដល់ការងារ តាំងមាំដល់ភាពមិនញាប់ញ័រយ៉ាងនេះដូច្នេះ ព្រះថេរៈ កាលសម្តែងដល់ការមិនញាប់ញ័រនោះ ទើបពោលពាក្យមាន ជាអាទិ៍ថា **សោឡសមូលានិ** មូល ១៦ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អនោនតំ** ចិត្តមិនងប់ជ្រុប គឺ មិនងប់ជ្រុបដោយសេចក្តីខ្ជិលច្រអូស អធិប្បាយថា មិនរួញរា ។ បទថា **អនុន្នតំ** ចិត្តមិនប៉ោងឡើង គឺ មិនស្ទុះឡើងខាងលើដោយសេចក្តីរាយមាយ អធិប្បាយ ចិត្តមិនរាយមាយ ។ បទថា **អនភិនតំ** ចិត្តមិនទន់ទៅ គឺ មិនបង្អោនទៅដោយសេចក្តីលោភ សេចក្តីថា មិនជាប់ជំពាក់ ។ លោកអធិប្បាយថា ចិត្តបង្អោនទៅ ទោរទៅដ៏ក្រៃលែង ព្រោះសេចក្តីប្រាថ្នាដ៏ក្រៃលែង ព្រោះហេតុនោះ ចិត្តមិនដូច្នោះ ។ បទថា **រាគេន** ដោយរាគៈ គឺ ដោយសេចក្តីលោភដែលមានសង្ខារជាទីតាំង ។ បទថា **អនបនតំ** ចិត្តមិនប្រទូស គឺ មិនប្រទូសដោយទោសៈ សេចក្តីថា មិនរឹងរូស ។ បទថា **នតំ នតិ** ដោយអត្ថដូចគ្នា គឺ បង្អោន



# អដ្ឋកថា ទសឥទ្ធិនិទ្ទេស

ព្រះសារីបុត្តត្ថេរ លុះសម្តែងធម៌ដែលជាភូមិ បាទ បទ និងមូលនៃឫទ្ធិយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងដល់ឫទ្ធិទាំងនោះ ទើបពោលពាក្យមានជាអាទិ៍ថា **កតមា អធិដ្ឋានា ឥទ្ធិ** ឫទ្ធិដែលអធិដ្ឋានដូចម្តេច ។ លោកពោលអត្ថនៃបទដែលលើកឡើងក្នុងបទនោះទុកក្នុងឥទ្ធិវិធញ្ញាណនិទ្ទេសហើយ ។ បទថា **ឥធ ភិក្ខុ** គឺ ភិក្ខុក្នុងសាសនានេះ ។ ដោយបទនោះ លោកសម្តែងដល់ការមិនមានអ្នកសម្តែងឫទ្ធិបានដោយប្រការទាំងពួងទុកក្នុងទីដទៃ ។ និទ្ទេសនៃបទទាំងពីរនេះមានអត្ថដូចដែលលោកបានពោលហើយក្នុងខាងក្រោយ ។ម្យ៉ាងទៀត ដោយបទនោះ ៗ ឯង ភិក្ខុអ្នកដល់ព្រមដោយធម៌ដែលជាភូមិ បាទ បទ និងមូលនៃឫទ្ធិ គឺ លោកពោលដល់ភាពជាអ្នកមានចិត្តហ្វឹកហាត់ហើយដោយអាការ ១៤ ឬ ១៥ ដូចពោលហើយក្នុងវិសុទ្ធិមគ្គ ដោយអំណាចនៃការចូលដល់ភាពជាធំមួយ ៗ មានឆន្ទៈជាដើម និងភាពជាអ្នកមានចិត្តទន់គួរដល់ការងារ ដោយភាពជាអ្នកជំនាញ មានអាវជ្ជនៈជាដើម ។ ភិក្ខុអ្នកដល់ព្រមដោយការប្រកបជាខាងដើមមានកម្លាំងជាអ្នកមានគុណ មានការបានអភិញ្ញាជាដើម ដោយការបានចំពោះនូវ

ព្រះអរហត្តនោះឯង ដោយការដល់ព្រមនៃការប្រកបជាខាងដើម ជាអ្នកប្រកបដោយធម៌ទាំងឡាយ មានភូមិជាដើម ព្រោះហេតុនោះ ទើបលោកពោលដល់ភិក្ខុសូម្បីនោះ ។

បទថា **ពហុកំ អាវជ្ជតិ** រមែងនឹកឲ្យទៅជាច្រើននាក់ គឺ ប្រសិនបើភិក្ខុចូលចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញា មានបឋវីកសិណជាអារម្មណ៍ លុះចេញហើយរមែងប្រាថ្នាជា ១០០ នាក់ រមែងនឹកដោយធ្វើបរិកម្មថា យើងចូរជា ១០០ នាក់ យើងចូរជា ១០០ នាក់ ដូច្នេះ ។ បទថា **អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ** លុះនឹកហើយ អធិដ្ឋានដោយញាណ គឺ ធ្វើបរិកម្មយ៉ាងនេះហើយ អធិដ្ឋានដោយអភិញ្ញាញាណ លុះធ្វើបរិកម្មក្នុងទីនេះហើយ លោកមិនពោលដល់ការចូលសមាបត្តិមានឈានជាបាទទៀត លោកមិនពោលទុកក៏ពិត តែក្នុងនោះ ក្នុងអដ្ឋកថាលោកក៏ពោលដោយអំណាចបរិកម្មថា **អាវជ្ជតិ** រមែងនឹក លុះនឹកហើយអធិដ្ឋានដោយញាណ ព្រោះហេតុនោះលោកទើបពោលដោយអំណាចនៃអភិញ្ញាញាណ ព្រោះដូច្នោះ ភិក្ខុរមែងធ្វើមនុស្សម្នាក់ឲ្យទៅជាច្រើននាក់ តអំពីនោះភិក្ខុរមែងចូលសមាបត្តិក្នុងទីបំផុតនៃចិត្តបរិកម្ម លុះចេញពីសមាបត្តិហើយនកទៀតថា យើងចូរជាមនុស្សច្រើននាក់ តពីនោះរមែងអធិដ្ឋានដោយអភិញ្ញាញាណតែម្យ៉ាងប៉ុណ្ណោះ



ដោយបានឈ្មោះថា **អធិដ្ឋានំ** ដោយអំណាចឲ្យសេចក្តីសម្រេចដោយការកើត ក្នុងលំដាប់នៃចិត្តដែលជាចំណែកខាងដើម ៣ ឬ ៤ ដួង ដែលប្រព្រឹត្តទៅហើយ ព្រោះហេតុនោះគប្បីឃើញយ៉ាងនេះឯង ព្រោះលោកពោលហើយ គប្បីឃើញអត្ថក្នុងប្រការនេះ ដោយប្រការដូច្នេះ ដូចកាលបើពោលថា បរិភោគហើយដេក ក៏មិនបានមានន័យថា មិនផឹកទឹក មិនលាងដៃជាដើម ហើយដេកបន្ទាប់ពីស៊ីស្រេចហើយនោះឯង សូម្បីកាលបើមានកិច្ចដទៃក្នុងរវាងនោះ ក៏ពោលថា ស៊ីហើយដេកយ៉ាងណា គប្បីឃើញសូម្បីក្នុងប្រការនេះក៏ដូច្នោះ សូម្បីការចូលសមាបត្តិមានឈានជាបាទជាលើកដំបូង លោកក៏មិនបានពោលទុកក្នុងបាលី ។

ម្យ៉ាងទៀត ព្រមដោយអធិដ្ឋានញាណនោះជា ១០០ នាក់ ។ សូម្បីក្នុងពាន់នាក់ សែននាក់ ក៏មានន័យនេះដូចគ្នា ។ ប្រសិនបើមិនបានសម្រេចដូច្នោះ គប្បីធ្វើបរិកម្មទៀត គប្បីចូលសមាបត្តិសូម្បីជាលើកទី ២ លុះចេញហើយគប្បីអធិដ្ឋាន ។ លោកពោលទុកក្នុងអដ្ឋកថាសំយុត្តថា គួរចូលសមាបត្តិ ១ ដង ២ ដង ក្នុងចិត្តទាំងនោះ ចិត្តមានឈានជាបាទ មាននិមិត្តជាអារម្មណ៍ ចិត្តបរិកម្មមនុស្ស ១០០ នាក់ ជាអារម្មណ៍ ឬ ១.០០០ នាក់ ជាអារម្មណ៍ ចិត្តទាំងនោះ រមែង

សម្រេចបានដោយវណ្ណៈ មិនមែនដោយបញ្ញត្តិ សូម្បីចិត្តអធិដ្ឋាន ក៏មានមនុស្ស ១០០ ឬ ១.០០០ នាក់ ជាអារម្មណ៍ដូចគ្នា ចិត្តអធិដ្ឋាននោះ ជារូបាវចរចតុត្ថជ្ឈានរមែងកើតឡើងក្នុងលំដាប់គោត្រភូ ដូចជាអប្បនាចិត្ត ដូចបានពោលហើយក្នុងកាលមុន ។

ដើម្បីសម្ដែងដល់កាយសក្ខី របស់សភាពជាច្រើននាក់ លោកទើបពោលថា ដូចព្រះចុឡបន្ថកៈតែមួយអង្គ ឲ្យទៅជាច្រើនអង្គបានដូច្នោះ ។ ក៏ក្នុងបទនេះ គប្បីជ្រាបថា លោកធ្វើពាក្យជាបច្ចុប្បន្ន ព្រោះព្រះថេរៈជាអ្នកមានប្រព្រឹត្តិធ្វើយ៉ាងនោះ និងព្រោះព្រះថេរៈនោះនៅមានជីវិតរស់នៅ ។ សូម្បីក្នុងវារៈថា ជារូបតែមួយក៏បាន ក៏មានន័យដូចគ្នា ក្នុងប្រការនោះ មានរឿងនិទានថា ព្រះថេរៈពីរនាក់បងប្អូន ឈ្មោះថា បន្ថកៈ ព្រោះកើតនៅតាមផ្លូវ ។ បងប្អូនពីរនាក់នោះ ព្រះមហាបន្ថកៈជាបងបានបួសហើយ ក៏សម្រេចជាព្រះអរហត្តព្រមដោយបដិសម្ភិទា ។ ព្រះមហាបន្ថកៈជាព្រះអរហន្ត ទើបឲ្យចុឡបន្ថកៈបួស នឹងឲ្យគាថានេះថា ៖

**ផ្កាបទុមឈ្មោះកោកមុទ រីកក្នុងវេលាព្រឹក ប្រកបដោយក្លិន ញុំាងក្លិនក្រអូបហើយ យ៉ាងណា អ្នកចូរមើលព្រះអង្គីរសដែលភ្លឺរុងរោចន៍ហើយ ដូចដួងព្រះអាទិត្យ**



**រុងរោចន៍ក្នុងផ្ទៃអាកាស ដូច្នោះ ។**

ព្រះចូឡបន្ថកៈ មិនអាចទន្ទេញគាថានោះឲ្យចាំបានកន្លងទៅ ៤ ខែ លំដាប់នោះ ព្រះថេរៈទើបពោលនឹងព្រះចុឡបន្ថកៈថា អ្នកមិនសមគួរនៅក្នុងព្រះសាសនានេះ ចូរចេញអំពីព្រះសាសនានេះចុះ ។ ក៏ក្នុងវេលានោះ ព្រះថេរៈជាភត្តុទ្ទេសក៍ ( អ្នកចែកភត្ត ) ។ ជីវកោមារភត្ត នាំយកផ្កាឈើ គ្រឿងក្រអូប និងគ្រឿងលាបជាច្រើនទៅកាន់អម្ពវ័នរបស់ខ្លួនដើម្បីបូជាព្រះសាស្ដា ស្ដាប់ព្រះធម៌ ថ្វាយបង្គំព្រះទសពល រួចចូលទៅរកព្រះថេរៈ ហើយពោលថា ករុណាលោកម្ចាស់ព្រឹកនេះ សូមលោកម្ចាស់នាំភិក្ខុ ៥០០ អង្គ មានព្រះពុទ្ធជាប្រធានទទួលភិក្ខា នៅផ្ទះរបស់ខ្ញុំម្ចាស់ចុះ ។

ព្រះថេរៈក៏ពោលថា អាត្មាទទួលនិមន្តដល់ភិក្ខុដ៏សេសវៀរតែព្រះចូឡបន្ថកៈ ។ ព្រះចូឡបន្ថកៈបានស្ដាប់ឮដូច្នោះ មានការតូចចិត្តយ៉ាងខ្លាំង លុះព្រឹកឡើងលោកបានចេញចាកពីវត្តតាំងពីព្រលឹម ឈរយំនៅនឹងខ្លោងទ្វារវិហារ ព្រោះជាអ្នកមានសេចក្ដីសង្ឃឹមក្នុងព្រះសាសនា ។

ព្រះមានព្រះភាគជាម្ចាស់ ឃើញឧបនិស្ស័យរបស់ព្រះចូឡបន្ថកៈ ទើបស្ដេចយាងចូលទៅរក ដោយត្រាស់ថា អ្នកយំធ្វើអ្វី ។

ព្រះចូឡបន្ថកៈបានក្រាបទូលរឿងរ៉ាវឲ្យទ្រង់ជ្រាប ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អ្នកមិនអាចធ្វើការស្វាធ្យាយឲ្យចាំបាន មិនមែនអ្នកមិនគួរក្នុងសាសនារបស់តថាគតទេ កុំសោកសៅឡើយបន្ថកៈ ហើយទ្រង់យកព្រះហស្តប្រកបដោយស្នាមចក្រ ស្ទាបសីរសៈរបស់ព្រះចូឡបន្ថកៈ រួចស្តេចយាងចូលព្រះវិហារ ឆ្ពោះកាន់ព្រះគន្ធកុដិហើយត្រាស់ថា បន្ថកៈ អ្នកចូរអង្គុយស្ទាបអង្អែលសំពត់ចាស់នៅដៃនេះថា **រជោហរណំ រជោ-ហរណំ** នាំធូលីចេញ នាំធូលីចេញ រួចទ្រង់ប្រទានកំណាត់សំពត់ចាស់ដែលបរិសុទ្ធិអាស្រ័យឫទ្ធិរបស់ព្រះអង្គដល់ព្រះចូឡបន្ថកៈ កាលដល់ពេលវេលា ទ្រង់ហែហមដោយភិក្ខុសង្ឃ ស្តេចយាងទៅកាន់ផ្ទះរបស់ជីវកប្រថាប់គង់លើអាសនៈដែលបានក្រាលថ្វាយ ។ កាលព្រះចូឡបន្ថកៈស្ទាបអង្អែលដល់កំណាត់សំពត់ចាស់យ៉ាងនោះហើយ កំណាត់សំពត់ក៏សៅហ្មង មានពណ៌ខ្មៅដោយលំដាប់ ព្រះចូឡបន្ថកៈបានកើតបញ្ញាថា អំពីមុនកំណាត់សំពត់ចាស់នេះបរិសុទ្ធិ មិនមានសេចក្តីសៅហ្មង តែព្រោះអាស្រ័យអត្តភាពនេះ ទើបបានសៅហ្មង ញ៉ាំងញាណឲ្យចុះកាន់ក្នុងខន្ធ ៥ ចម្រើនវិបស្សនា ។ ខណៈនោះ ព្រះមានព្រះភាគទ្រង់បញ្ចេញព្រះឱភាស ប្រាកដដូចជាព្រះអង្គប្រថាប់នៅទីងមុខព្រះចូឡ-បន្ថកៈ បានត្រាស់ឱភាសគាថា នេះថា ៖



ធុលី គឺ រាគៈ មិនមែនរេណូ ( លំអង ) ពាក្យថា រជោ ( ធុលី ) នេះ ជាឈ្មោះរបស់រាគៈ បណ្ឌិតទាំងឡាយនោះ លះធុលីនោះហើយ នៅក្នុងសាសនារបស់តថាគត ដែលប្រាសចាកធុលីហើយ ។ ធុលី គឺ ទោសៈ ។ល។ ក្នុងសាសនារបស់តថាគត ដែលប្រាសចាកធុលីហើយ ។ ធុលី គឺ មោហៈ ។ល។ ក្នុងសាសនារបស់តថាគត ដែលដែលប្រាសចាកធុលីហើយ ។ សេចក្តីសោកទាំងឡាយរមែងមិនមានដល់អ្នកដែលមានចិត្តមិនប្រមាទ ជាមុនីសិក្សានៅក្នុងគន្លងនៃមុនី អង្គុយក្នុងទីស្ងប់ស្ងាត់ មានសតិសព្វកាល ។

កាលចប់គាថា ព្រះថេរៈក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ព្រះថេរៈនោះជាអ្នកបានឈានសម្រេចអំពីចិត្ត រូបតែម្នាក់ធ្វើឲ្យជាច្រើននាក់ក៏បាន ច្រើននាក់ធ្វើមកជាម្នាក់ក៏បាន ។ បិដកទាំងឡាយ ៣ និងអភិញ្ញា ៦ បានប្រាកដដល់ព្រះថេរៈព្រមនឹងអរហត្តមគ្គនោះឯង ។

សូម្បីជីវក ក៏បង្អោនទក្ខិណោទកថ្វាយដល់ព្រះទសពល ព្រះសាស្តាទ្រង់បិទបាត្រ ជីវកក្រាបទូលសួរថា មានហេតុដូចម្តេចព្រះអង្គ

ព្រះមានព្រះភាគត្រាស់ថា នៅមានភិក្ខុ ១ អង្គ នៅក្នុងវិហារ ជីវកនោះទើបបញ្ជូនបុរសឲ្យទៅប្រាប់ថា អ្នកចូរទៅនាំលោកម្ចាស់មកឲ្យឆាប់ ព្រះចូឡបន្ថកត្ថេរបំណងនឹងឲ្យបងប្រុសដឹងថា ខ្លួនសម្រេចធម៌វិសេសហើយ មុនពេលបុរសនោះមកដល់ ទើបនិម្មិតជាភិក្ខុ ១.០០០ អង្គ សូម្បី ១ អង្គ ៗ ក៏មិនដូចគ្នា មួយអង្គធ្វើកិច្ចរបស់សមណៈ មានការដេរចីវរជាដើមមិនដូចអង្គដទៃ បុរសនោះទៅឃើញ ភិក្ខុក្នុងវត្តច្រើនអង្គត្រឡប់មកប្រាប់ជីវកថា លោកម្ចាស់ ភិក្ខុនៅក្នុងវត្តមានច្រើនណាស់ ខ្ញុំមិនបានឃើញលោកម្ចាស់ដែលគួរនឹងនិមន្តឡើយ ។ ជីវកក្រាបទូលសួរ ព្រះសាស្តាប្រាប់ឈ្មោះរបស់ព្រះថេរៈអង្គនោះ ហើយបញ្ជូនបុរសទៅម្តងទៀត បុរសនោះទៅសួរថា លោកម្ចាស់អង្គណាឈ្មោះ ចុឡ-បន្ថកៈ ភិក្ខុទាំងពាន់អង្គពោលព្រមគ្នាថា យើងគឺ ចុឡបន្ថកៈ យើងគឺចុឡបន្ថកៈ បុរសនោះក៏ត្រឡប់មកម្តងទៀត នឹងពោលប្រាប់ថា ន័យថា លោកម្ចាស់ទាំងអស់សុទ្ធតែជាចូឡបន្ថកៈ ខ្ញុំមិនដឹងនិមន្តលោកម្ចាស់អង្គណាឡើយ ជីវកបានដឹងដោយន័យថា ភិក្ខុមានឫទ្ធិ ព្រោះចាក់ធ្លុះសច្ចធម៌ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អ្នកចូរទៅ ចូរចាប់ភិក្ខុ ដែលបានឃើញមុនគេត្រង់ជាយចីវរ ហើយពោលថា ព្រះសាស្តាត្រាស់ហៅលោកម្ចាស់ ហើយនាំលោកមកចុះ បុរសនោះទៅហើយ



បានធ្វើតាមសេចក្តីនោះ ក្នុងពេលនោះឯង ភិក្ខុដែលជានិម្មិតក៏អន្តរធានទៅ ព្រះថេរៈបញ្ជូនបុរសនោះឲ្យត្រឡប់ទៅ សម្រេចកិច្ច មានលប់មុខជាដើម ហើយបានទៅដល់មុនគង់លើអាសនៈដែលគេក្រាលទុក ក្នុងខណៈនោះ ព្រះសាស្តាទ្រង់ទទួលទក្ខិណោទក សោយព្រះក្រយាហារស្រេចហើយ ឲ្យព្រះចុឡបន្ថកត្ថេរសម្តែងធម្មកថា អនុមោទនាភត្ត ព្រះថេរៈសម្តែងធម្មកថា មានប្រមាណស្មើនឹងគម្ពីរទីឃនិកាយ និងមជ្ឈិមនិកាយ ។

ភិក្ខុអង្គដទៃ ៗ និម្មិតកាយដែលសម្រេចអំពីចិត្ត ដោយការអធិដ្ឋាន រមែងនិម្មិតបាន ៣ អង្គ ឬ ២ អង្គ រមែងនិម្មិតច្រើនអង្គឲ្យមកតែមួយអង្គក៏បាន និងធ្វើកម្មបានតែមួយប៉ុណ្ណោះ តែព្រះចុឡបន្ថកត្ថេរនិម្មិតបាន ១.០០០ អង្គ ដោយនឹកតែម្តងប៉ុណ្ណោះ មិនបានធ្វើ ២ នាក់ឲ្យមកជាម្នាក់ មិនបានធ្វើកម្មតែមួយ ព្រោះដូច្នោះ ព្រះថេរៈទើបជាកំពូលលើសភិក្ខុទាំងឡាយផ្នែកនិម្មិតកាយដែលសម្រេចអំពីចិត្ត ចំណែកភិក្ខុដទៃ ៗ មិនកំណត់ចំនួនច្រើន ទើបជាអ្នកមានឫទ្ធិនិម្មិតប៉ុណ្ណោះ ភិក្ខុអង្គដទៃៗ រមែងធ្វើកម្មដែលអ្នកមានឫទ្ធិធ្វើ មានឈរ អង្គុយជាដើម និងភាពជាអ្នកមិននិយាយជាដើមបានប៉ុណ្ណោះ តែប្រសិនបើថា បំណងនឹងធ្វើវណ្ណៈផ្សេង ៗ ពួកខ្លះក៏ធ្វើបានក្នុងបឋមវ័យ ពួកខ្លះក៏ក្នុង

មជ្ឈិមវ័យ ពួកខ្លះក៏ក្នុងបច្ឆិមវ័យ មយ៉ាងទៀតបំណងធ្វើសក់ឲ្យវែង រោមទាំងអស់ មានសក់ខាងលើ មានចីវរពណ៌ក្រហមពាក់កណ្តាល ពណ៌លឿងពាក់កណ្តាល ឬធ្វើបទភាណ ធម្មកថា សរភញ្ញៈ សួរបញ្ហា ឆ្លើយបញ្ហា ជ្រលក់ ស្ងោ ដេរ កាត់ចីវរជាដើម មានប្រការផ្សេង ៗ សូម្បីយ៉ាងដទៃ លុះចេញចាកសមាបត្តិមានឈានជាបាទហើយ ធ្វើបរិកម្ម ដោយន័យមានជាអាទិ៍ថា ភិក្ខុប្រមាណប៉ុណ្ណេះចូរជាអ្នកមានបឋមវ័យ ហើយចូលសមាបត្តិទៀត លុះចេញហើយគប្បីអធិដ្ឋាន ទើបជាអ្នកមានប្រការដែលខ្លួនប្រាថ្នាមកហើយ ជាមួយនឹងចិត្តអធិដ្ឋាន ក្នុងបទមានជាអាទិ៍ថា **ពហុធាបិ ហុត្វា ឯកោ ហោតិ** ច្រើននាក់ឲ្យមកជាម្នាក់ក៏បាន មានន័យនេះដូចគ្នា ។

ប៉ុន្តែសេចក្តីផ្សេងគ្នា មានដូចតទៅនេះ បទថា **បកតិយា ពហុលោ** ដោយប្រក្រតីច្រើននាក់ គឺ ដោយប្រក្រតីដែលនិម្មិតក្នុងរវាងកាលនិម្មិតជាច្រើននាក់ ក៏ភិក្ខុនេះលុះនិម្មិតរូបជាច្រើននាក់យ៉ាងនេះហើយ ទើបត្រិះរិះថា មួយអន្លើយើងនឹងចង្ក្រម មួយអន្លើធ្វើការទន្ទេញព្រះធម៌ មួយអន្លើសួរបញ្ហា ព្រោះភាពជាអ្នកមានការប្រាថ្នាតិច ថា វត្តនេះមានភិក្ខុតិច បើភិក្ខុដទៃមក នឹងដឹងចំពោះយើងថា ភិក្ខុប្រមាណប៉ុណ្ណេះដូចតែមួយអន្លើ នាំគ្នាមកអំពីទីណា នេះនឹងជាអានុភាព



របស់ព្រះថេរៈដោយពិត ដូច្នេះទើបប្រាថ្នាថា យើងចូរមានរូបតែម្នាក់ ក្នុងរវាងចូលសមាបត្តិមានឈានជាបាទ លុះចេញហើយ ធ្វើបរិកម្មថា យើងចូរមានរូបតែម្នាក់ រួចចូលសមាបត្តិម្តងទៀត លុះចេញហើយ គប្បីអធិដ្ឋានថា យើងចូរមានរូបតែម្នាក់ ព្រមជាមួយចិត្តអធិដ្ឋាននោះឯង ក៏មានរូបតែម្នាក់ បើមិនធ្វើយ៉ាងនេះ រមែងមានរូបតែម្នាក់បានឯង តាមដែលកំណត់ទុក ។

ព្រោះបទថា **អាវិភាវំ** ធ្វើឲ្យប្រាកដ មកជាបទតាំង ហើយពោលថា **កេនចិ អនាវដំ ហោតិ** ធ្វើមិនឲ្យមានអ្វីបិទបាំង ទើបលោកពោលដល់អត្ថនៃសេចក្តីប្រាកដរបស់បទថា **អាវិភាវ** ដោយបទថា **កេនចិ អនាវដំ** ។ លោកពោលដល់បាឋៈដ៏សេសថា **ករោតិ** ដោយបទថា **ហោតិ** ដូច្នេះ ព្រោះកាលធ្វើឲ្យជាក់ច្បាស់ ក៏ជាការធ្វើឲ្យប្រាកដ ។ បទថា **កេនចិ អនាវដំ** គឺ មិនមានអ្វី ៗ មានសពត់ជាដើមបិទបាំង គឺ ប្រាសចាកគ្រឿងបិទបាំង ។ បទថា **អប្បដិច្ឆន្នំ** មិនបិទបាំង គឺ មិនបិទបាំងពីខាងលើ ឈ្មោះថា **វិវដំ** បើកបង្ហាញ ព្រោះមិនបិទបាំង ឈ្មោះថា **បាកដំ** ប្រាកដ ព្រោះមិនបិទបាំង ។ បទថា **តិរោភាវំ** ធ្វើឲ្យវិនាសទៅ គឺ ធ្វើឲ្យនៅក្នុងរវាង ឈ្មោះថា **បិហិតំ** បិទបាំង ព្រោះគ្រឿងការពារនោះបិទបាំង ឈ្មោះថា **បដិកុជ្ជិតំ** បិទជិត ព្រោះ

បិទទីដែលបិទបាំងទុកនោះឯង ។ បទថា **អាកាសកសិណសមាបត្តិយា** បានដល់ ចតុត្ថជ្ឈានសមាបត្តិដែលកើតឡើងហើយក្នុងអាកាសកសិណដែលកំណត់ទុក ។ បទថា **លាភី** ជាអ្នកបានឈ្មោះថា **លាភី** ព្រោះជាអ្នកមានលាភ ។ បទថា **អបរិក្ខិត្តេ** មិនមានអ្វីការពារទុក គឺ ក្នុងផ្ទៃដែលមិនមានអ្វីការពារទុកដោយល្អ ព្រោះលោកពោលអាកាស-កសិណទុកក្នុងទីនេះ ឈានដែលចម្រើនហើយក្នុងទីនោះ ៗ ឯងរមែងជាបច្ច័យនៃអាកាសកសិណ មិនគប្បីឃើញយ៉ាងដទៃ គប្បីឃើញឈានមានកសិណនោះជាអារម្មណ៍ ក្នុងបណ្ដាអាបោកសិណក្នុងខាងដើម ជាដើម មិនមែនយ៉ាងដទៃ ។ បទថា **បឋវី អាវជ្ជតិ ឧទកំ អាវជ្ជតិ អាកាសំ អាវជ្ជតិ** រមែងនឹកដល់ផែនដី រមែងនឹកដល់ទឹក រមែងនឹកដល់អាកាស គឺ រមែងនឹកដល់ផែនដី ទឹក និងអាកាសតាមប្រក្រតី ។ បទថា **អន្តលិក្ខេ** លើអាកាស លោកសម្ដែងដល់ទីអាកាសនោះ ជាអាកាសឆ្ងាយពីផែនដី ព្រោះលោកមិននិយមកសិណ ក្នុងការស្ទាបអង្អែលព្រះច័ន្ទ និងព្រះអាទិត្យ ទើបពោលមិនឲ្យផ្សេងគ្នាថា អ្នកមានឫទ្ធិ ជាអ្នកដល់នូវភាពជំនាញនៃចិត្ត ។ បទថា **និសិន្នកោ វា និប-ន្នកោ វា** គឺ អង្គុយក្ដី ដេកក្ដី ដោយបទនេះលោកពោលដល់ឥរិយាបថទាំងពីរក្រៅអំពីនោះផង ។ បទថា **ហត្ថបាសេ ហោតុ** គឺ ព្រះច័ន្ទ



ព្រះអាទិត្យចូរមានក្នុងទីជិតដៃ ។ បាឋៈថា **ហត្ថបស្សេ ហោតុ** ចូរមានក្នុងទីក្បែរដៃខ្លះ បទនេះលោកពោលដោយអំណាចអ្នកប្រាថ្នានឹងធ្វើយ៉ាងនោះ ។ ម្យ៉ាងទៀត អ្នកមានឫទ្ធិនេះសូម្បីទៅក្នុងទីនោះហើយក៏យកដៃស្ទាបអង្អែលបាន ។ បទថា **អាមសតិ** ស្ទាប គឺ ប៉ះពាល់បន្តិចបន្តួច ។ បទថា **បរាមសតិ** អង្អែល គឺ ប៉ះពាល់ច្រើនជាង ។ បទថា **បរិមជ្ជតិ** សម្ផស្ស គឺ ពាល់ត្រូវដោយជុំវិញ ។ បទថា **រូបគតំ** គឺ រូបជាទីតាំងនៅជិតដៃនោះឯង ។ បទថា **ទូរេបិ សន្តិកេ អធិដ្ឋាតិ** អធិដ្ឋានទីឆ្ងាយឲ្យមកជាទីជិត គឺ អ្នកមានឫទ្ធិលុះចេញចាកសមាបត្តិមានឈានជាបាទហើយ រមែងនឹកដល់ទេវលោកក្ដី ព្រហ្មលោកក្ដីក្នុងទីឆ្ងាយថា ចូរមាននៅក្នុងទីជិតដូច្នេះ លុះនឹកដល់ហើយ ធ្វើបរិកម្មចូលសមាបត្តិទៀត លុះចេញហើយអធិដ្ឋានដោយញាណថា ចូរមានក្នុងទីជិតដូច្នេះ ព្រះច័ន្ទ និងព្រះអាទិត្យរមែងមានក្នុងទីជិត សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងដល់សេចក្ដីវិសេសនៃការសម្រេចឫទ្ធិនេះ សូម្បីមិនមានឧបការៈដល់អ្នកនឹងទៅព្រហ្មលោក ពោលដល់ការធ្វើទីឆ្ងាយឲ្យមកជាទីជិត ហើយទៅព្រហ្មលោកបាន ទើបពោលពាក្យមានជាអាទិ៍ថា **សន្តិកេបិ** សូម្បីនៅក្នុងទីជិត ។

ក្នុងបទនោះ មិនមែនជាការធ្វើតិចតួច និងធ្វើឲ្យច្រើនតែម្យ៉ាងប៉ុណ្ណោះ វត្ថុទាំងអស់ដែលប្រាថ្នា រមែងសម្រេចដល់អ្នកមានឫទ្ធិ សូម្បីក្នុងបទមានជាអាទិ៍ថា **អមធុរំ មធុរំ** ទាំងមិនឆ្ងាញ់ទាំងឆ្ងាញ់ គប្បីជ្រាបន័យដទៃទៀត ។ បទថា **ទូរេបិ សន្តិកេ អធិដ្ឋាតិ** អធិដ្ឋានសូម្បីទីឆ្ងាយឲ្យមកជាទីជិត គឺ អធិដ្ឋានព្រហ្មលោកដែលនៅក្នុងទីឆ្ងាយ ឲ្យមកជាទីជិតមនុស្សលោក ។ បទថា **សន្តិកេបិ ទូរេ អធិដ្ឋាតិ** អធិដ្ឋានសូម្បីក្នុងទីជិតឲ្យទៅជាទីឆ្ងាយ គឺ អធិដ្ឋានមនុស្សលោកដែលនៅក្នុងទីជិតឲ្យឆ្ងាយពីព្រហ្មលោក ។ បទថា **ពហុកម្បិ ថោកំ អធិដ្ឋាតិ** អធិដ្ឋាបរបស់ច្រើនឲ្យជារបស់តិច គឺ ប្រសិនបើព្រហ្មទាំងឡាយមកប្រជុំគ្នាច្រើន ព្រោះព្រហ្មមានរាងកាយធំមួយទស្សនូបចារៈ ( ការឃើញជិតបង្កើយ ) សវនូបចារៈ ( ការស្តាប់ជិតបង្កើយ ) អ្នកមានឫទ្ធិក៏បំព្រួញគ្នាក្នុងទស្សនូបចារៈ និងសវនូបចារៈ អធិដ្ឋានសូម្បីរបស់ច្រើនឲ្យជារបស់តិច ។ បទថា **ថោកម្បិ ពហុកំ អធិដ្ឋាតិ** អធិដ្ឋានរបស់តិចឲ្យជារបស់ច្រើន គឺ ប្រសិនបើអ្នកមានឫទ្ធិបំណងនឹងទៅជាមួយបរិវារច្រើន ជាអ្នកមានបរិវារច្រើន ព្រោះអធិដ្ឋានខ្លួន ឈ្មោះថាតិច ព្រោះមានតែម្នាក់ឯងឲ្យច្រើនហើយទៅ គប្បីឃើញអត្ថក្នុងបទនេះដោយប្រការដូច្នេះឯង ។ បើដូច្នោះ សូម្បីបទ ៤ យ៉ាងនេះ រមែង



មានឧបការៈក្នុងការទៅព្រហ្មលោក ។ បទថា **ទិព្វេន ចក្ខុនា តស្ស ព្រហ្មុនោ រូបំ បស្សតិ** រមែងឃើញរូបព្រហ្មនោះ ដែលបំណងនឹងឃើញដោយទិព្វចក្ខុ គឺ អ្នកមានឫទ្ធិឈរក្នុងទីនេះ ចម្រើនអាលោកកសិណ រមែងឃើញរូបព្រហ្មនោះដោយទិព្វចក្ខុ ឈរក្នុងទីនោះឯង រមែងបានឮសំឡេងរបស់ព្រហ្មនោះកំពុងនិយាយគ្នា ដោយទិព្វសោតធាតុ រមែងដឹងចិត្តរបស់ព្រហ្មដោយចេតោបរិយញ្ញាណ ។ បទថា **ទិស្សមានេន** ដោយកាយដែលប្រាកដ គឺ សម្លឹងឃើញដោយចក្ខុ ។ បទថា **កាយវសេន ចិត្តំ បរិណាមេតិ** គឺ បង្អោនចិត្តដោយអំណាចនៃរូបកាយ ប្រកាន់ចិត្តមានឈានជាបាទហើយឡើងក្នុងកាយ ធ្វើការទៅរបស់កាយដោយសម្គាល់ថាស្រោល ឲ្យជាការទៅរហ័ស ព្រោះការទៅដោយកាយជារបស់យឺតយូរ ។ បទថា **អធិដ្ឋាតិ** ជាវេវចនៈរបស់បទនោះ ៗ ឯង សេចក្តីថា ឲ្យសម្រេច ។ បទថា **សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមិត្វា** ចុះកាន់សុខសញ្ញា និងលហុសញ្ញា គឺ ចូលទៅពាល់ត្រូវដល់សុខសញ្ញា និងលហុសញ្ញាដែលកើតព្រមជាមួយឥទ្ធិចិត្តមានឈានជាបាទជាអារម្មណ៍ សញ្ញាសម្បយុត្តដោយឧបេក្ខា ឈ្មោះសុខសញ្ញា ព្រោះឧបេក្ខាលោកពោលថា សេចក្តីស្ងប់ដែលជាសេចក្តីសុខ សញ្ញានោះឯង គប្បីជ្រាបថា ជាលហុសញ្ញា ព្រោះផុតចាក

នីវរណៈ និងធម៌ជាសត្រូវមានវិតក្កៈជាដើម ។

សូម្បីករជកាយរបស់អ្នកមានឫទ្ធិចុះកាន់សញ្ញានោះ ក៏ស្រាលដូចប៉ុយគ អ្នកមានឫទ្ធិនោះទៅកាន់ព្រហ្មលោកដោយកាយស្រាលដូចប៉ុយគដែលត្រូវខ្យល់បក់ទៅ កាលបើទៅយ៉ាងនេះ ប្រសិនបើប្រាថ្នា ក៏និម្មិតផ្លូវលើអាកាសដោយបឋវីកសិណ ហើយដើរទៅ ប្រសិនបើប្រាថ្នា ក៏និម្មិតផ្កាបទុមគ្រប់ ៗ ជំហានជើង លើអាកាសដោយបឋវីកសិណនោះឯង ហើយដាក់ជើងលើផ្កាបទុមដើរទៅ ប្រសិនបើប្រាថ្នា ក៏អធិដ្ឋានខ្យល់ដោយវាយោកសិណ ហើយទៅជាមួយខ្យល់ដូចប៉ុយគ ភាពជាអ្នកប្រាថ្នានឹងទៅនោះឯង ជាប្រមាណក្នុងរឿងនេះ ព្រោះអ្នកប្រាថ្នានឹងទៅ អ្នកមានឫទ្ធិនោះ ទើបអធិដ្ឋានចិត្តធ្វើយ៉ាងនោះ អណ្តែតទៅដោយកម្លាំងរបស់អធិដ្ឋាន ប្រាកដដូចកូនសរស្មុះទៅដោយកម្លាំងរបស់ខ្សែធ្នូ ។ បទថា **ចិត្តវសេន កាយំ បរិណាមេតិ** បង្អោនកាយទៅដោយអំណាចចិត្ត គឺ ប្រកាន់ករជកាយ ហើយលើកឡើងក្នុងចិត្តដែលមានឈានជាបាទ ធ្វើការទៅរបស់ចិត្តឲ្យជាការទៅរហ័ស ព្រោះការទៅដោយចិត្តមានភាពរហ័ស ។

បទថា **សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមិត្វា** គឺ ចុះកាន់សុខសញ្ញា និងលហុសញ្ញា ដែលកើតព្រមជាមួយឥទ្ធិចិត្ត ដែលមានរូប-



កាយជាអារម្មណ៍ ។ បទដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ តែបទនេះ ជាការទៅដោយចិត្ត បើសួរថា អ្នកមានឫទ្ធិនេះ កាលទៅដោយកាយដែលមិនប្រាកដយ៉ាងនេះ រមែងទៅក្នុងឧប្បាទខណៈនៃចិត្តអធិដ្ឋាននោះឬ ឬថាក្នុងឋិតិខណៈ ឬភង្គខណៈ ។ ព្រះថេរៈពោលថា ទៅក្នុងខណៈសូម្បីទាំង ៣ ទៅដោយខ្លួនឯង ឬថាបញ្ជូនរូបនិម្មិតទៅ ធ្វើតាមសេចក្តីពេញចិត្ត តែក្នុងទីនេះ អ្នកមានឫទ្ធិនោះទៅមកដោយខ្លួនឯង ។ បទថា **មនោមយំ** សម្រេចអំពីចិត្ត ឈ្មោះថា **មនោមយំ** ព្រោះជារូបនិម្មិតដោយចិត្តអធិដ្ឋាន ។ ឈ្មោះថា **សព្វង្គបច្ចង្គំ** មានអវយវៈគ្រប់សព្វ គឺ មានអវយវៈតូចធំគ្រប់ទាំងអស់ ។ បទថា **អហីនិន្ទ្រិយំ** មានឥន្ទ្រិយមិនខ្វាក់មិនថ្លង់ លោកពោលដោយអំណាចនៃសណ្ឋានរបស់ចក្ខុ និងសោតៈជាដើម ព្រោះក្នុងរូបនិម្មិតមិនមានប្រសាទ ។

បទមានជាអាទិ៍ថា **សចេ សោ ឥទ្ធិមា ចង្កមតិ និម្មិតោបិ តត្ថ ចង្កមតិ** បើអ្នកមានឫទ្ធិចង្ក្រម សូម្បីរូបនិម្មិតក៏ចង្ក្រមក្នុងទីនោះ លោកពោលសំដៅដល់សាវកនិម្មិតទាំងអស់ ចំណែកពុទ្ធនិម្មិតទាំងឡាយរមែងធ្វើវត្ថុដែលព្រះមានព្រះភាគទ្រង់ធ្វើសូម្បីយ៉ាងដទៃដោយអំណាចចិត្តរបស់ព្រះមានព្រះភាគ ។ បទថា **ធូមាយតិ បជ្ជលតិ** បាំងកំដៅថ្ងៃ

ត្រឡប់ទៅមកឲ្យឆ្អិន លោកពោលដោយអំណាចចេតោកសិណ ។ ៣ បទមានជាអាទិ៍ថា **ធម្មំ ភាសតិ** លោកពោលធម៌មិនពិតប្រាកដ ។ បទថា **សន្តិដ្ឋិ** ឈរនៅ គឺ ឈររួមគ្នា ។ បទថា **សល្លបតិ** នៅសន្ទនា គឺ សន្ទនារួមគ្នា ។ បទថា **សាកច្ឆំ សមាបជ្ជតិ** ប្រាស្រ័យគ្នា គឺ ប្រាស្រ័យដោយការផ្លាស់ប្ដូរគំនិតគ្នានឹងគ្នា ។ មួយ៉ាងទៀត អ្នកមានឫទ្ធិនោះឈរនៅទីនេះ រមែងឃើញរូបដោយទិព្វចក្ខុ រមែងបានឮសំឡេងដោយទិព្វសោតធាតុ រមែងដឹងចិត្តអ្នកដទៃដោយចេតោបរិយញ្ញាណ រមែងឈរសន្ទនាប្រាស្រ័យជាមួយព្រហ្មនោះ ។ ការអធិដ្ឋានរបស់អ្នកមានឫទ្ធិនោះ មានជាអាទិ៍ថា រមែងអធិដ្ឋានសូម្បីក្នុងទីឆ្ងាយឲ្យមកជិតបាន អ្នកមានឫទ្ធិនោះ ទៅកាន់ព្រហ្មលោកដោយកាយដែលប្រាកដ ឬមិនប្រាកដ ដោយហេតុត្រឹមប៉ុណ្ណេះ ក៏មិនអាចប្រព្រឹត្តទៅតាមផ្លូវកាយបាន រមែងញ៉ាំងវិធីដូចពោលទុកដោយន័យមានជាអាទិ៍ថា អ្នកមានឫទ្ធិនោះ រមែងនិម្មិតមនុស្សមានរូបទុកខាងមុខព្រហ្មលោកនោះសិន ដោយហេតុត្រឹមប៉ុណ្ណេះ ឈ្មោះថា រមែងញ៉ាំងកាយឲ្យប្រព្រឹត្តទៅបាន ។ ចំណែកបទដ៏សេស លោកពោលទុក ដើម្បីបង្ហាញឲ្យឃើញចំណែកខាងដើមនៃការញ៉ាំងអំណាចផ្លូវកាយឲ្យប្រព្រឹត្តទៅ នេះជាឫទ្ធិដែលអធិដ្ឋាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **វិកុព្វនិទ្ធិនិទ្ទេស** ដូចតទៅនេះ ។ លោក



ពោលលើកតួយ៉ាងសាវករបស់ព្រះមានព្រះភាគព្រះនាមសិខី ដើម្បីបង្ហាញឲ្យឃើញកាយសក្ខីរបស់ឫទ្ធិដែលក្លែងបានផ្សេង ៗ ។ ព្រះសារីបុត្តត្ថេរ កាលសម្ដែងដល់ឫទ្ធិដែលក្លែងបានផ្សេង ៗ នោះ ទើបសម្ដែងឫទ្ធិដែលអធិដ្ឋានបានឮសំឡេងនៃពាន់លោកធាតុ ដែលគួរអស្ចារ្យយ៉ាងក្រៃលែងមិនធ្លាប់មានមកអំពីមុនថា ព្រះពុទ្ធជាម្ចាស់ ព្រះនាមសិខី ស្ថិតនៅព្រហ្មលោក ទ្រង់បន្លឺសំឡេងឲ្យពាន់លោកធាតុជ្រាបច្បាស់ ដូច្នេះ ។

ឥឡូវនេះ ដើម្បីសម្ដែងរឿងរ៉ាវនោះ លោកទើបពោលប្រការនេះ ។ ក្នុងកប្ប ៣១ ដោយរាប់ថយអំពីកប្បនេះ ព្រះដ៏មានព្រះភាគព្រះនាមថា **សិខី** ចុតិចាកសួគ៌ជាន់តុសិតក្នុងជាតិជាលំដាប់ ឧប្បត្តិក្នុងព្រះគភ៌របស់ព្រះមហេសីព្រះនាមថា **បភាវតី** របស់ព្រះបាទ **អរុណវតី** ក្នុង **អរុណវតីនគរ** មានព្រះញាណចាស់ក្លា ស្ដេចក៏ចេញអភិនេស្ក្រម ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណនៅពោធិមណ្ឌល ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ទ្រង់អាស្រ័យអរុណវតីនគរគង់ប្រថាប់ ថ្ងៃមួយ នាពេលព្រលឹមទ្រង់ជម្រះព្រះកាយហើយ ហែហមដោយភិក្ខុសង្ឃដ៏ច្រើន ទ្រង់ត្រិះរិះថា នឹងចូលទៅអរុណវតីនគរដើម្បីបិណ្ឌបាត្រ ទ្រង់ប្រថាប់ឈរនៅជិតខ្លោងទ្វារព្រះវិហារ ត្រាស់ហៅព្រះអគ្គសាវក

ព្រះនាម **អភិភូ** មានព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុ ចូលនាំគ្នាទៅអរុណវតីនគរដើម្បីបិណ្ឌបាត្រចុះ តថាគតនឹងទៅព្រហ្មលោកជាន់ណាមួយ សមដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគព្រះនាមថា សិខី ជាព្រះអរហន្តសម្មាសម្ពុទ្ធ ត្រាស់ហៅអភិភូភិក្ខុ ដោយព្រះតម្រាស់ថា ម្នាលព្រាហ្មណ៍ មកយើងនឹងទៅព្រហ្មលោកជាន់ណាមួយ រហូតដល់វេលាឆាន់ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគព្រះនាមថាសិខី ដែលជាព្រះអរហន្តសម្មាសម្ពុទ្ធស្រេចហើយ លំដាប់នោះឯង ព្រះមានព្រះភាគព្រះនាមថា សិខី និងអភិភូភិក្ខុ បានចូលទៅកាន់ព្រហ្មលោកជាន់ណាមួយ ។

នៅព្រហ្មលោកនោះ មហាព្រហ្មឃើញព្រះសម្មាសម្ពុទ្ធជាម្ចាស់ហើយ មានសេចក្តីរីករាយ ធ្វើការក្រោកទទួល ក្រាលព្រហ្មាសនៈថ្វាយ ក្រាលអាសនៈដ៏សមគួរដល់ព្រះថេរៈផង ។ ព្រះមានព្រះភាគប្រថាប់គង់លើអាសនៈដែលបានក្រាលទុក ។ សូម្បីព្រះថេរៈក៏គង់លើអាសនៈរបស់ខ្លួន ។ មហាព្រហ្មថ្វាយបង្គំព្រះទសពលហើយ អង្គុយក្នុងចំណែកម្ខាង ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា លំដាប់



នោះឯងព្រះមានព្រះភាគព្រះនាមថា **សិខី** ដែលជាព្រះអរហន្តសម្មា-សម្ពុទ្ធត្រាស់នឹងអភិភូភិក្ខុថា ម្នាលព្រាហ្មហ៍ ធម្មីកថាចូរជាក់ច្បាសដល់ព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មបារិសជ្ជៈទាំងឡាយចុះ ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ ដែលជាព្រះអរហន្តសម្មាសម្ពុទ្ធហើយ សម្តែងធម្មកថាដល់ព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មបារិសជ្ជៈទាំងឡាយ កាលព្រះថេរៈពោលធម្មកថា ពួកព្រហ្មទាំងឡាយលើកទោសថា ក៏ពួកយើងបានមកកាន់ព្រហ្មលោករបស់ព្រះសាស្តាអស់កាលយូរ ភិក្ខុអង្គនេះ វៀរព្រះសាស្តាចេញហើយសម្តែងធម៌ដោយខ្លួនឯង ។

ព្រះសាស្តាទ្រង់ជ្រាបថា ពួកព្រហ្មមិនពេញចិត្ត ទើបត្រាស់នឹងភិក្ខុអភិភូថា ម្នាលព្រាហ្មណ៍ ព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មបារិសជ្ជៈទាំងឡាយនោះនាំគ្នាលើកទោស ម្នាលព្រាហ្មណ៍ បើដូច្នោះអ្នកចូរឲ្យព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មបារិសជ្ជាទាំងឡាយ តក់ស្លុតដោយក្រៃលែងចុះ ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្តាហើយ ក៏ក្លែងឫទ្ធិផ្សេង ៗ ច្រើនយ៉ាង ញុំាងពាន់លោកធាតុឲ្យដឹងច្បាស់ដោយសំឡេង បានពោលគាថា ២ គាថានេះថា ៖

**អ្នកទាំងឡាយចូររីករាយ ចូរបែរមុខ ចូរប្រកប**

**( សេចក្តីព្យាយាម ) ក្នុងព្រះពុទ្ធសាសនា ចូរ**
**កម្ចាត់សេនានៃមច្ចុ ដូចដំរីកម្ចាត់ផ្ទះឈើបបុស**
**ដូច្នោះ អ្នកណាមិនប្រមាទក្នុងធម្មវិន័យនេះហើយ**
**អ្នកនោះនឹងលះបង់សង្សារ គឺ ជាតិ ហើយធ្វើ**
**ទីបំផុតនៃទុក្ខបាន ។**

ក៏ព្រះថេរៈធ្វើដូចម្តេច ទើបញុំាងពាន់លោកធាតុឲ្យដឹងច្បាស់ដោយសំឡេង ។ ព្រះថេរៈចូលនីលកសិណមុន លុះចេញហើយ ផ្សាយកាពងងឹតទៅក្នុងទីទាំងពួង ក្នុងពាន់ចក្រវាឡដោយអភិញ្ញាញាណ កាលសត្វទាំងឡាយកើតសេចក្តីគិតថា ហេតុអ្វីក៏បានជាងងឹត ព្រះថេរៈទើបចូលអាលោកកសិណ លុះចេញហើយក៏ធ្វើពន្លឺឲ្យប្រាកដ កាលសត្វទាំងឡាយកំពុងសម្លឹងមើលថា ភ្លឺច្បាស់ហើយតើ ព្រះថេរៈទើបសម្តែងខ្លួនឲ្យប្រាកដ ។ ទេវតា និងមនុស្សក្នុងចក្រវាឡផ្សេងៗ ផ្គងអញ្ជលីឈរនមស្ការព្រះថេរៈ ព្រះថេរៈពោលថា សូមមហាជនចូរស្តាប់សំឡេងរបស់យើងសម្តែងធម៌ ទើបបានពោលគាថាទាំងនេះ ។ ទេវតា និងមនុស្សទាំងឡាយ បានឮសំឡេងរបស់ព្រះថេរៈ ដូចអង្គុយសម្តែងធម៌ក្នុងកណ្តាលបរិស័ទក្នុងទីប្រជុំគ្នា សូម្បីអត្ថន័យ ក៏បានប្រាកដដល់ទេវតា និងមនុស្សទាំងនោះ លោកពោលថា ព្រះថេរៈធ្វើឲ្យដឹងច្បាស់



ដោយសំឡេង សំដៅដល់ ឲ្យដឹងច្បាស់ខ្លឹមសារនោះ ។ លោកពោលពាក្យមានជាអាទិ៍ថា **សោ ទិស្សមានេនបិ** ព្រះថេរៈសម្តែងធម៌ដោយកាយដែលប្រាកដខ្លះ ដូច្នេះទៀត សំដៅដល់ ឫទ្ធិដែលក្លែងបានផ្សេង ៗ ច្រើនយ៉ាងនេះ ។

ក្នុងបទទាំងនោះ បទថា **ធម្មំ ទេសេសិ** ព្រះថេរៈសម្តែងធម៌ គឺ សម្តែងឫទ្ធិដែលក្លែងបានផ្សេង ៗ មានប្រការដូចពោលហើយអំពីមុន ទើបសម្តែងធម៌ ។ ប៉ុន្តែគប្បីជ្រាបថា ព្រះថេរៈពោល ២ គាថា ដោយលំដាប់ តាមដែលពោលហើយ ទើបធ្វើឲ្យដឹងច្បាស់ដោយសំឡេង ។ ម្យ៉ាងទៀត ក្នុងបទមានជាអាទិ៍ថា **ទិស្សមានេនបិ កាយេន** ដោយកាយដែលប្រាកដខ្លះ ជាតតិយាវិភត្តិចុះក្នុងលក្ខណៈនៃឥត្ថម្ភូតៈ ( មាន ឬដោយ ) គឺ មានកាយដូច្នោះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ លុះសម្តែងរឿងរ៉ាវនោះហើយ កាលនឹងសម្តែងដល់វិធីធ្វើឫទ្ធិដែលក្លែងបានផ្សេង ៗ របស់អ្នកមានឫទ្ធិដទៃទៀត ទើបពោលពាក្យមានជាអាទិ៍ថា **សោ បកតិវណ្ណំ វិជហិត្វា** អ្នកមានឫទ្ធិនោះ លះបង់ភេទប្រក្រតីហើយ ។

ក្នុងបទទាំងនោះ បទថា **សោ** គឺ ភិក្ខុអ្នកមានឫទ្ធិ មានចិត្តទន់សមគួរដល់ការងារ ដែលធ្វើតាមវិធីបានពោលហើយក្នុងខាងក្រោយ ។

ប្រសិនបើភិក្ខុអ្នកមានឫទ្ធិបំណងនឹងធ្វើឫទ្ធិ ដែលក្លែងបានផ្សេង ៗ ភិក្ខុអ្នកមានឫទ្ធិនោះ លះបង់ភេទប្រក្រតី គឺ សណ្ឋានប្រក្រតីរបស់ខ្លួនហើយ សម្តែងភេទជាកុមារខ្លះ ។ យ៉ាងណា គឺ ចេញចាកចតុត្ថជ្ឈាន មានបឋវីកសិណជាអារម្មណ៍ មានអភិញ្ញាជាបាទ ហើយនឹកដល់ភេទកុមារដែលគួរនិម្មិតថា យើងចូរជាកុមារមានរូបយ៉ាងនេះដូច្នេះហើយ កាលធ្វើបរិកម្មស្រេចទើបចូលសមាបត្តិទៀត លុះចេញហើយ អធិដ្ឋានដោយអភិញ្ញាញាណថា យើងចូរជាកុមារមានរូបយ៉ាងនេះដូច្នេះ ។ ភិក្ខុអ្នកមានឫទ្ធិនោះ ក៏ក្លាយជាកុមារព្រមនឹងការអធិដ្ឋាន ។

លោកពោលទុកក្នុងបឋវីកសិណ ក្នុងវិសុទ្ធិមគ្គថា សមាបត្តិមានបឋវីកសិណជាអារម្មណ៍ មានឈានជាបាទ រមែងសមគួរក្នុងទីនេះ ដោយពាក្យថា ឫទ្ធិដែលក្លែងផ្សេង ៗ មានជាអាទិ៍យ៉ាងនេះថា ភាពជាបុគ្គលម្នាក់ឲ្យទៅជាច្រើននាក់ក៏បាន ដោយអំណាចបឋវីកសិណ ។ល។ រមែងសម្រេច ដូច្នេះ ។ ក៏ក្នុងអភិញ្ញានិទ្ទេស ក្នុងវិសុទ្ធិមគ្គនោះ ៗ ឯង លោកពោលថា ចេញចាកបឋវីកសិណជាដើមណាមួយជាអារម្មណ៍ ចាកឈានមានអភិញ្ញាជាបាទដូច្នេះ ដោយឫទ្ធិដែលក្លែងបានផ្សេង ៗ ។ ម្យ៉ាងទៀត ក្នុងនិទ្ទេសនោះ លោកពោលថា គួរគិតនឹកដល់ភេទកុមាររបស់ខ្លួន ។ ពាក្យពោលនោះ ដូចជាមិន



សមគួរក្នុងការនិម្មិត មាននាគជាដើម ។ សូម្បីក្នុងការនិម្មិត មានភេទនាគជាដើម ក៏មានន័យនេះដូចគ្នា ។

ក្នុងបទទាំងនោះ បទថា **នាគវណ្ណំ** ភេទនាគ គឺ មានសណ្ឋានស្រដៀងពស់ ។ បទថា **សុបណ្ណវណ្ណំ** ភេទគ្រុឌ គឺ មានសណ្ឋានស្រដៀងគ្រុឌ ។ បទថា **ឥន្ទវណ្ណំ** ភេទព្រះឥន្ទ្រ គឺ មានសណ្ឋានស្រដៀងស្តេចសក្កៈ ។ បទថា **ទេវវណ្ណំ** ភេទទេវតា គឺ មានសណ្ឋានស្រដៀងទេវតាដ៏សេស ។ បទថា **សមុទ្ទវណ្ណំ** ភេទសមុទ្រ រមែងសម្រេចដោយអំណាចនៃអាបោកសិណ ។ បទថា **បត្តឹ** ពលរាប គឺ ពលថ្មើរជើង ។ បទថា **វិវិធម្បិ សេនាព្យូហំ** កងទ័ពតាំងនៅយ៉ាងជិតស្និទ្ធគ្នាផ្សេង ៗ គឺ ពួកទាហានច្រើនប្រភេទ មានពលដំរីជាដើម ។ តែក្នុងវិសុទ្ធិមគ្គ លោកពោលបទមានជាដើមថា សម្តែងសូម្បីដំរីផងដើម្បីឲ្យឃើញដំរីជាដើម សូម្បីក្នុងខាងក្រៅ ។ ក្នុងវិសុទ្ធិមគ្គនោះ មិនគប្បីអធិដ្ឋានថា យើងចូរជាដំរី គប្បីអធិដ្ឋានថា ដំរីចូរមាន ។ សូម្បីសេះជាដើម លោកក៏ពោលថាមានន័យដូចគ្នា ពាក្យនោះខុសជាមួយបទដើមដែលពោលថា លះបង់ភេទប្រក្រតី និងដោយភាពដែលឫទ្ធិក្លែងបានផ្សេង ៗ ព្រោះថា ការមិនលះបង់ភេទប្រក្រតីតាមលំដាប់ដូចពោលក្នុងបាលីហើយ សម្តែងភេទដទៃដោយអំណាចអធិដ្ឋាន ឈ្មោះ

ថា ឫទ្ធិដែលអធិដ្ឋាន ។ កាលលះបង់ភេទប្រក្រតីហើយ សម្តែងខ្លួនជាយ៉ាងដទៃដោយអំណាចអធិដ្ឋាន ឈ្មោះថា ឫទ្ធិដែលក្លែងបានផ្សេង ៗ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **មនោមយិទ្ធិនិទ្ទេស** ដូចតទៅ ។ ក្នុងបទមានជាអាទិ៍ថា **ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ** ភិក្ខុនិម្មិតកាយដទៃចាកកាយនេះ សេចក្តីថា ភិក្ខុអ្នកមានឫទ្ធិ បំណងនឹងធ្វើមនោមយិទ្ធិ (ឫទ្ធិផ្លូវចិត្ត) លុះចេញចាកសមាបត្តិ មានអាកាសកសិណជាអារម្មណ៍ មានឈានជាបាទហើយ នឹកដល់រូបកាយរបស់ខ្លួនជាមុនហើយអធិដ្ឋានថា ចន្លោះចូរមាន ( ប្រហោង ) ចន្លោះរមែងមាន តពីនោះនឹកដល់កាយដទៃ ដោយអំណាចបឋវីកសិណក្នុងខាងក្នុងចន្លោះនោះហើយធ្វើបរិកម្មអធិដ្ឋាន ដោយន័យដូចពោលហើយនោះឯង កាយដទៃរមែងមានក្នុងចំណែកចន្លោះនោះ ភិក្ខុនោះបើកកាយនោះចេញពីមាត់ ហើយតាំងទុកខាងក្រៅ ។ ឥឡូវនេះ ព្រះសារីបុត្តត្រេកាលនឹងប្រកាសសេចក្តីនោះដោយឧបមា ទើបពោលពាក្យមានជាអាទិ៍ថា **សេយ្យថាបិ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **មុញ្ជម្ហា** គឺ ចាកស្មៅយាប្លង ។ បទថា **ឦសិកំ បវាហេយ្យ** គប្បីដាក់សសៃ គឺ ដុតធ្នាំង ។ បទថា **កោសិយា** គឺ បើកគម្រប ។ បទថា **កណ្ឌា** គឺ ចាកគម្រប គឺ



ចាកគម្របធ្នាំងចាស់ ។

មយ៉ាងទៀត ក្នុងបទនោះ បទថា **ឧទ្ធរេយ្យ** គប្បីលើកចេញគប្បីជ្រាបការលើកចេញនៃគម្របនោះ ដោយចិត្តប៉ុណ្ណោះ ព្រោះធម្មតាពស់នេះតាំងនៅក្នុងជាតិរបស់ខ្លួន អាស្រ័យចន្លោះមែកឈើខ្លះចន្លោះដើមឈើខ្លះ ដោយកម្លាំង គឺ ការសកសំណកចេញអំពីខ្លួនស្អប់ខ្ពើមស្បែកចាស់ ដូចកណ្ឌៀរកេកេរស៊ីខ្លួន រមែងលះបង់សំណកដោយខ្លួនឯង ដោយហេតុ ៤ ប្រការទាំងនេះ ។ ក៏ក្នុងរឿងនេះ លោកពោលឧបមាទាំងនោះទុក ដើម្បីឲ្យឃើញថា រូបសម្រេចអំពីឫទ្ធិនេះរបស់អ្នកមានឫទ្ធិ រមែងដូចអាការទាំងពួង ដូចបណ្តូលស្មៅយាប្លងរមែងដកចេញពីស្មៅយាប្លងដូច្នោះ ។ កាយដែលធ្វើដោយចិត្ត គឺ អភិញ្ញា ក្នុងបទនេះថា អ្នកមានឫទ្ធិចូលទៅដោយឫទ្ធិ ដោយកាយសម្រេចអំពីចិត្ត ឈ្មោះថា **មនោមយកាយោ** កាយសម្រេចអំពីចិត្ត កាយដែលកើតឡើងដោយចិត្ត គឺ ឈាន ក្នុងបទនេះថា អ្នកមានឫទ្ធិចូលដល់ កាយសម្រេចអំពីចិត្តណាមួយ ឈ្មោះថា **មនោមយកាយោ** កាយសម្រេចអំពីចិត្ត ព្រោះចិត្តនោះធ្វើពីក្នុងទីនេះ កាយកើតឡើងហើយដោយចិត្ត គឺ អភិញ្ញា ឈ្មោះថា **មនោមយកាយោ** កាយសម្រេចអំពីចិត្ត ព្រោះចិត្តនោះធ្វើ ។ បើដូច្នោះ ប្រសិនបើសួរថា ឈ្មោះថា កាយ

សម្រេចអំពីចិត្ត ដែលឫទ្ធិបានអធិដ្ឋាន និងឫទ្ធិបានក្លែងធ្វើជារូបផ្សេងៗ រមែងធ្វើមិនបានឬ ។ ឆ្លើយថា រមែងមានបាន តែក្នុងទីនេះ ការនិម្មិតចាកខាងក្នុងប៉ុណ្ណោះ ឈ្មោះថា **មនោមយិទ្ធិ** ព្រោះលោកពោលទុកថា ជាឫទ្ធិដែលអធិដ្ឋាន និងជាឫទ្ធិដែលក្លែងបានផ្សេង ៗ ព្រោះធ្វើឲ្យពិសេសផ្សេងគ្នារបស់ឫទ្ធិទាំងនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ញាណវិប្ផារនិទ្ទេស** ដូចតទៅនេះ ។ ឈ្មោះថា **ញាណវិប្ផារា** ឫទ្ធិដែលផ្សាយទៅដោយញាណ ព្រោះមានកម្លាំងផ្សាយទៅនៃញាណ ។ ក៏ក្នុងបទនេះ គប្បីជ្រាបថា លោកសម្តែងឫទ្ធិដោយអនុបស្សនា ៧ ហើយសន្ទេបឫទ្ធិដ៏សេស រហូតដល់អរហត្តមគ្គ ។

ក្នុងបទមានជាអាទិ៍ថា ព្រះពាកុលៈ មានឫទ្ធិដែលផ្សាយទៅដោយញាណ មានសេចក្តីថា ព្រះពាកុលត្ថេរ មានឈ្មោះយ៉ាងនេះ ព្រោះជាអ្នកចម្រើនក្នុងត្រកូលទាំងពីរ សន្សំបុញ្ញបារមីមក ក្នុងព្រះពុទ្ធអង្គមុន ៗ លោកជាព្រះថេរៈដែលដល់ព្រមដោយបុញ្ញសម្បទា សោយមហាសម្បត្តិ ។ ពិតណាស់ ព្រះថេរៈនោះត្រាច់រង្គត់ទៅក្នុងទេវលោក និងមនុស្សលោក កើតក្នុងព្រះសាសនារបស់ព្រះទសពលនៃយើង លោកកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងកោសម្ពី ( មុន ) ។ ក្នុងវេលាដែល



ព្រះថេរៈនោះកើត អ្នកបម្រើព្រមទាំងបរិវារ ក៏នាំទៅកាន់ទន្លេយមុនាព្រមជាមួយបរិវារដ៏ច្រើន ផ្ងូតទឹកជម្រះកាយដើម្បីសិរិមង្គល ។ ត្រីធំមួយក្បាល សម្គាល់ថា ទារកនេះជាអាហាររបស់យើង ទើបហាមាត់ហែលទៅរក ។ ស្ត្រីបម្រើក៏ព្រលែងទារកចោល ម្នីម្នាគេចចេញ ។ ត្រីធំក៏លេបទារកនោះ ។ សត្វដែលមានបុណ្យ មិនបានទទួលនូវទុក្ខអ្វីឡើយ ហាក់បីដូចចូលទៅនៅក្នុងបន្ទប់ដេកដូច្នោះ ដោយតេជៈរបស់ទារក ត្រីក៏ក្តៅក្រហល់ក្រហាយ ដូចលេបក្បៀងក្តៅ ហើយហែលទៅយ៉ាងលឿនអស់ចម្ងាយ ៣០ យោជន៍ ចូលទៅជាប់សំណាញ់របស់ព្រានប្រម៉ង់អ្នកក្រុងពារាណសី ។ ត្រីនោះ ពេលព្រានប្រម៉ង់យកចេញពីសំណាញ់ក៏ស្លាប់ទៅ ដោយតេជៈរបស់ទារកនោះ ។ ព្រានប្រម៉ង់យកត្រីនោះដាក់លើសង្រែក គិតថា នឹងលក់ក្នុងតម្លៃ ១.០០០ កហាបណៈ រួចត្រាសច់ទៅក្នុងនគរ ទៅដល់ទ្វារផ្ទះរបស់សេដ្ឋីមិនមានបុត្រ មានទ្រព្យ ៨០ កោដិ បានលក់ត្រីឲ្យភរិយាសេដ្ឋី ១ កហាបណៈ ។ សេដ្ឋីនីយកត្រីទុកលើបន្ទះក្តារដោយខ្លួនឯង ហើយវះត្រីនោះអំពីខ្នង លុះឃើញទារកមានពណ៌ដូចមាសនៅក្នុងពោះត្រី ទើបពោលឡើងថា យើងបានបុត្រក្នុងពោះត្រីហើយ រួចនាំទារកចូលទៅរកស្វាមី ។ ក្នុងពេលនោះឯង សេដ្ឋីឲ្យវាយស្គរប្រកាស ហើយនាំទារកទៅគាល់ព្រះរាជា ក្រាបទូល

ដើម្បីឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា ទារកមានបុណ្យ លោកចូរចិញ្ចឹមទារកឲ្យបានល្អ ។ ត្រកូលសេដ្ឋីដែលជាមាតាបិតា លុះជ្រាបរឿងរ៉ាវនោះ ទើបទៅកាន់ទីនោះ និយាយថា បុត្ររបស់យើងទើបដណ្តើមគ្នាយកទារកនោះ ។ ទាំងពីរនាក់ក៏បានទៅគាល់ព្រះរាជា ។

ព្រះរាជាត្រាស់ថា យើងមិនអាចធ្វើឲ្យត្រកូលទាំងពីរ មិនឲ្យមានបុត្របាន ទារកនេះចូរជាទាយាទរបស់ត្រកូលទាំងពីរចុះ ។ តាំងអំពីនោះមក ត្រកូលទាំងពីរ ក៏ឧត្តមសំបូរដោយលាភច្រើន ។ ព្រោះទារកនោះ ជាអ្នកចម្រើនដោយត្រកូលទាំងពីរ ទើបតាំងឈ្មោះថា **ពាកុលកុមារ** ។ កាលពាកុលកុមារនោះដឹងសេចក្តីហើយ មាតាបិតាទើបសាងប្រាសាទមួយកន្លែងមានបីខ្នងក្នុងនគរទាំងពីរ រកអ្នកច្រៀងរាំមកសម្តែងជាប្រចាំ ។ ពាកុលកុមាររស់នៅក្នុងនគរមួយ ៗ រយៈពេលបួនខែ ។ កាលពាកុលកុមាររស់នៅក្នុងនគរមួយ គ្រប់បួនខែ មាតាបិតាទើបសាងមណ្ឌបទុកលើទូកធំមួយ ហើយឲ្យពាកុលកុមារព្រមទាំងអ្នករបាំឡើងទៅនៅលើទូកធំនោះ ហើយនាំពាកុលកុមារ សោយមហាសម្បត្តិ ទៅមួយពួកទៀត ពីរខែបានពាក់កណ្តាលផ្លូវ ។ សូម្បីពួកអ្នកនគរមួយពួកទៀត ក៏ត្រៀមទទួលដូចគ្នា ដោយគិតថា ពីរខែទៀត ពាកុលកុមារនឹងមកដល់ពាក់កណ្តាលផ្លូវ ហើយនាំទៅកាន់នគរ



របស់ខ្លួន ឲ្យរស់នៅបានពីរខែ ។ ពាកុលកុមាររស់នៅក្នុងនគរនោះបួនខែ ហើយត្រឡប់ទៅនគរមួយទៀត ដោយទំនងនោះ ។ កាលពាកុលកុមារសោយសម្បត្តិយ៉ាងនេះឯង រហូតអាយុ ៨០ ឆ្នាំ ។

ក្នុងសម័យនោះ ព្រះពោធិសត្វរបស់យើង បានសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ទ្រង់ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ស្តេចចារិកទៅតាមលំដាប់រហូតដល់ក្រុងកោសម្ពី ។ ព្រះមជ្ឈិមភាណកាចារ្យពោលថា ក្រុងពារាណសី ។ សូម្បីពាកុលសេដ្ឋី ក៏បានឮថា ព្រះទសពលស្តេចយាងមក ទើបកាន់យករបស់ក្រអូប និងផ្កាឈើដ៏ ច្រើនទៅគាល់ព្រះសាស្តាស្តាប់ព្រះធម្មកថា មានសទ្ធាហើយក៏បួស ។ ព្រះពាកុលៈនៅជាបុថុជ្ជន ៧ ថ្ងៃប៉ុណ្ណោះ ក្នុងអរុណថ្ងៃទី ៨ ក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ។

លំដាប់នោះ មាតុគ្រាមដែលនៅក្នុងនគរទាំងពីរ មកអំពីត្រកូលរបស់ខ្លួន ៗ ទៅទីកន្លែងនោះ ធ្វើចីវរប្រគេនដល់លោក ។ ព្រះថេរៈប្រើប្រាស់ចីវរដែលអ្នកក្រុងកោសម្ពីបញ្ជូនទៅប្រគេនកន្លះខែ ។ អ្នកក្រុងកោសម្ពី ក៏បញ្ជូនទៅប្រគេនរាល់កន្លះខែ ដោយទំនងនេះ បាននាំវត្ថុដ៏ឧត្តមក្នុងនគរទាំងពីរ មកប្រគេនព្រះថេៈ ដោយប្រការដូច្នេះ ។ ព្រះថេរៈបួសបាន ៨០ វស្សា យ៉ាងមានសេចក្តីសុខ ។ អាពាធសូម្បី

ប្រមាណតិចតួច ក៏មិនធ្លាប់មានដល់ព្រះថេរៈនោះ ទាំងពីរត្រកូល ព្រះថេរៈពោលពាកុលសូត្រក្នុងទីបំផុតចុងក្រោយ ហើយក៏បរិនិព្វាន ដោយប្រការដូច្នេះ ។ ការមិនមានរោគក្នុងពោះត្រី ឈ្មោះថា ឫទ្ធិ ដែលផ្សាយទៅដោយញាណ ព្រោះព្រះពាកុលៈមានភពចុងក្រោយ កើតដោយអានុភាពនៃអរហត្តញ្ញាណ ដែលគួរបានដោយអត្តភាព នោះ ។ អាចារ្យទាំងឡាយពោលថា ដោយអានុភាពនៃបដិសម្ភិទា-ញាណ ដែលសម្រេចដោយផលកម្មជាសុចរិត ។

សូម្បីព្រះសង្កិច្ចត្ថេរ ក៏ធ្លាប់ធ្វើបុណ្យទុកអំពីមុន បានកើតក្នុងគភ៌របស់ធីតាត្រកូលស្តុកស្តម្ភក្នុងក្រុងសាវត្ថី ដែលជាឧបដ្ឋាករបស់ព្រះធម្មសេនាបតីថេរៈ ។ ធីតានោះ កាលទារកនៅក្នុងគភ៌ បានដល់កម្មចាស់ ក្នុងខណៈនោះឯងដោយរោគណាមួយក៏ធ្វើកាលកិរិយាទៅ ។ កាលរាងកាយរបស់ធីតាត្រូវបានដុត សាច់ដែលសល់អំពីភ្លើងមានតែសាច់ត្រង់គភ៌ប៉ុណ្ណោះ ។ លំដាប់នោះ សាច់ត្រង់គភ៌របស់នាងជ្រុះធ្លាក់អំពីជើងថ្ករ អ្នកដុតសពយកឈើចាក់ក្នុងសាច់នោះ ២-៣ កន្លែង ។ ចុងឈើក៏ចាក់ត្រូវភ្នែករបស់ទារក ។ អ្នកដុតសពទាំងឡាយចាក់សាច់ត្រង់គភ៌ហើយ យកទៅដាក់លើគំនរផេះ យកផេះលុបអំពីខាងលើ ហើយនាំគ្នាត្រឡប់ទៅផ្ទះរៀង ៗ ខ្លួនទៅ ។ សាច់គភ៌



ដែលឆេះ ។ តែនៅខាងលើផេះ ទារកដែលមានពណ៌ដូចមាស ដូចដេកលើត្របកផ្កាឈូក ។ ពិតណាស់ កាលសត្វដែលមានភពចុងក្រោយ សូម្បីត្រូវភ្នំសិនេរុសង្កត់ ក៏មិនអាចអស់ជីវិតដែរ ព្រោះនៅមិនទាន់សម្រេចព្រះអរហត្ត ។ លុះព្រឹកឡើងអ្នកដុតខ្មោចគិតថា នឹងទៅរំលត់ជើងថ្ករ ទើបនាំគ្នាទៅ ហើយបានឃើញទារកដេកនៅទីនោះ ក៏កើតសេចក្តីអស្ចារ្យដែលមិនធ្លាប់មាន ទើបនាំទារកទៅកាន់នគរ សួរអ្នកព្យាករណ៍ ។ អ្នកព្យាករណ៍ពោលថា ប្រសិនបើទារកនេះនៅគ្រប់គ្រងផ្ទះ ពពួកញាតិនឹងកើតសេចក្តីលំបាកអស់ ៧ ជួរត្រកូល ប្រសិនបើបួសនឹងមានសមណៈ ៥០០ ហែហម ។ តាបានចិញ្ចឹមទារកនោះរហូតដល់ធំ កាលទារកចម្រើនវ័យសូម្បីពួកញាតិ ក៏នាំគ្នាចិញ្ចឹមរក្សាដោយប្រាថ្នាថា នឹងឲ្យបួសក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់របស់យើង ។ កាលទារកមានអាយុបាន ៧ ខួប បានឮក្មេង ៗ និយាយគ្នាថា មាតារបស់លោកបានស្លាប់តាំងអំពីលោកនៅក្នុងគភ៌ កាលបើសពរបស់មាតាត្រូវដុត លោកក៏ឆេះភ្លើង ទើបប្រាប់ពួកញាតិថាសេចក្តីដែលខ្ញុំផុតចាកភ័យបែបនេះ ខ្ញុំមិននៅជាយរាវាសឡើយ ខ្ញុំនឹងចេញបួស ។ ពួកញាតិពោលថា ប្រសើរហើយ ទើបនាំគ្នាទៅរកព្រះធម្មសេនាបតីសារីបុត្តប្រាប់លោកឲ្យបានជ្រាបថា សូមលោកម្ចាស់អនុញ្ញាតឲ្យកុមារ

នេះបួសផង ។ ព្រះថេរៈយល់ព្រម នឹងឲ្យតចបញ្ចកកម្មដ្ឋានដល់កុមារតូច ។ កុមារតូចត្រឹមតែកោរសក់អស់ប៉ុណ្ណោះ ក៏បានសម្រេចជាព្រះអរហន្តព្រមដោយបដិសម្ភិទា ។ លុះមានអាយុគ្រប់ ក៏ឧបសម្បទបួសបាន ១០ វស្សា មានភិក្ខុ ៥០០ ជាបរិវារ ។ ភាពជាអ្នកមិនមានរោគលើដើងថ្កូ ដោយន័យដូចពោលហើយនោះឯង ឈ្មោះថា ឫទ្ធិផ្សាយទៅដោយញាណរបស់ព្រះសង្កិច្ចត្ថេរ ។

សូម្បីព្រះភូតបាលត្ថេរ ក៏ជាអ្នកដល់ព្រមដោយហេតុមកអំពីមុន ។ បិតារបស់លោកជាអ្នកក្រលំបាករស់នៅក្នុងក្រុងរាជគ្រឹះ ។ បិតានាំទារកនោះទៅព្រៃជាមួយរទេះដើម្បីរកឧស កាលរកឧសពេញរទេះហើយ ក៏ធ្វើដំណើរត្រឡប់មកដល់ជិតទ្វារក្រុងក្នុងវេលារសៀល ។ លំដាប់នោះ គោទាំងឡាយរបស់គេរលាស់ចេញពីនឹមហើយដើរចូលទៅក្នុងក្រុង ។ គេឲ្យបុត្តតូចអង្គុយក្រោមរទេះចាំ ហើយដើរតាមស្នាមជើងគោចូលទៅក្នុងក្រុង ។ គេមិនអាចចេញអំពីក្រុងបាន ព្រោះទ្វារក្រុងបានបិទ ។ ទារកដេកនៅក្រោមរទេះតែម្នាក់ឯងរហូតដល់យប់ ។ តាមប្រក្រតីក្រុងរាជគ្រឹះ មានអមនុស្សច្រើន ក៏ទីដែលទារកដេកនៅជិតទីព្រៃស្មសាន និងមិនមានយក្សណា ៗ អាចធ្វើអន្តរាយដល់ទារក ដែលមានភពចុងក្រោយនោះបាន ។ លុះតមក ទារកនោះបួស



ក៏បានសម្រេចជាព្រះអរហន្ត មានឈ្មោះថា **ភូតបាលត្ថេរ** ។ ភាពជាអ្នកមិនមានរោគ ដោយន័យដូចពោលហើយក្នុងទីកន្លែង សូម្បីជាទីត្រាច់ទៅនៃយក្សកាចយ៉ាងនេះ ឈ្មោះថា ឫទ្ធិដែលផ្សាយទៅដោយញាណរបស់ព្រះភូតបាលៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សមាធិវិប្ផារិទ្ធិនិទ្ទេស** ដូចតទៅនេះ ។ ក្នុងបទមានជាអាទិ៍ថា **អាយស្មតោ សារីបុត្តត្ថេរស្ស សមាធិវិប្ផារឥទ្ធិ** ឫទ្ធិដែលផ្សាយទៅដោយសមាធិរបស់ព្រះសារីបុត្ត មានសេចក្តីថា កាលព្រះសារីបុត្តនៅឯកបោតកន្ទ្រជាមួយនឹងព្រះមហាមោគ្គល្លានក្នុងយប់ខែភ្លឺ មិនទាន់បានកោរសក់ អង្គុយក្នុងទីវាល យក្សកំណាចម្នាក់ សូម្បីត្រូវយក្សជាសំឡាញ់ហាមហើយ ក៏បានប្រហារមកលើសីរសៈរបស់ព្រះថេរៈ មានសំឡេងយ៉ាងកងរំពងដូចសំឡេងរន្ទះ ។ ក្នុងខណៈដែលយក្សប្រហារ ព្រះថេរៈអង្គុយចូលសមាបត្តិ ទើបមិនមានឈឺចាប់អ្វី ដោយការប្រហារនោះ ។ នេះជាឫទ្ធិដែលផ្សាយទៅដោយសមាធិរបស់ព្រះសារីបុត្តត្ថេរនោះ ។ សមដូចព្រះសារីបុត្តត្ថេរពោលទុកថា :

ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ សម័យមួយព្រះដ៏មាន-ព្រះភាគជាម្ចាស់ប្រថាប់នៅព្រះវិហារវេឡុវនកលន្ទកនិវាបៈ ជិតក្រុង

រាជគ្រឹះ ។ សម័យនោះ ព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន គង់នៅឯកបោតកន្ទរា ។ សម័យនោះ ព្រះសារីបុត្តគង់ក្នុងកណ្ដាលយប់ខែភ្លឺ មិនបានកោរសក់ គង់ចូលសមាធិណាមួយ នៅទីវាលស្រឡះ ។

សម័យនោះឯង យក្សជាសឡាញ់ពីរនាក់ចេញចាកពីទិសឧត្តរទៅទិសទក្សិណដោយកិច្ចឯណាមួយ ។ យក្សទាំងពីរបានឃើញព្រះសារីបុត្ត ។ល។ គង់នៅទីវាល លុះឃើញហើយ យក្សម្នាក់បាននិយាយនឹងយក្សជាសំឡាញ់ថា ម្នាលសំឡាញ់ ពន្លឺស្វាងស្វែសមល្មមដល់យើងនឹងប្រហារសីរសៈរបស់សមណៈនេះ ។ កាលយក្សពោលយ៉ាងនេះហើយ យក្សសំឡាញ់បាននិយាយនឹងយក្សនោះថា កុំឡើយសំឡាញ់ កុំមើងងាយសមណនោះឡើយ សមណៈនោះជាអ្នកធំក្រៃលែង មានឫទ្ធិច្រើន មានអានុភាពច្រើន ។ សូម្បីលើកទី ២ សូម្បីលើកទី ៣ ។ល។ ម្នាលសំឡាញ់ សមណៈជាអ្នកធំក្រៃលែង មានឫទ្ធិច្រើន មានអានុភាពច្រើន ។

គ្រានោះឯង យក្សនោះមិនបានស្ដាប់ពាក្យយក្សជាសំឡាញ់ ក៏បានប្រហារសីរសៈរបស់ព្រះសារីបុត្ត គឺ ជាការប្រហារដ៏យ៉ាងខ្លាំង ដោយការប្រហារនោះ អាចធ្វើឲ្យដំរីដែលមានទំហំ ៧ ហត្ថ ឬ ៧ ហត្ថកន្លះ លិចស្រុតទៅក្នុងផែនដីបាន ឬអាចទំលាយកំពូលភ្នំដ៏ធំបាន



ប៉ុន្តែយក្សនោះស្រែកថា យើងក្ដៅ យើងក្ដៅ ហើយក៏ធ្លាក់ចុះទៅក្នុងមហានរក ត្រង់ទីនោះឯង ។

ព្រះមហាមោគ្គល្លានត្ថេរ ឃើញយក្សនោះប្រហារសីរសៈរបស់ព្រះសារីបុត្តដោយទិព្វចក្ខុដ៏បរិសុទ្ធិប្រសើរជាងរបស់មនុស្ស ទើបចូលទៅរកព្រះសារីបុត្ត បានពោលនឹងព្រះសារីបុត្តថា ម្នាលសារីបុត្តដ៏មានអាយុ ល្មមអត់ទ្រាំបានឬ គប្បីព្យាបាលឬ មិនមានទុក្ខអ្វីខ្លះទេឬ ព្រះសារីបុត្តពោលថា ម្នាលមោគ្គល្លានល្មមអត់ទ្រាំបាន ល្មមព្យាបាលបាន ក៏សីរសៈរបស់ខ្ញុំមានទុក្ខបន្តិចបន្តួចប៉ុណ្ណោះ ។

ព្រះមហាមេគ្គល្លានពោលថា ម្នាលសារីបុត្ត គួរអស្ចារ្យក្នុងរឿងមិនធ្លាប់មានមកឡើយ ប្រការដែលព្រះសារីបុត្តមានឫទ្ធិច្រើន មានអានុភាពច្រើន ម្នាលសារីបុត្ត យក្សម្នាក់នេះបានប្រហារសីរសៈរបស់លោក គឺ ជាការប្រហារដ៏ធំក្រៃលែង ។ល។ ក៏សីរសៈរបស់ខ្ញុំមានទុក្ខតែបន្តិចបន្តួច ។

ព្រះសារីបុត្តត្ថេរពោលថា ម្នាលមោគ្គល្លាន គួរអស្ចារ្យមិនធ្លាប់មានមកឡើយ ប្រការដែលព្រះមហាមោគ្គល្លានមានអានុភាពច្រើន រមែងឃើញសូម្បីយក្សក្នុងទីណា ឥឡូវនេះពួកយើងមិនបានឃើញសូម្បីបិសាចនោះ ក្នុងទីនោះទៀតឡើយ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានស្តាប់ការសន្ទនារបស់មហានាគទាំងពីរ ដោយទិព្វសោតដ៏បរិសុទ្ធិកន្លងសោតរបស់មនុស្ស ទើបទ្រង់ឧទានឡើងថា :

**ចិត្តរបស់អ្នកណាប្រៀបដូចភ្នំថ្ម តាំងមាំមិនញាប់ញ័រ មិនត្រេកអរក្នុងអារម្មណ៍ ជាទីតាំងនៃតម្រេក មិនក្រោធក្នុងអារម្មណ៍ ដែលជាទីតាំងនៃសេចក្តីក្រោធ ចិត្តរបស់អ្នកណាអប់រំហើយយ៉ាងនេះ ទុក្ខនឹងចូលដល់អ្នកនោះដូចម្តេចបាន ។**

ក៏ពាក្យក្នុងអដ្ឋកថាថា ដោយការប្រហារនោះ មិនមានសេចក្តីឈឺចាប់ណា ៗ ឡើយ សមដូចនឹងព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគត្រាស់ទុកថា ទុក្ខនឹងមានដល់អ្នកនោះបានអំពីណា ព្រោះដូច្នោះទុក្ខ-វេទនា រមែងមិនមាន ដូចពាក្យព្រះសារីបុត្តត្ថេរពោលថា ក៏សីរសះរបស់យើងមានទុក្ខបន្តិចបន្តួច តែលោកពោលថា ទុក្ខ សំដៅដល់សីរសះនោះមិនគួរដល់ការងើរ ពិតណាស់ សូម្បីក្នុងលោក លោកក៏ពោលថា ប្រក្រតីសេចក្តីសុខអាចរក្សាបានដោយមិនលំបាក ប្រក្រតីនៃសេចក្តីទុក្ខអាចនឹងរក្សាបានដោយលំបាក តែសីរសះមិនគួរដល់ការងើរនោះ គប្បីជ្រាបថា ដែលមាន ព្រោះជាសម័យចេញចាកសមា-



បត្តិហើយ ក្នុងសម័យដែលរីករាយដោយសមាបត្តិមិនគប្បីមានឡើយ លោកពោលថា ឥឡូវនេះ យើងរមែងមិនឃើញសូម្បីបិសាចនោះឡើយ ព្រោះមិនអាចនឹងឃើញបាន លោកពោលព្រោះមិនមានសេចក្តីខ្វល់ខ្វាយក្នុងអភិញ្ញាទាំងឡាយ មានន័យថា ព្រះថេរៈអនុគ្រោះដល់ពពួកជនក្នុងកាលជាខាងក្រោយ កុំមានការសម្គាល់ឫទ្ធិដែលជារបស់បុថុជ្ជនថាមានសារៈឡើយ ដោយច្រើនមិនឲ្យឫទ្ធិ ក្នុងថេរគាថាលោកពោលទុកថា :

**សេចក្តីប្រាថ្នារបស់យើង មិនមែនដើម្បីបុព្វេនិវាសញ្ញាណ មិនមែនដើម្បីទិព្វចក្ខុ មិនមែនដើម្បីឫទ្ធិ ដែលជាចេតោប-រិយញ្ញាណ ដើម្បីចុតិ ដើម្បីឧប្បត្តិ ដើម្បីសេចក្តីបរិសុទ្ធិនៃសោតធាតុឡើយ ។**

ព្រះថេរពោលដល់ ការមិនមានសេចក្តីប្រាថ្នាក្នុងអភិញ្ញាទាំងឡាយដោយខ្លួនឯង តែព្រះថេរៈសម្រេចនូវបារមី ក្នុងសាវកបារមី-ញាណ ។

មនុស្សចិញ្ចឹមគោជាដើមយល់ថា ព្រះសជ្ជីវត្ថេរដែលចូលនិ-រោធ ជាអគ្គសាវកទីពីររបស់ព្រះដ៏មានព្រះភាគ ព្រះនាមថា **កកុសន្ធ** មរណភាពហើយ ទើបប្រមូលយកស្មៅ និងឧសជាដើមមកគរដុត សូម្បី

ត្រឹមតែអង្រួះ ចីវរ របស់ព្រះថេរៈក៏មិនឆេះ នេះជាឫទ្ធិដែលផ្សាយទៅដោយសមាធិ សមដូចព្រះដ៏មានព្រះជាម្ចាស់ត្រាស់ទុកថា :

ម្នាលមារដ៏លាមក ក៏សម័យនោះឯង ព្រះដ៏មានព្រះជាម្ចាស់ព្រះនាមថា **កកុសន្ធ** ជាព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ម្នាលមារដ៏លាមក ព្រះមានព្រះភាគជាម្ចាស់ព្រះនាមថា កកុសន្ធៈ ដែលជាព្រះអរហន្តសម្មាសម្ពុទ្ធ មានសាវកគូ ឈ្មោះថា វិធុរៈ និងសញ្ជីវៈ ជាគូចម្រើនដ៏ប្រសើរ សាវកទាំងឡាយរបស់ព្រះដ៏មានព្រះ-ភាគជាម្ចាស់ព្រះនាមថា **កកុសន្ធ** ជាអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ មិនមានសាវកណា ៗ នឹងស្មើដូចព្រះវិធុរៈ ក្នុងការសម្តែងធម៌ ដោយបរិយាយនេះ ព្រះវិធុរៈ ទើបឈ្មោះថា **វិធុរោ** ចំណែកព្រះសញ្ជីវៈទៅកាន់ព្រៃខ្លះ ទៅកាន់គល់ឈើខ្លះ ទៅកាន់ផ្ទះស្ងាត់ខ្លះ រមែងចូលកាន់សញ្ញាវេទយិតនិរោធដោយមិនលំបាកឡើយ ។

ម្នាលមារមានចិត្តបាប រឿងធ្លាប់មានមកហើយ ព្រះសញ្ជីវៈអង្គុយចូលសញ្ញាវេទយិតនិរោធទៀបគល់ឈើកន្លែងមួយ ពួកមនុស្សចិញ្ចឹមគោ ចិញ្ចឹមបសុសត្វ អ្នកស្រែ អ្នកត្រាច់ទៅ បានឃើញព្រះសញ្ជីវៈចូលសញ្ញាវេទយិតនិរោធទៀបគល់ឈើកន្លែងមួយ គ្រាឃើញហើយក៏គិតថា គួរអស្ចារ្យពិតហ្ន៎ ព្រះអើយ មិនធ្លាប់មានមក



ហើយ សមណៈនេះអង្គុយមរណកាល ពួកយើងជួយគ្នាដុតចុះ ។

លំដាប់នោះ បុគ្គលចិញ្ចឹមគោ បុគ្គលចិញ្ចឹមបសុសត្វ អ្នកស្រែ អ្នកត្រាច់ទៅ ទើបទាញស្មៅ ឧស គោម័យ គរលើកាយរបស់ព្រះសញ្ជីវៈដុតភ្លើងត្រឡប់ទៅ លំដាប់នោះ ព្រះសញ្ជីវៈដោយរាត្រីនោះកន្លងទៅ ចេញចាកសមាបត្តិរលាស់ចីវរ ស្លៀកពាក់ពេលព្រឹកកាន់យកបាត្រនិងចីវរចូលទៅស្រុកដើម្បីបិណ្ឌបាត មនុស្សចិញ្ចឹមគោមនុស្សចិញ្ចឹមបសុសត្វ អ្នកស្រែ អ្នកត្រាច់ទៅ ឃើញព្រះសញ្ជីវៈចេញបិណ្ឌបាត ទើបគិតថា គួរអស្ចារ្យណាស់ ព្រះអើយ មិនធ្លាប់មានមកហើយ ព្រះសមណៈនេះអង្គុយមរណកាល លោករស់ឡើងមកវិញហើយ ដោយបរិយាយនេះឯង ព្រះសញ្ជីវៈទើបឈ្មោះថា **សញ្ជីវោ** ដោយប្រការដូច្នេះឯង ។

ចំណែកព្រះខាណុកោណ្ឌញ្ញត្ថេរតាមប្រក្រតី ជាអ្នកច្រើនដោយសមាបត្តិ ព្រះថេរៈនោះអង្គុយចូលសមាបត្តិរហូតយប់ ក្នុងព្រៃមួយកន្លែង ចោរ ៥០០ នាក់ លួចស្រូវ របស់អ្នកដំណើរទៅបំណងនឹងសម្រាកដោយគិតថា ឥឡូវនេះមិនមានមនុស្សដើរតាមស្នាមជើងពួកយើង ទើបដាក់ស្រូវរបស់ពួកគេចុះ សម្គាល់ថាជាឈើ ទើបដាក់ស្រូវរបស់ពួកគេទាំងអស់ទុកលើរាងកាយនៃព្រះថេរៈនោះឯង កាល

ពួកចោរសម្រាកហើយត្រៀមនឹងដើរទៅ ក្នុងខណៈដែលនឹងកាន់ស្រូវរបស់ពួកគេដែលដាក់ទុកក្នុងគ្រាដំបូង ព្រះថេរៈក្រោកឡើងតាមវេលាដែលកំណត់ទុក ពួកចោរឃើញអាការដែលព្រះថេរៈធ្វើចលនាបានក៏ស្រែកឡើងដោយការភ័យខ្លាច ព្រះថេរៈពោលថា ឧបាសកទាំង-ឡាយកុំខ្លាចឡើយ យើងជាភិក្ខុ ពួកចោរទើបនាំគ្នាមកសំពះដោយសេចក្តីជ្រះថ្លាក្នុងព្រះថេរៈ ទើបបានបួស ហើយសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ចាប់ផ្តើមពីនោះមក ព្រះថេរៈទើបបានឈ្មោះថា **ខាណុកោណ្ឌញ្ញត្ថេរោ** សេចក្តីដែលព្រះខាណុកោណ្ឌញ្ញត្ថេរនោះត្រូវចោរយកស្រូវអង្ករ ៥០០ កញ្ចប់ ដាក់សង្កត់ពីលើ មិនមានឈឺចាប់ នេះជាឫទ្ធិដែលផ្សាយទៅដោយញាណ ។

ចំណែកនាងឧត្តរាឧបាសិកា ធិតារបស់បុណ្ណសេដ្ឋី អ្នកមានទ្រព្យច្រើនក្នុងក្រុងរាជគ្រឹះ ក្នុងវេលាជាកុមារិកានោះឯង បានសម្រេចសោតាបត្តិផលព្រមជាមួយមាតាបិតា នាងចម្រើនវ័យហើយ មាតា-បិតាបានលើកនាងឲ្យដល់បុត្តរបស់រាជគហសេដ្ឋី ដែលជាមិច្ឆាទិដ្ឋិដោយការទាក់ទងគ្នាច្រើន នាងឧត្តរាឧបាសិកាមិនបានឱកាសដើម្បីនឹងឃើញព្រះពុទ្ធជាម្ចាស់ ដើម្បីស្តាប់ធម៌ និងដើម្បីឲ្យទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ជាអ្នកខ្វល់ខ្វាយ ទើបហៅនាងពេស្យា



ឈ្មោះថា **សិរិមា** ក្នុងនគរនោះឯង ហើយឲ្យកហាបណៈ ១៥.០០០ ដែលនាងនាំមកពីផ្ទះរបស់បិតា ដើម្បីបានធ្វើបុណ្យតាមឱកាសដល់នាងសិរិមានោះ ហើយប្រាប់ថា នាងចូរកាន់យកកហាបណៈទាំងនេះ ហើយបម្រើសេដ្ឋីបុត្តរហូតកន្លះខែនេះ ឲ្យនាងសិរិមាពេញចិត្តជាមួយស្វាមីរបស់ខ្លួន អធិដ្ឋានអង្គឧបោសថល្អហើយ យើងនឹងបានឃើញព្រះពុទ្ធជាម្ចាស់ជាដើមរហូតកន្លះខែនេះ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានរហូតបវារណា បានថ្វាយមហាទានរហូតកន្លះខែ ខាងក្រោយអាហារឲ្យចាត់ចែងរបស់ទំពាររបស់បរិភោគក្នុងរោងផ្ទះបាយធំ ចំណែកស្វាមីរបស់នាងគិតថា ស្អែកនេះនឹងជាថ្ងៃបវារណា ទើបឈរត្រង់មុខបង្អួចជាមួយនឹងនាងសិរិមាចេញទៅខាងក្រៅ ឃើញនាងឧត្តរាដើរយ៉ាងនោះ ញើសជោគពេញទៅដោយផេះ ប្រឡាក់ទៅដោយម្រែងភ្លើង ទើបសើចថា ស្រីល្ងង់មិនចេះបរិភោគសម្បត្តិរបស់ខ្លួន ធ្វើតែកុសល សូម្បីនាងឧត្តរាក៏ក្រលេកមើលស្វាមី សើចថា មនុស្សល្ងង់មិនធ្វើកុសលដើម្បីភពមុខ ។

នាងសិរិមាឃើញកិរិយារបស់មនុស្សទាំងពីរ សម្គាល់ថា យើងជាម្ចាស់ផ្ទះ ទើបគិតច្រណែនក្រោធនាងឧត្តរាគិតថា យើងនឹងធ្វើឲ្យនាងឧត្តរាលំបាក ទើបចុះពីប្រាសាទ នាងឧត្តរាដឹងហេតុនោះទើបអង្គុយ

លើតាំងផ្សាយមេត្តាចិត្តទៅកាន់នាងសិរិមានោះ នាងសិរិមាចុះចាកប្រាសាទ ចូលរោងផ្ទះបាយ យកទឹកដោះថ្លាដែលក្តៅពេញក្របោយ ព្រោះស្មានជាទឹកដោះជះទៅលើសីសៈរបស់នាងឧត្តរា ទឹកដោះថ្លាក្លាយទៅដូចទឹកត្រជាក់លើស្លឹកឈូក ពួកទាសីនាំគ្នាវាយនាងសិរិមាដោយដៃ និងឈើឲ្យដួលចុះលើផែនដី នាងឧត្តរាចេញចាកមេត្តាឈាន ហើយទើបហាមពួកទាសី នាងសិរិមាសូមទោសនាងឧត្តរា នាងឧត្តរាពោលថា ស្អែកនេះ នាងចូរមកសូមខមាទោសចំពោះព្រះភ័ក្ត្រនៃព្រះ-សាស្តា ហើយប្រាប់ការតាក់តែងអាហារដល់នាងសិរិមាអ្នកអង្វរទទួលប្រើផ្ទូវកាយ នាងសិរិមាមកតាក់តែងអាហារហើយ មានស្រីពេស្យា ៥០០ បរិវាររបស់ខ្លួនអង្គាសព្រះសាស្តា និងព្រះសង្ឃហើយពោលថា ពួកនាងចូរជាមិត្តក្នុងការឲ្យនាងឧត្តរាលើកទោសចុះ លុះព្រឹកឡើងព្រមដោយស្រីពេស្យាទាំងនោះ កាលព្រះសាស្តាសោយព្រះក្រយាហារស្រេចហើយ ទើបថ្វាយបង្គំព្រះសាស្តាទូលថា បពិត្រព្រះមានព្រះភាគជាម្ចាស់ នាងខ្ញុំបានធ្វើខុសចំពោះនាងឧត្តរា សូមឲ្យនាងឧត្តរាលើកទោសឲ្យដល់នាងខ្ញុំចុះ ព្រះសាស្តាត្រាស់ថា ម្នាលនាងឧត្តរា ចូរលើកទោសចុះ កាលនាងទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងខ្ញុំលើកទោសឲ្យហើយ ទ្រង់សម្តែងធម៌មានជាអាទិ៍ថា **អក្កោធេន ជិនេ កោធំ**



គប្បីឈ្នះសេចក្តីក្រោធដោយការមិនក្រោធ នាងឧត្តរានាំស្វាមី ឪពុកក្មេក ម្តាយក្មេក ចូលទៅគាល់ព្រះសាស្តាចំពោះព្រះភ័ក្ត្រ កាលចប់ទេសនា ជនទាំង ៣ ទាំងនោះ និងស្រីពេស្យាទាំងអស់ តាំងនៅក្នុងសោតាបត្តិផល ការមិនមានសេចក្តីឈឺចាប់ដោយទឹកដោះថ្លាដ៏ក្តៅនៃនាងឧត្តរាឧបាសិកា ជាឫទ្ធិ៍ដែលផ្សាយទៅដោយសមាធិ ។

ឧបាសិកាសាមាវតីអគ្គមហេសីរបស់ព្រះបាទឧទេន ព្រះរាជាក្រុងកោសម្ពី ។ ព្រះបាទឧទេននោះមានអគ្គមហេសី ៣ អង្គ មានស្រីបរិវារមួយអង្គ ៗ ៥០០ ។ បណ្តាមហេសីទាំងនោះ នាងសាមាវតីជាធិតារបស់ភទ្ទិយសេដ្ឋីក្នុងភទ្ទិយនគរ កាលបិតាស្លាប់ហើយ មានស្រី ៥០០ ជាបរិវារ ធំឡើងក្នុងផ្ទះរបស់ឃោសិកសេដ្ឋី ក្នុងក្រុងកោសម្ពី ជាសម្លាញ់របស់បិតា ។ ព្រះរាជាទតព្រះនេត្រឃើញនាងចម្រើនវ័យហើយ ទ្រង់កើតសេចក្តីស្នេហា ទើបនាំនាងព្រមដោយបរិវារទៅកាន់ព្រះរាជវាំង ទ្រង់បានប្រកបការអភិសេកមង្គលការ ។ មហេសីមួយអង្គទៀត ឈ្មោះថា វាសុលទត្តា ជាព្រះធិតារបស់ព្រះបាទចណ្ឌប-ជោត ។ ធិតារបស់មាគន្ទិយព្រាហ្មណ៍ ដែលបិតាលើកឲ្យជាបាទបរិចារិកា បានស្តាប់គាថាដែលព្រះដ៏មានព្រះភាគត្រាស់ថា

**សូម្បីសេចក្តីពេញចិត្តក្នុងមេថុនធម្មមិនមាន ព្រោះឃើញ**

នាងតណ្ហា នាងអរតី និងនាងរាគា សេចក្តីអ្វីពេញចិត្តនឹង
មាន ព្រោះឃើញសរីរៈធិតារបស់លោកដែលពេញទៅ
ដោយមូត្រ និងនិងករីសៈ យើងមិនប្រាថ្នាពាល់ត្រូវ
សរីរៈធិតារបស់លោកនោះ សូម្បីដោយជើង ។

បានចងអាឃាតចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ មាតាបិតារបស់នាងបានសម្រេចអនាគាមិផល ក្នុងកាលចប់មាគណ្ឌិយសុត្តន្តទេសនា ទើបបួសហើយសម្រេចព្រះអរហត្ត ។ មាគណ្ឌិយព្រាហ្មណ៍ឪពុកមារបស់នាងនាំទៅកាន់ក្រុងកោសម្ពី ថ្វាយនាងចំពោះព្រះរាជា នាងទើបបានជាមហេសីមួយអង្គនៃព្រះរាជា ។

គ្រានោះឯង សេដ្ឋី ៣ នាក់ គឺ ឃោសិកសេដ្ឋី កុក្កុដសេដ្ឋី បាវារិកសេដ្ឋី បានស្តាប់ថា ព្រះតថាគតទ្រង់ឧប្បត្តិឡើងក្នុងលោក ទើបទៅគាល់ព្រះសាស្តានៅព្រះវិហារជេតពន ស្តាប់ធម៌ហើយសម្រេចសោតាបត្តិផល ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាម្ចាស់ជាប្រធានរហូតកន្លះខែ ទូលអារាធនាព្រះសាស្តាស្តេចទៅក្រុងកោសម្ពី ជនទាំង ៣ នាក់ សាងអារាម ៣ កន្លែង គឺ ឃោសិតារាម កុក្កុដារាម បាវារិការាម និមន្តព្រះសាស្តាស្តេចមកក្នុងទីនោះអារាធនាព្រះអង្គប្រថាប់នៅក្នុងវិហារម្តងមួយថ្ងៃៗ តាមលំដាប់ សេដ្ឋីម្នាក់ៗ បានថ្វាយ



មហាទានចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ព្រមដោយព្រះសង្ឃ ។ សម័យថ្ងៃមួយ នាយមាលាកាឈ្មោះថា សុមនៈ ឧបដ្ឋាករបស់សេដ្ឋីទាំងនោះ បានសូមអនុញ្ញាតពីសេដ្ឋី អារាធនាព្រះសាស្តាព្រមដោយព្រះសង្ឃមកគង់ប្រថាប់ក្នុងផ្ទះរបស់ខ្លួនដើម្បីឆាន់ភត្តាហារ ។ ខណៈនោះ នាងខុជ្ជុត្តរាទាសីទទួលបម្រើរបស់ព្រះនាងសាមាវតី ទទួលយក ៨ កហាបណៈ បានទៅកាន់ផ្ទះនាយមាលាកានោះ ។ នាយមាលាកានិយាយថា ចូរនាងជាមិត្តក្នុងការអង្គាសព្រះសាស្តាចុះ ។ នាងខុជ្ជុត្តរាបានធ្វើយ៉ាងនោះ កាលព្រះសាស្តាសោយស្រេចហើយ ស្តាប់ព្រះធម៌ទេសនាជាសោតបន្ន ក្នុងកាលដទៃកាន់យក ៤ កហាបណៈដើម្បីខ្លួន ព្រោះមិនគួរកាន់យកវត្ថុដែលគេមិនឲ្យ ទើបឈ្មោះថា ផ្កាឈើ ៨ កហាបណៈ នាំចូលទៅឲ្យដល់ព្រះនាងសាមាវតី ។ កាលព្រះនាងសាមាវតីសួរដល់ហេតុដែលផ្កាឈើមានច្រើន នាងទើបទូលប្រាប់តាមសេចក្តីពិត ព្រោះមិនគួរនិយាយកុហក ។ ព្រះនាងសាមាវតីសួរថា ព្រោះហេតុអ្វី ថ្ងៃនេះនាងទើបមិនយក ។ នាងខុជ្ជុត្តរាទូលឆ្លើយថា ខ្ញុំស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយបានធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ហើយ ។ ព្រះនាងសាមាវតីសួរថា បពិត្រនាងឧត្តរា ចូរប្រាប់អមតធម៌នោះ ដល់ពួកយើងខ្លះ ។ នាងទូលថា បើដូច្នោះ

ព្រះនាងឲ្យខ្ញុំផ្លូតទឹកហើយ ឲ្យសំពត់បរិសុទ្ធមួយគូ ឲ្យអង្គុយលើអាសនៈខ្ពស់ ព្រះនាងទាំងអស់ ចូរអង្គុយក្នុងអាសនៈទាប ។

ស្ត្រីទាំងអស់នោះបានធ្វើយ៉ាងនោះ នាងខុជ្ជុត្តរា ជាអរិយសាវិកា សម្រេចសេក្ខបដិសម្ភិទា ទើបស្លៀកសំពត់មួយផ្ទាំង ដណ្តប់សំពត់មួយផ្ទាំង កាន់យកផ្ចិតវិជនី សម្តែងធម៌ដល់ស្ត្រីទាំងនោះ ។ ព្រះនាងសាមាវតី និងស្ត្រី ៥០០ បានសម្រេចសោតាបត្តិផល ស្ត្រីទាំងអស់នោះសំពះនាងខុជ្ជុត្តរា ហើយពោលថា បពិត្រអ្នកម្ចាស់តាំងពីថ្ងៃនេះទៅ នាងមិនត្រូវធ្វើការជាអ្នកបម្រើទៀតឡើយ ចូរនាងម្ចាស់តាំងនៅក្នុងឋានៈជាមាតា ជាអាចារ្យរបស់ពួកយើង កាលស្តាប់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ចូរពោលដល់ពួកយើង ។ នាងខុជ្ជុត្តរាធ្វើតាមនោះ តមកជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ព្រះសាស្តាទ្រង់តាំងនាង នៅក្នុងឋានៈជាអ្នកប្រសើរលើសឧបាសិកាទាំងឡាយផ្នែកខាងពហុស្សូត នាងបានតំណែងជាអ្នកប្រសើរ ។ ស្ត្រីដែលនៅជាមួយនាងសាមាវតីប្រាថ្នាក្នុងការឃើញពុទ្ធជាម្ចាស់ កាលព្រះទសពលទ្រង់ដំណើរដល់វាំងថ្នល់ កាលបង្អួចមិនល្មម ក៏ចោះជញ្ជាំងក្រឡេកមើលព្រះសាស្តា ធ្វើការសំពះ និងបូជា ។

នាងមាគន្ទិយាទៅក្នុងទីនោះ ឃើញប្រហោងទាំងនោះហើយ



ទើបសួរហេតុក្នុងទីនោះ ដឹងថាព្រះសាស្តាស្តេចយាងមក ដោយការចងអាឃាតក្នុងព្រះដ៏មានព្រះភាគជាម្ចាស់ ទើបក្រោធនឹងស្ត្រីទាំងនោះបានទូលព្រះរាជាថា បពិត្រមហារាជ ស្ត្រីដែលនៅជាមួយនាងសាមាវតីមានសេចក្តីប្រាថ្នាខាងក្រៅ ចោះជញ្ជាំងសម្លឹងមើលព្រះសមណគោតមក្នុងកាលមិនយូរក៏នឹងសម្លាប់ព្រះអង្គ ព្រះរាជាសូម្បីឃើញប្រហោងក៏មិនជឿពាក្យទូលរបស់នាងមាគន្ទិយា ទ្រង់ត្រាស់បញ្ជាឲ្យធ្វើបង្អួចមានប្រហោងខាងលើ ។ នាងមាគន្ទិយាប្រាថ្នានឹងឲ្យព្រះរាជាកម្ចាត់ស្ត្រីទាំងនោះ ទើបឲ្យនាំមាន់រស់មក ៨ ក្បាល ហើយទូលថា មហារាជដើម្បីសាកល្បងស្រីទាំងនោះ សូមព្រះអង្គទ្រង់បញ្ជូនមាន់ទាំងនេះទៅដោយត្រាស់បញ្ជាថា នាងចូរសម្លាប់មាន់ទាំងនេះស្ងោរឲ្យយើង ។ ព្រះរាជាទ្រង់បញ្ជូនទៅតាមនោះ កាលព្រះនាងសាមាវតីត្រាស់ថា ពួកយើងមិនធ្វើបាណាតិបាត នាងមាគន្ទិយាទើបនិយាយទៀតថា ចូរស្ងោរបញ្ជូនទៅថ្វាយព្រះសមណៈគោតមនោះ ។ កាលព្រះរាជាទ្រង់បញ្ជូនទៅយ៉ាងនោះ នាងមាគន្ទិយា ទូលតាមនោះហើយ ទើបបញ្ជូនមាន់ស្ងោរ ៨ ក្បាល ។ ព្រះនាងសាមាវតីទើបស្ងោរទៅថ្វាយព្រះទសពល ។ សូម្បីដោយហេតុនោះ នាងមាគន្ទិយាក៏មិនអាចឲ្យព្រះរាជាពិរោធបាន ។

ព្រះរាជាប្រថាប់នៅសំណាក់មួយ ៗ ៧ ថ្ងៃ ក្នុងសំណាក់នៃ

មហេសីអង្គមួយ ៗ ក្នុងមហេសី ៣ អង្គប្រថាប់នៅ ។ ព្រះរាជាទ្រង់កាន់ពិណហៅដំរី ស្តេចទៅកាន់កន្លែងដែលព្រះអង្គស្តេចទៅ ក្នុងវេលាព្រះរាជាទៅកាន់សំណាក់ព្រះនាងសាមាវតី នាងមាគន្ទិយាឲ្យនាំកូនពស់វែកមួយក្បាលមក យកថ្នាំលាបដកចង្កូម ហើយឲ្យដាក់ចូលក្នុងបំពង់ឫស្សី ហើយដាក់ក្នុងពិណ យកដុំផ្កាឈើនោះបិទប្រហោងពិណ ក្នុងវេលាដែលព្រះរាជាស្តេចទៅក្នុងទីនោះ នាងមាគន្ទិយាធ្វើការដើរទៅដើរមក ហើយក៏ដកដុំផ្កាឈើនោះចេញពីប្រហោងពិណ ។ ពស់វាចេញមកព្រួសពិស បើកពពា ដេកលើទីផ្ទុំ នាងមាគន្ទិយាស្រែកដោយសំឡេងខ្លាំង ៗ ថា ពស់ ៗ ព្រះរាជាទ្រង់ឃើញពស់ហើយទ្រង់ពិរោធ ។ ព្រះនាងសាមាវតីដឹងថា ព្រះរាជាទ្រង់ពិរោធ ទើបបានណាត់ដល់ស្រី ៥០០ ថា ថ្ងៃនេះ ពួកនាងចូរផ្សាយមេត្តាដល់ព្រះរាជាដោយឧទិស្សកមេត្តា ( ផ្សាយចំពោះ ) ។ សូម្បីនាងខ្លួនឯង ក៏ទ្រង់បានធ្វើយ៉ាងនោះ ព្រះរាជាទ្រង់ចាប់សហស្សធ្នូ ( ធ្នូប្រើកម្លាំងមនុស្សមួយពាន់ ) ទាញខ្សែសំដៅព្រះនាងសាមាវតីមុន ហើយដល់នាងស្រីទាំងអស់នោះតាមលំដាប់ ទ្រង់ដាក់កូនសរលាបដោយថ្នាំពិស ប្រថាប់ឈរបញ្ចូលធ្នូហើយ មិនអាចនឹងបាញ់កូនសរទៅបាន មិនអាចដាក់ចុះបាន ព្រះសេទោហូរចេញចាកព្រះវរកាយ ទ្រង់ឈឺចាប់ព្រះវរកាយ



ព្រះខេឡ្បះហូរចេញចាកព្រះឱឋ: មិនឃើញវត្ថុគួរចាប់កាន់បាន លំដាប់នោះព្រះនាងសាមាវតីទូលសួរព្រះរាជាថា បពិត្រមហារាជ ព្រះអង្គទ្រង់លំបាកឬ ព្រះរាជាត្រាស់ថា ត្រូវហើយព្រះទេវី យើងលំបាកណាស់នាងចូរជាទីពឹងរបស់យើងចុះ ។ ព្រះនាងសាមាវតីទូលថា បពិត្រមហារាជ ល្អហើយ សូមព្រះអង្គចូរធ្វើកូនសរឲ្យមានមុខត្រង់ផែនដីចុះ ។ ព្រះរាជទ្រង់បានធ្វើយ៉ាងនោះ ។ ព្រះនាងសាមាវតី ទ្រង់អធិដ្ឋានថា សូមកូនសរចូរផុតចាកព្រះហស្តរបស់ព្រះរាជាចុះ ។ ក្នុងខណៈនោះកូនសរក៏ធ្លាក់ចុះ ។ ក្នុងខណៈនោះឯង ព្រះរាជាទ្រង់ចុះទៅក្នុងទឹកមានសំពត់ជោក មានព្រះកេសាជោក ទ្រង់បង្អោនចុះទៀបជើងរបស់ព្រះនាងសាមាវតី ត្រាស់ថា ព្រះទេវី លើកទោសឲ្យយើងផង ។

**យើងវង្វេងល្ងីល្ងើ ទិសទាំងពួងងងឹតស្លុបដល់យើង ម្នាល**
**នាងសាមាវតី ចូរជួយយើង ចូរជាទីពឹងរបស់យើងចុះ ។**

ព្រះនាងសាមាវតីទូលថា

**ព្រះអង្គកុំដល់ខ្ញុំម្ចាស់ជាទីពឹងឡើយ ខ្ញុំម្ចាស់ដល់ព្រះពុទ្ធជា**
**ម្ចាស់អង្គណាជាទីពឹង សូមព្រះអង្គចូរទ្រង់ដល់ព្រះពុទ្ធជាម្ចាស់**
**អង្គនោះជាទីពឹងចុះ និងសូមព្រះអង្គចូរជាទីពឹងរបស់ខ្ញុំម្ចាស់**
**ផង ។**

ព្រះរាជាត្រាស់ថា បើដូច្នោះយើងនឹងសូមដល់នាង និងព្រះសាស្តាជាទីពឹង ម្យ៉ាងទៀត យើងនឹងឲ្យពរដល់នាង ។ ព្រះនាងសាមាវតី ទូលថា បពិត្រមហារាជ សូមព្រះអង្គចូរទ្រង់ឲ្យខ្ញុំម្ចាស់ទទួលពរចុះ ។ ព្រះរាជាស្តេចទៅគាល់ព្រះសាស្តាសូមដល់ជាទីពឹង ហើយនិមន្តថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានរហូត ៧ ថ្ងៃ ត្រាស់ដល់នាងសាមាវតីថា ចូរទទួលពរចុះ ។ ព្រះនាងទទួលថា ល្អហើយ បពិត្រមហារាជ សូមព្រះអង្គចូរទ្រង់ឲ្យពរដល់ខ្ញុំម្ចាស់ គឺសូមព្រះសាស្តាចូរស្តេចមកក្នុងទីនេះព្រមដោយភិក្ខុសង្ឃ ៥០០ ចុះ ខ្ញុំម្ចាស់ នឹងស្តាប់ធម៌ ។ ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គនិមន្តមកក្នុងទីនេះ ជាមួយភិក្ខុ ៥០០ ជាប្រចាំចុះ ពួកស្រីដែលនៅជាមួយព្រះនាងសាមាវតីក៏ពោលថា ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ការទៅកាន់ទីកន្លែងតែមួយជាប្រចាំ មិនសមគួរដល់ព្រះពុទ្ធទាំងឡាយ សូម្បីមហាជនក៏នៅសង្ឃឹមនឹងឲ្យទៅ ។ ព្រះរាជាទូលថា បើដូច្នោះសូមព្រះអង្គត្រាស់បញ្ជូនភិក្ខុចុះ ។ ព្រះសាស្តាត្រាស់បញ្ជូនដល់ព្រះ-អានន្ទត្ថេរ ។ ព្រះថេរៈនាំភិក្ខុ ៥០០ ទៅកាន់រាជត្រកូលជាប្រចាំ ។ សូម្បីស្ត្រីទាំងឡាយ មានព្រះទេវីជាប្រធានទាំងនោះ ក៏អង្គាសព្រះថេរៈ



ហើយ នាំគ្នាស្តាប់ធម៌ ។ ម្យ៉ាងទៀត ព្រះសាស្តាទ្រង់តាំងព្រះនាងសាមាវតីទុកក្នុងឋានៈជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ អ្នកមានមេត្តាវិហារធម៌ ។ សេចក្តីដែលព្រះរាជាមិនអាចព្រលែងកូនសរទៅបាន ជាឫទ្ធិដែលផ្សាយទៅដោយសមាធិរបស់ព្រះនាងសាមាវតីឧបាសិកាដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ក្នុងទីនេះលោកហៅថា ឧបាសិកា ព្រោះចូលជិតព្រះរតនត្រ័យដោយសេចក្តីជ្រះថ្លា ដែលមិនញាប់ញ័រដោយសេចក្តីជ្រះថ្លាដ៏ជ្រាលជ្រៅ ឬដោយការដល់ព្រះរតនត្រ័យ ជាទីពឹង ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **អរិយិទ្ធិនិទ្ទេស** ដូចតទៅនេះ ។ បទថា **អរិយា ឥទ្ធិ** ឫទ្ធិរបស់ព្រះអរិយៈ លោកពោលថា ឫទ្ធិរបស់ព្រះអរិយៈ ព្រោះកើតដល់ព្រះអរិយៈ ជាព្រះខីណាស្រពអ្នកដល់ភាពជំនាញផ្លូវចិត្ត ។ បទថា **ឥធ ភិក្ខុ** គឺ ភិក្ខុជាព្រះខីណាស្រពក្នុងសាសនានេះ ។ បទថា **អនិដ្ឋស្មឹ វត្ថុស្មឹ** ក្នុងវត្ថុដែលមិនគួរប្រាថ្នា គឺក្នុងវត្ថុ ក្នុងសត្វ ឬក្នុងសង្ខារដែលមិនពេញចិត្ត ដោយអារម្មណ៍ប្រក្រតី ។ បទថា **មេត្តាយ វា ផរតិ** ភិក្ខុផ្សាយទៅដោយមេត្តា គឺប្រសិនបើជាសត្វ រមែងផ្សាយទៅដោយមេត្តាភាវនា ។ បទថា **ធាតុ-តោ វា ឧបសំហរតិ** បង្អោនចូលទៅដោយភាពជាធាតុ គឺ ប្រសិនបើ

ជាសង្ខារ រមែងបង្អោនទៅនូវធាតុមនសិការថា ត្រឹមតែជាធាតុ ការបង្អោនទៅសូម្បីក្នុងសត្វថា ជាធាតុក៏គួរ ។ បទថា **អសុភាយ វា ផរតិ** រមែងផ្សាយទៅដោយភាពមិនស្អាត គឺ ប្រសិនបើជាសត្វ រមែងផ្សាយទៅដោយអសុភភាវនា ។ បទថា **អនិច្ចតោ វា ឧបសំហរតិ** រមែងបង្អោនចូលទៅដោយភាពជារបស់មិនទៀង គឺ ប្រសិនបើជាសង្ខារ រមែងបង្អោនចូលទៅនូវមនសិការថា ជារបស់មិនទៀង ។ បទថា **តទុភយំ** កាត់បទជា **តំ ឧភយំ** បានដល់ ទាំងពីរនោះ ។ បទថា **ឧបេក្ខកោ** មានឧបេក្ខា គឺ មានឧបេក្ខាដោយឧបេក្ខាមានអង្គ ៦ ។ បទថា **សតោ** មានសតិ គឺ ព្រោះដល់ភាពជាអ្នកបរិបូរណ៍ដោយសតិ ។ បទថា **សម្បជានោ** មានសម្បជញ្ញៈ ព្រោះជាអ្នកមាន ការរលឹកដោយបញ្ញា ។ បទថា **ចក្ខុនា រូបំ ទិស្វា** ឃើញរូបដោយចក្ខុ គឺ ឃើញរូបដោយចក្ខុវិញ្ញាណដែលអាចឃើញរូប ដែលបានវោហារថា ចក្ខុ ដោយអំណាចនៃហេតុ តែព្រះបោរាណាចារ្យពោលថា ចក្ខុ រមែងមិនឃើញរូប ព្រោះចក្ខុមិនមានចិត្ត ចិត្តរមែងមិនឃើញរូប ព្រោះចិត្តមិនមានចក្ខុ តែក្នុងកាលប៉ះខ្ទប់គ្នាតាមទ្វារម្មណៈ រមែងឃើញបានដោយចិត្ត មានបសាទជាវត្ថុ ។ ម្យ៉ាងទៀត កថាដូច្នេះនេះ ឈ្មោះថា សសម្ភារកថា ( កថាលាយឡំគ្នា ) ដូចក្នុងបទថា ចាក់ដោយ



ធ្នូ ព្រោះដូច្នោះ ក្នុងបទនេះទើបមានអធិប្បាយថា ឃើញរូបដោយចក្ខុវិញ្ញាណ ។ ម្យ៉ាងទៀត ឃើញរូបដោយចក្ខុជាហេតុ ។ បទថា **នេវ សុមនោ ហោតិ** ចិត្តមិនល្អ គឺ បដិសេធសោមនស្ស អាស្រ័យផ្ទះ មិនមែនសោមនស្សវេទនាដែលជាកិរិយា ។ បទថា **ន ទុម្មនោ** ចិត្តមិនល្អ គឺ បដិសេធទោមនស្សទាំងអស់ ។ បទថា **ឧបេក្ខកោ វិហរតិ** ជាអ្នកព្រងើយកន្តើយ គឺ ជាអ្នកព្រងើយកន្តើយ ដោយឧបេក្ខា គឺ ដាក់ខ្លួនជាកណ្តាលក្នុងអារម្មណ៍នោះ ដែលបានឈ្មោះថា ឧបេក្ខាមានអង្គ ៦ ព្រោះប្រព្រឹត្តទៅក្នុងទ្វារ ៦ ដែលជាអាការនៃការមិនលះសេចក្តីបរិសុទ្ធជាប្រក្រតី ក្នុងគន្លងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ សូម្បីក្នុងបទមានជាដើមថា **សោតេន សទ្ទំ សុត្វា** ស្តាប់សម្លេងដោយត្រចៀក ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **កម្មវិបាកជិទ្ធិនិទ្ទេស** ដូចតទៅ ។ បទថា **សព្វេសំ បក្ខីនំ** នៃបក្សីទាំងពួង គឺ ការទៅផ្លូវអាកាសវៀរឈាន និងអភិញ្ញា របស់បក្សីទាំងឡាយគ្រប់ប្រភេទ ការទៅផ្លូវអាកាសរបស់ទេវតាទាំងពួង និងការឃើញជាដើមក៏យ៉ាងនោះ ។ បទថា **ឯកច្ចានំ មនុស្សានំ** នៃមនុស្សពួកខ្លះ គឺ នៃមនុស្សអ្នកកើតក្នុងដើមកប្ប ។ បទថា **ឯកច្ចានំ វិនិបាតិកានំ** នៃវិនិបាតពួកខ្លះ គឺ ឫទ្ធិកើតពីផលកម្ម

មានការទៅផ្លូវអាកាសជាដើម របស់វិនិបាតិកប្រេតពួកដទៃ ព្រោះធ្លាក់ទៅចាកកាយដែលជាសេចក្ដីសុខ មានជាដើមយ៉ាងនេះ គឺ បិយង្ករ-មាតា បុនព្វសុកមាតា ផុស្សមិត្តា ធម្មគុត្តា ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ឥទ្ធិនិទ្ទេស** របស់អ្នកមានបុញ្ញ ដូចតទៅ ។ បទថា **រាជា** ឈ្មោះថា **រាជា** ព្រោះញុំាងអ្នកដទៃឲ្យត្រេកអរដោយធម៌ ឈ្មោះថា **ចក្កវត្តី** ព្រោះញុំាងចក្ករតន៍ឲ្យប្រព្រឹត្តទៅ ។ បទថា **វេហាសំ គច្ឆតិ** ហោះទៅកាន់អាកាស ជាទុតិយាវិកត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ ។ បទថា **ចតុរង្គិនិយា** ដោយចតុរង្គិនីសេនា បានដល់សេនាមានអង្គ ៤ គឺ ដំរី សេះ រថ និងពលថ្មើរជើង ។ បទថា **សេនា** គឺ រួមអង្គទាំង ៤ នោះ ។ បទថា **អន្តមសោ** ដោយទីបំផុត ។ មនុស្សរក្សាសេះ ឈ្មោះថា **អស្សពន្ធា** ។ មនុស្សរក្សាគោ ឈ្មោះថា **គោបុរិសា** ។ បទថា **ឧបាទាយ** សំដៅដល់ គឺ មិនប្រលែង អធិប្បាយថា ការហោះទៅកាន់អាកាសរបស់ជនទាំងនោះ យ៉ាងនេះ ជាឫទ្ធិរបស់អ្នកមានបុណ្យ ។

បទថា **ជោតិយស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** ឫទ្ធិរបស់ជោតិយគហបតីអ្នកមានបុណ្យ គឺ សេដ្ឋីក្នុងក្រុងរាជគ្រឹះ អ្នកសន្សំបុញ្ញាធិការទុកក្នុងព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ ក្នុងកាល



មុន ឈ្មោះថា **ជោតិក** ។ បានឮថា ក្នុងវេលាជោតិកៈនោះកើត សព្វាវុធក្នុងនគរទាំងអស់រុងរោចន៍ សូម្បីគ្រឿងអាភរណ៍ដែលតាក់តែងទុកត្រង់កាយរបស់ជនទាំងពួង ក៏បញ្ចេញពន្លឺរុងរោចន៍ នគរបានមានពន្លឺរុងរោចន៍ជាចំណែកដូចគ្នា លំដាប់នោះ ក្នុងថ្ងៃដែលដាក់ឈ្មោះកុមារនោះ ទើបឈ្មោះថា ជោតិកៈ ព្រោះនគរទាំងអស់រុងរោចន៍ជាចំណែកដូចគ្នា គ្រាជោតិកៈចម្រើនវ័យ កាលជម្រះផែនដីសាងផ្ទះ សក្កទេវរាជ ស្ដេចមកប្រាប់ផែនដីក្នុងប្រមាណ ១៦ ករីសៈ សាងប្រាសាទ ៧ ជាន់សម្រេចដោយកែវ ៧ ប្រការ សាងកំផែង ៧ ជាន់ ប្រកបដោយស៊ុមទ្វារ ៧ សម្រេចដោយកែវ ៧ ប្រការ ក្នុងចុងកំផែង ដាំដើមកប្បព្រឹក្សទុក ៦៤ ដើម ក្នុងមុខទាំង ៤ របស់ប្រាសាទ ជញ្ជាំងកប់ទ្រព្យប្រមាណមួយយោជន៍ ៣ គាវុត ២ គាវុត ១ គាវុត ក្នុងមុខទាំង ៤ របស់ប្រាសាទ ដើមអំពៅសម្រេចដោយមាស ៤ ដើម ប្រមាណប៉ុនដើមត្នោតកើតឡើង ស្លឹករបស់ដើមអំពៅទាំងនោះ សម្រេចដោយកែវមណី ថ្នាំងសម្រេចដោយមាស ត្រង់ស៊ុមទ្វារទាំង ៧ មួយ ៗ មានយក្ស ៧ នាក់ មានបរិវារម្នាក់ ៗ ១.០០០ ២.០០០ ៣.០០០ ៤.០០០ ៥.០០០ ៦.០០០ ៧.០០០ ចាំរក្សា ។

ព្រះបាទពិម្ពិសារមហារាជ ទ្រង់ស្តាប់ដល់ការសាងប្រាសាទជាដើមហើយ ទើបទ្រង់បញ្ជូនស្វេតច័ត្ររបស់សេដ្ឋីទៅឲ្យ ។ សេដ្ឋីនោះទើបឈ្មោះថា **ជោតិកសេដ្ឋី** ជាអ្នកប្រាកដទូទៅជម្ពូទ្វីប សោយមហាសម្បត្តិនៅក្នុងប្រាសាទនោះជាមួយភរិយាដែលទេវតាទាំងឡាយនាំមកអំពីឧត្តរកុរុទ្វីប ហើយឲ្យអង្ករយលំហរក្នុងបន្ទប់ដ៏មានសិរី ដែលកាន់យកអង្ករមួយនាឡិ និងដុំថ្មឲ្យកើតភ្លើង ៣ ដុំមកផង កត្តរមែងត្រឹមតែល្មមដល់គេ ដោយអង្ករមួយនាឡិរហូតជីវិត បានឮថា ប្រសិនបើជនទាំងឡាយប្រាថ្នានឹងផ្ទុកអង្ករក្នុងរទេះ ១០០ រទេះ នាឡិអង្ករនោះឯងក៏នៅតាំងនៅ ក្នុងវេលាដាំបាយ ដាក់អង្ករទៅក្នុងឆ្នាំងបាយហើយ ទុកខាងលើដុំថ្មទាំងនោះ ដុំថ្មក៏នឹងក្តៅជាភ្លើងភ្លាម កាលបាយឆ្អិនក៏រលត់ ដោយសញ្ញានោះ ជនទាំងឡាយក៏ដឹងថា បាយឆ្អិនហើយ ។ ស្ល (សូម្បី) ក្នុងវេលាដែលស្ងោរជាដើម ក៏មានន័យនេះដូចគ្នា ។ អាហាររបស់ជនទាំងនោះ រមែងចម្អិនដោយថ្មឲ្យកើតភ្លើងយ៉ាងនេះ ជនទាំងឡាយរមែងនៅដោយពន្លឺនៃកែវមណី រមែងមិនស្គាល់ពន្លឺនៃភ្លើង ឬរបស់ប្រទីប ។ ជោតិកសេដ្ឋីបានប្រាកដទូទៅក្នុងជម្ពូទ្វីបថា មានសម្បត្តិបែបនេះ មហាជនឡើងយានជាដើម មកដើម្បីនឹងឃើញ ។ ជោតិកសេដ្ឋីឲ្យភត្តាហារនៃអង្ករមកពីឧត្តរកុរុទ្វីបដល់មនុស្សដែលមកហើយ ៗ



ប្រាប់ថា ជនទាំងឡាយចូរកាន់យកសំពត់ និងអាភរណ៍អំពីដើមកប្បព្រឹក្សចុះ ប្រាប់ថា ជនទាំងឡាយចូរបើកមាត់ឆ្នាំងគ្រប់ទ្រព្យមួយគាវុតហើយកាន់យកត្រឹមតែល្មម ។ កាលអ្នកស្រុកជម្ពូទ្វីបទាំងអស់ កាន់យកទ្រព្យទៅ ឆ្នាំងដាក់ទ្រព្យក៏មិនបានស្រកសូម្បីមួយអង្គុលី នេះជាឫទ្ធិ៍របស់លោកអ្នកមានបុណ្យនោះ ។

បទថា **ជដិលស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** ឫទ្ធិ៍របស់ជដិលគហបតីអ្នកមានបុញ្ញ គឺ សេដ្ឋីក្នុងនគរតក្កសិលា សន្សំបុណ្យសាងធាតុចេតិយ៍របស់ព្រះដ៏មានព្រះភាគព្រះនាមថា **កស្សប** ឈ្មោះ **ជដិល** ។ បានឮថា មាតារបស់ជដិលនោះ ជាធិតារបស់សេដ្ឋីក្នុងក្រុងពារាណសី មានរូបស្អាតក្រៃលែងណាស់ ។ កាលធិតាមានអាយុ ១៥ ១៦ ឆ្នាំ មាតាបិតាឲ្យនាងនៅខាងលើប្រាសាទ ៧ ជាន់ ដើម្បីថែរក្សា ។ ថ្ងៃមួយ វិជាធរហោះទៅផ្លូវអាកាស ឃើញនាងបើកបង្អួចក្រឡេកមើលខាងក្រៅកើតសេចក្តីស្រឡាញ់ ទើបចូលទៅផ្លូវបង្អួចធ្វើសន្ថវៈជាមួយនឹងនាង ។ នាងទើបតាំងគភ៌ដោយហេតុនោះ ។

លំដាប់នោះ ទាសីឃើញនាង ទើបសួរថា នេះអ្វីម៉ែម្ចាស់ ។ នាងពោលថា កុំស្តីបន្ទោសឡើយ នាងកុំប្រាប់នរណា ៗ ជាដាច់ខាត ។ ទាសីក៏ស្ងៀមព្រោះខ្លាច ។ គ្រប់ ១០ ខែ នាងក៏ប្រសូតបុត្ត ឲ្យទាសី

នាំភាជនៈថ្មីមក ឲ្យទារកដេកលើភាជនៈនោះ ហើយបិទភាជនៈនោះ ដាក់ផួងផ្កាឈើទុកខាងលើបញ្ជាទាសីថា នាងចូរយកភាជនៈនេះទូលដោយសីសៈទៅចោលត្រង់ទន្លេគង្គា កាលមានមនុស្សសួរថា នេះអ្វី នាងគប្បីប្រាប់ថា ជាពលីកម្មរបស់ម៉ែម្ចាស់របស់ខ្ញុំ ។ ទាសីបានធ្វើតាមនោះ ។ ត្រង់ទន្លេគង្គាខាងក្រោម មានស្រីពីរនាក់ងូតទឹកឃើញភាជនៈនោះអណ្តែតទឹកមក ម្នាក់និយាយថា នោះភាជនៈរបស់ខ្ញុំ ម្នាក់ពោលថា វត្ថុដែលនៅខាងក្នុងភាជនៈនោះជារបស់ខ្ញុំ កាលភាជនៈអណ្តែតមកដល់ ស្រីម្នាក់បីភាជនៈនោះមកដាក់ទុកលើគោក គ្រាបើកចេញឃើញទារក ទើបពោលថា ទារកត្រូវជារបស់ខ្ញុំ ព្រោះខ្ញុំនិយាយថា ភាជនៈជារបស់ខ្ញុំ ។ ស្រីម្នាក់និយាយថា ទារកជារបស់ខ្ញុំ ព្រោះខ្ញុំនិយាយថា វត្ថុដែលនៅខាងក្នុងភាជនៈនោះជារបស់ខ្ញុំ ។ ស្រីទាំងពីរនាក់ប្រកែកគ្នា នាំគ្នាទៅសាលា កាលអ្នកពិភាក្សាមិនអាចកាត់ក្តីបាន បាននាំគ្នាទៅគាល់ព្រះរាជា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ស្រីទាំងពីរនោះហើយ ត្រាស់បង្គាប់ថា នាងចូរទទួលទារកទៅ នាងចូរទទួលភាជនៈទៅ ស្រីដែលបានទារកទៅជាឧបដ្ឋាករបស់ព្រះមហាកច្ចាយនត្ថេរ ។ នាងចិញ្ចឹមទារកនោះ ដោយសង្ឃឹមថា នឹងឲ្យបួសក្នុងសម្នាក់របស់ព្រះថេរៈ ។



ក្នុងថ្ងៃដែលទារកនោះប្រសូត ព្រោះមិនបានលាងមន្ទិលនៃគភ៌ ហើយនាំចេញទៅ សក់ទើបស៊ើងកន្ទ្រើង ដោយហេតុនោះ ទើបមានឈ្មោះថា **ជដិល** ។ កាលទារកនោះដើរបាន ព្រះថេរៈចូលទៅបិណ្ឌបាតកាន់ផ្ទះនោះ ។ ឧបាសិកានិមន្តព្រះថេរៈឲ្យគង់ ហើយថ្វាយអាហារ ។ ព្រះថេរៈឃើញទារក ទើបសួរថា ឧបាសិកា ប្អូនស្រីបានទារកមកឬ នាងឆ្លើយថា ករុណាលោកម្ចាស់ ខ្ញុំចិញ្ចឹមមកដោយសង្ឃឹមថា នឹងឲ្យបួសក្នុងសំណាក់លោកម្ចាស់ ។

ព្រះថេរៈទទួលថា ល្អហើយ ៗ ក៏នាំទារកនោះទៅពិចារណាមើលថា ទារកនេះមានបុញ្ញកម្មដើម្បីសោយសម្បត្តិរបស់គ្រហស្ថ ទេហ្ន៎ គិតថា សត្វនេះមានបុណ្យ នឹងបានសោយមហាសម្បត្តិពេលជាកំលោះសិន សូម្បីញាណរបស់គេក៏នៅមិនទាន់ចាស់ក្លាល្មម ទើបនាំទារកនោះទៅផ្ទះរបស់ឧបដ្ឋាកម្នាក់ក្នុងក្រុងតក្កសិលា ។

ឧបដ្ឋាកនោះឈរសំពះព្រះថេរៈ ឃើញទារកទើបសួរថា បានទារកមកពីណា ព្រះថេរៈឆ្លើយថា ត្រូវហើយឧបាសក ទារកនេះនឹងបួស តែនៅកំលោះសូមឲ្យនៅជាមួយនឹងលោកសិន ឧបាសកទទួលថា ល្អហើយលោកម្ចាស់ ទើបតាំងទារកនោះទុកក្នុងឋានៈជាបុត្ត ផ្គត់ផ្គង់យ៉ាងល្អ ម្យ៉ាងទៀត ក្នុងផ្ទះរបស់ឧបដ្ឋាកនោះ មានទំនិញសន្សំមក

រហូត ១២ ឆ្នាំ ឧបដ្ឋាកនោះ ទៅក្នុងរវាងស្រុកនាំទំនិញទាំងអស់នោះទៅផ្សារ ប្រាប់តម្លៃរបស់ទំនិញនោះដល់ជដិលកុមា ហើយពោលថា អ្នកគប្បីទទួលទ្រព្យប៉ុណ្ណេះ ៗ ហើយឲ្យទៅក្នុងថ្ងៃនោះ ទេវតាអ្នករក្សានគរ បណ្ដាលឲ្យអ្នកមានសេចក្ដីត្រូវការដោយទីបំផុត សូម្បីជី និងម្ទេស មានមុខឆ្ពោះទៅរបស់ជដិលកុមារនោះ ជដិលកុមារនោះលក់ទំនិញដែលសន្សំមករហូត ១២ ឆ្នាំ អស់ក្នុងថ្ងៃមួយប៉ុណ្ណោះ កុដុម្ពីមកមិនឃើញអ្វី ៗ ក្នុងផ្សារ ទើបនិយាយថា កូនសម្លាញ់ អ្នកធ្វើទំនិញវិនាសទៅអស់ហើយឬ ជដិលកុមារប្រាប់ថា មិនបាត់ទេបិតា ខ្ញុំលក់អស់តាម ដែលបិតាប្រាប់ទុកថា របស់នោះតម្លៃប៉ុណ្ណេះ របស់នេះតម្លៃប៉ុណ្ណេះ ព្រោះហេតុនោះ ទំនិញទាំងអស់ទើបបានតាមតម្លៃ កុដុម្ពីរីករាយគិតថា បុរសដែលរកតម្លៃបានមិនអាចទ្រទ្រង់ជីវិតនៅបាន មិនថាក្នុងកាលណា ៗ ទើបលើកកូនរបស់ខ្លួនដែលចម្រើនវ័យហើយឲ្យដល់គេហើយ បញ្ជារមនុស្សធ្វើការងារថា ចូរសាងផ្ទះជដិលកុមារ កាលសាងផ្ទះស្រេចហើយ ទើបពោលថា អ្នកទាំងពីរចូរទៅនៅក្នុងផ្ទះរបស់ខ្លួនចុះ ក្នុងខណៈដែលគេចូលផ្ទះល្មមជើងមួយម្ខាងជិតទ្វារ ភ្នំមាសប្រមាណ ៨០ ហត្ថ ផុសឡើងក្នុងផ្ទៃ ត្រង់ចំណែកខាងក្រោយបំផុតរបស់ផ្ទះ ន័យថា ព្រះរាជាទ្រង់ស្ដាប់ថា



ភ្នំមាសផុសឡើង ទម្លាយផ្ទៃដីក្នុងផ្ទះរបស់ជដិល ទើបទ្រង់បញ្ជូនស្វេតឆត្រទៅឲ្យជដិលនោះ ជដិលនោះ ទើបបានឈ្មោះថា ជដិល-សេដ្ឋី នេះជាឫទ្ធិ៍របស់អ្នកមានបុណ្យនោះ ។

បទថា **មេណ្ឌកស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** ឫទ្ធិ៍របស់មេណ្ឌកគហបតីអ្នកមានបុណ្យ គឺសេដ្ឋីក្នុងភទ្ទិយនគរដែនមគធៈ បានសន្សំបុញ្ញាធិការក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ព្រះនាមថា **វិបស្សី** ឈ្មោះមេណ្ឌកៈ បានឮថា ត្រង់ខាងក្រោយផ្ទះរបស់សេដ្ឋីនោះ មានពពែមាសប្រមាណប៉ុនដំរី សេះ និងគោឧសភៈក្នុងប្រមាណ ៨ ករីសៈ ទម្លាយផែនដីផុសឡើងខាងក្រោយផ្ទះ កាលជនដកឆ្នុកស្បែក របស់អំបោះ ៥ ពណ៌ ដាក់ទុកក្នុងមាត់ពពែមាសទាំងនោះ ជនទាំងឡាយកាលមានសេចក្ដីត្រូវការដោយទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើមក្ដី ដោយគ្រឿងបិទបាំងប្រាក់ និងមាសជាដើមក្ដី ទាញឆ្នុកស្បែកចេញពីមាត់របស់ពពែមាសទាំងនោះ ទឹកដោះថ្លា ប្រេង ទឹកឃ្មុំ គ្រឿងស្លៀកដណ្ដប់ ប្រាក់ និងមាស ល្មមដល់ជនជម្ពូទ្វីបទាំងអស់ចេញពីមាត់របស់ពពែសូម្បីមួយក្បាល បន្ទាប់ពីនោះមក សេដ្ឋីនោះក៏ប្រាកដឈ្មោះថា **មេណ្ឌកសេដ្ឋី** នេះជាឫទ្ធិ៍របស់អ្នកមានបុណ្យនោះ ។

បទថា **ឃោសិតស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** ឫទ្ធិ៍របស់

ឃោសិតគហបតីអ្នកមានបុណ្យ គឺ សេដ្ឋីក្នុងក្រុងកោសម្ពី ដែនសក្កៈ សន្សំបុញ្ញាធិការក្នុងព្រះបច្ចេកពុទ្ធជាម្ចាស់ ឈ្មោះថា **ឃោសិត** បានឮថា សេដ្ឋីនោះ ចុតិចាកទេវលោក កើតក្នុងផ្ទៃរបស់ស្រីសោភិនីក្រុងកោសម្ពី ក្នុងកាលប្រសូត ស្រីសោភនីក្រុងនោះ ឲ្យទារកដេកលើចង្អេរ ហើយឲ្យយកទៅចោលត្រង់គំនរសំរាម ក្អែក និងសុនខទាំងឡាយចោមរោមទារកនោះ បុរសម្នាក់ឃើញដូច្នោះ ទើបបានសម្គាល់ថាជាបុត្ត គិតថា យើងបានបុត្តហើយ ទើបនាំទៅផ្ទះ ក្នុងកាលនោះ កោសម្ពីសេដ្ឋី ឃើញបុរោហិតទើបសួរថា លោកអាចារ្យថ្ងៃនេះលោកត្រួតមើលផ្កាយតិថីហើយឬ កាលបុរោហិតឆ្លើយថា មើលហើយលោកមហាសេដ្ឋី ទើបសួរថា នឹងមានអ្វីដល់ជនបទ បុរោហិតឆ្លើយថា ក្នុងនគរនេះក្មេងកើតថ្ងៃនេះ នឹងបានជាសេដ្ឋីធំ ក្នុងកាលនោះ ភរិយារបស់សេដ្ឋីមានគភ៌ចាស់ ព្រោះដូច្នោះ សេដ្ឋីនោះទើបប្រញាប់បញ្ជារមនុស្សទៅផ្ទះថា អ្នកចូរទៅ ចូរដឹងថា ភរិយារបស់យើងប្រសូតបុត្តឬនៅ ឬមិនទាន់ប្រសូត គ្រាស្តាប់ថា នៅមិនទាន់ប្រសូត ទើបទៅផ្ទះហៅនាងកាឡីទាសីមក ឲ្យទ្រព្យ ១.០០០ បញ្ជារថា នាងចូរទៅ ចូរស៊ើបមើល ក្នុងនគរនេះ ហើយនាំទារកដែលកើតក្នុងថ្ងៃនេះមក ទាសីទៅស៊ើបមើល ក៏ទៅដល់ផ្ទះនោះ ឃើញទារកដឹងថា



កើតក្នុងថ្ងៃនោះ ទើបឲ្យទ្រព្យ ១.០០០ នាំទារកមកឲ្យដល់សេដ្ឋី សេដ្ឋីគិតថា បើកូនស្រីរបស់យើងនឹងកើត យើងនឹងរៀបការទារកនោះឲ្យជាមួយនឹងកូនស្រី ហើយឲ្យនៅក្នុងតំណែងជាសេដ្ឋី បើជាកូនប្រុស យើងនឹងសម្លាប់ទារកនោះ ហើយចិញ្ចឹមទារកជាកូននោះឲ្យធំធាត់ក្នុងផ្ទះនោះ ។

លំដាប់នោះកន្លងទៅ ២-៣ ថ្ងៃ ភរិយារបស់សេដ្ឋីប្រសូតបុត្តប្រុស សេដ្ឋីគិតថា កាលមិនមានទារកនេះ បុត្តរបស់យើងនឹងបានតំណែងសេដ្ឋី ឥឡូវនេះយើងគួរនឹងសម្លាប់ទារកនោះ ហើយហៅនាងកាឡីទាសីមកបញ្ជារថា នែ៎នាងមេដោះ ក្នុងវេលាគោចេញពីក្រោលនាងចូរឲ្យទារកនេះដេកទទឹងពាក់កណ្តាលទ្វារក្រោល មេគោទាំងឡាយនឹងជាន់ទារកនោះឲ្យស្លាប់ នាងដឹងថាទារកនោះត្រូវមេគោជាន់ ឬមិនជាន់ហើយចូរត្រឡប់មក នាងកាឡីទាសីទៅជួបអ្នកចិញ្ចឹមគោ បើកទ្វារក្រោល ហើយឲ្យទារកនោះដេកដូចយ៉ាងនោះ គោឧសភៈប្រធានហ្វូង គ្រាមុន ៗ ចេញក្រោយគោទាំងអស់ តែថ្ងៃនោះបានចេញមុនគោទាំងអស់ ឈរបាំងទារកទុកក្នុងចន្លោះជើងទាំង ៤ មេគោទាំងឡាយ ច្រើនរយចេញសង្ខាងនៃគោឧសភៈនោះ សូម្បីអ្នកចិញ្ចឹមគោក៏គិតថា គោឧសភៈនេះ កាលមុនចេញក្រោយគោទាំងអស់ តែថ្ងៃ

នេះចេញមុន មកឈរស្ទៀមត្រង់កណ្តាលទ្វារ ដោយហេតុអ្វីហ្ន៎ ទើបដើរទៅឃើញទារកដេកនៅខាងក្រោមគោឧសភៈនោះ ក៏កើតសេចក្តីស្រឡាញ់ក្នុងបុត្ត គិតថា យើងបានបុត្តហើយ ទើបនាំទៅផ្ទះ នាងកាឡីទាសីត្រឡប់ទៅសេដ្ឋីសួរ ទើបប្រាប់សេចក្តីទាំងអស់ សេដ្ឋីប្រាប់ថា នាងចូរទៅឲ្យទ្រព្យ ១.០០០ នេះ ដល់អ្នកចិញ្ចឹមគោ ហើយនាំទារកនោះមកទៀត ។

គ្រានោះសេដ្ឋី ទើបប្រាប់នាងកាឡីទាសីថា ក្នុងក្រុងនេះមានរទេះ ៥០០ ចេញក្នុងពេលព្រលឹមស្រាង ៗ ទៅធ្វើការទិញលក់ នាងចូរនាំទារកនេះឲ្យដេកត្រង់ផ្លូវកង់ ឬគោទាំងឡាយនឹងជាន់ទារកនោះ ឬកង់នឹងជាន់លើ នាងដឹងការប្រព្រឹត្តទៅហើយត្រឡប់មក នាងទាសីទៅឲ្យទារកដេកត្រង់ផ្លូវកង់ ប្រធានមនុស្សបររទេះបានចេញទៅខាងមុខ ។

លំដាប់នោះ គោរបស់ប្រធានមនុស្សបររទេះដល់កន្លែងនោះស្រាប់តែឈប់ឯង សូម្បីអ្នកបររទេះដេញគោឲ្យទៅរឿយ ៗ គោក៏មិនព្រមទៅខាងមុខ កាលអ្នកបររទេះនោះព្យាយាមដេញគោទាំងនោះយ៉ាងនេះ អរុណរះឡើងហើយ អ្នកបររទេះគិតថា គោធ្វើអ្វី កាលឃើញទារកទើបគិតថា កម្មធ្ងន់ណាស់ហ្ន៎ ល្អហើយយើងបានបុត្ត ទើបនាំ



ទារកនោះទៅផ្ទះ សូម្បីនាងទាសីកាឡីក៏ត្រឡប់មក ត្រូវសេដ្ឋីសួររឿងឲ្យស្តាប់ សេដ្ឋីពោលថា នាងចូរទៅឲ្យទ្រព្យ ១.០០០ ហើយនាំទារកនោះមក នាងកាឡីក៏បានធ្វើតាមនោះ ។

លំដាប់នោះ សេដ្ឋីពោលចំពោះនាងទាសីកាឡីនោះថា ឥឡូវនេះ នាងចូរនាំទារកនោះទៅព្រៃចោលខ្មោច ហើយឲ្យដេករវាងគល់ឈើ សុនខជាដើមក្នុងទីនោះ នឹងទំពារស៊ី ឬអមនុស្សនឹងប្រហារ នាងគប្បីដឹងថា ទារកនោះស្លាប់ ឬមិនស្លាប់ នាងកាឡីនោះនាំទារកនោះទៅឲ្យដេកក្នុងទីនោះ ហើយឈរនៅកន្លែងមួយ សុនខជាដើម ឬអមនុស្ស មិនអាចនឹងចូលទៅជិតបាន លំដាប់នោះអ្នកចិញ្ចឹមពពែម្នាក់ នាំពពែទៅរកអាហារខាងព្រៃខ្មោច ។

មេពពែមួយ ស៊ីស្លឹកឈើចូលទៅរវាងគល់ឈើ ឃើញទារកហើយឈរលត់ជង្គង់ឲ្យដោះទារក កាលមនុស្សចិញ្ចឹមពពែដេញថា ហេ ហេ ! ក៏មិនចេញទៅ អ្នកចិញ្ចឹមពពែគិតថា យើងនឹងវាយពពែនោះនាំចេញទៅ ទើបចូលទៅក្នុងរវាងគល់ឈើ ឃើញពពែឈរលត់ជង្គង់ឲ្យទារកផឹកទឹកដោះ បានកើតសេចក្តីស្រឡាញ់ក្នុងទារកថា ជាបុត្ត គិតថាយើងបានបុត្តហើយ ទើបនាំត្រឡប់ទៅ នាងកាឡីត្រឡប់ទៅត្រូវសេដ្ឋីសួរ ទើបប្រាប់រឿងឲ្យស្តាប់ សេដ្ឋីពោលថា នាងចូរទៅ

ចូរឲ្យទ្រព្យអ្នកចិញ្ចឹមពពែ ១.០០០ ហើយនាំទារកមកទៀត នាងកាឡីបានធ្វើតាមនោះ ។

លំដាប់នោះ សេដ្ឋីទើបនិយាយនឹងនាងកាឡីថា នាងចូរនាំទារកនេះឡើងទៅលើភ្នំជ្រោះចោរ ហើយបោះចុះក្នុងជ្រោះ ទារកក៏នឹងត្រូវទង្គិចយ៉ាងខ្លាំងត្រង់ជើងភ្នំជាចំណិតល្អិត ចំណិតតូចនឹងធ្លាក់ចុះលើផែនដី នាងគប្បីដឹងថា ទារកនោះស្លាប់ ឬមិនស្លាប់ ហើយត្រឡប់មក នាងកាឡីនាំទារកនោះទៅតាមនោះ ឈរនៅលើកំពូលភ្នំ ហើយបោះទារកចុះទៅ គុម្ពឫស្សីធំអាស្រ័យជើងភ្នំនោះ លូតលាស់ទៅតាមភ្នំ គុម្ពដុះក្រាស់ព័ទ្ធជុំវិញកំពូលឫស្សីនោះ ទារកកាលធ្លាក់ចុះទៅ ក៏បានធ្លាក់លើគុម្ពក្រាស់នោះ ដូចធ្លាក់ក្នុងអង្រឹងកូនក្មេងដូច្នោះ ក្នុងថ្ងៃនោះ មេជាងតម្បាញដល់វេលានឹងកាត់ឫស្សី ទើបទៅជាមួយបុត្តចាប់ផ្តើមកាត់គុម្ពឫស្សីនោះ កាលគុម្ពឫស្សីញ័រ ទារកបានយំ គេបានឮដូចសម្លេងទារក ទើបឡើងទៅម្ខាងទៀត ឃើញទារកនោះ ត្រេកអរថា យើងបានបុត្តហើយ ទើបនាំទារកត្រឡប់មក នាងកាឡីត្រឡប់ទៅវិញត្រូវសេដ្ឋីសួរ ទើបនិយាយរឿងឲ្យស្តាប់ សេដ្ឋីប្រាប់ថា នាងចូរទៅឲ្យទ្រព្យ ១.០០០ ហើយចូរនាំទារកនោះមក នាងកាឡីបានធ្វើតាមនោះ ។



កាលសេដ្ឋីធ្វើហើយទទេ ៗ យ៉ាងនេះ ទារកក៏ធំឡើង ព្រោះទារកនោះយំច្រើន ទើបមានឈ្មោះថា **ឃោសិត** ឃោសិត នោះប្រាកដដល់សេដ្ឋីដូចនាមដែលផ្សាល់ភ្នែក មិនអាចមើលត្រង់ ៗ បាន សេដ្ឋីទើបគិតរកឧបាយនឹងសម្លាប់ឃោសិតនោះ ទើបទៅរកជាងស្មូនឆ្នាំងរបស់ខ្លួន សួរថា កាលណាលោកនឹងដុតរណ្តៅ កាលជាងស្មូនឆ្នាំង ប្រាប់ថ្ងៃស្អែក សេដ្ឋីទើបនិយាយថា បើដូច្នោះលោកចូរទទួលទ្រព្យ ១.០០០ នេះទុក ហើយធ្វើធុរៈម្យ៉ាងដល់យើង ជាងស្មូនឆ្នាំងសួរថា ធ្វើអ្វីលោកម្ចាស់ សេដ្ឋីប្រាប់ថា យើងមានបុត្តជាអវជាតបុត្តម្នាក់ យើងនឹងបញ្ជូនមករកលោក បន្ទាប់ពីនោះលោកគប្បីឲ្យបុត្តនោះចូលទៅកាន់បន្ទប់ យកកាំបិតដែលមុតកាត់ឲ្យជាចំណិតល្អិត ចំណិតតូចដាក់ចុះក្នុងឡ ហើយកប់ក្នុងរណ្តៅ នេះទ្រព្យ ១.០០០ របស់លោកជាការទទួលពាក្យ ម្យ៉ាងទៀត ដែលក្រៃលែងជាងនោះ យើងនឹងសងគុណលោកក្នុងខាងក្រោយ ជាងស្មូនឆ្នាំងក៏ទទួលពាក្យសេដ្ឋី ។

ព្រឹកស្អែក សេដ្ឋីហៅឃោសិតៈមកប្រាប់ថា កាលម្សិលមិញពុកបានប្រាប់ជាងស្មូនឆ្នាំងឲ្យធ្វើធុរៈម្យ៉ាង មកចុះកូនទៅរកជាងស្មូនឆ្នាំងនោះ ហើយប្រាប់ថា កាលម្សិលមិញនេះពុកប្រាប់ឲ្យលោកធ្វើធុរៈម្យ៉ាងឲ្យស្រេចដូច្នេះ ហើយបញ្ជូនទៅ ឃោសិតៈទទួលពាក្យ

ហើយក៏ទៅ  ឯបុត្តរបស់សេដ្ឋីកំពុងលេងកូនឃ្លីជាមួយនឹងពួកទារក ឃើញឃោសិតៈកំពុងដើរមកដល់ទីនោះ  ទើបស្រែកហៅ  សួរថា នឹងទៅណា កាលឃោសិត្តប្រាប់ថា ពុកបញ្ជារឲ្យទៅរកជាងស្មូនឆ្នាំង បុត្តសេដ្ឋីប្រាប់ថា ខ្ញុំទៅទីនោះខ្លួនឯង ទារកទាំងនេះឈ្នះយើងច្រើនណាស់ បងលេងឈ្នះឲ្យច្រើន ហើយចូរឲ្យដល់ខ្ញុំ ។ ឃោសិតៈប្រាប់ថា ខ្ញុំខ្លាចពុក កូនសេដ្ឋីប្រាប់ថា កុំខ្លាចឡើយបង ខ្ញុំនឹងនាំដំណឹងនោះទៅខ្លួនឯង  ហើយប្រាប់តទៅទៀតថា  ពួកទារកជាច្រើនឈ្នះខ្ញុំហើយ បងចូរឈ្នះវិញឲ្យខ្ញុំ ខ្ញុំនឹងត្រឡប់មក ។ បានឮថា ឃោសិតៈឈ្លាសក្នុងការលេងកូនឃ្លី  ។  ដោយហេតុនោះ  បុត្តសេដ្ឋីទើបកាន់យកនូវហេតុនោះ ។ ឃោសិតៈប្រាប់ថា បើដូច្នោះ ប្អូនចូរទៅប្រាប់ដល់ស្មូនឆ្នាំងថា  កាលពីម្សិលមិញនេះ  ពុកខ្ញុំបញ្ជារឲ្យលោកធ្វើធុរៈម្យ៉ាង  សូមឲ្យលោកធ្វើធុរៈនោះឲ្យស្រេចចុះ  ហើយពញ្ជូនបុត្តសេដ្ឋីនោះទៅ ។ បុត្តសេដ្ឋីនោះទៅរក ជាងស្មូនឆ្នាំងហើយបានប្រាប់តាមពាក្យនោះ ។

គ្រានោះ ជាងស្មូនឆ្នាំង ក៏ចាប់បុត្តសេដ្ឋីនោះតាមដែលសេដ្ឋីបញ្ជារ  ហើយបោះចោលទៅក្នុងរណ្តៅ  ។  ឃោសិតៈលេងរហូតថ្ងៃពេលល្ងាចទើបត្រឡប់ទៅផ្ទះ កាលសេដ្ឋីសួរថា មិនបានទៅទេឬកូន



គេទើបប្រាប់ហេតុដែលខ្លួនមិនបានទៅ និងហេតុដែលប្អូនទៅជំនួស ។ សេដ្ឋីស្រែកយំយ៉ាងខ្លាំងថា ស្លាប់ហើយ ស្លាប់ហើយ បណ្តាលឲ្យលោហិតក្តៅពេញទាំងខ្លួន ផ្គងដៃយំសោកថា ជាងស្មូនឆ្នាំងកុំសម្លាប់កូនខ្ញុំ ៗ ក៏បានទៅរកជាងស្មូនឆ្នាំង ជាងស្មូនឆ្នាំងឃើញសេដ្ឋីមកយ៉ាងនោះ ទើបពោលថា កុំព្រួយអ្វីឡើយលោកម្ចាស់ ធុរៈកិច្ចស្រេចហើយ ។ សេដ្ឋីត្រូវសោកធំ វង្វេងដូចភ្នំសង្កត់ សោយទោមនស្សយ៉ាងខ្លាំងក្លា ។

សូម្បីយ៉ាងនោះ សេដ្ឋីក៏មិនអាចមើលឃោសិតៈត្រង់ ៗ បានគិតថា យើងនឹងសម្លាប់ឃោសិតៈនោះបានដូចម្តេច ឃើញឧបាយថា យើងនឹងបញ្ជូនទៅរកអ្នកចាត់ចែងទ្រព្យខ្ញុំក្នុង ១០០ ភូមិ របស់យើង ហើយឲ្យសម្លាប់ ទើបសរសេរសំបុត្របញ្ជូនឲ្យអ្នកចាត់ចែងទ្រព្យ មានសេចក្តីថា បុត្តម្នាក់នេះ ជាអវជាតបុត្តរបស់យើង សូមឲ្យសម្លាប់ហើយច្រានចុះក្នុងរណ្តៅលាមក ក៏កាលធ្វើយ៉ាងនេះហើយ យើងនឹងសងគុណដល់អ៊ុំ ហើយពោលនឹងឃោសិតៈថា ឃោសិតៈ បិតាមានអ្នកចាត់ចែងទ្រព្យក្នុង ១០០ ភូមិ អ្នកចូរនាំសំបុត្រនេះ ទៅឲ្យគេហើយចងសំបុត្រត្រង់ជាយសំពត់របស់ឃោសិតៈ ឃោសិតៈមិនដឹងអក្ខរៈសម័យ ព្រោះតាំងពីនៅក្មេង សេដ្ឋីបំណងនឹងសម្លាប់គេម្តង

ហើយម្តងទៀត ក៏មិនអាចសម្លាប់បាន នឹងឲ្យរៀនអក្ខរៈសម័យបានដូចម្តេច យោសិតៈទើបចងស្លឹកមរណៈរបស់ខ្លួនទុកត្រង់ជាយសំពត់ កាលនឹងចេញទៅពោលថា បិតាខ្ញុំមិនមានស្បៀងឡើយ សេដ្ឋីពោលថា មិនចាំបាច់ត្រូវការស្បៀងទេ កូនសេដ្ឋីសម្លាញ់របស់បិតាមាននៅស្រុកឯនោះ ក្នុងរវាងផ្លូវ អ្នកចូរបរិភោគអាហារព្រឹកត្រង់ផ្ទះរបស់មិត្តនោះ ហើយដើរទៅ ។

យោសិតៈទទួលពាក្យហើយសំពះបិតា ចេញទៅដល់ស្រុកនោះ សួររកផ្ទះសេដ្ឋី ទៅឃើញករិយាសេដ្ឋី ។ កាលករិយាសេដ្ឋីសួរថា អ្នកមកពីណា គេប្រាប់ថាមកពីខាងនគរ ករិយាសេដ្ឋីសួរថា អ្នកជាបុត្តនរណា ឆ្លើយថា ជាបុត្តសេដ្ឋីដែលជាសម្លាញ់របស់លោកបាទ ។ សួរថា អ្នកឈ្មោះយោសិតៈមែនទេ ឆ្លើយថា មែន ។ លុះឃើញប៉ុណ្ណោះ ករិយាសេដ្ឋីក៏កើតសេចក្តីស្រឡាញ់ក្នុងយោសិតៈ ជាបុត្តសេដ្ឋី មានកូនក្រមុំម្នាក់ អាយុ ១៥-១៦ ឆ្នាំ រូបរាងស្អាតគួរជាទីស្រឡាញ់ ។ មាតាបិតាឲ្យទាសីទទួលមនុស្សម្នាក់ ដើម្បីមើលថែនាងឲ្យដេកក្នុងបន្ទប់សិរីជាន់លើនៃប្រាសាទ ៧ ជាន់ ។ ក្នុងខណៈនោះ កូនក្រមុំសេដ្ឋីបញ្ជូនទាសីនោះទៅផ្សារ ។

លំដាប់នោះ ករិយាសេដ្ឋីឃើញទាសីនោះ សួរថា នាងនឹងទៅ



ណា កាលទាសីឆ្លើយថា ធិតារបស់ម៉ែម្ចាស់ឲ្យទៅផ្សារចា៎ ទើបពោលថា ចូរមកនេះសិន វៀរការទៅផ្សារទុកសិន នាងចូរក្រាលតាំងឲ្យបុត្តរបស់យើង រកទឹកមកលាងជើង លាបប្រេង ក្រាលទីដេកឲ្យខាងក្រោយ ទើបទៅផ្សារ ទាសីបានធ្វើតាមនោះ កូនក្រមុំសេដ្ឋីឃើញទាសីមកយឺត ទាសីទើបប្រាប់ដល់ធិតាថា កុំក្រោធនឹងខ្ញុំឡើយ យោសិតៈបុត្តសេដ្ឋីមក ខ្ញុំធ្វើនោះខ្លះ នេះខ្លះ ឲ្យដល់យោសិតៈនោះ ទើបបានទៅផ្សារ ស្រេចហើយទើបត្រឡប់មកនេះឯង ចា៎ ។ កូនក្រមុំសេដ្ឋី លុះបានស្តាប់ឈ្មោះថា យោសិតៈបុត្តសេដ្ឋីប៉ុណ្ណោះ សេចក្តីស្រឡាញ់ដោយអំណាចបុព្វេសន្និវាសកាត់ស្បែកជាដើម រហូតខួរឆ្អឹងតាំងនៅ ។ នាងទើបសួរទាសីនោះថា គេដេកត្រង់ណា ឆ្លើយថា ដេកលក់លើទីដេកចា៎ ។ សួរថា មានអ្វីត្រង់ដៃរបស់គេខ្លះ ។ ឆ្លើយថា មានសំបុត្រត្រង់ជាយសំពត់ចា៎ នាងគិតថា នោះជាសំបុត្រអ្វីហ្ន៎ កាលយោសិតៈកំពុងដេកលក់ កាលមាតាបិតាមិនឃើញ ព្រោះបញ្ជូនចិត្តទៅទីដទៃ ទើបទៅរកយោសិតៈនោះ ស្រាយសំបុត្រចេញ កាន់ទៅបន្ទប់របស់ខ្លួនបិទទ្វារ បើកបង្អួច ព្រោះនាងឆ្លាតក្នុងអក្ខរៈសម័យ ទើបអានសំបុត្រនោះ គិតថា ឱនាយល្ងង់ណាស់ ចងស្លឹកមរណៈរបស់ខ្លួនទុកត្រង់ជាយសំពត់ដើរទៅ ប្រសិនយើងមិនឃើញ គេនឹង

មិនមានជីវិត ទើបហែកសំបុត្រនោះ ហើយសរសេរសំបុត្រដទៃជំនួស ដោយពាក្យរបស់សេដ្ឋីថា បុត្តរបស់យើងឈ្មោះឃោសិតៈឲ្យនាំបណ្ណាការភូមិទាំង ១០០ មកធ្វើការមង្គលផ្សំជាមួយនឹងធិតារបស់សេដ្ឋីជនបទនេះ ឲ្យធ្វើផ្ទះ ២ ជាន់ ពាក់កណ្តាលស្រុកជាទីនៅរបស់ខ្លួនហើយ ចាត់ចែងការរក្សាឲ្យល្អ ដោយការលោមព័ទ្ធកំផែង និងតាំងអ្នកយាមការពារ កាលធ្វើគ្រប់យ៉ាងរៀបរយហើយ ចូរបញ្ជូនដំណឹងឲ្យយើងជ្រាបផង កាលធ្វើយ៉ាងនេះស្រេចហើយ យើងនឹងសងគុណដល់លោកគ្រាសរសេរស្រេច ទើបមូរសំបុត្រចងទុកត្រង់ជាយសំពត់របស់គេ ។

យោសិតៈដេកលក់រហូតថ្ងៃ ក្រោកឡើងបរិភោគអាហារ ហើយក៏បន្តដំណើរទៅរហូតដល់ស្រុកនោះពីព្រឹក ឃើញអ្នកចាត់ចែងទ្រព្យខ្លី កំពុងធ្វើការងារក្នុងភូមិ ។ អ្នកចាត់ការទ្រព្យខ្លី ឃើញឃោសិតៈទើបសួរថា អ្វីលោក ឃោសិតៈឆ្លើយថា បិតារបស់ខ្ញុំបញ្ជូនសំបុត្រមកឲ្យលោក គេទទួលសំបុត្រទៅអានសប្បាយចិត្ត បញ្ជូនជាងធ្វើផ្ទះមើលចុះម្ចាស់របស់យើគេស្រឡាញ់យើង បញ្ជូនបុត្តមករកយើង សូមឲ្យធ្វើមង្គលដល់បុត្តរបស់គេនឹងកូនក្រមុំរបស់យើង ពួកលោកប្រញាប់ទៅរកឈើជាដើមមកចុះ ហើយឲ្យធ្វើផ្ទះតាមដែលពោលហើយ ក្នុងពាក់កណ្តាលភូមិ ឲ្យនាំគ្រឿងបណ្ណាការមកពី ១០០ ភូមិ ហើយនាំ



ធិតារបស់សេដ្ឋីជនបទមកធ្វើពិធីមង្គលស្រេចហើយ បញ្ជូនដំណឹងទៅឲ្យសេដ្ឋីជ្រាបថា បានធ្វើគ្រប់យ៉ាងស្រេចហើយ ។

សេដ្ឋីបានស្តាប់ពាក្យនោះ ក៏កើតការខូចចិត្តធំ វង្វេងថា ធុរៈដែលយើងឲ្យធ្វើមិនសម្រេច ធុរៈដែលយើងមិនឲ្យធ្វើសម្រេច ព្រមជាមួយការសោកដល់បុត្ត សេចក្តីសោកនោះ កាន់តែរុកគួនចូលមកបន្ថែមទៀត ទើបកើតការក្តៅពោះដល់ពោះស្រួយ សូម្បីកូនក្រមុំសេដ្ឋីក៏បញ្ជារថា ប្រសិនបើមាននរណាពីសំណាក់របស់សេដ្ឋី ចូរប្រាប់យើង កុំប្រាប់ដល់បុត្តរបស់សេដ្ឋីមុន ។ សូម្បីសេដ្ឋីក៏គិតថាឥឡូវនេះ យើងនឹងមិនឲ្យបុត្តអាក្រក់ជាម្ចាស់របស់សម្បត្តិរបស់យើងទើបពោលដល់អ្នកចាត់ការទ្រព្យម្នាក់ទៀតថា លោក ខ្ញុំចង់ឃើញបុត្តរបស់ខ្ញុំ លោកបញ្ជូនមនុស្សជិតស្និទ្ធម្នាក់ ហើយសរសេរសំបុត្រមួយច្បាប់បញ្ជូនទៅ ហៅបុត្តរបស់យើងមក ។

អ្នកចាត់ការទ្រព្យខ្លីទទួលពាក្យហើយ ឲ្យសំបុត្របញ្ជូនទៅបុរសម្នាក់ទៅ កូនក្រមុំសេដ្ឋី បាននាំឃោសិតៈកុមារទៅក្នុងវេលាដែលសេដ្ឋីឈឺធ្ងន់ សេដ្ឋីក៏ដល់ពេលចាស់ហើយ កាលបិតាធ្វើកាលកិរិយា ព្រះរាជាទ្រង់ប្រទានសម្បត្តិដែលបិតាប្រើប្រាស់ ទ្រង់ប្រគល់តំណែងសេដ្ឋីព្រមដោយឆត្រឲ្យ ។ ឃោសិតៈសេដ្ឋីតាំងនៅក្នុងមហា

សម្បត្តិ ដឹងថា ខ្លួនផុតចាកពីសេចក្តីស្លាប់ក្នុងឋាន ៧ លើក ចាប់ផ្តើមអំពីពាក្យរបស់កូនក្រមុំសេដ្ឋី និងនាងកាឡី ទើបលះបង់ទ្រព្យមួយថ្ងៃ ១.០០០ បរិច្ចាគទាន ។ សេចក្តីដែលឃោសិតៈសេដ្ឋីមិនមានរោគក្នុងឋាន ៧ លើក នេះជាឫទ្ធិ៍របស់អ្នកមានបុណ្យ ។

ក្នុងបទទាំងនោះ បទថា **គហំ** គឺ ផ្ទះ ជាអ្នកធំក្នុងផ្ទះ គឺ គហបតី បទនេះ ជាឈ្មោះរបស់អ្នកជាធំក្នុងត្រកូលមហាសាល ក្នុងគម្ពីរខ្លះ សរសេរមេណ្ឌកសេដ្ឋីទុកក្នុងលំដាប់របស់ឃោសិតសេដ្ឋី ។ ក្នុងបទថា **បញ្ចន្នំ មហាបុញ្ញានំ បុញ្ញវតោ ឥទ្ធិ** ឫទ្ធិអ្នកមានបុណ្យ ៥ នាក់ ជាឫទ្ធិរបស់លោកអ្នកមានបុណ្យនេះ មានសេចក្តីថា គប្បីឃើញបុញ្ញឫទ្ធិរបស់អ្នកមានបុណ្យច្រើន ៥ នាក់ ។ ជន ៥ នាក់ទាំងនេះ ឈ្មោះថា អ្នកមានបុណ្យច្រើន ៥ គឺ មេណ្ឌកសេដ្ឋី ១ នាងចន្ទបទុមា ភរិយាមេណ្ឌកសេដ្ឋី ១ ធនញ្ជ័យសេដ្ឋីបុត្ត ១ នាងសុមនាទេវីសភោ ១ នាយបុណ្ណទាសៈ ១ បានសន្សំបុញ្ញាធិការក្នុងព្រះបច្ចេកពុទ្ធជាម្ចាស់ ។ ក្នុងជនទាំងនោះ មេណ្ឌកសេដ្ឋីសាងជង្រុកស្រូវទុក ១.២៥០ ជង្រុក ស្នាបសីសៈហើយ អង្គុយត្រង់ទ្វារ សម្លឹងមើលទៅលើស្រូវសាលីក្រហម ធ្លាក់ចុះពីអាកាសពេញជង្រុកទាំងអស់ ។ ភរិយារបស់មេណ្ឌកសេដ្ឋីនោះ យកអង្ករប្រមាណ



មួយនាឡិដាំបាយ ហើយធ្វើសម្ល និងម្ហូបក្រៀមម្យ៉ាង ប្រដាប់ដោយគ្រឿងប្រដាប់គ្រប់ប្រភេទ អង្គុយជាប់អាសនៈដែលក្រាលទុកត្រង់ស៊ុំទ្វារ ប្រកាសហៅថា អ្នកមានសេចក្តីត្រូវការភត្តាហារទាំងពួងចូរមកចុះ កាន់វែកធ្វើអំពីមាស ដាក់ចុះក្នុងភាជនៈដែលមនុស្សមកហើយ ៗ នាំចូលទៅឲ្យ សូម្បីកាលនាងឲ្យអស់មួយថ្ងៃ ក៏ប្រាកដត្រឹមតែកាន់យកដោយត្រឹមតែមួយវែកប៉ុណ្ណោះ ។

បុត្តរបស់មេណ្ឌកសេដ្ឋី ស្នាបសីសៈហើយកាន់យកថង់ទ្រព្យ ១.០០០ ប្រកាសថា អ្នកមានសេចក្តីត្រូវការកហាបណៈចូរមកចុះ ហើយដាក់ភាជនៈដែលមនុស្សមកហើយ ៗ ឲ្យទៅ កហាបណៈ ១.០០០ ក៏មិនចេះអស់ ។

កូនប្រសាររបស់សេដ្ឋី ប្រដាប់ដោយគ្រឿងប្រដាប់គ្រប់ប្រភេទ កាន់យកកញ្ជើស្រូវ ៤ នាឡិ អង្គុយលើទីអង្គុយប្រកាសថា អ្នកមានសេចក្តីត្រូវការពូជស្រូវចូរមកយកចុះ ហើយដួសដាក់ភាជនៈដែលមនុស្សកាន់មកហើយ ៗ ឲ្យ ជាលក៏នៅពេញដូចដើម ។

ទាសៈរបស់សេដ្ឋីប្រដាប់ដោយគ្រឿងប្រដាប់គ្រប់ប្រភេទ ខ្សែមាស ទឹមគោដោយនឹមមាស កាន់ដងជន្លួញមាស ឲ្យគ្រោមទាំង ៥ របស់គោមានក្លិនក្រអូប ពាក់ស្រោមមាសត្រង់ជើងទាំងពីរខាង ចេញ

ទៅភ្ជួរស្រែ ស្នាមភ្ជួរទុក ៧ កន្លែង គឺ ខាងនេះ ៣ ខាងនោះ ៣ កណ្ដាល ១ ហើយទៅ អ្នកស្រុកជម្ពូទ្វីបកាន់យកកត្ត ពូជ ប្រាក់ និង មាសជាដើម ពីផ្ទះសេដ្ឋីតាមសេចក្ដីពេញចិត្ត កាលព្រះដ៏មានព្រះភាគ ស្ដេចដល់កទ្ទិយនគរដោយលំដាប់ អ្នកមានបុណ្យទាំង ៥ និងនាងវិ-សាខា ធិតារបស់ធនញ្ជ័យសេដ្ឋី បានសម្រេចសោតាបត្តិផល ដោយ ការស្ដាប់ព្រះធម៌របស់ព្រះដ៏មានព្រះភាគ នេះឫទ្ធិរបស់អ្នកមានបុណ្យ ច្រើន ៥ នាក់ ជាឫទ្ធិរបស់លោកអ្នកមានបុណ្យ តែដោយសង្ខេប សេចក្ដីវិសេសនៃការសម្រេចក្នុងការសន្សំបុណ្យ ដែលដល់កាលចាស់ ក្លា ជាឫទ្ធីរបស់អ្នកមានបុណ្យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **វិជ្ជាមយិទ្ធិនិទ្ទេស** ដូចតទៅនេះ ។ ឈ្មោះថា **វិជ្ជាធរា** ព្រោះទ្រទ្រង់ទុកនូវវិជ្ជារបស់អ្នកស្រុកគន្ធារៈ មានអាការឲ្យសម្រេច ឬវិជ្ជាដទៃដែលសម្រេច ដែលសម្រេចតាម ប្រាថ្នា ។ បទថា **វិជ្ជំ បរិជប្បេត្វា** រាយវិជ្ជា គឺ រាយវិជ្ជាតាមចិត្ត ដោយមាត់ បទដ៏សេសមានអត្ថដូចពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាបយោគិទ្ធិនិទ្ទេស** ដូចតទៅនេះ ។ លោកសួរត្រឹមតែអាការនៃកាសម្រេច មិនសួរថា **កតមា** តើដូចម្ដេច ព្រោះមិនមានគុណវិសេសយ៉ាងដទៃ ហើយសួរត្រឹមតែប្រការប៉ុណ្ណោះ



ទើបតាំងសួរថា **កថំ** យ៉ាងណា ហើយសរុប **ឯវំ** យ៉ាងនេះ ។ ក៏ក្នុង និទ្ទេសនេះ បាលីមានក្នុងកាលមុនមកហើយដោយការសម្ដែង ការ ប្រកបប្រពៃ ពោលការបដិបត្តិនោះឯង តែមកក្នុងអត្ថថា សេចក្ដីវិសេស កើតឡើង ព្រោះធ្វើកម្មនោះ សំដៅដល់ការត្រៀមយ៉ាងណាមួយ ដោយធ្វើសកដព្យូហៈ ( ការតាំងជំរុំកងរទេះ ) ជាដើម សិល្បកម្ម ណាមួយ វេជ្ជកម្មណាមួយ ការរៀនត្រៃវេទ ការរៀនព្រះត្រៃបិដក ដោយទីបំផុត ការភ្ជួរ និងការរាស់ជាដើម ឈ្មោះថា **ឥទ្ធិ** ដោយ ការសម្រេច ព្រោះហេតុនៃការប្រកបប្រពៃក្នុងចំណែកនោះ ៗ ដោយ ប្រការដូច្នេះ ។

(ចប់អដ្ឋកថា ឥសឥទ្ធិកថា)

# ៣-អដ្ឋកថា អភិសមយកថា

ឥឡូវនេះ នឹងពណ៌នាតាមសេចក្ដីដែលនៅមិនទាន់បានពណ៌នា នៃអភិសមយកថា ដែលព្រះសារីបុត្តត្ថេរ អ្នកសម្ដែងអភិសមយដែលជាឫទ្ធិយ៉ាងក្រៃលែង ក្នុងលំដាប់នៃឥទ្ធិកថាពោលហើយ ។

ក្នុងបទទាំងនោះ បទថា **អភិសមយោ** ការត្រាស់ដឹង គឺ ដល់ព្រមដោយធម៌ជាប្រធាននៃសច្ចៈទាំងឡាយ អធិប្បាយថា ចាក់ធ្លុះ អាចារ្យពួកខ្លះពោលថា ការត្រាស់ដឹងអត្ថ ។ បទថា **កេន អភិសមេតិ** រមែងត្រាស់ដឹងដោយអ្វី លោកអធិប្បាយទុកដូចម្ដេច លោកពោលការត្រាស់ដឹងថា ការត្រាស់ដឹងជាកិច្ចនោះណា ក្នុងបទនៃព្រះសូត្រមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងធម៌ដែលឲ្យសម្រេចប្រយោជន៍ធំយ៉ាងនេះឯង កាលការត្រាស់ដឹងនោះប្រព្រឹត្តទៅ បុគ្គលអ្នកត្រាស់ដឹង រមែងត្រាស់ដឹងសច្ចៈដោយធម៌អ្វី ជាអ្នកមានធម៌ជាប្រធាន រមែងដល់ព្រម អធិប្បាយថា ចាក់ធ្លុះ នេះជាពាក្យសួរជំទាស់មុន ។ បទថា **ចិត្តេន អភិសមេតិ** រមែងត្រាស់ដឹងដោយចិត្ត ក៏ឆ្លើយយ៉ាងនោះ ព្រោះវៀរចិត្តចេញហើយ មិនមានការត្រាស់ដឹង ។ បទ



មានជាអាទិ៍ថា **ហញ្ចិ** ជាការជំទាស់ទៀត **ហញ្ចិ** ប្រែថា ប្រសិនបើ ។ ព្រោះលោកពោលថា ដោយមានចិត្តជំទាស់ ទើបពោលថា បើដូច្នោះ បុគ្គល អ្នកមិនមានញាណក៏ត្រាស់ដឹងបាន ។ បទថា **ន អញ្ញាណី អភិសមេតិ** បុគ្គលមិនមានញាណត្រាស់ដឹងមិនបាន គឺ បដិសេធ ព្រោះមិនមានការត្រាស់ដឹងត្រឹមតែចិត្តប៉ុណ្ណោះ ។ បទថា **ញាណេន អភិសមេតិ** រមែងត្រាស់ដឹងដោយញាណដែលជាការទទួល ។ បទ មានជាអាទិ៍ថា [illegible]

**សច្ចានុលោមិកចិត្តេន ច ញាណេន ច** ផង **សច្ចានុលោមិកចិត្ត** និងដោយញាណ គឺ ដោយចិត្តសម្បយុត្តដោយវិបស្សនា ពោលគឺ **សច្ចានុលោមិកញាណ** ព្រោះអនុលោមដល់ការចាក់ធ្លុះសច្ចៈ និងដោយវិបស្សនាញាណ ។

បទថា **កថំ** តើដូចម្ដេច ជាកថេតុកម្យតាបុច្ឆា ( សួរខ្លួនឯងឆ្លើយខ្លួនឯង ) ន័យដូចអភិសម័យ ។ បទថា **ឧប្បាទាធិបតេយ្យំ** ចិត្តជាធំក្នុងការឲ្យកើតឡើង បានដល់ ព្រោះកាលមិនមានចិត្តកើត ចេតសិកក៏មិនកើត ព្រោះចិត្តកាន់យកអារម្មណ៍ ចេតសិកក៏កើតព្រមជាមួយចិត្តនោះ កាលមិនមានអារម្មណ៍នឹងកាន់យក នឹងកើតបានដូចម្ដេចទៅ សូម្បីក្នុងអភិធម្ម លោកក៏ចែកចេតសិកទុកដោយការកើតឡើងនៃចិត្តនោះឯង ដូច្នោះចិត្តទើបជាធំក្នុងការកើតឡើងនៃមគ្គញាណ ។ បទថា **ញាណស្ស** គឺ នៃមគ្គញាណ ។ បទថា **ហេតុ បច្ចយោ ច** ជាហេតុ ជាបច្ច័យ គឺ ជាអ្នកឲ្យកើត និងជាអ្នកឧបត្ថម្ភ ។ បទថា **តំ សម្បយុត្តំ** គឺ ចិត្តសម្បយុត្តដោយញាណនោះ ។ បទថា **និរោធគោចរំ** មាននិរោធជាគោចរ គឺ មាននិព្វានជាអារម្មណ៍ ។ បទថា **ទស្សនាធិបតេយ្យំ** ញាណជាធំក្នុងការឃើញ គឺ ជាធំក្នុងការឃើញនិព្វាន ព្រោះមិនមានកិច្ចដែលនឹងឃើញវត្ថុដ៏សេសសល់ ។ បទថា



**ចិត្តស្ស** នៃចិត្ត គឺ នៃចិត្តសម្បយុត្តដោយមគ្គ ។ បទថា **តំសម្បយុត្តំ** គឺ ញាណ ដែលសម្បយុត្តដោយចិត្តនោះ ។

ព្រោះបរិយាយសូម្បីនេះ មិនមែនការត្រាស់ដឹងដោយចិត្ត និងញាណប៉ុណ្ណោះ ដែលពិតធម៌ គឺ ចិត្ត និងចេតសិកដែលសម្បយុត្តដោយមគ្គសូម្បីទាំងអស់ ឈ្មោះថា ជាការត្រាស់ដឹង ដោយញុំាងកិច្ច គឺ ការត្រាស់ដឹងសច្ចៈ ដូច្នោះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្ដែងបរិយាយសូម្បីនោះ ទើបសួរថា ការត្រាស់ដឹងមានប៉ុណ្ណោះ ឬ បដិសេធថា **នហិ** មិនមែនមានប៉ុណ្ណោះ ហើយពោលពាក្យមានជាអាទិ៍ថា **លោកុត្តរមគ្គក្ខណេ** ក្នុងខណៈនៃលោកុត្តរមគ្គ ។ បទថា **ទស្សនាភិសមយោ** កាត្រាស់ដឹងដោយការឃើញ គឺ ការត្រាស់ដែលជាការឃើញ សូម្បីក្នុងបទដ៏សេសសល់ក៏មានន័យនេះ ។ បទថា **សច្ចា** គឺ សច្ចៈញាណ មគ្គញាណនោះឯង ឈ្មោះថា វិបស្សនាដោយអត្ថថា ពិចារណាឃើញព្រះនិព្វាន ។ បទថា **វិមោក្ខោ** គឺ មគ្គវិមោក្ខ ។ បទថា **វិជ្ជា** គឺ មគ្គញាណនោះឯង ។ បទថា **វិមុត្តិ** គឺ សមុច្ឆេទវិមុត្តិ ។ និព្វាន ឈ្មោះថា **អភិសមយោ** ព្រោះត្រាស់ដឹងដ៏សេស ឈ្មោះថា **អភិសមយា** ព្រោះជាហេតុត្រាស់ដឹង ។

ព្រះសារីបុត្តត្ថេរ ដើម្បីសម្ដែងចែកអភិសម័យដោយមគ្គ និង

ផល ទើបពោលពាក្យមានជាអាទិ៍ថា **កិន្នុ** ដូច្នេះ មយ៉ាងទៀត ក្នុងទីនេះ ព្រោះញាណរមែងមិនបានក្នុងការអស់ទៅ ដោយអត្ថថា ដាច់ជាសមុច្ឆេទក្នុងខណៈផល ដូច្នោះ ទើបលោកពោលថា **អនុប្បាទេ-ញាណំ** ញាណក្នុងនិព្វានដែលមិនមានការកើតឡើង ។ គប្បីជ្រាបបទដ៏សេសតាមសមគួរ ឥឡូវនេះ ព្រោះកាលមានការលះកិលេស ការត្រាស់ដឹងក៏រមែងមានបាន និងកាលមានការត្រាស់ដឹង ការលះកិលេសក៏រមែងមានបាន ដូច្នេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងដល់ការលះកិលេសដែលមានការជំទាស់ជាខាងដើម ទើបពោលពាក្យមានជាអាទិ៍ថា **ស្វាយំ** បុគ្គលនេះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ស្វាយំ** គឺ ព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងមគ្គនេះ ។ ពាក្យ ៤ ពាក្យ ក្នុងបទនេះមាន **ឯវំ** ជាដើម ជាការសួរបស់អ្នកជំទាស់ ។ បទនេះថា **អតីតេ កិលេសេ បជហតិ** ការលះកិលេសដែលជាអតីត ជាពាក្យឆ្លើយ ដើម្បីឲ្យឱកាសដល់ការជំទាស់ ។

បទថា **ខីណំ** គឺ អស់ទៅហើយដោយការរំលត់ ។ បទថា **និរុទ្ធំ** រំលត់ហើយ គឺ រំលត់ហើយដោយការមិនកើតឡើងរឿយ ៗ ក្នុងសន្តាន ។ បទថា **វិគតំ** ប្រាសទៅ គឺ ប្រាសទៅចាកខណៈដែល



កំពុងប្រព្រឹត្តទៅ ។ បទថា **វិគមេតិ** គឺ ឲ្យប្រាសទៅ ។ បទថា **អត្ថង្គតំ** ដល់ការរំលត់ទៅ គឺ ដល់ការមិនមាន ។ បទថា **អត្ថង្គមេតិ** គឺ ឲ្យដល់ការមិនមាន ។ កាលសម្តែងទោសក្នុងប្រការនោះហើយ ទើបពោលបដិសេធថា បុគ្គលលះកិលេសដែលជាអតីតក៏ទេ ។ បទថា **អជាតំ** ដែលមិនកើតឡើង គឺ នៅមិនទាន់កើតឡើង ក្នុងការជំទាស់ដែលជាអនាគត ។ បទថា **អនិព្វត្តំ** កិលេសដែលនៅមិនទាន់កើត គឺ កិលេសដែលនៅមិនដល់សភាវៈ ។ បទថា **អនុប្បន្នំ** កិលេសដែលនៅមិនទាន់កើត គឺ នៅមិនទាន់បដិបត្តិក្នុងអនាគតចាប់ផ្តើមអំពីកើត ។ បទថា **អបាតុភូតំ** មិនប្រាកដ គឺ មិនប្រាកដនៃចិត្តជាបច្ចុប្បន្ន ។ កាលអ្នកលះក្នុងអតីត និងអនាគត សេចក្តីព្យាយាមមិនមានផលរមែងបានទទួល ព្រោះមិនមានវត្ថុដែលគួរលះ ព្រោះហេតុនោះ លោកទើបបដិសេធ សូម្បីទាំងពីរយ៉ាង ។

បទថា **រត្តោ រាគំ បជហតិ** បុគ្គលអ្នកប្រាសចាកតម្រេករមែងលះរាគៈបាន គឺ បុគ្គលអ្នកប្រាសចាកតម្រេក រមែងលះរាគៈនោះបាន ដោយរាគៈដែលកំពុងប្រព្រឹត្តទៅ ។ សូម្បីក្នុងកិលេសកំពុងប្រព្រឹត្តទៅ ក៏មានន័យនេះដូចគ្នា ។ បទថា **ថាមគតោ** អ្នកមានកិលេសស្រោលស្តើង គឺ អ្នកដល់សភាពតាំងមាំ ។ បទថា **កណ្ហសុក្កា**

ធម៌ខ្មៅ និងធម៌ស គឺ ធម៌ដែលជាអកុសល និងកុសល ដែលជាគូគ្នាកំពុងប្រព្រឹត្តទៅ គឺ រមែងដល់សភាពស្មើគ្នា ។ បទថា **សង្កិលេសិកា** មគ្គភាវនាដែលមានសេចក្ដីសៅហ្មងដោយកិលេស គឺ កាលបើសេចក្ដីសៅហ្មងសម្បយុត្តគ្នាហើយ មគ្គភាវនាប្រកបដោយសេចក្ដីសៅហ្មង ក៏រមែងកើតឡើងបាន កាលលះក្នុងបច្ចុប្បន្នយ៉ាងនេះ មគ្គភាវនាដែលមានសភាពសៅហ្មងរមែងមានបាន និងសេចក្ដីព្យាយាម ក៏មិនមានផល ព្រោះមានវត្ថុដែលគួរលះជាមួយការព្យាយាម ព្រោះមិនមានការចែកចិត្តចេញពីកិលេសដែលជាបច្ចុប្បន្ន ។

បទថា **ន ហិ** មិនមាន គឺ បដិសេធពាក្យដែលលោកពោលទុកហើយ ៤ ចំណែក ។ បទថា **អត្ថិ** មាន គឺ ទទួលរ៉ាប់រង ។ បទថា **យថា កថំ វិយ** ដូចអ្វី ជាការសួរដើម្បីបង្ហាញឲ្យឃើញឧទាហរណ៍នៃការមាន គឺ មានដូច ដោយប្រការណា មានដូចអ្វី ។ បទថា **យថាបិ** សូម្បីយ៉ាងណា ។ បទថា **តរុណោ រុក្ខោ** ដើមឈើតូច គឺ កាន់យកដើមឈើតូច ដើម្បីនឹងបានឲ្យផល ។ បទថា **អជាតផលោ** ផលដែលនៅមិនទាន់កើត គឺ សូម្បីមានការឲ្យផល ក៏ជ្រុះចោលមុនពេលការឲ្យផល ។ បទថា **តមេនំ** គឺ ដើមឈើនោះ ។ បទថា **ឯនំ** ត្រឹមតែជានិបាត ឬគឺ **តំ ឯតំ** ។ បទថា **មូលំ ឆិន្ទេយ្យ** គប្បី



កាត់ឫស គឺ គប្បីកាត់តាំងអំពីឫស ។ បទថា **អជាតផលា** គឺ ផលដែលមិនទាន់កើត ។ បទថា **ឯវ មេវ** កាត់បទជា **ឯវំ ឯវំ** ។ លោកពោលដល់ការបន្តនៃខន្ធដែលជាបច្ចុប្បន្ន ដោយហេតុ ៤ ប្រការ គឺ ការកើត ១ ការប្រព្រឹត្តទៅ ១ និមិត្ត ១ ការប្រមូល ១ ខន្ធសន្តានមិនមែនជាពូជរបស់កិលេស ដែលគួរលះបានដោយមគ្គញាណ ព្រោះខន្ធសន្តាននោះ មិនមែនជាពូជ កិលេសនោះ មានខន្ធសន្តាននោះ ជាបច្ច័យនៅមិនទាន់កើតឡើង រមែងមិនកើតឡើង ។ បទថា **អាទីនវំ ទិស្វា** ឃើញទោស គឺ ឃើញទោសដោយភាពជារបស់មិនទៀងជាដើម ។ លោកពោលដល់និព្វានប៉ុណ្ណោះ ដោយបទ ៤ បទ មាន ជាអាទិ៍ថា **អនុប្បាទោ** ការមិនកើតឡើង ។ បទថា **ចិត្តំ បក្ខន្ទតិ** ចិត្តស្ទុះទៅ គឺ ចិត្តសម្បយុត្តដោយមគ្គ រមែងស្ទុះទៅ ។ បទថា **ហេតុនិរោធា ទុក្ខនិរោធោ** ព្រោះហេតុរំលត់ ទុក្ខក៏រំលត់ គឺ ព្រោះការមិនកើតសន្តានដែលជាពូជរបស់កិលេសទាំងឡាយរលត់ ក៏ជាការរលត់ការមិនកើតកិលេសដែលជាហេតុនៃទុក្ខ ដែលជាខន្ធក្នុងអនាគត ។ ព្រោះការមិនកើតកិលេសដែលជាហេតុនៃទុក្ខយ៉ាងនេះរលត់ ទើបជាការរលត់ការមិនកើតនៃទុក្ខផង ។ ព្រះសារីបុត្តត្ថេរពោលពាក្យមានជាអាទិ៍ថា **អត្ថិ មគ្គភាវនា** មគ្គភាវនាមានហើយ ព្រោះមានប្រការយុតិ

ក្នុងការលះកិលេស ។

ប៉ុន្តែក្នុងអដ្ឋកថាពោលទុកថា ដោយបទនេះ លោកសម្តែងទុកដូចម្តេច ។ លោកសម្តែងដល់ការលះកិលេសដែលបានភូមិហើយ ក៏ភូមិដែលបាននោះជាអតីត អនាគត ឬបច្ចុប្បន្ន ។ គប្បីជ្រាបកថាពិស្តារនៃការលះកិលេសដែលលោកពោលហើយថា កិលេសដែលបានភូមិកើតឡើងហើយ ដោយន័យដូចពោលហើយក្នុងអដ្ឋកថាមគ្គ-សច្ចនិទ្ទេសនៃសុតមយញ្ញាណកថា ។ តែក្នុងទីនេះ លោកប្រាថ្នាយកកិលេសដែលគួរលះបានដោយមគ្គញ្ញាណប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថាអភិសមយកថា)



# ៤-អដ្ឋកថា វិវេកកថា

ដោយអត្ថថា ប្រាសចាក ឈ្មោះថា **និរោធ** ដោយអត្ថថា រលត់ ឈ្មោះថា **វោស្សគ្គ** ដោយអត្ថថា លះបង់ ។

ម្យ៉ាងទៀត ឈ្មោះថា **វិវេក** ព្រោះស្ងាត់ចាកកិលេសទាំងឡាយ ឈ្មោះថា **វិរាគ** ព្រោះប្រាសចាកកិលេសទាំងឡាយ ឈ្មោះថា **និរោធ** ព្រោះរលត់កិលេសទាំងឡាយ ឈ្មោះថា **វោស្សគ្គ** ព្រោះលះបង់កិលេសទាំងឡាយ ព្រោះបណ្តោយចិត្តទៅក្នុងនិព្វាន ។ ម្យ៉ាងទៀត **វោស្សគ្គ** មាន ២ យ៉ាង គឺ **បរិច្ចាគវោស្សគ្គ** ( បណ្តោយដោយការលះបង់ ) និង **បក្ខន្ទនវោស្សគ្គ** ( បណ្តោយដោយការស្ទុះទៅ ) ។ ក្នុងវោស្សគ្គៈ ២ យ៉ាងនោះ ការលះកិលេសដោយតទង្គ ក្នុងខណៈនៃវិបស្សនា ដោយសមុច្ឆេទក្នុងខណៈនៃមគ្គ ឈ្មោះថា **បរិច្ចាគវោស្សគ្គ** ។ ការស្ទុះទៅកាន់និព្វាន ដោយការបង្អោនទៅកាន់និព្វាននោះ ក្នុងខណៈនៃវិបស្សនា ដោយការធ្វើនិព្វានឲ្យជាអារម្មណ៍ ក្នុងខណៈនៃមគ្គ ឈ្មោះថា **បក្ខន្ទនវោស្សគ្គ** ។ សូម្បីទាំងពីរនោះ ក៏សមគួរក្នុងន័យនៃការពណ៌នាសេចក្តីដែលលាយដោយលោកិយៈ និងលោកុត្តរៈនេះ ។ សេចក្តីពិតនោះ ក្នុងសម្មាទិដ្ឋិជាដើម ធម៌នេះមួយ ៗ រមែង

លះបង់កិលេសដោយប្រការតាមដែលពោលហើយ និងរមែងស្មុះទៅកាន់និព្វាន ។ បទថា **វោស្សគ្គបរិណាមី** បង្អោនទៅក្នុងការលះបង់ លោកអធិប្បាយថា បង្អោនទៅ ទោរទៅ អប់រំ បន្ទុំឲ្យចាស់ក្លា ដើម្បីការលះបង់ដោយពាក្យទាំងអស់នេះ ។ ភិក្ខុអ្នកខ្វល់ខ្វាយក្នុងអរិយមគ្គភាវនានេះ រមែងចម្រើនអរិយមគ្គនោះ ដោយប្រការដែលធម៌មួយ ៗ ក្នុងសម្មាទិដ្ឋិជាដើម រមែងអប់រំ និងធ្វើឲ្យចាស់ក្លា ដើម្បីបន្សាត់ក្នុងការលះបង់កិលេស និងដើម្បីបន្សាត់ក្នុងការស្មុះទៅកាន់និព្វាន ។

ក្នុងបទថា **ពីជគាមភូតគាមា** ពីជគាម និងភូតគាមនេះ មានអធិប្បាយថា ពីជ ៥ យ៉ាង គឺ ពូជកើតពីឫស ១ ពូជកើតពីដើម ១ ពូជកើតពីត្រួយ ១ ពូជកើតខ្នាំង ១ ពូជកើតពីពូជ ១ រួមពូជ ៥ នេះ ឈ្មោះថា **ពីជគាម** ។ ឈ្មោះថា ភូតគាមចាប់ផ្ដើមពីការប្រាកដនៃពន្លកខៀវសំបូរណ៍ហើយ ។ អធិប្បាយថា រួមឫស ពន្លកពណ៌ខៀវរបស់ភូតគាមដែលកើតហើយ អាចារ្យពួកខ្លះពោលថា កាលទេវតាហួងហែង រមែងមានតាំងពីវេលាមានពន្លកពណ៌ខៀវ ព្រោះហេតុនោះទើបឈ្មោះថា ភូតគាម ព្រោះជាភូមិរបស់ភូត គឺ ទេវតាទាំងនោះ ។ បទថា **វុឌ្ឍឹ** សេចក្ដីចម្រើន គឺ ចម្រើនដោយពន្លកជាដើម ។ បទ



ថា **វិរុឡ្ហឹ** លូតលាស់ គឺ លូតលាស់ដោយដើម ជាដើម ។ បទថា **វេបុល្លំ** បរិបូណ៌ គឺ បរិបូណ៌ដោយផ្កាជាដើម ម្យ៉ាងទៀត ក្នុងផ្លូវធម៌ បទថា **វុឌ្ឍឹ** គឺ ចម្រើនដោយការប្រព្រឹត្តធម៌ ដែលនៅមិនទាន់ធ្លាប់ប្រព្រឹត្ត ។ បទថា **វិរុឡ្ហឹ** គឺ លូតលាស់ដោយការធ្វើកិច្ចឲ្យសម្រេច ។ បទថា **វេបុល្លំ** គឺ បរិបូណ៌ដោយសម្រេចកិច្ចហើយ ។ បាឋៈថា **វិបុលត្តំ** គឺ ការបរិបូណ៌ខ្លះ ។

ម្យ៉ាងវិញទៀត បទ ៣ ទាំងនេះ ប្រកបដោយសីល សមាធិ បញ្ញា ។

(ចប់ អដ្ឋកថាវិវេកកថា)

# អដ្ឋកថា មគ្គង្គនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះ ។ បទថា **សម្មាទិដ្ឋិយា** ជាឆដ្ឋីវិភត្តិនៃសម្មាទិដ្ឋិដែលប្រព្រឹត្តទៅអំពីការប្រកបតាមសមគួរ និងចាកអារម្មណ៍ ក្នុងឈាន វិបស្សនា មគ្គ ផល និងនិព្វានហើយ ក្នុងចិត្តដែលសម្បយុត្តដោយលោកិយវិរតិ គឺ នៃសម្មាទិដ្ឋិ ដែលកើតជាមួយគ្នា ដោយសាមញ្ញលក្ខណៈ ។ បទថា **វិក្ខម្ភនវិវេកោ** វិក្ខម្ភនវិវេក គឺ សេចក្តីស្ងាត់ដោយការគ្របសង្កត់ទុក ដោយការធ្វើឲ្យឆ្ងាយនៃអ្វី នៃនីវរណ៍ទាំងឡាយ ។ បទមានជាអាទិ៍ថា **បឋមជ្ឈានំ ការយតោ** ចម្រើនបឋមជ្ឈាន លោកពោលដល់បឋមជ្ឈានដោយការគ្របសង្កត់ទុក កាលលោកពោលដល់បឋមជ្ឈាននោះក៏គឺ ពោលដល់សូម្បីឈានដ៏សេសដូចគ្នា ។ ឈ្មោះថា **សម្មាទិដ្ឋិវិវេក** ព្រោះមានសម្មាទិដ្ឋិសូម្បីក្នុងឈានទាំងឡាយ ។

បទថា **តទង្គវិវេកោ** គឺ ការស្ងាត់ដោយវិបស្សនាញាណនោះ ៗ ។ បទថា **ទិដ្ឋិគតានំ** ទិដ្ឋិទាំងឡាយ លោកពោលថា ទិដ្ឋិវិវេកព្រោះទិដ្ឋិវិវេកធ្វើបានលំបាក និងព្រោះជាប្រធាន កាលលោកពោលដល់ទិដ្ឋិវិវេក ក៏ជាការពោលសូម្បីវិវេក មាននិច្ចសញ្ញាជាដើម ។



បទថា **និព្វេធភាគិយំ សមាធឹ** សមាធិដែលជាចំណែកនៃការទម្លាយកិលេស គឺ សមាធិសម្បយុត្តដោយវិបស្សនា ។ បទថា **សមុច្ឆេទវិវេកោ** សមុច្ឆេទវិវេក គឺ ការស្ងាត់ដោយការកាត់ផ្តាច់កិលេសទាំងឡាយ ។ បទថា **លោកុត្តរំ ខយគាមឹ មគ្គំ** លោកុត្តរមគ្គដែលឲ្យដល់ការអស់ទៅ គឺ លោកុត្តរមគ្គដែលឲ្យដល់និព្វាន ពោលគឺ ការអស់ទៅ ។ បទថា **បដិប្បស្សទ្ធិវិវេកោ** បដិបស្សទ្ធិវិវេក គឺ សេចក្តីស្ងាត់ ក្នុងការស្ងប់កិលេសទាំងឡាយ ។ បទថា **និស្សរណវិវេកោ** និស្សរណវិវេក គឺ ការស្ងាត់សង្ខារដែលជាការនាំសង្ខតធម៌ទាំងអស់ចេញទៅ ។ បទថា **ឆន្ទជាតោ ហោតិ** ភិក្ខុជាអ្នកកើតឆន្ទៈ គឺ ជាអ្នកកើតសេចក្តីពេញចិត្តក្នុងធម៌ ក្នុងចំណែកខាងដើម ។ បទថា **សទ្ធាធិមុត្តោ** គឺ ជាអ្នកបង្អោនទៅដោយសទ្ធាក្នុងចំណែកខាងដើម ។ បទថា **ចិត្តំ ចស្ស ស្វាធិដ្ឋិតំ** មានចិត្តតាំងមាំដោយល្អ គឺ តាំងមាំដោយល្អ គឺ ចិត្តរបស់ព្រះយោគាវចរនោះ តាំងមាំដោយល្អ គឺ តាំងមាំដោយល្អក្នុងចំណែកខាងដើម ។ ធម៌ ៣ ប្រការទាំងនេះ គឺ ឆន្ទៈ ១ សទ្ធា ១ ចិត្ត ១ ឈ្មោះថា ជាទីអាស្រ័យ ព្រោះជាទីចូលទៅអាស្រ័យនៃវិវេកដែលកើតឡើងហើយក្នុងចំណែកខាងដើម ។ តែអាចារ្យពួកខ្លះពោលថា លោកពោលសមាធិថា មានចិត្តតាំងមាំដោយល្អ សូម្បី

ក្នុងវិរាគៈជាដើម ក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុង **និរោធវារ** ដូចតទៅនេះ ។ លោកសម្តែងពាក្យបរិយាយដទៃអំពីនិរោធសព្ទ ហើយពោលថា **អមតាធាតុ** អមតធាតុ ។ គប្បីជ្រាបក្នុងបទដ៏សេសតទៅ បទថា **និរោធោ និព្វានំ** ជានិរោធ គឺ និព្វាន សូម្បីក្នុងបទទាំងពីរក៏ជានិព្វានដូចគ្នា ។ បទថា **ទ្វាទស និស្សយា** មាននិស្ស័យ ១២ គឺ ធ្វើឆន្ទៈ សទ្ធា ចិត្ត មួយ ៗ ៣ ក្នុងមួយ ៗ ជា ៤ យ៉ាង មានវិវេកជាដើម រួមជានិស្ស័យ ១២ ។ សូម្បីសម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ក៏គប្បីជ្រាបការប្រកបសេចក្តី ដោយន័យនេះដូចគ្នា ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលដល់វិរតិ ដែលប្រព្រឹត្តទៅដោយអំណាចជាចំណែកខាងដើម និងចំណែកខាងចុង នៃឈាន និងវិបស្សនា ព្រោះមិនមានសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ក្នុងខណៈនៃឈាន ក្នុងខណៈវិបស្សនា ធ្វើឈាន និងវិបស្សនាឲ្យអាស្រ័យគ្នា ។ ម្យ៉ាងទៀត គប្បីជ្រាបថា វិវេក វិរាគៈ និរោធ និងបដិនិស្សគ្គៈ នៃនីវរណៈ និងទិដ្ឋិ ឈ្មោះថា វិវេកជាដើមនៃវិរតិទាំងឡាយដែលកើតហើយយ៉ាងនោះ ។ ដូចដែលលោកពោលទុកក្នុងអដ្ឋកនិបាតថា ម្នាលភិក្ខុ បន្ទាប់ពីអ្នកចម្រើនសមាធិនេះ ព្រមដោយវិតក្កៈ



និងដោយវិចារៈ គប្បីចម្រើនសូម្បីត្រឹមតែវិចារៈ មិនមានវិតក្កៈ គប្បីចម្រើនសូម្បីមិនមានទាំងវិតក្កៈមិនមានទាំងវិចារៈ គប្បីចម្រើនព្រមដោយបីតិ គប្បីចម្រើនសូម្បីមិនមានបីតិ គប្បីចម្រើនសូម្បីសហគតៈដោយសេចក្តីពេញចិត្ត គប្បីចម្រើនសូម្បីសហគតៈដោយឧបេក្ខា ។ លោកពោលមេត្តាជាដើម និងកាយានុបស្សនាជាដើម ដោយអំណាចនៃសមាធិដែលជាមូលខាងក្នុងរបស់ខ្លួន ដូចពោលដល់ចតុកឈាន និងបញ្ចកឈាន សូម្បីក្នុងបទនេះ ក៏គប្បីជ្រាបថា លោកពោលដល់វិរតិ ដោយអំណាចខាងដើម និងខាងចុងយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់កាន់យកត្រឹមតែព្យញ្ជនៈឆាយា ( ស្រមោលនៃព្យញ្ជនៈ ) ទើបមិនគួរពោលបន្ទំ ។ ព្រោះព្រះពុទ្ធវចនៈជ្រាលជ្រៅណាស់ គប្បីចូលទៅរកអាចារ្យ ហើយរៀនយកតាមសេចក្តីប្រាថ្នា ។

សូម្បីក្នុងពោជ្ឈង្គវារៈ ពលវារៈ និងឥន្ទ្រិយវារៈ ក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ។

(ចប់ អដ្ឋកថាមគ្គង្គនិទ្ទេស)

# ៥-អដ្ឋកថា ចរិយាកថា

ឥឡូវនេះ ដើម្បីឲ្យឃើញឧបាយការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ពោលគឺ និស្សរណវិវេក ដែលជាសេចក្ដីស្ងាត់យ៉ាងក្រៃលែងក្នុងលំដាប់វិវេកកថា នឹងដើម្បីឲ្យឃើញការធ្វើប្រយោជន៍សុខដល់លោក នៃនិរោធដែលធ្វើឲ្យជាក់ច្បាស់នោះ ព្រះសារីបុត្តត្ថេរ ទើបពោលចរិយាកថាសូម្បីបន្ទាញទុកហើយក្នុងឥន្ទ្រិយកថាទៀត ។ ការពណ៌នាសេចក្ដីនៃចរិយាកថានោះ លោកពោលទុកហើយក្នុងឥន្ទ្រិយកថានោះឯង ដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថាចរិយាកថា)



# ៦-អដ្ឋកថា បាដិហារិយកថា

ឥឡូវនេះ នឹងពណ៌នាតាមសេចក្ដីដែលនៅមិនធ្លាប់ពិចារណា នៃបាដិហារិយកថា ដែលមានព្រះសូត្រជាខាងដើម ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងបាដិហារិយ មានការប្រៀនប្រដៅប្រយោជន៍ដល់លោកជាទីបំផុត ក្នុងលំដាប់នៃចរិយាកថា ដែលមានការប្រព្រឹត្តជាប្រយោជន៍ដល់លោកជាទីបំផុតគ្រប់ហើយ ។

ក្នុងព្រះសូត្រនោះ គប្បីជ្រាបសេចក្ដីដូចតទៅនេះមុន បទថា **បាដិហារិយានិ** គឺ បាដិហារិយដោយការនាំវត្ថុជាសឹកសត្រូវចេញទៅ គឺ នាំកិលេសចេញទៅ ។ បទថា **ឥទ្ធិបាដិហារិយំ** ឥទ្ធិបាដិហារិយ ឈ្មោះថា **ឥទ្ធិ** ដោយការសម្រេច ឈ្មោះថា **បាដិហារិយ** ដោយការនាំចេញទៅ ឥទ្ធិនោះឯងជាបាដិហារិយ ទើបឈ្មោះថា ឥទ្ធិបាដិហារិយ ចំណែកក្នុងបាដិហារិយក្រៅនេះ ឈ្មោះថា **អាទេសនា** ដោយការដាស់តឿនចិត្ត ឈ្មោះថា **អនុសាសនី** ដោយការប្រៀនប្រដៅបទដ៏សេស មានន័យដូចពោលហើយនោះឯង ។ បទថា **ឥទ្ធិ** គឺ ក្នុងលោកនេះ ។ បទថា **ឯកច្ចោ** គឺ បុរសម្នាក់ ឥទ្ធិបាដិហារិយនិទ្ទេសមានអត្ថដូចពោលទុកហើយក្នុងខាងក្រោយ ។ បទថា **និមិត្តេន អាទិ-**

**សតិ** រមែងទាយចិត្តតាមនិមិត្ត គឺ រមែងពោលដោយនិមិត្តដែលមក ហើយដោយនិមិត្តដែលទៅហើយ ឬដោយនិមិត្តនៃចិត្ត ។

បទថា **ឯវម្បិ តេ មនោ** ចិត្តរបស់លោកជាយ៉ាងនោះ គឺ ចិត្តរបស់លោកជាយ៉ាងនេះ មានសោមនស្ស មានទោមនស្ស ឬសម្បយុត្តដោយកាមវិតក្កៈជាដើម **អបិ** សព្ទ ជាសម្បិណ្ឌនត្ថៈ ( មានការរួមគ្នា ) ។ បទថា **ឥត្ថម្បិ តេ មនោ** ចិត្តរបស់លោក មានប្រការនេះ គឺ សម្តែងប្រការផ្សេង ៗ ក្នុងចិត្តសូម្បីមួយយ៉ាង ៗ អំពីចិត្តមានសោមនស្សជាដើម ។ បទថា **ឥតិបិ តេ ចិត្តំ** ចិត្ត របស់លោកមានដូច្នេះ គឺ ចិត្តរបស់លោកសូម្បីជាដូច្នេះ សេចក្តីថា ចិត្តគិតដល់ប្រយោជន៍នេះ ៗ ប្រព្រឹត្តទៅ ។ បទថា **ពហុំពេ្ចបិ អាទិសតិ** សូម្បីភិក្ខុនោះទាយចិត្តដោយច្រើន គឺ ពោលសូម្បីយ៉ាងច្រើនជាងចិត្តនេះ ចិត្តនេះដទៃពីចិត្តមានហើយ រមែងនឹងមាន ។ បទថា **តថេវ តំ ហោតិ នោ អញ្ញថា** ការទាយចិត្តនោះ ក៏ជាយ៉ាងនោះមិនជាយ៉ាងដទៃ គឺ ការទាយចិត្ត ក៏ដូចដែលពោលហើយទាំងអស់ មិនជាយ៉ាងដទៃ ។ បទថា **ន ហេវ ខោ និមិត្តេន អាទិសតិ** ភិក្ខុមិនទាយចិត្តតាមនិមិត្តឡើយ គឺ សូម្បីដឹងនិមិត្ត ក៏នៅមិនពោលតាមនិមិត្តមែនពិត ។ បទថា **អបិច** ជាបទសម្តែងបរិយាយដទៃទៀត ។ បទថា **មនុស្សានំ** គឺ នៃមនុស្ស



អ្នកញ៉ាំងចិត្តឲ្យកើត ។ បទថា **អមនុស្សានំ** គឺ យក្សបិសាចជាដើម ដែលបានស្តាប់ហើយ ឬនៅមិនទាន់បានស្តាប់ ។ បទថា **ទេវតានំ** គឺ ទេវតាជាន់ចាតុម្មហារាជិកាជាដើម ។ បទថា **សទ្ទំ សុត្វា** ស្តាប់សម្លេងហើយ គឺ ស្តាប់សម្លេងរបស់អ្នកដឹងចិត្តរបស់មនុស្សដទៃ ហើយពោល ។ បទថា **បន** ជានិបាតចុះក្នុងការរីករាយទៀត ។ បទថា **វិតក្កយតោ** របស់អ្នកមានវិតក្កៈ គឺ របស់អ្នកនឹកគិតដោយវិតក្កៈតាមធម្មតា ។ បទថា **វិចារយតោ** របស់អ្នកពិចារណាដោយវិចារៈសម្បយុត្តដោយវិតក្កៈនោះឯង ។ បទថា **វិតក្កវិចារសទ្ទំ សុត្វា** ស្តាប់សម្លេងវិតក្កវិចារៈ គឺ ស្តាប់សម្លេងមមីមមើរបស់មនុស្សដេកលក់ របស់មនុស្សប្រមាទ រអ៊ូរទាំដែលកើតឡើងដោយកម្លាំងរបស់វិតក្កៈ រមែងទាយមានជាអាទិ៍ថា ចិត្តរបស់លោកយ៉ាងដូច្នេះ ដោយអំណាចនៃសម្លេងដែលកើតដល់អ្នកវិតក្កៈ ។

បទថា **អវិតក្កំ វិចារំ សមាធិំ** សមាធិដែលមិនមានវិតក្កៈ មិនមានវិចារៈ លោកពោលសម្តែងការអាចក្នុងការដឹងចិត្ត ដែលស្ងប់ប្រាសចាកវិតក្កវិចារៈ និងការកម្រើក តែមិនត្រូវពោលក្នុងការដឹងចិត្តដ៏សេស ។ បទថា **ចេតសា ចេតោ បរិច្ច បជានាតិ** កំណត់ចិត្តដោយចិត្តរមែងដឹង ជាការបានចេតោបរិយញ្ញាណ ។ បទថា **កោតោ**

គឺ អ្នកចម្រើន ។ បទថា **មនោសង្ខារា បណិហិតា** តាំងមនោសង្ខារទុក គឺ តាំងចិត្តសង្ខារទុក ។ បទថា **អមុន្នាម វិតក្កំ វិតក្កេស្សតិ** នឹងនឹក គិតដល់វិតក្កៈឈ្មោះនុ៎ះ គឺ រមែងដឹងថា នឹងនឹកគិត នឹងប្រព្រឹត្តវិតក្កៈ មានកុសលវិតក្កៈជាដើម ម្យ៉ាងទៀត កាលដឹងដោយការចូលដល់ រមែងដឹងដោយចំណែកខាងដើម ពិនិត្យមើលចិត្តក្នុងខាងក្នុងសមាបត្តិ ហើយដឹង រមែងដឹងថា ភិក្ខុនោះផ្តើមកសិណភាវនា ញុំាងបឋមឈាន ទុតិយឈានជាដើម ឬញុំាងសមាបត្តិ ៨ ឲ្យកើត ដោយអាការណា ការបរិកម្មកសិណនោះឯង ឈ្មោះថា រមែងដឹង ដោយការចូលដល់ កាលផ្តើមបឋមវិបស្សនារមែងដឹង រមែងដឹងថា ភិក្ខុនោះផ្តើមវិបស្សនា ញុំាងសោតាបត្តិមគ្គឲ្យកើត ។ល។ ឬញុំាងអរហត្តមគ្គឲ្យកើត ដោយអាការណា ឈ្មោះថា រមែងដឹងដោយចំណែកខាងដើម រមែងដឹងថា មនោសង្ខារតាំងនៅដល់ចិត្តនេះ ភិក្ខុនឹងពិចារណាដល់ចិត្ត ឈ្មោះថា នេះក្នុងលំដាប់នៃចិត្តឈ្មោះនេះ ឬកាលភិក្ខុចេញចាកចិត្តនេះ សមាធិដែលជាចំណែកនៃការសាបសូន្យនឹងមាន នឹងឲ្យសមាធិដែលជាចំណែកនៃការតាំងនៅ ដែលជាចំណែកនៃសេចក្តីវិសេស ដែលជាចំណែកនៃការទម្លាយ ឬអភិញ្ញាដោយអាការណា ឈ្មោះថា ពិនិត្យមើលចិត្ត ក្នុងខាងក្នុងសមាបត្តិ ហើយដឹង ។ បទថា **ពហុព្ចេបិ**



**អាទិសតិ** ដល់សូម្បីភិក្ខុនោះទាយចិត្តទុកដ៏ច្រើន គឺ ដល់ សូម្បីពោលទុកជាចំណែកច្រើនដោយប្រភេទ ១៦ មានសរាគៈជាដើម ព្រោះធ្វើចេតោបរិយញ្ញាណឲ្យជាអារម្មណ៍នៃចិត្ត និងចេតសិក គប្បីជ្រាបថាមិនមែនដោយអំណាចយ៉ាងដទៃ ។ បទថា **តថេវ តំ ហោតិ** ការទាយចិត្តនោះ ក៏ជាយ៉ាងនោះ គឺ ការដឹងដោយចេតោបរិយញ្ញាណ ក៏យ៉ាងនោះ ដោយចំណែកតែមួយ មិនមានដោយប្រការដទៃ ។ បទថា **ឯវំ វិតក្កេថ** ចូរត្រិះរិះយ៉ាងនេះ គឺ ចូរត្រិះរិះញុំាងនេក្ខម្មវិតក្កៈជាដើម ឲ្យប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **មា ឯវំ វិតក្កយិត្ថ** ចូរកុំត្រិះរិះយ៉ាងនេះ គឺ ចូរកុំត្រិះរិះឲ្យកាមវិតក្កៈជាដើម ប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **ឯវំ មនសិករោថ** ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ គឺ ចូរធ្វើទុកក្នុងចិត្តនូវអនិច្ចសញ្ញា ឬក្នុងទុក្ខសញ្ញាជាដើមណាមួយ ។ បទថា **មា ឯវំ មនសាករិត្ថ** ចូរកុំធ្វើទុកក្នុងចិត្តយ៉ាងនេះ គឺ ចូរកុំធ្វើទុកក្នុងចិត្ត ដោយន័យមានជាអាទិ៍ថា ទៀងជាដើមយ៉ាងនេះ ។ បទថា **ឥទំ បជហថ** ចូរលះធម៌នេះ គឺ ចូរលះកាមគុណ ៥ និងរាគៈជាដើមនេះ ។ បទថា **ឥទំ ឧបសម្បជ្ជ វិហរថ** ចូរចូលដល់ធម៌នេះចុះ គឺ ចូរធ្វើឲ្យសម្រេចលោកុត្តរធម៌ ដែលមានប្រភេទជាមគ្គ ៤ ផល ៤ នេះចុះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងបរិយាយដទៃក្នុងឥទ្ធិបាដិហារិយដោយវិសេស ទើបពោលពាក្យមានជាអាទិ៍ថា **នេក្ខម្មំ ឥជ្ឈតីតិ ឥទ្ធិ** ឈ្មោះថា ឥទ្ធិ ព្រោះនេក្ខម្មៈ រមែងសម្រេចក្នុងបទទាំងនោះ ។ បទថា **កាមច្ឆន្ទំ បដិហរតិ** នេក្ខម្មៈរមែងកម្ចាត់កាមច្ឆន្ទៈបាន គឺ នេក្ខម្មៈមានកម្លាំងចំពោះ រមែងនាំចេញ គឺ លះកាមច្ឆន្ទៈដែលជាបដិបក្ខរបស់ខ្លួន ព្រោះហេតុនោះ នេក្ខម្មៈនោះឯងទើបឈ្មោះថា **បាដិហារិយ** ។ បទថា **យេ តេន នេក្ខម្មេន សមន្នាគតា** ជនពួកណាប្រកបដោយនេក្ខម្មៈនោះ គឺ បុគ្គលពួកណាប្រកបដោយនេក្ខម្មៈនោះ នាំកាមច្ឆន្ទៈចេញទៅយ៉ាងនេះ ដោយការបានចំពោះ ។ បទថា **វិសុទ្ធចិត្តា** គឺ មានចិត្តបរិសុទ្ធ ព្រោះមិនមានកាមច្ឆន្ទៈ ។ បទថា **អនាវិលសង្កប្បា** មានការត្រិះរិះមិនល្អក់ គឺ មានការត្រិះរិះក្នុងនេក្ខម្មៈមិនល្អក់ ដោយការត្រិះរិះដល់កាម ។ បទថា **ឥតិ អាទេសនាបាដិហារិយំ** ព្រោះហេតុនោះ នេក្ខម្មៈទើបជាអាទេសនាបាដិហារ្យ គឺ នេក្ខម្មៈជាអាទេសនាបាដិហារ្យយ៉ាងនេះ ដោយចិត្តដទៃជាកុសល ដោយព្រះសម្មាសម្ពុទ្ធជាម្ចាស់ដទៃ ឬដោយព្រះពុទ្ធសាវកទាំងឡាយ ។

ម្យ៉ាងវិញទៀត គប្បីប្រកបធ្វើ **អាទេសនសព្ទ** ឲ្យជាបាឋៈ



ដ៏សេស ព្រោះហេតុនោះ ការទាយចិត្តយ៉ាងនេះ ឈ្មោះថា អាទេសនាបាដិហារិយ ។ បទថា **ឯវំ អាសេវិតព្វំ** គប្បីសេពយ៉ាងនេះ គឺ គប្បីសេពដោយប្រការនេះអំពីខាងដើម ក្នុង ៣ បទដ៏សេស ក៏មានន័យនេះដូចគ្នា បទថា **តទនុធម្មតា សតិ ឧបដ្ឋាបេតព្វា** គប្បីតាំងសតិជាធម្មតាតាមសមគួរ គឺ គប្បីតាំងសតិដែលឧបត្ថម្ភនេក្ខម្មៈនោះឲ្យក្រៃលែង បទថា **ឥតិ អនុសាសនីបាដិហារិយំ** ព្រោះហេតុនោះ នេក្ខម្មៈទើបជាអនុសាសនីបាដិហារិយៈនេះ គប្បីធ្វើការប្រកបដូចដែលការប្រកបអាទេសនាបាដិហារិយៈ សូម្បីក្នុងព្យាបាទជាដើម ក៏មានន័យនេះដូចគ្នា តែបាឋៈលោកសង្ខេបឈានជាដើម ហើយសម្តែងអរហត្តមគ្គទុកក្នុងទីបំផុត គប្បីជ្រាបថា លោកពោលបទមានជាអាទិ៍ថា **ឯវំ អាសេវិតព្វោ** គប្បីសេពយ៉ាងនេះ ដោយជាចំណែកខាងដើមនៃមគ្គ ព្រោះប្រព្រឹត្តទៅក្នុងខណៈចិត្ត មួយដួង ពិតណាស់ គប្បីជ្រាបថា កាលញ៉ាំងមគ្គឲ្យកើតដោយវិបស្សនា ដែលជាវុដ្ឋានគាមិនី ពោលគឺលោកិយមគ្គដែលជាចំណែកខាងដើមនៃមគ្គ កាលធ្វើអាសេវនៈជាដើមហើយ សូម្បីមគ្គកើតឡើងដោយវិបស្សនានោះ ក៏ជាឈ្មោះថា សេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ។ ចំណែកអាចារ្យអ្នកជាសព្វត្ថិកវាទ (មានវាទៈគ្រប់យ៉ាងមានប្រយោជន៍) ពោលថា មគ្គមួយ ៗ

មាន ១៦ ខណៈ តែការតាំងសតិជាធម្មតាតាមសមគួរដល់មគ្គនោះ រមែងព្យាយាមក្នុងចំណែកខាងដើមប៉ុណ្ណោះ ។ ដើម្បីសម្តែងសេចក្តីនៃបទថា **ឥទ្ធិបាដិហារិយំ** ជាកម្មធារយសមាស លោកទើបពោលបទមានជាអាទិ៍ថា **នេក្ខម្មំ ឥជ្ឈតីតិ ឥទ្ធិ** ម្តងទៀត កាលលោកពោលសេចក្តីដែល ឥទ្ធិបាដិហារិយៈជាសមាសក្នុង ៣ បាដិហារិយៈ ដូចពោលហើយក្នុងព្រះសូត្រ ក៏ជាការពោលដល់ សូម្បីបាដិហារិយៈ ២ ដ៏សេសផង ព្រោះហេតុនោះគប្បីជ្រាបថា លោកពោលអត្ថនៃសមាសរបស់ឥទ្ធិបាដិ-ហារិយៈ ដែលជាបទដើមក្នុងបរិយាយនេះឯង ។

(ចប់អដ្ឋកថា ចាដិហារិយកថា)



## ៧–អដ្ឋកថា សមសីសកថា

ឥឡូវនេះ ដើម្បីសម្តែងសេចក្តីដ៏ត្រង់នៃសមសីសៈ ( រំលត់កិលេសព្រម និងជីវិត ) សង្គ្រោះចូលក្នុងឥទ្ធិបាដិហារិយៈដែលជាបាដិហារិយៈខាងដើម ក្នុងលំដាប់នៃបាដិហារិយកថា ថា ជាឥទ្ធិបា-ដិហារិយៈ ព្រះសារីបុត្តត្ថេរទើបពោលសមសីសកថា ( ធម៌ស្មើការស្ងប់ សីសធម៌ ធម៌ជាចំណែកសំខាន់ ) ទុក សូម្បីលោកសម្តែងទុកហើយក្នុងញាណកថា ដោយសម្ពន្ធ និងបាដិហារិយៈទៀត ។ ការពណ៌នាសេចក្តីសមសីសកថានោះ លោកពោលទុកហើយក្នុងញាណ-កថានោះឯង ដោយប្រការដូច្នេះ ។

(ចប់អដ្ឋកថា សមសីសកថា)

## ៨–អដ្ឋកថា សតិប្បដ្ឋានកថា

ឥឡូវនេះ នឹងពណ៌នាតាមសេចក្ដីដែលនៅមិនធ្លាប់ពណ៌នា នៃសតិប្បដ្ឋានកថា ដែលមានព្រះសូត្រជាខាងដើម ដែលព្រះដ៏មានព្រះ-ភាគជាម្ចាស់ទ្រង់សម្ដែងអនុបស្សនាជាវិសេស ៧ យ៉ាង លើកឥទ្ធិ-បាដិហារិយៈ ដែលព្រះអង្គត្រាស់ហើយក្នុងលំដាប់សមសីសកថា ជាតួយ៉ាង ។

គប្បីជ្រាបសេចក្ដីក្នុងព្រះសូត្រនោះមុន បទថា **ចត្តារោ** សតិប្បដ្ឋាន ៤ ជាការកំណត់ចំនួន ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្ដែងការកំណត់សតិប្បដ្ឋានទុកថា មិនតិចជាងនោះ មិនច្រើនជាងនោះ ។ បទថា **ឥមេ** នេះ ជាបទបង្ហាញឲ្យឃើញវត្ថុដែលគួរបង្ហាញឲ្យឃើញ ។ បទថា **ភិក្ខវេ** ជាពាក្យត្រាស់ហៅបុគ្គលអ្នកទទួលធម៌ ។ បទថា **សតិប្បដ្ឋានា** គឺ សតិប្បដ្ឋាន ៣ យ៉ាង បានដល់សតិជាគោចរ ១ សេចក្ដីដែលព្រះសាស្ដា ទ្រង់ធ្វងផុតការស្រឡាញ់និងការស្អប់ ក្នុងសាវ័កទាំងឡាយអ្នកបដិបត្តិ ៣ យ៉ាង ១ និងសតិ ១ ។

សតិគោចរៈ លោកពោលថា **សតិប្បដ្ឋាន** មកក្នុងព្រះបាលី



មានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងការកើត និងការរលត់ទៅនៃសតិប្បដ្ឋាន ៤ ។ បទនោះមានអធិប្បាយថា ឈ្មោះថា **បដ្ឋាន** ព្រោះជាទីតាំង អ្វីតាំង សតិតាំង ការតាំងសតិ ឈ្មោះថា **សតិប្បដ្ឋាន** ។

ការកន្លងល្មើសពាក្យណែនាំដោយការជាប់ចិត្តរបស់សាស្ដា ក្នុងសាវ័កអ្នកបដិបត្តិ លោកពោលថា **សតិប្បដ្ឋានំ** ក្នុងព្រះបាលីនេះថា គប្បីជ្រាបការតាំងសតិ ៣ ប្រការ ដែលព្រះអរិយៈសេព កាលដែលសេពឈ្មោះថា ជាសាស្ដាគួរដើម្បីប្រៀនប្រដៅពួក ។ បទនោះមានអធិប្បាយថា ឈ្មោះថា **បដ្ឋាន** ព្រោះគួរតាំងទុក អធិប្បាយថា គួរប្រព្រឹត្ត គួរតាំងទុកដោយអ្វី ដោយសតិ ការតាំងទុកដោយសតិ ឈ្មោះថា **សតិប្បដាន** ។

មយ៉ាងទៀត **សតិ** នោះឯងលោកពោលថា **សតិប្បដ្ឋាន** មកក្នុងព្រះបាលីមានជាអាទិ៍ថា សតិប្បដ្ឋាន ៤ ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងញុំាងពោជ្ឈង្គៈ ៧ ឲ្យបរិបូរណ៍ ។ បទនោះមានអធិប្បាយថា ឈ្មោះថា **បដ្ឋានំ** ព្រោះរមែងតាំងទុក សេចក្ដីថា តាំងទុក ឈានទៅ ស្ទុះទៅហើយ ប្រព្រឹត្តទៅហើយ សតិនោះឯងតាំងទុក ឈ្មោះថា **សតិប្បដ្ឋាន** ។

ម្យ៉ាងវិញទៀត ឈ្មោះថា **សតិ** ព្រោះអត្ថថា ជាទីរលឹក ឈ្មោះថា **ឧបដ្ឋាន** ព្រោះអត្ថថា ជាទីចូលទៅតាំងទុក ព្រោះហេតុនោះ ឈ្មោះថា **សតិប្បដ្ឋាន** ព្រោះសតិចូលទៅតាំងទុកខ្លះ ។ នេះជាសេចក្ដីបំណាងក្នុងទីនេះ ។ បើសួរថា ព្រោះហេតុអ្វី ទើបធ្វើជាពហុវចនៈថា **សតិប្បដ្ឋានា** ។ ព្រោះមានសតិច្រើន ។ ពិតណាស់ កាលពោលដោយប្រភេទនៃអារម្មណ៍ សតិទាំងនោះមានច្រើន ។ បទថា **កតមេ ចត្តារោ** ៤ ប្រការ តើដូចម្ដេច ជាកថេតុកម្យតាបុច្ឆា សួរដើម្បីឆ្លើយខ្លួនឯង ។ បទថា **ឥធ** គឺ ក្នុងព្រះសាសនានេះ ។ បទថា **ភិក្ខុ** ឈ្មោះថា ភិក្ខុ ព្រោះឃើញភ័យក្នុងសង្សារ ។ ក៏ការពណ៌នាសេចក្ដី នៃបទដ៏សេសក្នុងគាថានេះ លោកពោលទុកហើយក្នុងអដ្ឋកថាមគ្គសច្ចនិទ្ទេស ក្នុងសុតមយញ្ញាណកថា ។

ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់សតិប្បដ្ឋាន ៤ មិនតិចជាង មិនច្រើនជាង ។ ព្រោះដើម្បីប្រយោជន៍ដល់វេនេយ្យសត្វ ព្រោះកាលតណ្ហាចរិត ទិដ្ឋិចរិត សមថយានិក វិបស្សនាយានិក ប្រព្រឹត្តទៅហើយដោយពីរចំណែក ដោយការទន់ខ្សោយ និងការចាស់ក្លា កាយានុបស្សនាសតិប្បដ្ឋាន យ៉ាងគ្រោតគ្រាតជាផ្លូវបរិសុទ្ធរបស់តណ្ហាចរិត និងទន់ខ្សោយ , វេទនានុបស្សនាសតិប្បដ្ឋាន



យ៉ាងល្អិតជាផ្លូវបរិសុទ្ធរបស់អ្នកចាស់ក្លា , ចិត្តានុបស្សនាសតិប្បដ្ឋាន ដែលមានប្រភេទមិនច្រើនពេក ជាផ្លូវបរិសុទ្ធរបស់អ្នកមានទិដ្ឋិចរិត និងទន់ខ្សោយ , ធម្មានុបស្សនាសតិប្បដ្ឋាន ដែលមានច្រើនប្រភេទ ជាផ្លូវបរិសុទ្ធរបស់អ្នកមានទិដ្ឋិចរិត និងចាស់ក្លា ។ សតិប្បដ្ឋានប្រការទី ១ ជានិមិត្តគួរដល់ដោយមិនលំបាក ជាផ្លូវបរិសុទ្ធរបស់អ្នកជាសមថយានិកទន់ខ្សោយ ។ សតិប្បដ្ឋានប្រការទី ២ ជាផ្លូវបរិសុទ្ធរបស់អ្នកជាសមថយានិកចាស់ក្លា ព្រោះមិនតាំងនៅក្នុងអារម្មណ៍គ្រោតគ្រាត ។ សតិប្បដ្ឋានប្រការទី ៣ មានប្រភេទមិនច្រើនពេក ជាអារម្មណ៍ ជាផ្លូវបរិសុទ្ធរបស់អ្នកជាវិបស្សនាយានិកទន់ខ្សោយ ។ សតិប្បដ្ឋានប្រការទី ៤ មានច្រើនប្រភេទជាអារម្មណ៍ ជាផ្លូវបរិសុទ្ធរបស់អ្នកជាវិបស្សនាយានិកចាស់ក្លា ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់សតិប្បដ្ឋាន ៤ ទុកមិនតិចជាង មិនច្រើនជាង ។

ម្យ៉ាងវិញទៀត ដើម្បីលះការសម្គាល់ខុសថា ជារបស់ស្អាត ជាសុខ ជារបស់ទៀង និងជារបស់តួខ្លួន ព្រោះថា កាយជារបស់មិនស្អាត ។ ម្យ៉ាងទៀត សត្វទាំងឡាយមានការសម្គាល់ខុសក្នុងកាយនោះថា ជារបស់ស្អាត ដើម្បីលះការសម្គាល់ខុសនោះ នៃសត្វ

ទាំងនោះ ដោយឃើញភាពជារបស់មិនស្អាតក្នុងកាយនោះ ទើបត្រាស់សតិប្បដ្ឋានប្រការទី ១ ។ ម្យ៉ាងទៀត ព្រះអង្គត្រាស់ដល់ទុក្ខវេទនាក្នុងវេទនាជាដើម ដែលសត្វប្រកាន់ថា ជាសុខ ជារបស់ទៀង ជាតួខ្លួន ព្រះអង្គត្រាស់ថា ចិត្តជាធម្មជាតមិនទៀង ធម៌ជាអនត្តា សត្វទាំងឡាយនៅមានការសម្គាល់ខុស ក្នុងវត្ថុទាំងនោះថា ជាសុខ ជារបស់ទៀង ជាតួខ្លួន ដើម្បីលះការសម្គាល់ខុសទាំងនោះ របស់សត្វទាំងនោះ ដោយសម្ដែងដល់ភាពជាទុក្ខជាដើមក្នុងវត្ថុនោះ ព្រះអង្គទើបត្រាស់សតិប្បដ្ឋាន ៣ ដ៏សេស ព្រោះហេតុនោះ ព្រះដ៏មាន-ព្រះភាគជាម្ចាស់ ទើបត្រាស់សតិប្បដ្ឋាន ៤ ដើម្បីលះការសម្គាល់ខុសថា ជារបស់ស្អាត ជាសុខ ជារបស់ទៀង ជាតួខ្លួន ដោយប្រការដូច្នេះ មិនមែនដើម្បីលះការសម្គាល់ខុសតែម្យ៉ាងប៉ុណ្ណោះទេ ដើម្បីលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឧបាទាន ៤ និងអគតិ ៤ ខ្លះ ដើម្បីកំណត់ដឹងអាហារ ៤ យ៉ាងខ្លះ គប្បីជ្រាបថា ព្រះអង្គទើបត្រាស់សតិប្បដ្ឋាន ៤ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះ ។ បទថា **បឋវីកាយំ** កងបឋវីធាតុ គឺ ធាតុដីក្នុងកាយនេះ ។ ដោយសង្គ្រោះបឋវីធាតុទាំងអស់ ព្រោះបឋវីធាតុក្នុងកាយទាំងអស់មានច្រើន លោក



ទើបប្រើ **កាយ** សព្ទ ដោយអត្ថថា ជាទីរួម ។

សូម្បីកងអាបោធាតុជាដើម ក៏មានន័យនេះដូចគ្នា ។ លោកប្រើគំនរសក់ជាដើម ព្រោះគំនរសក់ជាដើមមានច្រើន ។ ម្យ៉ាងទៀត បទថា **វគ្គ** ទាចជាដើម ព្រោះកំណត់ទុកហើយទើបមិនប្រើ **កាយ** ព្រោះហេតុនោះ គប្បីជ្រាបថា លោកទើបមិនប្រើ **កាយ** នៃវគ្គៈជាដើមនោះ ។

គប្បីជ្រាបសេចក្ដីក្នុងបទមានជាអាទិ៍ថា **សុខំ វេទនំ** ដូចតទៅនេះ ។ បទថា **សុខំ វេទនំ** សុខវេទនា បានដល់ សុខវេទនាផ្លូវកាយ ឬផ្លូវចិត្ត ។ ទុក្ខវេទនាក៏យ៉ាងនោះ ។ ចំណែកបទថា **អទុក្ខមសុខំ វេទនំ** បានដល់ ឧបេក្ខាវេទនាផ្លូវចិត្តប៉ុណ្ណោះ ។ បទថា **សាមិសំ សុខំ វេទនំ** សុខវេទនាលាយអាមិស គឺ សោមនស្សវេទនាអាស្រ័យផ្ទះ ៦ ។ បទថា **និរាមិសំ សុខំ វេទនំ** សុខវេទនាមិនលាយអាមិស បានដល់ សោមនស្សវេទនាអាស្រ័យនេក្ខម្មៈ ៦ ។ បទថា **សាមិសំ ទុក្ខំ វេទនំ** ទុក្ខវេទនាលាយអាមិស បានដល់ ទោមនស្សវេទនាអាស្រ័យផ្ទះ ៦ ។ បទថា **និរាមិសំ ទុក្ខំ វេទនំ** ទុក្ខវេទនាមិនលាយអាមិស បានដល់ ទោមនស្សអាស្រ័យនេក្ខម្មៈ ៦ ។ បទថា **សាមិសំ អទុក្ខមសុខំ វេទនំ** អទុក្ខមសុខវេទនាលាយអាមិស បានដល់ ឧបេក្ខា-

វេទនាអាស្រ័យផ្ទះ ៦ ។ បទថា **និរាមិសំ អទុក្ខមសុខំ វេទនំ** អទុក្ខមសុខវេទនាមិនលាយអាមិស បានដល់ ឧបេក្ខាវេទនាអាស្រ័យនេក្ខម្មៈ ៦ ។ បទមានជាអាទិ៍ថា **សរាគំ ចិត្តំ** ចិត្តមានរាគៈ មានអត្ថដូចពោលហើយក្នុងញាណកថា ។ បទថា **តទវសេសេ ធម្មេ** ក្នុងធម៌ដ៏សេសពីនោះ គឺ ក្នុងធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសពីកាយវេទនា និងចិត្តប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ក្នុងបទទាំងពួង បទថា **តេន ញាណេន** គឺ ដោយអនុបស្សនាញាណ ៧ យ៉ាងនោះ ។ ម្យ៉ាងទៀត បទពួកណាមានអត្ថមិនបានពោលទុកក្នុងចន្លោះ ៗ ក្នុងកថានេះ បទទាំងនោះ មានអត្ថដូចបានពោលហើយក្នុងកថានោះ ៗ ក្នុងខាងក្រោយនោះឯង ដោយប្រការដូច្នេះ ។

(ចប់ អដ្ឋកថាសតិប្បដ្ឋានកថា)



## ៩-អដ្ឋកថាវិបស្សនាកថា

គប្បីជ្រាប នឹងពណ៌នាតាមសេចក្តីដែលនៅមិនធ្លាប់ពណ៌នា នៃវិបស្សនាកថា ដែលមានព្រះសូត្រជាខាងដើម ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងប្រភេទនៃវិបស្សនា ក្នុងលំដាប់នៃសតិប្បដ្ឋានកថា បដិសំយុត្តដោយវិបស្សនាត្រាស់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រនោះមុនដូចតទៅនេះ បទថា **សោ** ព្រោះជាសព្វនាម ទើបជាការសង្គ្រោះភិក្ខុសូម្បីទាំងអស់ដែលមានហើយ ។ បទថា **វត** ជានិបាតចុះក្នុងអត្ថឯកង្ស ( ធ្វើបទឲ្យពេញ ) ។ បទថា **កញ្ចិ សង្ខារំ** សង្ខារណា ៗ គឺ សង្ខារសូម្បីមានប្រមាណតិច ។ ក្នុងបទថា **អនុលោមិកាយ ខន្តិយា** ដោយអនុលោមខន្តិនេះ មានសេចក្តីដូច្នេះ ។ ឈ្មោះថា **អនុលោមិក** ព្រោះវិបស្សនានោះឯងរមែងអនុលោមលោកុត្តរមគ្គ ឈ្មោះថា អនុលោមិកា ព្រោះសម្ងឹងដល់ខន្តិនោះឯង ឈ្មោះថា **ខន្តិ** ព្រោះសង្ខារទាំងពួង រមែងពេញចិត្ត រមែងចូលចិត្តដល់ភិក្ខុនោះ ដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ ដោយភាពជាអនត្តា ។ ខន្តិនោះមាន ៣ យ៉ាង គឺ ទន់ខ្ចី ១ យ៉ាងកណ្តាល ១ យ៉ាងចាស់ក្លា ១ ខន្តិមានការពិចារណាជាកលាបៈ

( សំនុំ ) ជាខាងដើម មានឧទយព្វយញ្ញាណជាទីបំផុត ជាអនុលោមខន្តិទន់ខ្ចី ខន្តិមានការពិចារណាដល់ការរលត់ជាខាងដើម មានសង្ខារុបេក្ខាញ្ញាណជាទីបំផុត ឈ្មោះថា អនុលោមខន្តិយ៉ាងកណ្តាល ខន្តិជាអនុលោមញ្ញាណ ( ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងអរិយសច្ចៈ ) ឈ្មោះថា អនុលោមខន្តិយ៉ាងចាស់ក្លា ។ បទថា **សមន្នាគតោ** ប្រកបហើយ គឺ ចូលដល់ហើយ ។ បទថា **នេតំ ឋានំ វិជ្ជតិ** ប្រការនេះមិនជាឋានៈដែលនឹងមានបាន គឺ មិនជាឋានៈ មិនជាហេតុដែលនឹងមានបានតាមសេចក្តីដែលពោលហើយ ។ ក្នុងបទនេះថា **សម្មត្តនិយាមំ** សម្មត្តនិយាម ( ភាពត្រឹមត្រូវ និងទៀង ) នេះ មានសេចក្តីដូច្នេះ ។ ឈ្មោះថា **សម្មត្តា** ព្រោះជាសភាវៈពិត ដោយសេចក្តីសង្ឃឹមយ៉ាងនេះថា នឹងនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់យើងដោយសេចក្តីចម្រើនយ៉ាងនោះ នឹងដោយប្រាកដការប្រព្រឹត្តទៅដែលមិនវិបរិតក្នុងវត្ថុមិនស្អាតជាដើមថា ជារបស់ស្អាត ឈ្មោះថា **និយាមោ** ព្រោះជាសេចក្តី ពិតប្រាកដដោយការឲ្យផលក្នុងលំដាប់ និងដោយការសម្រេចព្រះអរហត្ត សេចក្តីថា ការតាំងចិត្តពិតប្រាកដ ។ ឈ្មោះថា **សម្មត្តនិយាមោ** ព្រោះដោយសភាពត្រឹមត្រូវ និងទៀង ។ នោះគឺអ្វី គឺ លោកុត្តរមគ្គ តែដោយវិសេស ក៏គឺ សោតាបត្តិមគ្គ ។



ដោយហេតុនោះ លោកទើបពោលថា **និយតោ សម្ពោធិបរាយនោ** មានការត្រាស់ដឹងក្នុងកាលមុនពិត ព្រោះពិតដោយមគ្គនិយាមចុះកាន់សម្មត្តនិយាមនោះ ។ បទថា **ឱក្កមិស្សតិ** នឹង ឈានចុះ គឺ នឹងចូលទៅ អធិប្បាយថា ប្រការនោះមិនមែនឋានៈ ម្យ៉ាងទៀត គប្បីជ្រាបថា លោកមិនកាន់យកឋានៈនោះ ព្រោះគោត្រភូជាទីតាំងនៃអាវជ្ជនៈរបស់មគ្គ ហើយពោលដល់ការឈានចុះកាន់សម្មត្តនិយាម ក្នុងលំដាប់នៃអនុលោមខន្តិ ។

ម្យ៉ាងវិញទៀត ក្នុងមហាវិបស្សនា ១៨ គោត្រភូជាវិវដ្ដនានុបស្សនា ( ការពិចារណាដល់និព្វាន ) ហេតុនោះ ទើបជាការសង្គ្រោះចូលក្នុងអនុលោមិកខន្តិនោះឯង សូម្បីក្នុង ៤ សូត្រ ក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ដោយបទទាំងនេះ លោកពោល ៤ សូត្រទុកក្នុងឆក្កនិបាតថា ធម៌ ៦ យ៉ាង ដោយអំណាចអនុលោមិកខន្តិសម្មត្តនិយាម និងអរិយផល ៤ ជាសេចក្តីពិត សូត្រ ៤ សូត្រ រមែងមានដោយបក្ខទាំងពីរ គឺ កណ្ហបក្ខ និងសុក្ខបក្ខ ។

ព្រះយោគាវចរអ្នកផ្តើមវិបស្សនា ដោយការពិចារណាកលាបៈកំណត់នាមរូប និងបច្ច័យនៃនាមរូប ក្នុងបទមានជាអាទិ៍ថា **បញ្ចក្ខន្ធេ អនិច្ចតោ** ពិចារណាឃើញបញ្ចក្ខន្ធដោយភាពជារបស់មិនទៀង ក្នុង

សុត្តន្តនិទ្ទេស ដែលមានពាក្យសួរជាដើមថា **កតីហាការេហិ** ដោយអាការប៉ុន្មាន ហើយឃើញថា ខន្ធមួយ ៗ ក្នុងខន្ធ ៥ មិនទៀងដោយភាពជារបស់មិនទៀង ព្រោះប្រាកដហើយ និងព្រោះមានខាងដើម និងទីបំផុត ។

មានសភាពជាទុក្ខ ព្រោះមានការកើតរលត់ និងបៀតបៀន និងព្រោះជាទីតាំងនៃទុក្ខ ។

មានសភាពជារោគ ព្រោះញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយបច្ច័យ និងព្រោះជាហេតុនៃរោគ ។

មានសភាពជាបូស ព្រោះប្រកបដោយសេចក្តីទុក្ខ និងសេចក្តីចាក់ដោត ព្រោះអសុចិ គឺ កិលេសហូរចេញ និងព្រោះហើមប៉ោង ហើយបែកធ្លាយដោយកើត ចាស់ និងរលត់ ។

មានសភាពដូចជាកូនសរ ព្រោះឲ្យកើតការបៀតបៀន ព្រោះចាក់ដោតខាងក្នុង និងព្រោះនាំចេញបានលំបាក ។

មានសភាពលំបាក ព្រោះគួរតិះដៀល ព្រោះនាំការមិនចម្រើនមកឲ្យ និងសេចក្តីអាក្រក់ថោកទាប ។

មានសភាពអាពាធ ព្រោះឲ្យកើតការមិនមានសេរី និងព្រោះជាទីតាំងនៃអាពាធ ។



មានសភាពជារបស់ដទៃ ព្រោះមិនមានអំណាច និងមិនជឿមិនស្តាប់បង្គាប់ ។

មានសភាពជារបស់វិនាស ដោយជរាព្យាធិ និងមរណៈ ។

មានសភាពជារបស់ចង្រៃ ព្រោះនាំសេចក្តីវិនាសមិនតិចមកឲ្យ ។

មានសភាពជាឧបទ្រព ព្រោះនាំសេចក្តីវិនាសច្រើនយ៉ាងដែលមិនដឹងហើយមកឲ្យ និងព្រោះជាវត្ថុនៃអន្តរាយទាំងពួង ។

មានសភាពជាភ័យ ព្រោះជាអណ្តូងកើតនៃភ័យទាំងពួង និងព្រោះជាបដិបក្ខនៃការដកដង្ហើមចូលជាយ៉ាងក្រៃលែង ពោលគឺ ស្ងប់បានលំបាក ។

មានសភាពជាឧបសគ្គ ព្រោះត្រូវសេចក្តីវិនាសមិនតិចជាប់តាមព្រោះទាក់ទងដោយទោសៈ និងព្រោះខំអត់មិនបានដូចឧបសគ្គ ។

មានសភាពញាប់ញ័រ ព្រោះញាប់ញ័រដោយជរា ព្យាធិ និងមរណៈ និងលោកធម៌ មានលាភជាដើម ។

មានសភាពបែកធ្លាយ ព្រោះចូលដល់ភាពបែកធ្លាយ ដោយព្យាយាម និងដោយមុខនាទី ។

មានសភាពមិនទៀង ព្រោះវត្ថុដែលតាំងនៅធ្លាក់ទៅ និងព្រោះ

មិនមានភាពគង់វង្ស ។

មានសភាពជារបស់មិនមានអ្វីជ្រកកោន ព្រោះជ្រកកោនមិនបាន និងព្រោះមិនបានទទួលភាពក្សេមក្សាន្ត ។

មានសភាពជារបស់មិនមានអ្វីទីពួន ព្រោះមិនគួរដើម្បីជាប់ និងព្រោះសូម្បីវត្ថុដែលជាប់ ក៏មិនធ្វើការរារាំងបាន ។

មានសភាពមិនមានទីពឹង ព្រោះមិនមានវត្ថុដែលអាស្រ័យដែលនឹងជាសារៈក្នុងភាពខ្លាចបាន ។

មានសភាពជាទីវាល ព្រោះទំនេរពីការទៀង ការសុខ និងអាហារឆ្ងាញ់តាមដែលកំណត់ទុក ។

មានសភាពជារបស់ទទេ ព្រោះជារបស់ទំនេរនោះឯង ឬព្រោះជារបស់តិច ព្រោះវត្ថុសូម្បីតិច លោកក៏ពោលថា ជារបស់ទទេក្នុងលោក ។

មានសភាពជារបស់សោះសូន្យ ព្រោះប្រាសចាកម្ចាស់ ដែលនៅអាស្រ័យ អ្នកដឹង អ្នកធ្វើ អ្នកតាំងចិត្ត ។

មានសភាពជាអនត្តា ព្រោះខ្លួនឯងមិនជាម្ចាស់ជាដើម ។

មានសភាពជាទោស ព្រោះជាទុក្ខប្រចាំ និងការដែលទុក្ខជាទោស ។



មួយ៉ាងទៀត ឈ្មោះថា **អាទីនវោ** ព្រោះហុយទៅ គឺ ប្រព្រឹត្តទៅនៃទោសទាំងឡាយ បទនេះជាឈ្មោះរបស់មនុស្សខ្វះខាត ។

មួយ៉ាងទៀតសូម្បីខន្ធ ៥ ក៏ជាការខ្វះខាតដូចគ្នា ព្រោះហេតុនោះ ឈ្មោះថា ដោយភាពជាទោស ព្រោះដូចនឹងទោសនោះឯង ។

ដោយមានការប្រែប្រួលជាធម្មតា ព្រោះតាមប្រក្រតីក៏ប្រែប្រួលដោយពីរចំណែក គឺ ដោយជរា និងមរណៈ ។

ដោយភាពមិនមានសារៈ ព្រោះមិនមានកំលាំង និងព្រោះទម្លាយសេចក្តីសុខ ដូចគ្នានខ្លឹមសារៈ ។

មានសភាពជាហេតុនៃសេចក្តីលំបាក ព្រោះជាហេតុនៃសេចក្តីអាក្រក់ថោកទាប ។

មានសភាពដូចជាឃាតករ ព្រោះទំលាយសេចក្តីវិសាសៈដូចសត្រូវ មាត់និយាយថាជាមិត្រ ។

ដោយប្រាសចាកសេចក្តីចម្រើន ព្រោះអស់សេចក្តីចម្រើន និងសេចក្តីសម្បូរណ៍ ។

មានសភាពជារបស់មានអាសវៈ ព្រោះជាទីតាំងនៃអាសវៈ ។

ដោយភាពជារបស់ដែលបច្ច័យតាក់តែង ព្រោះហេតុបច្ច័យតាក់តែង ។

ដោយភាពជានុយរបស់មារ ព្រោះភាពជានុយរបស់មច្ចុមារ និងកិលេសមារ ។

មានសភាពជារបស់មានការកើត ចាស់ ឈឺ ស្លាប់ ជាធម្មតា ព្រោះមានជាតិ ជរា ព្យាធិ និងមរណៈ ជាប្រក្រតី ។

ដោយភាពជារបស់មានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីចង្អៀតចង្អល់ជាធម្មតា ព្រោះមានសេចក្ដីសោក សេចក្ដីខ្សឹក ខ្សួល និងសេចក្ដីចង្អៀតចង្អល់ជាហេតុ ។

ដោយភាពជារបស់មានសេចក្ដីសៅហ្មងជាធម្មតា ព្រោះការដែលតណ្ហា ទិដ្ឋិ ទុច្ចរិត និងសង្កិលេស ជាវិស័យធម្មតា ។

ម្យ៉ាងទៀត ក្នុងបទទាំងអស់នេះ គប្បីជ្រាបបាឋៈថា **បស្សតិ** ដូច្នេះ ។ បទថា **បញ្ចក្ខន្ធេ** ខន្ធ ៥ សូម្បីកាលពោលដោយចំណែករួម ក៏គប្បីជ្រាបថា លោកពោលពណ៌នាអត្ថដោយខន្ធមួយ ៗ ព្រោះមកផ្សេង ៗ គ្នា ក្នុងកលាបសម្មសននិទ្ទេស ព្រោះក្នុងទីបំផុតនៃចំនួនអនុបស្សនា ដោយអំណាចខន្ធទាំងឡាយផ្សេង ៗ គ្នា និងព្រោះមានការប្រព្រឹត្តទៅសូម្បីក្នុងចំណែកអវយវៈ នៃពាក្យដែលប្រព្រឹត្តទៅក្នុងចំណែករួមគ្នា ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា លោកពោលថា **បញ្ចក្ខន្ធេ** ដោយការសង្ខេបសម្មសនៈដែលប្រព្រឹត្តទៅផ្សេង ៗ



គ្នា រួមជាមួយគ្នា ។ ម្យ៉ាងទៀត ការពិចារណាខន្ធ ៥ ជាមួយគ្នា ព្រោះប្រាកដពាក្យក្នុងអដ្ឋកថាថា ដោយការប្រហារមួយគ្រា ខន្ធ ៥ ក៏ចេញទៅដូច្នេះ រមែងគួរតែម្យ៉ាង ។

បទថា **បញ្ចន្នំ ខន្ធានំ និរោធោ និច្ចំ និព្វានន្តិ បស្សន្តោ** កាលពិចារណាឃើញថា ការរលត់នៃបញ្ចក្ខន្ធជានិព្វានទៀង គឺ កាលពិចារណាឃើញថា និព្វានទៀង ដោយអំណាចនៃញាណដែលជាផ្លូវស្ងប់ ក្នុងកាលនៃវិបស្សនាតាមដែលពោលហើយ ក្នុងអាទីនវញ្ញាណនិទ្ទេស ។ បទថា **សម្មត្តនិយាមំ ឱក្កមតិ** រមែងឈានចុះកាន់សម្មត្តនិយាម គឺ រមែងឈានចុះក្នុងខណៈនៃមគ្គ ក៏ឈ្មោះថា ឈានចុះក្នុងខណៈនៃផលផង ក្នុងបរិយាយនៃការឈានចុះក្នុងនិយាមទាំងអស់ក៏មានន័យនេះដូចគ្នា ។ បទថា **អារោគ្យំ** គឺ ការមិនមានរោគ ។ បទថា **វិសល្លំ** គឺ ប្រាសចាកសរ ក្នុងបទនេះក៏មានន័យនេះដូចគ្នា ។ បទថា **អនាពាធំ** គឺ ប្រាសចាកអាពាធ ឬជាបដិបក្ខចំពោះអាពាធ ។ ក្នុងបទនេះ ក៏មានន័យនេះ បទថា **អបរបច្ចយំ** គឺ ប្រាសចាកបច្ច័យដទៃ អាចារ្យពួកខ្លះពោលប្រកបគ្នាថា **ឧបស្សគ្គតោតិ ច អនុបស្សគ្គន្តិ ច** ឃើញខន្ធ ៥ មានឧបសគ្គ និងនិព្វានមិនមានឧបសគ្គ ។ បទថា **បរមសុញ្ញំ** សូន្យយ៉ាងក្រៃលែង ឈ្មោះថាសូន្យយ៉ាងក្រៃលែង

ព្រោះសូន្យចាកសង្ខារទាំងអស់ និងព្រោះសូន្យយ៉ាងខ្ពង់ខ្ពស់ ។ បទថា **បរមត្ថំ** មានប្រយោជន៍យ៉ាងខ្ពង់ខ្ពស់ ព្រោះជារបស់ដ៏ប្រសើរជាងសង្ខាត និងអសង្ខត ជានបុំលិង្គ ព្រោះលិង្គវិបល្លាស ។ លោកមិនពោលបរិយាយដោយអនុលោមក្នុងបទទាំងពីរនេះ ព្រោះនិព្វានជារបស់សូន្យ និងព្រោះជាអនត្តា ។ បទថា **អនាសវំ** គឺ ប្រាសចាកអាសវៈ ។ បទថា **និរាមិសំ** គឺ ប្រាសចាកអាមិស ។ បទថា **អជាតំ** គឺ មិនកើតព្រោះប្រាសចាកការកើត ។ បទថា **អមតំ** គឺ ប្រាសចាកសេចក្តីស្លាប់ ព្រោះមិនស្លាប់ ។ ពិតណាស់ សូម្បីសេចក្តីស្លាប់ លោកក៏ពោលថា **មតំ** ព្រោះជានបុំសកលិង្គ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ធ្វើការសង្គ្រោះជាចំណែកតែមួយក្នុងអនុបស្សនា ៣ ដោយសង្គ្រោះតាមសភាវធម៌ក្នុងអនុបស្សនា ៤០ ដែលផ្សេងគ្នាដោយអាការដូចពោលហើយតាមលំដាប់នេះ ដោយប្រការដូច្នេះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **អនិច្ចតោតិ អនិច្ចានុបស្សនា** ការពិចារណាឃើញបញ្ចក្ខន្ធដោយភាពជារបស់មិនទៀង ជាអនិច្ចានុបស្សនា គប្បីប្រកបក្នុងភាពមិនទៀង ជាទុក្ខ ជាអនត្តា តាមសមគួរក្នុងអនុបស្សនាទាំងនោះ តែក្នុងទីបំផុតលោកសម្តែងអនុបស្សនាទាំងនោះ ដោយចំនួនផ្សេងគ្នា ។



ក្នុងបទទាំងនោះ បទថា **បញ្ចវីសតិ** ២៥ គឺ អនត្តានុបស្សនា ២៥ ក្នុងខន្ធ ៥ ធ្វើខន្ធមួយ ៗ ជា ៥ គឺ **បរតោ** (ជារបស់ដទៃ) ១ **រិត្តតោ** (ជារបស់ទទេ) ១ **តុច្ឆតោ** (ជារបស់ទំនេរ) ១ **សុញ្ញតោ** (ជារបស់សូន្យ) ១ **អនត្តតោ** ( ជាអនត្តា ) ១ ។

បទថា **បញ្ញាស** ៥០ គឺ អនិច្ចានុបស្សនា ៥០ ក្នុងខន្ធ ៥ ធ្វើខន្ធមួយ ៗ ជា ១០ គឺ **អនិច្ចតោ** ( ជារបស់មិនទៀង ) ១ **បលោកតោ** ( ដោយការបែកធ្លាយ ) ១ **ចលតោ** ( ញាប់ញ័រ ) ១ **បកង្គតោ** ( បែកធ្លាយ ) ១ **អទ្ធុវតោ** ( មិនទៀង ) ១ **វិបរិណាមធម្មតោ** ( ប្រែប្រួលជាធម្មតា ) ១ **អសារកតោ** ( មិន មានសារៈ ) ១ **វិភវតោ** ( ប្រាសចាកសេចក្តីចម្រើន ) ១ **សង្ខតោ** ( ដោយបច្ច័យប្រជុំតាក់តែង ) ១ **មរណធម្មតោ** ( មានសេចក្តីស្លាប់ជាធម្មតា ) ១ ។

បទថា **សតំ បញ្ចវីសតិ** ១២៥ គឺ ទុក្ខានុបស្សនា ១២៥ ក្នុងខន្ធ ៥ ធ្វើខន្ធមួយ ៗ ជា ២៥ មានជាអាទិ៍ថា **ទុក្ខតោ រោគតោ** ។ បទថា **យានិ ទុក្ខេ បវុច្ចរេ** គប្បីជ្រាបការភ្ជាប់សេចក្តីថា អនុបស្សនាដែលលោកពោលដោយអំណាចការធ្វើចំនួនខន្ធបញ្ចកៈ ជាទុក្ខ ១២៥ យ៉ាង ៗ ម្យ៉ាងទៀត ក្នុងបទថា **យានិ** នេះ គប្បីឃើញថាជាលិង្គវិបល្លាស ។

**( ចប់ អដ្ឋកថាវិបស្សនាកថា )**

## ១០–អដ្ឋកថា មាតិកាកថា

ឥឡូវនេះ ព្រះមហាថេរៈប្រាប្ថនានឹងសរសើរធម៌ គឺ សមថៈ វិបស្សនា មគ្គ ផល និព្វាន ដែលលោកសម្ដែងទុកហើយ ក្នុងបដិសម្ភិទាមគ្គទាំងអស់ ក្នុងលំដាប់នៃវិបស្សនាកថា ដោយបរិយាយផ្សេង ៗ ដោយសេចក្ដីផ្សេងគ្នានៃអាការ ទើបលើកបទមាតិកា ១៩ បទមានជាអាទិ៍ថា **និច្ឆាតោ** អ្នកមិនមានការស្រេកឃ្លាន ហើយពោលមាតិកាកថា ដោយសម្ដែងបទមាតិកាទាំងនោះ ។ បន្ទាប់ពីនេះទៅនឹងពណ៌នាតាមសេចក្ដីដែលមិនធ្លាប់ពណ៌នានៃមាតិកាកថានោះ គប្បីជ្រាបវិនិច្ឆ័យក្នុងមាតិកាសិន ។ បទថា **និច្ឆាតោ** គឺ អ្នកមិនមានការស្រេកឃ្លាន ។ ពិតណាស់ កិលេសសូម្បីទាំងអស់ ឈ្មោះថា **មិលិតា** ( ស្វិតស្រពោន ) ព្រោះប្រកបដោយការបៀតបៀន សូម្បីរាគៈដែលប្រព្រឹត្តទៅក្នុងលំដាប់ ក៏ដុតបំផ្លាញរាងកាយ នឹងនិយាយទៅថ្វីដល់កិលេសយ៉ាងដទៃ ។ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់កិលេស ៣ យ៉ាង ដែលជាតួរបស់កិលេសថា ម្នាលភិក្ខុទាំងឡាយ ភ្លើង ៣ យ៉ាង គឺ **រាគគ្គិ** ( ភ្លើងរាគៈ ) **ទោសគ្គិ** ( ភ្លើងទោសៈ ) **មោហគ្គិ** ( ភ្លើងមោហៈ ) ។ សូម្បីកិលេសដែលប្រកបដោយរាគៈ



ទោសៈ មោហៈ នោះ ក៏រមែងដុតបំផ្លាញដូចគ្នា ។ ឈ្មោះថា **និច្ឆាតោ** ព្រោះមិនមានកិលេសកើតហើយយ៉ាងនេះ អ្នកមិនមាន សេចក្ដីស្រេកឃ្លាននោះ តើដូចម្ដេច ។ គប្បីឃើញថា ការរួចផុតដោយការចងព័ន្ធនិងវិមោក្ខ ឈ្មោះថា **មោក្ខោ** ព្រោះរួច ឈ្មោះថា **វិមោក្ខោ** ព្រោះរួចផុត នេះជាបទមាតិកា ១ ។ បទថា **វិជ្ជាវិមុត្តិ** គឺ វិជ្ជានោះឯង គឺ វិមុត្តិ នេះជាបទមាតិកា ១ ។ បទថា **ឈានវិមោក្ខោ** គឺ ឈាននោះឯងជាវិមោក្ខ នេះជាបទមាតិកា ១ ។ បទមាតិកាដ៏សេសក៏ជាបទមួយ ៗ ព្រោះហេតុនោះ ទើបជាបទមាតិកា ១៩ ដោយប្រការដូច្នេះ ។

បទថា **នេក្ខម្មេន កាមច្ឆន្ទតោ និច្ឆាតោ** បុគ្គលអ្នកមិនមានសេចក្ដីស្រេកឃ្លាន រមែងរួចផុតចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ គឺ ព្រះយោគាវចរអ្នកមិនមានកិលេស រមែងរួចផុតចាកកាមច្ឆន្ទៈ ព្រោះប្រាសចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ សូម្បីនេក្ខម្មៈដែលព្រះយោគាវចរនោះបាន ក៏អស់សេចក្ដីស្រេកឃ្លាន មិនមានកិលេសជាការរួចផុតសូម្បីក្នុងបទដ៏សេសក៏យ៉ាងនោះ ។

បទថា **នេក្ខម្មេន កាមច្ឆន្ទតោ មុច្ចតីតិ វិមោក្ខោ** ឈ្មោះថា វិមោក្ខ ព្រោះផុតចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ គឺ ព្រះយោគាវចររមែង

ផុតចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ ព្រោះហេតុនោះ នេក្ខម្មៈនោះទើបជា
វិមោក្ខ សូម្បីក្នុងបទដ៏សេសក៏យ៉ាងនោះ ។

បទថា **វិជ្ជតីតិ វិជ្ជា** នេក្ខម្មៈ ឈ្មោះថា វិជ្ជា ព្រោះអត្ថថា
មានហើយ សេចក្ដីថា នេក្ខម្មៈឈ្មោះថា វិជ្ជា ព្រោះអត្ថថា មានហើយ
កាន់ចូលទៅបានដោយសភាវៈ ។ ម្យ៉ាងវិញទៀត នេក្ខម្មៈឈ្មោះថា
វិជ្ជា ព្រោះអត្ថថា ដែលព្រះយោគាវចរអ្នកបដិបត្តិ ដើម្បីដឹងសេចក្ដី
ពិត រមែងស្គាល់ រមែងដឹងសេចក្ដីពិត ។

ម្យ៉ាងវិញទៀត ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ដែលព្រះយោ-
គាវចរអ្នកបដិបត្តិ ដើម្បីបានគុណវិសេស រមែងស្គាល់ រមែងបាន ។

ម្យ៉ាងទៀត ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ព្រះយោគាវចររមែង
ប្រសព្វ រមែងបានភូមិដែលខ្លួនគួរប្រសព្វ ។

ម្យ៉ាងទៀត ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ព្រះយោគាវចររមែង
ធ្វើការដឹងច្បាស់សភាវធម៌ ព្រោះឃើញសភាវធម៌ជាហេតុ ។

បទថា **វិជ្ជន្តោ មុច្ចតិ មុច្ចន្តោ វិជ្ជតិ** ឈ្មោះថា វិជ្ជាវិមុត្តិ
ព្រោះអត្ថថា មានការរួចផុត ការរួចផុតមាន អធិប្បាយថា ឈ្មោះថា
វិជ្ជាវិមុត្តិ ព្រោះអត្ថថា ធម៌តាមដែលពោលហើយមាន ដោយអត្ថ
តាមដែលពោលហើយ រមែងរួចផុតចាកធម៌តាមដែលពោលហើយ



កាលរួចផុតចាកធម៌តាមដែលពោលហើយ រមែងមានដោយអត្ថ តាម
ដែលពោលហើយ ។

បទថា **កាមច្ឆន្ទំ សំវរដ្ឋេន** ដោយអត្ថថា ជាគ្រឿងរាំងកាម-
ច្ឆន្ទៈ សេចក្ដីថា នេក្ខម្មៈនោះឈ្មោះថា សីលវិសុទ្ធិ ព្រោះអត្ថថាជា
គ្រឿងហាមកាមច្ឆន្ទៈ នេក្ខម្មៈឈ្មោះថា ចិត្តវិសុទ្ធិ ព្រោះអត្ថថា មិន
រាយមាយ ព្រោះការមិនរាយមាយជាហេតុ ឈ្មោះថា ទិដ្ឋិវិសុទ្ធិ
ព្រោះអត្ថថា ឃើញព្រោះការឃើញជាហេតុ សូម្បីក្នុងបទដ៏សេស
ក៏មានន័យនេះដូចគ្នា ។

បទថា **បដិប្បស្សម្ភេតិ** រមែងរម្ងាប់ សេចក្ដីថា ធម៌មាននេក្ខម្មៈ
ជាដើម ឈ្មោះថា បស្សទ្ធិ ព្រោះព្រះយោគាវចររមែងរម្ងាប់កាមច្ឆន្ទៈ
ជាដើម ដោយនេក្ខម្មៈជាដើម ។ បទថា **បហីនត្តា** គឺ ព្រោះជាហេតុ
ឲ្យលះដោយការប្រហារនោះៗ ។ បទថា **ញាតដ្ឋេន ញាណំ** ឈ្មោះថា
ញាណ ដោយអត្ថថា ដឹង សេចក្ដីថា នេក្ខម្មៈជាដើម ឈ្មោះថា
ញាណ ដោយអត្ថថា ដឹង ដោយអំណាចការពិចារណាឈាន វិបស្សនា
មគ្គ សូម្បីក្នុងបទនេះថា **ទិដ្ឋត្តា ទស្សនំ** ឈ្មោះថា ទស្សនៈ ព្រោះ
អត្ថថា ឃើញ ក៏មានន័យនេះដូចគ្នា ឈ្មោះថា **យោគី** ព្រោះបរិសុទ្ធ
គឺ វិសុទ្ធិ មាននេក្ខម្មៈជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនេក្ខម្មនិទ្ទេស ដូចតទៅនេះ ។ នេក្ខម្មៈ

ឈ្មោះថា និស្សរណៈ (រលាស់ចាកកាម) ព្រោះរលាស់ចាកកាមរាគៈ ព្រោះមិនមានលោភៈ ឈ្មោះថា នេក្ខម្មៈ ព្រោះចេញចាកកាមរាគៈនោះ ។ កាលពោលថា នេក្ខម្មៈជាគ្រឿងរលាស់ចេញនូវរូប ដើម្បីសម្តែងដោយវិសេស ព្រោះមិនសម្តែងសេចក្តីវិសេសរបស់អរូប លោកទើបពោលថា **យទិទំ អារុប្បំ** អរូបឈានរលាស់ចេញនូវរូបតាមលំដាប់ បាឋៈដែលពោលទុកហើយក្នុងទីដទៃនោះឯង ។ ម្យ៉ាងទៀត អរូបឈាននោះ ឈ្មោះថា នេក្ខម្មៈ ព្រោះចេញចាករូប ព្រោះហេតុនោះ គឺ លោកពោលដោយអធិការ ។ បទថា **ភូតំ** វត្ថុដែលកើតហើយ ជាបទសម្តែងដល់ការប្រកបនឹងវត្ថុដែលកើតឡើង ។ បទថា **សង្ខតំ** វត្ថុដែលប្រជុំតាក់តែង ជាបទសម្តែងដល់សេចក្តីវិសេសនៃកម្លាំងបច្ច័យ ។ បទថា **បដិច្ចសមុប្បន្នំ** អាស្រ័យគ្នាកើតឡើង ជាបទសម្តែងដល់ការមិនខ្វល់ខ្វាយនៃបច្ច័យ សូម្បីក្នុងការប្រកបបច្ច័យ ។ បទថា **និរោធោ តស្ស នេក្ខម្មំ** និរោធ ជានេក្ខម្មៈចាកវត្ថុដែលមានដែលកើត គឺ និព្វាន ឈ្មោះថា នេក្ខម្មៈចាកវត្ថុដែលប្រជុំតាក់តែងនោះ ព្រោះចេញចាកវត្ថុដែលប្រជុំតាក់តែងនោះ ការកាន់យកអរូបឈាននិងនិរោធ លោកធ្វើតាមលំដាប់ ដូចពោលហើយក្នុងបាឋៈដទៃ ។ កាលពោលថា ការចេញចាកកាមច្ឆន្ទៈជានេក្ខម្មៈ គឺ លោកពោលដដែលទៀត ។ លោកមិនពោលថា សេចក្តីសម្រេចនៃការចេញចាក



កាមច្ឆន្ទៈ ដោយពាក្យថា នេក្ខម្មៈប៉ុណ្ណោះ ហើយពោលថា នេក្ខម្មៈដ៏សេស ប្រការនោះត្រង់ពិត សូម្បីក្នុងនិស្សរណនិទ្ទេសក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ម្យ៉ាងទៀត ធាតុជាគ្រឿងរលាស់ចេញ ក្នុងនិទ្ទេសនេះ លោកពោលថា ជានេក្ខម្មៈដោយត្រង់តែម្យ៉ាង ។

បទថា **បវិវេកោ** សេចក្តីស្ងាត់ គឺ ស្ងប់ស្ងាត់ជានេក្ខម្មៈជាដើមតែម្យ៉ាង ។ បទថា **វោស្សជ្ជតិ** រមែងលះ គឺ យោគី ។ នេក្ខម្មៈជាដើម ជាការលះ ។ លោកពោលថា ព្រះយោគាវចរប្រព្រឹត្តនេក្ខម្មៈ រមែងប្រព្រឹត្តទៅដោយនេក្ខម្មៈ ។ ម្យ៉ាងទៀត នេក្ខម្មៈនោះ ជាចរិយា សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ គួរនឹងពោលទុកក្នុងឈានវិមោក្ខនិទ្ទេស លោកក៏ពោលទុកក្នុងវិមោក្ខកថា ក្នុងវិមោក្ខកថានោះ លោកពោលថា **ឈានវិមោក្ខោ** រួចផុតព្រោះឈានថា **ជានាតិ** រមែងដឹងតែម្យ៉ាង ។ តែក្នុងឈានវិមោក្ខនិទ្ទេសនេះ មានសេចក្តីប្លែកចេញទៅថា លោកសម្តែងជាបុគ្គលាធិដ្ឋានថា **ជាយតិ** រមែងកើត ។

ម្យ៉ាងទៀត ក្នុងភាវនាធិដ្ឋានជីវិតនិទ្ទេស លោកសម្តែងជាបុគ្គលាធិដ្ឋាន ។ តែតាមធម្មតានេក្ខម្មៈជាដើមនោះឯង ឈ្មោះថា **ភាវនា** ចិត្តដែលតាំងទុកដោយនេក្ខម្មៈជាដើម ឈ្មោះថា **អធិដ្ឋាន** សម្មាអាជីវៈរបស់អ្នកមានចិត្តតាំងទុកដោយនេក្ខម្មៈជាដើម ឈ្មោះថា

**ជីវិត** ។ សម្មាអាជីវៈនោះ តើដូចម្ដេច ការវៀរចាកមិច្ឆាជីវៈ និងព្យាយាមស្វែងរកបច្ច័យដោយធម៌ដែលស្មើ ។

ក្នុងបទទាំងនោះ បទថា **សមំ ជីវតិ** ជាការរស់នៅស្ងប់ គឺមានជីវិតរស់នៅយ៉ាងស្ងប់ អធិប្បាយថា ជាការរស់នៅដោយស្ងប់ ។ បទថា **នោ វិសមំ** មិនជាការរស់នៅមិនស្ងប់ លោកធ្វើជាអវធារណៈ ( ពាក្យបដិសេធ ) ដោយពាក្យបដិសេធសេចក្ដីដែលពោលថា **សមំ ជីវតិ** ជាការរស់នៅស្ងប់ ។ បទថា **សម្មា ជីវតិ** ជាការរស់នៅដោយប្រពៃ ជាបទបង្ហាញអាការ ។ បទថា **នោ មិច្ឆា** មិនជាការរស់នៅខុស គឺ កំណត់ការរស់នៅនោះឯង ។ បទថា **វិសុទ្ធិ ជីវតិ** រស់នៅបរិសុទ្ធិ គឺ មានជីវិតរស់នៅបរិសុទ្ធិ ដោយបរិសុទ្ធិតាមសភាវៈ ។ បទថា **នោ កិលិដ្ឋិ** មិនមែនរស់នៅសៅហ្មងទេ គឺ កំណត់ការរស់នៅនោះឯង ។ ព្រះសារីបុត្តត្ថេរ សម្ដែងអានិសង្សនៃសម្បទា ៣ តាមដែលពោលហើយនៃញាណសម្បត្តិ ដោយបទមានជាអាទិ៍ថា **យញ្ញទេវ** ។ បទថា **យញ្ញទេវ** កាត់បទថា **យំ យំ ឯវ** ។ បទថា **ខត្តិយបរិសំ** គឺ ប្រជុំពួកក្សត្រ ។ លោកពោលថា បរិស័ទ ព្រោះអង្គុយដោយជុំវិញ ៗ មិនត្រូវប្រើការដឹងអ្វីគ្នា ក្នុង ៣ បរិស័ទទៀត ក្រៅអំពីនេះក៏មានន័យនេះដូចគ្នា ការកាន់យកបរិស័ទ ៤ នោះ ព្រោះប្រកបដោយអាគមសម្បត្តិ និងញាណសម្បត្តិរបស់ក្សត្រជាដើម



នោះឯង មិនមែនដោយបរិស័ទរបស់ពួកសូទ្រ ។ បទថា **វិសារទោ** ជាអ្នកក្លាហាន គឺ ដល់ព្រមដោយបញ្ញា ប្រាសចាកសេចក្ដីភ័យខ្លាច គឺ មិនខ្លាច ។ បទថា **អមង្កុតោ** មិនមានអៀនអន់ គឺ មិនញញើតមានការអាចហ៊ាន ។ បទថា **តំ កិស្ស ហេតុ** ប្រការនោះព្រោះហេតុអ្វី បើសួរថា ភាពជាអ្នកក្លាហាននោះ រមែងកើតព្រោះហេតុអ្វី ព្រោះការណ៍អ្វី ពោលដល់ហេតុនៃសេចក្ដីក្លាហាននោះថា **តថា ហិ** ព្រោះជាអ្នកដល់ព្រមដោយសម្បទា ៣ គឺ ភាវនា អធិដ្ឋាន អាជីវៈ ដូច្នោះ ព្រះសារីបុត្តត្ថេរ កាលសម្ដែងដល់ហេតុនៃភាពជាអ្នកក្លាហានថា **វិសា-រទោ ហោតិ** ជាអ្នកក្លាហានហើយ ទើបធ្វើទីបញ្ចប់ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា មាតិកាកថា

នៃអដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះថា សទ្ធម្មប្បកាសិនី

ចប់ការពណ៌នាតាមលំដាប់សេចក្ដីដែលមិនធ្លាប់ពណ៌នានៃចូឡវគ្គ

ចប់អដ្ឋកថាបដិសម្ភិទាមគ្គ ប្រដាប់ដោយកថា ៣០

សង្គ្រោះចុះក្នុង ៣ វគ្គ ដោយហេតុត្រឹមនេះឯង ។

## រួមកថាដែលមានក្នុងបករណ៍បដិសម្ភិទាមគ្គ

## និងអដ្ឋកថា គឺ :

១- ញាណកថា ២- ទិដ្ឋិកថា ៣- អានាបានស្សតិ ៤- ឥន្ទ្រិយកថា
៥- វិមោក្ខកថា ៦- គតិកថា ៧- កម្មកថា ៨- វិបល្លាសកថា
៩- មគ្គកថា ១០- មណ្ឌបេយ្យកថា ។

១- យុគនទ្ធកថា ២- សច្ចកថា ៣- ពោជ្ឈង្គកថា ៤- មេត្តាកថា
៥- វិរាគកថា ៦- បដិសម្ភិទាមគ្គកថា ៧- ធម្មចក្កកថា
៨- លោកុត្តរកថា ៩- ពលកថា ១០- សុញ្ញកថា ។

១- មហាបញ្ញាកថា ២- ឥទ្ធិកថា ៣- អភិសមយកថា ៤- វិវេកកថា
៥- ចរិយាកថា ៦- បាដិហារិយកថា ៧- សមសីសកថា
៨- សតិប្បដ្ឋានកថា ៩- វិបស្សនាកថា ១០- មាតិកាកថា ។

៣ វគ្គក្នុងបករណ៍បដិសម្ភិទា មានអត្ថទូលំទូលាយជ្រាលជ្រៅ
ក្នុងមគ្គជាអនន្តន័យ ប្រៀបដូចសាគរ ដូចនភាកាសពាសពេញ
ដោយដួងតារា និងដូចស្រះធំ

សេចក្ដីក្ដីស្វាងនៃញាណរបស់ព្រះយោគីទាំងឡាយរមែង
មានបានដោយភាពក្ដីស្វាងនៃគណៈព្រះធម្មកថិកាចារ្យដូច្នេះឯង ។
ចប់អដ្ឋកថាបដិសម្ភិទាដោយប្រការដូច្នេះ



## និគមកថា

ក្នុងបដិសម្ភិទាមគ្គនេះ ព្រះសារីបុត្តត្ថេរពោលទុក ៣ វគ្គ តាមលំដាប់នៃខ្នាតដោយឈ្មោះថា មហាវគ្គ មជ្ឈិមវគ្គ និងចុល្លវគ្គ ។ ក្នុងវគ្គមួយ ៗ លោកសម្ដែងទុកវគ្គមួយ ៗ ១០ កថា ការពណ៌នាឧទាន កថាទាំងនេះ លោកសម្ដែង តាមលំដាប់នៃកថាទាំងនោះ ។

+ កថាទាំងនេះមាន ១០ គឺ ញាណកថា ១ ទិដ្ឋិកថា ១ អានាបានកថា ១ ឥន្ទ្រិយកថា ១ វិមោក្ខកថា ១ គតិកថា ១ កម្មកថា ១ វិបល្លាសកថា ១ មគ្គកថា ១ មណ្ឌបេយ្យ-កថា ១ រួមជា ១០ កថា ។

+ កថាតទៅនេះ គឺ យុគនទ្ធកថា ១ សច្ចកថា ១ ពោជ្ឈង្គកថា ១ មេត្តាកថា ១ វិរាគកថា ១ បដិសម្ភិទាមគ្គកថា ១ ធម្មចក្កកថា ១ លោកុត្តរកថា ១ ពលកថា ១ សុញ្ញកថា ១ ។

+ មហាបញ្ញាកថា ១ ឥទ្ធិកថា ១ អភិសមយកថា ១ វិវេកកថា ១ ចរិយាកថា ១ បាដិហារិយកថា ១ សមសីសកថា ១ សតិប្ប-ដ្ឋានកថា ១ វិបស្សនាកថា ១ មាតិកាកថា ១ ។

ព្រះថេរៈ អ្នកជាធំជាងព្រះសាវ័កដែលស្តាប់មកអំពីព្រះសុគត អ្នកត្រេកអរក្នុងការធ្វើប្រយោជន៍ដល់សត្វ អ្នកមានគុណដ៏មាំទាំ ពោលបដិសម្ភិទាណាទុកហើយ អដ្ឋកថាបដិសម្ភិទាមគ្គនោះ ខ្ញុំម្ចាស់ផ្តើមរចនាព្រោះអាស្រ័យន័យរបស់អដ្ឋកថាមុន ៗ ជាចំណុចយុតិយ៉ាងនោះ អដ្ឋកថានោះ ទើបដល់សេចក្តីសម្រេចបានដោយប្រការដូច្នេះ ។

លោកអ្នកមានបញ្ញាក្រៃលែង ជាអ្នកប្រកបដោយគុណ គឺបញ្ញាប្រកបដោយសទ្ធា បានធ្វើគុណ និងសេចក្តីល្អទុកមិនតិច ក្នុងបរិវេណមហាវិហារ ព្រះថេរៈអ្នកអាស្រ័យនៅក្នុងវិហារនេះ មានឈ្មោះប្រាកដហើយថា **មោគ្គលាន** ក្នុងវស្សទី ៣ បានឃ្លាតទៅហើយ អដ្ឋកថាអនុលោមតាមសម័យ ញ៉ាំងប្រយោជន៍ឲ្យកើតដល់លោក បានសម្រេច ព្រោះអាស្រ័យព្រះថេរៈអ្នកសម្តែងថេរវាទ សេចក្តីអដ្ឋកថាអនុលោមតាមធម៌ដែលឲ្យសម្រេចប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ជាទីជ្រះថ្លារបស់សព្វសត្វ ចូរដល់សេចក្តីសម្រេច ដូចយ៉ាងនោះចុះ ។

ចំណែកភាណវារៈ ៥៨ ភាណវារៈ ដែលគួរដឹងច្បាស់ បណ្ឌិតអ្នកឆ្លាតក្នុងចំនួនពាក្យ បានរចនាទុកក្នុងអដ្ឋកថាសទ្ធម្មប្បកាសិនីនេះ ភាណវារៈចំនួន ១៤.០០០ និងគាថា ៥០០ គាថា លោកពោលពាក្យ



ចំនួន ដោយការប្រព័ន្ធជាធនុៈនៃអដ្ឋកថាសទ្ធម្មប្បកាសិនីនោះ យ៉ាងហ្មត់ចត់ ។

ខ្ញុំម្ចាស់អ្នកអើពើដើម្បីឲ្យសាសនាតាំងនៅយូរ និងដើម្បីប្រយោជន៍ទំនុងបម្រុងដល់លោក បានសន្សំបុណ្យនេះ ដល់ការសម្បូណ៌មានតិច សូមលោកចូរបរិភោគរសនៃព្រះសទ្ធម្ម ដែលប្រាសចាកមន្ទិលនៃព្រះទសពលដោយបុណ្យនោះ ដល់សេចក្តីសុខ ដោយសេចក្តីសុខពិតប្រាកដហោង ។

## ចប់

## អដ្ឋកថា គម្ពីរបដិសម្ភិទាមគ្គ
## ឈ្មោះ សទ្ធម្មប្បកាសិនី

# ប្រជុំកថធម៌
# ក្នុងគម្ពីរអដ្ឋកថាបដិសម្ភិទាមគ្គ


| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| បុថុជ្ជន | ២ | ២៨ |
| វិន័យ | ២ | ៣១ |
| ការប្រាសចាកតម្រេក | ២ | ១៦៧ |
| លះបង់សេចក្ដីងងឹត | ២ | ១៦៨ |
| អរិយបុគ្គល | ២ | ៣៤២ |
| ធម្មចក្ក | ២ | ៥០២ |
| តថាគតពលៈ | ២ | ៥២៧ |
| បដិវេធញ្ញាណ | ២ | ៥៣៣ |
| ទេសនាញាណ | ២ | ៥៣៣ |
| កាយកម្ម | ៣ | ២០ |
| សមថៈ | ៣ | ២១១ |
| វិវេក | ៣ | ៥២៥ |
| ពាលលក្ខណៈ | ៣ | ៥៥៩ |
| បណ្ឌិតលក្ខណៈ | ៣ | ៥៦០ |
| សង្ខតលក្ខណៈ | ៣ | ៥៦០ |
| មហាភូតរូប | ៤ | ១៩៤ |
| សោតាបត្តិយង្គៈ | ៤ | ២៦៤ |
| វិសញ្ញោគៈ | ៤ | ២៩២ |
| សញ្ញោគៈ | ៤ | ២៩២ |
| កម្ម | ៤ | ៣៧៤ |





| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| កម្មម្យ៉ាងទៀត | ៤ | ៣៧៥ |
| សំវរវិន័យ | ៥ | ៣១ |
| បហានវិន័យ | ៥ | ៣១ |
| សទ្ធិ | ៥ | ១៤៧ |
| មគ្គបានឈ្មោះដោយហេតុ | ៥ | ២៩៨ |
| បីតិ | ៥ | ៤១៧ |
| បញ្ចវគ្គិយ៍ | ៥ | ៤៨៣ |
| វិវេក | ៥ | ៥២៥ |
| បុគ្គលអ្នកមានបុណ្យច្រើន | ៥ | ៦៩៧ |
| ពូជ | ៥ | ៧១១ |
| ភគវា ព្រោះហេតុ | ៦ | ២៣៤ |
| ទោសនៃការអង្គុយ | ៦ | ៥៤៧ |
| អភិញ្ញា | ៦ | ៥៧៦ |
| សង្វេគវត្ថុ | ៨ | ២៨៨ |
| មហាវិបស្សនា | ៨ | ២៩០ |
| បរិស័ទ | ៨ | ៥៣១ |
| សមយ សព្ទ ប្រាកក្នុងអត្ថ | ៩ | ២៣១ |
| វិបស្សនាញាណ | ៩ | ៣៤៧ |
| លោកុត្តរធម៌ | ៩ | ៥១៤ |
| ត្រកូលដ៏រី | ១០ | ៥២៧ |
| ឯកាយនមគ្គ មានឈ្មោះ | ១១ | ១២៧ |
| ឧបាទាយរូប | ២៤ | ១៩៤ |
| ពោធិបក្ខិយធម៌ | ៣៧ | ៣៩៥ |
| លោកុត្តរធម៌ | ៤៦ | ៥១៤ |

# នាមសប្បុរស បូជាធម្មទាន

## ពុទ្ធបរិស័ទក្នុងប្រទេស

| | |
|---|---|
| ឧបាសក សោម រតនៈ និងភរិយា ព្រមទាំងបុត្ត ( ព្រៃវែង) | 100 $ U.S.A |
| ឧបាសិកា ពូ ហ៊ាង ( បាត់ដំបង) ............................ | 100 $ U.S.A |
| ឧបាសក ជា ស៊ីបាន ( ភ្នំពេញ) ............................ | 50 $ U.S.A |
| | និងម៉ាស៊ីនព្រីនធ័រ.១ គ្រឿង |

## ភិក្ខុ-សាមណេរវត្តស្នាពីមុខ

| | |
|---|---|
| ភិក្ខុ ហិម សុខា ................................................ | ២៧.000៛ |
| សាមណេរ ថៃ ថី ............................................ | ១០.000៛ |
| សាមណេរ ជា ទីណា ( វត្តព្រៃក្រូច ) .................. | ១០.000៛ |
| សាមណេរ គី រិទ្ធ ............................................ | ៧.000៛ |
| សាមណេរ ធី ចាន់ថា ....................................... | ៥.000៛ |
| សាមណេរ ឈាង ហ៊ ....................................... | ៥.000៛ |
| ឧបាសក ហាយ ចំរើន ( បាត់ដំបង) ..................... | ១០.000៛ |
| ឧបាសក ហុក ស៊ីងហួត ( បាត់ដំបង) ................... | ១០.000៛ |
| ឧបាសក អ៊ឹម រ៉ៃយ៉ា ( បាត់ដំបង) ...................... | ១០.000៛ |
| ឧបាសក សន ម៉ារឌី ( បាត់ដំបង) ....................... | ១០.000៛ |
| ឧបាសក ទំ ទូន ( បាត់ដំបង) ............................ | ១០.000៛ |

## អ្នកភូមិស្វរអើ-ក្តុលដូនទាវ

| | |
|---|---|
| អ្នកគ្រូ ពេជ្រ សុវណ្ណារ័ត្ន ស្វាមី និងបុត្រ .............. | 10 $ និង ១០.000៛ |
| កញ្ញា ប៊ុន ពេជ្រ ............................................ | 10 $ |
| ឧបាសិកា ខាត់ ផាន់លី និងបុត្ត .......................... | 9 $ និង ១០.000៛ |
| ឧបាសិកា ជា សុខចេង ស្វាមី និងបុត្ត ................. | 5 $ |
| ឧបាសិកា មាស ទូច ...................................... | 1 $ |
| អ្នកស្រី មេត ម៉ាលីកា និងស្វាមី ........................<br>កញ្ញា មេត សាមឿន ....................................<br>កញ្ញា មេត ចន្ទណា ...................................... | ២០.000៛ |



| | |
|---|---|
| លោកគ្រូ រស់ ប៊ុនហ៊ី និងសិស្សវិទ្យាល័យឯកភ្នំ .... | ១០.000៛ |
| ឧបាសិកា ពិន សារ៉ូន .................................... | ១០.000៛ |
| ឧបាសិកា នុត សឿន និងបុត្ត .......................... | ១០.000៛ |

## ពុទ្ធបរិស័ទអូស្ត្រាលី តាមរយៈ ព្រះអគ្គទិន្នោ ភិក្ខុ នៅ បូរ៉ា

| | |
|---|---|
| លោក ដុង ឡេង និងអ្នកស្រី .......................... | 100 $ AUS |
| ឧបាសក សេង លី ឧបាសិកា ចាន់ ផល្លា ............ | 100 $ AUS |
| ឧបាសក នូ សុរ៉ាវុធ និងភរិយា ......................... | 50 $ AUS |
| ឧបាសក រិន ក្រេត និងភរិយា ......................... | 50 $ AUS |
| ឧបាសក លឹម ហុងលី ឧបាសិកា តេង គី ........... | 50 $ AUS |
| ឧបាសក ង៉ូវ ឈីវ ឧបាសិកា ហេង ពាស៊ីម និងបុត្ត ៤ នាក់ | 50 $ AUS |
| ឧបាសក ទូត សឿប ឧបាសិកា សល់ កែវ........... | 50 $ AUS |
| ឧបាសក សឹម តាដួន .................................... | 20 $ AUS |
| ឧបាសក ជួន យ៉ារ៉ន ឧបាសិកា អ៊ិន ផល្លី ............ | 20 $ AUS |
| ឧបាសក ភុន ញ៉ាន ....................................... | 20 $ AUS |
| លោក SO KON និងអ្នកស្រី HUn ................ | 20 $ AUS |
| ឧបាសក ហ៊ាង ម៉ុន ...................................... | 20 $ AUS |
| លោក RRUN SRANN និងអ្នកស្រី RANY KAO | 20 $ AUS |
| លោក PHEAP KAO ................................ | 10 $ AUS |
| លោក SOU SOPHON ............................ | 10 $ AUS |
| លោក THEAR ROS ................................ | 10 $ AUS |
| ឧបាសក ប៊ុន ដេត ឧបាសិកា ម៉ាច និងបុត្ត ........ | 10 $ AUS |
| លោក SOKEN និងអ្នកស្រី SEYLA ............ | 10 $ AUS |
| ឧបាសក ផៃ មន្ទីកៅ ................................ | 10 $ AUS |
| ឧបាសក ពៅ វ៉ាន់ទីន ................................. | 10 $ AUS |
| លោក Chouy Sannykao ......................... | 10 $ AUS |

| | |
|---|---|
| ឧបាសក ស៊ុន គិមឆេង ................................. | 10 $ AUS |
| លោក KIM YEE ...................................... | 5 $ AUS |
| ឧបាសក ឆាយ ឈួយលិម ហៅ មិត ឆិម .......... | 5 $ AUS |

**ពុទ្ធបរិស័ទវត្តត្រៃរតនារាម សហរដ្ឋអាមេរិក**

**តាមរយៈ ព្រះភិក្ខុ ធម្មត្ថេរោ សៅ ឃួន ព្រះភិក្ខុធម្មប្បញ្ញោ ផុំ សារឿន**

| | |
|---|---|
| ព្រះភិក្ខុ ធម្មត្ថេរោ សៅ ឃួន ............................. | 300 $ U.S.A |
| ព្រះភិក្ខុ កិត្តិកធម្មោ ប៊ូ សាំយ៉ុន ........................... | 50 $ U.S.A |
| ឧបាសិកា ទូន សឿយ ........................................ | 50 $ U.S.A |
| ឧបាសិកា ឈួន ផៃ ........................................... | 30 $ U.S.A |
| ឧបាសិកា ប្រាក់ យឿត ...................................... | 30 $ U.S.A |
| ឧបាសិកា អុក ណៃ ........................................... | 30 $ U.S.A |
| ឧបាសក អួន មិត្ត ឧបាសិកា នាក់ ប្រិម ................. | 25 $ U.S.A |
| ឧបាសិកា ចាប ឡាន ........................................ | 25 $ U.S.A |
| ឧបាសក សាន សុទ្ធ ឧបាសិកា យស់ សារី ................ | 20 $ U.S.A |
| លោកអាចារ្យ កង កាក់ ឧបាសិកា ទឹម សារី ........... | 20 $ U.S.A |
| ឧបាសិកា សរ គឹម ............................................. | 20 $ U.S.A |
| ឧបាសក លឹម សេងហ៊ួ ........................................ | 20 $ U.S.A |
| ឧបាសិកា កែវ ស៊ីណាត ....................................... | 20 $ U.S.A |
| ឧបាសក គាំ សាមុត .......................................... | 20 $ U.S.A |
| វ៉ា ស៊ីម៉ន ........................................................ | 20 $ U.S.A |
| អេម អែម និង អ៊ែល អ៊ុន .................................. | 20 $ U.S.A |
| ឧបាសក ឃុន ខេន ......................................... | 20 $ U.S.A |
| ឧបាសក ម៉ៅ សារី ឧបាសិកា ឯក ផេន និងបុត្ត ...... | 20 $ U.S.A |
| ឧបាសិកា អ៊ុំ សឿន ឧបាសិកា សែម អ៊ុំ ................ | 20 $ U.S.A |
| ផូ លាង និង សុខ ខេន ..................................... | 20 $ U.S.A |
| នាង ឡាយ សុវណ្ណ .......................................... | 20 $ U.S.A |
| ឃុត នីកង ..................................................... | 20 $ U.S.A |



| | |
|---|---|
| ទឹម សុជាតិ .................................................. | 20 $ U.S.A |
| ឧបាសិកា ជួប ប៉ាក់ ........................................ | 15 $ U.S.A |
| ជាស់ ស៊ីន .................................................... | 10 $ U.S.A |
| អ៊ិស ស៊ីន .................................................... | 10 $ U.S.A |
| សារុន ម៉ន .................................................... | 10 $ U.S.A |
| មឿង ម៉ៅ ..................................................... | 10 $ U.S.A |
| មាន ណាត .................................................... | 10 $ U.S.A |
| គិម លាងជា .................................................. | 10 $ U.S.A |
| វី យ៉ាត ........................................................ | 10 $ U.S.A |
| ឧបាសិកា ចិន ឈួន ......................................... | 10 $ U.S.A |
| គង់ថៃ ប៊ុនរឿង ............................................... | 10 $ U.S.A |
| ឧបាសិកា ឡឹក រេត ........................................ | 10 $ U.S.A |
| ព្រហ្ម សារិន .................................................. | 10 $ U.S.A |
| ព្រហ្ម វ៉ារុធ ................................................... | 10 $ U.S.A |
| វ៉ារិត អួន ..................................................... | 10 $ U.S.A |
| ឌិកូឡូ ជីរ៉ូខាយ ............................................. | 10 $ U.S.A |
| អាន ណាង ............................................. | 10 $ U.S.A |
| សយស ាម៉ុន និងបុត្ត ....................................... | 10 $ U.S.A |
| ចិន្តា អឿវ និង ចក់ ណាហួត ............................. | 10 $ U.S.A |
| សែង ឈឹម និង ហួត ចាន់នួន ........................... | 10 $ U.S.A |
| ហួត ចាន់ណាត និង ឈឿង សុភាព ..................... | 10 $ U.S.A |
| វិន ឡៃ ......................................................... | 10 $ U.S.A |
| ទឹម ស៊ីនួន ..................................................... | 10 $ U.S.A |
| ឈី ជិម ....................................................... | 10 $ U.S.A |
| ឡេង ដា ...................................................... | 10 $ U.S.A |
| ឌី ណាញឹប .................................................... | 10 $ U.S.A |
| ញឹប ហុង ..................................................... | 10 $ U.S.A |
| នី សាញឹប ..................................................... | 10 $ U.S.A |

| | |
|---|---|
| ឧបាសិកា ញ៉ឹប ទាង | 10 $ U.S.A |
| ឧបាសិកា អ៊ឹម លឹម | 10 $ U.S.A |
| ឧបាសិកា ខាត់ សំអឿន | 10 $ U.S.A |
| ម៉ៅ ចំបើង | 10 $ U.S.A |
| ម៉ៅ វ៉ាត | 10 $ U.S.A |
| ម៉ៅ កំសត់ | 10 $ U.S.A |
| ម៉ៅ កំសាន្ត | 10 $ U.S.A |
| ម៉ៅ សុខា | 10 $ U.S.A |
| ម៉ៅ គឹមសុង | 10 $ U.S.A |
| លោកយាយ ភួង សឿន | 5 $ U.S.A |
| សែម ម៉ីញ៉ឹប | 5 $ U.S.A |
| ឧបាសិកា មឿង ញ៉ិល | 5 $ U.S.A |
| គីម ស៊ា | 5 $ U.S.A |

**ពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ រដ្ឋមាសាជូសេត សហរដ្ឋអាមេរិក**

**តាមរយៈ  ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន**

| | |
|---|---|
| ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន | 120 $ U.S.A |
| ឧបាសិកា ពិន សាត | 100 $ U.S.A |
| ឧបាសក ចាន់ ម៉ុល ឧបាសិកា ជា សុផា | 100 $ U.S.A |
| ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | 100 $ U.S.A |
| កែម សុធា និង មាស ចំណាន | 100 $ U.S.A |
| ឧបាសិកា ម៉ៅ លន់ ព្រមទាំងបុត្ត | 100 $ U.S.A |
| ឧបាសិកា គីម កក់ និងម្តាយ ស្រេន ង៉ោ | 100 $ U.S.A |
| ព្រះភិក្ខុ ឈួម បូ និងឧបាសិកា ជី | 50 $ U.S.A |
| ជា សុផល និង សុំ ឆៃយ៉ាន | 50 $ U.S.A |
| កែម សុធា និង មាស ចំណាន | 50 $ U.S.A |
| ឧបាសក ឡាង ឆវី ឧបាសិកា កុក សា វ៉ាង | 50 $ U.S.A |
| ឧបាសក កាន គង់ ឧបាសិកា ជី វ៉ូម | 50 $ U.S.A |



| | |
|---|---|
| ឧបាសិកា ដុះ ឡឿម | 50 $ U.S.A |
| ឧបាសិកា កែវ សារិន ឧបាសិកា សុំ អែម និងបុត្ត | 50 $ U.S.A |
| កៅ ចាន់ស៊ូសាណា | 50 $ U.S.A |
| ជា សុភ័ណ និង ម៉ាប់ | 40 $ U.S.A |
| ជា សុភី និង សារិន ណៃ | 30 $ U.S.A |
| នាង លីន ពិសី | 30 $ U.S.A |
| ឧបាសក យុន ឈួរ ឧបាសិកា ម៉ូវ ឈាវក្លួយ | 30 $ U.S.A |
| ឧបាសក ចាន់ សួន ឧបាសិកា តែង អន | 30 $ U.S.A |
| ឧបាសិកា ហៀ ណន | 20 $ U.S.A |
| ឧបាសិកា ចាំង យុនថេង និងបុត្ត | 20 $ U.S.A |
| ឡាច ម៉ាឡៃ | 20 $ U.S.A |
| ព្រំ ហោ | 20 $ U.S.A |
| ឧបាសិកា នួន សូនី | 20 $ U.S.A |
| ឧបាសិកា កាង លាង | 20 $ U.S.A |
| ឧបាសិកា សាយ ហេង | 20 $ U.S.A |
| តាំង ហួយ និង ស្រីមុំ | 20 $ U.S.A |
| ឧបាសិកា ប៉ៃ លិន | 20 $ U.S.A |
| មុត សំអុល ព្រមទាំងកូនចៅ | 15 $ U.S.A |
| ឧបាសិកា ប៊ុន សារុំ | 15 $ U.S.A |
| ឧបាសក គង លេង ភរិយា និងបុត្ត | 10 $ U.S.A |
| ឧបាសក កែវ ណន និងភរិយា ព្រមទាំងបុត្ត | 10 $ U.S.A |
| ឧបាសិកា ណាំ | 10 $ U.S.A |
| អ៊ុំ បូរិន | 10 $ U.S.A |
| អ៊ុំ បូនី | 10 $ U.S.A |
| ជឹម ណយ | 10 $ U.S.A |
| ឧបាសិកា តាន់ សៀ | 10 $ U.S.A |
| និត ភាព និងស្វាមី ព្រមទាងបុត្ត | 10 $ U.S.A |

| | |
|---|---|
| សា ឆៃហេង និងភរិយា ម៉ុង ដណេ និងកូនស្រី ........... | 10 $ U.S.A |
| ចូត គង់ ព្រមទាំងគ្រួសារ និងបុត្ត ............................ | 10 $ U.S.A |
| ច្រឹម ........................................................... | 10 $ U.S.A |
| មឹង លាភ ......................................................... | 5 $ U.S.A |
| ប៊ុន ណ្ណារី ......................................................... | 5 $ U.S.A |
| លីន នី ............................................................. | 5 $ U.S.A |
| បេ រ៉ូចម៉េង ...................................................... | 5 $ U.S.A |
| ម៉ន លីណា ........................................................ | 5 $ U.S.A |
| សុគីន ............................................................... | 5 $ U.S.A |
| រ៉ុន ឆា .............................................................. | 5 $ U.S.A |
| កាន់ ណាល ....................................................... | 5 $ U.S.A |
| ជុំ ម៉ាឡា .......................................................... | 5 $ U.S.A |
| សារឿត សរិត .................................................... | 5 $ U.S.A |
| ឧបាសិកា អាង ណារី ......................................... | 5 $ U.S.A |
| ឧបាសិកា ជា ហុង ............................................. | 5 $ U.S.A |
| ឧបាសិកា ទូត ចាន់វណ្ណី ........................................ | 5 $ U.S.A |
| ឧបាសិកា ជំនិត .................................................. | 5 $ U.S.A |
| ជុំ ចានថា .................................................... | 5 $ U.S.A |
| លីនដា ....................................................... | 5 $ U.S.A |
| មឹង ឃីម ......................................................... | 2 $ U.S.A |
| គីម ហួ ............................................................. | 2 $ U.S.A |
| សថា ............................................................... | 2 $ U.S.A |
| វណ្ណា ............................................................... | 2 $ U.S.A |
| ហ៊ុន ថា ............................................................ | 2 $ U.S.A |
| ស៊ីមឿង .......................................................... | 2 $ U.S.A |